នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៨

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Sept-2018, 08:00
CMS/CFO: Sann Rada

<u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ

<u>ដាក់ដោយ៖</u>

សហមេធាវី៖

អាង ឧត្តម

Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

សហចៅក្រមស៊ើបអង្កេត៖

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

សហព្រះរាជអាជ្ញា៖

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់

មាតិកា

I. ទិដ្ឋភាពទូទៅ ១

II. បញ្ហាពាក់ព័ន្ធនឹងការសម្រេចសេចក្តី ៥

ក. ស.ច.ស. ចាំបាច់ត្រូវតែផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ នៅក្នុងរឿងក្តី ០០៣ ពីព្រោះ មាស មុត នឹងមិនអាចទទួលបានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ បើគិតពីវិបត្តិថវិកា ៥

ខ. ក្តីបារម្ភរបស់ ស.ច.ស. ក្នុងការសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី ៩

គ. ការិយាល័យរដ្ឋបាល អ.ស.ប. ប្រទេសផ្តល់ជំនួយ និង ប្រសិតពិសេសអគ្គលេខាធិការ អ.ស.ប. មិនបានឆ្លើយតបចំពោះការព្រួយបារម្ភ របស់ ស.ច.ស. ១១

ឃ. ស.ច.ស. បានពន្យារពេល ចេញសេចក្តីសម្រេចលើបញ្ហាថាតើត្រូវផ្អាកកិច្ចដំណើរការនីតិវិធីដែរឬយ៉ាងណា ដោយរង់ចាំការវិវឌ្ឍន៍បន្តទៀត ១៣

ង. ថវិកាដែលបានគ្រោង នឹងមិនបំពេញបានតាមតម្រូវការរបស់ អ.វ.ត.ក. ទេ ហើយមិនមានការធានាឱ្យមានការគោរពតាមអាប់រហ័ស និង គួរឱ្យជឿជាក់បានពីសំណាក់ប្រទេសផ្តល់ជំនួយ ១៨

ច. មិនមានផែនការចក្ខុវិស័យបុរេសកម្ម ដែលពិចារណាលើលទ្ធភាពដែលថា រឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/២ អាចត្រូវបានជំនុំជម្រះនៅសវនាការ ២៦

ឆ. ទាំង អ.វ.ត.ក ទាំង UNAKRT មិនអាចធានាថា កិច្ចដំណើរការនីតិវិធីនឹងមានយុត្តិធម៌ ដោយសារវិបត្តិហិរញ្ញវត្ថុ ប្រសិនបើ ស.ច.ស. ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ៣៨

ជ. មានតែការផ្អាកកិច្ចដំណើរការនីតិវិធីរឿងក្តី ០០៣ ទាំងស្រុងជាអចិន្ត្រៃយ៍ទេ ទើបធានាបាននូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត ៤៥

III. ចប់ ៤៧

ក. កត្តាសម្រាប់ការវាយតម្លៃលើយុត្តាធិការបុគ្គល ៤៧

១. ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ៥១

២. គោលការណ៍វិមតិសង្ស័យ នឹងបានជាប្រយោជន៍ដល់ជនត្រូវចោទ និង ការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត ៥៣

៣. តួនាទីផ្លូវការរបស់ជនត្រូវចោទ នៅក្នុងឋានានុក្រម និង កម្រិតដែលគាត់អាចធ្វើការសម្រេចលើគោលនយោបាយរបស់ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយនេះ ៥៣

៤. ស្ថានទម្ងន់ប្រហាក់ប្រហែលនៃអំពើរបស់ជនត្រូវចោទ និង ផលប៉ះពាល់នៃអំពើនោះ គឺអាស្រ័យទៅតាមចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ក្នុងការកម្រិតព្រំដែនយុត្តាធិការ

របស់ អ.វ.ត.ក. ឱ្យនៅត្រឹមបុគ្គលណាដែលមានការទទួលខុសត្រូវធំបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ៥៤

៥. សេចក្តីសន្និដ្ឋាន ៥៥

ខ. បទដ្ឋានបង្ហាញភស្តុតាង សម្រាប់ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ៥៥

១. បទដ្ឋានបង្ហាញភស្តុតាងជាធរមាន គួរតែជាបទដ្ឋានដែលថា តើអង្គជំនុំជម្រះសាលាដំបូងដែលមានហេតុផលអាចផ្តន្ទាទោសជនត្រូវចោទ ឱ្យហួសពីវិមាត្រសង្ស័យដែរឬយ៉ាងណា ដោយផ្អែកលើភស្តុតាងនៅក្នុងសំណុំរឿង ៥៨

២. បទដ្ឋានបញ្ជាក់លើការបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់ដោយ ស.ព.អ. និង បទដ្ឋានរបស់តុលាការ និង សាលាក្តីអន្តរជាតិដទៃទៀត គឺមិនសមស្របឡើយសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក. ៦៤

ក. បទដ្ឋានបញ្ជាក់របស់តុលាការ ICC គឺខ្ពស់ជាងបទដ្ឋានភាពនីយភាព ប៉ុន្តែ មានលក្ខណៈមិនសមស្រប សម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក. ៦៤

ខ. បទដ្ឋានបញ្ជាក់របស់សាលាក្តី ICTY និង សាលាក្តី ICTR គឺទាបជាងបទដ្ឋានភាពនីយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក. ៦៧

គ. បទដ្ឋានបញ្ជាក់របស់តុលាការ SCSL គឺទាបជាងបទដ្ឋានភាពនីយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក. ៦៩

ឃ. បទដ្ឋានបញ្ជាក់របស់សាលាក្តី STL គឺទាបជាងបទដ្ឋានភាពនីយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក. ៧០

ង. បទដ្ឋានបញ្ជាក់របស់តុលាការ KSC គឺទាបជាងបទដ្ឋានភាពនីយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក. ៧១

៣. សេចក្តីសន្និដ្ឋាន ៧២

គ. ឧក្រិដ្ឋកម្ម និង ទម្រង់នៃការទទួលខុសត្រូវជាធរមាន ៧៣

១. អ.វ.ត.ក. មិនមានយុត្តាធិការ ដើម្បីជំនុំជម្រះលើឧក្រិដ្ឋកម្មជាតិ ៧៥

២. ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនអាចអនុវត្តបាននៅ អ.វ.ត.ក. ឬ ជាជម្រើសមួយផ្សេងទៀត ប្រសិនបើអាចអនុវត្តបាន ក៏មិនអាចអនុវត្តចំពោះឧក្រិដ្ឋកម្ម ដែលមានចេតនាជាក់លាក់ ឬ ចំពោះឧក្រិដ្ឋកម្មដែលមិនជាប់ទាក់ទង ជាមួយជម្លោះប្រដាប់អាវុធជាអន្តរជាតិដែរ ៧៨

៣. សហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ មិនអាចអនុវត្តបាននៅ អ.វ.ត.ក. ៨១

៤. អ.វ.ត.ក. មិនមានយុត្តាធិការ ដើម្បីជំនុំជម្រះអំពើរំលោភបំពានធ្ងន់ធ្ងរ ៨៦

៥. អ.វ.ត.ក. មិនមានយុត្តាធិការក្នុងការជំនុំជម្រះលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ដទៃទៀត ៩០

៦. ការវាយប្រហារដោយរដ្ឋ ឬ អង្គការ ទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន មិនមែនជាការវាយប្រហារសំដៅប្រឆាំង "ប្រជាជនស៊ីវិល" ៩២

ឃ. គោលការណ៍ទូទៅនៃភស្តុតាង ៩៦

១. គោលការណ៍គ្រប់គ្រង លើការវាយតម្លៃភស្តុតាង ៩៦

២. ភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម ឬ ភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម គឺមិនអាចពឹងផ្អែកបាន ១០០

ក. កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលកើតចេញពីចម្លើយសារភាពទទួលបាន ដោយការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ឬ ទទួលបានដោយការប្រើប្រាស់ប្រវត្តិរូបដែលទទួលបាន ដោយការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ធ្វើជាតម្រុយនៃកិច្ចស៊ើបអង្កេត គឺមិនអាចយកមកធ្វើជាមូលដ្ឋាន ១០១

ខ. ចម្លើយសារភាពនៅមន្ទីរស-២១ មិនអាចត្រូវបានយកមកធ្វើជាមូលដ្ឋាន ដើម្បីកំណត់ពីអង្គហេតុផ្សេងទៀត ក្រៅពីការពិតនៃខ្លឹមសាររបស់ចម្លើយសារភាព ១០៩

IV. មាស មុត មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ហើយក៏មិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ១១៥

ក. មាស មុត មិនមែនជាមេដឹកនាំជាន់ខ្ពស់ នៅក្នុង ប.ក.ក. ឬ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ១១៨

១. មាស មុត មិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ១១៩

២. មាស មុត មិនធ្លាប់ជាសមាជិកគណៈកម្មាធិការមជ្ឈិម ១២៣

៣. មាស មុត មិនធ្លាប់ជាអនុលេខានៃអគ្គសេនាធិការ ឬ ជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ ១៣១

ក. មាស មុត មិនធ្លាប់ជាអនុលេខានៃអគ្គសេនាធិការ ឬ សមាជិកគណៈកម្មាធិការអគ្គសេនាធិការ ទាំងតាមផ្លូវច្បាប់ (de jure) និង ការអនុវត្តជាក់ស្តែង (de facto) ១៣១

ខ. ការទទួលខុសត្រូវរបស់ មាស មុត ចំពោះអគ្គសេនាធិការ មិនមានការផ្លាស់ប្តូរខ្លាំងឡើយ នៅក្នុងឆ្នាំ ១៩៧៨ ..... ១៤៨

គ. សេចក្តីសន្និដ្ឋាន ១៥៥

៤. បើទោះបីជា មាស មុត បានបញ្ជាកងពលធំលេខ ៣ និង ក្រោយមកបញ្ជាកងពលធំលេខ ១៦៤ និង កងទ័ពជើងទឹកក៏ដោយ ក៏មុខដំណែងទាំងនេះ មិនធ្វើឱ្យគាត់ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ដែរ ១៥៥

ក. កងពលធំលេខ ៣ ស្ថិតក្រោមសិទ្ធិអំណាចរបស់ តា ម៉ុក ដែលជាលេខាភូមិភាគនិរតី.... ១៥៦

ខ. កងពលធំលេខ ១៦៤ ស្ថិតក្រោមអំណាចរបស់អគ្គសេនាធិការ និងគណៈកម្មាធិការអចិន្ត្រៃយ៍ ១៥៧

គ. ទំហំ និង រចនាសម្ព័ន្ធរបស់កងពលធំលេខ ១៦៤ មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ១៦៣

ឃ. កងពលធំលេខ ១៦៤ បានប្រតិបត្តិការនៅក្នុងតំបន់មានកម្រិតកំណត់នៃរបបកម្ពុជាប្រជាធិបតេយ្យ ១៦៨

ង. សេចក្តីសន្និដ្ឋាន ១៧២

៥. មាស មុត មិនមែនជាលេខាតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងគណៈកម្មាធិការតំបន់ស្វយ័តកំពង់សោមឡើយ ហើយបើទោះបីជាគាត់មានមុខដំណែងទាំងនេះក្តី ក៏វាមិនអាចធ្វើឱ្យគាត់ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ដែរ ១៧២

ក. មាស មុត មិនមែនជាលេខាតំបន់ស្វយ័តកំពង់សោម ១៧៣

ខ. មាស មុត មិនមែនជាសមាជិកខ្ពស់បំផុត នៃគណៈកម្មាធិការតំបន់ស្វយ័តកំពង់សោម.. ១៨៣

គ. បើទោះបីជា មាស មុត ជាលេខាតំបន់ស្វយ័តកំពង់សោម ឬ ជាសមាជិកគណៈកម្មាធិការតំបន់ស្វយ័តក្តី ក៏តំបន់ស្វយ័តកំពង់សោម មិនមែនជាផ្នែកសំខាន់គ្រប់គ្រាន់របស់របបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" នោះដែរ ១៨៧

ឃ. សេចក្តីសន្និដ្ឋាន ១៩១

ខ. ការជួបទាក់ទងញឹកញាប់ជាមួយ មេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឬ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ១៩២

១. ការទំនាក់ទំនងរវាងមជ្ឈិម និង កងពលធំ ១៩២

២. ការប្រាស្រ័យទាក់ទងរបស់ មាស មុត ជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. មិនមានន័យថាគាត់គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ១៩៥

៣. សេចក្តីសន្និដ្ឋាន ២០៦

គ. មាស មុត មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា ដែលបានប្រព្រឹត្តឡើងនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ..... ២០៦

១. មាស មុត មិនមានអំណាចក្នុងការសម្រេចលើគោលនយោបាយ ប.ក.ក. ឬ ការអនុវត្តគោលនយោបាយទាំងនោះ ២០៧

ក. គណៈអចិន្ត្រៃយ៍ និង អគ្គសេនាធិការ បានផ្សព្វផ្សាយគោលនយោបាយ និង ការណែនាំ ទៅកងពលធំ ហើយតម្រូវឱ្យមានរបាយការណ៍ពីថ្នាក់ក្រោមមកវិញ ២០៧

ខ. ការចូលរួមក្នុងកិច្ចប្រជុំអគ្គសេនាធិការ និង សន្និបាតបក្ស មិនមានន័យថា មាស មុត អាចចូលរួមចំណែកដល់គោលនយោបាយរបស់ ប.ក.ក. ២១២

គ. ការបើកវគ្គរៀនសូត្រនយោបាយសម្រាប់កម្មាភិបាលនៃកងពលធំលេខ ១៦៤ មិនមានន័យថា មាស មុត បានចូលរួមចំណែកក្នុងគោលនយោបាយរបស់ ប.ក.ក. ២២៣

ឃ. សេចក្តីសន្និដ្ឋាន ២២៧

២. វិសាលភាពនៃការទទួលខុសត្រូវរបស់កងពលធំលេខ ១៦៤ គឺមិនធំទូលាយគ្រប់គ្រាន់ ដើម្បីធ្វើឱ្យ មាស មុត ក្លាយជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ ២២៧

ក. មាស មុត មិនមានអំណាចទៅលើកងពលធំលេខ ១ ឬ កងពលធំផ្សេងទៀត ២២៨

ខ. បើទោះបីជាកងពលធំលេខ ១ និង កងពលធំលេខ ១៦៤ បានសហការចាប់ទូកថៃ និង ទូកវៀតណាមក៏ដោយ ក៏ការសហការបែបនេះមិនមានន័យថា មាស មុត មានសិទ្ធិអំណាចលើកងពលធំលេខ ១ នោះដែរ ២៣៥

គ. សេចក្តីសន្និដ្ឋាន ២៣៨

៣. សិទ្ធិអំណាចលើកងពលធំលេខ ១៦៤ មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ២៣៩

ក. មាស មុត មិនបានចេញបញ្ជា ឬ ធ្វើសេចក្តីសម្រេចតែឯងឡើយ ពាក់ព័ន្ធនឹងប្រតិបត្តិការយោធានៃកងពលធំលេខ ១៦៤ ..... ២៣៩

ខ. មាស មុត មិនបានឃ្លាំមើលដែនគោក ដែនកោះ និង កងទ័ព ២៤៦

គ. មាស មុត មិនបានចេញបញ្ជាឱ្យយាមល្បាត និង ចាប់ទូក ២៥១

ឃ. មាស មុត មិនបានចេញបញ្ជាឱ្យចល័តកងទ័ព រំសាយកងទ័ព ឬ ផ្ទេរកងទ័ព ២៥៣

ង. មាស មុត មិនបានចេញបញ្ជាទាក់ទងនឹងការចាប់ខ្លួន ២៥៦

ច. មាស មុត មិនបានចេញបញ្ជាទាក់ទងនឹងការកាប់សម្លាប់ ២៥៨

ឆ. មាស មុត មិនបានចេញបញ្ជាទាក់ទងនឹងការបង្កបង្កើនផលកសិកម្ម ២៦០

ញ. សេចក្តីសន្និដ្ឋាន ២៦៤

៤. សិទ្ធិអំណាចលើតំបន់ស្វយ័តកំពង់សោមមិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ២៦៥

៥. មាស មុត មិនមានសិទ្ធិអំណាចលើមន្ទីរសន្តិសុខ ការដ្ឋាន ឬ សហករណ៍ បើទោះបីជាគាត់មានសិទ្ធិអំណាចបែបនេះក៏ដោយ ក៏សិទ្ធិអំណាចនេះមិនធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ ២៧៥

ក. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ២៧៦

ខ. មន្ទីរសន្តិសុខទឹកសាប ២៨៦

គ. ការដ្ឋានស្ទឹងហាវ ២៩២

ឃ. ការដ្ឋាន និង សហករណ៍តំបន់រាម ២៩៧

ង. សេចក្តីសន្និដ្ឋាន ៣០៦

៦. សិទ្ធិអំណាចក្នុងការតែងតាំង ដំឡើងដំណែង និង បណ្តេញបុគ្គលិកនៅក្នុងកងពលធំលេខ ១៦៤ និង តំបន់ស្វយ័តកំពង់សោម មិនបានធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ៣០៧

៧. សិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មបុគ្គលិកក្រោមបង្គាប់ មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ដែល "ទទួលខុសត្រូវខ្ពស់បំផុត" ៣១២

៨. សិទ្ធិអំណាចលើបុគ្គលិកកងពលធំលេខ ១១៧ ឬ តំបន់ ៥០៥ មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ៣១៩

៩. មាស មុតមិនទទួលខុសត្រូវលើការបោសសម្អាតកងពលធំលេខ ១៦៤ ..... ៣៣២

ក. មាស មុត មិនបានខ្នះខ្នែងអនុវត្តគោលនយោបាយបោសសម្អាតរបស់បក្សជាមួយនឹង ប.ក.ក. និង មេដឹកនាំជាន់ខ្ពស់របស់កងពលធំលេខ ១៦៤ ..... ៣៣២

ខ. មាស មុត មិនមានអំណាចផ្តាច់មុខក្នុងការសម្រេចថា តើត្រូវចាប់ខ្លួន ឬ សម្លាប់ទាហានរបស់កងពលធំលេខ ១៦៤ ..... ៣៤១

គ. មាស មុត មិនបានបញ្ជាឱ្យចាប់ខ្លួនកងទ័ពរបស់កងពលធំលេខ ១៦៤ ..... ៣៤៣

i. អតីតទាហានរបស់កងពលធំលេខ ៣ ..... ៣៤៣

ii. ទាហានតំបន់ ៣៧ និង កងវរសេនាតូចលេខ ៣៨៦ ..... ៣៤៤

iii. អតីតទាហានភូមិភាគបូព៌ា ៣៤៧

iv. ទាហានដែលមានការពាក់ព័ន្ធនឹងរបប លន់ នល់ ៣៤៩

v. ទាហានដែលមានការជាប់ពាក់ព័ន្ធជាមួយបរទេស ៣៥១

vi. អ្នកដែលត្រូវបានគេយល់ឃើញថាជាជនក្បត់ និង បណ្តាញរបស់ពួកគេ ៣៥៣

vii. អ្នករត់ចោលជួរ និង អ្នកផ្តាច់ខ្លួន ៣៥៥

ឃ. មិនមានការបន្តបោសសម្អាតទៅលើកម្មាភិបាលរបស់កងពលធំលេខ ១៦៤ ..... ៣៥៨

ង. សេចក្តីសន្និដ្ឋាន ៣៥៩

១០. បើទោះជាកងពលធំលេខ ១៦៤ បានចាប់ខ្លួន ឃុំខ្លួន ឬ កាប់សម្លាប់ជនជាតិវៀតណាម ជនជាតិថៃ ឬ ជនជាតិបស្ចិមប្រទេសមែនក៏ដោយ ក៏អំពើបែបនេះមិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ ៣៦០

ក. ការចាប់ខ្លួន ការឃុំខ្លួន ឬ ការកាប់សម្លាប់ជនជាតិវៀតណាម ៣៦១

i. គោលនយោបាយ ប.ក.ក. ទាក់ទងនឹងវៀតណាមបានកើតចេញពីការភ័យខ្លាចជាលក្ខណៈប្រវត្តិសាស្ត្រអំពីការឈ្លានពានរបស់យោធាវៀតណាម ៣៦១

ii. ជនជាតិវៀតណាមមិនត្រូវបានឃុំខ្លួន ឬ កាប់សម្លាប់ដោយារមូលហេតុនៃការធ្វើទុក្ខបុកម្នេញ ៣៦៣

ខ. ការចាប់ខ្លួន ការឃុំខ្លួន ឬ ការកាប់សម្លាប់ជនជាតិថៃ និង ជនជាតិបស្ចិមប្រទេស ៣៧៣

i. មាស មុត មិនបានទទួលខុសត្រូវលើការចាប់ខ្លួន ឬ ការកាប់សម្លាប់ជនជាតិថៃ ៣៧៣

ii. មាស មុត មិនបានទទួលខុសត្រូវលើការចាប់ខ្លួន ឬ ការកាប់សម្លាប់ជនបស្ចិមប្រទេស ៣៧៨

គ. សេចក្តីសន្និដ្ឋាន ៣៨២

១១. មាស មុត មិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះអ្នកដែលត្រូវបញ្ជូនទៅ មន្ទីរ ស-២១ ..... ៣៨៣

ក. ទំនាក់ទំនងរវាង មាស មុត និង តំណាងមន្ទីរ ស-២១ នៅកិច្ចប្រជុំអគ្គសេនាធិការ មិនមានន័យថា មាស មុត បានដឹងពីអ្វីដែលមន្ទីរ ស-២១ បានធ្វើ ៣៨៣

ខ. មាស មុត មិនបានទទួលខុសត្រូវចំពោះអ្នកទោសកងពលធំលេខ ១៦៤ កំពង់សោម ឬ អ្នកទោសផ្សេងទៀតដែលបញ្ជូនទៅមន្ទីរ ស-២១ ..... ៣៨៧

i. មាស មុត មិនបានដើរតួនាទីសំខាន់នៅក្នុងការសម្រេចថាបញ្ជូននរណាទៅមន្ទីរ ស-២១ ..... ៣៨៧

ii. មាស មុត មិនបានទទួលខុសត្រូវចំពោះមនុស្សចំនួន ៧០៦ នាក់ ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ នោះទេ។ បើទោះបីជាគាត់មានការទទួលខុសត្រូវនេះក៏ដោយ ក៏ការទទួលខុសត្រូវបែបនេះមិនអាចធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ ៣៩៤

គ. សេចក្តីសន្និដ្ឋាន ៣៩៨

១២. ការដែលមានកេរ្តិ៍ឈ្មោះថាមានភាពតឹងរ៉ឹង ឬ កាច មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" ៣៩៨

ឃ. មាស មុត មិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ៤០២

១. ទាំង មាស មុត ទាំងថ្នាក់ដឹកនាំកងពលធំលេខ ១៦៤ មិនបានប្រកាសនៅក្នុងកងពលធំលេខ ១៦៤ អំពីគោលនយោបាយកាប់សម្លាប់ជនជាតិវៀតណាមទាំងអស់ ៤០៣

២. មាស មុត មិនបានចេញបញ្ជាសម្លាប់អ្នកជាប់ឃុំវៀតណាមនៅហ្នឹងកន្លែង ឬ បញ្ជូនពួកគេទៅដែនគោកដើម្បីសម្លាប់ចោល ៤០៩

៣. គ្មានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញថា ប្រជាជនវៀតណាមរាប់រយនាក់ ឬ រាប់ពាន់នាក់ ត្រូវបានសម្លាប់ចោលដោយមិនលើកលែងដោយកងពលធំលេខ ១៦៤ ..... ៤១៤

៤. សេចក្តីសន្និដ្ឋាន ៤១៦

ង. មាស មុត មិនទទួលខុសត្រូវចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភសេពសន្ថវៈ នៅតំបន់កំពង់សោមនោះទេ។ បើទោះបីជាគាត់ទទួលខុសត្រូវក៏ដោយ ក៏អំពើទាំងនេះមិនមានភាពធ្ងន់ធ្ងរគ្រប់

គ្រាន់ អាចធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ ក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ ៤១៧

១. មាស មុត មិនទទួលខុសត្រូវចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភសេពសន្ថវៈ ដែលបានកើតឡើងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់ ៤១៨

២. មានភ័ស្តុតាងមិនគ្រប់គ្រាន់បង្ហាញថា ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់ស្វយ័តកំពង់សោម បានទទួលរងការប៉ះទង្គិចផ្លូវចិត្ត ឬ ផ្លូវកាយ ៤២៥

៣. សេចក្តីសន្និដ្ឋាន ៤២៨

ច. បើទោះបីជាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ មាស មុត ក៏ដោយ ហើយបើទោះជាការទទួលខុសត្រូវព្រហ្មទណ្ឌអាចធ្លាក់លើ មាស មុត ក៏ដោយ ក៏ឧក្រិដ្ឋកម្មទាំងនេះ និងចំនួនជនរងគ្រោះ មិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលអាចឱ្យ មាស មុត ក្លាយជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ ៤២៨

១. មានភ័ស្តុតាងមិនគ្រប់គ្រាន់បង្ហាញថា ប្រជាជនជាង ១000 នាក់ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅសមុទ្រ ឬ នៅតំបន់ស្វយ័តកំពង់សោម ៤២៩

ក. ការប៉ាន់ស្មានអំពីការកាប់សម្លាប់ និង ការចាប់ខ្លួន ដែល ស.ព.អ. ដកស្រង់ គឺជាការទាយស្មាន និង មិនអាចជឿជាក់បាន ៤៣០

ខ. ស.ព.អ. និយាយបំផ្លើសការរៀបរាប់របស់សាក្សីម្នាក់ៗ ដែលអះអាងថាបានឃើញការចាប់ទូក និង មិនពិចារណាពីសក្តីកម្ម ដែលបដិសេធ ឬ ធ្វើឱ្យការអះអាងរបស់គាត់មិនរឹងមាំ ៤៣៧

គ. ភ័ស្តុតាងឯកសារដែល ស.ព.អ. ដកស្រង់ មិនអាចជឿជាក់បាន មានតម្លៃជាភ័ស្តុតាងទាប ឬ មិនគាំទ្រការអះអាងរបស់គាត់អំពីចំនួនជនរងគ្រោះ ៤៤២

២. មានភ័ស្តុតាងមិនគ្រប់គ្រាន់បង្ហាញអំពីចំនួនជនរងគ្រោះដ៏ច្រើននៃឧក្រិដ្ឋកម្ម នៅតាមមន្ទីរសន្តិសុខ ការដ្ឋានការងារ ឬ សហករណ៍ នៅតំបន់ស្វយ័តកំពង់សោម ៤៤៥

ក. វត្តឥន្ទញ្ញាណ ៤៤៥

i. សាក្សីដែលបានទៅមើលវត្តឥន្ទញ្ញាណ ក្រោយឆ្នាំ ១៩៧៩ មិនអាចជឿជាក់បាន និង បាននិយាយផ្ទុយគ្នា ៤៤៦

ii. សាក្សីដែលបានឃើញ ឬ បានជាប់ឃុំនៅវត្តឥន្ទញ្ញាណ នៅក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ និង របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មិនគាំទ្រការអះអាងរបស់ ស.ព.អ. ៤៤៩

ខ. ទីកសាប ៤៥៤

i. ការប៉ាន់ស្មានចំនួនជនរងគ្រោះនៅទីកសាបដែល ស.ព.អ. ដកស្រង់ គឺជាការទាយស្មាន និង មិនអាចជឿជាក់បាន ៤៥៥

ii. ភស្តុតាងរបស់សាក្សី ដែលបានរកឃើញឆ្អឹងនៅសេសសល់ជិតទីកសាបក្រោយឆ្នាំ ១៩៧៩ មិនគាំទ្រការអះអាងរបស់ ស.ព.អ. ៤៥៧

iii. ស.ព.អ. មិនអើពើនឹងភស្តុតាងដែលថា អ្នកដែលកប់នៅក្នុងផ្នូររួមអាចជាទាហានកម្ពុជាប្រជាធិបតេយ្យ ឬ ជាទាហាន លន់ នល់ ឬ អ្នកដែលស្លាប់ដោយសារជំងឺគ្រុនចាញ់ ឬ ជំងឺផ្សេងទៀត ៤៦១

គ. ការដ្ឋានស្ទឹងហាវ ៤៦៣

i. ការប៉ាន់ស្មានចំនួនកម្មករនៅស្ទឹងហាវដែល ស.ព.អ. ដកស្រង់ គឺជាការទាយស្មាន និង មិនអាចជឿជាក់បាន ៤៦៣

ii. ភស្តុតាងរបស់សាក្សីដែលជាប់ឃុំនៅស្ទឹងហាវ គឺមិនអាចជឿជាក់បាន និង មិនគាំទ្រការអះអាងរបស់ ស.ព.អ. ៤៦៨

ឃ. ការដ្ឋានការងារនៅតំបន់រាម ៤៦៩

ង. វាលពិឃាតដែលត្រូវបានចោទប្រកាន់ ៤៨០

៣. សេចក្តីសន្និដ្ឋាន ៤៨៣

V. សេចក្តីសន្និដ្ឋាន ៤៨៤

I. ទិដ្ឋភាពទូទៅ

១. ក្នុងការផ្តល់ថវិកាដល់ អ.វ.ត.ក. មិនបានអនុវត្តឱ្យបានល្អត្រឹមត្រូវ តាមការប្តេជ្ញាចិត្តរបស់ពួកគេដែលបានសម្តែងចេញរួចមកហើយនោះទេ។ ការផ្តល់ថវិកាដែលបានគ្រោង នឹងមិនអាចបំពេញបានតាមលក្ខខណ្ឌតម្រូវពេលនេះជាពេលវេលាសមស្របហើយ សម្រាប់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស.") ក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ផ្អាកកិច្ចដំណើរការនីតិវិធីរឿងក្តី ០០៣ ទាំងស្រុងជាអចិន្ត្រៃយ៍។ អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត របស់តុលាការ ដែលបានលើកឡើងនៅក្នុងថវិកាឆ្នាំ ២០១៨-២០១៩ នោះឡើយ ហើយមិនមានការធានាឱ្យមានការគោរពតាមពីដើមដំបូង និង គួរឱ្យទុកចិត្តបាន ពីសំណាក់ប្រទេសផ្តល់ជំនួយឡើយ។ ការិយាល័យរដ្ឋបាលមិនអាចធានាដល់ ស.ច.ស. ថា ប្រសិនបើមានដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ នោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត នឹងត្រូវបានគោរពនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ឬ ថាកិច្ចដំណើរការនីតិវិធី (ដំណាក់កាលការពិនិត្យមើលលើដីកាដំណោះស្រាយមុនពេលជំនុំជម្រះ ដំណាក់កាលជំនុំជម្រះ និង ដំណាក់កាលប្តឹងសាទុក្ខ) នឹងកើតមានឡើងនោះឡើយ។ ព្យសនកម្មចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺមិនអាចកែតម្រូវបានឡើយ នឹងបណ្តាលឱ្យមានភាពអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរឡែត។ ព្យសនកម្មនេះមិនអាចកែតម្រូវបានឡើយ នៅក្រោយពេលចេញដីកាដំណោះស្រាយ។

២. ប្រសិនបើ ស.ច.ស. បដិសេធមិនផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ស.ច.ស. ត្រូវចេញដីកាលើកលែងការចោទប្រកាន់។ មាស មុត មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។ គាត់មិនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ។

៣. មាស មុត មិនមែនជាបុគ្គល ដែលត្រូវបានប្រមើលមើលទុកដោយភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ថាត្រូវស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ ព្រោះគាត់មិនមែនស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវធំបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ ការណ៍នេះទាញចេញពីភស្តុតាង តាមរយៈការអនុវត្តន៍នូវគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ (in dubio pro reo) និង ការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត។ តួនាទីរបស់គាត់ គឺមិនខ្ពស់គ្រប់គ្រាន់ នៅក្នុងឋានានុក្រមរបស់របបកម្ពុជាប្រជាធិបតេយ្យឡើយ។ គាត់

មិនមានសិទ្ធិអំណាច ឬ ឆន្ទានុសិទ្ធិ ដើម្បីសម្រេចទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្ត កម្ពុជា ("ប.ក.ក.") ឬ ការអនុវត្តគោលនយោបាយទាំងនោះឡើយ។ អំពើរបស់គាត់ដែលរងការចោទប្រកាន់ និង លទ្ធផលនៃអំពើទាំងនោះ គឺមិនធ្ងន់ធ្ងរគ្រប់គ្រាន់ឡើយ បើគិតពីការឈឺចាប់រងទុក្ខវេទនាទាំងមូល នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ ទោះបីជាពិនិត្យមើលដោយលម្អៀងបំផុតទៅខាងសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") ក៏ដោយ ក៏ភស្តុតាងមិនបានបង្ហាញថា មាស មុត ធ្លាប់ជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់នោះដែរ។

៤. មាស មុត មិនធ្លាប់មានតួនាទីនៅក្នុង ប.ក.ក. ឬ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលផ្តល់ឱ្យគាត់នូវសិទ្ធិអំណាច ឬ ការទទួលខុសត្រូវនៅទូទាំងប្រទេសឡើយ។ គាត់មិនធ្លាប់ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ បានចូលរួមក្នុងសកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ឡើយ។ គាត់មិនធ្លាប់ជាសមាជិកគណៈកម្មាធិការមជ្ឈិមឡើយ។ ទាំងតាមផ្លូវច្បាប់ និង ទាំងការអនុវត្តជាក់ស្តែង គាត់ក៏មិនធ្លាប់ជាអនុលេខានៃអគ្គសេនាធិការ សមាជិកគណៈកម្មាធិការអគ្គសេនាធិការ លេខាតំបន់ស្វយ័តកំពង់សោម ឬ មានសិទ្ធិអំណាចខ្ពស់បំផុតលើគណៈតំបន់ស្វយ័តកំពង់សោមនោះដែរ។ សិទ្ធិអំណាចដែល មាស មុត អាចធ្លាប់មានក្នុងនាមជាមេបញ្ជាការកងពលធំលេខ ១៦៤ គឺមានកម្រិតត្រឹមតែលើបញ្ហាកងទ័ពជើងទឹក នៅតាមបណ្តោយតំបន់ឆ្នេរ និង តំបន់ដីគោកនៅកំពង់សោម និង នៅរយៈពេលពីរខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺនៅតំបន់ ៥០៥ ប៉ុណ្ណោះ។

៥. មាស មុត មិនធ្លាប់ជាផ្នែកនៃស្ថាប័នធ្វើសេចក្តីសម្រេចជាន់ខ្ពស់ នៅក្នុង ប.ក.ក. ឡើយ។ គាត់មិនធ្លាប់មានសិទ្ធិអំណាច ឬ ឆន្ទានុសិទ្ធិ ក្នុងការសម្រេចលើគោលនយោបាយរបស់ ប.ក.ក. ឬ ការអនុវត្តគោលនយោបាយទាំងនោះឡើយ។ រាល់ការទាក់ទងណាមួយដែលគាត់អាចមាន ជាមួយនឹងមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. នោះ គឺមិនអាចធ្វើឱ្យគាត់ក្លាយជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឡើយ។ គាត់ និង សមាជិកដទៃទៀតនៃគណៈកម្មាធិការកងពលធំលេខ ១៦៤ និង គណៈតំបន់ស្វយ័តកំពង់សោម បានរាយការណ៍ និង ទទួលបានការណែនាំ និង គោលនយោបាយ ពីសំណាក់មេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. និង អគ្គសេនាធិការ ហើយតម្រូវឱ្យពួកគាត់គោរពតាម។ បើទោះបីជា មាស មុត ធ្លាប់មានសិទ្ធិអំណាចចេញបញ្ជា ឬ សេចក្តីសម្រេច ទាក់ទងនឹងកងពលធំលេខ ១៦៤ ក៏ដោយ ក៏ប្រតិបត្តិការ និង ផលប៉ះពាល់ មានកម្រិតត្រឹមតែតំបន់ភូមិសាស្ត្រដែលកំណត់ជាស្រេច គឺផ្នែកទឹកនៅក្បែរកំពង់សោម ដូចជា កោះពូលូវ៉ៃ កោះតាង និង កោះរ៉ុងជាដើម។

មាស មុត មិនមានសិទ្ធិអំណាចទៅលើមន្ទីរសន្តិសុខនៅវត្តឥន្ទញ្ញាណ ឬ ទឹកសាប ឬ ការដ្ឋាន និង សហការណ៍នៅស្ទឹងហាវ និង រាមឡើយ។ គាត់ក៏មិនទទួលខុសត្រូវលើប្រជាជនស៊ីវិល ឬ កងទ័ព ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ឬ ត្រូវបានសម្លាប់នៅទីនោះដែរ។

៦. ដោយមិនកាត់បន្ថយឱ្យនៅតិច នូវផលប៉ះពាល់លើជនរងគ្រោះ និង ព្យសនកម្មទទួលរងដោយជនរងគ្រោះ ដោយសារឧក្រិដ្ឋកម្មណាមួយ ដែលអាចត្រូវបានប្រព្រឹត្តឡើង នៅលើផ្ទៃសមុទ្ររបស់របបកម្ពុជាប្រជាធិបតេយ្យ ឬ នៅកំពង់សោម បើទោះបីជាការទទួលខុសត្រូវព្រហ្មទណ្ឌ អាចត្រូវបានទម្លាក់ទៅលើ មាស មុត ក៏ដោយ ក៏ឧក្រិដ្ឋកម្ម និង ចំនួនជនរងគ្រោះ គឺមិនធ្ងន់ធ្ងរគ្រប់គ្រាន់សម្រាប់ធ្វើឱ្យគាត់ក្លាយជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់នោះដែរ។ នៅពេលគិតពីការឈឺចាប់រងទុក្ខវេទនាទាំងមូល នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ចំនួនមនុស្សស្លាប់សរុបដោយសារការសម្លាប់ ភាពអត់ឃ្លាន ពលកម្មដោយបង្ខំ និង កង្វះខាតសេវាសុខាភិបាលសាធារណៈ ព្រមទាំងចំនួនប្រជាជនដែលត្រូវផ្លាស់ទីលំនៅ និង អ្នកដែលត្រូវបានបង្ខំឱ្យធ្វើពលកម្មធ្ងន់ធ្ងរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងរយៈពេលនេះនោះ ការទទួលសត្រូវដែលត្រូវបានចោទប្រកាន់ចំពោះ មាស មុត គឺតូចតាចបំផុត។

៧. ក្នុងការអះអាងថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់" និង ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់នោះ ស.ព.អ. បានពឹងផ្អែកយ៉ាងខ្លាំងទៅលើភស្តុតាងដែលមានមន្ទិល៖ គឺភស្តុតាងដែលមិនបញ្ជាក់ការពិត ភស្តុតាងដែលប្រមូលបានដោយបុគ្គល ឬ ស្ថាប័នដែលមិនស្ថិតក្រោម អ.វ.ត.ក. ការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ការស្តាប់ចម្លើយរបស់ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព.") ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ការសម្ភាសន៍ជាមួយ មាស មុត ដែលធ្វើឡើងដោយស្ថាប័នដែលមិនស្ថិតក្រោម អ.វ.ត.ក. ភស្តុតាងជាពាក្យចចាមអារ៉ាម និង ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ឬ ភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម។

៨. ស.ព.អ. ពឹងផ្អែកលើ៖ សាក្សីដែលចម្លើយរបស់ពួកគេ មានមូលដ្ឋានលើពាក្យចចាមអារ៉ាម ឬ ការទាយស្មាន ឬ ទទួលបានដោយការធ្វើទារុណកម្ម សាក្សីដែលចម្លើយរបស់ពួកគេ មិនបានគាំទ្រការអះអាងរបស់ ស.ព.អ. ភស្តុតាងជាភាពយន្តឯកសារ ដែលមិនអាចជឿជាក់បាន ដែលមានតម្លៃភស្តុតាងទាប ឬ មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. និង ភស្តុតាងដែលទទួលបានតាមរយៈការប្រើប្រាស់ដែលមិនត្រូវបានអនុញ្ញាតនូវភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម។

៩. ស.ព.អ. បង្ហាញភស្តុតាងខុស និង មិនអើពើនឹងភស្តុតាងបរិបទ និង រចនាសម្ព័ន្ធពាក់ព័ន្ធ ដែលអាចធ្វើឱ្យការអះអាងរបស់គាត់ ចុះខ្សោយ ឬ គ្មានអានុភាព។

១០. ស.ព.អ. ពឹងផ្អែកយ៉ាងខ្លាំង ទៅលើសាក្សីដែលដែលមិនអាចជឿជាក់បាន ក្នុងការកំណត់ពីតួនាទី និង សិទ្ធិអំណាចរបស់ មាស មុត ដូចជា ឌុច ប៉ាក សុខ ជេត ប៊ុណ្ណា ស៊ឹម នី មាស រឿន អែម សុន លុន សេង ម៉ឹង វេត និង សេង សឿន។

១១. ស.ព.អ. ស្នើសុំឱ្យ ស.ច.ស. បញ្ជូន មាស មុត ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្ម និង ក្រោមទម្រង់នៃការទទួលខុសត្រូវ ដែលមិនអាចអនុវត្តបាននៅ អ.វ.ត.ក.។ តាមគោលការណ៍នីត្យានុកូលភាព វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ និង ការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត ស.ច.ស. ចាំបាច់ត្រូវតែអនុវត្តច្បាប់ ដូចដែលមានចែងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គឺមិនមែនច្បាប់ដូចដែលមានក្នុងពេលបច្ចុប្បន្ននេះឡើយ។ មាស មុត មិនអាចត្រូវបានកាត់ទោសពីឧក្រិដ្ឋកម្ម ដែលមាននៅក្នុងមាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. (“ឧក្រិដ្ឋកម្មជាតិ”) ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ (“ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ”) និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងទៀតឡើយ។ គេមិនអាចឱ្យ មាស មុត ទទួលខុសត្រូវ ក្រោមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ និង ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមបានទេ។ គេក៏មិនអាចឱ្យគាត់ទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិណាមួយ ដែលបានប្រព្រឹត្តដោយ ប.ក.ក. ទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនបានដែរ ពីព្រោះកងកម្លាំងទាំងនោះគឺមិនមែនជា “ជនស៊ីវិល” ទេ បើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

១២. ភស្តុតាងនៅក្នុងសំណុំរឿង ០០៣ មិនគ្រប់គ្រាន់ឡើយ សម្រាប់គាំទ្រដល់ការសម្រេចថា អង្គជំនុំជម្រះសាលាដំបូងដែលមានហេតុផល អាចផ្តន្ទាទោស មាស មុត ឱ្យហួសពីវិមតិសង្ស័យបាន។ បទដ្ឋាននៃការបង្ហាញភស្តុតាងនេះ អាចត្រូវបានធ្វើយុត្តិកម្ម ដោយសារតែលក្ខណៈវិសាមញ្ញនៃឧក្រិដ្ឋកម្ម បន្ទុកដ៏ធ្ងន់ក្នុងការចោទប្រកាន់ជនសង្ស័យនៅ អ.វ.ត.ក. រយៈពេលស៊ើបអង្កេតដ៏វែង និង ឱកាសដ៏ច្រើនរបស់ ស.ច.ស. ក្នុងការវាយតម្លៃទៅលើភស្តុតាងនៅក្នុងសំណុំរឿង រហូតដល់ពេលដែលពួកគាត់ព្រាងដីកាដំណោះស្រាយ។

១៣. ស.ច.ស. គួរផ្អាកកិច្ចដំណើរការនីតិវិធីទាំងស្រុង ជាអចិន្ត្រៃយ៍ នៅក្នុងរឿងក្តី ០០៣។ ជាជម្រើសមួយផ្សេងទៀត ស.ច.ស. គួរចេញដីកាលើកលែងការចោទប្រកាន់។

II. បញ្ហាពាក់ព័ន្ធនឹងការសម្រេចសេចក្តី

ជញ្ជីងយុត្តិធម៌ (Justicia) មិនថ្លឹងថ្លែងសេរីភាពរបស់ជនណាម្នាក់ ជាមួយនឹងធនធានទ្រព្យសម្បត្តិដែលមានឡើយ។ ឃើងក៏មិនត្រូវធ្វើដូច្នេះដែរ"[1]

ក. ស.ច.ស. ចាំបាច់ត្រូវតែផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ នៅក្នុងរឿងក្តី ០០៣ ពីព្រោះ មាស មុត នឹងមិនអាចទទួលបានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ បើគិតពីវិបត្តិថវិកា

១៤. ការអត់ធ្មត់របស់តុលាការលែងជាជម្រើសទៀតហើយ។ នេះគឺជាពេលវេលាដែល ស.ច.ស. ត្រូវប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ក្នុងការផ្អាកកិច្ចដំណើរការនីតិវិធីទាំងស្រុង ជាអចិន្ត្រៃយ៍ នៅក្នុងរឿងក្តី ០០៣។ ស្ថានភាពថវិការបស់តុលាការ និង ទស្សនវិស័យទៅពេលខាងមុខ មិនមានការវិវឌ្ឍន៍ប្រសើរឡើងឡើយ ដោយសារតែ ស.ច.ស. បានប្រកាសថា ស្ថានភាពថវិកា "មិនស្របតាមគោលការណ៍គ្រឹះ នៃការជំនុំជម្រះក្តីដោយយុត្តិធម៌ នីតិរដ្ឋ និង ឯករាជ្យភាពតុលាការ"[2]។ ទោះបីជា ស.ច.ស. ព្យាយាម រំឭកដល់អង្គការសហប្រជាជាតិ ("អ.ស.ប.") និង ប្រទេសផ្តល់ជំនួយអំពីវិបត្តិថវិការបស់ អ.វ.ត.ក. ក៏ដោយ ក៏អ្នកទទួលខុសត្រូវខ្ពស់បំផុត ក្នុងការផ្តល់ថវិកាដល់ អ.វ.ត.ក. មិនបានអនុវត្តឱ្យបានល្អត្រឹមត្រូវ តាមការប្តេជ្ញាចិត្តរបស់ពួកគេនោះដែរ។ ការិយាល័យរដ្ឋបាលមិនអាចធានាដល់ ស.ច.ស. ថា ប្រសិនបើមានដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ នោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត នឹងត្រូវបានគោរពនៅគ្រប់ដំណាក់កាលទាំងអស់ នៃកិច្ចដំណើរការនីតិវិធី ឬ ថាកិច្ចដំណើរការនីតិវិធី (ដំណាក់កាលពិនិត្យមើលលើដីកាដំណោះស្រាយមុនពេលជំនុំជម្រះ ដំណាក់កាលជំនុំជម្រះ និង ដំណាក់កាលប្តឹងសាទុក្ខ) នឹងកើតមានឡើងនោះឡើយ។

---

[1] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 ("សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក.") កថាខណ្ឌ ៥។

[2] *ដូចខាងលើ* កថាខណ្ឌ ១។

១៥. ស.ច.ស. បានរំឭកដល់ភាគីនានា និង ការិយាល័យរដ្ឋបាល ហើយតាមរយៈការពន្លឿត បានរំឭកទៅដល់ អ.ស.ប. រាជរដ្ឋាភិបាលកម្ពុជា ប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប. គឺលោក David Scheffer ថា ស.ច.ស. គិតបម្រុង ដល់ការផ្អាកកិច្ចស៊ើបអង្កេតទាំងអស់ជាអចិន្ត្រៃយ៍ ពីព្រោះ ស.ច.ស. មានការព្រួយបារម្ភយ៉ាងខ្លាំង អំពីស្ថានភាពថវិការបស់ អ.វ.ត.ក.[3]។ ស.ច.ស. បានពិចារណាឃើញថា "តាមពាក្យសច្ចាប្រណិធានរបស់យើង ពេលចូលកាន់តំណែង យើងមានភារកិច្ចត្រូវពិចារណាលើជម្រើសទាំងអស់ និង ជម្រើសណាក៏ដោយ ដើម្បីធានាថា ការវិវឌ្ឍន៍ទៅមុខនៅក្នុងកិច្ចស៊ើបសួរនៅចំពោះមុខតុលាការនេះ" គោរពដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ[4]។ សេចក្តីសង្កេតយល់ឃើញត្រូវបានស្នើសុំ[5]។ ស.ច.ស. ស្វែងរកការធានាថា មានថវិកាគ្រប់គ្រាន់សម្រាប់ឱ្យ ស.ច.ស. បញ្ចប់អាណត្តិការងាររបស់ខ្លួន ពិនិត្យបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ និង ប្រសិនបើមានដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ គឺមានកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី និង បណ្តឹងសាទុក្ខ[6]។ ស.ច.ស. បានសន្និដ្ឋានថា ប្រសិនបើមិនមានការធានាបែបនេះទេ រាល់ការស៊ើបអង្កេតទាំងអស់នឹងត្រូវបញ្ចប់[7]។

១៦. ស.ច.ស. មិនទាន់បានទទួល ព័ត៌មានលម្អិត និង ការធានាដែលខ្លួនបានស្នើសុំនៅឡើយទេ[8]។ ផ្ទុយទៅវិញ ការិយាល័យរដ្ឋបាល អ.ស.ប. ក្រុមប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប. បែរជាលើកបង្ហាញដោយបញ្ជោត តែទិដ្ឋភាពល្អនៃស្ថានភាពថវិការបស់ អ.វ.ត.ក. ជាទម្លឹករណ៍ថា ស.ច.ស. បានអនុវត្តហួសពីសិទ្ធិអំណាចតាមផ្លូវច្បាប់ (ultra vires) ដោយលើកឡើងនូវការដោះសារអំពីមូលហេតុ ដែលមិនអាចមានការធានាចំពោះការផ្តល់ថវិកា

---

[3] *ដូចខាងលើ*។

[4] *ដូចខាងលើ*។

[5] *ដូចខាងលើ* កថាខណ្ឌ ៨៥។

[6] *ដូចខាងលើ* កថាខណ្ឌ ១ កថាខណ្ឌ ៧៩។

[7] *ដូចខាងលើ* កថាខណ្ឌ ១ កថាខណ្ឌ ៧៩។

[8] ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ និង សារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី ឃឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 ("ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា") កថាខណ្ឌ ៦១៖ "ចម្លើយតបរបស់ អ.ស.ប. និង ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗដែលបានដាក់តាមរយៈការិយាល័យរដ្ឋបាល មិនដល់កម្រិតច្បាស់លាស់ទាំងស្រុងដែលយើងបានសង្ឃឹមឡើយ"។

និង ការសន្យាមិនច្បាស់លាស់ អំពីការធានាឱ្យមានការផ្តល់ថវិកា[9]។ ស.ច.ស. មិនបានជឿជាក់លើការបង្ហាញនោះឡើយ ហើយបានប្រាប់ថា ការបង្ហាញទាំងនោះ គឺគ្មានភាពពិតប្រាកដ និង ទទេស្អាត[10]។

១៧. ស.ច.ស. បានជ្រើសរើសយកការអត់ធ្មត់តាមផ្លូវតុលាការ ដោយពិចារណាឃើញថា ចម្លើយរបស់ អ.ស.ប. និង ប្រទេសផ្តល់ជំនួយ មិនបានបង្ហាញពីការមិនចង់ពាក់ព័ន្ធជាមួយក្តីបារម្ភរបស់ពួកគាត់ឡើយ ហើយក៏មានការផ្តល់ថវិកាមកភ្លាមៗដែរ។ ស.ច.ស. បានពន្យារពេលចេញសេចក្តីសម្រេចថាតើត្រូវផ្អាកកិច្ចដំណើរការនីតិវិធីដែរឬយ៉ាងណា *នោះ* ដោយរងចាំការវិវឌ្ឍន៍បន្តទៅមុខទៀត ហើយបានសន្យាថា នៅតែពិចារណាលើបញ្ហានេះ ហើយនឹងចាត់វិធានការចាំបាច់នានា ប្រសិនបើឯករាជ្យភាពតុលាការ យុត្តិធម៌ និង សុចរិតភាពរបស់កិច្ចដំណើរការនីតិវិធី ទទួលរងការគំរាមកំហែង[11]។

---

[9] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស មតិយោបល់របស់ការិយាល័យរដ្ឋបាលស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/០២ ចុះថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០១៧ ឯកសារ D349/3 ("មតិយោបល់របស់ការិយាល័យរដ្ឋបាល")។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឧបសម្ព័ន្ធ ១៖ សេចក្តីសង្កេតរបស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិទាក់ទិននឹងសំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/០២ ឯកសារ D349/3.1.1 ("សេចក្តីសង្កេតរបស់ អ.ស.ប.")។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឧបសម្ព័ន្ធ ២៖ សេចក្តីថ្លែងការណ៍របស់ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ស្តីពី *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់លើរឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/០២* ដែលសហចៅក្រមស៊ើបអង្កេតបានចេញនៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ (សំណើសុំមតិយោបល់) ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D349/3.1.2 ("សេចក្តីសង្កេតរបស់ក្រុមប្រទេសផ្តល់ជំនួយ")។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឧបសម្ព័ន្ធ ៣៖ អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប. ទទួលបន្ទុកជំនួយ អ.ស.ប.សម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម សេចក្តីថ្លែងការណ៍សម្ងាត់ទាក់ទិននឹង *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/០២* ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D349/3.1.3 ("សេចក្តីសង្កេតរបស់អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប.")។ *សូមមើលផងដែរ* កថាខណ្ឌ ២៩-៤០ *ខាងក្រោម*។

[10] *សូមមើល* កថាខណ្ឌ ១៦-៦០ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។ *សូមមើលផងដែរ* កថាខណ្ឌ ២៩-៤០ *ខាងក្រោម*។

[11] កថាខណ្ឌ ៦៧ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។

១៨. ក្នុងពេលឥឡូវនេះ គឺប្រហែលមួយឆ្នាំក្រោយពេលដែល ស.ច.ស. បានចេញសំណើរបស់ខ្លួន ស្ថានភាពថវិកា និង ទស្សនវិស័យទៅពេលខាងមុខ មិនមានការប្រសើរឡើងឡើយ ហើយប្រហែលជាកាន់តែអាក្រក់ទៅទៀត។ ថវិកាដែលបានគ្រោង ដែលពឹងផ្អែកទៅលើការសន្យា ដែលមានភាពប្រែប្រួល និងមិនចងជាប់កាតព្វកិច្ចរបស់ប្រទេសផ្តល់ជំនួយនោះ នឹងមិនអាចបំពេញបានតាមតម្រូវការរបស់តុលាការ ដូចមានកំណត់នៅក្នុងគម្រោងថវិកាឆ្នាំ ២០១៨-២០១៩ ឡើយ។ ការចូលរួមចំណែកតាមការស្ម័គ្រចិត្ត ត្រូវបានរំពឹងទុកថានឹងធ្លាក់ចុះ។ ព្យុះអាក្រក់កំណាចទាំងអស់ដែល ស.ច.ស. បានលើកឡើង គឺនៅតែបន្តមាននៅឡើយ៖ ថវិកាដែលគ្មានការធានា និង មិនអាចឱ្យជឿជាក់បាន ការខ្វះបុគ្គលិក និង ការផ្លាស់ប្តូរបុគ្គលិក ការពន្យារពេល ឬ សូម្បីតែការផ្អាកកិច្ចដំណើរការនីតិវិធីដោយគ្មានរបៀបរបប រួមជាមួយផលប៉ះពាល់ទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត។

១៩. មាស មុត ប្រហែលជានឹងត្រូវជំនុំជម្រះឃ្លួរៗម្តង ឬ ជាដំណាក់កាល ទៅតាមការទម្លាក់ថវិការបស់ប្រទេសផ្តល់ជំនួយ។ ប្រហែលជាការផ្តល់ថវិកានឹងបញ្ចប់ ហើយនាំឱ្យប្រតិបត្តិការរបស់តុលាការបែកខ្ញែកគ្មានសណ្តាប់ធ្នាប់ ហើយធ្វើឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅបន្តលងបន្លាចនៅពីលើក្បាល មាស មុត ជានិច្ចនិរន្តន៍ទៅ ហើយនឹងផ្តល់ងារជាអចិន្ត្រៃយ៍ដល់ មាស មុត ថាជាឧក្រិដ្ឋជនសង្គ្រាម និង ជា *ឧក្រិដ្ឋជនប្រល័យពូជសាសន៍*។ ប្រហែលជា មាស មុត ត្រូវទទួលការជំនុំជម្រះក្តី នាពេលអនាគត ដោយតុលាការផ្សេងទៀត។ អ្វីដែលប្រាកដសម្រាប់ការគណនាពេលនេះគឺថា ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះមែននោះ មាស មុត នឹងមិនទទួលបានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចនឹងជនជាប់ចោទដទៃទៀតនៅក្នុងរឿងក្តី ០០១ និងរឿងក្តី ០០២ គឺសច្ចធារណ៍និរទោស និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ឆាប់រហ័ស ដែលរួមមានដូចជា សិទ្ធិទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ សម្រាប់ត្រៀមរៀបចំការការពារក្តី ការពិនិត្យមើលសាក្សី និង ភស្តុតាងដាក់បន្ទុក ការជំនុំជម្រះក្តីក្នុងពេលវេលាសមស្រប និង បណ្តឹងសាទុក្ខឡើយ។

២០. ស.ច.ស. បានពិចារណាឃើញថា ជាភារកិច្ចរបស់ *ខ្លួន* ក្នុងការបង្ការភាពអយុត្តិធម៌យ៉ាងច្បាស់ក្រឡែតនេះ។ ដោយសារតែស្ថានភាពមិនល្អនៃថវិការបស់ អ.វ.ត.ក. ការមិនមានផែនការសម្រាប់ការជំនុំជម្រះក្តី និង បណ្តឹងសាទុក្ខនាពេលអនាគតនៅក្នុងរឿងក្តី ០០៣ រឿងក្តី ០០៤ និងរឿងក្តី ០០៤/០២ ព្រមទាំងលទ្ធភាពខ្ពស់ដែលថា ក្នុងករណីដែលត្រូវបានបញ្ជូនទៅជំនុំជម្រះ មាស មុត

នឹងមិនមានមធ្យោបាយផ្នែកនីតិវិធី ដើម្បីជំទាស់តវ៉ានឹងការចោទប្រកាន់ប្រឆាំងគាត់ ស.ច.ស. ចាំបាច់ត្រូវតែសម្រេចនាពេលនេះ ហើយផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំង មាស មុត ទាំងស្រុង ជាអចិន្ត្រៃយ៍។

ខ. ក្តីបារម្ភរបស់ ស.ច.ស. ក្នុងការសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី

២១. នៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៧ ស.ច.ស. បានពិចារណាដោយស្មាក់ស្មើរ ក្នុងការចេញដីកាសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីរឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/០២ ទាំងស្រុង មិនឱ្យហួសពីចុងខែមិថុនា ឆ្នាំ ២០១៧ ឡើយ លើកលែងតែ ស.ច.ស. បានទទួលការធានាអះអាងជាក់លាក់ និង គួរឱ្យជឿជាក់បានគ្រប់គ្រាន់ថា ស្ថានភាពថវិកានឹងប្រសើរឡើងខ្លាំង ព្រមទាំងការធានាអះអាង ដែលជាក់លាក់ និង គួរឱ្យជឿជាក់បានគ្រប់គ្រាន់ អំពីចក្ខុវិស័យរៀបចំផែនការដ៏សកម្មមួយ[12]។ ស.ច.ស. បានស្នើដល់ការិយាល័យរដ្ឋបាល ឱ្យបញ្ជូនសំណើរបស់ខ្លួនបន្តទៅ អ.ស.ប. រាជរដ្ឋាភិបាលកម្ពុជា ប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប. និង "សុំឱ្យពន្យល់លម្អិតតាមដែលអាចធ្វើទៅបាន" ទូវព័ត៌មានស្តីពីការពិភាក្សាថវិកាការព្យាករណ៍ថវិកាសម្រាប់ឆ្នាំ ២០១៧ និង ឆ្នាំបន្តបន្ទាប់ "ពិសេសសម្រាប់សេណារីយ៉ូដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្ទាប់មកមានកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ ការជំនុំជម្រះក្តី និង បណ្តឹងសាទុក្ខនៅអង្គជំនុំជម្រះតុលាការកំពូល"[13]។

២២. នៅពេលដែលមានសំណើពី ស.ច.ស. ស្ថានភាពថវិការបស់តុលាការ បានឈានដល់ "ចំណុចវិបត្តិ"[14]។ ថវិកាមិនត្រូវបានផ្តល់ឱ្យ ដល់កម្រិតដែលបានអនុម័តយល់ព្រមឡើយ មិនថាតាមរយៈថវិកាឧបត្ថម្ភធនរបស់ អ.ស.ប. ឬ តាមរយៈការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្តក្តី[15]។ អ.វ.ត.ក. នៅខ្វះថវិការាប់សិបលានដុល្លារ នៃចំនួនថវិកាដែលបានអនុម័តយល់ព្រមរបស់ខ្លួន[16]។ ការិយាល័យរដ្ឋបាលបានជម្រាបជូន ដល់ ស.ច.ស. ថា មិនទំនងថា នឹងមានថវិកាបន្ថែមទៀត

---

[12] កថាខណ្ឌ ៧៩ នៃសំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក.។

[13] *ដូចខាងលើ* កថាខណ្ឌ ៨៦-៨៧។

[14] *ដូចខាងលើ* កថាខណ្ឌ ៧៥។

[15] *ដូចខាងលើ* កថាខណ្ឌ ២។

[16] *ដូចខាងលើ*។

សម្រាប់ឆ្នាំ ២០១៧ ឬ ថាកម្រិតថវិកានឹងកើនឡើង បន្ទាប់ពីឆ្នាំ ២០១៧ នោះដែរ[17]។ ភាពធ្ងន់ធ្ងរ នៃស្ថានភាពគឺថា "នៅពេលដែលអស់ថវិកាសម្រាប់ចៅក្រម និង បុគ្គលិកអន្តរជាតិ ពេលនោះកិច្ច សន្យាការងាររបស់ពួកគាត់ត្រូវបញ្ចប់ហើយ ភាគីអន្តរជាតិនឹងត្រូវបាត់រូបរាងផងដែរ។ ករណី នេះដូចគ្នានឹងភាគីជាតិដែរ"[18]។

២៣. ស.ច.ស. ព្រួយបារម្ភថា "ចក្ខុវិស័យអំពីធនធានថវិកា នាពេលអនាគតដែលមិនច្បាស់លាស់ទាល់ តែសោះ សម្រាប់កិច្ចដំណើរការនីតិវិធី *បន្ទាប់ពី* ចេញដីកាដំណោះស្រាយ ទោះជាលើកលែងការ ចោទប្រកាន់ក្តី ឬ បញ្ជូនទៅជំនុំជម្រះក្តី ក៏នាំឱ្យមានបញ្ហាចោទយ៉ាងសំខាន់ អំពីភាពយុត្តិធម៌ សម្រាប់កិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការ..."[19]។ ស.ច.ស. បានសម្រេចថា គឺជារឿងដែល មិនអាចទទួលយកបាន ក្នុងការចេញដីកាដំណោះស្រាយ ជាពិសេសដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើមានលទ្ធភាពខ្ពស់ដែលថា នឹងមិនមានថវិកាគ្រប់គ្រាន់ សម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់ ដីកាដំណោះស្រាយ "ហើយបន្តទៅមុខនេះទៀត នៅតែមានមន្ទិលយ៉ាងខ្លាំង អំពីការចូលរួមរបស់ ភាគីទាំងអស់ នៅក្នុងសវនាការចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង និង [អង្គជំនុំជម្រះតុលាការ កំពូល]"[20]។

២៤. ស.ច.ស. ក៏មិនបានដឹង អំពីយុទ្ធសាស្ត្របញ្ចប់ណាមួយដែរ៖ ថាតើមានវេទិកាដែរឬទេ សម្រាប់ ជនត្រូវចោទធ្វើការជំទាស់ទៅនឹងការចោទប្រកាន់ប្រឆាំងពួកគេ ប្រសិនបើប្រតិបត្តិការរបស់ អ.វ.ត.ក. ត្រូវបញ្ចប់ភ្លាមៗនោះ[21]។ ការទុកចោលកិច្ចស៊ើបអង្កេត ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនទាន់បញ្ចប់៖ ឱ្យនៅអន្ទងតាមជនត្រូវចោទ ដោយការគ្រាន់តែបញ្ចប់ប្រតិបត្តិការរបស់ អ.វ.ត.ក. នោះ គឺមិនសមស្របតាមតម្រូវការជាមូលដ្ឋានរបស់នីតិរដ្ឋឡើយ[22]។

២៥. ស.ច.ស. បានទទួលស្គាល់ថា ពួកគាត់មិនអាចគ្រាន់តែចេញដីកាដំណោះស្រាយហើយ គឺអាច លាងសម្អាតដៃបញ្ចប់បញ្ហាបាននោះទេ។ "ក្នុងនាមជាចៅក្រមស៊ើបសួរ ចក្ខុវិស័យរបស់យើង មិន

---

[17] *ដូចខាងលើ*។

[18] កថាខណ្ឌ ៥៦ នៃសំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក.។

[19] *ដូចខាងលើ* កថាខណ្ឌ ៥២។

[20] *ដូចខាងលើ* កថាខណ្ឌ ៥៣។

[21] *ដូចខាងលើ* កថាខណ្ឌ ៥៥។

[22] *ដូចខាងលើ* កថាខណ្ឌ ៥៤។

អាចផ្តោត តែនៅត្រឹមក្របខណ្ឌពេលវេលា ដែលចេញដីកាដំណោះស្រាយរួចហើយ ថាជាពេលវេលាចុងបញ្ចប់ នៃអាណត្តិការងាររបស់យើងទេ”[23]។ ការងាររបស់ ស.ច.ស. គឺពាក់ព័ន្ធជាមួយការកសាងសំណុំរឿងដំបូង ដែលបង្កើតជាដំណើរការនៃការជំនុំជម្រះក្តីនៅសាលាដំបូង និងតុលាការកំពូលដោយជោគជ័យ ប្រសិនបើចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[24]។ ការទទួលស្គាល់ដែលស្របតាមច្បាប់របស់ ស.ច.ស. ចំពោះភារកិច្ចរបស់ពួកគាត់ ក្នុងការធានានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ គឺមិនបញ្ចប់នៅត្រឹមការចេញដីកាដំណោះស្រាយឡើយ។

គ. ការិយាល័យរដ្ឋបាល អ.ស.ប. ប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប. មិនបានឆ្លើយតបចំពោះការព្រួយបារម្ភរបស់ ស.ច.ស.

២៦. ចម្លើយតបរបស់ការិយាល័យរដ្ឋបាល អ.ស.ប. ប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប. បានបង្ហាញថា មិនមានផែនការស្វែងរកថវិកាបែបបរិសកម្ម និង បានគិតគូរដោយល្អិតល្អន់ ដើម្បីបន្តប្រតិបត្តិការរបស់ អ.វ.ត.ក. នោះឡើយ ជាពិសេសនៅក្នុងករណីដែលមានសំណុំរឿងមួយ ឬ ពីរ ឬ ទាំងបី នៃរឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/២ ត្រូវបញ្ជូនទៅជំនុំជម្រះនោះ។ មិនមានការផ្តល់ព័ត៌មានលម្អិត អំពីការពិភាក្សាលើថវិកាដែលកំពុងដំណើរការឡើយ។ ស.ច.ស. មិនបានទទួលព័ត៌មាន អំពីពេលវេលា ឬ ការប៉ាន់ប្រមាណតម្លៃណាមួយឡើយ។ មិនមានការធានាអះអាងគួរឱ្យជឿជាក់ណាមួយថា នឹងមានថវិកាសម្រាប់ការជំនុំជម្រះក្តីនៅសាលាដំបូង និងតុលាការកំពូល ដែលគោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទឡើយ។

២៧. ក្រៅពីការបញ្ជាក់បំភ្លឺថា មិនមានការរៀបចំយុទ្ធសាស្ត្របញ្ចប់នោះ[25] ការិយាល័យរដ្ឋបាលមិនបានឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់ ស.ច.ស. ឡើយ។ ការិយាល័យរដ្ឋបាលមិនបានផ្តល់ព័ត៌មានជាក់លាក់ អំពីការពិភាក្សាលើថវិកាដែលកំពុងដំណើរការ ជាមួយ អ.ស.ប. រាជរដ្ឋាភិបាលកម្ពុជា និង ប្រទេសផ្តល់ជំនួយឡើយ។ ជាជំនួសវិញ ការិយាល័យរដ្ឋបាលបានផ្តល់ចម្លើយ “ដែលមិនមែន

[23] *ដូចខាងលើ* កថាខណ្ឌ ៥២។

[24] កថាខណ្ឌ ៥២ នៃសំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក.។

[25] កថាខណ្ឌ ២៦ នៃមតិយោបល់របស់ការិយាល័យរដ្ឋបាល។

ជាចម្លើយ"៖ ជាការសង្ខេបបច្ចេកទេសនៃដំណើរការអនុម័តលើថវិកាទៅវិញ[26]។ ទោះបីជាបានទទួលស្គាល់អំពីការខ្វះខាតថវិការាប់លានដុល្លារសម្រាប់ឆ្នាំ ២០១៧ ក៏ដោយ ក៏ការិយាល័យរដ្ឋបាលបានអះអាងថា អ្វីៗគឺល្អប្រសើរ៖ ថវិកាដែលបានគ្រោងនឹងមានគ្រប់គ្រាន់ សម្រាប់ឱ្យ អ.វ.ត.ក. បញ្ចប់អាណត្តិការងាររបស់ខ្លួន កិច្ចប្រឹងប្រែងស្វែងរកថវិកាត្រូវបានធ្វើឡើង ដើម្បីធានាឱ្យមានថវិកាសម្រាប់ឆ្នាំ ២០១៧ និង ឆ្នាំបន្ទាប់ ហើយថវិកា និង មូលនិធិសម្រាប់ការជំនុំជម្រះក្តីនៅក្នុងរឿងក្តី ០០៣ និង រឿងក្តី ០០៤ នឹងត្រូវពិចារណានៅក្នុងដំណើរការកំណត់ថវិកាសម្រាប់ឆ្នាំ ២០១៨-២០១៩[27]។

២៨. ទោះបីជាបានអះអាងថានៅតែបន្ត "ប្តេជ្ញាយ៉ាងមុឺងម៉ាត់" ដើម្បីធានាឱ្យមានថវិកាសម្រាប់ អ.វ.ត.ក. ក៏ដោយ[28] ក៏ អ.ស.ប. ប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប. (ដែលដាក់ជូនទស្សនៈរបស់ពួកគេ តាមរយៈការិយាល័យរដ្ឋបាល) បានទទួចថា៖

ក. ស.ច.ស. គួរផ្តោតលើសេចក្តីសម្រេចទាក់ទងនឹងការស៊ើបអង្កេត ដោយ ស.ច.ស. មិនមានសិទ្ធិអំណាចក្នុងការសម្រេចលើបញ្ហាហិរញ្ញវត្ថុឡើយ ហើយការព្រួយបារម្ភផ្នែកហិរញ្ញវត្ថុដែលនៅឃ្លាសពីការចេញដីកាដំណោះស្រាយ គឺសម្រាប់តែអង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូលប៉ុណ្ណោះ ប្រសិនបើមាន[29]។

ខ. មិនមានវិបត្តិហិរញ្ញវត្ថុឡើយ[30]។

គ. មិនមានអ្វីជាពិសេសអំពីស្ថានភាពថវិការបស់ អ.វ.ត.ក. ឡើយ (ការមិនមានការធានាផ្នែកហិរញ្ញវត្ថុ គឺជាបទដ្ឋានសម្រាប់សាលាជម្រះក្តី និង តុលាការព្រហ្មទណ្ឌអន្តរជាតិ (ឬ មានលក្ខណៈអន្តរជាតិ) សូម្បីតែក្រោមគំរូនៃការរួមចំណែកថវិកាជាប្រចាំក្តី ក៏រដ្ឋជាសមាជិកមិនបានទូទាត់គ្រប់ពេល ទៅតាមកាតព្វកិច្ចរបស់ខ្លួននោះដែរ)[31]។

---

[26] *ដូចខាងលើ* កថាខណ្ឌ ២១-២៣។

[27] *ដូចខាងលើ* កថាខណ្ឌ ១០ កថាខណ្ឌ ២៤-២៥។

[28] សេចក្តីសង្កេតរបស់ក្រុមប្រទេសផ្តល់ជំនួយ ទំព័រ ១-២។

[29] កថាខណ្ឌ ៦ នៃសេចក្តីសង្កេតរបស់ អ.ស.ប.។

[30] *ដូចខាងលើ* កថាខណ្ឌ ១៦។ កថាខណ្ឌ ១០ កថាខណ្ឌ ២៤ នៃមតិយោបល់របស់ការិយាល័យរដ្ឋបាល។

[31] *សូមមើល* កថាខណ្ឌ ១៤-១៥ នៃសេចក្តីសង្កេតរបស់ អ.ស.ប.។ កថាខណ្ឌ ៨ នៃសេចក្តីសង្កេតរបស់អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប.។

ឃ. មិនមានលក្ខខណ្ឌតម្រូវផ្លូវច្បាប់ ដើម្បីធានាឱ្យមានថវិកាសម្រាប់ អ.វ.ត.ក. ឡើយ[32]។

ង. មិនអាចមានការធានាឱ្យមានឡើយ ដោយសារតែវដ្តថវិការបស់រដ្ឋសមាជិក អ.ស.ប. និងប្រទេសផ្តល់ជំនួយ មានការប្រែប្រួល[33]។ និង

ច. សេចក្តីសម្រេចផ្តល់ថវិកា គឺមិនមានចេតនាដើម្បីគាបសង្កត់ដល់កិច្ចដំណើរការនីតិវិធីឡើយ[34]។

ឃ. ស.ច.ស. បានពន្យារពេល ចេញសេចក្តីសម្រេចលើបញ្ហាថាតើត្រូវផ្អាកកិច្ចដំណើរការនីតិវិធីដែរឬយ៉ាងណា ដោយរង់ចាំការវិវឌ្ឍន៍បន្តទៀត

២៩. ការបង្ហាញរបស់ការិយាល័យរដ្ឋបាល អ.ស.ប. ប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប. មិនធ្វើឱ្យ ស.ច.ស. មានការផ្លាស់ប្តូរឡើយ។ ស.ច.ស. បានចេញមុខបញ្ជាក់បំភ្លឺអំពីមូលហេតុ និង អំពីមូលដ្ឋានគតិយុត្តិ ដែលពួកគាត់ដាក់ចេញនូវសំណើនោះ។ តាមរយៈការចេញមុខបែបនេះ ស.ច.ស. បានបង្ហាញថា តើអ្នកទទួលខុសត្រូវលើបញ្ហាថវិកា អ.វ.ត.ក. ទទួលបានដំណឹងដោយរបៀបណា ចាប់តាំងពីខែតុលា ឆ្នាំ ២០១៦ មក អំពីវិបត្តិហិរញ្ញវត្ថុរបស់ អ.វ.ត.ក. និង លទ្ធភាពដែលកិច្ចដំណើរការនីតិវិធីអាចត្រូវបានផ្អាក[35]។ សំណើរបស់ ស.ច.ស. មិនគួរជាបញ្ហាគួរឱ្យភ្ញាក់ផ្អើលឡើយ[36]។

៣០. ស.ច.ស. បានឆ្លើយតបយ៉ាងច្បាស់លាស់ទៅនឹងទម្លឹករណ៍របស់ការិយាល័យរដ្ឋបាល អ.ស.ប. ប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប. ថា៖ **ក.** ស.ច.ស. មិនមានអំណាចចេញដីកាសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី **ខ.** ស.ច.ស. មិនមានអំណាចចេញសេចក្តីសម្រេចទៅលើបញ្ហាហិរញ្ញវត្ថុ **គ.** ស.ច.ស. មិនបានព្រួយបារម្ភ អំពីបញ្ហាហិរញ្ញវត្ថុនៅដំណាក់កាលបន្ទាប់ពីដំណាក់កាលដីកាដំណោះស្រាយ **ឃ.** មិនមានវិបត្តិហិរញ្ញវត្ថុ **ង.** តុលាការ

---

[32] កថាខណ្ឌ ១៣ នៃសេចក្តីសង្កេតរបស់ អ.ស.ប.។ សេចក្តីសង្កេតរបស់ក្រុមប្រទេសផ្តល់ជំនួយ ចំពីរ ២។

[33] សេចក្តីសង្កេតរបស់ក្រុមប្រទេសផ្តល់ជំនួយ ចំពីរ ១។ កថាខណ្ឌ ៣ នៃសេចក្តីសង្កេតរបស់អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប.។

[34] សេចក្តីសង្កេតរបស់ក្រុមប្រទេសផ្តល់ជំនួយ ចំពីរ ២។

[35] កថាខណ្ឌ ២១ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។

[36] *សូមមើល* សេចក្តីសង្កេតរបស់ក្រុមប្រទេសផ្តល់ជំនួយ ចំពីរ ២៖ "ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗមានការភ្ញាក់ផ្អើល និងព្រួយបារម្ភចំពោះសំណើសុំមតិយោបល់របស់សហចៅក្រមស៊ើបអង្កេត ដែលបានចេញកាលពីថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ កន្លងមក"។

ចាំបាច់ត្រូវរស់នៅជាមួយនឹងបញ្ហាថវិកាដែលមិនប្រាកដប្រជានេះ ហើយរដ្ឋជាសមាជិកមិនសុទ្ធតែបង់ថវិកាទាន់ពេលវេលាឡើយ សូម្បីតាមរយៈគំរូនៃការរួមចំណែកថវិកាជាប្រចាំក្តី **ច.** មិនមានកាតព្វកិច្ចផ្លូវច្បាប់ ដើម្បីផ្តល់ថវិកាដល់តុលាការ នៅក្នុងអាយុកាលរបស់តុលាការឡើយ **ឆ.** មិនអាចឱ្យមានការធានាលើបញ្ហាថវិកាឡើយ ដោយសារតែវដ្តថវិកា **ជ.** ប្រទេសផ្តល់ជំនួយមិនមានបំណង ជះឥទ្ធិពលលើកិច្ចដំណើរការនីតិវិធីឡើយ និង **ឈ.** មិនមានយុទ្ធសាស្ត្របញ្ចប់[37]។

៣១. ***ស.ច.ស. មិនមានអំណាច ចេញដីកាសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី***៖ ស.ច.ស. បានចេញសំណើរបស់ខ្លួន បន្ទាប់ពីបានពិចារណា និង ពិភាក្សាយ៉ាងប្រុងប្រយ័ត្ន។ ស.ច.ស. នឹងមិនចាត់វិធានការខ្លាំងក្លាបែបនេះទេ ប្រសិនបើ ស.ច.ស. មិនប្រាកដ អំពីសិទ្ធិរបស់ខ្លួន ក្នុងការផ្អាកកិច្ចដំណើរការនីតិវិធី[38]។

៣២. ***ស.ច.ស. មានសិទ្ធិអំណាច ក្នុងការព្រួយបារម្ភអំពីបញ្ហាហិរញ្ញវត្ថុ***៖ ស.ច.ស. បានបញ្ជាក់ថា ទង្វើករណ៍ដែលថា ស.ច.ស. មិនមានអំណាច ក្នុងការសម្រេចលើបញ្ហាហិរញ្ញវត្ថុ ដែលជា "លេសបញ្ឆោត"។ ស.ច.ស. បានសម្រេចថា "យើងមានអំណាចបញ្ឈប់ការស៊ើបសួរទាំងអស់ ដោយសារមានការរំលោភបំពានជាសារវន្ត លើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាក់ស្តែងដោយសារការបំបាត់ចោលការិយាល័យរបស់យើងក្នុងនាមជា ស.ច.ស."[39]។

៣៣. ***ស.ច.ស. ត្រូវតែព្រួយបារម្ភអំពីបញ្ហាហិរញ្ញវត្ថុ នៅបន្ទាប់ពីដំណាក់កាលដីកាដំណោះស្រាយ***៖ ស.ច.ស.បានបញ្ជាក់ឡើងវិញថា ខ្លួនត្រូវតែព្រួយបារម្ភអំពីបញ្ហាហិរញ្ញវត្ថុ នៅបន្ទាប់ពីដំណាក់កាលដីកាដំណោះស្រាយ បើទោះបីជាចៅក្រមអង្គជំនុំជម្រះដទៃ ក៏នឹងត្រូវធានាឱ្យមានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដល់ជនត្រូវចោទ នៅទូទាំងកិច្ចដំណើរការនីតិវិធីក៏ដោយ[40]។

៣៤. ***មានវិបត្តិហិរញ្ញវត្ថុ***៖ ស.ច.ស. បានបង្ហាញពីភាពមិនស្មោះត្រង់ នៃការអះអាងបែបនេះ៖

ក. *ការិយាល័យរដ្ឋបាល*៖ ការិយាល័យរដ្ឋបាលបានជូនដំណឹងដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស.") ជាច្រើនលើកនៅក្នុងអំឡុងពេលចចារថវិកាឆ្នាំ ២០១៧ ថា "តាមប្រវត្តិ

[37] កថាខណ្ឌ ៧ កថាខណ្ឌ ១៦-៦០ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។

[38] *ដូចខាងលើ* កថាខណ្ឌ ១៦។

[39] *ដូចខាងលើ* កថាខណ្ឌ ១៧។

[40] *ដូចខាងលើ* កថាខណ្ឌ ១៨។

តុលាការនេះ ចក្ខុវិស័យអំពីថវិកាមិនដែលមិនល្អបែបនេះទេ ហើយការចរចាថវិកានាពេលអនាគតនឹងក្លាយជាបញ្ហាលំបាកហួសពីកម្រិតធម្មតា នៃការខិតខំប្រឹងប្រែង ហើយតុលាការពិតជាស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ អាចធ្លាក់ទៅជាជនរងគ្រោះ ដោយសារការបិទបញ្ចប់ដោយចៃដន្យ ដោយគ្រាន់តែមូលហេតុថា ថវិកាអាចឈប់បន្ត”[41]។ ការិយាល័យរដ្ឋបាលក៏បានជម្រាបដល់ ក.ស.ច.ស. ដោយយោងតាមការផ្អាកជ្រើសរើសបុគ្គលិកថា បុគ្គលិក ក.ស.ច.ស. ដែលទទួលបានការងារនៅកន្លែងផ្សេង គួរទទួលយកការងារនោះទៅ[42]។

ខ. *ប្រទេសផ្តល់ជំនួយ*៖ ស.ច.ស. បានជួបជាមួយក្រុមប្រទេសផ្តល់ជំនួយ ហើយព្យាយាមពន្យល់អំពីក្របខ័ណ្ឌការងាររបស់ ស.ច.ស. បញ្ហាក់បំភ្លឺនូវការយល់ច្រឡំទាំងឡាយ ឆ្លើយតបនឹងសំណួរ និង ជំរុញទឡ្ហីករណ៍របស់ខ្លួន ដើម្បីឱ្យមានថវិកាគ្រប់គ្រាន់[43]។ ស.ច.ស. បែរជាត្រូវជួបនឹងភាពអវិជ្ជា៖ “មតិយោបល់ដំបូងដែលបានបង្ហាញ គឺរិះគន់លើល្បឿននៃការស៊ើបសួរ ចំណែកឯមតិមួយទៀត ពាក់ព័ន្ធនឹងការទប់ទល់ជាមួយនឹងយុទ្ធសាស្ត្រពន្យារពេលរបស់មេធាវីការពារក្តី”[44]។

គ. *អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប.*៖ ការបង្ហាញរបស់អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប. បានបង្ហាញនូវភាពផ្ទុយគ្នាពី “អ៊ុំមែលដោយស្មោះត្រង់មួយចំនួន” ដែលគាត់បានផ្ញើជូន ស.ច.ស. ដែល “បង្ហាញរូបភាពថ្នាក់អន្តរជាតិ ស្រដៀងគ្នានឹងការសន្ទនាពីដើមជាមួយការិយាល័យរដ្ឋបាល”[45]។

៣៥. ***តុលាការមិនអាចរស់នៅជាមួយបញ្ហាថវិកាមិនប្រាកដប្រជាបានឡើយ***៖ ស.ច.ស. យល់ឃើញថា ហេតុផលដែលថា រដ្ឋនានាមិនបានទូទាត់ទៀងទាត់ចំណែកថវិការបស់ខ្លួន តាមគំរូនៃការរួមចំណែកថវិកាជាប្រចាំនោះ គឺជាការទទួលស្គាល់ពីការខកខានរបស់រដ្ឋ មិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួន តាមសន្ធិសញ្ញា និង សេចក្តីសម្រេច ដែលពួកគេបានបង្កើតដោយខ្លួនឯង[46]។

---

[41] *ដូចខាងលើ* កថាខណ្ឌ ២៥។

[42] *ដូចខាងលើ*។

[43] កថាខណ្ឌ ២៣ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។

[44] *ដូចខាងលើ*។

[45] *ដូចខាងលើ* កថាខណ្ឌ ២៦។

[46] *ដូចខាងលើ* កថាខណ្ឌ ២៨។

៣៦. ***មានកាតព្វកិច្ចផ្លូវច្បាប់ ក្នុងការផ្តល់ថវិកាដល់តុលាការ សម្រាប់អំឡុងពេលអាយុកាលរបស់តុលាការ***៖ ស.ច.ស. បានសង្កត់ធ្ងន់ថា ការផ្តល់ថវិកា "ដោយស្ម័គ្រចិត្ត" គឺជាមូលនិធិដែលត្រូវបំពេញដោយរដ្ឋជាសមាជិក អ.ស.ប. មួយចំនួន ដែលផ្ទុយពីការរួមចំណែកថវិកាជាប្រចាំ ដែលត្រូវបំពេញដោយរដ្ឋជាសមាជិកទាំងអស់នោះ នេះមិនមែនមានន័យថា ជាការផ្តល់ថវិកាតាម "ជម្រើស" នោះទេ[47]។ ប្រសិនបើកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. នៅមានជាធរមាន ភាគីនៃកិច្ចព្រមព្រៀងមានកាតព្វកិច្ច ក្នុងការអនុវត្តឱ្យបានល្អនូវកាតព្វកិច្ចរបស់ពួកគេ[48]។

៣៧. ***រដ្ឋថវិកាប្រែប្រួលមិនមែនជាមូលហេតុការពារខ្លួន ក្នុងការទូទាត់តាមកាតព្វកិច្ចដែលត្រូវបង់ឡើយ***៖ ស.ច.ស. យល់ឃើញថា ពួកគាត់មិនអាចផ្តល់ទម្ងន់ ដល់រដ្ឋថវិកាដែលមានការប្រែប្រួល ថាជាមូលហេតុសម្រាប់ការទូទាត់របស់រដ្ឋ ចំពោះកាតព្វកិច្ចដែលខ្លួនត្រូវបង់ឡើយ។ វាជាកាតព្វកិច្ចទូទៅផ្លូវច្បាប់ ដែលរដ្ឋមួយត្រូវទូទាត់ចំពោះកាតព្វកិច្ច ដែលខ្លួនត្រូវបង់។ នីតិវិធីថវិកាផ្ទៃក្នុងមិនមែនជាមូលហេតុការពារខ្លួនឡើយ[49]។

៣៨. ***ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ បានប៉ុនប៉ងជះឥទ្ធិពល ទៅលើកិច្ចដំណើរការនីតិវិធី***៖ ស.ច.ស. មិនយល់ស្របជាមួយ "ការបង្ហាញសេចក្តីសោកស្តាយហួសហេតុ" ដែលថាក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ឬ សមាជិករបស់ខ្លួនមិនបានព្យាយាមជះឥទ្ធិពលទៅលើការស៊ើបអង្កេតតាមផ្លូវតុលាការឡើយ[50]។ ស.ច.ស. បានលើកឡើងនូវឧទាហរណ៍ នៃការជះឥទ្ធិពលដោយផ្ទាល់ដោយសមាជិកមួយនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ គឺសហរដ្ឋអាមេរិក ទាក់ទងនឹងការចងក្តាប់ថវិកាទៅនឹងដីកាបញ្ជូនរឿងក្តី មាស មុត ទៅជំនុំជម្រះ[51]។ "ប្រសិនបើយើងចោទប្រកាន់ មាស មុត បញ្ជូនទៅជំនុំជម្រះ អ្នកសង្កេតការណ៍តុលាការអាចនិយាយថា យើងចុះញ៉ែមធ្វើតាមការទាមទាររបស់សហរដ្ឋអាមេរិក ហើយប្រសិនបើយើងលើកលែងការចោទប្រកាន់ ឬ មិនចោទប្រកាន់បញ្ជូនទៅជំនុំជម្រះវិញ យើងមានហានិភ័យអាចបាត់បង់ម្ចាស់ជំនួយដ៏សំខាន់មួយសម្រាប់ អ.វ.ត.ក."[52]។ ស.ច.ស. ក៏បានរំឭកផងដែរ ពីការជ្រៀតជ្រែកដែលមិនជាផ្លាល់ខ្លាំង ចូលទៅក្នុងការសម្រេច

---

[47] *ដូចខាងលើ* កថាខណ្ឌ ៣១។

[48] *ដូចខាងលើ* កថាខណ្ឌ ៣០-៣២។

[49] កថាខណ្ឌ ៣៣ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។

[50] *ដូចខាងលើ* កថាខណ្ឌ ៤៤។

[51] *ដូចខាងលើ* កថាខណ្ឌ ៤៥-៤៧។

[52] *ដូចខាងលើ* កថាខណ្ឌ ៤៨។

របស់តុលាការ៖ គឺសំណើមានលក្ខណៈច្រំដែល និង ជ្រៀតជ្រែក នៅក្នុងដំណើរការថវិកាឆ្នាំ ២០១៦[53]។

៣៩. ***មិនមានយុទ្ធសាស្ត្រសម្រាប់បញ្ចប់៖*** ស.ច.ស. បានកត់សម្គាល់ថា ដោយសារតែមិនមានយុទ្ធសាស្ត្រសម្រាប់បញ្ចប់ កង្វះថវិកានឹងបណ្តាលឱ្យ "កិច្ចដំណើរការនីតិវិធីដែលមិនទាន់ចប់នេះបរាជ័យដោយគ្មានច្បាប់ទម្លាប់ និង ជាប់គាំងដោយគ្មានច្បាប់ចែង"[54]។

៤០. ដោយពិចារណាឃើញថា មានការផ្តល់ថវិកាយ៉ាងល្មើនមួយចំនួន ចាប់តាំងពីពេលមានសំណើរបស់ ស.ច.ស. សុំមតិយោបល់នោះ[55] ហើយដោយចម្លើយតបរបស់ អ.ស.ប. និង ក្រុមប្រទេសផ្តល់ជំនួយមិនបានបង្ហាញឱ្យឃើញពីការផ្តាច់ខ្លួនចេញទាំងស្រុង ពីការព្រួយបារម្ភរបស់ ស.ច.ស. ទើប ស.ច.ស. បានពន្យារពេលចេញសេចក្តីសម្រេចថា តើត្រូវផ្អាកកិច្ចដំណើរការនីតិវិធីដែរឬយ៉ាងណា ដោយរង់ចាំមើលការវិវឌ្ឍន៍បន្តទៅមុខទៀត[56]។ ថវិកាចាំបាច់ត្រូវតែបំពេញបាន តាមការតម្រូវរបស់តុលាការ ដូចមានចែងនៅក្នុងថវិកានាពេលខាងមុខ ហើយចាំបាច់ត្រូវមានការធានាឱ្យអនុវត្តតាមឆាប់រហ័ស និង អាចជឿជាក់បាន[57]។

---

[53] *ដូចខាងលើ* កថាខណ្ឌ ៤៩-៥៥។

[54] *ដូចខាងលើ* កថាខណ្ឌ ៥៧។

[55] *សូមមើល* កថាខណ្ឌ ៦៣ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា៖ "នាពេលថ្មីៗនេះ តាមរយៈ *សារព័ត៌មានភ្នំពេញប៉ុស្តិ៍* យើងបានដឹងថា សហភាពអឺរ៉ុប បានបង្ហាញឱ្យឃើញថា បានសន្យាផ្តល់ថវិកាចំនួន ១០ លានអឺរ៉ូ ដល់ អ.វ.ត.ក សម្រាប់ទូទាត់ចំណាយរបស់តុលាការរហូតដល់ឆ្នាំ ២០១៩។ នាពេលថ្មីៗនេះ យើងក៏ទទួលបានដំណឹងថា រដ្ឋាភិបាលជប៉ុន បានប្រកាសផ្តល់ជំនួយថ្មីចំនួនជាង ១.២ លានដុល្លារ ដល់ភាគីអន្តរជាតិនៅ អ.វ.ត.ក. សម្រាប់ឆ្នាំសារពើពន្ធ ២០១៧"។ ខណៈ ស.ច.ស. សូមស្វាគមន៍ការសន្យា និង ជំនួយទាំងនេះ ស.ច.ស. យល់ឃើញថា "ដោយគិតពីការដែលអាចមានផលប៉ះពាល់រំខានបណ្តាលមកពីកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះទាក់ទងនឹងសំណើនោះ គឺមិនគួរ ហើយក៏មិនមានប្រសិទ្ធផលដែរដែលយើងបែរជាត្រូវដឹងដំណឹងអំពីការសន្យារបស់សហភាពអឺរ៉ុប តាមរយៈប្រព័ន្ធផ្សព្វផ្សាយទៅវិញ មិនមែនតាមរយៈការិយាល័យរដ្ឋបាល (ឬ ប្រទេសផ្តល់ជំនួយសំខាន់ៗ)។ ... ហេតុនេះ ការបង្កើនតម្លាភាព និង ការជូនដំណឹងភ្លាមៗអំពីការវិវឌ្ឍន៍ថវិកា-ជាបញ្ហាមួយដែលយើងបានផ្តល់តម្រុយថា មានសារសំខាន់ណាស់សម្រាប់សំណុំរឿងទាំងអស់នោះ គួរតែជាបញ្ហាសំខាន់ណាស់ចំពោះការិយាល័យរដ្ឋបាល នាពេលខាងមុខទៀត"។ *ដូចខាងលើ*។ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[56] *ដូចខាងលើ* កថាខណ្ឌ ៦១-៦៣ កថាខណ្ឌ ៦៥។

[57] *ដូចខាងលើ* កថាខណ្ឌ ៦៦។

ង. ថវិកាដែលបានគ្រោង នឹងមិនបំពេញបានតាមតម្រូវការរបស់ អ.វ.ត.ក. ទេ ហើយមិនមានការធានាឱ្យមានការគោរពតាមឆាប់រហ័ស និង គួរឱ្យជឿជាក់បានពីសំណាក់ប្រទេសផ្តល់ជំនួយ

៤១. ថវិកាដែលមិនមានការធានា និង មិនអាចជឿជាក់បាន កង្វះខាត និង ការផ្លាស់ប្តូរបុគ្គលិក ព្រមទាំងការពន្យារពេលដែលបណ្តាលមកពីបញ្ហាទាំងនេះ (និង ប្រហែលជាការបញ្ឈប់កិច្ចដំណើរការនីតិវិធី ដោយគ្មានសណ្តាប់ធ្នាប់) គឺសុទ្ធតែស្ថិតក្នុងការព្យាករណ៍ទាំងអស់។ "ដំណើរការវិវឌ្ឍន៍ [រឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៥/២] នៅតែបន្តពឹងផ្អែកយ៉ាងខ្លាំងទៅលើកត្តានានា ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ចៅក្រម ជាពិសេស គឺផ្អែកលើថវិកាគ្រប់គ្រាន់ បុគ្គលិកគ្រប់គ្រាន់ ការជ្រើសរើសបំពេញកន្លែងការងារដែលទំនេរ និង ការបកប្រែបានឆាប់រហ័ស"[58]។

៤២. បន្ទាប់ពីមានសេចក្តីសម្រេចរបស់ ស.ច.ស. ពន្យារពេលផ្អាកកិច្ចដំណើរការនីតិវិធី អគ្គលេខាធិការ អ.ស.ប. បានស្នើសុំការឧបត្ថម្ភធនចំនួន ១០,៤ លានដុល្លារ សម្រាប់ឆ្នាំ ២០១៨ ពីព្រោះ "ស្ថានភាពហិរញ្ញវត្ថុរបស់អង្គជំនុំជម្រះវិសាមញ្ញ មិនបានប្រសើរឡើងឡើយ"[59]។ អគ្គលេខាធិការបានកត់សម្គាល់ថា ទោះបីជាមានការប្រឹងប្រែងដើម្បីស្វែងរកថវិកា ដោយក្រុមប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសរបស់អគ្គលេខាធិការក៏ដោយ ក៏កម្រិតនៃការរួមចំណែកដោយស្ម័គ្រចិត្តបានធ្លាក់ចុះជាបន្តបន្ទាប់នៅក្នុងឆ្នាំ ២០១៥ ឆ្នាំ ២០១៦ និង ឆ្នាំ ២០១៧ ហើយ "ត្រូវបានប៉ាន់ប្រមាណថានឹងបន្តធ្លាក់ចុះទៀត"[60]។ "មានការរំពឹងទុកថា ធនធាននឹងត្រូវបានសន្យាផ្តល់ជាដំណាក់កាល និង ក្នុងចំនួនខុសៗគ្នា ដោយតុល្យភាពថវិកាមានមិនគ្រប់គ្រាន់នៅតាមពេលវេលាដើម្បីធានាឱ្យកិច្ចសន្យាការងារបុគ្គលិកមានរយៈពេលសមស្រប"[61]។ អគ្គលេខាធិការក៏បានលើកបង្ហាញថា ដោយមានការខ្វះខាតជាបន្តបន្ទាប់ នៅក្នុងការចូលរួមដោយស្ម័គ្រចិត្ត និង ការថយចុះ

---

[58] កថាខណ្ឌ ២៣ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨។

[59] អគ្គលេខាធិការ អ.ស.ប. សំណើសុំឧបត្ថម្ភធនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ អ.ស.ប. លេខ A/៧២/៣៤១ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧ ("សំណើសុំឧបត្ថម្ភធន ឆ្នាំ២០១៨") កថាខណ្ឌ ៣៨។

[60] *ដូចខាងលើ* កថាខណ្ឌ ២៨។

[61] *ដូចខាងលើ* កថាខណ្ឌ ៣៧។

ទូវទុនបម្រុងសម្រាប់ប្រតិបត្តិការ តែមិនមាន "យន្តការថវិកា ដើម្បីឆ្លើយតបចំពោះយថាភាពប្រតិបត្តិការដែលមិនអាចមើលឃើញមុន"[62]។

៤៣. អ.ស.ប. ទើបបានអនុម័តឧបត្ថម្ភធន ត្រឹមតែ ៨ លានដុល្លារប៉ុណ្ណោះ សម្រាប់ឆ្នាំ ២០១៨ ដោយបានអនុម័តលើអនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាលើបញ្ហាថវិកា និង រដ្ឋបាល ("ACABQ") ដើម្បីកាត់បន្ថយចំណាយ និង តម្រូវឱ្យមានការដាក់ការគ្រប់គ្រងតឹងរ៉ឹងបន្ថែមទៀត ទៅលើការប្រើប្រាស់ថវិការបស់ អ.វ.ត.ក.[63]។ គណៈកម្មាធិការប្រឹក្សាលើបញ្ហាថវិកា និង រដ្ឋបាល បានផ្តល់អនុសាសន៍ថា ថវិកាសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ នៅក្នុងរឿងក្តី ០០៣ រឿងក្តី ០០៤ និងរឿងក្តី ០០៤/២ ត្រូវកាត់បន្ថយពីចំនួន ៥៦៤.៣៧៥ ដុល្លារ ទៅចំនួន ៤៦០.៣១៧ ដុល្លារវិញ ដើម្បីតម្រូវទៅតាមថវិកា ដែលបានបែងចែកទៅឱ្យក្រុមមេធាវីការពារក្តីនីមួយៗ នៅក្នុងរឿងក្តី ០០២/០២[64] ដោយមិនគិតថារឿងក្តីទាំងអស់នេះស្ថិតក្នុងដំណាក់កាលខុសៗគ្នានៃកិច្ចដំណើរការនីតិវិធី ហើយមានតម្រូវការធនធានខុសៗគ្នាដែរនោះទេ[65]។ គណៈកម្មាធិការប្រឹក្សាលើបញ្ហាថវិកា

---

[62] *ដូចខាងលើ*។

[63] មហាសន្និបាត អ.ស.ប. ប្រធានបទពិសេសទាក់ទងនឹងគម្រោងថវិកាដែលត្រូវបានស្នើឡើងសម្រាប់រយៈពេល ២ ឆ្នាំ ឆ្នាំ ២០១៨-២០១៩ ឯកសារ អ.ស.ប. លេខ A/RES/៧២/២៦២ ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៨ ទំព័រ ៥-៦។

[64] មហាសន្និបាត អ.ស.ប. របាយការណ៍ទី៨ របស់គណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីបញ្ហារដ្ឋបាល និង ថវិកា លើគម្រោងថវិកា ដែលត្រូវបានស្នើឡើងសម្រាប់រយៈពេល ២ ឆ្នាំ ឆ្នាំ ២០១៨-២០១៩ ឯកសារ អ.ស.ប. លេខ A/៧២/៧/Add.៧ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៧ ("អនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីបញ្ហារដ្ឋបាល និង ថវិកា") កថាខណ្ឌ ៣០៖ "**គណៈកម្មាធិការប្រឹក្សាយោបល់យល់ឃើញថា ធនធានដែលបានផ្តល់សម្រាប់ជំនួយផ្នែកច្បាប់ដល់ជនជាប់ចោទនីមួយៗ គួរតែមានចំនួនស្មើគ្នា និង គួរតែត្រូវបានកែសម្រួលត្រឹមកម្រិត ដែលបានផ្តល់ក្នុងរឿងក្តី ០០២/០២ ដែលមានចំនួន ៥៦០.៣១៧ ដុល្លារក្នុងមួយឆ្នាំ សម្រាប់ជនជាប់ចោទម្នាក់**"។ (អក្សរដិតនៅក្នុងឯកសារដើម)។

[65] សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងរឿងក្តី ០០២/០២ ដែលត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងរួចហើយ ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវបានរំពឹងថា នឹងចេញសាលក្រមក្នុងត្រីមាសទីពីរ ឆ្នាំ២០១៨។ កថាខណ្ឌ ៦ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។ *រឿងក្តី ន្ឋួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលបានកែប្រែរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២ ខែតុលា ឆ្នាំ ២០១៧ ឯកសារ E457/6/1/1។ *រឿងក្តី ន្ឋួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សារណាបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ (ឯកសារសាធារណៈកាសល្បប ដោយមានឧបសម្ព័ន្ធសម្ងាត់) ចុះថ្ងៃទី ២ ខែតុលា ឆ្នាំ២០១៧ ឯកសារ E457/6/2/3។ *រឿងក្តី ន្ឋួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សារណាបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់ ន្ឋួន ជា ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ E457/6/3/1។ ជនជាប់ចោទក្នុងរឿងក្តី ០០២/០២ នឹងប្តឹងសាទុក្ខក្នុងពេលអាប់ៗនេះ ដែល

និង រដ្ឋបាលក៏បានផ្តល់អនុសាសន៍ឱ្យកាត់បន្ថយថវិកាលើគ្រឿងសង្ហារឹម ឱ្យត្រូវទៅតាមថវិកាឆ្នាំ ២០១៧ ដែលច្បាស់ណាស់ថាមិនបានប្រមើលមើលពីលទ្ធភាពដែលថារឿងក្តីមួយ ឬ ច្រើន នឹងត្រូវបញ្ជូនទៅជំនុំជម្រះនៅសវនាការ[66]។ អនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាលើបញ្ហាថវិកា និង រដ្ឋបាល បានចង្អុលបង្ហាញថា អ.ស.ប. មិនបានប្រមើលមើលពីការជំនុំជម្រះ និង ពីការប្តឹងសាទុក្ខនាពេលអនាគតនៅក្នុងរឿងក្តី ០០៣ រឿងក្តី ០០៤ និងរឿងក្តី ០០៤/២ ឬ ថាប្រសិនបើកិច្ចដំណើរការនីតិវិធីបែបនេះកើតឡើង វិធានការកាត់បន្ថយចំណាយ នឹងត្រូវបានអនុវត្តឡើង ហើយបង្កផលប៉ះពាល់ធ្ងន់ធ្ងរ ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ។

៤៤. ថវិកាឧបត្ថម្ភធនចំនួន ៨ លានដុល្លារ គ្រាន់តែអាចជួយសម្រួលបសម្រួល ដល់ប្រតិបត្តិការដោយមិនមានការរំខាន សម្រាប់ អ.វ.ត.ក. ត្រឹមរយៈពេលប្លន់ខែដំបូងនៃឆ្នាំ ២០១៨ ប៉ុណ្ណោះ ដោយទុកឱ្យថវិកាដែលត្រូវចំណាយបន្តទៀតក្នុងឆ្នាំ ត្រូវបំពេញដោយការចូលរួមដោយស្ម័គ្រចិត្ត ប្រសិនបើមាន[67]។ យោងតាមផែនការបញ្ចប់ការងារចុងក្រោយបំផុតនេះ ការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្ត ត្រូវបានប៉ាន់ប្រមាណថា មានកង្វះខាត សម្រាប់ថវិកាឆ្នាំ ២០១៨ ដល់ទៅរាប់លានដុល្លារ ទាំងខាងភាគីជាតិ និង ខាងភាគីអន្តរជាតិ[68]។ “ការចូលរួមចំណែកថវិកាដោយស្ម័គ្រចិត្ត ត្រូវបានប៉ាន់ប្រមាណនាពេលបច្ចុប្បន្ន ថាមានចំនួន ៩,២២ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និង ចំនួន ០,១៣ លានដុល្លារ សម្រាប់ភាគីជាតិ បើធៀបនឹងថវិកាដែលបានអនុម័តចំនួន ១៨,៩៣ លាន

ត្រូវការធនធានតិចជាងការជំនុំជម្រះ។ នៅក្នុងការជំនុំជម្រះ តម្រូវការធនធានមួយចំនួន គឺពាក់ព័ន្ធនឹងរឿងក្តីជាក់លាក់ និងអាស្រ័យលើ “ចំនួន និង លក្ខណៈនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចជា ... វិសាលភាព និង ភាគស្មុគស្មាញនៃការចោទប្រកាន់”។ សំណើសុំថវិកា អ.វ.ត.ក. សម្រាប់រយៈពេល ២ ឆ្នាំ ឆ្នាំ២០១៨-២០១៩ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៧ (“ថវិកា អ.វ.ត.ក. ឆ្នាំ ២០១៨-២០១៩”) កថាខណ្ឌ ៧១។ *សូមមើលផងដែរ* Richard J. Rogers *ការវាយតម្លៃនៃប្រព័ន្ធជំនួយផ្នែកច្បាប់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* នៅថ្ងៃទី ៤-៥ ខែមករា ឆ្នាំ ២០១៧ កថាខណ្ឌ ២៥៦ *អាចរកបាននៅ* គេហទំព័រ https://www.icc-cpi.int/itemsDocuments/legalAidConsultations-LAS-REP-ENG.pdf។

[66] *សូមមើល* កថាខណ្ឌ ៣១ នៃអនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីបញ្ហារដ្ឋបាល និង ថវិកា៖ **“គណៈកម្មាធិការប្រឹក្សាយោបល់ កត់សម្គាល់ឃើញថា តម្រូវការសម្រាប់គ្រឿងសង្ហារឹម និង សម្ភារ មានចំនួន ២១០៥០០ ដុល្លារ ក្នុងឆ្នាំ ២០១៧។ ដោយពិចារណាលើចំនួនបុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវកាត់បន្ថយចំនួន ២៧ តំណែង ពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៨ គណៈកម្មាធិការយល់ឃើញថា តម្រូវការសម្រាប់គ្រឿងសង្ហារឹម និង សម្ភារ សម្រាប់ឆ្នាំ ២០១៨ គួរត្រូវបានកែតម្រូវមកត្រឹមកម្រិតឆ្នាំ២០១៧”** (អក្សរដិតនៅក្នុងឯកសារដើម)។

[67] កថាខណ្ឌ ១២ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[68] *ដូចខាងលើ*។

ដុល្លារ សម្រាប់ភាគីអន្តរជាតិ និង ចំនួន ៥,៧៩ លានដុល្លារ សម្រាប់ភាគីជាតិក្នុង ឆ្នាំ ២០១៨"[69]។ នៅត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧ ភាគីអន្តរជាតិទើបតែប្រមូលបានចំនួន ០,៤៨ លានដុល្លារ តាមរយៈការចូលរួមដោយស្ម័គ្រចិត្ត[70]។ នៅត្រឹមខែកុម្ភៈ ឆ្នាំ២០១៨ ទើបតែមានការចូលរួមតែមួយគត់ពីសំណាក់ប្រទេសឥណ្ឌា ដែលបានផ្តល់ថវិកាចំនួន ០,០៥ លានដុល្លារទៅភាគីជាតិ[71] ជាបរិមាណដែលគ្រប់គ្រាន់សម្រាប់គ្រប់ដណ្តប់លើចំនួន ១,៣% នៃទឹកប្រាក់ចំនួន ៣,៨ លានដុល្លារ ដែលត្រូវការសម្រាប់បន្តការងារចំនួន ១៦០ កន្លែងរបស់ភាគីជាតិនៅក្នុងឆ្នាំ ២០១៨[72]។

៤៥. ដូចដែលក្រុមប្រទេសផ្តល់ជំនួយ និង អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប. បានអះអាងកន្លងមក គឺមិនអាចធានាបានទាល់តែសោះ ថានៅពេលណាដែលការចូលរួមដោយស្ម័គ្រចិត្តនឹងត្រូវបានផ្តល់មកទាន់ពេលវេលា ដោយសារតែអាទិភាព និង វដ្តថវិកាខុសៗគ្នារបស់រដ្ឋនីមួយៗ[73]។ ដោយពិចារណាទៅលើភាពតឹងតែង និង ការកាត់បន្ថយថវិកា ដែលត្រូវបានអនុវត្តដោយ អ.ស.ប.[74]

---

[69] *ដូចខាងលើ*។

[70] *ដូចខាងលើ*។

[71] *សូមមើល* សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. *រដ្ឋាភិបាលឥណ្ឌាផ្តល់វិភាគទាន ៥០ ០០០ ដុល្លារ ដល់ អ.វ.ត.ក.* ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៨ គេហទំព័រ https://www.eccc.gov.kh/km/articles/rtthaabhipaalinndaaphtlvibhaagdaan-5-myyntullaar-tl-qvtk។

[72] *សូមមើល* កថាខណ្ឌ ១៩ នៃថវិកា អ.វ.ត.ក. ឆ្នាំ ២០១៨-២០១៩៖ "តម្រូវការធនធានសម្រាប់ឆ្នាំ ២០១៨ ដែលមានចំនួន ៣,៥៨ លានដុល្លារ សម្រាប់ការបន្តតំណែងចំនួន ១៦០ តំណែង នៅខាងភាគីជាតិ (D-1 ចំនួន ១៥ តំណែង, P-5 ចំនួន ១ តំណែង, NO-D ចំនួន ២០ តំណែង, NO-C ចំនួន ១៦ តំណែង, NO-B/A ចំនួន ១៧ តំណែង និង បុគ្គលិកជ្រើសរើសក្នុងស្រុក ចំនួន ៩១ តំណែង)"។

[73] សេចក្តីសង្កេតរបស់ក្រុមប្រទេសផ្តល់ជំនួយ ទំព័រ ១។ កថាខណ្ឌ ៣ នៃសេចក្តីសង្កេតរបស់អ្នកជំនាញពិសេសតំណាងអគ្គលេខាធិការ អ.ស.ប.។

[74] *សូមមើល* បេសកកម្ម ស.រ.អ. ប្រចាំនៅ អ.ស.ប. *ឯកអគ្គរដ្ឋទូត Haley ទាក់ទងនឹងការចរចារបស់សហរដ្ឋអាមេរិកលើការកាត់បន្ថយច្រើនសន្ធឹកសន្ធាប់ក្នុងថវិកា អ.ស.ប.* ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៧ តាមគេហទំព័រ https://usun.state.gov/remarks/8243៖ "ថ្ងៃនេះ អង្គការសហប្រជាជាតិបានព្រមព្រៀងលើថវិកាសម្រាប់ឆ្នាំសារពើពន្ធ ២០១៨-២០១៩។ ក្នុងចំណោមជោគជ័យដទៃទៀត សហរដ្ឋអាមេរិកបានចរចាលើការកាត់បន្ថយថវិកាចំនួន ២៨៥ លានដុល្លារ សម្រាប់ថវិកាចុងក្រោយនៃឆ្នាំ២០១៦-២០១៧។ បន្ថែមលើការកាត់បន្ថយការចំណាយដ៏សន្ធឹកសន្ធាប់នេះ យើងបានកាត់បន្ថយមុខងារផ្តល់ការគាំទ្រ និងគ្រប់គ្រងដែលត្រូវបានបំប៉ោង ពង្រឹងការគាំទ្រជាអាទិភាពសំខាន់ៗរបស់ ស.រ.អ. នៅទូទាំងពិភពលោក និង ដាក់បញ្ចូលនូវវិន័យ និង គណនេយ្យភាពបន្ថែម នៅទូទាំងប្រព័ន្ធ អ.ស.ប."។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មាន អ.ស.ប. *ការបញ្ចប់ផ្នែកសំខាន់នៃកិច្ចប្រជុំលើកទី ៧២ មហាសន្និបាតអនុម័តថវិកា ៥,៣៩៧ ពាន់លានដុល្លារ សម្រាប់ឆ្នាំ ២០១៨-២០១៩ ដោយ*

និង យ៉ាងតិចបំផុតក៏រដ្ឋមួយនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ[75] កង្វះឆន្ទៈនយោបាយក្នុងការផ្តល់ថវិកាដល់ អ.វ.ត.ក. គឺមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលឡើយ។

៤៦. ទោះបីជានៅក្នុងពេលដែលកិច្ចខិតខំប្រឹងប្រែង ស្វែងរកថវិកាសម្រាប់តុលាការ មានសកម្មភាពខ្លាំងក្លាបំផុតក៏ដោយ ក៏កង្វះខាតថវិកានៅតែមាន។ នៅក្នុងឆ្នាំ ២០១៣ ថវិកាមានមិនគ្រប់គ្រាន់សម្រាប់ទូទាត់ឱ្យបុគ្គលិកជាតិ ដែលបណ្តាលឱ្យមានការដើរចេញ និង ការធ្វើបាតុកម្ម[76]។ "រាជរដ្ឋាភិបាលកម្ពុជាមិនបានទូទាត់ឱ្យបុគ្គលិកជាតិ ហើយជាច្រើនលើកដែលលេខាធិការដ្ឋាន ចាំបាច់ត្រូវតែជម្រុញដល់ប្រទេសផ្តល់ជំនួយ ដែលបានសន្យាផ្តល់ថវិកាច្បាស់លាស់ជាមួយ អ.ស.ប. ឱ្យបង្វែរការសន្យាទាំងអស់នោះ ទៅឱ្យភាគីជាតិវិញ ដើម្បីធានាវត្តមានរបស់បុគ្គលិកជាតិនៅក្នុងតុលាការ"[77]។ នៅក្នុងសំណើសុំការឧបត្ថម្ភធនសម្រាប់ឆ្នាំ ២០១៨ អគ្គលេខាធិការ អ.ស.ប. បានកត់សម្គាល់ថា ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ "ទោះបីជាមានការខិតខំប្រឹងប្រែងរួមគ្នារបស់ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ លេខាធិការដ្ឋាន និង អ្នកជំនាញពិសេសក៏ដោយ ក៏ការចូលរួមដោយស្ម័គ្រចិត្តសម្រាប់ភាគីអន្តរជាតិ នៅតែបន្តធ្លាក់ចុះដែរ"[78]។

អនុវត្តតាមអនុសាសន៍របស់គណៈកម្មាធិការទីប្រាំ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៧ គេហទំព័រ https://www.un.org/press/en/2017/ga11997.doc.htm។

[75] *សូមមើល* ការិយាល័យគ្រប់គ្រង និង ថវិកា ស.ប.អ. ការសន្សំ និង កំណែទម្រង់សំខាន់ ថវិការបស់រដ្ឋាភិបាល ស.ប.អ. ឆ្នាំសារពើពន្ធ ២០១៨ ទំព័រ ៧១ *អាចរកបាននៅគេហទំព័រ* https://www.whitehouse.gov/wp-content/uploads/2017/11/msar.pdf៖ "សំណើសុំថវិកាដើម្បីបញ្ចប់ ឬ កាត់បន្ថយការផ្តល់មូលនិធិសម្រាប់កម្មវិធី និង អង្គការអន្តរជាតិ ដែលបេសកកម្មរបស់ពួកគេមិននាំឱ្យមានការរីកចំរើនដុំកំភួនដល់គោលនយោបាយការបរទេសរបស់ ស.ប.អ. ឬ បន្ទុកនៃការផ្តល់មូលនិធិនេះមិនត្រូវបានចែករំលែកស្មើគ្នាក្នុងចំណោមរដ្ឋសមាជិក"។ *សូមមើលផងដែរ* ឃុត្តិកម្មថវិកាសភា ស.ប.អ. ក្រសួងការបរទេស ប្រតិបត្តិការបរទេស និង កម្មវិធីពាក់ព័ន្ធ ឆ្នាំសារពើពន្ធ ២០១៨ ទំព័រ ១៧៩ *អាចរកបាននៅគេហទំព័រ* https://www.state.gov/documents/organization/271013.pdf (សំណើសុំការកាត់បន្ថយ ៣១% - ចំនួន ៤៤៧ លានដុល្លារ - នៅក្នុងវិភាគទានរបស់ ស.ប.អ. ដល់អង្គការអន្តរជាតិ ក្នុងការប៉ាន់ប្រមាណឆ្នាំសារពើពន្ធ ២០១៧)។

[76] កថាខណ្ឌ ២៧ នៃសំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[77] *ដូចខាងលើ*។

[78] កថាខណ្ឌ ២៨ នៃសំណើសុំឧបត្ថម្ភធន ឆ្នាំ២០១៨។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ២៥៖ "សកម្មភាពរៃអង្គាសថវិកាពីមុនៗ រួមបញ្ចូលទាំងសន្និសីទសន្យាផ្តល់ថវិកាចំនួនពីរ (ក្នុងឆ្នាំ ២០១០ និង ឆ្នាំ ២០១៣) ការសុំអំពាវនាវជាលាយលក្ខណ៍អក្សររបស់អគ្គលេខាធិការ អ.ស.ប. ទៅរដ្ឋជាសមាជិកទាំងអស់ សំណើទ្វេភាគីរបស់មន្ត្រីជាន់ខ្ពស់ អ.ស.ប. ដល់ប្រទេសម្ចាស់ជំនួយ និង ការសុំអំពាវនាវជាលាយលក្ខណ៍អក្សរពីប្រធាននៃក្រុមប្រទេសម្ចាស់ជំនួយសំខាន់ៗ ទៅបេសកកម្ម

៤៧. ដូចដែលការិយាល័យរដ្ឋបាលបានចង្អុលបង្ហាញ កង្វះបុគ្គលិក និង សូម្បីតែការផ្លាស់ប្តូរបុគ្គលិកបន្តិចបន្តួច ធៀបទៅនឹងវិបត្តិហិរញ្ញវត្ថុរបស់តុលាការជាទូទៅក៏ដោយ ក៏វិធីសាស្ត្របញ្ចប់អណត្តិរបស់តុលាការ ឬ ផែនការការងារ បានប៉ះពាល់ ហើយនឹងប៉ះពាល់ ដល់ពេលវេលាដែលបានគ្រោងទុក និង ការចងចាំជាស្ថាប័នរបស់អង្គជំនុំជម្រះ[79]។ តុលាការអាចត្រឹមតែរំពឹងថា នឹងមានការផ្លាស់ប្តូរបុគ្គលិកកាន់តែច្រើនឡើង ដោយគិតពី "ស្ថានភាពថវិកាមិនប្រាកដប្រជា និង លក្ខណៈបណ្តោះអាសន្នរបស់តុលាការ ដែលកាន់តែជំរុញឱ្យបុគ្គលិក ស្វែងរកការងារដែលមានរយៈពេលវែង និង មានសុវត្ថិភាពជាង"[80]។

៤៨. លទ្ធភាពរបស់តុលាការ ក្នុងការជ្រើសរើសបុគ្គលិកដែលមានគុណវុឌ្ឍិ មានភាពស្មុគស្មាញដោយសារតែតុលាការមិនមានលទ្ធភាពផ្តល់កិច្ចសន្យាការងាររយៈពេលវែង[81] និង ដំណើរការជ្រើសរើស

អចិន្ត្រៃយ៍នៃរដ្ឋសមាជិក នៅទីក្រុងញ៉ូវយ៉ក ឆ្នាំ ២០១៥ មិនទទួលបានជោគជ័យក្នុងការបង្កើតនូវប្រភពថ្មីសំខាន់ៗនៃមូលនិធិឡើយ"។

[79] កថាខណ្ឌ ២៥ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។ *សូមមើលផងដែរ* កថាខណ្ឌ ៥៩ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។ កថាខណ្ឌ ២៥ នៃសំណើសុំឧបត្ថម្ភធន ឆ្នាំ២០១៨ ដែលដកស្រង់កិច្ចប្រជុំប្រចាំត្រីមាសលើកទី៨របស់ថ្នាក់គ្រប់គ្រងអង្គភាពហិរញ្ញវត្ថុ-ជំនួយ អ.ស.ប. សម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម៖កំណត់ហេតុនៃកិច្ចពិភាក្សា ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៧ ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១៧ និង ត្រូវបានដាក់នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៧៖ "ជាឧទាហរណ៍ ការចាកចេញរបស់បុគ្គលិកសំខាន់ៗ ដោយសារស្ថានភាពថវិកាទូទៅ ការខិតកាន់តែជិតនៃអាណត្តិរបស់ការិយាល័យរដ្ឋបាល ឬ ការរៀបចំផែនការអាជីព បង្ហាញពីហានិភ័យធ្ងន់ធ្ងរមួយទៀតដល់តារាងពេលវេលាដែលត្រូវបានរំពឹងទុក"។

[80] កថាខណ្ឌ ៣៨ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៤ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៧។

[81] ក.ស.ច.ស. បានសង្កត់ធ្ងន់ថា មន្ត្រីច្បាប់ និង អ្នកស៊ើបអង្កេតរបស់ខ្លួនមួយចំនួន បានចាកចេញពីការិយាល័យ ដើម្បីទទួលយកការងារដែលមានស្ថេរភាពជាងនេះ។ កថាខណ្ឌ ៥៩ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា។ កថាខណ្ឌ ២៣ នៃសំណើសុំឧបត្ថម្ភធន ឆ្នាំ២០១៨៖ "របាយការណ៍មុនៗរបស់អគ្គលេខាធិការ បានបង្ហាញដល់រដ្ឋសមាជិក អំពីការប្រឈមមុខផ្នែកហិរញ្ញវត្ថុរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលបន្តកើតមានក្នុងឆ្នាំ ២០១៦ និង ឆ្នាំ ២០១៧។ នៅក្នុងឆ្នាំមុនៗ ផលប៉ះពាល់នៃការប្រឈមទាំងនេះ រួមទាំងការបង្កការជ្រើសរើសបុគ្គលិក និង ភាពមិនច្បាស់លាស់របស់បុគ្គលិកដែលមានកិច្ចសន្យាការងារមួយខែៗ ដែលជាសក្តានុពលនៃការធ្វើឱ្យបាត់បង់ការផ្តង់អារម្មណ៍ក្នុងការបំពេញមុខងារសំខាន់ៗ។ បុគ្គលិកភាគីជាតិមិនបានទទួលកិច្ចសន្យាការងារ និង ប្រាក់ខែ សម្រាប់រយៈពេលវែង ដែលជាលទ្ធផល ក្នុងចំណោមនោះ បុគ្គលិកចំនួន ១០០ នាក់ បានដើរចេញពីការងារក្នុងខែកញ្ញា ឆ្នាំ ២០១៣។ ដោយហេតុថា រចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញ តម្រូវឱ្យបុគ្គលិកភាគីជាតិ និង ភាគីអន្តរជាតិ ធ្វើការងារទន្ទឹមគ្នា សកម្មភាពនេះបង្កជាឧបសគ្គធ្ងន់ធ្ងរដល់ការងារទូទៅរបស់តុលាការ"។

បុគ្គលិកដ៏ស្មុគ្រស្មាញរបស់ អ.ស.ប. សម្រាប់តំណែងបុគ្គលិក[82]។ បុគ្គលិកដែលត្រូវបានជ្រើសរើសថ្មី នឹង "ត្រូវការពេលវេលាជាចាំបាច់ ដើម្បីស្គាល់នីតិវិធី និង ភស្តុតាង ដើម្បីធ្វើការលើរឿងក្តីប្រកបដោយប្រសិទ្ធភាព" ដែល "នឹងប៉ះពាល់មិនអាចចៀសរួច ទៅលើការវិវឌ្ឍន៍នៃរឿងក្តីនានា"[83]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ.") បានដឹងយ៉ាងច្បាស់ អំពីផលប៉ះពាល់នៃវិបត្តិថវិការបស់តុលាការ ទៅលើធនធានមនុស្ស ក៏ដូចជាទៅលើក្រុមការងាររបស់គាត់ក្នុងរឿងក្តី ០០៣៖

> បុគ្គលិកទាំងអស់នៅក្នុងក្រុមដើមបានលាឈប់ទាំងអស់ នៅសល់តែមន្ត្រីច្បាប់ម្នាក់ប៉ុណ្ណោះ... ដែលតម្រូវជាចាំបាច់ឱ្យមានការប្រឹងប្រែង ជ្រើសរើសបុគ្គលិកជាបន្ទាន់ និង ការចាត់ចែងថ្មីទៅលើបុគ្គលិកដែលមានស្រាប់ មកពីក្រុមដទៃផ្សេងទៀត ហើយនាំឱ្យមានការខាតបង់នូវពេលវេលាបំពេញការងារ និង ប្រសិទ្ធិភាពការងាររឿងក្តីជាក់ស្តែង៖ បុគ្គលិកដែលបានជ្រើសរើសថ្មី មិនមាននរណាម្នាក់មានចំណេះដឹងជ្រៅជ្រះអំពីរឿងក្តី នៅពេលពួកគេចូលមកធ្វើការ ហើយពួកគេចាំបាច់ត្រូវស្វែងយល់ឱ្យបានច្បាស់ អំពីកិច្ចដំណើរការនីតិវិធី និង ភស្តុតាងដែលមានចំនួនច្រើនលើសលុបនៅក្នុងសំណុំរឿង មុនពេលដែលពួកគេអាចធ្វើការដោយមានប្រសិទ្ធភាព។ ផលប៉ះពាល់ពេញលេញនៃការវិវឌ្ឍន៍នេះ ទៅលើដំណើរការរឿងក្តី ០០៣ គឺមិនមានភាពច្បាស់លាស់នៅឡើយទេ ប៉ុន្តែបច្ចុប្បន្ននេះពេលវេលាបន្ថែមចំនួនបីខែ គឺចាំបាច់ត្រូវបញ្ចូលបន្ថែមទៅលើពេលវេលាដែលបានគ្រោង...[84]។

---

[82] កថាខណ្ឌ ៥៩ នៃដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកា៖ "តាមប្រព័ន្ធបច្ចុប្បន្ននេះ អាចស៊ីពេលប្រហែលជា ២ ខែ ចាប់ពីពេលប្រកាសតំណែងទំនេររហូតដល់ការជ្រើសរើសសមាជិកបុគ្គលិកថ្មីម្នាក់របស់ អ.ស.ប. តែចំណាយពេលតិចជាងនេះទេ ប្រសិនបើស្នើសុំតំណែងជាអ្នកប្រឹក្សាវិញ។ ប៉ុន្តែ យើងបានទទួលដំណឹងពីការិយាល័យរដ្ឋបាលថា ទីស្នាក់ការ អ.ស.ប. កាន់តែមិនពេញចិត្តជាមួយនឹងការប្រើប្រាស់កិច្ចសន្យាការងារប្រភេទជាអ្នកប្រឹក្សា"។ *សូមមើលផងដែរ* កថាខណ្ឌ ៤១ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[83] កថាខណ្ឌ ២៤ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[84] កថាខណ្ឌ ២២ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៤ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៧ (ការគូសបញ្ជាក់បន្ថែមក្នុងឯកសារដើម)។ រឿងក្តី ០០២/០២ ក៏ជាឧទាហរណ៍ដែល "ការរៀបចំព្រោងសាលក្រមត្រូវទទួលផលប៉ះពាល់ដោយការលាឈប់របស់បុគ្គលិកនៅក្នុងអង្គជំនុំជម្រះដែរ"។ *ដូចខាងលើ* កថាខណ្ឌ ៣៨។

៤៩. លទ្ធភាពរបស់តុលាការ ក្នុងការផ្តល់សេវាបកប្រែឱ្យទាន់ពេលវេលា ក៏នឹងបង្អាក់ផងដែរនូវដំណើរការវិវឌ្ឍន៍របស់កិច្ចដំណើរការនីតិវិធី[85]។ ឯកសារទាំងអស់ចាំបាច់ត្រូវដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬ ភាសាបារាំង[86]។ ពេលវេលាសម្រាប់ការដាក់ឯកសារ ចាប់ផ្តើមគិតចាប់ពីពេលទទួលបានការជូនដំណឹង អំពីសំណៅជាភាសាខ្មែរនៃឯកសារ[87]។ ចៅក្រមជាតិ និង ក្រុមរបស់ពួកគាត់ ភាគច្រើនប្រើឯកសារជាភាសាខ្មែរ ក្នុងការងាររបស់គាត់[88]។ ជនត្រូវចោទ/ជនជាប់ចោទចាំបាច់ផងដែរត្រូវមានសំណៅជាភាសាខ្មែរនៃឯកសារដែលបានដាក់ក្នុងសំណុំរឿង ដែលនេះជាផ្នែកមួយនៃសិទ្ធិរបស់ពួកគេ ក្នុងការទទួលបានការជូនដំណឹង អំពីលក្ខណៈ និង ការវិវឌ្ឍន៍នៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេ[89]។

---

[85] កថាខណ្ឌ ២៥ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[86] មាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក. អ.វ.ត.ក/០១/២០០៧/វិ.លើកទី ៨ ចុះថ្ងៃទី ៧ ខែមីនា ឆ្នាំ ២០១២ ។

[87] *ដូចខាងលើ* មាត្រា ៨.៥៖ "លើកលែងតែមានការណែនាំផ្ទុយពីនេះរបស់សហចៅក្រមស៊ើបអង្កេត ឬ ពីអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក. ពេលវេលាកំណត់ត្រូវរាប់មួយថ្ងៃបន្ទាប់ពីថ្ងៃនៃការជូនដំណឹងពីឯកសារជាភាសាខ្មែរ និង ភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក.។ ក្នុងករណីពិសេស សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អាចសម្រេចថា ពេលវេលាកំណត់ត្រូវចាប់ផ្តើមគិតពីថ្ងៃដាក់ឯកសារជាបីភាសាផ្លូវការ"។

[88] កថាខណ្ឌ ២០ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[89] *សូមមើល រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ A190 កថាខណ្ឌ ខ៤៖ "ជនត្រូវចោទ មានសិទ្ធិទទួលបានការបកប្រែជាភាសាខ្មែរ នូវរាល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ស្របតាមវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ដោយហេតុថា ដីកានេះបង្ហាញពីអង្គហេតុ និង មូលដ្ឋាននៃបទចោទទាំងអស់ សម្រាប់ការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ លើសពីនេះទៀត ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែជាភាសាខ្មែរនូវភស្តុតាងទាំងឡាយដែលជីការបញ្ជូនរឿងទៅជំនុំជម្រះបានយកធ្វើជាសំអាង ..."។ ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក. ត្រូវធានាសិទ្ធិរបស់ជនត្រូវចោទ/ជនជាប់ចោទ ក្នុងការទទួលបានការ "ជូនដំណឹងភ្លាមៗ និង លម្អិតជាភាសាដែលខ្លួនយល់ អំពីប្រភេទ និង មូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន"។ *សូមមើល* មាត្រា ៣១, មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលត្រូវបានកែសម្រួលដោយក្រម ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើវិសោធនកម្មលើមាត្រា ១១, ១២, ១៣, ១៨, ២២, ២៦, ២៨, ៣០, ៣៥, ៥១, ៩០, ៩១, ៩៣ និង មាត្រាដទៃទៀតពីជំពូកទី ៨ ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩ ("រដ្ឋធម្មនុញ្ញកម្ពុជា")។ មាត្រា ១២(២), មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣៣ ថ្មី, ៣៥ ថ្មី (ក)-(ង) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(៣)(ក)-(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលត្រូវបានអនុម័ត និង បើកឱ្យចុះហត្ថលេខា ការបង្ហាញពីផលប៉ះពាល់ និង ការចូលជាសមាជិក ដោយ

ច. មិនមានផែនការចក្ខុវិស័យបុរេសកម្ម ដែលពិចារណាលើលទ្ធភាពដែលថា រឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/២ អាចត្រូវបានជំនុំជម្រះនៅសវនាការ

៥០. មិនមានផែនការចក្ខុវិស័យបុរេសកម្មទាល់តែសោះ។ មកដល់ពេលនេះហើយ គួរតែដឹងហើយថា តើការជំនុំជម្រះរឿងក្តីមួយនៅ អ.វ.ត.ក. ចាប់ពីពេលផ្តើមដំបូង រហូតដល់ពេលបណ្តឹងសាទុក្ខ មានលក្ខណៈបែបណានោះ៖ តើត្រូវចំណាយថវិកាអស់ប៉ុន្មាន ដើម្បីផ្គត់ផ្គង់ដល់ព្រះរាជអាជ្ញា និង ក្រុមមេធាវីការពារក្តី ដើម្បីផ្តល់ធនធានដល់ដើមបណ្តឹងរដ្ឋប្បវេណី មានបុគ្គលិកគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះ និង អង្គភាពគាំទ្រតុលាការរបស់អង្គជំនុំជម្រះ ព្រមទាំងតម្រូវការផ្នែកបច្ចេកវិទ្យា និងសម្ភារ (គ្រឿងសង្ហារឹម ទីកន្លែង គ្រឿងម៉ាស៊ីន និង ការទិញសិទ្ធិប្រើប្រាស់កម្មវិធីកុំព្យូទ័រ (Software licenses)) ដើម្បីរៀបចំកិច្ចដំណើរការនីតិវិធី។ ទោះបីជា រឿងក្តីពីរបានឈានដល់ដំណាក់កាលបណ្តឹងសាទុក្ខហើយក៏ដោយ ក៏ការិយាល័យរដ្ឋបាលនៅតែមិនអាចធ្វើការប៉ាន់ប្រមាណទៅលើពេលវេលា និង ធនធានដែលត្រូវការចាំបាច់ ក្នុងករណីដែលរឿងក្តីមួយ ឬ ច្រើនក្នុងចំណោមរឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/២ ត្រូវបន្តទៅដំណាក់កាលជំនុំជម្រះនៅក្នុងសវនាការនោះដែរ[90]។ ប្រហែលជាការិយាល័យរដ្ឋបាល មិនចង់បង្អាក់ទឹកចិត្តប្រទេសផ្តល់ជំនួយ ពីការសន្យាផ្តល់ថវិកាក្នុងរយៈពេលវែង ដោយការផ្តល់ឱ្យពួកគេនូវការប៉ាន់ប្រមាណដោយឥតលាក់លៀម ឬ មួយប្រហែលជាការិយាល័យរដ្ឋបាល បណ្តោយខ្លួនទៅតាមការណ៍ដែលថា UNAKRT មានរយៈពេល និង អាណត្តិការងារដែលមានកំណត់[91] និង គ្រាន់តែបន្តដំណើរការ

សេចក្តីសម្រេចរបស់មហាសន្និបាតរបស់ អ.ស.ប. លេខ ២២២០A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ និង ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ ដោយអនុលោមតាម មាត្រា ៤៩ ("កតិកាសញ្ញា ICCPR")។

[90] កថាខណ្ឌ ៤៧ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧៖ "លុះត្រាតែមានសេចក្តីសម្រេចថា តើរឿងក្តី ០០៣ និង/ឬ រឿងក្តី ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះឬយ៉ាងណា ទើបយើងអាចស្មានទុកបានទៅលើរយៈពេលតម្រូវសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបានឡើយ"។ កថាខណ្ឌ ៧១ នៃថវិកា អ.វ.ត.ក. ឆ្នាំ ២០១៨-២០១៩៖ "ខណៈដែលទំហំនៃតម្រូវការធនធានសម្រាប់ការជំនុំជម្រះនៃរឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/០២ អាស្រ័យលើចំនួន និងលក្ខណៈនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចជា ចំនួនរឿងក្តី ចំនួនជនជាប់ចោទ និង វិសាលភាព និង ភាពស្មុគស្មាញនៃការចោទប្រកាន់ ដែលត្រូវមានភាពច្បាស់លាស់ នៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញ ខ្ទង់ថវិកាសម្រាប់ការចំណាយលើបុគ្គលិកដទៃទៀតនឹងបង្ហាញពីតម្រូវការចាំបាច់ រួមបញ្ចូលទាំងតម្រូវការធនធានអប្បបរមា សម្រាប់ការជំនុំជម្រះមួយដោយមានជនជាប់ចោទម្នាក់"។

[91] *សូមមើល រឿងក្តី ឃឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ការដាក់ព័ត៌មានដែលទើបទទួលបាននាពេលថ្មីៗរបស់ ឃឹម ទិត្យ ពាក់ព័ន្ធនឹងសំណើរបស់ ស.ច.ស. សុំឱ្យដាក់សារណាស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់លើសំណុំរឿង ០០៣, ០០៤ និង ០០៤/២ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៧ ឯកសារ D355/5 កថាខណ្ឌ ១២

រហូតដល់ពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលពេលមកដល់ចំណុចនេះនឹងប្រកាសនូវជ័យជំនះ ហើយបន្ទាប់មករៀបចំឥវ៉ាន់ និង ត្រឡប់ទៅផ្ទះវិញ។

៥១. ដោយប្រើប្រាស់បន្ទុកក្តីកន្លងមករបស់ អ.វ.ត.ក. ធ្វើជាឧបករណ៍វាស់ស្ទង់ វាបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ប្រសិនបើមានការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ កិច្ចដំណើរការនីតិវិធីនៅក្នុងរឿងក្តី ០០៣ នឹងបន្តទៅមុខច្រើនឆ្នាំតទៅទៀត៖

ក. ដីកាដំណោះស្រាយនៅក្នុងរឿងក្តី ០០៣ ត្រូវបានរំពឹងថា នឹងចេញនៅចុងត្រីមាសទីបីនៃឆ្នាំ ២០១៨[92] ហើយមានការរំពឹងថា អង្គបុរេជំនុំជម្រះនឹងត្រូវសម្រេចសេចក្តី ទៅលើបណ្តឹងឧទ្ធរណ៍ដែលអាចមាន ប្រឆាំងដីកាដំណោះស្រាយ រហូតដល់ត្រីមាសទីពីរនៃឆ្នាំ ២០១៩[93]។ ទោះបីជាការប៉ាន់ប្រមាណទាំងនេះ “ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានថា អង្គជំនុំជម្រះ និង ការិយាល័យទាំងអស់ មានបុគ្គលិកគ្រប់គ្រាន់ និង ថាកិច្ចដំណើរការនីតិវិធីតុលាការ នឹងមិនត្រូវរំខានដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ” ក៏ដោយ[94]។ បទពិសោធន៍បង្ហាញថា ការព្រាងដីកាដំណោះស្រាយ នឹងទំនងជាចំណាយពេលយូរជាង ការប៉ាន់ប្រមាណរបស់ការិយាល័យរដ្ឋបាល។ នៅក្នុងរឿងក្តី ០០១ ដែលជនជាប់ចោទសឹងតែទទួលស្គាល់បទចោទទាំងអស់ប្រឆាំងរូបគាត់ ការព្រាងដីកាដំណោះស្រាយ បានចំណាយពេលប្រមាណបីខែ[95]។ នៅក្នុងរឿងក្តី ០០២ ការព្រាងដីកាដំណោះស្រាយបានចំណាយពេលប្រាំបីខែ[96]។ នៅក្នុងរឿងក្តី ០០៤/១ ចាប់ពីពេលដាក់ចម្លើយរបស់មេធាវីការពារក្តី តបទៅនឹងដីកាសន្និដ្ឋានស្តាពររបស់

ដែលដកស្រង់ កិច្ចប្រជុំប្រចាំត្រីមាសលើកទី៨របស់ថ្នាក់គ្រប់គ្រងអង្គភាពហិរញ្ញវត្ថុ-ជំនួយ អ.ស.ប. សម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម៖ កំណត់ហេតុនៃកិច្ចពិភាក្សា ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៧ ធ្វើបច្ចុប្បន្នភាព នៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១៧៖ “វាលែងជាការសម្ងាត់ទៀតហើយ ដែល UNAKRT កំពុងត្រៀងខ្លួនបញ្ចប់...។ UNAKRT គឺជាគម្រោងជំនួយបច្ចេកទេសមួយ ដែលនឹងបញ្ចប់អាណត្តិរបស់ខ្លួន នៅចំណុចកំណត់មួយ។ ដូច្នេះ បុគ្គលិកគួរតែរៀបចំសម្រាប់ការបញ្ចប់នេះ។ មន្ត្រីសម្របសម្រួលបានណែនាំដល់បុគ្គលិកឱ្យដាក់ពាក្យសុំការងារថ្មី ជាពិសេសគឺការចុះឈ្មោះក្នុងទុកសម្រាប់មុខតំណែងដែលនឹងត្រូវរើសបុគ្គលិកនៅពេលក្រោយ”។

[92] កថាខណ្ឌ ២៨ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[93] *ដូចខាងលើ* កថាខណ្ឌ ៣២។

[94] *ដូចខាងលើ* កថាខណ្ឌ ១៤។

[95] កថាខណ្ឌ ២៣ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៤ ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៧។

[96] *ដូចខាងលើ* កថាខណ្ឌ ២៣។

ស.ព.អ. គឺត្រូវចំណាយពេលប្រហែលជាប្រាំពីរខែ ដើម្បីព្រាងសំអាងហេតុ សម្រាប់ផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយ[97]។

ខ. ប្រសិនបើ រឿងក្តី ០០៣ ត្រូវបញ្ជូនទៅជំនុំជម្រះនៅក្នុងសវនាការ ការជំនុំជម្រះអាចចាប់ផ្តើមយ៉ាងឆាប់បំផុតនៅក្នុងខែមករា ឆ្នាំ ២០២០ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំរៀបចំសវនាការ និង សវនាការលើអញ្ជត្រកម្មនានា[98]។ នៅក្នុងរឿងក្តី ០០១ រយៈពេលចាប់ពីដីកាដំណោះស្រាយ រហូតដល់ពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី គឺប្រហែលប្រាំបីខែ[99]។ មេធាវីការពារក្តីក្នុងរឿងក្តី ០០១ មិនបានប្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយឡើយ ហើយអង្គបុរេជំនុំជម្រះបានចំណាយពេលវេលាប្រហែលចំនួនបួនខែ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា[100]។ នៅក្នុងរឿងក្តី ០០២ រយៈពេលនេះគឺ ១៤ ខែ ដោយអង្គបុរេជំនុំជម្រះបានចេញដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ដោយផ្តល់សំអាងហេតុតាមក្រោយ ដើម្បីអនុញ្ញាតិឱ្យអង្គជំនុំជម្រះសាលាដំបូង ទទួលចាត់ការរឿងក្តីនៅមុនការរំពឹងទុក[101]។

---

[97] ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានដាក់នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦។ ដីកាដំណោះស្រាយដែលមានសំអាងហេតុ ត្រូវបានចេញនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧។ *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៥/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំ៖ (១) ដីកាសម្រេចដកចេញសេចក្តីសង្ខេបនៃដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង (២) សេចក្តីប្រកាសរួមជាសាធារណៈរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D306/2.1 កថាខណ្ឌ ៧។ *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៥/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងរឿងក្តី ០០៥/១ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D261 ("ដីកាដំណោះស្រាយក្នុងរឿងក្តី ០០៥/១")។

[98] កាលបរិច្ឆេទនេះសន្មតថា ដីកាដំណោះស្រាយនឹងត្រូវចេញនៅចុងត្រីមាសទីបីនៃឆ្នាំ២០១៨ ហើយបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាដំណោះស្រាយនេះ នឹងត្រូវសម្រេចដោយមានសម្ពាងហេតុ ក្នុងរយៈពេលបីខែ ក្រោយពីបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់។

[99] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188 "សាលក្រមក្នុងរឿងក្តី ០០១" កថាខណ្ឌ ៦ កថាខណ្ឌ ៩។

[100] *ដូចខាងលើ* កថាខណ្ឌ ៧។

[101] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០២" ឯកសារ D427/1/30។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១០៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១១ ឯកសារ D427/4/15។ *រឿងក្តី នួន ជា*

គ. ការជំនុំជម្រះនៅក្នុងរឿងក្តី ០០៣ ប្រហែលជាត្រូវចំណាយពេលយ៉ាងហោចណាស់ពីរឆ្នាំ។ នៅក្នុងរឿងក្តី ០០១ សវនាការលើអង្គសេចក្តី ចំណាយពេលប្រាំបីខែ[102]។ នៅក្នុងរឿងក្តី ០០២/០១ សវនាការលើអង្គសេចក្តីចំណាយពេលប្រហែល ២០ ខែ[103]។ នៅក្នុងរឿងក្តី ០០២/០២ សវនាការលើអង្គសេចក្តី មានរយៈពេលជាងពីរឆ្នាំ ដោយគិតជាសរុបទៅមានថ្ងៃសវនាការចំនួន ២៧៥ ថ្ងៃ[104]។ ប្រសិនបើរឿងក្តី ០០៣ ឈានទៅដល់ដំណាក់កាលជំនុំជម្រះក្នុងសវនាការ គឺអាចរំពឹងទុកថាត្រូវចំណាយពេលយូរ ដូចកិច្ចដំណើរការនីតិវិធី នៅក្នុងរឿងក្តី ០០២/០១ ឬ រឿងក្តី ០០២/០២ ដូច្នេះដែរ។

ឃ. សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានរំពឹងថាចេញនៅក្នុងឆ្នាំ ២០២៣។ នៅក្នុងរឿងក្តី ០០១ អង្គជំនុំជម្រះសាលាដំបូងបានចំណាយពេលប្រាំបីខែ ដើម្បីចេញសាលក្រមបន្ទាប់ពីសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល[105]។ នៅក្នុងរឿងក្តី ០០២/០១ ការចេញសាលក្រមត្រូវចំណាយពេលប្រាំបួនខែ[106]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ រំពឹងថានឹងចេញសាលក្រមរបស់ខ្លួន នៅក្នុងត្រីមាសទីពីរឆ្នាំ ២០១៨ ទោះបីជា "បញ្ហាទាំងឡាយ រួមទាំងហិរញ្ញវត្ថុ អ.វ.ត.ក. បុគ្គលិករបស់អង្គជំនុំជម្រះ និង ការបកប្រែសាលក្រមទៅជាភាសាខ្មែរ និង ភាសាបារាំង អាចតម្រូវឱ្យមានការពន្យារពេលក៏ដោយ..."[107]។

និង អ្នកផ្សេងទៀត សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ &១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/3/15។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៤ ឯកសារ E313 ("សាលក្រមក្នុងរឿងក្តី ០០២/០១") កថាខណ្ឌ ៧។

[102] កថាខណ្ឌ ៩-១០ នៃសាលក្រមក្នុងរឿងក្តី ០០១។

[103] កថាខណ្ឌ ៧-៨ នៃសាលក្រមក្នុងរឿងក្តី ០០២/០១ ។

[104] កថាខណ្ឌ ៣៨ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥៖ "កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើសវនាការចំនួនបីថ្ងៃក្នុងមួយសប្តាហ៍។ ... សវនាការលើភស្តុតាងបានបញ្ចប់នៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៧ ក្រោយពីសវនាការសរុបចំនួន ២៧៥ ថ្ងៃ"។

[105] កថាខណ្ឌ ១០ នៃសាលក្រមក្នុងរឿងក្តី ០០១។

[106] កថាខណ្ឌ ៨ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[107] កថាខណ្ឌ ៤៦ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

ង. សាលដីកាអាចរំពឹងថាត្រូវចេញនៅក្នុងឆ្នាំ ២០២៤។ នៅក្នុងរឿងក្តី ០០១ សាលដីកាបានចេញនៅក្នុងរយៈពេល ១៨ ខែ ក្រោយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[108]។ នៅក្នុងរឿងក្តី ០០២/០១ សាលដីកាត្រូវបានចេញនៅក្នុងរយៈពេល ២៧,៥ ខែ បន្ទាប់ពីចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[109]។

៥២. ហេតុដូច្នេះ ជាការចាំបាច់ ដែលត្រូវមានធនធានគ្រប់គ្រាន់ *យ៉ាងហោចណាស់* រហូតដល់ឆ្នាំ ២០២៤ ដើម្បីអនុញ្ញាតឱ្យដំណើរការជំនុំជម្រះ និង បណ្តឹងសាទុក្ខក្នុងរឿងក្តី ០០៣ បន្តដំណើរការបាន។ ការិយាល័យរដ្ឋបាលបានប៉ាន់ប្រមាណថវិកាចំនួន ៧,២៦ លានដុល្លារ សម្រាប់ឆ្នាំ ២០១៨-២០១៩ សម្រាប់ "តម្រូវការធនធានអប្បបរមា សម្រាប់ករណីដែលមានសវនាការតែមួយ សម្រាប់ជនជាប់ចោទតែមួយ ដែលត្រូវជំនុំជម្រះ"[110]។ ក្នុងបរិមាណនេះ ទឹកប្រាក់ចំនួន ១,៤៨ លានដុល្លារ គឺសម្រាប់ការចំណាយលើកិច្ចប្រជុំរៀបចំសវនាការក្នុងឆ្នាំ ២០១៨ និង ទឹកប្រាក់ចំនួន ៥,៧៨ លានដុល្លារ សម្រាប់ចំណាយលើសវនាការបឋម សេចក្តីថ្លែងបើក និង សវនាការលើភស្តុតាងនៅក្នុងឆ្នាំ ២០១៩[111]។ ដោយសន្មតថា បន្ទាត់ថវិកានេះបានឆ្លុះបញ្ចាំងដោយត្រឹមត្រូវ នូវការចំណាយទាំងអស់ ដែលទាក់ទងនឹងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[112] ទឹកប្រាក់ចំនួន ៣៦ លានដុល្លារ គឺជា *ខ្សែបន្ទាត់* ចំណាយទាបបំផុត ដែលត្រូវការចាំបាច់សម្រាប់បញ្ចប់រឿងក្តីត្រឹមមួយប៉ុណ្ណោះ ដោយមិនគិតពីការពន្យារពេល ដែលអាច/មិនអាចប្រមើលមើលឃើញជាមុន ឬ ក៏ភាពស្មុគស្មាញនានានៅក្នុងកិច្ចដំណើរការនីតិវិធី[113]។

---

[108] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 ("សាលដីកាក្នុងរឿងក្តី ០០១")។

[109] *រឿងក្តី ន្តួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ F36 ("សាលដីកាក្នុងរឿងក្តី ០០២/០១")។

[110] កថាខណ្ឌ ៧១ នៃថវិកា អ.វ.ត.ក. ឆ្នាំ ២០១៨-២០១៩ (ការគូសបញ្ជាក់បន្ថែម)។

[111] *ដូចខាងលើ* កថាខណ្ឌ ៧៣។

[112] ការចំណាយនេះ រួមបញ្ចូលការចំណាយលើចៅក្រម សហព្រះរាជអាជ្ញា និង សហមេធាវី និង បុគ្គលិករបស់ពួកគេ ផ្នែកគ្រប់គ្រងតុលាការ អង្គភាពបកប្រែភាសា អង្គភាពប្រតិចារឹក អង្គភាពគាំពារសាក្សី និង អ្នកជំនាញ អង្គភាពឃុំឃាំង អង្គភាពកំណត់ហេតុ និង បណ្ណសារ អង្គភាពសោតទស្សន៍ និង ការចំណាយផ្សេងទៀត ដូចជា ការដឹកជញ្ជូនសាក្សី អ្នកបើកបរថយន្តក្រុង និង អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ។

[113] កថាខណ្ឌ ៣៦ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧៖ "តារាងពេលវេលានៃការបញ្ចប់សវនាការរងឥទ្ធិពលពីកត្តានានាដូចជា៖ លក្ខណៈ និង ភាពស្មុគស្មាញនៃរឿងក្តី បញ្ហាសុខភាពរបស់ជនជាប់ចោទដែល

៥៣. នៅក្នុងរឿងក្តីធម្មតា ការពន្យារពេលគឺជារឿងអកុសល ប៉ុន្តែមិនមែនជារឿងស្លាប់រស់នោះទេ។ ដោយពិចារណាទៅលើសុខភាព និង វ័យចំណាស់របស់ មាស មុត ការពន្យារពេលបែបនេះអាចជារឿងស្លាប់រស់។ អៀង សារី និង អៀង ធីរិទ្ធ គឺជាឧទាហរណ៍ស្រាប់[114]។

៥៤. ថវិកាឆ្នាំ ២០១៨-២០១៩ មិនបានត្រៀមបម្រុងសម្រាប់ចំណាយឡើយ ក្នុងករណីដែលមានរឿងក្តីលើសពីមួយ ត្រូវបន្តនីតិវិធីទៅជំនុំជម្រះក្នុងសវនាការនោះ។ តាមការដឹងឮរបស់មេធាវីការពារក្តី និង ផ្អែកលើព័ត៌មានដែលមាន[115] មិនមានការត្រៀមផែនការសម្រាប់លទ្ធភាពដែលថា រឿងក្តីច្រើនអាចត្រូវបញ្ជូនទៅជំនុំជម្រះក្នុងសវនាការ ក្នុងពេលជាមួយគ្នា និង ថាតើតុលាការអាចចាត់ចែងដោយរបៀបណា សម្រាប់អ្នកចូលរួមប្រចាំឆ្នាំ តម្រូវការធនធានមនុស្ស និង សម្ភារនោះឡើយ[116]។

មានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ ដែលត្រូវកោះហៅ ភាពទំនេរ និង រយៈពេលនៃសក្ខីកម្មរបស់សាក្សីទាំងនោះ ឧបសគ្គទាក់ទងនឹងការរៀបចំ និង ការប្រព្រឹត្តទៅជាក់ស្តែងនៃកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដែលដាក់ដោយភាគី និង ការពិនិត្យពិចារណាផ្នែករដ្ឋបាលផ្សេងៗទៀត រួមមាន ការបកប្រែផ្ទាល់មាត់ឱ្យបានត្រឹមត្រូវ និង ការបកប្រែឯកសារឱ្យទាន់ពេលវេលា"។

[114] អៀង សារី បានទទួលមរណភាពនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១៣ នៅពាក់កណ្តាលការជំនុំជម្រះរឿងក្តី ០០២/០១។ អង្គជំនុំជម្រះសាលាដំបូងបានផ្អាកដំណើរការនីតិវិធីប្រឆាំងនឹង អៀង ធីរិទ្ធ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១១ ដោយរកឃើញថា អ្នកស្រីពុំមានកាយសម្បទាគ្រប់គ្រាន់សម្រាប់ចូលរួមការជំនុំជម្រះ។ អ្នកស្រីទទួលមរណភាពនៅថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៥។ សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. *ជនជាប់ចោទ អៀង សារី បានទទួលមរណភាព* ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៣ គេហទំព័រ https://www.eccc.gov.kh/km/node/25888។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138 KH 00753507-00753508។ សេចក្តីប្រកាសព័ត៌មាន អ.វ.ត.ក. ជនជាប់ចោទ អៀង ធីរិទ្ធ បានទទួលមរណភាព ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៥ នៅតាមគេហទំព័រ https://www.eccc.gov.kh/km/node/34041។

[115] ថវិកា អ.វ.ត.ក. ឆ្នាំ ២០១៨-២០១៩។ ផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។ លិខិតផ្ញើជូន អ.គ.ក. ចំណងជើងថា "សំណើសុំព័ត៌មានពាក់ព័ន្ធនឹងការពិភាក្សាលើការវិវឌ្ឍន៍នៃរឿងក្តី ០០៣, ០០៤ និង រឿងក្តី ០០៤/០២ និង ផលប៉ះពាល់លើថវិការបស់ អ.វ.ត.ក." ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៨ (*សូមមើល* ឯកសារភ្ជាប់ ១)។ លិខិតរបស់ អ.គ.ក. ចំណងជើងថា "ឆ្លើយតប៖ សំណើសុំព័ត៌មានពាក់ព័ន្ធនឹងការពិភាក្សាពីការវិវឌ្ឍន៍នៃរឿងក្តី ០០៣, ០០៤ និង រឿងក្តី ០០៤/០២ និងផលប៉ះពាល់លើថវិការបស់ អ.វ.ត.ក." ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៨ (*សូមមើល* ឯកសារភ្ជាប់ ២)។ *សូមមើលផងដែរ* កថាខណ្ឌ ៥៨-៥៩ *ខាងក្រោម*។

[116] *សូមមើល កថាខណ្ឌ ៥៥-៦០ ខាងក្រោម*។

៥៥. ជម្រើសមួយគឺបង្កើតក្រុមប្រឹក្សាជំនុំជម្រះបន្ថែម សម្រាប់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែជម្រើសនេះមិនអាចធ្វើទៅបានឡើយ បើគិតពីដំណើរការនៃការតែងតាំងចៅក្រម។ ក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. បានចែងកំណត់ចំនួនចៅក្រមរបស់អង្គជំនុំជម្រះនីមួយៗ[117]។ ចៅក្រមបម្រុងមានត្រឹមតែបីរូបប៉ុណ្ណោះ[118] ហើយមិនមានបញ្ជីឈ្មោះចៅក្រមឡើយ[119]។ បើទោះបីជាអាចបែងចែកចៅក្រមបម្រុង ដែលបានតែងតាំងរួចហើយ ទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះទីពីរក្តី ក៏ចាំបាច់ត្រូវតែមានការតែងតាំងដោយព្រះរាជក្រឹត្យដែរ[120]។ ចៅក្រមអន្តរជាតិថ្មីណាម្នាក់ ដែលមកពីខាងក្រៅ អ.វ.ត.ក. ចាំបាច់ត្រូវតែទទួលបានការជ្រើសតាំងដោយអគ្គលេខាធិការ អ.ស.ប. និង ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[121]។ សិទ្ធិអំណាចរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ក៏មានភាពមិន

---

[117] ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមជាតិចំនួនប្រាំពីររូប និង តែងតាំងចៅក្រមបម្រុងតាមភាពចាំបាច់។ បេក្ខជនសម្រាប់ចៅក្រមអន្តរជាតិត្រូវបានតែងតាំងដោយអគ្គលេខាធិការ អ.ស.ប. ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមពេញសិទ្ធិចំនួនប្រាំរូប និង ចៅក្រមបម្រុងយ៉ាងហោចណាស់ ចំនួនពីររូប។ មាត្រា ១១ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ E301/4 ("អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង") កថាខណ្ឌ ៣៖ "ក្របខ័ណ្ឌគតិយុត្តិនៃ អ.វ.ត.ក. បានកំណត់ជាក់លាក់នូវចំនួនចៅក្រមនៃអង្គជំនុំជម្រះនីមួយៗ"។

[118] គេហទំព័រ អ.វ.ត.ក. ផ្នែកតុលាការ https://www.eccc.gov.kh/en/organs/judicial-chambers (ការចូលទស្សនាចុងក្រោយនៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨)។

[119] មិនដូចគ្នាទៅនឹងឃ្លាការសម្រាប់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ និង តុលាការ KSC អ.វ.ត.ក. មិនមានបញ្ជីចៅក្រមសម្រាប់ការកោះអញ្ជើញចៅក្រម តាមភាពចាំបាច់នោះទេ។ *សូមមើល* មាត្រា ៨ នៃលក្ខន្តិក:នៃយន្តការអន្តរជាតិដែលនៅសល់សម្រាប់សាលាក្តីព្រហ្មទណ្ឌ ច្បាប់លេខ S/RES/1966 (ឆ្នាំ ២០១០)។ មាត្រា ២៦ នៃច្បាប់ស្តីពីអង្គជំនុំជម្រះពិសេស និង ការិយាល័យរដ្ឋអាជ្ញាពិសេស ច្បាប់លេខ 05/L-053 ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១៥។ កថាខណ្ឌ ២ នៃអនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង។

[120] កថាខណ្ឌ ៥ នៃអនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង។

[121] ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមជាតិចំនួនប្រាំពីររូប និង តែងតាំងចៅក្រមបម្រុងតាមភាពចាំបាច់។ បេក្ខជនសម្រាប់ចៅក្រមអន្តរជាតិត្រូវបានតែងតាំងដោយអគ្គលេខាធិការ អ.ស.ប. ដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមពេញសិទ្ធិចំនួនប្រាំរូប និង ចៅក្រមបម្រុងយ៉ាងហោចណាស់ ចំនួនពីររូប។ មាត្រា ១១ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។

ច្បាស់លាស់ដែរ ដូចដែលលោកប្រធាន និល ណុន បានសន្និដ្ឋាន នៅពេលពិចារណាថាតើត្រូវ បង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរដែរឬយ៉ាងណា ដើម្បីស្តាប់បទចោទប្រកាន់ដែលនៅសេសសល់ ក្នុងរឿងក្តី ០០២/០២[122]។

៥៦. អ.វ.ត.ក. មានសាលសវនាការតែមួយគត់។ បើទោះបីជាអាចតែងតាំងចៅក្រមថ្មី បានទាន់ពេលវេលាក៏ដោយ ក៏ចាំបាច់ត្រូវតែសាងសង់សាលសវនាការថ្មី និង ជ្រើសរើសបុគ្គលិកថ្មីផងដែរ (ដូចជាមន្ត្រីច្បាប់ ទីប្រឹក្សា អ្នកបកប្រែសរសេរ អ្នកបកប្រែផ្ទាល់មាត់ បុគ្គលិកជំនាញព័ត៌មានវិទ្យា បុគ្គលិកជួយគាំទ្រដល់ចៅក្រម និង សូម្បីតែអ្នកបើករថយន្តក្រុង)[123]។ បន្ថែមលើនេះ "នៅពេលដែលចៅក្រម និង មន្ត្រីច្បាប់ថ្មីមកដល់ប្រទេសកម្ពុជា ពួកគាត់ចាំបាច់ត្រូវស្វែងយល់ពីដីកាដំណោះស្រាយ ភស្តុតាងនៅក្នុងសំណុំរឿង នីតិវិធី និង កិច្ចដំណើរការនីតិវិធីកន្លងមក"[124]។ កត្តាទាំងអស់នេះនឹងបង្កើនទ្វេការចំណាយថវិកា និង ពេលវេលាយ៉ាងច្រើន ដែលចាំបាច់សម្រាប់បញ្ចប់រឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/២។

៥៧. អង្គជំនុំជម្រះសាលាដំបូងតែមួយ នឹងត្រូវដោះស្រាយនូវភាពស្មុគស្មាញ នៃការកំណត់កាលបរិច្ឆេទ ទាក់ទងការរៀបចំសវនាការជាច្រើន នៅក្នុងសាលសវនាការតែមួយ៖

ក. *ជម្រើសទី ១៖* អង្គជំនុំជម្រះសាលាដំបូង អាចបើកសវនាការរឿងក្តី ០០៣ នៅពេលខ្លះក្នុងសប្តាហ៍ ហើយបើកសវនាការរឿងក្តី ០០៤ និង/ឬ រឿងក្តី ០០៤/២ នៅពេលផ្សេងទៀតក្នុងសប្តាហ៍។ ការនេះនឹងបង្កើនរយៈពេលជារួមយ៉ាងច្រើន សម្រាប់កិច្ចដំណើរការនីតិវិធី ដែលធ្វើឱ្យមានលទ្ធភាពដែលថា មាស មុត សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចនៅរស់បានឃើញដល់ចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធី។

ខ. *ជម្រើសទី ២៖* រឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/០២ អាចត្រូវបានជំនុំជម្រះរួមគ្នានៅក្នុងពេលខ្លះក្នុងសប្តាហ៍ លើបញ្ហារួមគ្នា ហើយជំនុំជម្រះដាច់ពីគ្នានៅពេលក្រោយក្នុងសប្តាហ៍លើបញ្ហានីមួយៗផ្សេងពីគ្នានៃរឿងក្តី។ ការអនុវត្តបែបនេះនឹងអូសបន្លាយ កិច្ចដំណើរការនីតិវិធីនេះនៅមិនទាន់គិតដល់បញ្ហាដែលថា តើជនជាប់ចោទអាចប្រើប្រាស់ដោយពេញលេញ នូវសិទ្ធិ

---

[122] កថាខណ្ឌ ៣ នៃអនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង។

[123] *ដូចខាងលើ* កថាខណ្ឌ ៦។

[124] *ដូចខាងលើ* កថាខណ្ឌ ៧។

ទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឬយ៉ាងណាផង ប្រសិនបើ ក្រុមមេធាវីការពារក្តីត្រូវប្រមូលផ្តុំគ្នា ហើយរំពឹងថាបង្ហាញការការពារក្តីរួមគ្នា ព្រមទាំងត្រូវបានបដិសេធមិនផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីបង្ហាញភស្តុតាង និង សួរដេញដោលសាក្សីទៀតនោះ[125]។

គ. *ជម្រើសទី ៣៖* អង្គជំនុំជម្រះសាលាដំបូងអាចបើកសវនាការមួយនៅពេលព្រឹក និង សវនាការមួយនៅពេលរសៀល៖ ប្រសិនបើសវនាការពេលព្រឹកចាប់ផ្តើមពីម៉ោង ៩ ព្រឹក រហូតដល់ប្រហែលម៉ោង ១:៤៥ រសៀល[126] ហើយសវនាការពេលរសៀល អាចត្រូវបន្តរហូតដល់ម៉ោង ៧ ល្ងាច[127]។ ដោយពិចារណាឃើញថា នៅក្នុងស្ថានភាពចរាចរណ៍ដែលល្អបំផុតនោះ ដើម្បីធ្វើដំណើរពីចំណុចកណ្តាលទីក្រុងភ្នំពេញ (ដែលបុគ្គលិកអន្តរជាតិរបស់តុលាការភាគច្រើនស្នាក់នៅ) មកដល់អង្គជំនុំជម្រះសាលាដំបូង ត្រូវចំណាយពេលមួយម៉ោង ការណ៍នេះនឹងបន្ថែមបន្ទុកជាពិសេសដល់បុគ្គលិកទាំងអស់ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី។ ការណ៍នេះក៏នឹងបង្កើនទំនួរការព្រួយបារម្ភផ្នែកសន្តិសុខផងដែរ។

---

[125] នៅក្នុង *រឿងក្តី Prlić និង អ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងបានកម្រិតពេលវេលានៃការសួរដេញដោយសាក្សី ដោយអនុវត្តន៍នូវ *ដំណោះស្រាយមួយ-ប្រាំមួយ* តាមបែបគណិតវិទ្យា (mathematical one-sixth-solution)៖ មេធាវីការពារក្តីជារួមមានពេលវេលាសួរដេញដោយសាក្សី ដូចគ្នាទៅនឹងពេលវេលារបស់រដ្ឋអាជ្ញាក្នុងការសួរដេញដោយផ្ទាល់ ហើយក្នុងករណីដែលមិនមានការព្រមព្រៀងគ្នារវាងមេធាវីការពារក្តី មេធាវីការពារក្តីម្នាក់ៗមានពេលវេលាមួយ-ប្រាំមួយនៃរយៈពេលដែលរដ្ឋអាជ្ញាមានសម្រាប់ការសួរដេញដោយផ្ទាល់។ មេធាវីការពារក្តីត្រូវបានបង្ខំឱ្យផ្តោតលើការកំហិតពេលវេលាជាជាងលើខ្លឹមសារនៃរឿងក្តី។ ការសួរដេញដោយសាក្សីឱ្យបានពិស្តារ និង ត្រឹមត្រូវ ត្រូវតែរៀបចំជាមុន ដោយត្រូវដឹងឱ្យបានពេញលេញពីពេលវេលាដែលត្រូវបានកំណត់។ មេធាវីការពារក្តីត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពមួយដែលពួកគេត្រូវជ្រើសរើសបញ្ហាមួយចំនួនយកមកពោលប្រាស្រ័យក្នុងការសួរដេញដោយសាក្សី ឬ ក៏ត្រូវយកបញ្ហាទាំងអស់មកចោទសួរ ដោយមិនបានចូលទៅក្នុងខ្លឹមសារនៃរឿងក្តី ដោយត្រូវលះបង់នូវគុណភាពនៃដំណើរការសាកសួរ។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-A ប្រតិចារឹក ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០០៦ ទំព័រ ១៤៧៦។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-A សេចក្តីជូនដំណឹងរបស់ Jadranko Prlić អំពីការដាក់ឯកសារឡើងវិញនូវសំណៅកោសល្យបជាសាធារណៈ នៃសារណាបណ្តឹងឧទ្ធរណ៍របស់ Jadranko Prlić ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ២០៨-១៥។

[126] *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-A ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៧ ទំព័រ ១៣២២៧, ១៣៣៤០ (ចាប់ផ្តើមនៅម៉ោង ៩:០២ ព្រឹក និង ផ្អាកសវនាការនៅម៉ោង ១:៤៧ ល្ងាច)។

[127] *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-A ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៨ ទំព័រ ២៧៣៤៨ (ផ្អាកសវនាការនៅម៉ោង ៧:០៨ យប់)។

៥៨. ដោយអនុវត្តតួនាទីដែលត្រូវមានស្មារតីប្រុងប្រយ័ត្នខ្ពស់[128] មេធាវីការពារក្តីបានផ្ញើលិខិតជូនប្រធានអង្គភាពគាំពារការការពារក្តី និង បានសាកសួរថា តើគាត់ ឬ ការិយាល័យរដ្ឋបាល មានព័ត៌មានណាមួយ ទាក់ទងនឹងផែនការបន្តរឿងក្តី ០០៣ រឿងក្តី ០០៤ និង រឿងក្តី ០០៤/២ ហួសពីដំណាក់កាលដីកាដំណោះស្រាយដែរឬយ៉ាងណា[129] រួមមាន៖

ក. តើការិយាល័យរដ្ឋបាលបានបង្កើតផែនការណាមួយ ឬ បានបើកកិច្ចពិភាក្សាណាមួយ អំពីលទ្ធភាព ដែលមានរឿងក្តីច្រើនត្រូវបានបញ្ជូនទៅជំនុំជម្រះក្នុងសវនាការ ដែរឬយ៉ាងណា។

ខ. តើការិយាល័យរដ្ឋបាលមានពិភាក្សាអំពីលទ្ធភាពរបស់ អ.វ.ត.ក. ក្នុងការបើកសវនាការច្រើនក្នុងពេលជាមួយគ្នា ដោយគិតពីតម្រូវការហិរញ្ញវត្ថុ ភស្តុភារ ធនធានមនុស្ស និង រូបវន្ត ដែរឬយ៉ាងណា។

គ. តើការិយាល័យរដ្ឋបាលបានលើកសំណើ សាងសង់អាគារអង្គជំនុំជម្រះសាលាដំបូងថ្មី ដែរឬយ៉ាងណា។

ឃ. តើការិយាល័យរដ្ឋបាលបានដាក់សំណើទៅ អ.ស.ប. ដើម្បីជ្រើសតាំងចៅក្រមអន្តរជាតិថ្មី ដែរឬយ៉ាងណា។

---

[128] ការបំពេញការងារដោយយកចិត្តទុកដាក់ តម្រូវឱ្យសហមេធាវីធ្វើអ្វីមួយ និង គ្រប់យ៉ាងទាំងអស់ ដើម្បីធានាឱ្យបានថា មាស មុត មានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ទាំងអស់ រួមទាំងធ្វើការតវ៉ាចាំបាច់ទាំងអស់តាមផ្លូវច្បាប់ និង អង្គហេតុ ដោយពិនិត្យសច្ចៈសីលភាព និង ភាពត្រឹមត្រូវនៃភស្តុតាង ដែលប្រមូលបានដោយ ស.ច.ស. ដែលត្រូវបានប្រើប្រាស់ប្រឆាំងនឹង មាស មុត ដោយ ស.ព.អ. នៅក្នុងដីកាសន្និដ្ឋានស្តាពរ។ល។ និង ។ល។ វិធានអាឡាស្កានៃក្រមសីលធម៌វិជ្ជាជីវៈ (ALASKA RULE OF PROF'L CONDUCT) (បោះពុម្ពផ្សាយឆ្នាំ ២០១៧-២០១៨) វិធាន ១.៣៖ "មេធាវីត្រូវបំពេញកិច្ចដោយយកចិត្តទុកដាក់ សមស្រប និង រហ័សរហួននៅក្នុងការតំណាងក្តីឱ្យកូនក្តី"។ *អ្នកខាងលើ* ការពន្យល់វិធាន ១.៣៖ "មេធាវីគួរតាមដានបញ្ហាក្នុងនាមកូនក្តី បើទោះបីជាការជំទាស់ ឧបសគ្គ ឬ ភាពមិនងាយស្រួលផ្ទាល់ខ្លួនមេធាវីក៏ដោយ និង ត្រូវចាត់វិធានការផ្លូវច្បាប់ និង សីលធម៌វិជ្ជាជីវៈអ្វីក៏ដោយ ដែលតម្រូវ ដើម្បីបង្ហាញថាបុព្វហេតុ ឬ កិច្ចប្រឹងប្រែងរបស់កូនក្តីខ្លួនគឺត្រឹមត្រូវ។ មេធាវីត្រូវបំពេញកិច្ចផងដែរ ដោយការតាំងចិត្ត និង ប្តេជ្ញាចិត្ត ដើម្បីផលប្រយោជន៍របស់កូនក្តី និង ប្រកបដោយថាមពលក្នុងការតស៊ូមតិក្នុងនាមកូនក្តី"។ *សូមមើលផងដែរ* មាត្រា ៧ នៃក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី (ឆ្នាំ ១៩៩៥)។ វិធាន ២២(៤) នៃវិធានផ្ទៃក្នុង។

[129] លិខិតផ្ញើជូន អ.គ.ក. ចំណងជើងថា "សំណើសុំព័ត៌មានពាក់ព័ន្ធនឹងការពិភាក្សាលើការវិវឌ្ឍន៍នៃរឿងក្តី ០០៣, ០០៤ និង រឿងក្តី ០០៤/០២ និង ផលប៉ះពាល់លើថវិការបស់ អ.វ.ត.ក." ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៨ (*សូមមើល* ឯកសារភ្ជាប់ ១)។

ង. តើការិយាល័យរដ្ឋបាលបានដាក់សំណើទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជ្រើសតាំងចៅក្រមជាតិថ្មី ដែរឬយ៉ាងណា។

ច. តើការិយាល័យរដ្ឋបាលមានពិភាក្សា អំពីបញ្ហាកំណត់កាលបរិច្ឆេទ ដែលអាចកើតមានឡើងក្នុងករណីដែលរឿងក្តីពីរ ឬ បីត្រូវដំណើរការរួមគ្នា នៅក្នុងអង្គជំនុំជម្រះសាលាដំបូងតែមួយដែរឬយ៉ាងណា។

ឆ. តើអគ្គលេខាធិការ អ.ស.ប. បានជ្រើសតាំងអ្នកជំនាញពិសេសថ្មីរបស់អគ្គលេខាធិការដែរឬយ៉ាងណា បើសិនជាមិនបានជ្រើសតាំងទេ តើមាននរណាម្នាក់ដែលត្រូវបានតែងតាំងឬទេនាពេលបច្ចុប្បន្ន ឱ្យបំពេញភារកិច្ចបញ្ចុះបញ្ចូល និង ស្វែងរកថវិកា ដែលកន្លងមកត្រូវបានអនុវត្តដោយលោក Scheffer។

ជ. តើការិយាល័យរដ្ឋបាលបានបង្កើតផែនការស្វែងរកថវិកា ដើម្បីបន្តដំណើរការរបស់ អ.វ.ត.ក. សម្រាប់ឆ្នាំ ២០១៨ និង ឆ្នាំបន្តបន្ទាប់ ដែរឬយ៉ាងណា។

ឈ. តើការិយាល័យរដ្ឋបាលបានបង្កើតក្រុមការងារ ឬ ជ្រើសតាំងទីប្រឹក្សាណាម្នាក់ ដើម្បីរៀបចំគម្រោងប៉ាន់ប្រមាណថវិកា និង ពេលវេលា សម្រាប់លទ្ធភាពដែលអាចមានរឿងក្តីពីរ ឬ បីដែលអាចត្រូវបន្តរួមគ្នា ទៅដល់ដំណាក់កាលជំនុំជម្រះក្នុងសវនាការ ដែរឬយ៉ាងណា។ និង

ញ. តើមានដែរឬទេទ្វេរកំណត់ហេតុកិច្ចប្រជុំបុគ្គលិក FSU-UNAKRT ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចប្រជុំគ្រប់គ្រងប្រចាំត្រីមាស ដែលបានធ្វើឡើងកាលពីថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៧ ដែលអនុប្រធានការិយាល័យរដ្ឋបាល បានបញ្ជាក់ថា "UNAKRT គឺជាគម្រោងជំនួយបច្ចេកទេស ដែលនឹងបញ្ចប់អាណត្តិរបស់ខ្លួន នៅចំណុចកំណត់មួយ។ ដូច្នេះបុគ្គលិកគួរតែរៀបចំសម្រាប់ការបញ្ចប់នេះ"[130]។

---

[130] កិច្ចប្រជុំប្រចាំត្រីមាសលើកទី៨របស់ថ្នាក់គ្រប់គ្រងអង្គភាពហិរញ្ញវត្ថុ-ជំនួយ អ.ស.អ. សម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម៖ កំណត់ហេតុនៃកិច្ចពិភាក្សា នៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៧ ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១៧ ដែលដកស្រង់ក្នុង *រឿងក្តី ឃីម ទិត្យ* ការដាក់ព័ត៌មានដែលទើបទទួលបាននាពេលថ្មីៗ របស់ ឃីម ទិត្យ ពាក់ព័ន្ធនឹងសំណើរបស់ ស.ច.ស. សុំឱ្យដាក់សារណាស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក និង ផលប៉ះពាល់លើសំណុំរឿង ០០៣, ០០៤ និង ០០៤/២ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៧ ឯកសារ D355/5 កថាខណ្ឌ ១២(គ)។

៥៩. អង្គភាពគាំពារការការពារក្តី បានជូនដំណឹងមកមេធាវីការពារក្តីថា "គោលជំហរនាពេលបច្ចុប្បន្ន របស់ការិយាល័យរដ្ឋបាលគឺថា ដូចនៅក្នុងសារណារបស់ការិយាល័យរដ្ឋបាល ដែលបានផ្ញើជូន ស.ច.ស. គឺបានផ្តល់រួចហើយនូវចម្លើយ ចំពោះសំណួរដែលលោកបានលើកឡើង..." ហើយថា ការិយាល័យរដ្ឋបាល "ត្រៀមខ្លួន និង ស្ម័គ្រចិត្តអនុវត្ត នូវរាល់ដីកាសម្រេចណាមួយ ដែលចេញ ដោយចៅក្រមរបស់ អ.វ.ត.ក."[131]។ ទោះបីជានៅក្នុងសារណាផ្ទាល់របស់ខ្លួន ការិយាល័យ រដ្ឋបាល "មិនមានអ្វីត្រូវបន្ថែមនៅពេលនេះក្តី"[132] ក៏ ស.ច.ស. អាចប្រើប្រាស់សិទ្ធិអំណាចស្វែងរក ការពិតរបស់ពួកគាត់ ដើម្បីស្នើសុំចម្លើយទៅនឹងសំណួរទាំងអស់នេះ សម្រាប់ធ្វើការសម្រេចលើ បញ្ហាថា តើត្រូវផ្លាកកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី ០០៣ ដែរឬយ៉ាងណា។ តាមរយៈការចង្អុល បង្ហាញទាំងអស់ ការណ៍ដែលការិយាល័យរដ្ឋបាលមិនមានផែនការបានបង្ហាញឱ្យឃើញថា មិន មានចំណង់ក្នុងការបន្ត ឱ្យហួសពីការត្រួតពិនិត្យដោយអង្គបុរេជំនុំជម្រះ ទៅលើដីកាដំណោះ ស្រាយឡើយ ឬ ប្រសិនបើរឿងក្តីឈានដល់ដំណាក់កាលជំនុំជម្រះនៅក្នុងសវនាការមែននោះ ផែនការ គឺជាការអង្វរសុំការផ្តល់ថវិកា ដែលជួយបំពេញកង្វះខាតបានអាប់រហ័សប៉ុណ្ណោះ។

៦០. ការដំណើរការសវនាការក្នុងពេលជាមួយគ្នា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតែមួយ នឹង មិនមានប្រសិទ្ធភាព ចំណាយពេលច្រើន ចំណាយថវិកាច្រើន និង ជាបន្ទុកធ្ងន់សម្រាប់គ្រប់អ្នក ដែលពាក់ព័ន្ធទាំងអស់ ជាមួយនឹងកិច្ចដំណើរការនីតិវិធី។ កត្តាបន្ថែមផ្សេងទៀតដូចជា "លក្ខណៈ និង ភាពស្មុគស្មាញនៃរឿងក្តីដែលត្រូវបានបញ្ជូនទៅជំនុំជម្រះក្នុងសវនាការ បញ្ហាសុខភាពរបស់ ជនជាប់ចោទ ដែលមានវ័យចាស់ជរា ឧបសគ្គផ្នែកភស្តុតាង និង ការអនុវត្ត ចំពោះការរៀបចំកិច្ច ដំណើរការនីតិវិធី និង ចំនួនញត្តិដាក់ដោយភាគីនានា" នឹងប៉ះពាល់ផងដែរដល់លទ្ធភាពរបស់ អ.វ.ត.ក. ក្នុងការរៀបចំសវនាការក្នុងពេលជាមួយគ្នា[133] ជាការសាកល្បងដ៏ធំផ្នែកគ្រប់គ្រងសំណុំរឿង សម្រាប់អង្គជំនុំជម្រះសាលាដំបូង និង អង្គភាពគាំពារតុលាការ។

---

[131] លិខិតរបស់ អ.គ.ក. ចំណងជើងថា "ឆ្លើយតប៖ សំណើសុំព័ត៌មានពាក់ព័ន្ធនឹងការពិភាក្សាលើការវិវឌ្ឍន៍នៃរឿងក្តី ០០៣, ០០៤ និង រឿងក្តី ០០៤/០២ និង ផលប៉ះពាល់លើថវិការបស់ អ.វ.ត.ក." ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៨ (*សូមមើល* ឯកសារភ្ជាប់ ២)។

[132] *ដូចខាងលើ*។

[133] កថាខណ្ឌ ៣៦ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

ឆ. ទាំង អ.វ.ត.ក. ទាំង UNAKRT មិនអាចធានាថា កិច្ចដំណើរការនីតិវិធីនឹងមានយុត្តិធម៌ ដោយសារវិបត្តិហិរញ្ញវត្ថុ ប្រសិនបើ ស.ច.ស. ចេញដីកាបញ្ឈប់រឿងទៅជំនុំជម្រះនោះ

៦១. មាស មុត ត្រូវតែទទួលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចគ្នានឹងជនជាប់ចោទក្នុងរឿងក្តី ០០១ និង រឿងក្តី ០០២ គឺមិនខុសគ្នាឡើយ បើមិនដូច្នោះទេសិទ្ធិរបស់គាត់ ក្នុងការទទួលបានការប្រព្រឹត្តស្មើគ្នា នឹងត្រូវបានរំលោភបំពាន[134]។ គាត់មានសិទ្ធិទទួលបានធនធានដូចគ្នា ការការពារផ្នែកនីតិវិធីដូចគ្នា និង ការពិចារណាតាមផ្លូវតុលាការ ដោយមានសំអាងហេតុ ដូចគ្នានឹងជនជាប់ចោទទាំងអស់នោះ ដែលបានទទួលនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល[135]។ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ តម្រូវឱ្យរឿងក្តីដែលមានលក្ខណៈដូចគ្នា ដោយសត្យានុម័ត ត្រូវតែទទួលបានការចាត់ការស្មើគ្នា[136]។ ចំណាត់ការខុសគ្នាចាំបាច់ត្រូវតែ "ផ្អែកលើលក្ខណៈវិនិច្ឆ័យដោយសមហេតុផល និង ដោយសត្យានុម័ត"[137]។ ការខ្វះខាតថវិកានឹងមិនមែនជាយុត្តិកម្ម សម្រាប់ចំណាត់ការ

---

[134] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់"។ សិទ្ធិទទួលបានការប្រព្រឹត្តស្មើគ្នា ក៏ត្រូវបានធានាផងដែរដោយមាត្រា ១៤(១) និង ២៦ នៃ កតិកាសញ្ញា ICCPR ។ សិទ្ធិទទួលបានការប្រព្រឹត្តស្មើគ្នា "គឺជាធាតុផ្សំមួយសំខាន់នៃការការពារសិទ្ធិមនុស្ស និង ប្រើជាមធ្យោបាយនីតិវិធី ដើម្បីការពារនីតិរដ្ឋ"។ គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីអធិប្បាយទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និង សាលាក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ឯកសារ អ.ស.ប. លេខ CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ ("សេចក្តីអធិប្បាយទូទៅលេខ ៣២") កថាខណ្ឌ ២។

[135] *សូមមើល ខាងលើ* កថាខណ្ឌ ៨៖ "សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និង សាលាក្តី ក្នុងន័យទូទៅ ជាការធានា បន្ថែមលើគោលការណ៍ដែលមានចែងក្នុងប្រយោគទីពីរនៃ មាត្រា ១៤ កថាខណ្ឌ ១ សិទ្ធិស្មើគ្នាចូលពិនិត្យសំណុំរឿង និង សិទ្ធិសមភាពមធ្យោបាយការពារក្តី និង ធានាថា ភាគីទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីចំពោះមុខ ទទួលបានប្រព្រឹត្តដោយគ្មានការរើសអើងណាមួយ"។

[136] *ខាងលើ* កថាខណ្ឌ ១៤៖ "ភាពស្មើគ្នានៅចំពោះមុខតុលាការ និង សាលាក្តី តម្រូវផងដែរថា រឿងក្តីស្រដៀងគ្នាត្រូវបានដោះស្រាយក្នុងដំណើរការនីតិវិធីស្រដៀងគ្នាដែរ។ ឧទាហរណ៍ ប្រសិនបើដំណើរការនីតិវិធីព្រហ្មទណ្ឌពិសេស ឬ តុលាការ ឬ សាលាក្តីដែលត្រូវបានបង្កើតឡើងជាពិសេស ត្រូវបានអនុវត្តក្នុងការកំណត់លើប្រភេទនៃរឿងក្តី មូលដ្ឋានច្បាស់លាស់ និង សមហេតុផល ត្រូវតែមានដើម្បីធ្វើយុត្តិកម្មដល់ការបែងចែកខុសគ្នានេះ"។

[137] *សូមមើល* Rita Hiro Balani *តទល់នឹង អេស្ប៉ាញ* ទំនាក់ទំនងព័ត៌មានលេខ 1021/2001 ឯកសារ អ.ស.ប. លេខ CCPR/C/77/D/1021/2001 (ឆ្នាំ ១៩៩៨) កថាខណ្ឌ ៤.៣។ *Waldman តទល់នឹង កាណាដា* (មតិដែលត្រូវបានអនុម័តនៅ ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៩) នៅ អ.ស.ប. របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្ស (ភាគទី II) ឯកសារ អ.ស.ប. លេខ A/55/40 កថាខណ្ឌ ១០.៦។

រឿងក្តីមិនស្មើភាពគ្នាឡើយ។ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ និងជនជាប់ចោទ មិនអាចពឹងផ្អែកទៅលើធាតុផ្សំខាងក្រៅឡើយ។ ប៉ុន្តែស្ថានភាពថវិការបស់ អ.វ.ត.ក. និង ចក្ខុវិស័យទៅមុខគឺថា សិទ្ធិមនុស្សរបស់ មាស មុត ត្រូវពឹងផ្អែកទៅលើធាតុផ្សំខាងក្រៅ គឺតាមចំណង់របស់ប្រទេសផ្តល់ជំនួយ។

៦២. <u>ដីកាដំណោះស្រាយ</u>៖ មាស មុត មានសិទ្ធិទទួលបានការវាយតម្លៃលើភស្តុតាង ដោយលម្អិត និងមិនលម្អៀង[138]។ គាត់ក៏មានសិទ្ធិទទួលបានផងដែរ នូវដីកាដំណោះស្រាយដែលមានសំអាងហេតុ[139] និងការបកប្រែឯកសារនេះទាន់ពេលវេលា[140] ដែលជាផ្នែកមួយនៃសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់

---

[138] កថាខណ្ឌ ៣៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[139] វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង៖ "ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ"។ មតិមានសំអាងហេតុ "បង្ហាញយ៉ាងច្បាស់និងជាក់ស្តែងនូវការយល់ឃើញផ្នែកអង្គហេតុ និង អង្គច្បាប់ ដែលជាមូលដ្ឋាននៃការចេញសេចក្តីសម្រេច"។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ndindiliyimana និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-00-56-A សាលក្រម ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ២៩៣ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ នៅ អ.វ.ត.ក. "វាល់សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ - មិនថាជាសេចក្តីសម្រេចផ្តាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរឡើយ - ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ ចំពោះសេចក្តីសម្រេចទាំងនោះ ដែលជាផលនៃការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ជាការពិតណាស់ សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងពេញលេញ គឺជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះ"។ *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.ជ.ស.ប/អ.ជ.ត.ក(១៥) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ន្ឈន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១២ ឯកសារ E176/2/1/4 កថាខណ្ឌ ២៥ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ ដីកាដំណោះស្រាយដែលមានសំអាងហេតុ ដាក់ម្ចាស់បណ្តឹងឧទ្ធរណ៍ "ក្នុងស្ថានភាពមួយដែលអាចកំណត់បានថា តើដាក់ប្តឹងឧទ្ធរណ៍ដែរឬយ៉ាងណា និង ប្តឹងលើមូលដ្ឋានអ្វី។ ដូចគ្នានេះដែរ ភាគីដែលឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍ មានសិទ្ធិទទួលបានការជូនដំណឹងអំពីសំអាងហេតុ ដើម្បីឱ្យខ្លួនអាចត្រៀមរៀបចំការឆ្លើយតបរបស់ខ្លួនឱ្យបានត្រឹមត្រូវ និង ពាក់ព័ន្ធ"។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏ត្រូវមានសេចក្តីសម្រេចដែលមានសំអាងហេតុក្នុងការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ដែរ។ *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ២៤។

[140] ជនត្រូវចោទ និង ជនជាប់ចោទនៅ អ.វ.ត.ក. មានសិទ្ធិទទួលបានការជូនដំណឹងទាន់ពេលវេលា និង លម្អិតស្តីពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងខ្លួន ក្នុងភាសាមួយដែលពួកគេអាចយល់ដឹងបាន។ ក្នុងរឿងក្តី ០០២ ស.ច.ស. បានពិចារណាថា "ការបកប្រែភាសាចំពោះដីកានានារបស់សហចៅក្រមស៊ើបអង្កេត ទៅជាភាសាផ្លូវការទាំងពីរដែលប្រើប្រាស់

គាត់ ទទួលបាននូវពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ ក្នុងការត្រៀមរៀបចំការការពារក្តី[141] និង ទទួលបានការជំនុំជម្រះក្តីក្នុងពេលវេលាមួយសមស្រប[142]។ ចំពោះបញ្ហាថា តើគាត់នឹងទទួលបាន សិទ្ធិទាំងអស់នេះដែរឬយ៉ាងណានោះ គឺអាស្រ័យលើការណ៍ដែលថា ក.ស.ច.ស. ទទួលបាន ធនធាន និង បុគ្គលិកគ្រប់គ្រាន់[143]។ ស.ច.ស. បានកត់សម្គាល់ថា ការផ្តាស់ប្តូរបុគ្គលិកបានបណ្តាល ឱ្យមានការបាត់បង់នូវការចងចាំរបស់ស្ថាប័ន ហើយបើមានការកាត់បន្ថយបុគ្គលិកបន្ថែមទៀត

ដោយមេធាវីការពារ មានគោលដៅធានាឱ្យមានការផ្តល់នូវរយៈពេលមួយគ្រប់គ្រាន់ដល់មេធាវីការពារក្តី ដើម្បីត្រៀមរៀបចំធ្វើការការពារក្តីរបស់ខ្លួននៅក្នុងពេលសវនាការលើអង្គសេចក្តី"។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេលកំណត់ ដែលដាក់ដោយជនត្រូវចោទ ខៀវ សំផន ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D335/1 កថាខណ្ឌ ៣។

[141] សិទ្ធិទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំការការពារក្តី មានចែងក្នុងមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង មាត្រា ១៤(៣)(ខ) នៃ កតិកាសញ្ញា ICCPR។ "ការរៀបចំបទដ្ឋានដើម្បីកំណត់ពេលវេលា និង មធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំការការពារក្តី គឺមិនអាចធ្វើបានទេ។ រយៈពេលនៃការរៀបចំ អាស្រ័យលើកត្តាជាក់លាក់មួយចំនួនសម្រាប់រឿងក្តីនីមួយៗ ដូចជា ឧទាហរណ៍ ភាពស្មុគស្មាញនៃរឿងក្តី ចំនួនតុលាការ និង បទចោទប្រកាន់ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ កាលៈទេសៈរបស់ជនជាប់ចោទម្នាក់ៗ ស្ថានភាព និង ទំហំនៃការបង្ហាញឯកសាររបស់រដ្ឋអាជ្ញា និង ចំនួនបុគ្គលិករបស់ក្រុមមេធាវីការពារក្តី"។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ngirabatware* សំណុំរឿងលេខ ICTR-99-54-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Augustin Ngirabatware ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធញត្តិសុំផ្តាស់ប្តូរកាលបរិច្ឆេទការជំនុំជម្រះ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២៨។

[142] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. តម្រូវឱ្យមានដំណើរការនីតិវិធីដែល "ប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និង រាប់រហ័ស ... ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ"។ វិធាន ២១(៤) នៃវិធានផ្ទៃក្នុង តម្រូវថា "ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ... ធ្វើការជំនុះជម្រះក្នុងរយៈពេលមួយសមស្រប"។ *សូមមើលផងដែរ* មាត្រា ៣៥ ថ្មី(គ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១២(១), ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញា ICCPR។ សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប "គឺមិនត្រឹមតែត្រូវបានបង្កើតឡើង ដើម្បីជៀសវាងកុំឱ្យមានការរង់ចាំយូរ ដោយមិនមានភាពច្បាស់លាស់អំពីជោគវាសនារបស់ខ្លួន ... ប៉ុន្តែក៏ដើម្បីបម្រើផលប្រយោជន៍យុត្តិធម៌ផងដែរ។ អ្វីដែលសមស្រប គឺត្រូវមានការវាយតម្លៃក្នុងស្ថានភាពនៃរឿងក្តីនីមួយៗ ដោយពិចារណាជាពិសេសទៅលើភាពស្មុគស្មាញនៃរឿងក្តី ការប្រព្រឹត្តរបស់ជនជាប់ចោទ និង លក្ខណៈនៃបញ្ហាដែលត្រូវបានដោះស្រាយដោយអាជ្ញាធររដ្ឋបាល និង អាជ្ញាធរតុលាការ។... នៅគ្រប់ដំណាក់កាលទាំងអស់ ទាំងនៅសាលាដំបូង ឬ សាលាឧទ្ធរណ៍ ត្រូវតែធ្វើការជំនុំជម្រះក្តី ដោយមិនមានការពន្យាពេលវេលា"។ កថាខណ្ឌ ៣៥ នៃសេចក្តីអធិប្បាយទូទៅលេខ ៣២។

[143] កថាខណ្ឌ ២៧ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧៖ "កង្វះធនធានគ្រប់គ្រាន់នឹងជះឥទ្ធិពលទៅលើការព្រាងដីកាដំណោះស្រាយក្នុងរឿងក្តីទាំងអស់"។

នោះ បុគ្គលិកត្រូវ "ស្ថិតក្រោមសម្ពាធកាន់តែខ្លាំង ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពការងារ និង ពន្យារពេលវេលាដែលត្រូវការ សម្រាប់បញ្ចប់កិច្ចស៊ើបសួរ ហេតុនេះហើយធ្វើឱ្យប៉ះពាល់ដល់កិច្ច ដំណើរការនីតិវិធីតុលាការទាំងអស់"[144]។

៦៣. <u>អង្គបុរេជំនុំជម្រះ</u>៖ ប្រសិនបើ មាស មុត ត្រូវបានបញ្ជូនទៅជំនុំជម្រះនោះ គាត់មានសិទ្ធិប្តឹង ឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ[145]។ គាត់ក៏មានសិទ្ធិផ្តល់ការឆ្លើយតបយ៉ាងស្វាហាប់ ទៅនឹង ចម្លើយរបស់ ស.ព.អ. និង ឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. ឬ របស់ភាគីដើមបណ្តឹង រដ្ឋប្បវេណី ដែលអាចមាន[146]។ គាត់ក៏មានសិទ្ធិផងដែរ ក្នុងការទទួលបានសាលដីកាលើបណ្តឹង ឧទ្ធរណ៍ ដែលមានសំអាងហេតុ គឺការពិចារណាពេញលេញទៅលើកំហុសអង្គហេតុ និង កំហុស អង្គច្បាប់ និង ការរំលោភបំពានលើឆន្ទានុសិទ្ធិនានា ដែលបានលើកឡើង នៅក្នុងពេលវេលាសម ស្រប ហើយនឹងត្រូវបកប្រែទៅជាភាសាដែលគាត់អាចយល់បាន[147]។ ថាតើគាត់អាចទទួលបាន សិទ្ធិទាំងនេះដែរឬយ៉ាងណានោះ គឺអាស្រ័យទៅលើអង្គបុរេជំនុំជម្រះ ថាបានទទួលធនធាន និង

---

[144] កថាខណ្ឌ ៤២ នៃសំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក.។

[145] វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ផ្តល់ឱ្យជនត្រូវចោទ នូវសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់ ស.ច.ស. ដែលបានបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក.។

[146] មេធាវីដែលត្រូវបានតែងតាំងឱ្យតំណាងក្តីឱ្យជនជាប់ចោទក្រីក្រ ត្រូវតែមានប្រសិទ្ធភាពនៅក្នុងការតំណាងក្តីរបស់ពួកគេ ដោយរួមបញ្ចូលការស្ថិតក្នុងស្ថានភាពមួយដែលអាចធ្វើការឆ្លើយតបដោយស្វាហាប់ ចំពោះការអះអាងផ្នែកច្បាប់ និង អង្គហេតុ ទាំងអស់ ដែលបានលើកឡើងដោយភាគីបដិបក្ខ។ *សូមមើល* កថាខណ្ឌ ៣៨ នៃ សេចក្តីអធិប្បាយទូទៅលេខ ៣២ (ចែងថា មេធាវីដែលត្រូវបានតែងតាំងឱ្យតំណាងក្តីឱ្យជនជាប់ចោទក្រីក្រ ត្រូវតែមានប្រសិទ្ធភាពនៅក្នុងការតំណាងក្តីរបស់ខ្លួន ហើយថា ការរំលោភលើសិទ្ធិទទួលបានជំនួយផ្នែកច្បាប់កើតមានឡើង "ប្រសិនបើតុលាការ ឬ អាជ្ញាធរដទៃទៀត រាំងមេធាវីដែលទទួល បានការតែងតាំង ពីការបំពេញកិច្ចរបស់ខ្លួនដោយប្រសិទ្ធភាព")។ *សូមមើលផងដែរ រឿងក្តី ន្លួន ជា និងអ្នកផ្សេងទៀត* សំណុំ រឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ២៤ (ទទួលស្គាល់ថា ភាគីដែលត្រូវឆ្លើយតប ត្រូវដឹងសំអាងហេតុនៃសេចក្តីសម្រេច ដើម្បីរៀបចំការឆ្លើយតបដោយប្រសិទ្ធភាព)។

[147] វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង តម្រូវឱ្យអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចដែលមានសម្អាងហេតុ។ *សូមមើលផងដែរ* ជើងទំព័រ ១៣៩ *ខាងលើ*។

បុគ្គលិកគ្រប់គ្រាន់ ដើម្បីពិនិត្យមើលលើសារណា ដែលដាក់ដោយភាគី និង ភស្តុតាងនៅក្នុងសំណុំរឿង[148]។

៦៤. <u>អង្គជំនុំជម្រះសាលាដំបូង</u>៖ នៅក្នុងពេលជំនុំជម្រះក្នុងសវនាការ មាស មុត ត្រូវទទួលបានសិទ្ធិលើកឡើងអញ្ជត្រកម្ម[149] មានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការការពារក្តី[150] សួរដេញដោលអ្នកចោទប្រកាន់គាត់ និង បង្ហាញរឿងក្តីរបស់គាត់[151] ជំទាស់ចំពោះភស្តុតាងដែលលើកឡើង ដោយសហព្រះរាជអាជ្ញា និង ភាគីដើមបណ្តឹងរដ្ឋប្បវេណី[152] ទទួលបានការតាម

---

[148] កថាខណ្ឌ ៣៣ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[149] វិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ចែងពីសិទ្ធិដល់ជនជាប់ចោទ ក្នុងការលើកបញ្ហាអញ្ជត្រកម្មទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ បញ្ហាណាមួយដែលតម្រូវឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធី និង មោឃភាពនៃកិច្ចនីតិវិធីណាមួយដែលត្រូវបានធ្វើឡើង ក្រោយពីការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិធាន ៨៩(៣) នៃវិធានផ្ទៃក្នុង តម្រូវឱ្យអង្គជំនុំជម្រះត្រូវសម្រេចអំពីអញ្ជត្រកម្មតាមសេចក្តីសម្រេចមួយដែលមានសំអាងហេតុ "ជាបន្ទាន់ ឬ នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី"។

[150] *សូមមើល* មាត្រា ៣៥ ថ្មី (ខ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១២(២), ១៣(២), ១៣(២) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញា ICCPR។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ngirabatware* សំណុំរឿងលេខ ICTR-99-54-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Augustin Ngirabatware ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធញត្តិសុំផ្លាស់ប្តូរកាលបរិច្ឆេទការជំនុំជម្រះ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ ២៨។ *សូមមើលផងដែរ* ជើងចំពរ ១៤១ *ខាងលើ*។

[151] មាត្រា ៣៥ ថ្មី (ង) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១៤(៣)(ង) នៃកតិកាសញ្ញា ICCPR។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ *សូមមើលផងដែរ* វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង៖ "ជនជាប់ចោទមានសិទ្ធិស្នើសុំឱ្យកោះហៅសាក្សីដាក់បន្ទុក ដែលជនជាប់ចោទមិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ"។ សិទ្ធិតទល់ ឬ សួរដេញដោលសាក្សី គឺជាសិទ្ធិជាមូលដ្ឋានក្នុងការទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ជា "ឧបករណ៍នីតិវិធីសម្រាប់ជួយធ្វើតេស្តភស្តុតាង និង ផ្តល់លទ្ធភាពឱ្យតុលាការសម្រេចថាតើភស្តុតាងនោះអាចជឿទុកចិត្តបានដោយសុវត្ថិភាពត្រឹមកម្រិតណា"។ Ian Dennis *សិទ្ធិតទល់សាក្សី៖ អត្ថន័យ ជំនឿ និង សិទ្ធិមនុស្ស* (Confront Witnesses: Meanings, Myths, and Human Rights) 4 CRIM L.REV ទំព័រ ២៥៥ និង ២៥៩។*សូមមើលផងដែរ ដូចខាងលើ* ទំព័រ ២៦៦៖ "ការសួរដេញដោលសាក្សីបដិបក្ខ ផ្តល់លទ្ធភាពឱ្យជនជាប់ចោទចូលរួមពេញលេញនៅក្នុងការបង្ហាញភស្តុតាងដល់អ្នកស្វែងរកការពិត។ សេរីភាព និង សេចក្តីថ្លៃថ្នូររបស់ជនជាប់ចោទ ត្រូវបានទទួលស្គាល់តាមរយៈការឱ្យសំឡេងរបស់ខ្លួនត្រូវបានដឹងឮក្នុងកម្រិតអតិបរមា ដោយមិនគិតពីអនុភាពនៃការសួរដេញដោលសាក្សីលើភាពអាចជឿបាននៃភស្តុតាង និង លទ្ធផលសមទំនងនៃរឿងក្តី"។

[152] *សូមមើល* វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង៖ "អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក- មិនជាប់ពាក់ព័ន្ធ ឬ ជាការស្មើសុំជាន់គ្នា ខ- មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ- មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ- ច្បាប់មិនអនុញ្ញាត ឬ ង- មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬ គ្មានប្រយោជន៍"។ *សូមមើលផងដែរ រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-

ដានពិនិត្យសុខភាព[153] ទទួលបានការបកប្រែឯកសារទាន់ពេលវេលា[154] ទទួលបានការបកប្រែកិច្ច ដំណើរការនីតិវិធី[155] ដាក់ញត្តិស្តីពីនីតិវិធី និង ច្បាប់ជាធរមាន[156] ដាក់បណ្តឹងសាទុក្ខបន្ទាន់បង្ខំ

២០០៧-អ.វ.ត.ក/អ.ជ.ស.ដ *សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១២ ឯកសារ E96/7 កថាខណ្ឌ ២៧៖ "នៅពេលដែលកំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗរបស់ ក.ស.ច.ស. ទៅលើសាក្សីដែលមិនត្រូវបានកោះហៅឱ្យផ្តល់ភ័ស្តុតាងនៅពេលសវនាការ ត្រូវបានស្នើសុំឱ្យដាក់... នៅចំពោះមុខអង្គជំនុំជម្រះ ដោយមិនមានវត្តមានរបស់សាក្សីផ្តល់ចម្លើយនោះទេ មេធាវីការពារក្តីត្រូវបានផ្តល់ឱ្យនូវសិទ្ធិដែលមានតម្លៃស្មើគ្នា ដើម្បីធ្វើការជំទាស់ដែលពាក់ព័ន្ធទៅនឹងសម្ភារនេះ ប្រសិនបើមាន"។

[153] វិធាន ៣២ នៃវិធានផ្ទៃក្នុង៖ "ក្នុងគោលបំណងដើម្បីបញ្ជាក់ថា ជនត្រូវចោទ ឬ ជនជាប់ចោទមានសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តអាចចូលរួមក្នុងការជម្រះក្តី ឬ ក៏ដោយសារមូលហេតុផ្សេងទៀត ឬ តាមសំណើរបស់ភាគីណាមួយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចបង្គាប់ឱ្យជនត្រូវចោទ ឬ ជនជាប់ចោទទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រវិកលចរិត ចិត្តសាស្ត្រដោយអ្នកជំនាញ"។ *សូមមើលផងដែរ* វិធាន ១១(១) នៃវិធានសម្រាប់គ្រប់គ្រងការឃុំខ្លួនជន ដែលរង់ចាំការជំនុំជម្រះ ឬ ប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៨៖ "អង្គភាពពេទ្យ អ.វ.ត.ក. ត្រូវផ្តល់ការថែទាំសុខភាពដល់ជនជាប់ឃុំ"។

[154] ជនត្រូវចោទ ឬ ជនជាប់ចោទ ត្រូវទទួលបានការបកប្រែឯកសារ ដែលជាផ្នែកមួយនៃសិទ្ធិរបស់ខ្លួន ក្នុងការចូលរួមការការពារក្តីខ្លួន។ ដើម្បីចូលរួមដោយប្រសិទ្ធភាពក្នុងកិច្ចដំណើរការនីតិវិធី ជនជាប់ចោទត្រូវមានលទ្ធភាពអាចយល់ដឹងប្រភេទនៃបទចោទ យល់ពីកិច្ចដំណើរការនីតិវិធី យល់ពីព័ត៌មានលម្អិតនៃភស្តុតាង ផ្តល់ការណែនាំមេធាវី និង ជួយក្នុងការការពារក្តីរបស់ខ្លួនផ្ទាល់ និង យល់ពីលទ្ធផលនៃកិច្ចដំណើរការនីតិវិធី។ ការអនុវត្តសិទ្ធិនេះត្រូវបានបញ្ជាក់តាមរយៈការផ្តល់ភស្តុតាង និងសេចក្តីសម្រេចក្នុងភាសាមួយដែលជនត្រូវចោទ ឬ ជនជាប់ចោទ អាចយល់ដឹងបាន។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Strugar* សំណុំរឿងលេខ IT-01-42-T សេចក្តីសម្រេច យោងញត្តិរបស់មេធាវីការពារក្តីសុំបញ្ចប់កិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៦។ *សូមមើលផងដែរ រឿងក្តី Lagerblom តទល់នឹង ស៊ុយអែត* តុលាការ HCtHR សំណុំរឿងលេខ 26891/95 សាលក្រម ចុះថ្ងៃទី ១៤ ខែមេសា ឆ្នាំ ២០០៣ កថាខណ្ឌ ៥៩ ដែលបានបង្ហាញថា មាត្រា ៦ នៃអនុសញ្ញា ECHR "ធានាសិទ្ធិរបស់ជនជាប់ចោទ ក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ។ មាត្រា ៦ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ដែលត្រូវបានធ្វើវិសោធនកម្មដោយពិធីសារលេខ ១១ និង ១៤ ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៥០ ("អនុសញ្ញា ECHR")។ នៅ អ.វ.ត.ក. ភាគីនានាដែលស្នើសុំបង្ហាញឯកសារនៅពេលសវនាការ ត្រូវធានាឱ្យទាន់ពេលវេលានូវឯកសារបកប្រែជាភាសាផ្លូវការទាំងបីភាសា។ *រឿងក្តី ខ្លួន ជា និងអ្នកផ្សេងទៀត* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158 ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១២ ឯកសារ E162 កថាខណ្ឌ ៨។

[155] *សូមមើល* មាត្រា ៣៥ ថ្មី (ច) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ៣០ នៃវិធានផ្ទៃក្នុង។

[156] វិធាន ៩២ នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យជនជាប់ចោទដាក់ញត្តិជាលាយលក្ខណ៍អក្សរ រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល។

ប្រឆាំងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅអង្គជំនុំជម្រះតុលាការកំពូល[157] និង ទទួលបានការជំនុំជម្រះក្តីក្នុងពេលវេលាមួយសមស្រប[158]។ ថាតើគាត់ទទួលបានសិទ្ធិទាំងអស់នេះដែរឬយ៉ាងណានោះ គឺអាស្រ័យទៅលើអង្គជំនុំជម្រះសាលាដំបូង និង អង្គភាពគាំទ្រកិច្ចការតុលាការ ដែលមានផ្នែកគ្រប់គ្រងតុលាការ អង្គភាពបកប្រែភាសា អង្គភាពប្រតិចារឹក អង្គភាពគាំពារសាក្សី និង អ្នកជំនាញ អង្គភាពមន្ទីរឃុំឃាំង អង្គភាពបណ្ណាសារ និង អង្គភាពសោតទស្សន៍ ដែលមានធនធាន និង បុគ្គលិកគ្រប់គ្រាន់[159]។

៦៥. <u>អង្គជំនុំជម្រះតុលាការកំពូល</u>៖ មាស មុត មានសិទ្ធិប្តឹងសាទុក្ខ ចំពោះសាលក្រមណាមួយដែលផ្តន្ទាទោសគាត់ និង ឆ្លើយតបយ៉ាងស្វាហាប់ចំពោះចម្លើយ និង បណ្តឹងសាទុក្ខណាមួយ ដែល ស.ព.អ. អាចនឹងដាក់[160]។ គាត់ក៏មានសិទ្ធិផងដែរទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ ដើម្បីបង្ហាញបណ្តឹងឧទ្ធរណ៍របស់គាត់ និង ការត្រួតពិនិត្យយ៉ាងពេញលេញ ដោយអង្គជំនុំជម្រះតុលាការកំពូល ទៅលើកំហុសអង្គហេតុ និង កំហុសអង្គច្បាប់ ដែលបានលើកឡើង[161]។ ថាតើគាត់

---

[157] វិធាន ១០៥(៤) នៃវិធានផ្ទៃក្នុង ចែងថាជនជាប់ចោទមានសិទ្ធិប្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ការឃុំខ្លួន និង ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ វិធានការការពារ និង ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។

[158] *សូមមើល* ជើងទំព័រ ១៤២ *ខាងលើ*។

[159] កថាខណ្ឌ ៤១ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។ កថាខណ្ឌ ៥៩ នៃថវិកា អ.វ.ត.ក. ឆ្នាំ ២០១៨-២០១៩។

[160] មាត្រា ១៤(៥) នៃ កតិកាសញ្ញា ICCPR ធានាថា "ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និង ការផ្តន្ទាទោសឡើងវិញ ស្របតាមច្បាប់"។ *សូមមើលផងដែរ* វិធាន ១០៥(១) នៃវិធានផ្ទៃក្នុង។ *រឿងក្តី ខួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសំណើសុំដាក់បញ្ចូលឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ២៤៖ "ភាគីមានសិទ្ធិជាមូលដ្ឋានដើម្បីបានទទួលដំណឹងអំពីហេតុផលនៃសេចក្តីសម្រេចណាមួយ។ ប្រការនេះអនុញ្ញាតឱ្យភាគីបានដឹងអំពីមូលដ្ឋាននៃសេចក្តីសម្រេចនីមួយៗ ដែលធ្វើឱ្យភាគីរងគ្រោះស្ថិតក្នុងស្ថានភាពមួយដែលអាចកំណត់បានថាតើនឹងដាក់ប្តឹងឧទ្ធរណ៍ដែរឬយ៉ាងណា និង ប្តឹងលើមូលដ្ឋានអ្វី។ ដូចគ្នានេះដែរ ភាគីដែលឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍មានសិទ្ធិទទួលបានការជូនដំណឹងអំពីសំអាងហេតុ ដើម្បីឱ្យខ្លួនអាចត្រៀមរៀបចំការឆ្លើយតបរបស់ខ្លួនឱ្យបានត្រឹមត្រូវ និង ពាក់ព័ន្ធ"។

[161] *សូមមើល* ជើងទំព័រ ១៤១ *ខាងលើ* ទាក់ទងនឹងសិទ្ធិទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ និង ជើងទំព័រ ១៣៩ ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ។

នឹងទទួលបានសិទ្ធិទាំងអស់នេះដែរឬយ៉ាងណានោះ គឺអាស្រ័យទៅលើអង្គជំនុំជម្រះតុលាការកំពូល ដែលមានធនធាន និងបុគ្គលិកគ្រប់គ្រាន់[162]។

៦៦. ប្រសិនបើថវិកាត្រូវកាត់បន្ថយ ហើយកិច្ចដំណើរការនីតិវិធីត្រូវបញ្ចប់ នៅចំណុចណាមួយ បន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត រួមទាំងសច្ចធារណ៍និរទោស និង សិទ្ធិតទល់ជាមួយអ្នកចោទប្រកាន់គាត់ នឹងត្រូវបានរំលោភបំពាន[163]។ មិនមានយន្តការដែលនៅសេសសល់ផ្សេងទៀត សម្រាប់ច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ នៅពេលដែលដីកានេះត្រូវបានចេញនោះ[164]។ មាស មុត នឹងមិនមានឱកាសណាមួយ ដើម្បីបង្ហាញពីភាពគ្មានទោសរបស់គាត់ទេ។ គាត់ត្រូវទទួលរងនូវស្នាកស្នាមអាក្រក់ជាអចិន្ត្រៃយ៍ ដែលគាត់ត្រូវបានតុលាការដែលគាំទ្រដោយ អ.ស.ប. បញ្ជូនទៅជំនុំជម្រះ អំពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ដែលជាក្តីបារម្ភរបស់សហគមន៍អន្តរជាតិទាំងមូល ដែលក្នុងនោះមានទាំងអំពើប្រល័យពូជសាសន៍ផងដែរ។ ប្រាកដណាស់ថា ស្ថានភាពនេះ គឺជាស្ថានភាពដែលមិនអាចទទួលបាន ដែល ស.ច.ស. បានព្យាយាមមិនឱ្យកើតឡើង។

ជ. មានតែការផ្អាកកិច្ចដំណើរការនីតិវិធីរឿងក្តី ០០៣ ទាំងស្រុងជាអចិន្ត្រៃយ៍ទេ ទើបធានាបាននូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត

៦៧. ស.ច.ស. បានដឹងថា កេរដំណែលរបស់ អ.វ.ត.ក. គឺត្រូវមានទាំងកេរដំណែលវិជ្ជមាន និងកេរដំណែលអវិជ្ជមាន[165]។ ស.ច.ស. ព្យាយាមដកខ្លួនចេញ ពីកេរតំណែលដែលពាក់ព័ន្ធនឹងការច្តឹងច្តែងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនណាម្នាក់ ជាមួយនឹងធនធានទ្រព្យសម្បត្តិដែលមាននោះ[166] ដោយលើកឡើងពីក្តីព្រួយបារម្ភ ពីការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយ

---

[162] កថាខណ្ឌ ៤៨ នៃផែនការបញ្ចប់ អ.វ.ត.ក. កំណែលើកទី ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧។

[163] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។

[164] កថាខណ្ឌ ១២ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[165] កថាខណ្ឌ ៣៩ នៃសំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក.។

[166] *អ្នកខាងលើ*៖ "ភាគីពាក់ព័ន្ធផ្សេងៗបាននិយាយយ៉ាងច្រើនអំពី "កេរដំណែល" ដែល អ.វ.ត.ក. ត្រូវបន្សល់ទុកសម្រាប់កិច្ចការរដ្ឋបាលតុលាការនៅក្នុងប្រទេសកម្ពុជា និង សម្រាប់សង្គមជាទូទៅ។ យើងសូមបញ្ជាក់ថា តាមការយល់ឃើញរបស់យើង "កេរដំណែល" ណាក៏ដោយក្នុងន័យនេះ មិនអាចបង្កើតឡើងដោយសិប្បនិម្មិត មិនអាចមិនឱ្យជាប់ពាក់ព័ន្ធ និង មិនពឹងផ្អែកលើការពិតជាក់ស្តែងបានឡើយ។ កេរដំណែលដែលយើងបន្សល់ទុក គឺជាកេរដំណែលដែលយើងបន្សល់ទុកគ្រប់រូបភាព ទាំង

បានក្រើនរំលឹកដល់អ្នកទាំងឡាយ ដែលទទួលខុសត្រូវលើថវិការបស់តុលាការ។ ស.ច.ស. បានដឹងថា គឺជាការបោះបង់ចោលនូវករណីយកិច្ចផ្លូវច្បាប់របស់ខ្លួន ក្នុងការចេញដីកាដំណោះស្រាយប្រសិនបើមានលទ្ធភាពខ្ពស់ដែលថា នឹងមិនមានថវិកាគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះ និង ការប្តឹងសាទុក្ខ[167]។ ស.ច.ស. ដឹងថា គឺជាការរំលោភបំពានលើសិទ្ធិមនុស្សជាសារវន្ត ដែលទុកឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅបន្តលងបន្លាចពីលើក្បាល មាស មុត ក្នុងរយៈពេលមិនមានកំណត់រហូតដល់មានការធានាថាមានថវិកា សម្រាប់ចាប់ផ្តើមកិច្ចដំណើរការនីតិវិធី ដោយមិនមានការធានាថា កិច្ចដំណើរការនីតិវិធីនឹងត្រូវធ្វើឡើងយ៉ាងឆាប់រហ័ស និង បញ្ចប់ដោយពេញលេញ ឬ ក្នុងករណីអាក្រក់បំផុត គឺមានត្រឹមដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅលងបន្លាចគាត់ និង គ្រួសារគាត់ជារៀងរហូត[168]។

៦៨. ស.ច.ស. ដឹងថា កំហុសនីតិវិធីនេះ មិនអាចកែតម្រូវបានឡើយ នៅពេលចេញដីកាដំណោះស្រាយរួច។ នៅពេលដែល មាស មុត ត្រូវបញ្ជូនទៅជំនុំជម្រះក្នុងសវនាការ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់ គឺអាស្រ័យទៅលើការប្រែប្រួលចិត្តរបស់ អ.ស.ប. និង ប្រទេសផ្តល់ជំនួយ ទៅលើ “ការសន្យា” ដែលមិនចងកាតព្វកិច្ច គ្មានភាពច្បាស់លាស់ និង មិនស៊ីចង្វាក់គ្នា។ ជាភាពអយុត្តិធម៌ មិនត្រឹមត្រូវ និង មិនអាចទទួលយកបានឡើយ ដែលត្រូវបញ្ចប់ការស៊ើបអង្កេត ហើយចេញដីកាដំណោះស្រាយដែលបញ្ជូនសំណុំរឿង មាស មុត ទៅជំនុំជម្រះក្នុងសវនាការ តែបដិសេធមិនឱ្យគាត់បានចូលសវនាការ និង បដិសេធនូវសិទ្ធិរបស់គាត់ ដែលទទួលស្គាល់ជាអន្តរជាតិនោះ។ គាត់នឹងមិនមានមធ្យោបាយណាផ្សេង ដើម្បីស្វែងរកដំណោះស្រាយឡើយ ប្រសិនបើចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយរឿងក្តីមិនអាចបន្តទៅមុខនោះ។

៦៩. ដើម្បីជៀសវាងពីព្យសនកម្មដែលមិនអាចកែតម្រូវបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ មាស មុត និង ភាពអយុត្តិធម៌យ៉ាងជាក់ស្តែងនោះ ស.ច.ស. ដើម្បីបំពេញបានតាមពាក្យសច្ចាប្រណិធាន ពេលចូលកាន់តំណែង ដែលត្រូវធានាឱ្យបាននូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ ចាំបាច់ត្រូវផ្អាករឿងក្តី ០០៣ ទាំងស្រុង ជាអចិន្ត្រៃយ៍។

វិជ្ជមាន ទាំងអវិជ្ជមាន។ កេរដំណែលមួយដែលយើងយល់ឃើញថា គុណាការណាក៏ដោយគួរប្រឹងប្រែងឱ្យអស់សមត្ថភាព ដើម្បីជៀសវាងសម្រាប់មនុស្សជំនាន់ក្រោយទាំងអស់ គឺកេរដំណែល ដែលភាពប្រញាប់ប្រញាល់សំខាន់ជាងដំណើរការនីតិវិធីត្រឹមត្រូវ”។

[167] *ដូចខាងលើ* កថាខណ្ឌ ៥៣។

[168] *ដូចខាងលើ* កថាខណ្ឌ ៥៤-៥៥។

III. ច្បាប់

ក. កត្តាសម្រាប់ការវាយតម្លៃលើយុត្តាធិការបុគ្គល

៧០. យុត្តាធិការលើបុគ្គលរបស់ អ.វ.ត.ក. គឺកម្រិតត្រឹម "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត" នៅក្នុងប្រទេសកម្ពុជារវាងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ ១៩៧៩[169]។ ស.ព.អ. ចោទប្រកាន់ថា មាស មុត គឺជាមេដឹកនាំជាន់ខ្ពស់ផង និង អ្នកទទួលខុសត្រូវខ្ពស់បំផុតផង[170]។ មាស មុត មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ហើយក៏មិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។ គាត់មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. នោះទេ[171]។

៧១. ពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនត្រូវបានកំណត់និយមន័យឱ្យ បានច្បាស់លាស់ឡើយ នៅក្នុងឯកសារបង្កើត អ.វ.ត.ក.៖ គឺកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[172]។ ខណៈដែលពាក្យ "មេដឹកនាំជាន់ខ្ពស់" ងាយស្រួលយល់ ពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មានលក្ខណៈពិបាកយល់ជាង។ សម្ភារឯកសារនៃកិច្ចចរចា ដែលមាន បានជួយផ្តល់ពន្លឺបន្តិចបន្តួច ទៅលើបញ្ហាថា តើនរណាដែលភាគីនៃកិច្ចព្រមព្រៀងស្តីពី ការបង្កើត អ.វ.ត.ក. ចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"[173]។ ឯកសារនៃកិច្ចចរចាភាគច្រើន មិនអាចរកបានជាសាធារណៈទេ[174]។

---

[169] មាត្រា ១ មាត្រា ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.៖ "កិច្ច ព្រមព្រៀងនេះ ទទួលស្គាល់ផងដែរថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរូបបុគ្គលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិប តេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានចែងក្នុងមាត្រា ១ នៃកិច្ចព្រមព្រៀង"។

[170] ដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D256/7 ("ដីកាសន្និដ្ឋានស្តាពរ") កថាខណ្ឌ ១០៧៨-១១០៨។

[171] *សូមមើល* ផ្នែកទី IV *ខាងក្រោម*៖ មាស មុត មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ហើយក៏មិនមែនជាអ្នក "ទទួលខុសត្រូវខ្ពស់ បំផុត" ដែរ។

[172] *សូមមើល* មាត្រា ១ មាត្រា ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១ មាត្រា ២(១) មាត្រា ៥(៣) មាត្រា ៦(៣) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។

[173] *សូមមើល* សំណើរបស់ មាស មុត សុំឱ្យយក និង ដាក់ទៅក្នុងសំណុំរឿងនូវសម្ភារឯកសាររបស់អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចារបង្កើត អ.វ.ត.ក. ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D170 ("សំណើសុំ

៧២. មេធាវីការពារក្តីបានស្នើដល់ ស.ច.ស. សុំសម្ភារឯកសារចរចា ហើយដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿង[175]។ ស.ច.ស.អ. "បានយល់ស្របតាមមេធាវីការពារក្តីថា ដើម្បីជួយបញ្ជាក់ពីចេតនារបស់អ្នកព្រាងកិច្ចព្រមព្រៀង គប្បីពិចារណាលើប្រវត្តិទាំងស្រុងនៃកិច្ចចរចារ ដែលនាំឱ្យមានការអនុម័តលើកិច្ចព្រមព្រៀង ទៅតាមកម្រិតដែលអាចធ្វើបាន មិនមែនពិចារណាលើឯកសារដែលសម្រិតសម្រាំងនោះទេ"[176]។ ស.ច.ស.អ. បានខិតខំប្រឹងប្រែងដើម្បីរកឯកសារនេះ ហើយផ្តល់ទៅឱ្យភាគីនានានៅក្នុងរឿងក្តីទាំងអស់ ដែលស្ថិតក្រោមការស៊ើបអង្កេតរបស់

សម្ភារឯកសារ អ.ស.ប.") កថាខណ្ឌ ៣១-៣៤។ ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីឃុត្តាធិការបុគ្គល ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D181 ("ដីកាសម្រេចរួមលើសំណើស្តីពីឃុត្តាធិការបុគ្គល") កថាខណ្ឌ ៣៣។

[174] *សូមមើល* សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេចដើម្បីទទួលបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D181/1 ("សេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេចដើម្បីទទួលបានឯកសារបណ្ណសារ") កថាខណ្ឌ ៤-៦។ មេធាវីការពារក្តីក៏បានផ្ញើលិខិតជូនលោក Scheffer - ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទទួលបន្ទុកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម - ដែលបានចូលរួមក្នុងការដឹកនាំការចរចាបង្កើត អ.វ.ត.ក. និង លោក Stephen Heder អតីតបុគ្គលិក ក.ស.ព. និង ជាអតីតអ្នកស៊ើបអង្កេត/អ្នកវិភាគនៃ ក.ស.ច.ស. ដែលបានសរសេរពីសាវតានៃការចរចាក្នុងការបង្កើត អ.វ.ត.ក. ដោយបានស្នើពួកគាត់ឱ្យផ្តល់ប្រភពសម្ភារឯកសារដែលពាក់ព័ន្ធ ហើយដែលត្រូវបានដកស្រង់នៅក្នុងសំណេររបស់ពួកគេ ដើម្បីឱ្យបានយល់ពីបរិបទ និង ខ្លឹមសារនៃការចរចា។ ស.ច.ស.អ. បានចាត់ទុកថា លិខិតរបស់មេធាវីការពារក្តីជាសំណើសុំបំពេញកិច្ចស៊ើបសួរតែប៉ុណ្ណោះ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ ស.ច.ស. ហើយបានស្នើឱ្យលោក Scheffer និង លោក Heder ធ្វើការឆ្លើយតបផ្ទាល់ទៅគាត់។ លោក Scheffer បានជូនដំណឹងទៅ ស.ច.ស.អ ថា "បន្ទាប់ពីបានពិភាក្សាជាមួយការិយាល័យប្រឹក្សាច្បាប់របស់ក្រសួងការបរទេស ស.រ.អ. និង ជាមួយការិយាល័យទទួលបន្ទុកកិច្ចការច្បាប់របស់ អ.ស.ប. ឯកសារមួយចំនួនដែលមេធាវីការពារក្តីបានស្នើ មិនអាចត្រូវបង្ហាញបានទេ។ ពាក់ព័ន្ធនឹងឯកសារដទៃទៀត លោក Scheffer បានជូនដំណឹងទៅ ស.ច.ស.អ. ឱ្យទាក់ទងទៅក្រសួងការបរទេស ស.រ.អ.។ ក្រសួងការបរទេស ស.រ.អ. មិនដែលបានឆ្លើយតបទៅនឹងសំណើសុំឯកសាររបស់ ស.ច.ស.អ. ឡើយ។ លោក Heder បានជូនដំណឹង ស.ច.ស.អ. ថា លោកលែងមានឯកសារភាគច្រើនដែលក្រុមមេធាវីការពារក្តីបានស្នើសុំហើយ។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧ ឯកសារ D224 EN 01375463-01375464 KH 01428543-01428546។ លិខិតផ្ញើជូនលោក David Scheffer ចំណងជើងថា "សំណើសុំប្រភពសម្ភារឯកសារពាក់ព័ន្ធនឹងឃុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D224.1។ លិខិតផ្ញើជូនលោក Stephen Heder ចំណងជើងថា "សំណើសុំប្រភពសម្ភារឯកសារពាក់ព័ន្ធនឹងឃុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D224.2។

[175] សំណើសុំសម្ភារឯកសារ អ.ស.ប.។ *សូមមើលផងដែរ* ជើងទំព័រ ១៧៤ *ខាងលើ*។

[176] កថាខណ្ឌ ៣៣ នៃដីកាសម្រេចរួមលើសំណើស្តីពីឃុត្តាធិការបុគ្គល។

ក.ស.ច.ស.[177]។ ទោះបីជា ស.ច.ស.អ. ប្រឹងប្រែងអស់ពីសមត្ថភាពយ៉ាងណាក្តី ក៏គាត់មិនអាចស្វែងរកឯកសារនេះឃើញដែរ[178]។ ដោយពិចារណាឃើញថា សម្ភារឯកសារទាំងនោះមានលក្ខណៈ "រសើប" អ.ស.ប. បានបដិសេធមិនបំពេញតាមសំណើរបស់ ស.ច.ស.អ.[179]។

៧៣. ស.ច.ស. បានសម្រេចរួចហើយថា ពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មិនអាចបណ្តាលឱ្យ "ក.ស.ព. ឬ ក.ស.ច.ស. មានឆន្ទានុសិទ្ធិដោយគ្មានកំណត់ ក្នុងការជ្រើសរើសនោះឡើយ"[180]។ ស.ច.ស. ក៏បានសម្រេចផងដែរថា ការប្រើប្រាស់យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះលើសមត្ថកិច្ច របស់សាលាក្តី ICTY ក្នុងការសម្រេចថាតើនរណាម្នាក់ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូចដែល ស.ព.អ. បានលើកទឡ្លីករណ៍ឡើងនោះ[181] គឺជាការមិនសមស្របឡើយ ដោយសារតែបរិបទនៃការចរចាជាពិសេសរបស់ អ.វ.ត.ក.[182]។ ស.ច.ស. បង្ហាញនូវកត្តាជាច្រើនសម្រាប់ពិចារណា ក្នុងការវាយតម្លៃថា តើជនត្រូវចោទស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណា[183]។

---

[177] *ដូចខាងលើ។ សូមមើលផងដែរ* ជើងចំពីរ ១៧៥ *ខាងលើ* ទាក់ទងនឹងការព្យាយាមរបស់ ស.ច.ស.អ. ដើម្បីទទួលបានពីលោក Scheffer និង លោក Heder នូវសម្ភារឯកសារ ដែលដកស្រង់នៅក្នុងសំណេររបស់ពួកគេអំពីការដឹកនាំការចរចាបង្កើត អ.វ.ត.ក.។

[178] កថាខណ្ឌ ៦ នៃសេចក្តីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេចដើម្បីទទួលបានឯកសារបណ្ណសារ។

[179] *ដូចខាងលើ* កថាខណ្ឌ ៥។

[180] កថាខណ្ឌ ៩ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ *សូមមើលផងដែរ* កថាខណ្ឌ ៣០ នៃដីកាសម្រេចរួមលើសំណើ ស្តីពីឃុត្តាធិការបុគ្គល៖ "ខ្ញុំមិនអាចទទួលយកថា "ឃុត្តាធិការបុគ្គល" នៅ អ.វ.ត.ក. គឺជាទស្សនទានមួយដែលមិនអាចធ្វើការវិនិច្ឆយបានទេ។ តាមការយល់ឃើញរបស់ខ្ញុំ ការណ៍ដែលថា ឆន្ទានុសិទ្ធិរបស់ ស.ច.ស. អាចត្រូវត្រួតពិនិត្យឡើងវិញដោយតុលាការ នៅពេលដែលអនុវត្តឆន្ទានុសិទ្ធិ "*ដោយពុំសុទ្ធចិត្ត*" (in bad faith) និង "*មិនស្របទៅតាមការវិនិច្ឆយប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ*" (unsound professional judgement) នោះ ជាគោលការណ៍ គឺធ្វើឱ្យការបកស្រាយពាក្យពេចន៍អាចធ្វើការវិនិច្ឆយបាន។ ទឡ្លីករណ៍របស់ [អ.ជ.ត.ក] ធ្វើការសន្និដ្ឋានដោយប្រយោលថា មានបទដ្ឋានមួយដែលអាចធ្វើការត្រួតពិនិត្យឡើងវិញបែបនោះបានដោយសារមានការរំលោភបំពាន។ តាមការយល់ឃើញរបស់ខ្ញុំ ចំណុចនេះធ្វើឱ្យពាក្យពេចន៍ទាំងនោះក្លាយជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការយ៉ាងពិតប្រាកដ ទោះបីជាត្រូវធ្វើការវាយតម្លៃឱ្យបានទូលំទូលាយយ៉ាងណាក៏ដោយ គឺខុសពីគោលការណ៍ណែនាំមួយដាច់ខាតចំពោះ ស.ច.ស."។ (អក្សរផ្តែកនៅក្នុងឯកសារដើម)។

[181] កថាខណ្ឌ ១០៥៤-៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[182] កថាខណ្ឌ ១៨ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[183] *ដូចខាងលើ* កថាខណ្ឌ ៣-៤១។

ក. ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ដែលចង់កម្រិតកំណត់យុត្តាធិការលើបុគ្គលរបស់ អ.វ.ត.ក. ឱ្យនៅត្រឹមបុគ្គលណាដែលមានការទទួលខុសត្រូវធំបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[184]។

ខ. គោលការណ៍មានវិមតិសង្ស័យ នឹងបានជាប្រយោជន៍ដល់ជនត្រូវចោទ និង ការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត[185]។

គ. តួនាទីផ្លូវការរបស់ជនត្រូវចោទ នៅក្នុងឋានានុក្រម និង កម្រិតដែលគាត់អាចសម្រេចលើគោលនយោបាយរបស់ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយនេះ[186]។ និង

ឃ. ស្ថានទម្ងន់ប្រហាក់ប្រហែល នៃអំពើរបស់ជនត្រូវចោទ និង ផលប៉ះពាល់នៃអំពើនេះ គឺអាស្រ័យទៅតាមចេតនារបស់ភាគី នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ក្នុងការកម្រិតយុត្តាធិការរបស់ អ.វ.ត.ក. ឱ្យនៅត្រឹមបុគ្គលណាដែលមានការទទួលខុសត្រូវធំបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[187]។

៧៤. ក្នុងការអះអាងថា មាស មុត គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះ ស.ព.អ. បានចង្អុលទៅ កាំង ហ្គេកអ៊ាវ ("ឌុច") ហើយចោទប្រកាន់ថា មាស មុត មានការទទួលខុសត្រូវធំជាង[188]។ ឌុច ជាករណីពិសេស។ ទោះបីជាគាត់មិនមានតួនាទីដឹកនាំនៅក្នុងបក្សក៏ដោយ ក៏ ឌុច ត្រូវបានគេចាត់ទុកថា មានការទទួលខុសត្រូវខ្ពស់ ចំពោះការសម្លាប់រង្គាលនៅមន្ទីរ ស-២១។ គាត់បានសារភាពជាសាធារណៈរួចមកហើយ អំពីឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១ ដែលជាទីតាំងមួយត្រូវបានផ្តោតជាពិសេស ដោយក្រុមអ្នកជំនាញរបស់អគ្គលេខាធិការ អ.ស.ប.[189]។ ឌុច ត្រូវបានឃុំខ្លួននៅតុលាការ

---

[184] *ដូចខាងលើ* កថាខណ្ឌ ១៨-១៩។

[185] *ដូចខាងលើ* កថាខណ្ឌ ២៦-៣៦។

[186] *ដូចខាងលើ* កថាខណ្ឌ ៣៩។

[187] *ដូចខាងលើ* កថាខណ្ឌ ៣៨។

[188] កថាខណ្ឌ ១០៩៦ នៃដីកាសន្និដ្ឋានស្តាពរ។

[189] *សូមមើល* របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតលេខ 52/135 ឯកសារ អ.ស.ប. លេខ A/53/850 និង លេខ S/1999/231 ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ("របាយការណ៍របស់ក្រុមអ្នកជំនាញ") ឧបសម្ព័ន្ធ កថាខណ្ឌ ៥៥ *អាចរកបាននៅគេហទំព័រ* http://undocs.org/A/53/850៖ "ដូចដែលកំណត់ត្រាឯកសារបង្ហាញច្បាស់ថា តួនាទីរបស់បុគ្គលជាក់លាក់ ដែលជាអ្នកចូលរួមផ្ទាល់ ឬ ជាថ្នាក់លើ វាហាក់ដូចលាតសន្ធឹងយ៉ាងខ្លាំងចំពោះអំពើឃោរឃៅមួយចំនួន ដែលគេស្គាល់ច្បាស់បំផុត គឺប្រតិបត្តិការនៃមន្ទីរសួរចម្លើយនៅឡូលស្តែង។

យោធា[190] ដូច្នេះហើយគាត់អាចយកមកធ្វើការជំនុំជម្រះបានភ្លាមៗ។ ការមិនចេញដីកាបញ្ជូនគាត់ទៅជំនុំជម្រះ នឹងបង្កឱ្យមានការសង្ស័យ[191]។ ស.ច.ស. គួរតែកុំអើពើនឹងការប្រៀបធៀបរវាង មាស មុត និង ឌុច ដោយ ស.ព.អ. ហើយវិភាគថាតើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬយ៉ាងណា ដោយផ្អែកលើកត្តាសម្រាប់ការវាយតម្លៃរបស់ពួកគេ។

១. ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.

៧៥. នៅពេលដែលក្រុមអ្នកជំនាញរបស់អគ្គលេខាធិការ អ.ស.ប. បានផ្តល់អនុសាសន៍សម្រាប់ការ "នាំយកមេដឹកនាំខ្មែរក្រហមមកធ្វើការជំនុំជម្រះ" ក្រុមអ្នកជំនាញបានសន្និដ្ឋានថា៖ "ការកាត់ទោសមិនគួរព្យាយាមនាំយកទៅជំនុំជម្រះ ទូវមនុស្សទាំងអស់ ឬ មនុស្សភាគច្រើន ដែលបានប្រព្រឹត្តការរំលោភបំពានទៅលើច្បាប់កម្ពុជា ឬ ច្បាប់អន្តរជាតិ នៅក្នុងពេលវេលាពាក់ព័ន្ធនោះឡើយ។ សេណារីយ៉ូបែបនេះ... គឺមិនអាចធ្វើទៅបានទាំងផ្នែកភស្តុភារ និង ផ្នែកហិរញ្ញវត្ថុ សម្រាប់រាល់សាលាក្តីទាំងឡាយណា ដែលគោរពសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានដំណើរការសមស្រប"[192]។ ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. គឺ អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា បានដឹងពីចំនួនអ្នកស្លាប់ដ៏ច្រើនលើសលប់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏ដឹងថាបុគ្គលដែលអាចជាចារី គឺមានចំនួនយ៉ាងច្រើន[193]។ "ការចុះកិច្ចព្រមព្រៀងដោយមិនមានចែងពីយុត្តាធិការបំពេញបន្ថែមផ្សេងទៀត នៅក្នុងតុលាការជាតិកម្ពុជា គឺជាជម្រើសមនសិការ

ចំពោះអំពើឃោរឃៅដទៃទៀត ភស្តុតាងឯកសារដែលជាប់ពាក់ព័ន្ធផ្ទាល់ជាមួយបុគ្គលនានា ដែលស្ថិតនៅក្នុងជួររដ្ឋាភិបាលជាន់ខ្ពស់ ឬ នៅថ្នាក់ភូមិភាគ ឬ ថ្នាក់មូលដ្ឋាន ឬក៏យ៉ាងណាទេ គឺមិនមានពេលបច្ចុប្បន្ននោះទេ ហើយក៏មិនអាចរកបានជារៀងរហូត ដោយសារតែភាពមិនស៊ីចង្វាក់នៃការថែរក្សាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ និង ការបាត់បង់ជាក់ស្តែងនៃឯកសារជាច្រើន ចាប់តាំងពីឆ្នាំ ១៩៧៩ មក"។

[190] ឧបសម្ព័ន្ធ I កថាខណ្ឌ ១ នៃសាលក្រមក្នុងរឿងក្តី ០០១។

[191] *សូមមើល* លោក Stephen Heder *យុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់" ខ្មែរក្រហម និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម៖ ប្រវត្តិ និង ការវិវឌ្ឍន៍នាពេលថ្មីៗនេះ* លេខ ២៧ (ថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១២) *ដែលអាចរកបាននៅ* http://www.cambodiatribunal.org/sites/default/files/A%20Review%20of%20the%20Negotiations%20Leading%20to%20the%20Establishment%20of%20the%20Personal%20Jurisdiction%20of%20the%20ECCC.pdf។

[192] *សូមមើល* កថាខណ្ឌ ១០៦ នៃរបាយការណ៍របស់ក្រុមអ្នកជំនាញ។

[193] កថាខណ្ឌ ១៨ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

នយោបាយ" របស់ អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា[194]។ ជាមួយគ្នានេះដែរ "មានគម្លាតនិទណ្ឌភាពយ៉ាងខ្លាំង សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ... មិនត្រូវមានឥទ្ធិពលលើផ្នែកគោលនយោបាយ" មកលើការវិភាគលើយុត្តាធិការបុគ្គលរបស់ ស.ច.ស. ឡើយ[195]។ យុត្តាធិការលើបុគ្គលដែលមានកម្រិតរបស់ អ.វ.ត.ក. បានឆ្លុះបញ្ចាំងពី "គោលបំណងថែរក្សាសន្តិភាព និង ការផ្សះផ្សាជាតិ" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលកើតចេញពីការធ្វើសមាហរណកម្មពួកខ្មែរក្រហម ចូលមកក្នុងសង្គម"[196] ហើយនិងសមត្ថភាពព្រមទាំងធនធានមានកម្រិតរបស់ អ.វ.ត.ក. ក្នុងការស៊ើបអង្កេត និង ជំនុំជម្រះ។

៧៦. ទឡ្ហីករណ៍របស់ ស.ព.អ. ដែលថា ស.ច.ស. ប្រើប្រាស់យុត្តាធិការរបស់អង្គជំនុំជម្រះលើសមត្ថកិច្ចរបស់សាលាក្តី ICTY ក្នុងការវាយតម្លៃលើស្ថានទម្ងន់ នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ធៀបទៅនឹងកម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ[197] គឺមិនសមស្របឡើយនៅ អ.វ.ត.ក. ដូចដែល ស.ច.ស. បានសម្រេចដូច្នេះដែរ[198]។ វិធីសាស្ត្រដែល ស.ព.អ. បានស្នើឡើង នឹងនាំទៅដល់បន្ទុកសំណុំរឿងកាន់តែធំ និង ការស៊ើបអង្កេតយ៉ាងច្រើន[199] ដែល "ច្បាស់ណាស់ពុំមែនជាអ្វីដែលអ្នកតាក់តែងច្បាប់គ្រប់គ្រង អ.វ.ត.ក. បានប្រមើលមើលឃើញនោះទេ ប៉ុន្តែ ពួកគេបានដឹងថានៅមានចារីប្រហោទនេះជាច្រើនសន្លឹកសន្ធាប់ទៀត ហើយពួកគេនឹងមិនត្រូវបាននាំមកកាត់ទោសនោះទេ"[200]។ មានតែបុគ្គលមួយក្រុមតូចប៉ុណ្ណោះ ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[201]។

---

[194] *ដូចខាងលើ* កថាខណ្ឌ ៣២។

[195] *ដូចខាងលើ* កថាខណ្ឌ ២៥។

[196] *ដូចខាងលើ* កថាខណ្ឌ ១៦។ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[197] កថាខណ្ឌ ១០៥៤-៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[198] កថាខណ្ឌ ១៨ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[199] *ដូចខាងលើ* កថាខណ្ឌ ១៩។ *សូមមើលផងដែរ* វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហព្រះរាជអាជ្ញាបើកការស៊ើបអង្កេត ប្រសិនបើពួកគេមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានកើតមានពិត។

[200] កថាខណ្ឌ ១៩ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[201] *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៣១៖ "ច្បាស់ណាស់ថា អ.វ.ត.ក. គឺជាតុលាការមួយដែលស្វែងរកយុត្តិធម៌តាមបែបជ្រើសរើស យោងតាមគោលបំណងនៃពាក្យពេចន៍ដែលបានចែង ពីព្រោះមានតែមនុស្សមួយក្រុមតូចតែប៉ុណ្ណោះ ដែលនឹងត្រូវយកមកចោទប្រកាន់នៅក្នុង អ.វ.ត.ក. ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺ អ្នកទាំងឡាយដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់តុលាការ"។

២. គោលការណ៍វិមតិសង្ឃ័យ នឹងបានជាប្រយោជន៍ដល់ជនត្រូវចោទ និង ការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត

៧៧. រាល់វិមតិសង្ឃ័យទាំងអស់ក្នុងការវាយតម្លៃទៅលើអង្គហេតុ និង ការបកស្រាយច្បាប់ រួមទាំងបទប្បញ្ញត្តិស្តីពីយុត្តាធិការរបស់ អ.វ.ត.ក. ចាំបាច់ត្រូវតែបកស្រាយជាប្រយោជន៍ដល់ជនត្រូវចោទ[202]។ "ការអនុវត្តគោលការណ៍ វិមតិសង្ឃ័យបានជាប្រយោជន៍ដល់ជនត្រូវចោទ ការបកស្រាយក្នុងន័យចង្អៀត... មានសារសំខាន់ជាងគេនៅក្នុងប្រព័ន្ធ ដែលច្បាប់មិនបានចែងពេញលេញ"[203]។ គោលការណ៍នេះកាន់តែសំខាន់ជាពិសេស ក្នុងករណីដែលតាមក្បែកសាធារណជន និង ប្រព័ន្ធផ្សព្វផ្សាយ ពិរុទ្ធភាពរបស់ជនត្រូវចោទ "ហាក់ដូចជាមិនចាំបាច់ពិភាក្សាដេញដោល *តាំងពីដំបូង* (*ab initio*) ហើយកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ ពុំមែនគ្រាន់តែជាការយល់ស្រប និង ការបញ្ជាក់ជាផ្លូវការគាំទ្រចំពោះទស្សនយល់ឃើញ ជាទូទៅដែលមានស្រាប់ប៉ុណ្ណោះទេ"[204]។

៣. តួនាទីផ្លូវការរបស់ជនត្រូវចោទ នៅក្នុងឋានានុក្រម និង កម្រិតដែលគាត់អាចធ្វើការសម្រេច លើគោលនយោបាយរបស់ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយនេះ

៧៨. ក្នុងការវាយតម្លៃទៅលើតួនាទីផ្លូវការរបស់ជនត្រូវចោទ នៅក្នុងឋានានុក្រម ការពិចារណាដ៏សំខាន់មួយគឺការពិចារណាទៅលើកម្រិតដែលគាត់អាចចូលរួមចំណែក ឬ កម្រិតដែលគាត់អាចសម្រេចលើគោលនយោបាយរបស់ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយនោះ[205]។ ការណ៍ដែលជនត្រូវចោទអាចធ្វើការទំនាក់ទំនង ជាមួយបុគ្គលដែលអាចត្រូវបានចាត់ទុក ថាជាមេដឹកនាំជាន់ខ្ពស់នោះ គឺមិនមែនជាកត្តាកំណត់ថា តើជននោះជាមេដឹកនាំជាន់ខ្ពស់ដែរឬយ៉ាងណានោះឡើយ[206]។ ការណ៍ដែលជនត្រូវចោទអាចមានតួនាទីខ្ពស់ នៅពេលណាមួយនោះ ក៏មិនមែនជាកត្តាកំណត់សម្រាប់ការវាយតម្លៃ ទៅលើតួនាទីរបស់គាត់នៅពេលដែលមានឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានគេ

---

[202] *ដូចខាងលើ* កថាខណ្ឌ ២៦-២៧។

[203] *ដូចខាងលើ* កថាខណ្ឌ ២៧។

[204] *ដូចខាងលើ* កថាខណ្ឌ ២៨។

[205] *ដូចខាងលើ* កថាខណ្ឌ ៣៩-៤០។

[206] *ដូចខាងលើ* កថាខណ្ឌ ៣១៥។

ស៊ើបអង្កេតនោះដែរ[207]។ ប្រហែលគ្នានេះ "ករណីបុគ្គលណាម្នាក់បានបង្កើត ឬ ត្រូវបង្កើតគំនិតផ្តួចផ្តើមរបស់ខ្លួន ... គឺពុំមែនជាលក្ខណៈវិនិច្ឆ័យមួយ ដែលអាចនឹងឱ្យបុគ្គលនោះស្ថិតក្នុងប្រភេទអ្នកទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ"[208]។

៥. ស្ថានទម្ងន់ប្រហាក់ប្រហែល នៃអំពើរបស់ជនត្រូវចោទ និង ផលប៉ះពាល់នៃអំពើនោះ គឺអាស្រ័យទៅតាមចេតនារបស់ភាគី នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ក្នុងការកម្រិតព្រំដែនយុត្តាធិការរបស់ អ.វ.ត.ក. ឱ្យនៅត្រឹមបុគ្គលណាដែលមាន ការទទួលខុសត្រូវធំបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

៧៩. ខណៈដែលស្ថានទម្ងន់ប្រហាក់ប្រហែល នៃអំពើរបស់ជនត្រូវចោទ និង ផលប៉ះពាល់នៃអំពើនោះគឺជាចំណុចដ៏ត្រឹមត្រូវនៃការយោង ការវាយតម្លៃនេះ គឺត្រូវផ្អែកតាមការយល់ដឹងដែលថា ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. "ចង់កំហិតយុត្តាធិការបុគ្គល ឱ្យនៅត្រឹមអ្នកដែលមានការទទួលខុសត្រូវខ្ពស់ជាងគេបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[209]។ លក្ខណៈ និង ចំនួននៃបទចោទប្រកាន់របស់ ស.ព.អ. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ព្រមទាំងវិសាលភាពដែលបទចោទប្រកាន់ទាំងនោះត្រូវបានបង្ហាញតាមរយៈភស្តុតាង គឺចាំបាច់ត្រូវតែពិនិត្យមើលធៀបនឹងទិដ្ឋភាពទាំងស្រុងនៃការឈឺចាប់ ដែលបណ្តាលមកពីគោលនយោបាយរបស់ ប.ក.ក.[210]។ ការណ៍នេះ "ចៀសមិនរួចនឹងមានការពិនិត្យលើចំនួនអ្នកស្លាប់សរុប ដែលបណ្តាលមកពីការសម្លាប់ ការបង្អត់អាហារដោយចេតនា ឬ ដោយការធ្វេសប្រហែល ចំពោះពលករដោយបង្ខំ និង អ្នកទោស ព្រមទាំងសេវាសុខភាពសាធារណៈដែលជាទូទៅមិនគ្រប់គ្រាន់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ចំនួនអ្នកដែលត្រូវផ្លាស់ទីលំនៅ និង អ្នកដែលត្រូវបានបង្ខំឱ្យធ្វើការធ្ងន់។ល។"[211]។

---

[207] កថាខណ្ឌ ៣១៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[208] *ដូចខាងលើ* កថាខណ្ឌ ៤០។

[209] *ដូចខាងលើ* កថាខណ្ឌ ១៨។

[210] *ដូចខាងលើ* កថាខណ្ឌ ៣១៧។

[211] *ដូចខាងលើ*។

៨០. ចាំបាច់ត្រូវពិនិត្យមើលចំនួនជនរងគ្រោះ នៅក្នុងបរិបទនៃភស្តុតាងទាំងមូល នៅក្នុងសំណុំរឿង ហើយនិងផ្អែកលើសកម្មភាព ការវិវឌ្ឍន៍ និង តួនាទីផ្ទាល់របស់ជនត្រូវចោទ[212]។ ការកំណត់ប្រភេទនៃបទចោទជាច្រើន ទៅលើអង្គហេតុតែមួយ ដែលអនុញ្ញាតឱ្យមានការចោទប្រកាន់ និង ការផ្តន្ទាទោសច្រើននោះ មិនបានបង្កើនខ្លាំង នូវស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ឡើយ[213]។ ការមានឈ្មោះថាជាមនុស្សកាចសាហាវ ក៏មិននាំឱ្យមានការកើនឡើងនូវការទទួលខុសត្រូវនោះដែរ[214]។

៥. សេចក្តីសន្និដ្ឋាន

៨១. នៅក្នុងការវាយតម្លៃថា តើ មាស មុត ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដែរឬយ៉ាងណានោះ ស.ច.ស. ចាំបាច់ត្រូវតែពិចារណាទៅលើចេតនារបស់ភាគី នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ទៅលើគោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ និង ការបកស្រាយច្បាប់ព្រហ្មទណ្ឌក្នុងន័យចង្អៀត ទៅលើតួនាទីផ្លូវការរបស់គាត់ នៅក្នុងឋានានុក្រម និង សិទ្ធិអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចគោលនយោបាយ របស់ ប.ក.ក. និង/ឬ ការអនុវត្តគោលនយោបាយនោះ ព្រមទាំងស្ថានទម្ងន់ប្រហាក់ប្រហែល នៃអំពើរបស់គាត់ និង ផលប៉ះពាល់នៃអំពើនោះ ដែលអាស្រ័យទៅតាមចេតនារបស់ភាគីនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ដែលបានកម្រិតយុត្តាធិការរបស់ អ.វ.ត.ក. ឱ្យនៅត្រឹមបុគ្គលដែលមានការទទួលខុសត្រូវខ្ពស់បំផុត ចំពោះការឈឺចាប់ដែលបង្កឡើង ដោយគោលនយោបាយរបស់ ប.ក.ក. នៅទូទាំងប្រទេសកម្ពុជា។

ខ. បទដ្ឋានបង្ហាញភស្តុតាង សម្រាប់ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ

៨២. តាមវិធាន ៦៧(៣)(គ) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. (“វិធានផ្ទៃក្នុង”) ស.ច.ស. ត្រូវចេញដីកាលើកលែងការចោទប្រកាន់ ប្រសិនបើ “ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ”។ បទដ្ឋានបង្ហាញភស្តុតាង សម្រាប់សម្រេចថា តើមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងជនត្រូវចោទ ឬយ៉ាងណានោះ គឺមានភាពមិនច្បាស់លាស់។ ច្បាប់បារាំង និង ច្បាប់កម្ពុជា មិនបានជួយដល់ការ

---

[212] *ដូចខាងលើ* កថាខណ្ឌ ៣១៨។

[213] កថាខណ្ឌ ៣២៣ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[214] *ដូចខាងលើ* កថាខណ្ឌ ៣២៥។

កំណត់អំពីបទដ្ឋានបង្ហាញភស្តុតាងឡើយ[215]។ នៅក្នុងរឿងក្តី ០០១ រឿងក្តី ០០២ និង រឿងក្តី ០០៤/១ ស.ច.ស. បានអនុវត្តបទដ្ឋានផ្សេងៗគ្នា ក្នុងការសម្រេចថា តើត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះឬយ៉ាងណានោះ[216]។

៨៣. នៅក្នុងរឿងក្តី ០០១ ស.ច.ស. បានសម្រេចថា មាន "ភស្តុតាងគ្រប់គ្រាន់" ដើម្បីបញ្ជូន ឌុច ទៅជំនុំជម្រះ ហើយបានបញ្ជូនគាត់ទៅជំនុំជម្រះក្នុងសវនាការ ដោយមិនបានបញ្ជាក់អំពីបទដ្ឋានបង្ហាញភស្តុតាងណាមួយឡើយ[217]។ នៅក្នុងរឿងក្តី ០០២ ស.ច.ស. បានអនុវត្ត "បទដ្ឋានភាវនីយភាព"[218] ប៉ុន្តែមិនមានភាពច្បាស់លាស់ឡើយថា តើ ស.ច.ស. កំណត់បទដ្ឋាននេះដោយរបៀបណា ដោយផ្អែកលើយុត្តិសាស្ត្រអន្តរជាតិ និង អ្នកច្បាប់បារាំងដូចដែលបានដកស្រង់[219]។ នៅក្នុងប្រព័ន្ធ

---

[215] ក្នុងរឿងក្តី ០០២ ស.ច.ស. បានកត់សម្គាល់ពីកង្វះចន្លោះនៅក្នុងវិធានផ្ទៃក្នុង និង ច្បាប់របស់កម្ពុជា ទាក់ទងនឹងបទដ្ឋាននៃការបង្ហាញភស្តុតាង "ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់"។ ដោយពិនិត្យមើលប្រភពផ្សេងៗទៀត រួមមាន យុត្តិសាស្ត្ររបស់តុលាការបារាំង ដែលចែងថា៖ "ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង... មិនបានកំណត់និយមន័យជាក់លាក់ទេ។ យុត្តិសាស្ត្ររបស់តុលាការបារាំងក៏ដូចគ្នានេះដែរ"។ *សូមមើល រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 ("ដីកាដំណោះស្រាយក្នុងរឿងក្តី ០០២") កថាខណ្ឌ ១៣២១-២២។ នៅប្រទេសបារាំង ចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិពេញលេញ ក្នុងការចេញដីកាបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ហើយបទដ្ឋានសម្រាប់ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ គឺជាឆន្ទានុសិទ្ធិ។ លិបិក្រមនីតិព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ (Dalloz) Christian Guéry ការស៊ើបអង្កេតបឋម (ខែមិថុនា ឆ្នាំ២០១៣) កថាខណ្ឌ ៧៩៩៖ "Le juge d'instruction … décide en toute indépendance sur le règlement de l'information." "ការបកប្រែក្រៅផ្លូវការ៖ ចៅក្រមស៊ើបអង្កេត... សម្រេចដោយឯករាជ្យលើលទ្ធផលនៃដំណើរការនីតិវិធី"។ *សូមមើលផងដែរ* J.-A ROGRON ក្រមស៊ើបអង្កេតព្រហ្មទណ្ឌ និង ការអត្ថាធិប្បាយពន្យល់ក្រមព្រហ្មទណ្ឌ (បោះពុម្ពលើកទី ៤ ឆ្នាំ ១៨៤៩) ដែលដកស្រង់តុលាការកំពូលសភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៨២៤ ព្រឹត្តិប័ត្រព្រហ្មទណ្ឌ លេខ ១២៦។ *សូមមើលផងដែរ ជើងទំព័រ* ២១៩ *ខាងក្រោម*។

[216] *សូមមើល* កថាខណ្ឌ ៨៣ *ខាងក្រោម* ។

[217] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99 កថាខណ្ឌ ១៣០។

[218] កថាខណ្ឌ ១៣២៣ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០២។

[219] ក្នុងរឿងក្តី ០០២ ស.ច.ស. បានសំអាងលើមេធាវីបារាំងពីររូប គឺលោក Pierre Chambon និង លោក Christian Guéry និង បទដ្ឋានបញ្ជាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះពីសាលាក្តី ICTY សាលាក្តី ICTR និង តុលាការ ICC ក្នុងការសន្និដ្ឋានថាបទដ្ឋាននៃការបង្ហាញភស្តុតាងសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅ អ.វ.ត.ក. គឺជាតុល្យភាពនៃភាវនីយភាព។ *សូមមើល* កថាខណ្ឌ ១៣២០-២៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០២។ ក្នុងប្រព័ន្ធច្បាប់បារាំង សេចក្តីសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ គឺជាឆន្ទានុសិទ្ធិ។ *សូមមើល* ជើងទំព័រ ២១៥ *ខាងលើ* និង ជើងទំព័រ ២២០ *ខាងក្រោម*។ ចៅក្រមស៊ើបអង្កេតអាច

បារាំង សេចក្តីសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ គឺជាអំណាចឆន្ទានុសិទ្ធិ[220]។ យុត្តិសាស្ត្រអន្តរជាតិដែលបានដកស្រង់ដោយ ស.ច.ស. ក្នុងរឿងក្តី ០០២ មិនបានបង្ហាញពីវិធីសាស្ត្រទូទៅឡើយ គឺផ្ទុយពីការសន្និដ្ឋានរបស់ពួកគាត់[221]។ នៅក្នុងរឿងក្តី ០០៤/១ ស.ច.ស. បានអនុម័តយកបទដ្ឋានភវនីយភាពដោយមិនមានការពន្យល់បកស្រាយ[222]។

៨៤. បទដ្ឋានបង្ហាញភស្តុតាង ដែល ស.ច.ស. គួរតែអនុវត្តគឺថា *តើអង្គជំនុំជម្រះសាលាដំបូងដែលមានហេតុផល អាចផ្តន្ទាទោសជនត្រូវចោទ ឱ្យហួសពីវិមតិសង្ស័យដែរឬយ៉ាងណា ដោយផ្អែកលើភស្តុតាងនៅក្នុងសំណុំរឿង*។ សម្រាប់សំអាងហេតុដែលពន្យល់នៅផ្នែកខាងក្រោម បទដ្ឋាននេះមានយុត្តិកម្ម ដោយសារតែលក្ខណៈពិសេសនៃឧក្រិដ្ឋកម្ម បន្ទុកដ៏ធ្ងន់ក្នុងការចោទប្រកាន់ជនសង្ស័យនៅ អ.វ.ត.ក. រយៈពេលវែងគួរសមនៃកិច្ចស៊ើបអង្កេត និង ឱកាសដ៏ច្រើនរបស់ ស.ច.ស. ក្នុងការវាយតម្លៃលើភស្តុតាងនៅក្នុងសំណុំរឿង រហូតដល់ពេលដែល ស.ច.ស. ត្រូវព្រោងដីកាដំណោះស្រាយ។

៨៥. ស.ព.អ. លើកឡើងថា ស.ច.ស. អនុវត្តបទដ្ឋានបញ្ជាក់លើការបញ្ជូនរឿងទៅជំនុំជម្រះរបស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ (“តុលាការ ICC”) សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“សាលាក្តី ICTY ”) និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (“សាលាក្តី ICTR”)[223]។ បទដ្ឋានបង្ហាញភស្តុតាងដែល ស.ព.អ. បានដកស្រង់ មិនបានគិតអំពីភាពខុសគ្នារវាងដំណើរការចេញដីកាដំណោះស្រាយរបស់ អ.វ.ត.ក. និង ដំណើរការ

សម្រេចដោយសេរី លើលទ្ធផល *ដោយផ្អែកលើការវាយតម្លៃជាឥស្សរចិត្ត* (intime conviction)។ មិនមានភាពច្បាស់លាស់ពីរបៀបដែលលោក Pierre Chambon និង លោក Pierre Chambon ធ្វើសេចក្តីសន្និដ្ឋានលើបទដ្ឋានភវនីយភាពដូចម្តេច ក្នុងការអនុវត្តជាក់ស្តែងទេ។ *សូមមើល កថាខណ្ឌ* ៩៥-១០៦ *ខាងក្រោម* ដែលពិភាក្សាអំពីបទដ្ឋានបញ្ជាក់របស់តុលាការ និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ ឬ អន្តរជាតូបនិយកម្មនានា។

[220] លិបិក្រមនីតិព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ (Dalloz) Christian Guéry ការស៊ើបអង្កេតបឋម (ខែមិថុនា ឆ្នាំ២០១៣) កថាខណ្ឌ ៧៩៩។ *សូមមើលផងដែរ* J.-A ROGRON ក្រមស៊ើបអង្កេតព្រហ្មទណ្ឌ និង ការអត្ថាធិប្បាយពន្យល់ក្រមព្រហ្មទណ្ឌ (បោះពុម្ពលើកទី ៤ ឆ្នាំ ១៨៤៩) ដែលដកស្រង់តុលាការកំពូល សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៨២៤ ព្រឹត្តិប័ត្រព្រហ្មទណ្ឌលេខ ១២៦។

[221] កថាខណ្ឌ ១៣២៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០២។ *សូមមើល កថាខណ្ឌ* ៩៥-១០៦ *ខាងក្រោម* ដែលពិភាក្សាអំពីបទដ្ឋានបញ្ជាក់របស់តុលាការ និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ ឬ អន្តរជាតូបនិយកម្មនានា។

[222] *សូមមើល* កថាខណ្ឌ ២ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[223] កថាខណ្ឌ ១០៤៨-៥០ នៃដីកាសន្និដ្ឋានស្តាពរ។

បញ្ជាក់លើការបញ្ជូនរឿងទៅជំនុំជម្រះរបស់តុលាការទាំងអស់នោះទេ។ ដោយសារតែលក្ខណៈពិសេសនៃបរិបទ និង នីតិវិធីរបស់ អ.វ.ត.ក. ស.ច.ស. មិនគួរអនុម័តទទួលយកបទដ្ឋានទាំងនេះ ឬ បទដ្ឋានបញ្ជាក់របស់តុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិដទៃទៀតឡើយ។

១. បទដ្ឋានបង្ហាញភស្តុតាងជាធរមាន គួរតែជាបទដ្ឋានដែលថា តើអង្គជំនុំជម្រះសាលាដំបូងដែលមានហេតុផល អាចផ្តន្ទាទោសជនត្រូវចោទ ឱ្យហួសពីវិមាត្រសង្ស័យដែរឬយ៉ាងណា ដោយផ្អែកលើភស្តុតាងនៅក្នុងសំណុំរឿង

៨៦. លក្ខណៈវិសាមញ្ញរបស់ឧក្រិដ្ឋកម្ម ដែលត្រូវកាត់ទោសនៅ អ.វ.ត.ក. តម្រូវឱ្យមានបទដ្ឋានបង្ហាញភស្តុតាងដើម្បីផ្តន្ទាទោសជនត្រូវចោទ ខ្ពស់ជាងបទដ្ឋានបង្ហាញភស្តុតាង ដែលតម្រូវនៅក្នុងតុលាការបារាំង ឬ តុលាការកម្ពុជាធម្មតា[224]។ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា "គោលបំណងរបស់ អ.វ.ត.ក. ខុសគ្នាយ៉ាងខ្លាំងពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជាដែលតម្រូវឱ្យ អ.វ.ត.ក. មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស"[225]។ ស.ព.អ. ក៏បានទទួលស្គាល់ផងដែរ "ពីភាពចាំបាច់ដែលត្រូវបានទទួលយកយូរមកហើយនៅ អ.វ.ត.ក. យោងតាមលក្ខណៈវិសាមញ្ញនៃឧក្រិដ្ឋកម្មដែលបានស៊ើបអង្កេត និង ផ្តន្ទាទោសនៅតុលាការនេះ ដើម្បីចាកឆ្ងាយពីការអនុវត្តក្នុងស្រុក ... ដើម្បីសម្រេចបានដំណើរការតុលាការ ប្រកបដោយភាពយុត្តិធម៌ និង ឆាប់រហ័ស"[226]។ ទំហំ ស្ថានទម្ងន់ និង ភាពធ្ងន់ធ្ងរនៃបទចោទប្រកាន់ប្រឆាំង មាស មុត (និង

---

[224] ក្នុងប្រទេសបារាំង ចៅក្រមស៊ើបមានឆន្ទានុសិទ្ធិពេញលេញក្នុងការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ *សូមមើល* កថាខណ្ឌ ១៣២២ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០២ ដែលដកស្រង់ PIERRE CHAMBON និង CHRISTIAN GUÉRY ច្បាប់ និង ការអនុវត្តស្តីពីការស៊ើបអង្កេតបឋម (Dalloz លើកទី ៦ ឆ្នាំ ២០០៧) កថាខណ្ឌ ២១៣.១២៖ "ចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះដែលពិនិត្យសំណុំរឿង មានឆន្ទានុសិទ្ធិពេញលេញក្នុងការវាយតម្លៃលើអត្ថិភាព និង ភាពធ្ងន់ធ្ងរនៃការចោទប្រកាន់"។ (ការបកប្រែដោយ ស.ច.ស. ក្នុងរឿងក្តី ០០២៖ "ចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះដែលពិនិត្យសំណុំរឿង មានឆន្ទានុសិទ្ធិពេញលេញក្នុងការវាយតម្លៃលើអត្ថិភាព និង ភាពធ្ងន់ធ្ងរនៃការចោទប្រកាន់")។ ស.ច.ស. ក្នុងរឿងក្តី ០០២ កត់សម្គាល់ថា "មិនមានយុត្តិសាស្ត្ររបស់តុលាការកម្ពុជាទាក់ទងនឹងសញ្ញានេះទេ"។ កថាខណ្ឌ ១៣២១ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០២។

[225] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៥។

[226] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំយោបល់ទាក់ទងនឹងអង្គហេតុចោទប្រកាន់ដែលមិនត្រូវស៊ើបអង្កេតបន្ថែម ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D184/2 ជើងទំព័រ ២១។

ស្គាកស្នាមទុរយសដែលជាប់ទាក់ទងជាមួយការចោទប្រកាន់ទាំងនេះ) គឺមិនអាចធៀបបានជាមួយបទចោទ នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការក្នុងស្រុកណាមួយបានឡើយ។

៨៧. ស.ច.ស. ចាំបាច់ត្រូវអនុវត្តបទដ្ឋានបង្ហាញភស្តុតាងខ្ពស់ជាងបទដ្ឋាន "ភស្តុតាងច្បាស់លាស់ និង ស៊ីចង្វាក់គ្នា" ដើម្បីចោទប្រកាន់ជនសង្ស័យ[227]។ ទោះបីជា ស.ច.ស. មិនដែលបានកំណត់និយមន័យបទដ្ឋាន "ភស្តុតាងច្បាស់លាស់ និង ស៊ីចង្វាក់គ្នា" ក៏ដោយ[228] ក៏ច្បាស់ណាស់ថា បទដ្ឋាននេះគឺខ្ពស់ជាងបទដ្ឋានបញ្ជាក់របស់តុលាការ និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិដទៃទៀត[229] ដោយពិចារណាទៅលើពេលវេលា ចាប់ពីពេលចាប់ផ្តើមកិច្ចស៊ើបអង្កេត និង កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ និង ការជូនដំណឹងអំពីបទចោទ[230]។ នៅមុនពេលសម្រេចចោទ

---

[227] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ លោក មាស មុត ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174 ("កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ លោក មាស មុត") EN 02287675 KH 01180564។ វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុងចែងពីអំណាច ស.ច.ស. បើកការស៊ើបសួរប្រឆាំងនឹងជនសង្ស័យទាំងឡាយណា ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ បុគ្គលដទៃទៀត នៅពេលដែលមាន "តម្រុយច្បាស់លាស់ និង ស៊ីចង្វាក់" បញ្ជាក់ថា ជនសង្ស័យ ឬ បុគ្គលដទៃទៀត អាចជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

[228] បទដ្ឋាននៃ "តម្រុយច្បាស់លាស់ និង ស៊ីចង្វាក់" មិនត្រូវបានកំណត់និយមន័យនៅក្នុងកំណត់ហេតុនៃការបង្ហាញខ្លួនដំបូងណាមួយ ដែលអាចរកបានជាសាធារណៈឡើយ។ *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៧ ឯកសារ E3/915។ *រឿងក្តី ន្ជួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អៀង សារី ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ E3/92។ *រឿងក្តី ន្ជួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ន្ជួន ជា ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54។ *សូមមើលផងដែរ* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ លោក មាស មុត។

[229] *សូមមើល កថាខណ្ឌ* ៩៥-១០៦ *ខាងក្រោម* ដែលពិភាក្សាអំពីបទដ្ឋានបញ្ជាក់របស់តុលាការ និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ ឬ អន្តរជាតូបនីយកម្មនានា។

[230] ក្នុងរឿងក្តី ០០៣ ស.ច.ស. បានបើកការស៊ើបអង្កេតនៅខែកញ្ញា ឆ្នាំ ២០០៩ ហើយលោក មាស មុត ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងក្រោមការពិនិត្យដោយ*កំប៉ាំងមុខ* ជាផ្លូវការ នៅខែមីនា ឆ្នាំ ២០១៥ ដោយអតីត ស.ច.ស.អ. Mark Harmon។ *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D128.1។ ស.ច.ស.អ. Bohlander បានដាក់លោក មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យជាផ្លូវការនៅខែធ្នូ ឆ្នាំ ២០១៥។ *សូមមើល* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ លោក មាស មុត។

ប្រកាន់ជនសង្ស័យ ស.ច.ស. បានពិនិត្យមើលត្រួសៗ លើភស្តុតាងនៅក្នុងសំណុំរឿង ហើយសម្រេចលើអង្គហេតុ និង បទចោទ ដែលត្រូវផ្តោតសម្រាប់ការស៊ើបអង្កេត[231]។

៨៨. បទដ្ឋានភវនីយភាព (ឬ ដែលត្រូវបានគេហៅថា បទដ្ឋានឧត្តមានុភាពនៃភស្តុតាង) មានន័យថា "លើសពីការដែលគ្រាន់តែជាលទ្ធភាពអាចកើតមាន"[232] ពោលគឺមានឱកាស ៥១% ដែលជនត្រូវចោទ គឺជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បទដ្ឋានបង្ហាញភស្តុតាងនេះ គឺមិនសមស្រប សម្រាប់ដីកាដំណោះស្រាយឡើយ ដោយសារតែលក្ខណៈវិសាមញ្ញនៃឧក្រិដ្ឋកម្មដែលត្រូវជំនុំជម្រះនៅ អ.វ.ត.ក. រយៈពេលវែងគួរសម ចាប់ពីពេលជនត្រូវចោទបង្ហាញខ្លួនជាលើកដំបូង រហូតដល់ពេលបញ្ចប់ការស៊ើបអង្កេត[233] ការស៊ើបអង្កេតដ៏វែង និង ពេញលេញរបស់ ស.ច.ស. និង ឱកាសជាច្រើនរបស់ ស.ច.ស. នៅក្នុងអំឡុងពេលស៊ើបអង្កេត ដើម្បីធ្វើការវាយតម្លៃទៅលើភស្តុតាងនៅក្នុងសំណុំរឿង។

---

[231] *សូមមើល កថាខណ្ឌ ៩០ ខាងក្រោម*។ *សូមមើលផងដែរ* កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ លោក មាស មុត EN 01187676, 01187682 KH 01180564-01180566, 01180574-01180575។

[232] កថាខណ្ឌ ១៣២៣ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០២៖ "នៅក្នុងដំណាក់កាលស៊ើបសួរមុនអង្គសេចក្តីនេះ មិនមានការតម្រូវឱ្យបង្ហាញអំពីពិរុទ្ធភាពរបស់ជនត្រូវចោទនោះទេ (អង្គជំនុំជម្រះសាលាដំបូង គឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការធ្វើដូច្នេះ) ប៉ុន្តែចាំបាច់ត្រូវមានការបង្ហាញអំពី "ភវនីយភាព" នៃពិរុទ្ធភាព (មានន័យថា ស្ថានភាពដែលលើសពីលទ្ធភាពដែលអាចកើតមានធម្មតា)" (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ *សូមមើលផងដែរ* វិចនានុក្រមច្បាប់ BLACK ១៣០១ (ការបោះពុម្ពលេខ ៩ ឆ្នាំ២០០៩) កំណត់និយមន័យ "ឧត្តមានុភាពនៃភស្តុតាង" ថា៖ "ជាទំងន់ធ្ងន់ជាងនៃភស្តុតាង ដែលមិនចាំបាច់ត្រូវបានបង្កើតតាមរយៈការបង្ហាញពីចំនួនសាក្សីច្រើនជាងដែលផ្តល់សក្តីកម្មលើអង្គហេតុ ប៉ុន្តែតាមរយៈភស្តុតាងដែលមានកម្លាំងធ្វើឱ្យជឿជាក់ខ្លាំងបំផុត ទំងន់នៃភស្តុតាងដែលប្រសើរជាង ដែលទោះបីជាមិនគ្រប់គ្រាន់សម្រាប់ឱ្យការគិតឃើញរួចផុតពីវិមតិសង្ស័យទាំងស្រុងក្តី ក៏វាគ្រប់គ្រាន់សម្រាប់នាំឱ្យមានការគិតឃើញត្រឹមត្រូវ និង មិនលម្អៀង លើផ្នែកម្ខាងនៃបញ្ហាជាជាងផ្នែកម្ខាងទៀត...។ ឃ្លានេះក៏ត្រូវបានប្រើដូចឃ្លា *"ឧត្តមានុភាពនៃការបង្ហាញភស្តុតាង"* ឬ *"តុល្យភាពនៃភវនីយភាព"* (អក្សរផ្តេកនៅក្នុងឯកសារដើម) ។

[233] មាស មុត ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយ ស.ច.ស.អ. នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥។ ស.ច.ស.អ. បានចេញសេចក្តីជូនដំណឹងលើកទីពីរស្តីពីការបិទកិច្ចស៊ើបសួរ នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៧ ហើយបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៧ ដើម្បីព្រាងសេចក្តីសន្និដ្ឋានស្តាពរ។ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ លោក មាស មុត។ សេចក្តីជូនដំណឹងលើកទី ២ ស្តីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D252។ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦ (៤) ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D256។

៨៩. ការស៊ើបអង្កេតដ៏វែង និង ពេញលេញ របស់ ក.ស.ច.ស. មានរយៈពេលជិតប្រាំបួនឆ្នាំ បានផ្តល់ឱ្យ ស.ច.ស. នូវពេលវេលាហួរហៀរ ក្នុងការវាយតម្លៃលើភស្តុតាងនៅក្នុងសំណុំរឿង ដែលតម្រូវឱ្យមានការអនុវត្តន៍នូវបទដ្ឋានបង្ហាញភស្តុតាងខ្ពស់។ ក.ស.ច.ស. អាចចូលពិនិត្យមើលសំណុំរឿងទាំងមូល ចាប់តាំងពីថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៩ មកម្ល៉េះ គឺនៅពេលដែល ស.ព.អ. ស្តីទី បានបញ្ជូនដីកាសន្និដ្ឋានបញ្ចប់រឿងឱ្យស៊ើបសួរ និង សំណុំរឿងទៅ ក.ស.ច.ស. ហើយស្នើសុំឱ្យ ក.ស.ច.ស. បើកកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ[234]។ យោងតាម ស.ព.អ. សំណុំរឿងនៅពេលនោះ “មានទាំងភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុក ហើយរួមមានឯកសារចំនួនជាងប្រាំរយ រួមមានកំណត់ហេតុស្តាប់ចម្លើយសាក្សី របាយការណ៍ និង ទូរលេខរបបកម្ពុជាប្រជាធិបតេយ្យ”[235]។ ចាប់ពីពេលនោះមក ក.ស.ច.ស. បានធ្វើការចុះពិនិត្យដល់ទីតាំងជាច្រើន[236] បានស្តាប់ចម្លើយសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣៥២ លើក[237]។ ក.ស.ច.ស. ក៏បានដើរតួនាទីជាអ្នកចម្រាញ់ជ្រើសរើស សម្រេចថាតើសម្ភារឯកសារណា ដែលត្រូវដាក់ចូលទៅក្នុងសំណុំរឿង ឬ ត្រូវទុកក្រៅសំណុំរឿង នៅពេលដែលធ្វើការសម្រេចលើសំណើរបស់ភាគីសុំឱ្យបំពេញកិច្ចស៊ើបសួរ[238]។

៩០. នៅក្នុងអំឡុងពេលស៊ើបអង្កេត ស.ច.ស. មានឱកាសជាច្រើន ក្នុងការវាយតម្លៃទៅលើភាពអាចជឿជាក់បាន និង តម្លៃជាភស្តុតាងនៃភស្តុតាងដែលមាននៅក្នុងសំណុំរឿង គឺភាពអាចជឿជាក់បាននៃសាក្សី ដែលត្រូវបានស្តាប់ចម្លើយដោយ ក.ស.ច.ស. ព្រមទាំងភាពអាចជឿជាក់បាន និង

---

[234] កថាខណ្ឌ ៩ នៃដីកាសន្និដ្ឋានស្តាពរ។

[235] *ដូចខាងលើ*។

[236] *សូមមើល ឧទា.* របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/30។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/99។

[237] ការស្វែងរកក្នុង Zylab បង្ហាញថា ក.ស.ច.ស. បានធ្វើកិច្ចសម្ភាសន៍សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៣៥២ លើក ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

[238] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ចែងថា ស.ច.ស. អាចចាត់វិធានការស៊ើបសួរ ដែលនាំទៅរកការបង្ហាញការពិត រួមបញ្ចូលទាំងការកោះហៅ និង សួរចម្លើយជនសង្ស័យ និង ជនត្រូវចោទ ស្តាប់ចម្លើយជនរងគ្រោះ និង សាក្សី និង កត់ត្រានូវចម្លើយរបស់ពួកគេ ប្រមូលភស្តុតាង ស្វែងរកមតិយោបល់ពីអ្នកជំនាញ និង ដឹកនាំការស៊ើបសួរ ចុះដល់ទីកន្លែងកើតហេតុ។ ស.ច.ស. ក៏អាចចាត់ទុកជាមោឃៈកិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះ ចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនសង្ស័យ ឬ ជនត្រូវចោទ។ *សូមមើល* វិធាន ៤៨ នៃវិធានផ្ទៃក្នុង។

យថាភាពនៃឯកសារដែលការិយាល័យបានប្រមូល រួមទាំងសម្ភារឯកសារដែលប្រមូលបានដោយ ក.ស.ព. រាជរដ្ឋាភិបាលកម្ពុជា និង អង្គការខាងក្រៅនានា[239]។ តាមពិតទៅ ស.ច.ស.អ. Bohlander បានពិនិត្យមើលត្រួសៗជាមុន នូវភស្តុតាងនៅក្នុងសំណុំរឿង នៅពេលដែលគាត់បានសម្រេចចោទប្រកាន់ មាស មុត ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍បន្ថែម និង លើកលែងបទចោទមួយចំនួន ដែលបានចោទប្រកាន់គាត់ *ដោយកំបាំងមុខ* ដោយអតីត ស.ច.ស.អ. Harmon[240]។

៩១. ស.ច.ស. គួរតែអនុវត្តបទដ្ឋានបង្ហាញភស្តុតាង ដែលដូចគ្នានឹងបទដ្ឋានបង្ហាញភស្តុតាងដែលប្រើប្រាស់នៅក្នុងកិច្ចដំណើរការនីតិវិធីតាមវិធាន ៩៨ ស្ទួន របស់សាលាក្តី ICTY។ នៅមុនឆ្នាំ ២០០៤ វិធាន ៩៨ ស្ទួន របស់សាលាក្តី ICTY បានផ្តុះបញ្ចាំងនូវវិធាន ៦៧(៣)(គ) ដែលចែងថា បន្ទាប់ពីបិទរឿងក្តីរបស់រដ្ឋអាជ្ញា "អង្គជំនុំជម្រះសាលាដំបូង ត្រូវបញ្ជាឱ្យមានសាលក្រមកាត់ឱ្យរួចទោស... ប្រសិនបើអង្គជំនុំជម្រះរកឃើញថា *មិនមានភស្តុតាងគ្រប់គ្រាន់* សម្រាប់ឱ្យមានការផ្តន្ទាទោសដោយផ្អែកលើបទចោទទាំងនោះ"[241]។

៩២. ការកំណត់នីតិវិធីសម្រាប់កិច្ចដំណើរការនីតិវិធីតាមវិធាន ៩៨ ស្ទួន គឺដូចទៅនឹងដំណាក់កាលដីកាដំណោះស្រាយ។ ការស៊ើបអង្កេតដោយភាគីត្រូវបានបញ្ចប់ រដ្ឋអាជ្ញាបង្ហាញភស្តុតាងរបស់ខ្លួនទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយភស្តុតាងរបស់រដ្ឋអាជ្ញាត្រូវបានត្រួតពិនិត្យ តាមរយៈការសួរដេញដោលដោយមេធាវីការពារក្តី។ អង្គជំនុំជម្រះសាលាដំបូង គឺដូចគ្នានឹង ស.ច.ស. នៅក្នុងដំណាក់កាលដីកាដំណោះស្រាយ គឺស្ថិតក្នុងតួនាទីមួយដែលត្រូវវាយតម្លៃ លើភស្តុតាងទាំងអស់របស់រដ្ឋអាជ្ញា ដើម្បីសម្រេចថាតើមានភស្តុតាងគ្រប់គ្រាន់ដែរឬទេ ដើម្បីរក្សានូវបទចោទខ្លះ ឬ បទចោទទាំងអស់។

---

[239] *សូមមើល រឿងក្តី ខ្លួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158 ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១២ ឯកសារ E162 កថាខណ្ឌ ៣៖ "វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការត្រួតពិនិត្យ និង វាយតម្លៃឯកសារទាំងឡាយ ដើម្បីកំណត់ថាតើជាទូទៅ មានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រដល់បទចោទនានាប្រឆាំងនឹងជនជាប់ចោទដែរ ឬយ៉ាងណា។ ដំណើរការនេះតម្រូវជាចាំបាច់នៅក្នុងដំណាក់កាលស៊ើបអង្កេតឱ្យមានការកំណត់នូវភាពពាក់ព័ន្ធ និង ផ្តល់តម្លៃជាភស្តុតាងមួយចំនួនដែលភស្តុតាងទាំងនោះត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ"។

[240] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ ឈោក មាស មុត EN 01187676, 01187682, KH 01180564-01180566, 01180574-01180575។

[241] វិធានទីតិវិធី និង ភស្តុតាងរបស់សាលាក្តី ICTY IT/32/Rev.32 ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៥ វិធាន ៩៨ *ស្ទួន*(ក)-(ខ) (ការគូសបញ្ជាក់បន្ថែម)។

៩៣. បទដ្ឋានបង្ហាញភស្តុតាងតាមវិធាន ៩៨ ស្ទួន របស់សាលាក្តី ICTY (ការពិនិត្យមើលដើម្បីសម្រេចថាតើមានភស្តុតាង *មិនគ្រប់គ្រាន់* ដើម្បីរក្សាទុកការផ្តន្ទាទោសដែរឬយ៉ាងណា) ត្រូវបានបកស្រាយថា "មិនមែនថាតើចៅក្រមដែលសម្រេចលើអង្គហេតុពិតជាអាចឈានដល់ការផ្តន្ទាទោសដែលហួសពីវិមតិសង្ស័យ ដោយផ្អែកលើភស្តុតាងរបស់រដ្ឋអាជ្ញាឬយ៉ាងណានោះទេ... តែគឺថាតើចៅក្រមដែលសម្រេចលើអង្គហេតុ *អាច* ធ្វើដូច្នោះបានឬយ៉ាងណា"[242]។ ក្នុងការពិចារណាថាតើត្រូវចេញសាលក្រមកាត់ឱ្យរួចទោស តាមវិធាន ៩៨ ស្ទួន ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តី ICTY ត្រូវពិនិត្យទៅលើភស្តុតាងរបស់រដ្ឋអាជ្ញា ព្រមទាំងភស្តុតាងដែលបង្ហាញដោយមេធាវីការពារក្តី តាមរយៈការស្នូរដេញដោលសាក្សី និង ឯកសាររបស់រដ្ឋអាជ្ញាដែលបានស្នើឡើងដោយមេធាវីការពារក្តី ហើយដែលអនុញ្ញាតដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអំឡុងពេលរឿងក្តីរបស់រដ្ឋអាជ្ញា[243]។ ទោះបីជាវិធាន ៩៨ ស្ទួន របស់សាលាក្តី ICTY ត្រូវបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ ២០០៤ ដោយមានការកែប្រែពាក្យពេចន៍បន្តិចបន្តួចក្តី[244] ក៏បទដ្ឋានបង្ហាញភស្តុតាងនៅតែមិនមានការផ្លាស់ប្តូរឡើយ[245]។

៩៤. ចក្ខុវិស័យហិរញ្ញវត្ថុរបស់ អ.វ.ត.ក. និង លទ្ធភាពខ្ពស់ដែលថា ប្រសិនបើត្រូវបញ្ជូនទៅជំនុំជម្រះនៅក្នុងសវនាការរឿងក្តី ០០៣ នឹងមិនអាចឈានដល់ទីបញ្ចប់នោះ ក៏តម្រូវផងដែរឱ្យអនុវត្ត

---

[242] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jelisić* សំណុំរឿងលេខ IT-95-10-A សាលក្រម ចុះថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ៣៧ (ការគូសបញ្ជាក់បន្ថែម)។

[243] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Orić* សំណុំរឿងលេខ IT-03-68 ប្រតិចារឹក ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០០៥ ទំព័រ ៨៩៨៤។

[244] វិធាននីតិវិធី និង ភស្តុតាងរបស់សាលាក្តី ICTY IT/32/Rev.33 ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៤ វិធាន ៩៨ *ស្ទួន*៖ "នៅចុងបញ្ចប់នៃការបង្ហាញរឿងក្តីរបស់រដ្ឋអាជ្ញា អង្គជំនុំជម្រះសាលាដំបូង ត្រូវចេញសាលក្រមផ្តាល់មាត់ និង ក្រោយពីបានស្តាប់ការធ្វើសេចក្តីសន្និដ្ឋានផ្តាល់មាត់ពីភាគីនានា សម្រេចឱ្យរួចខ្លួនពីការចោទប្រកាន់ បើមិនមានភស្តុតាងគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការផ្តន្ទាទោស"។

[245] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Orić* សំណុំរឿងលេខ IT-03-68 ប្រតិចារឹក ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០០៥ ទំព័រ ៨៩៨៣៖ "វិសោធនកម្មចុងក្រោយលើវិធាន ៩៨ ស្ទួន មិនបានធ្វើឱ្យផ្លាស់ប្តូរបទដ្ឋាននៃការពិនិត្យ... ដែលដូច្នេះហើយ នៅតែដូចគ្នានឹងអ្វីដែលមានចែង... ក្នុងបណ្តឹងឧទ្ធរណ៍របស់ Jelisic"។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះខ្លះនៃសាលាក្តី ICTY បានពិចារណាដោយភ័ន្តច្រឡំថា វិធាន ៩៨ ស្ទួន ដែលត្រូវបានធ្វើវិសោធនកម្ម បានកែប្រែបទដ្ឋាននៃការបង្ហាញភស្តុតាង ហើយតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាតែទៅលើភស្តុតាងរបស់រដ្ឋអាជ្ញា ដោយមិនពិចារណាលើភស្តុតាងបង្ហាញដោយមេធាវីការពារក្តីឡើយ។ *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-T ប្រតិចារឹក ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០០៨ ទំព័រ ២៧២០៦។

បទដ្ឋានបង្ហាញភស្តុតាងដែលខ្ពស់បំផុត ដែលទាបជាងគោលការណ៍ភស្តុតាងដែលហួសពីវិមតិសង្ស័យតែបន្តិចប៉ុណ្ណោះ។ ដើម្បីបញ្ជូនរឿងក្តី មាស មុត ទៅជំនុំជម្រះក្នុងសវនាការ ដោយផ្អែកលើបទដ្ឋានភវនីយភាព ៥១% នៅក្នុងភាពមិនប្រាកដប្រជាបែបនេះ ដោយមានស្តាកស្នាមទុរយសជាប់ជាមួយឧក្រិដ្ឋកម្ម ដែលត្រូវចោទប្រកាន់ប្រឆាំងរូបគាត់ និង ការមិនមានយន្តការបន្ទាប់បន្សំដើម្បីជំទាស់ចំពោះការចោទប្រកាន់ទាំងអស់នេះ នឹងនាំទៅដល់ការរំលោភបំពានជាក់ស្តែង ទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់ (សូមមើលផ្នែក II *ខាងលើ*)។

២. បទដ្ឋានបញ្ជាក់លើការបញ្ជូនរឿងទៅជំនុំជម្រះ ដែលដកស្រង់ដោយ ស.ព.អ. និង បទដ្ឋានរបស់តុលាការ និង សាលាក្តីអន្តរជាតិដទៃទៀត គឺមិនសមស្របឡើយសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក.

៩៥. ស.ព.អ. លើកឡើងថា ស.ច.ស. ប្រើប្រាស់បទដ្ឋានមិនត្រឹមត្រូវរបស់តុលាការ ICC សាលាក្តី ICTY និង សាលាក្តី ICTR[246] ដោយមិនបានគិតអំពីភាពខុសគ្នា រវាងដំណើរការដីកាដំណោះស្រាយរបស់ អ.វ.ត.ក. និង ដំណើរការបញ្ជាក់លើការបញ្ជូនរឿងទៅជំនុំជម្រះរបស់សាលាក្តីទាំងនោះ។ បទដ្ឋានបញ្ជាក់លើការបញ្ជូនរឿងទៅជំនុំជម្រះរបស់តុលាការ និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដូចជាតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (“តុលាការ SCSL”) សាលាក្តីពិសេសសម្រាប់ប្រទេសលីបង់ (“សាលាក្តី STL”) និង តុលាការពិសេសសម្រាប់ប្រទេសកូសូវ៉ូ (“តុលាការ KSC”) ក៏មិនសមស្របផងដែរ សម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក. ដោយសារមូលហេតុប្រហែលគ្នានេះ។

ក. បទដ្ឋានបញ្ជាក់របស់តុលាការ ICC គឺខ្ពស់ជាងបទដ្ឋានភវនីយភាព ប៉ុន្តែ មានលក្ខណៈមិនសមស្រប សម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក.

៩៦. នៅដំណាក់កាលបញ្ជាក់ អង្គបុរេជំនុំជម្រះរបស់តុលាការ ICC ត្រូវសម្រេច “ថាតើមានភស្តុតាងគ្រប់គ្រាន់ឬយ៉ាងណា សម្រាប់បង្កើតបានទ្វមូលដ្ឋានសំខាន់ ដើម្បីជឿជាក់ថា បុគ្គលម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗដែលបានចោទប្រកាន់”[247]។ បទដ្ឋានបង្ហាញភស្តុតាងដែលបានតម្រូវ នៅ

[246] កថាខណ្ឌ ១០៤៨-៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[247] លក្ខន្តិក:ទីក្រុងរ៉ូម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចូលជាធរមាននៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០០២ (“លក្ខន្តិក:ទីក្រុងរ៉ូម”) មាត្រា ៦១(៧)។

ដំណាក់កាលបញ្ជាក់គឺជា "ភស្តុតាងជាក់ស្តែង និង ច្បាស់លាស់ ដែលបង្ហាញឱ្យឃើញនូវខ្សែបន្ទាត់ច្បាស់លាស់មួយនៃសំអាងហេតុ ដែលពង្រឹងដល់ការចោទប្រកាន់ជាក់លាក់របស់ខ្លួន"[248]។

៩៧. ដោយមានលក្ខណៈខុសពី ក.ស.ច.ស. នៅដំណាក់កាលដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះនៃតុលាការ ICC មិនមានសិទ្ធិចូលពិនិត្យមើលភស្តុតាងទាំងស្រុង នៅក្នុងដំណាក់កាលបញ្ជាក់ការចោទប្រកាន់ឡើយ។ លក្ខន្តិកៈទីក្រុងរ៉ូមមិនតម្រូវឱ្យការស៊ើបអង្កេតរបស់រដ្ឋអាជ្ញា ត្រូវតែបញ្ចប់នៅមុនពេលសវនាការបញ្ជាក់នោះឡើយ[249]។ អង្គបុរេជំនុំជម្រះរបស់តុលាការ ICC អាចផ្អាកសវនាការបញ្ជាក់ ហើយស្នើដល់រដ្ឋអាជ្ញាឱ្យធ្វើការស៊ើបអង្កេតបន្ថែមទៀត[250]។ បើទោះបីជាអង្គបុរេជំនុំជម្រះបដិសេធ មិនបញ្ជាក់ទៅលើបទចោទខ្លះ ឬ ទាំងអស់ក៏ដោយ ក៏រដ្ឋអាជ្ញាមិនត្រូវបានហាមឃាត់ មិនឱ្យស្នើសុំការបញ្ជាក់នៅពេលបន្ទាប់ ដោយមានភស្តុតាងបន្ថែមឡើយ[251]។ អង្គជំនុំជម្រះតុលាការកំពូលរបស់ តុលាការ ICC បានពិចារណាឃើញថា ការរារាំងកិច្ចស៊ើបអង្កេតបន្ទាប់ពីសវនាការបញ្ជាក់អាច "ដកហូតនូវភស្តុតាងពាក់ព័ន្ធ និង សំខាន់ពីតុលាការ រួមទាំងភស្តុតាងដែលអាចមានលក្ខណៈដោះបន្ទុក ជាពិសេសនៅក្នុងស្ថានភាពដែលលក្ខណៈនៃជម្លោះដែលកំពុងបន្ត បណ្តាលឱ្យភស្តុតាងបែបបង្ខំ លេចចេញឡើងជាលើកដំបូង នៅក្រោយពេលសវនាការបញ្ជាក់[252]។

៩៨. មេធាវីការពារក្តីនៅតុលាការ ICC ត្រូវបានរិតបន្តឹង លើលទ្ធភាពក្នុងការវាយតម្លៃទៅលើភស្តុតាងរបស់រដ្ឋអាជ្ញា ហើយត្រូវបំពេញកិច្ចស៊ើបសួរក្នុងពេលជាមួយគ្នា ក្នុងអំឡុងពេលដ៏ខ្លីមួយដែលត្រូវ

---

[248] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-803-tEN សេចក្តីសម្រេចលើការបញ្ជាក់បទចោទប្រកាន់ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៩។

[249] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-568 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី ១ ស្តីពី "សេចក្តីសម្រេចលើបង្កើតគោលការណ៍ទូទៅ សម្រាប់គ្រប់គ្រងលើការដាក់ពាក្យស្នើសុំកម្រិតការបង្ហាញឯកសារ ដោយអនុលោមតាមវិធាន ៨១ (២) និង (៤) នៃវិធាននីតិវិធី និង ភស្តុតាង" ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៦ កថាខណ្ឌ ៥៤។

[250] មាត្រា ៦១(៧)(គ)(i) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[251] *ដូចខាងលើ* មាត្រា ៦១(៨)។

[252] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-568 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី ១ ស្តីពី "សេចក្តីសម្រេចបង្កើតគោលការណ៍ទូទៅ សម្រាប់គ្រប់គ្រងការដាក់ពាក្យស្នើសុំកម្រិតការបង្ហាញឯកសារ ដោយអនុលោមតាម វិធាន ៨១ (២) និង (៤) នៃវិធាននីតិវិធី និង ភស្តុតាង" ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៦ កថាខណ្ឌ ៥៤។

បានបែងចែក សម្រាប់រយៈពេលបញ្ជាក់អះអាង។ រយៈពេលចាប់ពីការបង្ហាញខ្លួនជាលើកដំបូងរបស់ជនជាប់ចោទ ពោលគឺពេលដែលជនជាប់ចោទទទួលបានសិទ្ធិមានជំនួយខាងផ្លូវច្បាប់[253] រហូតដល់ពេលមានសវនាការបញ្ជាក់ ជាទូទៅ គឺមានរយៈពេលមិនដល់មួយឆ្នាំទេ[254]។ រដ្ឋអាជ្ញាត្រូវការត្រឹមតែដាក់បង្ហាញនូវការពណ៌នាលម្អិតអំពីបទចោទ និង បញ្ជីភស្តុតាងដែលខ្លួនមានចេតនាប្រើប្រាស់នៅក្នុងសវនាការបញ្ជាក់ ក្នុងរយៈពេល ៣០ ថ្ងៃមុនថ្ងៃសវនាការ[255]។ មេធាវីការពារក្តីត្រូវដាក់បង្ហាញបញ្ជីភស្តុតាងរបស់ខ្លួន ក្នុងរយៈពេល ១៥ ថ្ងៃ មុនថ្ងៃចាប់ផ្តើមសវនាការបញ្ជាក់[256]។

៩៩. នៅក្នុងសវនាការបញ្ជាក់ រដ្ឋអាជ្ញា "មិនចាំបាច់ដាក់ភស្តុតាង លើសពីតម្រូវការចាំបាច់ ដើម្បីបំពេញតាមកម្រិតនៃមូលដ្ឋានសំខាន់សម្រាប់ការជឿជាក់ឡើយ"[257] ហើយរដ្ឋអាជ្ញាអាចពឹងផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សីអនាមិក[258]។ "រដ្ឋអាជ្ញាអាចត្រៀមបម្រុង ការប្រើប្រាស់នូវអ្វីដែលគេហៅថា "ភស្តុតាងប្រយោល (smoking gun)" សម្រាប់ដំណាក់កាលជំនុំជម្រះ ប្រសិនបើ

---

[253] វិធាន ១២១(១) នៃវិធានទីតិវិធី និង ភស្តុតាងរបស់តុលាការ ICC។

[254] ក្នុងរឿងក្តី *Mbarushimana* ជនជាប់ចោទបានបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១១ ដោយសវនាការបញ្ជាក់ត្រូវបានធ្វើឡើងពីថ្ងៃទី ១៦ ដល់ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១១ ហើយសេចក្តីសន្និដ្ឋានស្តាពរជាលាយលក្ខណ៍អក្សររបស់ភាគីទាំងអស់ត្រូវបានទទួលនៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១១ ហើយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើការបញ្ជាក់បទចោទប្រកាន់ ត្រូវបានចេញនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១១។ *អ្វីដែលក្តី រដ្ឋអាជ្ញា តទល់នឹង Mbarushimana* សំណុំរឿងលេខ ICC-01/04-01/10-465-Red សេចក្តីសម្រេចលើការបញ្ជាក់បទចោទប្រកាន់ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ១៦ កថាខណ្ឌ ៣២។ ក្នុងរឿងក្តី *Abu Garda* ការបង្ហាញខ្លួនលើកដំបូងរបស់ជនជាប់ចោទធ្វើឡើងនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ហើយកិច្ចដំណើរការនីតិវិធីបញ្ជាក់បានចាប់ផ្តើមនៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៩។ *អ្វីដែលក្តី រដ្ឋអាជ្ញា តទល់នឹង Abu Garda* សំណុំរឿងលេខ ICC-02/05-243-Red សេចក្តីសម្រេចលើការបញ្ជាក់បទចោទប្រកាន់ ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ៥-១៣។

[255] វិធាន ១២១(៣) នៃវិធានទីតិវិធី និង ភស្តុតាងរបស់តុលាការ ICC (ឆ្នាំ ២០១៦)។

[256] *ដូចខាងលើ* វិធាន ១២១(៦)។

[257] *អ្វីដែលក្តី រដ្ឋអាជ្ញា តទល់នឹង Mbarushimana* សំណុំរឿងលេខ ICC-01/04-01/10-514 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី ១ នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១១ ស្តីពី "សេចក្តីសម្រេចលើការបញ្ជាក់បទចោទប្រកាន់" ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៤៧។

[258] មាត្រា ៦១(៥) នៃលក្ខន្តិក:ទីក្រុងរ៉ូម។

រដ្ឋអាជ្ញាមិនត្រូវការភស្តុតាងទាំងនោះ សម្រាប់លក្ខណៈតម្រូវ "ភស្តុតាងគ្រប់គ្រាន់..."[259]។ នេះគឺជាចេតនារបស់អ្នកតាក់តែងលក្ខន្តិកៈទីក្រុងរ៉ូម ដែលបានជឿជាក់ថា ការផ្តល់ដល់អង្គបុរេជំនុំជម្រះ នូវសិទ្ធិចូលពិនិត្យសំណុំរឿងទាំងស្រុងរបស់រដ្ឋអាជ្ញា "នឹងបណ្តាលឱ្យមានការពន្យារពេលដែលមិនចាំបាច់ 'ប្រសិនបើភស្តុតាងដែលប្រមូលបានក្នុងរឿងក្តី មានចំនួនច្រើនលើសលប់'"[260]។

ខ. បទដ្ឋានបញ្ជាក់របស់សាលាក្តី ICTY និង សាលាក្តី ICTR គឺទាបជាងបទដ្ឋានភាវនីយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក.

១០០. នៅសាលាក្តី ICTY និង សាលាក្តី ICTR កិច្ចដំណើរការនីតិវិធីបញ្ជាក់ការបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានធ្វើឡើងដោយឯកភាគី (*ex parte*)[261]។ មេធាវីការពារក្តីអាចជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តែនៅពេលដែលដីកានេះត្រូវបានបញ្ជាក់ ដោយចៅក្រមត្រួតពិនិត្យប៉ុណ្ណោះ[262]។ បើយោងតាមអតីតរដ្ឋអាជ្ញារបស់សាលាក្តី ICTY គឺលោក Michael Keegan និង លោក Daryl Mundis នីតិវិធីបញ្ជាក់នេះកើតឡើង គឺដោយសារមូលហេតុថា នៅពេលដែល សាលាក្តី ICTY និង សាលាក្តី ICTR ចាប់ផ្តើមការងាររបស់ពួកគេ រដ្ឋអាជ្ញាត្រូវព្រាងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងពេលកំពុងមានអរិភាព ហើយជនសង្ស័យនៅមានសេរីភាព[263]។ ជាលទ្ធផល បទដ្ឋាន

---

[259] Kai Ambos និង Dennis Miller *រចនាសម្ព័ន្ធ និង មុខងារនៃនីតិវិធីនៃការបញ្ជាក់នៅចំពោះមុខតុលាការ ICC តាមរយៈទស្សនទាននៃការប្រៀបធៀប* ការពិនិត្យច្បាប់ព្រហ្មទណ្ឌអន្តរជាតិលើកទី ៧ ទំព័រ ៣៣៥, ៣៤៣-៣៤៤ (ឆ្នាំ ២០០៧)។

[260] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gbagbo* សំណុំរឿងលេខ ICC-02/11-01/11-432-Anx-Corr សេចក្តីសម្រេចផ្អាកការបញ្ជាក់បទចោទប្រកាន់ មតិជំទាស់របស់ចៅក្រម Silvia Fernández de Gurmundi ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២០ ដែលដកស្រង់របាយការណ៍របស់គណៈកម្មាធិការរៀបចំស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ភាគទី ១ (ឆ្នាំ ១៩៩៦) កថាខណ្ឌ ២៣២។

[261] *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milošević* សំណុំរឿងលេខ IT-02-54 សេចក្តីសម្រេចលើការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០១។ *សូមមើលផងដែរ* ARCHBOLD តុលាការព្រហ្មទណ្ឌអន្តរជាតិ ការអនុវត្តន៍នីតិវិធី និង ភស្តុតាង ទំព័រ ១៩៩ (អ្នកនិពន្ធ Khan និង Dixon ឆ្នាំ ២០០៩)។

[262] វិធាននីតិវិធី និង ភស្តុតាងរបស់សាលាក្តី ICTY IT/32/Rev.50 ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០១៥ ("វិធាននីតិវិធី និង ភស្តុតាងរបស់សាលាក្តី ICTY") វិធាន ៧២(ក)(ii)។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac* សំណុំរឿងលេខ IT-97-25 សេចក្តីសម្រេចលើញត្តិបឋមរបស់ក្រុមមេធាវីការពារក្តីលើទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៩។ ARCHBOLD តុលាការព្រហ្មទណ្ឌអន្តរជាតិ ការអនុវត្តន៍ នីតិវិធី និង ភស្តុតាង ទំព័រ ១៩៩ (អ្នកនិពន្ធ Khan និង Dixon ឆ្នាំ ២០០៩)។

[263] *សូមមើល* Michael J. Keegan និង Daryl A. Mundis *តម្រូវការច្បាប់សម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុង* សេចក្តីអធិប្បាយស្តីពី វិធាន និង ភស្តុតាងរបស់សាលាក្តី ICTY ជាកិត្តិយសដល់ GABRIELLE KIRK MCDONALD ទំព័រ ១២៥

បង្ហាញភស្តុតាង ដើម្បីបញ្ជាក់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺមានលក្ខណៈទាប។ ចៅក្រមត្រួតពិនិត្យនៅសាលាក្តី ICTY និង សាលាក្តី ICTR គ្រាន់តែត្រូវ "ជឿជាក់ថារឿងក្តីកម្រិតដំបូង (prima facie) ត្រូវបានកំណត់ថាមានពិត ដោយរដ្ឋអាជ្ញាតែប៉ុណ្ណោះ"[264]។ នៅក្នុងការសម្រេចថាតើរដ្ឋអាជ្ញាបានកំណត់ថាមានពិត ទ្វរឿងក្តីកម្រិតដំបូងដែរឬយ៉ាងណានោះ ចៅក្រមត្រួតពិនិត្យមិនខ្វល់ខ្វាយអំពីភាពគ្រប់គ្រាន់នៃភស្តុតាងរបស់រដ្ឋអាជ្ញាឡើយ គឺចៅក្រមពិចារណាថា តើអង្គហេតុដែលរដ្ឋអាជ្ញាបានលើកឡើង នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពិតជាបង្កើតបានជារឿងក្តីដែលអាចជឿជាក់បានដែរឬយ៉ាងណា ប្រឆាំងនឹងជនជាប់ចោទ[265]។ "រឿងក្តីកម្រិតដំបូង... ជារឿងក្តីដែលអាចជឿជាក់បាន ដែលប្រសិនបើត្រូវបានទទួលហើយមិនមានការជំទាស់ប្រឆាំង នឹងក្លាយជាមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ការផ្តន្ទាទោសចំពោះជនជាប់ចោទ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចថា តើទទួលយកអង្គហេតុ ដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរឬយ៉ាងណា៖ នេះមិនមែនជាភារកិច្ចរបស់ចៅក្រមត្រួតពិនិត្យនោះទេ"[266]។

(Richard May និង អ្នកផ្សេងទៀត ឆ្នាំ ២០០១)៖ "វាក៏មានសារសំខាន់ផងដែរ ដែលជម្លោះស្តីពីអាណត្តិរបស់សាលាក្តី ICTY ត្រូវបានលើកឡើង នៅតែបន្ត នៅខណៈដែលសាលាក្តី ICTY បានចាប់ផ្តើមដំណើរការ។ ដូច្នេះ ការិយាល័យរដ្ឋអាជ្ញា បានចាប់ផ្តើមធ្វើពង្រាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងអំឡុងពេលដែលការបង្កការវាយប្រយុទ្ធ និង ការស៊ើបអង្កេតកំពុងបន្ត"។

[264] លក្ខន្តិកៈនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលត្រូវបានធ្វើវិសោធនកម្មតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ១៨៧៧ ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ១៩៩៩ មាត្រា ១៩។ លក្ខន្តិកៈនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ដែលត្រូវបានធ្វើវិសោធនកម្មតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៩០១ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០៩ មាត្រា ១៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milošević* សំណុំរឿងលេខ IT-02-54 សេចក្តីសម្រេចលើការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ ២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Serushago* សំណុំរឿងលេខ ICTR-98-39-1 សេចក្តីសម្រេចលើការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ១៩៩៨។

[265] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milošević* សំណុំរឿងលេខ IT-02-54 សេចក្តីសម្រេចលើការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ ១៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krnojelac* សំណុំរឿងលេខ IT-97-25 សេចក្តីសម្រេចលើញត្តិបឋមរបស់មេធាវីការពារក្តីលើទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧ "សេចក្តីថ្លែងការពារក្តីគឺមិនមានវិការៈដោយសារតែបែបបទនៃការសរសេរមិនប្រសព្វនោះទេ នៅពេលពិចារណាលើអត្ថបទទាំងមូល ហើយពិនិត្យឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបង្ហាញច្បាស់ដល់ជនជាប់ចោទម្នាក់ៗ អំពី (ក) លក្ខណៈនៃការទទួលខុសត្រូវមួយ (ឬ ច្រើន) ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និង (ខ) អង្គហេតុសម្ភារ - ប៉ុន្តែមិនមែនជាភស្តុតាង - នឹងត្រូវបានបង្កើតឱ្យមានការទទួលខុសត្រូវជាក់លាក់មួយ (ឬ ច្រើន)"។

[266] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milošević* សំណុំរឿងលេខ IT-02-54 សេចក្តីសម្រេចលើការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ ១៤។

គ. បទដ្ឋានបញ្ហាក់របស់តុលាការ SCSL គឺទាបជាងបទដ្ឋានភាពនីយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក.

១០១. តុលាការ SCSL បានអនុវត្តវិធាននីតិវិធី និង ភស្តុតាងប្រហែលគ្នានឹងសាលាក្តី ICTY និង សាលាក្តី ICTR[267] ហើយបានប្រើប្រាស់បទដ្ឋានបង្ហាញភស្តុតាង ប្រហែលគ្នានឹងបទដ្ឋានរឿងក្តីកម្រិតដំបូងរបស់សាលាក្តី ICTY និង សាលាក្តី ICTR ដែរ[268]។ ដើម្បីឱ្យមានការអនុម័តទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតុលាការ SCSL ចៅក្រមដែលត្រូវបានចាត់តាំង ត្រូវតែជឿជាក់ថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ គឺស្ថិតក្នុងយុត្តាធិការរបស់តុលាការ ហើយជឿជាក់ថា "ការចោទប្រកាន់នៅក្នុងសេចក្តីសង្ខេបរឿងក្តី ប្រសិនបើត្រូវបានបង្ហាញថាមានពិត គឺបង្កើតបានជាឧក្រិដ្ឋកម្មមួយ ឬ ច្រើន ដូចដែលបានបញ្ជាក់ច្បាស់លាស់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[269]។ នៅក្នុងការអនុវត្តជាក់ស្តែង ចៅក្រមដែលត្រូវបានចាត់តាំង ត្រូវបញ្ជាក់ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងករណីដែល "មានភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តល់ជាមូលដ្ឋានសមហេតុផល សម្រាប់ជឿជាក់ថា ជនសង្ស័យ... បានប្រព្រឹត្តបទឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ ហើយថាប្រសិនបើបង្ហាញថាមានពិត ការចោទប្រកាន់នេះ គឺបង្កើតបានជាឧក្រិដ្ឋកម្មដែលមានចែងជាក់លាក់ និង ច្បាស់លាស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ"[270]។

---

[267] មាត្រា ១៤ នៃលក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលីអូន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០២។

[268] Tom Periello និង Marieke Wierda បានលើកឡើងថា មិនមានលក្ខខណ្ឌតម្រូវការសម្រាប់រឿងក្តី *ជាបឋម* (Prima facie) នៅតុលាការ SCSL ដូចដែលថា "កម្រិតនៃការពិនិត្យរបស់តុលាការត្រូវបានកាត់បន្ថយ" មានអត្ថិភាពនៅដំណាក់កាលនៃការបញ្ជាក់។ Tom Perriello និង Marieke Wierda *តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលីអូន ស្ថិតនៅក្រោមការពិនិត្យ* មជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល អនុក្រមករណីសិក្សាការកាត់ទោស ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០០៦ ទំព័រ ១២ នៅគេហទំព័រ www.ictj.org/static/Prosecutions/Sierra.study.pdf។ *សូមមើលផងដែរ* Cecily Rose *ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានបញ្ហានៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលីអូន៖ សេចក្តីថ្លែងការពារក្តីនៃសហឧក្រិដ្ឋកម្មរួម និង ឧក្រិដ្ឋកម្មផ្លូវភេទ* រាជកិច្ចស្តីពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ លេខ ៧ ទំព័រ ៣៥៣ និង ៣៥៨ (ឆ្នាំ ២០០៩)។

[269] វិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ SCSL ដែលត្រូវបានធ្វើវិសោធនកម្មនៅ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១២ ("វិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ SCSL") វិធាន ៤៧(ង)។

[270] *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Taylor* សំណុំរឿងលេខ SCSL-2003-06-I សេចក្តីសម្រេចឯកភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ដីកាហាមមិនឱ្យបង្ហាញឯកសារ ចុះថ្ងៃទី ៧ ខែមីនា ឆ្នាំ ២០០៣ ទំព័រ ២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Norman* សំណុំរឿងលេខ SCSL-2003-08-I សេចក្តីសម្រេចឯកភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ដីកាហាមមិនឱ្យបង្ហាញឯកសារ ចុះថ្ងៃទី ៧ ខែមីនា ឆ្នាំ ២០០៣ ទំព័រ ២។

១០២. ដូចគ្នានឹងសាលាក្តី ICTY និង សាលាក្តី ICTR ដែរ មេធាវីការពារក្តីមិនបានចូលរួម ក្នុងដំណើរការត្រួតពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ហើយញត្តិបឋមដែលជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចធ្វើឡើងតែបន្ទាប់ពីមានការអនុម័ត ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ[271]។ ដោយសារតែការស៊ើបអង្កេតនៅអាចបន្ត ក្រោយពេលអនុម័តលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[272] ដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចត្រូវបានបញ្ឆាក់ ដោយចៅក្រមត្រួតពិនិត្យមិនចាំបាច់ត្រូវមានសិទ្ធិចូលពិនិត្យមើលសម្ភារឯកសារទាំងអស់ ដែលរដ្ឋអាជ្ញាអាចប្រើប្រាស់ នៅពេលសវនាការជំនុំជម្រះឡើយ។

ឃ. បទដ្ឋានបញ្ឆាក់របស់សាលាក្តី STL គឺទាបជាងបទដ្ឋានភាវនីយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក.

១០៣. សាលាក្តី STL អនុវត្តបទដ្ឋានបង្ហាញភស្តុតាងដូចនឹងសាលាក្តី ICTY សាលាក្តី ICTR និងតុលាការ SCSL ដែរ៖ ចៅក្រមអង្គបុរេជំនុំជម្រះ ចាំបាច់ត្រូវជឿជាក់ថា រឿងក្តីស្ថិតក្នុងយុត្តាធិការរបស់តុលាការ ហើយថា "មានអត្ថិភាពរឿងក្តីកម្រិតបឋម ប្រឆាំងជនសង្ស័យ"[273]។ ចៅក្រមអង្គបុរេជំនុំជម្រះបានសម្រេចថាដូច្នេះ គឺមានន័យថា "តើភស្តុតាងដែលរដ្ឋអាជ្ញាបានដាក់ជូន ដើម្បីគាំទ្របទចោទ មានលក្ខណៈគ្រប់គ្រាន់ដែរឬយ៉ាងណា សម្រាប់ជំនុំជម្រះជនសង្ស័យ"[274]។

---

[271] វិធាន ៧២(ក), (ខ)(ii) នៃវិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ SCSL។

[272] នៅតុលាការ SCSL អយ្យការបានស្តាប់ចម្លើយជនជាប់ចោទ Issa Sesay ចំនួន ១១ លើក បន្ទាប់ពីដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានឯកភាព។ ការស្តាប់ចម្លើយទាំងនោះត្រូវបានសម្រេចចុងក្រោយថា មិនអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋាននៃភាពមិនស្មើគ្រៃគ្តត្តិ។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-04-15-T សំអាងហេតុជាលាយលក្ខណ៍អក្សរ - សេចក្តីសម្រេចលើការទទួលយកនូវចម្លើយមួយចំនួនពីមុន ដែលជនជាប់ចោទបានផ្តល់ទៅអយ្យការ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៨ ទំព័រ ២។

[273] វិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ STL STL-BD-2009-01-Rev.9 ដែលបានធ្វើវិសោធនកម្ម និង បានកែសម្រួលនៅ ថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៧ ("វិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ SCSL") វិធាន ៦៨(ច)។

[274] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ayyash និង អ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-01/I សេចក្តីសម្រេចទាក់ទងនឹងការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១១ ដែលបានចេញប្រឆាំងនឹងលោក Salim Jamil Ayyash លោក Mustafa Amine Badreddine លោក Hussein Hassan Oneissi និង លោក Assad Hassan Sabra ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ២៣។

១០៤. ការវាយតម្លៃរបស់ចៅក្រមអង្គបុរេជំនុំជម្រះ នៅដំណាក់កាលបញ្ជាក់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានធ្វើឡើង ដោយមិនគិតពីភស្តុតាងទាំងអស់ដែលបង្ហាញដោយរដ្ឋអាជ្ញា ឬ មេធាវីការពារក្តី[275]។ បើយោងតាមអតីតរដ្ឋអាជ្ញានៅសាលាក្តី STL គឺលោក Daniel Bellemare ការស៊ើបអង្កេតនៅសាលាក្តី STL នៅតែបន្ត សូម្បីតែនៅក្នុងពេលសវនាការជំនុំជម្រះ[276]។ មេធាវីការពារក្តីនៅសាលាក្តី STL ក៏មិនបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី នៅមុនពេលបញ្ជាក់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ[277]។

ង. បទដ្ឋានបញ្ជាក់របស់តុលាការ KSC គឺទាបជាងបទដ្ឋានភាពនឹយភាព ហើយមិនសមស្របសម្រាប់ដីកាដំណោះស្រាយនៅ អ.វ.ត.ក.

១០៥. បទដ្ឋានបង្ហាញភស្តុតាង ក្នុងការបញ្ជាក់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតុលាការ KSC គឺថាតើសម្ភារឯកសារគាំទ្រនោះ បានគាំទ្រដែរឬយ៉ាងណាចំពោះ "ការសង្ស័យដែលមានមូលដ្ឋានច្បាស់លាស់" ប្រឆាំងជនត្រូវចោទ[278]។ ពាក្យបច្ចេកទេសនេះ ត្រូវបានយកចេញពីក្រមនីតិវិធីព្រហ្មទណ្ឌកូសូវ៉ូ ដែលកំណត់និយមន័យ "ការសង្ស័យដែលមានមូលដ្ឋានច្បាស់លាស់" ថាជា "ការមាន

---

[275] វិធាន ៨៨(ឃ) នៃវិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ STL តម្រូវឱ្យរដ្ឋអាជ្ញា "នៅពេលដែលខ្លួនយល់ថា ជាពេលវេលាសមស្រប" ត្រូវផ្តល់ទៅឱ្យចៅក្រមអង្គបុរេជំនុំជម្រះនូវ "វត្ថុណាមួយ ដែលរដ្ឋអាជ្ញាចាត់ទុកថា ចាំបាច់សម្រាប់ការបំពេញមុខងាររបស់ចៅក្រមអង្គបុរេជំនុំជម្រះ"។ វិធាន ៦៨(ខ) ចែងថា រដ្ឋអាជ្ញាត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមាន "សម្ភារគាំទ្រ"។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ayyash និង អ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-01/I សេចក្តីសម្រេចទាក់ទងនឹងការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១១ ប្រឆាំងនឹងលោក Salim Jamil Ayyash លោក Mustafa Amine Badreddine លោក Hussein Hassan Oneissi និង លោក Assad Hassan Sabra ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១១។

[276] Daniel A. Bellemare *ការនាំយកអោវរកមកចំពោះមុខយុត្តធម៌អន្តរជាតិ៖ ទស្សនពីខ្សែត្រៀមខាងមុខ កំណត់សម្គាល់សម្រាប់ការពោលប្រស្រ័យ* វេទិកាច្បាប់ព្រហ្មទណ្ឌ លេខ ២៣ ទំព័រ ៤២៥ (ឆ្នាំ ២០១២)។

[277] វិធាន ៨៨(ង) នៃវិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ STL។ *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Merhi* សំណុំរឿងលេខ STL-13-04/I/PTJ ឯកសារសាធារណៈដែលត្រូវបានកោសលុបនៃ "សេចក្តីសម្រេចទាក់ទងនឹងការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០១៣ ដែលបានចេញប្រឆាំងនឹងលោក Hassan Habib Merhi នៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣" ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣។

[278] វិធាននីតិវិធី និង ភស្តុតាង ចំពោះមុខអង្គជំនុំជម្រះពិសេសប្រទេស កូសូវ៉ូ KSC-BD-03/Rev1/2017/1 ដែលបានចូលជាធរមាននៅថ្ងៃទី ៥ ខែកក្កដា ឆ្នាំ ២០១៧ ("វិធាននីតិវិធី និង ភស្តុតាងរបស់អង្គជំនុំជម្រះ KSC") វិធាន ៨៦(៤)។ ច្បាប់ស្តីពីអង្គជំនុំជម្រះពិសេស និង ការិយាល័យរដ្ឋអាជ្ញាពិសេស ច្បាប់លេខ 05/L-053 ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១៥ មាត្រា ៣៩(២)។

ភស្តុតាងដែលអាចទទួលយកបាន ដែលធ្វើឱ្យអ្នកសង្កេតការណ៍ដោយសត្យានុម័ត អាចជឿជាក់ថា បទល្មើសព្រហ្មទណ្ឌមួយបានកើតឡើង ហើយជនជាប់ចោទបានប្រព្រឹត្តបទល្មើសនោះ"[279]។ ដោយសារតែមិនមានការដាក់ជីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតុលាការ KSC នៅដំណាក់កាលនេះ ទើបមានភាពមិនច្បាស់លាស់ថា តើតម្រូវឱ្យមានកម្រិតភស្តុតាងបែបណា ដើម្បីបំពេញតាមបទដ្ឋាន "ការសង្ស័យដែលមានមូលដ្ឋានច្បាស់លាស់"។

១០៦. ខុសពីដំណើរការជីកាដំណោះស្រាយនៅ អ.វ.ត.ក. នៅតុលាការ KSC មេធាវីការពារក្តីមិនចូលរួម ក្នុងដំណើរការបញ្ជាក់ទេ[280]។ ខណៈដែលវិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ KSC តម្រូវឱ្យរដ្ឋអាជ្ញាពិសេស ដាក់ជីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមានសម្ភារភស្តុតាងគាំទ្រ និង "ការពណ៌នាលម្អិត ដែលបង្ហាញពីភាពពាក់ព័ន្ធរបស់សម្ភារនីមួយៗនៃភស្តុតាង ទៅនឹងបទចោទប្រកាន់នីមួយៗ ដោយមានការយោងជាពិសេស ទៅរកការប្រព្រឹត្តរបស់ជនសង្ស័យ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់"[281] តែមិនមានភាពច្បាស់លាស់ទេថា តើរដ្ឋអាជ្ញាត្រូវផ្តល់សម្ភារភស្តុតាង *ទាំងអស់* ដែលគាត់មានឬយ៉ាងណា ព្រោះនាពេលបច្ចុប្បន្ននេះ មិនមានរឿងក្តីកំពុងដំណើរការឡើយនៅតុលាការ KSC។

៣. សេចក្តីសន្និដ្ឋាន

១០៧. ស.ច.ស. គួរតែអនុវត្តបទដ្ឋានបង្ហាញភស្តុតាងដែលខ្ពស់បំផុត ដែលអាចបង្ហាញភស្តុតាងឱ្យហួសពីវិមតិសង្ស័យ ក្នុងការសម្រេចថា តើត្រូវបញ្ជូន មាស មុត ទៅជំនុំជម្រះឬយ៉ាងណា *ថាតើអង្គជំនុំជម្រះសាលាដំបូងដែលមានហេតុផល អាចផ្តន្ទាទោស មាស មុត ឱ្យហួសពីវិមតិសង្ស័យដែរឬយ៉ាងណា ដោយផ្អែកលើភស្តុតាងនៅក្នុងសំណុំរឿង*។ បទដ្ឋាននេះមានយុត្តិកម្ម ដោយសារតែលក្ខណៈវិសាមញ្ញនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក. បទដ្ឋានភស្តុតាងដែលច្បាស់លាស់ និង ស៊ីចង្វាក់គ្នា ដែលបានប្រើប្រាស់ក្នុងការចោទប្រកាន់ជនសង្ស័យ ការស៊ើបអង្កេតដែលពេញលេញ និងមានរយៈពេលយូររបស់ ស.ច.ស. និង ឱកាសក្នុងការវាយតម្លៃទៅលើ

---

[279] ក្រមនីតិវិធីព្រហ្មទណ្ឌ កូសូវ៉ូ ឆ្នាំ ២០១២ ច្បាប់លេខ 04/L-123 ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១២ មាត្រា ១៩ (១.១២)។

[280] វិធាន ៨៦(២) នៃវិធាននីតិវិធី និង ភស្តុតាងរបស់អង្គជំនុំជម្រះ KSC៖ "រដ្ឋអាជ្ញាពិសេសត្រូវដាក់ជីកាបញ្ជូនរឿងទៅជំនុំជម្រះជាសម្ងាត់ និង*ជាភាគីតែម្ខាង* ជាមួយចៅក្រមអង្គបុរេជំនុំជម្រះ ដើម្បីស្នើសុំសេចក្តីសម្រេច អនុលោមតាម មាត្រា ៣៩(២) នៃច្បាប់"។

[281] *ដូចខាងលើ* វិធាន ៨៦(៣)។

ភស្តុតាងនៅក្នុងសំណុំរឿង និង ភវនីយភាពខ្ពស់ដែលថា ថវិកានឹងមានមិនគ្រប់គ្រាន់ សម្រាប់ដំណើរការរឿងក្តី ០០៣ ដល់ទីបញ្ចប់។

១០៨. ស.ច.ស. មិនគួរពឹងផ្អែកលើបទដ្ឋានបញ្ជាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែល ស.ព.អ. ដកស្រង់ ឬ បទដ្ឋានបញ្ជាក់របស់តុលាការ ឬ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិដទៃទៀតឡើយ។ កម្រិតនៃ *មូលដ្ឋានសំខាន់ក្នុងការជឿជាក់* របស់តុលាការ ICC គឺទាបពេក ហើយមិនសមស្រប ក្នុងការបញ្ជូនជនត្រូវចោទនៅ អ.វ.ត.ក. ទៅជំនុំជម្រះឡើយ ព្រោះអង្គបុរេជំនុំជម្រះរបស់តុលាការ ICC មិនមានសិទ្ធិចូលពិនិត្យមើលភស្តុតាងទាំងអស់។ បទដ្ឋានរឿងក្តីកម្រិត *បឋម* របស់សាលាក្តី ICTY សាលាក្តី ICTR និង សាលាក្តី STL គឺទាបជាងបទដ្ឋានភវនីយភាព ហើយមេធាវីការពារក្តីក៏មិនបានចូលរួម ក្នុងដំណើរការបញ្ជាក់ដែរ។ បទដ្ឋានបញ្ជាក់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់តុលាការ SCSL និង តុលាការ KSC គឺមិនសមស្របសម្រាប់ដីកាដំណោះស្រាយឡើយ ដោយពិចារណាទៅលើភាពខុសគ្នាផ្នែកនីតិវិធីរបស់តុលាការទាំងនេះ ធៀបទៅនឹង អ.វ.ត.ក.។

គ. ឧក្រិដ្ឋកម្ម និង ទម្រង់នៃការទទួលខុសត្រូវជាធរមាន

១០៩. ជាទូទៅ មេធាវីការពារក្តីយល់ស្រប ជាមួយនិយមន័យឧក្រិដ្ឋកម្ម និង ទម្រង់នៃការទទួលខុសត្រូវដែលមាននៅក្នុងដីកាដំណោះស្រាយរឿងក្តី ០០៤/១[282]។ ប៉ុន្តែ មេធាវីការពារក្តីមិនយល់ស្របជាមួយនឹង ស.ច.ស. ដែលថា អ.វ.ត.ក. មានយុត្តាធិការក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មជាតិ ហើយថា ការទទួលខុសត្រូវរបស់ថ្នាក់លើ និង សហឧក្រិដ្ឋកម្មរួមទម្រង់១ គឺជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន តាមមាត្រា ២៩ ថ្មី។ មេធាវីការពារក្តីក៏មិនយល់ស្របផងដែរ ជាមួយនឹងសេចក្តីសម្រេចរបស់ ស.ច.ស.អ. នៅក្នុងរឿងក្តី ០០៣ ដែល ស.ច.ស.អ. ពិចារណាឃើញថា អ.វ.ត.ក. មានយុត្តាធិការក្នុងការជំនុំជម្រះលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និង ការវាយប្រហារដោយរដ្ឋ ឬ អង្គការ ទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដែលអាចបង្កើតបានជាការវាយប្រហារសំដៅប្រឆាំង “ប្រជាជនស៊ីវិល” តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

---

[282] កថាខណ្ឌ ៤៣-៥៦ (ឧក្រិដ្ឋកម្មថ្នាក់ជាតិ) កថាខណ្ឌ ៥៧-៧៧ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) កថាខណ្ឌ ៧៨-១០០ (ទម្រង់នៃការទទួលខុសត្រូវ) នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

១១០. មេធាវីការពារក្តីមិនយល់ស្របជាមួយ ការអះអាងជាច្រើនរបស់ ស.ព.អ. ស្តីពីធាតុផ្សំនៃឧក្រិដ្ឋកម្ម និង ទម្រង់នៃការទទួលខុសត្រូវ[283]។ ការយល់ខុសគ្នាទាំងនេះមិនត្រូវបានលើកឡើង នៅក្នុងចម្លើយតបនេះទេ ដោយសារតែការយល់ខុសគ្នានេះ ទាក់ទងទៅនឹងទម្រង់ជាក់លាក់នៃឧក្រិដ្ឋកម្ម ឬ ទម្រង់នៃការទទួលខុសត្រូវ។ អង្គបុរេជំនុំជម្រះបានសម្រេចថា ការជំទាស់បែបនេះ គឺជាបញ្ហាសម្រាប់ការជំនុំជម្រះក្នុងសវនាការ[284]។

១១១. ស.ព.អ. បានលើកទឡ្ហីករណ៍ដោយខុសថា មិនមានផ្នែកណាមួយក្នុងវិធានផ្ទៃក្នុង ដែលហាមឃាត់ឧក្រិដ្ឋកម្ម ឬ ទម្រង់នៃការទទួលខុសត្រូវ ដែលមិនត្រូវបានចោទប្រកាន់ ដោយ ស.ច.ស. នៅពេលបង្ហាញខ្លួនជាលើកទីមួយ ឬ នៅពេលបង្ហាញខ្លួនលើកបន្ទាប់ មិនឱ្យបង្កើតបានជាផ្នែកនៃដីកា

---

[283] *សូមមើល ខ.ថ.* កថាខណ្ឌ ៨៨៤-៨៥ នៃដីកាសន្និដ្ឋានស្តាពរ (លើកទឡ្ហីករណ៍ថា ការធ្វើតេស្ត *Nottebohm* គឺមានន័យចង្អៀតពេកចំពោះនិយមន័យ "ក្រុមជាតិ" សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍) កថាខណ្ឌ ៨៩៤-៩៥ (លើកទឡ្ហីករណ៍ថា ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ "ការបំផ្លិតបំផ្លាញ" ដោយចេតនា ចំពោះក្រុមមួយ មិនចាំបាច់មានលក្ខណៈរូបវន្ត ឬ ជីវសាស្ត្រនោះទេ) កថាខណ្ឌ ៩៥១ (លើកទឡ្ហីករណ៍ថា ការរស់នៅក្នុងសភាពថប់អារម្មណ៍ និង ភាពស្រពេចស្រពិលជាប់ជាប្រចាំ ដែលជាលទ្ធផលនៃការបំពានរូបរាងកាយ និង ការបង្ខាំង ជាទុក្ខវេទនាផ្លូវចិត្តដែលស្មើនឹងការធ្វើទារុណកម្ម ហើយថា ការគំរាមគំហែងដែលអាចជឿជាក់បានអំពីការប្រើប្រាស់ទារុណកម្មលើរូបរាងកាយ ការបង្កគ្រោះថ្នាក់ ឬ ការសម្លាប់ជនរងគ្រោះ គឺជាទារុណកម្មផ្លូវចិត្ត) កថាខណ្ឌ ៩៥៣ (លើកទឡ្ហីករណ៍ថា *ធាតុអត្តនោម័ត* នៃការធ្វើទារុណកម្ម រួមបញ្ចូលទាំងអំពើនៃការធ្វើទារុណកម្ម ក្នុងគោលបំណងរើសអើងប្រឆាំងជនរងគ្រោះ ឬ តតិយបុគ្គល) កថាខណ្ឌ ៩៩០ (លើកទឡ្ហីករណ៍ថា នៅពេលដែលជម្លោះប្រដាប់អាវុធអន្តរជាតិមានអត្ថិភាព ច្បាប់មនុស្សធម៌អន្តរជាតិអនុវត្តបន្ថែមក្រោយពីការឈប់មានអរិភាព) កថាខណ្ឌ ៩៩៤ (លើកទឡ្ហីករណ៍ថា ការធ្វើតេស្ត "ភក្តីភាព" ត្រូវបានប្រើសម្រាប់កំណត់សញ្ជាតិ ស្របតាមគោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ) កថាខណ្ឌ ១០២០, កថាខណ្ឌ ១០២៣ (លើកទឡ្ហីករណ៍ថា ចំពោះគោលបំណងនៃ "ការរៀបចំផែនការ" និង "ការញុះញង់" ដែលចារីផ្ទាល់បានដឹងពីហានៈរបស់ជនរងគ្រោះ ជាជនស៊ីវិល ឬ *ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ* មិនចាំបាច់បង្ហាញថា ជនត្រូវចោទ/ជនជាប់ចោទ មានចេតនា ឬ បានដឹងអំពីភវនីយភាពជាសារវន្តនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជាលទ្ធផលនៃការរៀបចំផែនការ ឬ ការញុះញង់នេះ) កថាខណ្ឌ ១០២៥ (លើកទឡ្ហីករណ៍ថា អត្ថិភាពនៃបញ្ហា អាចនឹងត្រូវទាញចេញពីលើកត្តាផ្សេងៗជាច្រើន) កថាខណ្ឌ ១០៤២ (លើកទឡ្ហីករណ៍ថា ចំពោះគោលបំណងនៃការទទួលខុសត្រូវថ្នាក់លើ មិនចាំបាច់មានការបង្ហាញពីទំនាក់ទំនងហេតុ និង ផល រវាងការខកខានរបស់ថ្នាក់លើ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មរបស់អ្នកក្រោមបង្គាប់ និង ការកើតឡើងនូវឧក្រិដ្ឋកម្មទេ)។

[284] កថាខណ្ឌ ៤៥-៤៦ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០២។

ដំណោះស្រាយឡើយ[285]។ ជនត្រូវចោទ "អាច... ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ តែចំពោះឧក្រិដ្ឋកម្មដែលគាតត្រូវបានចោទប្រកាន់ ហើយនឹងជួនដំណឹងត្រឹមត្រូវប៉ុណ្ណោះ"[286]។

១. អ.វ.ត.ក. មិនមានយុត្តាធិការ ដើម្បីជំនុំជម្រះលើឧក្រិដ្ឋកម្មជាតិ

១១២. អ.វ.ត.ក. មិនមានយុត្តាធិការ ដើម្បីជំនុំជម្រះឧក្រិដ្ឋកម្មជាតិឡើយ ពីព្រោះអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មជាតិបានកន្លងផុតទៅហើយ។ ឧក្រិដ្ឋកម្មជាតិមានអាជ្ញាយុកាលចំនួន ១០ ឆ្នាំ[287]។ ទោះបីជាច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. "បង្កើន" រយៈពេលអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មទាំងអស់នេះ ដល់ទៅ ៣០ ឆ្នាំបន្ថែមក៏ដោយ[288] ក៏រយៈពេល ១០ ឆ្នាំបានកន្លងហួស មុនពេលដែលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានអនុម័តក្នុងឆ្នាំ ២០០១ ដែរ[289]។ អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០២ មានកំហុសឆ្គងនៅពេលដែលសម្រេចថាប្រព័ន្ធតុលាការកម្ពុជាមិនមានដំណើរការរហូតដល់ឆ្នាំ ១៩៨២ ហើយថាអាជ្ញាយុកាលត្រូវបានបញ្ឈប់រហូតដល់ឆ្នាំ ១៩៩៣ ដោយសារតែអយ្យការ និង ចៅក្រមស៊ើបសួរ ត្រូវបានបង្ខាក់ហូតដល់ពេលនោះ[290]។ ភាពទន់ខ្សោយនៅក្នុងប្រព័ន្ធតុលាការកម្ពុជា មិនបានបង្ហាញថា *មិនអាច* មានបណ្តឹងផ្លូវច្បាប់នៅមុនឆ្នាំ ១៩៩៣ បាននោះឡើយ[291]។ ការចាប់ផ្តើម

---

[285] កថាខណ្ឌ ១០៦២ នៃដីកាសន្និដ្ឋានស្តាពរ។

[286] កថាខណ្ឌ ២៤៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[287] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ចែងថា បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំនួនយ៉ាងតិច ៥ ឆ្នាំ មានអាជ្ញាយុកាល ១០ឆ្នាំ។ មាត្រា ២១ មាត្រា ៣២ មាត្រា ៣៣ មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

[288] មាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.៖ "អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យាពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ"។

[289] *សូមមើល* ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ សន/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០១។

[290] កថាខណ្ឌ ២៨៦ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០២។

[291] ប្រព័ន្ធតុលាការកម្ពុជាមានអត្ថិភាព និង ដំណើរការក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ *សូមមើល* EVAN GOTTESMAN កម្ពុជាក្រោយរបបខ្មែរក្រហម ទំព័រ ២៤១-៤៧ (សៀវភៅ Silkworm ឆ្នាំ ២០០៤)។ Suzannah Linton *ការពិនិត្យអង្គជំនុំជម្រះវិសាមញ្ញកម្ពុជាក្នុងបរិបទ* 11 SING. Y.B. INT'L L. ទំព័រ ១៩៥ ទំព័រ ១៩៩-២០០ (ឆ្នាំ ២០០៧)។ Basil Fernando *ប្រព័ន្ធនៃការជំនុំជម្រះនៅក្រោមគំរូវៀតណាម-ខ្មែរ (ឆ្នាំ ១៩៨១-១៩៩៣) នៅក្នុង* បញ្ហាប្រឈមនឹងប្រព័ន្ធច្បាប់កម្ពុជា (គណៈកម្មការសិទ្ធិមនុស្សអាស៊ី ឆ្នាំ ១៩៩៨)។ *សូមមើលផងដែរ* Michael Vickery *និតិរដ្ឋក្នុងប្រទេសកម្ពុជា* 14.3 CULTURAL SURVIVAL Q (ឆ្នាំ

ឡើងវិញនូវអាជ្ញាយុកាល ដែលបានផុតកំណត់ទៅហើយនោះ គឺជាការរំលោភបំពានលើគោលការណ៍មិនប្រតិសកម្ម[292]។ រាល់មន្ទិលសង្ស័យណាមួយទាក់ទងនឹងប្រតិសកម្ម ត្រូវដោះស្រាយឱ្យបានជាប្រយោជន៍ដល់ជនត្រូវចោទ ស្របតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង គោលការណ៍វិមតិសង្ស័យ នឹងបានជាប្រយោជន៍ដល់ជនត្រូវចោទ[293]។

១១៣. ការអនុវត្តឧក្រិដ្ឋកម្មជាតិក៏រំលោភបំពានផងដែរ លើសិទ្ធិទទួលបានការប្រព្រឹត្តដូចគ្នារបស់ មាស មុត[294]។ មាស មុត អាចត្រូវបានបញ្ជូនទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មជាតិ ខណៈដែលអ្នក

១៩៩០)។ MICHAEL VICKERY កម្ពុជា៖ នយោបាយ សេដ្ឋកិច្ច និង សង្គម ទំព័រ ១២០ (ការបោះពុម្ពនៅបាវ៉ាំង ឆ្នាំ ១៩៨៦)៖ "ការជំនុំជម្រះដែលមិនមានលក្ខណៈនយោបាយមួយត្រូវបានវាយការណ៍ថា មានពាក់ព័ន្ធនឹងបុរសប្រាំរូប ដែលត្រូវបានចោទប្រកាន់ក្នុងខែឧសភា ឆ្នាំ ១៩៨២ ពីបទប្តន់ និង នៅក្នុងករណីបទមនុស្សឃាតមួយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារយៈពេលពី១៨ ឆ្នាំ ដល់ ទោសអស់មួយជីវិតចំពោះឃាតករ"។ ចៅក្រម Judges Cartwright និង ចៅក្រម Lavergne បានចង្អុលបង្ហាញក្នុងរឿងក្តី ០០១ ថា "ទោះបីជាសង្គ្រាមស៊ីវិល និង ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ខ្មែរក្រហមលើតំបន់មួយចំនួនក្នុងប្រទេស ដែលអាចបង្ហាញពីឧបសគ្គយ៉ាងពិតប្រាកដនៅក្នុងការផ្តួចផ្តើមការចោទប្រកាន់ ឬ ការស៊ើបសួរបស់តុលាការក៏ដោយ... ការចោទប្រកាន់ ឬ ការស៊ើបសួរមិនបានបង្អាក់គ្រប់កន្លែងនៅក្នុងប្រទេសនោះទេ"។ ហើយនៅមាន "ភស្តុតាងដែលបង្ហាញថា ចាប់តាំងពីឆ្នាំ ១៩៧៩ មក ច្បាប់ និងក្រឹត្យ-ច្បាប់នានា ត្រូវបានអនុម័តជាបន្តបន្ទាប់"។ *សូមមើល រឿងក្តី កាំង ហ្គេក អ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចស្តីពីអញ្ជើញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E187 កថាខណ្ឌ ៣២-៣៣។

[292] គោលការណ៍អប្រតិសកម្ម ហាមឃាត់ការអនុវត្តប្រតិសកម្មនៃច្បាប់ដែលនាំឱ្យខាតប្រយោជន៍ជនត្រូវចោទ។ ច្បាប់ថ្មី អាចអនុវត្តបែបប្រតិសកម្ម ដើម្បីជាប្រយោជន៍ដល់ជនត្រូវចោទ ជាជាងច្បាប់ដែលអនុវត្តពីមុនមក។ *សូមមើល* សេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តតាមសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២១៧ A(III) ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨ ("សេចក្តីប្រកាស UDHR") មាត្រា ១១(២)។ មាត្រា ១៥(១) នៃកតិកាសញ្ញា ICCRP។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ១២(២) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ *សូមមើលផងដែរ* មាត្រា ៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ និង មាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ ដែលមាត្រាទាំងពីរហាមឃាត់ការអនុវត្តច្បាប់បែបប្រតិសកម្ម។ *សូមមើល ផងដែរ* ព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញ សេចក្តីសម្រេចលេខ ០៤០/០០២/២០០១ ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០០១ ទំព័រ ២ ដែលសន្និដ្ឋានថា មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. "ប៉ះពាល់ដល់គោលការណ៍ជាសារវន្ត ដែលមិនអាចប្រកែកបាន" "ភាពអប្រតិសកម្មនៃច្បាប់ថ្មីណាមួយ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងអតីតកាល...' " (ការបកប្រែក្រៅផ្លូវការ)។

[293] *សូមមើល* កថាខណ្ឌ ២៦-៣៦ នៃដីកាដំណោះស្រាយ។

[294] សិទ្ធិប្រព្រឹត្តិស្មើគ្នាចំពោះមុខច្បាប់ ត្រូវបានធានាក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៧ នៃសេចក្តីប្រកាស UDHR និង មាត្រា ១៤(១) និង ២៦ នៃ កតិកាសញ្ញា ICCPR ។ *សូមមើលផងដែរ* កថាខណ្ឌ ២ នៃសេចក្តីអធិប្បាយទូទៅលេខ ៣២៖ "សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និង សាលាក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺជាធាតុផ្សំសំខាន់នៃការការពារ

ផ្សេងទៀតដែលត្រូវបានចោទប្រកាន់ ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មជាតិនៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការកម្ពុជាណាមួយ មិនអាចត្រូវបានបញ្ជូនទៅជំនុំជម្រះពីបទនេះទៅវិញ[295]។ សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការប្រព្រឹត្តស្មើគ្នា ក៏ត្រូវបានរំលោភផងដែរ ដោយការណ៍ដែលថា ឧក្រិដ្ឋកម្មជាតិមិនត្រូវបានអនុវត្ត នៅក្នុងរឿងក្តី ០០១ ឬ រឿងក្តី ០០២[296] ប៉ុន្តែ បែរជាត្រូវចោទប្រកាន់ក្នុងរឿងក្តីរបស់គាត់។

សិទ្ធិមនុស្ស និង មានតួនាទីជាមធ្យោបាយនីតិវិធីសម្រាប់ការពារនីតិរដ្ឋ"។ ការប្រព្រឹត្តផ្សេងពីនេះណាមួយ ត្រូវតែ "ផ្អែកលើលក្ខណៈវិនិច្ឆយសមហេតុផល និង សត្យានុម័ត"។ *Rita Hiro Balani គទល់នឹង អេស្ប៉ាញ* ទំនាក់ទំនងព័ត៌មានលេខ ១០២១/២០០១ ឯកសារ អ.ស.ប. លេខ CCPR/C/77/D/1021/2001 (ឆ្នាំ ១៩៩៨) កថាខណ្ឌ ៤.៣។ *Waldman គទល់នឹង កាណាដា* (មតិដែលត្រូវបានអនុម័តនៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៩) នៅ អ.ស.ប. របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្ស (ភាគទី II) ឯកសារ អ.ស.ប. លេខ A/៥៥/៤០ កថាខណ្ឌ ១០.៦។

[295] មាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. "ពន្យា" អាជ្ញាយុកាល ចំពោះបទមនុស្សឃាត ទារុណកម្ម ការវាយប្រហារលើសាសនា ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ *សម្រាប់តែ* នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. ប៉ុណ្ណោះ។ អាជ្ញាយុកាលមិនត្រូវបានពន្យាជាទូទៅទេ។

[296] ក.ស.ព. បានស្នើឱ្យឧក្រិដ្ឋកម្មថ្នាក់ជាតិអនុវត្តប្រឆាំងនឹង ឌុច ឆួន ជា អៀង សារី អៀង ធារិទ្ធ និង ខៀវ សំផន ក៏ប៉ុន្តែជាចុងក្រោយ មិនត្រូវបានអនុវត្តទេ ដោយសារចៅក្រមអង្គជំនុំជម្រះសាលាដំបូង (ក្នុងរឿងក្តី ០០១) និង ស.ច.ស. (ក្នុងរឿងក្តី ០០២) មិនបានឯកភាពថា យុត្តាធិការរបស់ អ.វ.ត.ក. ត្រូវយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មថ្នាក់ជាតិទេ។ ពុំមានលក្ខណៈវិនិច្ឆយសមស្រប ឬ សត្យានុម័ត ដែលនឹងអនុញ្ញាតឱ្យអនុវត្តឧក្រិដ្ឋកម្មថ្នាក់ជាតិចំពោះ មាស មុត នៅខណៈដែលពួកគេមិនអាចអនុវត្តបានចំពោះជនជាប់ចោទ ក្នុងរឿងក្តី ០០១ និង រឿងក្តី ០០២។ *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចស្តីពីអញ្ជត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E187 កថាខណ្ឌ ១៤។ *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើអញ្ជត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E122 EN 00743463 KH 00743451-00743452។ ក្នុងរឿងក្តី ០០២ ស.ច.ស. មិនបានឯកភាពគ្នាថា តើឧក្រិដ្ឋកម្មថ្នាក់ជាតិត្រូវយកមកអនុវត្តឬយ៉ាងណាទេ ហើយពួកគេបានទុកឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូង មិនអាចអនុវត្តឧក្រិដ្ឋកម្មថ្នាក់ជាតិបានឡើយ (ទោះបីជាចៅក្រមយល់ថា អាចត្រូវអនុវត្តបានក៏ដោយ) ដោយហេតុថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានកំហុស - ស.ច.ស. មិនបានបង្ហាញអង្គហេតុសម្ភារ ដែលនាំឱ្យមានការចោទប្រកាន់ ឬ ចរិកលក្ខណៈនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនោះទេ។ *សូមមើល ដូចខាងលើ* កថាខណ្ឌ ២១-២២។

១១៤. មេធាវីការពារក្តីដាក់បញ្ចូល តាមរយៈការយោងទង្វើករណ៍ ដែលបានលើកឡើងក្នុងសារណាកន្លងមករបស់ខ្លួន[297]។

២. ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនអាចអនុវត្តបាននៅ អ.វ.ត.ក. ឬ ជាជម្រើសមួយផ្សេងទៀត ប្រសិនបើអាចអនុវត្តបាន ក៏មិនអាចអនុវត្តចំពោះឧក្រិដ្ឋកម្ម ដែលមានចេតនាជាក់លាក់ ឬ ចំពោះឧក្រិដ្ឋកម្មដែលមិនជាប់ទាក់ទង ជាមួយជម្លោះប្រដាប់អាវុធជាអន្តរជាតិដែរ

១១៥. ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនអាចអនុវត្តបាននៅ អ.វ.ត.ក. ទេ ព្រោះការទទួលខុសត្រូវនេះមិនមានអត្ថិភាពនៅក្នុងច្បាប់ជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ ច្បាប់សន្ធិសញ្ញាជាធរមានណាមួយ នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ។ អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០២ មានកំហុសឆ្គងដែលបានសម្រេចថា ការទទួលខុសត្រូវរបស់ថ្នាក់លើ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[298]។ រឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរមួយចំនួនតូច ដែលបានអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ មិនបានផ្តល់នូវភស្តុតាងគ្រប់គ្រាន់ អំពីការអនុវត្តរបស់រដ្ឋ ឬ *ទស្សនច្បាប់* (Opinio juris) ទូលំទូលាយ និង ស៊ីចង្វាក់គ្នា ទាក់ទងការទទួលខុសត្រូវរបស់ថ្នាក់លើឡើយ[299]។ ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមានភាពស្របគ្នា

---

[297] ញត្តិរបស់លោក មាស មុត សុំជំទាស់នឹងការអនុវត្ត បទល្មើសនានាដែលមានចែងក្នុងមាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. (បទល្មើសតាមច្បាប់ជាតិ) ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.13។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D174/1/1 កថាខណ្ឌ ៣១-៥៣។

[298] កថាខណ្ឌ ៣៩៩-៤៦០ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០២។

[299] រឿងក្តី *Yamashita* គឺជារឿងក្តីសម័យថ្មីដំបូង ដែលអនុវត្តច្រើស្តីការទទួលខុសត្រូវរបស់ថ្នាក់លើ ហើយប្រហែលជារឿងក្តីដែលទទួលរងការរិះគន់ច្រើនបំផុត ដោយសារតែរឿងក្តីនេះជារួម បានយកបទដ្ឋាននៃការទទួលខុសត្រូវដ៏តឹងរ៉ឹងបំផុតមកអនុវត្ត។ *សូមមើល រឿងក្តី In re Yamashita* ៣២៧ ស.រ.អ. ១ ១៥-១៦ (ឆ្នាំ ១៩៤៦)។ *សូមមើលផងដែរ ដូចខាងលើ ទំព័រ* ៣៤ (មតិជំទាស់របស់ចៅក្រម Murphy) និង ទំព័រ ៤៣-៤៤ (មតិជំទាស់របស់ចៅក្រម Rutledge)។ Jenny S. Martinez *ការយល់ដឹងពី* ធាតុផ្សំអត្តនោម័ត នៅក្នុង*ការទទួលខុសត្រូវរបស់ថ្នាក់លើ៖ ពី Yamashita ទៅ Blaškić និង លើសពីនេះ* (Understanding Mens Rea in Command Responsibility: From Yamashita to Blaškić and and Beyond) ទំព័រ ៥៣ រាជកិច្ចយុត្តធម៌ព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ៦៣៨ និង ៦៤១ (ឆ្នាំ ២០០៧)។ Major Bruce L. Landrum ការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាម *Yamashita៖ ការទទួលខុសត្រូវរបស់ថ្នាក់លើ នៅពេលនោះ និង ពេលបច្ចុប្បន្ន* ទំព័រ ១៤៩ វិរៈចនាច្បាប់យោធា ទំព័រ ២៩៣ និង ២៩៤ (ឆ្នាំ ១៩៩៥)៖ "ឧត្តមសេនីយ Yamashita មិនមានមធ្យោបាយដើម្បីដឹងថា គាត់នឹងត្រូវវិនិច្ឆយតាមបទដ្ឋានដ៏តឹងរ៉ឹងបំផុត ដែលត្រូវបានរៀបចំឡើងសម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះអំពើរបស់ជនក្រោមបង្គាប់របស់

ឬ ញឹកញាប់គ្រប់គ្រាន់ សម្រាប់បង្កើតជាមូលដ្ឋាននៃការអនុវត្តរបស់រដ្ឋ ទូលំទូលាយ ឬ ស៊ីចង្វាក់គ្នា ដែលតម្រូវសម្រាប់សម្រេចថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ[300]។ ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និង ពិធីសារទាក់ទងជាមួយការការពារជនរងគ្រោះ ដោយសារជម្លោះប្រដាប់អាវុធអន្តរជាតិ[301] មិនអាចតាក់តែងជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ទាក់ទងការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយសារតែការអនុវត្តរបស់រដ្ឋដែលមិនស្របគ្នា ឬ ការមិនមានការអនុវត្តរបស់រដ្ឋ ហើយនិងការអនុវត្តផ្សេងៗគ្នានៅក្នុងយុត្តិសាស្ត្រសង្គ្រាមលោកលើកទីពីរ[302]។

១១៦. ប្រសិនបើការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានសម្រេចថាអាចអនុវត្តបាន ការទទួលខុសត្រូវនេះប្រហែលជាមិនអាចអនុវត្តបាន ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជាឧក្រិដ្ឋកម្ម

លោកទេ"។ អង្គបុរេជំនុំជម្រះ ក្នុងរឿងក្តី ០០២ បានពិចារណាករណីចំនួន ៤ នៅក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រង លេខ ១០ នៅក្នុងតំបន់គ្រប់គ្រងដោយសហរដ្ឋអាមេរិក និង ក្នុងករណីមួយទៀតពីតំបន់ ដែលគ្រប់គ្រងដោយប្រទេសបារាំង ដែលបានអនុវត្តគោលការណ៍ការទទួលខុសត្រូវរបស់ថ្នាក់លើ។ កថាខណ្ឌ ៤២៨-៤៣ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០២។ ករណីទាំងនេះមិនបានបង្កើតជាយុត្តិសាស្ត្រអន្តរជាតិដែលមានសុពលភាពនោះទេ ព្រោះថា ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០ ត្រូវបានអនុម័តក្រោមអំណាចច្បាប់របស់ប្រទេសអាល្លឺម៉ង់ (ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត)។ Attila Bogdan *ការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ ក្នុងការអនុវត្ត "សហឧក្រិដ្ឋកម្មរួម" នៅក្នុងយុត្តិសាស្ត្រសាលាក្តី* ចំពោះកិច្ច *អន្តរជាតិពិសេសសម្រាប់អតីតប្រទេសយូហ្គោស្លាវី* វិវរណនាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លេខ ៦ ទំព័រ ៦៣ និង ១០០ (ឆ្នាំ ២០០៦)។ អង្គបុរេជំនុំជម្រះក៏បានពិចារណាផងដែរថា សាលាក្តីយោធាអន្តរជាតិសម្រាប់ប្រទេសចុងបូព៌ា ("សាលាក្តី IMTFE") បានរកឃើញថា មេបញ្ជាការមួយចំនួន មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មសង្គ្រាម តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ ប៉ុន្តែ បានទទួលស្គាល់ថាទម្រង់នៃធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅសាលាក្តី IMTFE មិនមានភាពច្បាស់លាស់ទេ។ កថាខណ្ឌ ៤៤៥-៥៥ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០២។ ជាចុងក្រោយ អង្គបុរេជំនុំជម្រះ បានពិចារណាការជំនុំជម្រះក្តី អូស្ត្រាលី/ស.រ.អ. លើឧត្តមនាវីឯក Toyoda។ *ដូចខាងលើ* កថាខណ្ឌ ៥៥៦-៥៧។ រឿងក្តីទាំងអស់នេះមិនគ្រប់គ្រាន់ ដើម្បីបង្ហាញពីទម្លាប់អនុវត្តន៍ដ៏ទូលាយ និង ស៊ីចង្វាក់របស់រដ្ឋនោះទេ។

[300] WARD N. FERDINANDUSSE ការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិផ្ទាល់ នៅក្នុងតុលាការជាតិ ទំព័រ ១១៨-១៩ (T.M.C. Asser Press ឆ្នាំ ២០០៦)។ Ilias Bantekas *ច្បាប់សហសម័យនៃការទទួលខុសត្រូវរបស់ថ្នាក់លើ* លេខ ៩៣ វារជកិច្ចច្បាប់អន្តរជាតិរបស់ ស.រ.អ. ទំព័រ ៥៧៣ និង ៥៧៤-៧៥ (ឆ្នាំ ១៩៩៩)។

[301] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ពិធីការបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធទៅនឹងការការពារជនរងគ្រោះនៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ១២៥៥ UNTS ៣ ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ ("ពិធីសារបន្ថែម I")។

[302] *សូមមើល* ជើងទំព័រ ២៩៩-៣០០ *ខាងលើ* ។

ប្រល័យពូជសាសន៍ ឬ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញឡើយ។ ការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មទាំងនោះ បានបន្តឃើញថា *ធាតុផ្សំអត្តនោម័ត* ដែលបានតម្រូវ ហើយបានដកចេញទាំងស្រុង នូវធាតុផ្សំចេតនាជាក់លាក់។ តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្នាក់លើម្នាក់អាចទទួលខុសត្រូវនៅពេលដែល គាត់មិនមានចេតនាឱ្យកើតមានឡើង នូវឧក្រិដ្ឋកម្មនោះទេ ហើយគាត់អាចសូម្បីតែមិនបានដឹង អំពីការកើតឡើងនូវឧក្រិដ្ឋកម្មនោះ រហូតដល់ក្រោយពេលមានអង្គហេតុ[303]។ "តាមតក្កភាព គឺមិនអាចទៅរួចឡើយ ក្នុងការផ្តន្ទាទោសជនណាម្នាក់ ដែលគ្រាន់តែធ្វេសប្រហែស ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់នោះ"[304]។

១១៧. ប្រសិនបើការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានសម្រេចថាអាចអនុវត្តបាននោះ ការទទួលខុសត្រូវនេះចាំបាច់ត្រូវអនុវត្ត ចំពោះឧក្រិដ្ឋកម្មដែលជាប់ទាក់ទងនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ។ ការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ត្រូវបានអនុវត្តជាលើកដំបូង នៅក្នុងសាលក្តីក្រោយសង្គ្រាមលោកលើកទីពីរ[305] ដែលទាក់ទងតែនឹងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។ មិនមានភស្តុតាងនៃការអនុវត្តរបស់រដ្ឋជាទូទៅ និង ស៊ីចង្វាក់គ្នាឡើយ កុំថាឡើយដល់ទៅទស្សនច្បាប់ ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ ទៅក្នុងបរិបទជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិនៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ។ ខណៈដែល ស.ច.ស.អ. ពិចារណាឃើញថា នេះគឺជាច្បាប់ដែលបានកំណត់នៅ អ.វ.ត.ក. ដែលថាការទទួលខុសត្រូវរបស់ថ្នាក់លើ គឺអាចអនុវត្តបានទាំងចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិ ទាំងមិនមែនអន្តរជាតិនោះ[306] យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូង

---

[303] ការទទួលខុសត្រូវរបស់ថ្នាក់លើ ចាត់ទុកថា បុគ្គលដែលមានឋានៈខ្ពស់ត្រូវទទួលខុសត្រូវ នៅពេលដែលខ្លួនខកខានដាក់ទណ្ឌកម្មជនក្រោមបង្គាប់ ក្រោយពីបានដឹងច្បាស់អំពីឧក្រិដ្ឋកម្ម ឬ មានហេតុផលនាំឱ្យដឹងថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត។ *សូមមើល* កថាខណ្ឌ ៥៣៨ នៃសាលក្រមក្នុងរឿងក្តី ០០១។

[304] William Schabas *ការណាដាអនុវត្តច្បាប់លក្ខន្តិក:ទីក្រុងរ៉ូម* សៀវភៅឆ្នាំទី ៣ នៃច្បាប់មនុស្សធម៌អន្តរជាតិ ទំព័រ ៣៣៧, ៣៤២ (ឆ្នាំ ២០០០)។

[305] កថាខណ្ឌ ៥២៣ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០២។

[306] ដីកាសម្រេចលើការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្រៅជម្លោះប្រដាប់អាវុធអន្តរជាតិ ចុះថ្ងៃទី ១ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D145/3 កថាខណ្ឌ ៣៣។

ដែល ស.ច.ស.អ. បានពឹងផ្អែកទៅលើនោះ មិនបានពិចារណាឡើយថា តើការទទួលខុសត្រូវរបស់ថ្នាក់លើ អាចអនុវត្តបានទៅលើជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិឬយ៉ាងណា[307]។

១១៨. មេធាវីការពារក្តីដាក់បញ្ចូល តាមរយៈការយោងទង្គឹកឆ្ពើកឆ្ពើងក្នុងសារណាកន្លងមករបស់ខ្លួន[308]។

៣. សហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ មិនអាចអនុវត្តបាននៅ អ.វ.ត.ក.

១១៩. សហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ មិនអាចអនុវត្តបានឡើយនៅ អ.វ.ត.ក. ព្រោះមិនមានទម្រង់ណាមួយនៃសហឧក្រិដ្ឋកម្មរួម មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ចៅក្រម Shahabuddeen ដែលជាចៅក្រមប្រធាននៃអង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *Tadić* បានទទួលស្គាល់ថាជា "កំហុសឆ្គងមួយ" សម្រាប់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការសន្និដ្ឋានសម្រេចថា ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម មានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ៖

> អ្នករៀបរៀងបានយោងទៅរកកំហុសឆ្គងមួយរបស់សាលាក្តី ដែលគាត់គឺជាភាគីមួយនៃតុលាការនោះដែរ។ នោះគឺទាក់ទងនឹងបញ្ហាថា តើសហឧក្រិដ្ឋកម្មរួមគឺជា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងកម្រិតដែលវាអាចអនុញ្ញាតឱ្យមានការផ្តន្ទាទោសដោយមិនមានភស្តុតាងបង្ហាញចេតនាឬយ៉ាងណា។ នៅក្នុងន័យនេះ ទ្រឹស្តីប្រឆាំងគ្នាពីរ សហឧក្រិដ្ឋកម្មរួម និង សហចារីកម្ម មានឥទ្ធិពលយ៉ាងខ្លាំងនៅសឹងគ្រប់ផ្នែកទាំងអស់ក្នុង

---

[307] កថាខណ្ឌ ៤១៣-៦០ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០២។ *រឿងក្តី ឆ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៤៥ & ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ឆ្លួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/3/15 កថាខណ្ឌ ១៩០-២៣២។

[308] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D174/1/1 កថាខណ្ឌ ៦៣-៨០។ ញត្តិរបស់ មាស មុត ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលមិនពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D145។

ពិភពលោក ប៉ុន្តែមិនមែនជាទូទៅទេ។ ហេតុដូច្នេះ ទ្រឹស្តីទាំងពីរមិនអាចមានសិទ្ធិទទួលបានការចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ[309]។

ដោយសារតែសហឧក្រិដ្ឋកម្មរួម ត្រូវបានទទួលស្គាល់ជាលើកដំបូងនៅសាលាក្តី ICTY[310] ទើបការទទួលស្គាល់បែបនេះ គឺជាហេតុផលមិនអាចប្រកែកបាន ក្នុងការងាកចេញពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ស្តីពីសហឧក្រិដ្ឋកម្មរួម ដើម្បីជាប្រយោជន៍យុត្តិធម៌[311]។

១២០. មិនមានការអនុវត្តរបស់រដ្ឋ "ទូលំទូលាយ និង រួមគ្នា" ឡើយ ទាក់ទងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១[312] ហើយក៏មិនមាន *ទស្សនច្បាប់* ដែលថាសហឧក្រិដ្ឋកម្មរួម គឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះដែរ[313]។ ការសិក្សាដែលធ្វើឡើងដោយការិយាល័យរដ្ឋអាជ្ញារបស់សាលាក្តី ICTY បានអះអាងបញ្ជាក់ថា "ការប្រៀបធៀបវិធានគ្រប់គ្រងលើការចូលរួមក្នុងឧក្រិដ្ឋកម្ម បានបង្ហាញពីកម្រិតខ្ពស់នៃអញ្ញត្រកម្ម នៅក្នុងចំណោមប្រព័ន្ធគតិយុត្តិដែលបានសិក្សា" ហើយថារដ្ឋភាគច្រើនបានប្រើប្រាស់សហចារី ជាជាងប្រើប្រាស់ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម[314]។ តុលាការ

---

[309] Mohamed Shahabuddeen *ការឆ្លៃប្រឌិតតុលាការ និង សហឧក្រិដ្ឋកម្មរួម នៅក្នុង* ការឆ្លៃប្រឌិតតុលាការនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ២០២-០៣ (ឆ្នាំ ២០១០)។

[310] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A សាលដីកា ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៩៩ ("សាលដីកា *Tadić*") កថាខណ្ឌ ១៨៧-២២៩។

[311] កថាខណ្ឌ ៥១២ នៃសាលក្រមក្នុងរឿងក្តី ០០១។ *រឿងក្តី ន្ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៦៩។ *រឿងក្តី ន្ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើភាពអាចអនុវត្តបានន្ទូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E100/6 កថាខណ្ឌ ២២។ កថាខណ្ឌ ៩១ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ ការអនុវត្តទម្រង់ទី I និងទី II នៃសហឧក្រិដ្ឋកម្មរួម មិនត្រូវបានជំទាស់តវ៉ានៅក្នុងបណ្តឹងឧទ្ធរណ៍រឿងក្តី ០០២/០១ ទេ។

[312] *រឿងក្តី តំបន់ខ្ពង់រាបសមុទ្រខាងជើង (សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តទល់នឹង ដាណឺម៉ាក សាធារណរដ្ឋអាល្លឺម៉ង់ តទល់នឹង ហូឡង់)* តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ១៩៦៩ (ថ្ងៃទី ២០ ខែកុម្ភៈ) កថាខណ្ឌ ៧៤។

[313] *រឿងក្តី សកម្មភាពយោធា និង យោធាប្រតិព័ទ្ធ (នីការ៉ាហ្គា តទល់នឹង ស.រ.អ.)* តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ១៩៨៦ (ថ្ងៃទី ២៧ ខែមិថុនា) កថាខណ្ឌ ២០៧។

[314] ការចូលរួមក្នុងឧក្រិដ្ឋកម្ម៖ ការទទួលខុសត្រូវព្រហ្មទណ្ឌនៃក្រុមឧក្រិដ្ឋកម្ម និង បណ្តាញឧក្រិដ្ឋកម្ម មតិអ្នកជំនាញ ដែលទទួលបានការតែងតាំងពីអង្គការសហប្រជាជាតិ - សាលាក្តី ICTY ការិយាល័យសម្របសម្រួលគម្រោងការងាររដ្ឋអាជ្ញា៖

ICC បានច្រានចោល សេចក្តីអំពាវនាវឱ្យអនុវត្ត ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ដោយសម្រេចថា ការទទួលខុសត្រូវនេះមិនមានចែងនៅក្នុងលក្ខន្តិក:ទីក្រុងរ៉ូម[315]។ គោលដៅនៃសន្និសីទទីក្រុងរ៉ូម គឺដើម្បីសម្រេចបាននូវការទទួលយក ដែលទូលំទូលាយតាមដែលអាចធ្វើបានដោយតុលាការ ICC តាមរយៈការអនុម័តជាសំខាន់ ដាក់ចូលទៅក្នុងបទប្បញ្ញត្តិនៃលក្ខន្តិក:ទីក្រុងរ៉ូម ដែលត្រូវបានទទួលស្គាល់ថា ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ[316]។ មាត្រា ២៥ នៃលក្ខន្តិក:ទីក្រុងរ៉ូម (ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល) ត្រូវបានព្រាងនៅក្នុងកិច្ចចរចាដ៏ធំទូលាយ ទៅលើលក្ខន្តិក:ទីក្រុងរ៉ូម អស់រយៈពេលជាងបីឆ្នាំ ហើយមានប្រទេសចូលរួមចំនួន ១៦០ប្រទេស[317]។ ដោយការទទួលយករបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* លក្ខន្តិក:ទីក្រុងរ៉ូម គឺជា "អត្ថបទដែលគាំទ្រដោយរដ្ឋជាច្រើន អាចត្រូវបានប្រើប្រាស់ សម្រាប់បង្ហាញនូវគោលជំហរផ្លូវច្បាប់ ពោលគឺ *ទស្សនច្បាប់* របស់រដ្ឋទាំងអស់នោះ"[318]។

១២១. ច្បាប់កម្ពុជាចែងថា សហចារីកម្ម គឺជាទម្រង់នៃការទទួលខុសត្រូវជាធរមាន[319]។ អង្គបុរេជំនុំជម្រះមានកំហុសឆ្គង នៅពេលដែលសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ ដូចនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល[320] ដោយអង្គបុរេជំនុំជម្រះមិនបានពិចារណាថា ខុសពីការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ សហចារីកម្មតម្រូវឱ្យមានការរួមចំណែករបស់

វិទ្យាស្ថាន Max-Planck សម្រាប់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និង បរទេស នៅ Freiburg ប្រទេសអាល្លឺម៉ង់ សេចក្តីផ្តើម ទំព័រ ៣។ ផ្នែកទី ១៖ ការវិភាគប្រៀបធៀបនៃប្រព័ន្ធច្បាប់ ទំព័រ ១៦។

[315] *សូមមើល* Thomas Weigend *ចេតនា កំហុសនៃច្បាប់ និង សហចារី នៅក្នុងសេចក្តីសម្រេចបញ្ជាក់បទចោទប្រកាន់* Lubanga វារជកិច្ចយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ លេខ ៦ ទំព័រ ៥៧១ និង ៥៧៦-៥៧៨ (ឆ្នាំ ២០០៨)។

[316] *សូមមើល* GERHARD WERLE គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លេខ ៤៥ អត្ថបទរឹមដើមទំព័រលេខ ១២៧, ៤០២ ជើងទំព័រ ១០៨ (ការបោះពុម្ពលើកទី ១ ឆ្នាំ ២០០៥)។

[317] John Washburn *ការចរចាស្តីពីលក្ខន្តិក:ទីក្រុងរ៉ូម សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ និង ទីតិកម្មអន្តរជាតិក្នុងសតវត្សរ៍ទី ២១* វារៈចនាច្បាប់អន្តរជាតិ PACE លេខ ១១ ទំព័រ ៣៦១ (ឆ្នាំ ១៩៩៩)។

[318] កថាខណ្ឌ ២២៣ នៃសាលដីកា *Tadić* ។

[319] មាត្រា ៨២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

[320] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៤១។

សហចារី នៅក្នុងផែនការរួម ដែល "សំខាន់" ឬ *មិនអាចខ្វះបាន* (sine qua non) សម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្ម[321]។

១២២. ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ ក៏រំលោភបំពានផងដែរលើគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* (nullem crimen sine lege) ។ សហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ មិនមានចែងនៅក្នុងច្បាប់ ស្តីពីការបង្កើត អ.វ.ត.ក. ដែលកំណត់ពីយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ។ អង្គបុរេជំនុំជម្រះមានកំហុសឆ្គង នៅពេលដែលសម្រេចថា អ្នកព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. អាចមានបំណងប្រើប្រាស់ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ដោយសារតែច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានរៀបរៀងដោយមានពាក្យពេចន៍ប្រហាក់ប្រហែលនឹងលក្ខន្តិកៈរបស់សាលាក្តី ICTY ហើយអ្នកព្រាងច្បាប់បានដឹងថា ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ត្រូវបានចាត់ទុកជាទម្រង់មួយនៃ "ការប្រព្រឹត្ត" នៅតុលាការ *ចំពោះកិច្ច* (ad hoc)[322]។ មានតែអង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *Tadić* តែមួយប៉ុណ្ណោះ ដែលបានអនុវត្តសហឧក្រិដ្ឋកម្មរួម នៅមុនពេលអនុម័តច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. នៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០១[323]។ បន្ទាប់ពីសាលដីកាក្នុងរឿង

---

[321] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សំណុំរឿងលេខ ICTR-2001-64-A សាលក្រម មតិដាច់ដោយឡែករបស់ចៅក្រម Shahabuddeen ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៥០៖ "ការចូលរួមរបស់ជនជាប់ចោទក្នុងសហឧក្រិដ្ឋកម្មរួមមួយមិនមែនជា *លក្ខខណ្ឌសំខាន់* (sine qua non) នៃការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ។ តាមការពិត ការចូលរួម *មិនចាំបាច់ត្រូវតែជាធំដុំ* ដូចក្នុងករណីនៃការជួយ និង ជម្រុញនោះទេ។ ផ្ទុយមកវិញ ក្រោមទ្រឹស្តីនៃសហចារីកម្ម ការចូលរួមចំណែករបស់ចារីចំនងជា *លក្ខខណ្ឌសំខាន់* (sine qua non) ដោយសារថាការខកខានរបស់ចារីមិនបានបំពេញការចូលរួមចំណែក ដែលខ្លួនបានសន្យានោះនឹង "បំផ្លាញ" សមិទ្ធផលនៃក្រុម ដូចបានគិតទុក"។ *សូមមើល ផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-803-tEN សេចក្តីសម្រេចលើការបញ្ជាក់បទចោទប្រកាន់ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៤២៖ "ទស្សនទាននៃសហចារីដោយផ្អែកលើការគ្រប់គ្រងរួមលើឧក្រិដ្ឋកម្ម គឺមានឫសគល់នៅក្នុងគោលការណ៍នៃការបែងចែកកិច្ចការសំខាន់ៗ សម្រាប់គោលបំណងនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម រវាងបុគ្គលពីរនាក់ ឬ ច្រើននាក់ ដែលធ្វើសកម្មភាពដោយព្រមព្រៀងគ្នា។ ដូច្នេះ ទោះបីជាមិនមានអ្នកចូលរួមណាម្នាក់គ្រប់គ្រងរួមលើឧក្រិដ្ឋកម្មក្តី ដោយសារតែពួកគេត្រូវពឹងផ្អែកគ្នាទៅវិញទៅមកក្នុងការប្រព្រឹត្ត ពួកគេទាំងអស់ចែកការគ្រប់គ្រងគ្នាទៅវិញទៅមក ដោយហេតុថា ពួកគេម្នាក់ៗ អាចរារាំងបង្អាក់ការប្រព្រឹត្តឧក្រិដ្ឋកម្ម បើខ្លួនមិនបានអនុវត្តភារកិច្ចរបស់ខ្លួននោះ"។

[322] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៤៩។

[323] *សូមមើល* គេហទំព័រ អ.វ.ត.ក. *ការបង្កើត អ.វ.ត.ក - កាលប្បវត្តិ* https://www.eccc.gov.kh/en/about-eccc/chronologies (ចូលមើលចុងក្រោយនៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨)។

ក្តី *Tadić* រួចហើយ សហឧក្រិដ្ឋកម្មរួមមិនត្រូវបានអនុវត្តឡើយ រហូតដល់សាលក្រមក្នុងរឿងក្តី *Krstić* នៅខែសីហា ឆ្នាំ ២០០១[324]។ ចំណុចនេះក៏ត្រូវបានពិភាក្សាផងដែរ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Brđanin និង Talić* ប៉ុន្តែជាថ្មីម្តងទៀតគឺមិនត្រូវបានអនុវត្តឡើយ រហូតដល់ពាក់កណ្តាលឆ្នាំ ២០០១ គឺហួសពេលទៅហើយសម្រាប់អ្នកព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ក្នុងការពិចារណាលើចំណុចនេះ នៅពេលធ្វើការសម្រេចលើពាក្យពេចន៍នៃមាត្រា ២៩ នោះ[325]។ មិនមាន "យុត្តិសាស្ត្រពីមុន និង ស៊ីចង្វាក់គ្នា" ស្តីពីសហឧក្រិដ្ឋកម្មរួមឡើយ នៅពេលដែលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានព្រាងនោះ ដែលផ្ទុយពីការសន្និដ្ឋានរបស់ អង្គបុរេជំនុំជម្រះ[326]។ ក្រៅពីការណ៍ដែលថា សហឧក្រិដ្ឋកម្មរួម មានលក្ខណៈចម្រុងចម្រាស់នៅពេល ចាប់ផ្តើមដំបូងរបស់ខ្លួន[327]

---

[324] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krstić* សំណុំរឿងលេខ IT-98-33-T សាលក្រម ចុះថ្ងៃទី ២ ខែសីហា ឆ្នាំ ២០០១ កថាខណ្ឌ ៦០១។

[325] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brđanin និង Talić* សំណុំរឿងលេខ IT-99-36-PT សេចក្តីសម្រេចលើទម្រង់នៃការធ្វើវិសោធនកម្មបន្ថែម និង ពាក្យសុំឱ្យមានការកាត់ទោស ដែលត្រូវបានធ្វើវិសោធនកម្ម ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០១។

[326] *រឿងក្តី ន្តន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៤៩។

[327] សហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវដែលចម្រុងចម្រាស់បំផុត នៅតុលាការអន្តរជាតិ*ចំពោះកិច្ច*។ ចាប់តាំងពីការបង្កើតមក បញ្ហានេះត្រូវបានរងការរិះគន់ធ្ងន់ធ្ងរ ជាពិសេសដោយសារត្រូវបានមើលឃើញថា វាត្រូវបានបង្កើតឡើងដោយចៅក្រម ហើយមិនឆ្លុះបញ្ចាំងពីច្បាប់ចំនៀមទម្លាប់អន្តរជាតិ។ *សូមមើល ឧទា.* Ciara Damgaard *ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម៖ "ទ្រឹស្តីដ៏ធំធេងនៃការទទួលខុសត្រូវ" ឬ ក៏ឧបករណ៍ស្របច្បាប់ និង អាចជឿជាក់បាន នៅក្នុងការកាត់ទោស ចារីនៃឧក្រិដ្ឋកម្មអន្តរជាតិសំខាន់ៗ? នៅក្នុង* ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះឧក្រិដ្ឋកម្មអន្តរជាតិសំខាន់ៗ ទំព័រ ១២៩ (Springer 2008)៖ "ទ្រឹស្តីនេះបង្ហាញការព្រួយបារម្ភធ្ងន់ធ្ងរមួយចំនួន។ ជាទូទ្បីករណ៍ នៅក្នុងចំណោមនោះ វាមានលក្ខណៈមិនច្បាស់លាស់ និង ធ្វើឱ្យថយចុះបទដ្ឋាននៃការបង្ហាញភស្តុតាង ធ្វើឱ្យទន់ខ្សោយដល់គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដើម្បីទទួលបានការទទួលខុសត្រូវរួម ដែលធ្វើឱ្យប៉ះពាល់ដល់គោលការណ៍មិនមានបទល្មើស បើគ្មានច្បាប់ចែង (the nullum crimen sine lege principle) និង ធ្វើឱ្យប៉ះពាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌"។ Mohamed Elewa Badar *"ត្រូវផ្តន្ទាទោសជនគ្រប់រូប" – ការប្រព្រឹត្តឧក្រិដ្ឋកម្មរួម៖ ពី* Tadić *ទៅ* Stakić *និងត្រលប់មកវិញ* វិវេចនាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លេខ ៦ ទំព័រ ២៣៩, ៣០១ (ឆ្នាំ ២០០៦)៖ "ប្រកពសំខាន់នៃការព្រួយបារម្ភពាក់ព័ន្ធនឹងការអនុវត្តទម្រង់ទី III នៃសហឧក្រិដ្ឋកម្មរួម នៅក្នុងដែននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺស្ថិតនៅក្រោមបទដ្ឋានសត្យានុម័ត និង អត្តនោម័ត អ្នកចូលរួមត្រូវទទួលខុសត្រូវដោយមិនត្រឹមត្រូវ ចំពោះឧក្រិដ្ឋកម្ម ដែលខ្លួនមិនមានចេតនាប្រព្រឹត្ត ឬមិនបានចូលរួម"។ William A. Schabas *ជាតុផ្សំអត្តនោម័ត្ត និង សាលក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី* វិវេចនាច្បាប់ NEW ENGLAND លេខ ៣៧ ទំព័រ ១០៣៣-១០៣៤ (ឆ្នាំ ២០០២)៖ "ដោយហេតុថា ពាក្យបច្ចេកទេសទាំងពីរនេះ (សហឧក្រិដ្ឋកម្មរួម និង ការទទួលខុសត្រូវរបស់ថ្នាក់លើ) ជួយសម្រួលឱ្យមានការផ្តន្ទាទោសឧក្រិដ្ឋជន

វាក៏អាចគួរឱ្យជឿជាក់បានដូចគ្នាដែលថា អ្នកព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មិនបានដឹងអំពីសហឧក្រិដ្ឋកម្មរួមឡើយ នៅពេលដែលព្រាងមាត្រា ២៩ ឬ ថាពួកគេបានដឹងអំពីសហឧក្រិដ្ឋកម្មរួម តែមានចេតនាមិនគិតពិចារណាលើចំណុចនេះ នៅក្នុងការព្រាងមាត្រា ២៩។ អង្គបុរេជំនុំជម្រះទាយស្មាន និង មិនបានគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន។

១២៣. មេធាវីការពារក្តីដាក់បញ្ចូលទឡ្ហីករណ៍ ដែលបានលើកឡើងក្នុងសារណាកន្លងមករបស់ខ្លួន[328]។

៤. អ.វ.ត.ក. មិនមានយុត្តាធិការ ដើម្បីជំនុំជម្រះអំពើរំលោភបំពានធ្ងន់ធ្ងរ

១២៤. អ.វ.ត.ក. មិនមានយុត្តាធិការដើម្បីជំនុំជម្រះ អំពើរំលោភបំពានធ្ងន់ធ្ងរឡើយ ដោយសារតែអាជ្ញាយុកាលរបស់ឧក្រិដ្ឋកម្មបែបនេះ បានកន្លងផុតហួសទៅហើយ។ អ.វ.ត.ក. ចាំបាច់ត្រូវតែអនុវត្តច្បាប់ ដូចដែលមានអត្ថិភាពនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលមានន័យថា អ.វ.ត.ក. ត្រូវតែអនុវត្តអាជ្ញាយុកាល ១០ ឆ្នាំ តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[329]។ រយៈពេល ១០ ឆ្នាំនេះ បានកន្លងផុតទៅហើយ នៅមុនពេលដែលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០១[330]។ ដោយមិនគិតថាតើអាជ្ញាយុកាលត្រូវបានលើកឬយ៉ាងណា ដោយសារតែស្ថានភាពនៅក្នុងប្រទេសកម្ពុជានៅក្រោយឆ្នាំ ១៩៧៩[331] នោះ រយៈពេលនៃអាជ្ញាយុកាលបានផុត

ជាលក្ខណៈបុគ្គល ដែលអាចមើលឃើញថាបានចូលរួមក្នុងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ក៏ប៉ុន្តែ ជាលទ្ធផល ពាក្យបច្ចេកទេសទាំងពីរនេះនាំឱ្យការផ្តន្ទាទោសមានការថយចុះ ដែលធ្វើឱ្យទន់ខ្សោយមិនអាចជៀសរួចពីការណែនាំដ៏សារសំខាន់នៃសាលក្រមតុលាការ និង ដែលធ្វើឱ្យខូចខាតដល់កេរដំណែលប្រវត្តិសាស្ត្ររបស់តុលាការ"។

[328] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D174/1/1 កថាខណ្ឌ ៥៤-៦២។

[329] មាត្រា ២១ មាត្រា ៣២ មាត្រា ៣៣ មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។ ឧក្រិដ្ឋកម្មនៃអំពើរំលោភបំពានធ្ងន់ធ្ងរត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលអប្បបរិមា ៥ឆ្នាំ។ *សូមមើល* មាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[330] *សូមមើល* ព្រះរាជក្រមលេខ នស/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ សន/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០១។

[331] យោងតាមចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង អាជ្ញាយុកាលដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ត្រូវអស់សុពលភាពយ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៩៣។ ចំណែកចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងវិញ យល់ឃើញថា អាជ្ញាយុកាលមិនត្រូវបានអស់សុពលភាពទេ និង បានចាប់ផ្តើមរាប់ពីខែមករា ឆ្នាំ ១៩៧៩ មក។ *សូមមើល*

កំណត់ នៅមុនពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងរឿងក្តី ០០៣ ទៅទៀត។ តាមគោលការណ៍ *អនុវត្តច្បាប់ដែលមានទោសស្រាលជាងមុន* (lex mitior) អាជ្ញាយុកាលមិនអាចត្រូវបានលុបចោល ដោយប្រតិសកម្មឡើយ៖ "ត្រូវយកច្បាប់ដែលមានលក្ខណៈបន្ធូរបន្ថយជាងគេមកអនុវត្ត ប្រសិនបើមានការកែប្រែច្បាប់ នៅចន្លោះពេលប្រព្រឹត្តបទល្មើស និង ពេលជំនុំជម្រះក្តី"[332]។

១២៥. បុគ្គលដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តអំពើរំលោភបំពានធ្ងន់ធ្ងរ នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ត្រូវទទួលការជំនុំជម្រះតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ ជាការចាំបាច់ត្រូវអនុវត្តក្រម

រឿងក្តី កាំង ហ្គេកអ៊ាវ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចស្តីពីអញ្ជត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E187 កថាខណ្ឌ ២៥, កថាខណ្ឌ ៣៥។ *សូមមើលផងដែរ* កថាខណ្ឌ ២៨៦ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងរឿងក្តី ០០២។ *សូមមើលផងដែរ កថាខណ្ឌ* ១១២-១៤ *ខាងលើ* ទាក់ទងនឹងយុត្តាធិការ អ.វ.ត.ក. ចំពោះឧក្រិដ្ឋកម្មថ្នាក់ជាតិ។

[332] កថាខណ្ឌ ២១ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ ខណៈរដ្ឋជាច្រើនបានអនុម័តច្បាប់ដកហូតអាជ្ញាយុកាលចេញពីឧក្រិដ្ឋកម្មមួយចំនួន រដ្ឋទាំងនោះបានយកចិត្តទុកដាក់ ដោយមិនអនុវត្តច្បាប់បែបប្រតិសកម្មទាំងនេះឡើយ។ *សូមមើល ឧទា.* មាត្រា ១១២-២ កថាខណ្ឌ ៤ នៃក្រមព្រហ្មទណ្ឌបារាំង៖ "ចំណុចដូចតទៅនេះ ត្រូវអនុវត្តភ្លាមៗ ចំពោះការបង្ក្រាបបទល្មើសដែលត្រូវបានប្រព្រឹត្ត មុនការចូលជាធរមាន...។ ៥. ក្នុងករណីដែលចិរវេលានៃអាជ្ញាយុកាលមិនទាន់ផុតកំណត់ ច្បាប់ដែលអនុវត្តលើអាជ្ញាយុកាលនៃការកាត់ទោសជាសាធារណៈ និង អាជ្ញាយុកាលនៃការផ្តន្ទាទោស" (ការបកប្រែផ្លូវការ)។ រដ្ឋទាំងឡាយ ដូចជាអតីត អល្លឺម៉ង់ខាងលិច ហុងគ្រី និង ស្វីស យល់ឃើញថា ការកាត់ទោសដែលផ្អែកលើការពន្យាប្រតិសកម្ម ឬ ដកហូតអាជ្ញាយុកាលនៃបទល្មើស គឺមិនស្របនឹងរដ្ឋធម្មនុញ្ញនោះទេ នៅពេលអាជ្ញាយុកាលបានផុតរលត់។ *សូមមើល* Martin Clausnitzer *អាជ្ញាយុកាលនៃអំពើមនុស្សឃាត នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់* ច្បាប់ប្រៀបធៀប និង ច្បាប់អន្តរជាតិ ចេញផ្សាយរាល់ត្រីមាស លេខ ២៩ ទំព័រ ៤៧៣, ៤៧៨-៤៧៩ (ឆ្នាំ ១៩៨០)។ Paul R. Dubinsky *ច្បាប់សិទ្ធិមនុស្ស ទល់នឹងសុខដុមរមនីយកម្មនៃច្បាប់ឯកជន៖ ជម្លោះដែលនឹងកើតមាន* ទិន្នានុប្បវត្តិច្បាប់អន្តរជាតិ YALE លេខ ៣០ ទំព័រ ២១១, ២៩២-២៩៣ (ឆ្នាំ ២០០៥)។ RUTH A. KOK អាជ្ញាយុកាលនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ២៨៩, ៣៩៩-៤០១ (T.M.C. Asser Press ឆ្នាំ ២០០៧) ("KOK អាជ្ញាយុកាល")។ YASMIN Q. NAQVI ឧបសគ្គចំពោះការអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ ទំព័រ ១៩៨ (T.M.C. Asser Press ឆ្នាំ ២០១០)។ អង្គនីតិបញ្ញត្តិប្រទេសហ្វឡង់ និង ប្រទេសជប៉ុន បានលុបចោលអាជ្ញាយុកាលនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ប៉ុន្តែយកចិត្តទុកដាក់មិនអនុវត្តការចោទប្រកាន់បែបប្រតិសកម្ម ចំពោះឧក្រិដ្ឋកម្មដែលចិរវេលាត្រូវបានហាមឃាត់។ KOK អាជ្ញាយុកាល ទំព័រ ៣៩៩-៤០១។ Shinichi Kawaranda *ជប៉ុនលុបចោលអាជ្ញាយុកាលចំពោះអំពើមនុស្សឃាត និង ពន្យាអាជ្ញាយុកាលចំពោះបទល្មើសផ្សេងទៀត* ASAHI SHIMBUN ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១០។ តុលាការកំពូល ស.រ.អ. សម្រេចថា ច្បាប់របស់រដ្ឋកាលីហ្វ័រនីយ៉ា ដែលអនុញ្ញាតឱ្យមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មរំលោភបំពានខាងផ្លូវភេទទាក់ទងនឹងកុមារ ដែលចិរវេលានៃអាជ្ញាយុកាល ស្ថិតនៅក្រោមអាជ្ញាយុកាលពីមុន ត្រូវបានផុតកំណត់ គឺរំលោភជំពូកច្បាប់នៃរដ្ឋធម្មនុញ្ញ ស.រ.អ. *គោលការណ៍អប្រតិសកម្ម* (the Ex post Facto)។ *Stogner តទល់នឹង រដ្ឋកាលីហ្វ័រនីយ៉ា* លេខ ៥៣៩ ស.រ.អ. ទំព័រ ៦០៧, ៦០៩ (ឆ្នាំ ២០០៣)។

ព្រហ្មទណ្ឌឆ្នាំ ១៩៥៦ រួមទាំងអាជ្ញាយុកាលផងដែរ។ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី ០០២/០១ បានសន្និដ្ឋានដោយខុសឆ្គងថា មានតែបទប្បញ្ញត្តិទាំងឡាយណា នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ដែលត្រូវបានចែងនៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ប៉ុណ្ណោះ ទើបអាចអនុវត្តបាន[333]។ ខណៈដែល អ.វ.ត.ក. អាចមិនមានយុត្តាធិការលើការជំនុំជម្រះ ឧក្រិដ្ឋកម្ម បន្ថែមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[334] ការណ៍នេះមិនមែនមានន័យថា បទប្បញ្ញត្តិដទៃទៀតនៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ អាចត្រូវបានបំភ្លេចចោលនោះឡើយ។ ខណៈដែលមាត្រា ៤ និង មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា មិនមានការអនុវត្តអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មាត្រា ៦ មិនបានចែងថា អាជ្ញាយុកាលមិនអាចអនុវត្តបាន ចំពោះអំពើរំលោភបំពានធ្ងន់ធ្ងរឡើយ។

១២៦. មិនមានច្បាប់ជាតិ ច្បាប់ដែលផ្អែកលើសន្ធិសញ្ញាជាធរមាន ឬ ច្បាប់ទំនៀមទម្លាប់អន្តរជាតិណាមួយ ដែលបាននិរាករណ៍ ឬ ជំនួសអាជ្ញាយុកាលនេះឡើយ។ ប្រទេសកម្ពុជាមិនបានអនុម័តច្បាប់ណាមួយ ដែលអនុវត្តន៍នូវបទប្បញ្ញត្តិការរំលោភបំពានធ្ងន់ធ្ងរ នៃអនុសញ្ញាទីក្រុងហ្សឺណែវឡើយ[335]។ មានរដ្ឋជាសមាជិក អ.ស.ប. ចំនួនមិនដល់ពាក់កណ្តាលផង ដែលបានបោះឆ្នោតគាំទ្រ អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីការមិនអនុវត្តអាជ្ញាយុកាល ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[336]។ ត្រឹមឆ្នាំ ១៩៧៩ អនុសញ្ញានេះមានរដ្ឋជាសមាជិកតែចំនួន ២២ ប៉ុណ្ណោះ ហើយ

---

[333] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-0៩-2007-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើអញ្ជត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២0១៤ ឯកសារ E306/6 កថាខណ្ឌ ៨។

[334] មាត្រា ៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បានកម្រិតយុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការវិនិច្ឆ័យទោសលើបទមនុស្សឃាត ទារុណកម្ម និង ការវាយប្រហារលើសាសនា ដែលបានរំលោភបំពានក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

[335] *សូមមើល* ការសិក្សាដែលអគ្គលេខាធិការបានដាក់ជូនទៅ គណៈកម្មការសិទ្ធិមនុស្ស "បញ្ហានៃការដាក់ទណ្ឌកម្មលើឧក្រិដ្ឋជនសង្គ្រាម និង បុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ឯកសារ អ.ស.ប. លេខ E/CN.៤/៩0៦ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៦0 ចំពីរ ៥0 កថាខណ្ឌ ៦៩។

[336] អនុសញ្ញាស្តីពីភាពមិនអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២៣៩១ (XXIII) ឧបសម្ព័ន្ធ កំណត់ហេតុផ្លូវការរបស់មហាសន្និបាត អ.ស.ប. ឯកសារបន្ថែម (លេខ ១៨) ទំព័រ ៤0 ឯកសារ អ.ស.ប. លេខ A/៧២១៨ (ឆ្នាំ ១៩៦៨)។

បច្ចុប្បន្ននេះ មានសមាជិកត្រឹម ចំនួន ៥៥ ប៉ុណ្ណោះ[337]។ មិនមានរដ្ឋណាមួយបានផ្តល់សច្ចាប័ន ដល់អនុសញ្ញាអឺរ៉ុបស្តីពីការមិនអនុវត្តអាជ្ញាយុកាល ចំពោះឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិឡើយ នៅត្រឹមឆ្នាំ ១៩៧៩[338]។ នៅក្នុងឆ្នាំ ១៩៨៥ *តុលាការកំពូលរបស់បារាំង* (Cour de cassation) បានសម្រេចថា "មិនមានគោលការណ៍ច្បាប់ណា ដែលមានសិទ្ធិអំណាចធំជាង សិទ្ធិអំណាចរបស់ច្បាប់ប្រទេសបារាំង ដែលអនុញ្ញាតឱ្យឧក្រិដ្ឋកម្មសង្គ្រាម ... ត្រូវបានប្រកាសថា មិនស្ថិតក្រោមអាជ្ញាយុកាល"[339]។

១២៧. មិនមាន "ករណីយកិច្ចត្រូវជំនុំជម្រះ" ដាច់ខាត លើអំពើរំលោភបំពានធ្ងន់ធ្ងរ ដែលអាចយកឈ្នះ លើអាជ្ញាយុកាលឡើយ។ "គឺជា... ការងាយស្រួលជ្រុលពេក ក្នុងការអះអាងថា អាជ្ញាយុកាល គឺ មិនអាចអនុវត្តបានចំពោះអំពើរំលោភបំពានធ្ងន់ធ្ងរ ដោយផ្អែកលើពាក្យពេចន៍ដែលហាក់ដូចជាដាច់ ខាត នៃកាតព្វកិច្ចក្នុងការស្វែងរក និង ជំនុំជម្រះលើអំពើរំលោភបំពានធ្ងន់ធ្ងរ ដែលមានចែងនៅក្នុង អនុសញ្ញាទីក្រុងហ្សឺណែវ។ របបធ្វើ *បត្យាប័ន ឬ ជំនុំជម្រះ* (aut dedere aut iudicare) ដែលផ្អែក លើសន្ធិសញ្ញា គឺមិនអាចត្រូវបានបកស្រាយតាមបែបនេះឡើយ នៅក្នុងការអនុវត្តរបស់រដ្ឋ"[340]។ វាល់វិមតិសង្ស័យទាក់ទងនឹងអានុភាពប្រតិសកម្ម ចាំបាច់ត្រូវតែដោះស្រាយជាប្រយោជន៍ដល់ មាស មុត យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង គោលការណ៍ *វិមតិសង្ស័យនឹងបានជា ប្រយោជន៍ដល់ជនត្រូវចោទ* (in dubio pro reo)[341]។

---

[337] *សូមមើល* កម្រងសន្ធិសញ្ញា អ.ស.ប. អនុសញ្ញាស្តីពីភាពមិនអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋ កម្មប្រឆាំងមនុស្សជាតិ គេហទំព័រ https://treaties.un.org/Pages/ViewDetails.aspx?src=IND&mtdsg_no=IV-6&chapter=4&clang=_en (ចូលមើលចុងក្រោយនៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨)។

[338] *សូមមើល* ក្រុមប្រឹក្សាអឺរ៉ុប *តារាងនៃហត្ថលេខា និង ការផ្តល់សច្ចាប័នលើសន្ធិសញ្ញា ០៨២ នៅគេហទំព័រ* https://www.coe.int/en/web/ conventions/full-list/-/ conventions/treaty/082/signatures?p_auth=3ZEIY1PQ (ចូលមើលចុងក្រោយនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៨)។

[339] តុលាការកំពូល សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៨៥ ព្រឹត្តប័ត្រព្រហ្មទណ្ឌ លេខ ៤០៧៖ (unofficial translation of: "Aucun principe de droit ayant une autorité supérieure à celle de la loi française ne permet de déclarer imprescriptibles les crimes de guerre")។

[340] *សូមមើល* Claus Kreß *ការឆ្លុះបញ្ចាំងស្តីពីការថែរក្សាការកាត់ទោសចំពោះរបបគតិយុត្តិនៃអំពើរំលោភបំពានធ្ងន់ធ្ងរ* (Reflection on the Iudicare Limb of the Grave Breaches Regimes) វាជកិច្ច ឃុត្តធម៌ព្រហ្មទណ្ឌអន្តរជាតិ លេខ ៧ ទំព័រ ៧៨៩, ៨០៦ (ឆ្នាំ ២០០៩)។ *សូមមើលផងដែរ* ដូចខាងលើ ទំព័រ ៧៩០។

[341] កថាខណ្ឌ ២៦-៣០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

១២៨. មេធាវីការពារក្តីដាក់បញ្ចូលទឡ្ហីករណ៍ ដែលបានលើកឡើងក្នុងសារណាកន្លងមករបស់ខ្លួន[342]។

៥. អ.វ.ត.ក. មិនមានយុត្តាធិការក្នុងការជំនុំជម្រះលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ដទៃទៀត

១២៩. អ.វ.ត.ក. មិនមានយុត្តាធិការក្នុងការជំនុំជម្រះ លើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ដទៃទៀតឡើយ ដោយសារតែអំពើនេះ មិនត្រូវបានកំណត់និយមន័យច្បាស់លាស់គ្រប់គ្រាន់ នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយវាមិនមានលក្ខណៈ និង ស្ថានទម្ងន់ ប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឡើយ[343]។

១៣០. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ ឬ ត្រូវបានកំណត់និយមន័យ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលបង្កើតជាច្បាប់សង្គ្រាមនៅឆ្នាំ ១៩៧៥ ឬ លក្ខន្តិកៈនៃតុលាការ ឬ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិណាមួយឡើយ។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* គឺជាអង្គជំនុំជម្រះដំបូងគេ ដែលបានកំណត់និយមន័យការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយបានកំណត់និយមន័យនេះ

---

[342] ញត្តិរបស់ មាស មុត ប្រឆាំងនឹងការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ដោយសារការផុតរលត់អាជ្ញាយុកាលជាធរមាន ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D103/1.3។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D174/1/1 កថាខណ្ឌ ៨-៣០។ *រឿងក្តី ខួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សំណើរបស់មេធាវីការពារក្តីក្នុងសំណុំរឿង ០០៣ ស្នើដាក់សារណារបស់អ្នកដែលមិនមែនជាភាគី និង សារណារបស់អ្នកមិនមែនជាភាគី ពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ E306/3។

[343] ទោះបីជាប្រភេទនៃអំពើអមនុស្សធម៌ដទៃទៀត មានអត្ថិភាពមុនឆ្នាំ ១៩៧៥ ក៏ដោយ ក៏ "អំពើអមនុស្សធម៌ដទៃទៀត" ដែលចោទជាបញ្ហា ត្រូវកំណត់និយមន័យឱ្យបានល្អគ្រប់គ្រាន់អំពីលក្ខណៈ និង ស្ថានទំងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែង ឬ គោលការណ៍នីតិានុកូលភាពនឹងត្រូវបានរំលោភបំពាន។ *រឿងក្តី អោ អាន និង ឃឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និង បង្កឱ្យមានផ្ទៃពោះដោយបង្ខំ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D301/5 កថាខណ្ឌ ៥១, កថាខណ្ឌ ៦៣។

"នៅក្នុងបរិបទនៃជម្លោះសេរ៉ាឡេអូន"[344] ដែលក្នុងនោះកងទ័ពបានចូលទៅក្នុងភូមិ ហើយចាប់ពង្រត់ស្ត្រី និង កុមារីដោយហិង្សា ហើយប្រកាសថាជា "ភរិយា" របស់ពួកគេ ដោយបង្ខំនារី និង កុមារីទាំងនោះ ឱ្យធ្វើជាដៃគូសហព័ទ្ធ ហើយចាត់ទុកពួកគេដូចជាទាសកររួចទៅ[345]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Taylor* បានពិចារណានាពេលបន្ទាប់មកថា ការកំណត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងបរិបទនេះគឺជា "ឈ្លោះមិនសមស្រប" ហើយបានសម្រេចថាទាសភាពផ្លូវភេទ ទើបបានសមបំផុត សម្រាប់អំពើនេះ[346]។

១៣១. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយផ្ទាល់ និង ដោយខ្លួនឯង គឺមិនមានលក្ខណៈ និង ស្ថានទម្ងន់ប្រហាក់ប្រហែល នឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.៖ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និង ការធ្វើទុក្ខបុកម្នេញផ្សេងៗ។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Brima និង អ្នកផ្សេងទៀត* បានផ្អែកលើភស្តុតាងដែលថា "ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវទទួលរងអំពើរំលោភសេពសន្ថវៈ និង អំពើហិង្សាផ្លូវភេទម្តងហើយម្តងទៀត ពលកម្មដោយបង្ខំ ការដាក់ទណ្ឌកម្មលើរូបរាងកាយ និង ការដកហូតសេរីភាព [ហើយត្រូវ]... បង្ខំឱ្យមើលការសម្លាប់ ឬ ការបង្ករបួសស្នាម សមាជិកគ្រួសារជិតស្និទ្ធដទៃទៀត" ដើម្បីសម្រេចថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺមានលក្ខណៈ និង ស្ថានទម្ងន់ ប្រហាក់ប្រហែលគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត[347]។ បើមិនមានលក្ខខណ្ឌបែបនេះទេ សកម្មភាពនៃការរៀបចំអាពាហ៍ពិពាហ៍ រវាងមនុស្សពេញវ័យពីរនាក់ នឹងមិនអាចបំពេញបាននូវកម្រិតធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ផ្សេងទៀតឡើយ។

---

[344] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-2004-16-A សាលក្រម ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៩៦។

[345] *ដូចខាងលើ* កថាខណ្ឌ ១៩០។

[346] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-T សាលក្រម ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៤២៥-២៨។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៤២៩៖ "ផ្នែកនៃការយល់ច្រលំ ដែកបង្កើតឱ្យមានការចោទប្រកាន់របស់អយ្យការ ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការបង្ហាញពីការចាប់បដិសន្ធិនៃឧក្រិដ្ឋកម្មថ្មីមួយ"។

[347] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brima និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-2004-16-A សាលក្រម ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៩៩។

១៣២. ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាអំពើអមនុស្សធម៌ផ្សេងទៀត គឺរំលោភបំពានលើគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* (nullem crimen sine lege)។ ជនត្រូវចោទ ឬជនជាប់ចោទ មិនអាចប្រមើលមើលដឹង ការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាបទល្មើសឡើយ នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ខណៈដែលលិខិតូបករណ៍សិទ្ធិមនុស្ស បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ នៅត្រឹមឆ្នាំ ១៩៧៥[348] គ្មានលិខិតូបករណ៍ណាមួយ ដែលបានហាមឃាត់ជាសាកលនូវ "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ដូចដែលបានហាមឃាត់ចំពោះការធ្វើទារុណកម្ម ឬ ទាសភាពឡើយ។ វាល់វិមតិសង្ស័យចំពោះភាពអាចប្រមើលមើលដឹងថាជាបទល្មើស និង ភាពអាចដឹងថាមានច្បាប់ចែងចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ចាំបាច់ត្រូវដោះស្រាយជាប្រយោជន៍ដល់ មាស មុត ស្របតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនត្រូវចោទ*[349]។

១៣៣. មេធាវីការពារក្តីដាក់បញ្ចូល តាមរយៈការយោង នូវទង្វើករណ៍ដែលបានលើកឡើងក្នុងសារណាកន្លងមករបស់ខ្លួន[350]។

៦. ការវាយប្រហារដោយរដ្ឋ ឬ អង្គការ ទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន មិនមែនជាការវាយប្រហារសំដៅប្រឆាំង "ប្រជាជនស៊ីវិល"

១៣៤. ការវាយប្រហារដោយរដ្ឋ ឬ អង្គការ ទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន មិនអាចបង្កើតបានជាការវាយប្រហារ សំដៅប្រឆាំង "ប្រជាជនស៊ីវិល" តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពី

---

[348] មាត្រា ១៦ នៃសេចក្តីប្រកាស UDHR។ មាត្រា ២៣(៣) នៃកតិកាសញ្ញា ICCPR។ មាត្រា ៨ មាត្រា១២ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។

[349] កថាខណ្ឌ ២៦-៣៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[350] ញត្តិរបស់ មាស មុត ជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D214។ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបនឹងញត្តិរបស់ មាស មុត ជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D214/1/1។

ការបង្កើត អ.វ.ត.ក. នោះទេ[351]។ ស.ច.ស.អ. បានសម្រេចដោយខុសឆ្គងថា ការវាយប្រហារដែលធ្វើឡើងដោយរដ្ឋ ឬ អង្គការ ទៅលើទាហានរបស់ខ្លួន បំពេញបានទ្វារលក្ខខណ្ឌ *ទូទៅ* (chapeau) របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការវាយប្រហារប្រឆាំង "ប្រជាជនស៊ីវិល"[352]។ និយមន័យនៃ "ប្រជាជនស៊ីវិល" ដែលរួមបញ្ចូលទាំងទាហាន គឺមិនត្រូវបានគាំទ្រដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយជនត្រូវចោទក៏មិនអាចប្រមើលមើលដឹងថាអំពើនោះជាបទល្មើស និង អាចដឹងថាមានច្បាប់ចែងអំពីបទល្មើសនោះដែរ។

១៣៥. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ តែងតែងញែកដាច់ពីគ្នារវាងទាហាន និង ជនស៊ីវិល ដោយតម្រូវថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែសំដៅប្រឆាំងប្រជាជន *ស៊ីវិល*[353]។ មិនមានការអនុវត្តរបស់រដ្ឋ ឬ *ទស្សនច្បាប់* ណាមួយ ដែលចង្អុលបង្ហាញថា ភាពខុសគ្នារវាងទាហាន និង ជនស៊ីវិល គឺពាក់ព័ន្ធតែជាមួយប្រជាជនរបស់សត្រូវនោះឡើយ។ យុត្តិសាស្ត្រចង្អុលបង្ហាញថា ការញែកចេញពីគ្នានេះ គឺពាក់ព័ន្ធនៅក្នុងពេលសន្តិភាព និង នៅពេលដែលវាយតម្លៃ លើការវាយប្រហារដោយរដ្ឋទៅលើទាហានរបស់ខ្លួន[354]។ មិនមានភាពមិនសមហេតុផល កើតឡើងដោយសារតែការអនុវត្ត

---

[351] សារណារបស់ មាស មុត ស្តីពីសំណួរថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬយ៉ាងណា ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/2។

[352] ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្នែកល់របស់របប ឬរដ្ឋនោះ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D191/18។

[353] គោលការណ៍នៃភាពខុសគ្នា ចែងថា ភាគីនៃជម្លោះ គ្រប់ពេលវេលាទាំងអស់ ត្រូវធ្វើការបែងចែករវាងជនស៊ីវិល និង ឃុទ្ធជន ការវាយប្រហារអាចធ្វើឡើងចំពោះតែឃុទ្ធជនប៉ុណ្ណោះ ហើយមិនត្រូវធ្វើចំពោះជនស៊ីវិលឡើយ។ គោលការណ៍នេះ ត្រូវបានទទួលស្គាល់ជាលើកដំបូង នៅក្នុងបុព្វកថានៃសេចក្តីប្រកាសឆ្នាំ ១៨៦៨ ស្តីពីការលុបចោលការប្រើប្រាស់អាវុធជាតិផ្ទុះមួយចំនួនក្នុងអំឡុងពេលសង្គ្រាម St. Petersburg ចុះថ្ងៃទី ២៩ ខែវិច្ឆិកា/ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៨៦៨។ បន្ទាប់មក គោលការណ៍នេះត្រូវបានចងក្រងជាច្បាប់នៅក្នុងពិធីសារបន្ថែម I និង II ទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និង សៀវភៅណែនាំយោធាជាតិជាច្រើនទៀត។ *សូមមើល* មាត្រា ៤៨, មាត្រា ៥១(២), មាត្រា៥២(២) នៃពិធីសារបន្ថែម I។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និង ពាក់ព័ន្ធការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធដែលមិនមែនអន្តរជាតិ ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ ទំព័រ ១១២៥ UNTS ៦០៩ ("ពិធីសារបន្ថែម II") មាត្រា ១៣(២)។ JEAN-MARIE HENCKAERTS & LOUISE DOSWALD-BECKS ច្បាប់មនុស្សធម៌ទំនៀមទម្លាប់អន្តរជាតិ ភាគ I ទំព័រ ៣-៦ (Cambridge ឆ្នាំ ២០០៥)។

[354] *សូមមើល ឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សំណុំរឿងលេខ ICTR-95-1-T សាលក្រមចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១២៧ ដែលអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR ក្នុងរឿងក្តី *Kayishema*

ភាពខុសគ្នានេះឡើយ។ អំពើរបស់របបមួយ ប្រឆាំងទៅនឹងទាហានរបស់ខ្លួន នៅក្នុងពេលសន្តិភាព នឹងត្រូវដោះស្រាយតាមច្បាប់ជាតិ ឬ អាស្រ័យទៅតាមកាល:ទេស: អាចត្រូវបានជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ ប្រសិនបើអ្នកមិនមែនជាជនស៊ីវិល (ដូចជា ទាហានសកម្ម ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ ឬ ទាហានត្រូវបានឃុំឃាំង) គឺជាគោលដៅនៃការវាយប្រហារ ដោយរដ្ឋរបស់ពួកគេផ្ទាល់ ពេលនោះការវាយប្រហារបែបនេះអាចជាការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ អំពើប្រល័យពូជសាសន៍ ឬ ច្បាប់ជាតិ

បានពិចារណាថា ទោះបីជាមាននិយមន័យទូលាយនៃជនស៊ីវិល ដែលអាចអនុវត្តបានក្នុងបរិបទមិនមានជម្លោះប្រដាប់អាវុធ "វាប់បញ្ចូលបុគ្គលគ្រប់រូប *លើកលែងតែ* ជនដែលមានកាតព្វកិច្ចរក្សាសណ្តាប់ធ្នាប់សាធារណៈ និង មានមធ្យោបាយស្របច្បាប់ដើម្បីប្រើប្រាស់កម្លាំង"។ (ការគូសបញ្ជាក់ក្នុងឯកសារដើម)។ ការបកស្រាយនៃជនស៊ីវិលនេះ ត្រូវបានយល់ស្របពីអ្នកវាយការណ៍ពិសេសលើប្រធានបទស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មហាសន្និបាត អ.ស.ប. របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ (ILC) *របាយការណ៍លើកទីមួយស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ឯកសារ អ.ស.ប. លេខ A/CN.៤/៦៨០ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៥ ជើងទំព័រ ២៧២។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kayishema* គឺស្របគ្នាជាមួយនឹងយុត្តិសាស្ត្រ*ចំពោះកិច្ច* ដែលមានតម្រូវការដូចគ្នាថា ប្រជាជនដែលត្រូវកំណត់ជាគោលដៅចាំបាច់ត្រូវតែមានលក្ខណៈជាជនស៊ីវិលភាគច្រើនលើសលុប បើទោះបីវត្តមានរបស់ជនមិនមែនជាស៊ីវិលមួយចំនួនក្នុងចំណោមពួកគេក៏ដោយ ក៏មិនបានប្តូរចរិកលក្ខណៈរបស់ប្រជាជនដែរ។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-T សាលក្រម ចុះថ្ងៃទី ៧ ខែឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៣៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez* សំណុំរឿងលេខ IT-95-14/2-A សាលក្រម ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៩៤-៩៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Galić* សំណុំរឿងលេខ IT-98-29-A សាលក្រម ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១២៩-៣០៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragomir Milošević* សំណុំរឿងលេខ IT-98-29/1-A សាលក្រម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៥០។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T សាលក្រម ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Fofana និង Kondewa* សំណុំរឿងលេខ SCSL-04-14-A សាលក្រម ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៥២៨។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Martić* សំណុំរឿងលេខ IT-95-11-A សាលក្រម ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៨ កថាខណ្ឌ ២៩១-៣១៤ ជាពិសេសកថាខណ្ឌ ៣០២, កថាខណ្ឌ ៣១១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-T សាលក្រម ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ៥០៨-១០។ យុត្តិសាស្ត្រ អ.វ.ត.ក. អនុវត្តតាមយុត្តិសាស្ត្ររបស់សាលាក្តី*ចំពោះកិច្ច*។ *សូមមើលផងដែរ* កថាខណ្ឌ ១៨៥ នៃសាលក្រមក្នុងរឿងក្តី ០០២/០១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។ កថាខណ្ឌ ៧៣៨ នៃសាលដីកាក្នុងរឿងក្តី ០០២/០១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

អាស្រ័យទៅតាមកាល:ទេស:[355]។ ការវាយប្រហារបែបនេះ នឹងមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

១៣៦. មេធាវីការពារក្តីដាក់បញ្ចូល តាមរយៈការយោង នូវទង្វើករណ៍ដែលបានលើកឡើងក្នុងសារណាកន្លងមករបស់ខ្លួន[356]។

---

[355] *សូមមើលឧទា. រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-T សាលក្រម ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៣ ភាគទី ៣ កថាខណ្ឌ ៦០៧-១១ កថាខណ្ឌ ៦៥៧-៤៨។ នៅក្នុងរឿងក្តី *Prlić និង អ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការអនុវត្តអំពើរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលកើតចេញមកពីការប្រព្រឹត្ត ទៅលើសមាជិកកាន់សាសនាឥស្លាមរបស់ក្រុមប្រឹក្សាការពារប្រទេសក្រូអាត ("HVO") - ស្ថាប័នយោធាផ្លូវការរបស់សហគមន៍ក្រូអាត Herzeg-Bosna - រួមមានទាំងទាហានក្រូអាត និង ទាហានកាន់សាសនាឥស្លាម- ដោយសមាជិកមិនកាន់សាសនាឥស្លាមរបស់ HVO។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សមាជិក HVO ដែលកាន់សាសនាឥស្លាម អាចចាត់ទុកថាជា "បុគ្គលដែលត្រូវទទួលបានការការពារ" ស្របតាមគោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវលើកទីបួន ដោយប្រើប្រាស់ភក្តីភាព ជាជាងសញ្ជាតិ ដើម្បីកំណត់ទៅលើឋានៈនៃទាហាន HVO ដែលកាន់សាសនាឥស្លាម។ នៅក្នុងការពង្រីកការការពារដល់ទាហានដែលស្ថិតនៅក្រោមរបបអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឋានៈនៃទាហានជាទាហានមិនបានកែប្រែនោះទេ ហើយនៅតែតម្រូវថា ប្រជាជនដែលត្រូវកំណត់ជាគោលដៅ ត្រូវតែជាជនស៊ីវិល តាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើលផងដែរ* JEAN-MARIE HENCKAERTS & LOUISE DOSWALD-BECKS ច្បាប់មនុស្សធម៌ទំនៀមទម្លាប់អន្តរជាតិ ភាគ I ទំព័រ ៣-៦ (Cambridge ឆ្នាំ ២០០៥) វិធាន ១៥៦។

[356] សារណារបស់ មាស មុត ស្តីពីសំណួរថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬយ៉ាងណា ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/2។ ចម្លើយរួមរបស់ មាស មុត តបនឹងសារណាររបស់ *អ្នកដែលមិនមែនជាភាគី* លើបញ្ហាដែលថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬយ៉ាងណា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D191/17។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីការបកស្រាយលើ "ការវាយប្រហារលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬ របបនោះ ចុះថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D191/18/1/4។ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីប្រជាជនស៊ីវិល ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១៧ ឯកសារ D191/18/1/7។

ឃ. គោលការណ៍ទូទៅនៃភស្តុតាង

១. គោលការណ៍គ្រប់គ្រង លើការវាយតម្លៃភស្តុតាង

១៣៧. ស.ច.ស. អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល បានកំណត់នូវគោលការណ៍គ្រប់គ្រងលើការវាយតម្លៃភស្តុតាង។ ស.ច.ស. ចាំបាច់ត្រូវអនុវត្តគោលការណ៍ទាំងនេះ នៅក្នុងការវាយតម្លៃទៅលើភស្តុតាង នៅក្នុងសំណុំរឿង ០០៣។

១៣៨. កំណត់ហេតុនៃការស្តាប់ចម្លើយ ដែល ក.ស.ច.ស. បានបង្កើតឡើងនៅក្នុងអំឡុងពេលស៊ើបអង្កេត ត្រូវទទួលបានសច្ចាធារណ៍នៃភាពពាក់ព័ន្ធ និង ភាពអាចជឿជាក់បាន[357]។ ប្រតិចារឹកសវនាការ នៃកិច្ចដំណើរការនីតិវិធីផ្សេងទៀតរបស់ អ.វ.ត.ក. ដែលត្រូវបានដាក់នៅក្នុងសំណុំរឿង ដោយសារតែភាពជាប់ពាក់ព័ន្ធរបស់ប្រតិចារឹកនោះ ទៅនឹងការចោទប្រកាន់ ត្រូវទទួលបានសច្ចធារណ៍ដូចគ្នា[358]។ ភស្តុតាងផ្សេងទៀត ដូចជា ភស្តុតាងដែលប្រមូលដោយបុគ្គល ឬ ស្តាប់ដែលមិនស្ថិតនៅក្នុង អ.វ.ត.ក. និង ដោយមិនមានការត្រួតពិនិត្យដោយតុលាការ កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ការសម្ភាសន៍របស់ ក.ស.ព. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង ភស្តុតាងចចាមអារ៉ាម តម្រូវឱ្យមានវិធីសាស្ត្រដែលប្រុងប្រយ័ត្នជាងនេះ ហើយអាចត្រូវបានពឹងផ្អែកតែនៅពេលដែលព័ត៌មានដែលមានក្នុងនោះ ត្រូវបានគាំទ្រដោយប្រភពដទៃផ្សេងទៀតប៉ុណ្ណោះ[359]។

១៣៩. ភស្តុតាងដែលប្រមូលដោយបុគ្គល ឬ ស្តាប់ដែលមិនស្ថិតនៅក្នុង អ.វ.ត.ក. និង ដោយមិនមានការត្រួតពិនិត្យដោយតុលាការ នឹងមិនទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធ និង ភាពអាចជឿជាក់បានឡើយ[360]។ ភស្តុតាងដែលមិនត្រូវបានប្រមូល ជាពិសេស សម្រាប់គោលដៅនៃការជំនុំជម្រះ

---

[357] កថាខណ្ឌ ១០៣ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១២ ឯកសារ E96/7 កថាខណ្ឌ ២៦។

[358] កថាខណ្ឌ ១០៤ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[359] *ដូចខាងលើ* កថាខណ្ឌ ១០៨។

[360] *ដូចខាងលើ* កថាខណ្ឌ ១០៤។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់

ព្រហ្មទណ្ឌ ដូចជា ព័ត៌មានដែលប្រមូលដោយអ្នកនិពន្ធ គឺមានតម្លៃជាភស្តុតាងទាប[361]។ *សូមមើល* ឧបសម្ព័ន្ធ ក។

១៤០. ខណៈដែលឯកសារសហសម័យ នៅរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានសច្ចធារណ៍មិនអាចបដិសេធបាន នៃភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន *ជាបឋម*[362] កំណត់ហេតុកិច្ចសម្ភាសន៍ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវតែទទួលបានការវាយតម្លៃដោយប្រុងប្រយ័ត្ន។ ការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មិនត្រូវបានធ្វើឡើង ដោយមានការត្រួតពិនិត្យដោយតុលាការ និង មិនធ្វើឡើងតាមទម្រង់ផ្លូវការ ដូចកំណត់ហេតុនៃការស្តាប់ចម្លើយ ដែលធ្វើឡើងដោយ ក.ស.ច.ស. ឡើយ[363]។ អ្នកសម្ភាសន៍មិនមែនជាអ្នកស៊ើបអង្កេត ដែលទទួលបានការបណ្តុះបណ្តាល សម្រាប់គោលដៅនៃការប្រមូលភស្តុតាង ដើម្បីប្រើប្រាស់ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ[364]។ អ្នកផ្តល់សម្ភាសន៍

ហេតុស្តាប់ចម្លើយសាក្សី និង ឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១២ ឯកសារ E96/7 កថាខណ្ឌ ២៩។

[361] កថាខណ្ឌ ២៩៦ នៃសាលដីកាក្នុងរឿងក្តី ០០២/០១៖ "លើកលែងតែកំណត់ហេតុស្តាប់ចម្លើយ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ជាគោលការណ៍ តម្លៃជាភស្តុតាងទាបត្រូវផ្តល់ចំពោះភស្តុតាងដែលពុំត្រូវបានប្រមូលជាក់លាក់សម្រាប់គោលបំណងនៃការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ ដូចជាក្នុងករណីនៃការរៀបរាប់ ដែលប្រមូលដោយ Henri LOCARD François PONCHAUD និង Stephen HEDER"។

[362] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ E185 ("សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារក្នុងរឿងក្តី ០០២") កថាខណ្ឌ ២៨។ *សូមមើលផងដែរ* កថាខណ្ឌ ៣៧៣ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។

[363] កថាខណ្ឌ ១០៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ កថាខណ្ឌ ២៨ នៃសេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារក្នុងរឿងក្តី ០០២ ។ កថាខណ្ឌ ៣៧៣ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។

[364] *សូមមើល រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹកចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១២ ឯកសារ E1/32.1 ម៉ោង 10:04:49-10:08:35៖ "អ៖ ទាក់ទងទៅនឹងការសម្ភាស យើងមានជាកម្រងសំណួរដើម្បីសួរទៅអ្នកកផ្តល់សម្ភាស ហើយកម្រងសំណួរនេះ ត្រូវបានពិនិត្យដោយទីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកម្រងសំណួរនេះក៏ត្រូវបានផ្តល់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ គឺជាពិសេស គឺដល់អង្គភាពការិយាល័យសហចៅក្រមស៊ើបអង្កេត។ ស៖ តើរបៀបដែលធ្វើនេះគឺវាដូចគ្នាទៅនឹងនៅពេលដែលលោកទទួលបានការបណ្តុះបណ្តាលដែរឬទេ? អ៖ ការចងក្រងឯកសារ ដែលយើងបណ្តុះបណ្តាល -- ទទួលបានការបណ្តុះបណ្តាលនេះគឺវាទាក់ទងទៅនឹងការរៀបចំចងក្រងឯកសារ។ ឯរឿងធ្វើការ ធ្វើសម្ភាស គឺជារឿងមួយដាច់ដោយឡែកផ្សេងទៀត"។

មិនបានផ្តល់ចម្លើយ ដោយមានការស្បថនោះឡើយ ហើយពួកគេក៏មិនប្រឈមនឹងការដាក់ទណ្ឌកម្ម ចំពោះការផ្តល់ចម្លើយមិនពិតនោះដែរ[365]។ *សូមមើល* ឧបសម្ព័ន្ធ ខ។

១៤១. ការស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងការស៊ើបអង្កេតបឋម ក៏ចាំបាច់ត្រូវតែប្រើប្រាស់ដោយមានការប្រុងប្រយ័ត្ន ទោះបីជាការស្តាប់ចម្លើយបែបនេះ ទទួលបានតម្លៃជាភស្តុតាងខ្ពស់ជាង ភស្តុតាងដែលត្រូវបានប្រមូល មិនមែនក្នុងគោលបំណងសម្រាប់ការជំនុំជម្រះព្រហ្មទណ្ឌក្តី (ដូចជាភស្តុតាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)[366]។ ការស្តាប់ចម្លើយទាំងនេះ “មិនត្រូវបានធ្វើឡើង ដោយមានការស្បថនោះឡើយ ហើយត្រូវបានរៀបចំឡើងដោយភាគី ដែលមានផលប្រយោជន៍នៅក្នុងសំណុំរឿង”[367]។ *សូមមើល* ឧបសម្ព័ន្ធ គ។

១៤២. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង ពាក្យបណ្តឹងរបស់ជនរងគ្រោះ មិនទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បានឡើយ ហើយ “ទទួលបានតម្លៃជាភស្តុតាងទាប ប្រសិនបើកាលៈទេសៈនៃការកត់ត្រាពាក្យទាំងនោះមិនមានភាពច្បាស់លាស់”[368]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង ពាក្យបណ្តឹងរបស់ជនរងគ្រោះ ដែលផ្តល់តែការសន្និដ្ឋានទូទៅ ឬ “ការរៀបរាប់ទូទៅ” ប៉ុណ្ណោះដែលខុសពីបទពិសោធន៍ផ្ទាល់ខ្លួន គឺមិនគ្រប់គ្រាន់ សម្រាប់កំណត់ពីអង្គហេតុពាក់ព័ន្ធ[369]។ ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្រៅតុលាការ ទទួលបានតម្លៃជាភស្តុតាងទាប[370]។ នៅក្នុងសវនាការ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងតុលាការ ត្រូវទទួលបានការវាយតម្លៃដោយប្រុងប្រយ័ត្ន[371]។ ដូចគ្នានឹងសហព្រះរាជអាជ្ញាដែរ ដើមបណ្តឹងរដ្ឋប្បវេណី

---

[365] *សូមមើល ខទ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/214 ទ.៦៖ “កាលនោះ អ្នកមកសម្ភាសនោះ មិនប្រាប់ខ្ញុំថាមកសម្ភាសទេ ថាមកសំណេះសំណាលលេង។ គាត់ថាមកសំណេះសំណាលលេងជាមួយខ្ញុំ បើជាកិច្ចសម្ភាសន៍ គឺល្អិតល្អន់បែបនេះ។ ដោយសារវាជាការសំណេះសំណាលលេង ដូច្នេះខ្ញុំប្រាប់គាត់ខ្លះពិត ខ្លះមិនពិត”។

[366] កថាខណ្ឌ ១០៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[367] *ដូចខាងលើ* កថាខណ្ឌ ១០៥។

[368] *ដូចខាងលើ* កថាខណ្ឌ ១០៧។ កថាខណ្ឌ ២៩៦ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។

[369] កថាខណ្ឌ ១០៧ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ កថាខណ្ឌ ៤៥៧ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។

[370] កថាខណ្ឌ ១០៧ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ កថាខណ្ឌ ៥៥០ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។

[371] កថាខណ្ឌ ៣១៥ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើកត្តាដែលមានលក្ខណៈពិសេសដាច់ដោយឡែកចំពោះភាគីដើមបណ្តឹងរដ្ឋប្បវេណី (ដើមបណ្តឹងរដ្ឋប្បវេណីពុំបានធ្វើសម្បថ ផលប្រយោជន៍ចម្បងរបស់ពួកគេ គឺដើម្បីទាមទារសំណង និង កង្វះការដាក់ទណ្ឌកម្មចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយ និង លទ្ធភាពក្នុងការពិគ្រោះពិភាក្សា

គឺជាភាគីនៃកិច្ចដំណើរការនីតិវិធី ដែលមានផលប្រយោជន៍ជាក់ស្តែង នៅក្នុងលទ្ធផលនៃរឿងក្តី[372]។ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីមិនមែនជាសាក្សី ដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្បថឡើយ ហើយជាលទ្ធផល ពួកគេមិនប្រឈមនឹងការដាក់ទណ្ឌកម្មទេ ក្នុងករណីផ្តល់សក្ខីកម្មក្លែងក្លាយ[373]។ *សូមមើល* ឧបសម្ព័ន្ធ ឃ។

១៤៣. ការសម្ភាសន៍ជនត្រូវចោទដែលធ្វើឡើងដោយបុគ្គល ឬ ស្ថាប័នដែលមិនស្ថិតនៅក្នុង អ.វ.ត.ក. គឺរៀបចំឡើង ដោយមិនស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ឬ មិនស្ថិតក្រោមការធានាផ្នែកនីតិវិធី និង ច្បាប់ឡើយ[374]។ ការសម្ភាសន៍បែបនេះទទួលបានតម្លៃទាបជាង ធៀបទៅនឹងភស្តុតាងដែលប្រមូលដោយ ក.ស.ច.ស. ក្នុងពេលដំណើរការកិច្ចស៊ើបសួរ ហើយភាពអាចជឿជាក់បាន និង តម្លៃជាភស្តុតាងរបស់កិច្ចសម្ភាសន៍ទាំងនេះ ចាំបាច់ត្រូវតែទទួលបានការវាយតម្លៃ ដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង[375]។ *សូមមើល* ឧបសម្ព័ន្ធ ង។

១៤៤. ខណៈដែលភស្តុតាងចចាមអារ៉ាម អាចទទួលយកបាន ហើយ ស.ច.ស. មានឆន្ទានុសិទ្ធិ ក្នុងការពិចារណា និង ពឹងផ្អែកលើភស្តុតាងចចាមអារ៉ាម នៅពេលធ្វើការសម្រេចក្តី ចាំបាច់ត្រូវតែមានការប្រុងប្រយ័ត្ន[376]។ ភស្តុតាងចចាមអារ៉ាមគួរតែត្រូវបានពឹងផ្អែក តែក្នុងករណីដែលមានការគាំទ្រដោយប្រភពដែលអាចជឿជាក់បានប៉ុណ្ណោះ។ នៅដំណាក់កាលជំនុំជម្រះ ទម្ងន់ និង តម្លៃជាភស្តុតាង ដែលផ្តល់ឱ្យភស្តុតាងចចាមអារ៉ាម ជាទូទៅ គឺទាបជាងសាក្សីដែលផ្តល់ភស្តុតាង ដោយ

ជាមួយនឹងមេធាវីពីដំណើរការនីតិវិធី) គឺជាកត្តាដែលត្រូវបានយកមកពិចារណា នៅពេលធ្វើការវាយតម្លៃលើតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ។

[372] វិធាន ២៣(១) នៃវិធានផ្ទៃក្នុង ចែងថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺផ្តល់ការគាំទ្រដល់ការចោទប្រកាន់ និង ទាមទារសំណងការខូចខាតដែលខ្លួនបានទទួលរង។ *សូមមើលផងដែរ* កថាខណ្ឌ ៣១៤ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។

[373] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង។ កថាខណ្ឌ ៣១៤-១៥ នៃសាលដីកាក្នុងរឿងក្តី ០០២/០១។ *សូមមើល ឧទា. រឿងក្តី ខួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ E1/465.1 ម៉ោង 09:14:53-09:23:49 (ដើមបណ្តឹងរដ្ឋប្បវេណីពុំបានធ្វើសម្បថ មុននឹងផ្តល់សក្ខីកម្មទេ)។

[374] *សូមមើល* កថាខណ្ឌ ១០៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៥/១។

[375] *ដូចខាងលើ* កថាខណ្ឌ ១៣៩។

[376] កថាខណ្ឌ ៣០២ នៃសាលដីកាក្នុងរឿងក្តី ០០២/០១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

មានសម្បថ ហើយដែលត្រូវបានសួរដេញដោល[377]។ ក្នុងការវាយតម្លៃទៅលើទម្ងន់ ឬ តម្លៃជាភស្តុតាងនៃភស្តុតាងចចាមអារ៉ាមនោះ ជាការចាំបាច់ត្រូវពិចារណាទៅលើប្រភពនៃការដឹងឮរបស់សាក្សី ភាពលម្អៀង មូលហេតុជំរុញ លក្ខណៈច្បាស់លាស់នៃព័ត៌មានរបស់សាក្សី និង ថាតើភស្តុតាងផ្សេងទៀតបានគាំទ្រចំពោះភស្តុតាងចចាមអារ៉ាមនេះឬយ៉ាងណា[378]។ នៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ក.ស.ច.ស. ជាអ្នកដែលទទួលខុសត្រូវលើការស្តាប់ចម្លើយសាក្សី[379]។ មេធាវីការពារក្តីមិនមានឱកាស ដើម្បីសួរដេញដោលសាក្សីទេ ដូច្នេះហើយចាំបាច់ណាស់ ដែលត្រូវពឹងផ្អែកលើអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស. ដើម្បីទាញចេញនូវប្រភពនៃការដឹងឮរបស់សាក្សី។ *សូមមើល* ឧបសម្ព័ន្ធ ច។

១៤៥. ដោយមិនគិតអំពីប្រភព រាល់ភស្តុតាងទាំងអស់ គួរតែត្រូវបានពឹងផ្អែក តែនៅពេលដែលព័ត៌មាននៅក្នុងភស្តុតាងនោះ ត្រូវបានគាំទ្រដោយប្រភពផ្សេងទៀតប៉ុណ្ណោះ។ *សូមមើល* ឧបសម្ព័ន្ធ ឆ។

២. ភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម ឬ ភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម គឺមិនអាចពឹងផ្អែកបាន

១៤៦. ស.ព.អ. ពឹងផ្អែកលើភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម ឬ ភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម ក្នុងលក្ខណៈដែលត្រូវបានហាមឃាត់ដោយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[380]។ យោងតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្ម អាចត្រូវបានប្រើប្រាស់ *សម្រាប់តែ* ប្រឆាំងអ្នកធ្វើទារុណកម្មដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះ ដើម្បីជាភស្តុតាងថា ចម្លើយ

---

[377] *ដូចខាងលើ* ដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kalimanzira* សំណុំរឿងលេខ ICTR-05-88-A សាលក្រម ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១០ កថាខណ្ឌ ៩៦ ដែលដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karera* សំណុំរឿងលេខ ICTR-01-74-A សាលក្រម ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។

[378] កថាខណ្ឌ ៣៥ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karera* សំណុំរឿងលេខ ICTR-01-74-A សាលក្រម ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។

[379] ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តីអាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី អែម សុន បានដែរឬអត់ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D173/1 កថាខណ្ឌ ៩៖ "វិធានផ្ទៃក្នុង ៥៥(១០) ចែងអំពីតួនាទីរបស់ជនត្រូវចោទ ដែលអាចអនុញ្ញាតឱ្យមាននៅក្នុងការបំពេញកិច្ចស៊ើបសួរ គឺកម្រិតនៅត្រឹមស្មើ ស.ច.ស. សុំបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ"។

[380] *សូមមើល* ឧបសម្ព័ន្ធ ជ។

សារភាពត្រូវបានធ្វើឡើងតាមរយៈការធ្វើទារុណកម្ម[381]។ កម្មវត្ថុ និង គោលបំណងនៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម តម្រូវឱ្យមានការដកចេញយ៉ាងទូលំទូលាយ នូវ ព័ត៌មានណាមួយដែលបានមកពីការធ្វើទារុណកម្ម ហើយចំពោះករណីលើកលែងនៃវិធាននេះ តាម ខ្លឹមសារ ត្រូវបកស្រាយក្នុងន័យចង្អៀត"[382]។ ការបកស្រាយណាមួយទៅលើមាត្រា ១៥ ដែលធ្វើ ឱ្យធ្លាក់ចុះការហាមឃាត់និង ការរារាំង ចំពោះការធ្វើទារុណកម្ម ចាំបាច់ត្រូវតែបដិសេធចោល[383]។

ក. កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលកើតចេញពីចម្លើយសារភាពទទួលបាន ដោយការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ឬ ទទួលបានដោយការប្រើប្រាស់ ប្រវត្តិរូបដែលទទួលបាន ដោយការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ធ្វើជាតម្រុយនៃ កិច្ចស៊ើបអង្កេត គឺមិនអាចយកមកធ្វើជាមូលដ្ឋាន

១៤៧. មិនត្រូវពឹងផ្អែកលើកំណត់ហេតុនៃការស្តាប់ចម្លើយ ដែលកើតចេញពីចម្លើយសារភាពទទួលបាន ដោយការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ឡើយ[384]។ ចម្លើយសារភាពនៅមន្ទីរ ស-២១ ត្រូវបាន សន្មតថាទទួលបានដោយការធ្វើទារុណកម្ម[385]។ ចម្លើយសារភាពទាំងនេះមិនអាចជាមូលដ្ឋាន ឬ បញ្ជាក់ឱ្យឃើញការពិតនៃខ្លឹមសាររបស់ចម្លើយសារភាពទាំងនោះ ឬ ប្រើប្រាស់ដើម្បីស្តីរដេញ ដោលសាក្សីឡើយ[386]។ មិនអាចមានការគេចចេញពីការដាក់កំហិតរបស់អនុសញ្ញាប្រឆាំងនឹងការ ធ្វើទារុណកម្ម តាមរយៈការប្រើប្រាស់សេចក្តីសង្ខេបនៃចម្លើយសារភាពនៅមន្ទីរ ស-២១ ដើម្បី

---

[381] មហាសន្និបាត អ.ស.ប. អនុសញ្ញាប្រឆាំងទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ និង បន្តោកបន្ទាប ឯកសារ ១៤៦៥ UNTS ៨៥ ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨៤ ("អនុសញ្ញាCAT") មាត្រា ១៥។

[382] *រឿងក្តី ន្ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសេចក្តី ជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ F26/12 ("សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូលលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារក្នុងរឿងក្តី ០០២/០១") កថាខណ្ឌ ៦៧។

[383] *ដូចខាងលើ* កថាខណ្ឌ ៥០។

[384] ពាក្យសុំរបស់មាស មុត សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D257/1/3។ *សូមមើលផងដែរ* កថាខណ្ឌ ១១២ នៃ ដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[385] សេចក្តីសម្រេចរួមលើសំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងការប្រើប្រាស់ជាសក្តានុពលនៃភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D251 កថាខណ្ឌ ២៧។

[386] ដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១ កថាខណ្ឌ ១០៩ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

សាកសួរសាក្សី ជំនួសឱ្យការប្រើចម្លើយសារភាពពិតប្រាកដនោះឡើយ[387]។ ការហាមឃាត់របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ទៅលើការប្រើប្រាស់ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម គឺគ្រប់ដណ្តប់ទៅលើ *"ព័ត៌មានណាមួយបានមកពីបុគ្គល ដែលទទួលរងការធ្វើទារុណកម្ម"*[388]។ ស.ច.ស. បានទទួលស្គាល់ការហាមឃាត់ទៅលើភស្តុតាង ដែលទទួលបានពីភស្តុតាងបានមកពីការធ្វើទារុណកម្ម នៅក្នុងរឿងក្តី ០០៤/១ នៅពេលដែលពួកគាត់មិនបានពិចារណា ទៅលើចម្លើយរបស់សាក្សី និង កំណត់សម្គាល់របស់អ្នកស៊ើបអង្កេត ដែលផ្អែកលើអង្គការលេខដែលមានឈ្មោះមនុស្ស យកចេញពីចម្លើយសារភាពនៅមន្ទីរ ស-២១[389]។

១៤៨. ក៏មិនត្រូវពឹងផ្អែកលើកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបាន ដោយប្រើប្រាស់ប្រវត្តិរូបនៅមន្ទីរ ស-២១ ដែលទទួលបានដោយការធ្វើទារុណកម្ម ធ្វើជាតម្រុយស៊ើបអង្កេតនោះដែរ[390]។ ការប្រើប្រាស់ប្រវត្តិរូបនៅមន្ទីរ ស-២១ ធ្វើជាតម្រុយស៊ើបអង្កេត គឺស្មើនឹងប្រើប្រាស់ប្រវត្តិរូបនេះធ្វើជា "ភស្តុតាង"[391]។ ការពឹងផ្អែកលើប្រវត្តិរូបនៅមន្ទីរ ស-២១ ធ្វើជាតម្រុយភស្តុតាង គឺផ្ទុយគ្នាទៅនឹងហេតុផលគោលនយោបាយ នៅពីក្រោយវិធានបដិសេធភស្តុតាងរបស់អនុសញ្ញាប្រឆាំងនឹងការ

---

[387] ពាក្យសុំរបស់មាស មុត សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D257/1/3 កថាខណ្ឌ ២១។ *សូមមើលផងដែរ* ពាក្យសុំរបស់ មាស មុត សុំឱ្យមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171 ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D253/1/3 កថាខណ្ឌ ១៨ កថាខណ្ឌ ៣០។

[388] កថាខណ្ឌ ៤២ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារក្នុងរឿងក្តី ០០២/០១ (ការគូសបញ្ជាក់បន្ថែម)។ *សូមមើល ផងដែរ* ពាក្យសុំរបស់ មាស មុត សុំឱ្យមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171 ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D253/1/3 កថាខណ្ឌ ១៨ កថាខណ្ឌ ៣០។

[389] កថាខណ្ឌ ១១២ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[390] ពាក្យសុំរបស់ មាស មុត សុំឱ្យមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171 ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D253/1/3។

[391] ភស្តុតាងមិនមែនគ្រាន់តែជាអ្វីមួយដែលត្រូវបានប្រើក្នុងការជំនុំជម្រះ ដើម្បីបង្ហាញភស្តុតាងថាជនជាប់ចោទមាន ឬ មិនមានពិរុទ្ធភាពនោះទេ។ វាអាចជាចំណងភ្ជាប់នៃខ្សែចង្វាក់ព័ត៌មានដែលប៉ុនប៉ងបញ្ជាក់ ឬ បដិសេធអង្គហេតុណាមួយ និង រាប់បញ្ចូលទាំងព័ត៌មានដែលចាំបាច់ក្នុងការបង្កើតជាមូលដ្ឋាននៃភស្តុតាង។ EDWARD J. IMWINKELREID មូលដ្ឋាននៃភស្តុតាង §1.02 (LexisNexis ការបោះពុម្ពផ្សាយលើកទី ៩ ឆ្នាំ ២០១៥)៖ "វិធាននីតិវិធីដែលសំខាន់បំផុត គឺថា អ្នកផ្តល់វត្ថុអ្វីមួយដែលជាភស្តុតាង ជាទូទៅ ត្រូវតែផ្តល់មូលដ្ឋាន មុនពេលផ្តល់វត្ថុនោះជាភស្តុតាងជាផ្លូវការ។ ឧទាហរណ៍ អ្នកផ្តល់លិខិតធ្វើជាភស្តុតាង ត្រូវតែបង្ហាញភស្តុតាងពីយថាភាពរបស់សំបុត្រនោះ មុននឹងផ្តល់លិខិតនោះធ្វើជាភស្តុតាង។ ភស្តុតាងយថាភាពរបស់លិខិតគឺជាផ្នែកមួយនៃ "មូលដ្ឋាន" ឬ "បុព្វហេតុ""។

ធ្វើទារុណកម្ម៖ មិនជំរុញឱ្យមានការធ្វើទារុណកម្ម រក្សានូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និង ការពារសិទ្ធិរបស់ជនជាប់ចោទ ឬ ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយ យុត្តិធម៌[392]។

១៤៩. នៅពេលបដិសេធសំណើរបស់ មាស មុត សុំមោយភាពឯកសារ D114/164, D114/167, D114/170 និង ឯកសារ D114/171[393] អង្គបុរេជំនុំជម្រះមានកំហុសឆ្គងក្នុងការសម្រេចថា តម្រុយស៊ើបអង្កេត គឺមិនត្រូវបានរាប់បញ្ចូលនៅក្នុងអត្ថន័យទូទៅនៃពាក្យ "ភស្តុតាង" ឡើយ។ អង្គបុរេជំនុំជម្រះបានពឹងផ្អែកដោយខុសឆ្គង ទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ ដែលថា ភស្តុតាងដែលទាញចេញ មិនស្ថិតនៅក្នុងវិធានបដិសេធភស្តុតាងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មឡើយ[394] ដោយអង្គជំនុំជម្រះសាលាដំបូង បកស្រាយខុសនូវអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម និង អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម[395] ហើយបែរជាមានន័យថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មានលក្ខខណ្ឌតម្រូវចំណាងទាក់ទងតឹងតែង[396]។

១៥០. ផ្ទុយពីការសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រុយស៊ើបអង្កេត គឺជា "ភស្តុតាង"[397]។ តម្រុយស៊ើបអង្កេត គឺចាំបាច់សម្រាប់កំណត់ប្រភពដើមនៃភស្តុតាងដែលទទួលបាន ដោយសារតម្រុយនោះ។ តម្រុយស៊ើបអង្កេត គឺជាការសំអាង ព្រមទាំងជាផ្នែក និង ចំណែករួមក្នុងកញ្ចប់តែមួយជាមួយភស្តុតាង ដែលបានដាក់ចូលទៅក្នុងសំណុំរឿង[398]។ ការប្រើប្រាស់ប្រវត្តិរូបនៅមន្ទីរ ស-២១ ដើម្បី

---

[392] *សូមមើល រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សំអាងហេតុសម្រាប់មតិជំទាស់ដោយផ្នែករបស់ចៅក្រម Fenz ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៦ ឯកសារ E350/8.1 កថាខណ្ឌ ២១។

[393] សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំធ្វើមោយភាពឯកសារ D114/164, D114/167, D114/170 និង D111/171 ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៧ ឯកសារ D253/1/8 ("សេចក្តីសម្រេចលើសំណើសុំមោយភាពភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម")។

[394] *ដូចខាងលើ* កថាខណ្ឌ ២៩-៣៣។ *សូមមើល* កថាខណ្ឌ ១៥១ *ខាងក្រោម* ។

[395] កថាខណ្ឌ ៣៦ នៃសេចក្តីសម្រេចលើសំណើសុំមោយភាពភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។ *សូមមើល* កថាខណ្ឌ ១៥២-៥៣ *ខាងក្រោម* ។

[396] កថាខណ្ឌ ៣៧ នៃសេចក្តីសម្រេចលើសំណើសុំមោយភាពភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។ *សូមមើល* កថាខណ្ឌ ១៥៤ *ខាងក្រោម* ។

[397] *សូមមើល* វចនានុក្រមច្បាប់ Black ទំព័រ ៦៣៥ (ការបោះពុម្ពផ្សាយលើកទី ៩ ឆ្នាំ ២០០៩)។

[398] *សូមមើល* ជើងទំព័រ ៣៩១ *ខាងលើ*។

ស្វែងរកសាច់ញាតិរបស់បុគ្គល ដែលត្រូវបានសម្លាប់នៅមន្ទីរ ស-២១ គឺជាការប្រើប្រាស់ឯកសារទាំងអស់នេះ ក្នុងតម្លៃជាភស្តុតាងរបស់វា។ ខណៈដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស. មិនបានប្រើប្រាស់ព័ត៌មានដូចជា ទីកន្លែងកំណើត ឬ ឈ្មោះសមាជិកគ្រួសារនៅក្នុងប្រវត្តិរូបនៅមន្ទីរ ស-២១ ដើម្បីបង្ហាញភស្តុតាងអំពីអង្គហេតុដែលរងការចោទប្រកាន់ កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលទទួលបានដោយសារតែកិច្ចរបស់អ្នកស៊ើបអង្កេតនេះ ត្រូវបាន ស.ព.អ. ពឹងផ្អែកដើម្បីគាំទ្រការចោទប្រកាន់របស់គាត់ប្រឆាំង មាស មុត[399]។

១៥១. អង្គបុរេជំនុំជម្រះ មិនគួរពឹងផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី ០០២/០២ ស្តីពីភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្មឡើយ[400]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ មានកំហុសឆ្គងក្នុងការសម្រេចថា មាត្រា ១៥ នៃវិធានបដិសេធភស្តុតាងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនគ្របដណ្តប់ទៅលើភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម[401]។ ការងារត្រៀមរៀបចំអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនបានគាំទ្រដល់ការសន្និដ្ឋានដែលថា មានចេតនាជាក់លាក់ក្នុងការដកចេញនូវភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម ពីអនុសញ្ញាប្រឆាំងនឹងការធ្វើ

---

[399] *សូមមើល* ជើងទំព័រ ៣៤៨៥ នៃដីកាសន្និដ្ឋានស្តាពរ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/164) ជើងទំព័រ ៣៤៧០, ៣៤៧២, ៣៤៧៦-៧៧, ៣៤៨៣, ៣៥៤៨ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ យ៉ា ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/167) ជើងទំព័រ ១៧៦, ៣៥៨, ២១២១, ២១២៤, ៣២៦៨, ៣៤៤៧, ៣៤៧៦, ៣១៨១, ៣៤៨៤, ៣៤៩២ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ ម៉ុន ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/170) ជើងទំព័រ ៣៤០៧, ៣៤៤៣, ៣៤៦៨, ៣៤៧៧, ៣៤៨៣, ៣៥៤៣ (ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/171)។

[400] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E350/8 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងរឿងក្តី ០០២/០២") កថាខណ្ឌ ៦៣-៧០។ *សូមមើលផងដែរ* ពាក្យសុំរបស់ មាស មុត សុំឱ្យមើលភាពឯកសារ D114/164, D114/167, D114/170 និង D114/171 ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D253/1/3 កថាខណ្ឌ ១៨-៣០។

[401] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងរឿងក្តី ០០២/០២ ទំព័រ ៣៣។

ទារុណកម្មឡើយ[402]។ ការណ៍ដែលពាក្យពេចន៍ពោលប្រាស្រ័យច្បាស់លាស់ អំពីភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម មិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងចុងក្រោយរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនបានចង្អុលបង្ហាញថាមាត្រា ១៥ មិនគ្របដណ្តប់ទៅលើភស្តុតាង ដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្មឡើយ[403]។ ពាក្យ "ធ្វើឡើងដោយសារការធ្វើទារុណកម្ម" គឺមានភាពបត់បែនគ្រប់គ្រាន់ ដើម្បីគ្របដណ្តប់ទៅលើភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម។ មិនមានភស្តុតាងបង្ហាញថា អ្នកព្រាងបានច្រានចោលយ៉ាងជាក់ច្បាស់ នូវការបកស្រាយដែលមានភាពបត់បែននេះឡើយ។ មិនមានរដ្ឋណាមួយ ក្នុងចំណោមរដ្ឋជាសមាជិកទាំង ១៦២ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម បានដាក់ខបម្រុងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ឬ បានដាក់

---

[402] ពុំមានព័ត៌មានគ្រប់គ្រាន់សម្រាប់កំណត់អំពីមូលហេតុដែលសេចក្តីព្រាងមាត្រា ១៥ នៃអនុសញ្ញា CAT ដែលត្រូវបានស្នើឡើង ដែលធ្វើការបញ្ជាក់បំភ្លឺយ៉ាងជាក់លាក់ថា ភស្តុតាងបន្ទាប់បន្សំ ត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃវិធានលើកលែង មិនត្រូវបានជ្រើសរើសទេ។ ភាពស្ងៀមស្ងាត់នៃមាត្រា ១៥ ទៅលើភស្តុតាងបន្ទាប់បន្សំ មិនមែនមានន័យថា ភស្តុតាងបន្ទាប់បន្សំមិនត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃមាត្រា ១៥ ឡើយ។ សនិទានភាពនយោបាយនៅពីក្រោយអនុសញ្ញា CAT បង្ហាញថាមានចេតនាក្នុងការដាក់បញ្ចូលភស្តុតាងបន្ទាប់បន្សំទៅក្នុងវិសាលភាពនៃមាត្រា ១៥។ *សូមមើល* កថាខណ្ឌ ១៤៨ *ខាងលើ* ។ មន្ទិលសង្ស័យណាមួយលើការអនុវត្តវិធានលើកលែងនៃមាត្រា ១៥ ទៅលើភស្តុតាងបន្ទាប់បន្សំ ត្រូវតែដោះស្រាយជាប្រយោជន៍ដល់លោក មាស មុត អនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង គោលការណ៍ *មន្ទិលសង្ស័យត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ* (in dubio pro reo)។ *សូមមើល* កថាខណ្ឌ ២៦-៣៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[403] ក្នុងអំឡុងពេលការចរចាដែលឈានទៅដល់ការអនុម័តអនុសញ្ញា CAT សមាគមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បានដាក់សំណើច្បាប់ពង្រាងមួយ ដែលបញ្ចូលការហាមឃាត់ប្រឆាំងនឹង "សេចក្តីថ្លែងការណ៍ ឬ ចម្លើយសារភាពផ្តាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ ដែលទទួលបានដោយមធ្យោបាយនៃការធ្វើទារុណកម្ម ឬ *ភស្តុតាងណាផ្សេងទៀតដែលទាញចេញពីនោះ*" (ការគូសបញ្ជាក់បន្ថែម)។ រដ្ឋផ្សេងទៀតជាច្រើនបានដាក់សំណើដោយប្រើពាក្យពេជន៍ផ្សេងៗគ្នា។ ការណ៍ដែលថាពាក្យពេជន៍របស់សមាគមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មិនត្រូវបានអនុម័តជាលើកចុងក្រោយ មិនមែនមានន័យថា ពាក្យពេជន៍ដែលត្រូវបានអនុម័ត - "*ដែលត្រូវបានធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្ម*" - មិនបានរាប់បញ្ចូលជាភស្តុតាងបន្ទាប់បន្សំនោះទេ។ *សូមមើល* សេចក្តីសម្រេចលើសំណើសុំមោឃភាពភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម កថាខណ្ឌ ៣៥ ដែលដកស្រង់សេចក្តីព្រាងដែលបានដាក់ជូនដោយសមាគមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឯកសារ អ.ស.ប. លេខ E/CN.4/NGO/213 ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៧៨ សេចក្តីព្រាងដើមដែលបានដាក់ជូនដោយប្រទេសស្វីស ឯកសារ អ.ស.ប. លេខ E/CN.4/1285 ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ១៩៧៨ សេចក្តីព្រាង ដែលបានដាក់ជូនដោយសហរដ្ឋអាមេរិក ឯកសារ អ.ស.ប. លេខ E/CN.4/1314 ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៧៨ សេចក្តីព្រាងដែលបានពិនិត្យឡើងវិញ និង បានដាក់ជូនដោយប្រទេសស្វីស ឯកសារ អ.ស.ប. លេខ E/CN.4/WG.1/WP.1 ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៧៩។

ការប្រកាសក្នុងកម្រិតដែលថា ភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម *គឺ*អាចទទួលយកបាននៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការនោះឡើយ[404]។

១៥២. ការអនុវត្តនាពេលបន្តបន្ទាប់របស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម អ.ស.ប. និង ប្រភពអន្តរជាតិផ្សេងទៀត ចង្អុលបង្ហាញថា ភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម ត្រូវបានដាក់បញ្ចូល នៅក្នុងវិធានបដិសេធភស្តុតាងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[405]។ អង្គបុរេជំនុំជម្រះបានបកស្រាយខុស នូវអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម និង អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម[406]។ អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ផ្តល់ដល់បណ្តារដ្ឋនានា គឺបញ្ចូលបទប្បញ្ញត្តិ ទៅក្នុងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋទាំងនោះ ដោយមិនរួមបញ្ចូលភស្តុតាងដែលទទួលបាន "ដោយផ្ទាល់ ឬ

---

[404] កម្រងសន្ធិសញ្ញា អ.ស.ប. អនុសញ្ញា CAT https://treaties.un.org/Pages/ViewDetails.aspx?src=IND&mtdsg_no=IV-9&chapter=4&lang=en (ចូលមើលចុងក្រោយនៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨)។

[405] គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម អ.ស.ប. បានផ្តល់អនុសាសន៍ទៅប្រទេសហ្វាំងឡង់ "ថាបទប្បញ្ញត្តិពិសេសត្រូវបានដាក់បញ្ចូលទៅក្នុងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋភាគី ដែលទាក់ទងនឹងការដកចេញពីកិច្ចដំណើរការនីតិវិធីតុលាការ នូវភស្តុតាងដែលបានទទួល *ដោយផ្ទាល់ ឬ ដោយប្រយោល* ដែលជាលទ្ធផលនៃការធ្វើទារុណកម្ម ដូចដែលមានចែងក្នុងមាត្រា ១៥"។ កំណត់ហេតុសង្ខេបនៃផ្នែកសាធារណៈនៃកិច្ចប្រជុំលើកទី ២៥០៖ ប្រទេសហ្វាំងឡង់ ឯកសារ អ.ស.ប. លេខ CAT/C/SR.250 ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ១៩៩៦ អនុសាសន៍ ទំព័រ ៧ កថាខណ្ឌ ១៨ (ការគូសបញ្ជាក់បន្ថែម)។ គណៈកម្មាធិការនេះបានផ្តល់អនុសាសន៍ដល់ប្រទេសហ្សកហ្ស៊ី និង ប៉ូឡូញ "ថា *ចវម្លើយដែលបានទទួលដោយផ្ទាល់ ឬ ដោយប្រយោលពី* ការធ្វើទារុណកម្ម មិនអាចធ្វើជាភស្តុតាងនៅក្នុងតុលាការឡើយ"។ កំណត់ហេតុសង្ខេបនៃផ្នែកសាធារណៈនៃកិច្ចប្រជុំលើកទី ២៧៩៖ ប្រទេសហ្សកហ្ស៊ី ប៉ូឡូញ ឯកសារ អ.ស.ប. លេខ CAT/C/SR.279 ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ១៩៩៧ អនុសាសន៍ ទំព័រ ៣ កថាខណ្ឌ ១៥ (ការគូសបញ្ជាក់បន្ថែម)។ គណៈកម្មាធិការនេះក៏បានផ្តល់អនុសាសន៍ដល់ប្រទេសអាល្លឺម៉ង់ថា "ការចាប់អារម្មណ៍ផ្នែកនីតិបញ្ញត្តិបន្ថែមទៀត ត្រូវផ្តោតការយកចិត្តទុកដាក់ចំពោះការអនុវត្ត [មាត្រា ១៥] ឱ្យបានតឹងរ៉ឹង ហើយថា *ភស្តុតាងទាំងអស់ដែលបានទទួលដោយផ្ទាល់ ឬ ដោយប្រយោលពីការធ្វើទារុណកម្ម* ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងមិនឱ្យឈានទៅដល់ការទទួលស្គាល់ពីចៅក្រមដែលសម្រេចសេចក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការទាំងអស់"។ កំណត់ហេតុសង្ខេបនៃផ្នែកសាធារណៈនៃកិច្ចប្រជុំលើកទី ៣២៩៖ ប្រទេសអាល្លឺម៉ង់ ឯកសារ អ.ស.ប. លេខ CAT/C/SR.329 ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៩៨ អនុសាសន៍ ទំព័រ ៨ កថាខណ្ឌ ១៥ (ការគូសបញ្ជាក់បន្ថែម)។ មហាសន្និបាត អ.ស.ប. របាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប Juan E. Méndez ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើទី ២៥ ឯកសារ អ.ស.ប. លេខ A/HRC/25/60 ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៤ កថាខណ្ឌ ២៩ ដែលដកស្រង់ *Cabrera García និង Montiel Flores តទល់នឹង México* តុលាការសិទ្ធិមនុស្សអន្តរអាមេរិក Series C លេខ ២២០ សាលក្រម ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ១៦៧។

[406] កថាខណ្ឌ ៣៦ នៃសេចក្តីសម្រេចលើសំណើសុំមោយភាពភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។

ប្រយោលពីការធ្វើទារុណកម្ម”[407] ឆ្ពុះបញ្ចាំងការបកស្រាយបែបអាជ្ញាព្រឹត្តិនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[408]។ អនុសាសន៍របស់គណៈកម្មាធិការនេះ មិន “ផ្ទុយនឹងពាក្យពេចន៍ត្រង់ៗនៃមាត្រា ១៥” ឡើយ[409]។ គណៈកម្មាធិការជំរុញដល់រដ្ឋទាំងនោះ ឱ្យចាត់វិធានការផ្លូវច្បាប់ ដើម្បីអនុវត្តមាត្រា ១៥ យ៉ាងតឹងរ៉ឹង[410]។

១៥៣. សេចក្តីសន្និដ្ឋានរបស់អ្នករាយការណ៍ពិសេស ស្តីពីការធ្វើទារុណកម្ម ដែលថា វិធានបដិសេធភស្តុតាងអាចអនុវត្តចំពោះភស្តុតាងដែលទាញចេញពីការធ្វើទារុណកម្ម[411] គឺមិនមែនជាផ្នែកនៃ “អនុសាសន៍ទូទៅជូនស្ថាប័នតុលាការរបស់រដ្ឋ ដែលស្នើសុំករណីពង្រីកវិសាលភាពនេះ ‘*ឱ្យលើសដែនកំណត់នៃពាក្យពេចន៍ទូទៅ នៅក្នុងមាត្រា ១៥ នៃអនុសញ្ញា*’” ដូចដែលបានកំណត់លក្ខណៈ ដោយអង្គបុរេ

---

[407] *សូមមើល* កំណត់ហេតុសង្ខេបនៃផ្នែកសាធារណៈនៃកិច្ចប្រជុំលើកទី ២៥០៖ ប្រទេសហ្វាំងឡង់ ឯកសារ អ.ស.ប. លេខ CAT/C/SR.250 ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ១៩៩៦ អនុសាសន៍ ទំព័រ ៧ កថាខណ្ឌ ១៨។ កំណត់ហេតុសង្ខេបនៃផ្នែកសាធារណៈនៃកិច្ចប្រជុំលើកទី ២៧៩៖ ប្រទេសហ្សកហ្ស៊ី ប៉ូឡូញ ឯកសារ អ.ស.ប. លេខ CAT/C/SR.279 ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ១៩៩៧ អនុសាសន៍ ទំព័រ ៣ កថាខណ្ឌ ១៥។ កំណត់ហេតុសង្ខេបនៃផ្នែកសាធារណៈនៃកិច្ចប្រជុំលើកទី ៣២៩៖ ប្រទេសអាល្លឺម៉ង់ ឯកសារ អ.ស.ប. លេខ CAT/C/SR.329 ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៩៨ អនុសាសន៍ ទំព័រ ៨ កថាខណ្ឌ ១៥។

[408] គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម អនុសញ្ញាប្រឆាំងទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប សេចក្តីអធិប្បាយទូទៅលេខ ២ ឯកសារ អ.ស.ប. លេខ CAT/C/GC/2 ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០០៨ កថាខណ្ឌ ១៖ “បទបញ្ញត្តិក្នុងមាត្រា ២ [នៃអនុសញ្ញា CAT] ... ជាមូលដ្ឋាននៃអំណាចរបស់គណៈកម្មាធិការក្នុងការអនុវត្តមធ្យោបាយហាមឃាត់ [ការធ្វើទារុណកម្ម] ប្រកបដោយប្រសិទ្ធភាព...”។

[409] កថាខណ្ឌ ៣៦ នៃសេចក្តីសម្រេចលើសំណើសុំមោឃភាពភស្តុតាងបានមកពីការធ្វើទារុណកម្ម។

[410] *សូមមើល ខ.ថ.* ផ្នែកនៃអនុសាសន៍សង្ខេបនៃកិច្ចប្រជុំលើកទី ៣២៩៖ ប្រទេសអាល្លឺម៉ង់ ឯកសារ អ.ស.ប. លេខ CAT/C/SR.329 ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៩៨ អនុសាសន៍ ទំព័រ ៨ កថាខណ្ឌ ១៥៖ “គណៈកម្មាធិការផ្តល់អនុសាសន៍ថា *ការចាប់អារម្មណ៍ផ្នែកនីតិបញ្ញត្តិបន្ថែមទៀតត្រូវផ្តោតការយកចិត្តទុកដាក់ចំពោះការអនុវត្តមាត្រា ១៥ នៃអនុសញ្ញា ឱ្យបានតឹងរ៉ឹង* និង ថាភស្តុតាងទាំងអស់ដែលបានទទួលដោយផ្ទាល់ ឬ ដោយប្រយោលពីការធ្វើទារុណកម្ម ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងមិនឱ្យឈានដល់ការទទួលស្គាល់ពីចៅក្រមដែលសម្រេចសេចក្តី នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការទាំងអស់”។ (ការគូសបញ្ជាក់បន្ថែម)។

[411] មហាសន្និបាត អ.ស.ប. របាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប Juan E. Méndez ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើកទី ២៥ ឯកសារ អ.ស.ប. លេខ A/HRC/25/60 ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៤ កថាខណ្ឌ ២៩។

ជំនុំជម្រះឡើយ[412]។ នេះជាការប្រកាសបែបអាជ្ញាព្រឺត្តិ ចំពោះការបកស្រាយលើវិធានបដិសេធ ភស្តុតាងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដោយផ្អែកលើយុត្តិសាស្ត្រសិទ្ធិមនុស្ស[413]។

១៥៤. អង្គបុរេជំនុំជម្រះបានបកស្រាយដោយខុសឆ្គងនូវមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មថា ជាលក្ខខណ្ឌតម្រូវចំណាងទាក់ទងតឹងតែងជ្រុលហួសហេតុ នៅពេលដែលអង្គបុរេជំនុំជម្រះពិចារណាឃើញថា កម្រិតនៃចំណាងទាក់ទងរវាងការធ្វើទារុណកម្ម ជាមួយនឹងកំណត់ហេតុនៃការស្តាប់ចម្លើយដែលពាក់ព័ន្ធ គឺតូចតាចមិនសំខាន់[414]។ ការណ៍ដែល អ.វ.ត.ក. មិនបានចូលរួមពាក់ព័ន្ធដោយខុសច្បាប់ នៅក្នុងការធ្វើទារុណកម្ម គឺមិនជាប់ពាក់ព័ន្ធឡើយ[415]។ ការស្វែងរកសាក្សីរបស់អ្នកស៊ើបអង្កេត ក.ស.ច.ស. ត្រូវបានចាប់ផ្តើមឡើងពីប្រវត្តិរូបនៅមន្ទីរ ស-២១។ បើមិន

---

[412] កថាខណ្ឌ ៣៦ នៃសេចក្តីសម្រេចលើសំណើសុំមោឃភាពភស្តុតាងបានមកពីការធ្វើទារុណកម្ម ដែលដកស្រង់មហាសន្និបាត អ.ស.ប. របាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ទោកបន្ទាប Juan E. Méndez ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើកទី២៥ ឯកសារ អ.ស.ប. លេខ A/HRC/25/60 ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៨ (ការគូសបញ្ជាក់របស់អង្គបុរេជំនុំជម្រះ)។

[413] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ទោកបន្ទាប Juan E. Méndez ឯកសារ អ.ស.ប. លេខ A/HRC/25/60 ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៤ កថាខណ្ឌ ២៩ ដែលដកស្រង់ *រឿងក្តី Cabrera García និង Montiel Flores តទល់នឹង México* តុលាការសិទ្ធិមនុស្សអន្តរអាមេរិក Series C លេខ ២២០ សាលក្រម ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ១៦៧។

[414] កថាខណ្ឌ ៣៧ នៃសេចក្តីសម្រេចលើសំណើសុំមោឃភាពភស្តុតាងបានមកពីការធ្វើទារុណកម្ម។

[415] កថាខណ្ឌ ៥៦ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារក្នុងរឿងក្តី ០០២/០១ ("សរុបសេចក្តីមក ស្ថាប័នស្តីពីសិទ្ធិមនុស្សបានយល់ឃើញថា ការហាមឃាត់ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងព័ត៌មានបានមកពីការធ្វើទារុណកម្ម គឺពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីផ្លូវការទាំងអស់ បើទោះបី ជាផ្អែកតុលាការក្តី ឬ ផ្អែករដ្ឋបាលក្តី។ ស្ថាប័ននេះបានបញ្ជាក់ទៀតថា បញ្ហាថាតើការធ្វើទារុណកម្មត្រូវបានប្រព្រឹត្តឡើងដោយរដ្ឋ ដែលមានយុត្តាធិការ ឬ ក៏រដ្ឋដទៃទៀត...") ដែលដកស្រង់ *Othman (Aby Qatada) តទល់នឹង ចក្រភពអង់គ្លេស* តុលាការសិទ្ធិមនុស្សអឺរ៉ុប សំណុំរឿងលេខ 8139/09 សាលក្រម ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១២ កថាខណ្ឌ ២៦៣ កថាខណ្ឌ ២៦៧។ *រឿងក្តី El Haski តទល់នឹង បែលហ្សិក* តុលាការសិទ្ធិមនុស្សអឺរ៉ុប សំណុំរឿងលេខ 649/08 សាលក្រម ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៨៥។ *សូមមើលផងដែរ* គណៈកម្មាធិការ អ.ស.ប. ប្រឆាំងការធ្វើទារុណកម្ម សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម ចក្រភពអង់គ្លេស និង អៀឡង់ខាងជើង ឯកសារ អ.ស.ប. លេខ CAT/C/CR/33/3 ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤ (គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្មបង្ហាញនូវការព្រួយបារម្ភថា ច្បាប់របស់ចក្រភពអង់គ្លេស "ត្រូវបានបកស្រាយដោយដកចេញនូវការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម តែនៅក្នុងករណីដែលមន្ត្រីរដ្ឋភាគីត្រូវបានចូលរួមប៉ុណ្ណោះ" ហើយផ្តែងថា "មាត្រា ១៥ នៃអនុសញ្ញា ហាមឃាត់ការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម បើទោះជាទទួលបាននៅកន្លែង ឬ ដោយបុគ្គលណាក្តី")។

មានប្រវត្តិរូបទាំងនោះទេ អ្នកស៊ើបអង្កេតនឹងមិនអាចរកឃើញសាក្សី មិនបាន ស្តាប់ចម្លើយពួកគាត់ និង មិនអាចដាក់កំណត់ហេតុនៃការស្តាប់ចម្លើយពួកគាត់ ចូលទៅក្នុងសំណុំរឿងបាននោះទេ។ កម្រិតនៃចំណងទាក់ទង មិនត្រូវបានបន្ធូរបន្ថយដោយសារការណ៍ដែលថា បន្ទាប់ពីប្រើប្រាស់ប្រវត្តិនៅមន្ទីរ ស-២១ ហើយអ្នកស៊ើបអង្កេតត្រូវស្វែងរកសាក្សី នៅកន្លែងផ្សេងៗគ្នាជាច្រើន និងកំណត់ថាតើសាក្សីទាំងនោះទំនេរ និងចង់ផ្តល់ចម្លើយឬយ៉ាងណានោះទេ[416]។

១៥៥. មេធាវីការពារក្តីដាក់បញ្ចូល តាមរយៈការយោងទូវទឡ្ហីករណ៍ ដែលបានលើកឡើងក្នុងសារណាកន្លងមករបស់ខ្លួន[417]។

ខ. ចម្លើយសារភាពនៅមន្ទីរស-២១ មិនអាចត្រូវបានយកមកធ្វើជាមូលដ្ឋាន ដើម្បីកំណត់ពីអង្គហេតុផ្សេងទៀត ក្រៅពីការពិតនៃខ្លឹមសាររបស់ចម្លើយសារភាព

១៥៦. ចម្លើយសារភាព ដែលទទួលបានដោយការធ្វើទារុណកម្មនៅមន្ទីរ ស-២១ មិនអាចត្រូវបានយកជាមូលដ្ឋាន ដើម្បីបង្ហាញឱ្យឃើញថាសកម្មភាពអ្វីដែលបានកើតឡើង ដោយផ្អែកលើការណ៍ដែលថាចម្លើយត្រូវបានធ្វើឡើង ជាឧទាហរណ៍ ដើម្បីបង្ហាញថាការចាប់ខ្លួនត្រូវបានអនុវត្តឡើង ដោយសារតែមានចម្លើយសារភាពនោះឡើយ។ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ហាមឃាត់មិនឱ្យប្រើប្រាស់ ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ដើម្បីបង្ហាញនូវការពិតនៃខ្លឹមសាររបស់ភស្តុតាងនោះ ឬ សូម្បីតែបញ្ជាក់ថា វាអាចជាការពិត[418]។ ការប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ ដែលត្រូវបានអនុញ្ញាតតែមួយគត់ គឺដើម្បីប្រឆាំងទៅនឹងអ្នកធ្វើទារុណកម្ម ដែលត្រូវបានចោទប្រកាន់ ក្នុងនាមជាភស្តុតាងដែលថា ការឆ្លើយសារភាពត្រូវបានធ្វើឡើង ដោយមានការធ្វើទារុណកម្ម។ ការប្រើប្រាស់ដទៃផ្សេងទៀត នូវភស្តុតាងបែបនេះ គឺត្រូវបានហាមឃាត់។ *សូមមើល* ឧបសម្ព័ន្ធ ជ។

---

[416] កថាខណ្ឌ ៣៧ នៃសេចក្តីសម្រេចលើសំណើសុំមោឃភាពភស្តុតាងបានមកពីការធ្វើទារុណកម្ម។

[417] ពាក្យសុំរបស់មាស មុត សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D257/1/3។ ពាក្យសុំរបស់ មាស មុត សុំឱ្យមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171 ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D253/1/3។

[418] កថាខណ្ឌ ៤៧ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារក្នុងរឿងក្តី ០០២/០១។

១៥៧. អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ មានកំហុសឆ្គងក្នុងការសម្រេចថា ព័ត៌មាននៅក្នុងចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម អាចយកមកធ្វើជាមូលដ្ឋាន ដើម្បីកំណត់អង្គហេតុក្រៅពីការពិតនៃចម្លើយ[419]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ មិនបានពន្យល់ពីមូលហេតុ ដែលការប្រើប្រាស់ត្រូវបានអនុញ្ញាត នូវភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម តាមមាត្រា ១៥ (ជាភស្តុតាងដែលថា ចម្លើយត្រូវបានធ្វើឡើងដោយទារុណកម្ម) គឺមិនគ្រប់គ្រាន់ដើម្បីជំនុំជម្រះ ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ហើយអង្គជំនុំជម្រះសាលាដំបូង ក៏មិនបានពន្យល់ថា តើការព្រួយបារម្ភលើអាចជឿជាក់បាន ត្រូវបានកាត់បន្ថយដោយរបៀបណា តាមរយៈការប្រើប្រាស់ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម នៅក្នុងលក្ខណៈបែបនេះ ហើយអង្គជំនុំជម្រះសាលាដំបូង បានពិចារណាដោយខុសឆ្គងថា សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ចាំបាច់ត្រូវតែថ្លឹងថ្លែង ដោយធៀបទៅនឹងភាពចាំបាច់របស់ព្រះរាជអាជ្ញាក្នុងការទទួលយកភស្តុតាង ប្រឆាំងជនទាំងឡាយណា ដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម[420]។

១៥៨. អង្គជំនុំជម្រះក្នុងរឿងក្តី ០០២/០២ បានពិចារណាដោយខុសឆ្គងថា គោលបំណងក្នុងការមិនជំរុញឱ្យមានការធ្វើទារុណកម្ម មិនបានសម្រេចទេ “ប្រសិនបើភស្តុតាងបែបនេះត្រូវបានហាមឃាត់ទាំងអស់ ក្នុងការចោទប្រកាន់ជនដែលទទួលខុសត្រូវ ចំពោះអំពើទារុណកម្មនោះ ដែលការនេះនឹងទៅជាការជួយដល់បុគ្គល ដែលត្រូវបានចោទប្រកាន់ពីបទឈ្មើសនេះទៅវិញ”[421]។ បើតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មានការប្រើប្រាស់មួយដែលត្រូវបានអនុញ្ញាតឱ្យសម្រាប់ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម៖ វាអាចត្រូវបានយកមកប្រើធ្វើជាភស្តុតាងបង្ហាញថា ចម្លើយសារភាពត្រូវបានធ្វើឡើង ដោយការធ្វើទារុណកម្ម។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ មិនបានពន្យល់ថា ហេតុអ្វីបានជាការប្រើប្រាស់នេះ មិនគ្រប់គ្រាន់សម្រាប់ជំនុំជម្រះ អ្នកធ្វើទារុណកម្មដែលត្រូវបានចោទប្រកាន់ឡើយ។

---

[419] កថាខណ្ឌ ៧៥ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងរឿងក្តី ០០២/០២។

[420] *សូមមើល* កថាខណ្ឌ ១៥៨-៦០ *ខាងក្រោម*។

[421] កថាខណ្ឌ ៧៤ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងរឿងក្តី ០០២/០២។

១៥៩. អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ បានពិចារណាឃើញថា ចម្លើយសារភាពនៅមន្ទីរ ស-២១ ដែលទទួលបានដោយការធ្វើទារុណកម្ម "មិនអាចជឿជាក់បានទេ" ប៉ុន្តែ បានពិចារណាឃើញថា ខ្លឹមសារនៃចម្លើយសារភាពអាចយកមកប្រើបាន សម្រាប់បង្ហាញថា អំពើត្រូវបានធ្វើឡើង ជាលទ្ធផលនៃការណ៍ដែលថាចម្លើយសារភាពនោះត្រូវបានធ្វើឡើង[422]។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ មិនបានពន្យល់ថា តើការប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ នៅក្នុងលក្ខណៈបែបនេះ អាចកាត់បន្ថយការព្រួយបារម្ភ ទាក់ទងនឹងភាពអាចជឿជាក់បាន ដោយរបៀបណានោះឡើយ។ ប្រភពនៃភស្តុតាង គឺកើតចេញពីជនរងគ្រោះ ដែលទទួលរងការធ្វើទារុណកម្ម គឺជនរងគ្រោះដែលចំទងជានិយាយអ្វីៗទាំងអស់ ដើម្បីបញ្ចប់ការធ្វើទារុណកម្ម[423]។ អង្គហេតុផ្សេងទៀតអាចត្រូវបានទាញចេញ តាមរយៈការសន្និដ្ឋាន លើភស្តុតាងដែលមិនអាចជឿជាក់បាន[424]។ "និយាយឱ្យសមហេតុផលទៅ... ភស្តុតាងបានមកតាមរយៈការធ្វើទារុណកម្ម ពុំអាចជឿទុកចិត្តបាន គឺមិនត្រឹមតែជាប់ពាក់ព័ន្ធទៅនឹង ចម្លើយសារភាពដោយបង្ខំប៉ុណ្ណោះទេ ជាទូទៅ *ថែមទាំងទៅនឹងព័ត៌មានណាមួយ បានមកពីការបុគ្គលដែលទទួលរងការធ្វើទារុណកម្ម* បើទោះបីជាបុគ្គលនោះ ពុំមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលចាំបាច់ត្រូវការប្រើប្រាស់ព័ត៌មាននោះក៏ដោយ"[425]។

១៦០. អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ បានពិចារណាដោយខុសឆ្គងថា សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ចាំបាច់ត្រូវធ្វើការពិចារណាជាបន្តបន្ទាប់ "ជាមួយនឹងសេចក្តីត្រូវការ ក្នុងការធានាភាពអាចរកបានន្ូវភស្តុតាង ដើម្បីចោទប្រកាន់ជនដែលត្រូវបានចោទប្រកាន់ចំពោះអំពើទារុណកម្ម"[426]។ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោល ការបកស្រាយបែបនេះ នៅពេលដែលសហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា កាតព្វកិច្ចចាំបាច់នៃការចោទប្រកាន់ប្រកបដោយប្រសិទ្ធភាព តម្រូវឱ្យធ្វើការពង្រីកន្ូវការប្រើប្រាស់ ចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម ឱ្យលើសពីពាក្យពេចន៍ជាក់ច្បាស់នៃមាត្រា ១៥ របស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម៖

---

[422] *ដូចខាងលើ* កថាខណ្ឌ ៧៥។

[423] កថាខណ្ឌ ៤២ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារក្នុងរឿងក្តី ០០២/០១។

[424] *ដូចខាងលើ* កថាខណ្ឌ ៦៨។

[425] *ដូចខាងលើ* កថាខណ្ឌ ៤២ (ការគូសបញ្ជាក់បន្ថែម)។

[426] កថាខណ្ឌ ៧៦ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងរឿងក្តី ០០២/០២ ។

> វិធានបដិសេធភស្តុតាងពុំបានគាំទ្រ ក្នុងការសម្រួលដល់ការបកស្រាយរបស់សហ ព្រះរាជអាជ្ញាឡើយ។ កម្មវត្ថុ និង គោលបំណងនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹង ការធ្វើទារុណកម្ម តម្រូវឱ្យមានការដកចេញយ៉ាងទូលំទូលាយ នូវព័ត៌មានណាមួយ ដែលបានមកពីការធ្វើទារុណកម្ម។ ហើយចំពោះករណីលើកលែងនៃវិធាននេះ តាមខ្លឹម សារ ត្រូវតែបកស្រាយក្នុងន័យចង្អៀត។ ជាពិសេសអង្គជំនុំជម្រះតុលាការកំពូល យល់ ស្របជាមួយនឹងយុត្តិសាស្ត្រដែលបានដកស្រង់ខាងលើ ដែលអះអាងថា ភាពចាំបាច់នៃ ការចោទប្រកាន់ ពុំអាចធ្វើយុត្តិកម្មលើការប្រើប្រាស់ចម្លើយ ដែលបានមកពីការធ្វើ ទារុណកម្មបានឡើយ រួមទាំងភាគីដទៃទៀតដែលស្នើសុំប្រើប្រាស់ចម្លើយនេះ ហើយពុំ មែនជាអ្នកទទួលខុសត្រូវចំពោះការធ្វើទារុណកម្មនោះផងដែរ[427]។

១៦១. ការណ៍ដែលថាការធ្វើទារុណកម្មមិនត្រូវបានចោទប្រកាន់នៅក្នុងរឿងក្តី ០០២/០១ មិនបានផ្តាស់ប្តូរ ការវិភាគឡើយ។ ការប្រើប្រាស់ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ទោះជាក្នុងមូល ហេតុណាក៏ដោយ សុទ្ធតែជាការធ្វើឱ្យស្របច្បាប់ដល់ការប្រើប្រាស់ទារុណកម្ម ហើយធ្វើឱ្យប៉ះ ពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ "ភស្តុតាងដោយការធ្វើទារុណកម្មត្រូវបានបដិសេធ ដើម្បីការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីការជំនុំជម្រះ និង ដើម្បីការពារនីតិរដ្ឋផ្ទាល់តែ ម្តង"[428]។ សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និង ភាពយុត្តិធម៌នៃកិច្ចដំណើរការ មិនអាចត្រូវបាន បោះបង់ចោល ដើម្បីផលប្រយោជន៍នៃការទទួលបានការផ្តន្ទាទោសឱ្យបានឆាប់រហ័សបំផុត តាម ដែលអាចធ្វើទៅបាននោះឡើយ។ ដូចដែលលោកសាស្ត្រាចារ្យ Kai បានពន្យល់៖

> ខណៈដែលពិបាកក្នុងការទទួលស្គាល់ថា ជនជាប់ចោទដូចជាមេដឹកនាំខ្មែរក្រហម កែង យកចំណេញពីមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ជាបទប្បញ្ញត្តិមួយ ដែលប្រាកដណាស់ថា មិនត្រូវបានតាក់តែងឡើងដើម្បីការពារពួកគេ ពីការទទួលខុស ត្រូវព្រហ្មទណ្ឌ តែគេមិនគួរមើលស្រាលទៅលើការខូចខាតចំពោះភាពស្របច្បាប់នៃ ការជំនុំជម្រះទៅលើអ្នកធ្វើទារុណកម្ម ដែលពឹងផ្អែកជាចម្បងទៅលើភស្តុតាងដែល ទទួលបានដោយការធ្វើទារុណកម្ម ផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនបួន ដែលបានលើក

---

[427] កថាខណ្ឌ ៦៧ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារក្នុងរឿងក្តី ០០២/០១ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[428] *រឿងក្តី Othman (Aby Qatada) តទល់នឹង ចក្រភពអង់គ្លេស* តុលាការសិទ្ធិមនុស្សអឺរ៉ុប សំណុំរឿងលេខ 8139/09 សាលក្រម ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១២ កថាខណ្ឌ ២៦៤។

ឡើងដោយ Scharf។ តាមពិតទៅលក្ខណៈវិនិច្ឆ័យទាំងនេះ គឺមិនទាក់ទងជាមួយបញ្ហានៃសុចរិតភាព ឬ យុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីឡើយ ប៉ុន្តែទាក់ទងជាមួយការលះបង់នូវការពិចារណាទាំងនេះ ដើម្បី "ប្រសិទ្ធិភាពរបស់តុលាការ" ដោយមានគោលបំណងផ្តន្ទាទោសជនជាប់ចោទ ឱ្យបានរលូនបំផុតតាមដែលអាចធ្វើទៅបាន។ "ភាពបត់បែន" បែបនេះ ដែលមានឧទាហរណ៍នាពេលបច្ចុប្បន្នស្រាប់ គឺការជំនុំជម្រះទៅលើ Saddam Hussein នៅក្នុងរយៈពេលយូរទៅមុខជានឹងនាំឱ្យមានផលអាក្រក់ចំពោះយុត្តិធម៌ព្រហ្មទណ្ឌ[429]។

១៦២. នាពេលបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០២ មិនបានគិតអំពីសេចក្តីសម្រេចរបស់ខ្លួន ហើយគោរពទៅតាមពាក្យពេចន៍ និង ស្មារតីនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម នៅពេលដែលអង្គជំនុំជម្រះ មិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអានការប្រកាសផ្សាយចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម ដើម្បីបង្ហាញថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានប្រើប្រាស់ការផ្សព្វផ្សាយបែបនេះ សម្រាប់គោលដៅឃោសនាប្រឆាំងវៀតណាម[430]។ "សំណួរនេះមិនអាចសួរបានទេ សហព្រះរាជអាជ្ញាអន្តរជាតិអាចតាំងសំណួរផ្សេងទៀត ព្រោះសំណួរនេះវាពាក់ព័ន្ធជាមួយខ្លឹមសារនៃចម្លើយសារភាពដែលអង្គជំនុំជម្រះ ពិបាកនឹងញែកដាច់

---

[429] Kai Ambos *ការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មជាអន្តរប្រទេស* វិវេចនាច្បាប់អ៊ឺស្រាអែល លេខ ៤២ ទំព័រ ៣៦២ និង ៣៨១ (ឆ្នាំ ២០០៩)។ លក្ខណៈវិនិច្ឆ័យទាំងបួនរបស់សាស្ត្រាចារ្យ Michael P. Scharf គឺ៖ (១) ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម មិនត្រូវប្រើក្នុងការជំនុំជម្រះ នៅពេលដែលជនរងគ្រោះនៃការបំពានបែបនេះ ជាជនជាប់ចោទ (២) ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម មិនត្រូវប្រើ នៅពេលដែលអាជ្ញាធរនៃការកាត់ទោសពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោល នៅក្នុងការធ្វើទារុណកម្ម (៣) ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម មិនគួរត្រូវយកមកពិចារណា លើកលែងតែមានការបញ្ជាក់កម្រិតខ្ពស់ និង (៤) ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម មិនគួរត្រូវទទួលយក បើអយ្យការអាចរកបានភស្តុតាងដែលមិនបានមកពីការធ្វើទារុណកម្ម ដែលមានប្រសិទ្ធភាពក្នុងការបង្កើតឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ។ *សូមមើល* Michael P. Scharf *ប្រភពដែលមិនស្អាតស្អំ តើពេលណា ប្រសិនបើមាន ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម គួរអាចទទួលយកបានដែរឬទេ?* វិវេចនាច្បាប់ WASH & LEE លេខ ៦៥ ទំព័រ ១២៩, ១៧០-១៧១ (ឆ្នាំ ២០០៨)។

[430] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 ម៉ោង 09:36:53-09:51:24។

រវាងគ្នា រវាងសេចក្តីផ្តើមហើយនិងការបង្ហាញពីចម្លើយសារភាព ដែលមាននៅក្នុងសារព័ត៌មានដែលផ្សាយដោយវិទ្យុនោះ"[431]។

១៦៣. ការបង្កើតនូវករណីលើកលែងថ្មី សម្រាប់មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម នឹងប្រឈមហានិភ័យនៃការធ្វើឱ្យថមថយ ការហាមឃាត់ប្រឆាំងភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្មនៅត្រឹមកម្រិតជាវិធានចចាមអារ៉ាម គឺ "វិធានដែលមានករណីលើកលែងច្រើន មានលក្ខណៈដូចជាឈើសស្វើស ដែលមានប្រហោងច្រើនដូច្នេះដែរ"[432]។ ការហាមឃាត់ដែលទន់ខ្សោយចំពោះការប្រើប្រាស់ភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម "គឺដូចជាទុកអាវុធដែលមានគ្រាប់ពេញ សម្រាប់ឱ្យអាជ្ញាធរណាដែលអាចលើកឡើង នូវការអះអាងពីតម្រូវការជាបន្ទាន់ ដែលអាចជឿបាន យកទៅប្រើប្រាស់យ៉ាងដូច្នេះ"[433]។ ដូចដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានក្រើនរំលឹកនៅក្នុងសារណារបស់អ្នកមិនមែនជាគូភាគីនៃរឿងក្តី ចំពោះបញ្ហាតែមួយនេះថា៖

> នៅតែមានការព្រួយបារម្ភជាក់ស្តែង ដែលថា តុលាការកម្ពុជានឹងទាញយកប្រយោជន៍ពីឆន្ទានុសិទ្ធិក្នុងការទទួលយកភស្តុតាងដែលទទួលបាន ដោយការធ្វើទារុណកម្ម... សេចក្តីសម្រេចណាមួយ ដែលពង្រីកករណីលើកលែងនៅក្នុងមាត្រា ១៥ អាចត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យស្របច្បាប់ និង បន្តជានិរន្តន្ទរការអនុវត្ត ការធ្វើទារុណកម្មដែលជាជំងឺរាំរ៉ៃមួយនៅប្រទេសកម្ពុជា... នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសង្គមដែលទើបបញ្ចប់ជម្លោះ ឬ សង្គមអន្តរកាលដែរ នគរបាលបានប្រើប្រាស់ទារុណកម្ម ដើម្បីទទួលបានចម្លើយសារភាពពីអ្នកជាប់ឃុំ ដែលដូច្នេះហើយមូលហេតុក្នុងការបង្អាក់ ដែលជា

---

[431] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 ម៉ោង 09:49:21-09:51:24។

[432] RICHARD A. POSNER ព្រំដែននៃទ្រឹស្តីច្បាប់ ទំព័រ ៣៩៥ (Harvard University Press ឆ្នាំ ២០០៤)។ នៅ ស.រ.អ.មានវិធានលើកលែងជាង ២៥ វិធាន រួមទាំងវិធានលើកលែងដែលនៅសល់ ចំពោះវិធានពាក្យចចាមអារ៉ាម។ *សូមមើល* វិធាន ៨០៣ វិធាន ៨០៧ នៃវិធាននៃភស្តុតាងសហព័ន្ធ ស.រ.អ.។

[433] *រឿងក្តី Korematsu តទល់នឹង សហរដ្ឋអាមេរិក* ៣២៣ ស.រ.អ. ទំព័រ ២១៤, ២៤៦ (ឆ្នាំ ១៩៤៤) មតិជំទាស់របស់ចៅក្រម Jackson។

មូលដ្ឋាននៃការហាមឃាត់ការប្រើប្រាស់ភស្តុតាងដែលទទួលបាន ដោយការធ្វើទារុណកម្ម គឺមានសារសំខាន់យ៉ាងខ្លាំង[434]។

១៦៤. កំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបាន ដោយការប្រើប្រាស់ចម្លើយសារភាពនៅមន្ទីរ ស-២១ ធ្វើជាតម្រុយស៊ើបអង្កេត និង កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលទាញចេញពីភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម គឺមិនត្រូវយកមកធ្វើជាមូលដ្ឋានឡើយ។ ខ្លឹមសារនៃចម្លើយសារភាពនៅមន្ទីរ ស-២១ មិនអាចជាមូលដ្ឋាន សម្រាប់កំណត់អង្គហេតុអ្វីផ្សេង ក្រៅពីការពិតនៃខ្លឹមសាររបស់ចម្លើយសារភាពនោះឡើយ។ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនមានការលើកលែងចំពោះការប្រើប្រាស់ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ឬ ភស្តុតាងដែលកើតចេញពីភស្តុតាងទទួលបានពីការធ្វើទារុណកម្មបែបនេះឡើយ។ តាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ការប្រើប្រាស់ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម *លែ*ងតែ *មួយគត់* ដែលត្រូវបានអនុញ្ញាត គឺការយកមកប្រើប្រាស់ជាភស្តុតាងប្រឆាំងបុគ្គល ដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម ក្នុងនាមជាភស្តុតាងបង្ហាញថា ចម្លើយនោះ ត្រូវបានធ្វើឡើងដោយទារុណកម្ម។

IV. មាស មុត មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ហើយក៏មិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ

១៦៥. មាស មុត មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្ត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ គាត់មិនមានតួនាទីណាមួយនៅក្នុង ប.ក.ក. ឬ របបកម្ពុជាប្រជាធិបតេយ្យ ដែលផ្តល់ឱ្យគាត់នូវសិទ្ធិអំណាច ឬ ការទទួលខុសត្រូវនៅទូទាំងប្រទេសឡើយ។ សិទ្ធិអំណាចដែលគាត់អាចមាន គឺកម្រិតនៅត្រឹមតែកងពលធំ ១៦៤ បញ្ជាកងទ័ពជើងទឹកនៅតាមតំបន់ដីគោក និង ផ្នែកំពង់សោម និងនៅក្នុងរយៈពេលពីរខែចុងក្រោយនៃរបប គឺលើបញ្ជាកងទ័ពនៅក្នុងតំបន់ ៥០៥។ សិទ្ធិអំណាចបែបនេះត្រូវបានប្រើប្រាស់ យោងទៅតាមបទបញ្ជា និង ការណែនាំ ដែលចេញដោយគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍ រួមទាំងអគ្គសេនាធិការ។ គោលជំហរ

---

[434] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ) សំណើរបស់ CCHR ស្នើដាក់សារណារបស់អ្នកដែលមិនមែនជាភាគី អនុលោមតាម វិធាន ៣៣ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ D253.1.1 កថាខណ្ឌ ២៦ កថាខណ្ឌ ២៨។

របស់សហព្រះរាជអាជ្ញាជាតិ ("ស.ព.ជ.") គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាដែលថា មាស មុត មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ហើយក៏មិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលខុសពី នួន ជា[435] អៀង សារី[436] ខៀវ សំផន[437] អៀង ធីរិទ្ធ[438] និង ឌុច[439]។ ស.ព.ជ. មានឱកាស ក្នុងការធ្វើការស៊ើបអង្កេតបឋម ហើយមានសិទ្ធិចូលពិនិត្យភស្តុតាងក្នុងរឿងក្តី ០០៣ តាំងពីឆ្នាំ ២០០៨ ឬក៏អាចមុនពេលនោះទៀតផង[440]។ មិនមានហេតុផលអ្វីដែលធ្វើឱ្យគិតថា ស.ព.ជ. មិនបានពិនិត្យមើលភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង មុនពេលឈានដល់ការសម្រេចរបស់គាត់នោះឡើយ[441]។ ការត្រួតពិនិត្យដោយមិនលម្អៀង និង ដោយម៉ត់ចត់ទៅលើភស្តុតាង គាំទ្រដល់គោលជំហររបស់ ស.ព.ជ. ដែលថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលទៅលើ មាស មុត។

១៦៦. បន្ថែមលើគោលការណ៍ទូទៅនៃភស្តុតាង ដែលត្រូវបានពិភាក្សានៅក្នុងផ្នែក III. ឃ នៅពេលធ្វើការវាយតម្លៃទៅលើភស្តុតាង ស.ច.ស. ចាំបាច់ត្រូវពិចារណាទៅលើបរិបទល្អចលាក់ជាសម្ងាត់ ដែល ប.ក.ក. បានប្រតិបត្តិការ។ តាមលក្ខន្តិក: ភារកិច្ចរបស់សមាជិកបក្ស គឺ "ខិតខំរក្សាការសម្ងាត់របស់បក្សជាដាច់ខាត ដោយមានគោលជំហរប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ច"[442]។ ហេតុដូច្នេះ

---

[435] នួន ជា ជាមេដឹកនាំជាន់ខ្ពស់ និង ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ព្រោះគាត់ជាអនុលេខា ប.ក.ក. ជាសមាជិកអចិន្ត្រៃយ៍នៃ ប.ក.ក. និង ជាប្រធានសភាដំណាងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ ហើយមានតួនាទីផ្សេងៗទៀត។ ដីកាសន្និដ្ឋានស្តាពរទាក់ទងករណី មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៧ ("ដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ.") ឯកសារ D256/6 កថាខណ្ឌ ៣០។

[436] អៀង សារី ជាមេដឹកនាំជាន់ខ្ពស់ និង ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ព្រោះគាត់ជាសមាជិកអចិន្ត្រៃយ៍នៃ ប.ក.ក. និង ជាឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស ហើយមានតួនាទីផ្សេងៗទៀត។ កថាខណ្ឌ ៣០ នៃដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ.។

[437] ខៀវ សំផន ជាមេដឹកនាំជាន់ខ្ពស់ និង ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ព្រោះគាត់ជាប្រមុខរដ្ឋ ជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក. ហើយមានតួនាទីផ្សេងៗទៀត។ កថាខណ្ឌ ៣០ នៃដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ.។

[438] អៀង ធីរិទ្ធ ជាមេដឹកនាំជាន់ខ្ពស់ និង ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ព្រោះគាត់ជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក និង ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ហើយមានតួនាទីផ្សេងៗទៀត។ កថាខណ្ឌ ៣០ នៃដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ.។

[439] ឌុច ជាមេដឹកនាំជាន់ខ្ពស់ និង ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ព្រោះគាត់ជាប្រធានមន្ទីរសន្តិសុខ ស-២១ "ដែលមានចរិកលក្ខណៈពិសេសជាងគេ" ហើយមានភារកិច្ចផ្សេងៗទៀត។ កថាខណ្ឌ ៣០ នៃដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ.។

[440] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកទី ២ របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 កថាខណ្ឌ ៨។

[441] កថាខណ្ឌ ២៦, ៣១, ៣៥ នៃដីកាសន្និដ្ឋានស្តាពររបស់ ស.ព.ជ.។

[442] មាត្រា ២.២.ង នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។

ប.ក.ក. បានអនុវត្ត "គោលនយោបាយរក្សាការសម្ងាត់ខ្ពស់"[443] ដែលតាមរយៈគោលនយោបាយនេះ គេប្រាប់ត្រឹមតែអ្វីដែលចាំបាច់ត្រូវដឹង ដើម្បីអនុវត្តការងាររបស់ពួកគេ និង គិតគូរតែពីខ្លួនឯង និង ការងារផ្ទាល់ខ្លួនប៉ុណ្ណោះ[444]។ អតីតសមាជិកកងពលធំលេខ ៨០១ បានរៀបរាប់ពីរបបនេះថា

---

[443] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.2 ម៉ោង 15.23.55-15.29.37 (បណ្ឌិត Craig Etcheson អតីតអ្នកវិភាគ ក.ស.ព. បានផ្តល់សក្ខីកម្មថា៖ "លក្ខណៈពិសេសមួយដែលយើងបានកត់សម្គាល់ឃើញអំពីបក្សកុម្មុយនីស្តកម្ពុជា ហើយនិងការទាក់ទងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានោះគឺថា ពួកគេមាននយោបាយដ៏តឹងរ៉ឹងបំផុតមួយទាក់ទងទៅនឹងភាពសម្ងាត់សម្រាប់ទៅលើប្រធានបទជាច្រើន ហើយជាការពិតណាស់ដូចជាសម្រាប់រយៈពេលពីរឆ្នាំកន្លះ ដែលថារដ្ឋនេះបានឡើងកាន់អំណាចនោះគឺថា ពួកគេបានបដិសេធមិនព្រមទទួលស្គាល់ថា បក្សកុម្មុយនីស្តកម្ពុជាហ្នឹងគឺថាមានអាទិភាពទេ។ នេះជាការធ្វើដើម្បីរក្សាទុកវត្ថុភាពសម្ងាត់របស់ខ្លួនឯងដែលមិនដែលមានទេនៅក្នុងប្រវត្តិសាស្ត្រពីមុនមកទាក់ទងទៅនឹងបក្សកុម្មុយនីស្ត។ ហើយដូច្នេះជាការមួយធ្វើឱ្យភ្ញាក់ផ្អើលបំផុតនៅពេលដែលយើងពិនិត្យមើល បើប្រៀបធៀបទៅនឹងបក្សកុម្មុយនីស្តដទៃទៀតនៅលើពិភពលោក")។

[444] *រឿងក្តី ន្ឃួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/297.1.40 ម៉ោង 09:46:35-09:50:25 (អៀង ងាន បានផ្តល់សក្ខីកម្មថា នៅកម្ពុជាប្រជាធិបតេយ្យសម័យនោះ លាក់ការណ៍ដឹកនាំជាសំខាន់។ ការងារគាត់ៗដឹង ការងារអ្នកនោះ មេគឺមេដឹងហើយ។ ដល់អីចឹងគេៗបែងចែកច្បាស់ណាស់ ការងារណាត្រូវឱ្យខាងក្រោមដឹង ការងារណាថ្នាក់លើដឹង គឺមានការបែងចែកច្បាស់លាស់ណាស់ មិនមែនចេះតែចម្លងជូនទូទៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែវ រឹម ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/180 អ. ៣០-៣១ (គាត់នៅអង្គភាពផ្សេងពីអ្នកដែលជិះកប៉ាល់ PCF ដូច្នេះ គាត់មិនបានដឹងថាពួកគេបានទទួលបញ្ជាអ្វីទេ។ ពួកគេដឹងតែពីធ្វើការងាររបស់ពួកគេប៉ុណ្ណោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៀង គុយ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/119 អ.៩ (សមាជិកក្រុមរកត្រីរបស់ ឡូញ ម្នាក់បាននិយាយថា ដោយពួកគេដឹងថាអាចមានគ្រោះថ្នាក់ ពួកគេកម្របាននិយាយរកគ្នា ឬ សួរនាំអ្នកដទៃថាពួកគេបានឃើញ ឬ ឮអ្វីខ្លះនោះទេ ដូច្នេះហើយពួកគេផ្តោតអារម្មណ៍តែទៅលើការងារដែលគេចាត់តាំងឱ្យពួកគេធ្វើប៉ុណ្ណោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 អ.៨ (គាត់ធ្វើការងារតាមកន្លែងរៀងៗខ្លួន ហើយការងារផ្សេងទៀតមិនបានដឹងទេ)។ អ.១០ (គាត់មិនដឹងទេថា ក្រុមរបស់គាត់ហ្នឹងមិនដឹងថាមានប៉ុន្មាននាក់ផង)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D4.1.1118 EN 00195602 KH 00195594 ("ន្ឃួន ជា បានឆ្លើយតបមកខ្ញុំថា "*មិត្តអើយ ថ្នាក់មូលដ្ឋាន គេចេះធ្វើការងារគេហើយ*" ដែលមានន័យថា "*ធ្វើតែការងារខ្លួនឯងទៅ ហើយកុំរវល់ពីរឿងអ្នកដទៃ*" ស្របតាមមាគ៌ានយោបាយនៃការរក្សាការសម្ងាត់៖ ម្នាក់ៗមានការងារផ្ទាល់រៀងខ្លួន (ជាអ្វីដែលគេហៅថា "មាគ៌ាសកម្មភាព")")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/245 អ.៤០ (" គឺដឹងតែការងារអ្នកណាធ្វើ អ្នកនោះដឹង។ នេះជាគោលការណ៍របស់ខ្ញុំ។ អ្វីដែលត្រូវនិយាយ អ្វីដែលមិនត្រូវនិយាយ។ គេមិនឱ្យខ្ញុំដឹង ឬឃើញអ្វីក្រៅពីការងាររបស់ខ្លួនទេ")។ *រឿងក្តី ន្ឃួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៣ ឯកសារ D98/3.1.20 ម៉ោង 14:28.06 (អោម សែ ប្រធានសន្តិសុខកងពល ៨០១៖ "[ចំពោះ]ដែលខ្ញុំបាទនេះដែលវាក្នុងហានៈដឹកនាំមានកម្រិតទាប មិនសូវជាដឹងសាច់រឿងនេះទេ រឿងជ្រាលជ្រៅអីចេះ វាមិនសូវឃើញជាក់ស្តែងទេ គិតតែពីរឿងបំពេញករណីយកិច្ចសម្រាប់ខ្លួនឯង ដើម្បីកុំឱ្យគេប្រកាន់ថ្នាក់ក្នុងការដឹកនាំដែល

ជា "គុកឥតជញ្ជាំង"[445]។ នៅក្នុងបរិយាកាសបែបនេះ ការដឹងឮរបស់សាក្សី គឺមានកម្រិតត្រឹមតែកងរបស់គាត់ និង ភារកិច្ចផ្តាល់របស់គាត់ប៉ុណ្ណោះ។ ដូចដែល ស.ច.ស. បានសម្រេច "ការប្រើប្រាស់ទូលំទូលាយ នូវប្រព័ន្ធទំនាក់ទំនងខ្សែបណ្តោយ នៅក្នុងខ្សែចង្វាក់នៃការបញ្ជា និង គោលការណ៍រក្សាការសម្ងាត់ជាប់មកជាមួយ ដែលជាទូទៅពុំអនុញ្ញាត ឬ យ៉ាងហោចណាស់ពុំលើកទឹកចិត្ត ឬ ជួយសម្រួលដល់ការផ្តាស់ប្តូរព័ត៌មានយុទ្ធសាស្ត្រ និង ប្រតិបត្តិតាមលក្ខណៈសមភាពនៃខ្សែទទឹង នៅតាមថ្នាក់ក្រោមៗនៃការដឹកនាំថ្នាក់លើ"[446]។ ស.ច.ស. ចាំបាច់ត្រូវពិនិត្យមើល ដោយភាពមិនជឿជាក់ទាំងស្រុង និង ដោយមានការប្រុងប្រយ័ត្ន ទៅលើការអះអាងទាំងឡាយណារបស់សាក្សី ដែលថាបានដឹងឮលម្អិត អំពីបញ្ហាដែលស្ថិតនៅក្រៅដែនកម្រិតកំណត់របស់គាត់។

ក. មាស មុត មិនមែនជាមេដឹកនាំជាន់ខ្ពស់ នៅក្នុង ប.ក.ក. ឬ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

១៦៧. ស.ព.អ. ទៅហួសឆ្ងាយ ក្នុងការអះអាងថា មាស មុត គឺជាមេដឹកនាំជាន់ខ្ពស់នៅក្នុង ប.ក.ក. ឬ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ សូម្បីតែក្នុងករណីដែលពិនិត្យមើល ដោយលម្អៀងបំផុតទៅខាង ស.ព.អ. ក៏ដោយ ក៏ភស្តុតាងមិនបានបង្ហាញថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់" ដែរ។ ស.ព.អ.៖ **ក.** ពឹងផ្អែកលើសាក្សីដែលចម្លើយរបស់ពួកគេ មានមូលដ្ឋានលើពាក្យចចាមអារ៉ាម ឬ ការទាយស្មាន ឬ ដែលត្រូវបានធ្វើឱ្យខូច **ខ.** ដកស្រង់ចម្លើយរបស់សាក្សី និង ភស្តុតាងជាឯកសារដែលមិនគាំទ្រដល់ការអះអាងរបស់គាត់ **គ.** មិនបានពិចារណាលើភស្តុតាងបរិបទ និង ភស្តុតាងរចនាសម្ព័ន្ធពាក់ព័ន្ធ **ឃ.** លើកបង្ហាញភស្តុតាងដោយមិនត្រឹមត្រូវ។ មាស មុត មិនមែនជាសមាជិក ដែលចូលរួមក្នុងគណៈកម្មាធិការបក្សកម្រិតខ្ពស់បំផុតឡើយ ហើយគាត់ក៏មិនមែនជាអនុលេខាអគ្គសេនាធិការ ឬ ជាសមាជិក គណៈកម្មាធិការអគ្គសេនាធិការនោះដែរ។ គាត់មិនមានសិទ្ធិអំណាចទាំងស្រុងទៅលើកងពលធំលេខ ១៦៤ ឬ កងទ័ពជើងទឹកឡើយ។ គាត់មិនមែនជាលេខា ឬ អាជ្ញាធរខ្ពស់បំផុតនៅតំបន់ស្វយ័តកំពង់សោមឡើយ។ មាស មុត មិនមែនជា "មេដឹកនាំជាន់ខ្ពស់" នោះទេ។

វាមិនពិតប្រាកដ។ អាហ្នឹងជាជំហរពង្រឹងតែខ្លួនឯងទេ ដើម្បីការពារផលប្រយោជន៍ ...។ អ៊ីចឹងបានថាកិច្ចការងារ វាដឹង តែឱ្យជ្រៅ ឱ្យសព្វឱ្យគ្រប់ ខ្ញុំបាទមិនបានទទួលសព្វគ្រប់ទេបាទ")។

[445] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិត ប៊ឿន ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/183 ន.១៣៤៖ "អត់។ ជំនាន់នោះ គេមិនឱ្យដើរហើរនោះទេ។ គុកឥតជញ្ជាំង។ គេខណ្ឌកន្លែងណានៅកន្លែងនោះ ដល់អ៊ីចឹងយើងម៉េចស្គាល់។ ធ្វើការដឹងតែធ្វើហើយ"។

[446] កថាខណ្ឌ ៤១ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

១. មាស មុត មិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍

១៦៨. មាសមុត មិនធ្លាប់ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយក៏មិនបានចូលរួមនៅក្នុងសកម្មភាពរបស់គណៈកម្មាធិការនេះដែរ ស.ព.អ. ក៏មិនបានអះអាងថា មាស មុត មានតួនាទីបែបនេះដែរ។

១៦៩. គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាស្ថាប័នដែលមានអំណាចបំផុត នៅក្នុង ប.ក.ក. ដែលបង្កើតមាគ៌ានយោបាយ និង ធ្វើសេចក្តីសម្រេចរបស់បក្ស[447]។ លក្ខណៈជាវរជនរបស់គណៈកម្មាធិការនេះត្រូវបានបង្ហាញតាមរយៈការណ៍ដែលថា គណៈកម្មាធិការនេះមានសមាជិកត្រឹមតែចំនួនប្រាំពីររូបប៉ុណ្ណោះ៖ ប៉ុល ពត ន្ឋន ជា អៀង សារី តាម៉ុក សោ ភឹម វន វ៉ែត និង សុន សេន[448]។

១៧០. ក្នុងចំណោមសមាជិកទាំងអស់នោះ ប៉ុល ពត តាម៉ុក និង សុន សេន មានអំណាចខ្លាំងជាងគេទាក់ទងនឹងបញ្ហាកងទ័ព[449]។ តាម៉ុកត្រូវបានគេរៀបរាប់ថា ជាមេដឹកនាំជាន់ខ្ពស់ដែលមានអំណាច

---

[447] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27. EN 00183396 KH 00019112-00019113 (គណៈកម្មាធិការអចិន្ត្រៃយ៍តាមដានការអនុវត្តមាគ៌ានៅផ្នែកនីមួយៗ)។ កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 EN 00156750 KH 00156619។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.6 ម៉ោង 14:06:44-14:13:29 (បណ្ឌិត Etcheson បានផ្តល់សក្ខីកម្មថា អំណាចពិតប្រាកដ និង អ្នកដែលមានអំណាចពិតប្រាកដនៅក្នុង ប.ក.ក. គឺមាននៅជាមួយនឹងគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិម នោះគឺជាហេតុផលដែលនាំឱ្យលោកជឿថា សេចក្តីសម្រេចរបស់គណៈមជ្ឈិម ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ បានផ្តល់សិទ្ធិសម្រេចក្នុងការកម្ទេច គឺផ្តល់ទៅឱ្យស្ថាប័នរបស់បក្សដទៃទៀតដែលចេញមកពីគណៈអចិន្ត្រៃយ៍ មិនមែនចេញពីគណៈមជ្ឈិមនោះទេ)។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.7 ម៉ោង 14:19:57-14:28:09, 15:29:53-15:36:00 (បណ្ឌិត Etcheson បានផ្តល់សក្ខីកម្មថា គណៈអចិន្ត្រៃយ៍ជាអ្នកកំណត់គោលនយោបាយ)។ *សូមមើលផងដែរ* កថាខណ្ឌ ២០៣ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[448] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 EN 00156750 KH 00156619។ កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច របស់តុលាការយោធាកម្ពុជា ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7 EN 00184829 KH 00089673-00089674 ("[តាម] ការរៀនសូត្រខ្លះ ខ្ញុំ")។ *សូមមើលផងដែរ* កថាខណ្ឌ ២០៣ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[449] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 EN 00156750 KH 00156619។ កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច របស់តុលាការយោធាកម្ពុជា ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7 EN 00184829 KH 00089673-00089674។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.៤, ឆ.២៤។

បំផុតរបស់ ប.ក.ក.។ មាស រឿន មេបញ្ជាការរងកងពលធំលេខ ១[450] បានរៀបរាប់ថា តាម៉ុក គឺជាអគ្គមេបញ្ជាការកងទ័ព ដែលមានអំណាចខ្លាំងជា សុន សេន ទៅទៀត ដោយតាម៉ុកមានអំណាចចេញបញ្ជាទៅកងណាមួយក៏បាន[451]។ តាម៉ុកមានសិទ្ធិអំណាចបញ្ជា នៅក្នុងបញ្ជាកងទ័ពជើងទឹក ដូចដែលបានបង្ហាញក្នុងរបាយការណ៍របស់ សុន សេន ផ្ញើជូនអង្គការដែលថា តាម៉ុកបានធ្វើការវាយតម្លៃទៅលើកប៉ាល់វៀតណាម ដែលបានចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ នៅជិតកោះតូច[452]។ តាម៉ុកអាចចេញបញ្ជា និង អនុវត្តសេចក្តីសម្រេច នៅគ្រប់ផ្នែកទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ[453]។ សិទ្ធិអំណាចរបស់គាត់ត្រូវបានឆ្លុះបញ្ចាំង តាមរយៈពាក្យស្លោកដែលចង្អុលបង្ហាញពីកម្រិតនៃអំណាចរបស់គាត់៖ លើក្បាលម៉ុកមានម្លូក នៅលើម្លូកមានមេឃ[454]។ មិនមាននរណាអាចត្រួតលើគាត់ទេ[455]។

---

[450] *រឿងក្តី ន្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 ម៉ោង 09:56:40-09:59:40។

[451] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.២៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.១។ *រឿងក្តី ន្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 ម៉ោង 13:50:04-13:53:04។ *រឿងក្តី ន្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.180 ម៉ោង 09:54:33-09:57:36។

[452] របាយការណ៍ ចំណងជើងថា "របាយការណ៍ពី មាស មុត ផ្ញើជូន សុន សេន ទាក់ទងនឹងស្ថានភាពនៅតាមបណ្តោយព្រំដែនថៃ" ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.18 EN 00233992-00233993 KH 00162487។

[453] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D4.1.851 ឆ.១២ (ក្នុងឆ្នាំ ១៩៧៨ ក្រោយពី មាស រឿន បានទៅខេត្តព្រះវិហារបានរយៈពេលប្រហែលពីរខែ ទើបតា ម៉ុក បានបញ្ជាឱ្យដកតា ឃីម ចេញពីគណៈតំបន់ ១០៣ ដោយចាត់កម្លាំងរបស់គាត់ឱ្យទៅដឹកតាមឃីមពីខេត្តព្រះវិហារមក)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/76 ឆ.២០-២១ (ក្នុងឆ្នាំ ១៩៧៧ តា ម៉ុក បានមកប្រជុំក្នុងតំបន់ ៣៧ អំពីការបោសសម្អាតវរសេនាតូច ៣៨៦ និង យោធាភូមិភាគបូព៌ា)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សក់ ស៊ីម ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/222 ឆ.២៨-២៩ (កងពល ៨០១ ឈរជើងនៅខេត្តរតនៈគិរី ភូមិភាគឦសាន តែប្រធានកងពលទទួលបញ្ជាពី តា ម៉ុក នៅខេត្តកំពត ភូមិភាគនិរតី)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជីម ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D98/3.1.207 ឆ.៩ (បន្ថែមលើតួនាទីជាលេខាភូមិភាគនិរតី តា ម៉ុក គ្រប់គ្រងភូមិភាគពាយ័ព្យ ភូមិភាគឧត្តរ និង ភូមិភាគកណ្តាល ក្រោយពីមានសភាពការណ៍ច្របូកច្របល់ក្នុងឆ្នាំ ១៩៧៨)។

[454] *រឿងក្តី ន្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/297.1.40 ម៉ោង 10:40:12-10:45:47 (អៀង ផាន បានផ្តល់សក្ខីកម្មថា ប្រជាជននិយាយថា លើក្បាល ម៉ុក មានម្លូក នៅលើម្លូកមានមេឃ អីចឹងមាននរណាត្រួត ម៉ុក ទៀតទេ)។ *រឿងក្តី ន្លួន ជា និង អ្នកផ្សេងទៀត*

១៧១. សុន សេន ក៏មានមុខដំណែងប្រកបដោយអំណាចដែរ នៅក្នុង ប.ក.ក. រដ្ឋាភិបាល និង កងទ័ព។ ដូចដែលបណ្ឌិត Craig Etcheson អតីតអ្នកវិភាគរបស់ ក.ស.ព. បានផ្តល់សក្ខីកម្មថា៖ "សុន សេន ជាតួនាទីដែលមានអំណាចរបស់ខ្លួន នៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ គឺថាបង្ហាញដោយមុខដំណែងដែលមានអំណាចពីរជាប់គ្នា នៅក្នុងរដ្ឋាភិបាល និង យោធា ហើយនិងនៅក្នុងបក្សផងដែរ"[456]។ នៅក្នុងរដ្ឋាភិបាល សុន សេន ធ្លាប់ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងការពារជាតិ។ នៅក្នុងកងទ័ព គាត់គឺជានាយអគ្គសេនាធិការនៃសេនាធិការរបស់កងទ័ព ហើយនៅក្នុងបក្ស គាត់គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍[457]។ សុន សេន គឺជាមេដឹកនាំជាន់ខ្ពស់បំផុតម្នាក់របស់ ប.ក.ក. ពាក់ព័ន្ធការងារផែនការកងទ័ព[458]។

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៣ ឯកសារ D98/3.1.28 ម៉ោង 11:19:52-11:24:21 (ឈូក រិន បានផ្តល់សក្ខីកម្មថា តា ម៉ុក ប្រើពាក្យស្លោក "នៅពីលើ ម៉ុក មានតែមួកទេ" ដែលមានន័យថា គាត់អាចចេញបញ្ជាទៅឱ្យយោធានៅទីកន្លែងណាក៏បាន)។

[455] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/297.1.40 ម៉ោង 10:40:12-10:45:47។

[456] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.1 ម៉ោង 16:08:18-16:15:54។

[457] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.1 ម៉ោង 16:08:18-16:15:54។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០០៩ ឯកសារ D4.1.618 EN 00483968 KH 00294539 (សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រែង ធី ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/199 ន.២២ (អគ្គសេនាធិការជាស្តាប់ខ្ពស់បំផុតរបស់យោធា) ន.២៦ (សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារប្រទេស)។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/277.8 ម៉ោង 09:54:40-09:58:07 (ឌុច និយាយថា សុន សេន ជាឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការពារជាតិ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អ៊ាន ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ D114/258 ន.២០ (សុន សេន ជាប្រធានយោធា និង ទទួលបន្ទុកក្រសួងការពារជាតិ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ន.៦៧ (សុន សេន ទទួលបន្ទុកអគ្គសេនាធិការ ដែលគ្រប់គ្រងកងពលលេខ ៣) ន.៨១-៨២ (ប៉ុល ពត បានចេញបញ្ជាឱ្យបង្កើតកងទ័ពជើងទឹក ហើយបានចេញបញ្ជាទៅក្រសួងការពារជាតិ ដែលបានចេញបញ្ជាបន្តទៅថ្នាក់កងពល)។

[458] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ន.១២។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D98/3.1.56 ម៉ោង 14:34:36-14:38:25 (អៀង ផាន បានថ្លែងថា មានតែ ប៉ុល ពត និង សុន សេន ប៉ុណ្ណោះ

១៧២. ប៉ុល ពត តាម៉ុក និង សុន សេន បានត្រួតពិនិត្យមើលលើការងារកងទ័ពសម្រាប់ ប.ក.ក. តាមរយៈគណៈយោធា[459]។ គណៈយោធា គឺជាអនុគណៈកម្មាធិការនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលដឹកនាំដោយ ប៉ុល ពត ដែលមានភារកិច្ចទទួលខុសត្រូវលើគោលនយោបាយសន្តិសុខ និង កងទ័ពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[460]។ គណៈយោធាគ្រប់គ្រងទៅលើកងពលធំមជ្ឈិម និង កងវរសេនាធំឯករាជ្យ តាមរយៈអគ្គសេនាធិការ ហើយបានអនុវត្តន៍នូវរបបរាយការណ៍ដែលតឹងរ៉ឹង[461]។ របាយការណ៍ និង សំណើ ត្រូវបានបញ្ជូនទៅគណៈយោធា តាមរយៈមន្ទីរ ៨៧០ ដែលអាចចេញបញ្ជាទៅគ្រប់ថ្នាក់ទាំងអស់នៃរដ្ឋាភិបាល ទាំងផ្នែកនយោបាយ និង ផ្នែកកងទ័ព[462]។ ចំពោះគណៈអចិន្ត្រៃយ៍វិញ មិនមានភស្តុតាងដែលបង្ហាញថា មាស មុត ធ្លាប់ជាសមាជិកនៃគណៈយោធាទេ ហើយ ស.ព.អ. ក៏មិនបានអះអាងថាគាត់មានតួនាទីបែបនេះដែរ។

ដែលកាន់ខាងយោធា)។ *សូមមើលផងដែរ* កថាខណ្ឌ ២០៤ នៃសាលក្រមក្នុងរឿងក្តី ០០២/០១ (ដែលបានរកឃើញថា ប៉ុល ពត ជាប្រធានគណៈកម្មាធិការយោធា ហើយ សុន សេន ជាសមាជិក)។

[459] របាយការណ៍អ្នកជំនាញការ Craig Etcheson ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ ឯកសារ D234/2.1.52 កថាខណ្ឌ ៩៩-១០០។ កំណត់ហេតុសួរចម្លើយជនសង្ស័យ អៀង សារី ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៦ ឯកសារ D4.1.964 EN 00417637-0417638 KH 00062500-00062503។ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ឌួន ជា ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ ឯកសារ D114/29.1.12 EN00148817 KH 00148743-00148744។

[460] *រឿងក្តី ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១២ ឯកសារ D98/3.1.133 ម៉ោង 11:14:32-11:16:36 (ឌួន ជា បានផ្តល់សក្ខីកម្មថា ប៉ុល ពត ជាប្រធានគណៈយោធា)។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.7 ម៉ោង 14:19:57-14:28:09 (ប៉ុល ពត ជាប្រធានគណៈយោធាមជ្ឈិម) ម៉ោង 14:19:57-14:28:09 (បណ្ឌិត Etcheson បានផ្តល់សក្ខីកម្មថា គណៈយោធាមជ្ឈិមជាអ្នកបង្កើតគោលនយោបាយ និង កំណត់គោលនយោបាយ)។ របាយការណ៍អ្នកជំនាញការ Craig Etcheson ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ ឯកសារ D234/2.1.52 កថាខណ្ឌ ១០៦។ *សូមមើលផងដែរ* កថាខណ្ឌ ២០៤ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[461] *សូមមើល* កថាខណ្ឌ ២១៣ *ខាងក្រោម*។

[462] *សូមមើល* សេចក្តីណែនាំរបស់គណៈមជ្ឈិមពីមន្ទីរ ៨៧០ ចំណងជើងថា "សេចក្តីណែនាំពី ៨៧០" ចុះថ្ងៃទី ៣ ខែមករា ឆ្នាំ ១៩៧៩ ឯកសារ D1.3.34.78 EN 00182799-00182803 KH 00002978-00002981 ។ របាយការណ៍អ្នកជំនាញការ Craig Etcheson ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ ឯកសារ D234/2.1.52 កថាខណ្ឌ ១០១។

២. មាស មុត មិនធ្លាប់ជាសមាជិកគណៈកម្មាធិការមជ្ឈិម

១៧៣. ប្រភពដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត ធ្លាប់ជាសមាជិកគណៈកម្មាធិការមជ្ឈិមឡើយ[463]។ ស.ព.អ. ដកស្រង់យកតែចម្លើយដែលមិនអាចជឿជាក់បានពី ខៀវ សំផន និង ឌុច។ សំខាន់បំផុតនោះ ចម្លើយរបស់ពួកគេ គឺមានភាពមិនច្បាស់លាស់ ទាក់ទងនឹងការចូលរួមរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម ហើយចម្លើយទាំងនោះមិនបានកំណត់ថា គាត់ធ្លាប់មានតួនាទីចូលរួមណាមួយ នៅក្នុងស្ថាប័ននេះឡើយ។

១៧៤. **ខៀវ សំផន៖** ខៀវ សំផន មានតួនាទីនិមិត្តរូប ជាប្រធាននៃគណៈប្រធានរដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ[464] ហើយបានអះអាងថា ចាប់ពីឆ្នាំ ១៩៧៦ មក គាត់គឺជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម[465]។ គាត់មិនបានចូលរួមពាក់ព័ន្ធជាមួយកិច្ចការកងទ័ពនោះទេ[466]។ គាត់បានអះអាងថា មេបញ្ជាការកងពល ដូចជា មាស មុត ជាដើម គឺជាសមាជិកគណៈមជ្ឈិម[467]។ ខៀវ សំផន មិនបានបង្ហាញថា គាត់ដឹងដោយរបៀបណា ឬ នៅពេលណានោះទេ ហើយគាត់ក៏មិនបានបង្ហាញថា សមាជិកភាពនេះមានសិទ្ធិអ្វីខ្លះ ឬ ថាតើមេបញ្ជាការកងពលធំ អាចចូលរួមក្នុងការពិភាក្សា ឬ ធ្វើសេចក្តីសម្រេចក្នុងគណៈកម្មាធិការនេះ ក្នុងកម្រិតណានោះឡើយ។ គាត់មិនបាននិយាយថា មាស មុត មានសិទ្ធិអំណាច ឬសមត្ថភាព ក្នុងការចូលរួមកិច្ចប្រជុំ កិច្ចពិភាក្សា ឬ ការសម្រេច ក្នុងគណៈមជ្ឈិមឡើយ។ គណៈមជ្ឈិមដែលមានអំណាចតិចជាងគណៈកម្មាធិការអចិន្ត្រៃយ៍[468] មានសមាជិក

---

[463] កថាខណ្ឌ ៤៩-៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[464] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ D98/1.2.42 ម៉ោង 15:21:27-15:24:51 (David Chandler បានផ្តល់សក្ខីកម្មថា តួនាទីនេះ មិនស្មើទៅនឹងមនុស្សផ្សេងទៀតដែលអនុវត្តអំណាចនៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ)។ *សូមមើលផងដែរ* កថាខណ្ឌ ៣៨១ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[465] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 EN 00156751 KH 00156619-00156620។

[466] កថាខណ្ឌ ៣៧៨ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[467] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 EN 00156751 KH 00156619-00156620។ កថាខណ្ឌ ៤៩ នៃដីកាសន្និដ្ឋានស្តាពរ។

[468] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 EN 00156751 KH 00156619។ *សូមមើល* កថាខណ្ឌ ១៦៩ *ខាងលើ* ពាក់ព័ន្ធនឹងគណៈកម្មាធិការអចិន្ត្រៃយ៍។ តាមលក្ខន្តិក: គណៈកម្មាធិការ

យ៉ាងហោចណាស់ក៏ ២០ ទៅ ៣០នាក់ដែរ[469] រួមទាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ផង[470]។ មិនមានកំណត់ហេតុកិច្ចប្រជុំគណៈមជ្ឈិម ឬ ឯកសារបក្សណាមួយដែលចង្អុលបង្ហាញថា មាស មុត ធ្លាប់ជាសមាជិកគណៈកម្មាធិការ ឬ បានចូលរួមក្នុងកិច្ចប្រជុំណាមួយឡើយ។ ការអះអាងរបស់ ខៀវ សំផន មិនត្រូវបានគាំទ្រដោយភស្តុតាងផ្សេងទៀតឡើយ។

១៧៥. **ឌុច៖** ឌុច ដែលជាប្រធានមន្ទីរ ស-២១ ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩[471] គឺមិនអាចជឿជាក់បានឡើយ ពាក់ព័ន្ធបញ្ហាណាមួយក្រៅពីមន្ទីរ ស-២១។ គាត់បានអះអាងថា បានដឹងថា មាស មុត គឺជាជំនួយការគណៈមជ្ឈិម[472] ប៉ុន្តែគាត់បានទទួលស្គាល់ថា សកម្មភាពរបស់គាត់ គឺមានកម្រិតត្រឹមតែនៅមន្ទីរ ស-២១ ប៉ុណ្ណោះ[473] ហើយការដើរហើរ និង ការដឹងឮរបស់គាត់ មានកម្រិតត្រឹមតែក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ[474]។ អ្វីៗដែលបានកើតឡើងនៅក្រៅមន្ទីរ ស-២១ គឺមិនមែនជាការងាររបស់គាត់ឡើយ[475]។ ដោយសារតែគាត់នៅ “ថ្នាក់ក្រោម” គាត់មិនទទួលបានព័ត៌មានពេញលេញអំពីហេតុការណ៍ទាំងនោះទេ[476]។ គាត់ “មិនដែលក្តាប់អ្វីបានជាក់ស្តែងទេ”[477]។ គាត់

មជ្ឈិមគឺជាស្ថាប័នដែលមានអំណាចធំជាងគេបំផុតទូទាំងបក្សនៅចន្លោះសន្និបាត។ មាត្រា ៧(១) នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។

[469] កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.15 EN 00156751 KH 00156619-00156620។ *សូមមើលផងដែរ* កថាខណ្ឌ ២០២ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[470] កថាខណ្ឌ ២០២ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[471] កថាខណ្ឌ ១២៨-២៩ នៃសាលក្រមក្នុងរឿងក្តី ០០១។ កថាខណ្ឌ ៣៤៣ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[472] *សូមមើល ខទ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796, KH 00680801-00680802។ ជើងទំព័រ ១៣៩, ១៤១ នៃដីកាសន្និដ្ឋានស្តាពរ។

[473] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២ ឯកសារ D98/1.2.16 ម៉ោង 11:26:46-11:28:19។

[474] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 09:02:58-09:05:47។

[475] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 10:00:00-10:02:22។

[476] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២ ឯកសារ D98/1.2.16 ម៉ោង 11:26:46-11:28:19។

[477] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 13.41.51-13:45:08។

មិនបានដឹងអំពីការងាររបស់អ្នកដទៃឡើយ[478]។ គាត់មិនដែលបានទទួលកំណត់ហេតុកិច្ចប្រជុំរបស់គណៈមជ្ឈិម ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ឡើយ[479] ហើយគាត់ក៏មិនបានសួរនាំនរណាម្នាក់ អំពីអ្វីដែលបានកើតឡើងនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែរ[480]។ គាត់មិនដែលបានទៅមន្ទីរ ៨៧០ ហើយក៏មិនបានដឹងថាមន្ទីរនេះ ស្ថិតនៅទីកន្លែងណានោះដែរ[481]។ ដូចដែលគាត់បាននិយាយប្រាប់ អង្គជំនុំជម្រះសាលាដំបូង "បើយើងនិយាយតែពីពេលហ្នឹង យកការយល់ដឹងពេលហ្នឹងមកនិយាយ។ ខ្ញុំគិតថា ដូចជាគ្មានស្នើនឹងឆ្លើយជូនជាតិប្រជាជនថា ពេលនុំង ជាតិប្រជាជនកម្ពុជា វាវេទនាយ៉ាងណា ដោយសារ ប.ក.ក. ទេ"[482]។

១៧៦. ការយល់ដឹងនៅសម័យនោះរបស់ ខុច ដែលអាចមានអំពីបញ្ហានៅក្រៅមន្ទីរ ស-២១ ត្រូវបានធ្វើឱ្យខូចដោយមិនអាចកែតម្រូវបានដោយ ក.ស.ច.ស. នៅក្នុងអំឡុងពេលដែលគាត់បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក.។ នៅក្នុងរឿងក្តី ០០១ ចំពោះ ខុច "ការយល់ដឹងវាវិវឌ្ឍន៍"[483]។ គាត់បានអានសៀវភៅស្តីពីកុម្មុយនីស្ត និង របបកម្ពុជាប្រជាធិបតេយ្យ[484]។ គាត់បានពិនិត្យមើល

---

[478] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D1.3.33.12 EN 00204286, KH 00187653-00187654។

[479] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 09:38:52-09:43:13។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.25 ម៉ោង 13:34:34-13:36:58។

[480] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 10.02.22-10.03.20។

[481] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 09:37:50-09:43:13។

[482] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២ ឯកសារ D98/1.2.16 ម៉ោង 11:26:46-11:28:19។

[483] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២ ឯកសារ D98/1.2.16 ម៉ោង 11:26:46-11:28:19។ *សូមមើលផងដែរ រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 11:00:12-12:05:04។

[484] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D1.3.33.12 EN 00204287, KH 00187654-00187655។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.25 ម៉ោង 13:51:03-13:58:23។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេង*

ឯកសារសំណុំរឿង ដែលមេធាវីរបស់គាត់ និង ស.ច.ស. បានផ្តល់ឱ្យ[485]។ ក.ស.ច.ស. បានផ្តល់សំណួរដល់គាត់ ហើយផ្តល់ពេលវេលាដល់គាត់រាប់សប្តាហ៍ ឬ រាប់ខែដើម្បីឆ្លើយនឹងសំណួរទាំងនោះ ដោយមានជំនួយបន្ថែមពីសម្ភារបន្ទាប់បន្សំទៀត[486]។ អ្នកប្រវត្តិសាស្ត្រ និង អ្នកជំនាញផ្សេងទៀត បានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការរបស់គាត់ ដូចជា David Chandler, Nayan Chanda, Raoul Jennar និង បណ្ឌិត Etcheson[487]។ តាមរយៈការត្រួតពិនិត្យមើលសំណុំរឿងរបស់គាត់ គាត់ "យល់ច្បាស់ជាងមុនអំពីរចនាសម្ព័ន្ធរបប"[488]។ មុនពេលដែល ឌុច មកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក. គាត់មិនដែលបានឃើញឯកសារ ឬ សេចក្តីសម្រេចណាមួយរបស់គណៈកម្មាធិការមជ្ឈិមឡើយ ព្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារស្នូលរបស់គាត់ គឺ លក្ខន្តិកៈបក្ស ព្រមទាំង ទស្សនាវដ្តី *ទង់បដិវត្ត* និង ទស្សនាវដ្តី *យុវជន យុវនារីបដិវត្ត*[489]។ ជាលើកដំបូងបំផុតសម្រាប់គាត់ គាត់បានដឹងអំពីគោលការណ៍ណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍/មជ្ឈិម ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ ស្តីពីការកម្ទេច និងចំណាររបស់ សុន សេន និង ន្ឋន ជា

ទៀត សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 10:30:00-10:33:45, 13:41:51-13:54:15។ *សូមមើល ផងដែរ រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 13:34:15-13:52:53។

[485] *រឿងក្តី ន្ឋន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 10:28:21-10:32:21, 13:50:15-13:56:25។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D1.3.33.12 EN 00204287 KH 00187654-00187655។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ D4.1.1117 EN 00154202 KH 00154232។

[486] *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.26 ម៉ោង 11:51:35-12:05:04។

[487] *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.25 ម៉ោង 13:54:38-13:58:23។

[488] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D4.1.1119 EN 00198882 KH 00198873-00198874។

[489] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D98/3.1.90 ម៉ោង 10:14:38-10:22:16។

ដែលសរសេរនៅលើចម្លើយសារភាពមន្ទីរស-២១[490]។ ដូចដែលគាត់បាននិយាយ "ហ្នឹងគឺយើងដឹងបន្តិចៗ ព្រោះការយល់ដឹងរបស់យើងវង់ប្រតិបត្តិការរបស់យើងវាតូចចង្អៀត។ ហើយយើងយកសភាពការណ៍ពិត ដែលយើងប្រមូលបានដើម្បីសរុប"[491]។ ជាលទ្ធផលនៃការជួបប្រទះនឹងព័ត៌មានដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក. នៅក្រោយឆ្នាំ ១៩៧៩ របស់ ឌុច គឺពិតជាមិនអាចឡើយក្នុងការញែកឱ្យដាច់ពីគ្នា ថាអ្វីដែលគាត់បានដឹងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង អ្វីដែលបានគាត់ដឹងនៅពេលក្រោយមក។ ការអះអាងណាមួយរបស់ ឌុច ដែលបានលើកឡើងអំពីបញ្ហាផ្សេងទៀត ក្រៅពីការងាររបស់គាត់នៅមន្ទីរស-២១ ចាំបាច់ត្រូវតែត្រួតពិនិត្យមើល ដោយមិនមានការជឿជាក់ទាំងស្រុង និង ត្រូវផ្តល់តម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ ប្រសិនបើមាន។

១៧៧. ដើម្បីបង្ហាញឱ្យឃើញពីភាពមិនអាចជឿជាក់បានរបស់គាត់ ឌុច បានធ្វើការអះអាងផ្ទុយគ្នា អំពីតួនាទីរបស់ មាស មុត នៅក្នុង ប.ក.ក. និង រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងខែមិថុនា ឆ្នាំ ១៩៩៩ ឌុច បានអះអាងថា "តាមការសិក្សារបស់គាត់" អំពីរចនាសម្ព័ន្ធមេដឹកនាំរបបកម្ពុជា

---

[490] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.25 ម៉ោង 14:03:52-14:10:02 (ដែលបានបញ្ជាក់ពីចម្លើយរបស់គាត់នៅចំពោះមុខ ក.ស.ច.ស. ថាគាត់បានអានសេចក្តីសម្រេច ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ នៅក្នុងសម្រង់ចេញពីសៀវភៅរបស់លោក David Chandler)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៨ ឯកសារ D4.1.1112 EN 00185474 KH 00185466-00185467 (បានថ្លែងថា គាត់បានរៀបចំចម្លើយឆ្លើយនឹងសំណួររបស់ ស.ច.ស. អំពីសៀវភៅរបស់លោក David Chandler ហើយបានអានសេចក្តីសម្រេច ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ នៅក្នុងសម្រង់ចេញពីសៀវភៅនោះ)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.860 EN 00403921 KH 00403909-00403910 (បានថ្លែងថា គាត់មិនដឹងថាមានការធ្វើចំណារលើចម្លើយសារភាពរបស់ ស-២១ រហូតដល់ពេលដែលគាត់បានអានចម្លើយទាំងនោះ ក្នុងសំណុំរឿង ០០១)។

[491] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២ ឯកសារ D98/1.2.16 ម៉ោង 11:28:19-11:32:17 (ឌុច បានរៀបរាប់ពីការដឹងរបស់គាត់ ដែលបានវិវត្តន៍អំពីការផ្សឹកលោកសង្ឃ ក្នុងអំឡុងពេលស៊ើបអង្កេតរបស់ ក.ស.ច.ស.៖ "ដល់ក្រោយមកយើងឮដំណឹងមួយ ដល់ក្រោយមកទៀត យើងចេះតែតាមដានទៅទៀត បានយើងសរុបបាន។ សរុបបានដោយសារការិយាល័យសហចៅក្រមស៊ើបអង្កេតចុះទៅខាងខេត្តតាកែវ។ ទៅយកមនុស្សដែលគេចាប់ផ្សឹកមក ហើយនុងមានចៅអធិការមួយអង្គបាត់ខ្លួន ខ្ញុំគិតវិភាគសព្វគ្រប់ អ៎! លោកសង្ឃគេចាប់ផ្សឹកអស់ហើយ វិហារគេកម្ទេចចោលអស់ហើយ។ ហ្នឹងគឺយើងដឹងបន្តិចៗព្រោះការយល់ដឹងរបស់យើងវង់ប្រតិបត្តិការរបស់យើងវាតូចចង្អៀត។ ហើយយើងយកសភាពការណ៍ពិតដែលយើងប្រមូលបានដើម្បីសរុប"។

ប្រជាធិបតេយ្យ គាត់បានដឹងថា[492] មាស មុត គឺជាមេបញ្ជាការកងទ័ពជើងទឹកនៅកំពង់សោម និង ជាប្រធានគណៈកំពង់សោម[493]។ នៅក្នុងការស្តាប់ចម្លើយដោយ ក.ស.ច.ស. ក្នុងឆ្នាំ ២០០៧ ២០០៨ និង ២០១១ គាត់បានអះអាងថា មាស មុត គឺជាជំនួយការ ឬ ជាសមាជិកគណៈជំនួយការ នៃគណៈមជ្ឈិម[494]។ នៅក្នុងឆ្នាំ ២០០៩ គាត់បានអះអាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា មាស មុត គឺនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍[495] ជាការអះអាងដែលមិនមានភស្តុតាងអ្វីគាំទ្រឡើយ។ គាត់ឈប់អះអាងដដែលបែបនេះ រហូតដល់ឆ្នាំ ២០១២ គឺនៅពេលដែលគាត់បានប្រាប់អង្គជំនុំជម្រះសាលាដំបូងថា មាស មុត "នៅក្នុងមជ្ឈិមបក្ស គាត់ទើបតែនឹងចូលជាជំនួយការមជ្ឈិមទេ"[496]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភស្តុតាងដល់ចម្លើយរបស់ ឌុច ស.ច.ស. ចាំបាច់ត្រូវតែពិចារណាថា ក្នុងចំណោមចម្លើយដែលផ្ទុយគ្នារបស់គាត់ គាត់បានអះអាងជាចម្បងថា មាស មុត

---

[492] កំណត់ហេតុសួរចម្លើយជនសង្ស័យ កាំង ហ្គេក អ៊ារ ហៅ ឌុច របស់តុលាការយោធាកម្ពុជា ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7 EN 00184829 KH 00089673-00089674។

[493] កំណត់ហេតុសួរចម្លើយជនសង្ស័យ កាំង ហ្គេក អ៊ារ ហៅ ឌុច របស់តុលាការយោធាកម្ពុជា ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7 EN 00184829-00184830 KH 00089673-00089675៖ "(KH 00089673) តាមការរៀនសូត្រខ្លះ ខ្ញុំដឹងថា... (KH 00089675) សមាជិកជំនួយការមជ្ឈិមនេះ មាន ឈឹម សំអោក ហៅ ប៉ង់ ជាបុគ្គលទីមួយទទួលភារកិច្ចជាប្រធានមន្ទីរមជ្ឈិម ហើយក្រៅពីនេះ មាន ចេង អន ប្រធានគណកម្មាធិការឧស្សាហកម្ម ពេទ្យ សៀង ប្រធានកងពលទីមួយ ភូមិភាគនារតី ក្រោយមកគាត់ជាសមាជិកគណកម្មាធិការភូមិភាគបច្ចឹម សំ ប៊ិត ជំនួយការមជ្ឈិមទទួលភារកិច្ចខាងកងទ័ពនៅភូមិភាគនារតី ហើយ មាស មុត ទទួលភារកិច្ចជាបញ្ជាការកងជើងទឹកប្រចាំការនៅក្រុងកំពង់សោម និង ជាប្រធានគណកម្មាធិការក្រុងកំពង់សោម ហើយ ស៊ូ សាម៉េត ជាប្រធានកងទ័ពជើងអាកាស ហើងជាសមាជិកជំនួយការមជ្ឈិម"។ *សូមមើលផងដែរ* កថាខណ្ឌ ៧៥ ជើងទំព័រ ២២៧ នៃដីកាសន្និដ្ឋានស្តាពរ។

[494] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ារ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.13 EN 00154911 KH 00154927 (អះអាងថា គាត់បានដឹងថា មាស មុត ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការជំនួយការរបស់គណៈកម្មាធិការមជ្ឈិម)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ារ ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.10 EN 00195577 KH 00195568-00195569 (អះអាងថា គាត់បានដឹងថា ផ្នែកយោធាត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការជំនួយការរបស់គណៈកម្មាធិការមជ្ឈិម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ារ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796 KH 00680801-00680802 (អះអាងថា មាស មុត ជាជំនួយការរបស់គណៈកម្មាធិការមជ្ឈិម)។

[495] *រឿងក្តី កាំង ហ្គេកអ៊ារ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D98/3.1.105 ម៉ោង 11:55:00-13:36:26។

[496] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.22 ម៉ោង 14:19:38-14:24:21។

បានជួយ ដល់គណៈមជ្ឈិម ប៉ុន្តែមិនបានចូលរួមក្នុងគណៈមជ្ឈិមទេ[497]។ ខុច ក៏បានអះអាងផងដែរថា សុន សេន ធ្លាប់បានបញ្ជាក់ពីតួនាទី ដែលគ្មានសិទ្ធិចូលរួមបែបនេះដែរ[498]។ ការដែលមានតួនាទីគ្មានសិទ្ធិចូលរួមនៅក្នុងគណៈមជ្ឈិម មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឡើយ។

១៧៨. ក្នុងការអះអាងថា គណៈមជ្ឈិមមានសមាជិក "ពេញសិទ្ធិ បម្រុង និង ជាក់ស្តែង" ដែលរួមមានគណៈកម្មាធិការអចិន្ត្រៃយ៍ លេខាភូមិភាគ និង តំបន់ រដ្ឋមន្ត្រី និង មេបញ្ជាការកងពលធំនោះ ស.ព.អ. បានបង្ហាញនូវរូបភាពដែលមិនពិតមួយ[499]។ យោងតាម ខុច (ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភស្តុតាងចំពោះសក្ខីកម្មរបស់គាត់ អំពីបញ្ហាក្រៅពីមន្ទីរស-២១ នោះ) សមាជិកគណៈមជ្ឈិម គឺមានបួនកម្រិត[500]។ គណៈកម្មាធិការអចិន្ត្រៃយ៍ គឺជាសមាជិកភាពកម្រិតខ្ពស់ជាងគេ

---

[497] កំណត់ហេតុសួរចម្លើយ កាំង ហ្គេក អ៊ាវ ហៅ ខុច របស់តុលាការយោធាកម្ពុជា ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7 EN 00184830 KH 00089674-00089675។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.10 EN 00195577 KH 00195568-00195569 (គាត់បានដឹងថា ផ្នែកយោធាត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការជំនួយការរបស់គណៈកម្មាធិការមជ្ឈិម)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.13 EN 00154911 KH 00154927-00154928 (គាត់បានដឹងថា មាស មុត ដែលជាមេបញ្ជាការជើងទឹក ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការជំនួយការរបស់គណៈកម្មាធិការមជ្ឈិម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796-00680797 KH 00680802-00680803 (មាស មុត ជាជំនួយការរបស់គណៈកម្មាធិការមជ្ឈិម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ឆ.៣-៥។ ស.ព.អ. ធ្វើការបកស្រាយខុសសក្ខីកម្មរបស់ខុច ក្នុងការជំនុំជម្រះ ឆ្នាំ ២០០៦។ គាត់ពិតជាបាននិយាយថា មាស មុត និង ស៊ូ ម៉ែត ជាកម្មាភិបាលដែលជាសមាជិករបស់មជ្ឈិម ប៉ុន្តែបន្ទាប់មក គាត់បាននិយាយថា មានកម្មាភិបាលរបស់មជ្ឈិម ឧទាហរណ៍ដូចជា ប៉ង់ និង ស៊ូ ម៉ែត ដែលជាជំនួយការរបស់មជ្ឈិម។ សក្ខីកម្មរបស់គាត់គឺស៊ីចង្វាក់គ្នាទៅនឹងចម្លើយដទៃទៀតរបស់គាត់ ដែលថា មាស មុត និង ស៊ូ ម៉ែត គឺជាជំនួយការរបស់មជ្ឈិម។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/277.8 ម៉ោង 10:57:59-11:00:47។

[498] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796-00680797 KH 00680801-00680803។

[499] កថាខណ្ឌ ៥០ ដើងចំពីរ ១៣៩ នៃដីកាសន្និដ្ឋានស្តាពរ។

[500] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ ឯកសារ D98/1.2.18 ម៉ោង 15:08:41-15:13:08។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ ឯកសារ D1.3.33.11 EN 00147570-00147571 KH 00146557-00146559។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/158 ឆ.៣២, ឆ.៣៥។

បំផុត ដែលមានសមាជិកប្រាំពីរនាក់[501]។ កម្រិតខ្ពស់បន្ទាប់នៃសមាជិកភាព គឺសមាជិកពេញសិទ្ធិ។ សមាជិកពេញសិទ្ធិអាចចូលរួម នៅក្នុងការពិភាក្សា និង ការបោះឆ្នោត[502]។ សមាជិកភាពកម្រិតទីបី គឺសមាជិកបម្រុង ឬ សមាជិកត្រៀម ដែលសមាជិកកម្រិតនេះមានចំនួន "ច្រើន"[503]។ សមាជិកបម្រុង/ត្រៀម អាចបញ្ចេញមតិយោបល់នៅក្នុងពេលពិភាក្សា ប៉ុន្តែមិនអាចបោះឆ្នោតទេ[504]។ សមាជិកភាពកម្រិតទីបួន និង ជាសមាជិកភាពកម្រិតទាបបំផុត គឺជាជំនួយការគណៈមជ្ឈិម ហើយក្រុមទីបួននេះ ជាក្រុមសមាជិកដែលមានចំនួនច្រើនជាងគេបំផុត[505]។ ជំនួយការអាចចូលរួមក្នុងវគ្គបណ្តុះបណ្តាលគណៈមជ្ឈិម និង កត់ត្រារបាយការណ៍ ប៉ុន្តែមិនមានសិទ្ធិចូលរួម ឬ បោះឆ្នោតលើការពិភាក្សា ឬ សេចក្តីសម្រេចអំពីមាគ៌ាបក្ស ឬ គោលនយោបាយបក្សឡើយ[506]។ នៅពេលក្រោយមក ខុច បានកែប្រែការពណ៌នារបស់គាត់បន្តិច ទៅលើកម្រិតខុសគ្នានៃសមាជិកភាព[507] ប៉ុន្តែគាត់នៅតែបន្តអះអាងថា ជំនួយការ គឺជាកម្រិត "សមាជិក" ទាបបំផុត ដែលមិនមានសិទ្ធិចូលរួម[508]។

---

[501] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796 KH 00680801-00680802។

[502] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796 KH 00680801-00680802។

[503] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ ឯកសារ D1.3.33.11 EN 00147571 KH 00146558-00146559។

[504] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796 KH 00680801-00680802។

[505] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ ឯកសារ D1.3.33.11 EN 00147571 KH 00146558-00146559។

[506] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.13 EN 00154911 KH 00154927 (សិទ្ធិទទួលការបណ្តុះបណ្តាលនៅមន្ទីរ ៨៧០ ជាមួយសមាជិកគណៈកម្មាធិការមជ្ឈិមដទៃទៀត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796 KH 00680802 (មិនមានសិទ្ធិបោះឆ្នោត ឬ ផ្តល់យោបល់នោះទេ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/158 ន.៣២ (មិនមានសិទ្ធិបោះឆ្នោត ឬ បញ្ចេញមតិទេ)។

[507] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.13 EN 00154911 KH 00154927-00154928 (យោងទៅថ្នាក់ទីពីរនៃសមាជិកភាព ជា "សមាជិកពេញសិទ្ធិ")។

[508] *សូមមើល* ជើងទំព័រ ៥០៦ *ខាងលើ* ។

១៧៩. ឌុច បានអះអាងថា នៅក្នុងសន្និបាតបក្សថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ១៩៧៨ មាស មុត បានក្លាយជាសមាជិកបម្រុងនៃគណៈមជ្ឈិម[509]។ ឌុច មិនបាននិយាយថា តើគាត់បានចូលរួមសន្និបាតនេះដែរឬយ៉ាងណានោះទេ ឬ ថាតើនេះជាព័ត៌មានដែលគាត់បានឮ ឬ ដឹង ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណានោះទេ។ ប្រសិនបើ ស.ច.ស. ពិចារណាទៅលើចម្លើយរបស់គាត់ ថាមានតម្លៃជាភស្តុតាងនោះ ស.ច.ស. ចាំបាច់ត្រូវតែពិចារណាថា មាស មុត អាចជាសមាជិកបម្រុងនៃគណៈមជ្ឈិម ត្រឹមតែរយៈពេលពីរខែប៉ុណ្ណោះ មុនពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់មិនមានសិទ្ធិបោះឆ្នោត ឬ ចូលរួមក្នុងសេចក្តីសម្រេចរបស់គណៈមជ្ឈិម ហើយដូច្នេះគាត់មិនមានលទ្ធភាពក្នុងការសម្រេចលើគោលនយោបាយបក្សឡើយ។ ក្នុងនាមជាសមាជិកបម្រុងគណៈមជ្ឈិម ក្នុងរយៈពេលពីរខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចធ្វើឱ្យ មាស មុត ក្លាយជាមេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក. ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ បានឡើយ។

១៨០. មាស មុត មិនធ្លាប់ជាសមាជិកគណៈមជ្ឈិម។ ខៀវ សំផន និង ឌុច មិនគាំទ្រលួមគ្រប់គ្រាន់ដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ នៅពេលពិនិត្យលើភស្តុតាង ក្នុងភាពលម្អៀងបំផុតទៅរក ស.ព.អ. យ៉ាងច្រើនបំផុត មាស មុត អាចត្រឹមជួយដល់គណៈមជ្ឈិម ក្នុងលក្ខណៈគ្មានសិទ្ធិចូលរួម ឬ បានក្លាយជាសមាជិកបម្រុង ក្នុងរយៈពេលពីរខែ មុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំប៉ុណ្ណោះ។ ភស្តុតាងនេះមិនបានដំឡើងគាត់ ឱ្យទៅជាប្រភេទ “មេដឹកនាំជាន់ខ្ពស់” ឡើយ។

៣. មាស មុត មិនធ្លាប់ជាអនុលេខានៃអគ្គសេនាធិការ ឬ ជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ

ក. មាស មុត មិនធ្លាប់ជាអនុលេខានៃអគ្គសេនាធិការ ឬ សមាជិកគណៈកម្មាធិការអគ្គសេនាធិការ ទាំងតាមផ្លូវច្បាប់ (de jure) និង ការអនុវត្តជាក់ស្តែង (de facto)

១៨១. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់នោះ មិនបានគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត ធ្លាប់ត្រូវបានតែងតាំងជាអនុលេខានៃអគ្គសេនាធិការ ឬ ជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ រហូតដល់ពេលដួលរលំរបបកម្ពុជាប្រជាធិបតេយ្យឡើយ[510]។ ស.ព.អ. ដកស្រង់ជា

[509] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ឧ.១៨។

[510] កថាខណ្ឌ ៥៣, ៥៦, ២២២ នៃដីកាសន្និដ្ឋានស្តាពរ ។

សំខាន់ នូវចម្លើយដែលមិនមានមូលដ្ឋានគាំទ្រ ឬ មិនអាចជឿជាក់បានរបស់ ម៉ឹង វេត សេង សឿន ជេត ប៊ុណ្ណា ឡាយ ប៊ុនហាក់ សាត ចក់ ព្រំ សារ៉ាត មាស រឿន លុន សេង ឌុច និងប៊ាង រ៉េត[511]។ មិនមានសាក្សីណាម្នាក់ ក្នុងចំណោមសាក្សីទាំងនេះ បានផ្តល់ភស្តុតាងគ្រប់គ្រាន់ អំពីការតែងតាំង មាស មុត តាមផ្លូវច្បាប់ ឬ ជាក់ស្តែង ជាអនុលេខាអគ្គសេនាធិការ ឬជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ ឬ អំពីពេលវេលាដែលគាត់កាន់មុខតំណែងទាំងនេះឡើយ។

១៨២. **ម៉ឹង វេត**៖ ម៉ឹង វេត មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយដែលផ្ទុយគ្នា និង ជាការទាយស្មាន អំពីសកម្មភាពរបស់ មាស មុត នៅអគ្គសេនាធិការ និង មជ្ឈិមបក្ស។ ម៉ឹង វេត ត្រូវបានបញ្ជូនទៅតំបន់ ៥០៥ នៅក្នុងឆ្នាំ ១៩៧៧[512] ហើយបានក្លាយជាអនុប្រធាន ទទួលបន្ទុកភស្តុភារ នៅកងពលធំលេខ ១១៧[513]។ គាត់បានអះអាងថា មាស មុត គឺជាអគ្គសេនាធិការរង[514]។ ម៉ឹង វេត មិនបាននិយាយថា មាស មុត គឺសមាជិកគណៈកម្មាធិការអគ្គសេនាធិការឡើយ[515]។ គាត់បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា គាត់មិនបានចូលរួមការប្រជុំនៅក្រចេះ ដែលនៅទីនោះ មាស មុត បានហៅអ្នកដែលត្រូវបានចាប់ខ្លួន នៅកងពលធំលេខ ១១៧ និង តំបន់ ៥០៥ ថាជាជនក្បត់ ប៉ុន្តែគាត់គ្រាន់តែបានឮអំពីការប្រជុំនេះ ពីអ្នកនៅក្នុងមន្ទីររបស់គាត់ប៉ុណ្ណោះ[516]។ ចម្លើយមួយនេះគឺផ្ទុយពីការសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងការសម្ភាសន៍នោះ គាត់បាននិយាយថាគាត់បានចូលរួមក្នុងការប្រជុំបែបនេះ[517]។ នៅក្នុងពេលស្តាប់ចម្លើយលើកក្រោយជាមួយ ក.ស.ច.ស. ម៉ឹង វេត បានផ្តាស់ប្តូររឿងរបស់គាត់ ហើយបាននិយាយថា គាត់ពិត

---

[511] ជើងទំព័រ ១៥៨, ១៦០, ១៦៨, ៦៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[512] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២។

[513] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.៦។

[514] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២២-២៣។ ជើងទំព័រ ១៦០ នៃដីកាសន្និដ្ឋានស្តាពរ។

[515] ដូចដែល ស.ព.អ. បានអះអាងនៅក្នុងកថាខណ្ឌ ៥៦ ជើងទំព័រ ១៧០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២៣។

[516] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.៣០-៣១។

[517] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 00992999-00992300 KH 00975743-00975746។ *C.f.* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212317 (មានការបកប្រែជាភាសារអង់គ្លេសផ្សេងគ្នា នូវកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងនោះ ភាពច្បាស់លាស់តិចតួចដែលថា ម៉ឹង វេត បាននិយាយថា គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំ ជាជាងគ្រាន់តែឆ្លើយថា មានកិច្ចប្រជុំមួយប៉ុណ្ណោះ)។

ជាបានចូលរួមក្នុងកិច្ចប្រជុំ ដោយថ្លែងថា "ថ្ងៃនេះខ្ញុំយល់ស្របជាមួយនឹងសម្ភាសរបស់ខ្ញុំ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា" ដោយអះអាងថា ការភ្ជេចភ្លាំង ធ្វើឱ្យគាត់ឆ្លើយផ្ទុយពីការសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា[518]។ សូម្បីតែនៅក្នុងការសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ ម៉ឹង វេត បាននិយាយថា គាត់ "ភ្លេចអស់ហើយ។ ល៊ែងចងចាំបានអស់ហើយឥឡូវហ្នឹង"[519]។ ក្រៅពីការឆ្លើយផ្ទុយគ្នា និង ភ្លេចភ្លាំង ម៉ឹង វេត បានដឹងឮព័ត៌មានមួយចំនួន នៅក្រោយឆ្នាំ ១៩៧៩។ គាត់បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា មនុស្សចំនួន ១១ នាក់ត្រូវបានចាប់ខ្លួននៅក្រចេះ ហើយបញ្ជូនទៅទួលស្លែង[520]។ នៅពេលគាត់ផ្តល់ចម្លើយដល់ ក.ស.ច.ស. គាត់បានទទួលស្គាល់ថា គាត់បានឮនៅក្រោយឆ្នាំ ១៩៧៩ ថា មនុស្សទាំង ១១ នាក់នេះ ត្រូវបានបញ្ជូនទៅទួលស្លែង[521]។

១៨៣. បើទោះបីជា ស.ច.ស. ពិចារណាថា ម៉ឹង វេត អាចជឿជាក់បានក៏ដោយ ក៏ការអះអាងរបស់គាត់ដែលថា មាស មុត គឺជាអគ្គសេនាធិការរង[522] គឺមានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ ព្រោះគាត់បានទាយស្មាន។ គាត់បានជឿជាក់ថា មាស មុត គឺជាអគ្គសេនាធិការរង ពីព្រោះ៖ **ក.** មាស មុត បានទៅព្រំដែនដើម្បីពិនិត្យសមរភូមិមុខ នៅពេលវៀតណាមវាយប្រហារ[523] **ខ.** កងទ័ពទាំងបីផ្នែកស្ថិតនៅក្រោមបញ្ជារបស់អគ្គសេនាធិការ ហើយ មាស មុត ជាអនុទទួលខុសត្រូវខាងជើងទឹក[524]

---

[518] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/63 ឧ.១។ ពេលគាត់ផ្តល់សក្ខីកម្មក្នុងរឿងក្តី ០០២/០២ គាត់បានឆ្លើយថា គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំ។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.23 ម៉ោង 09:35:25-09:44:15។ *សូមមើល* ជើងទំព័រ ១០០៨ នៃដីកាសន្និដ្ឋានស្តាពរ។

[519] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212294 KH 00975730-00975731។

[520] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 00992992 KH 00975732-00975733 (EN 01212299 នៅក្នុងឯកសារបកប្រែលើកទីពីរ)។

[521] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.៣៨-៣៩។

[522] ជើងទំព័រ ១៦០-៦១, ៣៤៦៦-៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[523] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២២, ឧ.២៥។ ជើងទំព័រ ១៦០, ៣៤៦៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* ផ្នែកទី IV.គ.៨ *ខាងក្រោម* សម្រាប់ការលើកឡើងលម្អិតទាក់ទងនឹងអំណាចរបស់ មាស មុត ដែលត្រូវបានចោទប្រកាន់ ទៅលើកងពល ១១៧ និង តំបន់ ៥០៥។

[524] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២៣។ ជើងទំព័រ ១៦០, ៣៤៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

និង **គ.** នៅចុងឆ្នាំ ១៩៧៨ រាល់សំណើសុំទាំងឡាយ ដែលស្នើទៅអគ្គសេនាធិការ ត្រូវបានឆ្លើយតបមកវិញដោយ ស៊ូ ម៉ែត និង មាស មុត[525]។ ម៉ឹង វេត មិនបានឃើញ មាស មុត ទៅព្រំដែនទេ[526] គឺគ្រាន់តែឮពីមេបញ្ជាការកងវរសេនាធំកងទ័ពជើងទឹកថា មាស មុត ទៅព្រំដែន[527]។ គាត់បានអះអាងត្រឹមថា មាស មុត បានទៅពិនិត្យបញ្ហាព្រំដែនជាពិសេស នៅខេត្តក្រចេះ និង ស្ទឹងត្រែង គឺមិនមែនថា មាស មុត ទទួលបន្ទុកជាទូទៅក្នុងនាមអគ្គសេនាធិការ លើបញ្ហាព្រំដែនទាំងអស់នោះឡើយ[528]។ ការណ៍ដែលថាកងទ័ពជើងទឹក នៅក្រោមអគ្គសេនាធិការ ហើយថា មាស មុត ប្រហែលជាធ្លាប់ទទួលខុសត្រូវលើកងទ័ពជើងទឹក មិនមានន័យថា មាស មុត ធ្លាប់ជាអគ្គសេនាធិការរង តាមផ្លូវច្បាប់ ឬ ការអនុវត្តជាក់ស្តែងឡើយ។ ការណ៍នេះ គឺគ្រាន់តែមានន័យថា កងទ័ពជើងទឹក ដែលជាផ្នែកមួយនៃកងទ័ព គឺស្ថិតក្រោមអំណាចរបស់អគ្គសេនាធិការ។ ម៉ឹង វេត ក៏បានអះអាងនៅក្នុងពេលផ្តល់សក្ខីកម្មរបស់គាត់ ក្នុងរឿងក្តី ០០២/០២ ផងដែរថា គាត់មិនបានដឹងឱ្យប្រាកដអំពីព័ត៌មានលម្អិតនៃការទំនាក់ទំនងនៅក្នុងអគ្គសេនាធិការឡើយ។ ប៉ុន្តែគាត់ធ្វើការសន្និដ្ឋានដោយផ្អែកលើការទាយស្មាន[529]។

១៨៤. **សេង សឿន៖** សេង សឿន មិនអាចជឿជាក់បានឡើយ។ ការចងចាំរបស់គាត់ត្រូវបានធ្វើឱ្យខូចនៅក្នុងពេលផ្តល់ចម្លើយដល់ ក.ស.ច.ស. ដែលធ្វើឱ្យការស្តាប់ចម្លើយរបស់គាត់ដោយ ក.ស.ច.ស. និង សក្ខីកម្មរបស់គាត់ ក្នុងរឿងក្តី ០០២/០២ មិនអាចឱ្យជឿជាក់បាន។ នៅក្នុងឆ្នាំ ២០១៦ សេង សឿន ដែលជាប្រធានមន្ទីរតំបន់ ៥០៥ សម្រាប់រយៈពេល ២៥ ថ្ងៃចុងក្រោយ នៃរបបកម្ពុជាប្រជា

---

[525] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/63 ឧ.៣១។ ជើងទំព័រ ១៦១, ៣៤៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[526] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២៦។

[527] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២៤។

[528] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២៤។

[529] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 ម៉ោង 10:11:57-10:16:50 (ដែលពិភាក្សាពីសក្ខីកម្មមុនៗរបស់គាត់ ក្នុង *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.23 ម៉ោង 13:44:41-13:48:51)។ *សូមមើល ផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 ម៉ោង 09:39:45-09:45:02។

ធិបតេយ្យ[530] បានអះអាងថា មាស មុត ធ្លាប់ជាអនុរដ្ឋមន្ត្រីការពារជាតិ ជំនួសឱ្យ សុន សេន[531]។ គាត់មិនបាននិយាយថា មាស មុត នៅក្នុងគណៈកម្មាធិការអគ្គសេនាធិការឡើយ[532]។ នៅមុនឆ្នាំ ២០១៦ សេង សឿន បានរៀបរាប់ថា មាស មុត គឺជាបញ្ហាការកងពលធំលេខ ១៦៥ នៅកំពង់សោម[533]។ នៅក្នុងឆ្នាំ ២០១៦ សេង សឿន ត្រូវបានស្តាប់ចម្លើយដោយ ក.ស.ច.ស. និង នៅពេលក្រោយមកបានផ្តល់សក្ខីកម្ម ក្នុងរឿងក្តី ០០២/០២។ ការចងចាំ និង ចម្លើយរបស់គាត់ ត្រូវបានធ្វើឱ្យខូច ដោយសារតែវិធីសាស្ត្រ ដែលអ្នកស៊ើបអង្កេត ក.ស.ច.ស. បានអនុវត្តក្នុងការស្តាប់ចម្លើយ។ អ្នកស៊ើបអង្កេតបានចាប់ផ្តើមការស្តាប់ចម្លើយដោយអានឡើងវិញឱ្យ សេង សឿន ស្តាប់នូវការស្តាប់ចម្លើយរបស់គាត់ដោយ ក.ស.ច.ស. កាលពីឆ្នាំ ២០០៩ ដើម្បី "ជួយរឭក"[534] ការចងចាំរបស់គាត់។ សេង សឿន មិនបានបង្ហាញនៅឡើយទេថា គាត់ត្រូវការឱ្យជួយរឭកការចងចាំរបស់គាត់នោះ។ បន្ទាប់ពីអានចប់ហើយ សេង សឿន បាននិយាយថា "ប៉ុណ្ណឹងបាននឹកឃើញ បើមិនបានស្តាប់ ខ្ញុំប្រហែលភ្លេចអស់ហើយ"[535]។ គាត់ក៏បាននិយាយផងដែរថា វាយូរមកហើយ ហើយគាត់ "ឈឺអត់ដឹងខ្លួនផង"[536]។ វិធីសាស្ត្រស្តាប់ចម្លើយរបស់អ្នកស៊ើបអង្កេត ធ្វើឱ្យប៉ះពាល់ដល់

---

[530] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.៥-៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.810 ឆ.២៤-២៥។

[531] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.២៥។ ជើងទំព័រ ៣៥៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[532] ដូចដែល ស.ព.អ. បានអះអាងក្នុងកថាខណ្ឌ ៥៦ ជើងទំព័រ ១៧០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 ម៉ោង 13:54:58-14:01:14។

[533] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.810 ឆ.៣០។ ក្នុងកិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជារបស់ សេង សឿន គាត់ត្រឹមតែបាននិយាយថា មាស មុត មកខេត្តក្រចេះ មករៀបចំកងទ័ពនៅទីនោះ "មករៀបចំជំនួសឱ្យប៉ុល ពត"។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៦ ឯកសារ D59/2/4.16a EN 00753837 KH 00059330។

[534] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 EN 01237985 KH 01203855-01203856៖ "ខ្ញុំមានកិច្ចសម្ភាសន៍របស់លោកជាភាសាខ្មែរ ដែលមានលេខ ERN 00402505 រហូតដល់លេខ ERN 00402517 ក្នុងឆ្នាំ ២០០៩។ ដើម្បីឱ្យមានភាពត្រឹមត្រូវ ខ្ញុំនឹងឱ្យអានអត្ថបទនេះ ក្នុងគោលបំណងរំឭកការចងចាំរបស់លោក ដែលយើងនឹងសួរនៅថ្ងៃនេះ"។

[535] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.១។

[536] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.២។

ភស្តុតាងរបស់ សេង ស៊ឿន[537]។ អ្នកស៊ើបអង្កេតបានផ្តល់ការចងចាំដល់ សេង ស៊ឿន ជាជាងដំបូងឡើយធ្វើការសាកសួរគាត់ ដើម្បីទទួលបាននូវការចងចាំដោយឯករាជ្យរបស់គាត់ ឬ ដើម្បីកំណត់ថា សេង ស៊ឿន មិនអាចចងចាំបានទេ ហើយត្រូវការជំនួយ ដើម្បីរឭកដល់ការចងចាំរបស់គាត់[538]។ ចម្លើយរបស់ សេង ស៊ឿន នៅក្នុងការស្តាប់ចម្លើយនេះ និង នៅក្នុងសវនាការរឿងក្តី ០០២/០២ គឺមានតម្លៃជាភស្តុតាងតិចតួច។

១៨៥. បើទោះបីជា ស.ច.ស. មិនពិចារណាថា ភស្តុតាងរបស់ សេង ស៊ឿន ត្រូវបានធ្វើឱ្យខូចក៏ដោយ ក៏សក្ខីកម្មរបស់គាត់នៅក្នុងសវនាការរឿងក្តី ០០២/០២ មានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ ពីព្រោះ៖ **ក.** សេង ស៊ឿន បានផ្តល់សក្ខីកម្មក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី[539] ហើយដូច្នេះគាត់មិនមែនជាអ្នកចូលរួម ដែលមិនមានផលប្រយោជន៍ឡើយ ហើយគាត់មិនបានស្បថទេ[540] និង **ខ.** នៅពេលចាប់ផ្តើមសក្ខីកម្មរបស់គាត់ ចម្លើយរបស់គាត់បានបណ្តាលឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងក្លា អំពីភាពអាចជឿជាក់បាន។ គាត់បាននិយាយថា គាត់មិនអាចអានកំណត់ហេតុនៃការស្តាប់ចម្លើយកន្លងមករបស់គាត់ គាត់សន្លប់បាត់ស្មារតីបីឬបួនដង គាត់បានដឹងខ្លួនវិញ ប៉ុន្តែក្តចអស់រលីង ហើយថា មេធាវីរបស់គាត់បានព្យាយាម រឭកការចងចាំរបស់គាត់ ទើបគាត់អាចចាំបានផ្នែកខ្លះៗ[541]។ ទោះបីជាគាត់បានឆ្លើយបែបនេះក្តី ក៏បន្ទាប់មក សេង ស៊ឿន បាននិយាយថា កំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់ គឺ “ជារឿងពិតដែលខ្ញុំបានពិនិត្យមើល ហើយដែលខ្ញុំបានជូនព័ត៌មានកន្លងមកនេះ គឺពិតអត់មានក្លែងក្លាយទេ គឺខ្ញុំបាននិយាយពិតពីរបស់ខ្ញុំ ដែលកត់ត្រាហ្នឹងកត់

---

[537] ជើងទំព័រ ១៦០-៦១ នៃដីកាសន្និដ្ឋានស្តាពរ។

[538] *សូមមើល* សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. ចតយកសំឡេង ឬរូបភាពនូវរាល់ការស្តាប់ចម្លើយសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D136 កថាខណ្ឌ ១៦-២៥ ដែលពិភាក្សាពីវិធីដែលបច្ចេកទេសសួរសំណួរអាចប៉ះពាល់ដល់ចម្លើយរបស់សាក្សី ជាពិសេស សាក្សីដែលមានវ័យចំណាស់។

[539] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 ម៉ោង 09:11:48-09:14:53 (ដោយយោងថា គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីលេខ 2-TCCP-219)។ វិធាន ២៣(១) នៃវិធានផ្ទៃក្នុង។ គាត់មិនទាន់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០៣ ដោយយោងតាមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 EN 01237985 KH 01203855។

[540] *សូមមើល* កថាខណ្ឌ ១៤២ *ខាងលើ* ទាក់ទងនឹងការប្រើប្រាស់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[541] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 ម៉ោង 09:20:14-09:22:05។

បានពិតប្រាកដ អត់ក្លែងក្លាយដែរ”[542]។ ចម្លើយនេះមិនអាចជឿជាក់បានទេ ដោយសារតែការរៀបរាប់កន្លងមករបស់គាត់ អំពីស្ថានភាពសុខភាពរាងកាយ និង ផ្លូវចិត្តរបស់គាត់។

១៨៦. **ជេត ប៊ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ។ គាត់គ្រាន់តែជាយុទ្ធជនម្នាក់ នៅលើកប៉ាល់ ដែលមិនបានដឹងអំពីកម្រិតថ្នាក់ដឹកនាំ នៅក្រោយដើមឆ្នាំ ១៩៧៧ ឡើយ[543]។ គាត់បានទាយស្មាន ហើយត្រូវបានជំរុញដោយការស្អប់ខ្ពើមចំពោះ មាស មុត[544]។ គាត់បានអះអាងថា គាត់បានឮនៅក្នុងសន្និបាតថា មាស មុត គឺជាអនុរបស់ សុន សេន ហើយគាត់បានគិតថា មាស មុត គឺជាអនុសេនាធិការ ព្រោះការងារការទទួលខុសត្រូវរបស់គាត់ និង មានយោធា “១៨ ពាន់នាក់” នៅក្រោមបញ្ជារបស់គាត់[545]។ គាត់មិនបាននិយាយថា មាស មុត ស្ថិតនៅក្នុងគណៈកម្មាធិការអគ្គសេនាធិការឡើយ[546]។ ក្នុងនាមជាយុទ្ធជនសាមញ្ញម្នាក់នៅលើកប៉ាល់ ការដឹងឮរបស់ ជេត ប៊ុណ្ណា អំពីរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់កងពលធំ ឬ ថ្នាក់ខ្ពស់ជាងនេះ គឺប្រាកដជាមានតិចតួចទេ ដោយសារតែការដឹងឮនេះគឺ នៅក្រោយដើមឆ្នាំ ១៩៧៧ តាមរយៈការឆ្លើយបញ្ជាក់របស់គាត់[547]។

១៨៧. ក្រៅពីការដឹងឮកម្រិតទាបរបស់គាត់ ដោយសារតែតួនាទីរបស់គាត់ ការចងចាំរបស់ ជេត ប៊ុណ្ណា ទៅលើហេតុការណ៍នានា គឺមិនអាចជឿជាក់បានឡើយ។ នៅពេលពិភាក្សាអំពីការចងចាំរបស់គាត់ អំពីកាលបរិច្ឆេទជាក់លាក់ ដែលគាត់ទៅធ្វើការនៅការដ្ឋានវាយថ្មស្ទឹងហាវ (ដែលគាត់អះអាងថា

---

[542] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 ម៉ោង 09:20:14-09:22:05។

[543] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឧ.១៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D114/86 ឧ.៥, ឧ.៦, ឧ.១៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ឧ.១៩។

[544] *សូមមើល* កថាខណ្ឌ ១៨៧-៨៨ *ខាងក្រោម*។

[545] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឧ.១០។ ជើងទំព័រ ១៦០ នៃដីកាសន្និដ្ឋានស្តាពរ។

[546] ដូចដែល ស.ព.អ. លើកឡើងក្នុងកថាខណ្ឌ ៥៦ ជើងទំព័រ ១៧០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឧ.១២។ *សូមមើលផងដែរ* កថាខណ្ឌ ២២២ ជើងទំព័រ ៦៦៨ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឧ.៩។

[547] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ឧ.១៩។

នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៧៨)[548] គាត់បាននិយាយថា គាត់អាចចងចាំកាលបរិច្ឆេទច្បាស់ ដោយសារតែគាត់មានសៀវភៅ ដែលគាត់បានកត់ត្រានូវហេតុការណ៍ទាំងអស់[549]។ នៅពេលសួរ ដេញដោលអំពីទីកន្លែងទុកដាក់សៀវភៅនោះ គាត់បានអះអាងថា សៀវភៅនោះបានបាត់ហើយ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់[550]។ រឿងនេះមិនអាចឱ្យជឿជាក់បានទេ។ ការណ៍ ដែលថា ជេត ប៊ុណ្ណា មានសៀវភៅ ពោលគឺទិនានុលេខន៍ ដែលគាត់បានបាត់នៅចុងឆ្នាំ ១៩៧៨ ឬ ដើមឆ្នាំ ១៩៧៩ មិនអាចពន្យល់បានថាតើគាត់អាចចងចាំកាលបរិច្ឆេទជាក់លាក់ និង ហេតុការណ៍ បានច្បាស់លាស់ ដោយរបៀបណាឡើយ នៅក្នុងរយៈពេលជាង ៣៥ ឆ្នាំក្រោយមកនេះ។ សក្ខីកម្ម ផ្សេងទៀតរបស់ ជេត ប៊ុណ្ណា បានបញ្ជាក់ពីភាពមិនត្រឹមត្រូវនៃការចងចាំរបស់គាត់។ អ្នកស៊ើប អង្កេត ក.ស.ច.ស. ម្នាក់បានសាកសួរអំពីការចងចាំដែលគាត់បានអះអាងដែលថា មាស មុត បាន ដឹកនាំការប្រជុំនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៧ ដើម្បីប្រកាសពីការចាប់ខ្លួន ឌឹម និង នង ឆាន នៅពេលដែលឯកសាររបស់មន្ទីរស-២១ បានបង្ហាញថា ការចាប់ខ្លួននោះត្រូវបានធ្វើឡើងនៅក្នុង ខែឧសភា ឆ្នាំ ១៩៧៧[551]។ ទោះបីជាគាត់ទទួលស្គាល់នូវកាលបរិច្ឆេទ នៅក្នុងឯកសារមន្ទីរស-២១ ក៏ដោយ ក៏ ជេត ប៊ុណ្ណា នៅតែបន្តអះអាងថា ការប្រជុំធ្វើឡើងនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៧ ដែលមានន័យថា សក្ខីកម្មរបស់គាត់គឺ ថា មាស មុត បានប្រកាសពីការចាប់ខ្លួន នៅមុនពេលដែល ការចាប់ខ្លួននោះបានកើតឡើង[552]។

១៨៨. ជាចុងក្រោយ ជេត ប៊ុណ្ណា អាចត្រូវបានជំរុញដោយការស្អប់ខ្ពើមចំពោះ មាស មុត។ គាត់ហាក់ ដូចជាជឿជាក់ថា មាស មុត បានចេញបញ្ជាផ្ទាល់ឱ្យចាប់ខ្លួនគាត់ និង បញ្ជូនគាត់ទៅកងផលិត[553]

---

[548] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/86 អ.១៦។

[549] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/86 អ.១៧។

[550] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/86 អ.១៨។

[551] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/85 ស.២៦។

[552] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/85 អ.១១, អ.២៥-២៧។

[553] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 អ.៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/86 អ.១, អ.១០-១១។

ហើយគាត់បានស្ម័គ្រចិត្តផ្តល់ការអះអាងអវិជ្ជមាន អំពីលក្ខណៈរបស់ មាស មុត ជាច្រើនលើកនៅក្នុងការស្តាប់ចម្លើយរបស់គាត់[554]។

១៨៩. ឡាយ ប៊ុនហាក់៖ ឡាយ ប៊ុនហាក់ មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយដែលផ្ទុយគ្នាទៅមជ្ឈមណ្ឌលឯកសារកម្ពុជា និង ក.ស.ច.ស. ហើយការស្តាប់ចម្លើយរបស់គាត់ជាមួយក.ស.ច.ស. ត្រូវបានធ្វើឡើងក្នុងកាលៈទេសៈ ដែលមិនមានតម្លាភាព។ គាត់គឺជាអ្នកជួយកាន់វិទ្យុទាក់ទងនៅបញ្ជាការដ្ឋានកងវរសេនាធំលេខ ១៤០[555]។ គាត់បានអះអាងថា មាសមុត ត្រូវបានផ្ទេរទៅអគ្គសេនាធិការ ហើយបានក្លាយទៅជាអនុប្រធាន[556]។ មានភាពផ្ទុយគ្នានៅក្នុងចម្លើយរបស់ ឡាយ ប៊ុនហាក់។ គាត់បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា មាស មុត បានក្លាយអនុប្រធានសេនាធិការ[557] ប៉ុន្តែគាត់បានប្រាប់ ក.ស.ច.ស. ថា មាស មុត ត្រូវបានផ្ទេរទៅអគ្គសេនាធិការ[558]។ គាត់បានអះអាងប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់បានបញ្ឈប់លើកងវិទ្យុទាក់ទង នៅក្នុងកងវរសេនាធំលេខ ១៤០ ប៉ុន្តែបានបដិសេធចំណុចនេះជាមួយ ក.ស.ច.ស.[559]។ គាត់បានអះអាងប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថាគាត់គឺជាអនុប្រធាននាវា ប៉ុន្តែគាត់បានបដិសេធជាមួយ ក.ស.ច.ស. ទាក់ទងនឹងចំណុចនេះ[560]។ ការស្តាប់ចម្លើយរបស់គាត់ ជាមួយ ក.ស.ច.ស. បានធ្វើឡើងជាច្រើនថ្ងៃ ប៉ុន្តែកំណត់ហេតុនៃការស្តាប់ចម្លើយ មិនបានបង្ហាញពេលវេលាដែលការស្តាប់ចម្លើយ បានបញ្ចប់នៅថ្ងៃ

---

[554] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ឆ.២០, ឆ.២២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឆ.៨។

[555] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/99 ឆ.៣៦។

[556] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ឆ.៩៣, ឆ.៩៥-៩៦។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D54/99.1 EN 01115988 KH 00990787។ ជើងទំព័រ ១៦០, ១៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[557] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D54/99.1 EN 01115988 KH 00990787។

[558] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ឆ.៩២, ៩៦។

[559] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/99 ឆ.៣៦។

[560] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/99 ឆ.៣៧-៣៨។

ទីមួយ បានចាប់ផ្តើមនៅថ្ងៃទីពីរ ឬ មូលហេតុដែលអ្នកស្តាប់ចម្លើយផ្លាស់ប្តូរគ្នា នៅក្នុងពេលស្តាប់ចម្លើយឡើយ[561]។

១៩០. បើទោះបីជាចម្លើយរបស់ ឡាយ ប៊ុនហាក់ ទទួលបានតម្លៃជាភស្តុតាងក៏ដោយ ក៏ចម្លើយរបស់គាត់ទាក់ទងនឹងការផ្ទេរ មាស មុត ទៅភ្នំពេញ គឺមិនមានភាពច្បាស់លាស់ឡើយ។ គាត់និយាយថា គាត់បានដឹងថា មាស មុត នៅអគ្គសេនាធិការ ពីព្រោះក្រោយពេលវៀតណាមវាយប្រហារ គាត់បានឃើញ មាស មុត "ត្រឡប់មកវិញប្រហែលជាង ១០ ថ្ងៃ មុនវៀតណាមទម្លាក់គ្រាប់បែក នៅក្រុងកំពង់សោម គឺចុងឆ្នាំ ១៩៧៨។ ខ្ញុំបានសន្និដ្ឋានថា គាត់ប្រហែលជាទៅអគ្គសេនាធិការ"[562]។ មិនមានភាពច្បាស់លាស់ឡើយថា តើ ឡាយ ប៊ុនហាក់ បានឃើញ មាស មុត "ត្រឡប់មក" កំពង់សោម ឬ ភ្នំពេញ។ ទោះជាក្នុងករណីណាក៏ដោយ ការសន្និដ្ឋានផ្ទាល់របស់ ឡាយ ប៊ុនហាក់ អំពីទីកន្លែងដែល មាស មុត "ប្រហែល" ជាទៅនោះ គឺមិនមានតម្លៃជាភស្តុតាងទេ។ ប្រសិនបើចម្លើយរបស់ ឡាយ ប៊ុនហាក់ ទទួលបានតម្លៃជាភស្តុតាងណាមួយនោះ ស.ច.ស. ចាំបាច់ត្រូវពិចារណាចម្លើយរបស់គាត់ ដែលផ្ទុយពីការអះអាងរបស់ ស.ព.អ. ដែលថា មាស មុត គ្រប់គ្រងលើកងពលធំលេខ ១៦៥ ក្រោយពេលគាត់ចាកចេញ[563] ទឹម សេង គ្រប់គ្រងលើកងយោធាទាំងអស់ ហើយទទួលបញ្ជូនបញ្ជាទាំងអស់ពីថ្នាក់លើ[564]។ ហ៊ឹង អ៊ុច ក៏បាននិយាយផងដែរថា ទឹម សេង ជាអ្នកចេញបញ្ជា ក្រោយពេល មាស មុត ចាកចេញទៅ[565]។

---

[561] ដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តី មាស មុត ទាក់ទងនឹងកែតម្រូវឯកសារនៅក្នុងសំណុំរឿង ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D176/1 កថាខណ្ឌ ៧(ច) ៖ "កំណត់ហេតុនៃការស្តាប់ចម្លើយ ឯកសារ D54/100 មិនបង្ហាញពីតារាងពេលវេលានៃការស្តាប់ចម្លើយនេះឡើយ ឧទាហរណ៍ មិនបានបង្ហាញថានៅពេលណាដែលសម្រាក ឬ នៅពេលដែលណាការស្តាប់ចម្លើយនេះបានបញ្ចប់នៅថ្ងៃទីមួយ ឬ បានចាប់ផ្តើមឡើងវិញនៅថ្ងៃទី ២ ឡើយ ហើយកំណត់ហេតុនេះមិនបានបង្ហាញថានៅពេលណា ឬ ហេតុអ្វីបានជាអ្នកធ្វើការស្តាប់ចម្លើយបានផ្លាស់ប្តូរពី Sarah Krys ទៅ Ignacio Tredici ដែរ។ ដោយសារបុគ្គលទាំងពីររូបនេះបានចាកចេញពី ក.ស.ច.ស. ហើយនិងពេលវេលាដែលកន្លងផុត ទើបតារាងពេលវេលាសម្រាប់ការស្តាប់ចម្លើយនេះមិនអាចផ្ទៀងផ្ទាត់បានឡើយ។ ការវាយតម្លៃអំពីផលប៉ះពាល់ដោយសារបញ្ហានេះមកលើតម្លៃភស្តុតាងនេះ នឹងធ្វើការវាយតម្លៃក្នុងពេលវេលាសមស្រប"។

[562] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 អ.១០០។

[563] កថាខណ្ឌ ៥៦ នៃដីកាសន្និដ្ឋានស្តាពរ។

[564] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 អ.៩៣, អ.៩៦។

[565] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/81 អ.១៤-១៦។

១៩១. **ព្រុំ សារ៉ាត**៖ ព្រុំ សារ៉ាត មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់អំពី មាស មុត និង អគ្គសេនាធិការ កើតចេញមកពីសំណួរនាំមុខរបស់អ្នកសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ព្រុំ សារ៉ាត ជាមេបញ្ជាការកងអនុសេនាធំ នៅក្នុងកងវរសេនាធំលេខ ១៤០ ដែលក្រោយមកក្លាយជាមេបញ្ជាការនាវា[566] បាននិយាយថា មាស មុត បានចាកចេញពីកំពង់សោមនៅក្នុងឆ្នាំ ១៩៧៨ ដើម្បីទៅភ្នំពេញ[567]។ ចម្លើយរបស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលថា មាស មុត ត្រូវបានតម្កើងឋានៈជាអគ្គមេបញ្ជាការរងនៃអគ្គសេនាធិការនៅដំណាច់ឆ្នាំ ១៩៧៨[568] គឺមានមូលដ្ឋានលើសំណួរនាំមុខរបស់អ្នកសម្ភាសន៍។ ក្រោយពេលដែល ព្រុំ សារ៉ាត បាននិយាយថា មាស មុត ទៅមេមត់ ដើម្បីជំនួស សុន សេន ដែលនៅជាអគ្គមេបញ្ជាការនៃអគ្គសេនាធិការនៅឡើយនោះ[569] អ្នកសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានសួរថា៖ "តាមុត អញ្ចឹងគាត់អគ្គមេបញ្ជាការរង?"[570]។ ព្រុំ សារ៉ាត បានឆ្លើយគាំទ្រ[571]។ ព្រុំ សារ៉ាត មិនបានផ្តល់ព័ត៌មានដោយខ្លួនឯង ដោយឯករាជ្យនោះទេ។

១៩២. **សាត ចក់**៖ សាត ចក់ មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ គឺផ្អែកលើពាក្យចចាមអារ៉ាមដែលមិនអាចផ្ទៀងផ្ទាត់បាន។ គាត់គឺជាទាហាននៅក្នុងកងវរសេនាធំលេខ ៦២ ដែលឈរជើងជាសំខាន់នៅលើកោះ[572]។ គាត់បានអះអាងថា គាត់បានឮ នៅក្នុងកិច្ចប្រជុំជាមួយមេបញ្ជាការរបស់គាត់ថា នៅក្នុងឆ្នាំ ១៩៧៨ មាស មុត ត្រូវបានផ្ទេរទៅភ្នំពេញ ដើម្បីទទួលតំណែងជាអគ្គ

---

[566] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.៥៥។

[567] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.៥៧។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.៧០ (ដែលឆ្លើយថា មាស មុត ស្ថិតនៅក្រោមបញ្ជាការផ្ទាល់របស់ សុន សេន)។

[568] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974226 KH 00926402-00926403។ ជើងទំព័រ ១៦០, ១៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

[569] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974225-00974226 KH 00926401-00926403។

[570] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974226 KH 00926402-00926403។

[571] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974226 KH 00926402-00926403។

[572] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.១៩-២១។ គាត់សម្រាកនៅមន្ទីរពេទ្យនៅកំពង់សោម រយៈពេលប្រហែល ៣ ខែ។ *សូមមើល ដូចខាងលើ* ឆ.៥១-៥២, ឆ.៥៤។

សេនាធិការរង[573]។ ការអះអាងរបស់ សាត ចក់ គឺផ្អែកលើការឮពីមនុស្សដែលមិនអាចកំណត់អត្តសញ្ញាណ[574]។

១៩៣. **មាស រឿន**៖ មាស រឿន មិនអាចជឿជាក់បានឡើយ។ គាត់មានការយល់ដឹងមានកម្រិត ហើយគាត់ទាយស្មានអំពី មាស មុត ហើយភរិយារបស់គាត់ បានធ្វើឱ្យប៉ះពាល់ដល់សក្តីកម្មរបស់គាត់នៅក្នុងពេលសម្ភាសន៍។ មាស រឿន បាន "តាំងខ្លួន"[575] ជាមេបញ្ជាការរងកងពលធំលេខ ១ នៃភូមិភាគបស្ចិម[576]។ គាត់ទទួលខុសត្រូវលើ "ទីតាំងភូមិសាស្ត្រមួយផ្នែកតូច" នៅក្នុងខេត្តកោះកុង[577] រហូតដល់ខែសីហា ឆ្នាំ១៩៧៨ ដែលនៅពេលនោះគាត់ត្រូវបានផ្ទេរទៅខេត្តព្រះវិហារវិញ[578]។ គាត់មិនមានទំនាក់ទំនងជាមួយ មាស មុត ទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[579]។ គាត់បានទាយស្មានថា មាស មុត គឺជាសមាជិកគណៈកម្មាធិការនៃអគ្គសេនាធិការ ពីព្រោះ មាស មុត បានផ្តល់យោបល់ដល់កងពលធំលេខ ១ អំពីប្រតិបត្តិការលើផ្ទៃសមុទ្រ ហើយបានរាយការណ៍ទៅ សុន សេន

---

[573] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឧ.១២៦-៣០។ ជើងទំព័រ ១៦០, ១៦៨ នៃដីកាសន្និដ្ឋានស្តាពរ ។

[574] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឧ.១២៦, ឧ.១២៩។

[575] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.180 ម៉ោង 09:43:42-09:48:37។

[576] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 ម៉ោង 09:56:40-09:59:40។

[577] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.180 ម៉ោង 09:43:42-09:48:37។

[578] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 ម៉ោង 09:51:44-09:56:40, 14:03:22-14:16:41។

[579] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 ម៉ោង 10:13:25-10:17:39។ *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 ម៉ោង 11:14:23-11:20:06, 11:40:21-11:46:59។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឧ.២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឧ.១៥។

និង បានទទួលការណែនាំពី សុន សេន[580]។ គាត់មិនដែលបានឮការប្រកាសជាផ្លូវការអំពី តួនាទី របស់ មាស មុត ឡើយ[581] ហើយការគិតរបស់គាត់ គឺផ្អែកលើអ្វីដែលគាត់បាន "សង្កេត" ទាក់ទងនឹង ការងាររបស់ មាស មុត[582] ទោះបីថា គាត់មិនដែលមានទំនាក់ទំនង ឬ បានជួបជាមួយ មាស មុត ក៏ដោយ[583]។ យ៉ាងច្រើនបំផុត ការអះអាងរបស់ មាស រឿន គឺឆ្លុះបញ្ចាំងអំពីតួនាទីរបស់មេ បញ្ជាការកងពលធំកងទ័ពជើងទឹក ដែលស្ថិតក្រោមអំណាចរបស់អគ្គសេនាធិការ[584] គឺមិនមែនជា អនុលេខានៅក្នុងអគ្គសេនាធិការឡើយ។ លើសពីនេះទៅទៀត ភរិយារបស់ មាស រឿន បានធ្វើឱ្យ ប៉ះពាល់ដល់ការចងចាំរបស់គាត់ ហើយជះឥទ្ធិពលដល់ភាពអាចជឿជាក់បាននៃចម្លើយរបស់ មាស រឿន។ ភរិយារបស់គាត់មានវត្តមាន នៅក្នុងការស្តាប់ចម្លើយដំបូងជាមួយ ក.ស.ច.ស. ដោយភរិយារបស់គាត់ស្តាប់សំណួរ និង ជួយគាត់ក្នុងការឆ្លើយសំណួរទាំងអស់នោះផង[585]។ ការ ជួយរបស់ភរិយាគាត់ ធ្វើឱ្យប៉ះពាល់ដល់សក្តិកម្មរបស់ មាស រឿន នៅក្នុងពេលស្តាប់ចម្លើយទាំង

---

[580] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.៥, អ.២៦។ ជើងទំព័រ ១៦០, ១៦៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* ផ្នែក IV.ត.២.ក *ខាងក្រោម* ទាក់ទងនឹងភាពគ្មានអំណាចរបស់ មាស មុត លើកងពលលេខ ១។

[581] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.៥។

[582] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.៥។

[583] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 ម៉ោង 10:13:25-10:17:39។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 ម៉ោង 11:14:23-11:20:06, 11:40:21-11:46:59។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 អ.២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.១៥។

[584] *សូមមើល* កថាខណ្ឌ ២១១ និង កថាខណ្ឌ ២១៣ *ខាងក្រោម* ទាក់ទងនឹងកងពល ១៦៤ និង អគ្គសេនាធិការ។

[585] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.180 ម៉ោង 10:35:04-11:38:02។ *សូមមើលផងដែរ* របាយការណ៍នៃសកម្មភាពការ ស៊ើបអង្កេត ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/56 ជើងទំព័រ ៧-៨ (កត់សម្គាល់ថា ព័ត៌មានរបស់ មាស រឿន ដែលថា ឡូញ នៅរស់ ហើយកំពុងរស់នៅប្រទេសថៃ គឺបានទទួលពីភរិយារបស់គាត់)។

នោះ ក៏ដូចជាសក្ខីកម្មរបស់គាត់នៅពេលក្រោយមក។ ការរឭកឡើងវិញដែលគាត់មាន នៅក្នុងសក្ខីកម្មដំបូងរបស់គាត់ បានទទួលរងឥទ្ធិពល ដោយសារតែការជួយរួមចំណែករបស់ភរិយាគាត់[586]។

១៩៤. **លុន សេង៖** លុន សេង មិនអាចជឿជាក់បានឡើយ។ ឋានន្តរសក្តិទាបរបស់គាត់ ធ្វើឱ្យគាត់មិនអាចដឹងបានលម្អិត អំពីសមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការអគ្គសេនាធិការជាទូទៅឡើយ។ លុន សេង រៀបរាប់ថា គាត់គឺជាប្រធានកងអនុសេនាធំ នៅក្នុងកងវរសេនាតូចលេខ ៤២០[587] ឬ ជាមេបញ្ជាការកងវរសេនាតូចលេខ ៤២០[588]។ គាត់បានអះអាងថា មេបញ្ជាការកងពលធំមជ្ឈិមទាំងអស់ គឺជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ ហើយថាតាមដែលគាត់បានដឹង មាស មុត គឺជាសមាជិកអគ្គសេនាធិការ ចាប់ពីខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ[589]។ ក្នុងនាមជាទាហានម្នាក់ ដែលយ៉ាងខ្ពស់បំផុត នៅកម្រិតកងវរសេនាតូច គាត់ប្រហែលជាមិនបានដឹងថាតើ មាស មុត គឺជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការឬយ៉ាងណានោះទេ។ ការមិនបានដឹងឮរបស់គាត់ត្រូវបានបញ្ជាក់ តាមរយៈការណ៍ដែលថា អគ្គសេនាធិការត្រូវបានបង្កើតឡើងតែចាប់ពីខែតុលា ឆ្នាំ ១៩៧៥ ប៉ុណ្ណោះ[590]។ មាស មុត មិនអាចជាសមាជិក (ទោះបីជាប្រភេទអ្វីក៏ដោយ) នៃអគ្គសេនាធិការឡើយ នៅក្នុងខែមេសា ឆ្នាំ ១៩៧៥។

១៩៥. **ឌុច៖** ឌុច មិនអាចជឿជាក់បានឡើយ[591]។ គាត់បានអះអាងថា មាស មុត ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការអគ្គសេនាធិការ នៅសន្និបាតបក្សថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ១៩៧៨[592]។ ការអះអាង

---

[586] *សូមមើល* សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. ចតយកសំឡេង ឬរូបភាពនូវរាល់ការស្តាប់ចម្លើយសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D136 កថាខណ្ឌ ១៦-២៤ ដែលពិភាក្សាពីវិធី ដែលបច្ចេកទេសសួរសំណួរអាចប៉ះពាល់ដល់ចម្លើយរបស់សាក្សី ជាពិសេស សាក្សីដែលមានវ័យចំណាស់។

[587] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/43 អ.៣។

[588] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/44 អ.១១។

[589] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/110 អ.៩-១០។ ជើងចំពរ ១៥៨ នៃដីកាសន្និដ្ឋានស្តាពរ។

[590] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN00183396, 00183402 KH 00019112-00019113, 00019119-00019120។

[591] *សូមមើល* កថាខណ្ឌ ១៧៥-៧៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[592] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 អ.១៨-១៩។ ជើងចំពរ ១៥៨ នៃដីកាសន្និដ្ឋានស្តាពរ។

នេះ គឺផ្ទុយពីការអះអាងផ្សេងទៀតរបស់គាត់ (រួមទាំងនៅក្នុងការស្តាប់ចម្លើយដដែលនេះ) ដែលថា មាស មុត គឺគ្រាន់តែជាសមាជិកបម្រុងនៃអគ្គសេនាធិការ[593] ឬ ជាសមាជិកនៃអគ្គសេនាធិការប៉ុណ្ណោះ[594]។ ដោយសារតែវង្វង់សមត្ថកិច្ចរបស់ ខុច មានដែនកម្រិតកំណត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ប្រហែលជាមិនបានដឹងអំពីព័ត៌មានជាក់លាក់អំពី មាស មុត ឡើយ។ បើទោះបីជា ស.ច.ស. ពិចារណាថាការអះអាងរបស់គាត់ មានតម្លៃជាភស្តុតាងក៏ដោយ ក៏ មាស មុត គឺជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ ក្នុងរយៈពេលចំនួនមិនដល់ពីរខែផង មុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ហើយគាត់បានបំពេញតួនាទីនេះ តែក្នុងការងារទាក់ទងនឹងកងពលធំលេខ ១៦៤ និង តំបន់ ៥០៥ ប៉ុណ្ណោះ។ កាលៈទេសៈចង្អៀតបែបនេះ មិនអាចលើកដំឡើង មាស មុត ឱ្យទៅដល់ប្រភេទ “មេដឹកនាំជាន់ខ្ពស់” បានឡើយ។

១៩៦. **ប៊ាង រ៉ែត**៖ ប៊ាង រ៉ែត មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ ប៊ាង រ៉ែត ដែលជាមេបញ្ជាការរងនៃកងអនុសេនាធំ នៅក្នុងកងវរសេនាតូចលេខ ៤៥០/១៦៥[595] គឺជាសាក្សីតែម្នាក់គត់ ដែល ស.ព.អ. បានដកស្រង់ថា បាននិយាយថា មាស មុត ស្ថិតនៅក្នុងគណៈកម្មាធិការ ហើយគាត់បានសំដៅទៅលើ “គណៈកម្មាធិការយោធា” ឬ “គណៈកម្មការយោធា”[596]។ គាត់មិនបានសំដៅជាពិសេស ទៅលើគណៈកម្មាធិការអគ្គសេនាធិការទេ[597]។

១៩៧. ស.ព.អ. អះអាងថា ឥទ្ធិពលរបស់ មាស មុត នៅក្នុងអគ្គសេនាធិការ “ឈានដល់ចំណុចកំពូលនៅចុងឆ្នាំ ១៩៧៨” នៅពេលដែលគាត់ត្រូវបានប្រគល់ភារកិច្ច ឱ្យគ្រប់គ្រងលើស្តាប់ន័យោធាទាំងបីផ្នែក ហើយត្រូវបានចាត់តាំងឱ្យធ្វើការបោសសម្អាត នៅក្នុងកងពលធំមជ្ឈិម និង តំបន់ស្វយ័តនានា

---

[593] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ន.២៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/160 ន.៨។

[594] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680797 KH 00680802-00680803។

[595] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ន.១១។

[596] ប្រតិចារឹកជាភាសាខ្មែរ នៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញថា ប៊ាង រ៉ែត បាននិយាយថា មាស មុត ជាអនុប្រធាន “គណៈកម្មការ” យោធា ហើយមិនមែន “គណៈកម្មាធិការ” ទេ។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ាង រ៉ែត ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D59/1/1.11a EN 00974120 KH 00926561។

[597] ផ្ទុយទៅនឹងការអះអាងរបស់ ស.ព.អ. នៅក្នុងកថាខណ្ឌ ៥៦ ជើងទំព័រ ១៧០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ាង រ៉ែត ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D59/1/1.11a EN 00974120 KH 00926561។

ជាច្រើន[598]។ ស.ព.អ. ក៏អះអាងផងដែរថា មាស មុត ត្រូវបានដំឡើងដំណែងជាអនុលេខា ដោយសារតែគាត់មាន "ការប្តេជ្ញា និង ការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវគោលនយោបាយប.ក.ក."[599]។ គាត់មិនបានបង្ហាញភស្តុតាងជាឯកសារ ឬ សាក្សី ដើម្បីគាំទ្រការអះអាងទាំងនេះឡើយ។ ជាការចាំបាច់ត្រូវតែបដិសេធចោលការអះអាងទាំងនេះ។ ចំពោះ "ការបោសសម្អាត នៅក្នុងកងពលធំមជ្ឈិម និង នៅក្នុងតំបន់ស្វយ័តនានា"[600] ស.ព.អ. នៅពេលក្រោយមក អះអាងត្រឹមថា មាស មុត បានចូលរួមក្នុងការបោសសម្អាត កម្លាភិបាលកងពលធំលេខ ១១៧ និង តំបន់ ៥០៥ នៅក្នុងខេត្តក្រចេះ ដោយចាប់ផ្តើមពីចុងខែវិច្ឆិកា ឆ្នាំ ១៩៧៨[601]។ *សូមមើល* ផ្នែក IV.គ.៨ *ខាងក្រោម* ទាក់ទងការអះអាងនេះ។

១៩៨. ស.ព.អ. មិនបានពិចារណាពីតួនាទីរបស់អគ្គសេនាធិការឡើយ នៅពេលអះអាងថា មាស មុត មានមុខដំណែងផ្លូវការនៅក្នុងអគ្គសេនាធិការនោះ។ អគ្គសេនាធិការតាមរយៈ សុន សេន[602] និង ប្រហែលជា តា ម៉ុក[603] បានអនុវត្ត និង ផ្សព្វផ្សាយ ការណែនាំ និង បទបញ្ជារបស់គណៈកម្ម

---

[598] កថាខណ្ឌ ៥៣ នៃដីកាសន្និដ្ឋានស្តាពរ។

[599] កថាខណ្ឌ ៥៦ ជើងទំព័រ ១៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[600] កថាខណ្ឌ ៥៣ នៃដីកាសន្និដ្ឋានស្តាពរ។

[601] កថាខណ្ឌ ៥៨ កថាខណ្ឌ ៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[602] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183396-00183397 KH 00019112-00019114 ដែល សុន សេន មានភារកិច្ចខាងគោលនយោបាយ ពាក់ព័ន្ធនឹងអគ្គសេនាធិការ ហើយបានណែនាំឱ្យ "[ចាត់]ចែងកងទ័ពថ្មី ជើងទឹក [និង] អាកាស"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៥៨, ឆ.៦០។ *សូមមើលផងដែរ* កថាខណ្ឌ ២៤០ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[603] សេចក្តីវាយការណ៍ ចំណងជើងថា "សេចក្តីវាយការណ៍របស់ មាស មុត ផ្ញើជូន សុន សេន ទាក់ទងនឹងស្ថានភាពនៅតាមព្រំដែនថៃ" ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.18 EN 00233992-00233993 KH 00162487 (សុន សេន បាននិយាយពី តា ម៉ុក វាយតម្លៃទូកបរទេសមួយ)។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 ម៉ោង 15:33:30-15:35:58។ កំណត់ហេតុនៃ ការស្តាប់ចម្លើយសាក្សី ឈួក រិន ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/87 ឆ.៨៥, ឆ.៨៩ (គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយ ដែល តា ម៉ុក ធ្វើឡើងសម្រាប់ "អង្គភាពរបស់ [តា ម៉ុក]" ដែលក្នុងពេលនោះ តា ម៉ុក បាននិយាយអំពីការការពារជាតិ ការពារពីខ្មាំង)។ *សូមមើល* កថាខណ្ឌ ១៦៩-៧០ និង កថាខណ្ឌ ១៧២ *ខាងលើ* ដែលពិភាក្សាពីតួនាទីរបស់ តា ម៉ុក នៅក្នុង ប.ក.ក. និង សិទ្ធិអំណាចគ្រប់គ្រង។

ធិការអចិន្ត្រៃយ៍ ទាក់ទងនឹងបញ្ហាកងទ័ព និង ការការពារជាតិ[604]។ នៅពេលដែលអគ្គសេនាធិការ បញ្ជូនការណែនាំ និង បទបញ្ជាបន្តទៅកងពលធំមជ្ឈិមហើយ[605] ពួកគេចាំបាច់ត្រូវតែគោរពតាម[606]។ កងពលធំមជ្ឈិមមិនមែនជាកងស្វយ័ត ដែលអាចធ្វើសកម្មភាពតាមចិត្តឯងឡើយ។ ដោយសារតែសិទ្ធិអំណាចរបស់អគ្គសេនាធិការទៅលើកងពលធំមជ្ឈិម វាជារឿងសមហេតុផលដែលថា សមាជិកគណៈកងពលធំមជ្ឈិម នឹងត្រូវបានចាត់ទុកថាជា អនុប្រធាន ឬ អ្នកនៅក្រោមបង្គាប់ ប្រធានអគ្គសេនាធិការ។

១៩៩. មានភស្តុតាងដែលថាចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧ សុន សេន មិនមានអនុប្រធានឡើយ នៅក្នុងអគ្គសេនាធិការ ប៉ុន្តែ ស៊ូ ម៉ែត បានធ្វើការនៅមន្ទីរអគ្គសេនាធិការ នៅពេល សុន សេន អវត្តមាន។ ចាប់ពីខែមិថុនា ឆ្នាំ ១៩៧៧ ឡុញ ដុស បានត្រួតពិនិត្យលើផ្នែកវិទ្យុទាក់ទង និង ទូរស័ព្ទ នៅមន្ទីរអគ្គសេនាធិការ[607]។ គាត់នៅស្និទ្ធិជាមួយ សុន សេន[608]។ នៅចុងឆ្នាំ ១៩៧៧ គាត់បានទៅខេត្ត

---

[604] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183396-00183397 KH 00019112-00019114 (ការការពារជាតិត្រូវបានរៀបចំនៅមជ្ឈិម)។ របាយការណ៍អ្នកជំនាញការ Craig Etcheson ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ ឯកសារ D234/2.1.52 កថាខណ្ឌ ១២១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680797-00680798 KH 00680802-00680804។ *សូមមើលផងដែរ* កថាខណ្ឌ ២៤០, កថាខណ្ឌ ២៤២ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។ ដូចដែល ស.ព.អ. បានទទួលស្គាល់នៅក្នុងកថាខណ្ឌ ៥២ នៃដីកាសន្និដ្ឋានស្តាពរ។

[605] *សូមមើលខ.ទ.* កថាខណ្ឌ ២១៣ *ខាងក្រោម* ទាក់ទងនឹងការប្រជុំរវាងអគ្គសេនាធិការ និង កងពលមជ្ឈិម និង វរសេនាធំឯករាជ្យ។

[606] មាត្រា ៦(៥) នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ កំណត់ហេតុនៃការប្រជុំយោធាចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភារកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.23 EN 00233719 KH 00095515 ("<u>ទីតាំងយោធា</u>៖ ត្រូវរៀបចំ ពិសេសកងអន្តរាគមន៍ ត្រូវសំរិតសំរាំងឱយស្អាត ហើយកងនេះ លុះត្រាតែមានបញ្ជាពីសេនាធិការទៅកងពល ហើយកងពលបញ្ជា ទើបអាចចេញប្រតិបត្តិការបាន")។ (ការគូសបញ្ជាក់ក្នុងឯកសារដើម)។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.1 ម៉ោង 16:15:54-16:30:00 ("[បណ្ឌិត Etcheson] ... [អំណាច]តាមឋានានុក្រម គឺវាស្ថិតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយវាស្ថិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ បុគ្គលទាំងឡាយដែលស្ថិតក្នុងការអង្គចាត់តាំងនេះ ត្រូវតម្រូវឱ្យធ្វើការគោរពទៅលើបញ្ជា និងសេចក្តីបង្គាប់ផ្សេងៗរបស់ថ្នាក់លើ")។

[607] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364070 KH 00357491។

[608] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D4.1.520 EN 00346152 KH 00340566។

ស្វាយរៀងជាមួយ សុន សេន[609]។ ឡុញ ដុស បាននិយាយថា តាមការដឹងឮរបស់គាត់ សុន សេន មិនមានអនុប្រធានទេ នៅពេលដែលគាត់នៅភ្នំពេញ ព្រោះមន្ទីររបស់គាត់គ្មានមនុស្សនៅ ពេលដែល សុន សេន មិននៅទីនោះ[610]។ គាត់ក៏បាននិយាយផងដែរថា នៅពេល សុន សេន នៅភូមិភាគបូព៌ា គាត់បានធ្វើដំណើរទៅមករវាងស្វាយរៀង និង ភ្នំពេញ[611]។ នៅពេល សុន សេន អវត្តមាន ឡុញ ដុស ជាញឹកញាប់បានឃើញ ស៊ូ ម៉ែត ចេញចូលអគ្គសេនាធិការ[612] ទោះបីជា ឡុញ ដុស មិនបាននិយាយពីអំឡុងពេលវេលា ដែលហេតុការណ៍នេះបានកើតឡើងក៏ដោយ។ គាត់មិនបាននិយាយថា គាត់បានឃើញ មាស មុត នៅមន្ទីរអគ្គសេនាធិការ នៅពេល សុន សេន អវត្តមានឡើយ។

ខ. ការទទួលខុសត្រូវរបស់ មាស មុត ចំពោះអគ្គសេនាធិការ មិនមានការផ្លាស់ប្តូរខ្លាំងឡើយ នៅក្នុងឆ្នាំ ១៩៧៨

២០០. ប្រភពដែល ស.ព.អ. ដកស្រង់ មិនគាំទ្រឡើយដល់ការអះអាងរបស់គាត់ដែលថា ការទទួលខុសត្រូវរបស់ មាស មុត បានផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងឆ្នាំ ១៩៧៨ ដោយសារតែគាត់ត្រូវដំឡើងដំណែងជាអនុលេខាអគ្គសេនាធិការ[613] ដោយប្តូរពីការផ្តល់ការគាំទ្រខាងភស្តុភារ ទៅជាទទួលខុសត្រូវចូលរួម ក្នុងការត្រួតពិនិត្យមើលបញ្ហាព្រំដែន មានសិទ្ធិអំណាចក្នុងការសម្រេច ជំនួសឱ្យសេនាធិការ និង ទទួលបន្ទុកលើការប្រតិបត្តិ តាមបញ្ជាពីមជ្ឈិមបក្ស[614]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន និង មិនមានការគាំទ្រ របស់ លៀត ឡន ម៉ឹង វេត មាស វឿន

---

[609] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 0036471 KH 00357492-00357493។

[610] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D114/142 EN 01175091 KH 01421504។

[611] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.845 អ.៤៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364072 KH 00357493-00357494 (បានឆ្លើយថា ពេលគាត់នៅស្វាយរៀង សុន សេន តែងតែឡើងមកប្រជុំនៅមជ្ឈិមជាមួយ ប៉ុល ពត)។

[612] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.845 អ.៤៥។ ឌុច ក៏បាននិយាយថា ពេលខ្លះ គាត់បានឃើញ ស៊ូ ម៉ែត ចេញពីផ្ទះ សុន សេន។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 អ.២៧។

[613] កថាខណ្ឌ ៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[614] កថាខណ្ឌ ៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

សេង សឿន និង ព្រំ សារ៉ាត[615]។ ភស្តុតាងដែលបង្ហាញថា មាស មុត ត្រូវបានផ្ទេរទៅតំបន់ ៥០៥ នៅចុងឆ្នាំ ១៩៧៨ គឺមិនមែនជាភស្តុតាងដែលបង្ហាញថា គាត់ត្រូវបានដំឡើងដំណែង ជាអនុលេខាអគ្គសេនាធិការឡើយ។ នេះគឺគ្រាន់តែជាភស្តុតាងដែលបង្ហាញថា នៅពេលដែលមានការវាយប្រយុទ្ធយ៉ាងតានតឹងជាមួយនឹង វៀតណាម[616] មជ្ឈិមបក្ស និង អគ្គសេនាធិការ បានបញ្ជូនកងពលធំមជ្ឈិមទៅតំបន់ ៥០៥ ជាទីកន្លែងដែលមានជម្លោះមួយចំនួនបានកើតឡើងប៉ុណ្ណោះ[617]។

២០១. **លៀត ឡុន៖** លៀត ឡុន មិនអាចជឿជាក់បានឡើយ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភាគច្រើនគាត់បានស្នាក់នៅប្រទេសចិន ហើយចម្លើយរបស់គាត់អំពី មាស មុត គឺផ្អែកលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ លៀត ឡុន ត្រូវបានបញ្ជូនទៅប្រទេសចិននៅក្នុងខែមករា ឆ្នាំ ១៩៧៦[618]។ រហូតដល់ចុងឆ្នាំ ១៩៧៨ ទើបគាត់ត្រឡប់មកវិញ[619] ហើយបានក្លាយជាមេបញ្ជាការកងវរសេនាតូចលេខ ១៤២[620]។ គាត់មិនបានជួប មាស មុត ទេ មុនពេលគាត់ត្រឡប់មកវិញ[621]។ ដោយសារតែគាត់ស្នាក់នៅបរទេស ទើបគាត់បានដឹងត្រឹមតែពេលចាប់ផ្តើម និង ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ[622]។ លៀត ឡុន បានឮពីមេរបស់គាត់គឺ ទឹម សេង ថា មាស មុត គឺជាជំនួយ

---

[615] ជើងទំព័រ ១៧១-៧៤ នៃដីកាសន្និដ្ឋានស្តាពរ។

[616] *សូមមើល ឧទា.* សារទូរលេខពីក្រសួងការបរទេស កម្ពុជាប្រជាធិបតេយ្យ ចំណងជើងថា "សារទូរលេខ សមាគមមិត្តភាពស៊ុយអែត-កម្ពុជា" ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៧៨ ឯកសារ D234/2.1.9 EN 00717585 KH 00749403-00749404។ សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D69.1.5 EN 00282392 KH 00277200។ Linda Mathews *ទីក្រុងហាណូយត្រៀមវាយលុកចូលប្រទេសកម្ពុជា* LOS ANGELES TIMES ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ១៩៧៨ ឯកសារ D1.3.25.65។

[617] សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ ក្រសួងឃោសនា និង ពត៌មាននៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៨ ឯកសារ D1.3.29.1 EN 00337188 KH 00234029៖ "ក្នុងពេលជាមួយគ្នានឹងសមរភូមិសំខាន់ៗខាងលើនេះ នៅមណ្ឌលគិរី រតនគិរី និង ក្រចេះ កងទ័ពយួនបានបាញ់ផ្តោង បាញ់រះ និង ទន្ទ្រានយកទឹកដីកម្ពុជា"។ *រឿងក្តី ឡុន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.23 ម៉ោង 11:07:06-11:09:10, 15:16:21-15:18:49។

[618] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/28 ឆ.១៧។

[619] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ឆ.៦០-៦២។ *សូមមើលផងដែរ ដូចខាងលើ* ឆ.៥១ ដែលគាត់បាននិយាយថា ក្រោយពីរឃៈពេល ២០ខែ គាត់បានត្រលប់មកវិញ។

[620] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ឆ.៦៧, ៨៦។

[621] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ឆ.៩៦។

[622] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ឆ.១។

ការអគ្គសេនាធិការ[623]។ "បើតាមការយល់ឃើញ" របស់គាត់ នេះមានន័យថា មាស មុត បានជួយផ្តល់ការគាំទ្រក្នុងការបែងចែកកងកម្លាំង បង្កើតយុទ្ធសាស្ត្រប្រយុទ្ធគាំទ្រផ្នែកភស្តុភារ ផ្គត់ផ្គង់ស្បៀងអាហារ និង គ្រាប់រំសេវ[624]។ លៀត ឡន ទើបបានដឹងអំពីតួនាទី "ជំនួយការ" របស់ មាស មុត នៅពេលដែលវៀតណាម ជិតនឹងចូលមកដល់កម្ពុជាទៅហើយ[625]។ យ៉ាងច្រើនបំផុត ចម្លើយរបស់ លៀត ឡន ចង្អុលបង្ហាញថា តួនាទីណាមួយរបស់ មាស មុត នៅក្នុងអគ្គសេនាធិការ គឺមាននៅចុងឆ្នាំ ១៩៧៨ ហើយគ្រាន់តែចូលរួមពាក់ព័ន្ធនឹងតួនាទីជាជំនួយការប៉ុណ្ណោះ គឺមិនមែនអនុលេខាទេ[626]។

២០២. **ម៉ឹង វេត**៖ ម៉ឹង វេត មិនអាចជឿជាក់បានឡើយ[627]។ ស.ព.អ. ពឹងផ្អែកយ៉ាងច្រើនទៅលើគាត់ ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួន អំពីការទទួលខុសត្រូវដែលកើនឡើងរបស់ មាស មុត។ ម៉ឹង វេត បានអះអាងថា មាស មុត មានការទទួលខុសត្រូវលើព្រំដែនខាងបូព៌ាចាប់តាំងពីឆ្នាំ ១៩៧៨[628] ហើយគាត់ទទួលរបាយការណ៍ និង ធ្វើសេចក្តីសម្រេចតាមសំណើ[629] ហើយគាត់បានត្រួតពិនិត្យលើ

---

[623] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 អ.៣។

[624] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 អ.១០។ ជើងទំព័រ ១៧១ នៃដីកាសន្និដ្ឋានស្តាពរ។

[625] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 អ.១៣។

[626] ចម្លើយរបស់ លៀត ឡន ដែលមិនត្រូវបានឆ្លុះបញ្ចាំងពេញលេញ នៅក្នុងដីកាសន្និដ្ឋានស្តាពរ គាំទ្រការបកស្រាយថា៖ "តាមការយល់ដឹងរបស់ខ្ញុំ មុខងាររបស់ជំនួយការសេនាធិការ គឺ*ជួយ* ខាងចាត់ចែងកម្លាំង *ជួយ* ឃុទ្ធសាស្ត្រវែ *ជួយ* ខាងភស្តុភារ ការផ្គត់ផ្គង់ស្បៀង និង គ្រាប់រំសេវ។ ទាំងអស់នេះគឺការងារចម្បងរបស់កងទ័ព"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 អ. ១០ (ការគូសបញ្ជាក់បន្ថែម)។

[627] *សូមមើល* កថាខណ្ឌ ១៨២-៨៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមអំពីសាក្សីរូបនេះ។

[628] ជើងទំព័រ ១៧២ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 អ.២២, អ.២៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/63 អ.១៩។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212292 KH 00975728-00975729។

[629] ជើងទំព័រ ១៧៣ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ *រឿងក្តី ឡន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 ម៉ោង 09:41:57-09:47:01។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/63 អ.១១-១៣។

ការបោសសម្អាតកងពលធំលេខ ១១៧ និង តំបន់ ៥០៥ នៅក្នុងខេត្តក្រចេះនៅចុងឆ្នាំ ១៩៧៨[630]។ ចម្លើយទាំងនេះមានមូលដ្ឋានលើពាក្យចចាមអារ៉ាម និង ការទាយស្មាន[631]។

២០៣. ម៉ឹង វេត គឺគ្រាន់តែជាសាក្សីដែល ស.ព.អ. ដកស្រង់ ដើម្បីគាំទ្រដល់ការអះអាងដែលថា មាស មុត មានសិទ្ធិអំណាចក្នុងការសម្រេច ជំនួសឱ្យអគ្គសេនាធិការប៉ុណ្ណោះ[632]។ ចម្លើយរបស់គាត់មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. នោះទេ។ នៅពេលដំបូង ម៉ឹង វេត បានប្រាប់ ក.ស.ច.ស. ថា របាយការណ៍របស់គាត់ ត្រូវបញ្ជូនទៅអគ្គសេនាធិការ មិនមែនទៅបុគ្គលជាក់លាក់ណាម្នាក់ទេ[633]។ បន្ទាប់មកគាត់បាននិយាយថា សុន សេន មាស មុត និង ស៊ូ ម៉ែត មានសិទ្ធិអំណាចក្នុងការទទួលរបាយការណ៍របស់គាត់ ហើយអ្នកណាឆ្លើយតប គឺស្រេចលើពួកគាត់[634] ហើយ មាស មុត និង សុន សេន នឹងទំនាក់ទំនងគ្នាទៅវិញទៅមក អំពីរបាយការណ៍[635]។ ម៉ឹង វេត មិនបានអះអាងថា នរណាជាអ្នកអាចសម្រេចចុងក្រោយបំផុតនោះទេ។ នៅពេលក្រោយមក គាត់ទទួលស្គាល់ថា គាត់ទាយស្មាន គឺគាត់មិនបានដឹងលម្អិតអំពីការទំនាក់ទំនង រវាង មាស មុត និង សុន សេន ឡើយ

---

[630] ជើងទំព័រ ១៧៦ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.23 ម៉ោង 09:35:25-09:39:51។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 ម៉ោង 09:52:25-09:55:21។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឆ.២៤, ឆ.២៩-៣០, ឆ.៣២-៣៣, ឆ.៣៨-៣៩។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 00992998-00992999 KH 00975741-00975744។ *សូមមើលផងដែរ* ជើងទំព័រ ១៧៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 ម៉ោង 09:39:45-09:47:01។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/63 ឆ.១១-១៩។

[631] *សូមមើល* កថាខណ្ឌ ១៨៣ *ខាងលើ* ដែលពិភាក្សាពីការអះអាងទាំងនេះ។

[632] កថាខណ្ឌ ៥៧ ជើងទំព័រ ១៧៣ នៃដីកាសន្និដ្ឋានស្តាពរ ។ *សូមមើលផងដែរ* កថាខណ្ឌ ៥៨ ជើងទំព័រ ១៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[633] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/63 ឆ.១៦។

[634] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 ម៉ោង 09:37:29-09:45:02។

[635] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.23 ម៉ោង 13:44:41-13:50:21។

ហើយគាត់ក៏មិនបានឃើញការទំនាក់ទំនងរវាងពួកគេទាំងពីរនោះដែរ[636]។ សក្ខីកម្មរបស់ ម៉ឹង វេត ដែលថា មាស មុត បានបញ្ជូនយន្តហោះទៅទីកន្លែងរបស់គាត់ មិនបានបង្ហាញថា មាស មុត ជាអ្នកសម្រេចបញ្ជូនយន្តហោះទៅឡើយ។ ម៉ឹង វេត គ្រាន់តែនិយាយថា មាស មុត បានប្រាប់រ៉ុមឱ្យរង់ចាំ ហើយនៅពេលរសៀលគាត់បញ្ជូនយន្តហោះទៅ[637]។ មិនមានការចង្អុលបង្ហាញថា មាស មុត បានចេញបញ្ជាឱ្យបញ្ជូនយន្តហោះឡើយ។ ដោយសារតែកងទ័ពអាកាស ស្ថិតក្រោមអំណាចផ្ទាល់របស់អគ្គសេនាធិការ[638] ប្រហែលជា ស៊ូ ម៉ែត ឬ សុន សេន ជាអ្នកធ្វើការសម្រេច។

២០៤. **មាស វឿន**៖ មាស វឿន មិនអាចជឿជាក់បានឡើយ[639]។ មាស វឿន បានអះអាងថា នៅក្នុងឆ្នាំ ១៩៧៨ មាស មុត និង សឿង ជាមេបញ្ជាការកងពលធំលេខ ១ បានផ្សព្វផ្សាយការណែនាំរបស់ សុន សេន ឱ្យបន្តយការប្រឈមមុខគ្នា នៅតាមព្រំដែនភាគបស្ចិម[640]។ ការអះអាងរបស់គាត់នេះ គឺផ្អែកតែលើពាក្យចចាមអារ៉ាមមួយមុខប៉ុណ្ណោះ។ មាស វឿន មិនដែលបានចូលរួមក្នុងការប្រជុំណាមួយជាមួយ មាស មុត និង សឿង ឡើយ[641] ហើយគាត់មិនដែលមានទំនាក់ទំនង ឬ ការប្រាស្រ័យទាក់ទងជាមួយ មាស មុត ឡើយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[642]។ ចម្លើយរបស់

---

[636] *រឿងក្តី ខ្លួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 ម៉ោង 10:11:57-10:16:50 (ដែលពិភាក្សាពីសក្ខីកម្មមុនៗរបស់គាត់ ក្នុង *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.23 ម៉ោង 13:44:41-13:50:21)។

[637] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/63 ឆ.១១-១៣។

[638] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183396-00183397 KH 00019112-00019114។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/160 ឆ.១៣-១៥។

[639] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមអំពីសាក្សីរូបនេះ។

[640] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.២៦។ កថាខណ្ឌ ៥៧ ជើងទំព័រ ១៧២ នៃដីកាសន្និដ្ឋានស្តាពរ។

[641] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.១៥។

[642] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 ម៉ោង 10:11:34-10:15:02។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 ម៉ោង 11.14.23-11.20.06។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.១៥។

គាត់មិនបានចង្អុលបង្ហាញថា មាស មុត គឺជាអនុលេខាអគ្គសេនាធិការ ឬ ជាអ្នកត្រួតពិនិត្យបញ្ហាព្រំដែនឱ្យ សុន សេន ឡើយ។ ចម្លើយនេះចង្អុលបង្ហាញត្រឹមថា មាស មុត បានចូលរួមក្នុងការប្រជុំជាមួយ សុន សេន និង មេបញ្ជាការយោធា ផ្សេងទៀត យ៉ាងហោចណាស់ម្នាក់ ហើយនៅក្នុងការប្រជុំនោះ មេបញ្ជាការទាំងពីរបានទទួលការណែនាំ អំពីការកាត់បន្ថយការប្រឈមមុខ នៅតាមព្រំដែនភាគបស្ចិម។ ការប្រជុំនេះ មិនមានអ្វីក្រៅពីការប្រជុំជាទូទៅរបស់អគ្គសេនាធិការប៉ុណ្ណោះ ដែលនៅក្នុងការប្រជុំនោះ សុន សេន បានផ្សព្វផ្សាយនូវគោលនយោបាយ និង ការណែនាំពីសំណាក់មេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក.[643]។

២០៥. **សេង សឿន**៖ សេង សឿន មិនអាចជឿជាក់បានឡើយ[644]។ សេង សឿន បាននិយាយថា នៅពេលដែលគាត់បានមកដល់ខេត្តក្រចេះ មាស មុត បានប្រកាសតែងតាំងរូបគាត់[645]។ សេង សឿន បានផ្តល់ចម្លើយផ្ទុយគ្នាអំពីតួនាទីរបស់ មាស មុត ក្នុងការតែងតាំងរូបគាត់។ នៅពេលប្រាប់ ក.ស.ច.ស. សេង សឿន បាននិយាយថា មាស មុត បានទទួលលិខិតពីគណៈមជ្ឈិម ដែលក្នុងលិខិតនោះមានរៀបរាប់ពីអ្នក ដែលត្រូវបានទទួលការចាត់តាំងថ្មីទៅតំបន់ ៥០៥[646] ហើយថាបទបញ្ជាចាប់ខ្លួនកម្លាភិបាលតំបន់ ៥០៥ និង កងពលធំលេខ ១១៧ គឺចេញពី សុន សេន[647]។ នៅក្នុងរឿងក្តី ០០២/០២ គាត់បានផ្លាស់ប្តូររឿងរបស់គាត់។ គាត់បាននិយាយថា មិនមានលិខិត ឬ បញ្ជាណាយលក្ខណ៍អក្សរឡើយ ហើយអ្នកត្រូវតែងតាំងថ្មីគ្រាន់តែយកប្រវត្តិរូបពួកគេ មកប្រគល់ឱ្យ មាស មុត ប៉ុណ្ណោះ[648]។ ចម្លើយរបស់ សេង សឿន អំពីការអនុវត្តបញ្ជារបស់មជ្ឈិមដោយ

---

[643] *សូមមើល* កថាខណ្ឌ ២១៣ *ខាងក្រោម* ដែលពិភាក្សាលម្អិតអំពីការប្រជុំរបស់អគ្គសេនាធិការ។

[644] *សូមមើល* កថាខណ្ឌ ១៨៤-៨៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមអំពីសាក្សីរូបនេះ។

[645] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ន.៥, ន.២៣។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៦ ឯកសារ D59/2/4.16a EN 00753837-00753838 KH 00059329-00059331។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 ម៉ោង 13:46:28-13:51:55។ ជើងទំព័រ ១៧៤, ១៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

[646] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.810 ន.២៦-២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ន.២០។

[647] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.810 ន.២៥, ន.៤៨។

[648] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 ម៉ោង 13:48:25-13:57:43។

មាស មុត នៅខេត្តក្រចេះនោះ គឺមិនមានតម្លៃជាភស្តុតាងឡើយ។ បើទោះបីជា ស.ច.ស. ពិចារណាចម្លើយរបស់គាត់ថា មានតម្លៃជាភស្តុតាងក៏ដោយ ក៏ចម្លើយទាំងនេះមិនបានកំណត់ថា មាស មុត "ទទួលខុសត្រូវ" លើការអនុវត្តបញ្ជារបស់មជ្ឈិមដែរ[649] គឺគ្រាន់តែបង្ហាញថា គាត់ត្រូវបានបញ្ជូនទៅខេត្តក្រចេះ ដើម្បីអនុវត្តបញ្ជាដែលចេញដោយមជ្ឈិមប៉ុណ្ណោះ។

២០៦. **ព្រុំ សារ៉ាត**៖ ព្រុំ សារ៉ាត មិនអាចជឿជាក់បានឡើយ[650]។ ការអះអាងរបស់ ព្រុំ សារ៉ាត ដែលថា មាស មុត ទៅភូមិភាគឫទ្ធិ គឺផ្អែកលើពាក្យចចាមអារ៉ាម ដែលមិនអាចផ្ទៀងផ្ទាត់បាន និង មិនមានអ្វីគាំទ្រឡើយ[651]។ គាត់បានអះអាងថា មាស មុត បានទៅខេត្តកំពង់ចាម ដើម្បីបំពេញការងារជំនួស សុន សេន ក្នុងការបង្ក្រាបពួកបះបោរភូមិភាគឫទ្ធិ ដែលដឹកនាំដោយ សោ ភឹម[652]។ គាត់បានឮរឿងនេះពីមេបញ្ជាការកងវរសេនាធំរបស់គាត់[653]។ រឿងនេះមិនមានការគាំទ្រដោយភស្តុតាងផ្សេងៗទៀតនៅក្នុងសំណុំរឿងនោះឡើយ។ នៅក្នុងការស្តាប់ចម្លើយចុងក្រោយរបស់គាត់ ជាមួយ ក.ស.ច.ស. ព្រុំ សារ៉ាត មិនបាននិយាយសំដៅលើ មាស មុត ថាត្រូវបានបញ្ជូនទៅខេត្តកំពង់ចាមឡើយ គឺគ្រាន់តែនិយាយថា មាស មុត ត្រូវបានបញ្ជូនទៅខេត្តក្រចេះប៉ុណ្ណោះ[654]។

---

[649] កថាខណ្ឌ ៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[650] *សូមមើល* កថាខណ្ឌ ១៩១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមអំពីសាក្សីរូបនេះ។

[651] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 អ.៧៣-៧៦។ *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 ម៉ោង 09:26:11-09:31:50។

[652] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 អ.៧៣-៧៦, អ.៨៤។ *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 ម៉ោង 09:26:11-09:31:50។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រុំ សារ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974226 KH 00926402-00926403។ កថាខណ្ឌ ៥៨ ជើងទំព័រ ១៧៤-៧៥, កថាខណ្ឌ ១២៤ ជើងទំព័រ ៣៧០ នៃដីកាសន្និដ្ឋានស្តាពរ។

[653] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 អ.៧៥។ *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 ម៉ោង 09:26:11-09:31:50។

[654] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 អ.២០៦, អ.២២៤-២២៥។

គ. សេចក្តីសន្និដ្ឋាន

២០៧. មាស មុត មិនមែនជាអនុលេខានៃអគ្គសេនាធិការ ឬ ជាសមាជិកគណៈកម្មាធិការនៃអគ្គសេនាធិការឡើយ ទាំងតាមផ្លូវច្បាប់ ទាំងការអនុវត្តជាក់ស្តែង ហើយគាត់ក៏មិនបានទទួលភារកិច្ចទទួលខុសត្រូវខ្ពស់ណាមួយខ្លាំងឡើយ នៅក្នុងឆ្នាំ ១៩៧៨។ ដោយត្រូវបានផ្ទេរទៅភ្នំពេញ ដើម្បីធ្វើការនៅបញ្ជាការដ្ឋានអគ្គសេនាធិការ ឬ ផ្ទេរទៅតំបន់ ៥០៥ ដើម្បីអនុវត្តបញ្ជារបស់អគ្គសេនាធិការ ឬ មជ្ឈិមបក្ស គឺមិនមានន័យថា មាស មុត គឺជាអនុលេខានៃអគ្គសេនាធិការ ឬ សមាជិកគណៈកម្មាធិការអគ្គសេនាធិការឡើយ។ យ៉ាងច្រើនបំផុត ភស្តុតាងចង្អុលបង្ហាញថា មាស មុត ក្នុងនាមជាសមាជិកគណៈកងពលធំលេខ ១៦៤ និង កងទ័ពជើងទឹក គឺស្ថិតក្រោមបញ្ជារបស់អគ្គសេនាធិការដែលចាំបាច់ត្រូវរាយការណ៍ទៅអគ្គសេនាធិការ ហើយត្រូវទទួលបញ្ជាពីអគ្គសេនាធិការ។ ទាល់តែក្នុងអត្ថន័យបែបនេះ ទើបអាចហៅ មាស មុត ថាជា "អនុ" របស់ សុន សេន ឬ "សមាជិក" អគ្គសេនាធិការ។

៤. បើទោះបីជា មាស មុត បានបញ្ជាកងពលធំលេខ ៣ និង ក្រោយមកបញ្ជាកងពលធំលេខ ១៦៤ និង កងទ័ពជើងទឹកក៏ដោយ ក៏មុខដំណែងទាំងនេះ មិនធ្វើឱ្យគាត់ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ដែរ

២០៨. ស.ព.អ. អះអាងថា មាស មុត គឺជាមេបញ្ជាការកងពលធំលេខ ៣ និង ក្រោយមកជាមេបញ្ជាការកងពលធំលេខ ១៦៤ ហើយថា មុខដំណែងទាំងនេះ បានធ្វើឱ្យគាត់ក្លាយជា "មេដឹកនាំជាន់ខ្ពស់"[655]។ ស.ព.អ. ពឹងផ្អែកលើភស្តុតាង ដែលមានមូលដ្ឋានលើពាក្យចចាមអារ៉ាម ឬ ការទាយស្មាន។ ស.ព.អ. មិនបានគិតពីភស្តុតាងបរិបទ ឬ រចនាសម្ព័ន្ធដែលពាក់ព័ន្ធឡើយ។ ស.ព.អ. មិនបានបង្ហាញភស្តុតាង ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់។ បើទោះបីជា មាស មុត បានដឹកនាំកងពលធំលេខ ៣ កងពលធំលេខ ១៦៤ និង កងទ័ពជើងទឹកក្តី ក៏តួនាទីទាំងនេះមិនបានធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" នោះដែរ។

[655] កថាខណ្ឌ ៤៥-៤៦, ៦៧, ៨១, ១០៨២-៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

ក. កងពលធំលេខ ៣ ស្ថិតក្រោមសិទ្ធិអំណាចរបស់ តា ម៉ុក ដែលជាលេខាភូមិភាគនិរតី

២០៩. កងពលធំលេខ ៣ ដែលជាកងយោធាភូមិភាគនិរតី គឺស្ថិតក្រោមអំណាចផ្ទាល់របស់ តា ម៉ុក ដែលជាលេខាភូមិភាគនិរតី និង ជាសមាជិកគណៈអចិន្ត្រៃយ៍ និង គណៈមជ្ឈិម តាំងពីយូរណាស់មកហើយ[656]។ ស.ព.អ. បានអះអាងថា កងពលធំលេខ ៣ ដែលស្ថិតក្រោមការដឹកនាំរបស់ មាស មុត បានចូលរួមនៅក្នុងការវាយប្រយុទ្ធយកទីក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ ហើយថា មាស មុត បានបញ្ជាលើសមរភូមិ ហើយបានចាត់តាំងគោលដៅវាយប្រយុទ្ធ ទៅឱ្យមេបញ្ជាការកងវរសេនាធំ និង កងវរសេនាតូចនានា[657]។ ស.ព.អ. មិនបានពិចារណាពីតួនាទីរបស់ តា ម៉ុក នៅក្នុងប្រតិបត្តិការកងពលធំលេខ ៣ ឡើយ។ តា ម៉ុក បានចេញបញ្ជាឱ្យ មាស មុត វាយប្រយុទ្ធលើសមរភូមិទាំងអស់។

២១០. តា ម៉ុក បានប្រើប្រាស់សិទ្ធិត្រួតត្រាទាំងស្រុង ទៅលើកងពលធំលេខ ៣ និង កងពលធំផ្សេងទៀត នៅក្នុងភូមិភាគនិរតី។ គាត់បានតែងតាំង មាស មុត ឱ្យដឹកនាំកងពលធំលេខ ៣ និង បានជ្រើសរើស និងសម្រិតសម្រាំងកម្លាភិបាលយោធាដទៃផ្សេងទៀត[658]។ តា ម៉ុក បានដឹកនាំការប្រជុំនានាជាមួយកងពលធំ រួមទាំងការប្រជុំស្តីពីការវាយប្រហារលើទីក្រុងភ្នំពេញ[659]។ គាត់បានចាត់តាំង

---

[656] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សាន ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/82 EN 01123314 KH 01110576 (កងពលលេខ ៣ ស្ថិតក្រោមភូមិភាគនិរតី)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.២៧ (កងពលលេខ ៣ ស្ថិតក្រោមការគ្រប់គ្រងរបស់ តា ម៉ុក នៅថ្នាក់ភូមិភាគ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/43 ឆ.៥-៦, ឆ.៨ (កងពលលេខ ៣ ជាកងពលរបស់ភូមិភាគនិរតី ដែលបង្កើតឡើងដោយ តា ម៉ុក។ មាស មុត ជាមេបញ្ជាការកងពលលេខ៣ និង វាយការណ៍ទៅ តា ម៉ុក)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/8 ឆ.២៣-២៥ (កងពលលេខ ៣ គឺជាអង្គភាពរបស់ភូមិភាគនិរតី)។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១២ ឯកសារ D98/1.2.20 ម៉ោង 10:19:40-10:29:34។ *សូមមើល* កថាខណ្ឌ ១៦៩-៧០ និង ១៧២ *ខាងលើ* ដែលពិភាក្សាអំពីអំណាច និង តួនាទីរបស់ តា ម៉ុក នៅក្នុងថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក.។

[657] កថាខណ្ឌ ៤៥-៤៦ នៃដីកាសន្និដ្ឋានស្តាពរ។

[658] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/43 ឆ.៥។

[659] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ឯកសារ D98/3.1.56 ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ម៉ោង 09:36:17-09:40:34។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ឆ.៣។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ឯកសារ D98/1.2.20 ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ

ការកិច្ចទៅឱ្យកងពលធំ នៅមុនពេលវាយប្រយុទ្ធ[660]។ តា ម៉ុក បានត្រួតត្រាលើការចល័តរបស់កងពលធំលេខ ៣ ដោយគាត់បានបញ្ជូនកងពលធំនេះទៅកំពង់សោម នៅក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥[661]។ កងពលធំលេខ ៣ ស្ថិតនៅក្រោមអំណាចរបស់ តា ម៉ុក ទាំងស្រុង។

ខ. កងពលធំលេខ ១៦៥ ស្ថិតក្រោមអំណាចរបស់អគ្គសេនាធិការ និង គណៈកម្មាធិការអចិន្ត្រៃយ៍

២១១. កងពលធំលេខ ១៦៥ ដូចគ្នានឹងកងទ័ពបដិវត្តន៍កម្ពុជា និង ស្តាប់ឥបក្សទាំងអស់ គឺ "ស្ថិតក្រោមការដឹកនាំផ្តាច់មុខទាំងស្រុងរបស់បក្សកុម្មុយនីស្តកម្ពុជា"[662]។ ស.ព.អ. អះអាងថា មាស មុត បានត្រួតត្រាលើប្រតិបត្តិការកងពលធំលេខ ១៦៥[663]។ ស.ព.អ. មិនបានពិចារណាដល់ការពិតជាក់ស្តែងនៃការអនុវត្ត និង តាមច្បាប់ នៃការគ្រប់គ្រងនៅក្នុងកម្ពុជាប្រជាធិបតេយ្យឡើយ។ កង

២០១២ ម៉ោង 10:21:49-10:26:19 (ឌុច បាននិយាយថា ប៉ុល ពត និង ន្ឋន ជា មានអំណាចបញ្ជាពេញលេញ លើកងពលនានាដែលចូលរួមក្នុងការវាយប្រហារទីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ ១៩៧៥)។

[660] *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.177 ម៉ោង 14:35:04-14:38:07។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស រឿន ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D59/1/1.36 EN 00849493 KH 00733319-00733320។ មេធាវីការពារក្តីបានជំទាស់ទៅនឹងតម្លៃជាភស្តុតាងនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (*សូមមើល* កថាខណ្ឌ ១៤០ *ខាងលើ*)។ ទោះជាយ៉ាងនេះក្តី ប្រសិនបើ ស.ច.ស. ចាត់ទុកថា កិច្ចសម្ភាសន៍ទាំងនេះមានតម្លៃជាភស្តុតាង ស.ច.ស. ក៏ត្រូវតែពិចារណាលើចម្លើយរបស់ មាស រឿន ដែរ។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/46 ឆ.៤០ (ឆ្លើយថា តា ម៉ុក ជាគណៈភូមិភាគនិរតី ដូច្នេះគាត់អាចបញ្ជាទៅអង្គភាពយោធាណាក៏បានដែរ ដែលស្ថិតនៅក្នុងភូមិភាគរបស់គាត់)។

[661] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៨, ឆ.២៧។

[662] មាត្រា ២៧ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ *សូមមើលផងដែរ* ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខ ៥ ខែមេសា ឆ្នាំ ១៩៧៦ ឯកសារ D4.1.883 EN 00517864 KH 00062764 ("កងទ័ព ជាឧបករណ៍ផ្តាច់ការរបស់បក្សសុទ្ធសាធ ហើយនេះ គឺជាសមូហភាពកំរិតខ្ពស់បំផុត")។ ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខ ៧ ខែកក្កដា ឆ្នាំ ១៩៧៦ ឯកសារ D1.3.24.2 EN 00268944 KH 00062942 ("ត្រូវយើញអំពីកងទ័ពបដិវត្តកម្ពុជា ជាអង្គការផ្តាច់ការរបស់បក្ស ឋិតនៅក្រោមការដឹកនាំផ្តាច់មុខគ្រប់ផ្នែក នឹងដាច់ខាតរបស់បក្ស")។ *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 ម៉ោង 10:54:11-10:59:49។

[663] កថាខណ្ឌ ៦៧, ៨១ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ២៣៣ និង ៣៣៧-៤២ *ខាងក្រោម* សម្រាប់សំណើបន្ថែមទៀត លើសាក្សីដែល ស.ព.អ. ដែលបានដកស្រង់នៅជើងទំព័រ ២០១ និង ២៣៩។

ពលធំលេខ ១៦៤ ត្រូវបានគ្រប់គ្រងដោយស្តាប់ធ្នាក់លើរបស់បក្ស គឺគណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ។ តាមរយៈអគ្គសេនាធិការ[664] គណៈកម្មាធិការអចិន្ត្រៃយ៍បានត្រួតត្រាទៅលើគ្រប់ផ្នែកទាំងអស់ នៃប្រតិបត្តិការកងទ័ព ការចេញបញ្ជាទាក់ទងការចល័តកងទ័ព[665] ការផលិតស្បៀវអង្ករ[666] ការតាមដាន[667] ព្រមទាំងការចាប់ខ្លួន និង ស្បៀចម្លើយ[668]។ គណៈកម្មាធិការអចិន្ត្រៃយ៍

---

[664] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183394 KH 00019110-00019111 (ផ្លែងថា ការការពារប្រទេសចាត់ចែងតាមមជ្ឈិម) EN 00183396-00183397 KH 00019113-00019114 (ពិភាក្សាពីការរៀបចំអគ្គសេនាធិការ និង ក.ប.ក.) EN 00183402 KH 00019120 (ប៉ុល ពត ចេញសេចក្តីសម្រេចរៀបចំគណៈអគ្គសេនាធិការ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ឆ.៨១ (ឆ្លើយថា ប៉ុល ពត បង្កើតកងទ័ពជើងទឹក)។ ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខ ៨ ខែសីហា ឆ្នាំ ១៩៧៥ ឯកសារ D4.1.861 EN 00401488 KH 00063324 (ទាក់ទងនឹងកិច្ចប្រជុំក្នុងខែកក្កដា ឆ្នាំ ១៩៧៥ របស់មជ្ឈិម ក្នុងពិធីចាត់តាំង ក.ប.ក.)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.៤។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៥៨, ឆ.៦០។

[665] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភារ កងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.23 EN 00233719 KH 00095515 ("ទីតាំងយោធា៖ ត្រូវរៀបចំពិសេសកងអន្តរាគមន៍ ត្រូវសំរិតសំរាំងឱយស្អាត ហើយកងនេះ លុះត្រាតែមានបញ្ជាពីសេនាធិការទៅកងពល ហើយកងពលបញ្ជា ទើបអាចចេញប្រតិបត្តិការបាន")។ ទូរលេខ ចំណងជើងថា "ទូរលេខ ១០ ជូនទៅបងមុត អំពីស្ថានការណ៍ខ្ទាំងនៅតាមបណ្តោយព្រំដែន" ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.2.2 (សុន សេន ចេញសេចក្តីណែនាំពីការធ្វើផែនការវាយកម្ទេចនៅលើកោះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ឆ.៦៧-៦៨, ឆ.៧០, ឆ.៧៣, ឆ.១៦៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.២៤-២៦។

[666] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ" ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.2 EN 00233956 KH 00162481-00162482។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.12 EN 00234456 KH 00052376-00052377។ ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខ ៥ ខែមេសា ឆ្នាំ ១៩៧៦ ឯកសារ D4.1.883 EN 00517867 KH 00062767-00062768។

[667] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183397 KH 00019114។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៧៦ D1.3.27.12 EN 00234458-00234459 KH 00052378-00052379។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុការប្រជុំលេខា និង ភស្តុភារកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.23 EN 00233718 KH 00095514។

ថែមទាំងត្រួតត្រាទៅលើពាក្យពេចន៍ ដែលកងពលធំ និង កងវរសេនាធំឯករាជ្យ ប្រើប្រាស់ថែមទៀតផង[669]។ នៅក្នុងកិច្ចប្រជុំអគ្គសេនាធិការមួយ សុន សេន បានណែនាំដល់អ្នកចូលរួមថា៖ “ស្មើមុននិយាយ កុំបាច់ថា សុំគោរពអង្គការទៀត”[670]។

២១២. ដូចគ្នានឹងស្តាប់ឥតបក្សទាំងអស់[671] កងពលធំលេខ ១៦៤ និង កងពលធំមជ្ឈិមផ្សេងទៀត ត្រូវបានដឹកនាំដោយគណៈកម្មាធិការដែលមានមនុស្សបីនាក់[672]។ គណៈកម្មាធិការនេះរួមមាន មេបញ្ជាការទទួលបន្ទុកនយោបាយ មេបញ្ជាការរងទទួលបន្ទុកកងទ័ព និង សមាជិកម្នាក់ទទួលបន្ទុកខាងភស្តុភារ[673]។ គណៈកម្មាធិការនេះធ្វើសេចក្តីសម្រេចជាសមូហភាព ស្របតាមលក្ខន្តិកៈរបស់

---

[668] សេចក្តីណែនាំរបស់គណៈមជ្ឈិម ចំណងជើងថា “សេចក្តីសំរេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន” ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.19.1 EN 00182809 KH 00003136 (ផ្តល់សិទ្ធិដល់អគ្គសេនាធិការក្នុងការសម្រេចកម្ទេចកងទ័ពមជ្ឈិមក្នុងជួរ និង ក្រៅជួរ)។ *រឿងក្តី កាំង វេគអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.6 ម៉ោង 14:06:44-14:13:29។ របាយការណ៍ ចំណងជើងថា “សេចក្តីការណ៍ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមរយៈទូរស័ព្ទសម្ងាត់” ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D4.1.639 (សុន សេន បញ្ជូនសាររបស់ មាស មុត បន្ត ហើយស្នូរអង្គការរកខ្សែខាងក្នុង រកផ្លូវចេញចូល និង សមាសភាពពួកអាក្បត់នៅតាមព្រំដែន)។ ទូរលេខ ចំណងជើងថា “ទូរលេខ ៧ ខ្សែ ៥៥៥ ខ្ទង់ សូមរាយការណ៍ជូនបងជាទីគោរព” ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.20 (ទូរលេខរបស់ វី ស្នើសុំមតិអង្គការ និង សុំសម្រេចលើការចាប់ខ្លួន និង ចម្លើយសារភាពរបស់កងទ័ពយួន ២០៩ នាក់ ដែលចាប់ខ្លួននៅម្តុំអូរល្អក់)។ *សូមមើលផងដែរ* របាយការណ៍អ្នកជំនាញការ Craig Etcheson ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ ឯកសារ D234/2.1.52 កថាខណ្ឌ ១២១។

[669] *សូមមើល* សេចក្តីណែនាំរបស់គណៈ៨៧០ ចំណងជើងថា “សេចក្តីណែនាំអំពីការប្រើពាក្យ “អង្គការ” និង ពាក្យ “បក្ស” ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ១៩៧៧ ឯកសារ D4.1.377 (សេចក្តីណែនាំដល់អង្គការបក្ស គ្រប់ថ្នាក់)។

[670] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភារកងពល និង វរសេនាធំឯករាជ្យ” ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D234/2.1.18 EN 00543728 KH 00383777-00383778។

[671] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១១ ឯកសារ D98/3.1.160 ម៉ោង 10:52:31-11:06:32។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/43 ឆ.១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៥ ឯកសារ D54/51 ឆ.៣។

[672] មាត្រា ១.២ ខ មាត្រា ៧ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ *សូមមើលផងដែរ* របាយការណ៍យោធា ចំណងជើងថា “បញ្ជីក្តាប់កម្លាំងប្រចាំខែកញ្ញា ឆ្នាំ ១៩៧៦” ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.5.19 (របាយការណ៍ប្រចាំខែផ្ញើពីគណៈកងពល ៥០២ ទៅឱ្យអគ្គសេនាធិការ)។

[673] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ឆ.១៦៤-៦៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 ឆ.១០។

ប.ក.ក.[674]។ បើយោងតាម នួន ជា អនុលេខា ប.ក.ក. រាល់អង្គការបក្សទាំងអស់ ចាប់តាំងពីសាខាបក្ស រហូតដល់គណៈមជ្ឈិម បានគោរពតាមគោលការណ៍ ធ្វើការសម្រេចជាសម្ងាត់ភាព។ គ្រប់គ្នាត្រូវបញ្ចេញមតិ ហើយលេខាគណៈកម្មាធិការ នឹងសរុបរួមនូវគំនិត ហើយការពិភាក្សាត្រូវបន្តទៀត ប្រសិនបើមិនអាចឈានដល់ការព្រមព្រៀងគ្នាទេនោះ[675]។

២១៣. លក្ខន្តិក: ប.ក.ក. បានតម្រូវឱ្យថ្នាក់ក្រោមរាយការណ៍ទៅថ្នាក់លើរបស់ខ្លួន ហើយថ្នាក់លើត្រូវផ្សព្វផ្សាយការណែនាំ និង បទបញ្ជាទៅថ្នាក់ក្រោមរបស់គេវិញ[676]។ គណៈកម្មាធិការអចិន្ត្រៃយ៍បានអនុវត្តលក្ខខណ្ឌតម្រូវនេះ[677]។ អគ្គសេនាធិការ និង គណៈកម្មាធិការអចិន្ត្រៃយ៍ បានចេញសេចក្តីណែនាំ និង បទបញ្ជាទៅគណៈកងពលធំលេខ ១៦៥[678] ហើយគណៈកងពលធំលេខ ១៦៥ បានរាយការណ៍ទៀងទាត់ទៅអគ្គសេនាធិការ[679]។ គណៈកម្មាធិការនេះក៏បានរាយការណ៍ដោយផ្ទាល់

---

[674] មាត្រា ៦(១) នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ *សូមមើលផងដែរ* ទស្សនាវដ្តី ប.ក.ក ចំណងជើងថា "ទង់បដិវត្ត" ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D4.1.887 EN 00455307 KH 00064991-00064992។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៥ ឯកសារ D54/51 ឆ.៣។

[675] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១១ ឯកសារ D98/3.1.160 ម៉ោង 11:02:15-11:06:32។

[676] មាត្រា ៦(៥) មាត្រា ២៧-២៨ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។

[677] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183394-00183395 KH 00019110-00019112។ សេចក្តីសម្រេចរបស់គណៈមជ្ឈិម ចំណងជើងថា "សេចក្តីសំរេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.19.1 EN 00182809 KH 00003136 (ការអនុវត្តរបបរាយការណ៍មអាទិត្យម្តងស្តីពីផលិតផលស្រូវ)។

[678] *សូមមើលឧទា.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំ ការងារយោធា នៅកំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3 EN 00234013-00234016 KH 00021497-00021502 (ក្នុងនោះ ប៉ុល ពត ណែនាំគណៈកងពល ១៦៥)។ *សូមមើល* កថាខណ្ឌ ១៧២ *ខាងលើ* ទាក់ទងនឹងរបបរាយការណ៍តាមឋានានុក្រមដែលត្រូវធ្វើ។

[679] *សូមមើល* សេចក្តីរាយការណ៍ ចំណងជើងថា "សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2 (យោងការដាក់សេចក្តីរាយការណ៍ "ប្រចាំខែ" នេះ)។ សេចក្តីសម្រេចរបស់គណៈមជ្ឈិម ចំណងជើងថា "សេចក្តីសំរេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.19.1 EN 00182809 KH 00003136 (បង្កើតរបបរាយការណ៍មអាទិត្យម្តងមក ទៅ ៨៧០ "ដើម្បីតាមដានផែនការ ឱ្យជាប់ និងដោះស្រាយបញ្ហា ឱ្យទាន់ពេលវេលា ក្នុងទិសដៅសម្រេច ៣ តោន ១ ហិកតា")។

ទៅអគ្គសេនាធិការ និង សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ[680]។ ហេតុដូច្នេះ សមាជិកគណៈកម្មាធិការម្នាក់ៗ អាចមានទំនាក់ទំនងផ្ទាល់ជាមួយអគ្គសេនាធិការ[681]។ សុន សេន បានដឹកនាំការប្រជុំជាមួយគណៈកម្មាធិការកងពលធំ និង កងវរសេនាធំឯករាជ្យ ហើយក្នុងការប្រជុំនេះ អ្នកចូលរួមបានរាយការណ៍ទៅ សុន សេន អំពីស្ថានភាពនៅក្នុងកងរបស់ខ្លួន ដូចជា ការបង្កបង្កើនផល ការកសាង សភាពការណ៍ខ្មាំង និង ចំណុចដទៃផ្សេងទៀត នៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ[682]។ ចំណែក សុន សេន វិញបានចេញសេចក្តីណែនាំ និង ព័ត៌មានអំពីគោលនយោបាយ ប្រាប់ទៅអ្នក

---

[680] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ" ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.2។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភារបស់កងពល និងវរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195341 KH 00052390-00052391។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3 EN 00234012 KH 00021496-00021497 (បង្ហាញថា មាស មុត, ឌឹម, និង ង៉ែត ចូលរួមប្រជុំជាមួយ ប៉ុល ពត, វន វេត និង សុន សេន)។ *សូមមើលផងដែរ* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.11 EN 00183962 KH 00052362-00052372 (ការប្រជុំរវាង សុន សេន និង គណៈប្រចាំការកងពល និង វរសេនាធំឯករាជ្យ ទោះបីជាគណៈកងពល ១៦៥ មិនមានវត្តមានក្តី)។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃកិច្ចប្រជុំដកពិសោធន៍ការងារយោមល្បាតការពារក្រុង" ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.9 EN 00233994-00233995 KH 00162477-00162478 (ដែលក្នុងនោះ សុន សេន សុំឱ្យផ្តល់ព័ត៌មានអំពីស្ថានការណ៍ខ្មាំង និង បញ្ហាការពារក្រុង ពីគណៈកងពល ឬ គណៈកងវរសេនាធំឯករាជ្យ ទោះបីមិនមានភាពច្បាស់លាស់ថានរណាខ្លះបានចូលរួមក្នុងការប្រជុំនេះក៏ដោយ)។

[681] *សូមមើលខាងលើ.* ទូរលេខ ចំណងជើងថា "ជម្រាបសមមិត្ត ឌឹម" ចុះថ្ងៃទី ២៦ ខែវិច្ឆិកា [មិនដឹងឆ្នាំ] ឯកសារ D1.3.4.2 (ទូរលេខពី សុន សេន ផ្ញើទៅសមមិត្ត ឌឹម បញ្ជាក់ថាបានទទួលទូរលេខដែលសមមិត្ត ឌឹម ផ្ញើមក)។

[682] *សូមមើលខាងលើ.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំ ថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៧៦ នៅម៉ោង ១៧" ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.1។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ" ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.2។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.11។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា - អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.16។ *សូមមើល* កថាខណ្ឌ ២៩៥ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

ចូលរួម[683]។ គណៈកម្មាធិការយោធា ក៏ចេញសេចក្តីណែនាំដោយផ្ទាល់ ទៅកងពលធំមជ្ឈិមផងដែរ[684]។

២១៤. មាស មុត អាចផ្គាប់ជាសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៥ ដែលបានចូលរួមពាក់ព័ន្ធក្នុងការទទួលខុសត្រូវរួមគ្នាទៅលើកងពលធំនេះ[685]។ ការទទួលខុសត្រូវរួមនេះ ត្រូវបានបង្ហាញឱ្យឃើញនៅក្នុងរបាយការណ៍មួយ ផ្ញើដោយ មាស មុត ទៅ សុន សេន និង ប៉ុល ពត។ នៅក្នុងឯកសារនេះ គាត់បានរាយការណ៍ថា គាត់ស្ថិតនៅកោះរ៉ុង និង កោះរ៉ុងក្រៅ ដើម្បីជួយក្នុងការធានាថា សេចក្តីសម្រេចរបស់បក្សត្រូវបានអនុវត្ត ប្រកបដោយប្រសិទ្ធភាព ចាន់ បានទៅជួបជាមួយ

---

[683] *សូមមើលខគ.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខាកងពលលេខា និង អនុលេខាវរសេនាធំ" ចុះថ្ងៃទី ២ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.10 EN 00656574, 00656576-00656579 KH 00052356-00052357, 00052358-00052361។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការការប្រជុំលេខា និង អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.12 EN 00234456-00234457, 00234458-00234459 KH 00052376-00052378, 00052378-00052379។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.16 EN 00184339-00184341 KH 00064955-00064957។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ" ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.2 EN 00233954-00233956 KH 00162480-00162482។ *សូមមើលផងដែរ* កថាខណ្ឌ ២៩៧ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[684] *សូមមើល* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំការងារយោធានៅ កំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3 EN 00234013-00234016 KH 00021497-00021502 (ដែលក្នុងនោះ ប៉ុល ពត ចេញសេចក្តីណែនាំទៅគណៈកងពល ១៦៥)។

[685] យោងតាម ព្រុំ សាវ៉ាត គណៈកងពល ១៦៥ មានសមាជិកចំនួនបួនរូប – មាស មុត, ឌឹម, នង ឆាន និង ង៉ែត ញ៉ាន់ – ដែលអ្នកទាំងនេះមានអំណាចចេញបញ្ជា ទៅតាមតម្រូវការជាក់ស្តែង។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៦ ឯកសារ D234/2.1.92 ម៉ោង 15:03:11-15:09:33។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សាវ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ន.១៨៨ (ឆ្លើយថា សមាជិកគណៈកម្មាធិការកងពលទាំងអស់ត្រូវទទួលបានដំណឹងអំពីសកម្មភាពរបស់កងពល ១៦៥ រួមទាំងការចាប់ទុកផងដែរ)។

សមាជិកកងផ្សេងទៀត ដើម្បីអនុវត្តសេចក្តីសម្រេចរបស់បក្ស ហើយ ឪម ចុះទៅពង្រឹងកងកម្លាំងដែលមានស្រាប់ នៅលើកោះសេះ និង កោះថ្មី ស្របតាមការណែនាំរបស់បក្ស[686]។

២១៥. គណៈកម្មាធិការកងពលធំលេខ ១៦៤ បានត្រួតពិនិត្យមើលលើប្រតិបត្តិការរបស់កងពលធំលេខ ១៦៤ ដោយផ្អែកទៅតាមសេចក្តីណែនាំ និង បទបញ្ជា ដែលចេញដោយអគ្គសេនាធិការ និង គណៈកម្មាធិការអចិន្ត្រៃយ៍។ បន្ថែមពីលើសារណាដែលបានបង្ហាញ នៅក្នុងផ្នែកនេះហើយ *សូមមើល* ផ្នែក IV.គ.៣ *ខាងក្រោម* ដែលផ្តើយតបលម្អិតបន្ថែម ទៅនឹងការអះអាងរបស់ សហ.ព.អ. ទាក់ទងនឹងសិទ្ធិអំណាចរបស់ មាស មុត ទៅលើកងពលធំលេខ ១៦៤។

គ. ទំហំ និង រចនាសម្ព័ន្ធរបស់កងពលធំលេខ ១៦៤ មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់"

២១៦. ប្រភពដែល សហ.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានបញ្ជាទៅលើកងពលធំមជ្ឈិមធំជាងគេបំផុត នៅក្នុងកម្ពុជាប្រជាធិបតេយ្យ[687] និង ថាការបញ្ជានេះរួមចំណែកដល់ការចាត់ប្រភេទរបស់ មាស មុត ជាមេដឹកនាំជាន់ខ្ពស់ឡើយ[688]។ សហ.ព.អ. ដកស្រង់ចម្លើយដែលមិនអាចជឿជាក់បានរបស់ ជេត ប៊ុណ្ណា និង "សៀង" ចម្លើយរបស់ មាស មុត និងឯកសាររបស់អគ្គសេនាធិការ[689]។ សហ.ព.អ. ទៅហួសឆ្ងាយពេក។ កងពលធំលេខ ១៦៤ គឺជាកងពលធំមួយក្នុងចំណោមកងពលធំ និង កងវរសេនាធំឯករាជ្យចំនួន ១២ ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់អគ្គសេនាធិការ។ ខណៈដែលកងពលធំនេះអាចមានទំហំធំ ទំហំ ឬ រចនាសម្ព័ន្ធបែបនេះ មិនមែនជាអ្វីដែលធំខុសពីធម្មតា នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ឬ នៅក្នុងចំណោមអង្គភាពយោធាផ្សេងទៀតរបស់របបកម្ពុជាប្រជាធិបតេយ្យឡើយ។ ទាំងទំហំ ទាំងរចនាសម្ព័ន្ធរបស់កងពលធំលេខ ១៦៤ គឺមិនធ្ងន់ធ្ងរគ្រប់គ្រាន់ សម្រាប់ធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឡើយ។

---

[686] សេចក្តីវាយការណ៍ ចំណងជើងថា "សូមគោរពវាយការណ៍ជូនបង ៨៩ ជម្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2។

[687] កថាខណ្ឌ ៦៥, ២១៩ នៃដីកាសន្និដ្ឋានស្តាពរ។

[688] កថាខណ្ឌ ១០៨២ នៃដីកាសន្និដ្ឋានស្តាពរ។

[689] ជើងទំព័រ ១៩៥-៩៦, ៦៤១ នៃដីកាសន្និដ្ឋានស្តាពរ។

២១៧. **ជេត ប៊ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[690]។ ជេត ប៊ុណ្ណា បានអះអាងថា "កងទ័ពជើងទឹកដែលស្ថិតនៅក្រោម មាស មុត គឺជាកងពលមួយដែលធំជាងគេបង្អស់ ក្នុងចំណោមកងពលទាំង ២៥ របស់ខ្មែរក្រហម"[691]។ ការអះអាងរបស់គាត់ គឺផ្អែកលើការចងចាំរបស់គាត់អំពីសន្និបាត ដែលគាត់បាននិយាយថា មេបញ្ជាការកងវរសេនាធំបានធ្វើឡើងរៀងរាល់ត្រីមាស[692]។ គាត់មិនបានផ្តល់ព័ត៌មានលម្អិតអំពីថា តើនៅពេលណា ទីកន្លែងណា ឬ ពីនរណាដែលគាត់ដឹងព័ត៌មាននេះទេ។ បើតាមការដឹងច្បាស់របស់មេធាវីការពារក្តី ការអះអាងរបស់ ជេត ប៊ុណ្ណា មិនមានការគាំទ្រពីភស្តុតាងផ្សេងទៀត នៅក្នុងសំណុំរឿងនោះឡើយ[693]។

២១៨. **"សៀង"**៖ សៀង មិនអាចជឿជាក់បានឡើយ។ គាត់បានបំពេញការងារនៅក្នុងផ្នែក ដែលមានដែនកម្រិតកំណត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ត្រូវបានស្តាប់ចម្លើយដោយ ក.ស.ព. តែមួយគត់ ហើយគាត់បានបដិសេធមិនឱ្យ ក.ស.ច.ស. ធ្វើការស្តាប់ចម្លើយគាត់នោះទេ។ គាត់គឺជាទាហាននៅក្នុងកងវរសេនាធំលេខ ៦២ ដែលត្រូវបានបញ្ជូនទៅកោះ ក្នុងរយៈពេលប្រាំមួយខែ[694] ហើយគាត់បាននិយាយថា កងពលធំលេខ ១៦៥ មានទាហានជាង ១០០០០ នាក់[695]។ ដោយសារតែហាន: និង ទីតាំងឈរជើងរបស់គាត់ គាត់នឹងមិនដឹងថាតើមានទាហានប៉ុន្មាននាក់ នៅក្នុងកងពលធំទាំងមូលនោះឡើយ។ លើសពីនេះទៅទៀត ការស្តាប់ចម្លើយរបស់គាត់ គឺមានតម្លៃជាភស្តុតាងតិចតួច ពីព្រោះការស្តាប់ចម្លើយនេះធ្វើឡើងដោយ ក.ស.ព. ហើយមានត្រឹមតែជាទម្រង់សង្ខេប

---

[690] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមអំពីសាក្សីរូបនេះ។

[691] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឆ.១២។ ជើងទំព័រ ១៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[692] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឆ.១០-១២។

[693] Ben Kiernan បានយោងទៅការប្រជុំលេខាតំបន់ និង ភូមិភាគ នៅទីក្រុងភ្នំពេញ នៅចុងឆ្នាំ ១៩៧៧ ដែល ប៉ុល ពត បាននិយាយយោងកងពលទាំង ១៥ របស់កម្ពុជាប្រជាធិបតេយ្យ។ Ben Kiernan របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និង អំពើប្រល័យពូជសាសន៍ នៅប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម ១៩៧៥-៧៩ ទំព័រ ៣៥៣ (Yale University Press ឆ្នាំ ១៩៩៦) ឯកសារD114/29.1.4 EN 00678678 KH 00637896-00637897 ។

[694] បទសម្ភាសន៍របស់ ក.ស.ព. ជាមួយ "សៀង" ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.11 EN 00217565-00217566។

[695] បទសម្ភាសន៍របស់ ក.ស.ព. ជាមួយ "សៀង" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.11 EN 00217565។ ជើងទំព័រ ១៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

ប៉ុណ្ណោះ[696]។ ដោយសារតែគាត់បានបដិសេធមិនផ្តល់ចម្លើយទៅឱ្យ ក.ស.ច.ស.[697] មេធាវីការពារក្តីនឹងមិនអាចសួរដេញដោលគាត់ អំពីចម្លើយសង្ខេបរបស់ ក.ស.ព. បានឡើយ។

២១៩. ស.ព.អ. ក៏ដកស្រង់ផងដែរ នូវការប៉ាន់ប្រមាណដែលអះអាងដោយ មាស មុត ថា កងពលធំលេខ ១៦៥ មានទាហានប្រមាណពី ១០០០០ ទៅ ១២០០០ នាក់[698]។ ការប៉ាន់ប្រមាណទាំងនេះ គឺមានចុះផ្សាយនៅក្នុងអត្ថបទសារព័ត៌មាន និង ការសម្ភាសន៍ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ POW/MIA។ ការសម្ភាសន៍មិនត្រូវបានធ្វើឡើង ក្រោមការត្រួតពិនិត្យរបស់តុលាការ ហើយត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សេង ក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌ។ ប្រភពទាំងនេះមិនអាចឱ្យជឿជាក់បាន ហើយមិនមានតម្លៃជាភស្តុតាង[699]។

២២០. បើទោះបីជាកងពលធំលេខ ១៦៥ ជាកងពលធំមជ្ឈឹមដែលធំជាងគេបំផុតក៏ដោយ ក៏ត្រឹមតែជាផ្នែកនៃគណៈកម្មាធិការរបស់កងពលធំនេះ មិនមានន័យថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់" ឡើយ។ កងពលធំលេខ ១៦៥ គឺជាកងពលមួយក្នុងចំណោមកងពលធំ និង កងវរសេនាធំឯករាជ្យទាំង ១២ ដែលមិនរាប់បញ្ចូលចំនួនមន្ទីរ មានបុគ្គលិកសរុបចំនួនប្រមាណ ៦១០០០ នាក់ ស្ថិតក្រោមការគ្រប់គ្រង និង សិទ្ធិអំណាចរបស់អគ្គសេនាធិការ[700]។ ឯកសាររបស់អគ្គសេនាធិការបង្ហាញថា នៅក្នុងខែមេសា ឆ្នាំ ១៩៧៧ កងពលធំលេខ ១៦៥ មានកងទ័ពប្រមាណ ៨៥០០

---

[696] បទសម្ភាសន៍របស់ ក.ស.ព. ជាមួយ "សៀង" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.11 EN 00217565។ *សូមមើល* កថាខណ្ឌ ១៤១ *ខាងលើ* ដែលពិភាក្សាអំពីការប្រើប្រាស់ប្រភេទនៃភស្តុតាងបែបនេះ។

[697] ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ ទី ២ និងទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៩ ខែមករា ឆ្នាំ ២០១៦ ឯកសារ D223 កថាខណ្ឌ ៩៩-១០០។

[698] ជើងចំព័រ ៦៤១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ Christine Chaumeau និង Bou Saroeun *យើងនៅក្នុងទ្រុង ដូចសព្វថ្ងៃនេះ* (We were in a cage like today) សារព័ត៌មានភ្នំពេញប៉ុស្ត៍ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០១ ថ្ងៃទី ២ ខែសីហា ឆ្នាំ ២០០១ ឯកសារ D1.3.33.16។ បទសម្ភាសន៍ជាមួយ មាស មុត (POW/MIA) ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០១ ឯកសារ D22.2.181 EN 00249692-00249700 KH 00741994-00742004។

[699] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[700] សេចក្តីវាយការណ៍យោធា ចំណងជើងថា "ស្ថិតិកម្លាំងរួម" ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.30.9។

នាក់[701]។ កងពលធំលេខ ១ មានទំហំប្រហែលគ្នា៖ ៧០០០ នាក់[702]។ កងពលធំលេខ ១៦៥ មិនមែនធំ ជាងកងពលធំផ្សេងទៀតច្រើនឡើយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

២២១. កងពលធំលេខ ១៦៥ ក៏មិនមានលក្ខណៈពិសេសអ្វីដែរ នៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន[703]។ រចនាសម្ព័ន្ធដែលមានកងវរសេនាធំ កងវរសេនាតូចឯករាជ្យ និង មន្ទីរមួយ ដែលដូចគ្នានឹងកងពលធំដទៃទៀតដែរ។ ដូចគ្នានឹងកងពលធំលេខ ១៦៥ ដែរ កងពលធំលេខ ៣១០ និង ៥០២ មានអនុកងចំនួនប្រហែល ១០ និង មន្ទីរមួយ ក្នុងកងពលធំនីមួយៗ។ កងពលធំលេខ ៣១០ មានកងវរសេនាធំចំនួនបី កងវរសេនាតូចចំនួនប្រាំពីរ កងមួយហៅថា ក-៥ និង មន្ទីរមួយ[704]។ កងពលធំលេខ ៥០២ មានកងវរសេនាធំចំនួនពីរ កងវរសេនាតូចចំនួនប្រាំពីរ កងអនុសេនាធំមួយ កងកុមារ កងពិការ និង កងទូរលេខមួយ រួមជាមួយមន្ទីរមួយ[705]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច នៅក្នុងរឿងក្តី ០០២/០១ ទោះបីជាមានរចនាសម្ព័ន្ធជាទូទៅ សម្រាប់កងពលធំយោធារបស់របបកម្ពុជាប្រជាធិបតេយ្យក៏ដោយ[706] ក៏រចនាសម្ព័ន្ធអង្គភាពជាក់ស្តែង អាចមានការប្រែប្រួលទៅតាមកងពលធំនីមួយៗ[707]។

---

[701] សេចក្តីវាយការណ៍យោធា ចំណងជើងថា "បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃ" ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.5.3។ សេចក្តីវាយការណ៍យោធា ចំណងជើងថា "ស្ថិតិកម្លាំងរួម" ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.30.9។

[702] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1057 ឆ.៩។ *រឿងក្តីខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 ម៉ោង 10:54:11-10:59:49 (មាស រឿន ផ្តល់សក្ខីកម្មថា ជួនកាល កងពលពិសេស ដែលបូកជាមួយនឹងកងពិសេស ប្រហែលជា ៧០០០ នាក់ ហើយកងពលធំលេខ ១ មានទំហំដូចគ្នា)។

[703] កថាខណ្ឌ ៦៥, ២១៧-១៨ នៃដីកាសន្និដ្ឋានស្តាពរ នៅក្នុងនោះ ស.ព.អ. ពិភាក្សាអំពីរចនាសម្ព័ន្ធនៃកងពល ១៦៥។

[704] សេចក្តីវាយការណ៍យោធា ចំណងជើងថា "ស្ថិតិយោធាទូទាំងប្រទេស កងពល ៣១០" ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.19។

[705] សេចក្តីវាយការណ៍យោធា ចំណងជើងថា "បញ្ជីក្តាប់កម្លាំងប្រចាំខែតុលា ឆ្នាំ ១៩៧៦" ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.5.21។ សេចក្តីវាយការណ៍យោធា ចំណងជើងថា "បញ្ជីក្តាប់កម្លាំងប្រចាំខែកញ្ញា ឆ្នាំ ១៩៧៦" ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.5.19។

[706] កថាខណ្ឌ ២៤៣ នៃសាលក្រមក្នុងរឿងក្តី ០០២/០១ (ដែលបង្ហាញថា ជាធម្មតា ក្នុងមួយកងពលធំរួមមានបីកងវរសេនាធំ។ បីកងវរសេនាតូចបង្កើតបានជាមួយកងវរសេនាធំ។ បីកងអនុសេនាធំបង្កើតបានជាមួយកងវរសេនាតូច។ បីកងអនុសេនាតូចបង្កើតបានជាមួយកងអនុសេនាធំ។ បីក្រុមបង្កើតបានមួយកងអនុសេនាតូច។ មួយក្រុមរួមមានកងទ័ពប្រហែលជា ១២ នាក់)។

[707] កថាខណ្ឌ ២៤៤ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។ *សូមមើលផងដែរ* សក្ខីកម្មរបស់ អៀង ផាន ក្នុងរឿងក្តី ០០២/០១ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា (កងអនុសេនាតូចហ្នឹងគឺថាមានគ្នា៣៦នាក់ ហើយមានជាបីក្រុម។ មួយកងអនុសេនាធំមានបីកង

២២២. ការណ៍ដែលមានកងវរសេនាតូចឯករាជ្យពិសេស ភ្ជាប់ជាមួយនឹងកងពលធំលេខ ១៦៤ គឺមិនមែនជារឿងមិនធម្មតានោះទេ[708]។ កងពលធំលេខ ១ មានកងវរសេនាតូចឯករាជ្យបែបនេះ[709] កងពលធំលេខ ២ នៅភូមិភាគនិរតីក៏មាន[710] ហើយកងពលធំលេខ ៨០១ នៅភូមិភាគឦសានក៏មានបែបនេះដែរ[711]។ កងវរសេនាធំមានកងពិសេសផ្ទាល់ខ្លួន[712]។ កងទ័ពតំបន់មានកងស៊ើបការណ៍ពិសេស[713]។ បន្ថែមលើនេះទៅទៀត កងវរសេនាតូចឯករាជ្យនៅក្នុងកងពលធំលេខ ១៦៤ គឺមិនមែនជាកងប្រយុទ្ធទាំងអស់នោះទេ។ កងវរសេនាតូចលេខ ១៦៧ គឺជាកងនារី[714]។ កងវរសេនាតូច ១៦៨ ត្រួតពិនិត្យលើការដឹកជញ្ជូន[715]។ កងវរសេនាតូចលេខ ១៦៩ គឺជាអង្គភាពពេទ្យ[716]។ កង

អនុសេនាតូច។ បីអនុសេនាតូចទៅជាមួយអនុសេនាធំ។ បួនអនុសេនាធំទៅជាមួយវរសេនាតូច។ អ៊ីចឹង បួនវរសេនាតូចទៅជាមួយវរសេនាធំ។ កងពលតូចមានបួនវរសេនាធំ។ កងពលធំមានប្រាំកងពលតូច)។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D98/3.1.56 នៅម៉ោង 09.27.55-09.36.17។

[708] កថាខណ្ឌ ២១៨ នៃដីកាសន្និដ្ឋានស្តាពរ នៅក្នុងនោះ ស.ព.អ. អះអាងថា មាន "កងវរសេនាតូចឯករាជ្យចំនួនប្រាំមួយ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមអំណាចផ្ទាល់របស់ មាស មុត និង គណៈកម្មាធិការកងពល ១៦៤ របស់គាត់"។

[709] *រឿងក្តី ខ្លួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 10.26.37-10.33.00។

[710] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D98/3.1.56 នៅម៉ោង 09.42.48។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ឆ.៥។

[711] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៣ ឯកសារ D98/3.1.20 នៅម៉ោង 14.21.10-14.22.26 (ឆោម សៃ)។

[712] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 ឆ.១២, ឆ.១៤។

[713] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៦ ឯកសារ D59/2/4.16a EN 00753847 KH 00059340 (បើទោះជាកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានតម្លៃជាភស្តុតាងគិចជាងកិច្ចសម្ភាសន៍របស់ ក.ស.ច.ស. ក៏ដោយ តែប្រសិនបើ ស.ច.ស. អនុញ្ញាតឱ្យកិច្ចសម្ភាសបែបនេះមានតម្លៃជាភស្តុតាង ស.ច.ស. ក៏ត្រូវតែពិចារណាចម្លើយនេះដែរ)។

[714] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.១៣។

[715] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ឆ.១៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.១៣។

[716] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.១៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ឆ.១៩។

វរសេនាតូចលេខ ១៧០ គឺជាអង្គភាពជាងក្រឡឹង ឬ ការងារជួសជុល[717]។ វត្តមានរបស់កង វរសេនាតូចទាំងអស់ បង្ហាញថា កងពលធំលេខ ១៦៤ អាចមិនមានកងកម្លាំងប្រយុទ្ធ ច្រើនជាងកងពលធំផ្សេងទៀត បើទោះបីជាកងពលធំនេះ មានចំនួនមនុស្សច្រើនជាងគេក្តី។

ឃ. កងពលធំលេខ ១៦៤ បានប្រតិបត្តិការនៅក្នុងតំបន់មានកម្រិតកំណត់ នៃរបបកម្ពុជាប្រជាធិបតេយ្យ

២២៣. ប្រភពដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រដល់ការអះអាងរបស់គាត់ដែលថា កងពលធំលេខ ១៦៤ មានអំណាចទៅលើកោះចំនួនប្រមាណជាង ២០០ និង តំបន់ឆ្នេរកម្ពុជាទាំងស្រុង[718] ហើយថាវិសាលភាពនៃសិទ្ធិអំណាចនេះធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" នោះឡើយ[719]។ ស.ព.អ. ដកស្រង់សាក្សីចំនួនពីរនាក់ដែលមិនអាចជឿជាក់បានគឺ ជេត ប៊ុណ្ណា និង កង សុំ ដែលថ្លែងថា កងពលធំលេខ ១៦៤ មានការទទួលខុសត្រូវលើកោះចំនួន ២០០។ ស.ព.អ. ក៏ដកស្រង់ផងដែរ ទូរសាក្សី និង ឯកសារផ្សេងទៀត ដែលមិនគាំទ្រដល់ការអះអាងរបស់គាត់។ កងពលធំលេខ ១៦៤ មានអំណាចត្រឹមតែលើឆ្នេរសមុទ្រ និង កោះ នៅក្នុងតំបន់កំពង់សោមប៉ុណ្ណោះ។

២២៤. **ជេត ប៊ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[720]។ គាត់បានអះអាងថា កងពលធំលេខ ១៦៤ បានត្រួតត្រាលើកោះចំនួនប្រមាណ ២០០[721]។ ការអះអាងរបស់គាត់ គឺផ្អែកលើការចងចាំរបស់គាត់អំពីសន្និបាតមួយ[722]។ គាត់មិនបានផ្តល់ព័ត៌មានលម្អិតអំពីទីកន្លែង ពេលវេលា ឬ ប្រភពដែលគាត់ដឹងព័ត៌មាននេះទេ។

---

[717] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង វ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.១៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង វ៉ែត ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/288 ឆ.៤៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/9 ឆ.២៥។

[718] កថាខណ្ឌ ៦២ កថាខណ្ឌ ២២0 នៃដីកាសន្និដ្ឋានស្តាពរ។

[719] កថាខណ្ឌ ១០៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[720] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមស្តីពីសាក្សីរូបនេះ។

[721] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឆ.១១។ ជើងទំព័រ ១៩៣, ៦៥៤ នៃដីកាសន្និដ្ឋានស្តាពរ។

[722] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឆ.១១។

២២៥. **កង សុំ**៖ កង សុំ មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយដែលផ្ទុយគ្នា នៅក្នុងការសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និង ការស្តាប់ចម្លើយរបស់ ក.ស.ច.ស.។ កង សុំ ធ្លាប់ជាឃ្លួនជនសាមញ្ញមួយរូប ដែលមិនមានតំណែងអ្វីឡើយ[723] ហើយបានអះអាងថា កងទ័ពជើងទឹក ឈរជើង *ក្នុងចំណោមនោះ* នៅប្រជុំកោះដែលមានកោះជាងពីរយ[724]។ នៅពេលដែល ក.ស.ច.ស ស្តាប់ចម្លើយ គាត់មានបញ្ហាលើការចងចាំរបស់គាត់ ហើយគាត់បានផ្តល់ចម្លើយដែលផ្ទុយពីការសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ គាត់បានពន្យល់ថា គាត់បានស្រវឹង នៅពេលដែលគាត់ផ្តល់ការសម្ភាសន៍ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា[725]។ បន្ទាប់មក អ្នកស៊ើបអង្កេត ក.ស.ច.ស បានធ្វើឱ្យខូចខាតដល់ការស្តាប់ចម្លើយ ដោយបានបង្ខំសួរដេញដោល កង សុំ ឱ្យផ្តល់ចម្លើយដែលស្របគ្នាជាមួយនឹងចម្លើយរបស់គាត់ប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលផ្ទុយពីការនិយាយទូរអ្វី ដែលគាត់បានចងចាំដោយឯករាជ្យ នៅពេលស្តាប់ចម្លើយនោះ[726]។ ទោះបីជាត្រូវបង្ខំសួរដេញដោលក្តី ក៏ កង សុំ នៅតែមិនអាចផ្តល់ទូរព័ត៌មានតាមលំដាប់លំដោយ នៃទីកន្លែងដែលគាត់នៅ ឱ្យបានច្បាស់លាស់ នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ[727]។ បើទោះបីជា ស.ច.ស. ចាត់ទុកថា កង សុំ ជាសាក្សីអាចជឿជាក់បានក៏ដោយ ក៏ចម្លើយរបស់គាត់មានតម្លៃជាភស្តុតាងតិចតួច។ គាត់មិនបាននិយាយថា តើគាត់ដឹងដោយរបៀបណា នូវ

---

[723] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.៧, ឆ.២៩។

[724] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.១១៤។ ជើងទំព័រ ៦៥៤ នៃដីកាសន្និដ្ឋានស្តាពរ។

[725] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.៩៩។

[726] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ស-ឆ.៣, ស-ឆ.៩៩, ស-ឆ.១០១, ស-ឆ.១០៦៖ "ស៖ បើសិនជាខ្ញុំសួរលោកថ្ងៃនេះ ដូចសំណួរដែលខាងមជ្ឈមណ្ឌលឯកសារកម្ពុជាសួរលោក តើលោកឆ្លើយប្រាប់ខ្ញុំដូចដែលលោកឆ្លើយប្រាប់ខាងមជ្ឈមណ្ឌលឯកសារកម្ពុជាឬទេ? ឆ.៣៖ បាទ។ ... ស៖ អ្វីដែលលោកប្រាប់ខ្ញុំនៅពេលនេះ មិនឆ្ងុះបញ្ចាំងពីអ្វីដែលលោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីខែមីនា ឆ្នាំ ២០១៥ ឡើយ។ ខ្ញុំមានបញ្ហាក្នុងការយល់ថា ហេតុអ្វីបានជាការចងចាំរបស់លោកកាលពីបីខែមុន ច្បាស់ជាងអ្វីដែលលោកឆ្លើយនៅពេលនេះ? ឆ.៩៩៖ ពេលនោះ ខ្ញុំស្រវឹង។ ... ស៖ ខ្ញុំចង់បញ្ជាក់ម្តងទៀតជាមួយលោកថា បើសិនជាខ្ញុំសួរសំណួរដដែល ដូចដែលក្រុមមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍លោកនោះ តើលោកនឹងឆ្លើយចម្លើយដដែល ឬខុសពីមុន ? ឆ.១០១៖ ខ្ញុំចងចាំមិនបានទេ។ ខ្ញុំឆ្លើយមិនបានដូចដដែលទេ។ ខ្ញុំចាំបានលុះណាតែខ្ញុំស្តាប់ខ្សែអាត់សំឡេងរបស់ខ្ញុំនៅពេលនោះ។ ... ស៖ ខ្ញុំចង់បញ្ជាក់លោកថា ការដែលលោកឆ្លើយនេះគឺក្រោមពាក្យសម្បថ តែលោកឥឡូវនេះ លោកដូចជាឆ្លើយក្នុងការបារម្ភ។ ខ្ញុំសូមឱ្យលោកជួយសម្រួលក្នុងចម្លើយរបស់លោក ហើយផ្ចង់អារម្មណ៍ឆ្លើយនឹងសំណួរខ្ញុំ។ ឆ.១០៦៖ ខ្ញុំឆ្លើយតែតាមការដែលខ្ញុំដឹង។ បើខ្ញុំមិនដឹង តើឱ្យខ្ញុំឆ្លើយយ៉ាងម៉េច?"។

[727] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ស-ឆ.២២៩។

ព័ត៌មានអំពីកោះដែលស្ថិតក្រោមការត្រួតត្រារបស់កងពលធំលេខ ១៦៥ នោះទេ។ គាត់មិនអាចដឹងដោយសារផែនទីទេ ព្រោះគាត់ជាអនក្ខរជន[728]។ លើសពីនេះទៅទៀតគាត់បានឈរជើងនៅលើកោះមួយ ត្រូវជាប់ឃុំឃាំងនៅលើកោះត្រល់ ហើយបន្ទាប់មកត្រូវបានផ្ទេរទៅតំបន់ព្រលានយន្តហោះកងកេង និង ស្ទឹងហាវ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[729]។ ជាការមិនអាចនោះឡើយដែលនៅពេលនោះ គាត់អាចបានដឹងអំពីវិសាលភាពភូមិសាស្ត្រទាំងមូល នៃការត្រួតត្រារបស់កងពលធំលេខ ១៦៥ នោះ។

២២៦. សាក្សីផ្សេងទៀតដែល ស.ព.អ. ដកស្រង់ បានត្រឹមតែថ្លែងជាទូទៅថា កងពលធំលេខ ១៦៥ ឬ មាស មុត បានការពារ "កោះ" ឬ "សមុទ្រ"[730]។ សារទូរលេខ និង របាយការណ៍ដែល ស.ព.អ. ដកស្រង់ ពាក់ព័ន្ធត្រឹមតែកោះចំនួន ១៥ ប៉ុណ្ណោះ[731]។ ភស្តុតាងនេះមិនគាំទ្រដល់ការសន្និដ្ឋានដែលថា កងពលធំលេខ ១៦៥ ឬ មាស មុត បានត្រួតត្រាលើកោះចំនួន ២០០ ឡើយ។

---

[728] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ន.១១៦។

[729] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ន.១២៦, ន.១៥0, ន.២២៩-៣0, ន.២៦២។

[730] ជើងទំព័រ ១៩៣ នៃដីកាសន្និដ្ឋានស្តាពរ ដែលបានដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ន.១៧ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/104 ន.១៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង សេង ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/209 ន.១៧-១៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/116 ន.៥-៦, ន.១0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញឹក ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/77 ន.៥២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១0 ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ន.៣៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ន.៤៩។ *សូមមើលផងដែរ* ជើងទំព័រ ៦៥៤ នៃដីកាសន្និដ្ឋានស្តាពរ ដែលបានដកស្រង់ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ ២០១២ ឯកសារ D98/1.2.22 នៅម៉ោង 14.17.25-14.21.14។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/297.1.21 នៅម៉ោង 13.33.48-13.38.41។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុច ទុយ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/105 ន.៣0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រៀង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.៣៤។

[731] ជើងទំព័រ ១៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

២២៧. កងពលធំលេខ ១៦៤ មិនបានត្រួតត្រាលើតំបន់ឆ្នេរកម្ពុជាទាំងស្រុងនោះទេ[732]។ ប្រតិបត្តិការ និង ឥទ្ធិពលរបស់កងពលធំនេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានកម្រិតត្រឹមតែលើតំបន់ភូមិសាស្ត្រដែលកំណត់ឱ្យប៉ុណ្ណោះ។ តំបន់ឆ្នេរដែល ស.ព.អ. អះអាងថា មានប្រវែង ៥០០ គីឡូម៉ែត្រនោះ[733] គឺតំណាងឱ្យប្រហែល ១៣% នៃតំបន់ព្រំដែនរបស់ប្រទេសកម្ពុជា ដែលមានប្រវែង ៣០១២ គីឡូម៉ែត្រ[734]។ សម្រាប់តំបន់ឆ្នេរទាំងមូល កងពលធំលេខ ១៦៤ បានត្រួតពិនិត្យតែត្រឹមផ្នែសមុទ្រនៅក្បែរកំពង់សោម ដូចជាកោះពូលូវ៉ៃ កោះតាង និង កោះរ៉ុង[735]។ ផ្នែសមុទ្រនៅកោះកុង និង កំពត ស្ថិតក្រោមបញ្ជាការរបស់កងកម្លាំងផ្សេងទៀត៖ កោះកុងត្រូវបានត្រួតពិនិត្យដោយកងពលធំលេខ ១[736] ហើយកំពតត្រូវបានត្រួតពិនិត្យដោយកងកម្លាំងតំបន់ ៣៥[737]។

---

[732] ដូចដែល ស.ព.អ. អះអាង។ កថាខណ្ឌ ២២០ នៃដីកាសន្និដ្ឋានស្តាពរ។

[733] កថាខណ្ឌ ៦២ ជើងចំព័រ ១៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

[734] បណ្ណាល័យសភា ស.រ.អ. ផ្នែកស្រាវជ្រាវសហព័ន្ធ កម្ពុជា៖ ការសិក្សាពីប្រទេស លេខ xv (ឆ្នាំ ១៩៩០) *អាចរកបាននៅតាម* គេហទំព័រ https://www.loc.gov/item/89600150/។

[735] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.11.34-10.15.02 (មាស រឿន បានឆ្លើយថា មុខសញ្ញាគាត់ទទួលត្រឹមពីកោះស្តេច កោះកុង ទល់គ្នានឹងកោះយ៉ ខណៈដែលកងពលលេខ៣ ទទួលការពារពីកោះស្តេច មកកោះរុង ទល់គ្នាកំពង់សោម ទៅកោះពូលូវ៉ៃ)។

[736] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.11.34-10.15.02។ *រឿងក្តី ខ្លួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.180 នៅម៉ោង 09.11.36-09.16.51។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ មាស រឿន ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D59/1/1.36 EN 00849498 KH 00733325 (កងវរសេនាធំកងពលលេខ១ របស់គាត់ នៅកោះកុង និង នៅព្រំដែនសមុទ្រនៅកោះកុង កោះយ៉ កោះមូល និង កោះចាំយាម)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/104 ឆ.១៦ (កោះម្នាស់ស្ថិតនៅក្នុងតំបន់១១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ផុន ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D114/140 ឆ.២០-២១ (តំបន់ ១១ នៅក្នុងភូមិភាគបស្ចឹម)។

[737] *សូមមើល ខទ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក័ម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 ឆ.៦២ (តំបន់៣៥ គឺមានខេត្តកំពតខ្លះ និង ខាងខេត្តតាកែវខ្លះ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉ែន ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/155 ឆ.២៣ (ប្រធានម្នាក់នៅព្រៃនប់ គឺមកពីតំបន់ ៣៥ កំពត)។ *សូមមើលផងដែរ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ជៀម ញ៉ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៤ ឯកសារ D1.3.32.10 EN 00184184 KH 00055936-00055937 (តាម៉ុកឧស្សាហ៍ចុះមើលកន្លែងគាត់នៅស្រែអំបិលក្នុងខេត្តកំពត ហើយ ប៉ុន កាន់កងពលធំរបស់គាត់)។ Kuehnel អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. បាននិយាយប្រាប់សាក្សីថា តំបន់ ៣៥ ស្ថិតនៅក្នុងខេត្តកំពត

ង. សេចក្តីសន្និដ្ឋាន

២២៨. ការបញ្ជារបស់ មាស មុត ទៅលើកងពលធំលេខ ៣ និង កងពលធំលេខ ១៦៥ ឬ សមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការកងពលធំលេខ ១៦៥ មិនបានធ្វើឱ្យគាត់ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឡើយ។ គណៈកម្មាធិការមួយបានធ្វើការសម្រេចជាសមូហភាពទៅលើបញ្ហានានា ហើយទទួលខុសត្រូវរួមគ្នាចំពោះកងពល។ កងពលធំលេខ ១៦៥ គឺជាកងពលធំមួយ ក្នុងចំណោមកងពលធំ និង កងវរសេនាធំឯករាជ្យចំនួន ១២។ កងពលធំនេះមិនមានទំហំធំជាង កងពលធំផ្សេងទៀតខ្លាំងឡើយ ហើយរចនាសម្ព័ន្ធរបស់កងពលធំលេខ ១៦៥ ក៏មិនមានអ្វីដែលពិសេសដែរ។ កងពលធំលេខ ១៦៥ ប្រតិបត្តិការនៅក្នុងតំបន់ភូមិសាស្ត្រដែលត្រូវបានកំណត់។ ការណ៍ដែលមានតួនាទីដឹកនាំណាមួយ ទាក់ទងនឹងកងពលធំលេខ ១៦៥ មិនបានដំឡើង មាស មុត ឱ្យទៅដល់កម្រិតជា "មេដឹកនាំជាន់ខ្ពស់" នោះឡើយ។

៥. មាស មុត មិនមែនជាលេខាតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងគណៈកម្មាធិការតំបន់ស្វយ័តកំពង់សោមឡើយ ហើយបើទោះបីជាគាត់មានមុខដំណែងទាំងនេះក្តី ក៏វាមិនអាចធ្វើឱ្យគាត់ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ដែរ

២២៩. ស.ព.អ. អះអាងថា មាស មុត ត្រូវបានតែងតាំងជាលេខាតំបន់ស្វយ័តកំពង់សោម នៅពេលដែលគាត់មកដល់កំពង់សោម នៅក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥[738] ហើយថា គាត់មានអំណាចខ្ពស់បំផុត នៅក្នុងគណៈកម្មាធិការតំបន់ស្វយ័តកំពង់សោម[739]។ ស.ព.អ. ដកស្រង់ភស្តុតាងដែលមិនអាចជឿជាក់បាន និង ផ្អែកលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ ស.ព.អ. វិភាគមិនត្រឹមត្រូវទៅលើភស្តុតាង។ គាត់មិនបានបង្ហាញភស្តុតាងគាំទ្រការអះអាងរបស់គាត់ឡើយ។ បើទោះបីជា ស.ច.ស. ពិចារណាថា មានភស្តុតាងគ្រប់គ្រាន់ អំពីតួនាទីរបស់ មាស មុត នៅក្នុងតំបន់

(កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 EN 01333468 KH 01301431)។ ក.ស.ច.ស. ហាក់ដូចជាយល់ស្របថា កំពតមិនស្ថិតនៅក្រោមការកាន់កាប់របស់កងពល ១៦៥ ឡើយ ពីព្រោះវាមិនមែនជាផ្នែកនៃកិច្ចស៊ើបសួរក្នុងរឿងក្តី ០០៣ ឡើយ។ របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/189 EN 01215547 KH 01504273 ("ព្រឹត្តការណ៍នៅកំពតមិនស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ")។

[738] កថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៧៥, ២២០, ១០៨៣។

[739] កថាខណ្ឌ ៧២, ២២១ នៃដីកាសន្និដ្ឋានស្តាពរ។

ស្វយ័តកំពង់សោមក៏ដោយ ក៏មុខដំណែងជាលេខាតំបន់ស្វយ័ត ឬ ជាសមាជិកគណៈកម្មាធិការតំបន់ មិនមែនជាឋានៈ "មេដឹកនាំជាន់ខ្ពស់" នោះដែរ។

ក. មាស មុត មិនមែនជាលេខាតំបន់ស្វយ័តកំពង់សោម

២៣០. ប្រភពដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត ធ្លាប់ជាលេខាតំបន់ស្វយ័តកំពង់សោមនោះទេ[740]។ ស.ព.អ. ដកស្រង់ជាចម្បង នូវចម្លើយដែលមិនអាចឱ្យជឿជាក់បានរបស់ ឌុច Ben Kiernan ប៉ាក សុខ ជេត ប៊ុណ្ណា អែម សុន សេង អុល យឹម ស្រឿង និង ភស្តុតាងឯកសារមិនអាចឱ្យជឿជាក់បាន[741]។ ស.ព.អ. មិនបានបង្ហាញភស្តុតាង ដើម្បីគាំទ្រការអះអាងរបស់គាត់ឡើយ។ មិនមានឯកសារភស្តុតាងរបស់ ប.ក.ក. ដែលចង្អុលបង្ហាញថា មាស មុត ត្រូវបានតែងតាំងជាផ្លូវការ ជាលេខាតំបន់ស្វយ័តកំពង់សោម ហើយមានភស្តុតាងមិនគ្រប់គ្រាន់ដែលថា គាត់កាន់មុខដំណែងនេះក្រៅផ្លូវការ។

២៣១. **ឌុច៖** ឌុច មិនអាចជឿជាក់បានឡើយ[742]។ គាត់បានអះអាងថា មាស មុត ធ្លាប់ជា "លេខាតំបន់ពិសេស" នៅកំពង់សោម និង ជាប្រធានគណៈកម្មាធិការបក្សកំពង់សោម ហើយថា កំពង់ផែស្ថិតក្រោមការត្រួតត្រារបស់ មាស មុត[743]។ ការអះអាងទាំងនេះ មិនអាចឱ្យជឿជាក់បាន និង មិនមានភាពត្រឹមត្រូវ។ ទោះបីជាបានផ្តល់ចម្លើយជាច្រើនអំពី មាស មុត ក៏ដោយ ក៏ ឌុច មិនដែលបានធ្លាប់អះអាងពីមុនថា មាស មុត ធ្លាប់ជា "លេខាតំបន់ពិសេស" នៅកំពង់សោមឡើយ។ នៅក្នុងខែមិថុនា ឆ្នាំ ១៩៩៩ គាត់បាននិយាយថា មាស មុត គឺជាមេបញ្ជាការកងទ័ពជើងទឹក ដែលឈរជើងនៅកំពង់សោម និង ជាប្រធានគណៈកម្មាធិការកំពង់សោម[744]។ នៅក្នុងការសួរចម្លើយដោយ ក.ស.ច.ស. នៅមុនឆ្នាំ ២០១៦ ឌុច បាននិយាយថា មាស មុត ដែលជាមេបញ្ជាការកងទ័ពជើងទឹក

---

[740] កថាខណ្ឌ ៧២, ៧៥, ២២០, ១០៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[741] ជើងទំព័រ ២១៧, ២២៦-២៩, ៦៦០ នៃដីកាសន្និដ្ឋានស្តាពរ។

[742] *សូមមើល* កថាខណ្ឌ ១៧៥-៧៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមចំពោះសាក្សីរូបនេះ។

[743] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ឧ.១០។ កថាខណ្ឌ ៧៥ នៃដីកាសន្និដ្ឋានស្តាពរ។

[744] កំណត់ហេតុសួរចម្លើយរបស់តុលាការយោធាកម្ពុជា ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៩៩ ឯកសារ D1.3.33.7 EN 00184830 KH 00089674-00089675។ គាត់ "ដឹង" ពីរឿងនេះ "តាមរយៈ "ការសិក្សារបស់គាត់" លើរចនាសម្ព័ន្ធនៃថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ *ដូចខាងលើ* EN 00184829 KH 00089673។ *សូមមើលផងដែរ* ជើងទំព័រ ២២៧ នៃដីកាសន្និដ្ឋានស្តាពរ។

និង ជាផ្នែកមួយនៃយោធា គឺជាជំនួយការរបស់គណៈមជ្ឈិម[745]។ គាត់មិនបាននិយាយពីតួនាទីជា "លេខាតំបន់ពិសេស" នៅកំពង់សោមឡើយ។ ដោយផ្អែកលើគោលនយោបាយរក្សាការសម្ងាត់របស់ ប.ក.ក.[746] វាហាក់ដូចជាមិនអាចដែលថា នៅក្នុងរបបនោះ ឌុច បានដឹងឮច្បាស់លាស់អំពីតួនាទីណាមួយរបស់ មាស មុត។ ផ្ទុយពីការអះអាងរបស់ ឌុច ដែលថា មាស មុត បានត្រួតត្រាលើកំពង់ផែ ស.ព.អ. បានទទួលស្គាល់[747] ហើយសាក្សីជាច្រើននាក់បាននិយាយថា ឌុច រិន បានត្រួតត្រាលើកំពង់ផែ និង បុគ្គលិកកំពង់ផែចំនួនប្រមាណ ៦០០០ នាក់[748]។

២៣២. **Ben Kiernan៖** Ben Kiernan មិនអាចជឿជាក់បានឡើយ។ គាត់គឺជាអ្នកសិក្សា ដែលបានបដិសេធមិនផ្តល់សក្ខីកម្ម ទាក់ទងនឹងការសិក្សាស្រាវជ្រាវ និង ការបោះពុម្ពផ្សាយរបស់គាត់ អំពីរបបកម្ពុជាប្រជាធិបតេយ្យ ការបដិសេធរបស់គាត់មិនឱ្យសួរដេញដោល ដោយភាគីនានានៅ អ.វ.ត.ក. គឺជាលទ្ធផលសម្រាប់ការធ្វើងថ្លែងផ្តល់ទម្ងន់ ចំពោះភស្តុតាងរបស់គាត់[749]។ លោក

---

[745] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.10 EN 00195577 KH 00195568 (គាត់ដឹងថា រចនាសម្ព័ន្ធយោធា ត្រូវបានតែងតាំងក្នុងគណៈកម្មាធិការជំនួយការនៃគណៈកម្មាធិការមជ្ឈិម)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D1.3.33.13 EN 00154911 KH 00154927 (គាត់ដឹងថា មាស មុត ជាមេបញ្ជាការជើងទឹក ហើយត្រូវបានចាត់តាំងជាសមាជិកគណៈកម្មាធិការជំនួយការនៃគណៈកម្មាធិការមជ្ឈិម) ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12 EN 00680796 KH 00680801-00680802 (មាស មុត ជាជំនួយការនៃគណៈកម្មាធិការមជ្ឈិម) ។

[746] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតម្លៃភស្តុតាង។

[747] កថាខណ្ឌ ២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[748] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 ឆ.១៨, ឆ.២០, ឆ.២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/234 ឆ.២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 ឆ.៥-៧, ឆ.១២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ឆ.៤0, ឆ.៥៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.២៦, ឆ.២៨, ឆ.៣០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃីម ស្រៀង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ឆ.១៩៩។

[749] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ឯកសារ E312 កថាខណ្ឌ ៥៩ ។ *រឿងក្តី ខ្លួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ សេចក្តីសម្រេចស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ ដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ E459 កថាខណ្ឌ ១៩០។

Ben Kiernan បានអះអាងថា ការតែងតាំង មាស មុត ធ្វើជាលេខាកំពង់សោម បានកើតឡើងនៅ "ប្រហែលក្នុងឆ្នាំ ១៩៧៥"[750]។ គាត់បានដកស្រង់នូវព័ត៌មានខាងក្រោម ដើម្បីជាការគាំទ្រ៖

- ការសម្ភាសន៍របស់គាត់ជាមួយសមាជិក ប.ក.ក. ពីឆ្នាំ ១៩៧៣ និង មេឃុំគីរីវង់ សម័យកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៩៨០។
- ការសម្ភាសន៍របស់គាត់ជាមួយសមាជិក ប.ក.ក. ពីឆ្នាំ ១៩៧៣ និង សមាជិកគណៈឃុំគងពិសី សម័យកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ១៩៨០។
- ការសម្ភាសន៍របស់គាត់ជាមួយ ចុន ខេត្តតាកែវ នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ១៩៨០។
- ការសម្ភាសន៍របស់គាត់នៅខេត្តកំពត នៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៨០។ និង
- ការសម្ភាសន៍របស់គាត់ជាមួយកម្មាភិបាលតំបន់ ១៣ នៅស្រែកែវ នៅថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៨០[751]។

ការសម្ភាសន៍ទាំងនេះមិនត្រូវបានធ្វើឡើង ដោយមានការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយធ្វើឡើងក្នុងគោលបំណងផ្សេង ក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌ។ គ្មានប្រភពណាមួយក្នុងចំណោមប្រភពទាំងនេះ ត្រូវបានកំណត់អត្តសញ្ញាណឱ្យបានពេញលេញទេ។ អ្នកនិពន្ធមិនបានផ្តល់ប្រតិចារឹក កំណត់ត្រា ឬ ខ្សែអាត់ថតសំឡេងនៃកិច្ចសម្ភាសន៍ទាំងនេះឡើយ។ *សូមមើល* កថាខណ្ឌ ២៣៩ *ខាងក្រោម* អំពីសារណាស្តីពីការសម្ភាសន៍របស់ Stephen Heder។ ភាពអាចជឿជាក់បាននៃប្រភពរបស់លោក Ben Kiernan មិនអាចត្រូវបានកំណត់ឡើយ។ ចម្លើយរបស់គាត់មិនអាចផ្ទៀងផ្ទាត់ ឬ សួរដេញដោលបាន ហេតុដូច្នេះហើយ គឺមិនមានតម្លៃជាភស្តុតាងទេ[752]។

២៣៣. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ។ គាត់គឺជាឃុទ្ធជនដែលមានឋានន្តរសក្តិទាបបំផុត ហើយការអះអាងរបស់គាត់អំពី មាស មុត គឺមិនត្រឹមត្រូវ មានភាពប្រទាំងប្រទើសគ្នា និងផ្អែកលើពាក្យចចាមអារ៉ាម។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមាននរណាម្នាក់មាន

---

[750] BEN KIERNAN របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ នៅកម្ពុជាក្រោមរបបខ្មែរ ១៩៧៥-៧៩ ទំព័រ ៨៨ (Yale University Press ឆ្នាំ១៩៩៦) ឯកសារ D114/29.1.4 EN 00678539 KH 00637490-00637491។ ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[751] BEN KIERNAN របប ប៉ុល ពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍ នៅកម្ពុជាក្រោមរបបខ្មែរ ១៩៧៥-៧៩ ទំព័រ ៧៧ (Yale University Press ឆ្នាំ១៩៩៦) ឯកសារ D114/29.1.4 EN 00678539 KH 00637490-00637491។

[752] *សូមមើល* កថាខណ្ឌ ១៣៩ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ប្រភពខាងក្រៅជាភស្តុតាង។

ហានន្តរសក្តិទាបជាង ប៉ាក សុខ ទេ[753]។ ដោយសារតែហានន្តរសក្តិទាបរបស់ ប៉ាក សុខ និង ដោយសារតែគោលនយោបាយរក្សាការសម្ងាត់របស់ ប.ក.ក.[754] គាត់មានការដឹងឮតិចតួចប៉ុណ្ណោះអំពីការទទួលខុសត្រូវ និង សិទ្ធិអំណាចរបស់ មាស មុត។ ប៉ាក សុខ បានអះអាងថា គាត់បាន "ឮ" ថា មាស មុត គឺជាលេខានៅកំពង់សោម[755]។ ចម្លើយផ្ទាល់របស់គាត់នេះបង្ហាញថា គាត់មិនបានដឹងឮផ្ទាល់ អំពីតួនាទីរបស់ មាស មុត នោះទេ។ ប៉ាក សុខ បានអះអាងដោយខុសថា មាស មុត គឺ "ទទួលខុសត្រូវរួមទាំងអស់នៅកំពង់សោម រួមមានខាងយោធា ខាងកម្មករ ខាងកំពង់ផែ"[756]។ នៅក្នុងតំបន់ដែលកងពលធំលេខ ១៦៥ ឈរជើង គណៈកម្មាធិការកងពលធំលេខ ១៦៥ គ្រប់គ្រងលើបញ្ហាកងទ័ព ធុច រិន គ្រប់គ្រងលើបញ្ហាប្រជាជនស៊ីវិល និង កំពង់ផែ[757] ហើយ ឡូញ ត្រួតពិនិត្យលើកងនេសាទ[758]។ រឿងរ៉ាវរបស់ ប៉ាក សុខ អំពីការបំផ្លាញគ្រាប់រំសេវនៅវាម តាមបញ្ជារបស់

---

[753] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/297.1.21 នៅម៉ោង 09.24.20-09.30.04។

[754] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតម្លៃកស្តុតាង។

[755] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 អ.១១ ។ ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[756] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 អ.១៥ ។ ជើងទំព័រ ២២៩ នៃដីកាសន្និដ្ឋានស្តាពរ។

[757] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.៩, អ.១៥, អ.១៧, អ.៣៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 អ.១៨, អ.២០, អ.២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/234 អ.២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 អ.៥-៧, អ.១២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 អ.៤0, អ.៥៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 អ.២៦, អ.២៨, អ.៣0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃឹម ស្រៀង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 អ.១៩៩។ *សូមមើលផងដែរ* កថាខណ្ឌ ២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[758] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 អ.៣0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 អ.១0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 អ.៣0។

មាស មុត[759] ដែលជាការបញ្ជាក់តែមួយគត់ អំពីទំនាក់ទំនងផ្ទាល់ជាមួយ មាស មុត មិនអាចកំណត់បានទេថា មាស មុត បានគ្រប់គ្រងទៅលើសេចក្តីសម្រេចទាំងអស់ ទាក់ទងនឹងកងពលធំលេខ ១៦៥ គឺត្រឹមតែថា មាស មុត អាចចេញបញ្ជាត្រឹមតែម្តងគត់ ដើម្បីបំផ្លាញគ្រាប់រំសេវមួយចំនួន។

២៣៤. ប៉ាក សុខ បានបង្ហាញឱ្យឃើញបន្ថែមទៀត អំពីការមិនបានដឹងឮពីព័ត៌មានពាក់ព័ន្ធ ទោះជាគាត់បានធ្វើការអះអាងលម្អិតប្រាប់ ក.ស.ច.ស. អំពីរចនាសម្ព័ន្ធរបស់កងពលធំលេខ ១៦៥ ក្តី[760] គឺនៅពេលដែលគាត់មិនស្គាល់ នង ឆាន ជានរណា ទោះបីជាគាត់ស្គាល់ថា នរណាគឺជា ឌឹម និង ញ៉ែត ញ៉ាន់ ក៏ដោយ[761]។ ស.ព.អ. អះអាងថា នង ឆាន ឌឹម និង ញ៉ែត ញ៉ាន់ គឺជាអនុលេខាកងពលធំលេខ ១៦៥[762]។ ប្រសិនបើ ប៉ាក សុខ បានស្គាល់មនុស្សពីរនាក់ ក្នុងចំណោមអ្នកដែលជាមនុស្សមានឋានៈខ្ពស់ វាជាការមិនសមស្របដែលគាត់មិនស្គាល់មនុស្សទីបីនោះ។ ប៉ាក សុខ បាននិយាយដោយមិនត្រឹមត្រូវផងដែរថា មាស មុត បានរៀបចំកងពលធំលេខ ១៦៥ ទៅជាកងទ័ពមជ្ឈិម[763]។ ជាការពិតជាក់ស្តែង មេដឹកនាំជាន់ខ្ពស់ ប.ក.ក. បានរៀបចំកងពលធំលេខ ១៦៥ នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ហើយបានរៀបចំកងទ័ពបដិវត្តន៍កម្ពុជា នៅក្នុងឋានានុក្រម ប.ក.ក.[764]។ ចម្លើយរបស់ ប៉ាក សុខ មិនអាចឱ្យជឿជាក់បានទេ។ បើទោះបីជាគាត់មានព័ត៌មានពាក់ព័ន្ធណាមួយនៅពេល

---

[759] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/24 ឆ.២០ ។ ជើងទំព័រ ២០១ នៃដីកាសន្និដ្ឋានស្តាពរ។

[760] *សូមមើល ខទ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ D54/24 ឆ.១៦-២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.១៩។

[761] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.១។

[762] ឧបសម្ព័ន្ធ ខ នៃដីកាសន្និដ្ឋានស្តាពរ ឯកសារ D256/7.3។

[763] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/24 ឆ.១៦។

[764] *សូមមើលខទ.* ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខ ៨ ខែសីហា ឆ្នាំ ១៩៧៥ ឯកសារ D4.1.861 EN 00401488 KH 00063324 (ស្តីពីមហាសន្និបាតនាខែកក្កដា ឆ្នាំ ១៩៧៥ ដែលនៅក្នុងឱកាសចាត់តាំង ក.ប.ក. របស់មជ្ឈិមបក្ស)។ មាត្រា ២៧ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183394, 00183396-00183397 KH 00019109-00019110, 00019112-00019114។ ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខ៧ ខែកក្កដា ឆ្នាំ ១៩៧៦ ឯកសារ D1.3.24.2 EN 00268945 KH 00062942 (ដែលថ្លែងថាមានតែបក្សដឹកនាំកងទ័ព)។

នោះក៏ដោយ ក៏សក្ខីកម្មរបស់គាត់មានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ ព្រោះតែបញ្ហាការចងចាំរបស់គាត់ ដែលគាត់បានទទួលស្គាល់រួចហើយ[765]។

២៣៥. **ជេត ប៊ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[766]។ គាត់បានអះអាងថា មាស មុត បានត្រួតត្រាលើតំបន់ស្វយ័តចាប់ពីទឹកសាប រហូតទៅដល់កងកេង រាម និង កំពង់សោម រួមទាំងកោះទាំងអស់[767]។ ដោយសារតែឋានៈរបស់គាត់ ការមិនបានដឹងឮអំពីកម្រិតថ្នាក់ដឹកនាំ ចាប់ពីដើមឆ្នាំ ១៩៧៧ រួមទាំងការស្អប់របស់គាត់ចំពោះ មាស មុត[768] ទើបចម្លើយរបស់គាត់មានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ។

២៣៦. **អែម សុន**៖ អែម សុន មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ដែលថា មាស មុត ធ្លាប់ជាលេខាតំបន់ស្វយ័តកំពង់សោម ឬ នៅក្នុងគណៈកម្មការរបស់តំបន់ស្វយ័តឡើយ[769]។ អែម សុន គឺជាសមាជិកនៃកងវរសេនាតូចលេខ ៤៥០[770]។ គាត់ឈរជើងនៅកោះតាង[771] ហើយបន្ទាប់មកត្រូវបានផ្ទេរទៅធ្វើការនៅកំពង់ផែ ដែលស្ថិតនៅក្រោម ធុច រិន[772]។ ស.ព.អ. បកស្រាយមិនត្រឹមត្រូវនូវចម្លើយរបស់ អែម សុន ដែលថា មាស មុត គឺជាលេខា ឬ ជាអ្នកតំណាងរបស់ ប.ក.ក. នៅកំពង់សោម[773]។ អ្នកស៊ើបអង្កេត ក.ស.ច.ស. បានបង្ហាញ អែម សុន នូវរបាយការណ៍របស់

---

[765] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 ម៉ោង 10.39.59-10.46.23 (ដែលនៅក្នុងនោះ គាត់ទទួលស្គាល់ថាបានផ្តល់សក្ខីកម្មផ្ទុយដោយសារតែបញ្ហាការចងចាំ)។

[766] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងសាក្សីរូបនេះ។

[767] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 អ.៩-១០។ ជើងទំព័រ ៦៦០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ១៦៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[768] *សូមមើល* កថាខណ្ឌ ១៨៦ និង ១៨៨ *ខាងលើ*។

[769] កថាខណ្ឌ ៧២, ៧៥, ២២០-២១, ១០៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[770] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ D54/46 អ.២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.៤២។

[771] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.៨។

[772] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.១៧-១៨។

[773] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.២៨-៣៣។ ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ។

FBIS ស្តីពីមេដឹកនាំជាន់ខ្ពស់ ប.ក.ក. ធ្វើទស្សនកិច្ចនៅកំពង់សោម ជាមួយប្រតិភូចិន[774] ហើយបាននិយាយថា៖ "នៅក្នុងចំណែងដំបូងនៃឯកសារ មាស មុត គឺជាលេខា ប.ក.ក. ក្រុងកំពង់សោម ហើយនៅចំណែងទីពីរ មាស មុត គឺជាលេខាបក្សក្រុងកំពង់សោម ប.ក.ក."[775]។ គាត់បានឱ្យ អែម សុន ពន្យល់នូវភាពខុសគ្នារវាងមុខដំណែងទាំងនេះ[776]។ អែម សុន បាននិយាយថា គាត់បានគិតថា មុខដំណែងត្រឹមត្រូវគឺ "លេខាគណៈ ប.ក.ក. ក្រុងកំពង់សោម"[777]។ គាត់មិនបានដឹងថា មាស មុត មានការទទួលខុសត្រូវអ្វីឡើយ ក្នុងនាមជាលេខាបក្សនោះ[778]។ ក្រោយមកគាត់បាននិយាយថា មាស មុត ទទួលខុសត្រូវលើកងទ័ព និង ជាអ្នកតំណាង ប.ក.ក. នៅកំពង់សោម ចំណែក ធុច រិន ទទួលខុសត្រូវលើប្រជាជនស៊ីវិល និង កម្មករនៅកំពង់ផៃ ហើយជាអនុលេខា[779]។ អែម សុន បានបង្ហាញភាពខុសគ្នារវាងតួនាទីរដ្ឋបាល និង តួនាទីបក្ស។ ចម្លើយរបស់គាត់មិនបានកំណត់ថា លេខាតំបន់ គឺមានឋានៈស្មើគ្នា និង លេខាបក្ស ឬ អ្នកតំណាងបក្សឡើយ។ ក្រៅពីចម្លើយដែលមិនមានការគាំទ្ររបស់គាត់ ជាទូទៅ អែម សុន គឺមិនអាចឱ្យជឿជាក់បានឡើយ ពេលនិយាយទាក់ទងនឹង មាស មុត។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នាជាច្រើន អំពីការប្រាស្រ័យទាក់ទងរវាងគាត់ជាមួយ មាស មុត នៅក្នុងអំឡុងហេតុការណ៍ម៉ាយ៉ាហ្គេ (Mayaguez)[780]។

២៣៧. **សេង អុល**៖ សេង អុល មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់អំពី មាស មុត គឺមិនមានតម្លៃជាភស្តុតាងឡើយ។ គាត់ជាកម្មាភិបាលឋានៈទាប ដែលទទួលខុសត្រូវលើកងនារី នៅក្នុងខេត្តតាកែវ ដែលត្រូវបានផ្ទេរទៅខេត្តបាត់តំបងនៅក្នុងឆ្នាំ ១៩៧៨[781]។ គាត់មិនដែលទៅកំពង់សោម

---

[774] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ស.២៧។ *សូមមើល* កថាខណ្ឌ ២៤០ *ខាងក្រោម* សម្រាប់ការលើកឡើងបន្ថែមពីរបាយការណ៍ FBIS។

[775] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ស.២៨។

[776] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ស.២៨។

[777] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.២៨។

[778] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.២៩។

[779] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.៣៣។ *សូមមើល* ជើងទំព័រ ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[780] *សូមមើល* កថាខណ្ឌ ៣៤៩ *ខាងក្រោម*។ *សូមមើលផងដែរ* កថាខណ្ឌ ២៤៤ និង ៥១៥ *ខាងក្រោម*។

[781] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/91 អ.៩, អ.១៣៧-៣៨, អ.១៦៥, អ.២២២, អ.៣៣៧។

ទេ[782]។ គាត់គ្រាន់តែបានឮថា មាស មុត ត្រួតពិនិត្យមើលលើកំពង់សោម តែគាត់មិនដែលឃើញគាត់ទេ[783]។ សេង អុល មិនដែលបញ្ជាក់ថា គាត់បានឮព័ត៌មាននេះ មកពីនរណាឡើយ។ តាមសក្ខីកម្មផ្ទាល់របស់គាត់ គាត់មិនមានការដឹងឮផ្ទាល់អំពី មាស មុត ឡើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

២៣៨. **យឹម ស្រឿង**៖ យឹម ស្រឿង មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ គឺផ្អែកទៅលើពាក្យចចាមអារ៉ាម និង ការទាយស្មានដែលមិនអាចផ្ទៀងផ្ទាត់បាន។ គាត់នៅក្នុងកងវរសេនាធំលេខ ១៤០ មានមូលដ្ឋាននៅលើកប៉ាល់ចល័ត[784]។ គាត់បានឮពីមេបញ្ជាការរបស់គាត់ថា មាស មុត បានត្រួតត្រាលើតំបន់កំពង់សោមទាំងមូល លើកលែងតែកំពង់ផែប៉ុណ្ណោះ[785]។ ចម្លើយនេះមិនអាចផ្ទៀងផ្ទាត់បញ្ជាក់បានឡើយ។ យឹម ស្រឿង ក៏បាននិយាយផងដែរថា គាត់គ្រាន់តែសន្មតថា មាស មុត បានគ្រប់គ្រងចាប់ពីទឹកសាប ទៅរាម និង នៅកំពង់សោម[786]។ យឹម ស្រឿង បានទាយស្មានថា ធុច រិន ដែលត្រួតត្រាលើកំពង់ផែ "ប្រហែលជានៅជាមួយតាៗខាងលើ" គឺខុសពី មាស មុត[787]។

២៣៩. ស.ព.អ. ដកស្រង់ចម្លើយពីឯកសារមិនអាចឱ្យជឿជាក់ និង មិនអាចផ្ទៀងផ្ទាត់បានជាច្រើន ដើម្បីធ្វើជាការគាំទ្របន្ថែមដល់ការអះអាងរបស់គាត់[788]។ ប្រភពអនាមិកដែល Stephen Heder បានសម្ភាសន៍នៅក្នុងឆ្នាំ ១៩៨០ បាននិយាយថា "ក្នុងឆ្នាំ ១៩៧៥ គាត់ (មាស មុត) ក៏បានកាន់តួនាទីជាលេខាក្រុងកំពង់សោមផងដែរ"[789]។ លោក Stephen Heder កំណត់អត្តសញ្ញាណប្រភពនេះ

---

[782] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/91 ន.២២០។

[783] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង អុល ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/91 ន.៣៥៩-៦១។ ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[784] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.៣៨, ន.៧១, ន.៧៩, ន.១០១។

[785] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.១៩៨។ *សូមមើលផងដែរ ដូចខាងលើ* ន.១៩៣-៩៧, ន.១៩៩-២០០។ ជើងទំព័រ ៦៦០ នៃដីកាសន្និដ្ឋានស្តាពរ។

[786] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.១៩៤។

[787] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.២០១។

[788] ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[789] បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ខែកុម្ភៈ - ខែមីនា ១៩៨០ ឯកសារ D1.3.30.29 EN 00170723 KH 00324723-00324724។

ត្រឹមតែជា "បុរសម្នាក់មកពីតំបន់ ១៣ (តាកែវ) ក្នុងប៉ែកនិរតី ដែលទំនងជាមនុស្សរបស់បក្ស"[790]។ ការសម្ភាសន៍នេះត្រូវបានធ្វើឡើង ដោយមិនមានការត្រួតពិនិត្យមើលតាមផ្លូវតុលាការ ហើយធ្វើឡើងក្នុងគោលបំណងផ្សេង ក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌ[791]។ អង្គជំនុំជម្រះតុលាការកំពូល បានកំណត់យ៉ាងជាក់ច្បាស់ថា ការសម្ភាសន៍របស់លោក Stephen Heder គឺមានតម្លៃជាភស្តុតាងទាបដោយសារតែកាលៈទេសៈ ដែលការសម្ភាសន៍នោះត្រូវបានធ្វើឡើង[792]។ ជារឿយៗ គាត់បានសម្ភាសមនុស្សជាច្រើនក្នុងពេលតែមួយ ហើយគាត់បានអនុញ្ញាតឱ្យភាគីទីបីចូលរួមក្នុងការសម្ភាសន៍នេះដែរ ដែលការនេះធ្វើឱ្យប៉ះពាល់ដល់ចម្លើយរបស់អ្នកផ្តល់សម្ភាសន៍[793]។ ខ្សែអាត់ថតសំឡេងនៃកិច្ចសម្ភាសន៍ ក៏មិនមាននៅក្នុងសំណុំរឿង។ ចម្លើយមិនអាចផ្ទៀងផ្ទាត់ ឬ សួរដេញដោលបាន។ ចម្លើយទាំងនេះមិនមានតម្លៃជាភស្តុតាងឡើយ។ ប្រហែលគ្នានេះ ចម្លើយ (របស់ ចាប ឡុញ) ដែលថា មាស មុត ធ្លាប់ជាលេខាគណៈកម្មាធិការបក្សកំពង់សោម ស្នងការនយោបាយនៃកងទ័ពជើងទឹក គឺមិនមានតម្លៃជាភស្តុតាងទេ[794]។ ឯកសារដែលមានកត់ត្រាការអះអាងនេះ គឺគ្រាន់តែជាឯកសារសង្ខេប ឬ សម្រង់ចេញពីចម្លើយដទៃទៀតដែលមិនត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឯកសារ[795]។ ឯកសារនេះត្រូវបានរៀបចំឡើងដោយអ្នកនិពន្ធមិនស្គាល់ឈ្មោះ ក្នុងពេលវេលាដែលមិនបានបញ្ជាក់ឱ្យដឹង[796]។ ចម្លើយដើមដែលពេញលេញរបស់ ចាប ឡុញ គឺមិនមាននៅក្នុងសំណុំរឿងឡើយ។ បើទោះបីជាឯកសារនេះ មានតម្លៃជាភស្តុតាងក្តី ក៏ ចាប ឡុញ អះអាង

---

[790] បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ខែកុម្ភៈ - ខែមីនា ១៩៨០ ឯកសារ D1.3.30.29 EN 00170723 KH 00324723-00324724។

[791] *សូមមើល* កថាខណ្ឌ ១៣៩ *ខាងលើ* ដែលពិភាក្សាអំពីការប្រើប្រាស់ប្រភេទនៃភស្តុតាងបែបនេះ។

[792] *សូមមើល* ជើងទំព័រ ៣៦១ *ខាងលើ* ។

[793] *សូមមើល* បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ ខែកុម្ភៈ-ខែមីនា ១៩៨០ ឯកសារ D1.3.30.29 EN 00170712 KH 00324702-00324703 (ក្នុងនេះមានបទសម្ភាសមួយធ្វើឡើងជាមួយនឹងទាហានខ្មែរក្រហមពីរនាក់ និងបទសម្ភាសន៍មួយទៀតធ្វើឡើងជាមួយនឹងប្រភពព័ត៌មានពីរទៀត) EN 00170718 KH 00324714-00324715 (មានមនុស្សពីរនាក់ចូលធ្វើអន្តរាគមន៍ក្នុងខណៈកំពុងសម្ភាសជនទីបី)។

[794] ឯកសារចំណាងជើងថា "បទសម្ភាសន៍របស់ ចាប ឡុញ POW/MIA ស.ន.អ." ពុំដឹងកាលបរិច្ឆេទ D4.1.1030 EN 00526844។ ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[795] ស.ព.អ. អះអាងថា ឯកសារនេះជា "បទសម្ភាសន៍ POW/MIA ស.ន.អ." របស់ ចាប ឡុញ (*សូមមើល* ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ) ក៏ប៉ុន្តែមិនមានការចង្អុលបង្ហាញនៅក្នុងឯកសារនេះផ្ទាល់ ឬ នៅក្នុងទិន្នន័យ Zylab ថាការរៀបរាប់វាពិតប្រាកដនោះទេ។

[796] *សូមមើល* ឯកសារ ចំណាងជើងថា "បទសម្ភាសន៍របស់ ចាប ឡុញ POW/MIA ស.ន.អ." ឯកសារ D4.1.1030។

ត្រឹមតែថា មាស មុត ជាលេខាគណៈកម្មាធិការបក្សកំពង់សោមប៉ុណ្ណោះ។ គាត់មិនបានបញ្ជាក់ពីពេលវេលា ដែលថា មាស មុត កាន់តំណែងនេះ ឬ ថា មាស មុត គឺជាលេខាតំបន់ស្វយ័តកំពង់សោមនោះទេ។

២៤០. ស.ព.អ. ក៏ដកស្រង់ផងដែរ របាយការណ៍របស់ FBIS អំពី *ក្នុងចំណោមនោះ* ដំណើរទស្សនកិច្ច របស់ប្រតិភូចិន ទៅកាន់កំពង់សោម ជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. គឺ ប៉ុល ពត និង អៀង សារី[797]។ របាយការណ៍នេះមានតម្លៃជាភស្តុតាងតិចតួច ឬ ក៏សឹងតែគ្មាន។ របាយការណ៍នេះគឺជាការប្រមូលផ្តុំ របាយការណ៍នានាដែលរៀបចំឡើង ដោយអ្នកនិពន្ធដែលមិនស្គាល់ឈ្មោះ ផ្អែកទាំងស្រុងលើពាក្យចចាមអារ៉ាម។ យ៉ាងច្រើនបំផុត បើយោងតាមបុគ្គលមិនស្គាល់ឈ្មោះ ដែលធ្វើការផ្សព្វផ្សាយ ដូចមានរាយការណ៍នៅក្នុងឯកសារនេះ គឺឯកសារដែលបង្ហាញថា បុគ្គលឈ្មោះ “មុត” មានតួនាទីជា “លេខា ប.ក.ក. ក្រុងកំពង់សោម និង គណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម” នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៧៧ ជាកាលបរិច្ឆេទនៃដំណើរទស្សនកិច្ច ដែលគេលើកឡើងនោះ[798]។ ឯកសារនេះមិនមែនជាភស្តុតាងបង្ហាញថា មាស មុត មានតួនាទីនេះ ឬ អំពីរយៈពេលដែលគាត់កាន់តួនាទីនេះឡើយ។

២៤១. បើទោះបីជា មាស មុត ធ្លាប់ជាលេខាតំបន់ស្វយ័តកំពង់សោមក្តី ក៏គាត់គឺជាលេខាម្នាក់ ក្នុងចំណោមលេខាទាំង ១២ នៃតំបន់ស្វយ័ត ឬ ភូមិភាគទាំងអស់[799]។ លេខាទាំងអស់ត្រូវស្ថិតក្រោមបញ្ជាដោយផ្ទាល់ និង គោរពតាមមជ្ឈិមបក្ស[800]។ មិនមានលេខាណាម្នាក់ អាចដើរតួនាទីក្នុងការសម្រេច ឬ បង្កើតគោលនយោបាយរដ្ឋាភិបាល ឬ បក្សឡើយ លើកលែងតែលេខាដែលជាសមាជិករបស់គណៈអចិន្ត្រៃយ៍ ឬ គណៈមជ្ឈិម[801]។ តួនាទីជាលេខាតំបន់ស្វយ័តកំពង់សោម ឬ

---

[797] ជើងទំព័រ ២១៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កម្រង FBIS ខែធ្នូ ឆ្នាំ ១៩៧៧ ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D22.1.10 EN 00168349 KH 01194843។ *សូមមើល ផងដែរ* កថាខណ្ឌ ៧៣-៧៤ និង ជើងទំព័រ ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[798] កម្រង FBIS ខែធ្នូ ឆ្នាំ ១៩៧៧ ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D22.1.10 EN00168349 KH 01194843។

[799] *សូមមើល* ផែនទីនៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៦ ឯកសារ D4.1.376។

[800] មាត្រា ៨ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ *សូមមើលផងដែរ* កថាខណ្ឌ ២០៦, ២៧៤ នៃសាលក្រមក្នុងរឿងក្តី ០០២/០១ (តំបន់ស្វយ័តបានរាយការណ៍ផ្ទាល់ទៅ “មជ្ឈិមបក្ស” គឺមានដូចជាគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការយោធា មន្ទីរ ៨៧០ មន្ទីររដ្ឋាភិបាល (មន្ទីរ ស-៧១) និង មន្ទីរចំណុះឱ្យមន្ទីររដ្ឋាភិបាល)។

[801] *សូមមើល* កថាខណ្ឌ ១៦៩, ១៧៤, និង ១៧៨ *ខាងលើ* ទាក់ទងនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម។

មានសិទ្ធិអំណាចលើប្រតិបត្តិការ និង សកម្មភាពនៅក្នុងតំបន់ មិនបានធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" នោះទេ។

២៤២. ស.ព.អ. ក៏អះអាងផងដែរថា មាស មុត ត្រូវបានតែងតាំងឱ្យត្រួតត្រាលើតំបន់ ៥០៥ នៅក្នុងខេត្តក្រចេះ នៅចុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយថា ការតែងតាំងនេះធ្វើឱ្យកើនឡើង នូវវិសាលភាពនៃតំបន់ភូមិសាស្ត្រ ដែលអំណាចរបស់គាត់ត្រូវបានពង្រីក[802]។ ស.ព.អ. មិនបានផ្តល់ភស្តុតាងគាំទ្រដល់ការអះអាងរបស់គាត់ឡើយ[803]។ បើទោះបីជា មាស មុត ត្រូវបានតែងតាំងឱ្យត្រួតត្រាតំបន់ ៥០៥ ក៏ដោយ ក៏ការតែងតាំងនេះទើបតែធ្វើឡើងនៅចុងឆ្នាំ ១៩៧៨ គឺពីរខែមុនពេលបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ[804]។ ការតែងតាំងនេះមិនមែនជាដំណែងនៅទូទាំងប្រទេសឡើយ។ ដំណែងនេះពង្រីកត្រឹមតែតំបន់មួយ ដែលស្ថិតក្នុងចំណោមតំបន់ស្វាយ័ត និង ភូមិភាគដែលតួចជាងគេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ[805]។

ខ. មាស មុត មិនមែនជាសមាជិកខ្ពស់បំផុត នៃគណៈកម្មាធិការតំបន់ស្វាយ័តកំពង់សោម

២៤៣. ប្រភពដែល ស.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត គឺមានអំណាចខ្ពស់បំផុត នៅក្នុងគណៈកម្មាធិការតំបន់ស្វាយ័តកំពង់សោម ដោយមាន ធុច រិន ជាអនុប្រធានទទួលបន្ទុក លើកំពង់ផែកំពង់សោម និង ឡូញ ជាសមាជិកទទួលបន្ទុកភស្តុភារឡើយ[806]។ ស.ព.អ. ដកស្រង់ជាសំខាន់ នូវចម្លើយមិនអាចជឿជាក់បានរបស់ អែម សុន ស៊ឹម នី សាំ គំនិត និង ឯកសារនានា ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់[807]។

---

[802] កថាខណ្ឌ ៥៨, ៨៧, ១០៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[803] *សូមមើល* ផ្នែក IV.គ.៨ *ខាងក្រោម* សម្រាប់ការលើកឡើងទាក់ទងនឹងការអះអាងរបស់ ស.ព.អ. ពីសកម្មភាពរបស់ មាស មុត នៅក្នុងតំបន់ ៥០៥ ។

[804] *សូមមើល* កថាខណ្ឌ ២០០ *ខាងលើ*។ *សូមមើលផងដែរ* កថាខណ្ឌ ១៧៩ *ខាងលើ* ទាក់ទងនឹងការអះអាងរបស់ ឌុច ពីការចាត់តាំង មាស មុត ជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ១៩៧៨។

[805] ផែនទីពណ៌នៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៦ ឯកសារ D4.1.376 EN00295143 KH 00193066។

[806] កថាខណ្ឌ ៧២, ២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[807] ដើងចំពរ ២២០-២៥, ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

២៤៤. **អែម សុន**៖ អែម សុន មិនអាចជឿជាក់បានឡើយ[808]។ គាត់ "ជឿ" ថា មាស មុត មានតួនាទីធំជាង ធុច រិន គ្រាន់តែដោយសារ មាស មុត មកពីគណៈកម្មាធិការយោធា[809]។ ហេតុផលនេះ គឺមិនគ្រប់គ្រាន់ទេ សម្រាប់ការសម្រេចថា មាស មុត គឺជាថ្នាក់លើរបស់ ធុច រិន នៅកំពង់សោម។ អែម សុន ក៏បានបង្ហាញផងដែរថា រាល់សិទ្ធិអំណាចដែល មាស មុត មាននៅកំពង់សោម គឺជាអំណាចរួមគ្នាជាមួយ ធុច រិន។ គាត់គ្រាន់តែបាននិយាយថា ធុច រិន និង មាស មុត មានអំណាចបញ្ជូនកងយោធាពីកងពលធំលេខ ៣ ទៅឱ្យ ធុច រិន[810]។

២៤៥. **ស៊ឹម នី**៖ ស៊ឹម នី មិនអាចជឿជាក់បានឡើយ។ គាត់បានធ្វើការអះអាងដែលមិនត្រឹមត្រូវ ហើយផ្ទុយគ្នាអំពី មាស មុត[811]។ ស៊ឹម នី នៅក្នុងកងវរសេនាតូចលេខ ៥៥០ ហើយគាត់បានដាំបន្ទែនៅក្បែវត្តឥន្ទញ្ញាណ និង បានធ្វើការនៅក្រោម ធុច រិន នៅកំពង់ផែ មុនពេលដែលគាត់ត្រូវបានបញ្ជូនទៅភូមិភាគបូព៌ា នៅចុងឆ្នាំ១៩៧៨[812]។ គាត់បានអះអាងដោយមិនត្រឹមត្រូវថា មាស មុត "ទទួលខុសត្រូវរួមទាំងអស់"[813]។ ការអះអាងនេះ គឺប្រឌិតឡើង ដោយសារចម្លើយរបស់គាត់ដែលថា មាស មុត ធុច រិន និង ឡូញ ស្ថិតនៅក្នុងគណៈកម្មការតំបន់ស្វយ័តកំពង់សោម គ្រប់គ្រងលើផ្នែក

---

[808] *សូមមើល* កថាខណ្ឌ ២៣៦ *ខាងលើ* និង កថាខណ្ឌ ៣៤៩, ៤១៦, និង ៥១៥ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[809] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ឆ.៣២។ ជើងទំព័រ ២១៧, ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[810] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ឆ.៣០។

[811] *សូមមើល* កថាខណ្ឌ ៤០៦-០៨ *ខាងក្រោម* ទាក់ទងនឹងការអះអាងរបស់ ស៊ឹម នី ពីអំណាចរបស់ មាស មុត នៅវត្តឥន្ទញ្ញាន។

[812] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/31 ឆ.៦-៧, ឆ.៩។

[813] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332612 KH 00735605។ ជើងទំព័រ ២២០-២១, ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។ ស.ព.អ. បានដកស្រង់សម្តី ស៊ឹម នី បីដង ដើម្បីគាំទ្រការអះអាងតែមួយ។ ជើងទំព័រ ២២០-២១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/31 ឆ.១០-១២។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/30.1 EN 01070550 KH 00964127-00964128។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332598 KH 00735595-00735596។ *សូមមើលផងដែរ* ជើងទំព័រ ២២៣ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សម្តី ស៊ឹម នី ទាក់ទងនឹងដំណើរការធ្វើសេចក្តីសម្រេចរបស់គណៈកម្មាធិការតំបន់ស្វយ័តកំពង់សោម។

ផ្សេងៗគ្នានៅកំពង់សោម៖ មាស មុត ទទួលខុសត្រូវខាងយោធា ធុច រិន គ្រប់គ្រងផ្នែកសហគ្រាស និង ឡូញ គ្រប់គ្រងអង្គភាពនេសាទរដ្ឋ[814]។

២៤៦. **សាំ គំនិត៖** សាំ គំនិត មិនអាចជឿជាក់បានឡើយ។ ក.ស.ច.ស. បានកត់សម្គាល់ពីក្តីបារម្ភ អំពីភាពអាចជឿជាក់បានរបស់គាត់ ហើយចម្លើយរបស់គាត់ មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ សាំ គំនិត គឺជាកម្មករកំពង់ផែ ទទួលខុសត្រូវលើផ្នែកសាងសង់ ដែលស្ថិតក្រោម ធុច រិន រហូតដល់ឆ្នាំ ១៩៧៧។ ឆ្នាំ ១៩៧៧ គាត់បានជាប់គុកនៅបាត់ដំបង[815]។ សាំ គំនិត បាននិយាយថា ក្រុងកំពង់សោមស្ថិតក្រោមយោធា ហើយថា ក្រុងកំពង់សោម និង កំពង់ផែកំពង់សោម មានមេដឹកនាំខុសគ្នា[816]។ សាំ គំនិត មិនបាននិយាយថា មាស មុត នៅក្នុងគណៈកម្មាធិការតំបន់ស្វយ័តកំពង់សោម ឬ ថាជាថ្នាក់លើរបស់ ធុច រិន ឬ ឡូញ ទេ[817]។ អ្នកស៊ើបអង្កេត ក.ស.ច.ស. បានរៀបរាប់ថា គាត់គឺជាសាក្សីដែល “មានការប៉ះទង្គិចផ្លូវចិត្ត និង ងាយទទួលរងការឈឺចាប់” ហើយគាត់ “មិនបានឆ្លើយបានល្អ នៅក្នុងចម្លើយជាលើកទីពីររបស់គាត់នោះទេ”[818]។ អ្នកស៊ើបអង្កេតមានមូលដ្ឋានក្នុងការជឿជាក់ថា សាំ គំនិត លាក់ទុកព័ត៌មាន ហើយអាចទទួលរងសម្ពាធពីសំណាក់មេឃុំ ឬ មេភូមិ[819]។ ចម្លើយរបស់ សាំ គំនិត ត្រូវតែទទួលបានការវាយតម្លៃដោយប្រុងប្រយ័ត្ន។

២៤៧. ស.ព.អ. ក៏ដកស្រង់ផងដែរនូវឯកសារ ដែលមានបញ្ហាលើភាពអាចជឿជាក់បាន និង តម្លៃជាភស្តុតាង[820]។ ចម្លើយរបស់ ចាប ឡូញ ដែលអះអាងថាបានធ្វើឡើងជាមួយ POW/MIA[821] និង

---

[814] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332612 KH 00735605។ ជើងទំព័រ ២២០-២១, ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[815] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 ស-អ.៣, ស-អ.៥។

[816] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 អ.២០។ ជើងទំព័រ ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[817] ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិអះអាងនៅក្នុងកថាខណ្ឌ ៧២ និង ២២១ នៅក្នុងដីកាសន្និដ្ឋានស្តាពររបស់ខ្លួន។

[818] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/235 EN 01310764 KH 01397174-01397175។

[819] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/235 EN 01310764 KH 01397174-01397175។

[820] ជើងទំព័រ ២២០, ២២៤-២៥, ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[821] ជើងទំព័រ ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

របាយការណ៍ FBIS អំពីដំណើរទស្សនកិច្ចរបស់ប្រតិភូចិនទៅកំពង់សោម[822] គឺមានតម្លៃជាភស្តុតាងតិចតួច[823]។ ឯកសាររុស្សីដែលអះអាងថា រៀបរាប់អំពីមេដឹកនាំ ប.ក.ក. នៅ "ភូមិភាគ" ជាច្រើននោះ ដែលមានរួមបញ្ចូលឈ្មោះ មាស មុត ផងដែរនោះ[824] គឺមិនអាចឱ្យជឿជាក់បានទេ។ យោងតាមឯកសារបកប្រែជាភាសាអង់គ្លេស[825] ឯកសាររុស្សីនេះ គឺជាឯកសារបកប្រែ ពីឯកសារជាភាសាអេស្ប៉ាញ ដែលភ្ជាប់ជាមួយអត្ថបទសង្ខេបរបស់ទីភ្នាក់ងារសារព័ត៌មានរុស្សី ស្តីពីសុន្ទរកថាចំនួនពីររបស់ ប៉ុល ពត ដែលបានថ្លែងឡើងនៅក្នុងខែកញ្ញា និង ខែតុលា ឆ្នាំ ១៩៧៧[826]។ ក.ស.ច.ស. ទទួលបានឯកសារនេះពីសំណុំរឿងក្តី ០០២ ដែលទទួលបានមកពីបណ្ណាសារអាល្លឺម៉ង់ខាងកើតរបស់ក្រសួងការបរទេសអាល្លឺម៉ង់[827]។ ទោះបីជា "ប្រភព" របស់ព័ត៌មាន (ឯកអគ្គរដ្ឋទូតសូវៀត) ត្រូវបានបញ្ជាក់ឈ្មោះនៅផ្នែកបញ្ចប់នៃបញ្ជីក្តី ក៏មិនមានព័ត៌មានអំពីកាលបរិច្ឆេទរបស់ឯកសារនេះ ទីតាំងរបស់ប្រភព និង អំពីថាតើឯកអគ្គរដ្ឋទូតសូវៀត ទទួលបានព័ត៌មាននេះតាមរបៀបណានោះទេ។

២៤៨. មាស មុត មិនមែនជាសមាជិក ហើយក៏មិនមែនជាប្រធានគណៈកម្មាធិការតំបន់ស្វយ័តកំពង់សោមនោះដែរ។ ច្រើនបំផុត ភស្តុតាងនៅក្នុងសំណុំរឿង អាចត្រឹមចង្អុលបង្ហាញថា គាត់បានត្រួតពិនិត្យលើកងទ័ពនៅក្នុងតំបន់ ធុច វិន ត្រួតពិនិត្យលើកំពង់ផែ និង ប្រជាជនស៊ីវិល ហើយ ឡូញ ត្រួតពិនិត្យមើលលើកងនេសាទរដ្ឋ[828]។ ដូចគ្នានឹងអង្គភាពរបស់បក្សទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិប

---

[822] ជើងទំព័រ ២២០, ២២៤-២៥, ៦៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[823] *សូមមើល* កថាខណ្ឌ ២៣៩-៤០ *ខាងលើ*។

[824] បញ្ជីឈ្មោះភ្ជាប់ជាមួយនឹងរបាយការណ៍ TASS របស់រុស្ស៊ី ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ១៩៧៧ ឯកសារ D114/266.1.2។ ជើងទំព័រ ២២០ នៃដីកាសន្និដ្ឋានស្តាពរ។

[825] បញ្ជីឈ្មោះភ្ជាប់ជាមួយនឹងរបាយការណ៍ TASS របស់រុស្ស៊ី ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ១៩៧៧ ឯកសារ D114/266.1.2 EN 01519465-01519466 KH 01509097-01509098។

[826] របាយការណ៍ TASS របស់រុស្ស៊ី ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ១៩៧៧ ឯកសារ D114/266.1.1 EN 01519460-01519464 KH 01509092-01509096។ *សូមមើល* របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/266 EN 01335526 KH 01397193។

[827] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/266 EN 01335525 KH 01397192-01397193។

[828] ដូចបង្ហើយរបស់សាក្សី ដែល ស.ព.អ. ដកស្រង់៖ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332612 KH 00735605។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ន.៩, ន.១៥, ន.១៧, ន.៣៣។ កំណត់ហេតុនៃការស្តាប់ចម្លើយ

តេយ្យដែរ តំបន់ស្វយ័តត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការ ដែលមានមនុស្សបីនាក់ ដែលអនុវត្តភារកិច្ចជាសម្ងហភាព[829]។ បើទោះបីជា មាស មុត ស្ថិតនៅក្នុងគណៈកម្មាធិការតំបន់ក្តី ក៏មុខងារប្រតិបត្តិរបស់គណៈកម្មាធិការនេះ គឺមានន័យថាគាត់មិនមានសិទ្ធិអំណាចផ្តាច់មុខ នៅក្នុងតំបន់នោះឡើយ។

គ. បើទោះបីជា មាស មុត ជាលេខាតំបន់ស្វយ័តកំពង់សោម ឬ ជាសមាជិកគណៈកម្មាធិការតំបន់ស្វយ័តក្តី ក៏តំបន់ស្វយ័តកំពង់សោម មិនមែនជាផ្នែកសំខាន់គ្រប់គ្រាន់របស់របបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" នោះដែរ

២៤៩. ដូចគ្នានឹងតំបន់ឆ្នេរកំពង់សោមដែរ[830] តំបន់ដីគោកកំពង់សោម គឺជាផ្នែកដ៏តូចមួយ នៃផ្ទៃដីសរុបទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យ។ ស.ព.អ. អះអាងថា តំបន់ស្វយ័តកំពង់សោម មានផ្ទៃដីប្រមាណ ៨០០ គីឡូម៉ែត្រក្រឡា[831]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន ឬ ចម្លើយដែលមានកម្រិតរបស់ មាស វឿន ឯក នី អ៊ុយ ញ៉ឹក មាស អ៊ឹម និង ឯកសារផ្សេងៗជាច្រើន ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់[832]។ ស.ព.អ. លើកឡើងជ្រុលហួស។

សាក្សី យឹម ស្រៀង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ឆ.១៩៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 ឆ.១៨, ឆ.២០, ឆ.២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/234 ឆ.២។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 ឆ.៥-៧, ឆ.១២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ឆ.៤0, ឆ.៥៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង វ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.២៦, ឆ.២៨, ឆ.៣0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ វ៉ែត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 ឆ.៣0។

[829] មាត្រា ៦.១, មាត្រា ៨ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ *សូមមើល* កថាខណ្ឌ ២១២ *ខាងលើ* សម្រាប់ការលើកឡើងអំពីគណៈកម្មាធិការទាំងនេះ។

[830] *សូមមើល* កថាខណ្ឌ ២២៧ *ខាងលើ* ដែលពិភាក្សាអំពីឆ្នេរសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ។

[831] កថាខណ្ឌ ៧១ នៃដីកាសន្និដ្ឋានស្តាពរ (ដែលអះអាងថាកំពង់សោមមានព្រំប្រទល់ជាប់នឹងកំពង់ផែស្នឹងហាវ ឃុំវាលរេញ ឃុំវាម និង ក្រុងកំពង់សោម ហើយពីជើងមកត្បូងមានចម្ងាយផ្លាយបំផុត ៣0 គីឡូម៉ែត្រ ហើយពីកើតមកលិច មានចម្ងាយ ៣៥ គីឡូម៉ែត្រ)។

[832] ជើងទំព័រ ២១៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ៦៥៥។

ប្រទេសកម្ពុជាមានផ្ទៃដីសរុបប្រហែល ១៨១000 គីឡូម៉ែត្រក្រឡា[833]។ បើទោះបីជាតំបន់ស្វយ័តកំពង់សោម មានផ្ទៃដី ៨00 គីឡូម៉ែត្រក្រឡាក៏ដោយ ក៏ផ្ទៃដីនេះគឺបានត្រឹមតែ 0,៤៤% នៃផ្ទៃដីសរុបរបស់របបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ។

២៥0. **មាស វឿន**៖ មាស វឿន មិនអាចជឿជាក់បានឡើយ[834]។ គាត់បានអះអាងថា កងទ័ពជើងទឹកបានត្រួតត្រាលើដីគោកចាប់ពីវាលរេញ រហូតទៅដល់កំពង់សោម[835]។ ការប្រាស្រ័យទាក់ទងរបស់គាត់ជាមួយកងពលធំលេខ ១៦៤ គឺមានកម្រិតត្រឹមតែជាការសម្របសម្រួល លើការផ្គាស់ទីលើផ្ទៃសមុទ្រ ជាមួយកងវរសេនាធំរបស់កងពលធំលេខ ១៦៤ នៅលើផ្ទៃសមុទ្រជុំវិញកោះកុងប៉ុណ្ណោះ[836]។ មាស វឿន មិនបានដឹងថា តើកងពលធំលេខ ១៦៤ មានប្រតិបត្តិការនៅលើដីគោកកន្លែងណាឡើយ។

២៥១. **ឯក នី**៖ ឯក នី មិនអាចជឿជាក់បានឡើយ។ គាត់គឺជាប្រធានក្រុមម្នាក់ នៅក្នុងកងវរសេនាតូចលេខ ៣៨0 ដែលឈរជើងនៅលើកោះចំនួនពីរ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧[837] ហើយបន្ទាប់មកគាត់បានឈរជើងនៅជិតកងកេង និង ទឹកសាប[838]។ ឯក នី បានអះអាងថា តំបន់ប្រតិបត្តិការរបស់កងពលធំលេខ ១៦៤ គឺមានព្រំដែនរហូតដល់ទន្លេសាប នៅទិស

---

[833] វិទ្យាស្ថានស្ថិតិជាតិ ក្រសួងផែនការ របាយការណ៍ប្រចាំប្រទេសកម្ពុជាដាក់ជូនកិច្ចប្រជុំលើកទី ៦ នៃគណៈកម្មាធិការអ្នកជំនាញ អ.ស.ប. ស្តីពីការគ្រប់គ្រងព័ត៌មានភូមិសាស្ត្រសកល ក្រុងញូវយ៉ក ថ្ងៃទី៣-៥ ខែសីហា ឆ្នាំ ២0១៦ ទំព័រ ១ *អាចរកបាននៅតាមគេហទំព័រ* http://ggim.un.org/country-reports/documents/Cambodia-2016-country-report.pdf។ *សូមមើលផងដែរ* បណ្ណាល័យសភា ស.រ.អ. ផ្នែកស្រាវជ្រាវសហព័ន្ធ កម្ពុជា៖ ការសិក្សាពីប្រទេស លេខ xv (ឆ្នាំ ១៩៩0) *អាចរកបាននៅតាមគេហទំព័រ* https://www.loc.gov/item/89600150/។

[834] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមស្តីពីសាក្សីរូបនេះ។

[835] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២0១៤ ឯកសារ D54/51 ឧ.១៧។ ជើងទំព័រ ២១៥, ១៦៥១, ១៨២៣ នៃដីកាសន្និដ្ឋានស្តាពរ។

[836] *សូមមើល* កថាខណ្ឌ ៣២0-៣៤ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីកងពលលេខ ១ និង កងពលលេខ ១៦៤។

[837] បទសម្ភាស POW-MIA ចំណងជើងថា "ការសាកសួរព័ត៌មានផ្តាល់មាត់របស់លោក ឯក នី អតីតសមាជិកកងវរសេនាតូច ៣៨0 របស់កុម្មុយនីស្តខ្មែរ" ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២00២ ឯកសារ D4.1.747 EN 00387287-00387288 KH 00640513-00640514។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ ២0១៤ ឯកសារ D54/101 ឧ.៩ (ដែលអះអាងបញ្ជាក់ និង កែតម្រូវបទសម្ភាស POW/MIA របស់គាត់)។

[838] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២0១៤ ឯកសារ D54/102 ឧ.៧, ឧ.២៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២0១៤ ឯកសារ D54/103 ឧ.៣។

ខាងកើត ស្ទឹងហាវនៅទិសខាងជើង និង ទៅដល់សមុទ្រ និង កោះមួយចំនួន នៅទិសខាងលិច[839]។ ដោយសារតែតំបន់ប្រតិបត្តិការរបស់គាត់មានទំហំមានកម្រិត វាដូចជាមិនទំនងដែលថា ឯក នី អាចដឹងបានអំពីតំបន់ទាំងមូល ដែលស្ថិតក្រោមការត្រួតត្រារបស់កងពលធំលេខ ១៦៥ នោះ នេះមិនគិតដល់ពេលវេលាដែលគាត់នៅលើតំបន់ដីគោកផង។

២៥២. **អ៊ុយ ញឹក**៖ អ៊ុយ ញឹក មិនអាចជឿជាក់បានឡើយ។ គាត់គឺជាយុទ្ធជននៅក្នុងកងវរសេនាតូចលេខ ៣៨៦ ដែលត្រូវបានបញ្ជូនទៅកងផលិតនៅក្នុងឆ្នាំ ១៩៧៧[840]។ គាត់បានអះអាងថា បានឃើញ មាស មុត ចុះមកពិនិត្យនៅស្ទឹងហាវ ដោយជិះរថយន្ត[841]។ កម្រិតនៃអ្វីដែលគាត់បានសង្កេតឃើញ គឺ៖ មាស មុត បានបើករថយន្តមកស្ទឹងហាវ ជារៀងរាល់ពីរសប្តាហ៍ម្តង មាស មុត មិនដែលឈប់រថយន្ត ឬ ចុះពីលើរថយន្តឡើយ ហើយ អ៊ុយ ញឹក បានឃើញគាត់ពីចម្ងាយ ប្រហែល ៣០ ទៅ ៤០ ម៉ែត្រ[842]។ ចម្លើយទាំងនេះបានត្រឹមបង្ហាញថា មាស មុត បានបើករថយន្តកាត់តាមស្ទឹងហាវ ប៉ុណ្ណោះ។ ចម្លើយទាំងនេះមិនអាចកំណត់បានថា កងពលធំលេខ ១៦៥ ឬ មាស មុត មានសិទ្ធិអំណាចណាមួយទៅលើស្ទឹងហាវ ឬ ថាស្ទឹងហាវស្ថិតក្នុងតំបន់ស្វយ័តកំពង់សោមឡើយ។ នៅពេលក្រោយមក អ៊ុយ ញឹក បានផ្លាស់ប្តូររឿងរបស់គាត់។ គាត់បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា គាត់មិនដែលបានឃើញ មាស មុត នៅស្ទឹងហាវទេ ប៉ុន្តែគាត់គ្រាន់តែបានឃើញ មាស មុត ដើរនៅកំពង់សោម[843]។ បន្ទាប់ពីអ្នកស៊ើបអង្កេត បានរំឭកឡើងវិញនូវចម្លើយលើកមុនរបស់គាត់ប្រាប់ទៅគាត់វិញនោះ អ៊ុយ ញឹក បានប្តូរទៅរកចម្លើយដើមរបស់គាត់វិញ[844]។

២៥៣. **មាស អ៊ឹម**៖ មាស អ៊ឹម មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយដែលផ្ទុយគ្នាអំពី មាស មុត ហើយគាត់មិនបានស្បថថា និយាយតែការពិតក្នុងការស្តាប់ចម្លើយជាមួយ ក.ស.ច.ស.

---

[839] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/104 ស.១៦។ ជើងទំព័រ ២១៥ នៃដីកាសន្និដ្ឋានស្តាពរ។

[840] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញឹក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/76 ស.១០, ស.១៤, ស.១៧។

[841] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញឹក ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/77 ស.៥២ ។ ជើងទំព័រ ២១៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កថាខណ្ឌ ១៩៧ ជើងទំព័រ ៥៣៣-៣៤, ៥៣៦-៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[842] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញឹក ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/77 ស.៥៤-៥៧។

[843] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញឹក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/146 ស.៥០-៥១។

[844] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញឹក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/146 ស-ស.៥២។

នោះទេ និង បាននិយាយកុហកប្រាប់អ្នកសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ មាស អ៊ឹម បានធ្វើការងារជាច្រើននៅក្នុងកងពលធំលេខ ១៦៥ ដូចជាត្រួតពិនិត្យលើគ្រាក់ទ័រនៅស្ទឹងហាវ[845]។ នៅស្ទឹងហាវ គាត់គ្រាន់តែបានដឹងអំពីការងាររបស់គាត់ប៉ុណ្ណោះ[846]។ មាស អ៊ឹម បាននិយាយថា មាស មុត បានមកស្ទឹងហាវម្តងក្នុងមួយសប្តាហ៍ ចាប់ផ្តើមពីដើមឆ្នាំ ១៩៧៧[847]។ គាត់មិនបាននិយាយថា ស្ទឹងហាវស្ថិតក្នុងតំបន់ស្វយ័តកំពង់សោមឡើយ។ គាត់ក៏បាននិយាយផងដែរថា មាស មុត បានចាប់ផ្តើមចុះពិនិត្យស្ទឹងហាវ នៅពាក់កណ្តាលឆ្នាំ ១៩៧៦[848] គឺមិនមែននៅដើមឆ្នាំ ១៩៧៧ ទេ ហើយថាគាត់ (មាស អ៊ឹម) មិនបានទៅស្ទឹងហាវទេ នៅមុនឆ្នាំ ១៩៧៧[849]។ ទោះបីជាមិនគិតពីភាពផ្ទុយគ្នាទាំងនេះក្តី ក៏សក្ខីកម្មរបស់ មាស អ៊ឹម គឺមានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ។ ដោយសារតែគាត់ជាសាច់ញាតិរបស់ មាស មុត គាត់មិនបានស្បថថា និយាយតែការពិតប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ឡើយ[850]។ ចាប់តាំងពីការសម្ភាសន៍លើកដំបូងរបស់គាត់ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា មាស អ៊ឹម បានបង្ហាញឱ្យឃើញទំនោរនិយាយកុហក។ ដូចដែលគាត់បានប្រាប់អ្នកស៊ើបអង្កេត ដោយសារតែគាត់ “សំណោះសំណាលលេង” ជាមួយអ្នកសម្ភាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា “ដូច្នេះខ្ញុំប្រាប់គាត់ខ្លះពិត ខ្លះមិនពិត”[851]។

២៥៤. ស.ព.អ. ក៏ដកស្រង់របាយការណ៍ និង កំណត់ហេតុកិច្ចប្រជុំ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់អំពីព្រំដែនរបស់តំបន់ស្វយ័តកំពង់សោមផងដែរ[852]។ ឯកសារទាំងនេះមិនបានបង្ហាញថា ទីតាងដែលបាននិយាយយោងនៅក្នុងនោះ គឺជាផ្នែករបស់តំបន់ស្វយ័តកំពង់សោមឡើយ។ ឯកសារទាំង

---

[845] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/214 ន.២២-២៥។

[846] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ន.៥២។

[847] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ន.៣៩។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ន.១២។ ជើងទំព័រ ២១៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កថាខណ្ឌ ១៩៧ ជើងទំព័រ ៥៣៣-៣៤, ៥៣៦-៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[848] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ន.១២, ន.៦៦។

[849] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/214 ន.២៥។

[850] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 EN 01333468 KH 01301430។ វិធានផ្ទៃក្នុង ២៥(២) នៃវិធានផ្ទៃក្នុង។

[851] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/214 ន.៦។

[852] ជើងទំព័រ ២១៥ នៃដីកាសន្និដ្ឋានស្តាពរ។

នោះគ្រាន់តែបង្ហាញថា កងពលធំលេខ ១៦៤ អាចធ្វើសកម្មភាពមួយចំនួន នៅតាមទីតាំងទាំងនេះ។ ឯកសារ D1.3.12.3 ជារបាយការណ៍ដែលថា ផ្ញើទៅ សុន សេន គឺពាក់ព័ន្ធត្រឹមតែការសម្រេចថា តើមានមនុស្សត្រូវបានចាប់ខ្លួន នៅខាងកើតទឹកសាបដែរឬយ៉ាងណា និង ថាតើមានមនុស្សលាក់ខ្លួនដែរឬយ៉ាងណា នៅជុំវិញវាលរេញ[853]។ ឯកសារ D1.3.8.3 ដែលជាបណ្តុំនៃកំណត់ហេតុកិច្ចប្រជុំ រវាងគណៈកម្មាធិការកងពលធំលេខ ១៦៤ និង សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍/គណៈកម្មាធិការយោធា បង្ហាញត្រឹមថា កងពលធំលេខ ១៦៤ បានអនុវត្តសកម្មភាពមួយចំនួន នៅទីក្រុងកំពង់សោម រាម កងកេង និង បណ្តាកោះដែលបានលើកឡើងនៅក្នុងឯកសារ[854]។ ឯកសារ D1.3.34.10 ដែលជាសារទូរលេខអះអាងថាផ្ញើទៅ សុន សេន គឺគ្រាន់តែពាក់ព័ន្ធជាមួយសកម្មភាព ដែលបានរាយការណ៍អំពីកោះតាង កោះយំ កោះស្តេច និង កំពង់សោមប៉ុណ្ណោះ[855]។ ឯកសារ D1.3.14.2 ដែលជាសារទូរលេខផ្ញើដោយ មឿង នៅក្នុងកងពលធំលេខ ១៦៤ គឺគ្រាន់តែពាក់ព័ន្ធជាមួយសកម្មភាព ដែលបានរាយការណ៍ថាបានកើតឡើងនៅអូរឈើទាលប៉ុណ្ណោះ[856]។

ឃ. សេចក្តីសន្និដ្ឋាន

២៥៥. មាស មុត មិនធ្លាប់ជាលេខាតំបន់ស្វយ័តកំពង់សោម ហើយគាត់ក៏មិនមែនជាអាជ្ញាធរខ្ពស់បំផុត នៅក្នុងគណៈកម្មាធិការតំបន់ដែរ។ យ៉ាងច្រើនបំផុត គឺមានត្រឹមភស្តុតាងដែលបង្ហាញថា មាស មុត បានគ្រប់គ្រងលើកងទ័ពនៅក្នុងតំបន់ប៉ុណ្ណោះ។ ការណ៍ដែលថា មាស មុត អាចមានការទទួលខុសត្រូវលើ សកម្មភាពនានារបស់កងទ័ពជើងទឹក នៅតាមតំបន់ឆ្នេរ ដែលមានប្រវែងមិនដល់មួយភាគប្រាំមួយ នៃតំបន់ឆ្នេរទាំងមូលរបស់របបកម្ពុជាប្រជាធិបតេយ្យ និង តំបន់ដីគោកចំនួន ០,៤៤% នៃផ្ទៃដីសរុបរបស់របបកម្ពុជាប្រជាធិបតេយ្យផងនោះ មិនធ្វើឱ្យ មាស មុត ក្លាយជា “មេដឹកនាំជាន់ខ្ពស់” នោះឡើយ។ ប្រហែលគ្នានេះដែរ ការណ៍ដែលថា មាស មុត អាចមានអំណាចលើតំបន់ ៥០៥ ក្នុងរយៈពេលពីរខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏មិនធ្វើឱ្យគាត់ក្លាយជា “មេដឹកនាំជាន់ខ្ពស់” នោះដែរ។

---

[853] សេចក្តីរាយការណ៍ ចំណងជើងថា “ជម្រាបបង ៨៩ គោរពជ្រាប” ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.3។

[854] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3។

[855] ទូរលេខ ចំណងជើងថា “ទូរលេខ ៥៥ ពីមុត ជូនបង ៨៩” ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.10។

[856] ទូរលេខ ចំណងជើងថា “ទូរលេខ ៥៣ ពី មឿន ជូនបង មុត” ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៧៧ ឯកសារ D1.3.14.2។

ខ. ការជួបទាក់ទងញឹកញាប់ជាមួយ មេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឬ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

២៥៦. ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ក្នុងការការពារ និង គាំពាររបបកម្ពុជាប្រជាធិបតេយ្យ និង ប្រជាជនខ្មែរ[857] កងពលធំលេខ ១៦៤ បានទាក់ទងជាទៀងទាត់ជាមួយអគ្គសេនាធិការ និង មេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. អំពីបញ្ហាទាក់ទងការការពារជាតិ សន្តិសុខ និង ការកសាងជាតិ។ ការទំនាក់ទំនងបែបនេះគឺជារឿងទូទៅ សម្រាប់កងទ័ពនៅទូទាំងពិភពលោក។ ការប្រាស្រ័យទាក់ទង ឬ មានទំនាក់ទំនងជិតស្និទ្ធិជាមួយមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក. មិនមានន័យថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់"[858] ឬ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ឡើយ។ ស.ព.អ. អះអាងថា មាស មុត មានទំនាក់ទំនង និង ធ្វើការងារយ៉ាងជិតស្និទ្ធិ ជាមួយមេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក. ដែលមានន័យថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ ហើយថា ការទំនាក់ទំនងទាំងនេះ បានជួយដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងតំបន់ដែលគាត់គ្រប់គ្រង[859]។ ស.ព.អ.៖ **ក.** ដកស្រង់សាក្សីមួយចំនួនតូច ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ **ខ.** ដកស្រង់ឯកសារមួយចំនួន ដែលមិនទាក់ទងនឹងកងពលធំលេខ ១៦៤ និង **គ.** ធ្វើការសន្និដ្ឋានដោយផ្អែកលើឯកសារមួយចំនួនតូច ដើម្បីធ្វើការអះអាងដ៏ទូលំទូលាយអំពី មាស មុត និង កងពលធំលេខ ១៦៤។ ស.ព.អ. មិនបានបង្ហាញភស្តុតាង ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ទេ។

១. ការទំនាក់ទំនងរវាងមជ្ឈិម និង កងពលធំ

២៥៧. ប្រភពដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រយ៉ាងពេញលេញឡើយ ដល់ការអះអាងរបស់គាត់ដែលថា កងពលធំ និង មជ្ឈិម មានការទាក់ទងគ្នាច្រើនដងក្នុងមួយថ្ងៃ តាមរយៈវិទ្យុទាក់ទងទូរស័ព្ទ ឬ សារទូរលេខ ដែលប្រើប្រាស់សម្រាប់ការទំនាក់ទំនងសម្ងាត់ និង ដើម្បីកោះហៅមេបញ្ជាការ មកចូលរួមកិច្ចប្រជុំសម្ងាត់[860]។ ស.ព.អ. បានដកស្រង់ ឡុញ ដុស ឈួក រិន អៀង ជាន

---

[857] *សូមមើល* មាត្រា ១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.2 ដែលកំណត់ភារកិច្ចនៃ ក.ប.ក.។

[858] កថាខណ្ឌ ៣១៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[859] កថាខណ្ឌ ៥១, ២៦២, ២៩៥-៣០៧, ៩៨០ នៃដីកាសន្និដ្ឋានស្តាពរ។

[860] កថាខណ្ឌ ២៩៦ នៃដីកាសន្និដ្ឋានស្តាពរ។

និង ជួន ធី[861]។ វិសាលភាព និង ភាពពាក់ព័ន្ធ នៃការដឹងឮរបស់សាក្សីទាំងនេះ គឺមានកម្រិតកំណត់ត្រឹមពេលវេលា និង កាលៈទេសៈជាក់លាក់របស់ពួកគេ។ ចម្លើយរបស់ពួកគេមិនបានកំណត់ នូវទម្រង់ធំទូលាយនៃការទំនាក់ទំនងរវាងកងពលធំ និង មជ្ឈិមឡើយ ទាក់ទងនឹងព័ត៌មានសម្ងាត់ និង ព័ត៌មានមិនសម្ងាត់។

២៥៨. **ឡុញ ដុស**៖ ការដឹងឮរបស់ ឡុញ ដុស អំពីការប្រាស្រ័យទាក់ទង គឺមានកម្រិតកំណត់ដោយពេលវេលា[862]។ គាត់ពិតជាបាននិយាយថា តំបន់របស់គាត់បានទាក់ទងតាមវិទ្យុទាក់ទងជាមួយកងពលធំ ជាច្រើនលើកក្នុងមួយថ្ងៃ ហើយទូរស័ព្ទ និង សារទូរលេខ ត្រូវបានប្រើប្រាស់សម្រាប់ការទាក់ទងសម្ងាត់ ហើយមេបញ្ជាការទទួលបានទូរសារ កោះហៅពួកគេទៅចូលរួមប្រជុំសម្ងាត់[863]។ ការដឹងឮរបស់គាត់អំពីរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទង គឺមានកម្រិតកំណត់ត្រឹមរយៈពេល ១៨ ខែ ដែលគាត់បានធ្វើការនៅអគ្គសេនាធិការ។ ចម្លើយរបស់គាត់ មិនមែនសម្រាប់រយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលឡើយ។

២៥៩. **ឈួក រិន**៖ ការដឹងឮរបស់ ឈួក រិន អំពីការប្រាស្រ័យទាក់ទង គឺមានកម្រិតកំណត់ដោយតួនាទីរបស់គាត់។ គាត់គឺជាមេបញ្ជាការកងវរសេនាតូច នៅក្នុងភូមិភាគនិរតី រហូតដល់ឆ្នាំ ១៩៧៧ នៅពេលដែលគាត់បានក្លាយជាមេបញ្ជាការកងវរសេនាធំ នៅក្នុងកងពលធំលេខ ៧០៣ នៅក្នុងខេត្តស្វាយរៀង[864]។ គាត់បាននិយាយថា ជាទូទៅ មានតែមេបញ្ជាការកងពលធំប៉ុណ្ណោះ ដែលអាចផ្ញើសារទូរលេខ ទៅអគ្គសេនាធិការ ហើយគាត់ថា គាត់មិនដែលបានផ្ញើសារទូរលេខបែបនេះទេ[865]។ ការដឹងឮរបស់គាត់អំពីសារទូរលេខ ថាជាទម្រង់មួយនៃការប្រាស្រ័យទាក់ទង គឺមានកម្រិតត្រឹមបញ្ជាតាមសារទូរលេខមួយ ដែលគាត់បានទទួល ដែលជាការបញ្ជូនគាត់ទៅខេត្តស្វាយរៀង

---

[861] ជើងទំព័រ ៩៦៥-៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[862] *សូមមើល* កថាខណ្ឌ ១៩៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[863] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364071 KH 00357492-00357493។ ជើងទំព័រ ៩៦៥-៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

[864] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.848 អ.១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D4.1.408 EN 00268869-00268870 KH 00194465-00194466។

[865] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.848 អ.៧។ ជើងទំព័រ ៩៦៧ នៃដីកាសន្និដ្ឋានស្តាពរ។

ប៉ុណ្ណោះ[866]។ ជាទូទៅ គាត់បានទទួលបញ្ជាតាមវិទ្យុទាក់ទង[867]។ គាត់មិនបាននិយាយឡើយថា កងពលធំធ្វើការទំនាក់ទំនងតាមវិទ្យុទាក់ទងជាមួយមជ្ឈិម ជាច្រើនដងក្នុងមួយថ្ងៃ ឬ ថាការទំនាក់ទំនងសម្ងាត់ ត្រូវបានបញ្ជូនតាមទូរលេខ ឬ តាមទូរស័ព្ទ។

២៦០. **អៀង ផាន**៖ ការដឹងឮរបស់ អៀង ផាន អំពីការប្រាស្រ័យទាក់ទង គឺមានកម្រិតកំណត់ត្រឹមការទំនាក់ទំនងរបស់កងពលធំគាត់ប៉ុណ្ណោះ។ គាត់គឺជាមេបញ្ជាការកងវរសេនាធំ នៅក្នុងកងពលធំលេខ ២[868]។ នៅក្នុងឆ្នាំ ១៩៧៨ គាត់ត្រូវបានបញ្ជូនទៅខេត្តស្វាយរៀង[869]។ គាត់បាននិយាយថា គាត់បានទាក់ទងជាមួយថ្នាក់លើ តាមរយៈសារទូរលេខ ប៉ុន្តែគាត់បានយោងទៅរកពេលវេលាដែលគាត់នៅក្នុងភូមិភាគបូព៌ា នៅពេលដែលគាត់បានទាក់ទងជាមួយមេបញ្ជាការកងពលធំរបស់គាត់ គឺ រិន និង សុន សេន អំពីផែនការកងទ័ព[870]។ គាត់មិនបានផ្តល់ចម្លើយទូលំទូលាយ អំពីការទំនាក់ទំនងរវាងអគ្គសេនាធិការ និង កងពលធំ ឬ ក៏និយាយថា ការទំនាក់ទំនងសម្ងាត់ត្រូវបានបញ្ជូនតាមសារទូរលេខ ឬ ទូរស័ព្ទឡើយ។

២៦១. **ជួន ធី**៖ ចម្លើយរបស់ ជួន ធី គឺទាក់ទងត្រឹមតែការទំនាក់ទំនងផ្ទៃក្នុងរបស់កងពលធំគាត់ប៉ុណ្ណោះ។ ជួន ធី គឺជាមេបញ្ជាការកងវរសេនាធំម្នាក់ នៅក្នុងកងពលធំលេខ ១[871]។ គាត់បានទទួលសារទូរលេខពីមេដឹកនាំកងពលធំលេខ ១ ដែលបាននិយាយអំពីសកម្មភាពខ្មាំង[872]។ គាត់មិនបានផ្តល់ចម្លើយទូលំទូលាយ អំពីការទំនាក់ទំនងរវាងអគ្គសេនាធិការ និង កងពលធំ ឬ ក៏និយាយថា ការទំនាក់ទំនងសម្ងាត់ ត្រូវបានបញ្ជូនតាមទូរលេខ ឬ ទូរស័ព្ទឡើយ។

---

[866] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D4.1.408 EN 00268871 KH 00194467។

[867] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D4.1.408 EN 00268873 KH 00194469។

[868] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ឆ.១។

[869] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ឆ.៥។

[870] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ឆ.១១។ ជើងទំព័រ ៩៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[871] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី ២ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1056 ឆ.៣។

[872] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី ២ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1056 ឆ.៩។ ជើងទំព័រ ៩៦៥ នៃដីកាសន្និដ្ឋានស្តាពរ។

២៦២. ស.ព.អ. ក៏ដកស្រង់ផងដែរ នូវប្រតិចារឹកវឿងក្តី ០០២/០១ និង អះអាងដោយខុសឆ្គងថា ប្រតិចារឹកនេះមានសក្ខីកម្មរបស់ មាស វឿន[873] ដែលថាវិទ្យុទាក់ទង និង សារទូរលេខ គឺជាបណ្តាញទំនាក់ទំនង ដែលប្រើប្រាស់ជាញឹកញាប់[874]។ ចម្លើយដែល ស.ព.អ. ដកស្រង់ គឺមិនមែនជាចម្លើយរបស់ មាស វឿន នោះទេ។ នេះគឺជាចម្លើយមកពីដីកាដំណោះស្រាយក្នុងវឿងក្តី ០០២ ដែលអានដោយក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង[875]។ ការសម្រេចនៅក្នុងដីកាដំណោះស្រាយ គឺមិនមែនជាភស្តុតាងទេ។

២. ការប្រាស្រ័យទាក់ទងរបស់ មាស មុត ជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. មិនមានន័យថាគាត់គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"

២៦៣. ប្រភពដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានធ្វើការងារជិតស្និទ្ធ និង មានទំនាក់ទំនងជាទៀងទាត់ជាមួយគណៈអចិន្ត្រៃយ៍ និង គណៈមជ្ឈិម ព្រមទាំងអគ្គសេនាធិការ[876] តាមរយៈសារទូរលេខ ទូរស័ព្ទ សំបុត្រ នីរសារ និង រថភ្លើងឡើយ[877]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន និង មិនមានការគាំទ្ររបស់ ឌុច លុន សេង មុត ម៉ៅ និង ហ៊ីង រ៉ែត រួមទាំងឯកសារនានា[878]។ ស.ព.អ. បំផ្លើសភស្តុតាង។ បើទោះបីជា មាស មុត បានធ្វើការងារជិតស្និទ្ធិ ឬ មានទំនាក់ទំនងញឹកញាប់ជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. ក៏នេះមិនមានន័យថាគាត់គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់នោះដែរ។

២៦៤. **ឌុច៖** ឌុច មិនអាចជឿជាក់បានឡើយ[879]។ គាត់អះអាងជាចម្បងថា មាស មុត *បានជួយ* ដល់គណៈមជ្ឈិម ប៉ុន្តែមិនបានចូលរួមក្នុងគណៈមជ្ឈិមទេ[880]។ គាត់មិនបាននិយាយថា មាស មុត

---

[873] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[874] ជើងទំព័រ ៩៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[875] *សូមមើល វឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹកចុះថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.177 នៅម៉ោង 09.08.38-09.11.10។

[876] កថាខណ្ឌ ៥១ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៩១។

[877] កថាខណ្ឌ ២៩៩, ៩៨០ នៃដីកាសន្និដ្ឋានស្តាពរ។

[878] ជើងទំព័រ ១៤១-៤៨, ៩៧៦-៧៩ នៃដីកាសន្និដ្ឋានស្តាពរ។

[879] *សូមមើល* កថាខណ្ឌ ១៧៥-៧៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[880] ជើងទំព័រ ១៤១ នៃដីកាសន្និដ្ឋានស្តាពរ។

"បានធ្វើការយ៉ាងជិតស្និទ្ធ" ជាមួយគណៈមជ្ឈិមនោះទេ[881]។ ការមានតួនាទីដែលមិនចូលរួម នៅក្នុងគណៈមជ្ឈិម មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឡើយ។ ប្រសិនបើ ស.ច.ស. សម្រេចថា មាស មុត គឺជាជំនួយការរបស់គណៈមជ្ឈិម ស.ច.ស. ក៏ត្រូវតែពិចារណាថា ជំនួយការមានត្រឹមសិទ្ធិចូលរួមក្នុងវគ្គបណ្តុះបណ្តាល ប៉ុន្តែមិនអាចបញ្ចេញមតិយោបល់ ឬ បោះឆ្នោតបានឡើយ[882]។

២៦៥. **លុន សេង**៖ លុន សេង មិនអាចជឿជាក់បានឡើយ[883]។ គាត់បានអះអាងថា បានស្តាប់ឮថា មាស មុត ស្ថិតនៅក្នុង "គណៈកម្មាធិការជំនួយ" សម្រាប់ផ្សព្វផ្សាយគោលនយោបាយបក្ស ទៅឱ្យថ្នាក់ក្រោមជាប្រជាជនស៊ីវិល ឬ យោធា[884]។ លុន សេង មិនបាននិយាយថា មាស មុត "បានធ្វើការយ៉ាងជិតស្និទ្ធ" ជាមួយគណៈមជ្ឈិមឡើយ[885]។ ដោយសារតែគោលនយោបាយរក្សាការសម្ងាត់របស់ ប.ក.ក.[886] វាមិនចំនងទេថា ព័ត៌មានបែបនេះត្រូវបានចែករំលែក ទៅដល់ទាហានដែលយ៉ាងខ្ពស់បំផុត នៅកម្រិតកងវរសេនាតូចនោះ។

២៦៦. **មុត ម៉ៅ**៖ មុត ម៉ៅ មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នាទៅឱ្យ ក.ស.ច.ស. អំពី មាស មុត អំពីការងាររបស់គាត់ជាអ្នកកាន់ទូរស័ព្ទ និង ពេលវេលារបស់គាត់នៅកំពង់សោម។ មុត ម៉ៅ គឺជាអ្នកឆ្លើយឆ្លងទូរស័ព្ទ នៅបញ្ជាការដ្ឋានកងពលធំលេខ ១៦៥ ដែលរស់នៅជាមួយ មាស មុត ក្នុងមួយរយៈពេលខ្លី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[887]។ ស.ព.អ. ដកស្រង់តែត្រង់ មុត ម៉ៅ អះអាងថា មន្ទីរក-១ មន្ទីរ និង កន្លែងស្នាក់នៅរបស់គណៈអចិន្ត្រៃយ៍ បានទូរស័ព្ទទៅមន្ទីរ

---

[881] កថាខណ្ឌ ៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[882] ដូចដែលបានពន្យល់ក្នុងកថាខណ្ឌ ១៧៨ *ខាងលើ*។

[883] *សូមមើល* កថាខណ្ឌ ១៩៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[884] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/110 ឆ.២០-២៣។ ជើងទំព័រ ១៤២ នៃដីកាសន្និដ្ឋានស្តាពរ។

[885] កថាខណ្ឌ ៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[886] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ទាក់ទងនឹងគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតម្លៃកស្តុតាង។

[887] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 ឆ.១០, ឆ.១៧-១៨, ឆ.២៣។ មុត ម៉ៅ ជាប់សាច់ញាតិយាយខុម ភរិយាទី១របស់ មាស មុត។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/70 EN 00983613 KH 00979221។

របស់ មាស មុត ម្តងក្នុងមួយថ្ងៃ ឬ ពីរថ្ងៃ[888]។ ស.ព.អ. មិនបានគិតអំពីចម្លើយដែលផ្ទុយគ្នារបស់ មុត ម៉ៅ នោះទេ។

២៦៧. ជាដំបូង មុត ម៉ៅ បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា គាត់មិនបានចាំថា ធ្លាប់បានភ្ជាប់បណ្តាញទូរស័ព្ទឱ្យ មាស មុត ទាក់ទងទៅថ្នាក់លើទេ ដោយទាយស្មានថា មាស មុត ប្រហែលមានខ្សែទូរស័ព្ទសម្ងាត់ ឬ បានប្រើប្រាស់សារទូរលេខ[889]។ បន្ទាប់មកគាត់បានអះអាងថា បណ្តាញទូរស័ព្ទកណ្តាលរបស់គាត់ ត្រូវតែភ្ជាប់ការហៅទូរស័ព្ទពី មាស មុត ទៅមជ្ឈិម ប៉ុន្តែគាត់បាននិយាយថា គាត់មិនចាំថាធ្លាប់ធ្វើការងារនេះទេ[890]។ នៅថ្ងៃបន្ទាប់គាត់បានបន្ថែមព័ត៌មានលម្អិតទៅលើរឿងរបស់គាត់ថា៖ មន្ទីរក-១ បានទូរស័ព្ទទៅកាន់ មាស មុត ម្តងក្នុងមួយថ្ងៃ ឬ ពីរថ្ងៃ ហើយមានទូរស័ព្ទហៅទៅវិញទៅមក រវាង មាស មុត និង មជ្ឈិម[891]។ សក្ខីកម្មផ្ទុយគ្នារបស់ មុត ម៉ៅ គឺមិនត្រឹមតែអំពីការទំនាក់ទំនងរវាង មាស មុត និង មជ្ឈិមប៉ុណ្ណោះទេ។ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសគាត់ គាត់បាននិយាយថា គាត់បានឃើញជនជាតិអាមេរិកដែលគេចាប់ខ្លួនបាននៅកំពង់សោម ដោយគាត់បានរៀបរាប់លម្អិតអំពីរូបរាងរបស់ជនជាតិអាមេរិកទាំងនោះ និង ទីកន្លែងដែលគាត់ឃើញពួកគេ[892]។ នៅពេលដែលគាត់ឆ្លើយជាមួយ ក.ស.ច.ស. គាត់បដិសេធថាមិនដែលបានឃើញពួកគេទេ[893]។

២៦៨. បើទោះបីជាមិនគិតអំពីសក្ខីកម្មដែលផ្ទុយគ្នារបស់គាត់ក្តី ក៏ភស្តុតាងរបស់ មុត ម៉ៅ គឺមានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ។ មុខងំណែងរបស់គាត់ជាអ្នកឆ្លើយឆ្លងទូរស័ព្ទ គឺមានកម្រិតនៅត្រង់ពេលវេលា ត្រឹមពាក់កណ្តាលឆ្នាំ ១៩៧៨។ គាត់បាននិយាយថា គាត់ត្រូវបានបញ្ជូនទៅកំពង់សោមនៅចុងឆ្នាំ ១៩៧៧[894] ហើយថា គាត់បានធ្វើការនៅផ្ទះសំណាក់សុខា ប្រហែលកន្លះឆ្នាំ (ពោលគឺ

---

[888] កថាខណ្ឌ ៥១, ៩១, ២៩៩ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល ដូចខាងលើ* ដើងចំពីរ ១៥៣, ២៧៦, ៩៧៧ ដែលដកស្រង់ពីកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/73 ឆ.៣-៥។

[889] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/72 ឆ.៤៦។

[890] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/72 ឆ.៤៧។

[891] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/73 ឆ.៤។

[892] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មុត ម៉ៅ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០០៧ ឯកសារ D59/1/1.13 EN 00966917-00966922 KH 00926660-00926665។

[893] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/70 ឆ.៧-១២។

[894] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/70 ឆ.៣៧។

រហូតដល់ត្រីមាសទីមួយ ឬ ត្រីមាសទីពីរនៃឆ្នាំ ១៩៧៨) ដែលបន្ទាប់ពីនោះមក គាត់បានក្លាយជាចុងភៅនៅផ្ទះ មាស មុត[895]។ គាត់បានស្នាក់នៅជាមួយ មាស មុត ប្រហែលពីរទៅបីខែ ទើបគេបញ្ជូនគាត់ឱ្យទៅរៀន ធ្វើជាអ្នកឆ្លើយឆ្លងទូរស័ព្ទ[896]។ ប្រហែលពីរ ឬ បីខែមុនពេល ពួកគេរត់គេចពីវៀតណាម ក្រុមរបស់គាត់ត្រូវបានរំសាយ ហើយគាត់ត្រឡប់ទៅដាំស្ពរឱ្យ មាស មុត វិញ[897]។ ផ្អែកលើចម្លើយទាំងនេះ គាត់បានធ្វើការជាអ្នកឆ្លើយឆ្លងទូរស័ព្ទ បានប្រហែលពីរ ឬ បីខែប៉ុណ្ណោះ នៅក្នុងឆ្នាំ ១៩៧៨។ សូម្បីតែចម្លើយទាំងនេះ ក៏មានលក្ខណៈផ្ទុយគ្នាពីចម្លើយដំបូងរបស់គាត់ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ មុត ម៉ៅ បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់បានធ្វើការជាអ្នកឆ្លើយឆ្លងទូរស័ព្ទ អស់រយៈពេលជាងមួយឆ្នាំ រួមទាំងរយៈពេលបណ្តុះបណ្តាលកន្លះឆ្នាំ[898]។ អំឡុងពេលវេលានេះមិនត្រូវគ្នាជាមួយ ការមកដល់កំពង់សោមនៅចុងឆ្នាំ ១៩៧៧ ឡើយ។

២៦៩. **ប៊ាង រ៉ែត**៖ ប៊ាង រ៉ែត មិនអាចជឿជាក់បានឡើយ។ គាត់មិនបានដឹងឮផ្ទាល់ អំពីរបៀបដែល មាស មុត បានទទួលបញ្ជានោះឡើយ។ គាត់គឺជាមេបញ្ជាការរងកងអនុសេនាធំនៃកងវរសេនាតូចលេខ ៤៥០/១៦៥[899] ដែលបាននិយាយថា បញ្ជាត្រូវបានបញ្ជូនទៅ មាស មុត តាមរយៈសារទូរលេខ[900]។ គាត់បានសន្មតការណ៍នេះ ដោយផ្អែកលើការចូលរួមក្នុងវគ្គរៀនសូត្រ អំពីការទំនាក់ទំនងតាមសារទូរលេខ និង អក្សរសម្ងាត់[901]។

២៧០. ស.ព.អ. ដកស្រង់ កំណត់ហេតុកិច្ចប្រជុំរវាងគណៈកម្មាធិការកងពលធំលេខ ១៦៥ និង សមាជិកគណៈអចិន្ត្រៃយ៍ ព្រមទាំងសារទូរលេខ និង របាយការណ៍ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់

---

[895] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 ឆ.១៧។

[896] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 ឆ.២៣។

[897] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 ឆ.៣៩។

[898] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ មុត ម៉ៅ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៧ ឯកសារ D59/1/1.13 EN 00966922 KH 00926665។ នៅក្នុងបទសម្ភាសជាមួយនឹង ក.ស.ច.ស. គាត់បាននិយាយម្តើងវិញថា ការបង្រៀននោះអស់រយៈពេល ៦ ខែ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/72 ឆ.២៩។

[899] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.១១។

[900] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៦២។ ជើងទំព័រ ៩៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

[901] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៦២ (គាត់ចាប់ផ្តើមឆ្លើយដោយនិយាយថា “តាមខ្ញុំដឹង...”។

ដែលថា មាស មុត បានផ្តល់ដំណឹងដល់មេដឹកនាំជាន់ខ្ពស់ អំពីស្ថានភាពនៅក្នុងតំបន់ ដែលស្ថិតក្រោមអំណាចរបស់គាត់[902]។ ការរាយការណ៍ជូនទៅ ប៉ុល ពត ន្ឋន ជា វន វ៉ែត ឬ មេដឹកនាំជាន់ខ្ពស់ ប.ក.ក. ផ្សេងទៀត មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឡើយ។ ដូចដែល អៀង ផាន បានផ្តល់សក្ខីកម្ម ទាហានជាទូទៅត្រូវរាយការណ៍ទៅអគ្គសេនាធិការ[903]។ ស.ព.អ. មិនបានពិចារណាអំពីឋានានុក្រមនៃការរាយការណ៍ ដែលមានចែងនៅក្នុងលក្ខន្តិក: ប.ក.ក. និងមុខដំណែងថ្នាក់ក្រោមរបស់គណៈកម្មាធិការកងពលធំលេខ ១៦៥ ធៀបទៅនឹងគណៈអចិន្ត្រៃយ៍ និង គណៈកម្មាធិការយោធាដែលមាន ប៉ុល ពត ន្ឋន ជា និង វន វ៉ែត ជាសមាជិក[904]។ ការទំនាក់ទំនងរវាង មាស មុត គណៈកម្មាធិការកងពលធំលេខ ១៦៥ និង មេដឹកនាំជាន់ខ្ពស់ ប.ក.ក. គឺតម្រូវតាមលក្ខន្តិក:របស់ ប.ក.ក. និង គណៈអចិន្ត្រៃយ៍ ពីព្រោះកងពលធំលេខ ១៦៥ ស្ថិតក្រោមអំណាចរបស់គណៈអចិន្ត្រៃយ៍ តាមរយៈអគ្គសេនាធិការ[905]។

២៧១. ស.ព.អ. ដកស្រង់របាយការណ៍ និង សារទូរលេខ[906] ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានទាក់ទងញឹកញាប់ជាមួយ សុន សេន តាមរយៈមធ្យោបាយផ្សេងៗគ្នា[907]។ ភាគច្រើននៃឯកសារទាំងនេះ និយាយខុស ឬ មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ.៖

- ឯកសារ **D1.3.30.25**៖ ស.ព.អ. ដកស្រង់សារទូរស័ព្ទចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ដោយប្រើលេខឯកសារផ្សេងៗគ្នាចំនួនបី[908] ដើម្បីធ្វើឱ្យមើលទៅឃើញថា គាត់ដកស្រង់ឯកសារដែលមានច្រើន លើសពីឯកសារដែលគាត់បានដកស្រង់ជាក់ស្តែង។

---

[902] កថាខណ្ឌ ៥១ ជើងចំព័រ ១៤៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៩១ ជើងចំព័រ ២៧៣-៧៦។

[903] *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/297.1.40 នៅម៉ោង 09.44.45-09.46.35។

[904] *សូមមើល* កថាខណ្ឌ ១៦៩ និង ១៧២ *ខាងលើ* ទាក់ទងនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ និង គណៈកម្មាធិការយោធា។

[905] *សូមមើល* កថាខណ្ឌ ២១១-១៣ *ខាងលើ* ទាក់ទងនឹងសិទ្ធិអំណាចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការលើកងពលធំលេខ ១៦៥ និង សមាជិកគណៈកម្មាធិការបីរូប ដែលបញ្ជាកងពលធំលេខ ១៦៥។

[906] ជើងចំព័រ ១៤៦, ២៧៣, ៩៧៦-៧៨ នៃដីកាសន្និដ្ឋានស្តាពរ។

[907] កថាខណ្ឌ ៥១, ៩១ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ២៩៩, ៩៨០។

[908] ជើងចំព័រ ៩៧៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ៤ ខែមករា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D54/23.3។ សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D54/73.1 និង សេចក្តីវាយការណ៍ ចំណង

- ឯកសារ **D1.3.30.26**៖ មិនមានការចង្អុលបង្ហាញថា សារទូរស័ព្ទចុះថ្ងៃទី ១៥ ខែមេសា ឆ្នាំ ១៩៧៨ ដែលថាផ្ញើពីកងវរសេនាធំលេខ ៦៣ ទៅ ន្ឋន ជា ទាក់ទងការវាយប្រយុទ្ធ នៅក្នុងភូមិភាគបូព៌ា គឺផ្ញើពី មាស មុត ឬ មានពាក់ព័ន្ធនឹង មាស មុត នោះឡើយ[909]។

- ឯកសារ **D1.3.12.20**៖ មិនមានការចង្អុលបង្ហាញថា នរណាជាអ្នកបង្កើតរបាយការណ៍ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ដែលថាផ្អែកលើការហៅទូរស័ព្ទមកពី មាស មុត ដោយមានចំណារ របស់ សុន សេន ឡើយ[910]។

- ឯកសារ **D1.3.34.64**៖ របាយការណ៍ទូរស័ព្ទចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨ ដែលថាផ្ញើទៅ សុន សេន គឺមិនបានរៀបរាប់ពីការសម្លាប់នៅផ្ទៃសមុទ្រឡើយ ប៉ុន្តែគឺរៀបរាប់ពីការចាប់ កាណូតថៃ និង វៀតណាម និង ការពន្លិចកាណូតវៀតណាមមួយ[911]។

- ឯកសារ **D4.1.637**៖ របាយការណ៍ទូរស័ព្ទចុះថ្ងៃទី ៤ ខែមេសា ឆ្នាំ ១៩៧៨ ដែលផ្ញើទៅ សុន សេន គឺមិនទាក់ទងជាមួយទាហាន ដែលរងរបួសនៅក្នុងការវាយប្រយុទ្ធនៅកោះត្រល់ ឡើយ ប៉ុន្តែ គឺទាក់ទងអ្នករងរបួសក្រោយពេលដែលគ្រាប់មីនក្នុងទឹកត្រូវបានលើកយកពីបាត សមុទ្រមក[912]។

ជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D1.3.30.25 ដែលឯកសារទាំងអស់មានខ្លឹមសារដូចគ្នា។ *សូមមើលផងដែរ* ជើងទំព័រ ៩៨១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ឯកសារ D54/23.3 និង សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D54/73.1។

[909] ជើងទំព័រ ៩៧៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ថ្ងៃទី ១៥ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១៥ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D1.3.30.26។

[910] ជើងទំព័រ ៩៧៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍ ចំណងជើងថា "សេចក្តីវាយការណ៍ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20។ *សូមមើលផងដែរ* ជើងទំព័រ ៩៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[911] ជើងទំព័រ ៩៧៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨ ឯកសារ D1.3.34.64។ *សូមមើលផងដែរ* ជើងទំព័រ ១៤៦, ២៧៣, ៩៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[912] ជើងទំព័រ ៩៧៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ៤ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ៤ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D4.1.637 ។ *សូមមើលផងដែរ* ជើងទំព័រ ២៧៣, ៩៨១, ៩៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

- ឯកសារ **D4.1.1010**៖ មិនមានការចង្អុលបង្ហាញថា មាស មុត គឺជា "មុត" ដែលចុះហត្ថលេខាលើលិខិតចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ១៩៧៨ អំពីសំណើរបស់ Elizabeth Becker សុំជួបជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. និង សុំធ្វើដំណើរនៅក្នុងកម្ពុជាប្រជាធិបតេយ្យឡើយ[913]។

- ឯកសារ **D1.3.30.2**៖ របាយការណ៍ដែលថាផ្ញើទៅ សុន សេន តាមរថភ្លើងនៅថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ មិនបានបង្ហាញថា របាយការណ៍ជាច្រើន ត្រូវបានផ្ញើតាមរថភ្លើង ឬ ថារបាយការណ៍បែបនេះ ត្រូវបញ្ជូនជារៀងរាល់ខែឡើយ។ ស.ព.អ. ដកស្រង់របាយការណ៍នេះចំនួនពីរដង ដោយប្រើលេខឯកសារពីរខុសគ្នា[914]។

២៧២. ស.ព.អ. ដកស្រង់សារទូរលេខ និង របាយការណ៍ចំនួនបួន ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានចម្លងជូន ប៉ុល ពត ឡួន ជា និង អៀង សារី នៅក្នុងលិខិតឆ្លើយឆ្លងជូនទៅ សុន សេន ជាពិសេសទាក់ទងនឹងការអនុវត្តគោលនយោបាយបក្សចំពោះខ្មាំង[915]។ ឯកសារទាំងនេះមិនគាំទ្រដល់ការអះអាងឡើយ៖

- ឯកសារ **D4.1.699**៖ ទូរលេខនេះមិនមែនផ្ញើពី មាស មុត ទៅមេដឹកនាំជាន់ខ្ពស់ ប.ក.ក. ឡើយ។ ទូរលេខនេះមិនទាក់ទងទាំងស្រុង ឬ ជាចម្បងទៅនឹងគោលនយោបាយបក្សចំពោះខ្មាំងឡើយ។-ទូរលេខនេះក៏ពិភាក្សាផងដែរអំពីបញ្ហាផលិតស្រូវ និង បញ្ហាព្រំដែន[916]។

- ឯកសារ **D1.3.34.60**៖ ទូរលេខនេះទាក់ទងនឹងគោលនយោបាយបក្ស ស្តីពីការការពារជាតិប្រឆាំងការឈ្លានពានរបស់វៀតណាម។ ទូរលេខនេះមិនទាក់ទងទៅនឹងគោលនយោបាយស្តីពីខ្មាំងផ្ទៃក្នុងឡើយ[917]។

---

[913] ជើងចំព័រ ៩៧៨ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីរាយការណ៍ ចំណងជើងថា "សំបុត្រពី កាន និង មុត "សូមគោរពជូនបង"" ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ១៩៧៨ ឯកសារ D4.1.1010។

[914] ជើងចំព័រ ៩៨០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីរាយការណ៍ ចំណងជើងថា "សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D114/19.1 និង សេចក្តីរាយការណ៍ ចំណងជើងថា "សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2។

[915] កថាខណ្ឌ ៩១ ជើងចំព័រ ២៧៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងចំព័រ ២០៣។

[916] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ពីសមមិត្ត ឌឹម ជូនបងមុតជ្រាប" ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699។

- ឯកសារ **D1.3.30.25**៖ របាយការណ៍នេះមិនទាក់ទងទាំងស្រុង ឬ ជាចម្បងទៅនឹងគោលនយោបាយបក្សចំពោះខ្មាំងឡើយ។ របាយការណ៍នេះក៏បានលើកឡើងផងដែរ អំពីបញ្ហាភស្តុភារដូចជាកាលវិភាគដោះដែងអ្នកជាប់ឃុំជនជាតិថៃ ការពិសោធន៍គ្រាប់មីន និងតម្រូវការគ្រាប់រំសេវ[918]។

- ឯកសារ **D1.3.12.2**៖ របាយការណ៍នេះមិនទាក់ទងទាំងស្រុង ឬ ជាចម្បងទៅនឹងគោលនយោបាយបក្សចំពោះខ្មាំងឡើយ។ របាយការណ៍នេះលើកឡើងផងដែរ អំពីបញ្ហាការពារជាតិទាក់ទងនឹងកោះត្រល់[919]។

សារទូរលេខផ្សេងទៀតដែលមាននៅក្នុងសំណុំរឿង បង្ហាញប្រហែលគ្នាថា បុគ្គលិកនៃកងពលធំលេខ ១៦៤ ចម្លងជូនមេដឹកនាំជាន់ខ្ពស់ ប.ក.ក. នូវរបាយការណ៍ស្តីពីបញ្ហាជាច្រើនផ្សេងៗគ្នា ដូចជាបញ្ហាការពារជាតិ ការប្រារព្ធកម្មវិធីបក្ស និង តម្រូវការភស្តុភារ ក៏ដូចជាបញ្ហាខ្មាំងខាងក្នុង ឬ ខាងក្រៅ[920]។

២៧៣. ស.ព.អ. ដកស្រង់អត្ថបទរបស់សារព័ត៌មាន *ឌីប៊ែមហ្គាដេលី* ដែលបានដកស្រង់សម្តី មាស មុត ដែលនិយាយថា គាត់បានជួបជាមួយ សុន សេន "ពីរបីដង"[921]។ យោងតាមអត្ថបទនេះ ការប្រជុំគឺ

---

[917] ទូរលេខ ចំណងជើងថា "ទូរលេខ ០០ – វិទ្យុ ៣៥៤ ខ្ទង់ – គោរពជូនគណៈ ម.៨៧០" ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.60។ *សូមមើល* កថាខណ្ឌ ៥១១ *ខាងក្រោម* ដែលពិភាក្សាពីបរិបទដែលទូរលេខនេះត្រូវបានបញ្ជូនចេញ។

[918] សេចក្តីរាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D1.3.30.25។

[919] សេចក្តីរាយការណ៍ ចំណងជើងថា "សេចក្តីរាយការណ៍ជូន បង ៨៩ ទីគោរព ជ្រាប" ចុះថ្ងៃទី ៦ ខែកុម្ភៈ [មិនដឹងឆ្នាំ] ឯកសារ D1.3.12.2។

[920] *សូមមើលឧទា.* ទូរលេខ ចំណងជើងថា "ទូរលេខ ១២ ជូនបងមុតជ្រាប" ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.12 EN 00897638 KH 00021528។ ទូរលេខ ចំណងជើងថា "ទូរលេខ ១៦ ពីសមមិត្ត ឌឹម ជូនបងមុតជ្រាប" ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.13។ ទូរលេខ ចំណងជើងថា "ទូរលេខ ១៥ ពីសមមិត្ត ឌឹម ជូនបងមុតជ្រាប" ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.14។ ទូរលេខ ចំណងជើងថា "សារតាមទូរស័ព្ទពី មឿន គោរពជូនសមមិត្ត បងមុត ជ្រាប" ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៧៧ ឯកសារ D1.3.14.2។

[921] កថាខណ្ឌ ៥១ នៃដីកាសន្និដ្ឋានស្តាពរ។

ដើម្បីអនុវត្តការងាររបស់គណៈកម្មាធិការមជ្ឈឹម[922]។ មិនមានខ្សែអាត់ថតសំឡេងនៃការសម្ភាសន៍នេះ នៅក្នុងសំណុំរឿងឡើយ។ ការសម្ភាសន៍នេះមិនត្រូវបានធ្វើឡើង ដោយមានការត្រួតពិនិត្យរបស់តុលាការឡើយ ហើយត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សេង ក្រៅពីការជំនុំជម្រះក្តីរឿងព្រហ្មទណ្ឌ។ ឯកសារនេះមានតម្លៃជាភស្តុតាងតិចតួច[923]។

២៧៤. ស.ព.អ. ក៏បានដកស្រង់ផងដែរ នូវការសម្ភាសន៍មួយដែលអ្នកស៊ើបអង្កេតជនជាតិអាមេរិករបស់ POW/MIA បានធ្វើឡើងជាមួយ មាស មុត ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានធ្វើការទំនាក់ទំនងជាមួយមជ្ឈឹម តាមរយៈនិរសារ[924]។ មាស មុត ត្រូវបានអះអាងថាបាននិយាយថា ការទំនាក់ទំនងជាមួយទីក្រុងភ្នំពេញ អំពីព្រឹត្តិការណ៍ម៉ាយ៉ាហ្គេ នៅខែឧសភា ឆ្នាំ ១៩៧៥ គឺធ្វើឡើងតាមរយៈនិរសារ[925]។ មិនមានខ្សែអាត់ថតសំឡេងនៃការសម្ភាសន៍នេះ នៅក្នុងសំណុំរឿងឡើយ។ ការសម្ភាសន៍នេះមិនត្រូវបានធ្វើឡើង ដោយមានការត្រួតពិនិត្យរបស់តុលាការ ហើយត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សេង ក្រៅពីការជំនុំជម្រះរឿងព្រហ្មទណ្ឌ។ ការសម្ភាសន៍នេះមានតម្លៃជាភស្តុតាងតិចតួច[926]។ ចម្លើយនេះគឺមានកម្រិតត្រឹមខែឧសភា ឆ្នាំ ១៩៧៥។ ចម្លើយនេះមិនពាក់ព័ន្ធដល់ការសម្រេច អំពីវិធីសាស្ត្រទូទៅនៃការទំនាក់ទំនងរវាងកងពលធំលេខ ១៦៥ និង មជ្ឈឹមឡើយ។

២៧៥. ស.ព.អ. ដកស្រង់ចម្លើយដែលថាមកពី អៀង សារី និង ឯកសារ FBIS ដើម្បីអះអាងថា មាស មុត បានអមដំណើរ អៀង សារី នៅក្នុងកិច្ចប្រជុំជាមួយអាជ្ញាធរបរទេស[927]។ ការមានវត្តមាននៅពេលដែលប្រតិភូបរទេស មកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ មិនធ្វើឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឡើយ។ ទោះជាក្នុងករណីណាក៏ដោយ ស.ព.អ. មិនបានបង្ហាញភស្តុតាង

---

[922] Erika Kinetz និង Yun Samean *អ្វីៗដែលកន្លងហួស សូមទុកជាអរហោសិកម្មចុះ* (Let Bygones be Bygones) សារព័ត៌មានឌីឌមប៊ូឌាដេលី ចុះថ្ងៃទី ១-២ ខែមីនា ឆ្នាំ ២០០៨ ឯកសារ D1.3.7.8 EN 00165821។ ជើងទំព័រ ១៤៨ នៃដីកាសន្និដ្ឋានស្តាពរ។

[923] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ប្រភេទនៃភស្តុតាងបែបនេះ។

[924] កថាខណ្ឌ ២៩៩ ជើងទំព័រ ៩៧៩ នៃដីកាសន្និដ្ឋានស្តាពរ។

[925] បទសម្ភាសន៍ជាមួយ មាស មុត (POW/MIA) ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០១ ឯកសារ D22.2.181 EN 00249694 KH 00741997។

[926] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* សម្រាប់ការលើកឡើងបន្ថែមពីប្រភេទនៃភស្តុតាងនេះ។

[927] កថាខណ្ឌ ៥១ នៃដីកាសន្និដ្ឋានស្តាពរ។

គាំទ្រដល់ការអះអាងរបស់គាត់ឡើយ។ ចម្លើយរបស់ អៀង សារី គឺគ្រាន់តែនិយាយពី "សមមិត្ត មុត" ចូលរួមក្នុងកិច្ចប្រជុំជាមួយ អៀង សារី និង អ្នកផ្សេងទៀតប៉ុណ្ណោះ[928]។ មិនមានការបង្ហាញថា "សមមិត្ត មុត" គឺជា មាស មុត ឡើយ។ ពាក្យពេចន៍នៅក្នុងឯកសារបង្ហាញថា មានតែបុគ្គលិករបស់ក្រសួងការបរទេសប៉ុណ្ណោះ ដែលបានចូលរួមនៅក្នុងការប្រជុំនោះ[929]។ របាយការណ៍ FBIS[930] គឺមានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ[931]។ របាយការណ៍នេះជាបណ្តុំរបាយការណ៍ ដែលបានរៀបចំឡើងដោយអ្នកនិពន្ធមិនស្គាល់ឈ្មោះ ដោយផ្អែកទាំងស្រុងលើពាក្យចចាមអារ៉ាម។ ប្រសិនបើ ស.ច.ស. យល់ស្របថាឯកសារនេះមានតម្លៃជាភស្តុតាង ស.ច.ស. គួរតែពិចារណាថា ឯកសារនេះមិនបានរៀបរាប់ថា មាស មុត គឺជាសមាជិកគណៈមជ្ឈិម (ដែលផ្ទុយពី ប៉ុល ពត ដែលត្រូវបានរៀបរាប់ថាជាលេខាគណៈមជ្ឈិម)[932]។ ឯកសារនេះបង្ហាញត្រឹមតែថា មាស មុត អាចជាផ្នែកមួយនៃព្រឹត្តិការណ៍នៅកំពង់សោម នៅពេលដែល ប៉ុល ពត និង អៀង សារី បាននាំប្រតិភូចិនទៅធ្វើទស្សនកិច្ចនៅទីក្រុងនោះ។

២៧៦. ស.ព.អ. ដកស្រង់សារទូរលេខ និង របាយការណ៍ជាច្រើន មកពីកងពលធំនានា ក្រៅពីកងពលធំលេខ ១៦៥ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត រាយការណ៍ទៅមជ្ឈិម អំពី

---

[928] សេចក្តីថ្លែងការណ៍របស់អៀង សារី ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ១៩៧៦ ឯកសារ D4.1.1031 EN 00003694 KH 00003684។

[929] *សូមមើលឧទា.* សន្ទនាការរបស់អៀង សារី ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៦ ឯកសារ D4.1.1031 EN 00003698 KH 00003691 ("ពិតមែនតែសមមិត្ត នាយ សារ៉ាន់ សេង ហុង និង សៃ ពុំបាននៅ តែក្រសួងការបរទេសនៅទីនេះ ជំនួសគណៈប្រតិភូ សូមសំដែងអំណរគុណចំពោះសមមិត្ត ដែលបានខិតខំប្រឹងប្រែងធ្វើការដើម្បីពង្រឹងសាមគ្គីភាព មិត្តភាពរវាងបក្សយើងទាំងពីរ") EN 00003700 KH 00003693 ("ក្នុងនាមនៃក្រសួងការបរទេស យើងខ្ញុំសូមអញ្ជើញអ្នកកាសែត និង អ្នកថតរូបទាំងខាងជើង ទាំងខាងត្បូង ពីបីទៅប្រាំនាក់ ក្នុងរយៈពេលពីមួយអាទិត្យទៅដប់ថ្ងៃ")។

[930] កម្រងឯកសារ FBIS ខែធ្នូ ឆ្នាំ ១៩៧៧ ចុះថ្ងៃទី ១-៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D22.1.10 EN 00168349 KH 01194843។ ជើងទំព័រ ១៤៧ នៃដីកាសន្និដ្ឋានស្តាពរ។

[931] *សូមមើល* កថាខណ្ឌ ២៤០ *ខាងលើ*។

[932] កម្រងឯកសារ FBIS ខែធ្នូ ឆ្នាំ ១៩៧៧ ចុះថ្ងៃទី ១-៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D22.1.10 EN 00168349 KH 01194843។ *សូមមើល* កថាខណ្ឌ ២៣៦ និង ២៤០ *ខាងលើ* ទាក់ទងនឹងឯកសារពាក់ព័ន្ធ ដែលសហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា មាស មុត ជាលេខាតំបន់ស្វាយតកំពង់សោម។

ប្រធានបទជាច្រើនផ្សេងៗគ្នា ដូចជាការចូលរួមរបស់កងទ័ព[933] ខ្មាំងផ្ទៃក្នុង និង បរទេស[934] ការបង្កបង្កើនផលស្រូវ[935] សុខភាពកងទ័ព[936] និង ដំណើរការសាងសង់[937]។ ឯកសារទាំងនេះមិនពាក់ព័ន្ធនឹងកងពលធំលេខ ១៦៤ ឬ មាស មុត ទេ។ ឯកសារទាំងនេះមិនមានតម្លៃជាភស្តុតាងឡើយ ដូច្នេះហើយចាំបាច់ត្រូវតែមិនយកមកពិចារណា។

---

[933] ជើងចំព័រ ៩៨២ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍ ចំណងជើងថា "កំណត់សម្គាល់សរសេរដៃ 'ជូនអង្គការ' 'គោរពជូនអ៊ុំ ៨៩' ពី រឿន ៨០១" ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D4.1.572 (សេចក្តីវាយការណ៍ពី អ៊ឹង រ៉ែន កងពល ៨០១ ជូន សុន សេន)។

[934] ជើងចំព័រ ៩៨៣-៨៤ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ចុះថ្ងៃទី ១ ខែឧសភា ឆ្នាំ ១៩៧៦ ពី អឿន គោរពជូនបង ៨៩" ចុះថ្ងៃទី ១ ខែឧសភា ឆ្នាំ ១៩៧៦ ឯកសារ D234/2.1.46 (សេចក្តីវាយការណ៍ពីកងពល ៣១០ ជូន សុន សេន)។ សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៧៧ ពីសុក ជូនបង ៨៩ ជាទីគោរព" ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.45 (សេចក្តីវាយការណ៍ពីកងពល ១៧០ ជូន សុន សេន) ។ សេចក្តីវាយការណ៍យោធា ចំណងជើងថា "សូមវាយការណ៍ពី រ៉ែន ជូនបង ៨៩" ចុះថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.48 (សេចក្តីវាយការណ៍ពីមន្ទីរសេនាធិការទៅកាន់ សុន សេន) ។ សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ពី រឿន ជូនអ៊ុំ ៨៩" ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D10.1.98 (សេចក្តីវាយការណ៍ពីកងពល ៨០១ ជូន សុន សេន)។ និង សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ពីគណៈកងពល ៣១០ ជូនបង ៨៩" ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៧ ឯកសារ D4.1.643 (សេចក្តីវាយការណ៍ពីគណៈកងពល ៣១០ ជូន សុន សេន)។

[935] ជើងចំព័រ ៩៨៥ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់របាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៧៧ ពីសុក ជូនបង ៨៩ ជាទីគោរព" ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.45 សេចក្តីវាយការណ៍កងពល ១៧០ ជូន សុន សេន)។ សេចក្តីវាយការណ៍យោធា ចំណងជើងថា "សូមវាយការណ៍ពី រ៉ែន ជូនបង ៨៩" ចុះថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.48 (សេចក្តីវាយការណ៍ពីមន្ទីរសេនាធិការជូន សុន សេន) និង សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ពី រឿន ជូនអ៊ុំ ៨៩" ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D10.1.98 (សេចក្តីវាយការណ៍ពីកងពល ៨០១ ជូន សុន សេន)។

[936] ជើងចំព័រ ៩៨៦ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ទូរលេខ ចំណងជើងថា "សេចក្តីវាយការណ៍ជម្រាបបង ៨៩ ពីកងពល ៨០១" ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៧៦ ឯកសារ D10.1.97 (សេចក្តីវាយការណ៍ពីកងពល ៨០១ ជូន សុន សេន)។

[937] ជើងចំព័រ ៩៨៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ពីគណៈកងពល ៣១០ ជូនបង ៨៩" ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៧ ឯកសារ D4.1.643 (សេចក្តីវាយការណ៍ពីគណៈកងពល ៣១០ ជូន សុន សេន) និង សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៧៦" ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៧៦ ឯកសារ D4.1.1014 (សេចក្តីវាយការណ៍ពីកងពល ៣១០ ជូន សុន សេន)។

៣. សេចក្តីសន្និដ្ឋាន

២៧៧. មិនមានអ្វីដែលមានលក្ខណៈឧក្រិដ្ឋឡើយ ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងរបស់ មាស មុត ជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក.។ កងទ័ពត្រូវបានគ្រប់គ្រងទាំងស្រុងដោយមជ្ឈិមបក្ស ដែលបង្កើតនូវឋានានុក្រមរាយការណ៍យ៉ាងម៉ឺងម៉ាត់ ហើយតម្រូវឱ្យមានរបាយការណ៍ជាទៀងទាត់[938]។ មាស មុត បានធ្វើការទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. អំពីបញ្ហាការពារជាតិ និង កងទ័ព។ ដោយមិនគិតពីភាពញឹកញាប់ ការដែលធ្វើដូច្នេះ មិនមានន័យថាគាត់ជា "មេដឹកនាំជាន់ខ្ពស់" ឬ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ឡើយ។

គ. មាស មុត មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា ដែលបានប្រព្រឹត្តឡើងនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩

២៧៨. បើទោះបីជាពិនិត្យមើលដោយលម្អៀងបំផុត ទៅរក ស.ព.អ. ក៏ដោយ ក៏ភស្តុតាងមិនបានកំណត់ថា មាស មុត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរ។ ស.ព.អ. បំផ្លើសហួស។ ស.ព.អ.៖ **ក.** ពឹងផ្អែកលើសាក្សីដែលចម្លើយរបស់ពួកគាត់ គឺផ្អែកលើពាក្យចចាមអារ៉ាម ឬ ការទាយស្មាន ឬ ត្រូវបានធ្វើឱ្យខូច **ខ.** ដកស្រង់ភស្តុតាងជាឯកសារដែលមិនអាចជឿជាក់បាន ឬ មិនគាំទ្រដល់ការអះអាងរបស់គាត់ **គ.** មិនគិតអំពីភស្តុតាងបរិបទ និង ប្រវត្តិសាស្ត្រ និង **ឃ.** បង្ហាញភស្តុតាងដោយខុសឆ្គង។ បើទោះបីជាអាចទម្លាក់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើ មាស មុត ចំពោះសកម្មភាព និង សិទ្ធិអំណាចដែលត្រូវបានចោទប្រកាន់លើគាត់ នៅក្នុងកងពលធំលេខ ១៦៤ តំបន់ស្វយ័តកំពង់សោម ឬ តំបន់ ៥០៥ ក្តី ក៏ការសម្រេចបែបនេះនឹងមិនអាចដំឡើង មាស មុត ឱ្យចូលទៅក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" បានដែរ។ សកម្មភាព និង សិទ្ធិអំណាចរបស់ មាស មុត គឺស្ថិតនៅក្នុងតែបញ្ហាកងទ័ពជើងទឹក នៅក្នុងតំបន់កំពង់សោម និង ត្រឹមតែពីរខែប៉ុណ្ណោះ នៅក្នុងតំបន់ ៥០៥។ បញ្ហាទាំងនេះចាំបាច់ត្រូវតែពិនិត្យមើល ធៀបទៅនឹងព្យសនកម្មទាំងស្រុងដែលបង្កឡើងដោយគោលនយោបាយរបស់ ប.ក.ក. នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[939]។

---

[938] *សូមមើល* កថាខណ្ឌ ១៧២ និង ២១៣ *ខាងលើ* ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃការរាយការណ៍របស់បក្ស។

[939] កថាខណ្ឌ ៣១៧ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

១. មាស មុត មិនមានអំណាចក្នុងការសម្រេចលើគោលនយោបាយ ប.ក.ក. ឬ ការអនុវត្តគោលនយោបាយទាំងនោះ

២៧៩. មាស មុត មិនស្ថិតក្នុងស្ថាប័នជាន់ខ្ពស់របស់ ប.ក.ក. ដែលធ្វើការសម្រេចចិត្តឡើយ៖ គឺមិនស្ថិតនៅក្នុង គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ គណៈយោធា ឬ អគ្គសេនាធិការ[940]។ គាត់ និង សមាជិកផ្សេងទៀត នៃគណៈកម្មាធិការកងពលធំលេខ ១៦៥ ក៏ដូចជាគណៈកម្មាធិការនៃតំបន់ស្វយ័តកំពង់សោម បានរាយការណ៍ និង ទទួលយកគោលនយោបាយ និង ការណែនាំ ពីអគ្គសេនាធិការ និង មេដឹកនាំជាន់ខ្ពស់ ប.ក.ក. ផ្សេងទៀត។ ពួកគេទាំងអស់ត្រូវបានតម្រូវឱ្យគោរពតាម។ បើទោះបីជាពិនិត្យមើលលើភស្តុតាង ដោយលម្អៀងបំផុតទៅរកខាង ស.ព.អ. ក្តី ក៏ភស្តុតាងមិនបានបង្ហាញថា មាស មុត អាចចូលរួមចំណែក ឬ ធ្វើការសម្រេចលើគោលនយោបាយ ប.ក.ក. និង ការអនុវត្តគោលនយោបាយទាំងនោះឡើយ។

ក. គណៈអចិន្ត្រៃយ៍ និង អគ្គសេនាធិការ បានផ្សព្វផ្សាយគោលនយោបាយ និង ការណែនាំ ទៅកងពលធំ ហើយតម្រូវឱ្យមានរបាយការណ៍ពីថ្នាក់ក្រោមមកវិញ

២៨០. ប្រភពដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រដល់ការអះអាងរបស់គាត់ដែលថា អគ្គសេនាធិការបានចេញបញ្ជាជាលាយលក្ខណ៍អក្សរ និង ដោយផ្ទាល់មាត់ទៅ មាស មុត រួមទាំងការកម្ទេចខ្ទាំងនោះទេ[941]។ ស.ព.អ. ដកស្រង់ចម្លើយដែលមិនគាំទ្ររបស់ ហ៊ីង អ៊ុច និង អ៊ុង រ៉ែន ក៏ដូចជាសារទូរលេខ និង របាយការណ៍ផ្សេងទៀត[942]។ ស.ព.អ. មិនបានគិតអំពីភស្តុតាងរចនាសម្ព័ន្ធពាក់ព័ន្ធអំពី ប.ក.ក.ឡើយ។ យ៉ាងច្រើនបំផុត ភស្តុតាងដែល ស.ព.អ. ដកស្រង់ ចង្អុលបង្ហាញពីកងទ័ពដែលបំពេញការងារជាកងទ័ព ដូចជាថ្នាក់លើចេញបញ្ជាណែនាំទៅថ្នាក់ក្រោម ហើយបណ្តាកងខាងក្រោមរាយការណ៍ទៅថ្នាក់លើរបស់ពួកគេ អំពីបញ្ហាទាក់ទងកងទ័ព និង ការការពារជាតិ។

២៨១. **ហ៊ីង អ៊ុច៖** ហ៊ីង អ៊ុច មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ ហ៊ីង អ៊ុច ដែលរៀបការជាមួយ មុត ម៉ៅ[943] គឺជាអ្នកបកប្រែសារនៅក្នុងកងវរសេនាធំលេខ ៦៣[944]។ គាត់គ្រាន់តែបាន

---

[940] *សូមមើល* IV.ក.១-៣ *ខាងលើ*។

[941] កថាខណ្ឌ ៣០១ នៃដីកាសន្និដ្ឋានស្តាពរ។

[942] ជើងទំព័រ ៩៨៨-៨៩, ៩៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[943] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 EN 01056696 KH 00984385។ *សូមមើល* កថាខណ្ឌ ២៦៦-៦៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សី មុត ម៉ៅ។

ដឹងអំពីដំណើរការរបស់កងគាត់ប៉ុណ្ណោះ[945]។ គាត់គ្រាន់តែទទួលទូរលេខពីកងពលធំលេខ ១៦៥ ប៉ុណ្ណោះ[946]។ គាត់មិនដែលបានឃើញ ឬ បានទទួលសារទូរលេខពី សុន សេន ឬ ពីអគ្គសេនាធិការឡើយ[947]។ គាត់បាននិយាយថា មន្ទីរ ៨៧០ បានផ្ញើសារណែនាំទៅកងពលធំលេខ ១៦៥ ហើយថា គាត់បានទទួលសារដែលបញ្ជូនបន្តពីកងពលធំលេខ ១៦៥[948]។ ចម្លើយរបស់គាត់ គឺពាក់ព័ន្ធត្រឹមតែមួយករណីនៅក្នុងឆ្នាំ ១៩៧៨ នៅពេលដែលគាត់បានទទួលពីកងពលធំលេខ ១៦៥ នូវការណែនាំដែលបានបញ្ជូនបន្តពីមន្ទីរ ៨៧០ អំពីការឈ្លានពានរបស់វៀតណាម នៅខេត្តស្វាយរៀង និងព្រៃវែង[949]។ នេះមិនមែនជាចម្លើយអំពីដំណើរការទូទៅ ដែលអគ្គសេនាធិការ (ឬ មន្ទីរ ៨៧០) បានចេញបញ្ជាទៅ មាស មុត ឬ កងពលធំលេខ ១៦៥ នោះទេ[950]។

២៨២. **អ៊ុង រ៉ែន**៖ អ៊ុង រ៉ែន មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ គាត់គឺជាមេបញ្ជាការកងវរសេនាធំ នៅក្នុងកងពលធំលេខ ៨០១ ដែលត្រូវបានដំឡើងឋានៈមួយរយៈពេលខ្លី ជាមេបញ្ជាការរងកងពលធំ នៅក្នុងឆ្នាំ ១៩៧៧[951]។ គាត់បាននិយាយថា បានដឹងអំពីការណែនាំពីថ្នាក់លើ តាមរយៈសារឿន ដែលជាលេខាកងពលធំលេខ ៨០១ តែនៅក្នុងការប្រជុំជាមួយ សារឿន ប៉ុណ្ណោះ[952]។ ចម្លើយរបស់គាត់ គឺពាក់ព័ន្ធ តែជាមួយកងពលធំលេខ ៨០១ ប៉ុណ្ណោះ។

២៨៣. ស.ព.អ. លើកឡើងដោយមិនត្រឹមត្រូវ អំពីទូរលេខចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ មកពី សុន សេន ដែល ស.ព.អ. អះអាងថា រួមមាន "សេចក្តីណែនាំលម្អិតដែលរាប់បញ្ចូល ទាំងភាពចាំបាច់ដាច់

---

[944] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 ស-អ.៣, ស-អ.៩។

[945] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 អ.១០។

[946] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 អ.៩។

[947] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 អ.៥។

[948] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 អ.៦ ។ ជើងទំព័រ ៩៨៨ នៃដីកាសន្និដ្ឋានស្តាពរ។

[949] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 អ.៥។

[950] កថាខណ្ឌ ៣០១ នៃដីកាសន្និដ្ឋានស្តាពរ។

[951] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុង រ៉ែន ចុះថ្ងៃទី ៧ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D55/4 អ.៣-៤, អ.៨។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុង រ៉ែន ចុះថ្ងៃទី ៧ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D55/4 អ.៣៣-៣៩ (ដែលបានបង្ហាញថា បន្ទាប់ពីទៅពីភ្នំពេញ ដល់ស្រុកបាលលុង លោកមិនមានតួនាទីអ្វីឡើយ)។

[952] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៣ ឯកសារ D98/3.1.307 នៅម៉ោង 09.23.30-09.26.11។

ខាតក្នុងការកម្ទេចសត្រូវចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ”[953]។ ស.ព.អ. បានលុបចោលពាក្យ “ខុសច្បាប់” ពីក្នុងការពណ៌នារបស់គាត់ ដែលដូច្នេះហើយគឺជាការផ្លាស់ប្តូរខ្លឹមសារនៃការណែនាំនេះ។ សុន សេន បានសំដៅលើការកម្ទេចសត្រូវ ដែលចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ *ដោយខុសច្បាប់*[954]។ សុន សេន បានលើកឡើងអំពីគោលដៅស្របច្បាប់របស់កងទ័ពក្នុងការការពារជាតិ។ ជាឧទាហរណ៍ដើម្បីសម្រេចគោលដៅនេះ សុន សេន បានបញ្ជាកងកម្លាំងឱ្យទៅកោះក្រសារ ដើម្បីពិនិត្យមើលថាតើកងទ័ពខ្មាំង ពិតជាបានចល័តទៅទីនោះមែនឬយ៉ាងណា និង ពិនិត្យវិធានការដើម្បីឆ្លើយតប ហើយបានណែនាំថា ត្រូវរៀបចំផែនការទាក់ទងកោះយ៉ និង កោះកុង ប្រសិនបើខ្មាំងខិតចូលមកកាន់តែជិត[955]។

២៨៤. ស.ព.អ. ក៏ដកស្រង់ផងដែរ នូវរបាយការណ៍ជាច្រើនរបស់កងពលធំផ្សេងទៀត ដែលមិនមែនជាកងពលធំលេខ ១៦៥[956]។ របាយការណ៍ទាំងនេះបង្ហាញថា កងពលធំផ្សេងទៀតបានស្នើសុំការណែនាំពីមជ្ឈិម ដែលការនេះបង្ហាញឱ្យឃើញពីការត្រួតត្រាទាំងស្រុង ដែលមេដឹកនាំជាន់ខ្ពស់បក្សបានអនុវត្តទៅលើគ្រប់ចំណុចទាំងអស់របស់កងទ័ព[957]។

២៨៥. ស.ព.អ. អះអាងថា មាស មុត ត្រូវបានតម្រូវឱ្យមានទំនាក់ទំនងក្នុងការរាយការណ៍ផ្ទាល់ ជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. ហើយថា មាស មុត បានអនុវត្តបែបនេះ តាមរយៈការរាយការណ៍យ៉ាងទៀងទាត់ទៅឱ្យ សុន សេន និង មេដឹកនាំជាន់ខ្ពស់ផ្សេងទៀត[958]។ ស.ព.អ. ដកស្រង់ ម៉ើ វ៉ែត មាស វឿន លក្ខន្តិក: ប.ក.ក. សារទូរលេខ កំណត់ហេតុការប្រជុំអគ្គសេនាធិការ និង របាយ

---

[953] ជើងចំព័រ ៩៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[954] ទូរលេខ ចំណងជើងថា “ទូរលេខ ១០ ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៦” ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.2.2 EN 00233970 KH 00162492។

[955] ទូរលេខ ចំណងជើងថា “ទូរលេខ ១០ ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៦” ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.2.2 EN 00233970 KH 00162492។

[956] ជើងចំព័រ ៩៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[957] *សូមមើល* កថាខណ្ឌ ២១១ *ខាងលើ* ទាក់ទងនឹងការគ្រប់គ្រងរបស់បក្សលើ ក.ប.ក.។

[958] កថាខណ្ឌ ៦៩, ៧២, ៣០២ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ២៦៣-៧៧ *ខាងលើ* ទាក់ទងនឹងការចោទប្រកាន់ដែលពាក់ព័ន្ធរបស់ ស.ព.អ. នៅក្នុងកថាខណ្ឌ ៩១ នៃដីកាសន្និដ្ឋានស្តាពររបស់ខ្លួន។

ការណ៍នានា[959]។ ភស្តុតាងនេះយ៉ាងច្រើនបំផុតត្រឹមកំណត់ថា មានរចនាសម្ព័ន្ធរបាយការណ៍ចាំបាច់នៅក្នុង ប.ក.ក. និង ថា មាស មុត គឺជាថ្នាក់ក្រោមនៅក្នុងរចនាសម្ព័ន្ធនេះ។

២៨៦. **ម៉ើ រ៉ែត**៖ ម៉ើ រ៉ែត មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ គាត់នៅក្នុងកងប្រឆាំងនាវាមុជទឹក នៅកងវរសេនាធំលេខ ១៤០[960]។ បន្ទាប់ពីបានបង្ហាញនូវសារ អំពីកាណូតម៉ាស៊ីនរបស់វៀតណាម និង ថៃ[961] រួចមក ម៉ើ រ៉ែត បាននិយាយថា មាស មុត ត្រូវតែរាយការណ៍ទៅ សុន សេន ដើម្បីឱ្យ សុន សេន អាចបញ្ជាទៅ មាស មុត អំពីវិធានការសមស្របដែលត្រូវអនុវត្ត[962]។ ដោយសារតែទីតាំងឈរជើងរបស់ ម៉ើ រ៉ែត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនអាចបានដឹងអំពីលក្ខខណ្ឌតម្រូវនៃការរាយការណ៍របស់ មាស មុត ឡើយ។ ចម្លើយរបស់ ម៉ើ រ៉ែត បានបញ្ជាក់អះអាងអំពីមុខងារត្រឹមត្រូវរបស់កងទ័ព៖ ថ្នាក់ក្រោមរាយការណ៍អំពីបញ្ហាសន្តិសុខជាតិទៅថ្នាក់លើ ហើយថ្នាក់លើបញ្ជូនការណែនាំទៅថ្នាក់ក្រោមរបស់គាត់។ ការរាយការណ៍តាមឋានានុក្រមបែបនេះ គឺជាការងារធម្មតានៅក្នុងកងទ័ព ហើយតម្រូវទៅតាមក្របខណ្ឌច្បាប់របស់បក្ស[963]។

២៨៧. **មាស វឿន**៖ មាស វឿន មិនអាចជឿជាក់បានឡើយ[964]។ គាត់និយាយថា មាស មុត ត្រូវតែរាយការណ៍ទៅថ្នាក់លើរបស់គាត់[965]។ ទោះបីជានៅពេលនោះ គាត់មិនអាចបានដឹងអំពីលក្ខខណ្ឌតម្រូវនៃការរាយការណ៍របស់ មាស មុត ក្តី ក៏ដូចគ្នានឹង ម៉ើ រ៉ែត ដែរ មាស វឿន គ្រាន់តែបញ្ជាក់អះអាង អំពីមុខងារត្រឹមត្រូវរបស់កងទ័ពប៉ុណ្ណោះ។

---

[959] ជើងទំព័រ ២១២-១៣, ២១៩ នៃដីកាសន្និដ្ឋានស្តាពរ។

[960] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៣ ឯកសារ D54/15 EN 00942726 KH 00984849។

[961] សេចក្តីវាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨ ឯកសារ D1.3.34.64។

[962] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 ឆ.១៩-២០, ឆ.២២។ ជើងទំព័រ ៩៩២ នៃដីកាសន្និដ្ឋានស្តាពរ។

[963] *សូមមើល* កថាខណ្ឌ ១៧២ និង ២១៣ *ខាងលើ* ទាក់ទងនឹងរចនាសម្ព័ន្ធឋានានុក្រមរបស់ ប.ក.ក. ពាក់ព័ន្ធនឹងការរាយការណ៍នៅក្នុងអង្គភាពយោធា និង បក្ស។

[964] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[965] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.១៣។ ជើងទំព័រ ៩៩២ នៃដីកាសន្និដ្ឋានស្តាពរ។

២៨៨. មាស មុត និង គណៈកម្មាធិការកងពលធំលេខ ១៦៥ បានរាយការណ៍ និង ទទួលបញ្ជាពី សុន សេន និង គណៈអនុត្រៃយ៍/គណៈយោធា ព្រោះកងពលធំលេខ ១៦៥ ស្ថិតក្រោមបញ្ជារបស់អគ្គសេនាធិការ និង គណៈអចិន្ត្រៃយ៍[966]។ ការរាយការណ៍របស់ មាស មុត គឺមិនដូចគ្នានឹងការមានសិទ្ធិអំណាចធ្វើការសម្រេចទៅលើគោលនយោបាយឡើយ។ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងរបាយការណ៍កិច្ចប្រជុំរបស់អគ្គសេនាធិការ ដែលមាននៅសល់នោះ ការចេញសេចក្តីណែនាំគឺធ្វើឡើងតែម្ខាងគឺពី សុន សេន ទៅកងពលធំ និង កងវរសេនាធំឯករាជ្យ។ មិនមានការផ្តាស់ប្តូរមតិ ឬ ការពិភាក្សាដោយសេរីនោះឡើយ។ នៅក្នុងរឿងក្តី ០០១ បណ្ឌិត Etcheson បានផ្តល់សក្ខីកម្មថា ការណែនាំរបស់ សុន សេន នៅក្នុងកិច្ចប្រជុំទាំងនេះគឺ "ត្រូវបានគេដឹងនៅក្នុងបក្សថា ជាការផ្សព្វផ្សាយមាគ៌ាបក្ស គឺការធ្វើឱ្យប្រាកដថាថ្នាក់ក្រោមរបស់គាត់ យល់ដឹងអំពីគោលនយោបាយរបស់បក្ស និង តួនាទីរបស់ពួកគេ នៅក្នុងការអនុវត្តគោលនយោបាយនោះ"[967]។ ការណែនាំទាំងនេះចាំបាច់ត្រូវតែគោរពតាម។ ដូចដែល ហ៊ឹង វ៉ែត បានកត់សម្គាល់ មាស មុត ត្រូវតែស្នើសុំការបំភ្លឺ ឬ មតិណែនាំពីថ្នាក់លើរបស់គាត់ មុនពេលដែលគាត់អាចធ្វើសកម្មភាពបាន[968]។ ដំណើរការនេះគឺ "ដូចគ្នានឹងច្បាប់កងទ័ពសម័យទំនើបដែរ គឺត្រូវតែរាយការណ៍ទៅអគ្គបញ្ជាការ បើសិនមានអ្វីកើតឡើង"[969]។

២៨៩. ការដែលលើកឡើងថា មាស មុត មានការទទួលខុសត្រូវ និង សិទ្ធិអំណាចផ្តាច់មុខ ក្នុងការរាយការណ៍ទៅមេដឹកនាំជាន់ខ្ពស់ ប.ក.ក.[970] គឺ ស.ព.អ. មិនបានពិចារណាពីកងពលធំលេខ ១៦៥ និង គណៈកម្មាធិការតំបន់ស្វយ័តកំពង់សោមឡើយ[971]។ គណៈកម្មាធិការទាំងនេះមានសិទ្ធិអំណាច ឬ ការទទួលខុសត្រូវរួមគ្នាលើកងពលធំលេខ ១៦៥ និង តំបន់ស្វយ័តកំពង់សោម តែត្រូវតែស្ថិត

---

[966] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364071 KH 00357492៖ "ទ័ពមជ្ឈិមគ្រប់កងពល ត្រូវរាយកាណ៍មកសេនាធិការទាំងអស់"។ *សូមមើល* កថាខណ្ឌ ២១១ និង ២១៣ *ខាងលើ* ដែលពិភាក្សាអំពីការគ្រប់គ្រងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការលើកងពលមជ្ឈិម។

[967] *រឿងក្តី កាំង រ៉ុកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.7 នៅម៉ោង 14.09.23-14.12.43។

[968] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង វ៉ែត ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/288 ន.៦០-៦១។

[969] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង វ៉ែត ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/288 ន.៦២។

[970] កថាខណ្ឌ ៦៩, ៧២ នៃដីកាសន្និដ្ឋានស្តាពរ (ក្នុងកថាខណ្ឌ ៧២ ស.ព.អ. ពោលប្រាស្រ័យលើលក្ខណៈសម្បូហភាពនៃការប្រជុំតំបន់ស្វយ័តកំពង់សោម ប៉ុន្តែយោងតែទៅលើ មាស មុត រាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ប៉ុណ្ណោះ)។

[971] *សូមមើល* កថាខណ្ឌ ២១២ *ខាងលើ* ទាក់ទងនឹងកងពល ១៦៥ និង គណៈកម្មាធិការតំបន់ស្វយ័តកំពង់សោម។

ក្រោមបញ្ជា និងការណែនាំ ដែលចេញដោយថ្នាក់លើផ្នាល់របស់ពួកគេ នៅក្នុងគណៈអចិន្ត្រៃយ៍ និង អគ្គសេនាធិការ។ ទាំង មាស មុត ទាំងសមាជិកផ្សេងទៀតរបស់គណៈកម្មាធិការ មិនមានអំណាចក្នុងការបង្កើត និង អនុវត្តគោលនយោបាយបក្សដោយផ្នាល់ខ្លួន មិនមានអំណាចក្នុងការបដិសេធមិនអនុវត្តតាមការណែនាំ ឬបញ្ជាដែលចេញដោយគណៈអចិន្ត្រៃយ៍ ឬ អគ្គសេនាធិការ ឬ អនុវត្តដោយឯករាជ្យនូវភារកិច្ចណាមួយ ដែលគណៈអចិន្ត្រៃយ៍ និង អគ្គសេនាធិការ បានចាត់តាំងឱ្យពួកគេ។

២៩០. បើទោះបីជា មាស មុត មានសិទ្ធិអំណាចទៅលើបញ្ជាទាំងអស់ ដែលស្ថិតក្រោមតំបន់ប្រតិបត្តិការរបស់កងពលធំលេខ ១៦៤ ដូចជា កោះ ការដ្ឋាន មន្ទីរសន្តិសុខ វគ្គរៀនសូត្រនយោបាយ ទទួលរបាយការណ៍ និង ចេញសេចក្តីណែនាំទៅថ្នាក់ក្រោម ធ្វើការរាយការណ៍ទៅថ្នាក់លើផ្នាល់របស់គាត់ក្តី ក៏សិទ្ធិអំណាចបែបនេះមិនអាចធ្វើឱ្យគាត់ ក្លាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្ត នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។ មាស មុត បានរស់នៅ និង ធ្វើការងារ នៅក្នុងតំបន់មួយនៃប្រទេស ហើយគាត់បានត្រឹមស្គាល់តំបន់ ៥០៥ រយៈពេលពីរខែប៉ុណ្ណោះ[972]។ គាត់មិនមានសិទ្ធិអំណាច ឬ ការគ្រប់គ្រងនៅទូទាំងប្រទេសឡើយ។

ខ. ការចូលរួមក្នុងកិច្ចប្រជុំអគ្គសេនាធិការ និង សន្និបាតបក្ស មិនមានន័យថា មាស មុត អាចចូលរួមចំណែកដល់គោលនយោបាយរបស់ ប.ក.ក.

២៩១. ប្រភពដែល ស.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានធ្វើដំណើរជាញឹកញាប់ទៅភ្នំពេញ ហើយបានចូលរួមការប្រជុំអគ្គសេនាធិការ និង សន្និបាត ដែលក្នុងនោះមានការពិភាក្សាអំពីគោលនយោបាយបោសសម្អាត ឬ ការជាប់ពាក់ព័ន្ធរបស់គាត់ ដែលសកម្មភាពទាំងអស់នេះធ្វើឱ្យ មាស មុត ក្លាយជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ឡើយ[973]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បានរបស់ ស៊ឹម នីលៀត ឡន លុន សេង មាស វឿន ឡុញ ដុស ហ៊ីង រ៉េត ព្រមទាំងឯកសារនានា ដែលរួមមានកំណត់ហេតុកិច្ចប្រជុំអគ្គសេនាធិការ និង ការសម្ភាសន៍ជាមួយ មាស មុត ដោយស្តាប់ឆ្គងមិនមែន អ.វ.ត.ក.[974]។

---

[972] *សូមមើល* IV.គ.៨ *ខាងក្រោម* ទាក់ទងនឹងការអះអាងរបស់ ស.ព.អ.ពីតំបន់ ៥០៥។

[973] កថាខណ្ឌ ៥៤-៥៥, ៩៥, ២៩៧-៩៨, ១០៩០, ១០៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

[974] ជើងទំព័រ ១៦៣-៦៧, ២៨៥, ៩៦៨-៧៤ នៃដីកាសន្និដ្ឋានស្តាពរ។

ស.ព.អ. និយាយបំផ្លើស។ ការចូលរួមក្នុងការប្រជុំអគ្គសេនាធិការ ឬ សន្និបាតបក្ស មិនមែនស្មើនឹងការមានសិទ្ធិអំណាច ក្នុងការសម្រេចលើគោលនយោបាយ ឬ ទទួលខុសត្រូវចំពោះហេតុការណ៍នានានៅទូទាំងប្រទេសឡើយ។

២៩២. **ស៊ឹម នី**៖ ស៊ឹម នី មិនអាចជឿជាក់បានឡើយ[975]។ គាត់ក៏មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ដែរ។ គាត់បាននិយាយថាថ្នាក់លើរបស់គាត់ ដែលមិនមែនជា មាស មុត នោះ បានចូលរួមក្នុងកិច្ចប្រជុំរៀងរាល់ខែ ហើយគាត់សន្មតថា មាស មុត ក៏ចូលរួមក្នុងកិច្ចប្រជុំទាំងនោះដែរ[976]។

២៩៣. **លៀត ឡូន**៖ លៀត ឡូន មិនអាចជឿជាក់បានឡើយ[977]។ គាត់បាននិយាយថា មាស មុត ត្រូវធ្វើដំណើរទៅមកភ្នំពេញ ដើម្បីជួបជាមួយ សុន សេន[978]។ គាត់បានទាយស្មានថា មាស មុត បានទៅភ្នំពេញដើម្បីរាយការណ៍ជូនមជ្ឈិម[979]។ បន្ទាប់មក គាត់បានបំពេញបង្គ្រប់ចម្លើយរបស់គាត់ អំពីការធ្វើដំណើររបស់ មាស មុត ទៅភ្នំពេញ ដោយការនិយាយថា គាត់មិនបានដឹងថា មាស មុត ធ្វើដំណើរទៅមកភ្នំពេញនេះញឹកញាប់បែបណាទេ[980]។ ស.ព.អ. មិនបានគិតដល់ការបំពេញចម្លើយនេះទេ[981]។ លៀត ឡូន មិនបាននិយាយថា មាស មុត បានជួបមេដឹកនាំ ប.ក.ក. នៅកំពង់សោមឡើយ[982]។ លៀត ឡូន បាននិយាយថា បន្ទាប់ពីគាត់បានចូលរួម ក្នុងសន្និបាតនៅស្តាតអូឡាំពិច ដែលក្នុងសន្និបាតនោះ ប៉ុល ពត បានថ្លែងអំពីការវាយប្រយុទ្ធ នៅតាមព្រំដែនវៀតណាមនោះ គាត់បានធ្វើដំណើរទៅកំពង់សោម ហើយបានជួបជាមួយ មាស មុត ដែលថ្លែងប្រហែលគ្នានឹង

---

[975] *សូមមើល* កថាខណ្ឌ ២៤៥ *ខាងលើ* និង កថាខណ្ឌ ៤០៦-០៨ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[976] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/37 ស-អ.៣0-៣១។ ជើងទំព័រ ១៦៣, ១៦៧, ២៨៥, ៩៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[977] *សូមមើល* កថាខណ្ឌ ២០១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[978] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 ឆ.៣។ ជើងទំព័រ ១៦៧, ៩៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[979] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ឆ.១៥២-៥៣។

[980] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 ឆ.៣។

[981] ជើងទំព័រ ៩៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[982] ជើងទំព័រ ៩៧១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 ឆ.៣។

សុន្ទរកថារបស់ ប៉ុល ពត[983]។ លៀត ឡែនមិនបាននិយាយថា មេដឹកនាំ ប.ក.ក. មានវត្តមាននៅក្នុងកិច្ចប្រជុំនោះ ឬ ថា មាស មុត បានជួបជាមួយមេដឹកនាំណាម្នាក់ឡើយ។

២៩៤. **លុន សេង**៖ លុន សេង មិនអាចជឿជាក់បានឡើយ[984]។ គាត់ក៏មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ដែរ។ គាត់បាននិយាយថា អគ្គសេនាធិការបានប្រមូលមតិរបស់មេបញ្ជាការកងពលធំនៅពេលដែលត្រូវការធ្វើផែនការការងារ ហើយថា មេបញ្ជាការកងពលធំ គឺជាសមាជិករបស់គណៈកម្មាធិការអគ្គសេនាធិការ[985]។ គាត់មិនបាននិយាយថា មាស មុត បានចូលរួមក្នុងកិច្ចប្រជុំយោធាប្រចាំខែ នៅអគ្គសេនាធិការឡើយ។

២៩៥. **មាស វឿន**៖ មាស វឿន មិនអាចជឿជាក់បានឡើយ[986]។ គាត់បានអះអាងថា កងពលធំលេខ ១៦៥ គឺស្ថិតក្រោមមជ្ឈិម និង អគ្គសេនាធិការផ្ទាល់[987]។ មាស វឿន មិនបាននិយាយថា មាស មុត បានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ នៅអគ្គសេនាធិការឡើយ។

២៩៦. **ឡុញ ដុស**៖ ភស្តុតាងរបស់ ឡុញ ដុស គឺមានកម្រិតកំណត់ដោយពេលវេលា[988]។ គាត់បាននិយាយថា កិច្ចប្រជុំអគ្គសេនាធិការ ត្រូវបានធ្វើឡើងរៀងរាល់សប្តាហ៍ ឬ រាល់ខែ "តែនៅពេលមានការចាំបាច់ប៉ុណ្ណោះ"[989]។ ស.ព.អ. មិនបានពិចារណាដល់ចម្លើយផ្នែកខាងក្រោយនេះឡើយ[990]។ ឡុញ ដុស មិនបាននិយាយថា ការប្រជុំតែងតែធ្វើឡើងជារៀងរាល់ខែនោះទេ។

២៩៧. **ហ៊ឹង អ៊ែត**៖ ហ៊ឹង អ៊ែត មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ គាត់បាននិយាយថា គាត់បានចូលរួមក្នុងសន្និបាតនៅភ្នំពេញ ដែលក្នុងពេលនោះ មាស មុត បានរាយការណ៍អំពីទូក

---

[983] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡែន ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 ឆ.៣។

[984] *សូមមើល* កថាខណ្ឌ ១៩៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមស្តីពីសាក្សីរូបនេះ។

[985] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/110 ឆ.៨។ ជើងទំព័រ ៩៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[986] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[987] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.៤។ ជើងទំព័រ ៩៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[988] *សូមមើល* កថាខណ្ឌ ១៩៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[989] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.845 ឆ.១៤។

[990] ជើងទំព័រ ៩៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

វៀតណាមបានចូលក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ[991]។ ស.ព.អ. មិនបានលើកឡើងពីផ្នែកនៅក្នុងចម្លើយរបស់ ហ៊ឹង រ៉ែត ដែលគាត់បាននិយាយថា សុន សេន បានបង្គាប់ដល់អ្នកចូលរួមថា ប្រសិនបើជនជាតិវៀតណាមគឺជាជនភៀសខ្លួន ធ្វើដំណើរទៅប្រទេសថៃ គឺមិនត្រូវចាប់ខ្លួនពួកគេ នោះឡើយ[992]។ ហ៊ឹង រ៉ែត ក៏បាននិយាយផងដែរថា ប្រសិនបើថ្នាក់លើ (សុន សេន និង អគ្គសេនាធិការ) ចេញបញ្ជាហើយ ថ្នាក់ក្រោម (កងពលធំលេខ ១៦៤) ត្រូវតែគោរព[993]។ ចម្លើយរបស់ ហ៊ឹង រ៉ែត បង្ហាញថា វត្តមាននៅឯកិច្ចប្រជុំអគ្គសេនាធិការ មិនមានន័យស្មើនឹងការចូលរួមនៅក្នុង ឬ ការរៀបចំគោលនយោបាយរបស់មេដឹកនាំជាន់ខ្ពស់ ប.ក.ក. ឡើយ។

២៩៨. សាក្សីដែលនៅសល់ពីរនាក់ទៀត ដែល ស.ព.អ. ដកស្រង់គឺ សាត ចក់ និង ព្រំ សារ៉ាត ត្រឹមតែអះអាងថា មាស មុត ត្រូវបានបញ្ជូនទៅភ្នំពេញ នៅក្នុងឆ្នាំ ១៩៧៨ គឺមិនមែនថា មាស មុត បានធ្វើដំណើរទៅទីនោះជាញឹកញាប់ ដើម្បីចូលរួមប្រជុំឡើយ[994]។ ពួកគាត់ទាំងពីរនាក់មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។

២៩៩. ស.ព.អ. ក៏ដកស្រង់ផងដែរ នូវរបាយការណ៍កិច្ចប្រជុំអគ្គសេនាធិការ ដែលចង្អុលបង្ហាញពីវត្តមានរបស់ មាស មុត និង អះអាងថា ការចូលរួមរបស់ មាស មុត នៅក្នុងកិច្ចប្រជុំអគ្គសេនាធិការ កាន់តែកើនឡើងញឹកញាប់ទៅៗ នៅបណ្តាឆ្នាំចុងក្រោយនៃរបប[995]។ ខណៈដែលកំណត់ហេតុកិច្ចប្រជុំ

---

[991] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៧៥។ ជើងទំព័រ ៩៧៥ នៃដីកាសន្និដ្ឋានស្តាពរ។

[992] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៧៥។

[993] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៧៥។

[994] ជើងទំព័រ ១៦៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.១២៦-២៧។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រំ សារ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974225-00974226 KH 00926401-00926403។ *សូមមើល* កថាខណ្ឌ ១៤០ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាភស្តុតាង។

[995] ជើងទំព័រ ៩៦៨ និង ១៦៦ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ" ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.22។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខា និង វរសេនាធំឯកវាជ្យ" ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.20។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ" ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.2 និង កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 (ដូចគ្នានឹងឯកសារ

ទាំងនេះ អាចបង្ហាញពីវត្តមានរបស់ មាស មុត នៅក្នុងកិច្ចប្រជុំ កំណត់ហេតុទាំងនេះមិនបានកំណត់ ពីភាពញឹកញាប់នៃការចូលរួមនោះឡើយ។ កំណត់ហេតុមិនបានចង្អុលបង្ហាញថា ការប្រជុំធ្វើឡើងរៀងរាល់ខែ ទៅតាមកាលបរិច្ឆេទដែលបានកំណត់ទុកនោះទេ។ កំណត់ហេតុគ្រាន់តែថា កិច្ចប្រជុំទាំងនេះធ្វើឡើងនៅក្នុងពេលវេលាជាក់លាក់។ ឯកសារទាំងនេះបង្ហាញថា ការប្រជុំចំនួនប្រាំមួយត្រូវបានធ្វើឡើង ក្នុងរយៈពេលជាង ១០ ខែ ដោយចាប់ផ្តើមឡើងប្រហែលមួយឆ្នាំ ក្រោយពេលចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនេះមិនមែនជាភស្តុតាងដែលបង្ហាញថា ការប្រជុំ "កើនឡើងញឹកញាប់" នៅចុងរបបនោះទេ[996]។ ស.ព.អ. ក៏បានដកស្រង់ផងដែរ នូវកំណត់ហេតុកិច្ចប្រជុំមួយដុំ ដែលបង្ហាញថា នៅថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ គណៈកម្មាធិការកងពលធំលេខ ១៦៥ បានជួបប្រជុំជាមួយ និង ទទួលការណែនាំលើបញ្ហាកងទ័ពពី ប៉ុល ពត និង សមាជិកគណៈយោធាផ្សេងទៀត[997]។ ឯកសារនេះមិនបានកំណត់ថា មាស មុត បានប្រជុំជារៀងរាល់ខែ ឬ ជាញឹកញាប់ ជាមួយអគ្គសេនាធិការ ឬ គណៈយោធាឡើយ។

៣00. ស.ព.អ. ដកស្រង់ការសម្ភាសន៍មួយរបស់សារព័ត៌មាន *Phnom Penh Post* ជាមួយ មាស មុត ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានចូលរួមប្រជុំអគ្គសេនាធិការជារៀងរាល់ខែ[998]។ មិនមានខ្សែអាត់សំឡេងនៃការសម្ភាសន៍នេះ នៅក្នុងសំណុំរឿងឡើយ។ ការសម្ភាសន៍នេះធ្វើឡើងដោយស្ថាប័នខាងក្រៅ ដោយមិនមានការត្រួតពិនិត្យដោយតុលាការ ហើយធ្វើឡើងក្នុង

D114/27.1.5)។ នៅជើងទំព័រ ៩៦៨ ស.ព.អ. ក៏ដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង កស្តុភារបស់កងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D234/2.1.18។ នៅជើងទំព័រ ១៦៦ ស.ព.អ. ក៏បានដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26។

[996] កថាខណ្ឌ ៥៤ ជើងទំព័រ ១៦៣ នៃដីកាសន្និដ្ឋានស្តាពរ។

[997] ជើងទំព័រ ១៦៦, ៩៦៨-៦៩, ៩៧១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំការងារយោធានៅកំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3។

[998] ជើងទំព័រ ៩៧0 នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ Christine Chaumeau និង Bou Saroeun *ពួកយើងនៅក្នុងទ្រុងដូចថ្ងៃនេះ* (We were in a cage like today) សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ២0 ខែកក្កដា ឆ្នាំ ២00១ - ថ្ងៃទី ២ ខែសីហា ឆ្នាំ ២00១ ឯកសារ D1.3.33.16 (មាស មុត និយាយថាគាត់បានពិភាក្សាពីការបង្កបង្កើនផលក្នុងការប្រជុំជាមួយ សុន សេន)។ ឯកសារនេះដូចគ្នានឹងឯកសារ D22.2.180។

គោលបំណងផ្សេង ក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌ។ ដូច្នេះ ការសម្អាសន៍នេះមានតម្លៃជាភស្តុតាងតិចតួចប៉ុណ្ណោះ[999]។

៣០១. ស.ព.អ. អះអាងបន្ថែមថា មាស មុត បានជួបមេដឹកនាំ ប.ក.ក. នៅកំពង់សោម ដោយគាត់បានដកស្រង់កំណត់ហេតុកិច្ចប្រជុំពីកិច្ចប្រជុំចំនួនពីរនៅក្នុងឆ្នាំ ១៩៧៦[1000]។ របាយការណ៍នៃកិច្ចប្រជុំទាំងនេះ មិនបានគាំទ្រដល់ការអះអាងនេះឡើយ។ មិនមានការបង្ហាញថា មាស មុត បានចូលរួមក្នុងកិច្ចប្រជុំនៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឡើយ[1001]។ ខណៈដែលកិច្ចប្រជុំទាំងពីរ អាចពិភាក្សាអំពីបញ្ហាកងទ័ពជើងទឹកនៅកំពង់សោម ទីកន្លែងនៃកិច្ចប្រជុំនេះមិនត្រូវបានបង្ហាញឡើយ នៅក្នុងកំណត់ហេតុទាំងនេះ។

៣០២. ស.ព.អ. អះអាងថា ក្នុងតួនាទីរបស់គាត់នៅអគ្គសេនាធិការ មាស មុត បានជំរុញមេបញ្ជាការកងពលធំ និង កងវរសេនាធំផ្សេងទៀត ឱ្យបោសសម្អាតខ្មាំងនៅក្នុងជួររបស់ពួកគេ[1002]។ មិនមានភស្តុតាងបង្ហាញថា មាស មុត បានជំរុញបែបនេះ នៅក្នុងការប្រជុំអគ្គសេនាធិការណាមួយ ដែលគាត់បានចូលរួមនោះឡើយ។ កំណត់ហេតុកិច្ចប្រជុំដែលនៅសេសសល់ មិនបានបង្ហាញថា ខ្មាំង ឬ គោលនយោបាយរបស់ ប.ក.ក. ចំពោះខ្មាំង គឺជាប្រធានបទសំខាន់នៃកិច្ចប្រជុំទាំងនេះ ដូចដែល ស.ព.អ. អះអាងនោះឡើយ[1003]។ ស្ថានភាពខ្មាំង និង គោលនយោបាយពាក់ព័ន្ធនានា គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទជាច្រើន ដែលត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនេះ។ ប្រធានបទផ្សេងទៀតមានដូចជា ការការពារជាតិ ការផលិតស្បៀង និង សុខភាព[1004]។ អ្នកចូលរួម

---

[999] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* សម្រាប់ការលើកឡើងបន្ថែមពីប្រភេទនៃភស្តុតាងនេះ។

[1000] កថាខណ្ឌ ២៩៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំការងារយោធានៅកំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4។

[1001] *សូមមើល* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4។

[1002] កថាខណ្ឌ ១០៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1003] កថាខណ្ឌ ៥៤ នៃដីកាសន្និដ្ឋានស្តាពរ។ ឯកសារ D1.3.27.20 គ្រាន់តែជាបណ្តុំនៃកំណត់ហេតុប្រជុំ ដែល ស.ព.អ. ដកស្រង់ដែលក្នុងនោះវាហាក់ដូចជាថា ការប្រជុំលើកឡើងតែអំពីបញ្ហាការពារជាតិ និង ការពារសត្រូវប៉ុណ្ណោះ។ *សូមមើលផងដែរ* កថាខណ្ឌ ៩៥-៩៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1004] *សូមមើលឧទា.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុតាងរបស់កងពលនិង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា

ម្នាក់ៗបានរាយការណ៍ត្រឹមតែស្ថានភាពនៅក្នុងកងរបស់ពួកគេផ្ទាល់ ហើយបានទទួលយកការណែនាំទូទៅ អំពីអ្វីដែលត្រូវអនុវត្តនៅក្នុងកងរបស់ពួកគេផ្ទាល់[1005]។ អ្នកចូលរួមមិនត្រូវបានណែនាំ ឱ្យធ្វើសកម្មភាពទាក់ទងកងរបស់សមាជិកផ្សេងទៀតឡើយ ហើយពួកគេក៏មិនបានផ្តួចផ្តើមលើកសំណើអំពីភារកិច្ច ឬ ការងារសម្រាប់កងពលធំផ្សេងទៀតដែរ។ ការផ្តួចផ្តើមបែបនេះ គឺមិនមាននរណាអាចគិតដល់ឡើយនៅពេលនោះ[1006]។

៣០៣. នៅក្នុងកិច្ចប្រជុំថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ មាស មុត ត្រូវបានកត់ត្រាពីការនិយាយឡើងវិញ តាមតួនាទី នូវមាគ៌ាបក្សទាក់ទងនឹងសមាសធាតុមិនល្អ ដែលបានលាក់ខ្លួន និង បង្កប់ខ្លួននៅក្នុងជួរ ហើយគាត់និយាយថា កត្តាសំខាន់បំផុត គឺក្តាប់សតិអារម្មណ៍ ហើយថា ត្រូវរៀបចំវិធានការណ៍ក្តាប់សភាពការណ៍ជាមុន ធ្វើម៉េចកុំឱ្យបាត់ម្ចាស់ការ និង កុំឱ្យខ្មាំងវាពង្រីងពង្រីកខ្លួនបានឱ្យសោះ[1007]។ ស.ព.អ. ដកស្រង់ការប្រជុំនេះធ្វើជាភស្តុតាងបង្ហាញអំពីការដឹងឮរបស់ មាស មុត ទាក់ទងនឹងគោលនយោបាយរបស់បក្សចំពោះខ្មាំង និង ការចូលរួមដោយចេតនា និង ដឹងច្បាស់ នៅក្នុងការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា[1008]។ ស.ព.អ. មិនបានគិតអំពីបរិបទដែលការប្រជុំអគ្គសេនាធិការនោះ ត្រូវបានរៀបចំឡើងនោះឡើយ។

"កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ" ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.22។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភារកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.23។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខា កងពល និង វរសេនាធំឯករាជ្យ ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំការងារយោធានៅកំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3 (ការប្រជុំនេះមានសមាជិកគណៈកម្មាធិការយោធា និង សុន សេន មិនមែន សុន សេន តែម្នាក់ឯងនោះទេ)។

[1005] *សូមមើលខាង.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភារកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.23។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18។

[1006] កថាខណ្ឌ ៤០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[1007] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.20 EN 00940350-00940351 KH 00052411-00052412។

[1008] កថាខណ្ឌ ៩២, ៩៩-១០០, ៥៤១, ៥៥២ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ៥០៧-១៣ *ខាងក្រោម* ដែលពិភាក្សាពីការអះអាងនៅក្នុងកថាខណ្ឌ ៥៤១ និង ៥៥២ នៃដីកាសន្និដ្ឋានស្តាពរ។

៣០៤. កំណត់ហេតុកិច្ចប្រជុំទាំងនេះ គឺជាភស្តុតាងស្តីពីនីតិវិធីប្រតិបត្តិការជាស្តង់ដាររបស់មជ្ឈិមបក្ស ទាក់ទងនឹងការផ្សព្វផ្សាយគោលនយោបាយ និង សេចក្តីសម្រេច។ សុន សេន បានណែនាំដល់ថ្នាក់ក្រោមរបស់គាត់ អំពីគោលនយោបាយ និង មាគ៌ាបក្ស[1009]។ ថ្នាក់ក្រោមរបស់ សុន សេន ឯកភាពតាមដោយគោរព ហើយនិយាយតាមឡើងវិញនូវមាគ៌ាបក្ស ដោយមានការកោតសរសើរជាចាំបាច់។ ដូចដែល ស.ច.ស. បានកត់សម្គាល់ នៅក្នុងរឿងក្តី ០០៤/១ ប្រព័ន្ធរបស់របបកម្ពុជាប្រជាធិបតេយ្យ “ដែលមានវិវឌ្ឍន៍ទាំងផ្នែកខាងក្រៅ ក៏ដូចជាផ្នែកខាងក្នុង ដោយមានការគ្រប់គ្រងដោយការភ័យខ្លាច និង ភាពរន្ធត់ តាមរយៈការប្រើប្រាស់ដោយចេតនានូវអំពើហឹង្សា និង ភាពសាហាវយង់ឃ្នង ជាទ្រង់ទ្រាយធំ”[1010]។ ខ្សែចង្វាក់បញ្ជា និង គោលការណ៍រក្សាការសម្ងាត់របស់បក្ស មិនបានអនុញ្ញាត ជំរុញ ឬ សម្របសម្រួលដល់ “ការផ្តាស់ប្តូរព័ត៌មានយុទ្ធសាស្ត្រ និង ប្រតិបត្តិ តាមខ្សែទទឹងដោយសេរី” របស់អ្នកដែលស្ថិតក្រោម អ្នកដឹកនាំថ្នាក់លើឡើយ[1011]។ សេចក្តីសម្រេចរបស់មេដឹកនាំជាន់ខ្ពស់ ប.ក.ក. ត្រូវតែគោរពតាម “ដោយផលវិបាកក្នុងលក្ខណៈបុគ្គល”[1012]។ មាស មុត បាននិយាយឡើងវិញនូវមាគ៌ាបក្ស ពីព្រោះបើគាត់មិនអនុវត្តតាមទេ គាត់នឹងត្រូវបានគេលាបពណ៌ថាប្រឆាំងបដិវត្តន៍[1013]។ ដូចដែល សួង ស៊ីគឿន អតីតកម្មាភិបាលនៅក្រសួងការបរទេស[1014] បានផ្តល់សក្ខីកម្ម “យើងទុកបក្សហ្នឹងជា ដូចខ្ញុំបានថាគឺថាជាអាទិទេព តែបក្សថាម៉េចគឺអ៊ីចឹងហើយបាទ។ បក្សឱ្យធ្វើអីគឺយើងធ្វើតាម បក្សមានទស្សនយ៉ាងម៉េច ក៏យើងយល់ព្រម យើងមានទស្សនដូចទស្សនរបស់បក្សដែរ”[1015]។ ការមិនយល់ស្រប ឬបង្ហាញក្តីបារម្ភ អំពីគោលនយោបាយរបស់បក្ស គឺមិនអាចធ្វើទៅរួចនោះឡើយ។

[1009] *សូមមើល* កថាខណ្ឌ ២៨៨ *ខាងលើ* ដែលដកស្រង់បណ្ឌិត Etcheson ទាក់ទងនឹងការចេញផ្សាយរបស់ សុន សេន អំពីខ្សែបក្សនៅក្នុងការប្រជុំសេនាធិការ។

[1010] កថាខណ្ឌ ៣២៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[1011] កថាខណ្ឌ ៤១ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[1012] កថាខណ្ឌ ៤០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[1013] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D4.1.520 EN 00346160 KH 00340575-00340576។ *សូមមើលផងដែរ* កថាខណ្ឌ ៤០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[1014] *សូមមើល* កថាខណ្ឌ ៥៩០ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1015] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១២ ឯកសារ D98/3.1.198 នៅម៉ោង 09.14.37-09.17.53។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១២ ឯកសារ

៣០៥. ស.ព.អ. ដកស្រង់កំណត់ហេតុកិច្ចប្រជុំអគ្គសេនាធិការចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ១៩៧៦ និង កិច្ចប្រជុំថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានរាយការណ៍អំពីការស្វែងរកខ្មាំងផ្ទៃក្នុង នៅក្នុងកងពលធំលេខ ១៦៥[1016]។ នៅក្នុងកិច្ចប្រជុំថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ១៩៧៦ មាស មុត បានរាយការណ៍ពីករណីជនជាតិថៃ លួចចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យដោយខុសច្បាប់ កងទ័ពជើងទឹកវៀតណាមបាញ់ប្រហារមកលើកងទ័ពជើងទឹកនៃកងទ័ពបដិវត្តន៍កម្ពុជា នៅពេលដែលពួកគេខិតចូលមកដល់ខ្សែបន្ទាត់ព្រំដែន និង ហេតុការណ៍លួចនៅកងកេង[1017]។ មាស មុត បានរាយការណ៍អំពីបញ្ហាសន្តិសុខជាតិ និង អំពើឧក្រិដ្ឋនៅកងកេង។ មាស មុត មិនបានរាយការណ៍អំពីការស្វែងរកខ្មាំងផ្ទៃក្នុងណាមួយឡើយ។ នៅក្នុងកិច្ចប្រជុំថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ "សមមិត្ត ម៉ូត" បានរាយការណ៍អំពីកងអនុសេនាតូចផ្នែកឃ្លាំង[1018]។ មិនមានភាពច្បាស់លាស់ដែលថាមនុស្សនេះគឺជា មាស មុត នោះទេ។ ជាភាសាខ្មែរឈ្មោះ "ម៉ូត" អាចមិនមែន "មុត" ទេ[1019]។

៣០៦. ស.ព.អ. អះអាងថា មាស មុត បានចូលរួមក្នុងសន្និបាតធំមួយ នៅស្ពាតអូឡាំពិក ដែលនៅក្នុងនោះមានវត្តមានមេដឹកនាំជាន់ខ្ពស់ ប.ក.ក. ហើយមានការពិភាក្សាអំពីការបោសសម្អាតកម្មាភិបាល

D98/3.1.243 នៅម៉ោង 11.53.35-11.56.27៖ "លោក អៀង សារី មិនបានប្រាប់ខ្ញុំថាជាសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទេ។ ហើយខ្ញុំថាដូចថាមិនចាំច្បាស់ទេ គឺគ្រាន់ថាអានេះជា ដែលគាត់និយាយនោះ គឺជាសេចក្តីសម្រេចរួមរបស់បក្សតែម្តង។ ត្រង់ថា បក្សរួមជាអ្នកណានោះ ខ្ញុំក៏មិនបានដឹងដែរ ប៉ុន្តែគ្រាន់តែតាមទម្លាប់ តែសេចក្តីសម្រេចរបស់ ប៉ុល ពត ខ្លួនឯងផ្ទាល់ខ្លួនលោកតែម្នាក់ឯង *ក៏ជាសេចក្តីសម្រេចរបស់បក្សដែរបាទ។ ហើយអ្នកឯទៀត ដែលសមាជិកឯទៀត ក៏ឯកភាពចំពោះសេចក្តីសម្រេចនេះដែរបាទ*"។ (ការគូសបញ្ជាក់បន្ថែម)

[1016] កថាខណ្ឌ ៩៨ ជើងទំព័រ ២៩០-៩៣ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195341 KH 00052390-00052391 (ស.ព.អ. ដកស្រង់ឯកសារ D4.1.655 EN 00143159 ក្នុងជើងទំព័រ ២៩០ នៃដីកាសន្និដ្ឋានស្តាពររបស់ខ្លួន។ ឯកសារ D4.1.655 គឺជាកម្រងឯកសារមួយដែលបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ ក.ស.ព.។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯកភាជ្យ" ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26 EN 00933835 KH 00052305។

[1017] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195340-00195341 KH 00052390-00052391។

[1018] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯកភាជ្យ" ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26 EN 00933835 KH 00052305។

[1019] យោងតាមសមាជិកក្រុមមេធាវីការពារក្តីដែលនិយាយភាសាខ្មែរ ឈ្មោះទាំងពីរនេះខុសគ្នា។

ភូមិភាគបូព៌ា ហើយថា មានសន្និបាតប្រហែលគ្នាផ្សេងទៀត ត្រូវបានរៀបចំធ្វើឡើងដែរ[1020]។ ស.ព.អ. ដកស្រង់ជាចម្បង នូវចម្លើយមិនអាចជឿជាក់បានរបស់ ឈូក រិន និង មាស រឿន[1021]។

៣០៧. **ឈូក រិន៖** ឈូក រិន មិនអាចជឿជាក់បានឡើយ[1022]។ គាត់បានផ្តល់ចម្លើយដែលផ្ទុយគ្នាអំពី មាស មុត និង ការប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ ហើយសាក្សីផ្សេងទៀតបានបដិសេធចម្លើយរបស់គាត់។ នៅពាក់កណ្តាលឆ្នាំ ១៩៧៧ ឈូក រិន បានចូលរួមក្នុងកិច្ចប្រជុំនៅផ្ទះ តា ម៉ុក នៅខេត្តតាកែវ ដែលនៅទីនោះ តា ម៉ុក បាននិយាយថា អ្នកចូលរួមនឹងត្រូវបញ្ជូនទៅបោសសម្អាតភូមិភាគបូព៌ា ដែលបានចូលដៃជាមួយជនជាតិវៀតណាម[1023]។ បន្ទាប់មក ឈូក រិន បាននិយាយថា ពីរបីសប្តាហ៍បន្ទាប់ពីការប្រជុំនេះ គាត់បានចូលរួមការប្រជុំធំមួយនៅភ្នំពេញជាមួយ ប៉ុល ពត តា ម៉ុក ន្ឋន ជា សុន សេន និងអ្នកចូលរួមផ្សេងទៀតចំនួនប្រមាណ ៦០០ ទៅ ៧០០ នាក់ (រួមទាំង មាស មុត ផងដែរ) ដើម្បីពិភាក្សាអំពីការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា[1024]។ ឈូក រិន ធ្លាប់បានប្រាប់ ក.ស.ច.ស. កាលពីលើកមុនថា មានមេបញ្ជាការកងវរសេនាធំ និង កងពលធំ ចំនួនប្រមាណ ៥០ ទៅ ៦០ នាក់ប៉ុណ្ណោះដែលចូលរួមក្នុងការប្រជុំ[1025]។ ក្រោយមកគាត់បាននិយាយថា គាត់បានឃើញ មាស មុត ញឹកញាប់នៅកិច្ចប្រជុំចាប់ពីឆ្នាំ ១៩៧៦ រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៧ ប៉ុន្តែក្រោយពេលនោះមក គាត់ដែលបានឃើញ មាស មុត ទៀតហើយ[1026]។ ឈូក រិន ក៏បាននិយាយផងដែរថា នៅក្នុងការប្រជុំ មិនមានការនិយាយអំពីភូមិភាគបូព៌ាឡើយ គឺទាល់តែដល់ចុងឆ្នាំ ១៩៧៧ ឬ ឆ្នាំ ១៩៧៨ ទើបមាននិយាយ[1027]។ ហេតុដូច្នេះផ្ទុយពីសក្ខីកម្មលើក

[1020] កថាខណ្ឌ ២៩៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1021] ជើងចំព័រ ៩៧៣-៧៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1022] *សូមមើល* កថាខណ្ឌ ២៥៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីមុខដំណែងសាក្សីរូបនេះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[1023] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៨ ឯកសារ D4.1.409 EN 00268896 KH 00210211។

[1024] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៨ ឯកសារ D4.1.409 EN 00268896-00268897 KH 00210211-00210212។ ជើងចំព័រ ៩៧៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1025] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D4.1.408 EN 00268871 KH 00194467។

[1026] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/87 ឆ.៥៤។

[1027] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/87 ស-ឆ.៦០-៦១។

មុនរបស់គាត់ ឈូក រិន មិនបានចូលរួមការប្រជុំណាមួយជាមួយ មាស មុត ដែលក្នុងការប្រជុំនោះមានការពិភាក្សាអំពីភូមិភាគបូព៌ាឡើយ។

៣០៨. ឈូក រិន បានអះអាងថា អៀង ផាន ដែលជាមេបញ្ជាការកងវរសេនាធំ ហើយបានក្លាយជាមេបញ្ជាការកងពលធំលេខ ២២១ នៅខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៧៨[1028] បានចូលរួមក្នុងការប្រជុំធំនៅភ្នំពេញ[1029]។ អៀង ផាន បាននិយាយថា គាត់មិនដែលបានចូលរួមការប្រជុំបែបនេះឡើយ បើទោះបីជាគាត់ធ្លាប់ចូលរួមប្រជុំនៅផ្ទះតាម៉ុកក្តី[1030]។ អៀង ផាន បាននិយាយថា ឈូក រិន មិនមានវត្តមានទេ នៅឯការប្រជុំជាមួយ តា ម៉ុក ព្រោះជាការប្រជុំរបស់មេបញ្ជាការ កងពលតូច និង កងពលធំ[1031]។ សាក្សីម្នាក់ទៀតគឺ ជួន ធី (ហៅ ធីឌី) ក៏បានបដិសេធថា មិនដែលបានចូលរួមការប្រជុំធំនៅភ្នំពេញដែរ ទោះបីជា ឈូក រិន បានអះអាងថា ជួន ធី បានចូលរួមនៅទីនោះក្តី[1032]។ ជួន ធី បាននិយាយថា គាត់បានចូលរួមតែក្នុងការប្រជុំជាមួយ ប៉ុល ពត នៅក្នុងឆ្នាំ ១៩៧៨ នៅខេត្តកំពង់ឆ្នាំងប៉ុណ្ណោះ ដែលនៅពេលនោះ ប៉ុល ពត បាននិយាយអំពីការការពារកម្ពុជាប្រជាធិបតេយ្យ ពីពួកឈ្លានពានបរទេស ដូចជាប្រទេសវៀតណាមជាដើម[1033]។

៣០៩. **មាស រឿន**៖ មាស រឿន មិនអាចជឿជាក់បានឡើយ[1034]។ គាត់បានអះអាងថា កម្មាភិបាលកម្រិតកងពលធំបានចូលរួមក្នុងការប្រជុំជាមួយមជ្ឈិម ដែលនៅពេលនោះមានការពិភាក្សាអំពីគោលនយោបាយសម្រិតសម្រាំង និង បោសសម្អាតខ្លាំង[1035]។ ការអះអាងរបស់គាត់ គឺផ្អែកតែលើអ្វី

[1028] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D98/3.1.56 នៅម៉ោង 10.13.17-10.18.53។

[1029] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៨ ឯកសារ D4.1.409 EN 00268897 KH 00210212។

[1030] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ឆ.៥, ឆ.៨-៩។

[1031] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D98/3.1.56 នៅម៉ោង 13.50.55-13.54.31។

[1032] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ D4.1.408 EN 00268872 KH 00194467។

[1033] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី ២ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1056 ឆ.៣-៤, ឆ.១៣។

[1034] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1035] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.១៤។ ជើងទំព័រ ៩៧៤ នៃដីកាសន្និដ្ឋានស្តាពរ។

ដែលបានគាត់ឮពី សៀង មេបញ្ជាការកងពលធលេខ ១ ប៉ុណ្ណោះ[1036]។ គាត់មិនបាននិយាយថា មាស មុត បានចូលរួមក្នុងការប្រជុំបែបនេះឡើយ។

៣១០. បើទោះបីជា មាស មុត បានចូលរួមក្នុងសន្និបាត ឬ ការប្រជុំអគ្គសេនាធិការ ក្នុងនាមជាសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៥ និង ជាមេបញ្ជាការកងទ័ពជើងទឹកក៏ដោយ ក៏ជាការសមហេតុផលដែលថា មាស មុត ត្រូវតែចូលរួមដូច្នេះ។ ការចូលរួមក្នុងសន្និបាតបក្ស ឬ ការប្រជុំនានា បើទោះបីជា សន្និបាត ឬ ការប្រជុំនោះ ពាក់ព័ន្ធនឹងការពិភាក្សា ឬ ការរាយការណ៍ អំពីការបោសសម្អាតក្តី ក៏មិនបានធ្វើឱ្យ មាស មុត ក្លាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើង នៅទូទាំងកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។ សកម្មភាពណាមួយទាក់ទងការបោសសម្អាតដែល មាស មុត អាចបានអនុវត្តឡើង គឺមានកម្រិតត្រឹមតែតំបន់កំពង់សោម និង តំបន់ ៥០៥ ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ហើយធ្វើឡើងតាមការបញ្ជារបស់មជ្ឈិម។ គាត់មិនបានធ្វើសកម្មភាពនៅទូទាំងកម្ពុជាប្រជាធិបតេយ្យឡើយ ហើយគាត់មិនបានចូលរួមក្នុងហេតុការណ៍ ដែលកើតឡើងក្រៅតំបន់ប្រតិបត្តិការរបស់គាត់ឡើយ។

គ. ការបើកវគ្គរៀនសូត្រនយោបាយសម្រាប់កម្មាភិបាលនៃកងពលធំលេខ ១៦៥ មិនមានន័យថា មាស មុត បានចូលរួមចំណែកក្នុងគោលនយោបាយរបស់ ប.ក.ក.

៣១១. ប្រភពដែល ស.ព.អ. ដកស្រង់ គឺមិនគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានបើកវគ្គរៀនសូត្រនយោបាយ សម្រាប់កម្មាភិបាលកងពលធំលេខ ១៦៥ អំពីសកម្មភាពខ្មាំងផ្ទៃក្នុងឡើយ[1037]។ ស.ព.អ. បានដកស្រង់ជាសំខាន់ នូវចម្លើយរបស់ ម៉ៅ វ៉ាន់ សយ ប៊ិន សំ សោម និង ចម្លើយខាងក្រៅដែលថាជារបស់ មាស មុត[1038]។ ភស្តុតាងនេះមិនកំណត់ថា មាស មុត ទទួលខុសត្រូវតែម្នាក់ឯង ទៅលើវគ្គរៀនសូត្របែបនេះទេ។ បើទោះបីជា មាស មុត ពិតជាបានបើកវគ្គរៀនសូត្របែបនេះ សម្រាប់កម្មាភិបាលកងពលធំលេខ ១៦៥ មែនក៏ដោយ ក៏ការធ្វើបែបនេះមិនមានន័យថា គាត់ត្រូវស្ថិតក្នុងប្រភេទ “អ្នកទទួលខុសត្រូវខ្ពស់បំផុត” នោះដែរ។

[1036] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.១៤-១៥។

[1037] កថាខណ្ឌ ៦៨, ១០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1038] ជើងទំព័រ ២០៥-០៧, ២០៩-១០, ៣០៦-០៨ នៃដីកាសន្និដ្ឋានស្តាពរ។

៣១២. **ម៉ៅ វ៉ាន់**៖ ម៉ៅ វ៉ាន់ មិនបានគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ ម៉ៅ វ៉ាន់ គឺជាទាហាន នៅក្នុងកងវរសេនាធំលេខ ២១ ដែលបន្ទាប់មកបានចូលរួមក្នុងកងទ័ពជើងទឹក ជាយុទ្ធជននៅលើទូក[1039]។ គាត់បានឃើញ មាស មុត "ម្តងម្កាល" នៅវគ្គរៀនសូត្រ ប៉ុន្តែគាត់មានហានន្តរសក្តិទាបពេកមិនអាចជួប មាស មុត បាន[1040]។ ម៉ៅ វ៉ាន់ បាននិយាយថា មាស មុត និង អនុរបស់គាត់ បានរៀបចំវគ្គរៀនសូត្រសម្រាប់កងវរសេនាធំលេខ ១៤០ អំពីនីតិវិធី និង វិន័យកងទ័ព អំពីកងទ័ពវៀតណាមចង់លេបយកទឹកដីកម្ពុជាប្រជាធិបតេយ្យ និង អំពីភាពចាំបាច់ក្នុងការការពារព្រំដែន[1041]។ ម៉ៅ វ៉ាន់ មិនដែលបានចូលរួមវគ្គរៀនសូត្រ ឬ ការប្រជុំណាផ្សេងទៀតជាមួយ មាស មុត ឡើយ[1042]។ ចម្លើយរបស់គាត់បង្ហាញថា វគ្គបណ្តុះបណ្តាលស្តីពីគោលដៅស្របច្បាប់របស់កងទ័ព៖ នីតិវិធីកងទ័ព និង ការការពារជាតិ។ ការពិភាក្សាអំពីតម្រូវការ ក្នុងការការពារព្រំដែនប្រទេសមួយ ប្រឆាំងកងទ័ពប្រទេសឈ្លានពាន គឺមិនមែនជាការពិភាក្សាអំពី "សកម្មភាពខ្លាំងនៅក្នុងជួរ" ឡើយ[1043]។

៣១៣. **សយ ប៊ិន**៖ សយ ប៊ិន មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ សយ ប៊ិន បានចូលរួមវគ្គនយោបាយប្រចាំឆ្នាំ នៅរោងភាពយន្តកោះរ៉ុង[1044]។ សយ ប៊ិន បាននិយាយថា មាស មុត ដែលជាមេបញ្ជាការទទួលបន្ទុកនយោបាយ បានបង្រៀនអំពីការងារនយោបាយ សតិអារម្មណ៍ និង ការចាត់តាំង។ ឌឹម ដែលជាមេបញ្ជាការទទួលបន្ទុកយោធា បានបង្រៀនអំពីបច្ចេកទេសយោធាប្រយុទ្ធហើយ ឆាន ដែលជាមេបញ្ជាការខាងភស្តុភារ បានបង្រៀនអំពីអាវុធយោធភ័ណ្ឌ ការហូបចុកប្រើប្រាស់ ផ្គត់ផ្គង់ និង សុខភាព[1045]។ សយ ប៊ិន បាននិយាយថា នៅពេលបិទវគ្គបណ្តុះបណ្តាល មាស មុត បានសង្ខេបពីវគ្គសិក្សា ហើយបានផ្តល់ការណែនាំបន្ថែម ដូចជាការស្វែងរកខ្លាំងនៅក្នុង

[1039] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/132 ឆ.២៧, ឆ.៧៤, ឆ.៨២។

[1040] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/132 ឆ.១៧។

[1041] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/132 ឆ.៦៣, ឆ.៦៦-៦៩។ ជើងទំព័រ ២០៥-០៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1042] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/132 ស-ឆ.១១៤-១៧, ស-ឆ.១៨៣ (ដែលនិយាយថាគាត់បានចូលរួមប្រជុំតាមក្រុម និង ការប្រជុំវរសេនាធំ)។

[1043] កថាខណ្ឌ ៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1044] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 ឆ.៦, ឆ.៨ ។ ជើងទំព័រ ២០៦-០៧, ៣០៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1045] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 ឆ.១០។

ជួរ[1046]។ ភស្តុតាងរបស់ សយ ប៊ិន បង្ហាញថា សមាជិកទាំងអស់ នៅគណៈកម្មាធិការកងពលធំលេខ ១៦៤ បានបង្រៀននៅក្នុងវគ្គរៀនសូត្រប្រចាំឆ្នាំ។

៣១៤. **សំ សោម**៖ សំ សោម មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ឡើយ។ គាត់បង្ហាញថា មនុស្សជាច្រើនមានវត្តមាននៅក្នុងវគ្គបណ្តុះបណ្តាល ដែលគាត់បានចូលរួមនោះ គឺមិនមែនមានតែ មាស មុត នោះទេ។ គាត់បាននិយាយថា មាស មុត បានចូលរួមវគ្គបណ្តុះបណ្តាល "ម្តងម្កាល"[1047] ហើយ មាស មុត បានថ្លែងក្នុងកម្មវិធីបើក និង បិទវគ្គ ហើយថា មាស មុត និង វ៉ាគ្នឺនដទៃទៀតបានថ្លែងអំពីប្រធានបទនានា ដូចជា ការហ្សេបៃ គិញរៀតណាម និង តាមដានសកម្មភាពខ្មាំងនៅសហករណ៍[1048]។

៣១៥. ស.ព.អ. ដកស្រង់ចម្លើយដែលថាជារបស់ មាស មុត ឆ្លើយប្រាប់អ្នកនិពន្ធ David Kattenberg ថាគាត់គ្រប់គ្រងនយោបាយរបស់កងពលធំ[1049]។ ការសម្ភាសន៍នេះធ្វើឡើង ដោយមិនមានការត្រួតពិនិត្យដោយតុលាការ ហើយធ្វើឡើងក្នុងគោលបំណងផ្សេង ក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌ។ ការសម្ភាសន៍នេះមានតម្លៃជាភស្តុតាងតិចតួច[1050]។

៣១៦. ដូចគ្នានឹង ម៉ៅ វ៉ាន់ សយ ប៊ិន និង សំ សោម ដែរ សាក្សីដទៃទៀតបាននិយាយថា សមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៤ បានបើកវគ្គរៀនសូត្រនយោបាយដែរ។ កឹម ម៉ែន និង ម៉ាក ឈឿន ដែលជាមេបញ្ជាការកងវរសេនាតូចទាំងពីរនាក់[1051] បាននិយាយថា ឌឹម ក៏បានបើកវគ្គរៀនសូត្រ

[1046] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 អ.១០-១១។

[1047] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/58 អ.២២។

[1048] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/58 អ.២៣, អ.២៦-២៧។ ជើងទំព័រ ៣០៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1049] កថាខណ្ឌ ៦៨ ជើងទំព័រ ២១០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ពីខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍រវាង មាស មុត និង David Kattenburg ខែមេសា ឆ្នាំ ២០០៩ ឯកសារ D54/16/1R នៅម៉ោង ២០:០៧-២៣:០៣។

[1050] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាពីប្រភេទនៃភស្តុតាងនេះ។

[1051] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កឹម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 អ.២១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/18 អ.៥។

នយោបាយផងដែរ[1052]។ យ៉ែម សំអុន បាននិយាយថា មាស មុត មិនបានបង្រៀនវគ្គនយោបាយ ដែលគាត់ចូលរួមទេ គឺមានតែ ឌឹម ម្នាក់ប៉ុណ្ណោះ[1053]។ សាក្សីដទៃទៀតនិយាយថា មាស មុត មិនបានពិភាក្សាអំពីខ្មាំងផ្ទៃក្នុងឡើយ នៅក្នុងវគ្គរៀនសូត្រ។ កឹម ម៉ែន បាននិយាយថា មាស មុត បាននិយាយអំពីការការពារប្រទេសពីខ្មាំងយួន[1054]។ គាត់មិនដែលឮ មាស មុត និយាយអំពីខ្មាំងបំផ្លាញបដិវត្តន៍ ឬ ខ្មាំងស៊ីរួងផ្ទៃក្នុងឡើយ ទោះបីជាគាត់បានចូលរួមក្នុងវគ្គរៀនសូត្រ ដែលពិភាក្សាអំពីប្រធានបទបែបនេះក្តី[1055]។ ស្វាយ សាម៉ែត បាននិយាយថា មាស មុត មិនបាននិយាយអំពីនិន្នាការនយោបាយ ឬ ប្រវត្តិរូបឡើយ តែ មាស មុត និយាយអំពីការទ្រទ្រង់ខ្លួនឯងឱ្យបានគ្រប់គ្រាន់[1056]។ ឡាយ ប៊ុនហាក់ បាននិយាយថា នៅក្នុងការប្រជុំនយោបាយដែលដឹកនាំដោយ មាស មុត មានពិភាក្សាតែអំពីខ្មាំងសតិអារម្មណ៍ (ខ្ពិលច្រអូស) ហើយការប្រជុំទាំងនោះ គឺនិយាយអំពីការកសាងកម្លាំង កសាងខ្លួន មនោគមន៍វិជ្ជា ព្រមទាំង របៀបរបបយោធា និង ការគោរព[1057]។

៣១៧. គោលនយោបាយណាដែលបានពិភាក្សា នៅក្នុងការប្រជុំកម្រិតកងពលធំ ឬ កម្រិតទាបជាងនេះក្តី គឺជាការតម្រូវដោយគណៈអចិន្ត្រៃយ៍។ គណៈកម្មាធិការកងពលធំលេខ ១៦៥ មិនមានស្ថ័យភាពក្នុងការសម្រេចលើខ្លឹមសារនៃវគ្គបណ្តុះបណ្តាលឡើយ។ គណៈកម្មាធិការបានផ្សព្វផ្សាយគោលនយោបាយ និង ការណែនាំ ដែលចេញដោយមជ្ឈិមបក្ស ដូចគ្នានឹងកម្មាភិបាលទាំងអស់ នៅក្នុងស្តាប័ននានារបស់បក្ស នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយ និង ការណែនាំទាំង

[1052] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កឹម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 ឆ.១០៩-១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/19 ឆ.១៦-១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/20 ឆ.២៥។

[1053] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ឆ.១៣-១៥។

[1054] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កឹម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 ឆ.១១១-១៤។

[1055] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កឹម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 ឆ.២៤៩។

[1056] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ែត ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/78 ឆ.៤៣ ឆ.៤៤។

[1057] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ឆ.៣១-៣២។ ទោះបីជាមេធាវីការពារក្តីស្នើសុំថា ការស្តាប់ចម្លើយនេះគួរតែត្រូវបានផ្តល់តម្លៃជាភស្តុតាងទាប ដោយសារតែបញ្ហានៅពេលយកចម្លើយក៏ដោយ (*សូមមើល* កថាខណ្ឌ ១៨៩ *ខាងលើ*) ប្រសិនបើ ស.ច.ស. ចាត់ទុកថាវាអាចជឿជាក់បាន ស.ច.ស. ក៏ត្រូវតែពិចារណាចម្លើយនេះផងដែរ។

នេះ ត្រូវបានចេញដោយគណៈអចិន្ត្រៃយ៍ ទៅអគ្គសេនាធិការ ហើយអគ្គសេនាធិការបានផ្សព្វផ្សាយទៅកងពលធំថ្នាក់ក្រោមតាមរយៈការប្រជុំ និង វគ្គរៀនសូត្រ[1058]។

ឃ. សេចក្តីសន្និដ្ឋាន

៣១៨. មាស មុត មិនមានអំណាចក្នុងការសម្រេចលើគោលនយោបាយ ប.ក.ក. ឬ ការអនុវត្តគោលនយោបាយទាំងនោះឡើយ។ គណៈកម្មាធិការកងពលធំលេខ ១៦៤ បានទទួលគោលនយោបាយ និង ការណែនាំ ពីគណៈអចិន្ត្រៃយ៍ និង អគ្គសេនាធិការ ហើយពួកគេត្រូវបានតម្រូវឱ្យអនុវត្តតាម។ ការចូលរួមក្នុងការប្រជុំ ឬ សន្និបាតរបស់អគ្គសេនាធិការ គឺមិនមានន័យថា មាស មុត អាចផ្តល់មតិយោបល់ ឬ គំនិត ទៅលើគោលនយោបាយ ឬ ផែនការរបស់បក្ស ដែលបានស្នើឡើងនោះទេ។ គណៈកម្មាធិការកងពលធំលេខ ១៦៤ មិនមានស្ងួយភាពឡើយ ទាក់ទងនឹងវគ្គរៀនសូត្រនយោបាយដែលខ្លួនបានរៀបចំឡើងនៅក្នុងកងពលធំលេខ ១៦៤។ គ្រូឧទ្ទេសត្រូវផ្សព្វផ្សាយមាគ៌ាបក្ស។ ការចូលរួមក្នុងការប្រជុំ និង សន្និបាត និង ការបើកវគ្គបណ្តុះបណ្តាល គឺមិនមានន័យថា មាស មុត គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់ឡើយ។

២. វិសាលភាពនៃការទទួលខុសត្រូវរបស់កងពលធំលេខ ១៦៤ គឺមិនធំទូលាយគ្រប់គ្រាន់ដើម្បីធ្វើឱ្យ មាស មុត ក្លាយជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់

៣១៩. ប្រភពដែល ស.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ក្រៅពីការល្បាតតំបន់ឆ្នេរ និង កោះនានាហើយនោះ កងពលធំលេខ ១៦៤ ទទួលខុសត្រូវលើការផ្តល់ការគាំទ្រផ្នែកយោធាដល់កងពលធំដទៃផ្សេងទៀត និង មានសិទ្ធិអំណាចទៅលើកងពលធំនៃកងទ័ពភូមិភាគទាំង

[1058] *សូមមើល* កថាខណ្ឌ ១៦៩ និង ២១៣ *ខាងលើ* ដែលពិភាក្សាពីការប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ប្រតិចារឹកចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 10.11.57-10.15.52 (ម៉ាក ឈឿន ឆ្លើយថា សេចក្តីណែនាំឱ្យចៀសវាងកុំវាយតបតនឹងវៀតណាម ត្រូវបានចេញដោយ ប៉ុល ពត នៅក្នុងវគ្គរៀនសូត្រ ហើយកងពលបញ្ជាក់តាមឯកសារហ្នឹងដែរទៅថ្នាក់ក្រោម ណែនាំតាមហ្នឹងដូចសម្តី ប៉ុល ពត ដែរ)។ ឯកសារវគ្គរៀនសូត្រខាងសេនាធិការ ចំណងជើងថា "តារាងស្តីតិសិក្ខាកាមរៀនវគ្គសេនាធិការលើកទី១" ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.5។ ឯកសារវគ្គរៀនសូត្រខាងសេនាធិការ ចំណងជើងថា "វគ្គសេនាធិការលើកទី២ តារាងស្តីតិសិក្ខាកាម" ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.6។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/105 ស-អ.១១ (ឆ្លើយថា ភាសារបស់ សុន សេន ដែលបានប្រើក្នុងកំណត់ហេតុនៃអង្គប្រជុំសេនាធិការនៅថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ទាក់ទងនឹងការបោសសំអាត ផ្អែកលើគោលការណ៍ចំនួនបី គឺត្រូវបានគេប្រើប្រាស់ភាសាដូចគ្នានៅក្នុងកងទ័ពកាលពីពេលនោះ)។

អស់ ដែលឈរជើងនៅតាមឆ្នេរសមុទ្រ ជាពិសេស គឺកងពលធំលេខ ១[1059]។ ស.ព.អ. ដកស្រង់សារទូរលេខ និង សាក្សីដែលមិនអាចជឿជាក់បាន ហើយដែលមិនគាំទ្រដល់ការអះអាងរបស់គាត់[1060]។ ស.ព.អ. មិនបានគិតពីភស្តុតាងដោះបន្ទុកឡើយ។ ភស្តុតាងដែលគាត់ដកស្រង់ទាក់ទងតែចំពោះកងពលធំលេខ ១ និង ប្រតិបត្តិការរបស់កងពលធំនេះ នៅជុំវិញកោះនានានៅក្នុងខេត្តកោះកុងប៉ុណ្ណោះ។ មាស មុត មិនមានអំណាចទៅលើកងពលធំលេខ ១ ឡើយ។ មិនមានភស្តុតាងបង្ហាញថា កងពលធំលេខ ១៦៤ បានផ្តល់ការគាំទ្រដល់កងពលធំផ្សេងទៀតឡើយ។

ក. មាស មុត មិនមានអំណាចទៅលើកងពលធំលេខ ១ ឬ កងពលធំផ្សេងទៀត

៣២០. ប្រភពដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត មានអំណាចទៅលើកងពលធំលេខ ១ ពីព្រោះ៖ **ក.** មាស មុត បានទាក់ទងជាមួយ សឿង មេបញ្ជាការកងពលធំលេខ ១ អំពីកប៉ាល់ និង កម្លាំងយោធានៅខេត្តកោះកុង ហើយ មាស មុត បានជួប សឿង ម្តងម្កាល ដើម្បីចេញសេចក្តីណែនាំដល់កងពលធំលេខ ១[1061] **ខ.** ប្រសិនបើឧប្បត្តិហេតុបានកើតឡើង ក្នុងអំឡុងពេលប្រតិបត្តិការរួមគ្នា សឿង ត្រូវពិភាក្សាជាមួយ មាស មុត មុននឹងចេញបញ្ជាទៅកងពលធំលេខ ១[1062] **គ.** មាស មុត មានសិទ្ធិអំណាចក្នុងការណែនាំ អំពីប្រតិបត្តិការដល់អង្គភាពយោធា ដូចជាកងពលធំលេខ ១ ជាដើម[1063]។ ស.ព.អ. ពឹងផ្អែកភាគច្រើនទៅលើចម្លើយដែលមិនអាចជឿជាក់បាន និង មិនមានការគាំទ្ររបស់ មាស វឿន ព្រមទាំងចម្លើយរបស់ អ៊ឹង ឆុន និង ឯក សុផល[1064]។ ស.ព.អ. ក៏ដកស្រង់ផងដែរ នូវសារទូរលេខដែលមិនគាំទ្រ ដល់ការអះអាងរបស់គាត់[1065]។

៣២១. **មាស វឿន៖** មាស វឿន មិនអាចជឿជាក់បានឡើយ[1066]។ បើទោះបីជាចម្លើយរបស់គាត់មានតម្លៃជាភស្តុតាងក៏ដោយ ក៏វាពុំគាំទ្រការអះអាងរបស់ ស.ព.អ. នោះដែរ។ មាស វឿន បានទាយស្មានថា

[1059] កថាខណ្ឌ ៦៣, ២២២ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៣០៣-០៦។

[1060] ជើងទំព័រ ១៩៤, ៦៦៩ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ៩៩៣-១០០៧។

[1061] កថាខណ្ឌ ៣០៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៣០៥។

[1062] កថាខណ្ឌ ៣០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1063] កថាខណ្ឌ ៣០៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1064] ជើងទំព័រ ៦៦៩, ១០០៥-១០០៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ១៩៥។

[1065] ជើងទំព័រ ១៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1066] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

មាស មុត មានសិទ្ធិអំណាចផ្តល់យោបល់ណែនាំដល់អង្គភាពយោធាផ្សេងទៀត ដូចជា កងពលធំលេខ ១ លើប្រតិបត្តិការនៅតាមដែនសមុទ្រ[1067]។ គាត់បានអះអាងថា មាស មុត បានតំណាងឱ្យមជ្ឈិម ហើយជាសមាជិកគណៈកម្មាធិការអគ្គសេនាធិការ[1068]។ គាត់ពុំដែលធ្លាប់បានឮសេចក្តីប្រកាសផ្លូវការណាមួយអំពីតួនាទីរបស់ មាស មុត នោះឡើយ[1069]។ គាត់បានសំអាងទស្សនៈរបស់គាត់លើអ្វីដែលគាត់ "បានកត់សម្គាល់ឃើញ" អំពីការងាររបស់ មាស មុត[1070]។ ដោយហេតុថា មាស វឿន មិនមានទំនាក់ទំនងជាមួយនឹង មាស មុត[1071] ហេតុដូច្នេះ ការអះអាងរបស់គាត់មានតម្លៃជាភ័ស្តុតាងតិចតួច។

៣២២. មាស វឿន បាននិយាយថា តា ម៉ុក និង អគ្គសេនាធិការមានសិទ្ធិអំណាចខ្ពស់បំផុតលើកងពលធំលេខ ១។ គាត់បាននិយាយថា តា ម៉ុក គឺជាអគ្គមេបញ្ជាការយោធាទទួលបន្ទុកកងទ័ពជើងទឹក កងទ័ពថ្មើរជើង និង កងទ័ពជើងអាកាស ហើយមានសិទ្ធិអំណាចចេញបញ្ជាលើកងពលធំលេខ ១ និង កងពលធំលេខ ១៦៥[1072]។ គាត់បាននិយាយផងដែរថា អគ្គសេនាធិការបានចេញសេចក្តីណែនាំ

[1067] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.៥។ កថាខណ្ឌ ៣០៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1068] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 អ.១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.៥។

[1069] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.៥។

[1070] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 អ.៥។ ជើងទំព័រ ៦៦៩, ១០០៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1071] *សូមមើល* កថាខណ្ឌ ១៩៣ និង ២០៤ *ខាងលើ* ។

[1072] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 13.48.39-13.53.04៖ "ស៖ លោកសាក្សី ដំបូង ខ្ញុំសួរលោកថា អ្វីដែលខ្ញុំរៀបរាប់អំពី តាម៉ុក នេះ តើត្រឹមត្រូវទេ គឺថា គាត់ជាមេបញ្ជាការទាំងបីសាខានៅតាមសមរភូមិ ហើយមានអំណាចជាង សុន សេន។ ខ្ញុំសង្ខេបបែបហ្នឹង ត្រឹមត្រូវទេ? ឆ៖ ត្រឹមត្រូវហើយ។ ... ស៖ លោកខ្លួនឯងផ្ទាល់និយាយអំពីកងទ័ពជើងទឹក ជើងគោក និង ជើងអាកាស។ ហើយលោកបានឆ្លើយថា តាម៉ុក ជាមេបញ្ជាការទាំងបីផ្នែកហ្នឹងឯង ទាំងជើងទឹក ជើងគោក ជើងអាកាស។ ហើយបើគិតពីអំណាចនៅក្នុងជួរកងទ័ពហ្នឹងគឺគាត់មានអំណាចខ្ពស់ជាង សុន សេន? ឆ៖ ខ្ញុំសូមបញ្ជាក់ពីអំណាចគ្រប់គ្រង និងបញ្ជា ព្រោះអីកងទ័ពទាំងជើងទឹក ទាំងជើងគោក ទាំងជើងអាកាស ដែលគាត់អាចបញ្ជាបាន។ ហ្នឹងជាកិច្ចការរបស់គាត់ គាត់មានអំណាច កិច្ចការងាររបស់ខាងលើ ខ្ញុំមិនដឹងកិច្ចការងារគាត់ទាំងអស់ថា យ៉ាងម៉េចទេ ក៏ប៉ុន្តែឃើញថាគាត់បានបញ្ជាគ្រប់កងទ័ពទាំងអស់ហ្នឹង ទាំងជើងទឹក ជើងគោក ជើងអាកាស គាត់បញ្ជាបាន ក៏ប៉ុន្តែកិច្ចការខាងលើរបស់គាត់រៀបរយយ៉ាងម៉េច អាហ្នឹងខ្ញុំអត់ដឹងអស់នូវកិច្ចការរបស់គាត់ទេ។ ស៖ ខ្ញុំនៅតែយល់មិនទាន់បានច្បាស់ថា តើលោកដឹងថា តាម៉ុក ជាអ្នកត្រួតត្រារួម ក្តាប់រួមនៅក្នុងការបញ្ជាកងទ័ព។ អ៊ីចឹងធ្វើម៉េចបានជាលោកដឹងថាដូច្នេះនៅពេលនោះ? ឆ៖ ខ្ញុំបានដឹងថាគាត់

ឱ្យទៅ សឿង និង មាស មុត ដើម្បីផ្សព្វផ្សាយបន្តទៅថ្នាក់ក្រោម។[1073] ដោយបានបង្ហាញថា មាស មុត ពុំមានសិទ្ធិអំណាចលើកងពលធំលេខ ១ នោះឡើយ។ ការអះអាងរបស់ មាស រឿន ថា ទាហានកងពលធំលេខ ១ អាចបាញ់ឃោធាដែលកំពុងដកថយពីកងពលធំផ្សេងនោះ គឺសំអាងលើភ័ស្តុតាងចចាមអារ៉ាមដែលមិនស៊ីចង្វាក់គ្នាពីសំណាក់ទាហានកងពលធំលេខ ១[1074]។

៣២៣. មាស រឿន បាននិយាយថា កងទ័ពជើងទឹកចូលជួយប្រសិនបើមានជម្លោះនៅតាមដែនសមុទ្រជាមួយប្រទេសណាមួយ[1075] ប៉ុន្តែ មិនអាចនឹកឃើញពេលដែលកងទ័ពជើងទឹកបានធ្វើការអន្តរាគមន៍ដោយផ្ទាល់នោះទេ[1076]។ មាស រឿន ក៏បានលើកឡើងផងដែរថា កងពលធំលេខ ១ បានជួយកងពលធំលេខ ១៦៥ នៅក្នុងការឃ្លាំមើលទូក ឬ កប៉ាល់ នៅតាមសមុទ្រ[1077]។ ការសម្របសម្រួលបែបនេះជាការសមហេតុផល ដោយសារកងពលធំលេខ ១ និង កងពលធំលេខ ១៦៥

បញ្ជាបានដោយសារថា កងខ្ញុំក៏គាត់បញ្ជាបាន កងដទៃគាត់បញ្ជាបាន ខ្ញុំដឹងគាត់ថា ដឹងថាអ្នកដឹកនាំ ដឹងថាគាត់មានអំណាចប៉ុណ្ណឹង ខ្ញុំដឹងថាប៉ុណ្ណឹង ប៉ុន្តែអំណាចរបស់គាត់រៀបរយយ៉ាងណាទៀតនោះ ខ្ញុំមិនដឹងទេ ប៉ុន្តែគាត់បញ្ជាបានគ្រប់កងអ៊ីចឹងឯង"។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.១, ឆ.១៦។

[1073] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ស-ឆ.២៦៖ "ស៖ តើកងរបស់លោកប្រឈមមុខជាមួយកងរបស់ថៃញឹកញាប់ដែរឬទេ ក្នុងឆ្នាំ ១៩៧៨? ឆ.២៦៖ ... នៅក្នុងពេលនោះ ក្នុងឆ្នាំ ១៩៧៨ យើងត្រូវបានគេណែនាំឱ្យបន្ថយជម្លោះនៅខាងលិច ពីព្រោះនៅព្រំដែនខាងកើតមានជម្លោះកាន់តែខ្លាំងឡើងៗ។ អគ្គសេនាធិការបានប្រជុំណែនាំតាមរយៈ តា មុត និង តា សឿង"។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 11.11.03-11.13.40៖ "ស៖ លោកឆ្លើយថា ក្នុងអំឡុងពេល៣ឆ្នាំនៅកោះកុង លោកទទួលបញ្ជាផ្ទាល់ពីតាសឿង។ ហើយពេលដែល តាសឿង មិននៅ លោកទទួលទូរលេខពី សុន សេន។ ដូច្នេះ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ? ឆ៖ បាទ ត្រឹមត្រូវ"។

[1074] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.៤-៥។ ជើងទំព័រ ៦៦៩ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.៧ (ដែលបង្ហាញថាគាត់មិនមានវត្តមានទេ)។

[1075] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.១៧-១៨។ ជើងទំព័រ ៩៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1076] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.២០។

[1077] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 11.40.21-11.46.59។

បានគ្រប់គ្រងតំបន់ជាប់គ្នា នៅចន្លោះខេត្តកោះកុង និង ខេត្តកំពង់សោម ដូចដែល ស.ព.អ. បានទទួលស្គាល់[1078]។

៣២៤. ស.ព.អ. ដកស្រង់សម្តីរបស់ មាស មឿន ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានទាក់ទងជាមួយ សឿង តាមវិទ្យុទាក់ទងពាក់ព័ន្ធនឹងកប៉ាល់ និង កងកម្លាំងយោធានៅខេត្តកោះកុង ហើយពេលខ្លះ បានជួបជាមួយគាត់ដើម្បីផ្តល់ការណែនាំឱ្យទៅកងពលធំលេខ ១[1079]។ ទោះបីជា មាស មឿន បានអះអាងថា មាស មុត បានទាក់ទង និង ជួបជាមួយ សឿង ក៏ដោយ[1080] ក៏ការទទួលស្គាល់របស់គាត់អំពីហេតុការណ៍បែបនេះមានកម្រិត។ គាត់មិនមានទំនាក់ទំនង ឬ មិនបានទាក់ទងជាមួយនឹង មាស មុត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ[1081]។ គាត់មិនដែលបានចូលប្រជុំជាមួយ មាស មុត និង សឿង នោះទេ[1082]។ គាត់គ្រាន់តែនៅចាំបានថា មានពេលមួយនោះនៅក្នុងឆ្នាំ ១៩៧៨ ពួកគេទាំងពីរបានទាក់ទងគ្នាម្តងអំពីកប៉ាល់ និង កងកម្លាំងយោធាប៉ុណ្ណោះ[1083]។ មាស មឿន មានទំនាក់ទំនងតិចតួចជាមួយ សឿង។ សឿង បានមកលេងគាត់ម្តងនៅពេលគាត់នៅក្នុងខេត្តកោះកុង។ ប៉ុន្តែ ពួកគេមិនបានមកជួបគ្នាញឹកញាប់នោះទេ[1084] ហើយគ្រាន់តែភាគច្រើនបានទាក់ទងគ្នាតាមទូរលេខប៉ុណ្ណោះ[1085]។

[1078] កថាខណ្ឌ ៣០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1079] កថាខណ្ឌ ៣០៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1080] ដើងទំព័រ ១០០៤-០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1081] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.11.34-10.15.02, 10.20.16-10.24.36។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 11.16.18-11.20.06, 11.40.21-11.46.59។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស មឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.១៩-២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស មឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.១៥។ *សូមមើល* ដើងទំព័រ ១០០៥ នៃដីកាសន្និដ្ឋានស្តាពរ ទាក់ទងនឹងការប្រជុំរបស់ មាស មឿន ជាមួយកងវរសេនាធំ និង កងវរសេនាតូចរបស់កងពលលេខ ១៦៤។

[1082] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស មឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.១៥។

[1083] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស មឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.២១។ ដើងទំព័រ ១០០៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1084] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.17.39-10.20.16។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស មឿន ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1042 ឆ.៦ (ឆ្លើយថាគាត់មិនបានមកប្រជុំជាមួយ តាសឿង ទេ។ គាត់ច្រើនតែ

៣២៥. ស.ព.អ. ដកស្រង់ដោយមិនស្មោះត្រង់ នូវការទាក់ទងរបស់ មាស រឿន ជាមួយ ស៊ីម មេបញ្ជាការកងវរសេនាធំនៃកងពលធំលេខ ៣/១៦៤ យកមកជាភ័ស្តុតាងបង្ហាញថា មាស មុត និង សឿង ដែលមេបញ្ជាការកងពលធំលេខ ១បានជួបគ្នា ឬ បានទាក់ទងគ្នាតាមវិទ្យុទាក់ទង[1086]។ មាស រឿន បាននិយាយថា គាត់ និង ស៊ីម បានទាក់ទងគ្នាតាមវិទ្យុទាក់ទង ហើយនឹងនៅក្នុងពេលប្រជុំដើម្បីសម្របសម្រួលសកម្មភាពរបស់ពួកគេ កុំឱ្យជាន់ការងារគ្នា ហើយកុំឱ្យមានការបាញ់បោះដាក់គ្នាទៅវិញទៅមក[1087] ចាប់ពីដើមឆ្នាំ ១៩៧៨[1088]។ ការទំនាក់ទំនងរវាង មាស មុត និង ស៊ីម មិនមែនជាភ័ស្តុតាងបង្ហាញអំពីការទាក់ទងគ្នារវាង មាស មុត និង សឿង ឡើយ។

៣២៦. ស.ព.អ. បំផ្លើសសារសំខាន់នៃការអះអាងរបស់ មាស រឿន ថា សឿង ត្រូវតែពិភាក្សាហេតុការណ៍ទាំងនោះជាមួយ មាស មុត នៅក្នុងអំឡុងពេលធ្វើប្រតិបត្តិការរួមគ្នាដោយសារកងពលធំ

រាយការណ៍តាមសារទូរលេខជូនប្រធានកងពល។ ក្នុងរយៈពេល ៣ ឬ ៤ ខែ បើមានការប្រជុំនៅភូមិភាគ ទើបគាត់ទៅចូលរួមពីព្រោះកោះកុងនៅឆ្ងាយពេក ពិបាករកមធ្យោបាយធ្វើដំណើរទៅមក)។ *រឿងក្តី ន្ឧន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 09.34.04-09.40.14 (ឆ្លើយថាគាត់ចូលរួមកិច្ចប្រជុំនៅថ្នាក់ភូមិភាគកន្លះឆ្នាំបានមករួចម្តង បើគេហៅខ្ញុំ ក៏បានមក)។

[1085] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1042 ឆ.៦។ តា សឿង ប្រចាំការនៅស្រុកព្រៃនប់ និង ខេត្តកំពង់ស្ពឺ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1057 ឆ.២។ *រឿងក្តី ន្ឧន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១២ D98/3.1.178 នៅម៉ោង 10.20.16-10.24.36។

[1086] កថាខណ្ឌ ៣០៦ ជើងទំព័រ ១០០៥-០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1087] *សូមមើលឧទា. រឿងក្តី ន្ឧន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 11.40.21-11.46.59។ *សូមមើលផងដែរ រឿងក្តី ន្ឧន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.13.25-10.17.39។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ D54/52 ឆ.៣២, ឆ.៣៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/53 ឆ.១, ឆ.៩ ។ កថាខណ្ឌ ៣០៣ ជើងទំព័រ ៩៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1088] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.៣២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.១៩-២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.២០។ ជើងទំព័រ ១០០៤-០៥ នៃដីកាសន្និដ្ឋានស្តាពរ។

លេខ ១ មិនមានសិទ្ធិអំណាចបញ្ជាកងទ័ពជើងទឹក[1089]។ មាស រឿន បាននិយាយថា ប្រសិនបើហេតុការណ៍មួយបានកើតឡើងនៅក្នុងអំឡុងពេលធ្វើប្រតិបត្តិការរួមគ្នា សឿង បានពិភាក្សាជាមួយនឹង មាស មុត នៅមុនពេលចេញបញ្ជាទៅឱ្យកងអង្គភាពនានាដើម្បីចាត់វិធានការរបស់ពួកគេរៀងៗខ្លួន[1090]។ គាត់បាននិយាយថា "ពួកខ្ញុំចាំតែទទួលបញ្ជាពីមេបញ្ជាការរបស់ខ្លួនតែប៉ុណ្ណោះ មានតាសឿង និង តាមុត"[1091] ប៉ុន្តែ ទំនងជាសំដៅលើកងអង្គភាពប្រតិបត្តិការចម្រុះ។ គាត់បានបន្តអះអាងថា កងពលធំលេខ ១ របស់គាត់ បានរាយការណ៍ និង ទទួលបញ្ជាពី សឿង ហើយថា កងវរសេនាធំនៃកងពលធំលេខ ១៦៥ បានរាយការណ៍ និង ទទួលបញ្ជាពីកងពលធំលេខ ១៦៥[1092]។ ការណ៍ដែលថា មាស មុត និង សឿង បានពិភាក្សាអំពីកិច្ចប្រតិបត្តិការរួមគ្នានោះ មិនមានន័យថា មាស មុត មានសិទ្ធិអំណាចលើ សឿង នោះទេ។ មាស រឿន បាននិយាយថា គាត់ និង ស៊ីម បានចាត់វិធានការរៀងៗខ្លួន ដូចជា ចាប់ទូក ដើម្បីដោះស្រាយសភាពការណ៍ទាំងនោះ[1093]។ ពេលខ្លះគាត់បានចាត់ការដោយគ្មានការណែនាំពីមេបញ្ជាការរបស់គាត់។ ចម្លើយរបស់គាត់មិនបានបង្ហាញថា មាស មុត មានសិទ្ធិអំណាចលើកងពលធំលេខ ១ ឬ កងពលធំទាំងអស់នៅតាមជួរឆ្នេរសមុទ្រនៃរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។

៣២៧. **អ៊ឹង ឆុន**៖ អ៊ឹង ឆុន មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នា និង មិនគួរឱ្យជឿអំពីការទំនាក់ទំនងគ្នារវាងកងពលធំលេខ ១ និង កងពលធំលេខ ១៦៥។ គាត់ "គ្រាន់តែជាយោធាធម្មតាម្នាក់" នៅក្នុងកងពលធំលេខ ១៦៥[1094] គ្មានហានន្តរសក្តិអ្វីនោះឡើយ ប៉ុន្តែគាត់បានពិពណ៌នា

[1089] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.៣។ កថាខណ្ឌ ៣០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1090] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.៣។

[1091] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.៣ (ការគូសបញ្ជាក់នៅក្នុងឯកសារដើម)។

[1092] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.២ ។ *រឿងក្តីនួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.20.16-10.24.36។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.១៨, ឆ.៣០-៣១។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ស-ឆ.២១។

[1093] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/53 ឆ.៧-៨។

[1094] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ឆ.១។

ខ្លួនគាត់ថាជាអនុប្រធានខាងម៉ាស៊ីននៅលើកប៉ាល់របស់គាត់[1095]។ គាត់មិនបានចូលរួមនៅក្នុងការបញ្ជូន ឬ ការទទួលការទំនាក់ទំនងគ្នាជាមួយនឹងបញ្ជាការដ្ឋានកងពលធំលេខ ១៦៥ ជាមួយនឹង មាស មុត ឬ សមាជិកថ្នាក់ខ្ពស់ៗនៅក្នុងជួរកងពលធំនោះឡើយ។ គាត់មិនបានដឹងថា តើកងពលធំ និង មេបញ្ជាការកប៉ាល់ ទាក់ទងគ្នាដោយរបៀបណា ដោយមិនបានដឹងថា ពួកគេទាក់ទងគ្នាដោយផ្ទាល់ ឬ ដោយប្រយោលតាមរយៈថ្នាក់កងវរសេនាធំ ឬ កងវរសេនាតូចនោះឡើយ[1096]។ ក៏ប៉ុន្តែ បន្ទាប់មក គាត់បានពិពណ៌នាលម្អិតអំពីរបៀបដែលការទំនាក់ទំនងគ្នាបានធ្វើឡើងរវាង មាស មុត និង កប៉ាល់របស់គាត់ និង របៀបដែលកងពលធំលេខ ១ រាយការណ៍ទៅកងពលធំលេខ ១៦៥[1097]។ អ៊ឹង ឆុន បានអះអាងថា យោងតាមការសង្កេតរបស់គាត់លើការទំនាក់ទំនងរវាងថ្នាក់ដឹកនាំនៅខេត្តកោះកុង ពេលខ្លះ ពួកគេបានបញ្ជូននិរសារតាមទូកធម្មតាគ្មានម៉ាស៊ីន ហើយមិនបានប្រើវិទ្យុទាក់ទង ឬ ទូរលេខនោះទេ[1098]។ ក្រោយមក គាត់បានឆ្លើយផ្ទុយនឹងចម្លើយមុនរបស់គាត់។ គាត់បាននិយាយថា វិទ្យុទាក់ទង និង ទូរលេខ ត្រូវបានប្រើប្រាស់ កងពលធំលេខ ១ បានរាយការណ៍អំពីទូកខុសច្បាប់ទៅកាន់មន្ទីរទូរលេខរបស់កប៉ាល់ តាមរយៈវិទ្យុទាក់ទង ហើយអ្នកកាន់ទូរលេខបានរាយការណ៍បន្តទៅ មាស មុត ដែលជាអ្នកបញ្ជូនបញ្ជាត្រលប់មកវិញ[1099]។

៣២៨. **ឯក សុផល**៖ ឯក សុផល មិនបានគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ[1100]។ គាត់គឺជាមេបញ្ជាការរងកងវរសេនាធំនៃកងពលធំលេខ ១ ឈរជើងនៅទល់មុខកោះត្រល់[1101]។ គាត់បាននិយាយថា កងពលធំលេខ ១ បានជួយកងពលធំលេខ ១៦៥ វែជាមួយវៀតណាមនៅលើកោះ

[1095] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ឹង ឆុន ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/33.1 EN 01073819 KH 00964206-00964207។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 អ.១៥។

[1096] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 អ.៤។

[1097] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 អ.២-៤, អ.១២។ ជើងចំពាក់ ៦៦៩ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 អ.១២។ *សូមមើលផងដែរ* កថាខណ្ឌ ៣០៤ ជើងចំពាក់ ៩៩៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1098] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 អ.៥។

[1099] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 អ.៥, អ.១២។ កថាខណ្ឌ ៣០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1100] កថាខណ្ឌ ២២២ នៃដីកាសន្និដ្ឋានស្តាពរ។

[1101] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/84, ស-អ.៣-៤។

ត្រល់[1102]។ គាត់មិនមានវត្តមាននៅពេលនោះទេ ហើយគាត់ទើបបានដឹងអំពីហេតុការណ៍នោះនៅក្រោយឆ្នាំ ១៩៧៩[1103]។ ដូចដែលគាត់បានកត់សម្គាល់ថា "ពុំមានការចែករំលែកព័ត៌មាននៅក្នុងសម័យនោះ"[1104]។

៣២៩. ស.ព.អ. ដកស្រង់ទូរលេខចំនួនពីរដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា កងពលធំលេខ ១៦៤ ទទួលខុសត្រូវយាមល្បាតតាមមាត់ឆ្នេរ និង នៅលើកោះ ហើយផ្តល់ការគាំទ្រផ្នែកយោធាដល់កងពលធំផ្សេងទៀត[1105]។ ទូរលេខទាំងនេះបានត្រឹមតែបង្ហាញថា ការយាមល្បាតបានធ្វើឡើងនៅម្តុំកោះកុង ហើយមិនបានបង្ហាញថា កងពលធំលេខ ១៦៤ បានយាមល្បាតនៅតំបន់ផ្សេងទៀត ឬបានផ្តល់ការគាំទ្រផ្នែកយោធាដល់កងពលធំផ្សេងទៀតក្រៅពីកងពលធំលេខ ១ នោះឡើយ[1106]។ ដូចបានពន្យល់នៅក្នុងកថាខណ្ឌ ២២៧ *ខាងលើ* ក្នុងចំណោម ១៣% នៃព្រំដែនប្រទេសកម្ពុជា ចម្ងាយ ៣០១២ គីឡូម៉ែត្រ កងពលធំលេខ ១៦៤ បានយាមល្បាតតែនៅតាមមាត់ឆ្នេរ និង កោះជិតៗ កំពង់សោមប៉ុណ្ណោះ។

ខ. បើទោះបីជាកងពលធំលេខ ១ និង កងពលធំលេខ ១៦៤ បានសហការចាប់ទូកថៃ និង ទូកវៀតណាមក៏ដោយ ក៏ការសហការបែបនេះមិនមានន័យថា មាស មុត មានសិទ្ធិអំណាចលើកងពលធំលេខ ១ នោះដែរ

៣៣០. ប្រភពដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា កងពលធំលេខ ១ និង កងពលធំលេខ ១៦៤ បានចែករំលែកព័ត៌មាន ដើម្បីជួយសម្រួលដល់ការចាប់ទូកថៃ និង ទូកវៀតណាម[1107] ហើយថាអ្នកជាប់ឃុំត្រូវបានបញ្ជូនទៅកងពលធំលេខ ១៦៤ នៅកំពង់សោម

[1102] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/84 អ.១៥-១៦។ កថាខណ្ឌ ២២២ ជើងទំព័រ ៦៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1103] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/84 អ.៧, អ.១៦។

[1104] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/84 អ.១០។

[1105] ជើងទំព័រ ១៩៥ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ទូរលេខ ចំណងជើងថា "ទូរលេខ ០៩ ពី មុត ជម្រាបបង ៨៩" ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.18។ ទូរលេខ ចំណងជើងថា "ទូរលេខ ០៤ ពី រឿន ចំពោះបងមុត" ចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.39។

[1106] *សូមមើល* កថាខណ្ឌ ២២៧ *ខាងលើ* សម្រាប់ការលើកឡើងពីវិសាលភាពភូមិសាស្ត្រនៃការល្បាតរបស់កងពល ១៦៤។

[1107] កថាខណ្ឌ ៣០៤ នៃដីកាសន្និដ្ឋានស្តាពរ។

នោះទេ[1108]។ ស.ព.អ. ដកស្រង់ចម្លើយដែលមិនមានមូលដ្ឋានសំអាង និង មិនអាចឱ្យជឿជាក់បានរបស់ មាស វឿន និង អ៊ឹង ឆុន[1109]។ គាត់បំផ្លើសនៅក្នុងការអះអាងរបស់គាត់។ គាត់ក៏មិនបានពិចារណាលើភ័ស្តុតាងដោះបន្ទុកដែលពាក់ព័ន្ធផងដែរ។ បើទោះបីជាកងពលធំទាំងពីរពិតជាសហការគ្នាមែនក៏ដោយចុះ ក៏សកម្មភាពបែបនោះមិនមានន័យថា មាស មុត មានសិទ្ធិអំណាចលើកងពលធំលេខ ១ នោះដែរ។ ហើយកិច្ចសហការបែបនេះក៏មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។

៣៣១. **មាស វឿន**៖ មាស វឿន មិនអាចជឿជាក់បានឡើយ[1110]។ ចម្លើយរបស់គាត់ក៏មិនគាំទ្រផងដែរដល់ការអះអាងរបស់ ស.ព.អ.។ អង្គភាពរបស់គាត់បានយាមល្បាតតំបន់មួយប្រហែលជាចម្ងាយ ៤០ គីឡូម៉ែត្រទឹកពីផ្លូវសមុទ្រអន្តរជាតិ[1111]។ កប៉ាល់កងពលធំលេខ ១៦៤ នៅជិតផ្លូវសមុទ្រអន្តរជាតិជាងកន្លែងគាត់[1112]។ នៅពេល មាស វឿន បានឃើញកប៉ាល់ដែលនៅចម្ងាយ ៧០ គីឡូម៉ែត្រទឹក ឬ ឆ្ងាយជាងនេះនោះ គាត់បានរាយការណ៍ឱ្យ ស៊ឹម ដែលជាមេបញ្ជាការកងវរសេនាធំនៃកងពលធំលេខ ១៦៤[1113] ទៅតាមការណែនាំរបស់ សឿង[1114]។ កងវរសេនាធំរបស់ ស៊ឹម ត្រូវបានទាក់ទងតែនៅពេលមានកប៉ាល់ចូលតំបន់ប្រតិបត្តិការរបស់កងពលធំលេខ ១៦៤ ប៉ុណ្ណោះ។ នៅពេលអង្គភាពរបស់ មាស វឿន ចាប់បានទូកនេសាទថៃ ឬ ទូកនេសាទវៀតណាម ដែលចូលតំបន់ប្រតិបត្តិការរបស់កងពលធំលេខ ១ ដោយខុសច្បាប់នោះ គាត់បានរាយការណ៍អំពីការចាប់

[1108] កថាខណ្ឌ ៣០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1109] ដើងទំព័រ ៩៩៦-១០០០, ១០០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1110] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1111] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.២៦។

[1112] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.២៦។

[1113] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.៣៥។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 11.46.59-11.52.42៖ "បើសិនជាកប៉ាល់វាចូលជ្រៅ ឬ ក៏វានៅដីគេហ្នឹង យើងអាចប្រាប់គេតាមៗ តេអូ ដែលអាចនិយាយឆ្លើយឆ្លងគ្នាបាន។ ... ខ្ញុំអត់ដែលរាយការណ៍ទៅកងពលលេខ៣ទេ ក៏ប៉ុន្តែអ្នកដែលកាន់កាប់កប៉ាល់ហ្នឹងប្រាប់ -- ខ្ញុំប្រាប់តាម អ្នកកប៉ាល់ហ្នឹង អ្នកបើកបរកប៉ាល់ហ្នឹង មួយភ្លែតគេប្រាប់តាមមេគេទៅកងពលលេខ៣ហើយ។ ហើយខ្ញុំវាយការណ៍ទៅខាងកងពលខ្ញុំណេះផ្សេង ទៅខាងតាសឿង ណេះផ្សេង នៅឯក្រោយឯណេះផ្សេង ដើម្បីឱ្យគាត់ដឹង"។

[1114] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/53 ឆ.១។

ទូកទាំងនោះទៅ សឿង[1115]។ កងពលធំលេខ ១៦៥ មិនត្រូវបានទាក់ទងអំពីគ្រប់ហេតុការណ៍កប៉ាល់ចូលដែនទឹកកោះកុងនោះឡើយ។

៣៣២. **អ៊ឹង ឆុន**៖ អ៊ឹង ឆុន មិនអាចជឿជាក់បានឡើយ[1116]។ គាត់បានអះអាងថា កងពលធំលេខ ១ បានប្រើប្រាស់រ៉ាដា និង កែវយឺតរកមើលទូកខុសច្បាប់[1117]។ មាស រឿន បាននិយាយថា នៅពេលគាត់នៅក្នុងខេត្តកោះកុង[1118] កប៉ាល់កងពលធំលេខ ១ បានត្រឹមតែប្រើកែវយឺតប៉ុណ្ណោះ ដោយសាររ៉ាដាមិនទាន់ត្រូវបានដំឡើងនៅឡើយ[1119]។ សក្ខីកម្មរបស់ មាស រឿន មានតម្លៃជាភស្តុតាងខ្ពស់ជាងសក្ខីកម្មរបស់ អ៊ឹង ឆុន។ ខុសពី អ៊ឹង ឆុន មាស រឿន ស្ថិតនៅក្នុងជួរកងពលធំលេខ ១។ ស.ព.អ. ក៏ដកស្រង់ផងដែរ នូវចម្លើយរបស់ អ៊ឹង ឆុន ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា នៅពេលកងពលធំលេខ ១ បានឃើញគោលដៅ កងពលនេះបានទាក់ទងកងពលធំលេខ ១៦៥[1120] ដោយមានន័យថា កងពលធំលេខ ១ *តែងតែ* បានទាក់ទងកងពលធំលេខ ១៦៥។ ការអះអាងរបស់ អ៊ឹង ឆុន អំពីការ

[1115] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.20.16-10.24.36។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.១៨, ឆ.៣០-៣១។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ស-ឆ.២១៖ "ស៖ តើពេលប្រយុទ្ធជាមួយគេ កងពលលេខ ១ រាយការណ៍ទៅឱ្យកងទ័ពជើងទឹកដែរឬទេ? ឆ.២១៖ ទេ យើងរាយការណ៍ទៅឱ្យភូមិភាគបស្ចឹម"។

[1116] *សូមមើល* កថាខណ្ឌ ៣២៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1117] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ឆ.៥, ឆ.៧។ ជើងទំព័រ ៩៩៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1118] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.៤ (ឆ្លើយថាគាត់បានទៅព្រះវិហារ នៅខែសីហា ឆ្នាំ ១៩៧៨)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.២៦ (ឆ្លើយថាគាត់បានទៅព្រះវិហារ នៅខែកក្កដា ឆ្នាំ ១៩៧៨)។

[1119] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 10.54.53-11.57.40៖ "ស៖ នៅកោះកុង តើមានរ៉ាដាដែរឬទេ? ឬក៏លោកធ្លាប់ទទួលព័ត៌មានពីរ៉ាដា ដែលដំឡើងនៅតាមឆ្នេរសមុទ្រដែរឬទេ? ឆ៖បាទ ដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺមិនទាន់មានរ៉ាដាឆ្លុះមើលទេ មើលទៅតាមអាសីម៉ែលឆ្លុះ"។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.២៦ (បង្ហាញថា ពួកគេកំពុងតែរៀបចំតម្លើងរ៉ាដានៅលើភ្នំតាម៉ាន នៅពេលនោះគាត់បានចាកចេញទៅ)។

[1120] កថាខណ្ឌ ៣០៤ ជើងទំព័រ ៩៩៨ នៃដីកាសន្និដ្ឋានស្តាពរ។

ទំនាក់ទំនងរវាង មាស មុត និង កប៉ាល់នៅក្នុងខេត្តកោះកុងមានចំណុចផ្ទុយគ្នា ហើយមិនបានផ្អែកលើការដឹងឮផ្ទាល់ខ្លួនរបស់គាត់ឡើយ[1121]។ ស.ព.អ. បំផ្លើសភ័ស្តុតាង[1122]។

៣៣៣. ស.ព.អ. អះអាងថា ក្រោយពេលកងពលធំលេខ ១ ចាប់បានទូកហួចហើយនោះ អ្នកជាប់ឃុំត្រូវបានបញ្ជូនទៅកងពលធំលេខ ១៦៤ នៅកំពង់សោម[1123]។ ស.ព.អ. ដកស្រង់ដោយមិនត្រឹមត្រូវនូវសំដីរបស់ មាស រឿន[1124]។ គាត់ក៏មិនអើពើនឹងភ័ស្តុតាងដោះបន្ទុកផងដែរ។ មាស រឿន មិនបាននិយាយថា អ្នកជាប់ឃុំត្រូវបានបញ្ជូនទៅកងពលធំលេខ ១៦៤ នោះទេ។ គាត់បាននិយាយថា ពួកគេត្រូវបានបញ្ជូនទៅកងទ័ពកងពលធំលេខ ១ នៅកំពង់សោម[1125]។ គាត់មិនបានដឹងថា តើកងទ័ពជើងទឹកបានធ្វើអ្វីចំពោះអ្នកជាប់ឃុំនោះទេ។ បេសកកម្មរបស់គាត់បានបញ្ចប់ត្រឹមបញ្ជូនពួកគេដល់កងពលធំលេខ ១[1126]។ គាត់មិនបានដឹងអំពីកិច្ចការរបស់ខាងកំពង់សោមឡើយ[1127]។

គ. សេចក្តីសន្និដ្ឋាន

៣៣៤. កងពលធំលេខ ១៦៤ មិនមានសិទ្ធិអំណាចលើកងពលធំនៃកងទ័ពភូមិភាគនៅតាមឆ្នេរសមុទ្រ ឬ ផ្តល់ការគាំទ្រផ្នែកយោធាដល់កងពលធំផ្សេងទៀតនោះឡើយ។ គ្មានភ័ស្តុតាងបង្ហាញថា មាស មុត មានសិទ្ធិអំណាចលើកងពលធំលេខ ១ នោះឡើយ។ ភ័ស្តុតាងបានត្រឹមបង្ហាញថា កងពលធំទាំងពីរបានសហការណ៍គ្នានៅក្នុងការងារយាមល្បាតដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ។ បើទោះបីជាកងពលធំលេខ ១៦៤ មានសិទ្ធិអំណាច ឬ បានផ្តល់ការគាំទ្រផ្នែកយោធាដល់កងពលធំផ្សេងទៀតក៏ដោយ

[1121] *សូមមើលេ* កថាខណ្ឌ ៣២៧ *ខាងលើ*។

[1122] *សូមមើលេ* កថាខណ្ឌ ៣៣១ *ខាងលើ*។

[1123] កថាខណ្ឌ ៣០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1124] ជើងទំព័រ ១០០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1125] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/53 ឆ.១៩-២០។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.20.16-10.24.36។

[1126] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/53 ឆ.១៩។

[1127] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/53 ឆ.១៩។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 13.31.11-13.37.22 (ដែលផ្តល់សក្ខីកម្មពីទូរលេខដែលអះអាងចេញពី មាស មុត ទាក់ទងនឹងការបាញ់ប្រជាជនវៀតណាម ១២០ នាក់ និង ការយឺតយ៉ាវដោះលែងជនជាតិថៃ)។

ក៏មិនមានន័យថា មាស មុត គឺជាបុគ្គលម្នាក់ដែលអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម ធ្ងន់ធ្ងរដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។ គាត់មិនមានឋានៈអំណាច ឬ សិទ្ធិអ្វីខុសពីមេបញ្ជាការកងវរសេនាធំឯករាជ្យ ឬ កងពលធំមជ្ឈិមផ្សេងទៀតនោះទេ។ គាត់បានធ្វើប្រតិបត្តិការនៅក្នុងតំបន់មួយចំនួនតូច ហើយត្រូវគោរពតាមគោលនយោបាយ និង ការណែនាំរបស់មេដឹកនាំជាន់ខ្ពស់ ប.ក.ក. នៅក្នុងជួរគណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ។

៣. សិទ្ធិអំណាចលើកងពលធំលេខ ១៦៤ មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត"

៣៣៥. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានយាមល្បាតគ្រប់ទិដ្ឋភាពនៃកងពលធំលេខ ១៦៤ ហើយបានចេញបញ្ជាជាច្រើនរូបភាពលើប្រតិបត្តិការយោធានោះឡើយ[1128]។ ស.ព.អ. ដកស្រង់សាក្សីដែលមិនអាចជឿជាក់បាន និង ភ័ស្តុតាងឯកសារដែលមានតម្លៃភ័ស្តុតាងទាប។ គាត់បកស្រាយភ័ស្តុតាងខុស។ គាត់មិនអើពើនឹងភ័ស្តុតាងបរិបទដែលពាក់ព័ន្ធ។ ស.ព.អ. ខកខានមិនបានរកមូលដ្ឋានគាំទ្រការអះអាងរបស់គាត់។ បើទោះបីជា មាស មុត ពិតជាគ្រប់គ្រងកងពលធំលេខ ១៦៤ មែនក៏ដោយ ក៏មិនធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។

ក. មាស មុត មិនបានចេញបញ្ជា ឬ ធ្វើសេចក្តីសម្រេចតែឯងឡើយ ពាក់ព័ន្ធនឹងប្រតិបត្តិការយោធានៃកងពលធំលេខ ១៦៤

៣៣៦. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានគ្រប់គ្រងគ្រប់សេចក្តីសម្រេចទាំងអស់ លើតំបន់ប្រតិបត្តិការនៃកងពលធំលេខ ១៦៤ រួមទាំង ការចេញបញ្ជាពាក់ព័ន្ធនឹងប្រតិបត្តិការយោធាឡើយ[1129]។ ស.ព.អ. ដកស្រង់ចម្លើយមិនអាចឱ្យជឿជាក់បាន និង គ្មានមូលដ្ឋានគាំទ្រពី ប៉ាក សុខ ម៉ើ រ៉េត ស៊ឹម នី កង សុំ លុន សេង ស៊ន សុត

[1128] កថាខណ្ឌ ៨១ ជើងទំព័រ ២៣៩-៤៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ២៦០-៦២។

[1129] កថាខណ្ឌ ៦៧, ៨១ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៨០, ១០៩៥។

សុក វណ្ណា និង ស្វាយ សាម៉ែត[1130]។ គាត់មិនអើពើនឹងភស្តុតាងបរិបទពាក់ព័ន្ធនឹងកងពលធំលេខ ១៦៥ ឡើយ។

៣៣៧. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1131]។ គាត់បានអះអាងដោយមិនត្រឹមត្រូវថា មាស មុត បានទទួលខុសត្រូវលើខាងផ្នែកយោធា ភស្តុភារ នេសាទ ជួសជុលកប៉ាល់ សកម្មភាពកំពង់ផែ[1132]។ គាត់ក៏បាននិយាយផងដែរថា ត្រូវរាយការណ៍គ្រប់ហេតុការណ៍ទាំងអស់ ជូនមេបញ្ជាការកងពលធំ[1133]។ នៅក្នុងតំបន់កំពង់សោមដែលកងពលធំលេខ ១៦៥ ឈរជើង មាស មុត បានចាត់ចែងលើកិច្ចការយោធា ធុច រិន ចាត់ចែងលើកិច្ចការស៊ីវិល និង កិច្ចការផែ[1134] ហើយ ឡូញ បានទទួលខុសត្រូវលើអង្គភាពនេសាទ[1135]។ ចម្លើយរបស់ ប៉ាក សុខ អំពីឋានានុក្រមរាយការណ៍ និង ណែនាំ[1136] បង្ហាញអំពីរចនាសម្ព័ន្ធរាយការណ៍ធម្មតានៅក្នុងជួរយោធា។ កងវរសេនាតូចរាយការណ៍ទៅកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅកងពលធំ ដែលជាអ្នករាយ

[1130] ជើងចំពរ ២០១, ២៣៩, ២៤៦, ៤៨៤-៨៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1131] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1132] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/24 ឆ.២០។

[1133] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.១៩។ ជើងចំពរ ២០១, ២៣៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1134] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ឆ.៩, ឆ.១៥, ឆ.១៧, ឆ.៣៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 ឆ.១៨, ឆ.២០, ឆ.២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/233 ឆ.៦៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/234 ឆ.២, ឆ.១៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 ឆ.៥-៧, ឆ.១២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ឆ.៤0, ឆ.៥៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.២៦, ឆ.២៨, ឆ.៣0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រៀង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ឆ.១៩៩។ *សូមមើល* កថាខណ្ឌ ២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[1135] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉េត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 ឆ.៣0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ឆ.១0។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 ឆ.៣0។

[1136] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.១៩។ ជើងចំពរ ២០៣ នៃដីកាសន្និដ្ឋានស្តាពរ។

ការណ៍បន្តទៅអគ្គសេនាធិការ។ បន្ទាប់មក អគ្គសេនាធិការចេញបញ្ជាទៅកងពលធំ ហើយបញ្ជាទាំងនេះត្រូវបានផ្សព្វផ្សាយជាបន្តបន្ទាប់ទៅថ្នាក់ក្រោមតាមរយៈរចនាសម្ព័ន្ធបញ្ជា[1137]។

៣៣៨. **ម៉ើ រ៉ែត**៖ ម៉ើ រ៉ែត មិនអាចជឿជាក់បានឡើយ។ គាត់បានអះអាងថា មាស មុត តាមឃ្លាំមើលអង្គភាពយោធា ផ្តល់ការបណ្តុះបណ្តាលនយោបាយ ព្រមទាំងបានបញ្ជា និង សម្របសម្រួលចលនាកងទ័ពនៅក្នុងសមរភូមិ[1138]។ ម៉ើ រ៉ែត គឺជាទាហានថ្នាក់ទាបនៅក្នុងអង្គភាពទ័ពជើងទឹក ប្រឆាំងនាវាមុជទឹក ដែលមានមូលដ្ឋានឈរជើងជាចម្បង នៅលើកប៉ាល់នៅឆ្នេរអូរឈើទាល[1139]។ ដោយសារថា ប.ក.ក. មានគោលនយោបាយរក្សាការសម្ងាត់[1140] ហើយដោយពិចារណាលើមូលដ្ឋានទីតាំង និង ឋានៈទាបរបស់ ម៉ើ រ៉ែត គាត់មិនអាចបានដឹងព័ត៌មានលម្អិតអំពីតួនាទី និង ការទទួលខុសត្រូវរបស់ មាស មុត នោះឡើយ។

៣៣៩. **ស៊ឹម នី**៖ ស៊ឹម នី មិនអាចជឿជាក់បានឡើយ[1141]។ គាត់បានអះអាងថា មាស មុត បានទទួលខុសត្រូវលើការស្នូរចម្លើយ និង សេចក្តីសម្រេចអនុញ្ញាតឱ្យបុគ្គលណាចូល និង ចេញពីវត្តឥន្ទ្រញាណ[1142]។ ចម្លើយផ្ទុយគ្នាជាច្រើនចំណុចរបស់ ស៊ឹម នី បង្ហាញថា គាត់ប្រហែលជាមិនធ្លាប់បានឃើញ មាស មុត នៅវត្តឥន្ទ្រញាណទាល់តែសោះ។ គាត់អាចគ្រាន់តែធ្លាប់ឮអំពី មាស មុត ពីអ្នកយាមប៉ុណ្ណោះ[1143]។

[1137] *សូមមើលខាង.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/288 ឧ.៦២។ *សូមមើល* កថាខណ្ឌ ១៧២ និង ២១៣ *ខាងលើ* ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃការរាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍។

[1138] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/10 ឧ.១២។ ជើងទំព័រ ២០១, ៤៨៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1139] *សូមមើល* កថាខណ្ឌ ២៨៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1140] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតម្លៃកស្តុតាង។

[1141] *សូមមើល* កថាខណ្ឌ ២៤៥ *ខាងលើ* និង កថាខណ្ឌ ៤០៦-០៨ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1142] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332607 KH 00735601-00735602។ ជើងទំព័រ ២០១ នៃដីកាសន្និដ្ឋានស្តាពរ។

[1143] *សូមមើល* កថាខណ្ឌ ៤០៧ *ខាងក្រោម*។

៣៤០. **កង សុំ**៖ កង សុំ មិនអាចជឿជាក់បានឡើយ[1144]។ គាត់បាននិយាយថា មាស មុត បានចេញបញ្ជាឱ្យអង្គភាពរបស់គាត់ទៅការពារកោះក្រចកសេះ[1145]។ គាត់បាននិយាយថា មាស មុត បានចេញបញ្ជាដែលទទួលពី ប៉ុល ពត[1146]។ ចម្លើយរបស់គាត់បង្ហាញថា មាស មុត មិនបានចេញបញ្ជាដោយឯករាជ្យចិត្តឯងនោះទេ។

៣៤១. **លុន សេង**៖ លុន សេង មិនអាចជឿជាក់បានឡើយ[1147]។ គាត់បាននិយាយថា មាស មុត បានបញ្ជាកងពលធំលេខ ៣ ឱ្យចូលភ្នំពេញនៅក្នុងអំឡុងពេលវាយប្រហារលើក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ ១៩៧៥ ហើយថា ក្នុងនាមជាស្នងការនយោបាយកងពលធំ មាស មុត បានរាយការណ៍ឱ្យ តា ម៉ុក[1148]។ តា ម៉ុក មានសិទ្ធិអំណាចខ្ពស់បំផុតលើកងពលធំលេខ ៣ ហើយបានចេញការណែនាំឱ្យ មាស មុត[1149]។ មាស មុត មិនបានចេញបញ្ជាដោយឯករាជ្យចិត្តឯង ពាក់ព័ន្ធនឹងការងារសមរភូមិនៃកងពលធំលេខ ៣ នោះទេ។ ម៉ៅ វ៉ាន់ បាននិយាយថា កងពលធំលេខ ៣ មិនត្រូវបានអនុញ្ញាតឱ្យចូលក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ នោះទេ ប៉ុន្តែជំនួសវិញ ត្រូវបានបញ្ជូនទៅកំពង់សោម[1150]។ លុន សេង ក៏បាននិយាយផងដែរថា មាស មុត បានផ្តល់លិខិតអនុញ្ញាតមួយច្បាប់ឱ្យទៅលេងគ្រួសាររបស់គាត់[1151] ដែល ស.ព.អ. ដកស្រង់ដើម្បីអះអាងថា មាស មុត បានគ្រប់គ្រង

[1144] *សូមមើល* កថាខណ្ឌ ២២៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1145] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ន.១២៦, ន.១៤៥-៤៧។ ជើងទំព័រ ២៣៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1146] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ន.១៤៦-៤៧។

[1147] *សូមមើល* កថាខណ្ឌ ១៩៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1148] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/43 ស-ន.៦-៩។ ជើងទំព័រ ២៣៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1149] *សូមមើល* កថាខណ្ឌ ២១០ *ខាងលើ*។

[1150] បទសម្ភាសជាមួយ ម៉ៅ វ៉ាន់ (POW/MIA) ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០០ ឯកសារ D4.1.759 EN 00387267 KH 00658138។ មេធាវីការពារក្តីបានជំទាស់នឹងការប្រើប្រកេទនៃបទសម្ភាសន៍ ផ្វើឡើងដោយ ស.ព.អ.។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើ ស.ច.ស. ពិចារណាថាបទសម្ភាសន៍នេះមានតម្លៃជាភស្តុតាងនោះ ស.ច.ស. ក៏គួរតែពិចារណាចម្លើយនេះផងដែរ។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/8 ន.៥៧ (ឆ្លើយថា កងពលលេខ៣ មិនបានចូលរាជធានីភ្នំពេញទេ គឺបានចូលត្រឹមពោធិ៍ចិនតុង)។

[1151] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ លុន សេង ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ D54/38.1 EN 01072400 KH 00967324។ ជើងទំព័រ ៤៨៥ នៃដីកាសន្និដ្ឋានស្តាពរ។

លើការដើរហើររបស់អ្នកនៅក្រោមបង្គាប់គាត់[1152]។ លិខិតអនុញ្ញាតឱ្យចាកចេញក្រៅតំបន់ណាមួយ គឺជាលក្ខខណ្ឌតម្រូវទូទៅរបស់ ប.ក.ក.[1153]។ កងពលធំលេខ ១៦៥ មិនមែនជាជាកងពលពិសេសមួយក្នុងការចេញលិខិតអនុញ្ញាតទាំងនេះឡើយ។

៣៤២. **ស៊ិន សុត**៖ ស៊ិន សុត មិនអាចជឿជាក់បានឡើយ។ គាត់បានទាយស្មានអំពីសិទ្ធិអំណាចរបស់ មាស មុត និង ការចេញបញ្ជា។ ស៊ិន សុត គឺជាទាហាននៅក្នុងកងវរសេនាតូចលេខ ៣៨៦ ដែលត្រូវបានបញ្ជូនឱ្យទៅធ្វើស្រែនៅចុងឆ្នាំ ១៩៧៦ ឬ ដើមឆ្នាំ ១៩៧៧[1154]។ គាត់បាននិយាយថា គាត់គឺជាក្មេងតូចម្នាក់ ពុំដែលធ្លាប់ទៅណាមកណា[1155]។ ការដឹងឮមានកម្រិតរបស់គាត់ត្រូវបានបង្ហាញឱ្យឃើញតាម រយៈការអះអាងរបស់គាត់អំពីសិទ្ធិអំណាច និង ការជាប់ពាក់ព័ន្ធរបស់ មាស មុត នៅក្នុងការចាប់ខ្លួន។ គាត់បានអះអាងថា ប្រធានក្រុម និង ប្រធានសហករណ៍បានស្ថិតនៅក្រោមបញ្ជាការរបស់ មាស មុត ដែលជាសេចក្តីសន្និដ្ឋានដោយផ្អែកតែទៅលើការសង្កេតរបស់គាត់ដែលថា និរសារកំពង់សោមបានទៅសហករណ៍[1156]។ គាត់បាននិយាយថា មាស មុត បានបញ្ជាឱ្យចាប់ទូក។ គាត់បានជឿជាក់ថា មានការចាប់ទូកមែន ដោយសារវិទ្យុ សេ ២៥ ត្រូវបានប្រើប្រាស់ដើម្បីទាក់ទង "ប្រធាន" នៅមុនពេលមានការចាប់ខ្លួនណាមួយ ហើយប្រសិនបើ "ប្រធាន" បានបញ្ជាឱ្យមានការចាប់ខ្លួន ពួកគេត្រូវតែចាប់[1157]។ គាត់បាននិយាយថា កូនចៅរបស់ មាស មុត បានចាប់ទាហានតំបន់ ៣៧ ប៉ុន្តែមិនបានដឹងកូនចៅទាំងនេះជានរណាទេ[1158]។ គាត់បានពន្យល់ការជឿជាក់របស់គាត់ថា កូនចៅរបស់ មាស មុត បានចាប់ខ្លួនទាហានតាមរយៈឧទាហរណ៍អំពីផ្ទះមួយដែល

[1152] កថាខណ្ឌ ១៨0 នៃដីកាសន្និដ្ឋានស្តាពរ។

[1153] *សូមមើលឧទាហ.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំដកពិសោធន៍ការងារយោមល្បាតការពារក្រុង" ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.9 EN 00233997 KH 00162479 (ដោយណែនាំឱ្យអ្នកយាមនៅទីក្រុងភ្នំពេញ ត្រូវសួរបញ្ជាក់ពីលិខិតមិនគ្រប់គ្រាន់ និង យកចិត្តទុកដាក់ចំពោះកម្មករដែលដើរហើរដោយគ្មានសំបុត្រស្នាម)។

[1154] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 អ.៥, អ.១២។

[1155] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 អ.៤៩។

[1156] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 អ.៤២-៤៣។ ជើងទំព័រ ២៣៩, ២៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[1157] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ស-អ.៥៤-៥៥។

[1158] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ស-អ.៦៩។

មានអ្នកគ្រប់គ្រង និង បុគ្គលម្នាក់នៅកន្លែងផ្សេង ចេញបញ្ជាតាមរយៈអ្នកគ្រប់គ្រងនោះ[1159]។ ចម្លើយរបស់ ស៊ន សុត ក៏បង្ហាញផងដែរថា គាត់មិនបានចងចាំត្រឹមត្រូវអំពី មាស មុត នោះឡើយ។ គាត់បានអះអាងថា គាត់បានជួប មាស មុត ម្តងនៅពេលប្រជុំក្នុងឆ្នាំ ១៩៧៥ ដោយបានពិពណ៌នាថា មាស មុត ខ្ពស់ មុខមានស្លាកស្នាមអុតស្វាយ[1160]។ គាត់អាចនៅចាំ ឈិន សម្បត្តិ ហៅ ប៊ូ[1161] ជាងចាំ មាស មុត[1162]។

៣៤៣. **សុក វណ្ណា**៖ សុក វណ្ណា មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់បានផ្អែកលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ គាត់បាននិយាយថា មាស មុត គឺជាប្រធានកងពលធំលេខ ៣ បានដឹកនាំអង្គភាពយោធា និង មានសិទ្ធិអំណាចលើប្រធានសហករណ៍ និង ប្រធានឃុំ[1163]។ ដោយសារហាន: និង ទីតាំងរបស់គាត់ ការដឹងឮរបស់គាត់អំពីការគ្រប់គ្រង ឬ ការងាររដ្ឋបាលនៃកិច្ចការយោធា គឺមានកម្រិត[1164]។ សុក វណ្ណា បានឮ មាស មុត មានសិទ្ធិអំណាចលើប្រធានសហករណ៍ និង ប្រធានឃុំ[1165]។ គាត់មិនមានការដឹងឮដោយផ្ទាល់អំពីសិទ្ធិអំណាចបែបនេះឡើយ។

៣៤៤. **ស្វាយ សាម៉ែត**៖ ស្វាយ សាម៉ែត មិនបានគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ គាត់គឺជាមេបញ្ជាការកងអនុសេនាធំនៅក្នុងកងវរសេនាតូចលេខ ៤៨០ ដែលក្រោយមកបានក្លាយជា

[1159] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ស-ឆ.៦៩។

[1160] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ឆ.៧១។

[1161] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជី ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ D114/264 ស-ឆ.២៨ (ដែលរៀបរាប់ថា ប៊ូ មានវាងខ្ពស់ខ្មៅ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ គីម ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/127 ស-ឆ.២១ (ដែលរៀបរាប់ថា ប៊ូ មានវាងខ្ពស់ សម្បុរខ្មៅ)។

[1162] រូបថតរបស់ មាស មុត ដែល ក.ស.ច.ស. ដាក់បញ្ចូលក្នុងសំណុំរឿង មិនមានបង្ហាញពីសម្គាកដោយសារជំងឺអុតស្វាយឡើយ។ *សូមមើល* រូបថតរបស់ មាស មុត ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66.1 EN 01044999-01044500 (ឯកសារ A66.1 ជាឯកសារដូចគ្នានឹងឯកសារ C1.1 ដែរ)។

[1163] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 ឆ.១១-១៤។ ជើងទំព័រ ២៤៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1164] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតម្លៃកស្តុតាង។

[1165] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 ឆ.១៥។

មេបញ្ជាការកងវរសេនាតូចនៅចុងឆ្នាំ ១៩៧៧[1166]។ គាត់បាននិយាយថា មាស មុត បានបង្កើតគណកម្មាធិការត្រួតពិនិត្យ ដើម្បីតាមដានមើលប្រវត្តិរូបរបស់កងទ័ព[1167] និង បានសម្រេចលើគ្រប់កិច្ចការទាំងអស់ ពីព្រោះគាត់បានទទួលខុសត្រូវលើកងពលធំលេខ ១៦៤[1168]។ គាត់ក៏បាននិយាយផងដែរថា ថ្នាក់លើបានបញ្ជាឱ្យ មាស មុត បង្កើតគណកម្មាធិការត្រួតពិនិត្យនេះ[1169]។ យ៉ាងច្រើនបំផុត ចម្លើយរបស់គាត់បង្ហាញថា មាស មុត បានធ្វើតាមបញ្ជាដែលចេញដោយមេដឹកនាំជាន់ខ្ពស់ ប.ក.ក. នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ[1170]។

៣៤៥. នៅក្នុងការអះអាងថា មាស មុត មានការគ្រប់គ្រង និង សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខ្ពស់បំផុតលើកងពលធំលេខ ១៦៤ នោះ ស.ព.អ. មិនបានពិចារណាអំពីគណកម្មាធិការកងពលធំ ១៦៤ នោះទេ[1171]។ គ្រប់សមាជិកគណៈកម្មាធិការទាំងអស់ បានអនុវត្តតាមសេចក្តីសម្រេចរបស់បក្ស[1172]

[1166] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/76 ផ.១១, ផ.១៣, ផ.២១។

[1167] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ែត ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/77 ផ.៣៩, ផ.៤៦-៤៧។ ជើងទំព័រ ២៤៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1168] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ែត ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/77 ផ.៤៦។

[1169] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ែត ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/77 ផ.៤៦-៤៧។

[1170] *សូមមើល* កថាខណ្ឌ ២១១ និង ២១៣ *ខាងលើ* ទាក់ទងនឹងអំណាចគណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការលើកងពលមជ្ឈិម។ *សូមមើល ផងដែរ* កថាខណ្ឌ ៤៦៩-៧១ *ខាងក្រោម* ទាក់ទងនឹងគោលនយោបាយ និង បទបញ្ជារបស់មជ្ឈិមលើការសម្រិតសម្រាំងប្រវត្តិរូប។

[1171] *សូមមើល* កថាខណ្ឌ២១២*ខាងលើ* ដែលពិភាក្សាអំពីគណៈកម្មាធិការកងពលលេខ១៦៤ និង មុខងាររបស់គណៈកម្មាធិការ។

[1172] *សូមមើលឧទា.* សេចក្តីវាយការណ៍ ចំណងជើងថា "សូមគោរពវាយការណ៍ជូនបង ៨៩ ជ្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2 (សេចក្តីវាយការណ៍ចុះហត្ថលេខាដោយ មាស មុត ក្នុងនោះ គាត់និយាយថា សេចក្តីវាយការណ៍ប្រចាំខែនេះធ្វើឡើងតាមរទេះភ្លើង ថា ឌឹម បានបញ្ជូនមនុស្ស និង អាវុធទៅកាន់កោះសេះ និង កោះសំពោជ ថា មាស មុត នៅកោះរុង និង កោះរុងក្រៅ ដើម្បីតាមដាន និងណែនាំអនុវត្តសេចក្តីសម្រេចរបស់ ប.ក.ក. ឱ្យមានប្រសិទ្ធភាព ហើយថា នង ឆាន ទៅជួបបង ញឹក បងសែ និងសមមិត្ត គីម ដើម្បីអនុវត្តសម្រេចរបស់ ប.ក.ក.)។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.92 នៅម៉ោង 15.03.11-15.06.23 (ព្រុំ សារ៉ាត ឆ្លើយថា អ្នកបួននាក់ក្នុងកងពល ១៦៤ ជាអ្នកចេញបញ្ជា គឺ មាស មុត ឌឹម ឆាន និង ញ៉ាន់)។

ហើយត្រូវដឹងអំពីសកម្មភាពរបស់កងពលធំលេខ ១៦៥[1173]។ បើទោះបីជា មាស មុត បានបញ្ជាកងពលធំលេខ ១៦៥ ក៏ដោយ ក៏នៅក្នុងជួរយោធា វាជារឿងធម្មតាដែលមេបញ្ជាការចេញបញ្ជាលើប្រតិបត្តិការយោធា។ ដូចដែល ព្រុំ សារ៉ាត បានផ្តល់សក្ខីកម្ម "ធម្មតា កងទ័ពធ្វើការងារតូចធំត្រូវមានបទបញ្ជា *[sic]*"[1174]។

ខ. មាស មុត មិនបានប្លាំមើលដែនគោក ដែនកោះ និង កងទ័ព

៣៤៦. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា ជាញឹកញាប់ មាស មុត បានណែនាំ និង ទទួលរបាយការណ៍ពីបុគ្គលិកក្រោមបង្គាប់អំពីដែនគោក និង ដែនកោះ បានត្រួតពិនិត្យដោយផ្ទាល់លើដែនកោះ ដើម្បីធានាថា សេចក្តីសម្រេចរបស់បក្សត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និង បានប្លាំមើលអង្គភាពយោធា ហើយបានសម្របសម្រួលចលនារបស់កងទ័ព[1175]។ ស.ព.អ. ដកស្រង់សារទូរលេខដែលមិនមានមូលដ្ឋានគាំទ្រ និង ចម្លើយដែលមិនអាចឱ្យជឿជាក់បាន ព្រមទាំងមិនមានមូលដ្ឋានសំអាងពី អែម សុន ម៉ាក ឈឿន ម៉ើ រ៉ែត និង ស៊ីម នី[1176]។ ស.ព.អ. ក៏នាំឱ្យយល់ខុសអំពីភ័ស្តុតាងផងដែរ។

៣៤៧. សារទូរលេខដែល ស.ព.អ. ដកស្រង់[1177] មិនបានបង្ហាញថា មាស មុត បានបញ្ជូនសេចក្តីណែនាំឱ្យថ្នាក់ក្រោមរបស់គាត់ និង បុគ្គលិកកងពលធំលេខ ១៦៥ ផ្សេងទៀតនោះឡើយ មានតែអ្នកទាំងនោះបានបញ្ជូនរបាយការណ៍មកគាត់វិញតែប៉ុណ្ណោះ។ ការណ៍ដែលថា មាស មុត អាចបានទទួលរបាយការណ៍ពី ឬ បានណែនាំបុគ្គលិកក្រោមបង្គាប់ និង បុគ្គលិកផ្សេងទៀតនៅក្នុងកងពលធំលេខ ១៦៥ ញឹកញាប់ ឬ មិនញឹកញាប់នោះ មិនមានន័យថា គាត់ស្ថិតនៅក្នុងកម្រិតនៃការទទួលខុសត្រូវមួយផ្សេង ឬ ខ្ពស់ជាងមេដឹកនាំកងពលធំផ្សេងទៀតនោះឡើយ។ រចនាសម្ព័ន្ធរាយការណ៍នេះ ត្រូវបានបង្កើតឡើងទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងលក្ខន្តិក: ប.ក.ក. និង គណៈកម្មាធិការអចិន្ត្រៃយ៍

[1173] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២0១៦ ឯកសារ D114/285 អ.១៨៨ (ឆ្លើយថា "ក្នុងគណៈកម្មាធិការកងពល ព័ត៌មានត្រូវដឹងទាំងអស់ ទាំងបញ្ជាការ ទាំងសមាជិក")។

[1174] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២0១៦ ឯកសារ D114/285 អ.១២២។

[1175] កថាខណ្ឌ ៦៧, ១៨0 នៃដីកាសន្និដ្ឋានស្តាពរ។

[1176] ជើងទំព័រ ២0៣-0៥, ៤៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1177] ជើងទំព័រ ២0៣ នៃដីកាសន្និដ្ឋានស្តាពរ។

ហើយជារឿងទូទៅនៅក្នុងជួរយោធា[1178]។ នៅក្នុងសារទូរលេខ ៧ ក្នុងចំណោមសារទូរលេខ ៨ ឆ្លួន ជា និង សុន សេន ត្រូវបានចម្លងជូន[1179]។ ការណ៍ដែលីសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ ត្រូវបានចម្លងជូននៅក្នុងសារទូរលេខទាំងនេះបង្ហាញថា អង្គភាពកងទ័ពបដិវត្តន៍កម្ពុជាថ្នាក់ក្រោមៗ បានរាយការណ៍ជូនថ្នាក់ដឹកនាំជាន់ខ្ពស់នៃ ប.ក.ក. នៅក្នុងពេលតែមួយ ដែលពួកគេរាយការណ៍ទៅថ្នាក់លើផ្ទាល់របស់ពួកគេនៅក្នុងជួរកងពលធំ[1180]។ រចនាសម្ព័ន្ធរាយការណ៍បែបនេះ គឺស្របជាមួយនឹងគោលការណ៍របស់បក្សដែលចែងថា កងទ័ពបដិវត្តន៍កម្ពុជាស្ថិតនៅក្រោមអំណាចដាច់ខាតរបស់បក្ស នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់[1181]។

៣៤៨. ស.ព.អ. ដកស្រង់សារទូរលេខចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ផ្ញើជូន សុន សេន ដែលក្នុងនោះ មាស មុត ត្រូវបានអះអាងថា គាត់នៅកោះរ៉ុង និង កោះរ៉ុងក្រៅ ដើម្បីធានាថា សេចក្តីសម្រេចរបស់បក្សត្រូវបានអនុវត្តនៅទីនោះ[1182]។ ស.ព.អ. ខកខានមិនបានបង្ហាញសារទូរលេខនេះទាំងមូល ហើយបាននាំឱ្យ ក.ស.ច.ស. យល់ខុសអំពីភាពពាក់ព័ន្ធ និង សារសំខាន់របស់វា។ មាស មុត មិនមែនជាសមាជិកតែម្នាក់គត់នៅក្នុងគណកម្មាធិការកងពលធំលេខ ១៦៥ ដែលបានធ្វើដំណើរ ឬ ទៅមើលកោះទាំងនោះទេ។ សារទូរលេខបង្ហាញថា យោងតាម "វិធានការណ៍ចាស់ និង

[1178] មាត្រា ៦ (៥) នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ សេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិម ចំណងជើងថា "សេចក្តីសំរេចរបស់មជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.19.1 EN 00182809 KH 00003136។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/288 ន.៦២។ *សូមមើល* កថាខណ្ឌ ១៧២ និង ២១៣ *ខាងលើ* សម្រាប់ការលើកឡើងពីលក្ខខណ្ឌតម្រូវរាយការណ៍ជូនកងពលលេខ ១៦៥។

[1179] ជើងទំព័រ ២០៣ នៃដីកាសន្និដ្ឋានស្តាពរ (ទូរលេខទាំងអស់ លើកលែងតែឯកសារ D1.3.34.39 ត្រូវបានចម្លងជូន ឆ្លួន ជា សុន សេន ឬ ទាំងពីរនាក់)។

[1180] របាយការណ៍អ្នកជំនាញការ Craig Etcheson ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧ ឯកសារ D234/2.1.52 កថាខណ្ឌ ១២៨។ *សូមមើលផងដែរ* កថាខណ្ឌ ៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[1181] មាត្រា ២៧ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។

[1182] ជើងទំព័រ ៤៨៣ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីរាយការណ៍ ចំណងជើងថា "សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2។

មតិណែនាំថ្មីរបស់បក្ស” ឌឹម បានបន្ថែមកងទ័ព និង អាវុធ នៅលើកោះសេះ កោះថ្មី និង កោះសំពោច ហើយ ឆាន បានជួបបងញឹក បងសៃ និង គីម “ដើម្បីអនុវត្តសម្រេចចិត្តរបស់បក្ស”[1183]។

៣៤៩. **អែម សុន**៖ អែម សុន មិនអាចជឿជាក់បានឡើយ[1184]។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នាអំពី មាស មុត ហើយនឹងហេតុការណ៍កប៉ាល់ម៉ាយ៉ាហ្គេ ដែល ក.ស.ច.ស. បានកត់សម្គាល់។ អែម សុន បាននិយាយថា គាត់បានរាយការណ៍ទៅ មាស មុត អំពីកប៉ាល់ម៉ាយ៉ាហ្គេ[1185]។ ដំបូង គាត់បានលើកឡើងថា គាត់បាននិយាយជាមួយនឹង មាស មុត ដោយផ្ទាល់តាមវិទ្យុទាក់ទង និង បានស្គាល់សំឡេងរបស់ មាស មុត ដោយសារគាត់បានស្គាល់ មាស មុត យូរមកហើយ[1186] ប៉ុន្តែ ក្រោយមក គាត់បាននិយាយថា គាត់មិនបាននិយាយជាមួយនឹង មាស មុត ដោយផ្ទាល់នោះទេ ប៉ុន្តែគាត់បាននិយាយជាមួយនឹងអ្នកកាន់វិទ្យុទាក់ទងពីរនាក់[1187]។ គាត់បានអះអាងថា បីថ្ងៃក្រោយការប្រគល់ទាហានអាមេរិកកាំងពីរនាក់ទៅមន្ទីរកងពលធំលេខ ១៦៥ នៅកំពង់សោមរួចមក គាត់បានជួប មាស មុត ដើម្បីពន្យល់ប្រាប់អំពីអ្វីដែលបានកើតឡើង ហើយបានឃើញសាកសពទាហានពីរនាក់ប្រហែលជា ២០ ថ្ងៃក្រោយមក[1188]។ គាត់ក៏បានប្រាប់ ក.ស.ច.ស. ផងដែរថា គាត់មិនបានដឹងថាមានអ្វីកើតឡើងចំពោះទាហានពីរនាក់នោះទេ ក្រោយពេលពួកគេបានទៅកំពង់សោមនោះ[1189]។ អែម សុន បានប្រាប់អ្នកកាសែតនាពេលក្រោយមក ដោយបានអះអាងថា គាត់មិនមានព័ត៌មានអំពី

[1183] សេចក្តីរាយការណ៍ ចំណងជើងថា “សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប” ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2។

[1184] *សូមមើល* កថាខណ្ឌ ២៣៦, ២៤៤, ៤១៦, និង ៥១៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1185] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.២១-២២, ឆ.២៦, ឆ.៣២។ ជើងទំព័រ ២០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1186] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.១១, ឆ.១៤។

[1187] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.១៥។

[1188] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.៣១-៣២, ឆ.៣៥-៣៦, ឆ.៣៩-៤៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/49 ឆ.៥៣។

[1189] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ឆ.៤៩។

ទាហានពីរនាក់នោះទេ ក្រោយពេលបានប្រគល់ពួកគេឱ្យ មាស មុត[1190]។ អ្នកស៊ើបអង្កេត POW/MIA ក៏បានកត់សម្គាល់ផងដែរ នូវការព្រួយបារម្ភអំពីភាពអាចជឿជាក់បានរបស់ អែម សុន ក្នុងនាមជាអ្នកសង្កេតផ្ទាល់លើការចាប់កប៉ាល់ម៉ាយ៉ាហ្គេ។ ពួកគេបានជឿជាក់ថា គាត់បានរាយការណ៍អំពីព័ត៌មានចចាមអារ៉ាម ថាជាព័ត៌មានដែលគាត់បានដឹងផ្ទាល់[1191]។

៣៥០. **ម៉ាក ឈឿន**៖ ម៉ាក ឈឿន មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។ គាត់បានបញ្ជាកងវរសេនាតូចលេខ ៥៦០ នៅលើកោះថ្មី[1192]។ គាត់បាននិយាយថា មាស មុត បានទៅមើលកោះរបស់គាត់តែម្តងប៉ុណ្ណោះនៅមុនហេតុការណ៍ឆ្នាំ ១៩៧៦ ដែលជាប់ពាក់ព័ន្ធនឹងការវាយជាមួយនឹងទូកនេសាទ និង កងទ័ពវៀតណាម[1193]។ គាត់បាននិយាយផងដែរថា គាត់ត្រូវរាយការណ៍អំពីព្រឹត្តិការណ៍ទាំងឡាយទៅកាន់កងវរសេនាធំ ដែលជាអ្នករាយការណ៍បន្តទៅ មាស មុត នៅក្នុងជួរកងពលធំ[1194]។

៣៥១. **ម៉ើ រ៉ែត**៖ ម៉ើ រ៉ែត មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ[1195]។ គាត់បាននិយាយថា មេបញ្ជាការកងវរសេនាធំ និង កងវរសេនាតូច តម្រូវឱ្យរាយការណ៍ទៅ មាស មុត[1196]។ គាត់ក៏បាននិយាយផងដែរថា មាស មុត បានតាមដានមើលអង្គភាព និង សម្របសម្រួលចលនាបន្តាស់ទី[1197]។ គាត់គឺជាសាក្សីតែម្នាក់គត់ដែល ស.ព.អ. ដកស្រង់យកមកធ្វើជាសំអាងគាំទ្រការអះអាងរបស់

[1190] Matt Blomberg & Sek Odom *ទាហានជើងចាស់ ស.វ.អ. មកទស្សនកិច្ចជាថ្មី នៅទីតាំងសមរភូមិចុងក្រោយ ក្នុងសង្គ្រាមវៀតណាម* (US Vets Revisit Site of Vietnam War's Last Battle) សារព័ត៌មានខេមបូឌាដែលី ចុះថ្ងៃទី ១៣ ខែសភា ឆ្នាំ ២០១៥ ឯកសារ D114/71.1 EN 01097304។

[1191] របាយការណ៍ Stony Beach POW/MIA ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៥ ឯកសារ D4.1.758 EN 00387316-00387317 KH 01506018-01506020។

[1192] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/18 ឆ.២៤, ឆ.៣២។

[1193] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/19 ឆ.៣0, ឆ.៣៣។ ជើងទំព័រ ៤៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1194] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/19 ឆ.៣៤-៣៥។ ជើងទំព័រ ៤៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1195] *សូមមើល* កថាខណ្ឌ ២៨៦ និង ៣៣៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1196] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/10 ឆ.២២។ ជើងទំព័រ ២០៣-០៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1197] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/10 ឆ.១២។

ស.ព.អ.[1198]។ ម៉ើ រ៉ែត បានទទួលស្គាល់ថា គាត់មិនបានដឹងថាតើ មាស មុត និង អនុរបស់គាត់បានបែងចែកការងារដោយរបៀបណានោះទេ[1199]។ ក្នុងនាមជាទាហានថ្នាក់ក្រោមម្នាក់[1200] ម៉ើ រ៉ែត មិនអាចដឹងឮដោយផ្ទាល់អំពីរបៀបដែលកងពលធំលេខ ១៦៤ ដំណើរការឡើយ។

៣៥២. **ស៊ឹម នី**៖ ស៊ឹម នី មិនអាចជឿជាក់បានឡើយ[1201]។ គាត់បាននិយាយថា មេបញ្ជាការកងវរសេនាធំបានទៅផ្ទះរបស់ មាស មុត ដើម្បីជួបប្រជុំពីរបីថ្ងៃរៀងរាល់ខែ[1202]។ ការដឹងឮរបស់ ស៊ឹម នី អំពីហេតុការណ៍បែបនេះមានកម្រិតទៅតាមពេលវេលា។ គាត់មិនបានស្ថិតនៅកំពង់សោមពេញមួយរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ គាត់បានធ្វើការនៅកំពង់ផែដែលស្ថិតនៅចន្លោះស្ទឹងហាវ និង កំពង់សោមចាប់ពីឆ្នាំ ១៩៧៧ រហូតដល់គាត់ត្រូវបានផ្ទេរទៅភូមិភាគបូព៌ានៅក្នុងឆ្នាំ ១៩៧៨[1203]។

៣៥៣. ជាថ្មីម្តងទៀត ស.ព.អ. មិនអើពើនឹងគណៈកម្មាធិការកងពលធំលេខ ១៦៤ ដោយបានអះអាងថា មាស មុត មានសិទ្ធិអំណាចផ្តាច់មុខមើលការខុសត្រូវលើអង្គភាពនៃកងពលធំលេខ ១៦៤[1204]។ សមាជិកគណកម្មាធិការកងពលធំលេខ ១៦៤ ផ្សេងទៀត អាចចេញបញ្ជាលើការចល័តទ័ព និងការឃ្លាំមើលអង្គភាពយោធា[1205]។ ការចល័តទ័ពណាមួយដែលសម្របសម្រួលដោយគណៈកម្មា

[1198] ជើងទំព័រ ២០៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1199] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/10 ស-ឆ.១១។

[1200] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/10 ឆ.១៨។

[1201] *សូមមើល* កថាខណ្ឌ ២៤៥ *ខាងលើ* និង កថាខណ្ឌ ៤០៦-០៨ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1202] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/31 ឆ.៥។ ជើងទំព័រ ២០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1203] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/31 ឆ.៨-៩។

[1204] កថាខណ្ឌ ៦៧, ១៨០ នៃដីកាសន្និដ្ឋានស្តាពរ។

[1205] *សូមមើលឧទា.* សេចក្តីវាយការណ៍ ចំណងជើងថា "សូមគោរពរាយការណ៍ជូនបង ៨៩ ជ្រាប" ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.30.2 (ដែលបង្ហាញថា ឌឹម កំពុងនៅលើកោះ មើលការខុសត្រូវការពង្រឹងកងទ័ព និង អាវុធ)។ ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ជូនបងមុតជ្រាបពីសភាពការណ៍ខ្លាំងនៅតាមព្រំដែន" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699 (នៅក្នុងទូរលេខនេះ ឌឹម សម្រេចបញ្ជូនយុទ្ធជនពីរនាក់)។

ធិការកងពលធំលេខ ១៦៥ គឺមានមូលដ្ឋានលើការណែនាំពី សុន សេន ឬ មេដឹកនាំជាន់ខ្ពស់ ប.ក.ក. ផ្សេងទៀត[1206]។

គ. មាស មុត មិនបានចេញបញ្ជាឱ្យឃាមល្បាត និង ចាប់ទូក

៣៥៤. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចេញបញ្ជាឱ្យឃាមល្បាត និង ចាប់ទូកនោះឡើយ[1207]។ ស.ព.អ. ដកស្រង់ចម្លើយដែលមិនអាចជឿជាក់បានរបស់ អ៊ូ ដាវ អ៊ឹង ឆុន និង នាក់ ឃឿន[1208]។ គាត់មិនអើពើនឹងភស្តុតាងបរិបទដែលពាក់ព័ន្ធនោះឡើយ។

៣៥៥. **អ៊ូ ដាវ៖** អ៊ូ ដាវ មិនអាចជឿជាក់បានឡើយ។ ការដឹងឮរបស់គាត់អំពី មាស មុត គឺផ្អែកតែលើពាក្យចចាមអារ៉ាមប៉ុណ្ណោះ[1209]។ គាត់គឺជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នៅក្នុងរឿងក្តី ០០២ ហើយបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០៣ និង រឿងក្តី ០០៤[1210]។ គាត់គឺជាមេបញ្ជាការកងអនុសេនាតូច ដែលមានទីតាំងឈរជើងជាចម្បង នៅលើកប៉ាល់នៅតាមដែនសមុទ្រនៅជិតព្រំដែនថៃ[1211]។ គាត់ក៏ត្រូវបានបញ្ជូនផងដែរ ទៅទីរួមខេត្តកោះកុង និង ទីកន្លែងផ្សេងទៀតដើម្បីកសាងស្ពាន[1212]។ អ៊ូ ដាវ បានអះអាងថា បញ្ជាឱ្យចាប់ទូកបរទេស គឺចេញមកពីមេបញ្ជាការកងវរសេនាតូចរបស់គាត់ ដែលបានទទួលបញ្ជាពី មាស មុត[1213]។ គាត់បាននិយាយថា

[1206] *សូមមើល* កថាខណ្ឌ ២១៣ *ខាងលើ* ដែលពិភាក្សាពីការប្រជុំសេនាធិការ និង សេចក្តីណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

[1207] កថាខណ្ឌ ៨១ នៃដីកាសន្និដ្ឋានស្តាពរ។

[1208] ជើងទំព័រ ២៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[1209] *សូមមើល* កថាខណ្ឌ ៥០៩ និង ៥៣៣-៣៤ *ខាងក្រោម* សម្រាប់ឧទាហរណ៍ផ្សេងទៀតនៃចម្លើយដែលមិនអាចគួរជឿជាក់របស់សាក្សី អ៊ូ ដាវ។

[1210] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ូ ដាវ ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D11/340 EN 01210462 KH 00990269។ *សូមមើល* កថាខណ្ឌ ១៤២ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[1211] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.៥៨, ឆ.៨៥, ឆ.១៦១។

[1212] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ឆ.៣៤។

[1213] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.៩១, ឆ.១៣៩-៤១។

មាស មុត បានទទួលបញ្ជាពីថ្នាក់លើ ប៉ុន្តែ ពេលខ្លះ មាស មុត បានចេញសេចក្តីសម្រេចដោយខ្លួនឯងផ្ទាល់[1214]។ អ៊ូ ដាវ បានត្រឹមតែធ្លាប់ឮការអះអាងអំពីតួនាទី និង សិទ្ធិអំណាចរបស់ មាស មុត តាមរយៈមេបញ្ជាការកងវរសេនាតូចរបស់គាត់ និង ទាហានផ្សេងទៀតនៅក្នុងអង្គភាពរបស់គាត់តែប៉ុណ្ណោះ[1215]។

៣៥៦. **នាក់ យឿន**៖ នាក់ យឿន មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់បានសំអាងលើការទាយស្មាន។ នាក់ យឿន គឺជាអ្នកកាន់កាំភ្លើងនៅលើកប៉ាល់ការពាររបស់កងវរសេនាធំលេខ ១៤០[1216]។ គាត់តែងតែធ្វើការនៅលើទូកជានិច្ច[1217]។ គាត់បាននិយាយថា មាស មុត នៅថ្នាក់កងពលធំ ដែលបានចេញបញ្ជាឱ្យមេបញ្ជាការកងវរសេនាតូចរបស់គាត់[1218]។ គាត់បាននិយាយពន្យល់ករណីនេះដូច្នេះថា "ការសម្រេចចិត្តទាំងអស់គឺចេញពីមេធំ" ហើយនៅក្នុងកងវរសេនាតូចរបស់គាត់ ហាន ដែលជាប្រធាន បានចេញសេចក្តីសម្រេច ហើយដំណើរការនេះអនុវត្តដូចគ្នានៅថ្នាក់កងពល[1219]។ គាត់បានទាយស្មានអំពីសកម្មភាពរបស់ មាស មុត ដោយផ្អែកលើដំណើរការនៅក្នុងកងវរសេនាតូចរបស់គាត់។ នាក់ យឿន មិនស្ថិតនៅក្នុងថ្នាក់កងពលធំនោះទេ ដូច្នេះ គាត់មិនអាចដឹងអំពីដំណើរការជាក់ស្តែងពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចនៅថ្នាក់នោះឡើយ។ ដូចនៅក្នុងអង្គភាពបក្សទាំងអស់ គណៈកម្មាធិការបានគ្រប់គ្រងលើកងពលធំលេខ ១៦៥[1220]។ ទាំង មាស មុត ទាំងសមាជិកគណៈកម្មាធិការផ្សេងទៀត មិនអាចចេញបញ្ជាដោយមិនបានទទួលបញ្ជាជាមុន ពីថ្នាក់លើផ្ទាល់របស់ពួកគេ គឺ សុន សេន ឬ គណៈកម្មាធិការយោធានោះឡើយ[1221]។

[1214] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.១៤០។

[1215] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ឆ.៨។

[1216] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/12 ឆ.៦-៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/11 ឆ.១០។

[1217] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/11 ឆ.៦, ឆ.១២។

[1218] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/12 ស-ឆ.២១។

[1219] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D114/12 ឆ.២២-២៣។

[1220] *សូមមើល* កថាខណ្ឌ ២១២ *ខាងលើ* ដែលពិភាក្សាអំពីគណៈកម្មាធិការកងពល ១៦៥។

[1221] *សូមមើល* កថាខណ្ឌ ២១១ និង ២១៣ *ខាងលើ* ដែលពិភាក្សាពីការចេញសេចក្តីណែនាំ និង បទបញ្ជាពីអគ្គសេនាធិការ និង គណៈកម្មាធិការអចិន្ត្រៃយ៍/គណៈកម្មាធិការយោធា។

៣៥៧. **អ៊ឹង ឆុន៖** អ៊ឹង ឆុន មិនអាចជឿជាក់បានឡើយ[1222]។ គាត់បានអះអាងថា មាស មុត បានចេញបញ្ជាឱ្យចាប់ទូកនេសាទខុសច្បាប់ ហើយមានម៉ាស៊ីនទូរលេខនៅកន្លែងគាត់ ដែលពីទីនោះ គាត់ចេញបញ្ជាឱ្យទៅអ្នកកាន់ទូរលេខនៅកំពង់ផែកោះកុង[1223]។ អ៊ឹង ឆុន បានផ្តល់ចម្លើយផ្ទុយគ្នានឹងចម្លើយរបស់គាត់ខ្លួនឯង[1224]។

ឃ. មាស មុត មិនបានចេញបញ្ជាឱ្យចល័តកងទ័ព រំសាយកងទ័ព ឬ ផ្ទេរកងទ័ព

៣៥៨. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចេញបញ្ជាឱ្យចល័តទីតាំង និង រំសាយកងទ័ព ព្រមទាំងផ្ទេរកងទ័ពនោះឡើយ[1225]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន ឬ គ្មានមូលដ្ឋានគាំទ្ររបស់ លៀត ឡុន លុន សេង មូល ឈិន និង អ៊ូ ដាវ[1226]។

៣៥៩. **លៀត ឡុន៖** លៀត ឡុន មិនអាចជឿជាក់បានឡើយ[1227]។ គាត់ក៏មិនគាំទ្រការអះអាងរបស់ ស.ព.អ. ដែរ។ នៅក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ គាត់បាននិយាយថា អង្គភាពរបស់គាត់ស្ថិតនៅក្រោមការបញ្ជារបស់ មាស មុត ហើយមួយថ្ងៃក្រោយពួកគេស្នាក់នៅរាម អង្គភាពរបស់គាត់ត្រូវបានបញ្ជូនទៅកោះសេះ[1228]។ គាត់មិនបាននិយាយថា មាស មុត បានចេញបញ្ជានោះទេ។ ព្រំ សារ៉ាត បាននិយាយថា សុន សេន បានចេញបញ្ជាឱ្យពង្រាយកងទ័ពទៅកាន់កងពលធំ ដែលបានផ្សព្វផ្សាយបញ្ជានេះបន្តទៅថ្នាក់ក្រោម[1229]។ ដំណើរការងារបែបនេះ អនុវត្តដូចគ្នាទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃនៅលើកោះ[1230]។

[1222] *សូមមើល* កថាខណ្ឌ ៣២៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1223] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ស-ឆ.១-២។

[1224] *សូមមើល* កថាខណ្ឌ ៣២៧ *ខាងលើ*។

[1225] កថាខណ្ឌ ៨១ នៃដីកាសន្និដ្ឋានស្តាពរ។

[1226] ជើងទំព័រ ២៤១-៤២ នៃដីកាសន្និដ្ឋានស្តាពរ។

[1227] *សូមមើល* កថាខណ្ឌ ២០១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1228] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/28 ឆ.១៤។ ជើងទំព័រ ២៤១ នៃដីកាសន្និដ្ឋានស្តាពរ។

[1229] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ឆ.៦៧-៧0, ឆ.១៦៦។

[1230] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ឆ.៧១-៧៤។

៣៦០. **លុន សេង**៖ លុន សេង មិនអាចជឿជាក់បានឡើយ[1231]។ គាត់បានទាយស្មានអំពីសេចក្តីសម្រេចឱ្យបញ្ជូនកងទ័ពទៅអង្គភាពផលិត។ គាត់ "មិនប្រាកដ" ថា នរណាជាអ្នកចេញសេចក្តីសម្រេច ប៉ុន្តែ "គិត" ថា មាស មុត ជាអ្នកចេញសេចក្តីសម្រេចនោះ[1232]។

៣៦១. **ម្ងូល ឈិន**៖ ម្ងូល ឈិន មិនអាចជឿជាក់បានឡើយ។ ការអះអាងរបស់គាត់អំពី មាស មុត គឺផ្អែកលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ គាត់គឺជាយុទ្ធជនសាមញ្ញម្នាក់នៅក្នុងកងវរសេនាតូច លេខ ៣៨៦ ដែលឈរជើងលើកោះចំនួនពីរ[1233] រហូតដល់ពេលអង្គភាពរបស់គាត់ត្រូវបានបញ្ជូនទៅកងផលិត[1234]។ គាត់មិនដែលបានជួប ឬ ឃើញ មាស មុត ឡើយ[1235]។ គាត់បាននិយាយថា មនុស្សរបស់ មាស មុត បានប្រមូលអង្គភាពរបស់គាត់ទៅប្រជុំ ហើយបានប្រាប់ពួកគេថា ពួកគេនឹងត្រូវបញ្ជូនទៅការដ្ឋានផ្សេងៗ[1236]។ គាត់បានទាយស្មានថា មាស មុត បានចេញបញ្ជាឱ្យរំសាយកងទ័ពនេះ[1237]។ ដំបូង គាត់បាននិយាយថា "មានការប្រជុំធំមួយ" ដែលពួកគេត្រូវតែទៅប្រជុំ[1238]។ បន្ទាប់មក គាត់បាននិយាយថា កិច្ចប្រជុំនោះមានការចូលរួមតែពីសំណាក់មេបញ្ជាការកងវរសេនាតូច និង មេបញ្ជាការកងវរសេនាធំប៉ុណ្ណោះ[1239]។ ក្នុងនាមជាយុទ្ធជនសាមញ្ញម្នាក់ដែលមិនធ្លាប់បានជួប ឬ ឃើញ មាស មុត[1240] គាត់ត្រឹមតែធ្លាប់បានឮពីមេរបស់គាត់ថា "ថ្នាក់លើ" បានចេញបញ្ជាប៉ុណ្ណោះ[1241]។ គាត់បានសន្និដ្ឋានថា "ថ្នាក់លើ" មានន័យថា តា ម៉ុក និង មាស មុត ដោយសំអាងលើ "ការយល់ដឹង និង ការវិភាគ" របស់គាត់[1242]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភស្តុតាងដល់ចម្លើយរបស់ ម្ងូល ឈិន មែននោះ ស.ច.ស. ត្រូវពិចារណាថា ការដែលគាត់បាន

[1231] *សូមមើល* កថាខណ្ឌ ១៩៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1232] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/45 ស-អ.១៥។

[1233] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.១៩, អ.២២-២៣។

[1234] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៨៩។

[1235] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៨៦, អ.៨៨។

[1236] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៩៣។

[1237] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ស-អ.៩៣។

[1238] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៩៥។

[1239] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៩៦។

[1240] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៨៦, អ.៨៨។

[1241] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៩៥-៩៧។

[1242] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៩៨។

និយាយថា តា ម៉ុក បានចូលរួមនៅក្នុងកិច្ចប្រជុំរំសាយកងទ័ពជាមួយ មាស មុត[1243] បង្ហាញឱ្យឃើញថា តា ម៉ុក មានសិទ្ធិអំណាចលើកងពលធំលេខ ១៦៥[1244]។

៣៦២. **អ៊ូ ដាវ៖** អ៊ូ ដាវ មិនអាចជឿជាក់បានឡើយ[1245]។ គាត់ក៏មិនគាំទ្រការអះអាងរបស់ ស.ព.អ. ដែរ។ គាត់បាននិយាយថា ក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ស៊ូ ម៉ែត មាស មុត និង តាម៉ុក បានបញ្ជូនកងវរសេនាតូចរបស់គាត់ទៅកំពង់សោម នៅទីនោះ គាត់បានចូលជាមួយនឹងកងទ័ពជើងទឹកក្រោមបញ្ជាការរបស់ មាស មុត[1246]។ អ៊ូ ដាវ បានសំដៅលើព្រឹត្តិការណ៍មួយ ដែលគាត់បានអះអាងថាបានកើតឡើងភ្លាមៗក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ នៅមុនពេលកងពលធំលេខ ១៦៥ ត្រូវបានបង្កើតឡើង[1247]។ ការអះអាងរបស់គាត់មិនពាក់ព័ន្ធនឹងសិទ្ធិអំណាច ដែលបានអះអាងថា មាស មុត មានលើកងពលធំលេខ ១៦៥ នោះទេ។ តាម៉ុក និង សុន សេន មានសិទ្ធិអំណាចក្នុងការពង្រាយកងទ័ពនៃកងពលធំលេខ ៣ និង បានបញ្ជាឱ្យមានការពង្រាយកងទ័ពនេះ[1248]។

[1243] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ន.៩៦។

[1244] *សូមមើល* កថាខណ្ឌ ១៦៩-៧0 និង ១៧២ *ខាងលើ* ទាក់ទងនឹងអំណាចរបស់តាម៉ុកលើបញ្ហាយោធា។

[1245] *សូមមើល* កថាខណ្ឌ ៣៥៥ *ខាងលើ* និង កថាខណ្ឌ ៥០៩ និង ៥៣៣-៣៤ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1246] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ន.៤២។

[1247] កងពលលេខ ១៦៥ ហាក់ដូចជាត្រូវបានបង្កើតឡើងនៅពាក់កណ្តាលចុងឆ្នាំ ១៩៧៥។ *សូមមើល* កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183394 KH 00019110 (បញ្ជាក់ថាការការពារប្រទេសចាត់ចែងតាមមជ្ឈិម) EN 00183396-00183397 KH 00019113-00019115 (ពិភាក្សាពីការរៀបចំសេនាធិការ និង ការរៀបចំ ក.ប.ក.) EN 00183402 KH 00019120 (ប៉ុល ពត ចេញសេចក្តីណែនាំសម្រាប់ការចាត់តាំងគណៈកម្មាធិការសេនាធិការ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ន.៨១ (ឆ្លើយថា ប៉ុល ពត បញ្ជាឱ្យបង្កើតកងទ័ពជើងទឹក) ។ ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខ ៨ ខែសីហា ឆ្នាំ ១៩៧៥ ឯកសារ D4.1.861 EN 00401488 KH 00063324 (ទាក់ទងនឹងសន្និបាតដែលប្រព្រឹត្តទៅនៅខែកក្កដា ឆ្នាំ ១៩៧៥ ដែលរៀបចំដោយមជ្ឈិម ក្នុងពិធីចាត់តាំង ក.ប.ក.)។

[1248] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/132 ន.២១ (ការបញ្ជាកងពលលេខ ៣ ទៅកាន់កំពង់សោម គឺមកពីថ្នាក់ខ្ពស់ជាងកងពល ដោយសារតែបញ្ជូនកងពលទាំងមូល)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ន.៩ ន.២៧ (តាម៉ុកទទួលខុសត្រូវលើយោធាទាំងអស់នៅភូមិភាគនិរតី ហើយកងពលលេខ ៣ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ន.៦៧-៧0, ន.១៦៦ (សុន សេន បានបញ្ជាការដាក់ពង្រាយកងទ័ពទៅតាមកោះ)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៥

ង. មាស មុត មិនបានចេញបញ្ជាទាក់ទងនឹងការចាប់ខ្លួន

៣៦៣. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចេញបញ្ជាឱ្យចាប់ខ្លួននោះឡើយ[1249]។ ស.ព.អ. ដកស្រង់ចម្លើយដែលមិនអាចជឿជាក់បាន និងមិនមានមូលដ្ឋានគាំទ្ររបស់ អ៊ូ ដាវ ជេត ប៊ុណ្ណា ឌុល សេង លុន សេង និង ស៊ឹម នី[1250]។ គាត់មិនបានពិចារណាលើភ័ស្តុតាងដែលបង្ហាញថា សុន សេន និង គណៈកម្មាធិការអចិន្ត្រៃយ៍/គណៈកម្មាធិការមជ្ឈិម បានបញ្ជាឱ្យមានការចាប់ខ្លួន[1251]។

៣៦៤. **អ៊ូ ដាវ៖** អ៊ូ ដាវ មិនអាចជឿជាក់បានឡើយ[1252]។ គាត់បាននិយាយថា នៅដើមឆ្នាំ ១៩៧៦ "អង្គការ" បានចាប់ខ្លួនមេបញ្ជាការកងវរសេនាតូចចំនួនបីនាក់ និង ទាហានផ្សេងទៀត រួមទាំងគាត់ផងដែរ[1253]។ គាត់មិនបាននិយាយថា មាស មុត បានបញ្ជាឱ្យមានការចាប់ខ្លួននោះឡើយ។ ការអះអាងណាមួយអំពីការដឹងឮពីសិទ្ធិអំណាចរបស់ មាស មុត ក្នុងការចេញបញ្ជានោះ គឺផ្អែកលើពាក្យចចាមអារ៉ាម[1254]។

ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឧ.២៤ (តាម៉ុក មានតួនាទីជាអគ្គបញ្ជាការកងទ័ពទាំងបីប្រភេទ ហើយមានអំណាចខ្ពស់ជាង សុន សេន)។

[1249] កថាខណ្ឌ ៨១ នៃដីកាសន្និដ្ឋានស្តាពរ។

[1250] ជើងទំព័រ ២៤៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1251] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.4 EN 00198219 KH 00197969-00197970។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364072 KH 00357493។ *សូមមើល* កថាខណ្ឌ ១៦៩ និង ១៧១-៧២ *ខាងលើ* ទាក់ទងនឹងសិទ្ធិ និង អំណាចរបស់សុន សេន និង គណៈកម្មាធិការអចិន្ត្រៃយ៍/គណៈគណកម្មាធិការមជ្ឈិម។

[1252] *សូមមើល* កថាខណ្ឌ ៣៥៥ *ខាងលើ* និង កថាខណ្ឌ ៥០៩ និង ៥៣៣-៣៤ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1253] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឧ.៤២។ ជើងទំព័រ ២៤៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1254] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/25 ឧ.៨។

៣៦៥. **ជេត ប៊ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[1255]។ ពាក់ព័ន្ធនឹងការចាប់ខ្លួន អ៊ឹង វេត ជេត ប៊ុណ្ណា បានថ្លែងថា "ពួកគេត្រូវចាប់ អ៊ឹង វេត" ហើយ មាស មុត បានប្រកាសការចាប់ខ្លួនជាសាធារណៈ[1256]។ គាត់មិនបាននិយាយថា មាស មុត បានចេញបញ្ជាឱ្យចាប់ខ្លួននោះទេ។

៣៦៦. **ឌុល សុង**៖ ឌុល សុង មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់មានមូលដ្ឋានលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ គាត់បាននិយាយថា មាស មុត បានទទួលខុសត្រូវលើការសម្រេចថាតើត្រូវចាប់ខ្លួនអ្នកដែលមានកំហុសឬយ៉ាងណា[1257]។ ឌុល សុង គ្រាន់តែបានឮអំពីការចាប់ខ្លួនពីប្រធានកងវរសេនាតូចរបស់គាត់ប៉ុណ្ណោះ[1258]។ គាត់បាននិយាយថា គ្មាននរណាដឹងថាគេមកពីណាមកចាប់នរណានោះឡើយ[1259]។ ឌុល សុង បានទាយស្មានថា មាស មុត បានទទួលខុសត្រូវលើការសម្រេចចាប់មនុស្សដោយសារតែ មាស មុត មានសិទ្ធិបញ្ជាលើកងពលធំខាងជើងទឹក។ តាមពិត គាត់មិនបានដឹងថាករណីនេះពិតជាកើតមានមែនឬយ៉ាងណាឡើយ[1260]។

៣៦៧. **លុន សេង**៖ លុន សេង មិនអាចជឿជាក់បានឡើយ[1261]។ គាត់បាននិយាយថា គាត់បានចូលរួមប្រជុំដែលនៅពេលនោះ មាស មុត បានប្រកាសថា កម្មាភិបាលភូមិភាគបូព៌ាចំនួន ១៥០០ នាក់ត្រូវរំសាយដោយសារពួកគេគឺជាសមាសភាពមិនល្អ[1262]។ គាត់បាននិយាយថា មានតែ មាស មុត ប៉ុណ្ណោះដែលមានសិទ្ធិអំណាចបញ្ជូនកម្មាភិបាលទៅកងផលិត[1263]។ គាត់បានទាយស្មាន[1264]។ ស.ព.អ. មិនអើពើនឹងការទាយស្មានរបស់ លុន សេង។

[1255] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1256] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/85 អ.១៩-២០។ ជើងទំព័រ ២៤៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1257] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/7 អ.១៦។ ជើងទំព័រ ២៤៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1258] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ស-អ.៩។

[1259] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 អ.១៣។

[1260] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/7 អ.១៦-១៧។

[1261] *សូមមើល* កថាខណ្ឌ ១៩៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1262] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/44 ស-អ.១៩, ស-អ.២២។ ជើងទំព័រ ២៤៤ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ២៦៨៦-៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1263] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/45 អ.១៦។

[1264] *សូមមើល* កថាខណ្ឌ ៣៦០ *ខាងលើ*។

៣៦៨. **ស៊ឹម នី៖** ស៊ឹម នី មិនអាចជឿជាក់បានឡើយ[1265]។ គាត់បានអះអាងថា មាស មុត បានទទួលខុសត្រូវលើការសួរចម្លើយ និង សេចក្តីសម្រេចថាតើនរណាចូល និង ចេញពីវត្តឥន្ទញ្ញាណ[1266]។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នាយ៉ាងខ្លាំងអំពី មាស មុត និង វត្តឥន្ទញ្ញាណ[1267]។

៣៦៩. ស.ព.អ. អះអាងថា មាស មុត បានរៀបចំកិច្ចប្រជុំ ដែលនៅពេលនោះគាត់បានប្រកាសអំពីការបោសសម្អាតសមាជិកជាន់ខ្ពស់នៃកងពលធំលេខ ១៦៤ អានចម្លើយសារភាពរបស់អ្នកត្រូវបានគេចាប់ខ្លួនឱ្យកងទ័ពស្តាប់ និង ប្រាប់អ្នកចូលរួមថា មានខ្មាំងនៅក្នុងជួរ[1268]។ ស.ព.អ. មិនអើពើនឹងបរិបទនៃកិច្ចប្រជុំបែបនេះ ហើយនឹងតួនាទីរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ។ កងពលធំលេខ ១៦៤ ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់មជ្ឈិមបក្ស រួមទាំង បញ្ហានានាដែលពាក់ព័ន្ធនឹងការចាប់ខ្លួន និង ការបោសសម្អាត[1269]។ ឡុញ ដុស[1270] និង ឌុច[1271] បាននិយាយថា សេចក្តីសម្រេចឱ្យចាប់ខ្លួនកម្មាភិបាលដែលត្រូវបានគេឆ្កើយដាក់ ត្រូវមានការយល់ព្រមពី សុន សេន និង គណៈកម្មាធិការមជ្ឈិម[1272]។

ច. មាស មុត មិនបានចេញបញ្ជាទាក់ទងនឹងការកាប់សម្លាប់

៣៧០. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចេញបញ្ជាឱ្យកាប់សម្លាប់នោះឡើយ[1273]។ ស.ព.អ. ដកស្រង់ចម្លើយមិនអាចឱ្យជឿជាក់បានរបស់ពេជ្រ ជឹម ប៉ាក សុខ មាស វឿន និង ស៊ន សុត[1274]។

[1265] *សូមមើល* កថាខណ្ឌ ២៤៥ *ខាងលើ* និង កថាខណ្ឌ ៤០៦-០៨ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1266] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ឯកសារ D59/2/2.16a EN 01332607 KH 00735601។ ជើងទំព័រ ២៤៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1267] *សូមមើល* កថាខណ្ឌ ៤០៦-០៨ *ខាងក្រោម*។

[1268] កថាខណ្ឌ ១០៧-១០ នៃដីកាសន្និដ្ឋានស្តាពរ។

[1269] *សូមមើល* កថាខណ្ឌ ២១១ *ខាងលើ* ទាក់ទងនឹងការត្រួតត្រារបស់បក្សលើកងពលមជ្ឈិម។

[1270] *សូមមើល* កថាខណ្ឌ ១៩៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1271] *សូមមើល* កថាខណ្ឌ ១៧៥-៧៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1272] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ឯកសារ D4.1.855 EN 00364072 KH 00357493។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.4 EN 00198219 KH 00197969-00197970។

[1273] កថាខណ្ឌ ៨១ នៃដីកាសន្និដ្ឋានស្តាពរ។

៣៧១. **ពេជ្រ ជឹម**៖ ភ័ស្តុតាងរបស់ ពេជ្រ ជឹម គឺមិនពាក់ព័ន្ធនោះឡើយ។ វាស្ថិតនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.។ ពេជ្រ ជឹម មិនមែនជាសមាជិកកងពលធំលេខ ១៦៥ ឬ នៅកំពង់សោមឡើយ។ គាត់គឺជាលេខាស្តីទីស្រុក ១០៥ នៅភូមិភាគបស្ចិម រហូតដល់ឆ្នាំ ១៩៧៧ នៅពេលគាត់ក្លាយជាប្រធានចម្ការកៅស៊ូភូមិភាគមជ្ឈិម[1275]។ គាត់បានអះអាងថា នៅក្នុងឆ្នាំ ១៩៧៤ តាម៉ុក បានស្តីបន្ទោស មាស មុត ដែលបានចេញបញ្ជាឱ្យសម្លាប់អ្នកយាមឃ្លាំងគ្រាប់ម្នាក់[1276]។ ហេតុការណ៍ដែលបានលើកឡើងនេះកើតឡើង នៅមុនយុត្តាធិការពេលវេលានៃ អ.វ.ត.ក. ហើយគ្មានពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ មាស មុត នៅក្នុងការចេញបញ្ជាឱ្យកាប់សម្លាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះឡើយ ហេតុដូច្នេះ ត្រូវតែច្រានចោល។

៣៧២. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1277]។ គាត់បានអះអាងអំពីការកាប់សម្លាប់ប្រជាជន ១៧ មេសា ដែលបានកើតឡើងនៅទីតាំងមួយក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៥[1278]។ គាត់បានជឿជាក់ថា កងពលធំលេខ ១៦៥ បានធ្វើការកាប់សម្លាប់ ពីព្រោះការកាប់សម្លាប់នេះ បានកើតឡើងនៅក្នុងតំបន់មួយ ដែលគាត់បាននិយាយថា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត[1279]។ គាត់មិនដែលធ្លាប់បានទៅទីតាំងនោះទេ[1280]។ ប៉ាក សុខ មិនបាននិយាយថា មាស មុត បានបញ្ជាឱ្យមានការកាប់សម្លាប់នោះទេ។ គាត់គ្រាន់តែបានទាយស្មានថា ប្រជាជនមកពីកងពលធំលេខ ១៦៥ បានធ្វើការកាប់សម្លាប់ប៉ុណ្ណោះ។

៣៧៣. **មាស វឿន**៖ មាស វឿន មិនអាចជឿជាក់បានឡើយ[1281]។ គាត់បានអះអាងថា ឡូញ បានរួចផុតពីការប៉ុនប៉ងសម្លាប់ដែល មាស មុត បានបញ្ជានៅចុងឆ្នាំ ១៩៧៨ ឬដើមឆ្នាំ ១៩៧៩[1282]។ មាស វឿន

[1274] ជើងចំពរ ២៤៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1275] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D4.1.783 EN 00379171 KH 00373459។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D64.1.50 អ.១។

[1276] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D4.1.786 EN 00381027-00381028 KH 00373477-00373478។ ជើងចំពរ ២៤៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1277] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1278] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/26 អ.២៦-២៧, អ.៣០។ ជើងចំពរ ២៤៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1279] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/26 ស-អ.៣0។

[1280] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/26 ស-អ.៣១។

[1281] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

បានឮរឿងរ៉ាវនេះពីនិរសារម្នាក់របស់ ឡូញ ក្រោយនិរសារនោះបានវិលត្រឡប់មកពីប្រទេសថៃវិញ[1283]។ គ្មានភ័ស្តុតាងចង្អុលបង្ហាញថាតើឆ្នាំណាដែល មាស រឿន បានឮរឿងរ៉ាវនេះនោះឡើយ។ តាមដែលមេធាវីការពារក្តីដឹងច្បាស់ រឿងរ៉ាវនេះមិនស៊ីចង្វាក់គ្នាជាមួយនឹងភ័ស្តុតាងផ្សេងទៀតនោះទេ។

៣៧៤. **ស៊ិន សុត**៖ ស៊ិន សុត មិនអាចជឿជាក់បានឡើយ[1284]។ គាត់បានអះអាងថា មេបញ្ជាការទាំងអស់ត្រូវបានចាប់ខ្លួនក្រោយកម្មាភិបាលតំបន់ ៣៧ ត្រូវបានចោទប្រកាន់ថាជាជនក្បត់។ ក្រុមរបស់គាត់ត្រូវបានរំលាយចោល ហើយបញ្ជូនទៅធ្វើស្រែ។ ជាទូទៅ មាស មុត បានចេញបញ្ជា ហើយមនុស្សរបស់គាត់ជាអ្នកធ្វើការចាប់ខ្លួន[1285]។ គាត់បានអះអាងថា អ្នកដែលមិនព្រមធ្វើតាមបញ្ជា មាស មុត នឹងត្រូវសម្លាប់ចោល[1286]។ ស៊ិន សុត បានទាយស្មានអំពីសិទ្ធិអំណាចរបស់ មាស មុត និង ការចូលរួមរបស់ មាស មុត នៅក្នុងបញ្ហាទាំងនេះ[1287]។

ឆ. មាស មុត មិនបានចេញបញ្ជាទាក់ទងនឹងការបង្កបង្កើនផលកសិកម្ម

៣៧៥. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចេញបញ្ជាឱ្យធ្វើការបង្កបង្កើនផលកសិកម្មនោះទេ[1288]។ ស.ព.អ. ដកស្រង់ចម្លើយដែលមិនអាចឱ្យជឿជាក់បាន ឬ ដែលមិនមានមូលដ្ឋានសំអាងរបស់ មាស អ៊ឹម នាក់ ស៊ីថា និង យិន តេង[1289]។

៣៧៦. **មាស អ៊ឹម**៖ មាស អ៊ឹម មិនអាចជឿជាក់បានឡើយ[1290]។ គាត់ក៏មិនគាំទ្រការអះអាងរបស់ ស.ព.អ. ដែរ។ គាត់បាននិយាយថា មាស មុត បានចេញបញ្ជាឱ្យធ្វើការសាងសង់ផ្លូវ មិនមែនឱ្យធ្វើការបង្ក

[1282] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/56 EN 00973406 KH 01001517។ ជើងទំព័រ ២៤៥, ៣៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[1283] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/53 ស-អ.២៩។

[1284] *សូមមើល* កថាខណ្ឌ ៣៤២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1285] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ឆ.៥, ឆ.៧០។ ជើងទំព័រ ២៤៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1286] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ឯកសារ D114/194 ឆ.៥, ឆ.៧០។

[1287] *សូមមើល* កថាខណ្ឌ ៣៤២ *ខាងលើ*។

[1288] កថាខណ្ឌ ៨១ នៃដីកាសន្និដ្ឋានស្តាពរ។

[1289] ជើងទំព័រ ២៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1290] *សូមមើល* កថាខណ្ឌ ២៥៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

បង្កើនផលកសិកម្មនោះទេ[1291]។ គាត់ក៏បានឆ្លើយផ្ទុយនឹងចម្លើយខ្លួនឯងផងដែរ។ ដំបូង គាត់បាននិយាយថា គាត់មិនបានដឹងអំពីការណែនាំពី មាស មុត ទៅឱ្យ ម៉ៀញ នោះទេ[1292] ប៉ុន្តែ បន្ទាប់មក គាត់បាននិយាយថា ពួកគេបានឆ្លើយឆ្លងដោយមធ្យោបាយតេអូ ហើយនិងទូរលេខ[1293]។

៣៧៧. **នាក់ ស៊ីថា**៖ នាក់ ស៊ីថា មិនអាចជឿជាក់បានឡើយ។ ការអះអាងរបស់គាត់អំពី មាស មុត គឺផ្អែកលើពាក្យចចាមអារ៉ាម ហើយមិនឃើញមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នោះឡើយ។ គាត់គឺជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលបានធ្វើការងារនៅក្នុងសហករណ៍នៅក្នុងតំបន់ ៣៥ ស្រុកព្រៃនប់ និង នៅកោះស្ពាក្នុងខេត្តកំពត[1294]។ គាត់បាននិយាយថា គាត់បានឮថា មាស មុត និយាយថាពួកគេត្រូវធ្វើការ[1295]។ ក្រោយមក គាត់បាននិយាយថា គាត់បានឮករណីនេះពីអ្នកផ្សេង[1296]។ គាត់បាននិយាយថា មាស មុត គឺជាប្រធានដោយបានពិពណ៌នាថា គាត់គឺជាមេបញ្ជាការតំបន់ផ្តាច់ការម្នាក់នៅព្រៃនប់ និង កន្លែងផ្សេងទៀតដែលគាត់បានធ្វើការ[1297]។ ទោះបីជាបានឆ្លើយចម្លើយទាំងនេះក៏ដោយ ក៏គាត់មិនបាននិយាយពីឈ្មោះ មាស មុត នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នោះទេ[1298]។ គាត់បានអះអាងថា ការមិនបានលើកឈ្មោះមកនិយាយនេះ គឺដោយសារព្រឹត្តិការណ៍ទាំងនោះបានកើតឡើងក្នុងរយៈពេល ២០ ទៅ ៣០ ឆ្នាំមកហើយ ហើយនៅពេលគាត់បានសរសេរពាក្យសុំរបស់គាត់ គាត់បានភ្លេចចំណុចនេះ[1299]។ លើសពីនេះទៀត គាត់មិនបានរស់នៅ ឬ ធ្វើការងារនៅកន្លែងក្រោម

[1291] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ស-អ.៧០។

[1292] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 អ.៦៧។

[1293] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ស-អ.៧៥។

[1294] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នាក់ ស៊ីថា ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D114/175 អ.១៧, អ.៤៤, អ.៤៦។

[1295] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នាក់ ស៊ីថា ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D114/175 អ.៤៨, អ.៥២។

[1296] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នាក់ ស៊ីថា ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/175 អ.៥៥-៥៦។

[1297] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នាក់ ស៊ីថា ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/175 អ.៥0-៥៣។ ជើងទំព័រ ២៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1298] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នាក់ ស៊ីថា ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D11/374។

[1299] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នាក់ ស៊ីថា ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D114/175 ស-អ.៤៩។

ការគ្រប់គ្រងរបស់គណៈកម្មាធិការកងពលធំលេខ ១៦៤ ឬ គណៈកម្មាធិការតំបន់ស្វយ័តកំពង់សោមនោះទេ។ តំបន់ ៣៥ ស្ថិតនៅក្នុងខេត្តតាកែវ និង កំពត[1300]។ កន្លែងខ្លះនៅក្នុងស្រុកព្រៃនប់ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់កងពលធំលេខ ១[1301]។

៣៧៨. **យិន តេង**៖ យិន តេង មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នាជាច្រើនអំពី មាស មុត និង គ្រួសាររបស់គាត់នៅក្នុងអំឡុងពេលសម្ភាសគាត់។ គាត់ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលបានរស់នៅក្នុងសហករណ៍ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[1302]។ ស.ព.អ. ដកស្រង់សម្តី យិន តេង ដើម្បីជាមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថាឈ្មោះរបស់ មាស មុត ត្រូវយកមកប្រើជាញឹកញាប់ដោយមេដឹកនាំ នៅពេលពិភាក្សាអំពីការងារដែលត្រូវធ្វើនៅការដ្ឋានរាម[1303]។ ស.ព.អ. មិនអើពើនឹងចម្លើយផ្ទុយគ្នារបស់ យិន តេង អំពី មាស មុត នោះឡើយ។ យិន តេង បាននិយាយថា តាមគាត់ដឹង ប្រធានភូមិបានជួប មាស មុត នៅ

[1300] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 EN 01333468 KH 01301431 (នៅក្នុងនោះ អ្នកស៊ើបសួររបស់ ក.ស.ច.ស. លោក Thomas Kuehnel បានជូនដំណឹងសាក្សីថា *ក្នុងចំណោមនោះ* តំបន់ ៣៥ ខេត្តកំពត)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កឹម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 ឧ.៦២។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 ស-ឧ.១២០ (ឆ្លើយថា ទាហានតំបន់ ៣៥ មកពីភូមិភាគនិរតី)។

[1301] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉េន ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/155 ឧ.១៣-១៤, ឧ.២៦ (តានែ ខាងព្រៃនប់ ចំណុះឱ្យកងពល ១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សម្បត្តិ ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៤ ឯកសារ D54/114 ឧ.១០, ឧ.១៥ (ភូមិបបុស ខាងព្រៃនប់ ស្ថិតក្រោមការគ្រប់គ្រងរបស់ សឿង មេបញ្ជាការកងពល ១)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/84 ឧ.៦។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ប្រតិចារឹកចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.21.54-10.24.36 (មាស រឿន ឆ្លើយថា ទីស្នាក់ការរបស់តាសឿង នៅព្រៃនប់)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយ ហែម អាង ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/33 ឧ.១០, ឧ.៣៩-៤១, ឧ.១០៩ (គាត់នៅក្នុងតំបន់ ៣៧ ហើយនៅដើមឆ្នាំ ១៩៧៦ បានចូលរួមប្រជុំមួយនៅវត្តព្រៃនប់ ដឹកនាំដោយតាម៉ុក ដែលជាកម្មាភិបាលជាន់ខ្ពស់នៅទីនោះ) ស-ឧ.១០៧ (គាត់មិនដែលធ្លាប់ឮឈ្មោះ មាស មុតទេ)។

[1302] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ឧ.៤, ឧ.២០។ *សូមមើល* កថាខណ្ឌ ១៤២ *ខាងលើ* ទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[1303] កថាខណ្ឌ ៦៦៦ ជើងទំព័រ ២៦៨៩-៩០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៩២ ជើងទំព័រ ៥២៣។

រៀងរាល់ព្រឹក[1304]។ ក្រោយមក គាត់បាននិយាយថា យោងតាមប្រធានភូមិ ពួកគេបានជួបគ្នាមួយខែម្តង[1305]។ គាត់បាននិយាយថា ប្រធានភូមិមិនបាននិយាយពី មាស មុត នៅក្នុងកិច្ចប្រជុំនោះទេ[1306]។ ក្រោយមក គាត់បាននិយាយថា មាស មុត ត្រូវបានគេលើកឡើងជារៀងរាល់មួយ ឬ ពីរសប្តាហ៍ម្តង នៅក្នុងកិច្ចប្រជុំសហការណ៍ប្រចាំថ្ងៃ ហើយថាប្រធានភូមិតែងតែនិយាយថា បញ្ហារបស់គាត់ត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងមានរឿងកើតឡើង[1307]។

៣៧៩. យិន តេង ក៏បានឆ្លើយផ្ទុយនឹងចម្លើយខ្លួនឯងពាក់ព័ន្ធនឹងគ្រួសាររបស់គាត់ផងដែរ។ គាត់បាននិយាយថា គាត់បានរៀបការនៅក្នុងឆ្នាំ ១៩៨២[1308] ប៉ុន្តែ បានដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយសារប្តីរបស់គាត់បានស្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[1309]។ បន្ទាប់មក គាត់បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា គាត់មិនចាំថា នៅពេលណាគាត់បានរៀបការនោះទេ[1310]។ គាត់បានប្រាប់អ្នកស៊ើបអង្កេតថា គាត់ និង ប្តីគាត់មានកូនបីនាក់ កូនបងគេបង្អស់បានស្លាប់ ចំណែកកូនពីរនាក់ទៀតនៅរស់នៅឡើយ[1311]។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ គាត់បានបង្ហាញថា គាត់មានកូនពីរនាក់ ដែលកូនទាំងពីរនាក់នោះបានស្លាប់អស់ហើយ[1312]។ គាត់បាននិយាយថា កូនប្រុសបងគេរបស់គាត់មានអាយុ ១០ ឆ្នាំ នៅពេលកូន

[1304] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 អ.៣១។ ជើងទំព័រ ២៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1305] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 អ.៣៤។

[1306] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ស-អ.៣៥, ស-អ.១១៤ (នៅក្នុងករណីទាំងពីរនេះ គាត់បានពិភាក្សាពីការប្រជុំប្រចាំថ្ងៃ ដែលធ្វើឡើងនៅភូមិថ្មធំ និង ភូមិពូធឿង)។

[1307] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 អ.១៥៣-៥៤។ *សូមមើល* ជើងទំព័រ ២៦៨-៩០ នៃដីកាសន្និដ្ឋានស្តាពរ។

[1308] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ឯកសារ D114/6 អ.២។

[1309] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ស-អ.៤ (នៅក្នុងនោះគាត់សុំទោសដោយសារតែភ្លេចហើយ បន្ទាប់ពីលោក Philip Weiner រំឭកប្រាប់គាត់ថា នៅក្នុងទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ គាត់បានសរសេរថា គាត់បានរៀបការនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០)។

[1310] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ឯកសារ D114/6 ស-អ.៤។

[1311] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 អ.៥។ នៅក្នុង អ.២០ ឆ្លើយថាមានកូនបីនាក់។

[1312] សេចក្តីសង្ខេបពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី យិន តេង ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D114/28.1.2 EN 00445741។ គាត់ក៏បាននិយាយផងដែរថា គាត់មានផ្ទៃពោះ ៦ ខែ។ *ដូចខាងលើ*។

នោះបានបាត់ខ្លួននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ កូនប្រុសកណ្តាលរបស់គាត់មានអាយុ ៧ ឆ្នាំ នៅពេលនោះ ហើយថា (នៅឆ្នាំ ២០១៤) កូនប្រុសកណ្តាល របស់គាត់មានអាយុ ៤០ ឆ្នាំ[1313]។ បើគិតតាមអាយុទាំងនេះ មានន័យថា នៅឆ្នាំ ២០១៤ កូនប្រុសបងគេរបស់គាត់មានអាយុ ៤៣ ឆ្នាំ។ ប្រសិនបើដូច្នេះមែន គាត់បានបាត់ខ្លួននៅប្រហែលឆ្នាំ ១៩៨១ ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ។

៣៨០. នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ យិន តេង បាននិយាយថា ប្តីរបស់គាត់បានជាប់ឃុំឃាំងម្តងនៅទឹកសាប ហើយក្រោយពេលដោះលែង គេបានចងគាត់នៅជុំវិញក ហើយអូសតាមឡានរហូតគាត់ស្លាប់ រួចទុកសាកសពចោលនៅជើងភ្នំ[1314]។ នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស. គាត់បាននិយាយថា ប្តីរបស់គាត់ជាប់ឃុំពីរដងនៅទឹកសាប[1315] ហើយត្រូវបានគេសម្លាប់ចោលនៅលើទូក និង ក្រោយពេលជាប់ឃុំឃាំងលើកទីមួយនៅទឹកសាប គាត់ត្រូវបានគេចង ឱ្យរត់តាមឡាន[1316]។ គាត់បាននិយាយថា ប្រធានភូមិ ពុត ធឿង បាននិយាយថា ប្តីរបស់គាត់ធ្វើការនៅក្នុងអង្គភាពកាំភ្លើងធំនៅទឹកសាប[1317] ប៉ុន្តែក្រោយមក គាត់បាននិយាយថា គេបានប្រាប់គាត់ថា ប្តីរបស់គាត់បានធ្វើការនៅក្នុងកងកាំភ្លើងធំឈរជើងនៅស្ទឹងហាវ[1318]។ គាត់ “បានបញ្ជាក់បំភ្លឺ” ថា ប្តីរបស់គាត់បានជាប់ឃុំឃាំងនៅទឹកសាប ហើយឈរជើងនៅស្ទឹងហាវ[1319]។ ចម្លើយផ្ទុយគ្នាជាច្រើននេះ ធ្វើឱ្យភ័ស្តុតាងរបស់យិន តេង មិនអាចជឿជាក់បាន។

ញ. សេចក្តីសន្និដ្ឋាន

៣៨១. មាស មុត មិនមានសិទ្ធិអំណាចតែម្នាក់ឯងលើកងពលធំលេខ ១៦៥ នោះទេ។ បញ្ជាទាំងឡាយដែលបានចេញទាក់ទងនឹងប្រតិបត្តិការយោធា ឃ្លាំមើល រំសាយកងទ័ព ឬ ផ្ទេរកងទ័ព ចាប់ខ្លួន និង កាប់សម្លាប់ ឬ បង្កបង្កើនផលកសិកម្ម ត្រូវបានធ្វើឡើងជាសមូហភាពដោយគណៈកម្មាធិការ

[1313] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ន.៩។

[1314] សេចក្តីសង្ខេបពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី យិន តេង ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D114/28.1.2 EN 00445741។

[1315] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ន.៥៧-៥៨។

[1316] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ន.១២១-២២។

[1317] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ន.២២។

[1318] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ន.១៣៨។

[1319] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ន.១៣៩។

កងពលធំលេខ ១៦៤។ ស.ព.អ. មិនអើពើនឹងតួនាទីមួយនេះរបស់គណៈកម្មាធិការកងពលធំលេខ ១៦៤។ គាត់ដកស្រង់ចម្លើយសាក្សីដែលមានចំណុចផ្ទុយគ្នា ឬ ចម្លើយដែលផ្អែកលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ គាត់មិនបានពិចារណាលើភ័ស្តុតាងបរិបទពាក់ព័ន្ធផ្សេងទៀត អំពីគណៈកម្មាធិការអចិន្ត្រៃយ៍ អគ្គសេនាធិការ និង អង្គភាពថ្នាក់ក្រោមៗ។ គាត់ខកខានមិនបានផ្តល់មូលដ្ឋានគាំទ្រការអះអាងរបស់គាត់។ បើទោះបីជា មាស មុត ពិតជាមានសិទ្ធិអំណាចផ្តាច់មុខលើកងពលធំលេខ ១៦៤ មែនក៏ដោយ ក៏សិទ្ធិអំណាចបែបនេះមិនអាចឱ្យគាត់ក្លាយជាបុគ្គលម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នោះដែរ។

៤. សិទ្ធិអំណាចលើតំបន់ស្វយ័តកំពង់សោមមិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត"

៣៨២. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានគ្រប់គ្រងកិច្ចការយោធា និង កិច្ចការស៊ីវិលនៅក្នុងតំបន់ស្វយ័តកំពង់សោមនោះទេ រួមទាំងសហការណ៍ស៊ីវិលផងដែរ[1320]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយមិនអាចជឿជាក់បានរបស់ ជេត ប៊ុណ្ណា សុក វណ្ណា ចេង ឡុង អ៊ូ ដាវ "សៀង" យ៉ែម សំអុន ម៊ឹង វេត ប៉ាក សុខ និង ឯក នី[1321]។ គាត់ក៏ដកស្រង់ផងដែរ នូវភ័ស្តុតាងឯកសារដែលមិនមានមូលដ្ឋានគាំទ្រ[1322]។ គាត់បង្ហាញភ័ស្តុតាងខុស។ គាត់មិនបានពិចារណាលើភ័ស្តុតាងដែលបង្ហាញថា ធុច វិន បានគ្រប់គ្រងផ្នែកស៊ីវិលនៅកំពង់សោម[1323] ហើយសហការណ៍ស៊ីវិលខ្លះស្ថិតនៅក្រោមសមត្ថកិច្ចរបស់កងពល

[1320] កថាខណ្ឌ ៧៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៧, កថាខណ្ឌ ២២០។

[1321] ជើងទំព័រ ២៣១-៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[1322] ជើងទំព័រ ២៣៣-៣៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1323] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 អ.៩, អ.១៥, អ.១៧, អ.៣៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 អ.១៨, អ.២០, អ.២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/234 អ.២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 អ.៥-៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 អ.៤0, អ.៥៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង វ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 អ.២៦, អ.២៨, អ.៣០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រៀង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 អ.១៩៩។ *សូមមើលផងដែរ* កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ូច កុយ ចុះថ្ងៃទី ១១-១២ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.1

ធំលេខ ១[1324]។ បើទោះបីជា មាស មុត បានគ្រប់គ្រងលើតំបន់ស្វយ័តកំពង់សោមទាំងស្រុងក៏ដោយ ក៏ដោយសារតែតំបន់នេះមានទីតាំងភូមិសាស្ត្រតូច សិទ្ធិអំណាចនេះមិនធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តឡើងនៅទូទាំងសម័យកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។

៣៨៣. **ជេត ប៊ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[1325]។ នៅក្រោយដើមឆ្នាំ ១៩៧៧ គាត់មិនបានដឹងអំពីកម្រិតថ្នាក់ដឹកនាំនោះទេ[1326]។ ទោះជាយ៉ាងនេះក្តី គាត់បានអះអាងថា មាស មុត បានគ្រប់គ្រងលើទឹកសាប រហូតដល់កងកេង រាម និង កំពង់សោម កោះទាំងអស់ និង បានមើលការខុសត្រូវលើសហករណ៍ស៊ីវិល[1327]។ ជេត ប៊ុណ្ណា មិនអាចដឹងលម្អិតអំពីវិសាលភាពនៃសិទ្ធិអំណាចរបស់ មាស មុត នោះឡើយ[1328]។

៣៨៤. **សុក វណ្ណា**៖ សុក វណ្ណា មិនអាចជឿជាក់បានឡើយ[1329]។ គាត់ "បានឮ" ថា មាស មុត មានសិទ្ធិអំណាចលើប្រធានសហករណ៍ និង ប្រធានឃុំ[1330]។

៣៨៥. **ចេង ឡុង**៖ ចេង ឡុង មិនអាចជឿជាក់បានឡើយ។ គាត់បានទាយស្មានដោយផ្អែកលើពាក្យចចាមអារ៉ាម។ គាត់គឺជាកសិករធ្វើការនៅក្នុងសហករណ៍។ អ្នកធ្វើការរួមជាមួយគាត់បាននិយាយថា មាស មុត នៅកំពង់សោម ហើយ "បានគ្រប់គ្រងលើយើងទាំងអស់គ្នា" ដែលមានន័យថា

EN 00217558។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទូច សៀលី ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៧ ឯកសារ D59/2/3.6a KH 00958669។ នៅពេលដែលមេធាវីការពារក្តីបានតវ៉ាជំទាស់ពីគុណភាពនៃបទសម្ភាសន៍ទាំងនេះ (*សូមមើល* កថាខណ្ឌ ១៤១-៤២ *ខាងលើ*) ប្រសិនបើ ក.ស.ច.ស. ពិចារណាលើប្រភេទនៃភស្តុតាងទាំងនេះ អាចគួរឱ្យជឿជាក់ និង មានសម្ពាងហេតុជាភស្តុតាងមែន ក.ស.ច.ស. ក៏គួរពិចារណាចម្លើយសាក្សីទាំងនេះដែរ។

[1324] *សូមមើលខុទ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សម្បត្តិ ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៤ ឯកសារ D54/114 អ.១០, អ.១៥(ភូមិបបុស ខាងព្រៃនប់ ស្ថិតក្រោមការគ្រប់គ្រងរបស់ សៀង មេបញ្ជាការកងពល ១)។

[1325] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1326] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 អ.១៩។

[1327] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 អ.៩-១០។ ជើងទំព័រ ២៣១-៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[1328] *សូមមើល* កថាខណ្ឌ ១៨៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1329] *សូមមើល* កថាខណ្ឌ ៣៤៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1330] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 អ.១៤-១៥។ ជើងទំព័រ ២៣១ នៃដីកាសន្និដ្ឋានស្តាពរ។

មាស មុត ក៏បានគ្រប់គ្រងលើតំបន់ផងដែរ[1331]។ ចេង ឡុង គ្រាន់តែបានជឿជាក់ថា ករណីនេះពិតដូច្នេះមែន ដោយផ្អែកតាមពាក្យចចាមអារ៉ាមនេះ។ ដោយសារតែមុខដំណែងរបស់គាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនអាចដឹងលម្អិតអំពីការគ្រប់គ្រង ឬ ការងាររដ្ឋបាលរបស់តំបន់ឡើយ[1332]។

៣៨៦. **អ៊ូ ដាវ**៖ អ៊ូ ដាវ មិនអាចជឿជាក់បានឡើយ[1333]។ គាត់បាននិយាយថា មាស មុត បានដឹកនាំបញ្ជាតំបន់កំពង់សោម[1334]។ ដំបូង គាត់បានប្រាប់ ក.ស.ច.ស. ថា គាត់ត្រឹមតែបានដឹងថា មាស មុត គឺជាមេបញ្ជាការកងទ័ពជើងទឹកប៉ុណ្ណោះ។ គាត់មិនបាននិយាយអំពីតួនាទីស៊ីវិលណាមួយនោះទេ[1335]។ ការដឹងឮរបស់គាត់អំពីសិទ្ធិអំណាចរបស់ មាស មុត នៅកំពង់សោម គឺផ្អែកលើពាក្យចចាមអារ៉ាម[1336]។

៣៨៧. **"សៀង"**៖ "សៀង" មិនអាចជឿជាក់បានឡើយ[1337]។ គាត់បានប្រាប់ ក.ស.ព. ថា មាស មុត បានគ្រប់គ្រងលើតំបន់កំពង់សោមទាំងមូល[1338]។ ដោយហេតុថា គាត់បានបដិសេធមិនផ្តល់សម្ភាសន៍ឱ្យ

[1331] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ឯកសារ D114/96 ឧ.១១, ឧ.១៣។

[1332] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតម្លៃភស្តុតាង។

[1333] *សូមមើល* កថាខណ្ឌ ៣៥៥ *ខាងលើ* និង កថាខណ្ឌ ៥០៩ និង ៥៣៣-៣៤ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1334] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ឧ.៨។ ជើងទំព័រ ២៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[1335] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឧ.៦៤។

[1336] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ឧ.៨។

[1337] *សូមមើល* កថាខណ្ឌ ២១៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1338] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ "សៀង" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៨ឯកសារ D1.3.13.11 EN 00217564។ ជើងទំព័រ ២៣១ នៃដីកាសន្និដ្ឋានស្តាពរ។

ក.ស.ច.ស.[1339] ចម្លើយរបស់គាត់មិនត្រូវបានដេញដោល ដោយភាគីដែលមិនមានប្រយោជន៍នៅក្នុងរឿងក្តីឡើយ។

៣៨៨. **យ៉ែម សំអុន**៖ យ៉ែម សំអុន មិនអាចជឿជាក់បានឡើយ។ គាត់ស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែក្នុងរយៈពេលមួយខ្លីប៉ុណ្ណោះ។ គាត់គឺជាប្រធានក្រុមនៅក្នុងជួរកងទ័ពជើងទឹក[1340]។ គាត់មិនបានធ្វើការផ្ទាល់ជាមួយនឹង មាស មុត នោះទេ[1341]។ គាត់បានផ្លាស់ទៅនៅប្រទេសចិននៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ១៩៧៦[1342] ហើយមិនបានវិលត្រលប់មកកម្ពុជាវិញទេរហូតដល់ឆ្នាំ ១៩៨១[1343]។ នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា យ៉ែម សំអុន បាននិយាយថា មាស មុត "អាច" ទទួលខុសត្រូវលើគ្រប់ការងារនៅកំពង់សោម ពីព្រោះគ្មានអង្គភាពផ្សេងមានវត្តមាននៅក្នុងតំបន់នោះ (តាមគាត់ដឹង)[1344]។ បន្ទាប់មក អ្នកសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់តម្រុយនាំមុខដោយសួរថា "ចឹងមានន័យថា ម៉ាកំពង់សោមហ្នឹងស្ថិតក្រោមការគ្រប់គ្រងរបស់មាស មុត ទាំងអស់?"[1345]។ គាត់បានឆ្លើយស្របតាម[1346]។ គាត់ក៏បាននិយាយផង

[1339] ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ ទី ២ និងទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៩ ខែមករា ឆ្នាំ ២០១៦ឯកសារ D223 កថាខណ្ឌ ៩៩-១០០។

[1340] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ផ.១០។

[1341] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ផ.៦២។

[1342] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ផ.៥៧។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ យ៉ែម សំអុន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D59/2/3.17a EN 01063514 KH 00958358។

[1343] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ យ៉ែម សំអុន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D59/2/3.17a EN 01063527-01063528 KH 00958367-00958368។

[1344] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម សំអុន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D59/2/3.17a EN 01063510 KH 00958354។ ជើងចំពីរ ២៣១ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ១៤០ *ខាងលើ* ដែលពិភាក្សាអំពីការប្រើប្រាស់បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាភស្តុតាង។

[1345] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម សំអុន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D59/2/3.17a EN 01063510 KH 00958354។

[1346] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម សំអុន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D59/2/3.17a EN 01063510 KH 00958354។

ដែរថា គាត់មិនច្បាស់ទេថាតើ មាស មុត បានទទួលខុសត្រូវលើកងពលធំលេខ ៣ ឬ តំបន់កំពង់សោមទាំងមូល[1347]។

៣៨៩. **ម៊ឹង វេត**៖ ម៊ឹង វេត មិនអាចជឿជាក់បានឡើយ[1348]។ គាត់បាននិយាយថា មាស មុត បានទទួលខុសត្រូវលើកំពង់សោម[1349]។ គាត់គ្រាន់តែបានទាក់ទងជាមួយ មាស មុត នៅក្នុងតំបន់ ៥០៥ ប៉ុណ្ណោះ ហើយបានទទួលស្គាល់ថាមានបញ្ហាលើការចងចាំ[1350]។

៣៩០. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1351]។ គាត់បាននិយាយថា តំបន់ចាប់ពីវាលរេញ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត[1352]។ ដោយសារគាត់មានហានៈទាប និង គោលនយោបាយរក្សាការសម្ងាត់របស់ ប.ក.ក.[1353] ប៉ាក សុខ អាចដឹងតិចតួចអំពីវិសាលភាពនៃសិទ្ធិអំណាចរបស់ មាស មុត។

៣៩១. **ឯក នី**៖ ឯក នី មិនអាចជឿជាក់បានឡើយ[1354]។ ទោះបីជាតំបន់ប្រតិបត្តិការរបស់គាត់មានកម្រិតក៏ដោយ ក៏ ឯក នី បានអះអាងថា មាស មុត មានសិទ្ធិអំណាចធ្វើការចាប់ខ្លួន និង ដាក់ទណ្ឌកម្មជនស៊ីវិល និង កងទ័ពដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយកងពលធំលេខ ១៦៥ បាន[1355]។ គាត់

[1347] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម សំអុន ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ D59/2/3.17a EN 01063510 KH 00958354។

[1348] *សូមមើល* កថាខណ្ឌ ១៨២-៨៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1349] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៊ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 00992990 KH 00975728។ ជើងទំព័រ ២៣១ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ១៤០ *ខាងលើ* ដែលពិភាក្សាអំពីការប្រើប្រាស់បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាភស្តុតាង ។

[1350] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៊ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 00992994 KH 00975735-00975736។ *សូមមើល* កថាខណ្ឌ ១៨២ *ខាងលើ*។

[1351] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1352] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/26 អ.៣០។ ជើងទំព័រ ២៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[1353] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតម្លៃភស្តុតាង។

[1354] *សូមមើល* កថាខណ្ឌ ២៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1355] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/104 អ.១៦។ ជើងទំព័រ ២៣២ នៃដីកាសន្និដ្ឋានស្តាពរ។

បានអះអាងថា តំបន់នេះមានព្រំដែនខាងកើតជាប់ទឹកសាប ខាងជើងនៅស្ទឹងហាវ ខាងលិចគឺសមុទ្រ ហើយនិងកោះមួយចំនួន[1356]។

៣៩២. ស.ព.អ. អះអាងថា មាស មុត មានជនស៊ីវិលចំនួន ៨០០០ ទៅ ៩០០០ នាក់ នៅក្រោមអំណាចរបស់គាត់នៅកំពង់សោម[1357]។ ស.ព.អ. បំផ្លើសខ្លឹមសារនៅក្នុងឯកសារយោធា ដែលគាត់ដកស្រង់។ ស.ព.អ. ដកស្រង់របាយការណ៍ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ផ្ញើឱ្យ សុន សេន ពាក់ព័ន្ធនឹងការបង្កបង្កើនផលស្រូវនៅកំពង់សោម[1358]។ គាត់អះអាងថា មាស មុត បានរាយការណ៍អំពីកងទ័ព និង ជនស៊ីវិលចំនួន ១៧០០០ នាក់ កំពុងធ្វើស្រែចម្ការនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់[1359]។ មាស មុត មិនបាននិយាយថា អ្នកទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ ឬ ធ្វើការងារនៅក្នុងតំបន់គាត់គ្រប់គ្រងនោះទេ។ គាត់គ្រាន់តែបានរាយការណ៍អំពីការងារដែលពួកគេកំពុងធ្វើនៅពេលនោះ[1360]។ នៅក្នុងបរិយាកាសដែលមនុស្សម្នាក់ ត្រូវតែគោរពតាមសំណើសុំព័ត៌មានទាំងអស់ពីថ្នាក់លើរបស់ខ្លួន[1361] ការផ្តល់ព័ត៌មានអំពីតំបន់នៅក្នុងអំឡុងពេលកិច្ចប្រជុំអគ្គសេនាធិការ មិនមានន័យថា មាស មុត បានត្រួតត្រាលើតំបន់នោះទេ។

៣៩៣. ស.ព.អ. អះអាងដោយគ្មានភស្តុតាង ដើម្បីសន្និដ្ឋានចំនួនជនស៊ីវិលក្រោមការគ្រប់គ្រងរបស់ មាស មុត ដោយប្រើប្រាស់តួលេខកងទ័ពចំនួន ១៧០០០ នាក់ ដែលបានរាយការណ៍នៅក្នុងឯកសារអគ្គសេនាធិការ[1362] ហើយនឹងសំណើរបស់កងពលធំលេខ ១៦៥ សុំសម្លៀកបំពាក់ចំនួន ៥០០០ កំប្លេ

[1356] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/104 ន.១៦។

[1357] កថាខណ្ឌ ២២០ ជើងទំព័រ ៦៥៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៧៧ ជើងទំព័រ ២៣៥។

[1358] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា " កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195341 KH 00052391។

[1359] កថាខណ្ឌ ៧៧ ជើងទំព័រ ២៣៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1360] *សូមមើល* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195341 KH 00052391។

[1361] *សូមមើល* កថាខណ្ឌ ១៧២ និង ២១៣ *ខាងលើ* ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃការរាយការណ៍ជូន ប.ក.ក.។

[1362] ជើងទំព័រ ៦៥៦ នៃដីកាសន្និដ្ឋានស្តាពរ។ ស.ព.អ. បានដកស្រង់ការអះអាងរបស់សាក្សី ជេត ប៊ុណ្ណា ដែលថា មាស មុត ជាអ្នកទទួលខុសត្រូវកងទ័ពចំនួន ១៨ ០០០ នាក់។ សាក្សី ជេត ប៊ុណ្ណា មិនអាចគួរឱ្យជឿជាក់ ដូចដែលបានបង្ហាញក្នុងកថាខណ្ឌ ១៨៦-៨៨ *ខាងលើ*។

ឱ្យប្រជាជន និង ៧០០០ កំប្លេឱ្យកងទ័ព[1363]។ សំណើសុំសម្លៀកបំពាក់ចំនួន ៥០០០ កំប្លេ មិនមានន័យថា ជនស៊ីវិលក្រោមការគ្រប់គ្រងរបស់ មាស មុត មានចំនួន "ជាង ៥០០០ នាក់" ដូចដែល ស.ព.អ. អះអាងនោះទេ[1364]។ ស.ព.អ. មិនមានវិធីណាមួយដែលអាចឱ្យដឹងថាមនុស្សចំនួនប៉ុន្មាននាក់នឹងត្រូវទទួលបានសម្លៀកបំពាក់ សម្លៀកបំពាក់ប៉ុន្មានកំប្លេនឹងត្រូវប្រគល់ឱ្យប្រជាជន ប្រជាជនទាំងនេះជានរណា ឬ ប្រជាជនទាំងនេះស្នាក់នៅទីណានោះឡើយ។ សំណើសុំបែបនេះអាចមានបំណងចែកឱ្យប្រជាជនចំនួន បី ប្រាំ ឬ ១០ កំប្លេ ក្នុងម្នាក់ក៏ថាបាន។ ស.ព.អ. ទាយស្មានតែម្តង។

៣៩៤. ស.ព.អ. អះអាងថា មាស មុត បានចេញ និង ទទួលរបាយការណ៍អំពីប្រជាជន និង ការផលិតម្ហូបអាហារ[1365]។ គាត់ដកស្រង់កំណត់ហេតុប្រជុំ និង ទូរលេខ[1366]។ ឯកសារទាំងនេះមិនបានបង្ហាញថា មាស មុត មានសិទ្ធិអំណាចលើតំបន់ស្វយ័តកំពង់សោមនោះទេ។ ពាក់ព័ន្ធនឹងរបាយការណ៍ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ផ្ញើឱ្យ សុន សេន *សូមមើល* កថាខណ្ឌ ៣៩២ *ខាងលើ*។ នៅក្នុងសារទូរលេខចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៧៦[1367] មាស មុត មិនបានពិពណ៌នាកងទ័ព និងប្រជាជនដែលច្រូតកាត់ស្រូវនៅកំពង់សោមថាជាប្រជាជននៅក្រោមការគ្រប់គ្រង ឬ សិទ្ធិអំណាចរបស់គាត់នោះទេ។ គាត់គ្រាន់តែបានរាយការណ៍អំពីការងារដែលពួកគេកំពុងធ្វើប៉ុណ្ណោះ។ សារទូរលេខចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ មកពី ឌឹម លើកឡើងថា "បងប្អូន [ឃុទ្ធជនយើង]" កំពុងប្រយុទ្ធសង្គ្រោះអង្ករ[1368]។ សារទូរលេខបង្ហាញថា កងទ័ពកំពុងធ្វើការងារកសិកម្ម ដែលស្របទៅតាមតម្រូវការរបស់មជ្ឈិមដែលថា អង្គភាពកងទ័ពបដិវត្តន៍កម្ពុជាត្រូវឧបត្ថម្ភខ្លួនឯងទាំង

[1363] ជើងទំព័រ ៦៥៦ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657355 KH 00162489។

[1364] ជើងទំព័រ ៦៥៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1365] កថាខណ្ឌ ៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1366] ជើងទំព័រ ២៣៣, ២៣៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1367] ទូរលេខ ចំណងជើងថា "ទូរលេខ ៤៤ ជម្រាបបង ៨៩ គោរពជ្រាបអំពីសភាពការណ៍ក្នុងខែសីហា ឆ្នាំ ១៩៧៦" ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.10 EN 00233647 KH 00000860 (ដែលបញ្ជាក់ថាប្រជាជនកំពុងបាចទឹកដាក់ស្រែ)។

[1368] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ជូនបងមុតជ្រាបពីសភាពការណ៍តាមព្រំដែនថៃ" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699។

ស្រុង[1369]។ សារទូរលេខនេះមិនបង្ហាញថា ប្រជាជនស៊ីវិលនៅកំពង់សោមស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ មាស មុត នោះឡើយ។

៣៩៥. ស.ព.អ. អះអាងថា មាស មុត បានអនុវត្តតាមសេចក្តីណែនាំរបស់ ប.ក.ក. លើរបបអាហារ[1370]។ ស.ព.អ. ដកស្រង់តែ ស៊ឹម នី ប៉ុណ្ណោះ[1371]។ ស៊ឹម នី មិនអាចឱ្យជឿជាក់បាន[1372]។ គាត់បានអះអាងថា គាត់បានដឹងថា គណៈកម្មាធិការមជ្ឈិមកំណត់គោលនយោបាយលើរបបអាហារ ដែល មាស មុត ត្រូវអនុវត្តតាម ដោយសារគាត់ស្ថិតនៅក្នុងសម្ព័ន្ធយុវកកម្ពុជា ហើយរបបអាហារត្រូវបានប្រកាសនៅក្នុងសន្និបាត[1373]។ ការណ៍ដែលថា ប.ក.ក. មានគោលនយោបាយស្តីពីរបបអាហារត្រូវផ្តល់ជូនភ្ញៀវបង្ហាញឱ្យឃើញថា ប.ក.ក. គ្រប់គ្រងទាំងស្រុងលើរាល់អង្គភាពទាំងអស់របស់បក្ស[1374]។ ការដែល មាស មុត អនុវត្តស្របតាមគោលនយោបាយដែលបានលើកឡើង មិនមានន័យថា គាត់មានសិទ្ធិអំណាចលើតំបន់ស្វយ័តកំពង់សោមទាំងមូលនោះឡើយ។

៣៩៦. ស.ព.អ. អះអាងថា មាស មុត នៅតែបន្តគ្រប់គ្រងលើកំពង់សោមក្រោយពេលត្រូវបានផ្ទេរទៅក្រុងភ្នំពេញនៅចុងឆ្នាំ ១៩៧៨ តាមរយៈការបញ្ជូនបញ្ជាទៅប្រធានកងទ័ពជើងទឹកនៃកងពលធំលេខ ១៦៥ ឈ្មោះ ទឹម សេង[1375]។ ស.ព.អ. ដកស្រង់សំដី ឡាយ ប៊ុនហាក់ សាត ចក់ ព្រំ សារ៉ាត

[1369] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ" ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.2 EN 00233956 KH 00162481-00162482 (កងពលត្រូវឧបត្ថម្ភខ្លួនឱ្យបាន ១០០% និងឧបត្ថម្ភអង្គការពី ៣០% ទៅ ១០០%)។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ឯកសារ D1.3.27.18 EN 00195350 KH 00052398 (ត្រូវជម្រុញសម្រេចផែនការបង្កបង្កើនផលស្រូវឱ្យបានពី ៩០% ទៅ ១០០%) ។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-*អ.វ.ត.ក/អ.ជ.ស.ដ* ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ឯកសារ D98/3.1.179 នៅម៉ោង 09.17.56-09.20.40។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧- *អ.វ.ត.ក/អ.ជ.ស.ដ* ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ឯកសារ D98/3.1.56 នៅម៉ោង 11.43.51-11.47.55។

[1370] កថាខណ្ឌ ៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1371] ជើងទំព័រ ២៣៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1372] *សូមមើល* កថាខណ្ឌ ២៤៥ *ខាងលើ* និង កថាខណ្ឌ ៤០៦-០៨ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1373] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/32 ឆ.១២។ ជើងទំព័រ ២៣៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1374] *សូមមើល* កថាខណ្ឌ ២១១ *ខាងលើ* ដែលពិភាក្សាពីការគ្រប់គ្រងរបស់បក្សលើប្រតិបត្តិការគ្រប់ផ្នែកទាំងអស់របស់កងពលមជ្ឈិម។

[1375] កថាខណ្ឌ ៧៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៥៦, កថាខណ្ឌ ២២៤។

ប៊ាង រ៉ែត ណុប ហាល់ និង ចម្លើយដែលអះអាងថាចេញមកពី មាស មុត[1376]។ ស.ព.អ. និយាយបំផ្លើស។ ភ័ស្តុតាងទាំងនោះមិនគាំទ្រការអះអាងរបស់គាត់នោះទេ។ យ៉ាងច្រើនបំផុត វាគ្រាន់តែបង្ហាញពីកម្រិតសិទ្ធិអំណាចលើកងទ័ពជើងទឹក ឬ បញ្ហាកងពលធំលេខ ១៦៤ ប៉ុណ្ណោះ មិនមែនពីតំបន់ស្វយ័តកំពង់សោមឡើយ។

៣៩៧. **ឡាយ ប៊ុនហាក់**៖ ឡាយ ប៊ុនហាក់ មិនអាចជឿជាក់បានឡើយ[1377]។ គាត់បាននិយាយថា ក្រោយពេល មាស មុត បានផ្លាស់ទៅអគ្គសេនាធិការ និង ក្លាយជាអនុប្រធាន[1378] ទីម សេង បានគ្រប់គ្រងលើអង្គភាពយោធាទាំងអស់ ហើយបានផ្សព្វផ្សាយគ្រប់បទបញ្ជាទាំងអស់បន្តពីថ្នាក់លើ[1379]។ គាត់បាននិយាយផងដែរថា មាស មុត លែងមានអំណាចចេញបញ្ជាទៀតហើយ នៅពេលគាត់នៅក្នុងក្រុងភ្នំពេញ[1380] ប៉ុន្តែ បន្ទាប់មក គាត់បានអះអាងថា ទីម សេង បានទទួលបញ្ជាពី មាស មុត[1381]។ បើទោះបីជាចម្លើយរបស់ ឡាយ ប៊ុនហាក់ ត្រូវបានផ្តល់តម្លៃជាភ័ស្តុតាងក៏ដោយ ក៏ចម្លើយរបស់គាត់ទាក់ទងនឹងកាលៈទេសៈនៃការផ្ទេរ មាស មុត ទៅក្រុងភ្នំពេញ មិនមានលក្ខណៈច្បាស់លាស់នោះដែរ[1382]។

៣៩៨. **សាត ចក់**៖ សាត ចក់ មិនអាចជឿជាក់បានឡើយ[1383]។ គាត់បានអះអាងថា ធ្លាប់បានឮនៅក្នុងកិច្ចប្រជុំជាមួយនឹងមេបញ្ជាការរបស់គាត់ថា នៅក្នុងឆ្នាំ ១៩៧៨ មាស មុត ត្រូវបានផ្ទេរទៅកាន់ក្រុង

[1376] ជើងទំព័រ ២៣៦, ៦៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1377] *សូមមើល* កថាខណ្ឌ ១៨៩-៩០ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1378] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D54/99.1 EN 01115988 KH 00990787។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ន.៩៣, ន.៩៥-៩៦។ ជើងទំព័រ ២៣៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ១៦០, ១៦៨, ៦៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1379] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ន.៩៣, ន.៩៦។

[1380] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D54/99.1 EN 01115988 KH 00990787។

[1381] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D54/99.1 EN 01115988 KH 00990787។

[1382] *សូមមើល* កថាខណ្ឌ ១៩០ *ខាងលើ*។

[1383] *សូមមើល* កថាខណ្ឌ ១៩២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

ភ្នំពេញ ដើម្បីឡើងកាន់ដំណែងជាអគ្គមេបញ្ជាការរងកងទ័ព[1384]។ ចម្លើយនេះមិនអាចឱ្យផ្ទៀងផ្ទាត់បាន។ សាត ចក់ មិនបាននិយាយថា មាស មុត នៅតែបន្តគ្រប់គ្រងលើកំពង់សោមក្រោយពេលចេញពីតំបន់នោះទេ។

៣៩៩. **ព្រុំ សារ៉ាត**៖ ព្រុំ សារ៉ាត មិនបានគាំទ្រការអះអាងរបស់ ស.ព.អ. នោះឡើយ[1385]។ គាត់បាននិយាយថា មាស មុត នៅតែបន្តមាន "ឥទ្ធិពល និង សិទ្ធិអំណាច" នៅក្រោយពេលដែលគាត់បានចាកចេញពីកំពង់សោម[1386]។ គាត់មិនបាននិយាយថា មាស មុត នៅបន្តគ្រប់គ្រងលើតំបន់នេះទាំងមូលនោះឡើយ។

៤០០. **ប៊ាង រ៉ែត**៖ ប៊ាង រ៉ែត មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះឡើយ[1387]។ ដំបូង គាត់បាននិយាយតែត្រឹមថា មាស មុត នៅតែបន្តមាន "ឥទ្ធិពល" ក្រោយគាត់ចាកចេញពីកំពង់សោម[1388]។ អ្នកសម្ភាសមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់តម្រុយឱ្យគាត់និយាយថា មាស មុត នៅតែបន្តទទួលខុសត្រូវលើកងពលធំលេខ ១៦៥ ក្រោយពេលគាត់បានចាកចេញពីក្រុងកំពង់សោម[1389]។ ក្រោយមក គាត់បាននិយាយថា ទឹម សេង បានក្លាយជាមេបញ្ជាការកងពលធំលេខ ១៦៥[1390] ដោយបានបង្ហាញថា ទឹម សេង មានការគ្រប់គ្រងទាំងស្រុងលើអង្គភាពនេះ។ ប៊ាង រ៉ែត មិនបាននិយាយថា មាស មុត បានមើលការខុសត្រូវលើតំបន់ស្វយ័តកំពង់សោមនោះទេ នៅក្រោយពេលគាត់ផ្លាស់ទៅក្រុងភ្នំពេញនោះ។

[1384] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ន.១២៦-៣០។ ជើងទំព័រ ២៣៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ១៦០, ១៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1385] *សូមមើល* កថាខណ្ឌ ១៩១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1386] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ន.១៧១។ ជើងទំព័រ ២៣៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1387] *សូមមើល* កថាខណ្ឌ ១៩៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1388] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ាង រ៉ែត ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D59/1/1.11a EN 00974119 KH 00926561៖ "ស៖ ចឹងគាត់នៅភ្នំពេញ គាត់នៅតែបញ្ជា? ឆ៖ គាត់នៅឥទ្ធិពល"។

[1389] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ាង រ៉ែត ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D59/1/1.11a EN 00974119 KH 00926561៖ "ស៖ ចឹងគាត់នៅភ្នំពេញ គាត់នៅតែបញ្ជា? ឆ៖ គាត់នៅឥទ្ធិពល។ ស៖ ចឹងគាត់នៅទទួលខាងកងពល ១៦៥ ដដែលឬយ៉ាងម៉េច? ឆ៖ បាទ! តែគាត់ទទួលខាងជើងទឹក"។

[1390] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ន.៣៥។

៤០១. **ណុប ហាល់**៖ ណុប ហាល់ មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះឡើយ។ គាត់គឺជាអ្នកបើកកាណូតនៅក្នុងកងវរសេនាតូចលេខ ៦២២[1391]។ ណុប ហាល់ បាននិយាយថា មាស មុត បានកាន់មុខដំណែងខ្ពស់ជាង ទឹម សេង ហើយអ្នកទាំងពីរជាអ្នកទទួលខុសត្រូវ ប៉ុន្តែ គាត់មិនបានដឹងថាតើពួកគេពិតជាបានធ្វើការរួមគ្នាឬយ៉ាងណានោះឡើយ[1392]។ គាត់មិនបាននិយាយថា មាស មុត នៅតែបន្តមានសិទ្ធិអំណាចលើតំបន់ស្វយ័តកំពង់សោមនោះទេ នៅក្រោយពេលគាត់ត្រូវបានផ្ទេរទៅភ្នំពេញនោះ។

៤០២. សាក្សីផ្សេងទៀតបញ្ជាក់ថា ទឹម សេង បានទទួលខុសត្រូវទាំងស្រុងលើកងពលធំលេខ ១៦៥ នៅក្រោយពេល មាស មុត ត្រូវបានផ្ទេរចេញពីកំពង់សោម។ លៀត ឡន បាននិយាយថា ទឹម សេង បានទទួលខុសត្រូវនៅពេល មាស មុត អវត្តមាន[1393]។ ហ៊ឹង អ៊ុច បាននិយាយថា ទឹម សេង មានសិទ្ធិអំណាចចេញបញ្ជានៅពេលនោះ ហើយថា គាត់មិនបានទទួលបញ្ជាពី មាស មុត នោះឡើយ[1394]។ បើទោះបីជា មាស មុត ពិតជានៅបន្តបញ្ជូនបញ្ជាទៅឱ្យមេបញ្ជាការកងទ័ពជើងទឹកនៃកងពលធំលេខ ១៦៥ លើបញ្ហាកងទ័ពជើងទឹកក្រោយពេលគេផ្ទេរ មាស មុត ទៅភ្នំពេញមែនក៏ដោយ ក៏វាមិនមានន័យថា មាស មុត នៅបន្តមានសិទ្ធិអំណាចលើតំបន់ស្វយ័តកំពង់សោមទាំងមូលនោះដែរ។

៥. មាស មុត មិនមានសិទ្ធិអំណាចលើមន្ទីរសន្តិសុខ ការដ្ឋាន ឬ សហករណ៍ បើទោះបីជាគាត់មាន សិទ្ធិអំណាចបែបនេះក៏ដោយ ក៏សិទ្ធិអំណាចនេះមិនធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ

៤០៣. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានពិនិត្យ និង មានសិទ្ធិអំណាចផ្តាល់លើមន្ទីរសន្តិសុខ ការដ្ឋានការងារ និង សហករណ៍នោះទេ[1395]។ ស.ព.អ. ដកស្រង់សាក្សីដែលមិនអាចឱ្យជឿជាក់បាន និង ភស្តុតាងឯកសារដែលគ្មានមូលដ្ឋានគាំទ្រ។ គាត់ខកខានមិនបានផ្តល់មូលដ្ឋានគាំទ្រការអះអាងរបស់គាត់។ បើទោះបីជា មាស មុត

[1391] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ហាល់ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/78 អ.១៣-១៤។

[1392] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ហាល់ ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/79 អ.២៦។ ជើងទំព័រ ៦៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1393] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 អ.៣។

[1394] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/81 អ.១៤-១៦។

[1395] កថាខណ្ឌ ៦៣, ៦៧, ១៥៦-៥៧, ១៦០-៦៣, ១៩១-៩២, ១៩៧, ៤៤៤-៤៧, ៤៨៦-៩០ នៃដីកាសន្និដ្ឋានស្តាពរ។

មានសិទ្ធិអំណាចលើមន្ទីរសន្តិសុខ ការដ្ឋានការងារ ឬ សហករណ៍នៅកំពង់សោមក៏ដោយ ក៏សិទ្ធិអំណាចបែបនេះមិនអាចធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ ដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។

ក. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

៤០៤. ស.ព.អ. អះអាងថា មាស មុត បានពិនិត្យ និង ទទួលខុសត្រូវលើមន្ទីរសន្តិសុខនៅក្នុងវត្តឥន្ទញ្ញាណ[1396]។ ស.ព.អ. ដកស្រង់ជាចម្បងនូវភស្តុតាងមិនអាចឱ្យជឿជាក់បានពី មាស វឿន កង សុំ ស៊ឹម នី ជេត ប៊ុណ្ណា ឯក នី ប៉ាក សុខ សំ ភីន ប៉ែន សារិន ប៊ូច កុយ ទូច សៀលី និង អែម សុន ព្រមទាំងឯកសារ និង កិច្ចសម្ភាសន៍ជាមួយនឹង មាស មុត ដែលមិនធ្វើដោយ អ.វ.ត.ក. ដែលមិនគាំទ្រការអះអាងរបស់គាត់[1397]។ ស.ព.អ. ក៏នាំឱ្យមានការយល់ខុសនូវភស្តុតាងមួយចំនួនទៀតផងដែរ។

៤០៥. ស.ព.អ. ដកស្រង់សំដី មាស វឿន កង សុំ និង របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស. ដើម្បីគាំទ្រការអះអាងទូទៅរបស់គាត់ដែលថា វត្តឥន្ទញ្ញាណស្ថិតនៅក្នុងតំបន់ទទួលខុសត្រូវរបស់ មាស មុត[1398]។ ភស្តុតាងនេះមិនគាំទ្រការអះអាងនេះទេ។ មាស វឿន ស្ថិតនៅក្នុងកងពលធំលេខ ១។ ការទាក់ទងរបស់គាត់ជាមួយនឹងកងពលធំលេខ ១៦៥ មានកម្រិតត្រឹមការទាក់ទងជាមួយនឹងកងវរសេនាធំនៅកោះកុងប៊ុណ្ណោះ[1399]។ គាត់មិនអាចដឹងដោយផ្ទាល់ថា កងទ័ពជើងទឹកបានគ្រប់គ្រងលើដែនគោកពីវាលរេញរហូតដល់កំពង់សោមនោះទេ[1400]។ ការអះអាង

[1396] កថាខណ្ឌ ១៥៥-៥៧, ៤៤៤-៤៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1397] ជើងទំព័រ ៤៤១-៤៩, ១៦៥0-៧២ នៃដីកាសន្និដ្ឋានស្តាពរ។

[1398] កថាខណ្ឌ ៤៤៤ ជើងទំព័រ ១៦៥១ នៃដីកាសន្និដ្ឋានស្តាពរ។ មេធាវីការពារក្តីបានពោលប្រាស្រ័យលើការអះអាងរបស់ ជេត ប៊ុណ្ណា នៅកន្លែងផ្សេងទៀតក្នុងចម្លើយតប។ *សូមមើល* កថាខណ្ឌ ២៣៥ *ខាងលើ*។

[1399] *សូមមើលឧទា.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.៣២-៣៣, ឆ.៣៥។ *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1400] ជើងទំព័រ ១៦៥១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.១៧។ *សូមមើលផងដែរ* ជើងទំព័រ ១៨២៣ នៃដីកាសន្និដ្ឋានស្តាពរ។

របស់ កង សុំ ដែលថា "មានតែ ១៦៤ មួយទេដែលនៅខេត្តកំពង់សោម"[1401] មិនអាចឱ្យជឿជាក់បាន[1402]។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស. លើកឡើងត្រឹមតែយោបល់ ឬ សេចក្តីសន្និដ្ឋានរបស់អ្នកស៊ើបអង្កេតប៉ុណ្ណោះ។ របាយការណ៍នេះផ្អែកលើតែចម្លើយសាក្សីចំនួនពីរនាក់ សៀវភៅមួយក្បាល និង "របកគំហើញ" របស់អ្នកស៊ើបអង្កេត ក.ស.ច.ស. នៅទីតាំងនោះប៉ុណ្ណោះ[1403]។

៤០៦. **ស៊ឹម នី**៖ ស៊ឹម នី មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នាយ៉ាងខ្លាំងអំពីវត្តឥន្ទញ្ញាណដែលធ្វើឱ្យបាត់បង់ជំនឿលើចម្លើយរបស់គាត់។ គាត់បានដាំបន្លែនៅជិតវត្តឥន្ទញ្ញាណ និង បានធ្វើការនៅផែក្រោម ធុច វិន មុនពេលទៅភូមិភាគបូព៌ានៅចុងឆ្នាំ ១៩៧៨[1404]។ ស.ព.អ. សំអាងលើតែ ស៊ឹម នី ដើម្បីគាំទ្រការអះអាងរបស់ខ្លួនដែលថា មាស មុត បានទៅមើលវត្តឥន្ទញ្ញាណមួយខែម្តង ដើម្បីពិនិត្យមើលស្ថានការណ៍ និង អាចនាំយកម្ហូបអាហារទៅឱ្យអ្នកយាមហើយថា គាត់បានស្នូរចម្លើយ និង បញ្ជូនមនុស្សចេញ[1405]។

៤០៧. ក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា អាស្រ័យទៅតាមការបកប្រែ ស៊ឹម នី បាននិយាយថា គាត់បានឃើញ មាស មុត នៅវត្តឥន្ទញ្ញាណ "ម្តងម្កាល"[1406] ឬ ក៏ថាគាត់ "ចេញចូលម្តងម្កាល"[1407]។ នៅក្នុងកិច្ចសម្ភាសន៍ដដែលនេះដែរ ក្រោយមកគាត់បាននិយាយថា គាត់

[1401] ជើងទំព័រ ១៦៥១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.៨៣។ *សូមមើលផងដែរ* ជើងទំព័រ ១៨២៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1402] *សូមមើល* កថាខណ្ឌ ២២៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1403] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22 EN 00634139 KH 00662102។ ជើងទំព័រ ១៦៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[1404] *សូមមើល* កថាខណ្ឌ ២៤៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីនេះ។

[1405] កថាខណ្ឌ ៤៤៥-៤៦ ជើងទំព័រ ១៦៥៥-៦៣, ១៦៦៦-៦៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៦៣ ជើងទំព័រ ១៩៤, កថាខណ្ឌ ១៥៦។

[1406] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/30.1 EN 01070552 KH 00964129។

[1407] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332601 KH 00735597។

បានឃើញ មាស មុត នៅវត្តឥន្ទញ្ញាណ "ជាញឹកញាប់"[1408] ឬ "អាសា"[1409] អាស្រ័យទៅតាមការបកប្រែ។ ទៅកាន់ ក.ស.ច.ស. ស៊ឹម នី បាននិយាយថា គាត់បានឃើញ មាស មុត ទៅវត្តឥន្ទញ្ញាណចំនួនពីរដង ដោយនាំយកអាហារទៅអោយឆ្មាំយាម[1410] ប៉ុន្តែបន្ទាប់មកបាននិយាយថា បើតាមគាត់ដឹង មាស មុត បានទៅទីនោះមួយខែម្តង[1411]។ នៅក្នុងកិច្ចសម្ភាសន៍ដដែលនេះដែរ គាត់បាននិយាយថា គាត់បានជឿជាក់ថា គាត់បានឃើញ មាស មុត នាំយកអាហារទៅទីនោះមួយខែម្តង ជាជាងនិយាយថា គ្រាន់តែឃើញគាត់នាំយកម្ហូបអាហារចំនួនពីរដងដូចដែលបានថ្លែងពីមុន[1412]។ គាត់បានដឹងរឿងនេះពីឆ្មាំយាមចំនួនពីរនាក់[1413]។ ប្រសិនបើគាត់បានឮព័ត៌មានពីឆ្មាំនោះ ស៊ឹម នី ប្រហែលជាមិនបានឃើញ មាស មុត នៅវត្តឥន្ទញ្ញាណនោះទេ។ ការណ៍ដែលការអះអាងរបស់ ស៊ឹម នី ថាបានឃើញ មាស មុត នៅក្នុងឡានម៉ាកហ្សីបរបស់ចិន[1414] ដូចគ្នាទៅនឹងការអះអាងរបស់សាក្សីម្នាក់ទៀតដែលបានឃើញ មាស មុត នៅទឹកសាបក្នុងឡានម៉ាកហ្សីបរបស់ចិននោះ[1415] មិនធ្វើឱ្យចម្លើយផ្ទុយគ្នារបស់គាត់កាន់តែគួរឱ្យជឿជាក់បាននោះទេ។ សាក្សីផ្សេងទៀតនិយាយថា មាស មុត បានប្រើប្រាស់ឡានហ្សីបរបស់អាមេរិក[1416]។

[1408] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/30.1 EN 01070558 KH 00964134។

[1409] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332607 KH 00735602។

[1410] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ឆ.១២។

[1411] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ឆ.១៣។

[1412] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ឆ.១៤។

[1413] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ឆ.១៥។

[1414] កថាខណ្ឌ ៤៤៥ ជើងទំព័រ ១៦៦៣ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/32 ឆ.៣៥។

[1415] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/116 ឆ.៨។ ជើងទំព័រ ១៦៦៤ នៃដីកាសន្និដ្ឋានស្តាពរ។ ក៏មានការព្រួយបារម្ភលើភាពគួរឱ្យជឿជាក់ពាក់ព័ន្ធនឹងចម្លើយរបស់ ស្វាយ សំអាន អំពីទឹកសាប ដូចដែលមេធាវីការពារក្តីបង្ហាញក្នុងកថាខណ្ឌ ៤២៣ *ខាងក្រោម*។

[1416] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/111 ឆ.១៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ឆ.៤០។

៤០៨. ស៊ឹម នី ក៏បានប្រាប់អ្នកសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរថា ឡូញ ប្រធានកងនេសាទរដ្ឋ បានទទួលខុសត្រូវលើវត្តឥន្ទញ្ញាណ[1417] ប៉ុន្តែក្រោយមកបាននិយាយថា មានតែ មាស មុត ម្នាក់គត់ដែលគ្រប់គ្រង និង ទទួលខុសត្រូវ ហើយថា ឡូញ ជាអ្នកផ្តត់ផ្តង់[1418]។ ទោះបីជាប្រាប់ ក.ស.ច.ស. ថាគាត់បានឃើញ ឡូញ "ស្ទើរតែរាល់ថ្ងៃ"[1419] ក៏ដោយ ក៏ ស៊ឹម នី មិនអាចកំណត់អត្តសញ្ញាណគាត់ពីក្នុងរូបថតបានដែរ[1420]។ សាក្សីម្នាក់ទៀតឈ្មោះ ឆេង ជាង ត្រូវបានបង្ហាញរូបថតដូចគ្នា ហើយបានកំណត់អត្តសញ្ញាណភ្លាមៗថាជា ឡូញ[1421]។

៤០៩. **ជេត ប៊ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[1422]។ គាត់បានអះអាងថា វត្តឥន្ទញ្ញាណ គឺជាគុកកងពលធំលេខ ១៦៤ របស់ មាស មុត[1423]។ គាត់បានឮព័ត៌មាននេះពីមេដឹកនាំរបស់គាត់[1424]។

៤១០. **ឯក នី**៖ ឯក នី មិនអាចជឿជាក់បានឡើយ[1425]។ គាត់បានអះអាងថា វត្តឥន្ទញ្ញាណ គឺជាមន្ទីរសន្តិសុខ និង មន្ទីរឃុំឃាំងរបស់កងពលធំលេខ ១៦៤ ក្រោមការគ្រប់គ្រងរបស់ មាស មុត[1426]។

[1417] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/30.1 EN 01070550 KH 00964127។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ឯកសារ D59/2/2.16a EN 01332598-01332599 KH 00735595-96។

[1418] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D54/30.1 EN 01070563 KH 00964137។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332612 KH 00735605។

[1419] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ឆ.២៣។

[1420] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ឆ.២២។ រូបថតរបស់ ឡូញ មាននៅក្នុងសំណុំរឿងជាឯកសារ D54/88.1 ដែលដូចគ្នានឹងឯកសារ D54/56.1។ នៅក្នុងរបាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/56 EN 00973407 KH 01001518 អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. ថ្លែងថា ក្រុមគ្រួសាររបស់ ឡូញ បានផ្តល់រូបថតរបស់ ឡូញ មួយសន្លឹក។

[1421] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ឆ.១៩។

[1422] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីនេះ។ *សូមមើល* ជើងទំព័រ ១៨២៣, ២៦៦៨ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឆ.៩ (ដែលអះអាងថាតំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំពីទឹកសាបកងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ)។

[1423] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ឆ.១៥។ ជើងទំព័រ ៤៤១, ១៦៥០-៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[1424] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ឆ.១៥។

ដូចការអះអាងរបស់ ជេត ប៊ុណ្ណា ការអះអាងរបស់ ឯក នី គឺផ្អែកលើពាក្យចចាមអារ៉ាម។ គាត់បានឮព័ត៌មាននេះពីទាហានផ្សេងទៀត[1427]។

៤១១. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1428]។ គាត់បានឮអំពីវត្តឥន្ទញ្ញាណពីទាហានផ្សេងទៀត ប៉ុន្តែមិនដែលបានចូលខាងក្នុងទេ[1429]។ គាត់បានប៉ាន់ស្មានថា ទីតាំងនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៥ ដោយសារកងទ័ពត្រូវបានគេប្រាប់មិនឱ្យទៅជិតកន្លែងនោះ[1430]។ ចម្លើយទាំងនេះមិនបានបង្ហាញថា វត្តឥន្ទញ្ញាណ គឺជាមន្ទីរសន្តិសុខ និង មន្ទីរឃុំឃាំងរបស់កងពលធំលេខ ១៦៥ ឬក៏ថា មាស មុត បានគ្រប់គ្រងមន្ទីរនេះទេ[1431]។

៤១២. **សំ ភីន**៖ សំ ភីន មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ គឺផ្អែកលើការទាយស្មាន។ គាត់គឺជាទាហានដែលមានឋានៈទាបនៅក្នុងកងមួយដែលយាមឃ្លាំងនៅផ្សារលើ[1432]។ គាត់មិនដែលបានចូលរួមកិច្ចប្រជុំណាមួយជាមួយ មាស មុត នោះទេ[1433]។ គាត់មិនដែលបានទៅវត្តឥន្ទញ្ញាណទេ[1434]។ ទោះបីជាយ៉ាងនេះក្តី សំ ភីន បានអះអាងថា “តាមខ្ញុំដឹង” វត្តឥន្ទញ្ញាណ គឺជាកន្លែងសម្រាប់យោធា[1435]។

[1425] *សូមមើល* កថាខណ្ឌ ២៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1426] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២0១៤ ឯកសារ D54/102 ឆ.៦។ ជើងចំពីរ ៤៤១, ១៦៥0 នៃដីកាសន្និដ្ឋានស្តាពរ។

[1427] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២0១៤ ឯកសារ D54/102 ឆ.៦។

[1428] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ និង *សូមមើល* កថាខណ្ឌ ៤២២ *ខាងក្រោម* ទាក់ទងនឹងទីកសាប។

[1429] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២0១៣ ឯកសារ D54/25 ឆ.២៥។ ជើងចំពីរ ១៦៥0 នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងចំពីរ ១៩៤, ១៨២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1430] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២0១៣ ឯកសារ D54/26 ឆ.៨។

[1431] ដូចដែល ស.ព.អ. អះអាងនៅក្នុងកថាខណ្ឌ ៤៤៤ នៃដីកាសន្និដ្ឋានស្តាពររបស់ខ្លួន។

[1432] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២0១៤ ឯកសារ D54/111 ស-ឆ.២, ឆ.៨-៩។

[1433] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២0១៤ ឯកសារ D54/111 ឆ.១២។

[1434] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២0១៤ ឯកសារ D54/111 ឆ.១៤។

[1435] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២0១៤ ឯកសារ D54/111 ឆ.១៥។ ជើងចំពីរ ១៦៥0 នៃដីកាសន្និដ្ឋានស្តាពរ។

៤១៣. **ប៉ែន សារិន**៖ ប៉ែន សារិន មិនអាចជឿជាក់បានឡើយ។ ភស្តុតាងរបស់គាត់ គឺផ្អែកលើពាក្យចចាមអារ៉ាម ហើយគ្មានការពិតអ្វីឡើយ។ គាត់គឺជាជាងម៉ាស៊ីនធ្វើការនៅកងពលធំលេខ ១៦៥ នៅកំពង់សោម និង ស្ទឹងហាវ[1436]។ គាត់មិនដែលបានជួប មាស មុត នោះទេ។ គាត់គ្រាន់តែបានឮពីកងទ័ព និង បុគ្គលិកក្រោមបង្គាប់របស់ មាស មុត និយាយអំពីគាត់ប៉ុណ្ណោះ[1437]។ បើតាមឮគេនិយាយ គាត់បាននិយាយថា គាត់បានដឹងថា មាស មុត ទទួលបន្ទុកនៅឯកងពលធំលេខ ១[1438] ហើយវត្តឥន្ទញ្ញាណ គឺជាទីកន្លែងឃុំឃាំងរបស់កងពលធំលេខ ១[1439]។ ប៉ែន សារិន ដំបូងគាត់បានដឹងអំពីវត្តឥន្ទញ្ញាណ នៅពេលដែលគាត់បានទៅទីនោះក្នុងខែមេសា ឆ្នាំ ១៩៧៩[1440]។ មិនមានអ្វីដែលបង្ហាញថា គាត់បានដឹងរឿងរ៉ាវអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ថានរណាជាអ្នកគ្រប់គ្រងតំបន់នោះទេ។ ការដឹងឮរបស់គាត់អំពីកងពលធំលេខ ១៦៥ ឬ មាស មុត គឺមិនពិត ដូចដែលបង្ហាញឱ្យឃើញតាមរយៈចម្លើយរបស់គាត់ដែលថា កងពលធំលេខ ១ មិនមែនកងពលធំលេខ ១៦៥ នោះទេ ដែលជាកង មាស មុត កាន់កាប់[1441]។ មេធាវីការពារក្តីនឹងមិនមានលទ្ធភាពតទល់ជាមួយ ប៉ែន សារិន នៅពេលជំនុំជម្រះនៅសវនាវការឡើយ ទាក់ទងនឹងចម្លើយរបស់គាត់ផ្លើយប្រាប់ ក.ស.ព.[1442] ពីព្រោះគាត់បានទទួលមរណភាពហើយ[1443]។

៤១៤. **ប៉ូច កុយ**៖ ប៉ូច កុយ មិនអាចជឿជាក់បានឡើយ។ គាត់បានដឹងអំពីវត្តឥន្ទញ្ញាណ នៅក្រោយថ្ងៃ ៧ ខែមករា ឆ្នាំ ១៩៧៩។ អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់គឺជាកសិករនៅស្រែអំបិល[1444]។

[1436] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7 ឆ.៣, ឆ.១០។

[1437] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7 ឆ.៧។

[1438] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7 ស-ឆ.៧។

[1439] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ែន សារិន ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.13.8 EN 00217562។ ជើងទំព័រ ៤៤១, ១៦៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1440] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ែន សារិន ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.13.8 EN 00217562។

[1441] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7 ឆ.៤, ឆ.៧។ កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ែន សារិន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.8 EN 00217562។

[1442] *សូមមើល* កថាខណ្ឌ ១៤១ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាភស្តុតាង។

[1443] ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ ទី ២ និងទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៩ ខែមករា ឆ្នាំ ២០១៦ ឯកសារ D223 កថាខណ្ឌ ១០១។

[1444] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ូច កុយ ចុះថ្ងៃទី ១១-១២ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.1 EN 00217557។

គាត់បានអះអាងថា វត្តឥន្ទញ្ញាណ គឺជាមន្ទីរឃុំឃាំង[1445] ប៉ុន្តែគាត់មិនដែលបានទៅទីនោះទេ រហូតដល់ខែសីហា ឆ្នាំ ១៩៧៩[1446]។ ដោយសារតែទីតាំង និង មុខដំណែងរបស់គាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនអាចដឹងថា គេប្រើប្រាស់វត្តឥន្ទញ្ញាណក្នុងគោលបំណងអ្វី ហើយប្រើប្រាស់ដោយនរណានោះទេ ប្រសិនបើមានការប្រើប្រាស់វត្តនោះមែននោះ។ ដូច ប៉ែន សារិនដែរ មេធាវីការពារក្តីនឹងមិនមានលទ្ធភាពតទល់ជាមួយ ប៉ូច កុយ នៅពេលជំនុំជម្រះនៅសវនាការឡើយ ទាក់ទងនឹងចម្លើយរបស់គាត់ដែលឆ្លើយប្រាប់ ក.ស.ព.[1447] ពីព្រោះគាត់បានទទួលមរណភាពហើយ[1448]។

៤១៥. **ទូច សឿលី**៖ ទូច សឿលី មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយមិនច្បាស់លាស់ និងផ្ទុយគ្នាអំពីវត្តឥន្ទញ្ញាណ ចម្លើយខ្លះគឺផ្អែកលើពាក្យចចាមអារ៉ាម។ គាត់នៅក្នុងវរសេនាតូចលេខ ៤៥០ ហើយក្នុងរយៈពេលប្រហែល ៤ ខែ ក្នុងឆ្នាំ ១៩៧៥ គាត់នៅវត្តឥន្ទញ្ញាណ ជានិរសារ មុនពេលចូលបម្រើការងារជាកងទ័ពជើងទឹក[1449]។ គាត់បានអះអាងថា វរសេនាតូចលេខ ៤៥០ “ប្រហែលជា” បានទទួលបញ្ជាពី មាស មុត[1450]។ ទៅកាន់ ក.ស.ព. គាត់បាននិយាយថា គាត់បានដឹងពីមិត្តរួមការងាររបស់គាត់ថា វត្តឥន្ទញ្ញាណ គឺជាមន្ទីរឃុំឃាំង[1451]។ ទៅកាន់ ក.ស.ច.ស. គាត់បាននិយាយថា គាត់បានត្រលប់ទៅវត្តឥន្ទញ្ញាណវិញ ក្នុងឆ្នាំ ១៩៧៧ ហើយបានឃើញអ្នកទោសនៅទីនោះ[1452]។ គាត់បាននិយាយថា នៅពេលដែលគាត់ចាកចេញពីវត្តឥន្ទញ្ញាណ ទីនោះមិនមែនជា

[1445] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ូច កុយ ចុះថ្ងៃទី ១១-១២ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.1 EN 00217557។ ជើងទំព័រ ១៦៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1446] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ូច កុយ ចុះថ្ងៃទី ១១-១២ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.1 EN 00217557។

[1447] *សូមមើល* កថាខណ្ឌ ១៤១ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាភស្តុតាង។

[1448] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៣ ឯកសារ D54/15 EN 00942731 KH 00984856។

[1449] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/15 អ.១២-១៤, អ.២៥។

[1450] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/187 អ.៤៧។ ជើងទំព័រ ៤៤២ នៃដីកាសន្និដ្ឋានស្តាពរ។

[1451] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ទូច សឿលី ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.13 EN 00217575 KH 01555822។ ជើងទំព័រ ១៦៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1452] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/15 ស-អ.២៧-៣២។

មន្ទីរឃុំឃាំង ហើយគ្មានអ្នកទោសទេ[1453]។ បន្ទាប់មក ទូច សៀលី ក៏បាននិយាយថា ក្នុងអំឡុងពេលគាត់ទៅមើលកន្លែងនោះនៅឆ្នាំ ១៩៧៧ គាត់បានគិតថា ទីនោះមិនមែនជាមន្ទីរឃុំឃាំងនោះទេ ពីព្រោះគាត់ត្រូវបានគេអនុញ្ញាតឱ្យដើរលេងសេរី ហើយគាត់បានឃើញមនុស្សម្នាក់ ដែលមិនមែនជាអ្នកទោស ប៉ុន្តែកំពុងជាប់ឃុំនៅទីនោះ[1454]។ ស.ព.អ. មិនអើពើនឹងភស្តុតាងពី "សៀង" ដែលជាអ្នកផ្តល់ចម្លើយម្នាក់ទៀតឱ្យ ក.ស.ព. ដែលថា វត្តឥន្ទញ្ញាណហាក់ដូចជាមិនមែនជាកន្លែងឃុំខ្លួននោះទេ[1455]។

៤១៦. **អែម សុន**៖ អែម សុន មិនអាចជឿជាក់បានឡើយ[1456]។ គាត់មិនបានធ្វើការនៅវត្តឥន្ទញ្ញាណទេ[1457]។ គាត់បាននិយាយថា នរណាៗក៏ដឹងថា វត្តឥន្ទញ្ញាណ គឺជាមន្ទីរសន្តិសុខរបស់កងពលធំលេខ ១៦៥ ដែរ[1458]។ អែម សុន បានផ្តល់ចម្លើយផ្ទុយគ្នាទាក់ទងនឹងទីកន្លែងនោះ។ ដំបូង គាត់បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា គាត់មិនដែលបានទៅវត្តឥន្ទញ្ញាណទេ[1459]។ បន្ទាប់មក គាត់ក៏បានប្តូរសាច់រឿង។ គាត់បាននិយាយថា គាត់បានទៅទីនោះម្តង ដើម្បីទៅពិនិត្យមើលទាហានរបស់គាត់ពីរនាក់ ដែលត្រូវបានគេឃុំខ្លួននៅទីនោះ[1460]។ ការប្តូរសាច់រឿងរបស់គាត់អំពីវត្តឥន្ទញ្ញាណ គឺស្រដៀងគ្នាទៅនឹងការផ្លាស់ប្តូរសាច់រឿង អំពីអ្វីដែលគាត់បានដឹងអំពីទាហានអាមេរិកក្រោយហេតុការណ៍កប៉ាល់ម៉ាយ៉ាហ្គេដែរ[1461]។

[1453] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សៀលី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/187 ឆ.១៩, ឆ.២១។

[1454] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សៀលី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/187 ឆ.២៥, ឆ.២៦, ឆ.២៩-៣៥។

[1455] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ "សៀង" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.11 EN 00217566។

[1456] *សូមមើល* កថាខណ្ឌ ២៣៦, ២៤៤ និង ៣៤៩ *ខាងលើ* និង កថាខណ្ឌ ៥១៥ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីនេះ។

[1457] *សូមមើល* កថាខណ្ឌ ២៣៦ *ខាងលើ*។

[1458] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.៤៤។ ជើងទំព័រ ១៦៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1459] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/46 ឆ.១៤។

[1460] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.៥២។

[1461] *សូមមើល* កថាខណ្ឌ ៣៤៩ *ខាងលើ*។

៤១៧. ស.ព.អ. ដកស្រង់ការសម្ភាសន៍ចំនួនពីររបស់ មាស មុត ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត គឺ "មិននិយាយការពិត" អំពីការដឹងឮរបស់គាត់ពីវត្តឥន្ទញ្ញាណ[1462]។ កិច្ចសម្ភាសន៍ទាំងនេះត្រូវបានធ្វើឡើងដោយបុគ្គលដែលមិនមែនមកពី អ.វ.ត.ក. ដោយគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ សម្រាប់គោលបំណងផ្សេងក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌ។ កិច្ចសម្ភាសន៍ទាំងនេះមានតម្លៃជាភ័ស្តុតាងតិចតួចណាស់[1463]។ ប្រសិនបើកិច្ចសម្ភាសន៍ទាំងនេះត្រូវបានផ្តល់តម្លៃជាភ័ស្តុតាងមែននោះ ស.ច.ស. ត្រូវតែពិចារណាថា ស.ព.អ. បង្ហាញចម្លើយរបស់ មាស មុត មិនត្រឹមត្រូវ។ មាស មុត បាននិយាយស៊ីចង្វាក់គ្នានៅក្នុងកិច្ចសម្ភាសន៍ទាំងពីរ ដោយបានបង្ហាញថា វត្តឥន្ទញ្ញាណមិនត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំងនោះទេ[1464]។ គាត់ក៏បានប្រាប់អ្នកស៊ើបអង្កេត POW/MIA ផងដែរថា អ្នកទោសអាមេរិកមិនត្រូវបានចាប់ខ្លួននោះទេ[1465]។ តាមហេតុផលជាក់ស្តែង គ្មានកន្លែងឃុំខ្លួនអ្នកទោសជនជាតិអាមេរិកនោះទេ។

៤១៨. ស.ព.អ. ដកស្រង់ដោយភាន់ច្រឡំអំពីការសម្ងាប់ រ៉ែម មេបញ្ជាការរងសេនាតូចលេខ ៣៨៦ នៅមុខវត្តឥន្ទញ្ញាណ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានដឹងហេតុការណ៍ពាក់ព័ន្ធនឹងការកាប់សម្ងាប់នៅក្នុងវត្ត ហើយបាននិយាយរឿងនេះក្នុងពេលប្រជុំ[1466]។ តាមការអះអាង រ៉ែម ត្រូវគេបាញ់សម្ងាប់នៅខាងក្រៅវត្ត បន្ទាប់ពីបានដាល់ទាហានកងពលធំលេខ ១៦៥ ហើយព្យាយាមតតាំងនឹងការចាប់ខ្លួន[1467]។ ព្រឹត្តការណ៍នេះបានកើតឡើងបន្ទាប់ពីកិច្ចប្រជុំជាមួយ មាស មុត ដែលត្រូវបានអះអាងថាពាក់ព័ន្ធនឹងជនក្បត់ [1468] មិនមែននៅមុនកិច្ចប្រជុំនេះទេ[1469]។ មិនមាន

[1462] កថាខណ្ឌ ៤៤៧ ជើងទំព័រ ១៦៧១ នៃដីកាសន្និដ្ឋានស្តាពរ (ដែលដកស្រង់ចេញពីខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍រវាង មាស មុត និង David Kattenburg) ជើងទំព័រ ១៦៧២ (ដែលដកស្រង់ចេញពីសេចក្តីសង្ខេប POW/MIA នៃកិច្ចសម្ភាសន៍ជាមួយ មាស មុត)។

[1463] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[1464] ផ្ញើជូន David Kattenburg មាស មុត បាននិយាយថា មិនមានមន្ទីរឃុំឃាំងនៅកំពង់សោមទេ (*សូមមើល* ជើងទំព័រ ១៦៧១ នៃដីកាសន្និដ្ឋានស្តាពរ) ហើយសម្រាប់អ្នកស៊ើបអង្កេត POW/MIA គាត់បាននិយាយថា មិនមានព័ត៌មានអំពីការប្រើប្រាស់វត្តឥន្ទញ្ញាណ ជាមន្ទីរឃុំឃាំងនោះទេ (*សូមមើល* ជើងទំព័រ ១៦៧២ នៃដីកាសន្និដ្ឋានស្តាពរ)។

[1465] បទសម្ភាសន៍ជាមួយ មាស មុត (POW/MIA) ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០១ ឯកសារ D22.2.181 EN 00249698 KH 00742001-00742002។

[1466] កថាខណ្ឌ ១៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1467] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D54/101 អ.១០។

[1468] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D54/102 អ.៣។ *សូមមើលផងដែរ ដូចខាងលើ* អ.៥ (ឯក នី និយាយថា គាត់មិនបានឮ មាស មុត និយាយអំពីរឿងរបស់ រ៉ែម នៅក្នុងអង្គប្រជុំណាមួយទេ)។

ការបង្ហាញណាមួយបញ្ជាក់ថា រ៉ែម ត្រូវបានគេឃុំខ្លួន ឬ សម្លាប់ចោលនៅវត្តឥន្ទញ្ញាណ ឬថា មាស មុត ជាប់ពាក់ព័ន្ធនឹងការកាប់សម្លាប់នេះឡើយ[1470]។

៤១៩. ស.ព.អ. ដកស្រង់របាយការណ៍ដែលអះអាងថាបញ្ជូនទៅឱ្យ សុន សេន នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានសួរចម្លើយអ្នកជាប់ឃុំនៅវត្តឥន្ទញ្ញាណ[1471]។ ស.ព.អ. បង្ហាញរបាយការណ៍នោះខុស។ មាស មុត មិនបានសរសេររបាយការណ៍នេះទេ[1472]។ របាយការណ៍នេះទាក់ទងនឹងការសួរចម្លើយអ្នកនេសាទថៃ ដែលត្រូវបានចាប់ខ្លួននៅខេត្តកោះកុង និង នាំយកទៅកំពង់សោម[1473]។ របាយការណ៍នេះសរសេរថា "យើង" កំពុងសួរពួកគេ[1474]។ របាយការណ៍នេះមិនបានបង្ហាញថា នរណាជាអ្នកសួរ ឬ ការសួរនោះធ្វើនៅកន្លែងណានៅកំពង់សោមនោះឡើយ។ មិនមានការបង្ហាញថា ការសួរនោះត្រូវបានធ្វើឡើងដោយកងពលធំលេខ ១៦៥ នោះទេ។ កងកម្លាំងកងពលធំលេខ ១ អាចទំនងជាអ្នកសួរ។ ពួកគេក៏នៅកំពង់សោមដែរ ហើយបានទទួលមនុស្សដែលត្រូវបានអង្គភាពកងពលធំលេខ ១ ចាប់ខ្លួននៅខេត្តកោះកុង[1475]។ ស.ព.អ. បាននិយាយដោយប្រយោលថា សុន សេន បានឆ្លើយតបទៅ មាស មុត ហើយបានស្នើសុំឱ្យ *"សួរសំណួរ"* ដើម្បីកំណត់បណ្តាញផ្ទៃក្នុង[1476]។ ផ្ទុយទៅវិញ សុន សេន បានផ្ញើរបាយការណ៍នេះទៅឱ្យ "អង្គការ" ដើម្បីស្នើសុំឱ្យគេសួរសំណួរទាំងនោះ ដើម្បីកំណត់អត្តសញ្ញាណ

[1469] *សូមមើល* កថាខណ្ឌ ១៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1470] ផ្ទុយពីការអះអាងរបស់ ស.ព.អ. នៅក្នុងកថាខណ្ឌ ១៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1471] កថាខណ្ឌ ៤៤៦ ជើងទំព័រ ១៦៦៩-៧០ នៃដីកាសន្និដ្ឋានស្តាពរ។

[1472] សេចក្តីរាយការណ៍ត្រូវបានគេអះអាងថា ផ្អែកលើសារទូរស័ព្ទពី មាស មុត។ សេចក្តីរាយការណ៍ ចំណងជើងថា "សេចក្តីរាយការណ៍ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់ អំពីសភាពការណ៍នៅតាមព្រំដែនជាមួយនឹងថៃ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20។ *សូមមើល* កថាខណ្ឌ ២៧១ *ខាងលើ* និង កថាខណ្ឌ ៥៧១ *ខាងក្រោម* ដែលពិភាក្សាពីសេចក្តីរាយការណ៍នេះ។

[1473] សេចក្តីរាយការណ៍ ចំណងជើងថា "សេចក្តីរាយការណ៍ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់អំពីសភាពការណ៍នៅតាមព្រំដែនជាមួយនឹងថៃ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20។

[1474] សេចក្តីរាយការណ៍ ចំណងជើងថា "សេចក្តីរាយការណ៍ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់អំពីសភាពការណ៍នៅតាមព្រំដែនជាមួយនឹងថៃ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20។

[1475] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ D54/53 ន.១៩-២០។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.178 នៅម៉ោង 10.17.39-10.24.36។

[1476] កថាខណ្ឌ ៤៤៦ នៃដីកាសន្និដ្ឋានស្តាពរ (ការគូសបញ្ជាក់នៅក្នុងឯកសារដើម)។

បណ្តាញផ្ទៃក្នុងទៅវិញទេ[1477]។ របាយការណ៍នេះមិនបានបង្ហាញថា មាស មុត បានសួរចម្លើយអ្នកជាប់ឃុំនៅវត្តឥន្ទញ្ញាណ ឬ កន្លែងផ្សេងទៀតណាមួយទេ។

ខ. មន្ទីរសន្តិសុខទឹកសាប

៤២០. ស.ព.អ. អះអាងថា មាស មុត បានត្រួតពិនិត្យ និងទទួលខុសត្រូវលើមន្ទីរសន្តិសុខនៅទឹកសាប[1478]។ ស.ព.អ. ដកស្រង់ចម្លើយ និង ភស្តុតាងឯកសារមិនគួរឱ្យជឿជាក់បានរបស់ ប៉ាក សុខ និង ស្វាយ សំអាន រួមទាំងរឿងរ៉ាវរបស់ ឡុង ផាន់ស៊ី សំ សោម ម៉ាក ឈឿន កុយ ណែន ប្រាក់ ប៊ុននី សុក វណ្ណា និង ហៀង រ៉ែត[1479]។

៤២១. ស.ព.អ. ដកស្រង់របាយការណ៍ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ និង កំណត់ហេតុកិច្ចប្រជុំអគ្គសេនាធិការនៅថ្ងៃទី ០៩ ខែតុលា ឆ្នាំ ១៩៧៦ ដើម្បីគាំទ្រការអះអាងរបស់គាត់ទាក់ទងនឹងសិទ្ធិអំណាចរបស់ មាស មុត លើមន្ទីរសន្តិសុខទឹកសាប[1480]។ ឯកសារទាំងនេះមិនបានគាំទ្រការអះអាងរបស់គាត់ទេ។ របាយការណ៍នេះបង្ហាញត្រឹមតែថា មានបុគ្គលម្នាក់ត្រូវបានចាប់ខ្លួននៅភាគខាងកើតនៃទឹកសាប។ របាយការណ៍នេះមិនបានបង្ហាញថា នរណាជាអ្នកចាប់ខ្លួន ទីតាំងជាក់លាក់នៃការចាប់ខ្លួន ឬ អ្នកដែលកំពុងសាកសួរបុគ្គលម្នាក់នោះឡើយ[1481]។ បើទោះបីជា មាស មុត បានផ្ញើទូរលេខនេះក៏ដោយ ក៏មិនមានន័យថា គាត់ជាអ្នកទទួលខុសត្រូវចំពោះព្រឹត្តិការណ៍ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍នោះដែរ។ ស្រដៀងគ្នានេះដែរ របាយការណ៍របស់ ឌឹម នៅក្នុងកិច្ចប្រជុំអគ្គសេនាធិការដែលថា មានក្មេងស្រីម្នាក់ អាយុ ១៣ ឆ្នាំ ត្រូវបានគេចាប់ខ្លួននៅក្បែរ

[1477] សេចក្តីរាយការណ៍ ចំណងជើងថា “សេចក្តីរាយការណ៍ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់ អំពីសភាពការណ៍នៅតាមព្រំដែនជាមួយនឹងថៃ” ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20 “ជូនអង្គការ៖ (១) យើងខ្ញុំឱ្យស្នើរកខ្សែខាងក្នុង (២) រកផ្លូវចេញចូល (៣) សភាពការណ៍ពួកអាក្បត់នៅតាមព្រំដែន”។

[1478] កថាខណ្ឌ ៦៣, ១៦០-៦៣, ៤៨៦-៩០ នៃដីកាសន្និដ្ឋានស្តាពរ។

[1479] ជើងទំព័រ ១៩៤, ៤៥៤-៥៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1480] កថាខណ្ឌ ១៦០-៦១ ជើងទំព័រ ៤៥៤-៤៥ កថាខណ្ឌ ៤៨៦-៨៧ ជើងទំព័រ ១៨២៥-២៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1481] ជើងទំព័រ ៤៥៤ និង ១៨២៥ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់សេចក្តីរាយការណ៍ ចំណងជើងថា “ជម្រាបជូន ៨៩ គោរពជ្រាប” ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.3។

ទឹកសាប ហើយស្នូរចម្លើយ[1482] បង្ហាញត្រឹមតែ ថា ក្មេងស្រីម្នាក់នោះ ដែលត្រូវបានគេចាប់នៅក្បែរទឹកសាប ហើយស្នូរចម្លើយប៉ុណ្ណោះ។ របាយការណ៍នេះមិនបានបង្ហាញថាមានមន្ទីរសន្តិសុខនៅទឹកសាប ឬថា មាស មុត បានទទួលខុសត្រូវលើមន្ទីរសន្តិសុខនេះ ឬថា មាស មុត ត្រូវបានគេ "ឱ្យដំណឹង" យ៉ាងច្បាស់អំពីលទ្ធផលនៃការស្នូរចម្លើយនៅទីនោះឡើយ[1483]។ ស្រដៀងគ្នានេះដែរ បើទោះបីជា សុន សេន បានបញ្ជាឱ្យកងពលធំលេខ ១៦៤ បញ្ឈប់ទឹកហូរចេញពី "ភ្នំ និង ព្រៃក ទឹកសាបតូចៗ" ក៏ដោយ[1484] ក៏នេះមិនមានន័យថា មានមន្ទីរសន្តិសុខនៅទឹកសាបដែល មាស មុត មានសិទ្ធិអំណាចលើនោះដែរ។

៤២២. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1485]។ គាត់បានអះអាងថា ទឹកសាប គឺជាមន្ទីរឃុំឃាំងកងពលធំលេខ ១៦៤[1486] ប៉ុន្តែគាត់ត្រឹមតែអះអាងថា មានថ្ងៃមួយនោះ ពេលគាត់ដើរទៅធ្វើការ គាត់ឃើញថាបុរសបីនាក់ជាប់ច្រវាក់ធ្វើការក្បែរទឹកសាប[1487]។ ប៉ាក សុខ ក៏បានផ្តល់សក្ខីកម្មផ្ទុយគ្នាដែរ អំពីអ្នកដែលត្រូវគេបញ្ជូនទៅទឹកសាប ដោយប្រាប់ ក.ស.ច.ស. ថា អ្នកប្រព្រឹត្តអំពើធ្ងន់ធ្ងរ ជាទូទៅ គេមិនយកទៅឃុំនៅទឹកសាបទេ[1488] ប៉ុន្តែក្រោយមកក៏បានប្រាប់អង្គជំនុំជម្រះសាលាដំបូងថា អ្នកប្រព្រឹត្តខុស ឬ បទល្មើសធ្ងន់ធ្ងរ ត្រូវបានបញ្ជូនទៅទីនោះទៅវិញ[1489]។

[1482] ជើងទំព័រ ៤៥៥ និង ១៨២៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខា និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.20 EN 00940340 KH 00052404-05។

[1483] កថាខណ្ឌ ៤៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1484] ជើងទំព័រ ១៨២៦ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D114/27.1.5 EN 00183980 KH 00052399។

[1485] *សូមមើល* កថាខណ្ឌ ២៣៣-៣៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1486] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 អ.៤០-៤១។ ជើងទំព័រ ១៨២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1487] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/27 អ.៦-១២។

[1488] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/27 អ.៨-៩។

[1489] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 14.07.12-14.11.54។

៤២៣. **ស្វាយ សំអាន៖** ស្វាយ សំអាន មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ភស្តុតាងផ្ទុយគ្នា អំពីទឹកសាប ហើយបានផ្តល់ចម្លើយដោយផ្អែកលើពាក្យចចាមអារ៉ាម។ ស្វាយ សំអាន គឺជាយុទ្ធជនធម្មតាម្នាក់នៅកងវរសេនាធំលេខ ៦៣ ដែលបានធ្វើការនៅអាកាសយានដ្ឋានកងកេង រហូតដល់ត្រូវបានគេបញ្ជូនទៅតំបន់ប៊ូព៉ា[1490]។ គាត់បាននិយាយថា គាត់គ្រាន់តែបានដឹងឮពី មាស មុត នៅពេលគាត់ផ្តល់ចម្លើយលើកដំបូងឱ្យ ក.ស.ច.ស. នៅឆ្នាំ ២០១៥ ប៉ុណ្ណោះ[1491] ប៉ុន្តែក្រោយមកគាត់បាននិយាយថា គាត់បានឃើញ មាស មុត ជិះឡានម៉ាកហ្សីបរបស់ចិន ត្រួតពិនិត្យគុកទឹកសាប[1492]។ បន្ទាប់មក គាត់បានសារភាពថា គាត់បានឮពីបុគ្គលិកក្រោមបង្គាប់ថា មាស មុត បានទៅពិនិត្យកន្លែងនោះជារៀងរាល់ប្អូនទៅប្រាំខែម្តង ប៉ុន្តែមិនបានឃើញហេតុការណ៍នោះដោយផ្ទាល់ទេ[1493]។ គាត់ក៏បាននិយាយផងដែរថា គាត់មិនមែនជាអ្នកយាមនៅទឹកសាប ដូចអ្វីដែលសាក្សីម្នាក់ផ្សេងទៀតបានអះអាងនោះឡើយ[1494]។ គាត់បាននិយាយថា គាត់មិនដែលទៅទឹកសាបទេ[1495] ហើយគាត់ក៏មិនបានដឹងពីការប្រើប្រាស់មន្ទីរនោះធ្វើអ្វីនោះដែរ[1496]។ បន្ទាប់មក គាត់ចង់ប្រាប់ការពិត និងបាននិយាយថា គាត់បានចម្អិនអាហារឱ្យអ្នកយាមនៅទីនោះ[1497]។

៤២៤. ស.ព.អ. ដកស្រង់សាក្សីជាច្រើនផ្សេងទៀត ដែលអះអាងថា ទឹកសាប គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៥[1498]។ ចម្លើយរបស់សាក្សីទាំងនេះភាគច្រើន ផ្អែកលើការទាយស្មានពាក្យចចាមអារ៉ាម ឬ ការបង្ហាញខុស។ ឡុង ផាន់ស៊ី មេបញ្ជាការកងវរសេនាតូចកាំភ្លើងធំ[1499]

[1490] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/114 អ.១១, អ.១៥, អ.២៦-២៧។

[1491] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/114 អ.១៩-២០។

[1492] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/116 អ.៦-៨។ ជើងទំព័រ ១៨២៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ១៩៤, ៤៥៦-៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1493] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/116 អ.៩-១១។

[1494] *សូមមើលខាង.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/114 អ.៣៧-៣៨, អ.៤០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/115 អ.២៦។

[1495] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/114 អ.២៨។

[1496] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/114 អ.៣៥-៣៦។

[1497] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/115 អ.២៧-២៨។

[1498] ជើងទំព័រ ១៨២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1499] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 អ.១៥។

បានអះអាងថា ទឹកសាបស្ថិតក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៥[1500] ប៉ុន្តែ ភ្លាមៗនោះ បានបញ្ជាក់ការអះអាងរបស់គាត់ ដោយនិយាយថា "នេះគ្រាន់តែជាការសន្និដ្ឋានរបស់ខ្ញុំទេ"[1501]។ សំ សោម បានឈរជើងលើកោះ ហើយបន្ទាប់មកនៅវាម[1502] បាននិយាយថា មាស មុត បានគ្រប់គ្រងលើគុកទឹកសាប[1503]។ គាត់បានឮរឿងនេះពីអ្នករួមការងារជាមួយគាត់[1504]។ ម៉ាក ឈឿន គឺជាមេបញ្ជាការកងវរសេនាតូចលេខ ៥៦០ នៅលើកោះថ្មី[1505] បាននិយាយថា ទឹកសាប គឺជាមន្ទីរឃុំខ្លួនតែមួយគត់របស់កងពលធំលេខ ១៦៥ ដែលគាត់បានស្គាល់[1506] ប៉ុន្តែ គាត់បានឮរឿងនេះពីទាហានកងវរសេនាធំលេខ ៦៣[1507]។ គាត់ក៏បានបង្ហាញផងដែរថា មេបញ្ជាការបានសម្រេចដោយចិត្តខ្លួនឯងក្នុងការបញ្ជូនទាហានទៅទឹកសាប[1508]។ គាត់បានឮថា ជនជាប់ឃុំទាំងអស់ត្រូវបានដោះលែង[1509] ដែលបញ្ជាក់ដោយ ហៀង វ៉ែត[1510]។ កុយ ណែន ដែលជាអ្នកនេសាទនៅជិតទឹកសាប[1511] មិនដែលបានទៅគុកទឹកសាបនោះទេ[1512] ហើយមិនដែលបានឃើញអ្នកទោសឡើយ[1513]

[1500] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 អ.៤១។

[1501] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ឯកសារ D114/208 អ.៤១។

[1502] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/20 អ.២-៤។

[1503] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/20 ស-អ.១០។ *សូមមើលផងដែរ* ជើងចំពរ ៤៥៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1504] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/20 អ.១១-១២។

[1505] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/18 ស-អ.២២, អ.៣២។

[1506] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/19 ស-អ.៨។

[1507] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/18 អ.៤៧ (នៅក្នុង អ.៣៨-៣៩ គាត់និយាយថា គាត់ធ្លាប់ឃើញមន្ទីរឃុំឃាំង ដោយសារគាត់ធ្វើដំណើរកាត់តាមនោះ ប៉ុន្តែក្រោយមកគាត់និយាយថា គាត់ឮពីយោធាវរសេនាធំ ៦៣ ថា វាអាចជាមន្ទីឃុំឃាំង)។

[1508] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/18 អ.៤២-៤៣ (ឆ្លើយថា គាត់មិនដែលបញ្ជូនយោធារបស់គាត់ដែលធ្វើខុសទៅទឹកសាបនេះទេ ប៉ុន្តែគាត់មិនអាចនិយាយជំនួសកងដទៃៗទៀតទេ)។

[1509] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/18 អ.៣៨។

[1510] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង វ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 អ.១៤១-៤២។

[1511] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 អ.១២។

[1512] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 អ.២០, អ.២២។

[1513] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 អ.១៩, អ.២១។

និង បានត្រឹមតែឮពីទាហានថា វាគឺជាកន្លែងឃុំខ្លួន ឬ គុកតែប៉ុណ្ណោះ[1514]។ ប្រាក់ ប៊ុននី សមាជិកនៅក្នុងកងកុមារ[1515] បាននិយាយថា គ្រប់គ្នាបានដឹងអំពីគុកទឹកសាប[1516] ប៉ុន្តែគាត់បានដឹងដោយផ្អែកលើពាក្យចចាមអារ៉ាម[1517] ហើយនឹងអ្វីដែលគាត់បានឃើញក្រោយខែមករា ឆ្នាំ ១៩៧៩[1518]។ សុក វណ្ណា ដែលចូលកងទ័ពនៅក្នុងឆ្នាំ ១៩៧៧[1519] ភាគច្រើននៅសមុទ្រ ឬ នៅលើកោះ ហើយទៅលេងដីគោកប្រហែលនៅរៀងរាល់ប្រាំមួយខែម្តង[1520]។ ស.ព.អ. ដកស្រង់ដោយមិនត្រឹមត្រូវនូវសំដីរបស់គាត់ ដើម្បីអះអាងថា ជនមេបញ្ជាការកងវរសេនាធំលេខ ៦៣ នៅទឹកសាប បានទទួលបញ្ជាផ្ទាល់ពី មាស មុត[1521]។ សុក វណ្ណា បាននិយាយថា ជន ទទួលបញ្ជាដោយផ្ទាល់ពី មាស មុត[1522]។ គាត់បានសំដៅលើមេបញ្ជាការរបស់កប៉ាល់ប្រឆាំងនាវាមុជទឹករបស់គាត់ មិនមែនមេបញ្ជាការកងវរសេនាធំលេខ ៦៣ នោះទេ[1523]។

៤២៥. ស.ព.អ. អះអាងថា មាស មុត បានធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំទៀងទាត់ជាមួយមេបញ្ជាការកងវរសេនាធំ ដោយសន្និដ្ឋានថា រួមទាំងមេបញ្ជាការកងវរសេនាធំដែលមើលការខុសត្រូវនៅទឹកសាប

[1514] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 ស.១៣-១៤, ស.១៩។

[1515] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 ស.៩។

[1516] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 ស.៩៨។

[1517] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 ស.៨២, ស.៨៦ "ស.៨២ ៖ ខ្ញុំឮសូរមេៗខ្ញុំនិយាយថា សុទ្ធតែកងទ័ពខុសនយោបាយ ខុសអី...។ ស.៨៦៖ ... ខ្ញុំសួរគ្នីគ្នាដែលធ្លាប់ឃើញប្លឹង គេថាបញ្ជូនទៅទឹកសាបបាត់អស់ហើយ"។

[1518] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 ស.៩៣-៩៤។

[1519] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 ស.៤-៦។

[1520] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/15 ស.១៩, ស.២១។ សុក វណ្ណា ចូលកងវរសេនាធំ ១៤០ នៅក្នុងឆ្នាំ ១៩៧៧ ហើយក្រោយមកទៀត គាត់ពុំដឹងពីរឿងកងទៀតទេ។ នៅមុនពេលចូលកងជើងទឹក គាត់នៅក្នុងកងវរសេនាធំ ៣៣ ដែលគាត់និយាយថាមានទីបញ្ជាការនៅទឹកសាប ស្ថិតនៅក្រោមបញ្ជារបស់យ៉ាន។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 ស.៤-៦។

[1521] កថាខណ្ឌ ៤៨៩ ជើងចំព័រ ១៨៤២ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/15 ស.២៦។

[1522] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/15 ស.២៦។

[1523] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/15 ស-ស.២៦ "ស៖ តើអ្នកណាជាមេកងកប៉ាល់ប្រឆាំងនាវាមុជទឹក? ស.២៦៖ ខ្ញុំនៅលើនាវា ០១១ ហើយមេបញ្ជាការខ្ញុំឈ្មោះ ជន។ ជន ទទួលបញ្ជាដោយផ្ទាល់មាត់ពី មាស មុត។ នាវាប្រឆាំងនឹងនាវាមុជទឹកទាំងពីរគ្រឿងស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ មាស មុត"។

ដែរ[1524]។ ស.ព.អ. ដកស្រង់ ឌុល សុង ជេត ប៊ុណ្ណា ម៉ាក ឈឿន និង ស៊ឹម នី[1525]។ សាក្សីទាំងនេះភាគច្រើនមិនបាននិយាយពីខ្លឹមសារនៃកិច្ចប្រជុំនោះទេ គ្រាន់តែនិយាយថាមានការប្រជុំរៀបចំឡើងប៉ុណ្ណោះ។ ឌុល សុង ដែល "គ្រាន់តែជាទាហានធម្មតា" [1526] បានអះអាងថា មាស មុត បានធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំទៀងទាត់រវាងមេបញ្ជាការកងវរសេនាធំ និង កងវរសេនាតូចពិសេស[1527]។ គាត់មិនបានចូលរួមកិច្ចប្រជុំទាំងនោះទេ[1528]។ ជេត ប៊ុណ្ណា បានអះអាងថា មាស មុត បានកោះហៅមេបញ្ជាការកងវរសេនាតូច និង កងវរសេនាធំ ទៅកន្លែងរបស់គាត់ដើម្បីទទួលបញ្ជា[1529]។ ដោយសារតែឋានន្តរសក្តិ និង ទីតាំងឈរជើងរបស់គាត់[1530] គាត់មិនអាចដឹងលម្អិតអំពីកិច្ចប្រជុំបែបនេះទេ។ លុន សេង[1531] បាននិយាយត្រឹមតែថា មាស មុត បានធ្វើជាប្រធាននៅក្នុងកិច្ចប្រជុំពិសេសដែលរៀបចំឡើងសម្រាប់ថ្នាក់ដឹកនាំកងវរសេនាតូច និង កងវរសេនាធំមួយចំនួន អំពីយោធាភូមិភាគបូព៌ា[1532]។ គាត់មិនបាននិយាយថា មាស មុត បានរៀបចំកិច្ចប្រជុំទៀងទាត់សម្រាប់មេបញ្ជាការកងវរសេនាតូច និង កងវរសេនាធំនោះទេ។ ម៉ាក ឈឿន បាននិយាយថា ទាំង ឌឹម ទាំង មាស មុត បានធ្វើជាប្រធានកិច្ចប្រជុំ[1533]។ ស៊ឹម នី[1534] បានអះអាងថា បានឃើញមេបញ្ជាការពីចម្ងាយ ដែលបានមកដល់ផ្ទះរបស់ មាស មុត[1535]។ គាត់មិនបាននិយាយថា គាត់បានចូលរួមកិច្ចប្រជុំណាមួយបែបនេះទេ។

[1524] កថាខណ្ឌ ៤៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1525] ជើងទំព័រ ១៨៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1526] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឆ.២៧។

[1527] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/7 ឆ.១៤-១៥។

[1528] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឆ.៥-៦, ឆ.៩។

[1529] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ឆ.២០។

[1530] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1531] *សូមមើល* កថាខណ្ឌ ១៩៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1532] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/44 ឆ.២៦-២៨។

[1533] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/19 ឆ.១៦-១៧។

[1534] *សូមមើល* កថាខណ្ឌ ២៤៥ និង ៤០៦-០៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1535] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/31 ឆ.៦។ ជើងទំព័រ ១៨៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

គ. ការដ្ឋានស្នឹងហាវ

៤២៦. ស.ព.អ. អះអាងថា មាស មុត បានទៅពិនិត្យ និង បានទទួលខុសត្រូវលើការដ្ឋានស្នឹងហាវ រួមទាំងរៀបចំប្រជុំនៅទីនោះផងដែរ[1536]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន ឬ គ្មានមូលដ្ឋានគាំទ្ររបស់ អ៊ុយ ញឹក មាស អ៊ឹម ឡុង ផាន់ស៊ី ប្រេស មៀន និង ប៉ែន សារិន[1537]។ គាត់ក៏ដកស្រង់ភស្តុតាងឯកសារដែលមិនគាំទ្រការអះអាងរបស់គាត់ផងដែរ។

៤២៧. **អ៊ុយ ញឹក**៖ អ៊ុយ ញឹក មិនអាចជឿជាក់បានទេ ទាក់ទងនឹង មាស មុត និង ស្នឹងហាវ[1538]។ បើទោះបីជា ស.ច.ស. ចាត់ទុកថាចម្លើយរបស់ អ៊ុយ ញឹក អាចជឿជាក់បានក៏ដោយ ក៏ចម្លើយទាំងនេះមិនបានបង្ហាញថា មាស មុត បានទៅពិនិត្យមើលស្នឹងហាវ “ជាច្រើនលើកច្រើនសារ ពេលខ្លះញឹកញាប់រហូតដល់រៀងរាល់សប្តាហ៍” នោះដែរ[1539]។ ចម្លើយទាំងនេះក៏មិនបានបង្ហាញថា មាស មុត បានចុះទៅពិនិត្យមើលទីតាំងនោះ ឬ មានសិទ្ធិអំណាចលើទីតាំងនោះដែរ។ ចម្លើយរបស់គាត់បង្ហាញត្រឹមតែថា មាស មុត បានបើកឡានកាត់ស្នឹងហាវប៉ុណ្ណោះ។

៤២៨. **មាស អ៊ឹម**៖ មាស អ៊ឹម មិនអាចជឿជាក់បានឡើយ[1540]។ គាត់បាននិយាយថា មាស មុត បានចាប់ផ្តើមទៅពិនិត្យមើលស្នឹងហាវនៅពាក់កណ្តាលឆ្នាំ ១៩៧៦[1541] ហើយបានណែនាំ មៀញ ប្រធានស្នឹងហាវ តាមទូរស័ព្ទ និង ទូរលេខ[1542]។ គាត់បាននិយាយថា គាត់បានដឹង មាស មុត ទាក់ទងជាមួយ មៀញ ដោយសារគាត់បានឃើញឧបករណ៍នៅផ្ទះមៀញ[1543]។ ទោះបីជាយ៉ាងនេះក្តី មាស

[1536] កថាខណ្ឌ ៦៣, ១៩៣-៩៧, ៦០៥-១២ នៃដីកាសន្និដ្ឋានស្តាពរ។

[1537] ជើងចំព័រ ១៩៤, ២៣៥៨-៦២, ២៣៦៥-៦៩, ២៣៧៣-៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1538] *សូមមើល* កថាខណ្ឌ ២៥២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីចម្លើយរបស់សាក្សីរូបនេះ។

[1539] កថាខណ្ឌ ៦០៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៩៧។

[1540] *សូមមើល* កថាខណ្ឌ ២៥៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1541] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ស-អ.៦២, ស-អ.៦៤។ កថាខណ្ឌ ៦០៥, ៦០៨ និង ជើងចំព័រ ២៣៥៩, ២៣៦១, ២៣៧៣-៧៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កថាខណ្ឌ ១៩៧, ៦១០ និង ជើងចំព័រ ១៩៤, ៥៣៦-៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1542] កថាខណ្ឌ ៦០៨ ជើងចំព័រ ២៣៧៣-៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1543] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 អ.៧៥-៧៦។ ជើងចំព័រ ២៣៧៤-៧៥ នៃដីកាសន្និដ្ឋានស្តាពរ។

អ៊ឹម ក៏បាននិយាយផងដែរថា គាត់មិនបានទៅស្នឹងហាវ ឬ ជួប មាស មុត ទេរហូតដល់ឆ្នាំ ១៩៧៧[1544]។

៤២៩. **ឡុង ផាន់ស៊ី**៖ ឡុង ផាន់ស៊ី មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។ គាត់ត្រូវបានផ្ទេរទៅធ្វើការនៅស្នឹងហាវនៅក្នុងឆ្នាំ ១៩៧៦[1545]។ គាត់បាននិយាយថា គាត់បានឃើញ មាស មុត នៅស្នឹងហាវនៅពេលពួកគេសម្ពោធការដ្ឋាន ឬ នៅពេលចិនចុះទៅពិនិត្យមើល[1546]។ ការណ៍ដែលថា មាស មុត អាចមានវត្តមាននៅស្នឹងហាវនៅពេលសម្ពោធស្នឹងហាវ ឬ នៅពេលអ្នកចុះពិនិត្យមើលជនជាតិចិននៅទីនោះ មិនមានន័យថា គាត់មានសិទ្ធិអំណាចលើទីតាំងនោះទេ។ ឡុង ផាន់ស៊ី បានអះអាងថា "ពួកគេ" មិនអនុញ្ញាតឱ្យគាត់ចូលទៅជិត មាស មុត ឡើយនៅស្នឹងហាវ ពីព្រោះ "ពួកគេ" លែងទុកចិត្តគាត់ទៀតហើយ[1547] ដោយបានបង្ហាញថា អ្នកផ្សេងក្រៅពី មាស មុត ដែលមានសិទ្ធិអំណាចលើស្នឹងហាវ។

៤៣០. **ប្រេស មាន**៖ ប្រេស មាន មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។ មេបញ្ជាការកងវរសេនាតូចរបស់គាត់បានបញ្ជូនគាត់ទៅស្នឹងហាវនៅក្នុងឆ្នាំ ១៩៧៦[1548]។ គាត់គឺជាសាក្សីតែម្នាក់គត់ដែល ស.ព.អ. ដកស្រង់ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានរៀបចំកិច្ចប្រជុំនៅស្នឹងហាវ[1549]។ ប្រេស មាន បាននិយាយថា នៅពាក់កណ្តាលឆ្នាំ ១៩៧៧ គាត់បានចូលរួមកិច្ចប្រជុំមិនទៀងទាត់មួយនៅស្នឹងហាវ ដែលដឹកនាំដោយ មាស មុត[1550]។ ចម្លើយនេះបានបង្ហាញអំពីកិច្ចប្រជុំពិសេសមួយតែប៉ុណ្ណោះ មិនមែនកិច្ចប្រជុំច្រើន ឬ ទៀងទាត់នោះទេ។ មាស អ៊ឹម មិនបានដឹង

[1544] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/214 ឆ.២៥, ឆ.២៨-២៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ឆ.៣៩។

[1545] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 ឆ.១៥។

[1546] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 ស-ឆ.២៦។ ជើងទំព័រ ៥៣៦-៣៧, ២៣៥៩-៦០ នៃដីកាសន្និដ្ឋានស្តាពរ។

[1547] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 ឆ.២៦។

[1548] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/12 ឆ.៤, ឆ.៦, ឆ.១១-១២, ឆ.១៤-១៥, ឆ.១៧។

[1549] កថាខណ្ឌ ៦០៦ ជើងទំព័រ ២៣៦៥-៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1550] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/12 ឆ.២៣, ឆ.២៥, ឆ.២៨, ឆ.៣០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/13 ស-ឆ.១-២, ស-ឆ.៤, ស-ឆ.១៧។ ជើងទំព័រ ២៣៦៥-៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

អំពីកិច្ចប្រជុំបែបនោះទេ[1551]។ សាក្សីផ្សេងទៀតបាននិយាយថា សមាជិកផ្សេងទៀតនៃកងពលធំលេខ ១៦៥ បានរៀបចំកិច្ចប្រជុំនៅស្ទឹងហាវ មិនមែន មាស មុត ជាអ្នករៀបចំនោះទេ[1552]។

៤៣១. ស.ព.អ. ព្យាយាមរកមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានរៀបចំកិច្ចប្រជុំនៅស្ទឹងហាវ ដោយបានដកស្រង់របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស. ដែលរួមបញ្ចូលការអះអាងដែលថា "កិច្ចប្រជុំត្រូវបានរៀបចំឡើងដោយ មាស មុត [នៅមូលដ្ឋានយោធានៅស្ទឹងហាវ] នៅពាក់កណ្តាលឆ្នាំ ១៩៧៧"[1553]។ ការអះអាងគ្មានប្រភពនេះ បានផ្អែកលើចម្លើយរបស់ ប្រេស មាន ដោយសារទស្សនកិច្ចនៅទីតាំងនេះត្រូវបានធ្វើឡើងជាមួយគាត់[1554]។ របាយការណ៍នេះមិនគាំទ្រការអះអាងរបស់ ស.ព.អ. ហើយមានតម្លៃជាភស្តុតាងតិចតួចតែប៉ុណ្ណោះ។ គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីកំណត់ជាក់ស្តែងទីកន្លែងដែលអាចជាទីតាំងឧក្រិដ្ឋកម្ម មិនមែនដើម្បីបង្ហាញការអះអាងអំពី មាស មុត នោះឡើយ[1555]។

៤៣២. **ប៉ែន សារិន**៖ ប៉ែន សារិន មិនអាចជឿជាក់បានឡើយ[1556]។ គាត់បានប្រាប់ ក.ស.ព. ថា មាស មុត បានទៅពិនិត្យស្ទឹងហាវជាច្រើនដង ហើយបានស្នាក់នៅមួយយប់នៅកន្លែងតែមួយ

[1551] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 ស-ឆ.៨១-៨២។ ប្រសិនបើ ស.ច.ស. ពិចារណាចម្លើយរបស់ មាស អ៊ឹម អាចគួរឱ្យជឿជាក់ និង មានតម្លៃជាភស្តុតាង ស.ច.ស. ក៏ត្រូវពិចារណាចម្លើយនេះដែរ។

[1552] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី ១ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/130 ឆ.១២២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 ឆ.២៤-២៥។ *សូមមើលផងដែរ* ជើងទំព័រ ២៣៧៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1553] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/60 EN 01082179។ ជើងទំព័រ ២៣៦៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1554] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/60 EN 01082172។

[1555] ក.ស.ច.ស. បានកត់សម្គាល់ថា៖ "របាយការណ៍នេះ គឺគ្រាន់តែជា**របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង** វាមិនមែនជាកោសល្យវិច័យ ឬ របាយការណ៍ទិដ្ឋភាពឧក្រិដ្ឋកម្ម ឬ របាយការណ៍ទូលាយបង្ហាញអំពីឧក្រិដ្ឋកម្ម និង ព្រឹត្តិការណ៍បានកើតឡើងទេ ពីព្រោះថាវាគ្រាន់តែជាការត្រួតពិនិត្យបឋម និង ការវាស់វែងស្វែងរកការពិតត្រូវបានធ្វើតាមរយៈ (រូបថត ការវាស់វែង ការកំណត់ទីតាំង GPS ការពណ៌នា គំនូរ ការបង្ហាញទីតាំងផ្សេង)។ មិនមានការវាស់វែងបន្តទៀត (ដូចជា ការគាស់កកាយផ្សេង) ត្រូវបានធ្វើឡើង ហើយក៏គ្មានអ្វីត្រូវរឹបអូសដែរ"។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/60 ជើងទំព័រ ១ (ការគូសបញ្ជាក់នៅក្នុងឯកសារដើម)។

[1556] *សូមមើល* កថាខណ្ឌ ៤១៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

ដែលអ្នកជំនាញការចិនបានស្គាក់នៅ[1557]។ ទៅកាន់ ក.ស.ច.ស. គាត់បាននិយាយថា គាត់មិនដែលបានឃើញ មាស មុត នោះឡើយ ហើយថា មាស មុត មិនដែលមកកន្លែងធ្វើការរបស់គាត់នោះទេ[1558]។

៤៣៣. ស.ព.អ. អះអាងថា ស្នឹងហាវត្រូវបានយកមកពិភាក្សានៅក្នុងកិច្ចប្រជុំកងពលធំលេខ ១៦៤ ហើយថា មាស មុត ត្រូវបាន "កោតសរសើរ" អំពីបញ្ហាពាក់ព័ន្ធនឹងស្នឹងហាវ រួមទាំង ការស្រាវជ្រាវរកខ្លាំងជាដើម[1559]។ នៅក្នុងកិច្ចខិតខំបង្ហាញមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ ស.ព.អ. បង្ហាញខុសនូវកំណត់ហេតុនៃកិច្ចប្រជុំចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ រវាង សុន សេន និង សមាជិកគ្មានអត្តសញ្ញាណនៃកងពលធំលេខ ១៦៤[1560]។ គ្មានការចង្អុលបង្ហាញថា មាស មុត មានវត្តមាន ឬ មានតួនាទីណាមួយនៅក្នុងកិច្ចប្រជុំនេះឡើយ[1561]។ ស្នឹងហាវត្រូវបានលើកឡើងម្តងពាក់ព័ន្ធនឹងកងកម្លាំងមកពីជ្រោយចង្វារវៀបចំចុះចូល[1562]។ កំណត់ហេតុប្រជុំត្រង់ផ្នែកនេះដែល ស.ព.អ. ដកស្រង់ ទាក់ទងនឹងការណែនាំរបស់ សុន សេន អំពីកងទ័ពចំនួន ៤០ នាក់ ដែលបានព្យាយាមរត់ចេញពីស្នឹងហាវ។ កំណត់ហេតុប្រជុំនេះមិនជាប់ពាក់ព័ន្ធទូទៅនឹងស្នឹងហាវ ឬ ការស្រាវជ្រាវរកខ្លាំងជារួមនោះទេ[1563]។

៤៣៤. ស.ព.អ. អះអាងថា ទូរលេខចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩៧៦ និង ទូរលេខចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ បង្ហាញអំពីសិទ្ធិអំណាចរបស់ មាស មុត និង ការដឹងឮអំពីស្នឹងហាវ រួមទាំងឧក្រិដ្ឋកម្ម

[1557] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ ប៉ែន សារិន ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1.3.13.8 EN 00217560។ ជើងទំព័រ ៥៣៦-៣៧, ២៣៦៣ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ១៤១ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាភស្តុតាង។

[1558] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7 ឆ.៧។

[1559] កថាខណ្ឌ ៦០៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៩៥-៩៦។

[1560] ជើងទំព័រ ២៣៧០-៧១ នៃដីកាសន្និដ្ឋានស្តាពរ។

[1561] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657354-00657356 KH 00162488-00162490។

[1562] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657355 KH 00162489។

[1563] កថាខណ្ឌ ៦០៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657356 KH 00162490។

ដែលបានប្រព្រឹត្តនៅទីនោះ[1564]។ សារទូរលេខទាំងនេះមិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។ សារទូរលេខចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩៧៦ មិនទាក់ទងនឹងស្នឹងហាវឡើយ ប៉ុន្តែ ទាក់ទងនឹងទូកមួយដែលឈប់នៅស្នឹងហាវ[1565]។ ជាជាងបង្ហាញអំពីសិទ្ធិអំណាច មាស មុត លើស្នឹងហាវ សារទូរលេខ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៧៦ បង្ហាញសិទ្ធិអំណាចរបស់ ឌឹម លើទីតាំងនោះ។ ឌឹម អាចធ្វើសេចក្តីសម្រេចលើកងទ័ពនៅទីនោះបាន ដូចបានបង្ហាញតាមរយៈសេចក្តីសម្រេចរបស់គាត់ផ្ទេរយុទ្ធជនចំនួនពីរនាក់ចេញពីស្នឹងហាវ[1566]។

៤៣៥. សាក្សីផ្សេងទៀតបាននិយាយថា មាស មុត មិនបានទៅស្នឹងហាវនោះទេ។ អៀម ភង់ ដែលបាននៅទីនោះអស់រយៈពេលពីរឆ្នាំ គ្រាន់តែធ្លាប់បានឃើញសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៥ ឈ្មោះ ឆាន និង ឌឹម ប៉ុណ្ណោះ។[1567] អែម សុន[1568] ជេត ប៊ុណ្ណា[1569] និង ប្រាក់ សុខា[1570] បាននិយាយថា មាស មុត មិនបានទៅពិនិត្យមើលស្នឹងហាវនោះទេ។ សុខ នាង ដែលមកពីកងវរសេនាតូចលេខ ១៦៧[1571] ក៏មិនបានឃើញ មាស មុត នៅទីនោះដែរ[1572]។

[1564] កថាខណ្ឌ ១៩៥, ៦០៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1565] ទូរលេខ ចំណងជើងថា "ទូរលេខពី មុត ជម្រាបបង ៨៩ គោរពជ្រាប" ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ D4.1.1020 EN 00525783 KH 0021459។ ជើងទំព័រ ៥២៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1566] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ជូនបងមុតជ្រាប អំពីសភាពការណ៍ខ្មាំងនៅតាមព្រំដែន" ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699។ ជើងទំព័រ ២៣៧៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កថាខណ្ឌ ៦០៨ នៃដីកាសន្និដ្ឋានស្តាពរ ដែល ស.ព.អ. អះអាងថា ឌឹម និង ឆាន "មានការទទួលខុសត្រូវមួយចំនួនលើស្នឹងហាវ" នៅមុនការចាប់ខ្លួនរបស់ពួកគេ។

[1567] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី ១ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/130 ស.-អ.១១៥។ ទោះជានៅពេលនោះ គាត់ឆ្លើយថា បញ្ជាពី មាស មុត ពីព្រោះ មាស មុត ជាអ្នកគ្រប់គ្រងនៅកំពង់សោម ស្នឹងហាវនៅជិតកំពង់សោម ហើយការកសាងយោធាកំពុងធ្វើនៅស្នឹងហាវ ចម្លើយទាំងនេះ គឺជាការបំផ្លើស ព្រោះគាត់មិនដែលឃើញ មាស មុត។ *ដូចខាងលើ* អ.១៣៦-៣៧, អ.១៤៦។

[1568] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/49 អ.៣២-៣៣។

[1569] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 អ.២០។ ជេត ប៊ុណ្ណា ឆ្លើយថា គាត់ធ្លាប់ឮ មាស មុត ទៅស្នឹងហាវ មុនពេល ជេត ប៊ុណ្ណា ទៅធ្វើការនៅទីនោះ។ ទោះជាយ៉ាងនេះក្តី ចម្លើយនេះមានតម្លៃជាភស្តុតាងតិចតួចបំផុត ដោយការផ្អែកលើពាក្យចចាមអារ៉ាម។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ D114/86 ស-អ.២៥។

[1570] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/36 អ.១៧-១៨។

[1571] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 អ.៥, អ.១៣។

ឃ. ការដ្ឋាន និង សហការណ៍តំបន់រាម

៤៣៦. ស.ព.អ. អះអាងថា មាស មុត បានចុះពិនិត្យតាមដាន និង ទទួលខុសត្រូវលើការដ្ឋាននិងសហការណ៍តំបន់រាម[1573]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន និង គ្មានមូលដ្ឋានគាំទ្ររបស់ សយ ប៊ិន អ៊ុក សុក ប្រាក់ សុខា សឹង ណុច យិន តេង សុក វណ្ណា សំ សោម ជេត ប៊ុណ្ណា គុយ សម្បត្តិ និង ឡុង លី ព្រមទាំងភ័ស្តុតាងឯកសារផងដែរ[1574]។

៤៣៧. **សយ ប៊ិន**៖ សយ ប៊ិន មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ផ្អែកលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ គាត់គឺជាទាហានឈរជើងនៅស្នាច់ដែងរហូតដល់ឆ្នាំ ១៩៧៦ នៅពេលដែលគាត់ផ្លាស់ទៅអូរឈើទាល[1575]។ គាត់បានអះអាងថា ទីតាំងឡឥដ្ឋកែងកងស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៥ ពីព្រោះ មាស មុត បានចុះទៅពិនិត្យមើលការងារនៅទីនោះ[1576]។ មិត្តភ័ក្ត្ររបស់គាត់បានប្រាប់គាត់ថា មាស មុត បានមកមើលកន្លែងនោះ[1577]។ យោងតាមចម្លើយនេះ សយ ប៊ិន បានសន្និដ្ឋានថា មាស មុត បានចុះពិនិត្យដល់ទីតាំងនោះ ហេតុដូច្នេះហើយ ទើបទីតាំងនោះស្ថិតនៅក្រោមកងពលធំលេខ ១៦៥[1578]។

៤៣៨. **អ៊ុក សុក**៖ អ៊ុក សុក មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ផ្អែកលើពាក្យចចាមអារ៉ាម។ គាត់ក៏បានផ្តល់ចម្លើយផ្ទុយគ្នា ហើយមានបញ្ហាការចងចាំផងដែរ។ គាត់គឺជាអ្នកមើលក្មេងនៅកំពង់សោម[1579]។ គាត់បានឮថា មាស មុត បានទៅមើលវាលស្រែនៅជិតព្រំណាន់យន្តហោះ

[1572] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ស-អ.៤២។

[1573] កថាខណ្ឌ ៦៣, ១៨៦-៩២, ៦៦២-៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1574] ជើងទំព័រ ១៩៤, ៥១៣-២៤, ២៦៦៨-៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1575] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D2/9 អ.៣, អ.៧, អ.៩-១០, អ.៤៤, អ.៥៥។

[1576] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 អ.១៤-១៥។ ជើងទំព័រ ១៩៤, ៥២០, ២៦៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1577] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 អ.១៦។

[1578] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 អ.១៥។

[1579] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 ស-អ.៥១-៥២។

កងកេង និង ពេលខ្លះបានឮថាគាត់បានឈរនៅលើផ្លូវជាតិ[1580]។ គាត់មិនដែលបានជួប មាស មុត នោះឡើយ[1581]។ គាត់មិនបានដឹងថា នរណាជាអ្នកមើលការខុសត្រូវលើខេត្តកំពង់សោមនោះ ទេ[1582]។ ទោះបីជាគាត់បានអះអាងថា កងពលធំលេខ ៣ មើលការខុសត្រូវលើការដ្ឋានការងារនៅ ជិតសហករណ៍របស់គាត់ក៏ដោយ ក៏គាត់មិនចងចាំថាតើកងពលធំលេខ ៣ បានក្លាយទៅជា អង្គភាពអ្វីទេ រហូតដល់អ្នកស៊ើបអង្កេត ក.ស.ច.ស. បានប្រាប់គាត់នូវឈ្មោះកងពលធំថ្មី ដែលនៅ ពេលនោះគាត់បានយកតាមចម្លើយរបស់អ្នកស៊ើបអង្កេត[1583]។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នានៅក្នុង ការស្តាប់ចម្លើយរបស់ ក.ស.ច.ស. និង កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំងទាក់ទង នឹងអ្នកមើលការខុសត្រូវលើមន្ទីរពេទ្យកងពលធំលេខ ១៦៥[1584] ក្បែងៗប៉ុន្មាននាក់ស្ថិតនៅក្នុង អង្គភាពរបស់គាត់ ហើយម្ហូបចំនួនប៉ុន្មានដែលពួកគេបានទទួល[1585] និង ថាតើមានមនុស្សបាត់ខ្លួន និង ចាប់ខ្លួនពីសហករណ៍របស់គាត់ដែរឬយ៉ាងណា[1586]។ គាត់ក៏បានទទួលស្គាល់ផងដែរថាគាត់ មានបញ្ហាការចងចាំ ដោយបានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា៖ “ដូចនៅពេលនេះ បន្ទាប់ពី ខ្ញុំនិយាយហើយ ខ្ញុំភ្លេចអស់”[1587]។

៤៣៩. **ប្រាក់ សុខា**៖ ប្រាក់ សុខា មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ផ្អែកលើពាក្យចចាម អារ៉ាម ហើយការស្តាប់ចម្លើយគាត់ដោយ ក.ស.ច.ស. ត្រូវបានធ្វើឱ្យខូច។ គាត់ស្ថិតនៅក្នុងកង កាំភ្លើងធំរហូតដល់ពេលគេផ្លាស់គាត់ទៅកងចល័តនៅកេងកង និង បន្ទាប់មកទៅស្ទឹងហារ[1588]។

[1580] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 ស-អ.២១៦-១៧, ស-អ.២២៤។ ជើងទំព័រ ៥២០, ២៦៧៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1581] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៦៤។

[1582] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 ស-អ.២៤៩។

[1583] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 ស-អ.២៥១-៥៣។ ជើងទំព័រ ២៦៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1584] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៨៣-៨៩។

[1585] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.១០២-០៣, អ.១១០-១៧។

[1586] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.១៤៧-៥២។

[1587] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.១៥០។ *សូមមើលផងដែរ ដូចខាងលើ* អ.១៥១ (ដែលនិយាយថា ខ្ញុំអត់មានប្រយិតទេ តែឥឡូវនេះខ្ញុំភ្លេចច្រើន)។

[1588] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/35 អ.១០, អ.១២, អ.១៧។

គាត់បានឮ "ពីមាត់មួយទៅមាត់មួយ" ថា មាស មុត បានមើលការខុសត្រូវលើភូមិភាគ ប៉ុន្តែមិនច្បាស់លើចំណុចនេះទេ ពីព្រោះគាត់មិនត្រូវបានអនុញ្ញាតឱ្យដឹងអំពីបញ្ហាបែបនេះ[1589]។ គាត់បានឮពីមេបញ្ជាការរបស់គាត់ថា កងរបស់គាត់ស្ថិតនៅក្រោមកងពលធំលេខ ១៦៥[1590] ប៉ុន្តែថ្នាក់ដឹកនាំកងពលធំមិនដែលមកពិនិត្យមើលកងអង្គភាពរបស់គាត់នោះទេ[1591]។ ក្រៅពីករណីដែល ប្រាក់ សុខា មិនបានដឹងដោយផ្ទាល់អំពី មាស មុត ឬ កងពលធំលេខ ១៦៥ ការស្តាប់ចម្លើយជាមួយគាត់ដោយ ក.ស.ច.ស. ត្រូវបានធ្វើឱ្យខូច។ អ្នកស៊ើបអង្កេត ក.ស.ច.ស. បានចាប់ផ្តើមស្តាប់ចម្លើយដោយអានកិច្ចសម្ភាសន៍ ប្រាក់ សុខា ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា "ដើម្បីរឭកឡើងវិញនៃការចងចាំរបស់ [លោក]"[1592]។ បន្ទាប់មក ប្រាក់ សុខា បានបញ្ជាក់លើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[1593]។ ដូចដែលអ្នកស៊ើបអង្កេតម្នាក់ទៀតបានធ្វើចំពោះសេង សឿន[1594] ជាជាងដំបូងឡើយសាកសួរ ប្រាក់ សុខា ដើម្បីទទួលបានការចងចាំពីគាត់ផ្ទាល់ ឬ កំណត់ថាតើគាត់មានភ្លេចចំណុចណាមួយនោះ អ្នកស៊ើបអង្កេត "បានរឭក" ការចងចាំរបស់ ប្រាក់ សុខា នៅមុនពេលមានការចង្អុលបង្ហាញអំពីភាពចាំបាច់ដែលត្រូវធ្វើដូច្នេះ។ ភ័ស្តុតាងរបស់ ប្រាក់ សុខា ត្រូវបានធ្វើឱ្យខូចខាត[1595]។

៤៤០. **សឹង ណុច៖** សឹង ណុច មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ផ្អែកលើពាក្យចចាមអារ៉ាម និង ការទាយស្មាន។ សឹង ណុច ស្ថិតនៅក្នុងកងកុមារក្នុងកងវរសេនាតូចលេខ ៥៨០[1596]។ គាត់

[1589] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/35 ឆ.១៦។

[1590] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/36 ឆ.១៩-២០។ ជើងទំព័រ ២៦៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1591] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/36 ឆ.១៨។

[1592] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/35 ស-ឆ.២។

[1593] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/35 ស-ឆ.៣។

[1594] *សូមមើល* កថាខណ្ឌ ១៨៤ *ខាងលើ* និង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 EN 01237985 KH 01203855-56។

[1595] *សូមមើល* សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. ថតយកសំឡេង ឬ រូបភាពនូវរាល់ការស្តាប់ចម្លើយសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D136 កថាខណ្ឌ ១៦-២៤ ដែលពិភាក្សាពីវិធីដែលបច្ចេកទេសសួរសំណួរ អាចប៉ះពាល់ដល់ចម្លើយរបស់សាក្សី ជាពិសេសសាក្សីដែលមានវ័យចំណាស់។

[1596] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឆ.១០, ឆ.១៣, ឆ.១៧។

មិនដែលបានជួប មាស មុត នោះទេ[1597]។ នៅដើមឆ្នាំ ១៩៧៧ នៅព្រលានយន្តហោះកែងកង គាត់បានឃើញបុរសម្នាក់ពីក្រោយដែលកំពុងជិះកង់ ហើយមានមនុស្សម្នាក់បានប្រាប់គាត់ថា បុរសម្នាក់នោះ គឺជា មាស មុត[1598]។

៤៤១. **យិន តេង**៖ យិន តេង មិនអាចជឿជាក់បានឡើយ[1599]។ ស.ព.អ. ដកស្រង់ យិន តេង ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា ឈ្មោះរបស់ មាស មុត តែងតែត្រូវបានលើកឡើងជាញឹកញាប់ដោយថ្នាក់លើ នៅពេលពិភាក្សាអំពីការងារដែលត្រូវធ្វើនៅការដ្ឋានរាម[1600]។ គាត់មិនអើពើនឹងចម្លើយផ្ទុយគ្នារបស់សាក្សីម្នាក់នេះអំពី មាស មុត នោះទេ[1601]។ ក្រោយមក យិន តេង បាននិយាយថា គេបាននិយាយអំពី មាស មុត រៀងរាល់មួយសប្តាហ៍ ឬ ពីរសប្តាហ៍ម្តងនៅក្នុងកិច្ចប្រជុំសហករណ៍ប្រចាំថ្ងៃ ហើយថាប្រធានភូមិនឹងនិយាយថា បញ្ជាតា មុត ត្រូវតែធ្វើតាម ត្រូវតែអនុវត្តតាម បើមិនដូច្នោះទេ អាចនឹងមានបញ្ហាកើតឡើង[1602]។

៤៤២. **សុក វណ្ណា**៖ សុក វណ្ណា មិនអាចជឿជាក់បានឡើយ[1603]។ គាត់បានឮពីអ្នកផ្សេងថា មាស មុត មានសិទ្ធិអំណាចលើ “ប្រជាជនទូទៅ” ដូចជា សហករណ៍ និង ប្រធានឃុំ[1604]។ គាត់មិនបានដឹងដោយផ្ទាល់អំពីសិទ្ធិអំណាចរបស់ មាស មុត លើការដ្ឋាន ឬ សហករណ៍នោះទេ។

៤៤៣. **សំ សោម**៖ សំ សោម មិនអាចជឿជាក់បានឡើយ។ គាត់បានទាយស្មានអំពីកងពលធំលេខ ១៦៤។ គាត់ស្ថិតនៅក្នុងកងវរសេនាធំ ដែលឈរជើងនៅលើកោះតាង ប៉ុន្តែបានចល័តទៅមកនៅកោះផ្សេង

[1597] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ស-អ.៥០។

[1598] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 អ.៥០-៥៤។ ជើងចំពរ ៥២០ នៃដីកាសន្និដ្ឋានស្តាពរ។

[1599] *សូមមើល* កថាខណ្ឌ ៣៧៨-៨០ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1600] កថាខណ្ឌ ៦៦៦, ជើងចំពរ ២៦៨៩-៩០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៩២ ជើងចំពរ ៥២៣។

[1601] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 ស-អ.៣៥, ស-អ.១១៤។

[1602] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/6 អ.១៥៣-៥៤។ ជើងចំពរ ២៦៨៩-៩០ នៃដីកាសន្និដ្ឋានស្តាពរ។

[1603] *សូមមើល* កថាខណ្ឌ ៣៥៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1604] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 អ.១៤-១៥។ ជើងចំពរ ១៩៤, ២៣១-៣២ នៃដីកាសន្និដ្ឋានស្តាពរ។

ទៀត និង រាម[1605]។ គាត់មិនច្បាស់ទេថា នរណាមានសិទ្ធិអំណាចលើទំនប់ពុតធ្មើង ប៉ុន្តែគាត់បានទាយស្មានថា ទំនប់នេះស្ថិតនៅក្រោមកងពលធំលេខ ១៦៥ ពីព្រោះទំនប់នេះស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយកងពលធំលេខ ១៦៥[1606]។ វាមិនទំនងទេថា គាត់អាចបានដឹងលម្អិតថាការដ្ឋាន ឬ សហករណ៍តំបន់រាមនៅក្រោមសិទ្ធិអំណាចរបស់កងពលធំលេខ ១៦៥ ពីព្រោះគាត់បានឈរជើងភាគច្រើននៅលើកោះតាង និង កោះផ្សេងទៀត[1607]។

៤៤៤. **ជេត ប៉ុណ្ណា**៖ ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[1608]។ គាត់បានអះអាងថា មាស មុត បានមើលការខុសត្រូវលើសហករណ៍ជនស៊ីវិល រួមទាំង ថ្មធំ អូរម្ខ្លូ ឡឥដ្ឋ ស្មាច់ដែង ពុតធ្មើង និង បបុស[1609]។ ជេត ប៊ុណ្ណា មិនមានវត្តមាននៅតាមទីកន្លែងទាំងអស់នេះទេ ហើយបានផ្តល់ព័ត៌មានផ្ទុយគ្នាអំពីទីតាំងរបស់គាត់ចាប់ពីដើមឆ្នាំ ១៩៧៧ ដល់ខែ កញ្ញា ឆ្នាំ ១៩៧៨។ ដំបូង គាត់បាននិយាយថា គាត់បានលើកទំនប់ ហើយជីកប្រឡាយនៅស្មាច់ដែង និង បបុស[1610]។ បន្ទាប់មក គាត់បាននិយាយថា គាត់បាននៅទឹកសាប[1611]។ ទីតាំងទាំងនេះស្ថិតនៅជិតគ្នា ប៉ុន្តែមិនមែនជាកន្លែងតែមួយនោះទេ[1612]។ ជេត ប៊ុណ្ណា មិនបានបង្ហាញថា គាត់ធ្លាប់បាននៅថ្មធំ អូរម្ខ្លូ ឡឥដ្ឋ ឬ ពុតធ្មើង នោះឡើយ។

៤៤៥. **គុយ សម្បត្តិ**៖ គុយ សម្បត្តិ មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះឡើយ។ គាត់បានរស់នៅជិតព្រលានយន្តហោះកែងកង[1613]។ គាត់បាននិយាយថា មាស មុត គឺជាមនុស្សល្អ និង ចិត្តបាន ដែលតែងតែហូបបាយល្ងាចនៅផ្ទះគាត់ ហើយមិនដែលបានឃើញធ្វើបាបនរណាម្នាក់នៅកែងកង

[1605] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/20 អ.២-៤។

[1606] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/58 អ.១៤។ ជើងចំព័រ ១៩៤ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កថាខណ្ឌ ៦៦៨ ជើងចំព័រ ២៦៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1607] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/20 អ.៣-៤, អ.១២។

[1608] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1609] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 អ.១០។ ជើងចំព័រ ២៦៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1610] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 អ.១៦។

[1611] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 អ.២៥។

[1612] *សូមមើលខគ.* ផែនទីរដ្ឋបាលខេត្តព្រះសីហនុ ឯកសារ D114/77.2 KH 01101729។ ផែនទីរដ្ឋបាលស្រុកព្រៃនប់ ឯកសារ D54/89.1 KH 00987086។

[1613] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ចុះថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/68 អ.៥។

ឡើយ[1614]។ គាត់មិនបាននិយាយថា មាស មុត បានចុះពិនិត្យតាមដានកេងកង ឬ ការដ្ឋាន ឬ សហករណ៍តំបន់រាមផ្សេងទៀតនោះឡើយ។

៤៤៦. **ឡុង នី៖** ឡុង នី មិនអាចជឿជាក់បានឡើយ។ គាត់មិនបានផ្តល់សក្ខីកម្មក្រោមសម្បថនោះឡើយ។ ឡុង នី បានរៀបការជាមួយនឹងប្រធានសហករណ៍ពុតធ្មើង[1615]។ គាត់បានអះអាងថា មាស មុត បានទៅសហករណ៍ម្តងម្កាល ដើម្បីពិនិត្យមើលថាតើពួកគេត្រូវការអ្វីទេ ពួកគេអាចប្រគល់ឱ្យគាត់នូវសំណើជាលាយលក្ខណ៍អក្សរ ហើយគាត់នឹងបញ្ជូននីរសារទៅប្រាប់គាត់អំពីកិច្ចប្រជុំ[1616]។ គាត់បានផ្តល់ចម្លើយទាំងនេះនៅក្នុងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានតម្លៃភ័ស្តុតាងតិចតួច[1617]។ ក.ស.ច.ស. មិនអាចសម្ភាសគាត់ដោយផ្ទែក ហើយធ្វើតេស្តដេញដោលលើភ័ស្តុតាងរបស់គាត់បាននោះទេ[1618]។

៤៤៧. ស.ព.អ. អះអាងថា ទូរលេខចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ពី ឌឹម ទាក់ទងនឹងបញ្ហានៅឃុំរាម និង បបុសពីរ បង្ហាញអំពីសិទ្ធិអំណាច និង ការដឹងឮរបស់ មាស មុត អំពីការដ្ឋាន និងសហករណ៍តំបន់រាម[1619]។ ជាជាងបង្ហាញថា មាស មុត មានសិទ្ធិអំណាចលើការដ្ឋាន និង សហករណ៍រាម ទូរលេខបង្ហាញថា ឌឹម មានសិទ្ធិអំណាចលើតំបន់នេះ។ ឌឹម បានចាប់ខ្លួនមនុស្សប្រាំនាក់ដែលមានឈ្មោះនៅក្នុងទូរលេខ បានចាត់វិធានការនយោបាយ និង សតិអារម្មណ៍ និង បានរៀបចំកងល្បាតច្រើនទៀតដើម្បីធ្វើការស្រាវជ្រាវ[1620]។ យ៉ាងច្រើនបំផុត ទូរលេខបង្ហាញថា មាស មុត បាន

[1614] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ចុះថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/68 អ.៥។ ជើងទំព័រ ៥២០, ២៦៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1615] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡុង លី ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១២ ឯកសារ D59/1/4.25 EN 00970702 KH 00930799។

[1616] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១២ ឯកសារ D59/1/4.25 EN 00970714 KH 00930812។ កថាខណ្ឌ ៦៧, ១៩២ ជើងទំព័រ ២០២, ៥២១-២២, ៥២៤ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កថាខណ្ឌ ៦៦៦ ជើងទំព័រ ២៦៩២, ២៦៩៤-៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1617] *សូមមើល* កថាខណ្ឌ ១៤២ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[1618] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D114/142 EN 01175091-01175092 KH 01421504-01421507។

[1619] កថាខណ្ឌ ៦៦២-៦៣ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ជូចខាងលើ* កថាខណ្ឌ ១៨៨ ជើងទំព័រ ៥១៣-១៥។

[1620] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ជូនបងមុតជ្រាបអំពីសភាពការណ៍ខ្មាំងនៅតាមព្រំដែន" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699។ *សូមមើលផងដែរ* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំ

សម្រេចវិធានការដែលមិនដឹងថាជាអ្វី ចំពោះមនុស្សដែលមិនអាចកំណត់ភិនភាគ ទាក់ទងនឹងបញ្ហាដែលមិនដឹងថាជាអ្វី។

៤៤៨. ស.ព.អ. អះអាងថា កំណត់ហេតុប្រជុំដែល មាស មុត និង ឌឹម អះអាងថាបានរាយការណ៍ឱ្យ សុន សេន អំពីបញ្ហាផ្សេងៗពាក់ព័ន្ធនឹងវាម បង្ហាញថា មាស មុត បានមើលការខុសត្រូវដោយផ្ទាល់ និង មានការដឹងឮដោយផ្ទាល់អំពីការដ្ឋានតំបន់វាម[1621]។ ស.ព.អ. និយាយបំផ្លើស។ ការណ៍ដែល មាស មុត អាចរាយការណ៍ទៅ សុន សេន អំពីការបង្កបង្កើនផលនៅកំពង់សោម ឬ វាម[1622] មិនមានន័យថា គាត់គឺជាអ្នកកាន់អំណាចតែម្នាក់គត់ ឬ មានសិទ្ធិអំណាចណាមួយលើព្រឹត្តិការណ៍ដែលត្រូវបានរាយការណ៍នោះឡើយ។ ដូចដែល ស.ព.អ. ទទួលស្គាល់[1623] ឌឹម និង សមាជិកគណៈកម្មាធិការកងពលលេខ ១៦៥ ផ្សេងទៀត ក៏បានរាយការណ៍ទៅ សុន សេន អំពីតំបន់វាមដែរ រួមទាំង ការចាប់ខ្លួន និង សកម្មភាពប្លែកៗនៅកងកេង[1624]។

៤៤៩. ស.ព.អ. អះអាងថា មាស មុត បានថ្លែងសុន្ទរកថា នៅជិតវាលយន្តហោះកេងកង ធ្វើការផ្តោលទោសជនក្បត់ ក្រោយមកប្រជាជនត្រូវបានបញ្ជូនទៅកងផលិត និង ការដ្ឋាននៅតំបន់វាម[1625]។

លេខា និង អនុលេខា និង វរសេនាធំឯកភាជ្យ” ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.20 EN 00940340 KH 00052404 ដែលក្នុងនោះ ឌឹម រាយការណ៍ទៅ សុន សេន អំពីការចាប់បានចោរព្រៃនៅ វាម ដែលពួកវាបានចូលទៅក្នុងព្រៃ។

[1621] កថាខណ្ឌ ៦៦៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1622] *សូមមើលខទ.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំលេខា និង កសួការរបស់កងពលនិង វរសេនាធំ” ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195341 KH 00052391។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ” ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.22 EN 00656384 KH 00088929។

[1623] កថាខណ្ឌ ៦៦៣ ជើងទំព័រ ២៦៧២-៧៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1624] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥” ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657355 KH 00162489។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខា និង វរសេនាធំឯកភាជ្យ” ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.20 EN 00940340 KH 00052404-00052405។ ជើងទំព័រ ៥១៧, ៥១៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1625] កថាខណ្ឌ ៦៦៤-៦៥ នៃដីកាសន្និដ្ឋានស្តាពរ។

ស.ព.អ. ដកស្រង់ចម្លើយដែលមិនអាចជឿជាក់បាន និងគ្មានមូលដ្ឋានគាំទ្ររបស់ ឯក នី សេង ស៊ីន លុន សេង និង ម៉ូល ឈិន[1626]។

៤៥០. **ឯក នី**៖ ឯក នី មិនអាចជឿជាក់បានឡើយ[1627]។ គាត់បាននិយាយថា មាស មុត បានផ្តែងសន្ទរកថានៅក្នុងកិច្ចប្រជុំធំមួយនៅជិតវាលយន្តហោះកងកេង ដែលនៅទីនោះគាត់បានអានចម្លើយសារភាពរបស់ជនក្បត់ ហើយគាត់បាននិយាយពីឈ្មោះមនុស្សដែលជាជនក្បត់នឹងបដិវត្តន៍[1628]។ វាមិនច្បាស់លាស់ទេបើយោងតាមចម្លើយរបស់ ឯក នី ថាតើគាត់សំដៅលើកិច្ចប្រជុំមួយ ឬ ច្រើននោះ។ គាត់មិនបាននិយាយថា មាស មុត បានបញ្ជូនកងទ័ពទៅកងផលិតនោះឡើយ។

៤៥១. **សេង ស៊ីន**៖ សេង ស៊ីន មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ព័ត៌មានផ្ទុយគ្នាអំពី មាស មុត។ គាត់ "គ្រាន់តែជាទាហានធម្មតា" នៅលើកោះតាង ដែលត្រូវបានផ្ទេរឱ្យទៅធ្វើការនៅក្នុងកងផលិតប៉ុណ្ណោះ[1629]។ គាត់បាននិយាយថា គាត់បានចូលរួមកិច្ចប្រជុំមួយនៅព្រលានយន្តហោះកងកេង ដែលនៅពេលនោះ មាស មុត បានអានចម្លើយសារភាពរបស់ នង អាន ខ្លាំងៗ ហើយបាននិយាយថា នង អាន គឺជាជនក្បត់ ក្រោយមក សេង ស៊ុន ត្រូវបានបញ្ជូនទៅធ្វើស្រែ[1630]។ គាត់មិនបាននិយាយថាកិច្ចប្រជុំនេះកើតឡើងនៅការដ្ឋាន ឬថា មាស មុត បានបញ្ជូនគាត់ធ្វើស្រែនោះទេ។ គាត់បាននិយាយថា មេបញ្ជាការកងអនុសេនាធំរបស់គាត់បានប្រាប់គាត់អំពីការបង្កើតកងពលធំលេខ ១៦៥ ហើយថា មាស មុត គឺជាមេបញ្ជាការរបស់កងពលធំនេះ និង ថាមិនមានអ្នកធំៗធ្លាប់ទៅ

[1626] ជើងទំព័រ ២៦៨០-៨៤, ២៦៨៦-៨៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ២៤២, ២៤៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1627] *សូមមើល* កថាខណ្ឌ ២៥១ និង ៤១០ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1628] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/104 ឆ.៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/105 ឆ.៦។ ជើងទំព័រ ២៦៨០, ២៦៨២-៨៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1629] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 ឆ.១០, ឆ.២៥, ឆ.៤៦, ឆ.៦១។

[1630] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 ឆ.៥៦, ឆ.៦០-៦១។ ជើងទំព័រ ២៦៨០-៨១ នៃដីកាសន្និដ្ឋានស្តាពរ។

កោះតាងនោះទេ[1631]។ បន្ទាប់មក គាត់បាននិយាយថា មាស មុត នង ឆាន និង មេបញ្ជាការរង ផ្សេងទៀតបានទៅកោះតាង ដើម្បីប្រកាសអំពីការបង្កើតកងពលធំលេខ ១៦៥[1632]។

៤៥២. **លុន សេង**៖ លុន សេង មិនអាចជឿជាក់បានឡើយ[1633]។ គាត់បាននិយាយថា គាត់បានចូលរួមកិច្ច ប្រជុំមួយដែលនៅពេលនោះ មាស មុត បាននិយាយថា កម្មាភិបាលភូមិភាគបូព៌ាត្រូវតែដកចេញឱ្យ ដាច់ពីកងពល ពីព្រោះ គឺជាយោធាដែលមានសមាសធាតុមិនល្អ ហើយថា កម្មាភិបាលទាំងនេះ បន្ទាប់មកត្រូវបានបញ្ជូនទៅកងផលិត[1634]។ គាត់បានត្រឹមតែនិយាយថា មាស មុត អាចមានសិទ្ធិ អំណាចក្នុងការបញ្ជូនកម្មាភិបាលទៅកងផលិត[1635]។ ស.ព.អ. ធ្វើឱ្យមានការយល់ច្រឡំលើចម្លើយ របស់ លុន សេង។ លុន សេង គឺ "មិនច្បាស់" ថា នរណាជាអ្នកបានសម្រេចបញ្ជូនទាហានទៅកង ផលិត ប៉ុន្តែ "គិត" ថា សេចក្តីសម្រេចត្រូវបានធ្វើឡើងដោយ មាស មុត[1636]។

៤៥៣. **ម្ងូល ឈិន**៖ ម្ងូល ឈិន មិនអាចជឿជាក់បានឡើយ[1637]។ គាត់បាននិយាយថា មនុស្សរបស់ មាស មុត បានប្រមូលកងរបស់គាត់ទៅ "ប្រជុំធំ" ហើយបានប្រាប់ពួកគាត់ថា ពួកគាត់នឹងត្រូវបញ្ជូនទៅ ការដ្ឋានផ្សេង[1638]។ ទោះបីជាដំបូងបាននិយាយថា គាត់ត្រូវតែចូលរួមប្រជុំនេះក៏ដោយ ក៏ក្រោយ មកគាត់បាននិយាយថា កិច្ចប្រជុំមានការចូលរួមពីមេបញ្ជាការកងវរសេនាតូច និង កងវរសេនាធំ តែប៉ុណ្ណោះ[1639]។ ម្ងូល ឈិន បានទាយស្មានអំពីតួនាទីរបស់ មាស មុត នៅក្នុងកិច្ចប្រជុំនេះ ហើយ

[1631] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 ឆ.១៦, ឆ.១៩, ឆ.៣៦។

[1632] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 ឆ.១៧១-៧៧។

[1633] *សូមមើល* *កថាខណ្ឌ* ១៩៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1634] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/44 ស-ឆ.១៩, ស-ឆ.២២។ ជើងទំព័រ ២៦៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1635] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/45 ស-ឆ.១៦។ ជើងទំព័រ ២៦៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1636] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/45 ឆ.១៥។

[1637] *សូមមើល* កថាខណ្ឌ ៣៦១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1638] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឆ.៩៣។ ជើងទំព័រ ២៦៨៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1639] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឆ.៩៥-៩៦។ ជើងទំព័រ ២៦៨៨ នៃដីកាសន្និដ្ឋានស្តាពរ។

នៅក្នុងការបញ្ជូនគាត់ទៅកងផលិត[1640]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភ័ស្តុតាងដល់ចម្លើយរបស់ មូល ឈិន ស.ច.ស. ត្រូវពិចារណាលើចម្លើយរបស់គាត់ថា តាម៉ុក បានចូលរួមនៅក្នុងការប្រជុំជាមួយនឹង មាស មុត[1641]។ ចម្លើយរបស់គាត់បង្ហាញថា តាម៉ុក មានសិទ្ធិអំណាចលើកងពលធំលេខ ១៦៥[1642]។

៤៥៤. ចំពោះស្នឹងហាវ សមាជិកផ្សេងទៀតនៃគណៈកម្មាធិការកងពលធំលេខ ១៦៥ មានសិទ្ធិអំណាចលើការដ្ឋាន និង សហករណ៍តំបន់រាម[1643]។ ឧទាហរណ៍ កង សុំ ដែលបានធ្វើការនៅកន្លែងវ៉ែថ្មនៅជិតព្រលានយន្តហោះកងកេង បានឮថា ញ៉ាន មេបញ្ជាការរងកងពលធំលេខ ១៦៥ បានកំណត់ទំហំការងារដែលត្រូវធ្វើនៅការដ្ឋាននោះ[1644]។ គាត់បាននិយាយថា ញ៉ាន បានបញ្ជាលើការដ្ឋាន ហើយគឺជាមេដឹកនាំកងពលធំលេខ ១៦៥ តែម្នាក់គត់ ដែលបានទៅពិនិត្យមើលការដ្ឋាននោះ[1645]។

ឯ. សេចក្តីសន្និដ្ឋាន

៤៥៥. មាស មុត មិនមានសិទ្ធិអំណាចលើមន្ទីរសន្តិសុខនៅវត្តឥន្ទញ្ញាណ ឬ ទឹកសាប ដែលជាការដ្ឋាននៅស្នឹងហាវ ឬ ការដ្ឋាន ឬ សហករណ៍នៅរាមនោះទេ។ ស.ព.អ. ដកស្រង់ចម្លើយសាក្សី និង ភ័ស្តុតាងឯកសារដែលមិនអាចជឿជាក់បាន ឬ មិនបានគាំទ្រដល់ការអះអាងរបស់គាត់។ សមាជិកកងពលធំលេខ ១៦៥ ផ្សេងទៀត មានសិទ្ធិអំណាចលើការដ្ឋានទាំងនេះ។ បើទោះបីជា មាស មុត មានសិទ្ធិអំណាចបែបនេះមែនក៏ដោយ ក៏នៅពេលគិតពីទំហំនៃការឈឺចាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វាមិនអាចដំឡើងគាត់ឱ្យឡើងដល់ប្រភេទ “អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត” នោះឡើយ។

[1640] *សូមមើល* កថាខណ្ឌ ៣៦១ *ខាងលើ*។

[1641] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឆ.៩៦។

[1642] *សូមមើល* កថាខណ្ឌ ១៦៩-៧០ និង ១៧២ *ខាងលើ* ទាក់ទងនឹងអំណាចរបស់ តាម៉ុក លើបញ្ហាយោធា។

[1643] *សូមមើល* កថាខណ្ឌ ៤៤៨ *ខាងលើ* ទាក់ទងនឹងសមាជិកកងពល ១៦៥ ផ្សេងទៀតរាយការណ៍ទៅ សុន សេន អំពីតំបន់រាម។

[1644] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.១៧៧-៧៨, ឆ.២២៩, ឆ.២៧១។ មេធាវីការពារក្តីបានស្នើថា សាក្សីនេះមិនអាចគួរឱ្យជឿជាក់ទេ (*សូមមើល* កថាខណ្ឌ ២២៥ *ខាងលើ*)។ ប៉ុន្តែ ប្រសិនបើ ស.ច.ស. ចាត់ទុកថា សក្ខីកម្មរបស់គាត់អាចគួរឱ្យជឿជាក់ ស.ច.ស. ក៏ត្រូវតែពិចារណាចម្លើយនេះផងដែរ។

[1645] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.២៧១, ឆ.២៧៣-៧៤។

៦. សិទ្ធិអំណាចក្នុងការតែងតាំង ដំឡើងដំណែង និង បណ្តេញបុគ្គលិកនៅក្នុងកងពលធំលេខ ១៦៥ និង តំបន់ស្វយ័តកំពង់សោម មិនបានធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត"

៤៥៦. ប្រភពដែល ស.ព.អ. ដកស្រង់មិនគាំទ្រការអះអាងដែលថា មាស មុត មានអំណាចតែងតាំង ដំឡើងដំណែង និង បណ្តេញបុគ្គលិកយោធា និង ស៊ីវិលនៅក្នុងកងពលធំលេខ ១៦៥ និង តំបន់ស្វយ័តកំពង់សោម រួមទាំង បញ្ជាឱ្យមានការរំសាយ ការចាប់ខ្លួន និង ការកាប់សម្លាប់ពួកគេនោះទេ[1646]។ ស.ព.អ. ដកស្រង់ជាចម្បងចម្លើយ និង បញ្ជីអ្នកទោសមន្ទីរ ស-២១ ដែលមិនអាចជឿជាក់បាន និង មិនមានមូលដ្ឋានគាំទ្ររបស់ សុខ អ៊ែន ហ៊ឹង អ៊ុច សេង ស៊ីន និង ឯក នី។ មិនមានឯកសារ និង ចម្លើយសាក្សីណាមួយដែលបង្ហាញថា មាស មុត គឺជាអ្នកដែលបានតែងតាំង ដំឡើងដំណែង ឬ បណ្តេញមនុស្សដែលមានឈ្មោះនៅក្នុងឯកសារ និង ចម្លើយនោះទេ។ សាក្សីត្រឹមតែបង្ហាញអត្តសញ្ញាណបុគ្គលទាំងនេះថាជាអ្នកដែលមានដំណែង ឬ ទៅកាន់ដំណែងនានានៅក្នុងកងពលធំលេខ ១៦៥ ប៉ុណ្ណោះ[1647]។ បើទោះបីជា មាស មុត ពិតជាមានសិទ្ធិអំណាចបែបនេះមែនក៏ដោយ ក៏វាមិនអាចធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។

៤៥៧. បញ្ជីអ្នកទោសមន្ទីរ ស-២១ ដែល ស.ព.អ. ដកស្រង់[1648] មិនបង្ហាញថា មាស មុត បានបញ្ជាឱ្យរំសាយ ចាប់ខ្លួន ឬ កាប់សម្លាប់មនុស្សកងពលធំលេខ ១៦៥ ដែលមានឈ្មោះនៅក្នុងបញ្ជីទាំងនេះឡើយ គ្រាន់តែថា ប្រជាជនដែលត្រូវបានអះអាងថាមកពីកងពលធំលេខ ១៦៥ គឺមានឈ្មោះនៅក្នុងបញ្ជីនោះ។ ឯកសារ D114/145.1.17 គឺជាបញ្ជីឈ្មោះមនុស្សដែលត្រូវបានអ្នកផ្សេងឆ្លើយដាក់ទំនងជារៀបចំឡើងដោយបុគ្គលិកមន្ទីរ ស-២១[1649]។ វាមិនបានបង្ហាញអំពីការចូលរួមពាក់ព័ន្ធ

[1646] កថាខណ្ឌ ៨២, ៥៩០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៧៥, ២២១។

[1647] *សូមមើលឧទា.* ជើងចំព័រ ២៥៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងចំព័រ ១៨៥១។

[1648] ជើងចំព័រ ២៥៩ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់បញ្ជីឈ្មោះអ្នកទោស ស-២១ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.28.45។ បញ្ជីឈ្មោះអ្នកទោស ស-២១ ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.28.2។

[1649] បញ្ជីឈ្មោះមនុស្សនៅកងពល ១៦៥ ដែលជាប់ក្នុងចម្លើយខ្ទាំង ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ១៩៧៧ ឯកសារ D114/145.1.17។ ជើងចំព័រ ២៥៩ នៃដីកាសន្និដ្ឋានស្តាពរ។

របស់ មាស មុត នៅក្នុងការរំសាយ ការចាប់ខ្លួន ឬ ការកាប់សម្លាប់អ្នកដែលត្រូវបានគេឆ្លើយដាក់នោះឡើយ។

៤៥៨. ស.ព.អ. ដកស្រង់ សុខ រ៉ែន ហ៊ីង អ៊ុច សេង ស៊ីន និង ឯក នី ដើម្បីជាមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានដំឡើងដំណែងបុគ្គលិកកងពលធំលេខ ១៦៤ ឱ្យជំនួសអ្នកដែលគាត់បានរំសាយ ចាប់ខ្លួន ឬ សម្លាប់ចោល[1650]។ គ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះបាននិយាយថា មាស មុត បានចូលរួមពាក់ព័ន្ធនៅក្នុងការរំសាយ ការចាប់ខ្លួន ឬ ការកាប់សម្លាប់នោះឡើយ។ សុខ រ៉ែន នៅក្នុងកងសិប្បកម្មក្រោមសិទ្ធិអំណាចរបស់កងពលធំលេខ ១[1651] បានឮថា មាស មុត គឺជាមេបញ្ជាការកងពលធំលេខ ១៦៤ ហើយគ្រាន់តែបាននិយាយថា ឌឹម យ៉ាន និង នង ឆាន គឺស្ថិតនៅក្នុងកងពលធំលេខ ១៦៤ តែប៉ុណ្ណោះ[1652]។ ហ៊ីង អ៊ុច[1653] បានត្រឹមនិយាយថា ឌឹម គឺជាមេបញ្ជាការរងកងពលធំមកពីភូមិភាគឫស្សីព៉ា ឆាន គឺជាសមាជិកកងពលធំមកពីខេត្តកោះកុង និង យ៉ាន ក្រោយមកបានមកមើលការខុសត្រូវលើកងពលធំលេខ ១៦៤ ជាមួយ មាស មុត[1654]។ សេង ស៊ីន បានអះអាងត្រឹមថា មាស មុត បានអានចម្លើយសារភាពរបស់ នង ឆាន នៅក្នុងកិច្ចប្រជុំ[1655]។ ស្រដៀងគ្នានេះដែរ ឯក នី[1656] បានត្រឹមអះអាងថា មាស មុត បានអានចម្លើយសារភាពរបស់ នង ឆាន នៅក្នុងកិច្ចប្រជុំ ហើយបានរៀបពាក្យជួនដួចកំណាព្យទូវឈ្មោះរបស់ជនក្បត់ រួមទាំងឈ្មោះរបស់ យ៉ាន ផងដែរ[1657]។

[1650] កថាខណ្ឌ ៨២, ៤៩០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៧៥, ២២១។

[1651] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉ែន ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦ ឯកសារ D114/155 ឆ.១៣-១៤, ឆ.១៧, ឆ.២៨, ឆ.៤៣។

[1652] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉ែន ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/155 ឆ.៦៧។ ជើងទំព័រ ២៤៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1653] *សូមមើល* កថាខណ្ឌ ២៨១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1654] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/81 ឆ.១៤។ ជើងទំព័រ ២៤៩, ២៣០ នៃដីកាសន្និដ្ឋានស្តាពរ។

[1655] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 ឆ.៦០។ ជើងទំព័រ ២៤៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1656] *សូមមើល កថាខណ្ឌ* ២៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1657] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/104 ឆ.៥។ ជើងទំព័រ ២៤៩ នៃដីកាសន្និដ្ឋានស្តាពរ។ ស.ព.អ. ក៏បានដកស្រង់ចម្លើយរបស់ ឯក នី ពី កិច្ចសម្ភាសន៍ POW/MIA ទាក់ទងនឹង នង ឆាង ត្រូវ

៤៥៩. សាក្សីផ្សេងទៀត ដែល ស.ព.អ. ដកស្រង់ ក៏មិនបាននិយាយនោះទេថា មាស មុត បានបញ្ជាឱ្យមានការវំសាយ ការចាប់ខ្លួន ឬ ការកាប់សម្លាប់មនុស្សដែលមានឈ្មោះនៅក្នុងចម្លើយរបស់ពួកគេដែរ ដោយគ្រាន់តែនិយាយថា មនុស្សត្រូវបាន "ដក" "បាត់ខ្លួន" "យកចេញ" ឬ "ចាប់ខ្លួន"[1658]។ សាក្សីមិនបាននិយាយថា តើនរណាដែលពួកគេគិតថាជាអ្នកទទួលខុសត្រូវចំពោះអំពើទាំងនេះឡើយ។ បើទោះបីជាត្រូវពិចារណាលើភ័ស្តុតាងដែល ស.ព.អ. ដកស្រង់ក៏ដោយ ក៏ ស.ព.អ. ខកខានមិនបានបង្ហាញថា មាស មុត "បានបណ្តេញ" "កម្ចាត់ភិបាលជាច្រើននាក់" ដែរ[1659]។ ភ័ស្តុតាងសំដៅលើបុគ្គលិកកងពលធំលេខ ១៦៤ ចំនួនប្រហែល ១៥ នាក់ ដែលត្រូវបានអះអាងថាដកចេញ ចាប់ខ្លួន ឬ សម្លាប់ចោល។

៤៦០. ស.ព.អ. អះអាងថា មាស មុត បានតែងតាំងមេបញ្ជាការជាន់ខ្ពស់កងពលធំលេខ ១៦៤ ឱ្យកាន់ដំណែងដឹកនាំនៅផែកំពង់សោម[1660]។ គាត់ដកស្រង់ជាចម្បងចម្លើយរបស់ អែម សុន នាក់ ខឿន មុត ម៉ៅ ណុប ហាល់ ស៊ីម នី និង ប៊ាង រ៉េត ដើម្បីគាំទ្រការអះអាងរបស់គាត់[1661]។ ស.ព.អ. និយាយបំផ្លើស។ គ្មានសាក្សីណាមួយក្នុងចំណោមសាក្សីទាំងនេះបង្ហាញថា មាស មុត បានដើរតួនាទីក្នុងការតែងតាំងបុគ្គលិកកងពលធំលេខ ១៦៤ ឱ្យកាន់មុខដំណែងប្រធាន និង អនុប្រធានផែកំពង់សោមនោះឡើយ។ អែម សុន[1662] គ្រាន់តែបាននិយាយថា ធុច រិន បានឧទ្ទេសនាម

បានសម្លាប់នៅវត្តឥន្ទញ្ញាណ (ជើងទំព័រ ២៤៩ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ចម្លើយរបស់ ឯក នី (POW/MIA) នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០២ ឯកសារ D4.1.747 EN 00387291 KH 00640517)។ ឯក នី ក្រោយមកបានកែតម្រូវចម្លើយនេះ ហើយបង្ហាញថា គាត់សំដៅលើ រ៉ែម មេបញ្ជាការកងវរសេនាតូច ៣៨៦ ដែលគាត់អះអាងថាត្រូវបានគេបាញ់សម្លាប់ បន្ទាប់ពីគាត់រឹងទទឹង និង បានប្រឆាំងតបតនឹងពួកយោធាដែលព្យាយាមចាប់គាត់។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/101 ឆ.១១។ *សូមមើល* កថាខណ្ឌ ៤១៨ *ខាងលើ* ទាក់ទងនឹងរឿងរ៉ាវនេះ។

[1658] ជើងទំព័រ ២៤៩ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉េត ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/10 ឆ.៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/104 ឆ.៥៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/116 ឆ.៣១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 ឆ.៥៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/7 ឆ.៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឆ.៤-៥។

[1659] កថាខណ្ឌ ៨២ នៃដីកាសន្និដ្ឋានស្តាពរ។

[1660] កថាខណ្ឌ ៧៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ២២១ ជើងទំព័រ ៦៦៦។

[1661] ជើងទំព័រ ២៣០, ៦៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1662] *សូមមើល* កថាខណ្ឌ ២៣៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

ឡុង សារឿន និង សុខ ភាព នៅក្នុងកិច្ចប្រជុំក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៨[1663]។ នាក់ ខឿន ជាងផ្សាដែក នៅផែ[1664] បានទាយស្មានថា "ប្រហែលជា" សារឿន ដែលបានជំនួស ធុច រិន[1665] ហើយបានសារភាពថា គាត់នៅតូចពេកមិនដឹងអំពីបញ្ហានេះទេ[1666]។ មុត ម៉ៅ[1667] បាននិយាយថា សារឿន និង ញ៉ាន គឺស្ថិតនៅក្នុងគណៈកម្មាធិការរបស់ មាស មុត[1668] ប៉ុន្តែ គាត់បានសន្មតថាដូច្នេះក៏ព្រោះតែពួកគេធ្វើការនៅក្នុងកន្លែងតែមួយជាមួយ មាស មុត[1669]។ ណុប ហាល់ បាននិយាយត្រឹមថា សារឿន ត្រូវបានផ្ទេរទៅទទួលខុសត្រូវផែ[1670]។ ស៊ឹម នី[1671] គ្រាន់តែបាននិយាយថា សារឿន បានជំនួស ធុច រិន[1672]។ ប៊ាង រ៉េត បាននិយាយត្រឹមថា មេបញ្ជាការរងតែងតែត្រូវបានផ្លាស់ប្តូរ ហើយថា ទឹម សេង បានជំនួស សារឿន[1673]។

៤៦១. មេដឹកនាំជាន់ខ្ពស់ ប.ក.ក. បានបញ្ជាឱ្យមានការជ្រើសរើស និង ផ្លាស់ប្តូរកម្លាភិបាលជាន់ខ្ពស់ និង យោធា។ តាមការអនុវត្តជាក់ស្តែង សមាជិកគណៈកម្មាធិការ ជាទូទៅ ត្រូវបានតែងតាំងដោយ គណៈកម្មាធិការ កម្រិតថ្នាក់លើបន្ទាប់[1674]។ ចំពោះកងពលយោធារបស់មជ្ឈិម អគ្គសេនាធិការ

[1663] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ទ.៣៧។ ជើងទំព័រ ២៣០, ៦៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1664] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 ទ.៥, ទ.៨។

[1665] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 ទ.១៧, ទ.១៩។

[1666] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 ទ.១៧។

[1667] *សូមមើល* កថាខណ្ឌ ២៦៦-៦៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ និង ភាពមិនអាចជឿជាក់នៃចម្លើយរបស់គាត់។

[1668] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/73 ទ.៦។ ជើងទំព័រ ២៣០, ៦៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1669] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/73 ទ.៨។

[1670] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០០៧ ឯកសារ D59/1/1.12 EN 00968421 KH 00926645។ ជើងទំព័រ ២៣០, ៦៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1671] *សូមមើល* កថាខណ្ឌ ២៤៥ និង ៤០៦-០៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1672] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ទ.២៦។ ជើងទំព័រ ៦៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1673] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ទ.២៨។ ជើងទំព័រ ៦៦៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1674] កថាខណ្ឌ ២១៨ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

បានតែងតាំងសមាជិកគណៈកម្មាធិការ[1675]។ ចំពោះតំបន់ស្វយ័ត គណៈកម្មាធិការមជ្ឈិម ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ បានតែងតាំងសមាជិកថ្នាក់ខ្ពស់[1676]។ ដូច្នេះ ប៉ុល ពត បានបង្កើតកងទ័ពជើងទឹក ហើយអគ្គសេនាធិការបានរៀបចំកងពលធំលេខ ១៦៥[1677]។ តាម៉ុក បានជ្រើសរើស និង សម្រិតសម្រាំងមនុស្ស មុនពេលពួកគេចូលកងពលធំលេខ ៣[1678]។ លុន សេង បានគិតថា ការបំបែកកងទ័ពភូមិភាគបូព៌ាមកពីកងពលធំលេខ ១៦៥ គឺធ្វើតាមបញ្ជាមជ្ឈិម ពីព្រោះសេចក្តីសម្រេចរៀបចំកងពលធំ ឬ ច្របាច់បញ្ចូលកងពលធំ អាចធ្វើឡើងតែដោយមជ្ឈិមប៉ុណ្ណោះ[1679]។ ប៊ាង រ៉ែត បាននិយាយថា មជ្ឈិមបានបញ្ជាកងរបស់គាត់ឱ្យផ្តាស់ទៅកន្លែងផ្សេង ហើយចាកចេញពីផែកំពង់សោម ទទួលខុសត្រូវលើអ្នកផ្សេង ហើយថា មជ្ឈិមចាត់តាំងប្រធានផែ[1680]។ មាស មុត មិនមានសិទ្ធិអំណាចផ្តាច់មុខលើការតែងតាំង ដំឡើងឋានៈ ឬ បណ្តេញបុគ្គលិកនោះទេ។ បើទោះបីជាគាត់មានសិទ្ធិអំណាចបែបនេះក៏ដោយ ក៏ដោយសារតែតំបន់ប្រតិបត្តិការមានកម្រិតរបស់គាត់ វាមិនអាចធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។

[1675] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183397 KH 00019114 (សុន សេន ត្រូវបានណែនាំឱ្យក្តាប់កម្លាំង រៀបចំកងពល ចាត់ចែងកងទ័ពថ្មី ជើងទឹក អាកាស)។

[1676] មាត្រា ៨ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D4.1.444 EN 00278695 KH 00251438 (ជាលេខាស្រុកពេជ្រចិន្តាតំបន់ ១០៥ បានឆ្លើយថា លេខាស្រុក ១០៥ បានប្រាប់គាត់ថា អង្គការលើឱ្យគាត់តែងតាំងលេខាស្រុក)។ *រឿងក្តី ខ្នុន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/277.4 នៅម៉ោង 11.11.52-11.15.32 (ឌុច បានផ្តល់សក្ខីកម្មថា រឿងអីៗនៅតំបន់ឯករាជ្យកំពង់សោម ៨៧០ សម្រេច មិនមែនលេខាភូមិភាគនិរតីសម្រេចទេ)។ *សូមមើលផងដែរ* កថាខណ្ឌ ២០៦, ២៧៤ នៃសាលក្រមក្នុងរឿងក្តី ០០២/០១ (តំបន់ស្វយ័តរាយការណ៍ដោយផ្ទាល់ទៅ "មជ្ឈិមបក្ស" មានន័យថា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការយោធា មន្ទីរ ៨៧០ និង មន្ទីររដ្ឋាភិបាល ស-៧១ និង មន្ទីរចំណុះឱ្យរដ្ឋាភិបាល)។

[1677] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សាវ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 អ.៨០-៨៣។ *សូមមើលផងដែរ* ជើងចំព័រ ១២៤៧ *ខាងលើ* ទាក់ទងនឹងការបង្កើត ក.ប.ក. និង កងទ័ពជើងទឹក។

[1678] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/43 អ.៥។

[1679] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/45 អ.៩-១០, អ.១២។

[1680] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 អ.២៤-២៦។

៧. សិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មបុគ្គលិកក្រោមបង្គាប់ មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ដែល "ទទួលខុសត្រូវខ្ពស់បំផុត"

៤៦២. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត មានអំណាច និង សិទ្ធិក្នុងការដាក់ទណ្ឌកម្មបុគ្គលិកក្រោមបង្គាប់របស់គាត់នោះទេ[1681]។ ស.ព.អ. ដកស្រង់ដោយភាន់ច្រឡំនូវលក្ខន្តិក: ប.ក.ក.[1682]។ គាត់មិនអើពើភ័ស្តុតាងបរិបទ និង រចនាសម្ព័ន្ធនោះទេ។ បើទោះបីជា មាស មុត មានសិទ្ធិអំណាចដាក់ទណ្ឌកម្មលើបុគ្គលិកក្រោមបង្គាប់ក៏ដោយ ក៏មិនមានន័យថា គាត់គឺជាបុគ្គលម្នាក់ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ និង ឆ្នាំ ១៩៧៩ នោះដែរ។

៤៦៣. ស.ព.អ. ដកស្រង់មាត្រា ៦(៥) នៃលក្ខន្តិក: ប.ក.ក. ដែលចែងថា៖ "តាមកាលកំណត់នីមួយៗ ថ្នាក់ក្រោម ត្រូវរាយការណ៍ឱ្យថ្នាក់លើ អំពីសភាពការណ៍ និង អំពីកិច្ចការដែលខ្លួនបានធ្វើ។ តាមកាលកំណត់នីមួយៗដែរ ថ្នាក់លើត្រូវរាយការណ៍ឱ្យថ្នាក់ក្រោមអំពីសភាពការណ៍រួម អំពីសេចក្តីណែនាំជាទិសការងារផ្សេងៗ"[1683]។ មាត្រា ៦(៥) គ្រាន់តែបង្ហាញឱ្យឃើញថា គណៈកម្មាធិការកងពលធំលេខ ១៦៥ និង តំបន់ស្វយ័តកំពង់សោម ក៏ដូចជាអង្គភាពបក្សទាំងឡាយ មានករណីយកិច្ច និង ការទទួលខុសត្រូវក្នុងការរាយការណ៍ ដូចមានចែងនៅក្នុងលក្ខន្តិក:។ ពួកគេត្រូវរាយការណ៍ទៅថ្នាក់លើរបស់ពួកគេ មិនខុសពីបុគ្គលិកក្រោមបង្គាប់របស់ មាស មុត ឬ របស់គណៈកម្មាធិការដែលត្រូវរាយការណ៍ឱ្យថ្នាក់លើដូចគ្នា។ មាស មុត គ្មានអំណាចពិសេស និងលទ្ធភាពខ្ពស់ជាងនេះដែលអាចឱ្យគាត់ជា "មេដឹកនាំជាន់ខ្ពស់" ម្នាក់ ឬ បុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះឡើយ។

៤៦៤. ស.ព.អ. អះអាងថា ជាផ្នែកមួយនៃអំណាចក្នុងការដាក់ទណ្ឌកម្ម មាស មុត បានទទួលខុសត្រូវលើការធានាថា ថ្នាក់ក្រោមៗបានអនុវត្តតាមមាគ៌ាបក្ស សេចក្តីណែនាំ និង បញ្ជាផ្សេងៗ[1684]។

[1681] កថាខណ្ឌ ៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1682] ជើងទំព័រ ២៥០, ២៥២ នៃដីកាសន្និដ្ឋានស្តាពរ។

[1683] មាត្រា ៦(៥) នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ ជើងទំព័រ ២៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1684] កថាខណ្ឌ ៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

ស.ព.អ. ដកស្រង់មាត្រា ១៩(១) នៃលក្ខន្តិក: ប.ក.ក.[1685]។ មាត្រា ១៩(១) អនុវត្តលើគណៈកម្មាធិការភូមិភាគ មិនមែនលើតំបន់ស្វយ័ត ឬ កងពលធំមជ្ឈិមនោះទេ។ គ្មានការចង្អុលបង្ហាញនៅក្នុងលក្ខន្តិក: ប.ក.ក. ថា តំបន់ស្វយ័ត ឬ កងពលធំមជ្ឈិម ស្ថិតនៅថ្នាក់ស្មើគ្នា ជាគណៈកម្មាធិការភូមិភាគ ឬ ថាលេខាតំបន់ស្វយ័ត ឬ មេបញ្ជាការកងពលធំមជ្ឈិម ស្ថិតនៅថ្នាក់ស្មើគ្នា ជាលេខាភូមិភាគ[1686] ដូច ស.ព.អ. បង្កប់ន័យនោះទេ។

៤៦៥. ស.ព.អ. អះអាងថា មាស មុត តម្រូវឱ្យដាក់ទណ្ឌកម្មលើអ្នកដែលខកខានមិនបានអនុវត្តតាមបញ្ជារបស់គាត់ ដោយការអនុវត្តវិន័យបក្ស តាមរយៈ "ការពិនិត្យ វិភាគ និង ការវិនិច្ឆយឬត់ចត់" លើការរំលោភបំពាននីមួយៗ[1687] ដោយបង្កប់ន័យថា មាស មុត គឺជាបុគ្គលតែម្នាក់គត់នៅក្នុងកងពលធំលេខ ១៦៤ ដែលទទួលខុសត្រូវលើការដាក់ទណ្ឌកម្មបុគ្គលិកក្រោមបង្គាប់។ ស.ព.អ. ដកស្រង់តែលក្ខន្តិក: ប.ក.ក. ប៉ុណ្ណោះ[1688]។ គាត់នាំឱ្យយល់ខុសនូវភាសានៃលក្ខន្តិក:នេះ។ ស.ព.អ. ដកស្រង់ប្រយោគចុងក្រោយនៃមាត្រា ៤(២) នៃលក្ខន្តិក: ប.ក.ក. ដើម្បីគាំទ្រការអះអាងរបស់គាត់ ប៉ុន្តែមិនអើពើនឹងភាសាដែលធ្វើឱ្យចំណុចនេះខ្សោយ។ ប្រយោគទាំងមូលចែងថា៖ "ត្រូវអនុវត្តវិន័យរបស់បក្សនេះ ដោយពិនិត្យ វិភាគ វិនិច្ឆយ ម៉ត់ចត់ ឈរលើលក្ខការណ៍សមូហភាពដាច់ខាត ហើយក្របខ័ណ្ឌសមូហភាពនេះត្រូវលែលកឱ្យបានច្រើនថ្នាក់ ទៅតាមសារសំខាន់នៃបញ្ហានីមួយៗទៀតផង"[1689]។ មាត្រា ៤(២) បង្ហាញថា វិធានការវិន័យត្រូវបានធ្វើឡើងរួមគ្នា ដោយគណៈកម្មាធិការកងពលធំលេខ ១៦៤ ឬ គណៈកម្មាធិការតំបន់ស្វយ័តកំពង់សោម។

៤៦៦. ស.ព.អ. អះអាងថា ដើម្បីបំពេញករណីយកិច្ចអនុវត្តវិន័យបក្ស មាស មុត បង្កើតប្រព័ន្ធមួយដើម្បីកត់ត្រា និង ពិនិត្យប្រវត្តិរូបកងទ័ព ដើម្បីរកមើលបុគ្គលិកលក្ខណៈខ្លាំង និង សកម្មភាពគួរឱ្យ

[1685] ជើងទំព័រ ២៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1686] មាត្រា ៨ នៃលក្ខន្តិក: ប.ក.ក.៖ ចំពោះតំបន់ណា ឬ អង្គការណា ដែលមានលក្ខណៈពិសេស អាចចាត់តាំងជាផ្នែកដោយឡែក ដោយគណៈកម្មាធិការមជ្ឈិម។ ជំពូកទី VI ដែលទាក់ទងនឹង ក.ប.ក. មិនមានបង្ហាញអង្គភាព ក.ប.ក. មានខ្សែចាត់តាំងដូចគ្នានឹងរចនាសម្ព័ន្ធបក្សផ្សេងទៀត។ មាត្រា ៧(៦) នៃលក្ខន្តិក: ចែងថា ចំពោះអង្គការបក្សក្នុង ក.ប.ក. ក៏មានខ្សែចាត់តាំងដូចនេះដែរ តាមក្របខ័ណ្ឌថ្នាក់បក្សនីមួយៗ ប៉ុន្តែមិនបានបញ្ជាក់ថាគណៈកម្មាធិការកងពលមជ្ឈិមមានឋានៈស្មើគណៈកម្មាធិការភូមិភាគទេ។

[1687] កថាខណ្ឌ ៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1688] ជើងទំព័រ ២៥២ នៃដីកាសន្និដ្ឋានស្តាពរ។

[1689] មាត្រា ៤(២) នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។

សង្ស័យ[1690]។ ស.ព.អ. ដកស្រង់ចម្លើយដែលមិនអាចជឿជាក់បាន និង មិនមានមូលដ្ឋានគាំទ្រពី ឌុល សុង និង សែម កុល[1691]។ *សូមមើល* កថាខណ្ឌ ៤៧១ *ខាងក្រោម* ទាក់ទងនឹងចម្លើយរបស់ លុន សេង អំពីការស៊ើបអង្កេតប្រវត្តិរូប។

៤៦៧. **ឌុល សុង**៖ ឌុល សុង មិនអាចជឿជាក់បានឡើយ[1692]។ គាត់បានអះអាងថា តាមគាត់ដឹង មេបញ្ជាការកងពលធំមើលការខុសត្រូវលើការសម្រិតសម្រាំងប្រវត្តិរូបកងទ័ព[1693]។ ករណីនេះគឺ "គ្រាន់តែជាការសន្មត[របស់គាត់]ប៉ុណ្ណោះ]"[1694]។ ឌុល សុង បានផ្អែកចម្លើយរបស់គាត់លើការ ទាយស្មានអំពីងារយោធា ជាជាងការដឹងឮជាក់ស្តែងទាក់ទងនឹង មាស មុត។ ឌុល សុង មិនបាន និយាយថា មាស មុត មានសិទ្ធិអំណាចឱ្យធ្វើការចាប់ខ្លួនអ្នកដែលត្រូវបានចោទថាជាជនក្បត់នោះ ទេ គាត់គ្រាន់តែនិយាយថា មាស មុត បានប្រកាសអំពីពួកគេប៉ុណ្ណោះ[1695]។ ជាថ្មីម្តងទៀត គាត់ បានទាយស្មានថា មាស មុត មានសិទ្ធិអំណាចនេះ ដោយផ្តល់ទស្សនថា ដោយសារ មាស មុត គឺ ជាមេបញ្ជាការកងពលធំ គាត់អាចជាបុគ្គលតែម្នាក់គត់ ដែលបញ្ជូនការប្រកាសអំពីការចាប់ខ្លួនទៅ ថ្នាក់ក្រោមៗ[1696]។

៤៦៨. **សែម កុល**៖ សែម កុល មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។ គាត់គឺជាអ្នកបញ្ជូលគ្រាប់ នៅលើកប៉ាល់ការពាររបស់កងទ័ពជើងទឹក[1697]។ គាត់ត្រូវធ្វើប្រវត្តិរូបរបស់គាត់ពីរដងក្នុងមួយ

[1690] កថាខណ្ឌ ៨៤, ១០៣-០៤ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៦៨។

[1691] ជើងទំព័រ ២០៩, ២៥៣, ៣០២-០៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1692] *សូមមើល* កថាខណ្ឌ ៣៦៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1693] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/7 អ.១៦។ ជើងទំព័រ ២០៩, ២៥៣, ៣០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1694] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/7 អ.១៧៖ "ខ្ញុំពុំបានឃើញរឿងរ៉ាវទាំងអស់នោះទេ ប៉ុន្តែនេះជាការសន្មតរបស់ខ្ញុំថា វាជាការទទួលខុសត្រូវរបស់មេបញ្ជាការកងពល"។

[1695] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 អ.៦-៨។ ជើងទំព័រ ២០៩, ២៥៣, ៣០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1696] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 អ.៧-៨។

[1697] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម កុល ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/181 អ.១៣, អ.១៦។

ឆ្នាំ[1698]។ គាត់មិនបាននិយាយថា មាស មុត បានបញ្ជាឱ្យកត់ប្រវត្តិរូប ឬ ដើរតួនាទីណាមួយនៅក្នុងដំណើរការនេះឡើយ។

៤៦៩. ស.ព.អ. បង្កប់ន័យដោយមិនត្រឹមត្រូវថា មាស មុត បានផ្តួចផ្តើមគំនិតបង្កើតប្រព័ន្ធកត់ត្រា និងសម្រិតសម្រាំងនេះនៅក្នុងកងពលធំលេខ ១៦៤ ពោលគឺ ប្រព័ន្ធនេះមិនត្រូវបានអនុវត្តនៅកន្លែងផ្សេងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះឡើយ ឬ មិនត្រូវបានអនុវត្តទៅតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការនោះឡើយ។ ប្រព័ន្ធកត់ត្រា និង សម្រិតសម្រាំងនេះត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍។ ប្រព័ន្ធនេះមាននៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។

៤៧០. នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ គណៈកម្មាធិការបានណែនាំ សុន សេន ឱ្យក្តាប់ប្រវត្តិរូបបុគ្គល និង សម្រិតសម្រាំង[1699]។ ជាបន្ត សុន សេន បានណែនាំបុគ្គលិកថ្នាក់ក្រោមរបស់គាត់ឱ្យយកប្រវត្តិរូបកម្មាភិបាល សមាជិកបក្ស និង យុវកកុម្មុយនីស្តកម្ពុជា ពីព្រោះពួកគេគឺជាសមាសភាពមិនល្អ និង សមាសភាពបំផ្លិចបំផ្លាញនៅក្នុងជួរបក្សដែលត្រូវសម្រិតសម្រាំង[1700]។ ការណែនាំទាំងនេះត្រូវតែអនុវត្តតាម[1701]។ ស្វាយ សាម៉ែត[1702] បានបញ្ជាក់អំពីការណែនាំពីថ្នាក់លើបែបនេះ។ គាត់បាននិយាយថា ថ្នាក់លើបានបញ្ជាឱ្យ មាស មុត ឱ្យបង្កើតគណៈកម្មាធិការតាមដានប្រវត្តិរូប[1703]។

[1698] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម កុល ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/181 អ.៤០។ ជើងទំព័រ ២៥៣, ៣០៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1699] កំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៥ ឯកសារ D1.3.27.1 EN 00183397 KH 00019114។

[1700] *សូមមើលឧទា.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខាកងពល លេខា និង អនុលេខាវរសេនាធំ" ចុះថ្ងៃទី ២ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.10 EN 00656579 KH 00052361។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខាកងពល និង វរសេនាធំឯកភាជ្ញ" ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.12 EN 00234458 KH 00052378-00052379។

[1701] *សូមមើល* កថាខណ្ឌ ២១៣ និង ២៨៨ *ខាងលើ* ដែលពិភាក្សាពីការផ្សព្វផ្សាយមាគ៌ាបក្សរបស់ សុន សេន ក្នុងការប្រជុំសេនាធិការ។

[1702] *សូមមើល* កថាខណ្ឌ ៣៤៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1703] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ែត ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/77 អ.៤៦-៤៧។

៤៧១. ការតាមដានប្រវត្តិរូបត្រូវបានធ្វើឡើងនៅក្នុងអង្គភាពបក្ស និង ស្ថាប័នទាំងអស់នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ លុន សេង បានថ្លែងថា "ការតាមដានប្រវត្តិទៅដល់ភូមិកំណើតមិនមែនធ្វើតែក្នុងកងពលលេខ ១៦៥ ទេ កងពលដទៃៗទៀតក៏ធ្វើដូចគ្នាដែរ"[1704]។ កងពលធំលេខ ១ មានកងកម្លាំងពិសេសទទួលភារៈស៊ើបអង្កេត និង ពិនិត្យប្រវត្តិរូប[1705]។ ការប្រមូលប្រវត្តិរូបកើតមាននៅមុនរបបកម្ពុជាប្រជាធិបតេយ្យ[1706] និង បានបន្តក្រោយការដួលរលំរបបនេះ។ ម៉ាក ឈឿន បាននិយាយថា ការប្រមូលប្រវត្តិរូបពីកងទ័ព គឺជាការអនុវត្តទូទៅដែលនៅធ្វើឡើងមកទល់សព្វថ្ងៃនេះ[1707]។ អៀង ផាន[1708] បាននិយាយថា គ្រប់គ្នារួមទាំងគាត់ផងដែរ ត្រូវសរសេរប្រវត្តិរូប ហើយថា គេបញ្ជូនមនុស្សទៅតាមភូមិដើម្បីរកមើលថាតើប្រវត្តិរូបពិតដែរឬយ៉ាងណា[1709]។ គាត់ក៏បាននិយាយផងដែរថា ការធ្វើប្រវត្តិរូប គឺជា "នេះជាគោលនយោបាយនៅក្នុងកងទ័ពអ៊ីចឹងតែម្តង។ ជាទូទៅឱ្យតែកងទ័ព"[1710]។ ទម្រង់ប្រវត្តិរូបទូទៅត្រូវបានបង្កើតឡើងដោយមជ្ឈិមបក្ស មិនមែនដោយកងពលធំលេខ ១៦៥ នោះទេ ដូចបានបង្ហាញឱ្យឃើញតាមរយៈប្រវត្តិរូបរបស់នង នេត[1711]។ នង នេត មិនមែនជាសមាជិកកងពលធំលេខ ១៦៥ នោះទេ ប៉ុន្តែត្រូវបានបញ្ជូនទៅស្ទឹងហាវនៅចុងឆ្នាំ ១៩៧៨[1712]។ គាត់បានបំពេញនៅក្នុងបែបបទប្រវត្តិរូបរបស់គាត់នៅមន្ទីរ ក-៥ នៅបុរីកីឡាក្នុងក្រុងភ្នំពេញ[1713]។ កងពលធំលេខ ១៦៥ មិនមែនធ្វើការម្នាក់ឯងនៅក្នុងការប្រមូល និង តាមដានប្រវត្តិរូបនោះឡើយ។

[1704] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/44 ឧ.២៩។ ជើងទំព័រ ២៥៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1705] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១០ ឯកសារ D4.1.1057 ឧ.១០។

[1706] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង សេង ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/209 ឧ.៤០ (គេឱ្យគាត់ធ្វើប្រវត្តិរូបនៅឆ្នាំ ១៩៧៣ ម្តង)។

[1707] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/20 ឧ.៤។

[1708] *សូមមើល* កថាខណ្ឌ ២៦០ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1709] *រឿងក្តី ន្ឃុន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D98/3.1.56 នៅម៉ោង 11.14.14-11.15.39។

[1710] *រឿងក្តី ន្ឃុន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D98/3.1.56 នៅម៉ោង 11.15.39-11.17.35។

[1711] ប្រវត្តិរូបរបស់សមមិត្ត នង នេត ឆ្នាំ ១៩៧៦ ឯកសារ D54/67.1។ ជើងទំព័រ ១១៧២ នៃដីកាសន្និដ្ឋានស្តាពរ។

[1712] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង នេត ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/68 ឧ.១៣។

[1713] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង នេត ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/67 ឧ.១៦-១៩។

៤៧២. ស.ព.អ. អះអាងថា នៅក្នុងអំឡុងពេលវគ្គរៀនសូត្រ មាស មុត បានបង្ខំប្រជាជនឱ្យប្រកាសថា ពួកគេមានជាប់ពាក់ព័ន្ធនឹង ម៉ុម ជីម ហៅ យ៉ាន ដែលជាសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៥ ត្រូវបានចាប់ខ្លួនពីបទក្បត់ជាតិ[1714]។ ស.ព.អ. ដកស្រង់សាក្សីតែម្នាក់គត់គឺ នាក់ យឿន[1715]។ គាត់បាននិយាយថា ញ៉ែត ញ៉ាន់ និង មាស មុត បានបញ្ជាឱ្យអ្នកចូលរួមវគ្គរៀនសូត្រឆ្លើយសំណួរអំពី យ៉ាន នៅក្នុងប្រវត្តិរូបរបស់ពួកគេ[1716]។ តាមដែលមេធាវីការពារក្តីបានដឹងចម្លើយរបស់ នាក់ យឿន មិនស៊ីចង្វាក់ជាមួយនឹងភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងនោះទេ។ ញ៉ែត ញ៉ាន់ គឺជាសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៥[1717]។ ចម្លើយរបស់ នាក់ យឿន បង្ហាញឱ្យឃើញថាគណៈកម្មាធិការរបស់កងពលធំលេខ ១៦៥ បានគ្រប់គ្រងលើការប្រមូលប្រវត្តិរូបពីកម្មាភិបាល មិនមែនមានតែ មាស មុត នោះទេ។

៤៧៣. ស.ព.អ. អះអាងថា មាស មុត នឹងដាក់ទណ្ឌកម្មលើ “ខ្មាំង” ដែលជាអ្នកមិនបានគោរពតាមបញ្ជារបស់គាត់ ហើយអ្នកដែលប្រព្រឹត្តខុសតាមរយៈវគ្គស្វ័យទិតៀន វគ្គអប់រំ ការរំសាយជ្រួរ ការចាប់ខ្លួន និង ការកាប់សម្លាប់[1718]។ គាត់ដកស្រង់ចម្លើយដែលមិនអាចជឿជាក់បាន ឬ គ្មានមូលដ្ឋានគាំទ្រពី ឌុល សុង ស៊ន សុត និង មូល ឈិន[1719]។

៤៧៤. **ឌុល សុង**៖ ឌុល សុង មិនអាចជឿជាក់បានឡើយ[1720]។ គាត់បាននិយាយថា មាស មុត បានទទួលខុសត្រូវលើការសម្រិតសម្រាំង និង ការចាប់ខ្លួនអ្នកដែលបានប្រព្រឹត្តខុស[1721]។ ឌុល សុង បានទាយស្មានអំពីសិទ្ធិអំណាចរបស់ មាស មុត ឬ អំណាចរបស់ មាស មុត[1722]។ គាត់មិនប្រាកដថា

[1714] កថាខណ្ឌ ៣៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1715] ជើងទំព័រ ១១៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1716] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/115 ឆ.១៥។

[1717] *រឿងក្តី ខួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.92 នៅម៉ោង 15.03.11-15.06.23។

[1718] កថាខណ្ឌ ៨៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1719] ជើងទំព័រ ២៥៤-៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1720] *សូមមើល* កថាខណ្ឌ ៣៦៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1721] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/7 ឆ.១៦-១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឆ.២។ ជើងទំព័រ ២៥៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1722] *សូមមើល* កថាខណ្ឌ ៤៦៧ *ខាងលើ*។

តើកំហុសប្រភេទអ្វីដែលឈានដល់ការចាប់ខ្លួន និង ការកាប់សម្លាប់ឡើយ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី គាត់បានផ្តល់ឧទាហរណ៍អំពីកំហុសបែបនោះ[1723]។

៤៧៥. **ស៊ិន សុត**៖ ស៊ិន សុត មិនអាចជឿជាក់បានឡើយ[1724]។ គាត់បានទាយស្មានអំពីសិទ្ធិអំណាច និង ការចូលរួមពាក់ព័ន្ធរបស់ មាស មុត នៅក្នុងការចាប់ខ្លួនកម្មាភិបាលតំបន់ ៣៧[1725]។

៤៧៦. **ម្ងូល ឈិន**៖ ម្ងូល ឈិន មិនអាចជឿជាក់បានឡើយ[1726]។ គាត់បានទាយស្មានថា មាស មុត បានចេញបញ្ជាឱ្យរំសាយជួរ ដោយបានចាត់ឱ្យកងទ័ពទៅតាមកងផលិតផ្សេងៗ ហើយថាមេបញ្ជាការកងទាំងនោះត្រូវបានសម្លាប់ចោលទាំងអស់[1727]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភ័ស្តុតាងដល់ចម្លើយរបស់ ម្ងូល ឈិន ស.ច.ស. ត្រូវពិចារណាថា គាត់បាននិយាយថា តាម៉ុក នៅជាមួយ មាស មុត[1728]។ តាម៉ុក បានចេញបញ្ជារំសាយជួរកងទ័ព និង បញ្ជាឱ្យចាប់ខ្លួនបុគ្គលិកកងពលធំលេខ ១៦៥[1729]។

៤៧៧. **សុក វណ្ណា**៖ សុក វណ្ណា មិនគាំទ្រការអះអាងរបស់ ស.ព.អ. ទាក់ទងនឹងការដាក់ទណ្ឌកម្មរបស់ មាស មុត លើខ្មាំងនោះទេ[1730]។ គាត់បាននិយាយថា មាស មុត មានអំណាចធំជាងគេលើកងពលធំលេខ ៣ ហើយអាចវៃ ឬ បាញ់អ្នកណាម្នាក់យ៉ាងងាយ ដោយបានអះអាងថាបានឃើញ មាស មុត

[1723] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឧ.៣។

[1724] *សូមមើល* កថាខណ្ឌ ៣៥២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។ *សូមមើល* ជើងទំព័រ ២៥៤-៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1725] *សូមមើល* កថាខណ្ឌ ៣៥២ *ខាងលើ*។

[1726] *សូមមើល* កថាខណ្ឌ ៣៦១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1727] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឧ.៩០-៩៤។ ជើងទំព័រ ២៥៤ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ៣៦១ *ខាងលើ* ទាក់ទងនឹងការស្មានរបស់ ម្ងូល ឈិន អំពីតួនាទីរបស់ មាស មុត នៅក្នុងព្រឹត្តិការណ៍នោះ។

[1728] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម្ងូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឧ.៩៦។

[1729] *សូមមើល* កថាខណ្ឌ ១៦៩-៧០ និង ១៧២ *ខាងលើ* ទាក់ទងនឹងសិទ្ធិអំណាចរបស់តាម៉ុកលើបញ្ហាយោធា។

[1730] កថាខណ្ឌ ៨៤ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* កថាខណ្ឌ ៣៥៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

វាយគេដល់សន្លប់[1731]។ គាត់រៀបរាប់ហេតុការណ៍ដែលគេចោទប្រកាន់ចំនួនមួយករណី ដែលមិនមានភ័ស្តុតាងគាំទ្រផ្សេងទៀតនៅក្នុងសំណុំរឿង។

៤៧៨. កងពលធំលេខ ១៦៤ និង តំបន់ស្វយ័តកំពង់សោមស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ[1732]។ មជ្ឈិមបក្ស គឺជាអ្នកធ្វើសេចក្តីសម្រេចចុងក្រោយលើការដាក់ទណ្ឌកម្ម[1733]។ បើទោះបីជា មាស មុត មានសិទ្ធិអំណាចលើការដាក់ទណ្ឌកម្មបុគ្គលិកក្រោមបង្គាប់នៅក្នុងកងពលធំលេខ ១៦៤ ឬ តំបន់ស្វយ័តកំពង់សោម ដែលមិនអនុវត្តតាមបញ្ជារបស់គាត់ក៏ដោយ ក៏ការមាន ឬ ការប្រើប្រាស់អំណាចបែបនោះ មិនមានន័យថា គាត់គឺជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។

៨. សិទ្ធិអំណាចលើបុគ្គលិកកងពលធំលេខ ១១៧ ឬ តំបន់ ៥០៥ មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត"

៤៧៩. ស.ព.អ. អះអាងយ៉ាងទូលំទូលាយថា ក្នុងនាមជាអនុប្រធានម្នាក់របស់ សុន សេន មាស មុត បានអនុវត្តការគ្រប់គ្រងស្រដៀងគ្នានេះទៅលើកងពលធំលេខ ១១៧ និង តំបន់ ៥០៥ ដូចដែលគាត់បានធ្វើទៅលើកងពលធំលេខ ១៦៤ និង នៅកំពង់សោមដូច្នេះដែរ[1734]។ ស.ព.អ. មិនអើពើនឹងភ័ស្តុតាងដែលប្រទាំងប្រទើសនឹងការអះអាងរបស់គាត់។ គាត់ខកខានមិនបានបង្ហាញមូលដ្ឋានគាំទ្រការអះអាងរបស់គាត់។ ការមានសិទ្ធិអំណាចលើកងពលធំលេខ ១១៧ និង តំបន់ ៥០៥ មិន

[1731] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 ឆ.២៣-២៥។ ជើងទំព័រ ២៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1732] *សូមមើល* កថាខណ្ឌ ២១១ *ខាងលើ* និង កថាខណ្ឌ ៥០៤ *ខាងក្រោម* ទាក់ទងនឹងការគ្រប់គ្រងរបស់បក្សលើកងពលមជ្ឈិម និង តំបន់ស្វយ័ត។

[1733] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.4 EN 00198220 KH 00197970 (សុន សេន គឺជាបុគ្គលម្នាក់ដែលបានបញ្ជាឱ្យចាប់ខ្លួនជាចុងក្រោយ)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364072 KH 00357493 (សុន សេន និង គណៈកម្មាធិការមជ្ឈិម ត្រូវតែអនុម័តការសម្រេចចិត្តចាប់ខ្លួនកម្មាភិបាល ដែលគេឆ្លើយដាក់)។ *សូមមើល* កថាខណ្ឌ ១៦៩, ១៧២ និង ២១១ *ខាងលើ* ទាក់ទងនឹងសិទ្ធិអំណាចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

[1734] កថាខណ្ឌ ៨៧ ជើងទំព័រ ២៦៣-៦៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៥៨, ៣០៧។

មានន័យថា មាស មុត គឺជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។

៤៨០. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រលើការអះអាងរបស់គាត់ដែលថា នៅខែវិច្ឆិកា ឆ្នាំ ១៩៧៨ មាស មុត បានទៅតំបន់ ៥០៥ ដើម្បីបោសសម្អាតបុគ្គលិកកងពលធំលេខ ១១៧ និងតំបន់ ៥០៥ តាមរយៈការចេញបញ្ជាឱ្យចាប់ខ្លួន ការរៀបចំដោយផ្ទាល់ខ្លួនន្យូវការដឹកជញ្ជូនអ្នកដែលត្រូវបានចាប់ខ្លួន និង ការរៀបចំរចនាសម្ព័ន្ធបញ្ជាការឡើងវិញនៅកងពលធំលេខ ១១៧ និងតំបន់ ៥០៥ នោះទេ[1735]។ ស.ព.អ. ដកស្រង់ជាចម្បងន្យូវចម្លើយដែលមិនអាចជឿជាក់បានរបស់ ម៉ឹង វេត សេង សឿន ព្រំ សារ៉ាត ប៉ាក សុខ ព្រំ ម៉ុន និង ឈាង ជួ។

៤៨១. **ម៉ឹង វេត៖** ម៉ឹង វេត មិនអាចជឿជាក់បានឡើយ[1736]។ គាត់បានអះអាងថា គាត់បានទទួលសារមួយពីមន្ទីរ ៨៧០ ដែលមានចុះឈ្មោះកម្មាភិបាលរបស់កងពលធំលេខ ១១៧ និង តំបន់ ៥០៥ ដែលត្រូវបានបញ្ជូនទៅកាន់ទីក្រុងភ្នំពេញ[1737]។ ម៉ឹង វេត បានឆ្លើយផ្ទុយនឹងចម្លើយខ្លួនឯង ទាក់ទងនឹងតួនាទីរបស់ មាស មុត ក្នុងការចាប់ខ្លួននេះ។ នៅក្នុងការស្តាប់ចម្លើយរបស់ ក.ស.ច.ស. គាត់បានថ្លែងថា កម្មាភិបាលត្រូវបានចាប់ខ្លួន ពីព្រោះ "មាស មុត គាត់ឈប់ជឿលើថ្នាក់ដឹកនាំកងពល [បន្ទាប់ពីចាញ់វៀតណាម] ហើយដកអ្នក ១១ នាក់នោះចេញ"[1738]។ ទោះជាយ៉ាងនេះក្តី ក្នុងរឿងក្តី ០០២/០២ គាត់បាននិយាយថា មន្ទីរ ៨៧០ បានផ្ញើលិខិតមួយច្បាប់ដែលមានឈ្មោះមនុស្សដែលត្រូវចាប់ខ្លួន[1739]។ ម៉ឹង វេត គឺជាសាក្សីតែម្នាក់គត់ដែល ស.ព.អ. ដកស្រង់ ដើម្បីអះអាងថា មាស មុត បានរៀបចំកិច្ចប្រជុំមួយក្នុងខេត្តក្រចេះអំពីការចាប់ខ្លួននេះ[1740]។ គាត់បានឆ្លើយផ្ទុយនឹងចម្លើយខ្លួនឯងអំពីកិច្ចប្រជុំនេះ។ ដំបូងឡើយ គាត់បាននិយាយថា គាត់បានចូលរួមក្នុងកិច្ចប្រជុំនេះ ក្រោយ

[1735] កថាខណ្ឌ ៨៧ ជើងចំពីរ ២៦៣-៦៤, កថាខណ្ឌ ៥៨ ជើងចំពីរ ១៧៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១២០-២៤។

[1736] *សូមមើល* កថាខណ្ឌ ១៨២-៨៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1737] *សូមមើលឧទា. រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 នៅម៉ោង 09.52.25-09.55.21។ ជើងចំពីរ ២៦៤, ៣៥៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងចំពីរ ៣៤៧៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1738] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D114/297.1.4 ឆ.២។

[1739] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 នៅម៉ោង 09.52.25-09.55.21។

[1740] កថាខណ្ឌ ១២២ នៃដីកាសន្និដ្ឋានស្តាពរ។

មកគាត់ថាមិនបានចូលរួម ហើយក្រោយមកទៀត គាត់បាននិយាយថា គាត់ពិតជាបានចូលរួមក្នុងកិច្ចប្រជុំនេះមែន[1741]។ ដោយមិនគិតពីបញ្ហានេះ ដោយសារតែ មាស មុត ប្រហែលជាអាចបានរៀបចំកិច្ចប្រជុំមួយអំពីការចាប់ខ្លួនមួយចំនួន មិនមានន័យថាគាត់មានសិទ្ធិអំណាចបញ្ជាឱ្យចាប់ខ្លួន ឬ ចាត់តាំងមនុស្សជំនួសនោះទេ។

៤៨២. **សេង សឿន**៖ សេង សឿន មិនអាចជឿជាក់បានឡើយ[1742]។ គាត់បាននិយាយថា មាស មុត បានប្រកាសអំពីការចាត់គាត់ទៅមន្ទីរតំបន់ ៥០៥[1743]។ សេង សឿន បានផ្តល់ចម្លើយផ្ទុយអំពីតួនាទីរបស់ មាស មុត ក្នុងការចាត់តាំងគាត់[1744]។ គាត់ក៏បាននិយាយផងដែរថា មាស មុត បានរៀបចំយន្តហោះដឹកអ្នកដែលត្រូវបានចាប់ខ្លួនចំនួន ១១ នាក់ ទៅកាន់ទីក្រុងភ្នំពេញ[1745]។ ការដឹកជញ្ជូនតាមយន្តហោះ ត្រូវបានរៀបចំដោយ សុន សេន[1746] មិនមែនដោយ មាស មុត ឡើយ។

៤៨៣. **ព្រំ សារ៉ាត**៖ ព្រំ សារ៉ាត មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. នោះទេ។ គាត់បានថ្លែងថា មាស មុត បានធ្វើដំណើរទៅកាន់ខេត្តក្រចេះ នៅពេលដែលការប្រយុទ្ធគ្នាតាមព្រំដែនជាមួយវៀតណាមមានស្ថានភាពកាន់តែខ្លាំងឡើង[1747]។ គាត់មិនបាននិយាយថា មាស មុត មានអំណាចចេញបញ្ជាទៅកាន់កងពលធំលេខ ១៧៧ ឬមានទំនាក់ទំនងផ្ទាល់ជាមួយមេបញ្ជាការកងពលធំនេះឡើយ[1748]។

[1741] *សូមមើល* កថាខណ្ឌ ១៨២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីចម្លើយទាំងនេះ។

[1742] *សូមមើលខាងលើ* កថាខណ្ឌ ១៨៤-៨៥ សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1743] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.៥, ឆ.២៣។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៦ ឯកសារ D59/2/4.16a EN 00753837-00753838 KH 00059329-00059331។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 នៅម៉ោង 13.46.28-13.51.55។ ជើងទំព័រ ១៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1744] *សូមមើល* កថាខណ្ឌ ២០៥ *ខាងលើ*។

[1745] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.៣០។ ជើងទំព័រ ១៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1746] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/160 ឆ.១៣-១៤។

[1747] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ឆ.២២៤។ ជើងទំព័រ ៣៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1748] កថាខណ្ឌ ៨៧ ជើងទំព័រ ២៦៣ នៃដីកាសន្និដ្ឋានស្តាពរ។

៤៨៤. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1749]។ ចម្លើយរបស់គាត់អំពី មាស មុត និង ខេត្តក្រចេះ ធ្វើឱ្យខូចដោយអ្នកស៊ើបអង្កេត ក.ស.ច.ស.។ ប៉ាក សុខ ដំបូងឡើយ បាននិយាយថា គាត់មិនបានដឹងថាតើ មាស មុត ធ្លាប់ត្រូវបានគេបញ្ជូនទៅខេត្តក្រចេះឬយ៉ាងណានោះទេ[1750]។ តាមសំណើរបស់ ប៉ាក សុខ អ្នកស៊ើបអង្កេតបានប្រាប់ ប៉ាក សុខ ថា មាស មុត បានធ្វើដំណើរទៅខេត្តក្រចេះក្នុងឆ្នាំ ១៩៧៨ ដែលជំរុញឱ្យ ប៉ាក សុខ អះអាងយ៉ាងដូច្នេះ ហើយទាយស្មានអំពីមូលហេតុដែល មាស មុត ធ្វើដំណើរទៅខេត្តក្រចេះ[1751]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភ័ស្តុតាងដល់ចម្លើយរបស់ ប៉ាក សុខ មែននោះ ស.ច.ស. ត្រូវពិចារណាថា ប៉ាក សុខ បាននិយាយថា មាស មុត បានស្ថិតនៅក្នុងខេត្តក្រចេះក្នុងរយៈពេលពីរសប្តាហ៍នៅចុងឆ្នាំ ១៩៧៨ និង ថា គាត់បានធ្វើដំណើរទៅកាន់ទីនោះ *បន្ទាប់ពី* ការចាប់ខ្លួនកម្មាភិបាល បានកើនឡើងនៅក្នុងតំបន់នោះ[1752]។

៤៨៥. **ព្រំ ម៉ុន**៖ ព្រំ ម៉ុន មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់គឺជាពាក្យចចាមអារ៉ាមដែលមិនអាចផ្ទៀងផ្ទាត់បាន ដែលទទួលបានតាមរយៈការប្រើប្រាស់ដោយខុសច្បាស់ នូវភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម។ ព្រំ ម៉ុន គឺជាភរិយារបស់ ឃុន សារ៉ុម ដែលជាលេខាកងពលធំលេខ ១១៧ ដែលត្រូវបានគេបញ្ជូនទៅកាន់ទីក្រុងភ្នំពេញ[1753]។ គាត់បាននិយាយថា មាស មុត បានបញ្ជាឱ្យមានការចាប់ខ្លួនប្តីរបស់គាត់[1754]។ ព្រំ ម៉ុន មិនបានស្ថិតនៅក្នុងខេត្តក្រចេះទេ។ ក្រោយមក

[1749] *សូមមើល* កថាខណ្ឌ ២៣៣-៣៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1750] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 អ.៧។ ជើងទំព័រ ១៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1751] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ស-អ.៧-៨៖ "ស៖ ឥឡូវយើងត្រឡប់មកនិយាយអំពី មាស មុត វិញ។ តាមមុខងារ និង តួនាទីរបស់ មាស មុត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តើគាត់ធ្លាប់ត្រូវបានគេបញ្ជូនទៅប្រតិបត្តិការនៅក្រចេះដែរឬទេ តាមដែលលោកដឹង? អ.៧៖ **ទេ ខ្ញុំមិនដឹងទេ។ តើលោកអាចបញ្ជាក់ប្រាប់ខ្ញុំ ថាតើឆ្នាំណាដែល មាស មុត ត្រូវបញ្ជូនទៅក្រចេះ**? អ.៨៖ តាមខ្ញុំចាំ ក្នុងឆ្នាំនោះ មាស មុត ត្រូវបានបញ្ជូនទៅក្រចេះ ពីព្រោះពេលនោះមានការចាប់កម្មាភិបាល គឺមានសន្ទុះខ្លាំង។ **ដូច្នេះ ប្រហែលជាមានការខ្វះខាតកម្មាភិបាលនៅទីនោះ ទើបគាត់ទៅកាន់នៅទីនោះ។** ប៉ុន្តែ នៅពេលដែលកងទ័ពវៀតណាមចូលមកកៀក គាត់ត្រឡប់មកកំពង់សោមវិញ"។ (ការគូសបញ្ជាក់បន្ថែម)។

[1752] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 អ.៨-៩។

[1753] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/170 អ.១៩។

[1754] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/170 អ.៣៥-៣៦។ ជើងទំព័រ ១៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

មេបញ្ជាការកងវរសេនាធំម្នាក់ បានប្រាប់គាត់ថា មាស មុត បានចាប់ប្តីរបស់គាត់[1755]។ ចម្លើយរបស់គាត់ត្រូវបានទទួល បន្ទាប់ពីអ្នកស៊ើបអង្កេតបានប្រើប្រាស់ដោយខុសច្បាប់នូវភ័ស្តុតាងពីមន្ទីរ ស-២១ ដែលទទួលបានពីការធ្វើទារុណកម្ម ធ្វើជាតម្រុយនៃការស៊ើបអង្កេត[1756]។

៤៨៦. **ឈាង ជួ**៖ ឈាង ជួ មិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ គាត់គឺជាមេបញ្ជាការកងអនុសេនាតូចនៃកងពលធំលេខ ១ រហូតដល់ឆ្នាំ ១៩៧៧ ជាពេលដែលគាត់បានក្លាយជាមេបញ្ជាការកងវរសេនាតូចក្នុងកងពលធំលេខ ១១៧[1757]។ គាត់បាននិយាយថា មាស មុត បានមកដើម្បីរៀបចំកងពលធំលេខ ១១៧ និង បានចាត់តាំង ញ៉ាន់ ឱ្យធ្វើជាមេបញ្ជាការកងពលធំនេះ[1758]។ ឈាង ជួ មិនបានដឹងថា តើមេដឹកនាំណាដែលបានមកផ្ទេរមេដឹកនាំរបស់កងពលធំលេខ ១១៧ ឡើយ។ គាត់ត្រឹមតែដឹងថា អ្នកមកជំនួសគឺមកពី "ក្រុមភូមិភាគនិរតី" និង ថា មជ្ឈិមបានសម្របសម្រួលដល់ការពង្រាយកងទ័ពរបស់ មាស មុត[1759]។ គាត់មិនដែលបានឃើញ មាស មុត នៅក្នុងខេត្តក្រចេះទេ[1760]។ គាត់បាននិយាយថា "មជ្ឈិម/៨៧" បានដកកម្លាភិបាលកងពលធំលេខ ១១៧[1761]។

៤៨៧. ស.ព.អ. អះអាងថា មាស មុត បានដាក់ជំនួសកម្លាភិបាលរបស់កងពលធំលេខ ១១៧ និង តំបន់ ៥០៥ ដែលត្រូវបានបោសម្អាតនេះ ដោយទាហានរបស់កងពលធំលេខ ១៦៥[1762]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនមានមូលដ្ឋានគាំទ្រ និង មិនអាចជឿជាក់បានរបស់ សេង សឿន ម៉ឹង វេត ម៉ិញ នឿន ចិន ផាត ម៉ាក ឈឿន លុន សេង និង ឈាង ជួ។

[1755] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/170 អ.៣៥-៣៦។

[1756] *សូមមើល* កថាខណ្ឌ ១៤៧-៥៥ *ខាងលើ* ទាក់ទងនឹងការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មជាតម្រុយក្នុងការស៊ើបអង្កេត។

[1757] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/51 EN 01076735 KH 01071581។

[1758] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/52 អ.៤០-៤១។ ជើងទំព័រ ២៦៥, ៣៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1759] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/51 EN 01076737 KH 01071583-01071584។

[1760] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/52 អ.៥៥។

[1761] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/52 អ.៣១-៣២។

[1762] កថាខណ្ឌ ៨៧ ជើងទំព័រ ២៦៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៥៨ ជើងទំព័រ ១៧៦, កថាខណ្ឌ ១២៣ ជើងទំព័រ ៣៦៣, កថាខណ្ឌ ៨៦៤, ជើងទំព័រ ៣៤៩៨-៣៥០១។

៤៨៨. **សេង សឿន**៖ សេង សឿន មិនអាចជឿជាក់បានឡើយ[1763]។ គាត់ក៏មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. ដែរ។ គាត់បាននិយាយថា មាស មុត បានប្រកាសនៅក្នុងអង្គប្រជុំមួយថា មនុស្សម្នាក់ឈ្មោះ ភាព ដែលមកពីកងទ័ពជើងទឹក គឺត្រូវបានតែងតាំងជាលេខាតំបន់ ៥០៥[1764]។ គាត់មិនបាននិយាយថា មាស មុត បានដំឡើងដំណែង ឬ បានចាត់តាំង ភាព ជាផ្លូវការនោះទេ។

៤៨៩. **ម៉ឹង វេត**៖ ម៉ឹង វេត មិនអាចជឿជាក់បានឡើយ[1765]។ គាត់បាននិយាយថា កងវរសេនាធំកងទ័ពជើងទឹកមួយស្ថិតក្រោមបញ្ជាការរបស់ ភាព បានមកជួយកងពលធំលេខ ១១៧ និង ថា ភាព ត្រូវបានដំឡើងដំណែងជាលេខាតំបន់ ៥០៥[1766]។ គាត់មិនបាននិយាយថា មាស មុត បានដំឡើងដំណែង ឬ បានចាត់តាំង ភាព ឬ មនុស្សជំនួសផ្សេងទៀតជាផ្លូវការនោះឡើយ។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភ័ស្តុតាងដល់សក្ខីកម្មរបស់ ម៉ឹង វេត មែននោះ ស.ច.ស. ត្រូវពិចារណាពីចម្លើយរបស់គាត់ដែលថា ញ៉ាន់ បានមកដល់ខេត្តក្រចេះតាមជើងយន្តហោះតែមួយ ដែលអ្នកត្រូវបានចាប់ខ្លួនចំនួន ១១ នាក់ បានជិះទៅទីក្រុងភ្នំពេញនៅពេលក្រោយមក[1767]។ ចម្លើយនេះបង្ហាញថា ញ៉ាន់ បាន

[1763] *សូមមើល* កថាខណ្ឌ ១៨៤-៨៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1764] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D114/297.1.27 នៅម៉ោង 13.46.28-13.51.55។ ជើងទំព័រ ១៧៦, ២៦៥ នៃដីកាសន្និដ្ឋានស្តាពរ។ គាត់ក៏បានឆ្លើយផងដែរនៅក្នុងកិច្ចសម្ភាសន៍របស់ ក.ស.ច.ស. (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.810 ឧ.៣២) និង បទសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៦ ឯកសារ D59/2/4.16a EN 00753837 KH 00059329។ ជើងទំព័រ ៣៤៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1765] *សូមមើល* កថាខណ្ឌ ១៨២-៨៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1766] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឧ.២៤។ ជើងទំព័រ ២៦៥, ៣៤៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1767] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212302 KH 00975735-00975736។

មកខេត្តក្រចេះពីទីក្រុងភ្នំពេញ[1768] ហើយទំនងជាត្រូវបានតែងតាំងដោយមន្ទីរ ៨៧០។ សេង សឿន ក៏បាននិយាយផងដែរថា គាត់ត្រូវបានផ្ទេរទៅកាន់ខេត្តក្រចេះ ដោយលិខិតមួយពីមន្ទីរ ៨៧០[1769]។

៤៩០. **ម៉ិញ ឈឿម**៖ ម៉ិញ ឈឿម មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. នោះឡើយ។ នៅក្នុងឆ្នាំ ១៩៧៨ គាត់បានចូលធ្វើទាហានក្នុងកងពលធំលេខ ១១៧[1770]។ គាត់មិនបានស្គាល់ មាស មុត នោះទេ ខណៈពេលដែលគាត់ស្ថិតនៅក្នុងខេត្តក្រចេះ[1771]។ គាត់គ្រាន់តែបាននិយាយថា ញ៉ាន់ គឺជាមេកងពលធំលេខ ១១៧[1772]។ គាត់មិនបាននិយាយថា មាស មុត បានដាក់ ញ៉ាន់ ឬ ទាហានរបស់កងពលធំលេខ ១៦៥ ផ្សេងទៀតឱ្យជំនួសកម្មាភិបាលជាន់ខ្ពស់របស់កងពលធំលេខ ១១៧ នោះឡើយ។

៤៩១. **ចិន ផាត**៖ ចិន ផាត មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. នោះឡើយ។ គាត់គឺជាទាហានម្នាក់នៅក្នុងភូមិភាគបស្ចិម រហូតដល់ពេលដែលគាត់ត្រូវបានផ្ទេរទៅកាន់កងពលធំលេខ ១៧៧ នៅក្នុងឆ្នាំ ១៩៧៧[1773]។ ចិន ផាត មិនបានដឹងថា តើ មាស មុត បានធ្វើដំណើរទៅកាន់ខេត្តក្រចេះឬយ៉ាងណានោះទេ ពីព្រោះគាត់តែងតែស្ថិតនៅសមរភូមិមុខ[1774]។ គាត់បាននិយាយថា ញ៉ាន ត្រូវបាន

[1768] អាចជាមួយនឹង សេង សឿន។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ឆ.៣៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ D114/169 ឆ.១៧។

[1769] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.810 ឆ.២៦-២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.២០។ *ប៉ុន្តែ សូមមើល* កថាខណ្ឌ ២០៥ *ខាងលើ* ទាក់ទងនឹងសាក្សី សេង សឿន បានផ្លាស់ប្តូររឿងរបស់គាត់ នៅពេលគាត់មកផ្តល់សក្ខីកម្មក្នុងរឿងក្តី ០០២/០២។

[1770] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ិញ ឈឿម ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/203 ឆ.៥, ឆ.១១។

[1771] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ិញ ឈឿម ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/203 ឆ.៤៥។

[1772] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ិញ ឈឿម ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/203 ឆ.៤៤។ ជើងទំព័រ ២៦៥, ៣៥០១ នៃដីកាសន្និដ្ឋានស្តាពរ។

[1773] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/192 ឆ.១២, ឆ.១៦-១៨។

[1774] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/192 ឆ.៣០។

បញ្ជូនទៅកាន់ខេត្តក្រចេះ ដើម្បីជំនួស រុំ និង ណាង[1775]។ គាត់មិនបាននិយាយថា មាស មុត មានការចូលរួមពាក់ព័ន្ធណាមួយនៅក្នុងការផ្ទេរនេះឡើយ។

៤៩២. **ម៉ាក ឈឿន**៖ ម៉ាក ឈឿន មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. នោះឡើយ។ ស.ព.អ. លើកឡើងមិនត្រឹមត្រូវអំពីចម្លើយរបស់ ម៉ាក ឈឿន ដែលមិនគាំទ្រដល់ការអះអាងរបស់គាត់។ ម៉ាក ឈឿន មិនបាននិយាយថា ញ៉ាន់ ត្រូវបានបញ្ជូនឱ្យទៅប្រយុទ្ធជាមួយវៀតណាមនៅក្នុងខេត្តក្រចេះនោះទេ[1776]។ គាត់បាននិយាយថា *គាត់បានគិតថា* ញ៉ាន ត្រូវបានបញ្ជូនឱ្យទៅប្រយុទ្ធប្រឆាំងនឹងវៀតណាមនៅព្រំដែនក្នុង *ខេត្តតាកែវ*[1777]។ ស.ព.អ. បានធ្វើឱ្យមានការយល់ខុស តាមរយៈការលុបសម្រង់សំដីពីក្នុងចម្លើយនូវពាក្យ “ខ្ញុំគិតថា គាត់ត្រូវបានបញ្ជូន” និង ពាក្យ “ក្នុងខេត្តតាកែវ”។

៤៩៣. **លុន សេង**៖ លុន សេង មិនអាចជឿជាក់បានឡើយ[1778]។ គាត់បាននិយាយថា ញ៉ាន បានធ្វើដំណើរទៅខេត្តក្រចេះជាមួយ មាស មុត[1779]។ លុន សេង បានឮព័ត៌មាននេះក្នុងអំឡុងកិច្ចប្រជុំមួយ[1780]។

៤៩៤. **ឈាង ជួ**៖ ឈាង ជួ មិនអាចជឿជាក់បានឡើយ[1781]។ គាត់បានទាយស្មានដោយផ្អែកលើពាក្យចចាមអារ៉ាម។ គាត់បាននិយាយថា មាស មុត បានចាត់តាំង ញ៉ាន ឱ្យធ្វើជាមេបញ្ជាការកងពលធំ

[1775] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ចិន ផាត ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១២ ឯកសារ D114/157.1.3 EN 01507038-01507039 KH 01197650-01197651។ ជើងទំព័រ ២៦៥, ៣៥០១ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/192 អ.៤១-៤២។

[1776] ដូចដែល ស.ព.អ. បានបញ្ជាក់នៅក្នុងជើងទំព័រ ២៦៥ និង ៣៥០១ នៃដីការសន្និដ្ឋានស្តាពរ។

[1777] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/18 អ.១៦, អ.១៧។

[1778] *សូមមើល* កថាខណ្ឌ ១៩៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1779] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/110 អ.៥។ ជើងទំព័រ ២៦៥, ៣៥០១ នៃដីកាសន្និដ្ឋានស្តាពរ។

[1780] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/110 អ.៦។

[1781] *សូមមើល* កថាខណ្ឌ ៤៨៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

លេខ ១១៧[1782]។ គាត់បានត្រឹមតែជឿជាក់ថា វាយ៉ាងដូច្នេះ ពីព្រោះ ញ៉ាន បាននិយាយថា មាស មុត បានមករៀបចំកងពលធំលេខ ១១៧[1783]។

៤៩៥. បើទោះបីជា ស.ច.ស. ផ្តល់តម្លៃជាភ័ស្តុតាងដល់ចម្លើយរបស់សាក្សីទាំងនេះក្តី ក៏សាក្សីទាំងនេះមិនបាននិយាយ ឬ បង្ហាញថា មាស មុត មានអំណាចចាត់តាំងមនុស្សឱ្យកាន់មុខតំណែងថ្មីនោះដែរ។ យ៉ាងច្រើនបំផុត ពួកគេបង្ហាញថា សមាជិកពីរនាក់នៃកងពលធំលេខ ១៦៥ បានជំនួសកម្មាភិបាលកងពលធំលេខ ១១៧ និង តំបន់ ៥៥[1784]។ សេង សឿន មិនមែនជាទាហានរបស់កងពលធំលេខ ១៦៥ នោះទេ។ គាត់បានជិះយន្តហោះពីទីក្រុងភ្នំពេញទៅកាន់ខេត្តក្រចេះ ដើម្បីធ្វើជាប្រធានមន្ទីរតំបន់ ៥០៥[1785]។ អ្នកជំនួសផ្សេងទៀតក៏បានមកពីទីក្រុងភ្នំពេញដែរ ហើយមិនមែនមកពីកងពលធំលេខ ១៦៥ នោះទេ[1786]។

៤៩៦. ស.ព.អ. អះអាងថា មាស មុត នៅតែស្ថិតក្នុងអំណាចបញ្ជាកងពលធំលេខ ១១៧ និង តំបន់ ៥០៥ និង បានរក្សាវត្តមាននៅទីនោះ រហូតដល់កងទ័ពវៀតណាមបានចូលមកដល់នៅចុងឆ្នាំ ១៩៧៨[1787]។ ស.ព.អ. ដកស្រង់តែចម្លើយដែលមិនអាចជឿជាក់បានរបស់ ម៉ឹង វេត និង សេង សឿន[1788]។ ស.ព.អ. ក៏ថ្លែងអំពីភ័ស្តុតាងខុសផងដែរ។

៤៩៧. **សេង សឿន**៖ សេង សឿន មិនអាចជឿជាក់បានឡើយ[1789]។ គាត់បាននិយាយថា មាស មុត បានមកកាន់តំបន់ ៥០៥ ដើម្បីរៀបចំខាងផ្នែកជនស៊ីវិល និង យោធា បានបញ្ជា សេង សឿន ឱ្យប្រមូលផ្តុំកងកម្លាំងដើម្បីភៀសខ្លួនចេញពីព្រំដែន និង ថា គាត់បានឮ មាស មុត រាយការណ៍ទៅ

[1782] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/52 ឯ.៤០។ ជើងទំព័រ ២៦៥, ៣៥០១ នៃដីកាសន្និដ្ឋានស្តាពរ។

[1783] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/52 ឯ.៤១។

[1784] *សូមមើល* ជើងទំព័រ ១៧៦, ២៦៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1785] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.810 ឯ.២៥-២៧។

[1786] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/62 ស-ឯ.៣៥។

[1787] កថាខណ្ឌ ៨៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៨៦៦។

[1788] ជើងទំព័រ ២៦៦-៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1789] *សូមមើល* កថាខណ្ឌ ១៨៤-៨៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

ស៊ូ ម៉ែត[1790]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភ័ស្តុតាងដល់សក្ខីកម្មរបស់ សេង សឿន មែននោះ ស.ច.ស. ត្រូវពិចារណាថា គាត់បាននិយាយថា ប៉ុល ពត មិនបានធ្វើដំណើរមកកាន់ខេត្តក្រចេះ ដោយខ្លួនគាត់ផ្ទាល់នោះទេ[1791] ដែលបង្ហាញថា មាស មុត មិនមែនជាអ្នកមានអំណាចខ្ពស់បំផុតនៅក្នុងតំបន់ ៥០៥ ឡើយ។

៤៩៨. **ម៉ឹង វេត**៖ ម៉ឹង វេត មិនអាចជឿជាក់បានឡើយ[1792]។ ស.ព.អ. ផ្តែងខុសអំពីការអះអាងរបស់ ម៉ឹង វេត ដែលថា មាស មុត គឺជាថ្នាក់លើតែម្នាក់គត់នៅខេត្តក្រចេះ[1793]។ គាត់ពឹងផ្អែកលើប្រតិចារឹកដែលមិនពេញលេញនៃការស្តាប់ចម្លើយរបស់គាត់ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ម៉ឹង វេត កំពុងសំដៅលើកិច្ចប្រជុំមួយ ដែលត្រូវបានរៀបចំធ្វើឡើង បន្ទាប់ពីកម្មាភិបាលរបស់កងពលធំលេខ ១១៧ និង តំបន់ ៥០៥ ត្រូវបានចាប់ខ្លួន។ គាត់បាននិយាយថា មាស មុត គឺជាថ្នាក់លើតែម្នាក់គត់ *នៅឯកិច្ចប្រជុំនោះ*[1794]។ ឯកសារបកប្រែដែល ស.ព.អ. យកមកសំអាងលុបចោលចម្លើយមួយចំនួនរបស់ ម៉ឹង វេត ដែលត្រូវបានបញ្ចូលនៅក្នុងប្រតិចារឹកដែលពេញលេញ[1795]។ ម៉ឹង វេត ក៏បាននិយាយផងដែរថា មាស មុត បានវិលត្រលប់ទៅកាន់កំពង់សោមវិញ បន្ទាប់ពីកិច្ចប្រជុំនោះ[1796]។ មាស មុត មិនបានស្នាក់នៅក្នុងខេត្តក្រចេះទេរហូតដល់ពេលវៀតណាម

[1790] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.២៣-២៤។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D114/297.1.27 នៅម៉ោង 10.58.13-11.00.53, 13.54.58-13.57.43, 13.59.44-14.01.14។ ជើងទំព័រ ២៦៦-៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1791] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.២៣។

[1792] *សូមមើល* កថាខណ្ឌ ១៨២-៨៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1793] ជើងទំព័រ ២៦៦ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212292 KH 00975728។

[1794] *សូមមើល* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212317-01212318 KH 00975745-00975746។

[1795] *ប្រៀបធៀប* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212317-01212318 KH 00975745-00975746 ជាមួយនឹងបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 00993000 KH 00975745 ទាក់ទងនឹងចម្លើយរបស់សាក្សីអំពីនិរសាររបស់ មាស មុត បានចូលរួមនៅក្នុងការប្រជុំ អ្វីដែល មាស មុត បាននិយាយ និង អត្តចរិករបស់គាត់។

[1796] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D54/60.2 EN 01212322 KH 00975748។

បានចូលមកដល់[1797]។ សេង សឿន ក៏បាននិយាយផងដែរថា មាស មុត បានវិលត្រឡប់ទៅ ទីក្រុងភ្នំពេញវិញនៅចុងឆ្នាំ ១៩៧៨[1798]។

៤៩៩. ទោះបីជាភស្តុតាងបង្ហាញថា មាស មុត បានចាកចេញពីតំបន់ ៥០៥ នៅចុងឆ្នាំ ១៩៧៨ ក៏ដោយ ក៏ ស.ព.អ. ប៉ុនប៉ងទម្លាក់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើ មាស មុត ចំពោះការផ្ទេរទៅមន្ទីរ ស-២១ និង ការកាប់សម្លាប់កម្មាភិបាលរបស់តំបន់ ៥០៥ ចំនួន ២២ នាក់ នៅចុងខែ ធ្នូ ឆ្នាំ ១៩៧៨[1799] និង ចំពោះការចាប់ខ្លួន ឬ ជម្លៀសកម្មាភិបាលមូលដ្ឋាន[1800]។ មិនមានឯកសារណាមួយរបស់មន្ទីរ ស-២១ ឬ ចម្លើយរបស់សាក្សី ដែល ស.ព.អ. ដកស្រង់ បង្ហាញថា មាស មុត មានការចូលរួមពាក់ព័ន្ធណាមួយនៅក្នុងព្រឹត្តិការណ៍ទាំងនេះទេ។

៥០០. ស.ព.អ. អះអាងថា មាស មុត បានទទួលខុសត្រូវចំពោះការបាញ់សម្លាប់កងកម្លាំងយោធាដែលដកថយនៅក្នុងតំបន់ ៥០៥ ស្របតាមគោលនយោបាយមជ្ឈិម[1801]។ គាត់ដកស្រង់តែចម្លើយដែលមិនអាចជឿជាក់បាន និង មិនមានមូលដ្ឋានគាំទ្ររបស់ មាស វឿន និង ប៉ាក សុខ[1802]។ គាត់ក៏ផ្តែងអំពីភស្តុតាងខុសផងដែរ។

៥០១. **មាស វឿន**៖ មាស វឿន មិនអាចជឿជាក់បានឡើយ[1803]។ គាត់បាននិយាយថា កងទ័ពរបស់កងពលធំលេខ ១៦៥ បានបាញ់សម្លាប់ទាហានរបស់កងពលធំលេខ ១ ដែលបានដកថយពីសមរភូមិប្រឆាំងនឹងកងទ័ពវៀតណាម[1804]។ ចម្លើយរបស់គាត់ ពឹងផ្អែកតែលើពាក្យចចាមអារ៉ាមពីទាហាន

[1797] ផ្ទុយនឹងការអះអាងរបស់ ស.ព.អ. នៅក្នុងកថាខណ្ឌ ៨៧ នៃដីកាសន្និដ្ឋានស្តារពៈ។

[1798] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/169 ឆ.២៨។

[1799] កថាខណ្ឌ ៨៦៨ ជើងទំព័រ ៣៥២៧-២៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1800] កថាខណ្ឌ ៨៦៨ ជើងទំព័រ ៣៥៩២-៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[1801] កថាខណ្ឌ ១២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1802] ជើងទំព័រ ៣៦៨-៦៩, ៣៥០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1803] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1804] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ឆ.៥, ឆ.៨។ ជើងទំព័រ ៣៦៩, ៣៥០៣ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ៦៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

របស់កងពលធំលេខ ១ ប៉ុណ្ណោះ[1805]។ មាស វឿន មិនមានវត្តមានទេនៅពេលនោះ ដោយត្រូវបានផ្ទេរទៅកាន់ខេត្តព្រះវិហារហើយ[1806]។

៥០២. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1807]។ ស.ព.អ. ផ្តែងខុសអំពីការអះអាងរបស់ប៉ាក សុខ ដែលថា ការបញ្ជាឱ្យចាប់ខ្លួន និង សម្លាប់ "ពួកគេ" បានចេញពី មាស មុត[1808]។ ប៉ាក សុខ បានសំដៅលើបញ្ជាដែលត្រូវបានចោទប្រកាន់ ទាក់ទងនឹងប្រជាជនវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ[1809] មិនមែនកងកម្លាំងរបស់កងពលធំលេខ ១ នៅព្រំដែនភាគខាងកើតនោះទេ។

៥០៣. ស.ព.អ. ក៏ដកស្រង់ផងដែរនូវចម្លើយរបស់ មាស មុត ដែលត្រូវបានអះអាងថាបានផ្តល់ឱ្យ David Kattenburg ដោយនិយាយថា គាត់បានធ្វើដំណើរទៅកាន់ខេត្តក្រចេះក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៨[1810]។ ការស្តាប់ចម្លើយរបស់ មាស មុត ដែលមិនត្រូវបានធ្វើឡើងដោយ អ.វ.ត.ក. និងត្រូវបានធ្វើឡើងដោយគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ សម្រាប់គោលបំណងក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌនោះ មានតម្លៃជាភស្តុតាងតិចតួចណាស់[1811]។

៥០៤. បញ្ជាណាមួយដែល មាស មុត អាចបានដាក់ចេញទៅកាន់កងពលធំលេខ ១១៧ និង តំបន់ ៥០៥ និងសកម្មភាពណាមួយដែលគាត់អាចអនុវត្តនៅក្នុងតំបន់ខេត្តក្រចេះ គឺបានផ្អែកលើបញ្ជាដែលចេញដោយ ប៉ុល ពត និង មន្ទីរ ៨៧០[1812]។ ដូច សៅ សារុន ដែលធ្លាប់ធ្វើជាលេខាតំបន់ ១០៥

[1805] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ន.៤-៥។

[1806] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/50 ន.៧។

[1807] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1808] ជើងទំព័រ ៣៦៩ នៃដីកាសន្និដ្ឋានស្តាពរ ដែលកស្រង់បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D54/24.1 EN 00978576 KH 00955507-00955508។

[1809] *សូមមើល* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D54/24.1 EN 00978576 KH 00955507-00955508។

[1810] កថាខណ្ឌ ១២៤ ជើងទំព័រ ៣៧១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ខ្សែអាត់សំឡេងនៃបទសម្ភាសន៍របស់ មាស មុត ជាមួយ David Kattenburg ខែមេសា ឆ្នាំ ២០០៩ ឯកសារ D54/16/1R នៅម៉ោង ៣៣:៣២-៣៥:២៦។ *សូមមើលផងដែរ* ជើងទំព័រ ២៦៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1811] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[1812] ដូចដែលបង្ហាញក្នុងសក្ខីកម្មថា ប៉ុល ពត និង មជ្ឈឹម បញ្ជាឱ្យចាប់កម្មាភិបាលក្នុងកងពល ១១៧ និង តំបន់ ៥០៥៖ *រឿងក្តីខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/297.1.24 នៅម៉ោង 09.52.25-09.55.21។

ក្នុងមួយរយៈពេលខ្លី[1813] បានផ្តល់សក្ខីកម្ម ប៉ុល ពត បានប្រកាសនៅក្នុងខែកញ្ញា ឆ្នាំ ១៩៧៨ ថា កងពលធំមិនត្រូវបានអនុញ្ញាតឱ្យចាប់ខ្លួន ឬ ឃុំខ្លួនកម្មាភិបាលដោយគ្មានការកោះហៅជាមុនពីគណៈមជ្ឈិម[1814]។ មិនមានការអនុញ្ញាត ឬ លទ្ធភាពសម្រាប់មេបញ្ជាការកងពលធំក្នុងការអនុវត្តសកម្មភាពឯករាជ្យដោយឯកឯងនោះឡើយ។ មិនមានភ័ស្តុតាងដែលបង្ហាញថា មាស មុត បានចេញបញ្ជាផ្ទាល់របស់គាត់ ឬ បានផ្តួចផ្តើមគោលនយោបាយផ្ទាល់របស់គាត់នៅក្នុងតំបន់ ៥០៥ នោះទេ។ កង្វះភ័ស្តុតាងបែបនេះណាមួយ គឺត្រូវនឹងការណ៍ដែលថា កងពលធំលេខ ១១៧ និងតំបន់ ៥០៥ បានស្ថិតនៅក្រោមអំណាចផ្ទាល់របស់មជ្ឈិម[1815]។

៥០៥. មាស មុត មិនបានអនុវត្តអំណាច ឬ សិទ្ធិដោយឯករាជ្យនោះទេទាក់ទងនឹងកងពលធំលេខ ១១៧ ឬ តំបន់ ៥០៥។ បើទោះបីជាគាត់បានអនុវត្តសិទ្ធិអំណាចបែបនេះមែនក៏ដោយ (មិនថាជាមេបញ្ជាការកងពលធំមជ្ឈិម ឬ ជាអនុប្រធាននៅអគ្គសេនាធិការ) ក៏សិទ្ធិអំណាចនេះបានកើតមានក្នុងរយៈពេលតិចជាងពីរខែ មុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំប៉ុណ្ណោះ។ យ៉ាងច្រើនបំផុត វាមានការពាក់ព័ន្ធនឹងការចាប់ខ្លួន និង ការផ្ទេរមនុស្សចំនួន ១១ នាក់[1816]។ សិទ្ធិអំណាច និង ទង្វើបែបនេះ មិនមានន័យថា មាស មុត គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។

[1813] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/193 ឆ.៧-៨, ឆ.៣០-៣១។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១២ ឯកសារ D98/1.2.32 នៅម៉ោង 14.21.31-14.24.25។ គាត់ក៏អាចធ្វើការងារមួយចំនួន ពីដើមឆ្នាំ ១៩៧៨ ជាលេខា *ជាក់ស្តែង* (de facto) ដែលប៉ុល ពត បានចាត់តាំង។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១២ ឯកសារ D98/1.2.34 នៅម៉ោង 09.32.17-09.34.25។

[1814] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១២ ឯកសារ D98/1.2.34 នៅម៉ោង 10.21.09-10.28.02។

[1815] ទូរលេខ ចំណងជើងថា "ទូរលេខ ពី កងពល ១១៧ សូមធ្វើសេចក្តីរាយការណ៍ ជូនសេនាធិការជ្រាប" ចុះថ្ងៃទី ២ ខែមីនា ឆ្នាំ ១៩៧៨ ឯកសារ D4.1.313។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/52 ឆ.៤-៥, ឆ.៤០។ *សូមមើល* កថាខណ្ឌ ២៤១ *ខាងលើ* ទាក់ទងនឹងតំបន់ស្វយ័ត។

[1816] កថាខណ្ឌ ៨៦១ នៃដីកាសន្និដ្ឋានស្តាពរ។

៩. មាស មុតមិនទទួលខុសត្រូវលើការបោសសម្អាតកងពលធំលេខ ១៦៤

៥០៦. ស.ព.អ. ខកខានមិនបានបង្ហាញថា មាស មុត ដែលបានខ្នះខ្នែងអនុវត្តការបោសសម្អាតនោះ មានអំណោចផ្តាច់មុខក្នុងការកម្ទេចកងទ័ព ឬ បានបញ្ជាឱ្យចាប់ខ្លួនទាហានរបស់កងពលធំលេខ ១៦៤។ ស.ព.អ. ដកស្រង់សាក្សី និង ភ័ស្តុតាងឯកសារដែលមិនអាចជឿជាក់បាន។ គាត់បង្ហាញភ័ស្តុតាងខុស។ គាត់មិនអើពើនឹងភ័ស្តុតាងបរិបទ និង ភ័ស្តុតាងប្រឆាំងគ្នាដែលពាក់ព័ន្ធផ្សេងទៀត ដែលធ្វើឱ្យការអះអាងរបស់គាត់កាន់តែខ្សោយ និង បដិសេធការអះអាងរបស់គាត់។ សូម្បីតែនៅពេលភ័ស្តុតាងនេះត្រូវបានពិនិត្យមើលក្នុងផ្លូវដែលមានភាពអំណោយផលបំផុតដល់ ស.ព.អ. ក៏ដោយ ក៏វាមិនបង្ហាញថា មាស មុត មានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការបោសសម្អាតកងពលធំលេខ ១៦៤ នោះដែរ។ បើទោះបីជា ស.ច.ស. រកឃើញថា មាស មុត មានការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ក៏នៅពេលពិចារណាលើអំពើស្រដៀងគ្នានេះ និង ចំនួនជនរងគ្រោះនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ភ័ស្តុតាង គឺមិនគ្រប់គ្រាន់សម្រាប់ធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងឡាយ “ដែលទទួលខុសត្រូវខ្ពស់បំផុត” នោះដែរ។

ក. មាស មុត មិនបានខ្នះខ្នែងអនុវត្តគោលនយោបាយបោសសម្អាតរបស់បក្ស ជាមួយនឹង ប.ក.ក. និង មេដឹកនាំជាន់ខ្ពស់របស់កងពលធំលេខ ១៦៤

៥០៧. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានខ្នះខ្នែងអនុវត្តគោលនយោបាយបោសសម្អាតរបស់បក្ស[1817] បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយ សុន សេន និង ឌឹម ដើម្បីបោសសម្អាតកងពលធំលេខ ១៦៤[1818] និង ទទួលខុសត្រូវចំពោះអ្នកទោសកងពលធំលេខ ១៦៤ ចំនួន ៦៧ នាក់ និង អ្នកទោសកងទ័ពបដិវត្តន៍កម្ពុជាដែលមិនមែនស្ថិតនៅក្នុងកងពលធំលេខ ១៦៤ ចំនួន ៤៨០០ នាក់ ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[1819]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន និង មិនមានមូលដ្ឋានគាំទ្ររបស់ ឌុច អ៊ូ ដាវ ប៊ាង អ៊ែត និង ឯក នី[1820]។ គាត់ដកស្រង់សារទូរលេខ កំណត់ហេតុកិច្ចប្រជុំរបស់អគ្គ

[1817] កថាខណ្ឌ ៣៣៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1818] កថាខណ្ឌ ១១១-១៣, ១១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1819] កថាខណ្ឌ ៥៤១, ៥៥២ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១០៣-១៩, ១៧២-៧៣, ៣២៩-៣៦។

[1820] ជើងទំព័រ ១១៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

សេនាធិការ និង ឯកសារផ្សេងទៀតដែលមិនគាំទ្រការអះអាងរបស់គាត់[1821]។ គាត់ក៏ផ្តែងខុសអំពីភស្តុតាងមួយចំនួនផងដែរ។

៥០៨. **ឌុច៖** ឌុច មិនអាចជឿជាក់បានឡើយ[1822]។ គាត់បានអះអាងថា មាស មុត បានត្រឹមតែបោសសម្អាតកងពលធំលេខ ១៦៥ និង បាននិយាយថា គាត់បានជឿជាក់ថា ការបោសសម្អាតនៅកំពង់ផែ នៅជិតភូមិ និង ទីក្រុងកំពង់សោម ក៏បានកើតមានឡើងផងដែរ[1823]។ គាត់បានទាយស្មាន។ គាត់មិនបានទទួលឯកសារណាមួយអំពីព្រឹត្តិការណ៍ទាំងនេះឡើយ[1824]។

៥០៩. **អ៊ូ ដាវ៖** អ៊ូ អារ មិនអាចជឿជាក់បានឡើយ[1825]។ អ៊ូ ដាវ បានអះអាងថា ក្នុងអំឡុងពេលប្រជុំដែល មាស មុត គឺជាអ្នកធ្វើបទឧទ្ទេសនាមនោះ បក្សបានប្រកាសផែនការសម្រិតសម្រាំងកងទ័ព និង កម្ទេចពួកមូលធននិយម ព្រមទាំងទាហានរបស់ លន់ នល់[1826]។ ស.ព.អ. បង្ហាញចម្លើយនេះ ហាក់បីដូចជាបទពិសោធន៍ផ្ទាល់របស់ អ៊ូ ដាវ[1827]។ អ៊ូ ដាវ មិនធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំអប់រំនយោបាយណាមួយនោះឡើយ។ គាត់គ្រាន់តែរៀបរាប់ឡើងវិញអំពីអ្វីដែលមិត្តភក្តិម្នាក់បានប្រាប់គាត់ប៉ុណ្ណោះ[1828]។

៥១០. **ប៊ាង រ៉ែត និង ឯក នី៖** ប៊ាង រ៉ែត និង ឯក នី មិនគាំទ្រដល់ការអះអាងរបស់របស់ ស.ព.អ. នោះឡើយ។ អ្នកទាំងពីរបានផ្តល់ចម្លើយទូទៅ ទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុងរបស់យោធា[1829]។

[1821] ជើងទំព័រ ៣២៤-២៧, ៣៣៤, ៣៤៣-៤៥, ២០៤០-៤៣, ២១២៩-៣០ នៃដីកាសន្និដ្ឋានស្តាពរ។

[1822] *សូមមើល* កថាខណ្ឌ ១៧៥-៧៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1823] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ទ.៣០។

[1824] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ទ.៣០, ទ.៣២។

[1825] *សូមមើល* កថាខណ្ឌ ៣៥៥ *ខាងលើ* និង កថាខណ្ឌ ៥៣៣-៣៤ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1826] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ទ.១៣-១៤។

[1827] ជើងទំព័រ ១១៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1828] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ទ.១២។

[1829] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ទ.៥៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/284 ទ.៨-៩។ ជើងទំព័រ ១១៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

ឯក នី បាននិយាយថា មាស មុត បានលើកឡើងនៅក្នុងអង្គប្រជុំ ឱ្យតាមដានខ្មាំងដែលលាក់ខ្លួននៅក្នុងជួរ[1830]។ ទាំងគាត់ ទាំង ប៊ាង រ៉ែត មិនបាននិយាយថា មាស មុត បានចូលរួមពាក់ព័ន្ធ ឬ ទទួលខុសត្រូវក្នុងការបោសសម្អាតនោះឡើយ។

៥១១. ស.ព.អ. ដកស្រង់ចម្លើយសារភាពដែលមានចំណារ និង របាយការណ៍ដែលមិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានសហការណ៍យ៉ាងជិតស្និទ្ធជាមួយ សុន សេន និង ឌឹម ដើម្បីបោសសម្អាតកងពលធំលេខ ១៦៥៖

- ឯកសារ **D234/2.1.55** និង ឯកសារ **D234/2.1.54**៖ ស.ព.អ. អះអាងថា ចំណារនៅលើចម្លើយសារភាពចំនួនពីរ បង្ហាញថា សុន សេន បានសុំឱ្យ មាស មុត ពិនិត្យមើលចម្លើយសារភាពរបស់មន្ត្រី ស-២១ ដើម្បីកំណត់ថា តើទាហានរបស់កងពលធំលេខ ១៦៥ ដែលត្រូវបានឆ្លើយដាក់ គឺជាជនក្បត់ឬយ៉ាងណា[1831]។ នៅលើចម្លើយសារភាពមួយក្នុងចំណោមចម្លើយសារភាពដែលត្រូវបានចារទាំងពីរនេះ ពោលគឺឯកសារ D234/2.1.55 ជនដែលមិនត្រូវបានស្គាល់អត្តសញ្ញាណម្នាក់បានសរសេរថា គាត់នឹង "អញ្ជើញស/ម មុត មកពិនិត្យជាសម្ងួហភាព"[1832]។ ស.ព.អ. អះអាងថា ជនម្នាក់នេះ គឺជា សុន សេន ដោយដកស្រង់ចម្លើយរបស់ខុច[1833]។ ស.ព.អ. លើកឡើងមិនត្រឹមត្រូវអំពី ខុច។ ខុច មិនបាននិយាយថា សុន សេន គឺជាអ្នកសរសេរនោះទេ។ គាត់បានស្មានថា អ្នកសរសេរនោះគឺជា សុន សេន បន្ទាប់ពីសម្រេចថា អ្នកសរសេរនោះមិនមែនជា ន្ឋន ជា៖ "ខ្ញុំគិតថា វាជាអក្សររបស់ សុន សេន។ ប៉ុន្តែ មិនមែនជាអក្សររបស់ ន្ឋន ជា ទេ ហើយមានតែពួកគេតែប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើចំណារបែបនេះលើចម្លើយសារភាពរបស់មន្ត្រី ស-២១"[1834]។ ក្រោយមកទៀត ខុច បានសារភាពថា គាត់គ្រាន់តែ

[1830] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/284 ឆ.៦-៧។ កថាខណ្ឌ ១០៥ ជើងទំព័រ ៣០៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1831] កថាខណ្ឌ ១១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1832] ចម្លើយសារភាព ស-២១ របស់ ហង់ ឌឿន ហៅ ឌឹម ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.55 និង D1.3.18.1 EN 00224085-00224086 (ហត្ថលេខារបស់ សុន សេន មិនមាននៅក្រោមចំណារទេ។ (ជើងទំព័រ ៣៤៣ នៃដីកាសន្និដ្ឋានស្តាពរ)។

[1833] ជើងទំព័រ ៣៤៣ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ 2009 ឯកសារ D4.1.766 EN 00398210 KH 00398202។

[1834] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ 2009 ឯកសារ D4.1.766 EN 00398210-00398211 KH 00398202-00398203។

បានឮអំពីចំណារនេះបន្ទាប់ពីបានមើលសំណុំរឿងក្តី ០០១ ប៉ុណ្ណោះ៖ "ខ្ញុំមិនដឹងថាមានការធ្វើចំណារលើចម្លើយសារភាពនោះទេ ហើយខ្ញុំត្រូវបានដឹងពីរឿងនេះ តែពីពេលនៃការដាក់ក្រោមការត្រួតពិនិត្យ បន្ទាប់ពីបានអានសំណុំរឿងប៉ុណ្ណោះ"[1835]។ នៅលើចម្លើយសារភាពទីពីរដែលត្រូវបានចារ ស.ព.អ. ដកស្រង់ឯកសារ D234/2.1.54 ដែល សុន សេន ត្រូវបានអះអាងថាបានសរសេរថា៖ "ទ/ទ ស/ម មុត ដើម្បីមានវិធានការ"[1836]។ ចំណារទាំងនេះមានភាពលម្អៀងទៅម្ខាង។ មិនមានការបង្ហាញថា មាស មុត បានទទួលចម្លើយសារភាព ឬ បានចាត់វិធានការទៅតាមចម្លើយសារភាពទាំងនោះទេ។

- ឯកសារ **D1.3.34.10** និង ឯកសារ **D1.3.12.7**៖ ស.ព.អ. អះអាងថា នៅថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៧៦ មាស មុត បានរាយការណ៍ទៅ សុន សេន ថា "អ្នកមានរឿងដែលឃុំឃាំង" ត្រូវបានដោះលែងដោយយុទ្ធជនចំនួនពីរនាក់របស់កងពលធំលេខ ១៦៥ និង ថា នៅក្នុងកិច្ចប្រជុំមួយរបស់កងទ័ពបដិវត្តន៍កម្ពុជានាពេលក្រោយមក គាត់ ឬ អ្នកតំណាងរបស់គាត់ បានហៅយុទ្ធជនទាំងពីរនាក់នោះថា "ក្បត់" ដោយសារតែសកម្មភាពរបស់ពួកគេ[1837]។ សារទូរលេខមិនបង្ហាញថា អ្នកជាប់ឃុំឃាំងទាំងនេះមកពីកងពលធំលេខ ១៦៥ នោះទេ។ វាត្រឹមតែបង្ហាញថា យុទ្ធជនទាំងពីរនាក់របស់កងពលធំលេខ ១៦៥ បានដោះលែងពួកគេ[1838]។ ឯកសារដែលទទួលបានពីកិច្ចប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជានេះ មិនបង្ហាញថាអ្នកណាបានហៅយុទ្ធជនកងពលធំលេខ ១៦៥ ទាំងពីរនាក់នេះថា "ក្បត់" នោះទេ ថាតើវាជានរណាម្នាក់មកពីកងពលធំលេខ ១៦៥ ឬជានរណាម្នាក់ផ្សេងទៀត[1839]។ មិនមានការបង្ហាញថាអ្នកណាបានរៀបចំឯកសាររបស់កងទ័ពបដិវត្តន៍កម្ពុជា ឬ នៅពេលណាដែលឯកសារនេះត្រូវបានរៀបចំនោះឡើយ។

[1835] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.860 EN 00403921 KH 00403909-00403910។

[1836] ចម្លើយសារភាព ស-២១ របស់ គុណ ឌីម ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.54 EN 00822359 KH 00175293។ ជើងទំព័រ ៣៤៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1837] កថាខណ្ឌ ១១១ នៃដីកាសន្និដ្ឋានស្តាពរ។

[1838] ទូរលេខ ចំណងជើងថា "ទូរលេខពី មុត ជម្រាបបង ៨៩ គោរពជម្រាប" ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.10។ ជើងទំព័រ ៣២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1839] សេចក្តីរាយការណ៍យោធា ចំណងជើងថា "សរុបសភាពការណ៍ ចាប់ពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ដល់ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ១៩៧៦" ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.7 EN 00233963 KH 00021503។ ជើងទំព័រ ៣២៥ នៃដីកាសន្និដ្ឋានស្តាពរ។

- ឯកសារ **D1.3.34.11**៖ ស.ព.អ. អះអាងថា នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ឌឹម បានរាយការណ៍ទៅ មាស មុត ថា គាត់បានធ្វើតាមបញ្ជារបស់ មាស មុត ដោយចាប់ខ្លួនបុគ្គលណាដែលត្រូវបានគេមើលឃើញថាជាខ្មាំង ឬ ជាជនក្បត់[1840]។ ស.ព.អ. លើកឡើងមិនត្រឹមត្រូវអំពីសារទូរលេខនេះ[1841]។ ឌឹម បាននិយាយថា ពួកគេបានចាត់វិធានការទៅតាមការសម្រេចរបស់ មាស មុត។ គាត់បាននិយាយថា ខ្មាំងចំនួនប្រាំនាក់ បានរត់ចូលក្នុងព្រៃ ប៉ុន្តែត្រូវបានចាប់ខ្លួន គាត់បានចាត់វិធានការនយោបាយ និង សតិអារម្មណ៍ និង បានរៀបចំអង្គភាពល្បាតបន្ថែមទៀត ដើម្បីប្រតិបត្តិការការស្វែងរក[1842]។ សារទូរលេខនេះ មិនបង្ហាញថា មាស មុត បានចេញបញ្ជាឱ្យចាប់ខ្លួននោះទេ គ្រាន់តែថា គាត់ប្រហែលជាអាចសម្រេចចិត្តលើវិធានការដែលមិនត្រូវបានស្គាល់ថាជាអ្វី។ សារទូលេខនេះ បង្ហាញសកម្មភាពជាក់លាក់ដែលធ្វើឡើងដោយ ឌឹម៖ គាត់បានចាប់ខ្លួនមនុស្ស បានចាត់វិធានការជាក់លាក់ និង បានរៀបចំការល្បាតបន្ថែម។

- ឯកសារ **D1.3.2.2**៖ ស.ព.អ. លើកឡើងមិនត្រឹមត្រូវអំពីសេចក្តីណែនាំចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ របស់ សុន សេន ផ្ញើឱ្យ មាស មុត ដែលណែនាំឱ្យគាត់រក្សាការសម្ងាត់ចំពោះការចាប់ខ្លួននាពេលថ្មីៗ នៅក្នុងការអះអាងថា វាជាភ័ស្តុតាងនៃការបន្តឃុបឃិតគ្នារបស់ មាស មុត ជាមួយ សុន សេន ទាក់ទងនឹងការចាប់ខ្លួន និង ការបោសសម្អាតកងពលធំលេខ ១៦៥[1843]។ សុន សេន បានសំដៅលើការចាប់ខ្លួនទាហានថៃ ឬ វៀតណាម នៅលើកោះមួយក្នុងចំណោមកោះនានា ដោយការដែលគាត់សំដៅលើ "ក្រែងវាមកតាម" បញ្ជាក់កាន់តែច្បាស់[1844]។ គាត់មិនបានសំដៅលើការចាប់ខ្លួនបុគ្គលិករបស់កងពលធំលេខ ១៦៥ នោះឡើយ។

- ឯកសារ **D1.3.27.26**៖ ស.ព.អ. អះអាងថា នៅថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ មាស មុត បានរាយការណ៍ទៅ សុន សេន និង មេបញ្ជាការកងពលធំអំពីការបោសសម្អាតកងអនុសេនាតូច

[1840] កថាខណ្ឌ ១១២ នៃដីកាសន្និដ្ឋានស្តាពរ។

[1841] ជើងទំព័រ ៣២៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1842] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ជូនបងមុត ជ្រាប អំពីសភាពការណ៍ខ្មាំងនៅតាមព្រំដែន" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699 (ឯកសារនេះដូចគ្នានឹងឯកសារ D1.3.34.11 ដែលឯកស្រង់ក្នុងជើងទំព័រ ៣២៦ នៃដីកាសន្និដ្ឋានស្តាពរ)។

[1843] កថាខណ្ឌ ១១៣ ជើងទំព័រ ៣២៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1844] ទូរលេខ ចំណងជើងថា "ទូរលេខពីបង ៨៩ ជម្រាបសមមិត្ត មុត" ចុះថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D1.3.2.2៖ "អំពីពួកខាងលិច ដែលយើងចាប់បាននៅកោះវ៉ៃ ត្រូវស្ងាត់ឱ្យមែនទែន ហើយត្រូវរៀបចំប្រយុទ្ធ ក្រែងវាមកតាម"។

មួយនៃកងពលធំលេខ ១៦៥[1845]។ កំណត់ហេតុកិច្ចប្រជុំនេះ មិនបានបង្ហាញថា មាស មុត បានចូលរួមក្នុងកិច្ចប្រជុំនេះទេ[1846]។

- ឯកសារ **D1.3.34.60**៖ ស.ព.អ. អះអាងថា នៅក្នុងសារទូរលេខចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ដែលផ្ញើទៅកាន់មន្ទីរ ៨៧០ មាស មុត បានបញ្ជាក់អំពីករណីយកិច្ចរបស់គាត់ក្នុងការសម្លាប់សត្រូវ[1847] ដែលបង្ហាញឱ្យឃើញពីការដឹងឮរបស់គាត់ និង ឆន្ទៈចូលរួមក្នុងការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា[1848]។ ស.ព.អ. បកស្រាយមិនត្រឹមត្រូវអំពីសារទូរលេខនេះ។ គាត់ក៏មិនអើពើផងដែរនឹងបរិបទដែលសារទូរលេខនេះត្រូវបានផ្ញើ។ មាស មុត បាននឹងកំពុងឆ្លើយតបទៅនឹងការណែនាំ និង តម្រង់ផ្លូវពីមជ្ឈិម ទាក់ទងនឹងការប្រយុទ្ធគ្នាដែលកំពុងបន្តកើតមានជាមួយប្រទេសវៀតណាម[1849]។ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម ដោយសារតែការឈ្លានពានដែលកំពុងបន្តធ្វើឡើងដោយវៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ[1850]។ រដ្ឋាភិបាលបានចេញ *សេចក្តីថ្លែងការណ៍* មួយ ដែលពន្យល់អំពីសេចក្តីសម្រេចចិត្តរបស់ខ្លួន[1851]។

[1845] កថាខណ្ឌ ១១៤ ជើងទំព័រ ៣៣៤ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26 EN 00933835 KH 00052305។

[1846] *សូមមើល* កថាខណ្ឌ ៣០៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីឯកសារនេះ។

[1847] កថាខណ្ឌ ១១៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលយោងទូរលេខរបស់មាស មុត ចំណងជើងថា "ទូរលេខ ០០ – វិទ្យុ ៣៥៤ ខ្ទង់ – គោរពជូនគណៈ ម.៨៧០" ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.60។ *សូមមើលផងដែរ* កថាខណ្ឌ ៣៣៤ ជើងទំព័រ ១១៥៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1848] កថាខណ្ឌ ៥៤១ នៃដីកាសន្និដ្ឋានស្តាពរ។

[1849] ទូរលេខរបស់មាស មុត ចំណងជើងថា "ទូរលេខ ០០ – វិទ្យុ ៣៥៤ ខ្ទង់ – គោរពជូនគណៈ ម.៨៧០" ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.60 EN 00184995 KH 00001325៖ "យើងខ្ញុំបានទទួលមតិណែនាំ និង សេចក្តីថ្លែងការណ៍របស់បក្សស្តីពីការឈ្លានពានរបស់ឃួន មកលេបទឹកដីមាតុភូមិកម្ពុជារបស់យើង"។ ជើងទំព័រ ២០៤០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កថាខណ្ឌ ៣៣៤ និង ជើងទំព័រ ៣៤៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1850] សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D69.1.5។

[1851] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029។

- រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានពិពណ៌នាអំពីការវាយប្រហាររបស់ប្រទេសវៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ និង កិច្ចប្រឹងប្រែងរបស់ប្រទេសនេះដើម្បីការពារខ្លួនឯង[1852] កិច្ចប្រឹងប្រែងរបស់វៀតណាមក្នុងការជ្រើសរើសជនជាតិកម្ពុជា ឱ្យមកទម្លាក់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ[1853] ការឃោសនារបស់វៀតណាមអំពីកម្ពុជាប្រជាធិបតេយ្យថាបានក្លាយជា "សមាជិករបស់សហព័ន្ធឥណ្ឌូចិន" [1854] ព្រមទាំងជនបរទេស និង រដ្ឋាភិបាលបរទេសដែលផ្តល់ជំនួយយោធាដល់ប្រទេសវៀតណាម[1855]។ រដ្ឋាភិបាលបាននិយាយថា "តែចំពោះជនបរទេសណាមកធ្វើជាទីប្រឹក្សា អ្នកជំនាញការ និង បញ្ជាការផ្ទាល់ ដើម្បីរួមវាយលុកឈ្លានពានកម្ពុជាប្រជាធិបតេយ្យ នោះរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យកំណត់ថា អ្នកនោះឯង និងរដ្ឋាភិបាលអ្នកនោះឯង ចូលមកឈ្លានពានកម្ពុជាប្រជាធិបតេយ្យ និង ប្រជាជនកម្ពុជាដោយផ្ទាល់តែម្តង" [1856]។ រដ្ឋាភិបាលបានអំពាវនាវឱ្យបក្ស កងទ័ពបដិវត្តន៍កម្ពុជា និង ប្រជាជនឱ្យបង្កើនការប្រុងប្រយ័ត្នបដិវត្តន៍ ការពារឯករាជ្យភាព និង បូរណភាពទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ និង បញ្ឈប់ការឈ្លានពានរបស់សត្រូវ និង កិច្ចប្រឹងប្រែងយកដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ[1857]។ រដ្ឋាភិបាលបានណែនាំថា៖ "យើងត្រូវពុះពារ ដោយស្មារតីប្រយុទ្ធទ្រាំទ្រគ្រប់បែបយ៉ាង ដើម្បីឯករាជ្យភាព សេរីភាព និង កិត្តិយសជាតិយើង កុំឱ្យធ្លាក់ទៅជាខ្ញុំកញ្ជះគេ។ ហើយយើងដាច់ខាតការពារទឹកដីដ៏ពិសិដ្ឋរបស់យើងបាន គ្មានកម្លាំងអ្វីមកវាយបំបាក់ ឬ លេបយើងបានដាច់

[1852] *សូមមើលខាង.* សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713102-00713106 KH 00442392-00442398។

[1853] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713104 KH 00442394-00442395។

[1854] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713105 KH 00442396។

[1855] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713107-00713108 KH 00442398-00442400។

[1856] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713108 KH 00442399-00442400។

[1857] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713108-00713109 KH 00442399-00442401។

ខាត”[1858]។ វាជាឯកសារនេះហើយ ដែលអំពាវនាវឱ្យមានការការពារជាតិប្រឆាំងនឹងការឈ្លានពានយោធា ដែល មាស មុត បានឆ្លើយតបនៅពេលដែលគាត់បានសំដៅលើការបោសសម្អាតសត្រូវបង្កប់វៀតណាម ឬ ខ្មាំងផ្សេងទៀត[1859]។ គាត់មិនមែនកំពុងយល់ស្រប ឬ ប្តេជ្ញាថានឹងបោសសម្អាតសមាជិករបស់កងពលធំលេខ ១៦៥ ឬ អង្គភាពកងទ័ពបដិវត្តន៍កម្ពុជាណាមួយនោះទេ។

៥១២. ស.ព.អ. ពឹងផ្អែកយ៉ាងខ្លាំងទៅលើកំណត់ហេតុកិច្ចប្រជុំ ដែលទទួលបានពីកិច្ចប្រជុំរបស់សេនាធិការនៅថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានដឹង និង មានឆន្ទៈចូលរួមក្នុងការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា[1860]។ ស.ព.អ. មិនអើពើនឹងបរិបទដែលកិច្ចប្រជុំបែបនេះ បានកើតមានឡើងនោះឡើយ[1861]។ ការណ៍ដែលថា មាស មុត ប្រហែលជាអាចត្រូវបានមើលឃើញថា លើកសរសើរគោលនយោបាយបោសសម្អាតសមាសភាពមិនល្អរបស់បក្ស មិនមានន័យថា គាត់បានឯកភាពឱ្យមានការចាប់ខ្លួន ឬ បញ្ជូនខ្លួនទាហានទៅកាន់មន្ទីរ ស-២១ ឬ បោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជានោះទេ។ “ការបោសសម្អាត” មិនមែនត្រឹមតែមានន័យថា ជាការចាប់ខ្លួន ឬ ការសម្លាប់នៅមន្ទីរ ស-២១ ឬ មន្ទីរសន្តិសុខផ្សេងទៀតនោះទេ។ វាក៏មានន័យផងដែរថា ជាការផ្ទេរទៅកាន់អង្គភាពផ្សេងទៀត ឬ ការបញ្ជូនឱ្យទៅធ្វើការ ឬ រៀនសូត្រផងដែរ[1862]។

[1858] សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713111 KH 00442403។

[1859] ទូរលេខរបស់ មាស មុត ចំណងជើង “ទូរលេខ ០០ – វិទ្យុ ៣៥៤ ខ្លង់ – គោរពជូនគណៈ ម.៨៧០” ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.60 EN 00184995 KH 00001325។

[1860] ជើងទំព័រ ២០៤០-៤៣, ២១២៩-៣០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ១១៣១-៣៤។

[1861] *សូមមើល* កថាខណ្ឌ ២៨៨, ៣០៣-០៤ *ខាងលើ*។

[1862] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/97 EN 01074507 KH 00988688៖ “បន្ទាប់ពីបោសសម្អាតនៅឆ្នាំ ១៩៧៧ លោកត្រូវបានបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកងកេង”។ កំណត់ហេតុនៃការស្តាប់ចម្លើយ តេង សារឹម ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/96 ឆ.៤៖ “នៅពេលដែលមានការចាប់ផ្តើមបោសសម្អាតយោធានៅភូមិភាគបូព៌ា គេបញ្ជូនខ្ញុំទៅខេត្តកំពង់ឆ្នាំង ហើយគេបង្ខំខ្ញុំឱ្យធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង”។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.846 ឆ.១៤៖ “បើគេរកឃើញថា អ្នកណាមាននិន្នាការជាមួយអតីតទាហាន លន់ នល់ ដែលមានឋានន្តរសក្តិធំ នឹងត្រូវបានគេដកតំណែង ឬបញ្ជូនឱ្យទៅកន្លែងផ្សេង ដូចជា កសិដ្ឋានចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក វៃច្នៃ ដាំកប្បាស ។ល។ ដោយមិនឱ្យយើងធ្វើការក្នុងរង្វង់ក្របខ័ណ្ឌយោធា

៥១៣. ស.ព.អ. ដកស្រង់កំណត់ហេតុកិច្ចប្រជុំរបស់អគ្គសេនាធិការផ្សេងទៀត ដែលមិនគាំទ្រដល់ការអះអាងរបស់គាត់។ គាត់ដកស្រង់កំណត់ហេតុដែលទទួលបានពីកិច្ចប្រជុំនៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ដែលក្នុងនោះ មាស មុត បានរាយការណ៍អំពីកងពលធំលេខ ១៦៥ ប៉ុន្តែមិនបាននិយាយអ្វីមួយ ដែលយល់ស្របនឹងការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជានោះឡើយ[1863]។ គាត់ដកស្រង់កំណត់ហេតុកិច្ចប្រជុំចំនួនបីដែល មាស មុត មិនបានចូលរួម។ គាត់ដកស្រង់កំណត់ហេតុកិច្ចប្រជុំនៅថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ដែលគាត់អះអាងថា មាស មុត បានរាយការណ៍អំពីការបោសសម្អាតដែលកំពុងបន្តធ្វើឡើងទៅលើកងអនុសេនាតូចមួយ[1864]។ មាស មុត មិនបានចូលរួមកិច្ចប្រជុំនេះទេ[1865]។ គាត់ដកស្រង់កិច្ចប្រជុំនៅថ្ងៃទី ២ ខែសីហា ឆ្នាំ ១៩៧៦ ដែល មាស មុត មិនបានចូលរួម ហើយទាយស្មានថា ចម្លើយរបស់ សុន សេន ទាក់ទងនឹងការបោសសម្អាត “គ្មានអ្វីសង្ស័យទេ [គឺ] ទាក់ទងទៅ” គាត់[1866]។ គាត់ដកស្រង់កិច្ចប្រជុំនៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៧៦ ដែលគ្មានអ្នកណាម្នាក់មកពីកងពលធំលេខ ១៦៥ បានចូលរួម[1867]។ មិនត្រូវយកឯកសារទាំងនេះមកពិចារណាឡើយ។

ខ្មែរក្រហមទៀតទេ។ ខ្ញុំមិនដែលឃើញមានការសម្លាប់ចំពោះអ្នកដែលបានរកឃើញថាមានទិន្នាការនោះទេ”។ *សូមមើលផងដែរ* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខា និង វរសេនាធំឯករាជ្យ” ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.20 EN 00940354-00940355 KH 00052413-00052414 (ក្នុងនោះ សុន សេន បានណែនាំអ្នកចូលរួមអំពីគោលការណ៍នៃការបោសសម្អាតបីយ៉ាងរបស់បក្ស ដែលរួមមាន សម្រិតសម្រាំង ដាច់ខាត អប់រំជាបន្តបន្ទាប់ និង អប់រំកសាង អាស្រ័យទៅលើការល្មើសបំពាន)។

[1863] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ” ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195340-00195341 KH 00052390-00052391។ ជើងទំព័រ ២០៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[1864] ជើងទំព័រ ២០៤០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯករាជ្យ” ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26 EN 00933835 KH 0052305។ *សូមមើលផងដែរ* កថាខណ្ឌ ៩៨ ជើងទំព័រ ២៩១-៩៣, ជើងទំព័រ ១១៣៣, ១១៣៥-៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1865] *សូមមើល* កថាខណ្ឌ ៣០៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីឯកសារនេះ។

[1866] ជើងទំព័រ ១១៣៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1867] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា “កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខា និង វរសេនាធំឯករាជ្យ” ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៧៦ឯកសារ D1.3.27.13។ជើងទំព័រ ២០៤០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ*ជើងទំព័រ ១១៣១ នៃដីកាសន្និដ្ឋានស្តាពរ។

ខ. មាស មុត មិនមានអំណាចផ្តាច់មុខក្នុងការសម្រេចថា តើត្រូវចាប់ខ្លួន ឬ សម្លាប់ទាហានរបស់កងពលធំលេខ ១៦៥

៥១៤. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មានតែ មាស មុត ទេ ដែលមានអំណាចសម្រេចលើការកម្ទេចខ្មាំងនៅក្នុងកងពលធំលេខ ១៦៥[1868]។ ស.ព.អ. ដកស្រង់សាក្សី អែម សុន និង ជេត ប៉ុណ្ណា ដែលមិនអាចជឿជាក់បាន និង ចម្លើយដែលមិនមានមូលដ្ឋានគាំទ្ររបស់ ប៊ាង រ៉ែត[1869]។

៥១៥. **អែម សុន៖** អែម សុន មិនអាចជឿជាក់បានឡើយ[1870]។ គាត់បានអះអាងថា មាស មុត មានអំណាចជាង តាម៉ុក (ទោះបីជា តាម៉ុក មានឋានៈខ្ពស់ជាងគាត់ក៏ដោយ) និង ថា តាម៉ុក មិនអាចដោះលែងអ្នកណាម្នាក់ដែល មាស មុត ចាប់ដាក់ឃុំឃាំងបាននោះឡើយ ប៉ុន្តែ មាស មុត អាចដោះលែងអ្នកណាម្នាក់ដែល តាម៉ុក ចាប់ដាក់ឃុំឃាំង[1871]។ ឯម សុន មិនបានពន្យល់ពីមូលដ្ឋានសម្រាប់ការអះអាងរបស់គាត់នេះទេ។ គាត់បាននិយាយនាពេលក្រោយមកថា វាគ្រាន់តែជាឧទាហរណ៍មួយសម្រាប់ការប្រៀបធៀប ហើយគាត់មិនធ្លាប់ដែលឃើញ មាស មុត ចាប់ខ្លួនអ្នកណាម្នាក់នោះទេ[1872]។ ប៉ុន្តែគាត់បានអះអាងថា អ្វីដែលគាត់បាននិយាយអំពីអំណាចរបស់ មាស មុត គឺជាការដឹងឮទូទៅ[1873]។ បើតាមដែលមេធាវីការពារក្តីដឹងនោះ មិនមានសាក្សីផ្សេងទៀតបានធ្វើការអះអាងនេះទាក់ទងនឹងអំណាចរបស់ មាស មុត ប្រៀបធៀបទៅនឹងអំណាចរបស់តាម៉ុក នោះទេ។ ផ្ទុយទៅវិញ ភស្តុតាងបង្ហាញឱ្យឃើញថា មិនដូចទៅនឹង មាស មុត តាម៉ុក មានអំណាចយ៉ាងខ្លាំងណាតសន្ធឹងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ[1874]។

[1868] កថាខណ្ឌ ៣៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[1869] ជើងទំព័រ ១១៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1870] *សូមមើល* កថាខណ្ឌ ២៣៦, ២៤៤, ៣៤៩, និង ៤១៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1871] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/46 ឆ.៤៣។ ជើងទំព័រ ១១៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1872] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ឆ.១។

[1873] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/47 ឆ.២។

[1874] *សូមមើល* កថាខណ្ឌ ១៦៩-៧០ និង ១៧២ *ខាងលើ* ទាក់ទងនឹងតួនាទី និង សិទ្ធិអំណាចរបស់ តាម៉ុក នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

៥១៦. **ជេត ប៉ុណ្ណា**៖ ជេត ប៉ុណ្ណា មិនអាចជឿជាក់បានឡើយ[1875]។ គាត់បានអះអាងថា មាស មុត មានអំណាចចាប់ខ្លួន និង សម្លាប់ទាហាន និង ជនស៊ីវិលក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ ដោយនិយាយប្រាប់រឿងមួយអំពី មាស មុត ដែលបញ្ជាឱ្យចាប់ខ្លួនមនុស្សថែទាំសត្វគោ ដែលធ្វើឱ្យគោស្គមស្គាំងពេក[1876]។ បើទោះបីជា រឿងនេះអាចឱ្យជឿជាក់បានក៏ដោយ ក៏វាមិនបង្ហាញថាមានតែ មាស មុត ម្នាក់ដែលអាចចាប់ខ្លួន ឬ សម្លាប់ទាហានរបស់កងពលធំលេខ ១៦៤ នោះដែរ។

៥១៧. **ប៊ាង រ៉ែត**៖ ប៊ាង រ៉ែត[1877] មិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. នោះទេ។ គាត់បាននិយាយប្រាប់រឿងមួយអំពី មាស មុត ដែលត្រូវបានគេចោទប្រកាន់ថាបានស្តីបន្ទោសឱ្យ ញ៉ាន ដែលជាមេបញ្ជាការកងវរសេនាធំលេខ ៦៣ អំពីរឿងសម្លាប់មនុស្សដោយគ្មានការអនុញ្ញាតពីគាត់។ គាត់មិនបាននិយាយថា មាស មុត មានអំណាចផ្តាច់មុខក្នុងការសម្រេចចិត្តសម្លាប់មនុស្សនោះឡើយ[1878]។ គាត់បាននិយាយថា មាស មុត *និង គណៈកងពលធំលេខ ១៦៤* ត្រូវធ្វើសេចក្តីសម្រេចចិត្តអំពីការសម្លាប់ទាហាន និងថា ការសម្រេចចិត្តស្រដៀងគ្នាមួយ ត្រូវធ្វើឡើងដោយគណៈថ្នាក់ក្រោមនីមួយៗ[1879]។ ប៊ាង រ៉ែត ក៏បានអះអាងផងដែរថា គណៈកងពលធំលេខ ១៦៤ មិនមានសិទ្ធិអំណាចនោះទេក្នុងការសម្រេចចិត្តថា មេបញ្ជាការកងវរសេនាធំគួរត្រូវសម្លាប់ ឬយ៉ាងណានោះ។ អគ្គសេនាធិការជាអ្នកមានសិទ្ធិអំណាចនេះ[1880]។

៥១៨. មាស មុត មិនអាចសម្រេចតែម្នាក់ឯងថា តើទាហានណាម្នាក់របស់កងពលធំលេខ ១៦៤ នឹងត្រូវដាក់ទណ្ឌកម្មដោយសារភាពមិនស្មោះត្រង់ ឬថា តើពួកគេនឹងត្រូវដាក់ទណ្ឌកម្មយ៉ាងដូចម្តេចនោះទេ។ គណៈកងពលធំលេខ ១៦៤ មានការទទួលខុសត្រូវរួមគ្នាលើកងពលធំលេខ ១៦៤ ទាក់ទងនឹងបញ្ហាទាំងអស់[1881]។ អគ្គសេនាធិការ និង គណៈអចិន្ត្រៃយ៍/យោធា ត្រូវអនុម័តលើការចាប់ខ្លួន

[1875] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1876] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/65 ឆ.៩។

[1877] *សូមមើល* កថាខណ្ឌ ១៩៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1878] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.១២០-២២។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៊ាង រ៉ែត ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D59/1/1.11a EN 00974135 KH 00926575-00926576។ ជើងទំព័រ ១១៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1879] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.១៣០។

[1880] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.១៣០។

[1881] *សូមមើល* កថាខណ្ឌ ២១២ *ខាងលើ* ទាក់ទងនឹងគណៈកម្មាធិការកងពលលេខ ១៦៤។

ឬ ការសម្លាប់ទាហានរបស់កងពលធំលេខ ១៦៤ នៅមុនពេលចំណាត់ការបែបនេះណាមួយ អាចធ្វើទៅបាន[1882]។

គ. មាស មុត មិនបានបញ្ជាឱ្យចាប់ខ្លួនកងទ័ពរបស់កងពលធំលេខ ១៦៤

៥១៩. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានបញ្ជាឱ្យចាប់ខ្លួនអតីតទាហានរបស់កងពលធំលេខ ៣ តំបន់ ៣៧ និង ទាហានរបស់កងវរសេនាតូចលេខ ៣៨៦ អតីតទាហានភូមិភាគបូព៌ា ទាហានដែលមានជាប់ពាក់ព័ន្ធនឹងរបបលន់ នល់ ឬ របបរបស់បរទេស ទាហានដែលត្រូវបានចាត់ទុកថាជាខ្មាំងផ្ទៃក្នុង និង កម្មាភិបាលផ្សេងទៀត[1883] និង ថា សមាជិករបស់កងពលធំលេខ ១៦៤ រាប់ពាន់នាក់ ត្រូវបានចាប់ឃុំឃាំង និង ធ្វើឱ្យទៅជាទាសករ រាប់រយនាក់ត្រូវបានសម្លាប់ ឬ បានបាត់ខ្លួន និង ៦៧ នាក់ត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១[1884]។ ស.ព.អ. សំអាងលើសាក្សី និង ឯកសារដែលមិនអាចឱ្យជឿជាក់បាន និង មិនមានមូលដ្ឋានគាំទ្រ[1885]។ គាត់ក៏មិនអើពើនឹងភស្តុតាងបរិបទដែលពាក់ព័ន្ធផងដែរ។

i. អតីតទាហានរបស់កងពលធំលេខ ៣

៥២០. ស.ព.អ. អះអាងថា ទាហានរបស់កងពលធំលេខ ៣ ចំនួនពី ៣០០ - ៧២០ នាក់ ដែលត្រូវបានឃុំឃាំងដោយកងកម្លាំងវៀតណាម ត្រូវបានបោសសម្អាត បន្ទាប់ពីពួកគេវិលត្រលប់មកវិញ តាមរយៈការបញ្ជូនពួកគេឱ្យទៅធ្វើការងារនៅឯកងនានា និងថា មេដឹកនាំរបស់ពួកគេបានបាត់ខ្លួន[1886]។ មានតែសាក្សីចំនួនពីរនាក់ប៉ុណ្ណោះ ដែលគាត់ដកស្រង់[1887] គឺ សិន សុត និង សាត ចក់ ដែលអះអាងថា មាស មុត មានសិទ្ធិអំណាចណាមួយ ឬ មានការចូលរួមពាក់ព័ន្ធនឹងការសម្រេចចិត្តនេះ

[1882] *សូមមើល* កថាខណ្ឌ ១៦៩, ១៧២, ២១១ និង ២១៣ *ខាងលើ* ទាក់ទងនឹងសិទ្ធិអំណាចខ្ពស់បំផុតរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការយោធា និង អគ្គសេនាធិការ លើកងពលលេខ ១៦៤ និង កងពលមជ្ឈិមទាំងអស់។

[1883] កថាខណ្ឌ ១០៨, ១១៣-១៤, ១១៦-១៨ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ខ្លឹមខាងលើ* កថាខណ្ឌ ៣៤២-៦២។

[1884] កថាខណ្ឌ ១១៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1885] ជើងទំព័រ ៣១៧, ៣៣០-៣៣, ៣៣៩, ៣៤២, ៣៤៦-៥១, ១១៨២-៨៣, ១១៨៥-៨៧, ១២០១-០៩, ១២២២-២៣, ១២៤៩-៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1886] កថាខណ្ឌ ៣៤២ នៃដីកាសន្និដ្ឋានស្តាពរ។

[1887] ជើងទំព័រ ១១៨២-៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

ឬថា មេដឹកនាំទាំងនោះបានបាត់ខ្លួន។ សាក្សីទាំងនេះមិនអាចឱ្យជឿជាក់បានឡើយ ហើយមិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ. នោះទេ។

៥២១. **ស៊ិន សុត**៖ ស៊ិន សុត មិនអាចជឿជាក់បានឡើយ[1888]។ គាត់បាននិយាយថា មាស មុត បានទម្លាក់ដំណែងទាហាននៅក្នុងក្រុមរបស់ តាជី ដែលត្រូវបានចាប់ខ្លួនដោយវៀតណាម[1889]។ គាត់បានឮរឿងនេះពី តាជី នៅក្រោយឆ្នាំ ១៩៧៩ ខណៈពេលដែលពួកគេបានជិះម៉ូតូឌុបជាមួយគ្នា[1890]។

៥២២. **សាត ចក់**៖ សាត ចក់ មិនអាចជឿជាក់បានឡើយ[1891]។ ស.ព.អ. លើកឡើងដោយមិនត្រឹមត្រូវអំពីចម្លើយរបស់ សាត ចក់ ដែលថា មេបញ្ជាការកងវរសេនាតូចលេខ ៣១០ ឈ្មោះ ហម បានបាត់ខ្លួន និងថា មេបញ្ជាការផ្សេងទៀតរបស់កងវរសេនាតូចលេខ ៣១០ បានបាត់ខ្លួន ឬ ត្រូវបានផ្ទេរ[1892]។ ចម្លើយពេញលេញរបស់ សាត ចក់ គឺ៖ "អ្នកខ្លះក៏បាត់ទៅ អ្នកខ្លះក៏ឡើងទៅកាន់នៅឯណាៗទៅ ខ្ញុំមិនច្បាស់ដែរ"[1893]។ គាត់មិនបាននិយាយត្រឹមតែថា មេដឹកនាំទាំងនោះបានបាត់ខ្លួនឡើយ។ គាត់ក៏បាននិយាយផងដែរថា ពួកគេត្រូវបានផ្ទេរទៅកន្លែងផ្សេង និងថា គាត់មិនប្រាកដអំពីបញ្ហានេះទេ។

ii. ទាហានតំបន់ ៣៧ និង កងវរសេនាតូចលេខ ៣៨៦

៥២៣. ស.ព.អ. អះអាងថា នង ឆាន ត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១ "ច្បាស់ណាស់ដោយមានការឯកភាពពី មាស មុត" និង ថា មាស មុត បានបញ្ជាឱ្យចាប់ខ្លួន និង ដកហូតអាវុធរបស់អតីតមេដឹកនាំ និង កម្មាភិបាលរបស់កងវរសេនាតូចលេខ ៣៨៦[1894]។ ស.ព.អ. គាំទ្រការអះអាងរបស់គាត់អំពី នង ឆាន តាមរយៈការយោងទង្វើករណ៍របស់គាត់ទាក់ទងនឹងមន្ទីរ ស-២១ និង ការ

[1888] *សូមមើល* កថាខណ្ឌ ៣៤២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1889] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/260 អ.៣៦-៣៧។ ជើងទំព័រ ១១៨២ នៃដីកាសន្និដ្ឋានស្តាពរ។

[1890] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/260 អ.៣៨។

[1891] *សូមមើល* កថាខណ្ឌ ១៩២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1892] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 អ.១១៦។ ជើងទំព័រ ១១៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1893] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 អ.១១៦។

[1894] កថាខណ្ឌ ៣៥០, ៣៥២ នៃដីកាសន្និដ្ឋានស្តាពរ។

អះអាងដែលថា មាស មុត បានដឹងអំពីអត្តិភាពរបស់មន្ទីរ ស-២១ បានអានចម្លើយសារភាពរបស់មន្ទីរ ស-២១ ទៅឱ្យកម្មាភិបាលស្តាប់ ព្រមទាំងបានអនុម័ត និង បានចូលរួមយ៉ាងសកម្មក្នុងការផ្ទេរមនុស្សទៅកាន់មន្ទីរ ស-២១[1895]។ *សូមមើល* ផ្នែកទី IV.C.11 សម្រាប់ការលើកឡើងអំពីកង្វះការទទួលខុសត្រូវរបស់ មាស មុត លើមន្ទីរ ស-២១ និង អ្នកដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរនេះ។ ភ័ស្តុតាងក្នុងសំណុំរឿងនេះ ដែល ស.ព.អ. ដកស្រង់[1896] បង្ហាញថា អគ្គសេនាធិការបានបញ្ជាឱ្យចាប់ខ្លួន នង អាន មិនមែន មាស មុត ជាអ្នកបញ្ជានោះទេ។ អគ្គសេនាធិការបានហៅ នង អាន ឱ្យទៅធ្វើការនៅទីក្រុងភ្នំពេញ ហើយក្រោយមកបានសម្រេចចាប់ខ្លួន និង បញ្ជូនគាត់ទៅកាន់មន្ទីរ ស-២១[1897]។

៥២៤. ស.ព.អ. ដកស្រង់សាក្សីមួយចំនួន ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា មាស មុត បានបញ្ជាឱ្យចាប់ខ្លួន និង ដកហូតអាវុធរបស់អតីតមេដឹកនាំកងវរសេនាតូចលេខ ៣៨៦ និង កម្មាភិបាលផ្សេងទៀត[1898]។ ក្នុងចំណោមសាក្សីដែលបានដកស្រង់ មានតែសាក្សីចំនួនបួននាក់ប៉ុណ្ណោះ ដែលបានអះអាងថា មាស មុត បានបញ្ជា ឬ អនុវត្តការចាប់ខ្លួន និង ការដកហូតអាវុធ[1899]។ សាក្សីទាំងនេះមិនអាចឱ្យជឿជាក់បានឡើយ។

[1895] ជើងទំព័រ ១២១៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1896] កថាខណ្ឌ ៣៥០ ជើងទំព័រ ១២១៩-២១, ១២២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[1897] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/277.2 នៅម៉ោង 11.07.31-11.10.23 (ឌុច បានផ្តល់សក្ខីកម្មថា បក្សចាប់អារម្មណ៍សង្ស័យ នង អាន ដូច្នេះក៏ដកគាត់ចេញពីកងពល ១៦៤ យកមកទុកតាមដាននៅសេនាធិការ នៅភ្នំពេញ) នៅម៉ោង 11.15.28-11.19.32 (ឆ្លើយថា បក្សបានដាក់ នង អាន ទុកតាមដាន)។ *សូមមើល* ជើងទំព័រ ១២២៤ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ចំណារនៅលើចម្លើយសារភាព ស-២១ របស់ ជ័យ សួន ហៅ នង សួន ហៅ សែន ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ D4.1.26 KH 00006320-00006321 (អ្នកសួរចម្លើយ និយាយថា "គណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្សជាអ្នកសម្រេចលើការឃុំខ្លួនរបស់អ្នក")។

[1898] ជើងទំព័រ ១២២២-២៣, ១២៣០-៣២ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១០៨ ជើងទំព័រ ៣១៧, កថាខណ្ឌ ១១៣ ជើងទំព័រ ៣៣០-៣២។

[1899] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 អ.៥, អ.១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/282 អ.១១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/103 អ.៧-៨។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/32 អ.៩០-៩៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 អ.៦០-៦២។

៥២៥. **ស៊ិន សុត**៖ ស៊ិន សុត មិនអាចជឿជាក់បានឡើយ[1900]។ គាត់បានអះអាងថា មនុស្សរបស់ មាស មុត បានចាប់ខ្លួនទាហានរបស់តំបន់ ៣៧[1901] ប៉ុន្តែមិនបានដឹងថា តើពួកគេគឺជាអ្នកណាឡើយ[1902]។ ការអះអាងរបស់គាត់ដែលថា មាស មុត បានបញ្ជាឱ្យចាប់ខ្លួនទាហានរបស់តំបន់ ៣៧ មានមូលដ្ឋានលើការទាយស្មាន[1903]។

៥២៦. **ឯក នី**៖ ឯក នី មិនអាចជឿជាក់បានឡើយ[1904]។ គាត់បានអះអាងថា មាស មុត បានចាប់ខ្លួន នង ឆាន ហើយយកគាត់ទៅសម្លាប់នៅជើងឯក[1905] និងថា កងពិសេសរបស់គាត់ បានចាប់ខ្លួនជនក្បត់[1906]។ ឯក នី ផ្អែកចម្លើយរបស់គាត់លើកិច្ចប្រជុំដែល មាស មុត បានធ្វើការប្រកាសថា នង ឆាន និង អ្នកផ្សេងទៀតគឺជាជនក្បត់[1907]។ ការប្រកាសនៅក្នុងកិច្ចប្រជុំ មិនមានន័យថា មាស មុត គឺជាអ្នកដែលបានបញ្ជាឱ្យចាប់ខ្លួននោះទេ។

៥២៧. **ម៉ូល ឈិន និង សេង ស៊ីន**៖ ម៉ូល ឈិន[1908] និង សេង ស៊ីន[1909] មិនអាចជឿជាក់បានឡើយ។ ម៉ូល ឈិន បានអះអាងថា មាស មុត បានចេញបញ្ជាឱ្យរំសាយកងរបស់គាត់ ប៉ុន្តែគាត់មិនបានចូលរួមក្នុងកិច្ចប្រជុំដែលត្រូវបានអះអាងថាបានរៀបចំដោយ មាស មុត ឡើយ[1910]។ សេង ស៊ីន

[1900] *សូមមើល* កថាខណ្ឌ ៣៤២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1901] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ឆ.១៧។ ជើងទំព័រ ១២២២, ៣១៧, ៣៣១-៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[1902] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ឆ.៦៩។

[1903] *សូមមើល* កថាខណ្ឌ ៣៤២ *ខាងលើ*។

[1904] *សូមមើល* កថាខណ្ឌ ២៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1905] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/282 ឆ.១១។ ជើងទំព័រ ៣៣០ នៃដីកាសន្និដ្ឋានស្តាពរ។

[1906] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.១៤។ ជើងទំព័រ ១២២៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1907] *សូមមើលខគ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/103 ឆ.៧-៨។ ជើងទំព័រ ៣៣២, ១២២៣,១២៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[1908] *សូមមើល* កថាខណ្ឌ ៣៦១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1909] *សូមមើល* កថាខណ្ឌ ៤៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1910] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឆ.៩០-៩៣។ ជើងទំព័រ ១២៣០, ១២៣២ នៃដីកាសន្និដ្ឋានស្តាពរ។

បានអះអាងថា មាស មុត បានអានចម្លើយសារភាពរបស់ នង ឆាន នៅឯកិច្ចប្រជុំមួយ ហើយក្រោយមកបានបញ្ជូនទាហានឱ្យទៅធ្វើការនៅតាមកងផលិត[1911]។

iii. អតីតទាហានភូមិភាគបូព៌ា

៥២៨. ស.ព.អ. អះអាងថា នៅដើមឆ្នាំ ១៩៧៧ មាស មុត បានអនុម័តឱ្យមានការចាប់ខ្លួនអនុប្រធានរបស់គាត់ឈ្មោះ ឌឹម ដែលមកពីភូមិភាគបូព៌ា[1912]។ ស.ព.អ. ដកស្រង់តែសក្ខីកម្មរបស់ ឌុច អំពីដំណើរការទូទៅ ដែលតាមរយៈនេះ សុន សេន ត្រូវបានអះអាងថា បានចាត់ការលើការចាប់ខ្លួន និង បានទាក់ទងជាមួយមេបញ្ជាការកងពលធំនានា[1913]។ ឌុច មិនអាចឱ្យជឿជាក់បានទេ[1914]។ ស.ព.អ. ក៏ដកស្រង់ផងដែរនូវចម្លើយសារភាពចំនួនពីរដែលមានចំណារ សម្រាប់អះអាងថា មាស មុត បានទទួលចម្លើយសារភាពរបស់ ឌឹម នៅមន្ទីរ ស-២១ និង បានពិភាក្សាពីចម្លើយសារភាពនេះជាមួយ សុន សេន[1915]។ មិនមានភ័ស្តុតាងគ្រប់គ្រាន់នោះទេដែលបង្ហាញថា សុន សេន បានចារនៅលើចម្លើយសារភាពចំនួនមួយនោះ។ ចំណារទាំងពីរ គឺជាការឆ្លើយឆ្លងតែពីភាគីម្ខាង[1916]។ ចំណារដែលលើកឡើងថា មាស មុត នឹងត្រូវបានអញ្ជើញឱ្យមកពិភាក្សាអំពីចម្លើយសារភាពមួយ ឬ គួរត្រូវបានទាក់ទងអំពីចម្លើយសារភាពមួយនោះ មិនមានន័យថា មាស មុត ត្រូវបានទាក់ទង ហើយពិតជាបានពិភាក្សាអំពីចម្លើយសារភាពនោះឡើយ។

៥២៩. ស.ព.អ. អះអាងថា ក្រោយការចាប់ខ្លួន និង ការសួរចម្លើយរបស់ ឌឹម មាស មុត បានបញ្ជាឱ្យបោសសម្អាតកម្មាភិបាល និង ទាហានចំនួនពី ៧០០ ទៅ ១០០០ នាក់ នៅក្នុងកងពលធំលេខ ១៦៥[1917]។ ស.ព.អ. ដកស្រង់ដោយខុសច្បាប់ នូវខ្លឹមសារនៃចម្លើយសារភាពរបស់ ឌឹម ដើម្បី

[1911] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 ឆ.៦០-៦២។ ជើងទំព័រ ១២៣០ នៃដីកាសន្និដ្ឋានស្តាពរ។

[1912] កថាខណ្ឌ ៣៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1913] ជើងទំព័រ ១២៤៩-៥០ នៃដីកាសន្និដ្ឋានស្តាពរ។

[1914] *សូមមើល* កថាខណ្ឌ ១៧៥-៧៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1915] កថាខណ្ឌ ៣៥៩ ជើងទំព័រ ១២៥៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1916] *សូមមើល* កថាខណ្ឌ ៥១១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែម។

[1917] កថាខណ្ឌ ៣៦០ នៃដីកាសន្និដ្ឋានស្តាពរ។

ចោទប្រកាន់ចំពោះសកម្មភាពដែលធ្វើឡើងដោយ មាស មុត ជាការឆ្លើយតប[1918]។ សាក្សីដែល ស.ព.អ. ដកស្រង់ អះអាងថា មាស មុត បានប្រកាសនៅក្នុងកិច្ចប្រជុំមួយថា ទាហានភូមិភាគបូព៌ា គឺជាសមាសភាពមិនល្អ ដែលត្រូវដកចេញ ហើយបញ្ជូនទៅឱ្យបណ្តុះបណ្តាល និងថា ទាហានភូមិភាគបូព៌ា ត្រូវបានដកចេញ ឬ ចាប់ខ្លួន បញ្ជូនឱ្យទៅធ្វើការនៅតាមកងនានា ឬ បានបាត់ខ្លួន[1919]។ គ្មានសាក្សីណាម្នាក់បាននិយាយថា មាស មុត *បានបញ្ជា* ឱ្យដកកងទ័ពភូមិភាគបូព៌ានោះទេ។ ការណ៍ដែលមនុស្សម្នាក់បានបាត់ខ្លួន មិនមានន័យថា អ្នកនោះត្រូវបានចាប់ខ្លួន ឬ សម្លាប់ឡើយ។ ដូចដែល ប៊ាង រ៉ែត បានកត់សម្គាល់ដូច្នេះដែរ ការប្រើប្រាស់ ឌុច ធ្វើជាឧទាហរណ៍ ដោយគ្រាន់តែដោយសារមាននរណាម្នាក់បានបាត់ខ្លួន មិនមានន័យថា គាត់នោះត្រូវបានចាប់ខ្លួន និង សម្លាប់ឡើយ។ គាត់អាចត្រូវបានផ្ទេរទៅកាន់មុខដំណែងមួយផ្សេងទៀតក៏ថាបាន[1920]។

៥៣០. ប៉ាក សុខ គឺជាសាក្សីតែម្នាក់គត់ដែលបាននិយាយថា ទាហានភូមិភាគបូព៌ាត្រូវបានយកទៅសម្លាប់ចោល[1921]។ គាត់មិនអាចឱ្យជឿជាក់បានទេ[1922] ហើយបានឆ្លើយផ្ទុយនឹងចម្លើយខ្លួនឯង។ ទៅកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់បានអះអាងថា ទាហានភូមិភាគបូព៌ាត្រូវបានយកទៅសម្លាប់ចោលនៅជិតចំណោតវាម[1923]។ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង គាត់បានអះអាងថា គាត់មិនបានដឹងអំពីទីកន្លែងដែលពួកគេត្រូវបានបញ្ជូនទៅទេ[1924]។

៥៣១. ស.ព.អ. អះអាងថា មាស មុត បានបោសសម្អាតមេបញ្ជាការតំបន់ ៣៧ និង ភូមិភាគបូព៌ា ដើម្បីបង្រួបបង្រួមសិទ្ធិ និង អំណាចរបស់គាត់ និង បានប្រឈមនឹងហានិភ័យតិចតួចទាក់ទងនឹងការឆ្លើយដាក់របស់មេបញ្ជាការនានា ពីព្រោះពួកគេមិនមែនជាបណ្តាញរបស់គាត់[1925]។ ស.ព.អ. មិន

[1918] *សូមមើល* កថាខណ្ឌ ១៥៦-៦៤ *ខាងលើ* ទាក់ទងនឹងការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម សម្រាប់គោលបំណងនេះ។

[1919] ជើងទំព័រ ១២៦២-៦៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1920] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/288 ន.៦៣, ន.៦៥។

[1921] ជើងទំព័រ ១២៦២, ១២៦៨ នៃដីកាសន្និដ្ឋានស្តាពរ។

[1922] *សូមមើល* កថាខណ្ឌ ២៣៣-៣៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1923] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D59/2/3.14a EN 01185002 KH 00958291។

[1924] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ D114/297.1.20 នៅម៉ោង 14.24.11-14.26.40។

[1925] កថាខណ្ឌ ៣៤៨ នៃដីកាសន្និដ្ឋានស្តាពរ។

បានដកស្រង់ភ័ស្តុតាងណាមួយ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ឡើយ។ ការអះអាងទាំងនេះមិនមានមូលដ្ឋានគាំទ្រទាល់តែសោះ។ មិនត្រូវយកការអះអាងទាំងនេះមកពិចារណានោះទេ។

iv. ទាហានដែលមានការពាក់ព័ន្ធនឹងរបប លន់ នល់

៥៣២. ស.ព.អ. អះអាងថា មាស មុត បានអនុវត្តតាមគោលនយោបាយបក្ស និង បានព្យាយាមកំណត់អត្តសញ្ញាណ និង បោសសម្អាតទាហានដែលមានចំណងទាក់ទងទៅនឹងរបប លន់ នល់[1926]។ សាក្សីដែលត្រូវបានដកស្រង់ បញ្ជាក់ថា សកម្មភាពណាមួយដែលកងពលធំលេខ ១៦៥ អាចធ្វើឡើងប្រឆាំងនឹងទាហានទាំងនេះ គឺការរឿងទូទៅនៅក្នុងកងពលធំមជ្ឈិមទាំងអស់ និង ត្រូវបានធ្វើឡើងទៅតាមការណែនាំរបស់មជ្ឈិមបក្ស[1927]។ ស.ព.អ. ដកស្រង់ អ៊ូ ដាវ នៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីភ្ជាប់ មាស មុត ទៅនឹងគោលនយោបាយបក្សស្តីពី លន់ នល់[1928]។

៥៣៣. **អ៊ូ ដាវ៖** អ៊ូ ដាវ មិនអាចជឿជាក់បានឡើយ[1929]។ គាត់បានប្រាប់រឿងរ៉ាវទៅកាន់ក្រុមអ្នកស៊ើបអង្កេត ក.ស.ច.ស. និង អង្គជំនុំជម្រះសាលាដំបូង អំពីឧប្បត្តិហេតុមួយដែលកើតឡើងនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ នៅព្រលានយន្តហោះពោធិ៍ចិនតុង ដែលនៅក្នុងឧប្បត្តិហេតុនោះ តាម៉ុក មាស មុត និង ស៊ូ ម៉ែត បានរៀបចំការចាប់ខ្លួន និង សម្លាប់ទាហាន និង អ្នកបើកបរយន្តហោះរបស់ លន់ នល់[1930]។ គាត់បានផ្តល់ចម្លើយផ្ទុយគ្នាអំពីព្រឹត្តិការណ៍នេះ។ ទីមួយ គាត់បាននិយាយថា តាម៉ុក ស៊ូ ម៉ែត និង មាស មុត បានមកដល់នៅម៉ោង ៩ ព្រឹក[1931] ហើយទាហាន និង អ្នកបើកយន្ត

[1926] កថាខណ្ឌ ៣៥៤-៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1927] ជើងទំព័រ ១១៨៧-៨៩ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលខគ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន សំអូន ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/198 អ.៥៤-៥៥ (ពិន សំអូន កងពល ៣១០ បានចូលរួមការប្រជុំនៅស្តាតអូឡាំពិក ដែលក្នុងនោះ សុន សេន បានថ្លែងថា ទំពឱ្យតែមានសមាជិកគ្រួសារជាប់និន្នាការជាអ្នករដ្ឋការលន់ នល់ អាចត្រូវបានដកទុកមួយកន្លែងផ្សេង ពីព្រោះពួកនេះអាចមានការសើរើ)។

[1928] ជើងទំព័រ ១១៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1929] *សូមមើល* កថាខណ្ឌ ៣៥៥ និង ៥០៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1930] ជើងទំព័រ ១១៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1931] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 អ.៣០។

ហោះត្រូវបានយកចេញទៅនៅម៉ោងប្រហែល ១០ ព្រឹក ឬ នៅពេលថ្ងៃត្រង់[1932]។ គាត់បាននិយាយថា តាម៉ុក ទទួលខុសត្រូវរួម[1933] ហើយបានប្រាប់ទាហាន និង អ្នកបើកបរយន្តហោះ លន់ នល់ ឱ្យឡើងឡាន[1934]។ គាត់បានថ្លែងថា តាម៉ុក បាននិយាយថា ទាហាន និង អ្នកបើកបរយន្តហោះទាំងនោះ ត្រូវបានយកទៅកម្ទេចចោល[1935]។ នៅពេលដែលគាត់បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងពីរឆ្នាំក្រោយមក គាត់មិនអាចនឹកឃើញពីការផ្តល់ចម្លើយនេះបានទេ[1936]។ នៅក្នុងការស្តាប់ចម្លើយរបស់ ក.ស.ច.ស. ដូចគ្នានេះដែរ នៅពេលនោះគាត់បាននិយាយថា ស៊ូ ម៉ែត និង មាស មុត បានមកដល់នៅម៉ោង ៩ ព្រឹក តាម៉ុក បានមកដល់នាពេលក្រោយមក ហើយ ស៊ូ ម៉ែត និង មាស មុត បានទទួលខុសត្រូវក្នុងការបញ្ជូនផ្តាល់[1937]។ នៅក្នុងការស្តាប់ចម្លើយមួយនាពេលក្រោយមក អ៊ូ ដាវ ជាថ្មីម្តងទៀតបានផ្លាស់ប្តូររឿងរ៉ាវរបស់គាត់។ គាត់បាននិយាយថា នៅពេលគាត់បានមកដល់ព្រលានយន្តហោះ គាត់បានឃើញ មាស មុត ហើយបន្ទាប់មកឃើញ ស៊ូ ម៉ែត និង តាម៉ុក ចូលមក[1938]។ រយៈពេលតិចជាងប្រាំមួយខែក្រោយមក នៅក្នុងការស្តាប់ចម្លើយក្នុងរឿងក្តី ០០៤ អ៊ូ ដាវ បាននិយាយថា គាត់បានឃើញ តាម៉ុក *តែម្តងទេគឺនៅឆ្នាំ ១៩៧៧* នៅពេលដែលគាត់នៅក្នុងទីក្រុងភ្នំពេញ ក្នុងរយៈពេលពីរថ្ងៃមុនពេលធ្វើដំណើរទៅកាន់ភូមិភាគបូព៌ា[1939]។

[1932] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.៣១។

[1933] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.២៤-២៥។

[1934] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.៣០។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D234/2.1.138 នៅម៉ោង 15.35.57-15.39.06។

[1935] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.៣៤-៣៥។

[1936] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D234/2.1.138 នៅម៉ោង 15.35.57-15.42.33។

[1937] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.៤០។ *សូមមើលផងដែរ ដូចខាងលើ* ឆ.៤១។

[1938] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ឆ.៩។

[1939] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D11/340/2 ឆ.៣៦។

គាត់មិនបាននិយាយពីការឃើញ តាម៉ុក នៅព្រលានយន្តហោះពោធិ៍ចិនតុងនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ នោះឡើយ។

៥៣៤. ក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខ ក.ច.ស.ច. លើកចុងក្រោយ មន្ត្រីច្បាប់បានកត់សម្គាល់ឃើញចម្លើយផ្ទុយគ្នាមិនពាក់ព័ន្ធមួយនៅក្នុងចម្លើយរបស់ អ៊ូ ដាវ។ គាត់បានរៀបរាប់រឿងផ្សេងគ្នាចំនួនពីរអំពីការស្លាប់មិត្តភក្តិរបស់គាត់ឈ្មោះ ចាន់ថា[1940]។ អ៊ូ ដាវ បាននិយាយថា គាត់មិនបានចាំរឿងទីមួយរបស់គាត់ទេ[1941]។ ក្រោយមក គាត់បាននិយាយថា រឿងរ៉ាវពិតអំពី ចាន់ថា គឺជាអ្វីដែលគាត់បាននិយាយក្នុងពេលថ្មីៗបំផុតនេះជាមួយ ក.ស.ច.ស.[1942] ដែលបង្ហាញថា រឿងទីមួយរបស់គាត់ គឺជារឿងមិនពិត។

v. ទាហានដែលមានការជាប់ពាក់ព័ន្ធជាមួយបរទេស

៥៣៥. ស.ព.អ. អះអាងថា មាស មុត បានគាំទ្រ និង អនុវត្តគោលនយោបាយរបស់ ប.ក.ក. ដើម្បីបោសសម្អាតសត្រូវផ្ទៃក្នុងដែលមានជាប់ពាក់ព័ន្ធជាមួយបរទេស ឬ ដែលត្រូវបានចោទប្រកាន់ថាបម្រើឱ្យប្រយោជន៍បរទេស[1943] តាមរយៈការហៅវៀតណាមថាជា “សត្រូវស្នូរពូជ” ឬ “ខ្មាំងទីមួយ” សត្រូវផ្ទៃក្នុងជា “ខ្មាំងទីពីរ” និង ការកម្ទេចនរណាម្នាក់ដែលបានបដិសេធមិនអនុវត្តតាមបញ្ជា ឬ បដិសេធមិនសម្លាប់ជនជាតិវៀតណាម[1944]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចឱ្យជឿជាក់បានរបស់ ប៉ាក សុខ[1945]។ គាត់មិនអើពើនឹងភស្តុតាងបរិបទ និង ផ្ទុយគ្នាដែលពាក់ព័ន្ធនោះឡើយ។

[1940] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ស.៥៣។

[1941] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 អ.៥៣។

[1942] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 អ.៥៤ (កិច្ចសម្ភាសន៍នេះធ្វើឡើងក្នុងរយៈពេលពីរថ្ងៃ)។

[1943] កថាខណ្ឌ ៣៦១-៦២ នៃដីកាសន្និដ្ឋានស្តាពរ។

[1944] កថាខណ្ឌ ៣៦៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1945] ជើងទំព័រ ១២៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

៥៣៦. ជំហរចំពោះប្រទេសវៀតណាមនេះ បានកើតចេញពីមជ្ឈិមបក្ស និង ភាពភ័យខ្លាចជាប្រវត្តិសាស្ត្រ របស់កម្ពុជាអំពីការឈ្លានពានរបស់វៀតណាម[1946]។ ការថ្លែងការណ៍នៅក្នុងកិច្ចប្រជុំរបស់កងពល ធំលេខ ១៦៥ អំពីវៀតណាម ឬ ខ្មាំងផ្សេងទៀត ត្រូវការចាំបាច់ដោយមជ្ឈិមបក្ស ដែលជាផ្នែក មួយនៃករណីយកិច្ចផ្សព្វផ្សាយមាគ៌ានយោបាយ[1947]។

៥៣៧. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[1948]។ គាត់បានអះអាងថា គាត់ត្រូវបានណែនាំឱ្យ សម្លាប់ជនជាតិវៀតណាមទាំងអស់ រួមទាំងទារកផងដែរ[1949]។ សាក្សីផ្សេងទៀត មិនបានទទួល ការណែនាំបែបនេះទេ ប៉ុន្តែត្រូវបានណែនាំឱ្យបាញ់ ឬ ចាប់ទុក ឬ ប្រជាជនវៀតណាម តែនៅ ពេលណាដែលពួកគេបានបាញ់ប្រហារ និង ប្រសិនបើពួកគេមិនមែនជាជនភៀសខ្លួនប៉ុណ្ណោះ[1950]។ ប៉ាក សុខ ក៏បានទទួលការណែនាំបែបនេះដែរ[1951]។ ផ្ទុយទៅនឹងការអះអាងរបស់ ស.ព.អ. ការ ខកខានមិនអនុវត្តតាមបទបញ្ជា មិនមែនមានន័យជាស្វ័យប្រវត្តិថាជាការសម្លាប់នោះទេ[1952]។ វា អាចមានន័យថាត្រូវបានបញ្ជូនទៅរៀនសូត្រ ឬ កសាងជាដើម[1953]។

[1946] *សូមមើល* កថាខណ្ឌ ៥៥២ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែម។

[1947] មាត្រា ២ នៃលក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ *សូមមើល* កថាខណ្ឌ ២១១, ២១៣ និង ២៨៩ *ខាងលើ* ទាក់ទងនឹងគណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការ ធ្វើការផ្សព្វផ្សាយមាគ៌ា និង សេចក្តីណែនាំរបស់ បក្ស ដល់ថ្នាក់ក្រោម។

[1948] *សូមមើល* កថាខណ្ឌ ២៣៣-៣៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1949] ជើងទំព័រ ១២៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1950] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 09.24.31-09.29.59, 09.35.02-09.38.23, 09.45.46, 09.47.55-09.54.22។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ឆ.១៣៩-១៤១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៧៥។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.92 នៅម៉ោង 10.46.11-10.51.25, 10.54.04។

[1951] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.54.39-10.58.13។

[1952] *សូមមើល* កថាខណ្ឌ ៣៦៣ ជើងទំព័រ ១២៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1953] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.១១៦ ដែលដកស្រង់នៅក្នុងជើងទំព័រ ១២៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

៥៣៨. ស.ព.អ. អះអាងថា មនុស្សត្រូវបានសួរចម្លើយ ក្នុងគោលបំណងឱ្យមានការបញ្ជាក់ថា ពួកគេគឺជាភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ ឬ ភ្នាក់ងារវៀតណាម ឬ ការកំណត់អត្តសញ្ញាណបុគ្គលផ្សេងៗទៀត ដែលជា "គោលបំណងរបស់មន្ទីរ ស-២១ និង ក្តីកង្វល់របស់មេដឹកនាំរបស់ ប.ក.ក. និង កងទ័ពបដិវត្តន៍កម្ពុជា"[1954]។ ស.ព.អ. មិនអើពើនឹងភ័ស្តុតាងបរិបទដែលពាក់ព័ន្ធ។ មេដឹកនាំរបស់ ប.ក.ក. និង កងទ័ពបដិវត្តន៍កម្ពុជា[1955] បានបញ្ជាក់គោលបំណងនៅពីក្រោយ និង មធ្យោបាយកំណត់ទីតាំងខ្មាំង។ ការស្រាវជ្រាវស្វែងរកការចាប់ខ្លួន និង ការសួរចម្លើយមនុស្សដែលត្រូវបានយល់ឃើញថាមានការជាប់ពាក់ព័ន្ធជាមួយរបបបរទេស មិនមែនជាគោលនយោបាយ ឬ ផែនការដែលត្រូវបានបង្កើតឡើងដោយឯករាជ្យនៅក្នុងកងពលធំ ១៦៥ នោះទេ។ វាកើតចេញពីមជ្ឈិមបក្ស[1956]។ អ្នកនៅក្រោមបង្គាប់របស់មជ្ឈិមបក្ស រួមទាំង មាស មុត ផងដែរនោះ តម្រូវឱ្យអនុវត្តតាមគោលនយោបាយ បើមិនដូច្នេះទេនឹងប្រឈមនឹងការបោសសម្អាត និង ការស្លាប់ខ្លួនឯង[1957]។

vi. អ្នកដែលត្រូវបានគេយល់ឃើញថាជាជនក្បត់ និង បណ្តាញរបស់ពួកគេ

៥៣៩. ស.ព.អ. អះអាងថា មាស មុត បានទទួលខុសត្រូវលើការសម្រិតសម្រាំង ការចាប់ខ្លួន និង ការផ្ទេរយោធារបស់កងពលធំ ១៦៥ ដែលត្រូវបានគេយល់ឃើញថាជាខ្មាំងផ្ទៃក្នុង ដែលត្រូវសួរចម្លើយដោយប្រើទារុណកម្មនៅវត្តឥន្ទញ្ជាណ ទឹកសាប និង មន្ទីរ ស-២១ និង ការបោសសម្អាតបណ្តាញរបស់ពួកគេ[1958]។ ស.ព.អ. មិនបានបង្ហាញភ័ស្តុតាងគាំទ្រដល់ការអះអាងរបស់គាត់។ *សូមមើល* ផ្នែក IV.C.5 និង IV.C.11 *ខាងលើ* សម្រាប់ការលើកឡើងទាក់ទងនឹងកង្វះការទទួលខុសត្រូវរបស់ មាស មុត លើទីតាំងទាំងនេះ និង មនុស្សដែលត្រូវបានបញ្ជូនទៅកាន់ទីតាំងទាំងនេះ។

[1954] កថាខណ្ឌ ៣៦៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1955] *សូមមើល* កថាខណ្ឌ ១៦៩-៧២ *ខាងលើ* ទាក់ទងនឹងតួនាទីជាន់ខ្ពស់នៅក្នុងបក្ស និង សិទ្ធិអំណាចលើ ក.ប.ក. របស់ប៉ុល ពត តា ម៉ុក និង សុន សេន។

[1956] *សូមមើលឧទា.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195348-00195349 KH 00052396-00052397។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26 EN 00933838-00933841 KH 00052306-00052309។

[1957] *សូមមើល* កថាខណ្ឌ ២១១, ២៨៨, ៣០៣-០៤ *ខាងលើ*។ កថាខណ្ឌ ៤០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[1958] កថាខណ្ឌ ៣៤៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១១៨។

៥៤០. ស.ព.អ. អះអាងថា យ៉ាងហោចណាស់កម្លាភិបាលរបស់កងពលធំលេខ ១៦៥ ចំនួន ៦៧ នាក់ ត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១[1959]។ គ្មានសាក្សីណាម្នាក់ ឬ ឯកសារណាមួយដែលគាត់ដកស្រង់ទាក់ទងនឹងកម្លាភិបាលរបស់កងពលធំលេខ ១៦៥ ជាក់លាក់ណាម្នាក់[1960] បង្ហាញថា មាស មុត បានសម្រេចចាប់ខ្លួន ឃុំឃាំង ឬ បញ្ជូនពួកគេទៅកាន់មន្ទីរ ស-២១ ឬ មន្ទីរសន្តិសុខមួយផ្សេងទៀតនោះទេ។ ការអានចម្លើយសារភាព ឬ ឈ្មោះរបស់ជនក្បត់នៅក្នុងកិច្ចប្រជុំ[1961] មិនមានន័យដូចគ្នានឹងការអនុម័ត ឬ ការអនុវត្តការចាប់ខ្លួន ការឃុំឃាំង ឬ ការសម្លាប់ពួកគេឡើយ។

៥៤១. សាក្សីម្នាក់ឈ្មោះ សំ ភីន បានអះអាងថា មាស មុត បានបញ្ជាឱ្យគេចាប់ខ្លួនគាត់[1962]។ សំ ភីន មិនអាចជឿជាក់បានទេ[1963]។ គាត់បានអះអាងថា មាស មុត បានចាប់ខ្លួនគាត់នៅចុងឆ្នាំ ១៩៧៧ ឬ ដើមឆ្នាំ ១៩៧៨[1964]។ គាត់បាននិយាយថា គេបានប្រគល់សំបុត្រឱ្យគាត់មួយច្បាប់ ចាត់តាំងគាត់ឱ្យទៅធ្វើការនៅទីតាំងការងារថ្មីមួយ[1965]។ គាត់មិនបានដឹងនោះទេថា តើអ្នកណាជាអ្នកចុះហត្ថលេខាលើសំបុត្រនេះ[1966]។ គាត់ត្រូវបានគេយកទៅកាន់មន្ទីរ ក-៧ ក្នុងទីក្រុងភ្នំពេញ ជាទីដែល ខៀវ សំផន បាននិយាយថា កំហុសមួយត្រូវបានធ្វើឡើង ហើយបានបញ្ជូនគាត់ឱ្យវិលត្រលប់ទៅកំពង់សោមវិញ[1967]។ សំ ភីន បានជឿជាក់ថា មាស មុត បានចាប់ខ្លួនគាត់ ពីព្រោះអ្នកបើកបរដែលមកយកគាត់ គឺមកពីកន្លែងរបស់ មាស មុត[1968]។ គាត់បាននិយាយថា នៅឆ្នាំ ១៩៨០ មាស មុត បាននិយាយលេងថា គាត់បានបញ្ជូន សំ ភីន ទៅកាន់ទីតាំងការងារថ្មីមួយ ប៉ុន្តែមិនបានដឹងនោះទេថា តើហេតុអ្វីបានជា សំ ភីន ត្រូវបានគេប្រព្រឹត្តមកលើគាត់យ៉ាងដូច្នេះ[1969]។ ការអះអាង

[1959] កថាខណ្ឌ ៣៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[1960] ដើងទំព័រ ១២០១-០៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1961] *សូមមើលខគ.* កថាខណ្ឌ ២៥២ នៃដីកាសន្និដ្ឋានស្តាពរ ទាក់ទងនឹងការចោទប្រកាន់ដែលថា មាស មុត បានប្រកាសពីការចាប់ខ្លួនជនក្បត់។

[1962] *សូមមើលខគ.* កថាខណ្ឌ ២៥២ នៃដីកាសន្និដ្ឋានស្តាពរ ទាក់ទងនឹងការអះអាងដែលថា មាស មុត បានប្រកាសពីការចាប់ខ្លួនជនក្បត់។

[1963] *សូមមើល* កថាខណ្ឌ ៤១២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[1964] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/111 ឆ.១៧។

[1965] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/111 ឆ.១៧។

[1966] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/111 ឆ.១៨។

[1967] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/111 ឆ.១៧។

[1968] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/111 ឆ.១៨។

[1969] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/111 ឆ.២៣-២៤។

របស់ សំ ភីន បង្ហាញថា យ៉ាងច្រើនណាស់ មាស មុត បានបញ្ជូន សំ ភីន ឱ្យទៅធ្វើការនៅកន្លែងផ្សេងមួយទៀតតែប៉ុណ្ណោះ។

៥៤២. ស.ព.អ. ដកស្រង់ចម្លើយមួយ ដែលត្រូវបានអះអាងថា មាស មុត បានធ្វើឡើងនៅក្នុងអំឡុងបទសម្ភាសន៍ជាមួយវិទ្យុ *សំឡេងសហរដ្ឋអាមេរិក* ដែលនៅក្នុងបទសម្ភាសន៍នោះ គាត់បាននិយាយថា ទាហានខ្លះមកពីកងរបស់គាត់ អាចត្រូវបានគេបញ្ជូនទៅកាន់មន្ទីរ ស-២១ ពីព្រោះអគ្គសេនាធិការបានកោះហៅមនុស្សឱ្យទៅទទួលការបណ្តុះបណ្តាល ហើយក្រោយមកបានប្រាប់កងរបស់គាត់វិញថា មនុស្សមួយចំនួននឹងមិនវិលត្រលប់មកវិញនោះទេ[1970]។ បទសម្ភាសន៍នេះ ត្រូវបានធ្វើឡើងដោយស្ថាប័នខាងក្រៅមួយ ដែលគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ សម្រាប់គោលបំណងផ្សេងក្រៅពីការជំនុំជម្រះព្រហ្មទណ្ឌ។ វាមានតម្លៃជាភស្តុតាងតិចតួចណាស់[1971]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភស្តុតាងដល់បទសម្ភាសន៍នេះ ស.ច.ស. ត្រូវពិចារណាថា ចម្លើយរបស់ មាស មុត បង្ហាញថា អគ្គសេនាធិការមានសិទ្ធិអំណាចលើអ្នកដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១[1972]។

vii. អ្នករត់ចោលជួរ និង អ្នកផ្តាច់ខ្លួន

៥៤៣. ស.ព.អ. អះអាងថា អ្នករត់ចោលជួរ ឬ អ្នកផ្តាច់ខ្លួន ជាទៀងទាត់ត្រូវបានចាប់ខ្លួនដោយមនុស្សរបស់ មាស មុត ហើយត្រូវបានសម្លាប់ចោល[1973]។ គាត់ដកស្រង់របាយការណ៍ស្ថិតិរបស់កងទ័ពបដិវត្តន៍កម្ពុជាដែលមិនមានមូលដ្ឋានគាំទ្រ កំណត់ហេតុកិច្ចប្រជុំរបស់អគ្គសេនាធិការនៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ និង សារទូរលេខ[1974]។ របាយការណ៍ស្ថិតិនានា ចុះបញ្ជីចំនួនកងទ័ព ដែល “បានរត់គេចខ្លួន” ឬ “បានរត់ចោលជួរ”។ របាយការណ៍ទាំងនេះ មិនបានបង្ហាញថា ទាហានទាំង

[1970] សុខ ខេមរា *ជនសង្ស័យរបស់តុលាការយល់ឃើញថា តួនាទីរបស់តុលាការ “មានកម្រិត”* វិទ្យុផ្សាយសំឡេងរបស់សហរដ្ឋអាមេរិក ភាសាខ្មែរ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១១ ឯកសារ D114/307.6 EN 00746176 KH 01380587-01380588។ ជើងទំព័រ ១១៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[1971] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[1972] សុខ ខេមរា *ជនសង្ស័យរបស់តុលាការយល់ឃើញថា តួនាទីរបស់តុលាការ “មានកម្រិត”* វិទ្យុផ្សាយសំឡេងរបស់សហរដ្ឋអាមេរិក ភាសាខ្មែរ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១១ ឯកសារ D114/307.6 EN 00746176 KH 01380587-01380588។

[1973] កថាខណ្ឌ ៣៥៣ នៃដីកាសន្និដ្ឋានស្តាពរ។

[1974] ជើងទំព័រ ១១៨៥ នៃដីកាសន្និដ្ឋានស្តាពរ។

នេះត្រូវបានសម្គាប់ឡើយ[1975]។ កំណត់ហេតុកិច្ចប្រជុំទាក់ទងនឹងយុទ្ធជនចំនួន ៤០ នាក់ ដែលមានផែនការផ្តាច់ខ្លួនពីស្ទឹងហាវ[1976]។ កំណត់ហេតុកិច្ចប្រជុំទាំងនេះ មិនបានបង្ហាញថា ទាហានទាំងនេះត្រូវបានចាប់ខ្លួន ឬ សម្គាប់ចោលឡើយ។ ជំនួសមកវិញ សុន សេន បានស្នើបញ្ជូនពួកគេឱ្យទៅធ្វើការនៅផលិតកម្មស្បៀង[1977]។ សារទូរលេខចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ពី ឌឹម ទាក់ទងនឹងមនុស្សប្រាំនាក់ដែលត្រូវបានចាប់ខ្លួន មិនបង្ហាញថា អ្នកទាំងនោះគឺជាទាហានរបស់កងពលធំលេខ ១៦៥ ដែលរត់ចោលជួរ ឬ ផ្តាច់ខ្លួនពីកងពលធំនេះឡើយ[1978]។

៥៤៤. ស.ព.អ. ក៏ដកស្រង់ផងដែរនូវចម្លើយរបស់សាក្សី ដែលពិពណ៌នាអំពីឧប្បត្តិហេតុដាច់ៗដោយឡែកពីគ្នា ដែលក្នុងនោះទាហានត្រូវបានអះអាងថា បានរត់គេចខ្លួន និង ត្រូវបានសម្គាប់[1979]។ ឧប្បត្តិហេតុដាច់ៗដោយឡែកពីគ្នាទាំងនេះ មិនបង្ហាញពីគោលនយោបាយរបស់មជ្ឈិមបក្ស ឬ របស់កងពលធំលេខ ១៦៥ ឱ្យសម្គាប់អ្នករត់ចោលជួរ ឬ អ្នកផ្តាច់ខ្លួននោះទេ។ ស.ព.អ. ដកស្រង់សាក្សីផ្សេងទៀត ដែលបាននិយាយថា មនុស្សត្រូវបានចាប់ខ្លួន ឬ មាស មុត បានប្រកាសពីការចាប់ខ្លួននៅក្នុងកិច្ចប្រជុំនានា[1980]។ សាក្សីទាំងនេះមិនបាននិយាយថា មាស មុត បានបញ្ជាឱ្យមានការចាប់ខ្លួននោះឡើយ។ កងពលធំលេខ ១៦៥ ស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់មជ្ឈិមបក្ស រួមទាំងទាក់ទងនឹងការចាប់ខ្លួន និង ការបោសសម្អាតផងដែរ[1981]។ មជ្ឈិមបក្ស គឺជាអ្នកសម្រេច

[1975] ស្ថិតិគណៈកម្មាធិការកងពល ១៦៥ សេចក្តីរាយការណ៍ ចំណងជើងថា "បញ្ជីក្តាប់កម្លាំង" ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ១៩៧៦ ឯកសារ D22.2.4 EN 00950655 KH 00160118។ ស្ថិតិគណៈកម្មាធិការកងពល ១៦៥ សេចក្តីរាយការណ៍ ចំណងជើងថា "បញ្ជីក្តាប់កម្លាំង" ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D22.2.5 EN 00950657 KH 00160123។ ស្ថិតិគណៈកម្មាធិការកងពល ១៦៥ សេចក្តីរាយការណ៍ ចំណងជើងថា "បញ្ជីកម្លាំងប្រយុទ្ធ" ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.5.3 EN 00233989 KH 00160145-00160147 (ដូចគ្នានឹងឯកសារ D54/24.2)។

[1976] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657355-00657356 KH 00162489-00162490។

[1977] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657356 KH 00162490។

[1978] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ជូន បងមុត ជ្រាប អំពីសភាពការណ៍ខ្មាំងនៅតាមព្រំដែន" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D4.1.699 (ឯកសារនេះដូចគ្នានឹងឯកសារ D1.3.34.11 ដែលដកស្រង់ជើងចំព័រ ១១៨៥ នៃដីកាសន្និដ្ឋានស្តាពរ)។

[1979] ជើងចំព័រ ១១៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1980] ជើងចំព័រ ៣១៧, ៣៣០-៣៣, ៣៣៩, ៣៤២, ៣៤៦-៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[1981] *សូមមើល* កថាខណ្ឌ ២១១ និង ២៤១ *ខាងលើ* ទាក់ទងនឹងការគ្រប់គ្រងរបស់បក្សលើកងពលមជ្ឈិម និង តំបន់ស្វយ័ត។

ចុងក្រោយលើការចាប់ខ្លួន និង ត្រូវអនុម័តលើការចាប់ខ្លួនកម្មាភិបាលដែលត្រូវបានគេឆ្លើយដាក់មុនពេលដែលបញ្ហាបែបនេះណាមួយអាចត្រូវបានអនុវត្ត[1982]។

៥៤៥. ស.ព.អ. អះអាងថា ការណែនាំឱ្យអនុវត្តតាមគោលនយោបាយបោសសម្អាតសត្រូវផ្ទៃក្នុង ត្រូវបានដាក់ចេញនៅឯកិច្ចប្រជុំរបស់កងពលធំលេខ ១៦៥[1983] និង ថា មាស មុត បានណែនាំឱ្យកម្មាភិបាល ស្រាវជ្រាវរក និង រាយការណ៍អំពីខ្មាំង ដែលបានបង្កប់ក្នុងជួរ[1984]។ ស.ព.អ. ដកស្រង់តែ ព្រំ សារ៉ាត និង សយ ប៊ិន ប៉ុណ្ណោះ ដើម្បីគាំទ្រការអះអាងនីមួយៗរបស់គាត់[1985]។ សាក្សីទាំងនេះគឺជាការគាំទ្រមិនគ្រប់គ្រាន់។ សាក្សីផ្សេងទៀត បាននិយាយថា មាស មុត មិនបានពិភាក្សាពីបញ្ហាបែបនេះនៅក្នុងកិច្ចប្រជុំនោះទេ[1986]។

៥៤៦. ស.ព.អ. អះអាងថា គោលនយោបាយបោសសម្អាត “ត្រូវបានអនុវត្តយ៉ាងឃោរឃៅជាពិសេស” នៅក្នុងកងពលធំលេខ ១៦៥ ដោយសារទាហានត្រូវបានបោសសម្អាត *យ៉ាងរង្គាល*[1987]។ ស.ព.អ. និយាយបំផ្លើស។ ព្រឹត្តិការណ៍ប្រហាក់ប្រហែលគ្នានេះ បានកើតឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ។ មនុស្សរាប់ពាន់នាក់ត្រូវបានបង្ខំឱ្យធ្វើការ នៅការដ្ឋានប្រឡាយស្ពានស្រែង ក្នុងខេត្តបន្ទាយមានជ័យ នៅភូមិភាគពាយ័ព្យ ដែលស្ថិតក្រោមការដឹកនាំរបស់ អ៊ឹម ចែម[1988]។ មនុស្សជាង ២០០០ នាក់ត្រូវបានសម្លាប់នៅឯមន្ទីរសន្តិសុខកម្រិតថ្នាក់តំបន់ភ្នំទ្រយោង នៅភូមិភាគពាយ័ព្យ ដែលប្រធានរបស់មន្ទីរនេះបានរាយការណ៍ផ្ទាល់ទៅកាន់ អ៊ឹម ចែម[1989]។ ទោះបីជាមានលទ្ធផលរកឃើញទាំងនេះ និង ការរកឃើញ *ក្នុងចំណោមនោះ* ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការដាក់

[1982] *សូមមើល* កថាខណ្ឌ ៣៦៩ *ខាងលើ*។

[1983] កថាខណ្ឌ ៣៣៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1984] កថាខណ្ឌ ៣៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[1985] ជើងទំព័រ ១១៥៧ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ភ.១១៥-១៦, ភ.១១៨-២០។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ភ.១១០-១១។ ជើងទំព័រ ១១៧៦ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 ភ.១១-១២។

[1986] *សូមមើល* កថាខណ្ឌ ៣១៦ *ខាងលើ* ដែលពិភាក្សាអំពីសាក្សីទាំងនេះ។

[1987] កថាខណ្ឌ ៣៣៥ នៃដីកាសន្និដ្ឋានស្តាពរ។

[1988] កថាខណ្ឌ ២២៤, ២៣០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[1989] កថាខណ្ឌ ១៨៩-៩០, ១៩៣ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

ក្នុងមន្ទីរឃុំឃាំង និង ការធ្វើឱ្យទៅជាទាសករ បានកើតមានឡើងនៅទីតាំងទាំងនេះក៏ដោយ[1990] ក៏ ស.ព.អ. បានរកឃើញថា អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ[1991]។ ការពិចារណាស្រដៀងគ្នានេះទាក់ទងនឹងតួនាទី និង ការទទួលខុសត្រូវរបស់ មាស មុត មាននៅទីនេះ។

ឃ. មិនមានការបន្តបោសសម្អាតទៅលើកម្មាភិបាលរបស់កងពលធំលេខ ១៦៥

៥៤៧. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រដល់ការអះអាងរបស់គាត់ដែលថា កំណត់ត្រាផ្លូវការនានា បង្ហាញពីការបន្តបោសសម្អាតទៅលើកម្មាភិបាលរបស់កងពលធំលេខ ១៦៥ ដោយកម្មាភិបាលយ៉ាងច្រើនត្រូវបានបោសសម្អាតក្នុងមួយខែៗ[1992]។ ស.ព.អ. ដកស្រង់ឯកសាររបស់អគ្គសេនាធិការ និង កម្ពុជាប្រជាធិបតេយ្យ ដែលមិនមានមូលដ្ឋានគាំទ្រ[1993]។

៥៤៨. ស.ព.អ. ដកស្រង់កំណត់ហេតុកិច្ចប្រជុំរបស់អគ្គសេនាធិការនៅថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ពីកិច្ចប្រជុំមួយដែល មាស មុត ដែលមិនបានចូលរួម[1994]។ គាត់ដកស្រង់សារទូរលេខចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ របស់ ឌឹម ដែលបង្ហាញពីការផ្ទេរយុទ្ធជនចំនួនពីរនាក់ ដែលបានរត់ចោលជួរ និងការចាប់ខ្លួនមនុស្សចំនួនប្រាំនាក់ដែលបានរត់គេចខ្លួនចូលក្នុងព្រៃ ដោយគ្មានព័ត៌មានទាក់ទងនឹងថាតើហេតុអ្វីបានជាអ្នកទាំងប្រាំនាក់នេះ ត្រូវបានចាត់ទុកថាជាខ្មាំងនោះឡើយ[1995]។ គាត់ដកស្រង់របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ទាក់ទងនឹងការចាប់ខ្លួនកម្មករបួននាក់ដែលបានចូលទៅ

[1990] កថាខណ្ឌ ៣០៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៥/១។។

[1991] កថាខណ្ឌ ៣១៣-២៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៥/១។

[1992] កថាខណ្ឌ ៣៣៦ នៃដីកាសន្និដ្ឋានស្តាពរ។

[1993] ជើងចំព័រ ១១៦១-៦២ នៃដីកាសន្និដ្ឋានស្តាពរ។

[1994] ជើងចំព័រ ១១៦១ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯកភាជ្ជ" ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26។ *សូមមើល* កថាខណ្ឌ ៣០៥ *ខាងលើ* ដែលពិភាក្សាអំពីកំណត់ហេតុប្រជុំទាំងនេះ។

[1995] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ជូន បងមុត ជ្រាប អំពីសភាពការណ៍ខ្មាំងនៅតាមព្រំដែន" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៧៦ D4.1.699 (ឯកសារនេះដូចគ្នានឹងឯកសារ D1.3.34.11 ដែលដកស្រង់នៅក្នុងជើងចំព័រ ១១៦១ នៃដីកាសន្និដ្ឋានស្តាពរ)។

ក្នុងឃ្លាំងអាវុធនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៧៦[1996]។ ការចាប់ខ្លួនដែលត្រូវបានលើកឡើងនេះ មិនបង្ហាញពីការ "បោសសម្អាត" នោះទេ ប៉ុន្តែជំនួសមកវិញ វាជាការចាប់ខ្លួនដ៏សមហេតុផលនូវមនុស្សដែលបានចូលទៅក្នុងឃ្លាំងអាវុធរបស់យោធាដោយគ្មានការអនុញ្ញាត។ គាត់ដកស្រង់កំណត់ហេតុនៃការប្រជុំនៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ រវាងអគ្គសេនាធិការ និង កងពលធំលេខ ១៦៥ ដែលនៅឯកិច្ចប្រជុំនោះ មានការពិភាក្សាអំពីផែនការផ្តាច់ខ្លួនរបស់ឃុទ្ធជនចំនួន ៤០ នាក់[1997]។ យ៉ាងច្រើនបំផុត ឯកសារទាំងបួននេះ បង្ហាញពីការបោសសម្អាត (តាមរយៈការផ្ទេរទៅកាន់កងមួយផ្សេងទៀត) មនុស្សចំនួន ៤២ នាក់។

៥៤៩. ស.ព.អ. ក៏ដកស្រង់ផងដែរ នូវរបាយការណ៍ស្ថិតិ[1998] ដែលមិនគាំទ្រដល់ការអះអាងរបស់គាត់។ មិនមានការបង្ហាញនៅក្នុងរបាយការណ៍ទាំងនេះ ទាក់ទងនឹងថា តើហេតុអ្វីបានជាទាហានណាម្នាក់ត្រូវបាន "ជម្រុះ" "ដកចេញ" ឬ "ចូលនិវត្តន៍" ឬ ថាតើពាក្យទាំងនោះមានន័យដូចម្តេចឡើយ។ ស.ព.អ. អះអាងថា មនុស្សដែលត្រូវបានបោសសម្អាត ត្រូវបានកំណត់អត្តសញ្ញាណតាមរយៈប្រវត្តិរូបរបស់ពួកគេ ត្រូវបានឆ្លើយដាក់ដោយអ្នកទោសដែលត្រូវបានធ្វើទារុណកម្ម នៅមន្ទីរសន្តិសុខ ជាអ្នកនៅក្រោមបង្គាប់របស់កម្លាភិបាលដែលត្រូវបានចាប់ខ្លួន ឬ បានប្រព្រឹត្តកំហុស[1999]។ គាត់មិនបានផ្តល់ភ័ស្តុតាងដើម្បីគាំទ្រដល់ការអះអាងនេះទេ។ មិនត្រូវយកការអះអាងនេះមកពិចារណាទាល់តែសោះ។

ង. សេចក្តីសន្និដ្ឋាន

៥៥០. មាស មុត មិនបានដឹង ឬ មិនមានឆន្ទៈចូលរួមក្នុងការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជាជាមួយ សុន សេន ឬ សមាជិកកងទ័ពបដិវត្តន៍កម្ពុជាផ្សេងទៀតឡើយ។ មិនមានភ័ស្តុតាងគ្រប់គ្រាន់ដែលបង្ហាញពីចេតនា ឬ សកម្មភាពរបស់ មាស មុត ទាក់ទងនឹងការបោសសម្អាតណាមួយទៅលើកងពលធំលេខ ១៦៥ ឬ កងទ័ពបដិវត្តន៍កម្ពុជានោះទេ។ ចម្លើយរបស់សាក្សី សារទូរលេខ និង

[1996] សេចក្តីរាយការណ៍ ចំណងជើងថា "សរុបសភាពការណ៍ ចាប់ពីថ្ងៃទី ១៥ ខែកក្កដា ដល់ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ១៩៧៦" ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.7 EN 00233963 KH 00021503។

[1997] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657355-00657356 KH 00162489-00162490។ *សូមមើល* កថាខណ្ឌ ៤៣៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីការប្រជុំនេះ។

[1998] ជើងទំព័រ ១១៦២ នៃដីកាសន្និដ្ឋានស្តាពរ។

[1999] កថាខណ្ឌ ៣៣៦ នៃដីកាសន្និដ្ឋានស្តាពរ។

ឯកសារផ្សេងទៀតដែល ស.ព.អ. ដកស្រង់ មិនអាចឱ្យជឿជាក់បានឡើយ ឬ មិនគាំទ្រដល់ការអះអាងរបស់គាត់។ ស.ព.អ. មិនអើពើនឹងបរិយាកាស ដែល ប.ក.ក. បានប្រតិបត្តិការ ដែលមិនអនុញ្ញាតឱ្យមានការជំទាស់។ បើទោះបីជា ស.ច.ស. រកឃើញភ័ស្តុតាងគ្រប់គ្រាន់ក៏ដោយ ក៏វាមិនដំឡើង មាស មុត ឱ្យទៅដល់ប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។ សកម្មភាពដែលទាក់ទងនឹងការបោសសម្អាតណាមួយ ដែលត្រូវបានអនុវត្តដោយ មាស មុត គឺតាមការណែនាំរបស់មជ្ឈិមបក្ស ដោយកម្រិតត្រឹមកងពលធំលេខ ១៦៤ និង (មួយរយៈពេលខ្លី) កងពលធំលេខ ១១៧ និង តំបន់ ៥០៥[2000]។ សកម្មភាពទាំងនេះ មានការពាក់ព័ន្ធទៅនឹងមនុស្សមួយក្រុមតូច ធៀបទៅនឹងចំនួនជនរងគ្រោះសរុបនៅទូទាំងកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[2001]។

១០. បើទោះជាកងពលធំលេខ ១៦៤ បានចាប់ខ្លួន ឃុំខ្លួន ឬកាប់សម្លាប់ជនជាតិវៀតណាម ជនជាតិថៃ ឬ ជនជាតិបស្ចិមប្រទេសមែនក៏ដោយ ក៏អំពើបែបនេះមិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ

៥៥១. មាស មុត មិនបានទទួលខុសត្រូវលើការចាប់ខ្លួន ការឃុំខ្លួន ឬ ការកាប់សម្លាប់ជនជាតិវៀតណាម ជនជាតិថៃ ឬ ជនជាតិបស្ចិមប្រទេសនោះទេ។ ស.ព.អ. មិនបានពិចារណាលើភ័ស្តុតាងប្រវត្តិសាស្ត្រ ឬ ភស្តុតាងបរិបទដែលធ្វើឱ្យការអះអាងរបស់គាត់ទន់ខ្សោយ ឬ បដិសេធការអះអាងរបស់គាត់នោះឡើយ។ គាត់សំអាងលើសាក្សី និង ភស្តុតាងឯកសារដែលមិនអាចឱ្យជឿជាក់បាន និង មិនមានមូលដ្ឋានគាំទ្រ។ បើទោះបីជា ស.ច.ស. យល់ឃើញថា ភ័ស្តុតាងគាំទ្រការរកឃើញដែលថា មាស មុត ទទួលខុសត្រូវចំពោះអំពើប្រឆាំងនឹងជនបរទេសដែលចាប់បាននៅសមុទ្រ ក៏ករណីនេះមិនដំឡើងឱ្យ មាស មុត ស្ថិតនៅក្នុងប្រភេទនៃអ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។ អំពើនេះត្រូវពិចារណាជាមួយនឹងការដែលមនុស្សស្លាប់ និង ការទទួលរងឈឺចាប់ទាំងអស់ដែលបង្កឡើងដោយគោលនយោបាយ ប.ក.ក. ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[2002]។

[2000] *សូមមើល* ផ្នែកទី IV.គ.៨ *ខាងលើ* សម្រាប់ការលើកឡើងពីការបញ្ជូន មាស មុត ទៅតំបន់ ៥០៥។

[2001] កថាខណ្ឌ ៣១៧-១៨ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[2002] កថាខណ្ឌ ៣១៧-១៨ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

ក. ការចាប់ខ្លួន ការឃុំខ្លួន ឬ ការកាប់សម្លាប់ជនជាតិវៀតណាម

i. គោលនយោបាយ ប.ក.ក. ទាក់ទងនឹងវៀតណាមបានកើតចេញពីការភ័យខ្លាចជាលក្ខណៈប្រវត្តិសាស្ត្រអំពីការឈ្លានពានរបស់យោធាវៀតណាម

៥៥២. ស.ព.អ. មិនអើពើនឹងបរិបទប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យ និង ប្រទេសវៀតណាម។ មាស មុត មិនបានបង្កើតពាក្យថា "ខ្មាំងស្នូរពូជ" ឬ គោលនយោបាយចំពោះប្រទេសវៀតណាមឡើយ។ ពាក្យ និង គោលនយោបាយនេះ ហើយរួមជាមួយនឹងការណែនាំទាក់ទងនឹងការការពារជាតិ គឺចេញមកពីមេដឹកនាំជាន់ខ្ពស់ ប.ក.ក.[2003]។ វាកើតចេញពីការភ័យខ្លាចជាយូរមកហើយថា ប្រទេសវៀតណាមនឹងកាន់កាប់ទឹកដីកម្ពុជាប្រជាធិបតេយ្យទាំងមូល[2004]។ ជំហររបស់មជ្ឈិមបក្សចំពោះប្រទេសវៀតណាម និង ការភ័យខ្លាចចំពោះការកាន់កាប់ដោយវៀតណាម មិនមែនជារឿងថ្មីនោះទេ។ វាកើតតាំងពីមុន និង នៅក្នុងអំឡុងរបប លន់ នល់ មកម្ល៉េះ[2005]។

[2003] *សូមមើលខទ. រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D234/2.1.113 នៅម៉ោង 09.12.09-09.16.18 (ប្រាក់ ខន អ្នកស្នូរចម្លើយនៅ ស-២១ បានផ្តល់សក្ខីកម្មថា ក្នុងពេលបង្រៀន សុន សេន និង ខុច បានបង្រៀនបុគ្គលិក ស-២១ ថា វៀតណាមជាសត្រូវស្នូរពូជរបស់ ប.ក.ក.)។ *សូមមើលផងដែរ* លិខិត ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ១៩៧៩ ពីតំណាងកម្ពុជាប្រជាធិបតេយ្យប្រចាំនៅអង្គការសហប្រជាជាតិ ជូនចំពោះលោកអគ្គលេខាធិការ ឧបសម្ព័ន្ធ I ចំណងជើង "សេចក្តីថ្លែង ចុះថ្ងៃទី ២ ខែមករា ឆ្នាំ ១៩៧៩ របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ" ឯកសារ អ.ស.ប. លេខ A/34/59 S/13024 ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ១៩៧៩ ឯកសារ D1.3.23.1 EN 00078239 KH 00234018 (រៀបរាប់ វៀតណាមជា "សត្រូវស្នូរពូជ")។ ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ សៀវភៅខ្មៅ៖ ការពិត និង ភស្តុតាងនៃអំពើឈ្លានពាន និង ភ្ជាប់យកទឹកដីកម្ពុជាពីសំណាក់វៀតណាម ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារ D1.3.17.3 (ការបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលពណ៌នាលម្អិតពីសកម្មភាពឈ្លានពានជាប្រវត្តិសាស្ត្ររបស់វៀតណាមមកលើកម្ពុជា)។

[2004] *សូមមើលខទ.* សេចក្តីណែនាំរបស់ ប.ក.ក. ចំណងជើង "សេចក្តីណែនាំរបស់ ៨៧០" ឆ្នាំ១៩៧៨ ឯកសារ D1.3.19.3 EN 00183995 KH 00052508 (សំដៅលើ "ឃ្លានឈ្លានពានលេបទឹកដី")។ សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះកងទ័ពបដិវត្តកម្ពុជា និង ប្រជាជនកម្ពុជា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D4.1.1029 EN 00713108 KH 00442400 (សំដៅលើការវាតកម្ចាត់ខ្មាំងសត្រូវ "ឃ្លានឈ្លានពាន វាតទី-លេបទឹកដី")។ ទស្សនាវដ្តី ប.ក.ក. ចំណងជើងថា "ទង់បដិវត្ត" លេខពិសេស ខែឧសភា-មិថុនា ឆ្នាំ ១៩៧៨ ឯកសារ D1.3.24.5 EN 00185333 KH 00064567 (សំដៅលើការវាយកម្ចាត់ខ្មាំងសត្រូវ "ឃ្លានឈ្លានពាន វាតទី-លេបទឹកដី" និង ឃ្លានចង់យកដីកម្ពុជារស់នៅ និង យកកម្ពុជាចូលសហព័ន្ធឥណ្ឌូចិន)។

[2005] PHILIP SHORT ប៉ុល ពត៖ ប្រវត្តិសាស្ត្រនៃសុបិន្តអាក្រក់ ទំព័រ ២៥ និង ២០៧ (គ្រឹះស្ថានបោះពុម្ពផ្សាយ John Murray ឆ្នាំ ២០០៤) ឯកសារ D54/74.1.20 EN 00396217, 00396407 (ដែលកត់សម្គាល់ថា ប្រជាជនកម្ពុជាក្នុងប្រវត្តិសាស្ត្រមាន

ព្រំ សារ៉ាត[2006] បានឮពាក្យថា "សត្រូវស្នូរពូជ" "តាំងពីគាត់នៅក្មេង"[2007]។ មាស រឿន[2008] បាន និយាយថា ប្រទេសកម្ពុជា និង វៀតណាម គឺជាខ្មាំងសត្រូវតាំងពីមុនពេលគាត់កើតទៅទៀត[2009]។ ការភ័យខ្លាចដែលថា ប្រទេសវៀតណាមនឹងកាន់កាប់ទឹកដីកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបង្ហាញឱ្យឃើញតាមរយៈការណែនាំរបស់មជ្ឈិមបក្សនៅទូទាំងប្រទេសថា ដោយសារតែប្រទេសវៀតណាម គឺជាប្រទេសធំជាងប្រទេសកម្ពុជា អង្គភាពទាំងឡាយមិនគួរផ្តើមការវាយប្រយុទ្ធជាមួយប្រទេសវៀតណាមនោះទេ ប៉ុន្តែគួរធ្វើការការពារទប់ទល់នឹងការវាយប្រយុទ្ធតែប៉ុណ្ណោះ ហើយគួរកុំបាញ់តបតប្រសិនបើកងកម្លាំងវៀតណាមត្រឹមតែបាញ់ពីរបីគ្រាប់នោះ[2010]។ ប.ក.ក. បានចាត់

ការភ័យខ្លាចវៀតណាមដណ្តើមយកទឹកដី ហើយរដ្ឋាភិបាល លន់ នល់ ត្រូវបានគេចោទប្រកាន់ថាបានសម្លាប់រង្គាលជនស៊ីវិលវៀតណាម ក្នុងការខិតខំប្រឹងប្រែងការពារប្រឆាំងនឹង "សត្រូវស្នូរពូជ")។ MICHAEL VICKERY កម្ពុជា៖ ១៩៧៥-១៩៨២ ទំព័រ ២៤៩ (South End Press ឆ្នាំ ១៩៨៤) ឯកសារ D88.1.32 EN 00839125 (ដែលកត់សម្គាល់ថា របបដែលប្រកាន់បក្សពួកជាច្រើនជំនាន់បណ្តុះផ្នត់គំនិត "សត្រូវស្នូរពូជ" ក្នុងចំណោមប្រជាជន ហើយដែលជាការអនុវត្តជាក់ស្តែងក្នុងរបបសីហនុ និង លន់ នល់)។

[2006] *សូមមើល* កថាខណ្ឌ ១៩១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2007] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 នៅម៉ោង 09.29.16-09.31.50 (ព្រំ សារ៉ាត បានឮជីតារបស់គាត់ប្រើពាក្យ "សត្រូវស្នូរពូជ") នៅម៉ោង 09.31.50-09.35.00 (ការយល់ដឹងរបស់ ព្រំ សារ៉ាត ថា ពាក្យហ្នឹងវាជាទម្លាប់របស់ខ្មែរ)។

[2008] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2009] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 10.06.58-10.10.14 (សំដៅលើគំនិត "សត្រូវស្នូរពូជ" មាស រឿន ឆ្លើយថា ខ្មែរ ហើយនិង ឃួន សត្រូវគ្នាយូរណាស់មកហើយ តាំងពីគាត់មិនទាន់កើត មិនមែនជាសត្រូវទើបសត្រូវ ៧៩ហ្នឹងទេ)។

[2010] ទស្សនាវដ្តី ប.ក.ក. ចំណងជើង "ទង់បដិវត្ត" លេខ ៨ ខែសីហា ឆ្នាំ ១៩៧៥ ឯកសារ D4.1.873 EN 00532685-00532686 KH 00399110-00399115។ សេចក្តីណែនាំនេះ ត្រូវបានផ្សព្វផ្សាយទៅថ្នាក់ក្រោម ដោយមេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក. ដូចជា សុន សេន និង តាម៉ុក។ *សូមមើលខគ.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំគណៈកម្មាធិការកងពល ៩២០ ពេញអង្គ" ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.14 EN 00184781 KH 00083160 (សុន សេន ណែនាំកងពល ៩២០៖ "ជាមួយវៀតណាម យើងត្រូវមានជំហរ៖ ១. យើងមិនមែនជាអ្នកបង្កហេតុទេ។ ២. តែយើងត្រូវការពារទឹកដី ដាច់ខាត មិនឱ្យអ្នកណាយក ឬ រំលោភជាដាច់ខាត។ ៣. បើវៀតណាមឈ្លានពាន យើងសុំឱ្យថយ បើមិនថយ យើងវាយ។ ទិសយើង គឺតស៊ូទាំងផ្នែនយោបាយ ទាំងផ្នែរយោធា"។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស រឿន ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D59/1/1.36 EN 00849511 KH 00733339 ("នៅខាងព្រំដែន [តាម៉ុក] បានណែនាំសត្រូវពីខាងក្រៅទេ។ គាត់ និយាយថា៖ យើងត្រូវការពារទឹកដីយើងត្រូវអត់ធ្មត់ បើគេតបតយើង យើងកុំតបតគេ យើងមានការអត់ធ្មត់ កុំឱ្យមានការប៉ះពាល់រឿងអ្វីៗ ដូចថាគេឃើញយើងគេបាញ់បន្តិចបន្តួចអីយើងកុំតបត យើងស្ងាត់ស្ងៀមទៅ កុំឱ្យកតើមានដូចថា គេបាញ់ហើយ យើងបាញ់ទៅវិញ បានន័យថាយើងបង្កកើតឡើងជារឿងធំណាស់")។

វិធានការស្របច្បាប់ប្រឆាំងនឹងជនឈ្លានពានយោធា។ បក្សមិនបានបង្កើតការភ័យខ្លាច ឬ ការស្អប់ខ្ពើមដែលនាំទៅដល់ការធ្វើទុក្ខបុកម្នេញជនជាតិវៀតណាមឡើយ។ *សូមមើល* ត្រង់ផ្នែក IV.D *ខាងក្រោម* ទាក់ទងនឹងការលើកឡើងអំពីការអះអាងរបស់ ស.ព.អ. ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម។

ii. ជនជាតិវៀតណាមមិនត្រូវបានឃុំខ្លួន ឬ កាប់សម្លាប់ដោយារមូលហេតុនៃការធ្វើទុក្ខបុកម្នេញ

៥៥៣. ជនជាតិវៀតណាមមិនត្រូវបានឃុំខ្លួន ឬ កាប់សម្លាប់ ដោយសារមូលហេតុនៃការធ្វើទុក្ខបុកម្នេញនោះឡើយ។ អំពើណាមួយបែបនេះមានមូលដ្ឋានលើការព្រួយបារម្ភផ្នែកសន្តិសុខជាតិ និង ការការពារជាតិ។ ស.ព.អ. អះអាងថា មាស មុត បានគាំទ្រ និង បានចូលរួមយ៉ាងសកម្ម នៅក្នុងការចាប់ខ្លួន ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និង ការកាប់សម្លាប់ពលរដ្ឋវៀតណាម ជនជាតិពន្ធុវៀតណាម និង ប្រជាជនដែលត្រូវបានគេយល់ឃើញថាជាជនជាតិវៀតណាម[2011]។ ស.ព.អ. ធ្វើការអះអាងយ៉ាងវិតត្បិតជាលក្ខណៈសើរី អំពីសកម្មភាពដែលត្រូវបានអះអាងថា បានប្រព្រឹត្តដោយ មាស មុត ក្នុងការចូលរួមចំណែកជាមួយនឹងការសម្លាប់ជនជាតិវៀតណាម។ ការអះអាងទាំងនេះនឹងត្រូវបានឆ្លើយតបម្តងមួយៗខាងក្រោម។ ស.ព.អ. ខកខានមិនបានបង្ហាញមូលដ្ឋានគាំទ្រការអះអាងទាំងនេះ។ យ៉ាងច្រើនបំផុត ភ័ស្តុតាងបង្ហាញថា មាស មុត និង កងពលធំលេខ ១៦៥ បាននឹងកំពុងការពាររបបកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម។

៥៥៤. ស.ព.អ. អះអាងថា មាស មុត បានបំពាក់បំប៉នកងទ័ពរបស់ខ្លួនអំពីមនោគមន៍វិជ្ជាបក្សទាក់ទងនឹងប្រទេសវៀតណាម ហើយឋានៈជា "សត្រូវស្បែរពូជ" និង "សត្រូវទីមួយ" របស់កម្ពុជាប្រជាធិបតេយ្យ[2012]។ ស.ព.អ. ដកស្រង់ភ័ស្តុតាងមិនអាចឱ្យជឿជាក់បាន ដែលទទួលបានពី ប៉ាក សុខ និង

រឿងក្តី នួន ជា និង អ្នកផ្សេងទៀត សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 10.05.14-10.11.57 (ម៉ាក ឈឿន បានបញ្ជាក់ពីគោលនយោបាយ និង សេចក្តីណែនាំចេញពី សុន សេន និង តាម៉ុក)។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៦ ឯកសារ D114/297.1.39 នៅម៉ោង 15.44.03-15.51.05 (អៀង ជាន បញ្ជាក់ពីគោលនយោបាយ និង សេចក្តីណែនាំចេញពី សុន សេន និង តាម៉ុក)។

[2011] កថាខណ្ឌ ១២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2012] កថាខណ្ឌ ១៣១ នៃដីកាសន្និដ្ឋានស្តាពរ។

ចម្លើយដែលគ្មានមូលដ្ឋានគាំទ្ររបស់ ឯក នី និង ម៉ាក ឈឿន[2013]។ ស.ព.អ. ក៏មិនបានពិចារណាផងដែរអំពីបរិបទយោធា និង ប្រវត្តិសាស្ត្រនៃចម្លើយរបស់សាក្សី។

៥៥៥. **ប៉ាក សុខ**៖ ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[2014]។ គាត់បាននិយាយថា គាត់បានចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់កងវរសេនាតូច និង កងវរសេនាធំ ដែលជនជាតិវៀតណាមត្រូវបានពិពណ៌នាថាជាសត្រូវស្នូរពូជ និង សត្រូវទីមួយ ហើយថា គោលគំនិតទាំងនេះត្រូវបានបង្រៀនដល់បុគ្គលិកថ្នាក់ក្រោមនៅក្នុងអំឡុងពេលបណ្តុះបណ្តាលកងពលធំដែល មាស មុត ជាអ្នកទទួលខុសត្រូវ[2015]។ នៅពេលពិចារណាអំពីតួនាទីតូចតាចរបស់ ប៉ាក សុខ[2016] និង គោលនយោបាយរក្សាការសម្ងាត់របស់បក្ស[2017] គាត់មិនអាចដឹងទេនៅពេលនោះថា នរណាជាអ្នកទទួលខុសត្រូវលើការបណ្តុះបណ្តាលកងពលធំនោះ។ ភាសាដែល ប៉ាក សុខ បានពិពណ៌នា និង អាកប្បកិរិយាចំពោះប្រទេសវៀតណាម គឺចេញមកពីមជ្ឈិមបក្ស[2018]។

៥៥៦. **ឯក នី**៖ សក្ខីកម្មរបស់ ឯក នី[2019] ចង្អុលបង្ហាញពីគោលចំណងយោធានៅពីក្រោយគោលនយោបាយរបស់បក្សចំពោះប្រទេសវៀតណាម។ គាត់បានអះអាងថា គេត្រូវតែ “បោសសម្អាត និង កម្ទេច” ជនជាតិវៀតណាមចេញពីក្នុងជួរកងទ័ព ដោយមិនគិតពីប្រភពដើម ឬ អាយុរបស់ពួកគេឡើយ[2020]។ គាត់ក៏បាននិយាយផងដែរថា ជនជាតិវៀតណាមត្រូវបាន “កម្ទេចចោល” ពីព្រោះរបបកម្ពុជាប្រជាធិបតេយ្យ បាននឹងកំពុងវាយប្រយុទ្ធជាមួយនឹងប្រទេសវៀតណាម ដែលបានយក

[2013] ជើងចំព័រ ៣៨០-៨២ នៃដីកាសន្និដ្ឋានស្តាពរ។

[2014] *សូមមើល* កថាខណ្ឌ ២៣៣-៣៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2015] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.៣២-៣៤។ ជើងចំព័រ ៣៨០, ៣៨២ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងចំព័រ ៣៩៨, ៤០០ នៃដីកាសន្និដ្ឋានស្តាពរ។

[2016] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/297.1.21 នៅម៉ោង 09.24.20-09.26.53 (ឆ្លើយថា មិនមានឃុទ្ធជននៅក្រោមតួនាទីរបស់គាត់ទេ)។

[2017] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលនយោបាយរក្សាការសម្ងាត់របស់បក្ស និង ផលប៉ះពាល់លើការវាយតម្លៃកស្តុតាង។

[2018] *សូមមើល* កថាខណ្ឌ ៥៥២ *ខាងលើ*។

[2019] *សូមមើល* កថាខណ្ឌ ២៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2020] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/284 ឆ.៣-៧។ ជើងចំព័រ ៣៨០ នៃដីកាសន្និដ្ឋានស្តាពរ។

កោះក្រចកសេះ និង កោះពូឡូវ៉ៃ ហើយជនជាតិវៀតណាម គឺជាជនឈ្លានពាន ដែលយោធាត្រូវទប់ទល់ការពារ[2021]។

៥៥៧. **ម៉ាក ឈឿន៖** សក្ខីកម្មរបស់ ម៉ាក ឈឿន[2022] ក៏ចង្អុលបង្ហាញផងដែរ អំពីគោលបំណងយោធានៅពីក្រោយគោលនយោបាយរបស់បក្សចំពោះប្រទេសវៀតណាម។ គេបានប្រាប់គាត់ឱ្យវាយប្រហារទូកនេសាទដែលចូលមកជ្រៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ មិនមែនទូកនេសាទដែលនៅជិតព្រំដែនសមុទ្រនោះឡើយ[2023]។ គាត់បាននិយាយថា កាណូតនេសាទវៀតណាមដែលមានកាំភ្លើង បានចូលមកក្នុងដែនទឹករបស់ពួកគេញឹកញាប់[2024]។ ស.ព.អ. ដកស្រង់ត្រឹមតែចម្លើយទាំងនេះប៉ុណ្ណោះ[2025]។ ម៉ាក់ ឈឿន ក៏បាននិយាយផងដែរថា គាត់នឹងបណ្តេញទូកដែលមិនមានបំពាក់អាវុធចេញពីដែនទឹក ហើយបាញ់ប្រហារតែលើទូកណាដែលបានបាញ់មកមុន ឬ មិនព្រមដកថយ[2026]។ គាត់បាននិយាយថា គាត់បានទទួលបញ្ជាឱ្យអនុញ្ញាតឱ្យទូកជនភៀសខ្លួនវៀតណាមបន្តដំណើរទៅមុខដោយគ្មានការចាប់ខ្លួនពួកគេ[2027]។

[2021] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 អ.១១-១២, អ.១៧។

[2022] *សូមមើល* កថាខណ្ឌ ៣៥០ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2023] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/19 អ.១៨។

[2024] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/19 អ.១៨។

[2025] ដើងទំព័រ ៣៨០ នៃដីកាសន្និដ្ឋានស្តាពរ។

[2026] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.02.05-14.04.46។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 09.24.31-09.29.59 (បើទូកវៀតណាមមកហួសកោះសេះ អាហ្នឹងមានការដេញ និង បើគេបាញ់យោធា ក.ប.ក. យើងវ៉ៃគ្នាហើយ) នៅម៉ោង 09.51.04-09.54.22 (ទូកនេសាទដែលបាញ់មុន យើងបាញ់។ បើគេអត់បាញ់ទេ យើងឆាបលិចកើតទៅគេទៅវិញ យើងក៏អត់បាញ់គេដែរ)។

[2027] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 09.35.02-09.38.23 (ឆ្លើយថា គាត់មិនដែលជួបប្រទេះ ឬក៏ជាក់ស្តែងណែនាំថា ឱ្យប្រជាជនវៀតណាមដែលរត់ទៅក្រៅប្រទេសហ្នឹងបាញ់ពន្លិចស្នើចោលអី គាត់ៗមិនដែលបានទទួលផែនការពីកងពលផលផ្តាល់ទេ) នៅម៉ោង 09.45.46 (ឆ្លើយថា ការណែនាំរបស់ថ្នាក់លើថាប្រជាជនរត់ពីវៀតណាម គេចសង្គ្រាមទៅក្រៅមិនមែនជាសត្រូវទេ)។

៥៥៨. ស.ព.អ. អះអាងថា មាស មុត ត្រូវធ្វើរបាយការណ៍ស្តីពីការចាប់ខ្លួនប្រជាជនវៀតណាម[2028] ដោយបានដកស្រង់ការរៀបរាប់របស់សាក្សីមួយចំនួន[2029]។ ស.ព.អ. និយាយបំផ្លើសភ័ស្តុតាង។ ព្រំ សារ៉ាត មិនបាននិយាយថា មាស មុត បានតម្រូវយ៉ាងជាក់លាក់ឱ្យធ្វើរបាយការណ៍ឱ្យគាត់អំពីការចាប់ខ្លួនជនជាតិវៀតណាមនោះទេ ដោយគាត់ត្រឹមតែតម្រូវឱ្យរាយការណ៍តាមវិទ្យុអំពីការចាប់ខ្លួនទាហាន និង ជនស៊ីវិលវៀតណាម ទៅកងពលធំប៉ុណ្ណោះ[2030]។ គាត់បានកំពុងសំដៅលើដំណើរការរាយការណ៍ជាទូទៅ ដែលអនុវត្តលើគ្រប់បញ្ហាទាំងអស់[2031]។ ប៉ាក សុខ បាននិយាយថា កងពលធំបានតម្រូវឱ្យធ្វើរបាយការណ៍លម្អិតអំពីការចាប់ខ្លួន រួមទាំងសញ្ជាតិផងដែរ[2032]។ បើពិចារណាពីឋានន្តរសក្តិរបស់គាត់[2033] ការដឹងឮរបស់គាត់អំពីហេតុផលតម្រូវឱ្យធ្វើរបាយការណ៍ គឺមានលក្ខណៈតិចតួច[2034]។ នាក់ យឿន បាននិយាយថា មាស មុត បានបញ្ជាមេបញ្ជាការកងវរសេនាតូចរបស់គាត់ ឱ្យចាប់ទូកនេសាទវៀតណាមដែលបានបាញ់មកលើទូករបស់ពួកគេ[2035]។ គាត់បានអះអាងថា គាត់បានឮថា មាស មុត បានបញ្ជាឱ្យកងវរសេនាតូច ធ្វើអ្វីក៏បានទៅតាមចិត្តចង់ ចំពោះជនជាតិវៀតណាមត្រូវបានចាប់ខ្លួន ដែលក្រោយមកត្រូវបានសម្លាប់[2036]។ គាត់បានប៉ាន់

[2028] កថាខណ្ឌ ១៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[2029] ជើងចំពីរ ៣៨៣-៨៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2030] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.១៣៨-៣៩។ ជើងចំពីរ ៣៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2031] *សូមមើលខុទា.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.១៤១៖ "គេរាយការណ៍តាមវិទ្យុទាក់ទង ហើយអ្នកនៅកន្លែងកាន់វិទ្យុទាក់ទងនោះ ត្រូវចុះកំណត់ហេតុក្នុងសៀវភៅប្រចាំថ្ងៃ ទោះព័ត៌មានអ្វីក៏ដោយ ដើម្បីបញ្ជូនព័ត៌មានទាំងនោះទៅឱ្យ មាស មុត"។

[2032] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.00.46-10.07.37, 11.03.07-11.09.46។ ជើងចំពីរ ៣៨៤ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងចំពីរ ៣៩០ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.២៨។

[2033] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2034] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលពិភាក្សាពីគោលនយោបាយរក្សាការសម្ងាត់របស់បក្ស និង ផលប៉ះពាល់លើការវាយតម្លៃភស្តុតាងក្នុងរឿងក្តី ០០៣។

[2035] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/12 ឆ.១៦-២១។ ជើងចំពីរ ៣៨៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2036] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/116 ឆ.៣៦-៤២។

ស្ថានដោយផ្អែកលើឋានានុក្រមនៅក្នុងជួរកងវរសេនាតូចរបស់គាត់[2037]។ នាក់ ឃឿន បានស្ថិតនៅលើកប៉ាល់ការពារ ដូច្នេះ គាត់មិនអាចដឹងអំពីដំណើរការធ្វើសេចក្តីសម្រេច ឬ ដំណើរការទំនាក់ទំនងគ្នានៅថ្នាក់កងពលធំនោះទេ[2038]។ គ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះបង្ហាញថា បក្សមានគោលនយោបាយ ដែលមានគោលដៅជាពិសេសចំពោះជនជាតិវៀតណាមនោះឡើយ តែជាគោលនយោបាយទប់ស្កាត់អ្នកឈ្លានពានដែលជាជនជាតិណាក៏ដោយ មិនឱ្យចូលមកក្នុងដែនទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ។

៥៥៩. ឯក នី បានអះអាងថា មាស មុត បានបញ្ជាឱ្យសម្លាប់ជនជាតិវៀតណាមដែលត្រូវបានចាប់នៅលើកោះ ជាជាងបញ្ជូនទៅកាន់ដីគោក ដើម្បីកុំឱ្យខាតសាំង[2039]។ ឯក នី មិនអាចឱ្យជឿជាក់បានទេ[2040]។ គាត់បានរៀបរាប់រឿងរ៉ាវនេះឡើងវិញនៅក្នុងកិច្ចសម្ភាសន៍មួយផ្សេងទៀត ដោយលើកឡើងមិនត្រឹមត្រូវថា គាត់បាននិយាយត្រឹមតែអំពីឧបទ្ទវហេតុដែលគាត់បានដឹងប៉ុណ្ណោះ[2041]។ រឿងរ៉ាវរបស់គាត់ គឺផ្អែកលើពាក្យចចាមអារ៉ាម ដែលគាត់ដឹងមកពីប្រធានកងរបស់គាត់[2042]។ តាមអ្វីដែលមេធាវីការពារក្តីដឹង រឿងរ៉ាវនេះមិនស៊ីចង្វាក់គ្នាជាមួយភស្តុតាងផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងនោះឡើយ។

៥៦០. ស.ព.អ. អះអាងថា ការពង្រឹងគោលនយោបាយបក្សរបស់ មាស មុត មានការជាប់ពាក់ព័ន្ធនឹងកងពលធំលេខ ១៦៥ ដែលសម្លាប់ទាហានវៀតណាម ជនភៀសខ្លួន អ្នកនេសាទ និង ខ្មែរក្រោម[2043]។ ស.ព.អ. ដកស្រង់ចម្លើយមិនអាចឱ្យជឿជាក់បាន និង ចម្លើយដែលគ្មានមូលដ្ឋាន

[2037] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ឃឿន ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/12 ឆ.២២។ *សូមមើល* កថាខណ្ឌ ៣៥៦ *ខាងលើ* ដែលពិភាក្សាអំពីចម្លើយនេះ។

[2038] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ឃឿន ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/12 ឆ.៦-៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ឃឿន ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/11 ឆ.១០។

[2039] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.២៩, ឆ.៤១។ កថាខណ្ឌ ១៣២ ជើងទំព័រ ៣៨៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2040] *សូមមើល* កថាខណ្ឌ ២៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2041] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 ឆ.៦៣។ ជើងទំព័រ ៣១៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2042] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.៤៤។

[2043] កថាខណ្ឌ ១៣៣ នៃដីកាសន្និដ្ឋានស្តាពរ។

គាំទ្ររបស់ ឯក នី ប៉ាក សុខ និង ប្រាក់ សុខា[2044]។ ឯក នី និង ប៉ាក សុខ បានអះអាងថា ជនភៀសខ្លួនវៀតណាមត្រូវបានចាប់ខ្លួន និង សម្លាប់ចោល[2045]។ ចម្លើយរបស់ ឯក នី គឺផ្អែកលើពាក្យចចាមអារ៉ាម[2046]។ ប៉ាក សុខ មិនអាចឱ្យជឿជាក់បានទេ[2047]។ ឯក នី ក៏បាននិយាយផងដែរថា អ្នកនេសាទវៀតណាមត្រូវបានចាប់ខ្លួន ប៉ុន្តែមិនបាននិយាយថា ពួកគេត្រូវបានសម្លាប់នោះឡើយ[2048]។ ប្រាក់ សុខា បាន និយាយត្រឹមតែថា ខ្មែរក្រោមមួយចំនួនត្រូវបានបញ្ជូនទៅកងចល័ត។ គាត់មិនបាននិយាយថា ពួកគេត្រូវបានសម្លាប់នោះឡើយ[2049]។

៥៦១. ទាក់ទងនឹងជនភៀសខ្លួនវៀតណាម សាក្សីបញ្ជាក់ថា សុន សេន បានចេញសេចក្តីណែនាំមិនឱ្យចាប់ខ្លួនពួកគេ។ ប៊ាង រ៉េត[2050] បាននិយាយថា សុន សេន បានណែនាំថា ជនភៀសខ្លួនវៀតណាមដែលធ្វើដំណើរទៅប្រទេសថៃ គួរត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរបន្ត ហើយមិនគួរចាប់ខ្លួននោះទេ[2051]។ ម៉ាក ឈឿន និង ព្រំ សាវ៉ាត បានបញ្ជាក់បន្ថែមលើចម្លើយរបស់ ប៊ាង រ៉េត[2052]។ មាស វឿន[2053] បាននិយាយស្រដៀងគ្នាថា ជនភៀសខ្លួនថៃ និង វៀតណាម ត្រូវបានឱ្យត្រឡប់ទៅ

[2044] ជើងទំព័រ ៣៨៦-៨៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2045] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.២៩។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៧ D54/24.1 EN 00978576 KH 00955507-00955508។ ជើងទំព័រ ៣៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2046] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.២៩៖ "គេថា គេយកអ្នកទាំងនោះទៅធ្វើជីដាក់ដើមធូរ៉ែន"។

[2047] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2048] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 ឆ.៤។ ជើងទំព័រ ៣៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2049] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/36 ឆ.១០។ ជើងទំព័រ ៣៨៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2050] *សូមមើល* កថាខណ្ឌ ១៩៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2051] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៧៥។

[2052] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 09.35.02-09.38.23, 09.45.46។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.92 នៅម៉ោង 10.46.11-10.51.25, 10.54.04។

[2053] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

ផ្ទះវិញ ឬ អនុញ្ញាតឱ្យធ្វើដំណើរទៅតាមទីកន្លែងគោលដៅរបស់ពួកគេ[2054] ហើយថា គាត់បានទទួលបញ្ជាមិនឱ្យសម្លាប់ជនភៀសខ្លួនទាំងនោះ[2055]។

៥៦២. ស.ព.អ. រៀបរាប់ឡើងវិញអំពីរឿងរ៉ាវរបស់ មុត ម៉ៅ ថា នៅចុងឆ្នាំ ១៩៧៨ ស្ត្រីជនជាតិវៀតណាម និង កុមារពីរនាក់ ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ត្រូវបានសម្លាប់នៅជិតផ្ទះរបស់ មាស មុត[2056]។ មុត ម៉ៅ គឺមិនអាចឱ្យជឿជាក់បាន[2057]។ រឿងរ៉ាវរបស់គាត់ភាគច្រើន បានផ្អែកលើពាក្យចចាមអារ៉ាមរបស់និរសារ នៅក្នុងការិយាល័យរបស់ មាស មុត។ គាត់បានឃើញប្រជាជនវៀតណាមចំនួនបីនាក់ និង ទាហានកងពលធំលេខ ១៦៥ ដើរកាត់ផ្ទះរបស់គាត់[2058]។ គាត់មិនបានឃើញ ឬ ឮថា ពួកគេត្រូវបានសម្លាប់នោះទេ គាត់បាននិយាយត្រឹមតែថា ក្រោយមកគាត់បានឃើញរណ្តៅពីរ ឬ បី នៅចម្ងាយ ៣០ ម៉ែត្រពីផ្ទះរបស់គាត់ប៉ុណ្ណោះ[2059]។ គាត់មិនបានដឹងថានរណាជាទាហានទាំងនោះឡើយ។ គាត់បានឮថា ពួកគេមកពីកងពិសេសរបស់កងពលធំ[2060]។ គាត់ក៏បានឮផងដែរថា ប្រជាជនត្រូវបានគេចាប់ខ្លួននៅសមុទ្រ[2061] ហើយនៅជាមួយ សេ.អ៊ី.អា.[2062]។ មុត ម៉ៅ មិនបាននិយាយថា មាស មុត មានវត្តមាននៅក្នុងអំឡុងពេលនៃឧបទ្ទវហេតុដែលបានលើកឡើងនេះ ឬ ជាប់ពាក់ព័ន្ធនៅក្នុងការចាប់ខ្លួន ឬ ការកាប់សម្លាប់ប្រជាជនទាំងនេះឡើយ។ តាមអ្វីដែលមេធាវីការពារក្តីដឹង រឿងរ៉ាវនេះមិនមានភាពស៊ីចង្វាក់គ្នាជាមួយនឹងភ័ស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងឡើយ។

2054 *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.08.12-14.15.00។

2055 *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 11.18.10-11.21.53, 11.21.53-11.26.24។

2056 កថាខណ្ឌ ១៤១ នៃដីកាសន្និដ្ឋានស្តាពរ។

2057 *សូមមើល* កថាខណ្ឌ ២៦៦-៦៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

2058 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 អ.៣៩, អ.៤៦, អ.៥៥, អ.៥៨។

2059 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 អ.៦៤-៦៥។

2060 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 អ.៤៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៤ D54/72 អ.៦។

2061 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/71 អ.៦១។

2062 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/72 អ.២៥។

៥៦៣. ស.ព.អ. អះអាងថា ការទទួលខុសត្រូវរបស់ មាស មុត លើការឃាត់ទុក ការចាប់ខ្លួន និង ការកាប់សម្លាប់ប្រជាជនវៀតណាមត្រូវបានបង្ហាញឱ្យឃើញតាមរយៈរបាយការណ៍របស់គាត់ ដែលរាយការណ៍ទៅមេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក. រួមទាំង សុន សេន ផងដែរ[2063]។ ស.ព.អ. ដកស្រង់សារទូរលេខ របាយការណ៍ និង កំណត់ហេតុនៃកិច្ចប្រជុំ ដើម្បីគាំទ្រការអះអាងរបស់គាត់[2064]។ ក្នុងចំណោមឯកសារដែល ស.ព.អ. ដកស្រង់ ឯកសារចំនួនប្រាំ គឺមិនជាប់ទាក់ទងនោះឡើយ៖

- ឯកសារ **D1.3.8.4**៖ គ្មានការបញ្ជាក់ថា មាស មុត បានចូលរួមកិច្ចប្រជុំនៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ រវាង សុន សេន និង កងពលធំលេខ ១៦៥ ឬថា មាននរណាម្នាក់បានរាយការណ៍ទៅ សុន សេន អំពីការចាប់ខ្លួននៅសមុទ្រ ឬ ការកាប់សម្លាប់ប្រជាជនវៀតណាមនោះឡើយ[2065]។
- ឯកសារ **D1.3.12.3**៖ របាយការណ៍ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ នេះ ដែលផ្ញើទៅ សុន សេន មិនមែនរាយការណ៍អំពីការចាប់ខ្លួននៅសមុទ្រ ឬ ការកាប់សម្លាប់ប្រជាជនវៀតណាមនោះទេ។ របាយការណ៍នេះទាក់ទងនឹងការចាប់ខ្លួនចោរព្រៃដែលគ្មានអត្តសញ្ញាណនៅវាលរេញ[2066]។
- ឯកសារ **D1.3.34.11** (ដូចឯកសារ **D4.1.699**)៖ សារទូរលេខចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៧៦ នេះ ដែលផ្ញើមកពី ឌឹម មិនមែនអំពីការចាប់ខ្លួននៅសមុទ្រ ឬ ការកាប់សម្លាប់ប្រជាជនវៀតណាមនោះទេ។ សារទូរលេខនេះទាក់ទងនឹងការចាប់ខ្លួនប្រជាជនចំនួនប្រាំនាក់ដែលគ្មានអត្តសញ្ញាណនៅវាម និង បបុស[2067]។ វាមិនមែនជារបាយការណ៍ដែល មាស មុត ផ្ញើទៅ សុន សេន នោះឡើយ។

[2063] កថាខណ្ឌ ១៣៥, ១៣៧, ១៣៩-៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[2064] ជើងទំព័រ ៣៨៩, ៣៩៤-៩៦, ៤០១, ៤០៣, ៤០៤-០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2065] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4។ ជើងទំព័រ ៣៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2066] សេចក្តីរាយការណ៍យោធា ចំណងជើងថា "សេចក្តីរាយការណ៍ ពីមុត ជម្រាបបង៨៩ គោរពជ្រាប" ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.3។ ជើងទំព័រ ៣៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2067] ទូរលេខ ចំណងជើងថា "ទូរលេខ ១១ ពី ឌឹម ជូនបងមុត ជ្រាប" ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៧៦ ឯកសារ D1.3.34.11។ ជើងទំព័រ ៣៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

- ឯកសារ **D1.3.34.12**៖ សារទូរលេខចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៧៦ នេះ ដែលផ្ញើមកពី ឪម មិនមែនអំពីការចាប់ខ្លួននៅសមុទ្រ ឬ ការកាប់សម្លាប់ប្រជាជនវៀតណាមនោះទេ។ សារទូរលេខនេះ ជាប់ទាក់ទងនឹងការចាប់ខ្លួនអ្នកដែលស៊ើបការឱ្យចោរព្រៃ ដែលគ្មានអត្តសញ្ញាណ[2068]។ វាមិនមែនជារបាយការណ៍ដែល មាស មុត ផ្ញើទៅ សុន សេន នោះឡើយ។

- ឯកសារ **D1.3.34.13**៖ សារទូរលេខចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩៧៦ នេះ ដែល ឪម ផ្ញើទៅ មាស មុត មិនមែនអំពីការចាប់ខ្លួននៅសមុទ្រ ឬ ការកាប់សម្លាប់ប្រជាជនវៀតណាមនោះទេ។ សារទូរលេខនេះជាប់ទាក់ទងនឹងចោរព្រៃដែលគ្មានអត្តសញ្ញាណ និងខ្មាំងផ្ទៃក្នុង[2069]។ វាមិនមែនជារបាយការណ៍ដែល មាស មុត ផ្ញើទៅ សុន សេន នោះឡើយ។

៥៦៤. ស.ព.អ. ដកស្រង់សារទូរលេខចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ដែល មាស មុត ផ្ញើទៅមន្ទីរ ៨៧០ ដែលក្នុងនោះ គាត់បាន *ក្នុងចំណោមនោះ* ប្តេជ្ញាការពារប្រទេស ដោយធ្វើការបោសសំអាត គ្មានស្មាក់ស្មើរ សមាសបង្កប់របស់ខ្មាំង ជាយួន និង ខ្មាំងដទៃទៀត[2070]។ ស.ព.អ. មិនបានពិចារណាពីបរិបទនៃសារទូរលេខនេះ[2071]។ មាស មុត បានឆ្លើយតបទៅនឹងការអំពាវនាវឱ្យការពាររបបកម្ពុជាប្រជាធិបតេយ្យ ប្រឆាំងនឹងឈ្លានពានយោធា មិនមែនឱ្យធ្វើទុក្ខបុកម្នេញ ឬ ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមនោះឡើយ[2072]។

៥៦៥. ស.ព.អ. ដកស្រង់សេចក្តីថ្លែងការណ៍របស់ មាស មុត នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនាថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ រវាងគណៈកម្មាធិការកងពលធំលេខ ១៦៥ និង សមាជិកគណៈកម្មាធិការ

[2068] ទូរលេខ ចំណងជើងថា "ទូរលេខ ១២ ជូនបងមុតជ្រាប" ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.12។ ជើងទំព័រ ៣៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2069] ទូរលេខ ចំណងជើងថា "ទូរលេខ ១៦ ពី ឪម ជូនបងមុត ជ្រាប" ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.34.13។ ជើងទំព័រ ៣៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2070] ទូរលេខពី មាស មុត ចំណងជើង "ទូរលេខ ០០ – វិទ្យុ ៣៥៤ ខ្ទង់ – គោរពជូនគណៈ៨៧០" ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.60។ ជើងទំព័រ ៤០៣ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* ជើងទំព័រ ៣៤៥, ២០៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[2071] *សូមមើល* កថាខណ្ឌ ៥១១ *ខាងលើ* ដែលពិភាក្សាពីបរិបទដែលទូរលេខនេះត្រូវបានផ្ញើ។

[2072] *សូមមើល* កថាខណ្ឌ ៥១១ *ខាងលើ* ដែលពិភាក្សាពីការផ្តាច់ទំនាក់ទំនងការទូតរបស់កម្ពុជាប្រជាធិបតេយ្យជាមួយវៀតណាម។

យោធា[2073]។ សេចក្តីថ្លែងការណ៍ទាំងនេះមិនគាំទ្រការអះអាងរបស់ ស.ព.អ. ដែលថា មាស មុត គឺជាអ្នកទទួលខុសត្រូវលើការឃាត់ទុក ការចាប់ខ្លួន ឬ ការកាប់សម្លាប់ទាហានវៀតណាម ជនភៀសខ្លួន អ្នកនេសាទ ឬ ខ្មែរក្រោមនោះឡើយ[2074]។ ហើយក៏គ្មានការយោងពាក្យ "ខ្មាំង" នោះដែរ ដែលវាគឺជាការសំដៅលើឧក្រិដ្ឋកម្ម ឬ ចេតនាឧក្រិដ្ឋរបស់ មាស មុត ឬ បុគ្គលិកក្រោមបង្គាប់របស់គាត់[2075]។ មាស មុត បានរាយការណ៍ថា ខាងវៀតណាមមិនឃើញមានធ្វើសកម្មភាពអីទេ លើកលែងតែបានលួចពោងដែលកងពលធំលេខ ១៦៥ បានដាក់នៅជិតកោះសេះដើម្បីទុកចំណាំព្រំប្រទល់[2076]។ គាត់បានរាយការណ៍អំពីបញ្ហាការពារជាតិទាក់ទងនឹងព្រំដែនទឹករវាងប្រទេសកម្ពុជា និងវៀតណាម ហើយបានឃ្លាំមើលកងទ័ពជើងទឹកវៀតណាម។ របាយការណ៍នេះមិនបានបង្ហាញឱ្យឃើញពីអាកប្បកិរិយាធ្វើទុក្ខបុកម្នេញនោះឡើយ។ ស.ព.អ. អះអាងថា នៅក្នុងកិច្ចប្រជុំអគ្គសេនាធិការនាថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦ មាស មុត និង ឌឹម បានព្រមព្រៀងគ្នាអំពីគោលនយោបាយស្តីពីការកាប់សម្លាប់ដែលមានគោលបំណងសំដៅលើជនជាតិវៀតណាម និង ខ្មាំងខាងក្រៅផ្សេងទៀត[2077]។ សេចក្តីថ្លែងការណ៍របស់ មាស មុត និង អ្នកចូលរួមផ្សេងទៀត នៅក្នុងអំឡុងកិច្ចប្រជុំនោះ គឺជាឧទាហរណ៍នៃការគោរពតាមមាគ៌ាបក្ស ដើម្បីជៀសវាងកុំឱ្យមានការលាបពណ៌ថាជាអ្នកប្រឆាំងបដិវត្តន៍[2078]។ គ្មានជម្រើសអ្វីផ្សេងទៀតទេ ក្រៅតែពីអះអាងនូវការយល់ស្របជាមួយនឹងគោលនយោបាយបក្សនោះឡើយ។

[2073] ជើងទំព័រ ៣៩៤ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់កំណត់ហេតុកិច្ចប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3 EN 00234012 KH 00021496-00021497។

[2074] កថាខណ្ឌ ១៣៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2075] កថាខណ្ឌ ១៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2076] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃអង្គប្រជុំ ការងារយោធា នៅកំពង់សោម" ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.3 EN 00234012 KH 00021496-00021497។

[2077] កថាខណ្ឌ ១៣៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើល* ផ្នែក IV.គ.១១ ទាក់ទងនឹងការទទួលខុសត្រូវរបស់ មាស មុត ក្នុងការបញ្ជូនអ្នកទោសវៀតណាម និង អ្នកទោសផ្សេងទៀតទៅ ស-២១។ *សូមមើល* ជើងទំព័រ ១៨៦២ ទាក់ទងនឹងអត្ថន័យខុសគ្នានៃ "ការបោសសម្អាត"។

[2078] *សូមមើល* កថាខណ្ឌ ២១៣, ២៨៨ និង ៣០៣-០៤ *ខាងលើ* ទាក់ទងនឹងការប្រជុំសេនាធិការ និង ជាពិសេស ការប្រជុំ នៅថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦។

ខ. ការចាប់ខ្លួន ការឃុំខ្លួន ឬ ការកាប់សម្លាប់ជនជាតិថៃ និង ជនជាតិបស្ចិមប្រទេស

៥៦៦. ស.ព.អ. អះអាងថា មាស មុត បានចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើទុក្ខបុកម្នេញ និង ការកាប់សម្លាប់ជនជាតិថៃ និង ពួក *បស្ចិម* ប្រទេស ដែលត្រូវបានចាប់ខ្លួននៅក្នុងដែនទឹក ឬ នៅលើកោះ[2079]។ គាត់សំអាងលើសាក្សីដែលមិនអាចជឿជាក់បាន និង ភស្តុតាងឯកសារដែលមិនពាក់ព័ន្ធ ឬ គ្មានមូលដ្ឋានគាំទ្រ។ គាត់ខកខានមិនបានបង្ហាញមូលដ្ឋានគាំទ្រការអះអាងរបស់គាត់។

i. មាស មុត មិនបានទទួលខុសត្រូវលើការចាប់ខ្លួន ឬ ការកាប់សម្លាប់ជនជាតិថៃ

៥៦៧. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចេញបញ្ជាមានអានុភាពចាប់ទូកបរទេសទាំងអស់ ដែលបានចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ ហើយបានបញ្ជាផ្ទាល់ឱ្យកាប់សម្លាប់ជនជាតិថៃនៅចំការចេងហោង (ឆ្នូរ៉ែន I)[2080]។ ស.ព.អ. ដកស្រង់ជាចម្បងសេចក្តីថ្លែងការណ៍មិនអាចឱ្យជឿជាក់បានរបស់ អ៊ូ ដាវ និង ឯក នី[2081]។ គាត់ក៏បានដកស្រង់ផងដែរ នូវរបាយការណ៍ និង ឯកសារផ្សេងទៀត ដែលមិនគាំទ្រការអះអាងរបស់គាត់[2082]។

៥៦៨. **អ៊ូ ដាវ៖** អ៊ូ ដាវ មិនអាចជឿជាក់បានឡើយ[2083]។ គាត់បានស្តាប់ឮនៅក្នុងកិច្ចប្រជុំថា បក្សបានបញ្ជាឱ្យចាប់ទូកបរទេសដែលបានចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ ហើយ “បក្ស” មានន័យថា ជា មាស មុត[2084]។ ស.ព.អ. ដកស្រង់ត្រឹមតែការអះអាងនេះប៉ុណ្ណោះ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត “បានចេញបញ្ជាមានអានុភាព” ចាប់ទូកបរទេសទាំងអស់ដែលបានចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ[2085]។ ការអះអាងនេះបានផ្អែកលើពាក្យចចាមអារ៉ាម[2086]។

[2079] កថាខណ្ឌ ១៤៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2080] កថាខណ្ឌ ១៤៤, ១៤៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2081] ជើងទំព័រ ៤១៣, ៤១៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2082] ជើងទំព័រ ៤១៤-១៧, ៤១៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2083] *សូមមើល* កថាខណ្ឌ ៣៥៥, ៥០៩ និង ៥៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ និង កថាខណ្ឌ ១៤២ ទាក់ទងនឹងការប្រើប្រាស់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[2084] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/24 អ.៨៩-៩១។

[2085] កថាខណ្ឌ ១៤៤ ជើងទំព័រ ៤១៣ នៃដីកាសន្និដ្ឋានស្តាពរ។

៥៦៩. សាក្សីផ្សេងទៀតមកពីកងពលធំលេខ ១៦៥ បាននិយាយថា ពួកគេបានទទួលបញ្ជាមិនឱ្យចាប់ទូកមួយចំនួន ដូចជាទូកជនភៀសខ្លួន[2087] ហើយថា បញ្ជា គឺឱ្យពួកគេបាញ់តែទៅលើ ឬ ចាប់ទូកប្រដាប់ដោយអាវុធ ដែលបាញ់មកលើពួកគេមុនតែប៉ុណ្ណោះ។ ម៉ាក ឈឿន បានជឿថា គោលនយោបាយអំពីការបាញ់លើទូកដែលបាញ់មកមុន ឬ មិនព្រមដកថយ ក៏ត្រូវបានអនុវត្តចំពោះទូកថៃផងដែរ[2088]។ ឡាយ ប៊ុនហាក់[2089] បាននិយាយថា កងទ័ពកងពលធំលេខ ១៦៥ បានបាញ់សំដៅទូក តែក្នុងករណីទូកទាំងនោះបាញ់មកលើខ្លួនប៉ុណ្ណោះ[2090]។ មាស រឿន បាននិយាយថា កងអង្គភាពរបស់គាត់បានបណ្តេញទូកថៃ និង បានបាញ់តបវិញ តែក្នុងករណីដែលមានការបាញ់មកលើខ្លួនមុនប៉ុណ្ណោះ[2091]។

៥៧០. **ឯក នី**៖ ឯក នី មិនអាចជឿជាក់បានឡើយ[2092]។ គាត់បានអះអាងថា មាស មុត បានយកជនជាតិថៃទៅចម្ការធូរេនចេងហោង ដើម្បីសម្លាប់ ហើយក្រោយមកបានបញ្ជាឱ្យអង្គភាពកុំអោយខ្ជះខ្ជាយប្រេងសាំងដឹកជនជាតិថៃទៅដីគោក[2093]។ ស.ព.អ. ដកស្រង់តែចម្លើយទាំងនេះប៉ុណ្ណោះ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចេញបញ្ជាឱ្យសម្លាប់ជនជាតិថៃនៅចម្ការធូរេនចេងហោង[2094]។ មិនយូរប៉ុន្មានក្រោយថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ឯក នី បានស្នាក់នៅជិត

[2086] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.៩១។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D114/25 ឆ.១០។

[2087] *សូមមើល* កថាខណ្ឌ ៥៦១ *ខាងលើ* ដែលពិភាក្សាពីកស្តុតាងទាក់ទងនឹងទូកជនភៀសខ្លួនវៀតណាម។

[2088] *សូមមើល* កថាខណ្ឌ ៥៥៧ *ខាងលើ* ទាក់ទងនឹងចម្លើយទាំងនេះ។

[2089] *សូមមើល* កថាខណ្ឌ ១៨៩-៩០ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2090] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ឆ.១៣៩-៥១។ ទោះបីមេធាវីការពារក្តីស្នើថា កិច្ចសម្ភាសន៍នេះគួរឱ្យតម្លៃជាភស្តុតាងទាប ដោយសារតែបញ្ហានៃការធ្វើកិច្ចសម្ភាសន៍ តែប្រសិនបើ ស.ច.ស. ពិចារណាថា កិច្ចសម្ភាសន៍នេះអាចគួរឱ្យជឿជាក់បាន ស.ច.ស. ក៏ត្រូវពិចារណាចម្លើយនេះផងដែរ។ *សូមមើល* កថាខណ្ឌ ១៨៩ *ខាងលើ* ដែលពិភាក្សាពីសាក្សីរូបនេះ។

[2091] *រឿងក្តី ន្ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.08.12-14.12.12 (ឆ្លើយបញ្ជាក់ថា ទូកដែលចូលដែនទឹកជម្រៅ អាចនឹង ១០ ទៅ ១១ គីឡូម៉ែត្រ អាចត្រូវចាប់ ហើយទូកដែលនៅឆ្ងាយ អាចត្រូវដេញ ហើយបើគេបាញ់យើងមុន យើងនឹងបាញ់វិញ)។

[2092] *សូមមើល* កថាខណ្ឌ ២៥១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2093] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.២៩, ឆ.៤១។

[2094] កថាខណ្ឌ ១៤៦ ជើងទំព័រ ៤១៨ នៃដីកាសន្និដ្ឋានស្តាពរ។

ចម្ការធូរេន និង ចម្ការដូង[2095]។ គាត់មិនដែលបានឃើញអ្នកទោសណាម្នាក់ត្រូវបានគេយក ឬ សម្លាប់ចោលទៅទីនោះទេ[2096]។ គាត់បានសំដៅទៅលើតែឧបទ្វរហេតុមួយ ដែលទូកថៃបីត្រូវបានចាប់ខ្លួន ហើយអ្នកនៅលើទូកនោះត្រូវបានអះអាងថាត្រូវបានបញ្ជូនទៅចម្ការធូរេន។ គាត់មិនបានចូលរួមពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុនេះទេ[2097]។ ឯក នី បានឮមេដឹកនាំនៅលើកោះនិយាយថាជនជាតិថៃត្រូវបានសម្លាប់ចោលនៅចម្ការធូរេន និង ចម្ការដូង[2098]។ គាត់មិនបាននិយាយថា មាស មុត បានចេញបញ្ជាឱ្យសម្លាប់ជនជាតិថៃនៅចម្ការធូរេនចេងហេងឡើយ។

៥៧១. ស.ព.អ. ក៏បានដកស្រង់ផងដែរ នូវទូរលេខ និង របាយការណ៍ទាក់ទងនឹងទូកថៃ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានរាយការណ៍ជាទៀងទាត់ ឱ្យមជ្ឈិម អំពីការលួចទូកបរទេស[2099]។ ឯកសារទាំងនេះមិនគាំទ្រការអះអាងរបស់ ស.ព.អ. ទេ៖

- ឯកសារ **D1.3.27.18**៖ ស.ព.អ. ដកស្រង់កំណត់ហេតុកិច្ចប្រជុំអគ្គសេនាធិការនៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ដែលត្រូវបានអះអាងថា មាស មុត បាននិយាយថា ទូកនេសាទថៃចំនួន ១០០ ទៅ ១៥០ បានចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ ហើយទូកមួយត្រូវបានចាប់ខ្លួន[2100]។ របាយការណ៍ដែលថាទូកមួយត្រូវបានគេចាប់ មិនចង្អុលបង្ហាញពីការបញ្ជារួមឱ្យចាប់ទូកបរទេសទាំងអស់នោះទេ។

[2095] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.៣០-៣១។

[2096] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.៣៨ (ឆ្លើយថា គាត់បានឃើញអ្នកនេសាទថៃ និង អ្នកនេសាទវៀតណាមដែលត្រូវបានចាប់ខ្លួន នៅកោះតាង)។

[2097] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.២៩, ឆ.៣៦។

[2098] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.៣២។ *សូមមើលផងដែរ ដូចខាងលើ* ឆ.៤៣។

[2099] កថាខណ្ឌ ១៤៤-៤៥ ជើងទំព័រ ៤១៤-១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2100] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង កស្តុភារបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195340-00195341 KH 00052390-00052391 (ឯកសារនេះដូចគ្នានឹងឯកសារ D114/27.1.5 ដែល ស.ព.អ. ដកស្រង់នៅជើងទំព័រ)។ ជើងទំព័រ ៤១៤ នៃដីកាសន្និដ្ឋានស្តាពរ។

- ឯកសារ **D1.3.12.20**៖ ស.ព.អ ដកស្រង់របាយការណ៍ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ដែលទាក់ទងនឹងការចាប់ខ្លួនជនជាតិថៃចំនួន ៥ នាក់ នៅតំបន់កោះកុង[2101]។ ស.ព.អ. អះអាងថា នេះជារបាយការណ៍មួយរបស់ មាស មុត ផ្ញើទៅ សុន សេន[2102]។ មិនមានការចង្អុលបង្ហាញថា នរណាជាអ្នកធ្វើរបាយការណ៍ ដែលត្រូវបានគេអះអាងថាបានផ្អែកលើការនិយាយទូរស័ព្ទជាមួយនឹង មាស មុត នោះឡើយ[2103]។ ស.ព.អ. អះអាងថា របាយការណ៍នេះបង្ហាញពីការសង្ស័យដែលជនជាតិថៃត្រូវបានឃាត់ខ្លួនដោយ មាស មុត និង ឋានានុក្រម ប.ក.ក.[2104]។ ផ្ទុយទៅវិញ របាយការណ៍នេះបង្ហាញពីក្តីបារម្ភផ្នែកសន្តិសុខជាតិស្របច្បាប់។ អ្នករាយការណ៍បានកត់សម្គាល់ថា ជនជាតិថៃស្ថិតនៅចម្ងាយ ២ គីឡូម៉ែត្រ ពីកោះកុង លើទូក ១៧៥ សេះ ដោយគ្មានឧបករណ៍នេសាទ ហើយថា យន្តហោះបានហោះឆ្លែ ២ ទៅ ៣ គីឡូម៉ែត្រ ពីលើក្បាល នៅពេលទូកត្រូវបានគេនាំខ្លួន[2105]។ ដោយសមហេតុផល សុន សេន បានស្នើសុំឱ្យកំណត់ថា ទូកនោះមកពីណា ហើយទប់ស្កាត់កុំឱ្យមានករណីចូលដែនទឹកស្រដៀងគ្នានេះនៅពេលអនាគត[2106]។

- ឯកសារ **D54/11.1** (ដូចគ្នានឹងឯកសារ **D1.3.30.25**)៖ ស.ព.អ. ដកស្រង់របាយការណ៍ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ទៅឱ្យ សុន សេន[2107]។ របាយការណ៍នេះបង្ហាញថា មិនមានគោលនយោបាយ ប.ក.ក. ឱ្យធ្វើទុក្ខបុកម្នេញ និង សម្លាប់ជនជាតិថៃនោះទេ។

[2101] សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ "តាមទូរស័ព្ទសម្ងាត់" ចុះថ្ងៃទី ១២ ខែសីហាឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20។ ជើងទំព័រ ៥១៥-១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2102] កថាខណ្ឌ ១៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2103] សេចក្តីវាយការណ៍ ចំណងជើងថា "សេចក្តីវាយការណ៍ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់អំពីសភាពការណ៍នៅតាមព្រំដែនជាមួយប្រទេសថៃ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20។

[2104] កថាខណ្ឌ ១៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2105] សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់អំពីសភាពការណ៍នៅតាមព្រំដែនជាមួយប្រទេសថៃ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20។

[2106] សេចក្តីវាយការណ៍យោធា ចំណងជើងថា "សេចក្តីវាយការណ៍ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ តាមទូរស័ព្ទសម្ងាត់អំពីសភាពការណ៍នៅតាមព្រំដែនជាមួយប្រទេសថៃ" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.12.20 (ជាមួយនឹងចំណារ សុន សេន ឱ្យអង្គការស្ងួររកខ្សែខាងក្នុង និង រកផ្លូវចេញចូល)។ កថាខណ្ឌ ១៥៥ ជើងទំព័រ ៥១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2107] សេចក្តីវាយការណ៍យោធាពីកងពល ១៦៤ ផ្នែកនយោបាយ ចំណងជើង "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ឯកសារ D54/11.1។ ជើងទំព័រ ៥១៧ នៃដីកាសន្និដ្ឋានស្តាពរ។

របាយការណ៍នេះលើកឡើងអំពីការដោះលែងអ្នកជាប់ឃុំជនជាតិថៃនៅខែមីនា ឆ្នាំ ១៩៧៨ ប្រគល់ឱ្យរដ្ឋាភិបាលរបស់ពួកគេវិញ[2108]។

៥៧២. ស.ព.អ. អះអាងថា មាស មុត បានទទួលរបាយការណ៍លម្អិតថា បុគ្គលិកក្រោមបង្គាប់គាត់បាននឹងកំពុងសម្លាប់អ្នកនេសាទថៃ[2109]។ គាត់ដកស្រង់របាយការណ៍មួយដែលគាត់អះអាងថាជារបស់ ឌឹម ដែលជាអនុលេខារបស់ មាស មុត[2110]។ របាយការណ៍នេះមិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ របាយការណ៍នេះ គឺផ្ញើមកពី ស៊ីម មិនមែន ឌឹម ទេ។ ស៊ីម បានបញ្ជាការទូក PCF របស់កងពលធំលេខ ១៦៥ នៅខេត្តកោះកុង[2111]។ គាត់បានរាយការណ៍ថា ទូកដែលមានកម្លាំង ៣០០ និង ៤០០ សេះ ត្រូវបានចាប់បាននៅខាងត្បូងខេត្តកោះកុង បន្ទាប់ពីពួកគេ “ចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ”[2112]។ អ្នកនៅលើទូកខ្លះបានលោតចូលទឹក។ អ្នកផ្សេងទៀតត្រូវបានសម្លាប់ចោល[2113]។ គាត់មិនបាននិយាយថាតើអ្នកដែលនៅលើទូកនោះជានរណា[2114] ត្រូវបានសម្លាប់យ៉ាងម៉េច ឬ មានអ្វីកើតឡើងនៅមុនពេលទូកនោះចូលដែនដីកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ របាយការណ៍នេះ

[2108] សេចក្តីរាយការណ៍យោធាពីកងពល ១៦៥ ផ្នែកនយោបាយ ចំណងជើង “ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨” ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D54/11.1 EN 01147584 KH 00936715។

[2109] កថាខណ្ឌ ១៥៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2110] សេចក្តីរាយការណ៍ ចំណងជើងថា “សេចក្តីរាយការណ៍តាមទូរស័ព្ទសំងាត់ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧៧ ជូនបងកងពល ស្នេហា” ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.28 ។ ស.ព.អ. ដកស្រង់ឯកសារ D118/207.2 ដែលមិនមាននៅក្នុងសំណុំរឿងក្តី ០០៣ ទេ។ ឯកសារ ស.ព.អ. មានអត្ថបទបកប្រែភាសាអង់គ្លេសខុសគ្នាបន្តិចបន្តួចធៀបទៅនឹងឯកសារ D1.3.34.28។ ជើងទំព័រ ៥១៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2111] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង អុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ឆ.១៤ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.៣៣ (ដែលរៀបរាប់ឈ្មោះ ស៊ីម គឺជាមេបញ្ជាការកងអនុសេនាធំនៅក្នុងកងពលលេខ ៣)។

[2112] សេចក្តីរាយការណ៍ ចំណងជើងថា “សេចក្តីរាយការណ៍តាមទូរស័ព្ទសំងាត់ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧៧ ជូនបងកងពលស្នេហា” ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.28 EN 00233654 KH 00161729។

[2113] សេចក្តីរាយការណ៍ ចំណងជើងថា “សេចក្តីរាយការណ៍តាមទូរស័ព្ទសំងាត់ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧៧ ជូនបងកងពលស្នេហា” ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.28 EN 00233654 KH 00161729។

[2114] ស.ព.អ. អះអាងថា អ្នកជិះលើទូកទាំងអស់គឺជាអ្នកនេសាទ ប្រហែលដោយសារអត្ថបទបកប្រែជាភាសាអង់គ្លេសនៃទូរលេខចង្អុលបង្ហាញថាមាន“កូឡាំង” នៅលើទូកនេះ ដែលអ្នកបកប្រែភាសាបានកត់សម្គាល់ “ជាឈ្មោះនៃឧបករណ៍នេសាទ”។ សេចក្តីរាយការណ៍ ចំណងជើងថា “សេចក្តីរាយការណ៍តាមទូរស័ព្ទសំងាត់ជូនបងកងពល ស្នេហា” ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧៧ ឯកសារ D1.3.34.28 EN 00233654 KH 00161729។ ប៉ុន្តែ អត្ថន័យដើមនៃពាក្យនេះនៅក្នុងសេចក្តីរាយកាណ៍ដើមជាភាសាខ្មែរ គឺមិនច្បាស់ទេ។ សេចក្តីរាយការណ៍មិនបញ្ជាក់ច្បាស់អំពីអ្នកជិះលើទូកនេះទេ។

មិនមែនជារបាយការណ៍លម្អិតនៃការកាប់សម្លាប់ទេ។ វាគ្រាន់តែជារបាយការណ៍ស្តីពីការរឹបអូសទ្រុកចំនួនពីរដែលមនុស្សមួយចំនួនត្រូវបានសម្លាប់ប៉ុណ្ណោះ។

៥៧៣. ស.ព.អ. អះអាងថា ជនជាតិថៃរាប់រយនាក់បានបាត់ខ្លួន ឬ ត្រូវបានគេសម្លាប់ចោល នៅក្នុងតំបន់ក្រោមការទទួលខុសត្រូវរបស់ មាស មុត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងនោះរួមមានជនជាតិថៃចំនួន ៥៨ នាក់ ត្រូវបានបញ្ជូនពីកំពង់សោម ទៅមន្ទីរ ស-២១[2115]។ ស.ព.អ. ខកខានមិនបានបង្ហាញមូលដ្ឋានគាំទ្រការអះអាងទាំងនេះ។ *សូមមើល* ផ្នែក IV.ច ដែលពិភាក្សាអំពីការចោទប្រកាន់ទាក់ទងនឹងជនរងគ្រោះជនជាតិថៃ។ *សូមមើលផងដែរ* កថាខណ្ឌ ៥៩៥ ដល់កថាខណ្ឌ ៥៩៧ *ខាងក្រោម* ទាក់ទងនឹងឯកសាររបស់មន្ទីរ ស-២១ ស្តីពីមនុស្សដែលត្រូវបានអះអាងថាត្រូវបានចាប់ខ្លួននៅកំពង់សោម។

ii. មាស មុត មិនបានទទួលខុសត្រូវលើការចាប់ខ្លួន ឬ ការកាប់សម្លាប់ជនបស្ចិមប្រទេស

៥៧៤. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត ទទួលខុសត្រូវចំពោះការចាប់ខ្លួន និង ការកាប់សម្លាប់ជនបស្ចិមប្រទេស យ៉ាងហោចណាស់ ចំនួន ១០ នាក់ដែលត្រូវបានចាប់ខ្លួននៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ រួមទាំង អ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[2116]។ ស.ព.អ. ដកស្រង់ជាចម្បងចម្លើយដែលមិនអាចជឿជាក់បានរបស់ មាស មុត ឌុច Robert Hamill និង អែម សុន[2117]។ គាត់ក៏បានដកស្រង់ផងដែរ នូវភស្តុតាងឯកសារដែលមិនគួរឱ្យជឿជាក់បាន។ *សូមមើល* កថាខណ្ឌ ៥៩៥ ដល់កថាខណ្ឌ ៥៩៧ *ខាងក្រោម* ទាក់ទងនឹងឯកសាររបស់មន្ទីរ ស-២១ ស្តីពីប្រជាជនដែលត្រូវបានអះអាងថាត្រូវបានចាប់ខ្លួននៅកំពង់សាម។

៥៧៥. ស.ព.អ. ដកស្រង់ចម្លើយ ដែលអះអាងជាសម្តីរបស់ មាស មុត ឆ្លើយប្រាប់អ្នកនិពន្ធ *David Kattenberg* ថា កងពលធំលេខ ១៦៤ មិនទុកជនបស្ចិមប្រទេស និង អ្នកមកពីប្រទេសផ្សេងទៀតទេព្រោះ ប៉ុល ពត និង មេដឹកនាំជាន់ខ្ពស់បក្សដទៃទៀតខ្លាចពួកគេ[2118]។ បទសម្ភាសន៍នេះត្រូវបាន

[2115] កថាខណ្ឌ ១៤៧ ជើងទំព័រ ៤២០-២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2116] កថាខណ្ឌ ១៤៨-៤៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2117] ជើងទំព័រ ៤២២-២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2118] កថាខណ្ឌ ១៤៨ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ខ្សែអាត់សំឡេងនៃការសម្ភាសន៍ មាស មុត ជាមួយ David Kattenburg ខែមេសា ឆ្នាំ ២០០៩ ឯកសារ D54/16/1R 00:43:52-00:46:09។

ធ្វើឡើងដោយអង្គភាពមិនមែន អ.វ.ត.ក. ដោយគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ សម្រាប់គោលបំណងផ្សេងក្រៅពីការជំនុំជម្រះក្តីព្រហ្មទណ្ឌ។ វាមានតម្លៃជាភស្តុតាងតិចតួចណាស់[2119]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភស្តុតាងណាមួយដល់កិច្ចសម្ភាសន៍នេះ ស.ច.ស. ត្រូវពិចារណាថា ស.ព.អ. បានបកស្រាយចម្លើយរបស់ មាស មុត ខុស។ មាស មុត មិនបាននិយាយថា កងពលធំលេខ ១៦៥ បានសម្លាប់ជនបស្ចិមប្រទេស ឬ ថា ត្រូវដោះស្រាយជនបស្ចិមប្រទេសឱ្យបានឆាប់រហ័ស ព្រោះថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ខ្លាចពួកគេនោះឡើយ។ គាត់បាននិយាយថា មនុស្សមកពីភ្នំពេញ បានមកយកជនបស្ចិមប្រទេសទាំងនោះទៅ ហើយមេដឹកនាំដូចជា ប៉ុល ពត និង ខៀវ សំផន ដែលបានទទួលការអប់រំនៅប្រទេសបារាំង និង អឺរ៉ុប ប្រហែលអាចជាខ្លាចថា ពួកគេអាចស្គាល់អ្នកទាំងនោះ[2120]។

៥៧៦. **ឌុច៖** ឌុច មិនអាចជឿជាក់បានឡើយ[2121]។ គាត់បាននិយាយថា មានតែជនបស្ចិមប្រទេសចំនួន ៥ នាក់ប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[2122]។ បើទោះបីជាគាត់បាននិយាយថា កងពលធំលេខ ១៦៥ បានចាប់ខ្លួនពួកគេក៏ដោយ ក៏គាត់បាននិយាយផងដែរថា អគ្គសេនាធិការ ឬ គណៈកម្មាធិការអចិន្ត្រៃយ៍បានបញ្ជូនពួកគេទៅមន្ទីរ ស-២១[2123]។ ដូចដែល ឌុច បានកត់សម្គាល់ "សិទ្ធិ

[2119] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាអំពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[2120] ខ្សែអាត់សំឡេងនៃការសម្ភាសន៍ មាស មុត ជាមួយ David Kattenburg ខែមេសា ឆ្នាំ ២០០៩ ឯកសារ D54/16/1R នៅម៉ោង 00:43:15-00:45:57៖ "មុត៖ នែមែនទែន អត់មានកន្លែងឃុំទុកនៅកំពង់សោមទេ។ បើទុកយ៉ាងយូរ១អាទិត្យ ខាងភ្នំពេញគេទៅយកហើយ។ ... មុត៖ នៅកោះឬស្សីដូចគ្នា។ ហើយបើពួកអឺរ៉ុប អត់យូរទេ ២ថ្ងៃ ឬក៏យ៉ាងយូរ--យ៉ាងយូរ២ថ្ងៃខាងភ្នំពេញគេមកយក។ ... មុត៖ តាមខ្ញុំគិតទេ ខ្ញុំប៉ាន់ប្រមាណថាមើលមេខ្សែក្រហមប៉ុល ពតហ្នឹង ក៏ដោយ លោកខៀវ សំផន ក៏ដោយ សុទ្ធតែអ្នករៀននៅបារាំងអ្នករៀននៅអឺរ៉ុប ដូច្នេះខ្លាចគេប៉ះមិត្តភ័ក្តិរបស់គាត់។ អារឿងនេះ បើតាមខ្ញុំគិត ដែលល្អជាងគេ ឱកាសឥឡូវ ទៅសួរលោកស្ពឺ ឌុចនោះ។ បាទ"។

[2121] *សូមមើល* កថាខណ្ឌ ១៧៥-៧៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2122] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.4 EN 00198221 KH 00197971-00197972 ។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D98/3.1.93 នៅម៉ោង 00.23.07-09.58.00 (KH 00341891-00341892), 10.05.29-10.18.09។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០០៧ ឯកសារ D1.3.33.3 EN 00147527 KH 00146488។ ជើងចំពីរ ៤២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2123] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.4 EN 00198221 KH 00197971-00197972 (ឆ្លើយថា ពីរនាក់ក្នុងចំណោមនោះ ត្រូវបានបញ្ជូនមកឱ្យខ្ញុំដោយ សុន សេន និង ២ នាក់ទៀតដោយ នួន ជា) ។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/

សម្រេចឱ្យចាប់ទាល់តែមនុស្សដែលមានសិទ្ធិសម្រេចឱ្យកម្ទេច”[2124]។ ក្នុងករណីដែលសក្ខីកម្ម របស់គាត់មានតម្លៃជាភ័ស្តុតាងណាមួយនោះ ចម្លើយនេះបង្ហាញថា សុន សេន និង មជ្ឈិមបក្ស គឺជាអ្នកដែលទទួលខុសត្រូវចុងក្រោយលើការចាប់ខ្លួន និង ការកាប់សម្លាប់ជនបរទេស។

៥៧៧. **Robert Hamill**៖ Robert Hamill មិនអាចជឿជាក់បានឡើយ។ គាត់គឺជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០៣ និង ០០៤ ហើយជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០១ និង ០០២[2125]។ គាត់មានប្រយោជន៍យ៉ាងច្បាស់លាស់នៅក្នុងការកាត់ទោស និងការផ្តន្ទាទោសណាមួយដែលអាចមានចំពោះ មាស មុត។ Robert Hamill បានធ្វើការស៊ើបអង្កេតផ្ទាល់ខ្លួនរបស់គាត់ អំពីការបាត់ខ្លួនរបស់បងប្រុសគាត់ Keryy Hamill ហើយបានសម្ភាស មាស មុត[2126]។ គាត់បានផ្តល់សក្ខីកម្មក្នុងរឿងក្តី ០០១[2127]។ គាត់បានចូលរួមនៅក្នុងខ្សែភាពយន្ត ឯកសារដែលមានចំណងជើងថា *បងធំទី១* អំពីការបាត់ខ្លួនរបស់បងប្រុសគាត់[2128]។ គាត់បានអះអាងដោយមិនត្រឹមត្រូវថា មាស មុត បានសារភាពថា ជនបរទេសដែលត្រូវបានចាប់ខ្លួននៅ

អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/277.3 នៅម៉ោង 15.08.51-15.11.37 (ឆ្លើយថាជនជាតិអាមេរិកាំងនេះ ចាប់បញ្ជូនដោយកងពលសមុទ្រពីកំពង់សោមមកភ្នំពេញ គឺបញ្ជូនមកគណៈមជ្ឈិម ហើយមជ្ឈិមបញ្ជូនមក ស-២១)។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D98/3.1.93 នៅម៉ោង 00.23.07-09.58.00 (00341891- 00341892), 10.05.29-10.18.09 (ឆ្លើយថាជនបស្ចិមប្រទេស ប្លននាក់ សុទ្ធតែពួកកងពល ១៦៥ ចាប់ទាំងអស់ ហើយបញ្ជូនមក ស-២១ តាមគណៈអចិន្ត្រៃយ៍មជ្ឈិម ឬតាមរយៈសេនាធិការ)។ កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០០៧ ឯកសារ D1.3.33.3 EN 00147527 KH 00146488 (ឆ្លើយថា ជនបស្ចិមប្រទេសបួននាក់ ត្រូវបានចាប់នៅក្នុងដែនសមុទ្រខ្មែរដោយកងសមុទ្រ ហើយចាប់បញ្ជូនមកឱ្យ នួន ជា)។

[2124] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ D98/3.1.93 នៅម៉ោង 09.58.00។

[2125] របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី Robert Hamill ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១១ ឯកសារ D11/2/1 EN 00681103។ *សូមមើល* កថាខណ្ឌ ១៤២ *ខាងលើ* ដែលបានពិភាក្សាពីការប្រើប្រាស់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[2126] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី Robert Hamill ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២ ឯកសារ D37 EN 00791865-00791867 KH 00945760-00945765។

[2127] របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី Robert Hamill ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១១ ឯកសារ D11/2/1 EN 00681103។ ប្រតិចារឹក *បងធំទីមួយ* (ឆ្នាំ ២០១១) ឯកសារ D114/307.5 EN 01389343, 01389351 KH 01505916-01505918, 01505944-01505947 (យោងសក្ខីកម្មរបស់គាត់ក្នុងរឿងក្តី ០០១)។

[2128] *សូមមើលឧទា.* ប្រតិចារឹក *បងធំទីមួយ* (ឆ្នាំ ២០១១) ឯកសារ D114/307.5។

សមុទ្រ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[2129]។ ការអះអាងនេះបានផ្អែកលើបទសម្ភាសន៍របស់គាត់ជាមួយ មាស មុត[2130]។ បទសម្ភាសន៍នេះត្រូវបានធ្វើឡើងដោយអង្គភាពមិនមែន អ.វ.ត.ក. ដោយគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ សម្រាប់គោលបំណងផ្សេងក្រៅពីការជំនុំជម្រះក្តីព្រហ្មទណ្ឌ។ វាមានតម្លៃជាភស្តុតាងតិចតួចណាស់[2131]។ យោងតាមប្រតិចារឹកខ្សែភាពយន្តឯកសារ *បងធំទី១* មាស មុត បាននិយាយថា ជនបរទេសដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ត្រូវបានបញ្ជូនទៅភ្នំពេញ[2132]។ គាត់មិនបាននិយាយថា ពួកគេត្រូវបានបញ្ជូនទៅមន្ទីរ ស -២១ នោះទេ។

៥៧៨. **អែម សុន៖** អែម សុន មិនអាចជឿជាក់បានឡើយ[2133]។ គាត់បានអះអាងថា អ្នកកាន់វិទ្យុទាក់ទងនៃកងពលធំលេខ ១៦៥ បាននិយាយថា មាស មុត បានបញ្ជាឱ្យបញ្ជូនទូកទៅកោះតាង ដើម្បីនាំទាហានអាមេរិកទៅដីគោក[2134]។ អែម សុន បានឆ្លើយផ្ទុយគ្នាទាក់ទងនឹងហេតុការណ៍នេះ ដែលចម្លើយខ្លះត្រូវបាន ក.ស.ច.ស. កត់សម្គាល់ហើយ[2135]។

៥៧៩. ស.ព.អ. ក៏ដកស្រង់ផងដែរ នូវចម្លើយចេញពីសៀវភៅរបស់ *David Kattenburg* គឺ *Foxy Lady: Truth, Memory & the Death of Western Yachtsmen in Democratic Kampuchea* ដោយបានសង្ខេបបទសម្ភាសន៍ POW/MIA ដែលអតីតសមាជិកកងពលធំលេខ ១៦៥ ត្រូវបានអះអាងថាបានសំដៅពីការចាប់ខ្លួនជនបរទេសនៅសមុទ្រ[2136]។ អ្នកនិពន្ធដកស្រង់របាយការណ៍

[2129] កំណត់ហេតុនៃការស្តាប់ចម្លើយជើមបណ្តឹងរដ្ឋប្បវេណី Robert Hamill ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១២ ឯកសារ D37 EN 00791867 KH 00945765 (ឆ្លើយថា មាស មុត និយាយថា ជនបរទេស "គួរត្រូវបានបញ្ជូនទៅស-២១") ។ ជើងទំព័រ ៤២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2130] *សូមមើលខគ.* ប្រតិចារឹក *បងធំទីមួយ* (ឆ្នាំ ២០១១) ឯកសារ D114/307.5 EN 01389355-01389356 KH 01505957-01505963។

[2131] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ដែលពិភាក្សាអំពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។ Robert Hamill បានបង្ហាញថា គាត់ចង់ផ្តល់កិត្តិយសទៅឱ្យការចងចាំអំពីបងប្អូនប្រុសរបស់គាត់ និង ដឹងពីការពិតដែលកើតមានឡើងចំពោះបងប្អូនប្រុសរបស់គាត់។ ប្រតិចារឹក *បងធំទីមួយ* (ឆ្នាំ ២០១១) ឯកសារ D114/307.5 នៅម៉ោង 01.05.57-01.06.15។

[2132] ប្រតិចារឹក *បងធំទីមួយ* (ឆ្នាំ ២០១១) ឯកសារ D114/307.5 នៅម៉ោង 01.44.18-01.44.32។

[2133] *សូមមើល* កថាខណ្ឌ ២៣៦, ២៤៤, ៣៤៩, ៤១៦ និង ៥១៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2134] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/48 អ.១៧-១៩ ។ កថាខណ្ឌ ១៤៩ ជើងទំព័រ ៤២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2135] *សូមមើល* កថាខណ្ឌ ៣៤៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីចម្លើយផ្ទុយគ្នារបស់ អែម សុន។

[2136] ជើងទំព័រ ៤២៤ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ DAVID KATTENBURG ចំណងជើងថា FOXY LADY៖ ការពិត ការចងចាំ និង ការស្តាប់របស់ម្ចាស់ទូកបស្ចឹមប្រទេសនៅក្នុងកម្ពុជាប្រជាធិបតេយ្យ (TRUTH, MEMORY & THE DEATH OF

ចំនួន ៤ របស់ POW/MIA[2137]។ ទាំងសៀវភៅ ទាំងរបាយការណ៍ មិនត្រូវបានសរសេរសម្រាប់គោលបំណងនៃការជំនុំជម្រះក្តីព្រហ្មទណ្ឌនោះទេ[2138]។ ប្រភពរបស់ POW/MIA មិនត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងរបាយការណ៍នោះឡើយ ហើយសេចក្តីថ្លែងការណ៍ជាច្រើនរបស់ពួកគេគឺផ្អែកទៅលើពាក្យចចាមអារ៉ាម[2139]។

គ. សេចក្តីសន្និដ្ឋាន

៥៨០. មាស មុត មិនបានទទួលខុសត្រូវ ហើយក៏មិនបានចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ ឬ ការសម្លាប់ជនជាតិវៀតណាម ថៃ ឬ ជនបស្ចិមប្រទេសនោះដែរ។ គណៈកម្មាធិការអចិន្ត្រៃយ៍ និង អគ្គសេនាធិការធ្វើការសម្រេចចិត្តបែបនេះ ដែលត្រូវបានអនុវត្តរួមគ្នាដោយគណៈកម្មាធិការកងពលធំលេខ ១៦៥។ ភ័ស្តុតាងប្រវត្តិសាស្ត្រ និង បរិបទពាក់ព័ន្ធបង្ហាញថា ការចាប់ខ្លួន ឬ សម្លាប់ជនជាតិវៀតណាម ត្រូវបានធ្វើឡើង ដើម្បីការពារប្រឆាំងនឹងការលុកលុយ និង ការឈ្លានពានរបស់ប្រទេសវៀតណាម។ គ្មានបញ្ហារួមឱ្យចាប់យកទូកបរទេសទាំងអស់ ដែលចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យនោះទេ។ មជ្ឈិមបក្សបានណែនាំថា ជនភៀសខ្លួនអាចត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរទៅកាន់គោលដៅរបស់ពួកគេ ហើយទូកនឹងមិនត្រូវបានបាញ់នោះទេ លុះត្រាតែពួកគេបានបាញ់មកលើទូកកងទ័ពបដិវត្តន៍កម្ពុជាមុន។ គោលនយោបាយរបស់មជ្ឈិមបក្ស ផ្តោតទៅលើការព្រួយបារម្ភផ្នែកសន្តិសុខជាតិស្របច្បាប់ ទាក់ទងនឹងជនបរទេសដែលចូលក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ

WESTERN YACHTSMEN IN DEMOCRATIC KAMPUCHEA) ទំព័រ ១៥៩ (Key Publishing House, Inc., ឆ្នាំ ២០១១) ឯកសារ D88.1.17 EN 00916182។

[2137] DAVID KATTENBURG ចំណងជើងថា FOXY LADY៖ ការពិត ការចងចាំ និង ការស្លាប់របស់ម្ចាស់ទូកបស្ចិមប្រទេសនៅក្នុងកម្ពុជាប្រជាធិបតេយ្យ (TRUTH, MEMORY & THE DEATH OF WESTERN YACHTSMEN IN DEMOCRATIC KAMPUCHEA) ទំព័រ ២៧៥ (Key Publishing House, Inc. ឆ្នាំ ២០១១) ឯកសារ D88.1.17 EN 00916298។ របាយការណ៍ POW/MIA ទាំងបីដែលគាត់ដកស្រង់គឺមាននៅក្នុងសំណុំរឿង៖ របាយការណ៍ Stony Beach POW/MIA ខែវិច្ឆិកា ឆ្នាំ ២០០៥ ឯកសារ D4.1.758 របាយការណ៍ Stony Beach POW/MIA ខែមេសា ឆ្នាំ ២០០៦ ឯកសារ D4.1.760 របាយការណ៍ Stony Beach POW/MIA ខែកុម្ភៈ ឆ្នាំ ២០០៧ ឯកសារ D4.1.761។

[2138] *សូមមើល* កថាខណ្ឌ ១៣៩ *ខាងលើ* ដែលពិភាក្សាអំពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[2139] របាយការណ៍ Stony Beach POW/MIA ខែវិច្ឆិកា ឆ្នាំ ២០០៥ ឯកសារ D4.1.758 EN 00387310-00387311 KH 00387310-00387313។ របាយការណ៍ Stony Beach POW/MIA ខែមេសា ឆ្នាំ ២០០៦ ឯកសារ D4.1.760 EN 00387293 KH 00724029-00724030។ របាយការណ៍ Stony Beach POW/MIA ខែកុម្ភៈ ឆ្នាំ ២០០៧ ឯកសារ D4.1.761 EN 00387297 KH 00157820-00157821។

ដោយខុសច្បាប់។ បើទោះបីជា ស.ច.ស. រកឃើញថា មាស មុត អាចទទួលខុសត្រូវចំពោះអំពើបែបនេះក៏ដោយ ក៏ការចាប់ខ្លួន ការឃុំឃាំង ឬ ការសម្លាប់ជនបរទេសនៅក្នុងដែនទឹក ឬ នៅជុំវិញដែនទឹកកម្ពុជាប្រជាធិបតេយ្យ មិនមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ដំឡើងឱ្យ មាស មុត ស្ថិតនៅក្នុងប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។

១១. មាស មុត មិនមែនជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះអ្នកដែលត្រូវបញ្ជូនទៅមន្ទីរ ស-២១

៥៨១. មាស មុត មិនបានទទួលខុសត្រូវចំពោះមនុស្សពីកងពលធំលេខ ១៦៥ ឬ កំពង់សោម ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ នោះទេ។ ការចូលរួមប្រជុំអគ្គសេនាធិការ ដែលក្នុងនោះតំណាងពីមន្ទីរ ស-២១ មានវត្តមាន មិនមានន័យថា មាស មុត ឬ គណៈកម្មាធិកងពលធំលេខ ១៦៥ បានដឹងអំពីគោលបំណង និង ការងាររបស់មន្ទីរ ស-២១ នោះទេ។ គ្មានភ័ស្តុតាងឯកសារបង្ហាញថា មាស មុត បានបញ្ជូនជនស៊ីវិល ឬ ទាហានទៅមន្ទីរ ស-២១ នោះឡើយ។ បើទោះបីជា ស.ច.ស. រកឃើញថា មាស មុត ជាអ្នកទទួលខុសត្រូវចំពោះមនុស្សចំនួន ៧០៦ នាក់ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១ ពីកងពលធំលេខ ១៦៥ និង កំពង់សោមក៏ដោយ ក៏នៅពេលពិចារណាលើចំនួនសរុបនៃជនរងគ្រោះនៅមន្ទីរ ស-២១ ជនរងគ្រោះចំនួន ៧០៦ នាក់នោះ មិនមែនជាចំនួនធ្ងន់ធ្ងរគ្រប់គ្រាន់ សម្រាប់ដំឡើងឱ្យ មាស មុត ស្ថិតនៅក្នុងប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។

ក. ទំនាក់ទំនងរវាង មាស មុត និង តំណាងមន្ទីរ ស-២១ នៅកិច្ចប្រជុំអគ្គសេនាធិការ មិនមានន័យថា មាស មុត បានដឹងពីអ្វីដែលមន្ទីរ ស-២១ បានធ្វើ

៥៨២. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានចូលរួមក្នុងកិច្ចប្រជុំអគ្គសេនាធិការ ជាមួយអ្នកតំណាងមន្ទីរ ស-២១ ឬ បានដឹងអំពីការងាររបស់មន្ទីរ ស-២១ នោះទេ[2140] ។ ស.ព.អ. ដកស្រង់សក្ខីកម្មរបស់ឌុច កំណត់ហេតុកិច្ចប្រជុំអគ្គសេនាធិការ និង សេចក្តីថ្លែងការណ៍ដែលអះអាងថាធ្វើឡើងដោយ មាស មុត[2141]។ យ៉ាងច្រើនណាស់

[2140] កថាខណ្ឌ ៥៤០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៥៣៦។

[2141] ដើងចំព័រ ២០១៧, ២០៣៦-៣៩ នៃដីកាសន្និដ្ឋានស្តាពរ។

ភ័ស្តុតាងនេះបង្ហាញថា អ្នកតំណាងមន្ទីរ ស-២១ បានចូលរួមកិច្ចប្រជុំអគ្គសេនាធិការមួយចំនួន ប៉ុន្តែមិនបានពិភាក្សាអំពីការចាប់ខ្លួន ចម្លើយសារភាព ឬ ទារុណកម្មនោះទេ។

៥៨៣. **ឌុច៖** ឌុច មិនអាចជឿជាក់បានឡើយ[2142]។ ចម្លើយរបស់គាត់អំពីវត្តមានរបស់មន្ទីរ ស-២១ នៅក្នុងកិច្ចប្រជុំជាមួយលេខាកងពលធំយ៉ាងណាក៏ដោយ បង្ហាញថា លេខាកងពលមិនបានដឹងអំពីវិសាលភាពនៃសកម្មភាពរបស់មន្ទីរ ស-២១ នោះទេ។ ឌុច បាននិយាយថា បុគ្គលិកក្រោមបង្គាប់របស់គាត់ នន់ ហ៊ុយ បានចូលរួមកិច្ចប្រជុំអគ្គសេនាធិការ ប៉ុន្តែត្រូវបានអនុញ្ញាតឱ្យនិយាយតែអំពីបញ្ហាដូចជាការបង្កបង្កើនផល និង បញ្ហាភស្តុភារផ្ទៃក្នុងជាដើម[2143]។ ឌុច ក៏បាននិយាយផងដែរថា មានតែមាគ៌ានយោបាយទូទៅតែប៉ុណ្ណោះ ដែលត្រូវបានគេពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនេះ មិនមែនជាការចាប់ខ្លួនជាក់លាក់នោះទេ[2144]។ ការងាររបស់ ឌុច គឺដាច់ដោយឡែកពីការងារកងពលធំ និងកងវរសេនាធំឯករាជ្យ។ ពួកគេមិនយល់ពីការងាររបស់គាត់ទេ។ “ខ្ញុំរាយការណ៍ពីអានេះអីចេះចម្លើយអានោះអីចុះ អីៗ ដូច្នេះគេមិនឱ្យខ្ញុំទៅប្រជុំទេ ប្រជុំអីចឹងៗ [ថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧៦]”[2145]។ បញ្ហាទាំងនេះត្រូវបានរាយការណ៍នៅក្នុងការប្រជុំសម្ងាត់ ឬ ការហៅទូរស័ព្ទរវាង សុន សេន និង ឌុច មិនមែននៅក្នុងកិច្ចប្រជុំធំៗ ជាមួយ កងវរសេនាធំឯករាជ្យ និង កងពលធំឡើយ[2146]។

៥៨៤. ស.ព.អ. ដកស្រង់កំណត់ហេតុប្រជុំអគ្គសេនាធិការពីថ្ងៃទី ២ ខែសីហា ឆ្នាំ ១៩៧៦ ដល់ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦[2147] ដែលបង្ហាញពីសិទ្ធិអំណាចដែលមានកម្រិតរបស់តំណាងមន្ទីរ ស-២១ នៅក្នុងកិច្ចប្រជុំអគ្គសេនាធិការនោះ។ តំណាងមន្ទីរ ស-២១ បានរាយការណ៍អំពីការផលិតអាហារ

[2142] *សូមមើល* កថាខណ្ឌ ១៧៥-៧៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2143] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨ ឯកសារ D4.1.1106 EN 00164330 KH 00164321។ ជើងទំព័រ ២០១៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2144] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨ ឯកសារ D4.1.1106 EN 00164330 KH 00164321។

[2145] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/277.8 នៅម៉ោង 15.26.38 ។

[2146] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364071-00364072 KH 00357492-00357494។ *សូមមើលផងដែរ រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.6 នៅម៉ោង 09.26.36-09.32.55។

[2147] ជើងទំព័រ ២០១៧, ២០៣៦-៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

បញ្ហាខ្សាំងផ្នែកក្នុង សុខភាព និង ស្ថានភាពបក្ស[2148]។ គាត់មិនបានរាយការណ៍អំពីការចាប់ខ្លួន ចម្លើយ សារភាព ឬ ការធ្វើទារុណកម្មនៅមន្ទីរ ស-២១ នោះទេ។ ផ្ទុយពីការអះអាងរបស់ ស.ព.អ.[2149] មិនមានការបង្ហាញណាមួយពី មាស មុត ឬ នរណាម្នាក់ មកពីកងពលធំលេខ ១៦៥ ថា បានចូលរួមក្នុងកិច្ចប្រជុំទាំងនេះនោះទេ។ ស.ព.អ. ក៏បានដកស្រង់ផងដែរ នូវកំណត់ហេតុកិច្ចប្រជុំមួយនៅថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ដែលក្នុងនោះ ស៊ូ ម៉ែត បានរាយការណ៍ថា "សមាសភាពមិនល្អ" ចំនួនជាង ៥០នាក់ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[2150]។ មាស មុត មិនបានចូលរួមការប្រជុំនេះទេ[2151]។ បើទោះបីជាគាត់បានចូលរួមកិច្ចប្រជុំនេះមែនក៏ដោយ ក៏កំណត់ហេតុកិច្ចប្រជុំមិនបានបង្ហាញថា គាត់អាចដឹងអំពីមន្ទីរ ស-២១ គោលបំណងរបស់មន្ទីរនេះ ឬ សកម្មភាពដែលបានកើតឡើងនៅទីនោះឡើយ។ មានឧទាហរណ៍ពីរអំពីកំណត់ហេតុកិច្ចប្រជុំអគ្គសេនាធិការដែលក្នុងនោះកងពលធំនីមួយៗបានរាយការណ៍ឱ្យ សុន សេន អំពីអ្នកដែលត្រូវបានចាប់ខ្លួន ក្នុងពេល ឌុច មានវត្តមាន[2152]។ ឌុចបាននិយាយថា កិច្ចប្រជុំប្រភេទនេះកើតឡើងតែពីរដងប៉ុណ្ណោះនៅក្នុងវត្តមានរបស់គាត់ ហើយមានតែការប្រជុំមួយប៉ុណ្ណោះដែលត្រូវបានរាយការណ៍[2153]។

៥៨៥. ស.ព.អ. ដកស្រង់ កិច្ចសម្ភាសពីរ ដែលមិនអាចជឿជាក់បានរបស់អ្នកសារព័ត៌មាន ជាមួយ មាស មុត[2154] ដែលគាត់អះអាងថា មានសេចក្តីថ្លែងផ្ទុយគ្នារបស់ មាស មុត អំពីការចាប់ខ្លួននៅ

[2148] *សូមមើលខាង.* កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195344 KH 00052393។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង អនុលេខាកងពល លេខា និង អនុលេខាវរសេនាធំ" ចុះថ្ងៃទី ២ ខែសីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.10 EN 00656573-00656574 KH 00052355-00052356។

[2149] កថាខណ្ឌ ៥៤០ ជើងទំព័រ ២០៣៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2150] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា-អនុលេខាកងពល និង វរសេនាធំឯករាជ្យ" ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.27.26 EN 00933834 KH 00052304-00052305។

[2151] *សូមមើល* កថាខណ្ឌ ៣០៥ *ខាងលើ* ទាក់ទងនឹងការប្រជុំនេះ។

[2152] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំខាងមន្ទីរអង្គការ ៧០៣ និង ស-២១" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.15។ កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្តតាល់ កងពល ២៩០ និង កងពល ១៧៩" ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.17។

[2153] កំណត់ហេតុនៃការស្តាចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨ ឯកសារ D4.1.1106 EN 00164328-00164329 KH 00164318។

[2154] ជើងទំព័រ ២០៣៨-៣៩ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ប្រតិចារឹក ចំណងជើងថា "កិច្ចសម្ភាសន៍ មាស មុត ជាអតីតលេខាធិការគណៈកម្មាធិការមជ្ឈិមសម្រាប់កងពលលេខ ១៦៥" ចុះថ្ងៃទី ២០ ខែកក្កដា - ថ្ងៃទី ២ ខែសីហា ឆ្នាំ ២០០១ ឯកសារ

មន្ទីរ ស-២១ និង កងពលធំលេខ ១៦៥។ ដំបូង គាត់និយាយថា គ្មាននរណាម្នាក់មកពីកងពលធំលេខ ១៦៥ ត្រូវបានចាប់ខ្លួន ហើយបន្ទាប់មកនិយាយថា អ្នកខ្លះត្រូវបានចាប់ខ្លួនដោយខុច ប៉ុន្តែគាត់មិនដឹងថាមានចំនួនប៉ុន្មាននាក់ទេ[2155]។ ឯកសារ D1.3.33.16 គឺជាប្រតិចារឹកនៃបទសម្ភាសន៍មួយដែលក្នុងនោះអ្នកសម្ភាសន៍បានសួរ មាស មុត អំពីរបាយការណ៍ដែលមិនត្រូវបានគេស្គាល់ថាជាអ្វី[2156]។ គ្មានខ្សែអាត់សំឡេងនៃបទសម្ភាសន៍នេះនៅក្នុងសំណុំរឿងទេ។ យើងមិនអាចផ្ទៀងផ្ទាត់ថាឯកសារនេះ ជាឯកសារពិតប្រាកដឬយ៉ាងណាឡើយ។ ឯកសារ D1.3.7.8 គឺជាអត្ថបទ *ការសែតឌីវែមបូឌាដេលី* ដែលមានកិច្ចសម្ភាសន៍ដែលអះអាងថាជារបស់ មាស មុត[2157]។ គ្មានខ្សែអាត់សំឡេង ឬ ប្រតិចារឹកនៃបទសម្ភាសន៍នេះនៅក្នុងសំណុំរឿងឡើយ។ កិច្ចសម្ភាសន៍ទាំងនេះត្រូវបានធ្វើឡើងដោយអង្គភាពខាងក្រៅ ដោយគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ សម្រាប់គោលបំណងផ្សេងក្រៅពីការជំនុំជម្រះក្តីព្រហ្មទណ្ឌ។ កិច្ចសម្ភាសន៍ទាំងនេះមានតម្លៃជាភស្តុតាងតិចតួចណាស់[2158]។

៥៨៦. ស.ព.អ. មិនបានភ្ជាប់ មាស មុត ជាមួយនឹងមន្ទីរ ស-២១។ ភស្តុតាងមិនបានបង្ហាញថា អ្នកចូលរួមក្នុងកិច្ចប្រជុំអគ្គសេនាធិការបានដឹងអំពីទំហំនៃប្រតិបត្តិការទាំងស្រុងរបស់មន្ទីរ ស-២១ នោះឡើយ។ អ្នកតំណាងមន្ទីរ ស-២១ មិនបានពិភាក្សាអំពីការចាប់ខ្លួន ការធ្វើទារុណកម្ម ឬ ចម្លើយសារភាពនៅក្នុងកិច្ចប្រជុំនោះទេ។ មិនមានភស្តុតាងបង្ហាញពីកិច្ចប្រជុំរវាង មាស មុត កងពលធំលេខ ១៦៥ និង គណៈកម្មាធិការតំបន់ស្វយ័តកំពង់សោម អគ្គសេនាធិការ និង នរណាម្នាក់មកពី

D1.3.33.16 EN 00089661-00089662 KH 00283078-00283080។ Erika Kinetz និង Yun Samean *អ្វីដែលកន្លងហួស ឱ្យហួសទៅចុះ* សារព័ត៌មានខេមបូឌាឌែលី ចុះថ្ងៃទី ១-២ ខែមីនា ឆ្នាំ ២00៨ ឯកសារ D1.3.7.8 EN 00165821។

[2155] ប្រតិចារឹក ចំណងជើងថា "កិច្ចសម្ភាសន៍ មាស មុត ជាអតីតលេខាធិការគណៈកម្មាធិការមជ្ឈឹមសម្រាប់កងពលលេខ ១៦៥" ចុះថ្ងៃទី ២0 ខែកក្កដា - ថ្ងៃទី ២ ខែសីហា ឆ្នាំ ២00១ ឯកសារ D1.3.33.16 (ឯកសារនេះគឺដូចគ្នានឹងឯកសារ D22.2.180 ដែរ)។

[2156] ប្រតិចារឹក ចំណងជើងថា "កិច្ចសម្ភាសន៍ មាស មុត ជាអតីតលេខាធិការគណៈកម្មាធិការមជ្ឈឹមសម្រាប់កងពលលេខ ១៦៥" ចុះថ្ងៃទី ២0 ខែកក្កដា - ថ្ងៃទី ២ ខែសីហា ឆ្នាំ ២00១ ឯកសារ D1.3.33.16 EN 00089661 KH 00283078-00283079។

[2157] Erika Kinetz និង Yun Samean *អ្វីដែលកន្លងហួស ឱ្យហួសទៅចុះ* សារព័ត៌មានឌីខេមបូឌាឌែលី ចុះថ្ងៃទី ១-២ ខែមីនា ឆ្នាំ ២00៨ ឯកសារ D1.3.7.8 EN 00165820-00165822។

[2158] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* សម្រាប់ការលើកឡើងបន្ថែមពីការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

មន្ទីរ ស-២១ ដែលនៅពេលនោះមានការពិភាក្សាពីការចាប់ខ្លួន ឬ ផ្ទេរមនុស្សពីកងពលធំលេខ ១៦៥ ឬ កំពង់សោមទៅមន្ទីរ ស-២១ ឡើយ។

ខ. មាស មុត មិនបានទទួលខុសត្រូវចំពោះអ្នកទោសកងពលធំលេខ ១៦៥ កំពង់សោម ឬ អ្នកទោសផ្សេងទៀតដែលបញ្ជូនទៅមន្ទីរ ស-២១

i. មាស មុត មិនបានដើរតួនាទីសំខាន់នៅក្នុងការសម្រេចថាបញ្ជូននរណាទៅមន្ទីរ ស-២១

៥៨៧. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត (និង លេខាកងពល និង ប្រធានអង្គភាពផ្សេងទៀត) មានការទទួលខុសត្រូវរួមគ្នានៅក្នុងមជ្ឈិមចំពោះការសម្រេចថាតើត្រូវចាប់ខ្លួន និង បញ្ជូនអ្នកណាពីកងពលធំលេខ ១៦៥ និង កំពង់សោម ទៅមន្ទីរ ស-២១ ឡើយ[2159]។ ស.ព.អ. ដកស្រង់ចម្លើយសាក្សីដែលមិនអាចជឿជាក់បាន និង មិនពាក់ព័ន្ធ របស់ ឌុច អោម សែ ហាំ អនស៊ី សៅ សារុន ភី ភួន សួង ស៊ីគឿន និង សាឡុត បាន[2160]។ ស.ព.អ. ក៏បានដកស្រង់ផងដែរ នូវភស្តុតាងឯកសារដែលមិនជាប់ទាក់ទងនឹងកងពលធំលេខ ១៦៥ ឬ កំពង់សោម ដែលមិនបានបង្ហាញថា មាស មុត បានចូលរួមសម្រេចចិត្តក្នុងការចាប់ និង បញ្ជូនអ្នកណាពីកងពលធំ ១៦៥ និង កំពង់សោម ទៅមន្ទីរ ស-២១[2161]។

៥៨៨. **ឌុច៖** ឌុច មិនអាចជឿជាក់បានឡើយ[2162]។ គាត់បានធ្វើការអះអាងជាច្រើនអំពីដំណើរការដែល សុន សេន បានអនុវត្ត បន្ទាប់ពី ឌុច បានផ្ញើចម្លើយសារភាព ឬ បញ្ជើឈ្មោះទៅគាត់[2163]។ គាត់បានអះអាងថា នៅពេលដែលនរណាម្នាក់នៅក្នុងអង្គភាពមួយត្រូវបានគេឆ្លើយដាក់ នៅក្នុងចម្លើយសារភាពនោះ ចម្លើយសារភាព ឬ ឈ្មោះនឹងត្រូវបញ្ជូនទៅប្រធានអង្គភាពដើម្បីផ្តល់យោបល់ ជាការជូនដំណឹងដល់ប្រធានអង្គភាពអំពីសកម្មភាពខ្លាំងផ្ទៃក្នុង ដើម្បីឱ្យប្រធានអង្គភាពពិចារណាចាប់

[2159] កថាខណ្ឌ ៥៣៩ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១០៦។

[2160] ជើងទំព័រ ២០៣០-៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2161] ជើងទំព័រ ២០៣២-៣៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2162] *សូមមើល* កថាខណ្ឌ ១៧៥-៧៦ *ខាងលើ* ដែលពិភាក្សាប្រភេទខុសគ្នាៗនៃព័ត៌មានដែល ឌុច បានលាតត្រដាងក្នុងអំឡុងពេលរឿងក្តី ០០១។

[2163] ជើងទំព័រ ២០៣០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ៣១១-១២ ។

ខ្លួនបុគ្គលជាប់ពាក់ព័ន្ធនោះ[2164]។ វាមិនបង្ហាញច្បាស់ទេថា គាត់បានដឹងអំពីដំណើរការនេះក្នុងរបប កម្ពុជាប្រជាធិបតេយ្យ[2165]។ ឌុច បានដឹងពីសេចក្តីណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង គណៈកម្មាធិការមជ្ឈិមចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ ស្តីពីការកម្ទេច តែក្នុងរឿងក្តី ០០១ ប៉ុណ្ណោះ[2166]។ គាត់ក៏បានដឹងផងដែរ ថាចម្លើយសារភាព ស-២១ មានចំណារ តែក្នុងអំឡុងពេលរឿងក្តី ០០១ ប៉ុណ្ណោះ[2167]។ សេចក្តីថ្លែងណាមួយដែលគាត់បានឆ្លើយទាក់ទងនឹងគោលនយោបាយបោសសម្អាតរបស់បក្ស ឬ ការបោសសម្អាត គឺមានតម្លៃជាភស្តុតាងតិចតួចណាស់[2168]។ ទោះជាយ៉ាងនេះក្តី ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភស្តុតាងដល់សក្ខីកម្មរបស់ ឌុច ស.ច.ស. ត្រូវពិចារណាលើសក្ខីកម្មរបស់គាត់ ដែលលើកឡើងអំពីសិទ្ធិអំណាចចុងក្រោយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និង របស់ សុន សេន ក្នុងការការចាប់ខ្លួន។

៥៨៩. ឌុច បាននិយាយថា សុន សេន មានអំណាចសម្រេចចិត្តចុងក្រោយលើការចាប់ខ្លួន និង ការកាប់សម្លាប់នៅក្នុងកងពលធំមជ្ឈិម[2169]។ បើទោះបីជា សុន សេន បានស្នើសុំប្រធានអង្គភាពឱ្យផ្តល់

[2164] *សូមមើលឧទា.* កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D4.1.404 EN 00242932 KH 00242921។

[2165] *សូមមើល* កថាខណ្ឌ ១៧៥-៧៦ *ខាងលើ* ដែលទាក់ទងទៅនឹងរបៀបដែលការដឹងរបស់ ឌុច បានវិវត្តន៍ឡើងនៅក្នុងអំឡុងពេលនៃការចូលរួមរបស់គាត់ក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក.។

[2166] *សូមមើល* ជើងទំព័រ ៥៩០ *ខាងលើ*។

[2167] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D4.1.860 EN 00403921 KH 00403909-00403910។

[2168] *សូមមើលឧទា.* កថាខណ្ឌ ៣៣២ នៃដីកាសន្និដ្ឋានស្តាពរ ដែលយោងចម្លើយរបស់ ឌុច ថា ការបោសសម្អាតជាគោលនយោបាយធំរបស់ ប.ក.ក.។ *សូមមើល ដូចខាងលើ* ជើងទំព័រ ១១៣៨ ដែលដកស្រង់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ឆ.៣១។

[2169] *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ ឯកសារ D98/3.1.86 នៅម៉ោង 10.05.50 (ឌុច បានផ្តល់សក្ខីកម្មថា ឯចំណែកនៅកងមជ្ឈិម ត្រូវសេនាធិការសម្រេច)។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.6 នៅម៉ោង 09.32.55-09.37.47 (ឌុច បានផ្តល់សក្ខីកម្មថា ចម្លើយដែលចេញពី ស-២១ [ទាក់ទងនឹងកងពល ៥០២] គឺទៅដៃមេ សុន សេន។ មេខ្ញុំឱ្យទៅ ស៊ូ ម៉េត ជ្រើសរើសមនុស្ស *ទៅតាមការសម្រេចចិត្តរបស់មេ* ឧទា. សុន សេន)។ សេចក្តីណែនាំរបស់គណៈមជ្ឈិមមានចំណងជើងថា "សេចក្តីសំរេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៦ ឯកសារ D1.3.19.1 EN 00182809 KH 00003136 (សិទ្ធិឱ្យសេនាធិការសម្រេចកម្ទេចយោធាមជ្ឈិម ក្នុងជួរ និង ក្រៅជួរ)។

យោបល់ ឬ បានជូនដំណឹងពួកគេអំពីចម្លើយសារភាពមន្ទីរ ស-២១ ក៏ដោយ[2170] ក៏ ឌុច បាន និយាយថា៖ "គ្រប់សេចក្តីសម្រេចក្នុងរឿងឃាត់ខ្លួន គ្រប់សេចក្តីសម្រេចក្នុងរឿងបញ្ជូនទៅ ស-២១ គឺអង្គការជាអ្នកសម្រេច។ និយាយឱ្យចំ គឺ សុន សុន...។ ក៏ប៉ុន្តែ គ្រប់បញ្ហាទាំងអស់ ដែលបញ្ជូនទៅ ស-២១ ឃាត់ខ្លួនយ៉ាងម៉េចអី យ៉ាងម៉េច គឺសុន សេន ជាអ្នកសម្រេច"[2171]។ ស្រដៀងនេះដែរ ប៉ុល ពត និង គណៈកម្មាធិការអចិន្ត្រៃយ៍ មានអំណាចសម្រេចចិត្តចុងក្រោយលើការចាប់ខ្លួន និង ការកាប់សម្លាប់នៅតំបន់ស្វយ័តកំពង់សោម[2172]។ តំបន់ទាំងនេះមិនមានសិទ្ធិធ្វើការសម្រេចចិត្តដោយខ្លួនឯងនោះទេ[2173]។ មាស មុត មិនមានសិទ្ធិធ្វើការសម្រេចចិត្តបែបនេះនៅក្នុងតំបន់ស្វយ័តកំពង់សោមនោះទេ ពីព្រោះគាត់មិនមែនជាសមាជិកពេញសិទ្ធិរបស់បក្ស[2174]។ ដូច ឌុច បានសង្កេតឃើញស្រាប់៖ "អ្នកទទួលខុសត្រូវនៃអង្គភាពពាក់ព័ន្ធ... ត្រូវបានដាក់បញ្ចូលទៅក្នុងនីតិវិធីផងដែរ *ក្នុងករណីដែលអ្នកទទួលខុសត្រូវនេះ ត្រូវទទួលយល់ព្រមតាមសេចក្តីសម្រេច*"[2175]។

[2170] *សូមមើល* ជើងទំព័រ ២០៣០ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ៣១១-១២។

[2171] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ D98/1.2.6 នៅម៉ោង 11.33.20-11.37.32។

[2172] តំបន់ស្វយ័តបានរាយការណ៍ និង ទទួលសេចក្តីណែនាំពីគណៈកម្មាធិការអចិន្ត្រៃយ៍។ មាត្រា ៨ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ ឯកសារ D1.3.22.1។ *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/277.4 នៅម៉ោង 11.11.52-11.15.32 (ឌុច បានផ្តល់សក្ខីកម្មថា តំបន់ឯករាជ្យកំពង់សោម រឿងអី។ ៨៧០ សម្រេច មិនមែនលេខាភូមិភាគនិរតីសម្រេចទេ)។ *សូមមើលផងដែរ* កថាខណ្ឌ ២១៦, ២៧៥ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។

[2173] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ ឯកសារ D98/3.1.86 នៅម៉ោង 10.02.56-10.05.50។ *សូមមើលផងដែរ* កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.4 EN 00198219 KH 00197970 (ជាក់ស្តែង ប៉ុល ពត ជាអ្នកសម្រេច សុន សេន ជាអ្នកអនុវត្ត ហើយ ន្ឋន ជា ជាអ្នកត្រួតពិនិត្យ។ អ្នកទទួលខុសត្រូវនៅអង្គភាព ចូលរួមពាក់ព័ន្ធ ក្នុងវិសាលភាពដែលគាត់ត្រូវបានអញ្ជើញឱ្យទទួលយក)។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.855 EN 00364072 KH00357493 (ខ្ញុំយល់ថា ការសម្រេចចាប់ខ្លួនកម្មាភិបាលដែលគេឆ្លើយដាក់ មិនមែនសម្រេចត្រឹមតែ សុន សេន តែឯងទេ គឺទាល់តែមានការសម្រេចពីគណៈមជ្ឈិមទៀត) EN 00364073 KH (ការបោសសម្អាតភូមិភាគបូព៌ាមានតែចេញមកពី ប៉ុត ពត ទេ ទើបហ៊ានអនុវត្ត)។

[2174] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ ឯកសារ D98/3.1.86 នៅម៉ោង 10.02.56-10.05.50។

[2175] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៨ ឯកសារ D1.3.33.4 EN 00198219 KH 00197970 (ការគូសបញ្ជាក់បន្ថែម)។

៥៩០. ស.ព.អ. ក៏ដកស្រង់សាក្សីជាច្រើននាក់ដែលមិនមែននៅក្នុងកងពលធំលេខ ១៦៥ ផងដែរ[2176]។ សាក្សីទាំងនេះមិនជាប់ទាក់ទងនឹង មាស មុត ទេ។ ឆោម សៃ ដែលបានដឹកនាំបញ្ជាការមន្ទីរសន្តិសុខអូរកន្សែងនៃកងពលធំលេខ ៨០១ មួយរយៈពេលខ្លី[2177] មិនបានស្គាល់ ឌុច ឬ មន្ទីរ ស-២១[2178] នោះឡើយ ហើយបានផ្អែកចម្លើយរបស់គាត់អំពីការចាប់ខ្លួនមនុស្សនៅកងពលធំលេខ ៨០១ ដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាព លើពាក្យចចាមអារ៉ាម និង ការទាយស្មាន[2179]។ លោក ហាំ អនស៊ី ដែលជាសមាជិកគណៈកម្មាធិការស្រុកនៃតំបន់ ១០៥[2180] បាននិយាយថា សុភា (មេបញ្ជាការយោធានៃតំបន់ ១០៥) បានបង្ហាញគាត់អំពីចម្លើយសារភាពមកពីមជ្ឈិម ដែលកងទ័ពកងពលធំលេខ ៩២០ បានឆ្លើយដាក់ទាហានក្នុងកងពលធំជាមួយគ្នា និង អ្នកផ្សេងទៀត[2181]។ គាត់មិនបាននិយាយថា សុភា ឬ លេខាតំបន់ ១០៥ បានសម្រេចថា តើមនុស្ស

[2176] កថាខណ្ឌ ៥៣៩, ជើងទំព័រ ២០៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2177] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆោម សៃ ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D55/5 ឆ.៣។

[2178] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆោម សៃ ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៣ ឯកសារ D55/5 ឆ.៤៩- ៥០។

[2179] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៣ ឯកសារ D98/3.1.20 នៅម៉ោង 14.28.06 (ឆ្លើយថា "ប៉ុន្តែចំពោះដែលខ្ញុំបាទនេះដែលវាក្នុងឋានៈដឹកនាំកម្រិតទាប មិនសូវជាដឹងសាច់រឿងនេះទេ រឿងជ្រាលជ្រៅអីចេះ វាមិនសូវឃើញជាក់ស្តែងទេ គិតតែពីរឿងបំពេញករណីយកិច្ចសម្រាប់ខ្លួនឯង ដើម្បីកុំឱ្យគេប្រកាន់ថ្នាក់ក្នុងការដឹកនាំដែលវាមិនពិតប្រាកដ។ ... អីចឹងបានថាកិច្ចការងារ វាដឹង តែឱ្យស៊ីជម្រៅឱ្យសព្វគ្រប់ ខ្ញុំបាទមិនបានសព្វគ្រប់ទេបាទ")។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៣ ឯកសារ D98/3.1.20 នៅម៉ោង 16.01.09 (ពាក់ព័ន្ធទៅនឹងការសម្រេចថា តើលេខាកងពល ត្រូវរង់ចាំការសម្រេចពីមជ្ឈិមបក្ស មុននឹងសម្រេចអំពីជោគវាសនារបស់អ្នកទោសណាម្នាក់នោះ គាត់បានឆ្លើយថា "អានេះ ច្បាប់នេះគេលាក់ការជាមូលដ្ឋាន គេវាមិនអាចបរិយាយប្រាប់យើងថាថ្នាក់ក្រោមកម្រិតនេះបានទេ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆោម សៃ ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៣ D55/5 ឆ.៥៨ (គាត់និយាយថា អ្នកទោសយោធាគេបញ្ជូនផ្ទាល់ទៅ ស-២១ តែម្តង គេមិនទុកនៅមន្ទីរសន្តិសុខរបស់គាត់ទេ ប៉ុន្តែបានឆ្លើយថា "គេមិនប្រាប់ឱ្យខ្ញុំដឹងផង ព្រោះជាការងារលាក់ការណ៍របស់គេ")។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៣ ឯកសារ D98/3.1.20 នៅម៉ោង 15.12.21-15.14.17 (ដោយបានពន្យល់ថា "រឿងអ្វីៗគេមិនអាចប្រាប់យើងទេ ប៉ុន្តែរឿងអស់នេះវាមិនអាចលាក់ជិតទេ តាមអង្គភាពមួយៗនោះ វាតែងតែមានកាលៈទេសៈខ្លះពេលវាលខ្លះទៅសិក្សាក្នុងសាលានយោបាយដូចគ្នា វាតែងតែប្រាប់ ផ្តល់ព័ត៌មាន បាត់អ្នកនេះ បាត់អ្នកនោះអីចឹងជាបន្តបន្ទាប់ដែរបាទ")។

[2180] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាំ អនស៊ី ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D4.1.443 EN 00250749 KH00242412។

[2181] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាំ អនស៊ី ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D4.1.443 EN 00250750 KH 00242413-00242414។ ជើងទំព័រ ២០៣១ នៃដីកាសន្និដ្ឋានស្តាពរ។

ដែលគេឆ្លើយដាក់ នឹងត្រូវចាប់ខ្លួន និង បញ្ជូនទៅ មន្ទីរ ស-២១ ឬយ៉ាងណានោះទេ។ សៅ សារុន ដែលជាលេខាតំបន់ ១០៥ ក្នុងមួយរយៈពេលខ្លី[2182] បាននិយាយថា ប៉ុល ពត បានប្រាប់គាត់អំពីចម្លើយសារភាពរបស់កម្មាភិបាលតំបន់ ១០៥ ដែលបានបង្ហាញថា សុត គឺជាជនក្បត់[2183]។ គាត់បានឃុំខ្លួន សុត ហើយបន្ទាប់មកបានស្នើសុំការណែនាំពី ប៉ុល ពត ថាត្រូវបញ្ជូន សុត ទៅណា[2184]។ ភី ភួន ប្រធានផ្នែករដ្ឋបាលនៃក្រសួងការបរទេស[2185] បានលើកឡើងថា អៀង សារី បានទទួលចម្លើយសារភាពពីមន្ទីរ ៨៧០ ដែលឆ្លើយដាក់ សេ.អ៊ី.អា កា.ហ្សេ.បេ ឬ កម្លាំងឈ្លានពានផ្សេងទៀត[2186]។ គាត់ក៏បាននិយាយផងដែរថា មន្ទីរ ៨៧០ បានសម្រេចចិត្តត្រូវដកនរណាចេញ[2187] ដោយបានបញ្ជាក់ថា មជ្ឈិមមានសិទ្ធិអំណាចចុងក្រោយលើការសម្រេចចិត្តបែបនេះ។ស្វង ស៊ីគឿន ប្រធានព័ត៌មាន និង ឃោសនាការនៃក្រសួងការបរទេស[2188] បានរំឭកឡើងវិញថា អៀង សារី បានអានចម្លើយសារភាពមួយចំនួន[2189] ហើយបាននិយាយថា ប៉ុល ពត មានអំណាចធ្វើការ

[2182] *សូមមើល* កថាខណ្ឌ ៥០៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2183] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ D98/1.2.33 នៅម៉ោង 11.10.14-11.13.09។ ជើងចំពីរ ២០៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2184] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ D98/1.2.33 នៅម៉ោង 11.19.12-11.26.58។

[2185] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ D98/3.1.220 នៅម៉ោង 14.41.00, 15.01.19-15.07.20 ។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១ ខែសីហា ឆ្នាំ ២០១២ ឯកសារ D98/3.1.223 នៅម៉ោង 11.43.58-11.47.22។

[2186] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ D98/3.1.221 នៅម៉ោង 11.33.01-11.44.49។ ជើងចំពីរ ២០៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2187] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០១២ ឯកសារ D98/3.1.221 នៅម៉ោង 11.33.01-11.34.51, 11.39.57-11.41.50។

[2188] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វង ស៊ីគឿន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D4.1.1130 EN 00223636 KH 00204147។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែសីហា ឆ្នាំ ២០១២ ឯកសារ D98/3.1.224 នៅម៉ោង 15.57.46។

[2189] *ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ D98/3.1.198 នៅម៉ោង 09.25.07-09.29.26។ ជើងចំពីរ ២០៣១ នៃដីកាសន្និដ្ឋានស្តាពរ។

សម្រេចចិត្ត និង ណែនាំថ្នាក់លើផ្សេងទៀត[2190] ហើយអាចធ្វើការសម្រេចចិត្តទាក់ទងនឹងក្រសួង ដោយមិនបាច់ជូនដំណឹងប្រាប់ អៀង សារី[2191]។សាឡុតបាន(ឬ សូ ហុង)ក្លួយប្រុសរបស់ ប៉ុល ពត និង ជាអនុប្រធានរបស់ អៀង សារី[2192] បាននិយាយថា ក្រសួងការបរទេសបានទទួលចម្លើយសារភាព[2193] ប៉ុន្តែ មិនមានសិទ្ធិធ្វើការសម្រេចចិត្តលើការសម្លាប់មនុស្សនោះទេ[2194]។ គាត់បាននិយាយថា គណៈកម្មាធិការមជ្ឈិមបានតែងតាំង សុន សេន ឱ្យមើលការខុសត្រូវលើការងារសន្តិសុខ[2195] ដែលជាការចង្អុលបង្ហាញពីសិទ្ធិអំណាចរបស់មជ្ឈិមលើបញ្ហាបែបនេះ។

៥៩១. ស.ព.អ. ក៏ដកស្រង់ចំណារនៅលើចម្លើយសារភាពមន្ទីរ ស-២១ ផងដែរ[2196]។ ក្នុងចំណោមចម្លើយសារភាពទាំងប្រាំបីដែលមានចំណារ ហើយត្រូវបានដកស្រង់ដោយ ស.ព.អ. មានតែពីរករណីប៉ុណ្ណោះដែលទាក់ទងនឹង មាស មុត[2197]។ ស.ព.អ. អះអាងថា ចម្លើយសារភាពទាំងពីរនេះ

[2190] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១២ឯកសារ D98/3.1.198 នៅម៉ោង 10.12.18-10.13.22។ *សូមមើលផងដែរ រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១២ ឯកសារ D98/3.1.243 នៅម៉ោង 10.11.14-10.16.34, 10.56.02-10.59.15។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១២ ឯកសារ D98/3.1.244 នៅម៉ោង 09.16.27-09.20.01។

[2191] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១២ ឯកសារ D98/3.1.198 នៅម៉ោង 10.13.22-10.36.41។

[2192] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៧ ឯកសារ D4.1.1126 EN 00223590-00223591 KH 00204094-00204095។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១២ឯកសារ D98/3.1.244 នៅម៉ោង 09.47.23-09.51.50។

[2193] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.835 EN 00361013-00361014 KH 00357530-00357531។ ជើងទំព័រ ២០៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2194] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.835 EN 00361012 KH 00357529។

[2195] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.835 EN 00361014 KH 00357531។

[2196] ជើងទំព័រ ២០៣២ នៃដីកាសន្និដ្ឋានស្តាពរ។

[2197] ជើងទំព័រ ២០៣២ នៃដីកាសន្និដ្ឋានស្តាពរ ដែលដកស្រង់ចម្លើយសារភាព ស-២១ របស់ ហង់ ឌឿន ហៅ ឌីម ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.55 EN 00224085 និង ឯកសារ D1.3.18.1 EN 00187721 KH 00162140។

បង្ហាញពីការទទួលបានចម្លើយសារភាពមន្ទីរ ស-២១ ដោយមាស មុត និង ការចូលរួមរបស់គាត់ក្នុងការសម្រេចចិត្តទាក់ទងនឹងកម្មាភិបាលកងពលធំលេខ ១៦៥[2198]។ គាត់ខកខានមិនបានបង្ហាញមូលដ្ឋានគាំទ្រការអះអាងរបស់គាត់[2199]។ វាមិនបង្ហាញច្បាស់ថា ចម្លើយមួយក្នុងចំណោមចម្លើយសារភាពទាំងពីរដែលមានចំណារ ត្រូវបានចារដោយ សុន សេន ឬយ៉ាងណានោះទេ[2200]។ ចំណារទាំងពីរគឺជាសេចក្តីថ្លែងការណ៍ដែលមានតែម្នាង។ មិនមានភស្តុតាងបង្ហាញថា មាស មុត បានទទួលចម្លើយសារភាពនេះទេ។ ចម្លើយសារភាពទាំងពីរនេះមិនបានបង្ហាញថា មាស មុត បានសម្រេចថាតើអ្នកដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពនោះ នឹងត្រូវចាប់ខ្លួន ឬ បញ្ជូនទៅមន្ទីរ ស-២១ ឬយ៉ាងណានោះទេ។ ចម្លើយសារភាពដែលនៅសល់ចំនួន ៦ ដែលមានចំណារបញ្ជាក់ស្រដៀងគ្នានេះត្រឹមតែបង្ហាញថា សុន សេន បានបញ្ជាឱ្យផ្ញើចម្លើយសារភាពមួយច្បាប់ឱ្យម្នាក់ៗ ឬថា ឯកសារមួយច្បាប់ត្រូវបានផ្ញើទៅនរណាម្នាក់[2201]។ ចម្លើយសារភាពទាំងនេះមិនបង្ហាញពីការទទួលបានឯកសារថតចម្លង ឬ សកម្មភាពណាមួយដែលអ្នកទទួលបានចាត់ការបន្តនោះឡើយ។

៥៩២. ស.ព.អ. ដកស្រង់សំណុំកំណត់ហេតុប្រជុំ និង ចម្លើយរបស់ ឌុច ទាក់ទងនឹងកិច្ចប្រជុំអគ្គសេនាធិការ ដែលនៅក្នុងនោះ លេខាកងពលធំ បានចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើការចាប់ខ្លួនកម្មា

ចម្លើយសារភាព ស-២១ របស់ គុណ ឌីម ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៧៧ ឯកសារ D234/2.1.54 EN 00822359 KH 00175293។

[2198] កថាខណ្ឌ ៥៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[2199] ជើងទំព័រ ២០៣៥ នៃដីកាសន្និដ្ឋានស្តាពរ ដែលយោងកំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០៩ ឯកសារ D4.1.766 EN 00398210 KH 00398202។

[2200] *សូមមើល* កថាខណ្ឌ ៥១១ *ខាងលើ* ទាក់ទងនឹងចម្លើយសារភាពទាំងនេះ។

[2201] ជើងទំព័រ ២០៣២ នៃដីកាសន្និដ្ឋានស្តាពរ ដែលយោងចម្លើយសារភាព ស-២១ របស់ សួរ ឌួន ហៅ ម៉ៅ ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៩៧៧ ឯកសារ D10.1.105 KH 00173999។ ចម្លើយសារភាព ស-២១ របស់ ស្រី សារឿន ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ១៩៧៧ ឯកសារ D1.3.1.10 EN 00824789 KH 00235161។ ចម្លើយសារភាព ស-២១ របស់ ណៃ ចាប ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.1.5 EN 00814489 KH 00162395។ ចម្លើយសារភាព ស-២១ របស់ សៀង ផុន ហៅ ផា ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៧៧ ឯកសារ D4.1.35 EN 00848203 KH 00004458។ ចម្លើយសារភាព ស-២១ របស់ យង់ ពៅ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ ១៩៧៧ ឯកសារ D10.1.1 EN 00182829 KH 00004599។ ចម្លើយសារភាព ស-២១ របស់ គង់ គៀន ហៅ អ៊ឹង វេត ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ១៩៧៧ ឯកសារ D1.3.18.4 EN 00822048 KH 00017305។

ភិបាលរបស់ខ្លួន[2202]។ ឯកសារទាំងនេះទាក់ទងតែជាមួយកងពលធំលេខ ២៩០ និង កងពលធំលេខ ១៧០ ប៉ុណ្ណោះ។ វាជាប់ទាក់ទងតែជាមួយនឹងសកម្មភាព ដែលបានកើតឡើងពាក់ព័ន្ធនឹងកងពលធំទាំងពីរនេះ អគ្គសេនាធិការ និង មន្ទីរ ស-២១ ប៉ុណ្ណោះ។

៥៩៣. ស.ព.អ. ដកស្រង់លិខិតពីលេខានៃកងពលធំលេខ ៥០២ និង កងពលធំលេខ ៣១០ ផ្ញើឱ្យ ឌុច ដោយបង្ហាញអត្តសញ្ញាណអ្នកដែលត្រូវបាន ឬ នឹងត្រូវបញ្ជូនទៅមន្ទីរ ស-២១[2203]។ លិខិតទាំងនេះជាប់ទាក់ទងនឹងការវាយតម្លៃលើការដឹងឮ និង សកម្មភាព ដែលបានធ្វើឡើងដោយប្រធានកងពលធំលេខ ៥០២ និង កងពលធំលេខ ៣១០ តែប៉ុណ្ណោះ។ មិនមានភ័ស្តុតាងបង្ហាញថា មាស មុត បានផ្ញើលិខិតស្រដៀងគ្នានេះទៅ មន្ទីរ ស-២១ ទាក់ទងនឹងប្រជាជនមកពីកងពលធំលេខ ១៦៥ ឬ កំពង់សោមនោះទេ។ ឌុច បាននិយាយថា គាត់មិនដែលបានឃើញឯកសារណាមួយដែលមានហត្ថលេខារបស់ មាស មុត នៅលើឯកសារនោះទេ[2204] ឬ ឯកសារដែលទាក់ទងនឹងការសម្អាតដោយ មាស មុត នោះឡើយ[2205]។

ii. មាស មុត មិនបានទទួលខុសត្រូវចំពោះមនុស្សចំនួន ៧០៦ នាក់ ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ នោះទេ។ បើទោះបីជាគាត់មានការទទួលខុសត្រូវនេះក៏ដោយ ក៏ការទទួលខុសត្រូវបែបនេះ មិនអាចធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ

៥៩៤. ប្រភពចម្បងដែល ស.ព.អ. ដកស្រង់មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត ទទួលខុសត្រូវចំពោះការបញ្ជូនមនុស្សចំនួន ៧០៦ នាក់ទៅមន្ទីរ ស-២១ នោះឡើយ[2206]។ ស.ព.អ. ដកស្រង់

[2202] កថាខណ្ឌ ៥៣៩ ជើងចំព័រ ២០៣៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2203] ជើងចំព័រ ២០៣៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2204] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/160 ឆ.៩។

[2205] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/159 ឆ.៣០, ឆ.៣២។

[2206] កថាខណ្ឌ ៥៥១ នៃដីកាសន្និដ្ឋានស្តាពរ (កម្មាភិបាល ១០១ នាក់មកពីកងពលធំលេខ ១៦៥ និង កងពលរបស់ភូមិភាគ និងតំបន់ អតីតទាហាន ឬ មន្ត្រីរដ្ឋការ លន់ នល់ ២១ នាក់ ពីក្រុងកំពង់សោម ពលរដ្ឋនៅកំពង់សោម ៧៣ នាក់ និង កម្មករកំពង់ផែកំពង់សោម ២៥១ នាក់ ជនជាតិវៀតណាម ឬ ខ្មែរក្រោម ១៩៥ នាក់ ជនជាតិថៃ ៥៨ នាក់ និង ពួកបស្ចិមប្រទេស ៨ នាក់)។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៧៣-៧៦, ៥៥២-៥០ ជើងចំព័រ ២០៥៤-២១២៧ ដែលរៀបរាប់លម្អិតពីប្រភេទខុស

ជាចម្បងនូវបញ្ជីអ្នកទោសមន្ទីរ ស-២១ ដែលចងក្រងដោយ ក.ស.ច.ស.[2207]។ បញ្ជីនេះ មិនបានបង្ហាញថា នរណាជាអ្នកដើរតួក្នុងការចាប់ខ្លួនអ្នកទោសនោះទេ។ ដោយគ្រាន់តែបញ្ជាក់ថា នរណាម្នាក់ត្រូវបានចាប់ខ្លួននៅក្នុង ឬ ពីខេត្តកំពង់សោម ឬ នៅសមុទ្រ មិនមានន័យថា មាស មុត ឬ កងពលធំលេខ ១៦៥ មានតួនាទីណាមួយនៅក្នុងការចាប់ខ្លួននោះទេ។

៥៩៥. ដូច សួស ធី បានចង្អុលបង្ហាញ ទីតាំងចាប់ខ្លួនដែលបានកត់ត្រានៅក្នុងប្រវត្តិរូបមន្ទីរ ស-២១ និងនៅក្នុងបញ្ជីឈ្មោះអ្នកទោសរបស់ ក.ស.ច.ស. មិនប្រាកដថាត្រូវគ្នានឹងទីតាំងជាក់ស្តែងនៃការចាប់ខ្លួននោះឡើយ។ គាត់គឺជាបុគ្គលិកមន្ទីរ ស-២១ ដែលមានភារកិច្ចចុះឈ្មោះអ្នកទោស និង កត់ត្រាប្រវត្តិរូបរបស់ពួកគេនៅពេលមកដល់[2208]។ ទាក់ទងនឹងការចាប់ខ្លួនមនុស្សដែលបានចូលដែនទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានចុះបញ្ជីថាមកពី "កំពង់សោម" គាត់បាននិយាយថា៖ "មានន័យថា ជាអ្នកដែលត្រូវបានកងទ័ពចាប់ខ្លួននៅឯសមុទ្រ។ គេតែងសរសេរបញ្ជាក់ថា កំពង់សោម បើទោះបីជាសមុទ្រស្ថិតនៅក្នុងខេត្តដទៃទៀតរបស់ប្រទេសកម្ពុជាក៏ដោយ។ អ្នកដែលគេចាប់ខ្លួនរមែង តែងត្រូវបានបញ្ជាក់ថា មកពីកំពង់សោមជានិច្ច។ ហើយមូលហេតុដែលខ្ញុំដឹងគឺ ហ៊ីរ ជាអ្នកប្រាប់ខ្ញុំ"[2209]។ ក្រោយមក គាត់បាននិយាយទាក់ទងនឹងការចាប់ខ្លួនពលរដ្ឋវៀតណាមថា៖ "ពីព្រោះការចាប់វៀតណាមដែលភៀសខ្លួនទៅថៃនោះ មិនៗសន្មតថាកំពង់សោមទេ ពីព្រោះនៅកន្លែងណាឱ្យតែដែនសមុទ្រ យើងឱ្យតែកងទ័ពចាប់បាន យើងថាកំពង់សោមៗតែម្តងទៅ"[2210]។ គ្រាន់តែដោយសារមនុស្សម្នាក់ មិនថាជនជាតិវៀតណាម ខ្មែរក្រោម ថៃ ឬ បស្ចឹមប្រទេសនោះ

គ្នានៃការចាប់ខ្លួន និង/ឬ ការសម្លាប់។ ទាក់ទងនឹងការអះអាងរបស់ ស.ព.អ. អំពីការចាប់ខ្លួនប្រជាជនតំបន់ ៥០៥ របស់ មាស មុត។ (កថាខណ្ឌ ១២០-២៤, ៥៥០ នៃដីកាសន្និដ្ឋានស្តាពរ) *សូមមើល* ផ្នែក IV.គ.៨។

[2207] ជើងចំពីរ ២០៤៤-៦៣, ២០៦៧-៧៥, ២០៧៧-៨៤, ២០៨៦, ២០៨៩-២១១៤, ២១១៦, ២១១៩, ២១២១-២៧, ២១៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2208] *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D234/2.1.118 នៅម៉ោង 09.34.55-09.38.03។ *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D234/2.1.119 នៅម៉ោង 10.34.23-10.37.12, 13.58.47-14.03.04។

[2209] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/41 អ.៩។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/43 អ.១២។

[2210] *រឿងក្តី ន្ឋន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D234/2.1.119 នៅម៉ោង 09.51.44-09.57.04។

ទេ[2211] ត្រូវបានចុះបញ្ជីថាមកពីកំពង់សោម ឬ ត្រូវបានចាប់ខ្លួននៅតាមសមុទ្រ មិនមានន័យថា គាត់ត្រូវបានចាប់ខ្លួនដោយកងកម្លាំងកងពលធំលេខ ១៦៥ នោះឡើយ។ កងកម្លាំងកងពលធំលេខ ១ ដែលកំពុងដើរល្បាតដែនទឹកនៅតាមខេត្តកោះកុង ឬ កងកម្លាំងល្បាតដែនទឹកនៅតាមខេត្តកំពត ប្រហែលជាអ្នកធ្វើការចាប់ខ្លួនទៅវិញទេ[2212]។

៥៩៦. មុខដំណែង ឬ អាជីពដែលកត់ត្រាក្នុងប្រវត្តិរូបមន្ទីរ ស-២១ និង នៅក្នុងបញ្ជីអ្នកទោសរបស់ ក.ស.ច.ស. ក៏មិនត្រូវគ្នាជាមួយមុខដំណែង ឬ អាជីពជាក់ស្តែងរបស់បុគ្គលនោះដែរ។ សួស ធី បាននិយាយថា អ្នកទោសវៀតណាមដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីមន្ទីរ ស-២១ ថាជា "អ្នកនេសាទ" ដោយសារតែបុគ្គលិកមន្ទីរ ស-២១ មិនចេះភាសាវៀតណាម ហើយមិនអាចសួរពត៌មានលំអិតបន្ថែមទៀតបាន ដូច្នេះហើយ "ហ៊ីរ សម្រេចចិត្តឱ្យចុះបញ្ជីគ្រួសារជនជាតិវៀតណាមទាំងនេះ ដែលមកពីកំពង់សោមថាជាអ្នកនេសាទ"[2213]។ ដំណើរការដូចគ្នានេះត្រូវបានអនុវត្តចំពោះជនជាតិវៀតណាម ដែលត្រូវបានចាត់ថាជា "គិញ" ផងដែរ[2214]។ ក្រោយមក គាត់បានបន្ថែមទៀតថា "ហ៊ីរ ឱ្យតែមកដល់ប្រាប់ខ្ញុំថា នរណាជាទាហាន យើងដាក់ជាចារកិច្ចទៅ អ្នកយកការណ៍ទៅ ហើយបើមកពីផែកំពង់សោមប្រជាជន យើងដាក់អ្នកនេសាទអីអ៊ីចឹង។ អាហ្នឹងគឺយើងដាក់ឱ្យតែបាន។ ឱ្យដឹងថាវៀតណាមមកតាមណាតាមហ្នឹង តាមណា តាមកំពង់សោម ឬ មកតាម ដែលចាប់បាននៅតាមស្វាយរៀងអីអ៊ីចឹង"[2215]។ សួស ធី មិនដែលឃើញអ្នកនេសាទថៃនៅមន្ទីរ ស-២១ ទេ[2216]។ សក្ខីកម្មរបស់គាត់បង្ហាញថា ក.ស.ច.ស. មិនអាចពឹងផ្អែកលើមុខដំណែង ឬ អាជីពដែលមានក្នុងប្រវត្តិរូបមន្ទីរ ស-២១ ដើម្បីវាយតម្លៃឋានៈរបស់អ្នកទោសក្នុងពេលចាប់ខ្លួននោះឡើយ។

[2211] កថាខណ្ឌ ៥៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[2212] *សូមមើល* កថាខណ្ឌ ២២៧ *ខាងលើ* ដែលពិភាក្សាពីការគ្រប់គ្រងរបស់កងពលធំ ១ លើខេត្តកោះកុង និង តំបន់ឆ្នេរត្រួតគ្នាដែលកងពល ១៦៥ ប្រតិបត្តិការ។

[2213] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/43 ឆ.២១។

[2214] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/43 ឆ.២៣។

[2215] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D234/2.1.119 នៅម៉ោង 15.30.22-15.33.02។

[2216] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ចុះថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/42 ឆ.២១-២៣។

៥៩៧. ស.ព.អ. សំដៅលើអ្នកទោសជាច្រើននាក់ ដែលមានឈ្មោះនៅក្នុងបញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស. ដែលមកពីផែកំពង់សោម ឬ ជាកម្មករផែ ឬ អ្នកនេសាទ[2217]។ គាត់អះអាងថា កម្មករផែកំពង់សោមចំនួន ២៥០ នាក់ និង ជនស៊ីវិលនៅកំពង់សោមចំនួន ៧៣ នាក់ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[2218]។ បើទោះបីជាទីតាំងចាប់ខ្លួននៅក្នុងបញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស. ត្រឹមត្រូវក៏ដោយ ក៏អ្នកដែលត្រូវបានចាប់ខ្លួនពីផែកំពង់សោម និង កម្មករផែ ឬ អ្នកនេសាទ មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត ឬ ការទទួលខុសត្រូវរបស់គាត់ទេ។ ពួកគេស្ថិតនៅក្រោមការគ្រប់គ្រង និង ការទទួលខុសត្រូវរបស់ ធុច រិន (ក្នុងករណីកំពង់ផែ) ឬ ឡូញ (ក្នុងករណីនេសាទ)[2219]។ បញ្ជីឈ្មោះ និង ចំនួនអ្នកទោសទាំងនេះ មិនពាក់ព័ន្ធនឹង មាស មុត នោះទេ ហើយមិនអាចយកមកធ្វើជាមូលដ្ឋាន ដើម្បីកំណត់ការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់លើ មាស មុត ចំពោះការបញ្ជូនមនុស្សចំនួន ៧០៦ ទៅមន្ទីរ ស-២១ ឡើយ។

៥៩៨. បើទោះបីជា ស.ច.ស. សម្រេចថា ភស្តុតាងបានបង្ហាញពីការទទួលខុសត្រូវរបស់ មាស មុត ក្នុងការបញ្ជូនមនុស្សចំនួន ៧០៦ នាក់ ទៅមន្ទីរ ស-២១ ក៏ដោយ ក៏ការណ៍នេះនឹងមិនធ្វើឱ្យគាត់ក្លាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស. មានឈ្មោះមនុស្សចំនួន ១៥១០១ នាក់ ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ពីគ្រប់

[2217] *សូមមើលខ១ទ.* ជើងទំព័រ ២០៨២, ២១០២ នៃដីកាសន្និដ្ឋានស្តាពរ។

[2218] កថាខណ្ឌ ៥៥១ នៃដីកាសន្និដ្ឋានស្តាពរ។

[2219] សាក្សីជាច្រើននិយាយថា ធុច រិន គ្រប់គ្រងកំពង់ផែកំពង់សោម និង កម្មករកំពង់ផែចំនួនប្រមាណ ៦០០០ នាក់។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/218 អ.១៨, អ.២០, អ.២៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D114/234 អ.២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/195 អ.៥-៧, អ.១២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 អ.៤០, អ.៥៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 អ.២៦, អ.២៨, អ.៣០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រៀង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 អ.១៩៩។ សាក្សីជាច្រើននិយាយថា ឡូញ គ្រប់គ្រងអង្គភាពនេសាទ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉េត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 អ.៣០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 អ.១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/286 អ.៣០។

ទីកន្លែងនៅក្នុងទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ[2220]។ ចំពោះការសន្មតថា មាស មុត ទទួលខុសត្រូវក្នុងការបញ្ជូនមនុស្សចំនួន ៧០៦ នាក់ ទៅមន្ទីរ ស-២១ គាត់អាចទទួលខុសត្រូវចំពោះតែប្រជាជនចំនួន ៤,៦% ប៉ុណ្ណោះ ដែលបានបញ្ជូនទៅមន្ទីរ ស-២១។

គ. សេចក្តីសន្និដ្ឋាន

៥៩៩. មាស មុត មិនបានទទួលខុសត្រូវក្នុងការបញ្ជូនមនុស្សទៅមន្ទីរ ស-២១ ពីកងពលធំលេខ ១៦៤ ឬ កំពង់សោម ឬ អង្គភាពកងទ័ពបដិវត្តន៍កម្ពុជាផ្សេងទៀតនោះទេ។ មិនមានឯកសារបង្ហាញថា មាស មុត បានបញ្ជូនអ្នកណាម្នាក់ មកមន្ទីរ ស-២១ ឬ បានពិភាក្សាអំពីការបញ្ជូនអ្នកណាម្នាក់មកមន្ទីរ ស-២១ នោះទេ។ ភស្តុតាងពីសាក្សីដែលមិនមែនមកពីកងពលធំលេខ ១៦៤ មិនបានបង្ហាញឱ្យឃើញថា មាស មុត មានការទទួលខុសត្រូវពាក់ព័ន្ធនឹងមន្ទីរ ស-២១ នៅក្នុងកងពលធំលេខ ១៦៤ ឬ កំពង់សោម។ បើទោះបីជា ស.ច.ស. រកឃើញថា ភស្តុតាងបង្ហាញអំពី មាស មុត មានការទទួលខុសត្រូវក្នុងការបញ្ជូនមនុស្សចំនួន ៧០៦ នាក់ទៅមន្ទីរ ស-២១ ក៏ដោយ ក៏ចំនួននេះគឺមិនគ្រប់គ្រាន់អាចដំឡើងឱ្យគាត់ស្ថិតនៅក្នុងប្រភេទនៃ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ នៅពេលពិនិត្យទៅលើចំនួនមនុស្សសរុប ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ពីទូទាំងកម្ពុជាប្រជាធិបតេយ្យនោះ។

១២. ការដែលមានកេរ្តិ៍ឈ្មោះថាមានភាពតឹងរ៉ឹង ឬ កាច មិនធ្វើឱ្យ មាស មុត ក្លាយជាបុគ្គលម្នាក់"ដែលទទួលខុសត្រូវខ្ពស់បំផុត"

៦០០. កេរ្តិ៍ឈ្មោះឃោរឃៅ មិនស្មើនឹងការបង្កើនការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ[2221]។ ដូច ស.ច.ស. បានសង្កេតទាក់ទងនឹង អ៊ឹម ចែម ក្នុងប្រព័ន្ធមួយដែល "ភាពឃោរឃៅ និង ភាពភ័យរន្ធត់ គឺជានិយាម" ភស្តុតាងមិនបង្ហាញថា គាត់បានប្រព្រឹត្តហួសនិយាមនេះហួសហេតុ រហូតដល់ក្លាយជាយុត្តិកម្មនៃការរកឃើញថា គាត់គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះឡើយ[2222]។ ករណីដូចគ្នានៅក្នុងរឿងក្តីនេះ។

[2220] បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស. ឯកសារ D114/230.1.1 ខែកក្កដា ឆ្នាំ ២០១៦។

[2221] កថាខណ្ឌ ៣២៤ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[2222] កថាខណ្ឌ ៣២៤ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

៦០១. ស.ព.អ. អះអាងថា មន្ត្រីក្រោមបង្គាប់របស់ មាស មុត បានធ្វើតាមបញ្ជារបស់គាត់ ព្រោះពួកគេបានគោរព និង ភ័យខ្លាចចរិតលក្ខណៈគ្មានមនោសញ្ចេតនា និង ឫត្ថ័ចត់របស់គាត់[2223]។ ស.ព.អ. ដកស្រង់សាក្សីតែម្នាក់គត់ឈ្មោះ យ៉ែម សំអុន។ គាត់បកស្រាយចម្លើយរបស់ យ៉ែម សំអុន ខុស និងមិនអើពើនឹងតម្លៃជាភស្តុតាងដែលមានកម្រិតរបស់គាត់[2224]។ យ៉ែម សំអុន ស្ថិតនៅក្រៅប្រទេសភាគច្រើនក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[2225]។ គាត់មិនបានធ្វើការដោយផ្ទាល់ជាមួយ មាស មុត ទេ[2226]។ គាត់បាននិយាយថា មាស មុត មានភាពល្អិតល្អន់ ហើយជាមនុស្សម្នាក់គោរពពាក្យសម្តី[2227]។ គាត់បាននិយាយថា ទាហានភ័យខ្លាច មាស មុត ដោយសារតែងំណែងយោធារបស់គាត់[2228]។ គាត់មិនប៉ានទៅជិត មាស មុត ទេ ព្រោះ មាស មុត គឺជាមេបញ្ជាការម្នាក់[2229]។ យ៉ែម សំអុន ក៏បាននិយាយផងដែរថា ទាហានមិនខ្លាច មាស មុត ធ្វើបាប ឬ សម្លាប់ពួកគេទេ[2230]។ ការភ័យខ្លាច មាស មុត គឺមានមូលដ្ឋានលើការណ៍ដែលថា គាត់គឺជាមេបញ្ជាការយោធា មិនមែនភ័យខ្លាចចរិតលក្ខណៈ ឬ កេរ្តិ៍ឈ្មោះរបស់គាត់នោះទេ។

៦០២. ស.ព.អ. អះអាងថា មាស មុត គឺជាជនផ្តាច់ការ ដែលបានឃ្លាំមើលយ៉ាងតឹងរ៉ឹងលើអ្នកក្រោមបង្គាប់[2231] ហើយគេខ្លាចគាត់[2232]។ គាត់ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន និង គ្មានមូលដ្ឋានគាំទ្រពី ស៊ឹម នី ជេត ប៊ុណ្ណា សុខ វណ្ណា ស៊ន សុត អ៊ូ សារ៉ាន់ និង ពេជ្រ ជឹម។ ស.ព.អ. នាំឱ្យមានការភាន់ច្រឡំដោយចាត់ទុកទស្សន និង ចម្លើយរបស់បុគ្គលទាំងនេះ ជាការតំណាងឱ្យបុគ្គលិកកងពលធំលេខ ១៦៥ ទាំងមូល។ នៅក្នុងវិសាលភាពមួយដែលចម្លើយទាំងនេះមានការជាប់ពាក់ព័ន្ធនោះ ភាពពាក់ព័ន្ធរបស់វាមានកម្រិតនៅត្រឹមការវាយតម្លៃអំពីរបៀបដែលសាក្សីនីមួយៗ យល់ឃើញអំពី មាស មុត។

[2223] កថាខណ្ឌ ៨០ នៃដីកាសន្និដ្ឋានស្តាពរ។

[2224] ជើងទំព័រ ២៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2225] *សូមមើល* កថាខណ្ឌ ៣៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2226] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ឆ.៦២។

[2227] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ឆ.៦៩។

[2228] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ឆ.៦៩។

[2229] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ឆ.៧២។

[2230] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម សំអុន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/92 ឆ.៦៩។

[2231] ជើងទំព័រ ២៣៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2232] កថាខណ្ឌ ៨៤-៨៥ ជើងទំព័រ ២៥៦-៥៩ នៃដីកាសន្និដ្ឋានស្តាពរ។

៦០៣. **ស៊ឹម នី៖** ស៊ឹម នី មិនអាចជឿជាក់បានឡើយ[2233]។ គាត់បានអះអាងថា មាស មុត បានវាយចំថ្ងាសមេជាងដោយពូថៅ ហើយថា មាស មុត អាចនឹងបញ្ជូនមិត្តភក្តិម្នាក់របស់ ស៊ឹម នី ទៅរាម ដោយសារបានយកចំណីអាហារ និង បារី ប្រសិនបើគាត់ដឹង[2234]។ រឿងរបស់គាត់មិនស៊ីចង្វាក់គ្នាជាមួយភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងនោះទេ។ ស៊ឹម នី បាននិយាយផ្ទុយខ្លួនឯងអំពីហេតុការណ៍ដែលទាក់ទងនឹងពូថៅដែលត្រូវបានអះអាង។ ដំបូង គាត់បានអះអាងចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជាថា មេជាងនោះបានស្លាប់ ក្រោយពី មាស មុត វាយក្បាលគាត់នឹងពូថៅ[2235]។ ក្រោយមក នៅក្នុងបទសម្ភាសន៍ដូចគ្នានេះ គាត់បានមានប្រសាសន៍ថា មេជាងនោះរួចជីវិត ហើយមិនមានបញ្ហាអ្វីនោះទេ[2236]។ នៅចំពោះមុខ ក.ស.ច.ស. គាត់បាននិយាយថា មុខរបួសនោះមិនធ្ងន់ធ្ងរទេ[2237]។

៦០៤. **ជេត ប៊ុណ្ណា៖** ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[2238]។ គាត់បានអះអាងថា គាត់មិនដែលឃើញនរណាម្នាក់ដែលមានឥរិយាបថ និង អាកប្បកិរិយា ដូច មាស មុត នោះទេ ហើយគាត់បាននិយាយថា មាស មុត មានភាពតឹងរ៉ឹងណាស់[2239]។ គាត់និយាយបែបនេះ ដោយសារតែមានគំនុំនឹង មាស មុត[2240]។

៦០៥. **សុខ វណ្ណា៖** សុខ វណ្ណា មិនអាចជឿជាក់បានឡើយ[2241]។ គាត់បាននិយាយថា មាស មុត អាចវាយ ឬ បាញ់នរណាម្នាក់យ៉ាងងាយ បើសិនមានកំហុសឆ្គង ដោយបានអះអាងថាបានឃើញ មាស មុត

[2233] *សូមមើល* កថាខណ្ឌ ២៤៥ និង ៤០៦-០៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ ។

[2234] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/37 ឆ.៦, ឆ.២៦។ ជើងទំព័រ ២៣៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2235] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332601 KH 00735598។

[2236] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D59/2/2.16a EN 01332605 KH 00735600-00735601។

[2237] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/37 ឆ.២៥។

[2238] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2239] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ឆ.២០-២១។ ជើងទំព័រ ២៣៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2240] *សូមមើល* កថាខណ្ឌ ១៨៨ *ខាងលើ*។

[2241] *សូមមើល* កថាខណ្ឌ ៣៤៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

វាយនរណាម្នាក់រហូតដល់សន្លប់[2242]។ តាមដែលមេធាវីការពារក្តីដឹង រឿងរ៉ាវរបស់ សុខ វណ្ណា មិនស៊ីចង្វាក់គ្នាជាមួយភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងនោះទេ។

៦០៦. **ស៊ិន សុត៖** ស៊ិន សុត មិនអាចជឿជាក់បានឡើយ[2243]។ គាត់អះអាងថា បើសិនជាទាហានមិនធ្វើតាម មាស មុត "ពួកគេនឹងត្រូវគេសម្លាប់ចោល"[2244]។ ស៊ិន សុត ធ្វើការទាយស្មានលើករណីនេះ។

៦០៧. **អ៊ូ សារ៉ាន់៖** អ៊ូ សារ៉ាន់ មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។ គាត់ជាពេទ្យនៅកងវរសេនាតូច ដែលត្រូវបានបញ្ជូនទៅភូមិភាគបូព៌ាក្នុងឆ្នាំ ១៩៧៧[2245]។ គាត់បានអះអាងថា មន្ត្រីក្រោមឱវាទរបស់ មាស មុត បានជៀសវាងប្រព្រឹត្ត "កំហុសឆ្គងពីព្រោះពួកគេទាំងអស់ភ័យខ្លាច"[2246]។ គាត់បានលើកឡើងអំពីការភ័យខ្លាចដល់អាយុជីវិតនៅសមរភូមិ និង ការប្រជុំស្វ័យទិតៀន[2247] មិនមែនខ្លាច មាស មុត នោះទេ។

៦០៨. **ពេជ្រ ជីម៖** ភស្តុតាងរបស់ ពេជ្រ ជីម គឺមិនពាក់ព័ន្ធ[2248]។ គាត់បានអះអាងថា ក្នុងឆ្នាំ ១៩៧៥ តាម៉ុក បានស្តីបន្ទោស មាស មុត អំពីការបញ្ជាឱ្យសម្លាប់អ្នកយាមគ្រាប់[2249]។ ឧបទ្ទវហេតុនេះកើតឡើងមុនយុត្តាធិការពេលវេលារបស់ អ.វ.ត.ក.។

៦០៩. កងកម្លាំងយោធាក្រោមបង្គាប់ អនុវត្តតាមបញ្ជារបស់មេបញ្ជាការរបស់ពួកគេ ហើយការភ័យខ្លាចថ្នាក់លើរបស់ពួកគេ ត្រូវបានរំពឹងទុកថាកើតមាននៅក្នុងរចនាសម្ព័ន្ធយោធា។ ដួច ព្រំ សារ៉ាត បានផ្តល់សក្ខីកម្មថា៖ "ធម្មតា កូនទាហាន និង មេបញ្ជាការ កាលណារៀបចំផែនការធ្វើការគ្រប់បែប

[2242] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/16 ន.២៣-២៥។ ដីកាជើងចំពីរ ២៣៨, ២៥៨ នៃសន្និដ្ឋានស្តាពរ។

[2243] *សូមមើល* កថាខណ្ឌ ៣៥២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2244] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/194 ន.៧០។ ជើងចំពីរ ២៥៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2245] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន់ ចុះថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/41 ន.១១, ន.២០, ន.២៨។

[2246] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន់ ចុះថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/41 ន.៨-១០។ ជើងចំពីរ ២៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2247] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន់ ចុះថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/41 ន.១០។

[2248] *សូមមើល* កថាខណ្ឌ ៣៧១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2249] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជីម ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D4.1.786 EN 00381027-00381028 KH 00373477-00373478។ ជើងចំពីរ ២៥៩ នៃដីកាសន្និដ្ឋានស្តាពរ។

យ៉ាង គឺត្រូវតែគោរពតាមបទបញ្ជា មិនថានៅកម្ពុជាប្រជាធិបតេយ្យ ឬ របបណាទេ គឺត្រូវគោរពជាសាកល”[2250]។ បុគ្គលិកក្រោមបង្គាប់របស់ មាស មុត អាចបានទទួលបញ្ជាពីគាត់ ហើយការភ័យខ្លាចគាត់ មិនមែនជាការបង្ហាញអំពីសិទ្ធិអំណាច ឬ ការទទួលខុសរបស់ មាស មុត ទេ។ ការគ្មានមនោសញ្ចេតនា ភាពឃ្មត់ចត់ ភាពផ្តាច់ការ ឬ សូម្បីតែភាពឃោរឃៅ មិនមានន័យថា មាស មុត មានទំនួលខុសត្រូវច្រើនជាងមេបញ្ជាការផ្សេងទៀត ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះឡើយ។

ឃ. មាស មុត មិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ

៦១០. ការចាប់ខ្លួនណាមួយដោយកងពលធំលេខ ១៦៤ នូវពលរដ្ឋវៀតណាម ជនជាតិពន្ធុវៀតណាម ឬ ប្រជាជនដែលត្រូវបានគេយល់ថាជាជនជាតិវៀតណាម ដែលបានចូលក្នុងដែនទឹករបស់របបកម្ពុជាប្រជាធិតេយ្យ បានកើតឡើងក្រោមករណីយកិច្ចការពារសន្តិសុខជាតិ និង ការពារកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម។ ជនជាតិវៀតណាមមិនត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ កាប់សម្លាប់ដោយសារហេតុផលនៃអំពើប្រល័យពូជសាសន៍នោះឡើយ។ ស.ព.អ. អះអាងថា៖ **ក.** មាស មុត បានដឹង បានផ្សព្វផ្សាយ និង បានអនុវត្តគោលនយោបាយបក្ស ក្នុងការកម្ទេចជនជាតិវៀតណាម ដែលជាក្រុមជនជាតិភាគតិច[2251] ហើយ **ខ.** ថ្នាក់ដឹកនាំកងពលធំលេខ ១៦៤ បានប្រកាសនៅទូទាំងកងពលធំ អំពីគោលនយោបាយទូទៅនៃការសម្លាប់រាល់ជនជាតិវៀតណាម បានទទួលរបាយការណ៍អំពីការចាប់នាវាជាក់លាក់ ហើយបានចេញបញ្ជាឱ្យសម្លាប់ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួនម្តងៗ[2252]។ ស.ព.អ. បានធ្វើការអះអាងតូចចង្អៀតអំពីសកម្មភាពដែលបានចោទប្រកាន់ដោយថា បានប្រព្រឹត្តឡើងដោយ មាស មុត ដើម្បីគាំទ្រ និង អនុវត្តគោលនយោបាយប្រល័យពូជសាសន៍របស់បក្ស[2253]។ គាត់ដកស្រង់សាក្សីមិនអាចជឿឱ្យជាក់បានភ័ស្តុតាងចចាមអារ៉ាម និង ចម្លើយដែលមិនគាំទ្រការអះអាងរបស់គាត់។ គាត់មិនអើពើនឹងភស្តុតាង បរិបទ ឬ ភ័ស្តុតាងប្រទាំងប្រទើសគ្នា ដែលធ្វើឱ្យការអះអាងរបស់គាត់មិនរឹងមាំ ឬ ច្រានចោលការអះអាងនោះ។

[2250] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/285 ទ.៥៨។

[2251] កថាខណ្ឌ ៧៨១ នៃដីកាសន្និដ្ឋានស្តាពរ។

[2252] កថាខណ្ឌ ៧៨២ នៃដីកាសន្និដ្ឋានស្តាពរ។

[2253] កថាខណ្ឌ ៧៨២-៩៨ នៃដីកាសន្និដ្ឋានស្តាពរ។

១. ទាំង មាស មុត ទាំងថ្នាក់ដឹកនាំកងពលធំលេខ ១៦៥ មិនបានប្រកាសនៅក្នុងកងពលធំលេខ ១៦៥ អំពីគោលនយោបាយកាប់សម្លាប់ជនជាតិវៀតណាមទាំងអស់

៦១១. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត បានបណ្តុះបណ្តាលកងទ័ពរបស់ខ្លួន អំពីគោលនយោបាយបក្ស ទាក់ទងនឹងវៀតណាម និង ហាន:ជា "សត្រូវស្នេហ៍ជ" និង "សត្រូវទីមួយ" ហើយបានណែនាំឱ្យសមាជិកកងពលធំ សម្លាប់ជនជាតិវៀតណាមទាំងអស់ រួមទាំង ទារក[2254]។ ស.ព.អ. ដកស្រង់ចម្លើយដែលមិនអាចឱ្យជឿជាក់បាន និង គ្មានមូលដ្ឋានគាំទ្ររបស់ ប៉ាក សុខ និង ឯក នី[2255]។ គាត់មិនអើពើនឹងភស្តុតាងបរិបទ និង ភ័ស្តុតាងផ្ទុយគ្នា។

៦១២. **ប៉ាក សុខ៖** ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[2256]។ លោកបាននិយាយថា គាត់បានចូលរួមវគ្គហ្វឹកហ្វឺនដែលក្នុងនោះជនជាតិវៀតណាមត្រូវបានគេពិពណ៌នាថាជា "សត្រូវស្នេហ៍ជ" និង "សត្រូវទីមួយ" ហើយថា គំនិតទាំងនេះត្រូវបានបង្រៀនដល់ថ្នាក់ក្រោមៗ ក្នុងវគ្គបណ្តុះបណ្តាលថ្នាក់កងពលធំ ដែល មាស មុត ទទួលខុសត្រូវ[2257]។ គាត់បានអះអាងថា នៅក្នុងការបណ្តុះបណ្តាលទាំងនេះ ទាហានត្រូវបានគេប្រាប់ឱ្យសម្លាប់ជនជាតិវៀតណាមទាំងអស់ចោល សូម្បីតែទារក[2258]។ ការអះអាងនេះផ្ទុយពីសក្ខីកម្មមុនរបស់គាត់ដែលថា ជាជាងការសម្លាប់ប្រជាជនវៀតណាមទាំងអស់ គាត់ត្រូវបានណែនាំឱ្យបាញ់ពន្លិចទូកប្រដាប់ដោយអាវុធ តែបន្ទាប់ពីពួកគេបានបាញ់មុនប៉ុណ្ណោះ[2259]។ សាក្សីផ្សេងទៀតមកពីកងពលធំលេខ ១៦៥ បញ្ជាក់ថា ពួកគេត្រូវបានណែនាំ

[2254] កថាខណ្ឌ ៧៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2255] ជើងទំព័រ ៣១៨៥-៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2256] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2257] *អឿងគ្ក ន្ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 13.43.50-13.48.28។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.៣២-៣៤។ ជើងទំព័រ ៣១៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2258] *អឿងគ្ក ន្ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 13.34.17-13.37.45។ ជើងទំព័រ ៣១៨៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2259] *អឿងគ្ក ន្ឌួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.56.53-11.00.41។

ឱ្យបាញ់ ឬ ចាប់ទូកវៀតណាម ឬ មនុស្ស តែនៅពេលដែលវៀតណាមបានបាញ់[2260]។ ពួកគេក៏បាននិយាយផងដែរថា សុន សេន បានណែនាំមិនឱ្យចាប់ខ្លួនជនភៀសខ្លួនវៀតណាម[2261]។

៦១៣. ប៉ាក សុខ បានអះអាងថា មាស មុត បានចេញបញ្ជា ឱ្យសម្លាប់ជនភៀសខ្លួនវៀតណាមមួយចំនួន[2262]។ ក្រោយមក គាត់បានប្រាប់អង្គជំនុំជម្រះសាលាដំបូងថា បញ្ជានេះគឺមកពីកងពលធំតាមរយៈខ្សែចង្វាក់បញ្ជា ហើយត្រូវបានអនុវត្តដោយកងទ័ពនៅលើកោះ[2263]។ គាត់បាននិយាយថា រឿងនេះបានកើតឡើងនៅមុនពេលគាត់ចូលរួមកងទ័ពជើងទឹកនៅឆ្នាំ ១៩៧៦[2264]។ ដោយសារបទបញ្ជានេះមិនត្រូវបានចេញដោយផ្ទាល់ទៅកាន់អង្គភាពរបស់គាត់[2265] គាត់មិនអាចដឹងថា មាស មុត បានចេញបញ្ជានោះទេ។ ការដឹងឮរបស់ ប៉ាក សុខ មានកម្រិត។ បន្ទាប់ពីគាត់បានចូលរួមជាមួយកងទ័ពជើងទឹក គាត់បានឈរជើងនៅកំពង់ផែឆ្នេរអូរឈើទាល រហូតដល់ពេលវៀតណាមចូលក្នុងឆ្នាំ ១៩៧៨[2266]។ គាត់ “មិនបានទៅហួសពីទឹកឆ្នែងរបស់គាត់នោះឡើយ” [2267]។ គាត់បានបង្ហាញឱ្យឃើញអំពីកម្រិតនៃចំណេះដឹងរបស់គាត់ តាមរយៈការយោងដែលមិនជាក់លាក់ម្តង

[2260] *សូមមើល* ជើងទំព័រ ១៩៥០ *ខាងលើ*។

[2261] *សូមមើល* កថាខណ្ឌ ៥៦១ *ខាងលើ*។

[2262] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៧ ឯកសារ D54/24.1 EN 00978576 KH 00955507-00955508។ ជើងទំព័រ ៣១៨៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2263] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 11.00.41-11.09.46។

[2264] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 11.03.07-11.09.46។

[2265] *សូមមើល រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 11.03.07-11.09.46៖ “ជំនាន់នោះ ឃើញថាមានការច្របូកច្របល់ច្រើនណាស់ បាទ ច្របូកច្របល់ច្រើន។ អ៊ីចឹងបញ្ជាពីកងពល បញ្ជាកងពល មិនមែនបញ្ជាមកផ្ទាល់ខ្លួនឯង ខ្លួនខ្ញុំផ្ទាល់តែម្តងទេ គឺបញ្ជាមកកងវរសេនាធំ កងពលបញ្ជាមកវរសេនាធំ។ វរសេនាធំបញ្ជាទៅវរសេនាតូច វរសេនាតូចបានបញ្ជាយោធាអ្នកដែលធ្វើសកម្មភាព។ ... ក្នុងខ្លួនខ្ញុំមិនទាន់ចេញមកនៅក្នុងកងពលវរសេនាធំ ១៤០ ទេ នោះគឺនៅក្នុងវរសេនាធំ ៦២។ នេះជាសកម្មភាពនៅក្នុងវរសេនាធំ នៅ ៦២២ របស់យើងខ្ញុំ។ អាហ្នឹងជាកងចាស់ ក្រោយមកបានខ្ញុំនិយាយឆ្នាំ ៧៥ -- ៧៧ នេះ អាហ្នឹងបានខ្ញុំរស់នៅផែអូរឈើទាល។ មុននោះ គឺថានៅខាងកោះ បាទ ខាងកោះពូធីវ៉ែ ព្រឹត្តិការណ៍ហ្នឹងឃើញថា អស់លោកសួរខ្ញុំមែន ហើយខ្ញុំឆ្លើយទៅតាមសំណួរហ្នឹងពិតប្រាកដមែនបាទ”។

[2266] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.៩។

[2267] *រឿងក្តី ន្ឈន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.39.59-10.46.23។

ហើយម្តងទៀត នូវឋានានុក្រមរាយការណ៍ទូទៅ នៅពេលមេធាវីការពារក្តី នួន ជា បានសួរគាត់ថាអ្នកណាដែលបានទទួល ឬ ចេញបញ្ជាជាក់លាក់ ឱ្យទៅកងទ័ពរសេនាធំលេខ ៦២ ដើម្បីសម្លាប់ក្រុមគ្រួសារជនជាតិវៀតណាម[2268]។ *សូមមើល* កថាខណ្ឌ ៦៤៥ *ខាងក្រោម* ចំពោះសេចក្តីសន្និដ្ឋានបន្ថែមទាក់ទងនឹង ប៉ាក សុខ និង ការអះអាងរបស់គាត់ទាក់ទងនឹងវៀតណាម។

៦១៤. **ឯក នី៖** ឯក នី មិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ[2269]។ ចម្លើយរបស់គាត់ បង្ហាញឱ្យឃើញអំពីគោលបំណងយោធា នៅពីក្រោយគោលនយោបាយរបស់បក្ស ចំពោះប្រទេសវៀតណាម។ គាត់បានអះអាងថា ច្បាប់មកពីថ្នាក់លើ គឺថាជនជាតិវៀតណាមត្រូវកម្ទេចចោលដាច់ខាត ទោះប្រជាជន ឬ អ្នកនេសាទអីត្រូវតែចាប់ទាំងអស់[2270]។ ការលើកឡើងរបស់ ឯក នី អំពី "ការកម្ទេច" សំដៅលើការចាប់ខ្លួនជនជាតិវៀតណាម មិនមែនសម្លាប់ពួកគេនោះទេ[2271]។ ទោះបីជាការប៉ុនប៉ងរបស់អ្នកស៊ើបអង្កេត ក.ស.ច.ស. ដើម្បីដឹកនាំ ឯក នី តាមរយៈការសាកសួរគាត់ថាតើអ្នកជាប់ឃុំវៀតណាមត្រូវបានកម្ទេច "ដោយសារការរើសអើងពូជសាសន៍" ក៏ដោយ[2272] ក៏ ឯក នី បាននិយាយថា ជនជាតិវៀតណាមត្រូវ "កម្ទេចចោល" ដោយសារតែកម្ពុជាប្រជាធិបតេយ្យកំពុងតែប្រយុទ្ធជាមួយពួកឈ្លានពានវៀតណាម ដែលបានកាន់កាប់កោះក្រចកសេះ និងកោះពូឡូវ៉ៃ[2273]។

[2268] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ឯកសារ D114/297.1.21 នៅម៉ោង 10.51.08-11.01.31។

[2269] *សូមមើល* កថាខណ្ឌ ២៥១ *ខាងលើ* និង កថាខណ្ឌ ៦៤៦ *ខាងក្រោម* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ និង ភាពមិនអាចជឿជាក់បានរបស់គាត់លើបញ្ហាផ្សេងៗទៀត។

[2270] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 ឆ.១៨។ ជើងទំព័រ ៣១៨៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2271] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 ឆ.១៨៖ "ព្រោះអាហ្នឹងច្បាប់ ... ត្រូវតែកម្ទេច ...ត្រូវតែចាប់ទាំងអស់"។

[2272] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 ស.១២។

[2273] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 ឆ.១១-១២, ឆ.១៧។

៦១៥. ឯក នី បានអះអាងថា មាស មុត បានចេញបទបញ្ជាថា ជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួនមិនគួរត្រូវបញ្ជូនទៅដីគោកទេ ប៉ុន្តែ គួរតែសម្លាប់ចោលនៅលើកោះដើម្បីសន្សំប្រេងសាំង[2274]។ រឿងនេះមានមូលដ្ឋានលើពាក្យចចាមអារ៉ាម[2275]។

៦១៦. ស.ព.អ. អះអាងថា មាស វឿន បានផ្តល់ចម្លើយស៊ីចង្វាក់គ្នាជាមួយសក្ខីកម្មរបស់ ប៉ាក សុខ និង ឯក នី ដែលថា កងពលធំលេខ ១៦៤ បានទទួលបានបញ្ជាឱ្យសម្លាប់ជនជាតិវៀតណាម[2276]។ គាត់ដកស្រង់សក្ខីកម្មរបស់ មាស វឿន ថា កងពលធំលេខ ១ និង កងពលធំលេខ ១៦៤ បានទទួលបញ្ជាដូចគ្នា[2277] ហើយថាមានការណែនាំឱ្យកម្ទេច ប្រជាជនវៀតណាម នៅកម្ពុជាប្រជាធិបតេយ្យ ដែលមិនបានវិលត្រលប់ទៅប្រទេសវៀតណាមវិញ[2278]។ ស.ព.អ. បកស្រាយចម្លើយរបស់ មាស វឿន មិនត្រឹមត្រូវ។ មាស វឿន សំដៅលើឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ មិនមែនឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[2279]។ គាត់បានឆ្លើយតបទៅនឹងសំណួរដែលកម្រិតជាក់លាក់ត្រឹម “ជនជាតិវៀតណាមដែលនៅក្នុងប្រទេសមិនមែនអ្នកដែលបានមកក្នុងនាមជាជនភៀសខ្លួននោះទេ ប៉ុន្តែ *អ្នក*

[2274] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.៤១។ ជើងទំព័រ ៣១៨៩ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.២៩។

[2275] *សូមមើល* កថាខណ្ឌ ៥៥៩ *ខាងលើ*។

[2276] កថាខណ្ឌ ៧៨៦-៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2277] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.02.05-14.04.46។ ជើងទំព័រ ៣២០១ នៃដីកាសន្និដ្ឋានស្តាពរ។

[2278] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 15.55.51-15.58.51។ ជើងទំព័រ ៣២០២ នៃដីកាសន្និដ្ឋានស្តាពរ។

[2279] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 15.55.51-15.58.51 (បើទោះបីជាសហព្រះរាជអាជ្ញារងសួរពីព្រឹត្តិការណ៍ចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ក៏ដោយ ក៏មាស វឿន ឆ្លើយពីព្រឹត្តិការណ៍ចន្លោះឆ្នាំ ១៩៧០-១៩៧៥ ដែរ) នៅម៉ោង 15.58.51-16.03.07 (ទាក់ទងទៅនឹងហេតុការណ៍ដែលកើតឡើងនៅឆ្នាំ ១៩៧០ ដែលក្មួយរបស់គាត់ត្រូវបានបញ្ជូនឱ្យទៅរស់នៅខេត្តតាយនិញនៅស្រុកឃួន ហើយពូជនជាតិឃួនរបស់គាត់គេចាប់)។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 09.18.29-09.20.33 (ដោយបានបញ្ជាក់ថា គាត់បាននិយាយសំដៅទៅលើព្រឹត្តិករណ៍ដែលបានកើតឡើងចន្លោះឆ្នាំ ១៩៧០-១៩៧៥)។

ដែលរស់នៅក្នុងប្រទេសកម្ពុជា"[2280]។ សំណួរនេះមិនអនុវត្តចំពោះប្រជាជនវៀតណាមឆ្លងកាត់ព្រំដែនសមុទ្រ ឬ ព្រំដែនគោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ដូចព្រះរាជអាជ្ញារងបានបញ្ជាក់[2281]។ ដំបូង មាស វឿន បាននិយាយថា មិនមានបញ្ហាឱ្យចាប់ជនភៀសខ្លួនវៀតណាមចូលដែនទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ[2282]។ លោកបាននិយាយថា ជនជាតិវៀតណាមដែលកងពលធំលេខ ១ បានប្រយុទ្ធនៅក្នុងខេត្តកោះកុង ត្រូវបានចាត់ទុកថាជាខ្មាំង ដោយសារតែការប្រយុទ្ធគ្នា[2283] ហើយថា គាត់មិនបាន "កម្ទេច" ជនជាតិវៀតណាមទាំងអស់ដែលត្រូវបានចាប់ខ្លួននៅសមុទ្រឡើយ។ គាត់បានបញ្ជូនពួកគេទៅថ្នាក់លើ[2284]។ ស.ព.អ. អះអាងថា មាស វឿន បានព្យាយាមដកសក្ខីកម្មរបស់គាត់ ដោយអះអាងថា ផែនការនោះគឺដើម្បីប្រមូលផ្តុំនៅក្នុងកន្លែងតែមួយនូវប្រជាជនវៀតណាមទាំងអស់ ដែលកំពុងរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនដើម្បីកម្ទេចពួកគេនោះទេ[2285]។ មាស វឿន បានផ្តល់សក្ខីកម្មអំពីការណែនាំដែលគាត់បានទទួលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទាក់ទងនឹងប្រជាជនវៀតណាមនៅក្នុងប្រទេស[2286]។ គាត់មិនបានដកសក្ខីកម្មមុនៗរបស់គាត់ ដែលលើកឡើងអំពីឆ្នាំ ១៩៧០-១៩៧៥ នោះទេ។

[2280] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D234/2.1.95 នៅម៉ោង 15.55.51-15.58.51 (ការគូសបញ្ជាក់បន្ថែម)។

[2281] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 09.28.27-09.31.38 ("ខ្ញុំនិយាយអំពីឈ្លួនដែលរស់នៅក្នុងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ ៧៥ ដល់ឆ្នាំ ៧៩ ខ្ញុំមិននិយាយអំពីជនភៀសខ្លួនឈ្លួនដែលចូលមកតាមសមុទ្រទេ")។

[2282] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D234/2.1.95 នៅម៉ោង 14.12.12-14.15.00។

[2283] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D234/2.1.96 នៅម៉ោង 09.55.49-09.58.50។

[2284] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 10.06.58-10.10.14។

[2285] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 09.13.46-09.16.14។ កថាខណ្ឌ ៧៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2286] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 09.13.46-09.16.14. (ឈ្លួននៅក្នុង ត្រូវប្រមូលយកមកទុកមួយកន្លែងដើម្បីយើងគ្រប់គ្រង។ ឯក្នុងការដែលថាកម្ទេចនោះ មិនទាន់មានផែនការកម្ទេចទេ) នៅម៉ោង 09.24.01-09.26.03 (នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ សេចក្តីណែនាំចំពោះគាត់ គឺបញ្ជូនឈ្លួនដែលគាត់ចាប់បានអ៊ីចឹង គាត់បញ្ជូនខាងលើ)។

៦១៧. ស.ព.អ. អះអាងថា សន្និបាតភូមិភាគពាយ័ព្យឆ្នាំ ១៩៧៧ បានបញ្ជាក់អំពីគោលនយោបាយ ប.ក.ក. ដើម្បីកម្ទេចប្រជាជនវៀតណាមទាំងអស់[2287]។ គាត់ដកស្រង់សក្ខីកម្មរបស់ មាស វឿន អំពីប្រធានបទ ដែលបានពិភាក្សានៅក្នុងសន្និបាត ហើយដកស្រង់ពីទស្សនាវដ្តី *ទង់បដិវត្តន៍* ស្តីពីសន្និបាត[2288]។ ស.ព.អ. និយាយបំផ្លើស។ មាស វឿន បាននិយាយថា ប្រធានបទមួយនៅក្នុងសន្និបាត (ដែលពាក់ព័ន្ធទូទៅនឹងសហការណ៍) គឺអំពីខ្មាំងស៊ីរូងផ្ទៃក្នុង និង កលល្បិចវៀតណាមដោយសារប្រទេសវៀតណាមមានផែនការវាយប្រហារកម្ពុជាប្រជាធិបតេយ្យ ហើយប្រទេសទាំងពីរកំពុងមានជម្លោះនឹងគ្នា[2289]។ គោលបំណងគឺដើម្បីស្វែងរក និង ចាប់ខ្លួនខ្មាំងដែលជ្រៀតចូលនៅក្នុងជួរកងទ័ព និង សហការណ៍[2290]។ គោលបំណងនេះមិនដូចនឹងផែនការ ឬ ចេតនាសម្លាប់ប្រជាជនវៀតណាមទាំងអស់នោះទេ។ *ទង់បដិវត្តន៍* បញ្ជាក់យ៉ាងច្បាស់ថា ការផ្តោតសំខាន់របស់សន្និបាត គឺ ការងារសហការណ៍ មិនមែនប្រទេសទាំងមូល យោធា ឬ ជនជាតិវៀតណាមក្នុងនាមជាក្រុមខ្មាំងទាំងមូលនោះឡើយ[2291]។

៦១៨. ជម្លោះប្រវត្តិសាស្ត្ររវាងកម្ពុជាប្រជាធិបតេយ្យ និង ប្រទេសវៀតណាម បានបង្ហាញថា គោលនយោបាយ និង ការណែនាំរបស់មជ្ឈិម ទាក់ទងនឹងប្រទេសវៀតណាម មានមូលដ្ឋានលើសន្តិសុខជាតិ និង ការការពារជាតិ។ ទស្សនដែលថាជនជាតិវៀតណាមជា "សត្រូវស្នូរពូជ" របស់កម្ពុជាប្រជាធិបតេយ្យ បានកើតចេញពីការភ័យខ្លាចជាយូរមកហើយថា ប្រទេសវៀតណាមនឹងកាន់កាប់

[2287] កថាខណ្ឌ ៧៩០-៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[2288] ដើងទំព័រ ៣២០៥-១១ នៃដីកាសន្និដ្ឋានស្តាពរ។

[2289] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D234/2.1.95 នៅម៉ោង 14.33.57-14.40.00។

[2290] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.33.57-14.40.00។

[2291] *សូមមើលឧទា.* ទស្សនាវដ្តី ប.ក.ក. ចំណងជើង៖ "ទង់បដិវត្ត" លេខ ៨ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D10.1.59 EN 00399236 KH 00062965៖ "ត្រូវរៀបចំកម្លាំងទៅវៃ វែកម្ទេចខ្មាំង និងសមាសភាពមិនល្អ បង្កប់កាន់កាប់ក្នុងសហការណ៍។ យកកម្លាំងណាទៅវៃ? យកកសិករក្រ និង កសិករកណ្តាល ថ្នាក់ក្រោមទៅវៃ។ បញ្ហានេះមិនមែនភូមិភាគបស្ចិមទេ គ្រប់ភូមិភាគទូទាំងប្រទេសគឺយ៉ាងនេះ។ ដូច្នេះយើងធ្វើវាហ៊ានបានទេ។ ត្រូវឃើញថាសហការណ៍ខ្លាំង និង វណ្ណៈផ្សេងនៅកាន់កាប់នៅឡើយ។ អញ្ចឹងបានជាស្រូវនៅតែបាត់ គោតែបាត់ ពូជវាចេះតែបាត់ សំណាបក៏ចេះតែខូច។ មកពីអ្វី? មកអំពីវណ្ណៈកាន់អំណាចនៅក្នុងសហការណ៍ គឺមិនមែនវណ្ណៈកម្មករ-កសិកររបស់បក្ស"។

ប្រទេស ដែលជាការភ័យខ្លាចកើតចេញពីការបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសវៀតណាម ក្នុងការឈ្លានពានកម្ពុជាប្រជាធិបតេយ្យ[2292]។

២. មាស មុត មិនបានចេញបញ្ជាសម្លាប់អ្នកជាប់ឃុំវៀតណាមនៅហ្នឹងកន្លែង ឬ បញ្ជូនពួកគេទៅដែនគោកដើម្បីសម្លាប់ចោល

៦១៩. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មាស មុត ត្រូវបានគេជូនដំណឹងអំពីឧប្បត្តិហេតុជាក់លាក់ ដែលមានការចាប់ទូក ឬ ចេញបញ្ជាឱ្យសម្លាប់អ្នកជាប់ឃុំវៀតណាមនៅហ្នឹងកន្លែង ឬ បញ្ជូនពួកគេទៅដីគោកដើម្បីសម្លាប់ចោលនោះទេ[2293]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន និង មិនមានមូលដ្ឋានគាំទ្រពី ប៉ាក សុខ ព្រំ សារ៉ាត និង មាស វឿន[2294]។ គាត់ក៏ដកស្រង់ផងដែរ នូវការរៀបរាប់នីមួយៗអំពីការចាប់ទូក និង ភស្តុតាងឯកសារ ដែលមិនគាំទ្រការអះអាងរបស់គាត់[2295]។

៦២០. **ប៉ាក សុខ៖** ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[2296]។ គាត់បាននិយាយថា កងពលធំត្រូវធ្វើរបាយការណ៍អំពីការចាប់ខ្លួន រួមទាំង ថាតើប្រជាជនជាជនភៀសខ្លួនវៀតណាម អ្នកនេសាទថៃ ឬ ជាទាហាន[2297]។ គាត់ក៏បានអះអាងផងដែរថា នាវិករបស់កងទ័ពជើងទឹកបានទទួលបញ្ជាតាមរយៈវិទ្យុដែលថា “បាញ់សម្លាប់វាចោល” ឬ “បញ្ជូនពួកវាទៅដីគោក”[2298]។ “តាមគាត់ដឹង” វាជាក្រមនីតិវិធីប្រតិបត្តិ ដែល មាស មុត បានចេញបញ្ជាឱ្យសម្លាប់[2299]។ ការដឹងឮ ដែលគាត់អាចមាន

[2292] *សូមមើល* កថាខណ្ឌ ៥៥២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែម។

[2293] កថាខណ្ឌ ៧៨៥, ៧៩៦-៩៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៣៨៥-៨៧។

[2294] ជើងទំព័រ ៣១៩០-៩៨, ៣២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2295] ជើងទំព័រ ៣២២៥-២៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2296] *សូមមើល* កថាខណ្ឌ ២៣៣-២៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2297] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.២៨។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.00.46-10.07.37, 11.03.07-11.09.46។ ជើងទំព័រ ៣១៩០-៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[2298] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.១-២។

[2299] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.៣។ កថាខណ្ឌ ៧៨៥ នៃដីកាសន្និដ្ឋានស្តាពរ។

អំពីរបាយការណ៍ ឬ ការបញ្ជាពី មាស មុត ត្រូវបានកម្រិតនៅត្រឹមឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦ តែប៉ុណ្ណោះ នៅពេលគាត់នៅជាមួយកងវរសេនាធំលេខ ៦២។ នៅឆ្នាំ ១៩៧៦ គាត់បានចូលរួមជាមួយកងទ័ពជើងទឹក និង នៅផែឆ្នេរអូរឈើទាលរហូតដល់ឆ្នាំ ១៩៧៨ ដោយធ្វើការចាត់ចែងចំណីអាហារសម្រាប់នាវា[2300]។ ដោយសារតែទីតាំង និង ឋានន្តរស័ក្តិរបស់ ប៉ាក សុខ ការដឹងឮរបស់គាត់អំពីព្រឹត្តិការណ៍បែបនេះ ឬ អំពី "ក្រមនីតិវិធីប្រតិបត្តិ" របស់កងពលធំ មានកម្រិតអប្បបរមា[2301]។

៦២១. ប៉ាក សុខ បានអះអាងថា កងទ័ព ឬ ទូកវៀតណាម ត្រូវបានបញ្ជូនទៅដីគោក[2302]។ គាត់មិនបានដឹងថាតើជនជាតិវៀតណាមត្រូវបានគេបញ្ជូនទៅណាទេ បន្ទាប់ពីពួកគេបានទៅដល់ដីគោក[2303]។ លោកក៏បានអះអាងផងដែរថា មានបញ្ហាពីថ្នាក់លើមកថា នៅពេលដែលមានជនជាតិវៀតណាមត្រូវបានចាប់ខ្លួនម្តងមានគ្នាតិចជាង ២០ នាក់ កងទ័ពត្រូវសម្លាប់ពួកគេចោលភ្លាមៗតែម្តង[2304]។ ប៉ាក សុខ មិនបាននិយាយថា គាត់ចង់មានន័យយ៉ាងម៉េចចំពោះពាក្យ "ថ្នាក់លើ" នោះទេ។ គាត់មិនបាននិយាយថា គាត់បានឃើញ ឬ ឮ មាស មុត ចេញបញ្ជានេះទេ។ គាត់បានអះអាងថា មេបញ្ជាការកងវរសេនាតូចរបស់គាត់បានចេញបញ្ជានៅក្នុងកិច្ចប្រជុំ ហើយថា គាត់មិនដែលបាន

[2300] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.៩។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 11.03.07-11.09.46។

[2301] *សូមមើល* កថាខណ្ឌ ១៦៦ *ខាងលើ* ដែលបានពិភាក្សាអំពីគោលការណ៍រក្សាការសម្ងាត់របស់បក្ស និង ផលប៉ះពាល់លើការវាយតំលៃកស្តុតាងនៅក្នុងរឿងក្តី ០០៣។

[2302] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/297.1.21 នៅម៉ោង 13.41.52-13.46.16។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.04.24-10.07.37។ ជើងទំព័រ ៣១៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2303] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.04.24-10.07.37។

[2304] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.២៥ ។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/297.1.21 នៅម៉ោង 13.58.06-14.00.39។ កថាខណ្ឌ ៧៨៥, ៧៩៦ ជើងទំព័រ ៣១៩៥- ៩៦, ៣២២២ នៃដីកាសន្និដ្ឋានស្តាពរ។

ចូលរួមកិច្ចប្រជុំកងវរសេនាធំ ឬ កងពលធំទេ ព្រោះគាត់មានឋានន្តរសក្តិទាបពេក[2305]។ តាម មេធាវីការពារក្តីដឹង ប៉ាក សុខ គឺជាសាក្សីតែម្នាក់គត់ ដែលអះអាងថាបានឮបញ្ហាបែបនេះ។ ព្រំ សារ៉ាត និង មាស រឿន មិនដែលបានឮអំពីបទបញ្ហាបែបនេះទេ[2306]។ *សូមមើល* កថាខណ្ឌ ៦៤៥ *ខាងក្រោម* ទាក់ទងនឹងចម្លើយរបស់ ប៉ាក សុខ អំពីការចាប់ខ្លួនជនជាតិវៀតណាម និង ជនបរទេសផ្សេងទៀត។

៦២២. **ព្រំ សារ៉ាត៖** ព្រំ សារ៉ាត មិនគាំទ្រការអះអាងរបស់ ស.ព.អ. ទេ។ គាត់ត្រូវបានគេប្រគល់ភារកិច្ច ឱ្យការពារព្រំដែនសមុទ្រ កុំឱ្យទូកប្រដាប់អាវុធចូលទៅក្នុងទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ[2307]។ គាត់បានឮតាមវិទ្យុថា កងទ័ពវៀតណាម ឬ ទូកវៀតណាម ត្រូវបានចាប់ខ្លួន[2308]។ គាត់មិនបាន និយាយថា មនុស្សត្រូវបានសម្លាប់នៅហ្នឹងកន្លែង ឬ ត្រូវបញ្ជូនទៅជីគោក ដើម្បីសម្លាប់ចោលនោះ ទេ។

៦២៣. **មាស រឿន៖** មាស រឿន មិនអាចជឿជាក់បានឡើយ[2309]។ សក្ខីកម្មរបស់គាត់ទាក់ទងនឹងការចាប់ ខ្លួនជនជាតិវៀតណាមនៅសមុទ្រ ក៏មិនគាំទ្រការអះអាងរបស់ ស.ព.អ. ដែរ។ គាត់បាននិយាយថា គោលនយោបាយបក្ស គឺដើម្បីទប់ទល់នឹងការប៉ុនប៉ងឈ្លានពានរបស់វៀតណាម[2310]។ គាត់ក៏បាន

[2305] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ឯកសារ D114/297.1.21 នៅម៉ោង 14.04.37-14.09.00។

[2306] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 នៅម៉ោង 09.58.11-10.04.17, 10.06.07-10.08.05។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 11.21.53-11.23.40។

[2307] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 នៅម៉ោង 09.58.11-10.00.59, 10.10.25-10.31.39, 13.54.26-13.58.03។ ជើងចំព័រ ៣១៩៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2308] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ឯកសារ D234/2.1.92 នៅម៉ោង 15.49.12-15.55.34។ ជើងចំព័រ ៣១៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2309] *សូមមើល* កថាខណ្ឌ ១៩៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2310] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 09.13.46-09.18.29។ ជើងចំព័រ ៣១៩៤ នៃដីកាសន្និដ្ឋានស្តាពរ។

និយាយផងដែរថា មានផែនការកម្ទេចខ្មាំងយួន និង ខ្មាំងស៊ីរួងផ្ទៃក្នុង[2311]។ គាត់មិនបានដឹងថាតើពួកគេត្រូវបានកម្ទេចដែរឬយ៉ាងណា[2312]។ មាស វឿន ក្រោយមក បាននិយាយថា មិនមានផែនការកម្ទេចយួនទេ។ គាត់បានបញ្ជូនជនជាតិវៀតណាម និង ជនភៀសខ្លួន ដែលចាប់ខ្លួនបាន ទៅថ្នាក់លើ ហើយមិនដឹងថាមានអ្វីកើតឡើងចំពោះពួកគេឡើយ[2313]។ គាត់ក៏បានបញ្ជាក់ផងដែរ អំពីបទបញ្ជាកុំឱ្យចាប់ខ្លួនជនភៀសខ្លួន[2314]។ ចម្លើយរបស់គាត់ ទាក់ទងតែជាមួយនឹងកងពលធំលេខ ១ ប៉ុណ្ណោះ។ គាត់មិនបានដឹងពីកិច្ចការរបស់កំពង់សោមទេ[2315]។

៦២៤. ស.ព.អ. អះអាងថា សាក្សី និង ឯកសារ ពិភាក្សាឧទាហរណ៍លម្អិតអំពីជនជាតិវៀតណាមដែលត្រូវចាប់ខ្លួនបាន ហើយត្រូវបានសម្លាប់នៅសមុទ្រ ឬ នៅវាលពិឃាតចេងហោង និង ទឹកសាប[2316]។ ស.ព.អ. ដកស្រង់ សំ សោម ប៉ាក សុខ ឡាក់ សាផាន ឯក នី ជុំ ជី ញូង ជ្រោង និង ទូច សៀលី[2317]។ សាក្សីទាំងនេះភាគច្រើន មិនមានចំណេះដឹងផ្ទាល់អំពីការសម្លាប់បែបនេះទេ។ សំ សោម បានឃើញទូកវៀតណាមមួយដែលចាប់បាន ត្រូវបានគេនាំទៅកោះតាង ហើយបានឮសហសេវិកនិយាយថា ប្រជាជនវៀតណាមត្រូវបានសម្លាប់ចោល។ គាត់បានប៉ាន់ស្មានថា នេះមានន័យថា ពួកគេត្រូវបានសំលាប់ភ្លាមៗ ឬ ត្រូវគេនាំទៅដីគោកសម្លាប់ចោល[2318]។ ប៉ាក សុខ

[2311] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 13.42.30-13.44.27។ ជើងទំព័រ ៣១៩៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2312] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 13.42.30-13.44.27។

[2313] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.96 នៅម៉ោង 09.24.01-09.26.03។ *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.17.20-14.19.04។ ជើងទំព័រ ៣១៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2314] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.08.12-14.15.00។

[2315] *រឿងក្តី ន្ឃន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០១២ ឯកសារ D98/3.1.179 នៅម៉ោង 13.34.35-13.37.22 (បានផ្តល់សក្ខីកម្មអំពីសារទូរលេខដែលអះអាងចេញពី មាស មុត ទាក់ទងទៅនឹងការបាញ់សម្លាប់ជនជាតិយួន ១២០ នាក់ និង ពន្យារការដោះលែងជនជាតិថៃ)។

[2316] កថាខណ្ឌ ៧៩៧ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៥១១។

[2317] ជើងទំព័រ ៣២២៥ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ដូចខាងលើ* ជើងទំព័រ ១៥០៩, ១៥១២។

[2318] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/57 ន.២៦-២៨។

បានអះអាងថាបានឃើញឧប្បត្តិហេតុមួយ ដែលក្នុងនោះជនជាតិវៀតណាមចំនួន ៣ នាក់ ត្រូវបានសម្លាប់ចោលនៅលើកោះពូឡូវ៉ៃ[2319]។ ការអះអាងរបស់គាត់ថា មនុស្សត្រូវបានសម្លាប់នៅចម្ការធូរេន គឺជាពាក្យចចាមអារ៉ាម។ គាត់បានឮអំពីការសម្លាប់ពីទាហាននៅក្នុងកងវរសេនាធំរបស់គាត់[2320]។ ឡាក់ សាផាន បានប៉ាន់ស្មានអំពីទឹកសាប។ គាត់មិនបានដឹងថា ទឹកសាបត្រូវបានគេប្រើប្រាស់សម្រាប់ធ្វើអ្វីទេនៅក្នុងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2321]។ គាត់បានទៅលេងទឹកសាប ក្រោយពីរបបនេះបានដួលរលំ[2322]។ ចម្លើយរបស់ ឯក នី គឺជាពាក្យចចាមអារ៉ាម។ គាត់មិនមានវត្តមានក្នុងអំឡុងពេលនៃការកាប់សម្លាប់ ដែលបានចោទប្រកាន់ថាបានកើតឡើងនៅលើកោះតាងនោះទេ[2323]។ គាត់បានឮថាជនភៀសខ្លួនវៀតណាមត្រូវបានបញ្ជូនទៅចម្ការធូរេនដើម្បីធ្វើជី[2324]។ ជុំ ជី បានឮអំពីការកាប់សម្លាប់ជនភៀសខ្លួនវៀតណាម ដែលអះអាងថាធ្វើនៅលើកោះពូឡូវ៉ៃពីអ្នកដទៃ[2325]។ ញូង ជ្រោង មិនដែលបានឃើញចម្ការធូរេននោះទេ។ គាត់បានឮអំពីចម្ការនេះពីអ្នកដទៃ[2326]។ ទូច សៀលី ក៏បានឮអំពីចម្ការធូរេនពីអ្នកដទៃដែរ។ គាត់មិនដឹងពីទីតាំងវាទេ[2327]។ សំ សោម បានលើកឡើងថា រដ្ឋាភិបាលបានចាត់តាំងទាហានពិការ និង មនុស្សចាស់ឱ្យថែទាំដើមឈើនៅចម្ការធូរេន។ គាត់មិនដែលបានឮអំពីការសម្លាប់នៅទីនោះទេ[2328]។ *សូមមើល*

[2319] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឆ.២០។

[2320] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.43.36-10.46.23។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឆ.៣៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/26 ឆ.១៦។

[2321] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/2 ឆ.៥។

[2322] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/123 ឆ.៨-៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/2 ឆ.៧។

[2323] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 ឆ.៣៣-៣៤ (ដោយបាននិយាយថា គាត់ចាប់តែទូកទេ)។

[2324] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 ឆ.២៩, ឆ.៣២។

[2325] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជី ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ D114/262 ឆ.៤៩, ឆ.៥១។

[2326] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6 ឆ.៤០។

[2327] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សៀលី ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/16 ឆ.៣២។

[2328] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/109 ឆ.១៧-១៨។

កថាខណ្ឌ ៦៦៤ ដល់កថាខណ្ឌ ៦៦៥ *ខាងក្រោម* ទាក់ទងនឹងតម្លៃជាភ័ស្តុតាងទាបនៃរបាយការណ៍យោធារបស់កម្ពុជាប្រជាធិបតេយ្យនិង ក្រសួងការពារជាតិអាមេរិកដែល ស.ព.អ. ដកស្រង់[2329]។

៦២៥. ស.ព.អ. ដកស្រង់រឿងរ៉ាវរបស់ មុត ម៉ៅ ដែលថា នៅចុងឆ្នាំ ១៩៧៨ ស្ត្រីវៀតណាមម្នាក់ និង កូនពីរនាក់ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ត្រូវបានសម្លាប់នៅជិតផ្ទះរបស់ មាស មុត[2330]។ មុត ម៉ៅ គឺមិនអាចជឿជាក់បាន[2331]។ រឿងរ៉ាវរបស់គាត់ភាគច្រើនគឺមានមូលដ្ឋានលើពាក្យចចាមអារ៉ាមរបស់និរសារកងពលធំលេខ ១៦៥[2332]។ *សូមមើល* កថាខណ្ឌ ៥៩៥ ដល់កថាខណ្ឌ ៥៩៦ *ខាងលើ* ចំពោះសេចក្តីសន្និដ្ឋានស្តីពីការអះអាងរបស់ ស.ព.អ. ថា អ្នកជាប់ឃុំវៀតណាមត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[2333]។

៦២៦. ស.ព.អ. អះអាងថា មាស មុត ធ្លាប់បានរិះគន់បុគ្គលិកក្រោមបង្គាប់ ចំពោះការសម្លាប់បុគ្គលម្នាក់ដោយមិនមានការអនុញ្ញាត ហើយនៅពេល មាស មុត អវត្តមាន អនុប្រធានរបស់គាត់ អាចចេញបញ្ជាអោយចាប់ខ្លួន ឬ សម្លាប់ចោលបាន[2334]។ ស.ព.អ. និយាយបំផ្លើស។ ភស្តុតាងបង្ហាញថា ការបញ្ជាឱ្យសម្លាប់ អាចចេញដោយគណៈកម្មាធិការកងពលធំលេខ ១៦៥ បន្ទាប់ពីទទួលបានការយល់ព្រមពីមជ្ឈិមបក្ស។ *សូមមើល* កថាខណ្ឌ ៥១៧ *ខាងលើ* ចំពោះសេចក្តីសន្និដ្ឋានស្តីពីការអះអាងទាំងនេះ។ បើទោះបីជាការអះអាងទាំងនេះអាចជឿជាក់បានក៏ដោយ ក៏វាមិនបានបង្ហាញឱ្យឃើញថា មាស មុត មានចេតនាប្រល័យពូជសាសន៍ទាក់ទងនឹងជនជាតិវៀតណាមនោះឡើយ។

៣. គ្មានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញថា ប្រជាជនវៀតណាមរាប់រយនាក់ ឬ រាប់ពាន់នាក់ ត្រូវបានសម្លាប់ចោលដោយមិនលើកលែងដោយកងពលធំលេខ ១៦៥

៦២៧. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា ជនជាតិវៀតណាម “រាប់រយ ឬ រាប់ពាន់នាក់” ដែលចាប់ខ្លួនបាននៅសមុទ្រ ត្រូវបានសម្លាប់ដោយមិន

[2329] ដើងចំពីរ ៣២២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2330] កថាខណ្ឌ ៧៩៧ ដើងចំពីរ ៣២២៦ នៃដីកាសន្និដ្ឋានស្តាពរ។ *សូមមើលផងដែរ ឯកសារខាងលើ* កថាខណ្ឌ ១៤១។

[2331] *សូមមើល* កថាខណ្ឌ ២៦៦-៦៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2332] *សូមមើល កថាខណ្ឌ* ៥៦២ *ខាងលើ* ទាក់ទងនឹងរឿងរ៉ាវរបស់ មុត ម៉ៅ។

[2333] កថាខណ្ឌ ៧៩៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2334] កថាខណ្ឌ ៧៨៥ នៃដីកាសន្និដ្ឋានស្តាពរ។

លើកលែងដោយកងពលធំលេខ ១៦៤[2335]។ ស.ព.អ. ដកស្រង់ជាចម្បងចម្លើយដែលមិនអាចជឿជាក់បាន ឬ គ្មានមូលដ្ឋានគាំទ្ររបស់ ប៉ាក សុខ ឯក នី ព្រំ សារ៉ាត និង អ៊ូ គីម ព្រមទាំងភ័ស្តុតាងឯកសារផងដែរ។ ស.ព.អ. លើកឡើងម្តងហើយម្តងទៀតនូវការអះអាងនៅក្នុងផ្នែក VIII.ខ នៃសេចក្តីសន្និដ្ឋានស្តាពររបស់គាត់[2336]។ ដូចបានពន្យល់នៅក្នុងផ្នែកទី IV.ច *ខាងក្រោម* គាត់បំផ្លើសដោយដកស្រង់ភ័ស្តុតាងដែលមិនអាចជឿជាក់បាន និង គ្មានមូលដ្ឋានគាំទ្រ។

៦២៨. ស.ព.អ. ដកស្រង់តែ ព្រំ សារ៉ាត និង ប៉ាក សុខ ដើម្បីគាំទ្រការអះអាងរបស់គាត់ទាក់ទងនឹងលក្ខណៈនៃការកាប់សម្លាប់ដោយមិនរើសមុខ[2337]។ ស.ព.អ. បង្ហាញមិនត្រឹមត្រូវ និង ជ្រើសរើសយកចំណុចដែលខ្លួនចង់បានពីក្នុងសក្ខីភាពរបស់ ព្រំ សារ៉ាត។ ព្រំ សារ៉ាត បាននិយាយថា ជនជាតិវៀតណាមដែលព្យាយាមឆ្លងកាត់ដែនទឹកនៅភាគខាងកើតកោះតាងត្រូវបានចាប់ខ្លួន[2338]។ គាត់ក៏បាននិយាយផងដែរថា ជនភៀសខ្លួនវៀតណាមមួយចំនួនត្រូវបានចាប់ខ្លួន[2339]។ គាត់បានលើកឡើងពីឧប្បត្តិហេតុតែមួយគត់[2340] ដែលគាត់បានឮពីទាហានផ្សេងទៀត[2341]។ ព្រំ សារ៉ាត បាននិយាយថា មានលទ្ធផលខុសគ្នាក្នុងចំណោមជនជាតិវៀតណាមដែលបានចាប់ខ្លួន៖ ជនភៀសខ្លួនវៀតណាមត្រូវដោះលែង ខណៈទាហានវៀតណាម ឬ ត្រូវបានសង្ស័យថាជាឃ្មុំជន ត្រូវគេសួរ

[2335] កថាខណ្ឌ ៧៩២, ៧៩៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2336] ជើងទំព័រ ៣២១២-២០ នៃដីកាសន្និដ្ឋានស្តាពរ។

[2337] ជើងទំព័រ ៣២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2338] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ឯកសារ D234/2.1.92 នៅម៉ោង 10.54.04-10.57.27។ ជើងទំព័រ ៣២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2339] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ឯកសារ D234/2.1.93 នៅម៉ោង 10.47.35-10.49.35។

[2340] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.92 នៅម៉ោង 10.54.04-10.57.27 និង *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 នៅម៉ោង 10.45.36-10.51.13។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.92 នៅម៉ោង 15.49.12-15.55.34។ ជើងទំព័រ ៣២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2341] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.93 នៅម៉ោង 10.12.16-10.31.39។

ចម្លើយ[2342]។ ព្រុំ សារ៉ាត បាននិយាយថា លោកមិនដែលដឹងអំពីគោលការណ៍ ការណែនាំ ឬ បទបញ្ជាណាមួយ ឱ្យសម្លាប់ទាហក និង ជនស៊ីវិលវៀតណាមឡើយ[2343]។ ព្រុំ សារ៉ាត ក៏បានថ្លែងផងដែរថា សុន្ទរកថារបស់ ប៉ុល ពតទាក់ទងនឹងខ្មែរម្នាក់កម្ទេច "ឃួន" ៣០ នាក់ គឺសំដៅលើទាហានកម្ពុជាប្រជាធិប តេយ្យម្នាក់ កម្ទេចទាហានវៀតណាមបាន ៣០ នាក់ មិនមែនជាការកម្ទេចជនជាតិវៀតណាមទូទៅនោះទេ[2344]។ ព្រុំ សារ៉ាត និង សាក្សីផ្សេងទៀត លើកឡើងផ្ទុយពីការអះអាងរបស់ ប៉ាក សុខ ដែលថា គាត់គ្រាន់តែឮបញ្ជាឱ្យចាប់ខ្លួនជនអៀសខ្លួន មិនមែនបញ្ជាឱ្យដោះលែងពួកគេនោះទេ[2345]។ សាក្សីទាំងនេះបញ្ជាក់ថាបានទទួលបញ្ជាពី សុន សេន និង មេបញ្ជាការថ្នាក់ក្រោមៗ មិនឱ្យចាប់ខ្លួនជនអៀសខ្លួន[2346]។

៤. សេចក្តីសន្និដ្ឋាន

៦២៩. មាស មុត មិនមានចេតនាសម្លាប់ប្រជាជនវៀតណាម ដែលត្រូវបានចាប់ខ្លួន ដោយកងពលធំលេខ ១៦៤ និង បំផ្លាញពួកគេ ក្នុងនាមជាក្រុមជាតិពិន្ទុនោះទេ។ មាស មុត ក៏មិនបានចេញបញ្ជា និង ធ្វើសកម្មភាពសំខាន់ៗ ដើម្បីរួមចំណែកក្នុងអំពើប្រល័យពូជសាសន៍ជនជាតិវៀតណាមនោះដែរ។ ភ័ស្តុតាងប្រវត្តិសាស្ត្រ និង បរិបទពាក់ព័ន្ធ បង្ហាញថា កងពលធំលេខ ១៦៤ បានការពារដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ ប្រឆាំងនឹងសកម្មភាពយោធាឈ្លានពាន និង ការលុកលុយរបស់ប្រទេសវៀតណាម។ មាស មុត មិនមានចេតនាប្រល័យពូជសាសន៍ ឬ ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមនោះទេ។

[2342] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ ឯកសារ D234/2.1.92 នៅម៉ោង 10.42.01-10.48.36 (ដែលបញ្ជាក់ចម្លើយរបស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា)។

[2343] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១៦ឯកសារ D234/2.1.93 នៅម៉ោង 15.17.22-15.19.11។

[2344] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ឯកសារ D234/2.1.92 នៅម៉ោង 15.25.55-15.33.17។

[2345] *សូមមើល រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ឯកសារ D114/297.1.21 នៅម៉ោង 14.29.11-14.31.58។ ជើងទំព័រ ៣២២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2346] *សូមមើល* កថាខណ្ឌ ៥៦១ *ខាងលើ* ។

ង. មាស មុត មិនទទួលខុសត្រូវចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភសេពសន្តវៈ នៅតំបន់កំពង់សោមនោះទេ។ បើទោះបីជាគាត់ទទួលខុសត្រូវក៏ដោយ ក៏អំពើទាំងនេះមិនមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ អាចធ្វើឱ្យគាត់ក្លាយជាបុគ្គលម្នាក់ ក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ

៦៣០. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ចំនៀមទម្លាប់អន្តរជាតិចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[2347]។ បើទោះបីជា ស.ច.ស. រកឃើញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏ភស្តុតាងមិនបានបង្ហាញថា មាស មុត ទទួលខុសត្រូវចំពោះការរៀបអាពាហ៍ពិពាហ៍បែបនេះនៅក្នុងកងពលធំលេខ ១៦៤ ឬ កំពង់សោមនោះដែរ។ ស.ព.អ. ធ្វើការអះអាងយ៉ាងទូលំទូលាយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្តវៈ និង តួនាទីដែលត្រូវបានអះអាងថាជារបស់ មាស មុត នៅក្នុងដំណើរការនេះ ប៉ុន្តែពឹងផ្អែកលើសាក្សីមួយចំនួនតូចតែប៉ុណ្ណោះ។ គាត់មិនអើពើ ឬ បន្តុយចំនួនសាក្សីដែលបានជ្រើសរើសរៀបការ ដែលមិនត្រូវបានគេដាក់ទណ្ឌកម្មចំពោះការបដិសេធមិនរៀបការ ឬ ជ្រើសរើសរួមភេទក្រោយការរៀបអាពាហ៍ពិពាហ៍។ គាត់មិនបានបង្ហាញភស្តុតាងថាតើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំចំនួនប៉ុន្មាន បានកើតឡើងនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត។ គាត់ខកខានមិនបានបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ទាំងនេះមានស្ថានទម្ងន់ស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត។ សាក្សីខ្លះអះអាងថា ពួកគេខ្លាចនឹងបដិសេធមិនព្រមរៀបការនោះទេ។ ការភ័យខ្លាចមិនមែនជាកត្តាដ៏ធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីធ្វើឱ្យអំពើដូចបានចោទប្រកាន់នោះ ក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ មានសាក្សីតែម្នាក់ប៉ុណ្ណោះដែលបាននិយាយថា គាត់ត្រូវបានគេដាក់ទណ្ឌកម្មលើរាងកាយដោយសារបដិសេធមិនព្រមរៀបការ។ នាងមិនស្ថិតនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ មាស មុត ទេ។ បើទោះបីជា ស.ច.ស.អ. រកឃើញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភសេពសន្តវៈបានកើតឡើងនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត ហើយថា អំពើនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏ការទទួលខុសត្រូវចំពោះអំពើទាំងនេះ មិនបានធ្វើឱ្យ មាស មុត ក្លាយជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនោះដែរ។

[2347] *សូមមើល* កថាខណ្ឌ ១២៩-៣៣ *ខាងលើ* ទាក់ទងនឹងព្រឹត្តិរបស់មេធាវីការពារក្តីជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

១. មាស មុត មិនទទួលខុសត្រូវចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភសេពសន្ថវៈ ដែលបានកើតឡើងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់

៦៣១. ស.ព.អ. ដកស្រង់ភ័ស្តុតាងតិចតួច ដើម្បីគាំទ្រការអះអាងរបស់គាត់ទាក់ទងនឹងការទទួលខុសត្រូវរបស់ មាស មុត ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវៈនៅក្នុងតំបន់កំពង់សោម[2348]។ គាត់ខកខានមិនបានរកមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថា ការរៀបអាពាហ៍ពិពាហ៍នៅកំពង់សោមមានលក្ខណៈពិសេស ដែលមិនមានដូចនៅកន្លែងផ្សេងទៀតនៅក្នុងប្រទេស[2349]។ គាត់អះអាងថា ការរៀបអាពាហ៍ពិពាហ៍នៅខេត្តកំពង់សោម មានភាពខុសប្លែកពីគេ ដោយសារតែកងពលធំលេខ ១៦៥ មានកងវរសេនាតូចនារីតែមួយ ហេតុដូច្នេះ នារីមកពីសហករណ៍ និង ការដ្ឋានកំពង់សោម ឬ មកពីក្រៅកំពង់សោម មករៀបការជាមួយបុរសនៅក្នុងកងពលធំលេខ ១៦៥[2350]។ គាត់មិនបានដកស្រង់សាក្សី ឬ ភស្តុតាងឯកសារ ដើម្បីបង្ហាញអំពីរបៀបដែលស្ថានភាពនេះខុសពីការរៀបអាពាហ៍ពិពាហ៍ នៅតាមកន្លែងផ្សេងទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ស.ព.អ. ទទួលស្គាល់នៅក្នុងផ្នែក VIII. ជ នៃសេចក្តីសន្និដ្ឋានសន្និដ្ឋានស្តាពររបស់គាត់[2351] ថា ការរៀបអាពាហ៍ពិពាហ៍មួយចំនួននៅកំពង់សោម បានប្រព្រឹត្តទៅតាមរបៀបស្រដៀងគ្នា ដូចការរៀបអាពាហ៍ពិពាហ៍នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យដែរ។

៦៣២. ស.ព.អ. បានធ្វើការអះអាងទូលំទូលាយជាច្រើនទាក់ទងនឹង មាស មុត និង ការរៀបអាពាហ៍ពិពាហ៍នៅកំពង់សោម។ គាត់គាំទ្រការអះអាងនីមួយៗ ដោយប្រើប្រាស់ប្រភពតែមួយ ដែលមិនគាំទ្រការអះអាងរបស់គាត់៖

- ស.ព.អ. អះអាងថា យ៉ាងហោចណាស់ នៅក្នុងវគ្គរៀនសូត្រនយោបាយមួយ មាស មុត និង ញ៉ាន បានពិភាក្សាពីគោលនយោបាយ ដើម្បីបង្កើនការរៀបអាពាហ៍ពិពាហ៍នៅកំពង់

[2348] ផ្នែក VIII.ជ.៤-៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2349] កថាខណ្ឌ ៨២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2350] កថាខណ្ឌ ៨២១ នៃដីកាសន្និដ្ឋានស្តាពរ។

[2351] *សូមមើលខ.ផ.* កថាខណ្ឌ ៨២៧ នៃដីកាសន្និដ្ឋានស្តាពរ (ដែលអះអាងថា "ដូចនៅផ្នែកផ្សេងទៀតនៃកម្ពុជាប្រជាធិបតេយ្យដែរ" ប្តីប្រពន្ធភាគច្រើនមិនដែលស្គាល់គ្នាទាល់សោះ ឬ ស្ទើរតែមិនបានឃើញអនាគតដៃគូរបស់ខ្លួន មុនពិធីរៀបអាពាហ៍ពិពាហ៍) កថាខណ្ឌ ៨២៨ (ដែលអះអាងថា "ជាលំនាំដូចៗគ្នាដែលមាននៅទូទាំងប្រទេស" មនុស្សជាច្រើនគូមិនបានទទួលការជូនដំណឹង") កថាខណ្ឌ ៨៣៥ (សំដៅទៅលើ "ជនរងគ្រោះរាប់ពាន់ផ្សេងទៀតទូទាំងប្រទេស" មិនបានព្រមព្រៀងចំពោះអាពាហ៍ពិពាហ៍របស់ពួកគេ)។

សោម[2352]។ គាត់បានដកស្រង់តែ លៀត ឡន ប៉ុណ្ណោះ[2353]។ លោក លៀត ឡន បានថ្លែងថា នៅក្នុងវគ្គអប់រំដែលលោកបានចូលរួម មាស មុត និង ញ៉ាន បាននិយាយថា ដើម្បីបង្កើនចំនួនប្រជាជន និង បំពេញចិត្តអ្នកដែលបាន *ស្នើសុំ* រៀបអាពាហ៍ពិពាហ៍ រាល់សំណើសុំរៀបអាពាហ៍ពិពាហ៍ទាំងអស់គួរត្រូវបានពិនិត្យឡើងវិញ ហើយប្រជាជនគួររៀបអាពាហ៍ពិពាហ៍[2354]។ ការពិភាក្សាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ដែលបានស្នើសុំមិនមែនជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ លោក លៀត ឡន ក៏បាននិយាយផងដែរថា គាត់ជឿថាផែនការនេះគឺមកពីថ្នាក់លើ មិនមែនមកពី មាស មុត នោះទេ ពីព្រោះការរៀបអាពាហ៍ពិពាហ៍បែបនេះក៏កើតមានឡើងនៅជនបទផងដែរ[2355]។

- ស.ព.អ. អះអាងថា មាស មុត បានណែនាំដល់បុគ្គលិកក្រោមបង្គាប់របស់គាត់ឱ្យរៀបចំ និង អបអរពិធីប្តេជ្ញា[2356]។ គាត់ដកស្រង់តែ ម៉ាក ឈឿន ប៉ុណ្ណោះ[2357]។ ស.ព.អ. អះអាងថា ម៉ាក ឈឿន បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ថា មាស មុត បានណែនាំគាត់ឱ្យរៀបការ[2358]។ ស.ព.អ. បង្ហាញភ័ស្តុតាងមិនត្រឹមត្រូវ។ ម៉ាក ឈឿន មិនបានផ្តល់ចម្លើយនេះទេ។ ប្រពន្ធរបស់គាត់ឈ្មោះ សួន វ៉ាត ជាអ្នកផ្តល់ចម្លើយនេះ[2359]។ គាត់មានវត្តមានក្នុងអំឡុងពេលនៃកិច្ចសម្ភាសន៍ និង បានឆ្លើយសំណួរទាំងនេះ[2360]។ គាត់មិនបាននិយាយថាហេតុអ្វីបានជាគាត់គិតថា មាស មុត បានណែនាំប្តីរបស់គាត់ឱ្យរៀបការនោះទេ។ ម៉ាក ឈឿន បាននិយាយថា គាត់ និង ប្រពន្ធគាត់ បានជ្រើសរើសរៀបការជាមួយគ្នា

[2352] កថាខណ្ឌ ៨២២ នៃដីកាសន្និដ្ឋានស្តាពរ។

[2353] ជើងទំព័រ ៣៣២១-២២ នៃដីកាសន្និដ្ឋានស្តាពរ។

[2354] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ន.២០៦។

[2355] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ន.២០៩។

[2356] កថាខណ្ឌ ៨២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2357] ជើងទំព័រ ៣៣២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2358] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ាក ឈឿន ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.7a EN 00969949 KH 00926329។ ជើងទំព័រ ៣៣២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2359] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ាក ឈឿន ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.7a EN 00969949-00969950 KH 00926329-00926230 (ការគូសបញ្ជាក់បន្ថែម)៖ "ដានី៖ កាលប្លឹងមានពីណាគេណែនាំ មានមតិណែនាំឱ្យការ? **វ៉ាត៖** តាម៉ុក។ ដានី៖ តាម៉ុត។ **វ៉ាត៖** ចាស!"។

[2360] *សូមមើលខាង.* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ាក ឈឿន ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.7a EN 00969932, 00969939, 00969942 KH 00926309, 00926317, 00926320-00926321។

ដោយបានពន្យល់ថា "ខ្ញុំស្គាល់គ្នា ដូចថាកងដឹកជញ្ជូនអញ្ចឹង ហើយកងទ័ពស្គាល់គ្នា ដល់អញ្ចឹង ទៅ ឃើញទៅ ខ្ញុំស្នើគេ សួរគេទៅ សួរគេថា គេស្រឡាញ់យើង ដល់ស្រឡាញ់ ក៏ស្រឡាញ់ទៅ ដល់អត់ ក៏អត់ទៅ"[2361]។

- ស.ព.អ. អះអាងថា ជួនកាល "មានគូស្វាមីភរិយាជាច្រើន" ដែលធ្វើឱ្យមនុស្សរៀបការជាមួយអ្នកផ្សេង ក្រៅពីដៃគូដែលខ្លួនចង់រៀបការ ឬ ភាន់ច្រឡំអត្តសញ្ញាណប្តី ឬ ប្រពន្ធរបស់ខ្លួន[2362]។ គាត់ដកស្រង់ ឈៀត ឡន តែមួយគត់[2363]។ ចម្លើយរបស់ ឈៀត ឡន គឺជាពាក្យចចាមអារ៉ាម។ គាត់បានឮរឿងនេះពីអ្នកផ្សេងទៀត[2364]។

- ស.ព.អ. អះអាងថា "ទាហាននារីភាគច្រើន" ដែលបានរៀបការ មិនហ៊ានបដិសេធឡើយ[2365]។ គាត់ដកស្រង់តែ សុខ នាង ប៉ុណ្ណោះ[2366]។ សុខ នាង បានអះអាងថា "ជាទូទៅ នារីមិនហ៊ានប្រកែកឡើយ"[2367]។ ប៉ុន្តែ គាត់បានបដិសេធមិនព្រមរៀបការ ហើយមិនប្រឈមមុខនឹងផលវិបាកអ្វីឡើយ[2368]។ គាត់បាននិយាយថា គូស្វាមីភរិយាមួយចំនួនបានស្នើសុំ និង យល់ព្រមរៀបការជាមួយគ្នា[2369]។

[2361] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ាក ឈ្បឿន ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.7a EN 00969950 KH00925329-00926330។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D234/2.1.141 នៅម៉ោង 15.51.10-15.57.39 (ឆ្លើយថា គាត់ និង ប្រពន្ធរបស់គាត់ បានឃើញមុនពេលរៀបការ ហើយគាត់បានស្នើសុំពួកគាត់រៀបការ ទោះជាមិនមានថាស្រឡាញ់អីពីមុនមកក្តី មុនរៀបការ ពួកគេបានសួរជាយោបល់ សួរជាអីទៅ ក៏គេឯកភាពទៅ)។

[2362] កថាខណ្ឌ ៨២៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2363] ជើងទំព័រ ៣៣៣៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2364] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈៀត ឡន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ឧ.២១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈៀត ឡន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 ឧ.៧។

[2365] កថាខណ្ឌ ៨២៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2366] ជើងទំព័រ ៣៣៣៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2367] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ឧ.៤៥។

[2368] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ឧ.៤៥។

[2369] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ឧ.៤៦។

- ស.ព.អ. អះអាងថា ការអនុញ្ញាតត្រូវស្នើសុំពីថ្នាក់លើចំពោះការផ្គូរផ្គងទាំងអស់ មិនថាបានស្នើ ឬ មិនបានស្នើនោះទេ[2370]។ គាត់ដកស្រង់តែ លៀត ឡន ប៉ុណ្ណោះ[2371]។ ចម្លើយរបស់ លៀត ឡន គឺរៀបរាប់តែអំពីបទពិសោធន៍របស់គាត់ផ្ទាល់ ក្នុងការរៀបចំអាពាហ៍ពិពាហ៍ ឱ្យបុរសនៅក្នុងកងរបស់គាត់ ដែលបានស្នើសុំរៀបការប៉ុណ្ណោះ[2372]។

៦៣៣. ស.ព.អ. អះអាងថា "គូស្វាមីភរិយាជាច្រើនដែលត្រូវបានគេបង្ខំឱ្យរៀបការនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត" បានទទួលការជូនដំណឹងជាមុនតិចតួចអំពីការរៀបអាពាហ៍ពិពាហ៍ ឬ មិនទទួលបានការជូនដំណឹងទាល់តែសោះ[2373]។ គាត់ដកស្រង់សាក្សីប្រាំនាក់[2374]។ ក្នុងនោះ សំ វុទ្ធី មិនបានរៀបការនោះឡើយ[2375]។ ចម្លើយរបស់មនុស្ស ៤ នាក់ មិនបានបង្ហាញថា មនុស្ស "ជាច្រើន" មិនបានទទួលការជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ពួកគេជាមុន ឬ បានទទួលការជូនដំណឹងតិចតួចនោះឡើយ។

៦៣៤. ស.ព.អ. អះអាងថា ដូចជនរងគ្រោះរាប់ពាន់នាក់ផ្សេងទៀតនៅទូទាំងប្រទេស បរិយាកាសទូទៅនៃការភ័យខ្លាច មានន័យថា មនុស្សដែលត្រូវបានបង្ខំឱ្យរៀបការនៅខេត្តកំពង់សាម មិនបានយល់ព្រមដោយពិតប្រាកដ និង ត្រូវទទួលយកការរៀបអាពាហ៍ពិពាហ៍ ឬ ប្រឈមមុខនឹងការគំរាមកំហែង ឬ ការដាក់ទណ្ឌកម្ម[2376]។ គាត់ដកស្រង់សាក្សីចំនួន ១១ នាក់[2377]។ សាក្សីទាំងនេះមិនបាននិយាយថា មាស មុត បានគំរាមកំហែង ឬ បានបញ្ជាឱ្យដាក់ទណ្ឌកម្មលើការបដិសេធមិនព្រមរៀបការឡើយ។ ស.ព.អ. មិនបានអះអាងថាមាស មុត បានធ្វើដូច្នេះនោះទេ។ យឹម ស្រឿង បានអះអាងថា ទាហានដែលមិនចង់រៀបការនឹងត្រូវចាប់ខ្លួន ហើយស្ត្រីនឹងត្រូវដកចេញពីអង្គភាពរបស់

[2370] កថាខណ្ឌ ៨៣០ នៃដីកាសន្និដ្ឋានស្តាពរ។

[2371] ជើងចំព័រ ៣៣៥៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2372] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ន.២១១-១២, ន.២១៥, ន.២១៨-១៩, ន.២២១។

[2373] កថាខណ្ឌ ៨២៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2374] ជើងចំព័រ ៣៣៥២-៥៥ នៃដីកាសន្និដ្ឋានស្តាពរ (ដែលដកស្រង់ការរៀបរាប់រឿងរ៉ាវរៀងៗខ្លួនរបស់ លៀត ឡន សំ វុទ្ធី ស្វាយ សាម៉ែត ណារ សុខន និង មាស សារ៉ាន)។

[2375] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/94 ន.១០៥ (ឆ្លើយថា វៀតណាមវាយចូលមកនៅយប់រៀបការ)។

[2376] កថាខណ្ឌ ៨៣៥-៣៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2377] ជើងចំព័រ ៣៣៦៩-៧១, ៣៣៧៤ នៃដីកាសន្និដ្ឋានស្តាពរ។

ពួក គេ[2378]។ គាត់បានពឹងផ្អែកលើព័ត៌មានប្រយោល[2379]។ គាត់តែងតែនៅលើផ្ទៃទឹក[2380] ហើយមិនបានបង្ហាញថា គាត់បានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ សុខ នាង បានរៀបរាប់ពាក្យ ចចាមអារ៉ាមពីអ្នកដទៃ មិនមែនជាបទពិសោធន៍ផ្ទាល់របស់គាត់ទេ[2381]។ តើ រី គឺជាសាក្សីតែម្នាក់គត់ ដែលបាននិយាយថា គាត់ត្រូវបានគេដាក់ទណ្ឌកម្មលើរាងកាយ ដោយសារបដិសេធមិនព្រមរៀបការ[2382]។ តើ រី មិនស្ថិតនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៥ ទេ។ គាត់គឺជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបាននិយាយថា គាត់បានរស់នៅក្នុងភូមិបឹងស្រី ក្នុងឃុំអូរចំណារ ស្រុកព្រៃនប់ ដែលប្រធានអង្គភាពរបស់គាត់បានព្យាយាមឱ្យគាត់រៀបការ ប៉ុន្តែ គាត់បានបដិសេធ[2383] ហើយថា គាត់ត្រូវបានបង្ខំឱ្យរៀបការនៅភូមិកោះខ្សាច នៅឃុំអូរជ្រៅ ក្នុងស្រុកព្រៃនប់ ប៉ុន្តែបានបដិសេធ[2384]។ គាត់មិនបាននិយាយអំពី មាស មុត ឬ កងពលធំលេខ ១៦៥ ឡើយ[2385]។ ទាំងភូមិបឹងស្រី ទាំងភូមិកោះខ្សាច គឺស្ថិតក្នុងក្របខ័ណ្ឌប្រតិបត្តិការនៃកងពលធំលេខ ១៦៥[2386]។

[2378] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រ៊ឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.២៦៣, ន.២៦៦។

[2379] *សូមមើលខគ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រ៊ឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.២៥៩-៦០។

[2380] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រ៊ឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 ន.១៥៨, ន.១៨៣។

[2381] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ន.៤៦។ ជើងទំព័រ ៣៣៧០ នៃដីកាសន្និដ្ឋានស្តាពរ។

[2382] កថាខណ្ឌ ៨៣៦ ជើងទំព័រ ៣៣៧៥-៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2383] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី តើ រី ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/47 ន.២០-២២, ន.៨៥-៨៦, ន.៩៧-១០៧។

[2384] របាយការណ៍នៃអង្គភាពគាំពារជនរងគ្រោះស្តីពីអ្នកដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី តើ រី ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D11/336/1 EN 00974621-00974622។

[2385] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី តើ រី ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/47។ របាយការណ៍នៃអង្គភាពគាំពារជនរងគ្រោះស្តីពីអ្នកដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី តើ រី ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D11/336/1។

[2386] *សូមមើល* កថាខណ្ឌ ៣៧៧ *ខាងលើ* ដែលពិភាក្សាអំពីស្រុកព្រៃនប់ និង ខេត្តកំពត។

៦៣៥. សាក្សីផ្សេងទៀតបានបដិសេធមិនព្រមរៀបការ ហើយមិនបានប្រឈមនឹងផលវិបាកអវិជ្ជមាននោះទេ។ លុន សេង បាននិយាយថា ការរៀបចំមួយចំនួនត្រូវបានស្នើមកគាត់ ហើយគាត់បានបដិសេធដោយមិនបានទទួលរងទណ្ឌកម្មអ្វីឡើយ។ មនុស្សមួយចំនួនត្រូវបានគេដាក់ទណ្ឌកម្មដោយសារបដិសេធការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែ អ្នកខ្លះមិនត្រូវបានគេដាក់ទណ្ឌកម្មនោះទេ[2387]។ កងនារីដែលត្រូវបានបញ្ជូនទៅចម្ការកៅស៊ូនៅកំពង់សោម បានបដិសេធមិនរៀបការទាំងអស់គ្នា ហើយត្រូវបាន តាម៉ុក បញ្ជូនមកភ្នំពេញវិញ[2388]។ ក័ម ម៉ែន បាននិយាយថា គេបានស្នើសុំយោបល់គាត់មុនពេលរៀបការ ហើយថាគ្មានអ្វីកើតឡើងនោះទេ ប្រសិនបើគាត់ ឬ ប្រពន្ធគាត់មិនព្រមរៀបការនោះ[2389]។

៦៣៦. ស.ព.អ. អះអាងថា បន្ទាប់ពីរៀបការ គូស្វាមីភរិយាត្រូវបានបញ្ជាឱ្យរស់នៅជាមួយគ្នាអស់រយៈពេលពីរបីថ្ងៃ ដើម្បីរួមភេទក្រោយអាពាហ៍ពិពាហ៍[2390] ហើយបានជឿជាក់ថា ពួកគេនឹងទទួលទណ្ឌកម្ម ត្រូវបានចាប់ខ្លួន ឬ សម្លាប់ប្រសិនបើពួកគេមិនបានរួមភេទ[2391]។ គាត់ដកស្រង់សាក្សីចំនួន ៥ នាក់ ដែលគ្មាននរណាម្នាក់គាំទ្រការអះអាងរបស់គាត់នោះទេ[2392]។ ទោះបី លៀត ឡន បាននិយាយថា គាត់ត្រូវធ្វើតាមបញ្ជារបស់ ញ៉ាន ហើយមិនចង់រួមភេទក៏ដោយ[2393] ក៏គាត់បាន

[2387] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ លុន សេង ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ D54/38.1 EN 01072395-01072396 KH 00967320។ គាត់បានបញ្ជាក់អំពីបទសម្ភាសន៍នេះនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/38 ន.៦-៧។

[2388] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ រីម ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៥ ឯកសារ D114/38 ន.៨៩-៩២, ន.១០៦-០៧, ន.១១៥។ កថាខណ្ឌ ៨៣៨ នៃដីកាសន្និដ្ឋានស្តាពរ។ គ្មានការចង្អុលបង្ហាញថា អង្គភាពនេះស្ថិតនៅតំបន់ក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៥ ទេ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ រីម ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៥ ឯកសារ D114/38 ន.១៧ និង ន.១៤៥ (ឆ្លើយថា គាត់អត់ធ្លាប់ឮពី មាស មុត ទេ) ន.១១៤ (ឆ្លើយថា គាត់ឮគេនិយាយថា តា ម៉ុក យកពួកគាត់ទៅភ្នំពេញ)។

[2389] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក័ម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 ន.២៣១, ន.២៣៦-៣៨។

[2390] កថាខណ្ឌ ៨៤០ នៃដីកាសន្និដ្ឋានស្តាពរ។

[2391] កថាខណ្ឌ ៨៤១ នៃដីកាសន្និដ្ឋានស្តាពរ។

[2392] ជើងទំព័រ ៣៣៨៧-៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[2393] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 ន.១៩៩-២០០។

យល់ព្រមរួមភេទជាមួយប្រពន្ធរបស់គាត់ ហើយបានគិតថា ប្រពន្ធគាត់ក៏យល់ស្របដែរ[2394]។ អ៊ុក សុក បាននិយាយថា ស្វាមីរបស់នាងមិនបានប៉ះពាល់ខ្លួនគាត់ទេ។ នាងយល់ព្រមរួមភេទជាមួយគាត់ ហើយពួកគេមិនបានរួមភេទជាមួយគ្នាទេ រហូតដល់ពួកគេយល់ចិត្តគ្នាទៅវិញទៅមក[2395]។ ណាវ សុខន បានយល់ព្រមរួមភេទជាមួយគ្នា ហើយបាននិយាយថា គាត់ស្រឡាញ់ប្តីរបស់គាត់ទោះបីជាគាត់មិនស្គាល់គ្នាជាមុនក៏ដោយ[2396]។ មាស សាវ៉ាន់ មិនបាននិយាយថា មាស មុត ឬ បុគ្គលិកក្រោមបង្គាប់ បានបង្ខំឱ្យគាត់រួមភេទជាមួយស្វាមីថ្មីរបស់គាត់ទេ។ គាត់បាននិយាយថា ប្តីរបស់គាត់នឹងបង្ខំគាត់ឱ្យធ្វើដូច្នេះ ប្រសិនបើគាត់បដិសេធ[2397]។ ចម្លើយរបស់ យឹម ស្រ៊ឿង ដែលថា គូស្វាមីភរិយាត្រូវបានតាមដាន[2398] គឺមានមូលដ្ឋានលើព័ត៌មានប្រយោល[2399]។

៦៣៧. ការរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្តបានកើតឡើងនៅខេត្តកំពង់ចាម[2400]។ ស.ព.អ. ទទួលស្គាល់បញ្ហានេះ[2401]។ ទោះបីជាមានភ័ស្តុតាងនេះក៏ដោយ ក៏គាត់មិនបានបែងចែកការរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្ត ឱ្យដាច់ពីការរៀបអាពាហ៍ពិពាហ៍ “ដោយបង្ខំ” ឡើយ នៅពេលពិភាក្សាអំពីដំណើរការរៀបអាពាហ៍ពិពាហ៍។ គាត់ចាត់ទុកដោយមិនស្មោះត្រង់ថា ការរៀបអាពាហ៍ពិពាហ៍

[2394] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 អ.១៩៣, អ.១៩៥។

[2395] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៣១៣-១៦។

[2396] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/117 អ.២៦៦, អ.៣១២-១៣, អ.៣១៦-១៧។

[2397] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤ D114/32 អ.៥៤-៥៦។

[2398] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រ៊ឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 អ.២៥៩-៨២។ ជើងចំពីរ ៣៣៨៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2399] *សូមមើល* កថាខណ្ឌ ៦៣៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2400] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 អ.៤៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/103 អ.២១៥, អ.២១៨-១៩, អ.២២១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រ៊ឿង ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/95 អ.២៥២ ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាំ គំនិត ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ឯកសារ D114/234 អ.៥១។

[2401] *សូមមើលឧទា.* កថាខណ្ឌ ៨៣០-៣១, ៨៣៨ នៃដីកាសន្និដ្ឋានស្តាពរ។

ទាំងអស់ គឺជាការរៀបអាពាហ៍ពិពាហ៍ "ដោយបង្ខំ"[2402]។ ហើយគាត់ក៏មិនបានផ្តល់នូវការប៉ាន់ប្រមាណថា តើការរៀបអាពាហ៍ពិពាហ៍ចំនួនប៉ុន្មានត្រូវបាន "បង្ខំ" នៅតំបន់កំពង់សោមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។ គាត់ខកខានមិនបានបង្ហាញពីគោលនយោបាយនៃការរៀបការដោយបង្ខំនៅកំពង់សោម ឬ ថា មាស មុត ទទួលខុសត្រូវចំពោះគោលនយោបាយបែបនេះ។

២. មានភ័ស្តុតាងមិនគ្រប់គ្រាន់បង្ហាញថា ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់ស្វាយតកំពង់សោម បានទទួលរងការប៉ះទង្គិចផ្លូវចិត្ត ឬ ផ្លូវកាយ

៦៣៨. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រការអះអាងរបស់គាត់ដែលថា ជនរងគ្រោះបានទទួលរង៖ **ក.** ការឈឺចាប់ផ្លូវកាយដោយសារត្រូវរៀបការ និង រួមភេទជាមួយបុគ្គលដែលពួកគេមិនស្គាល់ ឬ ស្រឡាញ់ **ខ.** ពិបាកទទួលយកការពិតដែលថា ពួកគេត្រូវបានបង្ខំឱ្យរៀបការ និងព្យាយាមលាក់បាំងវា ឬ **គ.** បំបែក ឬ ដែងលះក្រោយឆ្នាំ ១៩៧៩[2403]។ ស.ព.អ. ដកស្រង់សាក្សីចំនួន ៨ នាក់[2404]។ គ្មាននរណាម្នាក់គាំទ្រការអះអាងរបស់គាត់ទេ។

៦៣៩. ស.ព.អ. ដកស្រង់សាក្សីពីរនាក់ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានការឈឺចាប់ផ្លូវកាយ[2405]។ សាក្សីទាំងនេះមិនគាំទ្រការអះអាងនេះទេ។ មាស សារ៉ាន់ បាននិយាយថា គាត់មានអារម្មណ៍ឈឺចាប់ ដោយសារ *ក្នុងចំណោមនោះ* ការរៀបអាពាហ៍ពិពាហ៍របស់គាត់ត្រូវបានរៀបចំដោយមិនបានប្រាប់ឪពុកម្តាយ ឬ បងប្អូនគាត់។ គាត់មិនបានរាយការណ៍អំពីអារម្មណ៍ឈឺចាប់ផ្លូវកាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ ក្នុងពេលសព្វថ្ងៃ ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍របស់គាត់ឡើយ[2406]។ លៀត ឡន និយាយថា គាត់មិន

[2402] *សូមមើលខាង.* កថាខណ្ឌ ៨៣១ នៃដីកាសន្និដ្ឋានស្តាពរ (ដែលពិភាក្សាពីដំណើរការនៃការយល់ព្រមលើសំណើសុំរៀបការ) កថាខណ្ឌ ៨៣៨ (ដែលអះអាងថា អ្នកចូលរួមក្នុងពិធី ជាទូទៅ មានអ្នកដែលត្រូវគេបង្ខំឱ្យរៀបការ ព្រមទាំងអ្នកផ្សេងទៀតដែល "យល់ព្រមទទួលយក" ស្ថានភាពនេះ ឬ រៀបការ "ដោយស្ម័គចិត្ត")។

[2403] កថាខណ្ឌ ៨៥៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2404] ជើងចំព័រ ៣៣៩៣-៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2405] កថាខណ្ឌ ៨៥៣ ជើងចំព័រ ៣៣៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2406] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/32 ឆ.១១៤។ ជើងចំព័រ ៣៣៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

សប្បាយចិត្ត និង ភ្ញាក់ផ្អើលនៅពេលគេថាត្រូវរៀបការ។ គាត់មិនបានប្រាប់អារម្មណ៍ឈឺចាប់ផ្លូវកាយគាត់ទេ[2407]។

៦៤០. ស.ព.អ. ដកស្រង់តែ ណាវ សុខន ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា "ពួកគេមានបញ្ហាក្នុងការទទួលយកក្នុងពេលសព្វថ្ងៃនេះថា ពួកគេត្រូវបានរៀបការដោយបង្ខំ ... ហើយថែមទាំងបានព្យាយាមលាក់បាំងវាផងដែរ"[2408]។ ណាវ សុខន បាននិយាយថា គាត់មិនបានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅមុនពេលនិយាយថា គាត់បានរៀបការនៅក្នុងឆ្នាំ ១៩៧៧ ឬ ឆ្នាំ ១៩៧៨[2409]។ ជាជាងព្យាយាមលាក់បាំងការរៀបអាពាហ៍ពិពាហ៍របស់គាត់ គាត់អាចគ្រាន់តែយល់ច្រឡំសំណួររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស.[2410]។ គាត់បាននិយាយថា គាត់បានស្រឡាញ់ប្តី[2411] ដែលមិនបង្ហាញចេតនាលាក់បាំងការរៀបអាពាហ៍ពិពាហ៍របស់គាត់ទេ។

៦៤១. ស.ព.អ. អះអាងថា គូស្វាមីភរិយា "ជាច្រើននាក់" ដែលរៀបការដោយបង្ខំ បានបែកគ្នា ឬ លែងលះគ្នាក្រោយឆ្នាំ ១៩៧៩[2412] ដែលមានន័យថា ពួកគេបានបែកគ្នា ឬ លែងលះគ្នាភ្លាមៗតែម្តងក្រោយមក។ គាត់ដកស្រង់សាក្សីចំនួន ៥ នាក់[2413]។ សាក្សីទាំងនេះមិនគាំទ្រការអះអាងរបស់គាត់ទេ។ អ៊ុក សុក បានចង្អុលបង្ហាញថា គាត់ និង ស្វាមីបានបែកគ្នានៅឆ្នាំ ១៩៧៩[2414]។ ការបែកគ្នានេះមិនមែនធ្វើឡើងដោយចេតនានោះទេ។ ពួកគេរស់នៅកន្លែងដាច់ដោយឡែកពីគ្នា ហើយបានរត់ដាច់ដោយឡែកពីគ្នានៅពេលដែលជនជាតិវៀតណាមចូលមក[2415]។ ក្រោយមក អ៊ុក សុក បាន

[2407] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 អ.៣, អ.៥ ។ ជើងទំព័រ ៣៣៩៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2408] កថាខណ្ឌ ៨៥៣ ជើងទំព័រ ៣៣៩៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2409] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/117 អ.២១៨-១៩, អ.២៤៩-៥១, អ.២៥៧។

[2410] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/117 អ.២៤៩។

[2411] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/117 អ.៣១៧។

[2412] កថាខណ្ឌ ៨៥៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2413] ជើងទំព័រ ៣៣៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2414] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.២៧៨។

[2415] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៣១១, អ.៣១៧-១៩, អ.៣៣៧-៣៨។

ព្យាយាមរកស្វាមីរបស់គាត់តែគាត់រកមិនឃើញ[2416]។ លៀត ឡួន និង វុន ប៊ុណ្ណា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយបានបង្ហាញថា ពួកគេបានលែងលះគ្នានៅចន្លោះឆ្នាំ ១៩៨៩ និងឆ្នាំ ១៩៩២ ដែលមានរយៈពេល ១០ ឆ្នាំបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ[2417]។ កឹម ម៉ែន មិនបាននិយាយថាគាត់លែងលះគ្នានៅពេលណានោះទេ ប៉ុន្តែបាននិយាយថា គាត់បានរៀបការនៅចុងឆ្នាំ ១៩៧៧ ឬ ដើមឆ្នាំ ១៩៧៨ ហើយគាត់ និង ប្រពន្ធគាត់មានកូនបីនាក់[2418] ដែលបង្ហាញថា ពួកគេបានរៀបការក្នុងរយៈពេលណាមួយ។ មាស សារ៉ាន់ បាននិយាយជាទូទៅថា ប្រជាជនបានបែកគ្នាបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនបាននិយាយថាតើគាត់បានដឹងពីរឿងនេះពីណាទេ[2419]។ គាត់ក៏បាននិយាយផងដែរថា គូស្វាមីភរិយាមួយចំនួន ដូចជាមីងឪពុករបស់គាត់ នៅតែរស់នៅជាមួយគ្នាដដែល[2420]។ សាក្សីផ្សេងទៀតដែលបានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅតែបន្តជាប្តីប្រពន្ធដដែលក្រោយមក ដូចជា គឹម ហាវ[2421] ស្វាយ សាម៉ែត[2422] សុខ រ៉ែន[2423] អ៊ុម អ៊ីត[2424] និង ងួន ឡាយ[2425]។

[2416] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៣៥០-៥១, អ.៣៥៤-៥៦។ *សូមមើលផងដែរ ដូចខាងលើ* អ.៣៥៩ (ឆ្លើយថា គាត់នៅនឹកប្តី)។

[2417] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡួន ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/29 អ.៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វុន ប៊ុនណា ចុះថ្ងៃទី ៧ ខែមីនា ឆ្នាំ ២០១៧ ឯកសារ D114/304 អ.១៥៧។

[2418] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កឹម ម៉ែន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/113 អ.២២៥-២៦។

[2419] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/32 អ.៩៦។

[2420] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/32 អ.១០៣។

[2421] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ហាវ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/226 អ.១៣៣, អ.១៣៩។

[2422] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ែត ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D114/78 អ.២៦-២៧។

[2423] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉ែន ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/155 អ.៩១-៩២។

[2424] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ អ៊ីត ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/120 អ.២៣។

[2425] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D114/139 អ.២១, អ.១៣៩ ។

៣. សេចក្តីសន្និដ្ឋាន

៦៤២. មាស មុត មិនទទួលខុសត្រូវចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភសេពសន្តវៈ ក្នុងខេត្តកំពង់សោមទេ។ មិនមានភស្តុតាងណាបញ្ជាក់ថា តើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានកើតឡើងនៅតំបន់ក្រោមការគ្រប់គ្រងរបស់ មាស មុត មានចំនួនប៉ុន្មាននោះទេ។ មិនមានភស្តុតាងបញ្ជាក់ថា ការរៀបអាពាហ៍ពិពាហ៍បែបនោះ មានស្ថានទម្ងន់ស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតនោះទេ។ បើទោះបីជា ស.ច.ស. រកឃើញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយបានកើតឡើងនៅតំបន់ក្រោមការគ្រប់គ្រងរបស់ មាស មុត ក៏ដោយ ក៏អំពើស្រដៀងគ្នានេះបានកើតឡើងនៅទូទាំងប្រទេស។ ការទទួលខុសត្រូវចំពោះអំពើបែបនេះ មិនអាចដំឡើងឱ្យ មាស មុត ស្ថិតនៅក្នុងប្រភេទនៃអ្នក "ដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។

ច. បើទោះបីជាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ មាស មុត ក៏ដោយ ហើយបើទោះជាការទទួលខុសត្រូវព្រហ្មទណ្ឌអាចធ្លាក់លើ មាស មុត ក៏ដោយ ក៏ឧក្រិដ្ឋកម្មទាំងនេះ និង ចំនួនជនរងគ្រោះ មិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលអាចឱ្យ មាស មុត ក្លាយជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ

៦៤៣. ស.ព.អ. បំផ្លើសភ័ស្តុតាង។ ដោយទទួលស្គាល់ថា គាត់មិនអាចបញ្ជាក់ចំនួនត្រឹមត្រូវនៃជនរងគ្រោះឧក្រិដ្ឋកម្ម[2426] នៅពេលប៉ាន់ប្រមាណចំនួនជនរងគ្រោះ គាត់៖ **ក.** ដកស្រង់សាក្សីដែលចម្លើយរបស់ពួកគេ បានផ្អែកលើពាក្យចចាមអារ៉ាម ឬ ការទាយស្មាន **ខ.** ដកស្រង់ភ័ស្តុតាងសាក្សីដែលមានតម្លៃជាភ័ស្តុតាងទាប ឬ មិនគាំទ្រការអះអាងរបស់គាត់ **គ.** ដកស្រង់ភស្តុតាងឯកសារដែលមិនអាចជឿជាក់បាន មានតម្លៃជាភ័ស្តុតាងទាប ឬ មិនគាំទ្រការអះអាងរបស់គាត់ **ឃ.** បំផ្លើសភ័ស្តុតាង និង **ង.** មិនអើពើនឹងភ័ស្តុតាងបរិបទ។ ភ័ស្តុតាងក្នុងសំណុំរឿងមិនគាំទ្រចំនួនជនរងគ្រោះច្រើន ដូច ស.ព.អ. អះអាងទេ។ បើទោះបីជា ស.ច.ស. រកឃើញថា ការប៉ាន់ប្រមាណចំនួនជនរងគ្រោះរបស់ ស.ព.អ. ត្រូវបានគាំទ្រដោយភស្តុតាងក៏ដោយ ក៏វានៅតែមិនអាចដំឡើង

[2426] កថាខណ្ឌ ៤៦៣, ៥០៤, ៦១៣ នៃដីកាសន្និដ្ឋានស្តាពរ។

ឱ្យ មាស មុត ស្ថិតនៅក្នុងកម្រិតនៃ "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ក្នុងចំណោមអ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ[2427]។

១. មានភស្តុតាងមិនគ្រប់គ្រាន់បង្ហាញថា ប្រជាជនជាង ១000 នាក់ ត្រូវបានចាប់ខ្លួន និង សម្លាប់ចោលដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅសមុទ្រ ឬ នៅតំបន់ស្វយ័តកំពង់សោម

៦៤៤. ប្រភពទាំងឡាយដែលដកស្រង់ដោយ ស.ព.អ. មិនគាំទ្រការអះអាងរបស់គាត់ដែលថា មនុស្សជាងមួយពាន់នាក់ដែលភាគច្រើនជាជនជាតិវៀតណាម និង ថៃ ត្រូវបានចាប់ខ្លួននៅសមុទ្រ ហើយត្រូវបានសម្លាប់ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅសមុទ្រ ឬ នៅតំបន់ស្វយ័តកំពង់សោមនោះឡើយ[2428]។ ស.ព.អ. ដកស្រង់ជាចម្បងនូវការប៉ាន់ទុកបំផ្លើសអំពីការចាប់ខ្លួន និង ការសម្លាប់ ដោយសាក្សីដែលមិនអាចជឿជាក់បាន ដូចជា ប៉ាក សុខ ឯក នី អ៊ូ គីម ព្រំ សារ៉ាត និង មូល ឈិន[2429]។ គាត់និយាយបំផ្លើសអំពីការរៀបរាប់របស់សាក្សីនីមួយៗ ដែលអះអាងថាបានឃើញការចាប់ទូក និង មិនអើពើផ្នែកខ្លះនៃសក្ខីកម្មរបស់ពួកគេ ដែលច្រានចោល ឬ ធ្វើឱ្យការអះអាងរបស់គាត់មិនរឹងមាំ[2430]។ គាត់ក៏បានដកស្រង់ភស្តុតាងឯកសារផងដែរ - បទសម្ភាសន៍ជាមួយ មាស មុត ដែលធ្វើឡើងដោយ David Kattenburg របាយការណ៍ក្រសួងការពារជាតិអាមេរិក និង របាយការណ៍យោធានៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនគាំទ្រការអះអាងរបស់គាត់[2431]។

[2427] ចំនួនជនរងគ្រោះនៃបទឧក្រិដ្ឋនៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ និង នៅកំពង់សោម ត្រូវតែបានពិនិត្យ ដោយធៀបនឹងការស្លាប់ និង រងទុក្ខវេទនាទាំងស្រុង ដែលបង្កឡើងដោយគោលនយោបាយរបស់ ប.ក.ក. នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ កថាខណ្ឌ ៣១៧-១៨ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[2428] កថាខណ្ឌ ៤០២, ១០៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[2429] ជើងទំព័រ ១៤៥១, ១៥៥៥-៥៦, ១៥៦១, ១៥៦៥, ១៥៧០ នៃដីកាសន្និដ្ឋានស្តាពរ។

[2430] ជើងទំព័រ ១៣៦០, ១៤២២, ១៤២៨-៣០, ១៤៣៨, ១៤៧៥, ១៥៣០-៣១, ១៥៥៧-៥៨, ១៥៦២, ១៥៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2431] ជើងទំព័រ ១៣៥៨, ១៤២៥-២៧, ១៤៦៤, ១៤៧២ នៃដីកាសន្និដ្ឋានស្តាពរ។

ក. ការប៉ាន់ស្មានអំពីការកាប់សម្លាប់ និង ការចាប់ខ្លួន ដែល ស.ព.អ. ដកស្រង់ គឺជាការទាយស្មាន និង មិនអាចជឿជាក់បាន

៦៤៥. **ប៉ាក សុខ៖** ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[2432]។ គាត់បានប៉ាន់ស្មានថា មនុស្សរាប់ពាន់នាក់ត្រូវបានគេបញ្ជូនតាមផែអូរឈើទាលនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយថា មនុស្សរាប់ពាន់នាក់ រួមទាំងអ្នកនេសាទថៃ និង ជនភៀសខ្លួនវៀតណាម ត្រូវបានចាប់ខ្លួន និង សម្លាប់ចោលនៅតាមសមុទ្រ នៅលើកោះ ឬ នៅលើដីគោក[2433]។ តំបន់ប្រតិបត្តិការរបស់ ប៉ាក សុខ មានដែនកំណត់។ បន្ទាប់ពីបានឈរជើងនៅលើកោះតាង និង កោះពូឡូវ៉ៃ គាត់បានធ្វើការនៅកំពង់ផែអូរឈើទាលពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨ ឱ្យប្រធានកងវរសេនាធំ ដែលចាត់ចែងការងារផ្គត់ផ្គង់អាហារសម្រាប់នាវា[2434]។ គាត់មិននៅលើទូក ឬ កោះទេ ខណៈពេលដែលគាត់ឈរជើងនៅអូរឈើទាលនោះ[2435]។ ប៉ាក សុខ មិនអាចប្រាប់ ក.ស.ច.ស. ថា ការចាប់ខ្លួនធ្វើឡើងប៉ុន្មានដងឡើយ ឬ ជនភៀសខ្លួនប៉ុន្មាននាក់ត្រូវបានចាប់ខ្លួនដោយកងរបស់គាត់ជារៀងរាល់ឆ្នាំ[2436]។ គាត់អាចត្រឹមតែរៀបរាប់ឡើងវិញដោយផ្ទាល់ អំពីការចូលរួមនៅក្នុងការចាប់ចំនួនបីលើក៖ ទូកវៀតណាមមួយ និង ទូកនេសាទថៃពីរគ្រឿង[2437]។ លោកបានប្រាប់ ក.ស.ច.ស. ថា គាត់ផ្ទាល់បានឃើញការសម្លាប់គ្រួសារវៀតណាមដែលចាប់ខ្លួនបាន ហើយថា សាកសពរបស់ពួកគេក្រោយមកត្រូវបានគេប្រើធ្វើជីសម្រាប់ដើមដូង ហើយថា ជនជាតិថៃត្រូវបានបញ្ជូនឱ្យត្រលប់ទៅប្រទេសថៃ ឬ ទៅរាមដើម្បីធ្វើការងារនៅលើកោះតាគៀវ[2438]។ ក្នុងអំឡុងពេលសវនាការរឿងក្តី ០០២/០១ ប៉ាក សុខ

[2432] *សូមមើល* កថាខណ្ឌ ២៣៣-៣៥ *ខាងលើ* សម្រាប់ព័ត៌មានពីសាក្សីរូបនេះ។

[2433] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឯ.១១-១៣។ ជើងទំព័រ ១៤៥១, ១៥៦០ នៃដីកាសន្និដ្ឋានស្តាពរ។

[2434] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/23 ឯ.២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឯ.៩។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 09.53.19-10.00.46។

[2435] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 09.53.19-10.00.46។

[2436] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឯ.១២។

[2437] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឯ.១២។

[2438] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/25 ឯ.១៥, ឯ.១៦, ឯ.២០។

បានផ្លាស់ប្តូររឿងរបស់គាត់។ គាត់បានផ្តល់សក្ខីកម្មថា គាត់បានឃើញតែការចាប់ទូកវៀតណាមម្តង ឬ ពីរដងប៉ុណ្ណោះ ហើយមិនមានហេតុការណ៍ណាមួយដែលបង្កគ្រោះថ្នាក់ដល់មនុស្សដែលចាប់ខ្លួនបាននោះទេ[2439]។ គាត់ក៏បានផ្តល់សក្ខីកម្មផងដែរថា គាត់មិនដឹងថាតើប្រជាជនត្រូវបានគេយកទៅកន្លែងណាឆ្ងាយពីខេត្តកំពង់សោម ឬ កន្លែងដែលពួកគេត្រូវបានគេសម្លាប់នោះទេ ព្រោះការទទួលខុសត្រូវរបស់គាត់មានកម្រិតត្រឹមកំពង់ផែ[2440]។ នៅពេលតទល់ជាមួយនឹងកិច្ចសម្ភាសន៍ ក.ស.ច.ស. ប៉ាក សុខ បានលើកឡើងថា គាត់មិនអាចនឹកឃើញពីព្រឹត្តិការណ៍នេះឱ្យបានជាក់លាក់ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ ឡើយ[2441]។

៦៤៦. **ឯក នី៖** ឯក នី មិនអាចជឿជាក់បានឡើយ[2442]។ គាត់បានប៉ាន់ស្មានថា ជនជាតិវៀតណាម និង ថៃ ពី ១២០០ ទៅ ១៣០០ នាក់ ត្រូវបានចាប់ខ្លួន និង សម្លាប់នៅសមុទ្រដោយកងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ[2443]។ ឯក នី បានប្រាប់ ក.ស.ច.ស. ថា គាត់គ្រាន់តែនឹកឃើញថាបានឃើញការចាប់ទូកថៃចំនួនបួនគ្រឿងប៉ុណ្ណោះ[2444]។ គាត់មិនអាចដឹងពីចំនួនមនុស្សសរុបដែលចាប់ខ្លួនបានក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ឬ ក៏ជោគវាសនារបស់អ្នកដែលត្រូវបានចាប់ខ្លួននោះទេ។ ចំពោះទូកវៀតណាម គាត់បានប្រាប់ ក.ស.ច.ស. ថា ភាពញឹកញាប់នៃការចាប់ខ្លួនមានការ ប្រែប្រួល៖ ពេលខ្លះមានទូក ៣ ទៅ ៤ គ្រឿងក្នុងមួយខែ ពេលខ្លះទៀតមានទូក ៣ ទៅ ៤ គ្រឿងក្នុងមួយថ្ងៃ[2445]។ គាត់មិនបាននិយាយថាគាត់បានឃើញជនជាតិវៀតណាមត្រូវបានសម្លាប់ឡើយ[2446]។ តាមមេធាវីការពារក្តីដឹងច្បាស់នោះ ចម្លើយរបស់ ឯក នី ដែលថា សាកសពវៀតណាមរាប់រយ

[2439] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.34.45-10.43.36។

[2440] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.34.45-10.43.36។

[2441] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.39.59-10.46.23។

[2442] *សូមមើល* កថាខណ្ឌ ២៥១ និង ៤១០ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2443] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/282 អ.៥៨-៦១។ ជើងទំព័រ ១៥៥៥-៥៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2444] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 អ.៣។

[2445] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 អ.៣។

[2446] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D114/283 អ.៣។

នាក់ ត្រូវបានគេកប់ក្រោមដើមដូងនៅលើកោះតាង មិនស៊ីចង្វាក់គ្នាជាមួយនឹងភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿងទេ។ ចំពោះសាកសពមនុស្សដែលតាមការអះអាង ត្រូវបានរកឃើញដោយ ឯក នី នៅលើកោះតាងនោះ អាចជាសាកសពរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ឬ ទាហានអាមេរិកដែលបានស្លាប់នៅក្នុងការប៉ះទង្គិចគ្នានៅលើកោះនេះកាលពីខែឧសភា ឆ្នាំ ១៩៧៥[2447]។

៦៤៧. **អ៊ូ គីម៖** អ៊ូ គីម មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់មានមូលដ្ឋានលើការទាយស្មាន និងពាក្យចចាមអារ៉ាមដែលមិនមានអ្វីផ្ទៀងផ្ទាត់។ អ៊ូ គីម បានទាយស្មានថា ជនជាតិថៃ និងវៀតណាមចំនួន ១000 នាក់ ត្រូវបានសម្លាប់នៅលើកោះពូឡាវ៉ៃ ទូកថៃត្រូវបានចាប់ច្រើនជាងទូកជនភៀសខ្លួនវៀតណាម ហើយថា ជាមធ្យម មានមនុស្ស ៣0 នាក់ នៅក្នុងទូកនីមួយៗ[2448]។ អ៊ូ គីម បានទទួលស្គាល់ទាំងចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជា ទាំងចំពោះ ក.ស.ច.ស. ថា ការប៉ាន់ស្មានរបស់គាត់គឺមិនត្រឹមត្រូវទេ[2449]។ គាត់ក៏បានប្រាប់ ក.ស.ច.ស. ផងដែរថា ចម្លើយមួយចំនួនរបស់គាត់នៅក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺផ្អែកលើចំណេះដឹងប្រយោលប៉ុណ្ណោះ[2450]។

[2447] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/104 ន.១៥១៖ "បាទ ធ្លាប់មានទាហាននៅទីនោះ [កោះតាង] រួចហើយ ប៉ុន្តែគេបានប្រយុទ្ធជាមួយទាហានអាមេរិក ហើយត្រូវពួកអាមេរិកចាប់ជាឈ្លើយសឹកយកទៅដាក់នៅវៀតណាមទាំងអស់។ ពេលពួកខ្ញុំទៅដល់ឃើញមានស្នាមគេបាញ់ មានយន្តហោះធ្លាក់នៅទីនោះ និង រណ្តៅដែលគេកប់សព"។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ផន ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/122 ន.៥0៖ "ពេលធ្វើការនៅលើកោះ គេបានប្រាប់ខ្ញុំថាមនុស្សខ្លះក៏បានស្លាប់ដែរក្នុងពេលវាយប្រយុទ្ធគ្នាជាមួយកងទ័ពខ្មែរក្រហម និង អាមេរិកាំង យ៉ាងណាមិញ ខ្ញុំក៏មិនដឹងថាគេស្លាប់ដោយរបៀបម៉េច និង កប់នៅទីណានោះដែរ។ ពេលធ្វើការនៅកោះតាង ខ្ញុំមិនដែលឃើញផ្សែងខ្មោច និង ឆ្អឹងខ្មោចនោះទេ"។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ុន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ឯកសារ D114/89 ន.១៥២-៥៦។

[2448] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ គីម ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/126 ន.៣៦-៣៧, ន.៤៣-៤៦។ ជើងចំពីរ ១៥៦១ នៃដីកាសន្និដ្ឋានស្តាពរ។

[2449] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ូ គីម ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D220/1.2.1 EN 01375006 KH 01102498៖ "អើម! បញ្ហាហ្នឹងវាពិបាកត្រង់ថា ការយ្យុលហ្នឹងខ្លាចវាមិនពិតដូច។ ... តែនេះជាការស្មាន"។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ គីម ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/126 ស-ន.៣៤៖ "ស៖ ជាមធ្យម តើមានអ្នកនេសាទប៉ុន្មាននាក់នៅលើទូកថៃ និង មានប៉ុន្មាននាក់នៅលើទូកវៀតណាម? ន.៣៤៖ ខ្ញុំយល់ថា តុលាការត្រូវការតួលេខច្បាស់លាស់ តែខ្ញុំមិនចាំតួលេខទេ ហើយខ្ញុំក៏មិនបាននៅជិត មិនបានចូលរួមឱ្យដឹងរឿងនេះច្បាស់លាស់ផងដែរ"។

[2450] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ គីម ចុះថ្ងៃទី ២0 ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/127 ស-ន.២៦-២៧៖ "ស៖ ក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រង់ចំពីរ ២១ និង ២៥ លោកបាននិយាយអំពីការឆែកឆេរមនុស្សដែលគេចាប់បាន និង មាសប្រហែល ៥ គីឡូក្រាម ដែលគេប្រមូលបានពីអ្នកទាំងនោះ។ តើហេតុការណ៍នេះកើតឡើងនៅទីណា

អ៊ូ គីម មិនបានចូលរួមក្នុងការចាប់ទូកនោះទេ គាត់មិននៅជិតកន្លែងដែលទូកត្រូវបានចាប់ ហើយ "មិនបានចូលរួមក្នុងការសិក្សាបញ្ហានេះឱ្យបានច្បាស់លាស់"[2451]។ ចម្លើយរបស់ អ៊ូ គីម ដែលថា អ្នកដែលបានចាប់ខ្លួនត្រូវបានសម្លាប់នៅលើកោះពូឡូវ៉ៃ គឺមិនមានអ្វីអាចផ្ទៀងផ្ទាត់បាន។ គាត់បានដឹងអំពីការកាប់សម្លាប់នេះពីសមាជិកកងអនុសេនាធំជាមួយគ្នា[2452]។ គាត់មិនបាន "ដឹងពីព័ត៌មានលម្អិតទេ ពីព្រោះនោះគឺជាការងាររបស់អ្នកផ្សេងទៀត"[2453]។

៦៤៨. **ព្រុំ សាវ៉ាត**៖ ព្រុំ សាវ៉ាត មិនអាចជឿជាក់បានឡើយ[2454]។ គាត់បានប៉ាន់ស្មានថា មនុស្សជាង ១០០ នាក់ត្រូវបានគេចាប់ខ្លួន ខណៈដែលគាត់ឈរជើងនៅលើកោះពូឡូវ៉ៃ[2455]។ គាត់បានប្រាប់ ក.ស.ច.ស. ថា កងពលធំលេខ ១៦៤ មិនបានចាប់ទូកវៀតណាមជាញឹកញាប់ទេ[2456]។ គាត់គ្រាន់តែចងចាំថាបានឃើញការចាប់ទូកវៀតណាមចំនួនពីរ ហើយបានឮម្តងអំពីការរឹបអូសទូកនេសាទថៃក្នុងអំឡុងពេលគាត់នៅលើកោះពូឡូវ៉ៃ[2457]។ គាត់មិនបានចូលរួម ឃើញការចាប់ខ្លួន ឬ មិនបានដឹងថាតើមានមនុស្សប៉ុន្មាននាក់នៅលើទូកនេសាទថៃនោះទេ។ គាត់គ្រាន់តែឮរឿងនេះតាមវិទ្យុទាក់ទងតែប៉ុណ្ណោះ[2458]។ គាត់មិនបានដឹងឮអំពីការចាប់ទូកថៃផ្សេងៗទៀតក្រៅពីហេតុការណ៍នេះ

និងនៅឆ្នាំណាដែរ? ឆ.២៦៖ តាមត្រង់ទៅ ខ្ញុំមិនបានដឹងរឿងនេះដោយផ្ទាល់នោះទេ ដោយសារខ្ញុំមិនមែនជាអ្នកឆែកឆេរ និងប្រមូលទុកមាសនោះដែរ។ ស៖ លោកក៏បាននិយាយផងដែរថា ស្រីៗគឺលាក់មាសនៅក្នុងប្រដាប់ភេទត្រង់ចំពីរ ២១ ក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើលោកអាចពន្យល់បន្ថែមបានដែរឬទេ? ឆ.២៧៖ ខ្ញុំបានដឹងរឿងនេះពីអ្នកដែលយាមល្បាតនៅតាមផ្សេង"។

[2451] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ គីម ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/126 ឆ.២៨, ឆ.៣៤។

[2452] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ គីម ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/127 ឆ.៣០។

[2453] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ គីម ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/127 ឆ.៣៣។

[2454] *សូមមើល* កថាខណ្ឌ ១៩១ *ខាងលើ* សម្រាប់ពបន្ថែមពីសាក្សីរូបនេះ។

[2455] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សាវ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.១២៩-៣២។ ជើងចំពីរ ១៥៦៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2456] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សាវ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ស-ឆ.១២១៖ "ស៖ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រង់ចំពីរ ៥៣ (ជាភាសាអង់គ្លេស) និង ចំពីរ ៥៤ (ជាភាសាខ្មែរ) លោកបាននិយាយអំពីការចាប់បានទូករបស់វៀតណាម។ តើកងពល ១៦៤ ចាប់បានទូកវៀតណាមហ្នឹងញឹកញាប់ដែរឬទេ? ឆ.១២១៖ មិនមានញឹកញាប់ទេ"។

[2457] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សាវ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.១២១, ឆ.១៥៦។

[2458] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សាវ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 ឆ.១៤៧-៤៩។

ទេ[2459]។ ការដឹងឮរបស់ ព្រុំ សារ៉ាត អំពីការចាប់ទូកវៀតណាមផ្សេងទៀត គឺផ្អែកលើអ្វីដែលគាត់បានឮតាមវិទ្យុ[2460]។ គាត់បានអះអាងថា បានរក្សាទុកបញ្ជីចាប់ខ្លួនប្រចាំថ្ងៃ អំពីអ្វីដែលគាត់បានឮតាមវិទ្យុទាក់ទង ប៉ុន្តែសៀវភៅឈ្មោះនោះបានបាត់ក្នុងសមុទ្រហើយ[2461]។ គាត់មិនបានដឹងផ្ទាល់អំពីជោគវាសនានៃអ្នកត្រូវបានចាប់ខ្លួននោះទេ។ គាត់បានឮពីមិត្តរួមការងារ និង មិត្តភក្តិនៅក្នុងកងពលធំលេខ ១៦៥ ថា អ្នកដែលត្រូវចាប់ខ្លួន ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ អស់ហើយ[2462]។

៦៤៩. **មូល ឈិន៖** មូល ឈិន មិនអាចជឿជាក់បានឡើយ[2463]។ គាត់បានប៉ាន់ស្មានថា ជាទូទៅ ទូកបីទៅបួន ត្រូវបានគេចាប់បានក្នុងមួយថ្ងៃ ហើយជាមធ្យម មានមនុស្សប្រហែលប្រាំមួយនាក់នៅលើទូកតូច និង រហូតដល់ ២០ ទៅ ៣០ នាក់ នៅលើទូកធំ។[2464] ខណៈដែលគាត់បានអះអាងថា បានឃើញជនភៀសខ្លួនវៀតណាម និង អ្នកនេសាទថៃត្រូវបានចាប់ខ្លួន និង ត្រូវបានគេយកទៅសម្លាប់នៅលើកោះពូឡូវ៉ៃ[2465] សាត ចក់ ដែលឈរជើងនៅលើកោះដដែលនោះ[2466] បាននិយាយថា ទូកមិនដែលត្រូវបានគេយកទៅកោះពូឡូវ៉ៃទេ បន្ទាប់ពីត្រូវបានចាប់ហើយនោះ[2467]។

[2459] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 អ.១៥០។

[2460] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 អ.១៣០។

[2461] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 អ.១៣១។ *សូមមើលផងដែរ* បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974206 KH 00926384៖ "សារ៉ាត៖ ហើយប្រភេទជនជាតិយួនទីងខ្លះគេភៀសខ្លួន ហើយខ្លះគេជាយុវជន ជាឯកសណ្ឋានកំម៉ង់ដូរ។ ដានី៖ ទីងផ្ទាកជាទាហានរបស់យួន? សារ៉ាត៖ បាទ! ជាទាហានរបស់យួន។ ... យើងចាប់យកមកសួរៗព័ត៌មាន បើថាគេភៀសខ្លួន យើងលែងទៅ ..."។

[2462] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/87 អ.១៣៥។

[2463] *សូមមើល* កថាខណ្ឌ ៣៦១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2464] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 អ.៣៩, អ.៤១-៤២។ ជើងចំពីរ ១៥៧០ នៃដីកាសន្និដ្ឋានស្តាពរ។

[2465] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៥ ឯកសារ D114/40 អ.៧៩, អ.៨៤-៨៥។

[2466] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 អ.២១។

[2467] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 អ.៨០៖ "ពេលចាប់បាន គេមិនដែលយកមកដាក់នៅលើកោះយើងនោះទេ"។

៦៥០. សុន សេន បានបញ្ជាឱ្យជនភៀសខ្លួនវៀតណាម គួរតែត្រូវបានអនុញ្ញាតឱ្យបន្តដំណើរទៅប្រទេសថៃ ហើយមិនត្រូវចាប់ខ្លួន[2468]។ មាស វឿន បានផ្តល់សក្ខីកម្មថា គោលនយោបាយដូចគ្នានេះត្រូវបានអនុវត្តចំពោះជនជាតិថៃ[2469] ហើយថា គាត់មិនដែលបានទទួលបញ្ជាឱ្យសម្លាប់ជនភៀសខ្លួនទេ[2470]។ ដោយសារបញ្ហាសន្តិសុខជាតិ ប្រសិនបើទូកទាំងនោះចូលជ្រៅទៅក្នុងដែនទឹកកម្ពុជា ប្រជាធិបតេយ្យ ពួកគេនឹងត្រូវបានចាប់ជាបណ្តោះអាសន្ន ហើយអ្នកដំណើរនឹងត្រូវបានសួរចម្លើយ[2471]។ ទូកមួយចំនួនមានទាំងយុទ្ធជន និង ជនស៊ីវិល[2472]។ ជនភៀសខ្លួននឹងត្រូវបានដោះលែង[2473]។ អ្នកដែលត្រូវគេសង្ស័យថាលាក់បាំងអត្តសញ្ញាណរបស់ពួកគេ ត្រូវបានចាប់ខ្លួន[2474]។

[2468] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 អ.៧៥៖ "សុន សេន និយាយថា បើវៀតណាមទាំងនោះជាជនភៀសខ្លួនទៅប្រទេសថៃ យើងមិនត្រូវចាប់ពួកគេទេ ហើយឱ្យពួកគេធ្វើដំណើរទៅចុះ"។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 09.35.02-09.38.23 (ឆ្លើយថា គាត់មិនដែលជួបប្រទះ ឬ ក៏ជាក់ស្តែងណែនាំថាឱ្យប្រជាជនវៀតណាមដែលរត់ទៅក្រៅប្រទេសហ្នឹងបាញ់ពន្លិចស្អីចោលអី ខ្ញុំមិនដែលបានទទួលផែនការពីកងពលផ្ទាល់ទេ) នៅម៉ោង 09.45.46 (ឆ្លើយថា ការណែនាំរបស់ខាងលើ គឺថា ប្រជាជនវៀតណាមដែលរត់ទៅប្រទេសផ្សេង មិនមែនជាខ្មាំងទេ)។

[2469] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.08.12-14.15.00។

[2470] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D234/2.1.96 នៅម៉ោង 11.19.40-11.21.53, 11.21.53-11.26.24។

[2471] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រុំ សាវ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974206 KH 00926384។

[2472] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សាវ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974206 KH 00926384៖ "មានទូកមានអីមកអែបនឹងទៅ ហើយដល់ពេលមើលទូកនឹងវាជាជនជាតិយួន។ ... យើងចាប់គេមក។... ហើយប្រភេទជនជាតិយួននឹងខ្លះគេភៀសខ្លួន ហើយខ្លះគេជាយុវជន ជាឯកសណ្ឋានកំម៉ង់ដូរម៉ង។... យើងចាប់យកមកសួរព័ត៌មាន បើថាគេភៀសខ្លួន យើងលែងទៅ ហើយបើគេជាប្រភេទគេមិននិយាយ មិនធ្វើដឹងឮជាមួយយើងៗបញ្ជូនមកកន្លែងសន្តិសុខ"។

[2473] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សាវ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974206 KH 00926384។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.12.12-14.19.04។

[2474] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សាវ៉ាត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.8a EN 00974206 KH00926384៖ "មានទូកមានអីមកអែបនឹងទៅ ហើយដល់ពេលមើលទូកនឹងវាជាជនជាតិយួន។ ... យើងចាប់គេមក។... ហើយប្រភេទជនជាតិយួននឹងខ្លះគេភៀសខ្លួន ហើយខ្លះគេជាយុវជន ជាឯកសណ្ឋានកំម៉ង់ដូរម៉ង។ ...

ទូកទូទៅត្រូវរងការបាញ់បោះដោយកម្លាភិបាលកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើទូករបស់ពួកគេរងការបាញ់បោះ ឬ គ្រាន់ធ្វើការបាញ់ព្រមានដើម្បីបំភ័យទូកឱ្យទៅឆ្ងាយពីដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ[2475]។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានចរចាជាមួយរដ្ឋាភិបាលថៃ ដើម្បីដោះលែងអ្នកជាប់ឃុំឃាំង[2476]។ ម្ចាស់ទូកថៃក៏ចរចាផងដែរ ដើម្បីមានការដោះលែងនាវិករបស់ពួកគេជាមួយអ្នកដែលបានចាប់ទូកទាំងនោះ[2477]។ ស.ព.អ. មិនអើពើនឹងភ័ស្តុតាងនេះ។

យើងចាប់យកមកសួរព័ត៌មាន បើថាគេភៀសខ្លួន យើងលែងទៅ ហើយបើគេជាប្រភេទគេមិននិយាយ មិនធ្វើដឹងឮជាមួយយើងៗបញ្ជូនមកកន្លែងសន្តិសុខ"។

[2475] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ឆ.១៤០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/51 ឆ.១៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.១១, ឆ.២៣។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.08.12-14.12.12។ *សូមមើលផងដែរ រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.02.05-14.04.46។ *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៦ ឯកសារ D114/297.1.47 នៅម៉ោង 09.24.31-09.26.55 (កាលណាកាណូតរៀតណាមចូលហួសកោះសេះ គឺមានដេញឱ្យគេទៅវិញហ្នឹង ហើយបើគេបាញ់ ក.ប.ក. យើង ខាងយើងនេះក៏បាញ់វិញដែរ) នៅម៉ោង 09.51.04-09.54.22 (ឆ្លើយថា បាទ គឺនិយាយសម្រាប់កាណូត ឬ ក៏ពួកនេសាទទេ និយាយការបាញ់មុន អីចឹងមានន័យថា យើងបាញ់វិញហ្នឹង។ បើគេអត់បាញ់ទេ យើងអាចលិចកើតទៅគេទៅវិញ)។

[2476] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/100 ឆ.១៦៥។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៨០៖ "ក្រោយមកមានការចរចាររវាងអាជ្ញាធរកម្ពុជា និង ថៃ នៅដើមឆ្នាំ ១៩៧៧ ហើយមានការដោះដូរអ្នកនេសាទទាំងនោះនៅលើកោះស្តេច"។

[2477] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ូ គីម ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D220/1.2.1 EN 01374987 KH 01102483-01102484។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ឃឿន ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/11 ឆ.១៥។ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.១០៦។

ខ. ស.ព.អ. និយាយបំផ្លើសការរៀបរាប់របស់សាក្សីម្នាក់ៗ ដែលអះអាងថាបានឃើញការចាប់ទូក និង មិនពិចារណាពីសក្ខីកម្ម ដែលបដិសេធ ឬ ធ្វើឱ្យការអះអាងរបស់គាត់មិនរឹងមាំ

៦៥១. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ ណុប ហាល់ ថា គាត់បាននឹកឃើញពីការរឹបអូសទូកវៀតណាមមួយនៅជិតកោះពូឡូវ៉ៃ ដែលមានមនុស្សប្រហែល ១៦ នាក់ នៅលើទូកនោះ[2478]។ ណុប ហាល់ គ្រាន់តែអាចនឹកឃើញឡើងវិញ អំពីការចូលរួមក្នុងការដឹកជញ្ជូនទូកវៀតណាមចំនួន *មួយ* ប៉ុណ្ណោះ[2479]។ គាត់មិនបានឮអំពីការសម្លាប់នៅលើកោះតាងទេ ហើយមិនអាចប្រាប់ ក.ស.ច.ស. ថាតើមានទូកប៉ុន្មានត្រូវបានរឹបអូសនៅលើកោះពូឡូវ៉ៃ ឬ កោះផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ[2480]។

៦៥២. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ អ៊ឹង ឆុន ដែលថា កងរបស់គាត់បានចាប់ខ្លួនប្រជាជនវៀតណាមចំនួន ២៣ នាក់[2481]។ អ៊ឹង ឆុន គ្រាន់តែបាននឹកឃើញពីការចាប់ជនជាតិវៀតណាមចំនួន ២៣ នាក់ ហើយមិនបានដឹងនោះឡើយពីជោគវាសនារបស់ពួកគេ បន្ទាប់ពីកងរបស់គាត់បានបញ្ជូនពួកគេទៅកំពង់សោម[2482]។ ខណៈដែលគាត់បាននិយាយថា គាត់បានចូលរួមក្នុងការចាប់ទូកជាច្រើនគាត់ គាត់មិនបានចងចាំអំពីចំនួនពិតប្រាកដទេ ហើយបានប៉ាន់ស្មានថា វាមានចំនួនតិចជាង ១០០[2483]។

៦៥៣. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ ឌុល សុង ដែលថាគាត់បានឃើញការចាប់ខ្លួនអ្នកនេសាទថៃចំនួន ៣០ នាក់ ដែលត្រូវបានគេនាំទៅកាន់កោះពូឡូវ៉ៃក្នុងឆ្នាំ ១៩៧៧[2484]។ ឌុល សុង បាននិយាយ

[2478] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ហាល់ ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/79 ឆ.៨។ ជើងទំព័រ ១៣៦០ នៃដីកាសន្និដ្ឋានស្តាពរ។

[2479] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ហាល់ ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/79 ឆ.៨។

[2480] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ហាល់ ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/79 ឆ.៣-៤, ឆ.២៤។

[2481] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ឆ.១៩។ ជើងទំព័រ ១៤២២ នៃដីកាសន្និដ្ឋានស្តាពរ។

[2482] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ឆ.១៩, ឆ.៣២ ។

[2483] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ឯកសារ D54/34 ឆ.២០។

[2484] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឆ.៤១-៤៩។ ជើងទំព័រ ១៤២៨, ១៤៧៥ នៃដីកាសន្និដ្ឋានស្តាពរ។

ថា គាត់ *គ្រាន់តែ* បានឃើញការចាប់ខ្លួននេះតែមួយ ហើយមិនបានឃើញការចាប់ខ្លួននៅកន្លែងផ្សេងទៀតទេ[2485]។ ផ្ទុយពីអ្វីដែលគាត់បានថ្លែងនៅក្នុងបទសម្ភាសន៍របស់គាត់ជាមួយសមាគមអាដហុក គាត់មិនបានឃើញការសម្លាប់ណាមួយឡើយ[2486]។ ភស្តុតាងរបស់គាត់ដែលបង្ហាញថា ជនជាតិថៃត្រូវបានសម្លាប់ គឺជាពាក្យចចាមអារ៉ាម ដែលគ្មានអ្វីអាចផ្ទៀងផ្ទាត់បាន។ គាត់បានឮរឿងនេះពីទាហាននៅលើកោះរបស់គាត់[2487]។

៦៥៤. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ ម៉ើ រ៉ែត ដែលថា គាត់បានឃើញអ្នកនេសាទថៃចំនួន ១០ នាក់ ត្រូវបានចាប់ខ្លួន និង នាំយកទៅកោះតាកៀវ ក្នុងឆ្នាំ ១៩៧៦[2488]។ ម៉ើ រ៉ែត មិនបាននិយាយថា អ្នកនេសាទទាំងនេះត្រូវបានគេធ្វើបាប ឬ សម្លាប់នោះទេ។ គាត់បានប្រាប់ ក.ស.ច.ស. ថា អ្នកនេសាទថៃចំនួន ១០ នាក់ ដែលគាត់បានសង្កេតឃើញត្រូវបានចាប់ខ្លួនមិនត្រូវបានចង និង កំពុងដើរលេងជុំវិញ និង ចម្អិនអាហារ[2489]។ គាត់ក៏បានថ្លែងផងដែរថា គាត់បានឮថា ការចរចាកំពុងដំណើរការជាមួយស្ថានទូតថៃអំពីជនជាតិថៃ ដែលបានចាប់ខ្លួន ដើម្បីប្រគល់ឱ្យថៃវិញ[2490]។ ស.ព.អ. មិនអើពើនឹងសក្ខីកម្មរបស់ម៉ើ រ៉ែត មួយផ្នែកនេះទេ។

[2485] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឆ.៥១ ។

[2486] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ស-ឆ.៤១, ស-ឆ.៤៦, ស-ឆ.៤៩៖ ស៖"នៅក្នុងបទសម្ភាសន៍របស់លោកជាមួយអង្គការអាដហុក លោកបាននិយាយថា លោកឃើញគេសម្លាប់ជនជាតិថៃ ៣០ នាក់ នៅលើទូក សូមលោករៀបរាប់ប្រាប់យើងអំពីព្រឹត្តិការណ៍នោះបានឬទេ? ឆ.៤១៖ រឿងរ៉ាវនេះកើតឡើងក្នុងរយៈពេលដែលខ្ញុំហាត់ហ្វឹកហ្វឺនទ័ពជើងទឹក។ ខ្ញុំបានឃើញថៃដែលគេចាប់បានយកមកដាក់នៅលើកោះមួយ។ ... ស៖ តើស្ថានភាពរបស់អ្នកដែលគេចាប់នោះយ៉ាងម៉េច ពេលណោកបានឃើញ? ឆ.៤៦៖ គេចងដៃ ហើយយោធានៅលើកោះបានប្រាប់ថា គេនឹងសម្លាប់ពួកនេសាទទាំងនោះ។ ... ស៖ តើគេសម្លាប់ពួកនេសាទទាំងនោះដោយរបៀបណា? ឆ.៤៩៖ ខ្ញុំមិនបានឃើញគេសម្លាប់ដោយផ្ទាល់ភ្នែកទេ តែខ្ញុំដឹងថា គេមិនបាញ់ទេ គឺគេសម្លាប់ចោលតែម្តង"។

[2487] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/8 ឆ.៤៦។

[2488] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 ឆ.២៤។ ជើងទំព័រ ១៤២៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2489] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 ឆ.២៤។

[2490] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 ឆ.២៤។

៦៥៥. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ នូ សារឿន ដែលថា គាត់បានឃើញអ្នកនេសាទចំនួន ២៥ នាក់ ត្រូវបានគេយកទៅចម្ការធូរេនចេងហោង[2491]។ នូ សារឿន បានធ្វើការនៅក្នុងកងកុមារនៅពេលគាត់អះអាងថា បានឃើញអ្នកនេសាទថៃចំនួន ២៥ នាក់ ត្រូវបានគេយកទៅចម្ការធូរេនដើម្បីសម្លាប់ចោល[2492]។ នូ សារឿន មិនបានឃើញការកាប់សម្លាប់ណាមួយនោះទេ។ វាមិនទំនងទេថា ការសម្លាប់បានធ្វើឡើងនៅក្បែរជនស៊ីវិល នៅពេលពិចារណាពីគោលនយោបាយរក្សាសម្ងាត់របស់ ប.ក.ក. នោះ[2493]។ ភស្តុតាងរបស់គាត់គឺជាពាក្យចចាមអារ៉ាម ដែលមិនអាចផ្ទៀងផ្ទាត់បាន។ គាត់បានឮអំពីការកាប់សម្លាប់នេះពីប្រធានកងរបស់គាត់[2494]។

៦៥៦. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ អ៊ូ ដាវ ដែលថា កងរបស់គាត់បានចាប់ទូកនេសាទចំនួនពីរដែលមានជនជាតិថៃប្រមាណចំនួន ១៥ នាក់នៅក្នុងខែមិថុនា ឆ្នាំ ១៩៧៥[2495]។ អ៊ូ ដាវ បានប្រាប់ ក.ស.ច.ស. ថា គាត់ត្រូវបានគេបញ្ជាមិនឱ្យសម្លាប់មនុស្សនៅលើទូកថៃ និង ទុកជីវិតពួកគេ ដើម្បីប្តូរពួកគេជាមួយប្រេងសាំង ហើយថាគាត់មិនបានដឹងអំពីការចាប់ទូកផ្សេងទៀត នៅកំពង់សោមឡើយ[2496]។ គាត់ក៏បានកត់សម្គាល់ផងដែរថា ជនជាតិថៃនៅលើទូកប្រដាប់ដោយអាវុធ។ មួយចំនួនស្លៀកឯកសណ្ឋានយោធា ដែលបង្ហាញថា វាជាកិច្ចការពារសន្តិសុខជាតិនៅពីក្រោយការចាប់នាវានៅដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ[2497]។ ស.ព.អ. មិនអើពើនឹងភស្តុតាងនេះ។

៦៥៧. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ ប៉ែន សារិន នៅ ក.ស.ព. ថា គាត់បានឃើញក្រុមអ្នកនេសាទថៃចំនួនពីរក្រុមដែលមានពី ១៥ ទៅ ២០ នាក់ ដែលត្រូវបានចាប់ខ្លួននៅម្តុំកោះតាង និង

[2491] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 ឆ.៣៥-៣៦។ ជើងចំពីរ ១៤៣០ នៃដីកាសន្និដ្ឋានស្តាពរ។

[2492] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 ឆ.៣៥-៣៦។

[2493] *សូមមើលខាងលើ* កថាខណ្ឌ ១៦៦ ដែលពិភាក្សាគោលការណ៍រក្សាការសំងាត់របស់ ប.ក.ក. និង ផលប៉ះពាល់លើការវាយតំលៃភស្តុតាង។

[2494] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 ឆ.៣៩។

[2495] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.១៣២-៣៤, ឆ.១៥០-៥២។ ជើងចំពីរ ១៤៣៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2496] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.១០៦, ឆ.១៦០។

[2497] កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/24 ឆ.១៤៩-៥២។

កោះរ៉ុង[2498]។ ប៉ែន សារិន មិនអាចជឿជាក់បាន ហើយចម្លើយរបស់គាត់មិនអាចផ្ទៀងផ្ទាត់បាន[2499]។ ចម្លើយរបស់គាត់នៅ ក.ស.ព. ក៏មានតម្លៃជាភស្តុតាងតិចតួចផងដែរ ពីព្រោះចម្លើយនេះត្រូវបានរៀបចំដោយភាគីដែលមានប្រយោជន៍នៅក្នុងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី[2500]។

៦៥៨. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ ហ៊ឹង អ៊ុច ដែលថា គាត់បានសង្កេតឃើញការចាប់ទូកថៃបានម្តង ឬ ពីរដង និង ទូកវៀតណាមចំនួន ៣ ដង[2501]។ ហ៊ឹង អ៊ុច បានប្រាប់ ក.ស.ច.ស. ថា ទូកត្រូវបានចាប់រឺបអូស "ឃ្យរៗម្តង"[2502] មិនមែនថា ពួកគេត្រូវបានចាប់ខ្លួនជាញឹកញាប់នោះទេ។ នៅក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់បាននិយាយថា គាត់កម្របានឃើញនាវាថៃចូលក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យណាស់ ហើយមានការណែនាំឱ្យអនុញ្ញាតជនភៀសខ្លួនបន្តធ្វើដំណើរទៅមុខ ហើយប្រសិនបើជនភៀសខ្លួនមិនមានអង្គរគ្រប់គ្រាន់នោះ កម្មាភិបាលនឹងផ្តល់ឱ្យពួកគេខ្លះទៀត[2503]។ ស.ព.អ. មិនអើពើនឹងភស្តុតាងនេះ។

៦៥៩. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ នាក់ ឃឿន ដែលថា គាត់បានឮអំពីការចាប់ទូកនេសាទវៀតណាមរៀងរាល់ពីរ ឬ បីខែម្តង[2504]។ ចម្លើយរបស់គាត់គឺមិនអាចជឿជាក់បាន ព្រោះវាជាពាក្យចចាមអារ៉ាម។ គាត់មិនដែលបានឃើញការចាប់ទូកនេសាទវៀតណាម ឬ ការសម្លាប់ប្រជាជនវៀតណាមទេ។ គាត់បានប្រាប់ ក.ស.ច.ស. ថា គាត់បានឃើញតែទូកថៃមួយគ្រឿងចតនៅ

[2498] ចម្លើយរបស់ ប៉ែន សារិន ជាមួយ ក.ស.ព. ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D1.3.13.8 EN 00217561-00217562។ ជើងទំព័រ ១៥៣០-១៥៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2499] *សូមមើល* កថាខណ្ឌ ៤១៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2500] *សូមមើល* កថាខណ្ឌ ១៤១ *ខាងលើ* ។ *សូមមើលផងដែរ* កថាខណ្ឌ ១០៥-១០៦ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[2501] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 អ.៣៤។ ជើងទំព័រ ១៥៥៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2502] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/82 អ.៣៤។

[2503] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០០៧ ឯកសារ D54/81.2 EN 01001406-01001407 KH 00984349-00984351។

[2504] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ឃឿន ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/11 អ.១៣-១៤។ ជើងទំព័រ ១៥៥៨ នៃដីកាសន្និដ្ឋានស្តាពរ។

កំពង់សោម ហើយថា មានការចរចាជាមួយម្ចាស់ទូកថៃ ដើម្បីដោះលែងអ្នកចាប់ខ្លួនជាថ្នូរនឹងទំនិញ[2505]។ ស.ព.អ. មិនអើពើនឹងភស្តុតាងនេះ។

៦៦០. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ សៅ សំ ដែលថា គាត់បាននឹកឃើញថា បានឃើញទូកដែលចាប់បានចំនួនបីដង[2506]។ សៅ សំ បាននិយាយថា គាត់នឹកឃើញថា បានឃើញទូកដែលត្រូវចាប់បាន "ប្រហែលបីដង *តែប៉ុណ្ណោះ*"[2507]។ គាត់មិនបានឮអំពីការកាប់សម្លាប់ទេ។ គាត់បានឮពីទាហាននៅក្នុងអង្គភាពរបស់គាត់ថា អ្នកត្រូវបានចាប់ខ្លួនក្រោយមកត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសរបស់ពួកគេ តាមដីគោកវិញ[2508]។

៦៦១. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ មាស វឿន ដែលថា គាត់បាននឹកឃើញថា មានការចាប់ទូកនេសាទប្រមាណពី ៥០ ទៅ ៦០ គ្រឿង ហើយថាមានតែអ្នកនេសាទប្រមាណ ១០ នាក់ប៉ុណ្ណោះដែលត្រូវបានចាប់ខ្លួន ព្រោះពួកគេភាគច្រើនលោតចូលក្នុងទឹក[2509]។ នេះមិនមានន័យថាអ្នកនេសាទទាំងនោះបានស្លាប់ទេ។ អ៊ឹង ឆុន បានលើកឡើងថា ទូកថៃមានឧបករណ៍សង្គ្រោះបន្ទាន់ដូចជាពោងបណ្តែតទឹក និង អាហារ[2510]។ មាស វឿន បាននិយាយថា កងរបស់គាត់មិនដែលបាញ់កម្មករនេសាទដែលលោតចូលក្នុងទឹកទេ[2511]។ កងរបស់គាត់បាញ់តែទូកថៃប្រសិនបើទូកនោះបាញ់មុន[2512]។ មាស វឿន ក៏បានប្រាប់ ក.ស.ច.ស. នៅក្នុងបទសម្ភាសន៍ជាបន្តបន្ទាប់ផងដែរថា ក្នុងអំឡុងពេលស្នាក់នៅរយៈពេល ៣ ឆ្នាំ នៅខេត្តកោះកុង គាត់គ្រាន់តែបានចងចាំការចាប់ទូកថៃមួយគ្រឿងនិង ទូកវៀតណាមពីរគ្រឿងប៉ុណ្ណោះ។ ទូកថៃត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសថៃវិញ[2513]។

[2505] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ឃឿន ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៤ ឯកសារ D114/11 ឆ.១៦។

[2506] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/109 ឆ.១៦។ ជើងទំព័រ ១៥៥៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2507] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/109 ឆ.១៦ (ការគូសបញ្ជាក់បន្ថែម)។

[2508] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សំ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D54/109 ឆ.១៩។

[2509] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.១៩-២០។ ជើងទំព័រ ១៥៦២ នៃដីកាសន្និដ្ឋានស្តាពរ។

[2510] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ឆ.១៥។

[2511] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.២៣។

[2512] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/52 ឆ.២៣។

[2513] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D54/54 ឆ.៣។

មាស វឿន ក៏បានបញ្ជាក់ផងដែរថា បញ្ហារបស់ សុន សេន ដែលមិនត្រូវចាប់ទូកជនភៀសខ្លួនវៀតណាម ក៏អនុវត្តដូចគ្នាចំពោះទូកថៃដែរ[2514]។ ស.ព.អ. មិនអើពើនឹងភស្តុតាងនេះ។

៦៦២. ស.ព.អ. និយាយបំផ្លើសចម្លើយរបស់ សាត ចក់ ដែលថា គាត់បានឃើញកងទ័ពជើងទឹកចាប់ទូកនេសាទតិចជាង ១០ ដង នៅកោះពូឡូវ៉ៃ[2515]។ សាត ចក់ បានទទួលស្គាល់ថា គាត់មិនអាចផ្តល់ការប៉ាន់ប្រមាណត្រឹមត្រូវអំពីចំនួនដងដែលគាត់បានឃើញហេតុការណ៍នោះទេ[2516]។ សាត ចក់ មិនបានឃើញ ឬ ឮអំពីការកាប់សម្លាប់ជនជាតិថៃ ឬ វៀតណាម ហើយមិនដែលឃើញសាកសពអណ្តែតទឹកនៅជុំវិញកោះនោះទេ[2517]។ គាត់បានប្រាប់ ក.ស.ច.ស. ថា នៅពេលទូកត្រូវបានចាប់បាន ពួកគេមិនដែលយកទៅកោះពូឡូវ៉ៃទេ[2518]។ គាត់ក៏បានថ្លែងផងដែរថា ប្រសិនបើវាមិនចាំបាច់ចាប់យកទូកទេនោះ ពួកគេនឹងត្រូវដោះលែង[2519]។ ស.ព.អ. មិនអើពើនឹងភស្តុតាងនេះ។

គ. ភស្តុតាងឯកសារដែល ស.ព.អ. ដកស្រង់ មិនអាចជឿជាក់បាន មានតម្លៃជាភស្តុតាងទាប ឬ មិនគាំទ្រការអះអាងរបស់គាត់អំពីចំនួនជនរងគ្រោះ

៦៦៣. ឯកសារ **D54/16/1R**៖ បទសម្ភាសន៍ មាស មុត ជាមួយអ្នកនិពន្ធ David Kattenburg ដែលក្នុងនោះ មាស មុត ត្រូវបានអះអាងថាបាននិយាយថា ទូកវៀតណាមត្រូវបានចាប់ម្តង ជារៀងរាល់ ៣ ខែ[2520] គឺមិនអាចជឿជាក់បាន និង មានតម្លៃជាភស្តុតាងទាប។ បទសម្ភាសន៍នេះត្រូវបានធ្វើឡើងដោយគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ និង មិនមែនសម្រាប់គោលបំណងនៃការជំនុំជម្រះ

[2514] *រឿងក្តី ឆួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.08.12-14.15.00។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/98 ឆ.៧៥៖ "សុន សេន បាននិយាយថា បើវៀតណាមទាំងនោះជាជនភៀសខ្លួនទៅប្រទេសថៃ យើងមិនត្រូវចាប់ពួកគេទេ ហើយឱ្យពួកគេធ្វើដំណើរទៅចុះ"។

[2515] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.៨៥។ ជើងទំព័រ ១៥៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2516] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.៨៤។

[2517] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.៨៦-៨៧។

[2518] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.៨០។

[2519] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.៧៩។

[2520] ខ្សែអាត់ចតសំឡេងនៃបទសម្ភាសន៍ មាស មុត ជាមួយ David Kattenburg ខែមេសា ឆ្នាំ ២០០៩ ឯកសារ D54/16/1R នៅម៉ោង 00:35:30-00:39:33។ ជើងទំព័រ ១៣៥៣ នៃដីកាសន្និដ្ឋានស្តាពរ។

ក្តីព្រហ្មទណ្ឌ[2521]។ ប្រសិនបើ ស.ច.ស. ផ្តល់តម្លៃជាភ័ស្តុតាងចំពោះកិច្ចសម្ភាសន៍នេះ ស.ច.ស. ត្រូវប្រុងប្រយ័ត្នកុំពិចារណាចម្លើយរបស់ មាស មុត ក្រៅបរិបទ។ ចម្លើយរបស់គាត់បង្ហាញថា មានគោលបំណងយោធា នៅពីក្រោយការចាប់ខ្លួននេះ[2522]។

៦៦៤. ឯកសារ **D4.1.754**៖ ក្រសួងការពារជាតិអាមេរិក ដែលរាយការណ៍ថា នៅខែមេសា ឬ ខែឧសភា ឆ្នាំ ១៩៧៥ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានចាប់ទូកមួយដែលដឹកជនភៀសខ្លួនវៀតណាម ប្រមាណជាង ១០ នាក់[2523] គឺមិនអាចជឿជាក់បាន និង មានតម្លៃជាភ័ស្តុតាងទាប។ ឯកសារនេះ ត្រូវបានប្រមូលដោយអង្គភាពខាងក្រៅ អ.វ.ត.ក. ដោយគ្មានការត្រួតពិនិត្យតាមផ្លូវតុលាការ និង មិនមែនសម្រាប់គោលបំណងនៃការជំនុំជម្រះក្តីព្រហ្មទណ្ឌ[2524]។

៦៦៥. ឯកសារ **D54/11.1** (ដូចគ្នានឹង ឯកសារ **D1.3.30.25**)៖ របាយការណ៍យោធាចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ដែលក្នុងនោះ មាស មុត បានរាយការណ៍ថា ជនជាតិវៀតណាមចំនួន ១២០ នាក់ត្រូវ បានចាប់ខ្លួន និង សម្លាប់នៅចន្លោះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ១៩៧៨ និង ថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៨[2525] មិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ របាយការណ៍នេះត្រូវបានចេញនៅ ពេលដែលកំពុងបង្កើនការប្រយុទ្ធប្រឆាំងនឹងប្រទេសវៀតណាម[2526]។ វាមិនបញ្ជាក់ថាតើជនជាតិ វៀតណាមចំនួន ១២០ នាក់នោះ ជាទាហាន ឬ ជនស៊ីវិលនោះទេ។ កថាខណ្ឌទីពីរនៃរបាយការណ៍ នេះបង្ហាញថា មានការចរចាកំពុងធ្វើឡើងរវាងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និង រដ្ឋាភិបាល

[2521] *សូមមើល* កថាខណ្ឌ ១៤៣ *ខាងលើ* ទាក់ទងនឹងការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[2522] *សូមមើល* ជើងទំព័រ ១៣៥៨ នៃដីកាសន្និដ្ឋានស្តាពរ។

[2523] របាយការណ៍របស់ក្រសួងការពារ ស.រ.អ. ចំណងជើងថា "ឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស និង ការសង្កេតទៅលើ កោះតាង" ខែធ្នូ ឆ្នាំ ១៩៧៥ ឯកសារ D4.1.754 EN 00387429 KH 00791383-00791384។ ជើងទំព័រ ១៤៧២ នៃដីកា សន្និដ្ឋានស្តាពរ។

[2524] *សូមមើល* កថាខណ្ឌ ១៣៩ *ខាងលើ* ទាក់ទងនឹងការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[2525] សេចក្តីរាយការណ៍យោធាពីកងពលធំលេខ ១៦៥ ផ្នែកនយោបាយ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D54/11.1 EN 01147584 KH 00936715។

[2526] *សូមមើលខ.ទ.* ទូរលេខពីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ចំណងជើងថា "សារទូរលេខជូនសមាគមមិត្តភាព ស៊ុយអែត-កម្ពុជា" ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៧៨ ឯកសារ D234/2.1.9 EN 00717585 KH 00749404។ សេចក្តីថ្លែងការណ៍ របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ ឯកសារ D69.1.5 EN 00282392 KH 00277200។ Linda Mathews *ទីក្រុងហាណូយត្រៀមរាយលុកចូលកម្ពុជា* LOS ANGELES TIMES ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ១៩៧៨ ឯកសារ D1.3.25.65។

ថៃស្តីពីការដោះលែងអ្នកជាប់ឃុំថៃ[2527]ដែលវាស៊ីចង្វាក់គ្នាជាមួយភស្តុតាងរបស់ មាស រឿន[2528] ម៉ើ រ៉ែត[2529] ឡាយ ប៊ុនហាក់[2530] អ៊ុយ ញឹក[2531] និង ប៊ាង រ៉ែត[2532]។ ស.ព.អ. មិនអើពើនឹងបរិបទនេះ។

៦៦៦. ឯកសារ **D1.3.34.64**៖ ការទំនាក់ទំនងតាមទូរស័ព្ទសម្ងាត់នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨ ដែលក្នុងនោះមាស មុត ត្រូវបានអះអាងថា បានរាយការណ៍ថា កាណូតវៀតណាមពីរគ្រឿងដែលមានមនុស្សចំនួន ៧៦ នាក់ ត្រូវបានចាប់ខ្លួននៅកោះតាងនៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨[2533] មិនបានគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ របាយការណ៍នេះមិនបានបង្ហាញថា តើវៀតណាមដែលត្រូវបានគេចាប់ខ្លួននោះ គឺជាទាហាន ឬ ជនស៊ីវិល ហើយមិនបាននិយាយអ្វីទាំងអស់អំពីជោគវាសនារបស់ពួកគេ ក្រៅពីថា ពួកគេត្រូវបានគេនាំទៅកាន់ដីគោក។

៦៦៧. ឯកសារ **D1.3.8.4** (ដូចគ្នានឹង **ឯកសារ D54/13.1**)៖ កំណត់ហេតុកិច្ចប្រជុំយោធាចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ដែលក្នុងនោះត្រូវបានគេរាយការណ៍ថា៖ **ក.** នៅថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ១៩៧៦ កងពលធំលេខ ១៦៥ បានប្រទះទូកតូចមួយ ដែលមានមនុស្សចំនួន ៦ នាក់នៅលើទូក (ជនជាតិថៃចំនួន ៥ នាក់ និង ជនជាតិខ្មែរម្នាក់) និង **ខ.** នៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៧៦ ទូកនេសាទថៃចំនួន

[2527] សេចក្តីរាយការណ៍យោធាពីកងពលធំលេខ ១៦៥ ផ្នែកនយោបាយ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៧៨ ឯកសារ D54/11.1 EN 01147584 KH00936715៖ "២. សៀមដែលត្រូវដោះលែង មានការយឺតយូរ មិនបានតាមការកំណត់ មូលហេតុពីការខុសឈ្មោះ អ្នកដែលមកទទួលខ្លះ តែខុសនេះតាមពិនិត្យ គឺមិនមានខុសទាំងស្រុងទេ គឺខុសចុងឈ្មោះបន្តិចៗ ជាមូលដ្ឋានត្រូវ ឯការទាក់ទងដល់យោបល់ ក៏មិនបានតាមសំណូមពរ ដោយតែអ្វូរមិនឮគ្នា ផ្អែកលើទូរលេខ ខាងសមមិត្តឡូញ ហើយដោយមានការបញ្ជូនសារយឺត និង បាត់ បានធ្វើឱ្យការប្រគល់ថៃនេះពន្យារពេលរហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៨..."។

[2528] *រឿងក្តី ន្ឃួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D234/2.1.95 នៅម៉ោង 14.08.12-14.15.00។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៥ ឯកសារ D54/54 ឆ.៣។

[2529] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉ែត ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/11 ឆ.២៤។

[2530] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៧ ឯកសារ D59/1/1.9a EN 00963735 KH 00926467-00926468។

[2531] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញឹក ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D54/77 ឆ.១៩។

[2532] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉ែត ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D54/98 ឆ.៨០។

[2533] របាយការណ៍ ចំណងជើងថា "ទូរស័ព្ទសម្ងាត់ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨" ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨ ឯកសារ D1.3.34.64។ ជើងទំព័រ ១៤២៧ នៃដីកាសន្និដ្ឋានស្តាពរ។

១០ ត្រូវបានចាប់ខ្លួននៅម្តុំកោះកុង និង កោះស្តេច[2534] មិនគាំទ្រការអះអាងរបស់ ស.ព.អ. ទេ។ របាយការណ៍នេះមិនបាននិយាយអំពីជោគវាសនារបស់មនុស្ស ៦ នាក់ ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ១៩៧៦ នោះឡើយ។ ចំពោះការចាប់ខ្លួននៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៧៦ កំណត់ហេតុកិច្ចប្រជុំយោធាបង្ហាញថា សមាជិកនាវិកចំនួន ៧ នាក់ បានណេតចូលក្នុងសមុទ្រ ហើយគេចផុតពីការចាប់ខ្លួន[2535]។ ដូច អ៊ឹង ឆុន បានរៀបរាប់ ទូកថែបំពាក់ដោយសម្ភារសង្គ្រោះបន្ទាន់ ដូចជាពោងបណ្តែតទឹក និង អាហារ[2536]។ មិនមានការនិយាយអំពីសមាជិកនាវិកដទៃទៀតទេ។

២. មានភស្តុតាងមិនគ្រប់គ្រាន់បង្ហាញអំពីចំនួនជនរងគ្រោះដ៏ច្រើននៃឧក្រិដ្ឋកម្ម នៅតាមមន្ទីរសន្តិសុខ ការដ្ឋានការងារ ឬ សហករណ៍ នៅតំបន់ស្វយ័តកំពង់សោម

ក. វត្តឥន្ទញ្ញាណ

៦៦៨. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា មនុស្សប្រមាណជាង ៥០០ នាក់ ទៅ ១០០០ នាក់ ត្រូវបានឃាត់ខ្លួន និង សម្លាប់នៅក្នុងវត្តឥន្ទញ្ញាណ[2537]។ ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយដែលមិនអាចជឿជាក់បាន មានលក្ខណៈប៉ាន់ស្មាន ផ្ទុយគ្នា និង គ្មានមូលដ្ឋានសំអាងរបស់ ន្ឋន យ៉ឹម ឱន ជុន ប៉ូច កុយ និង សុខ ឡាង[2538]។ ស.ព.អ. ដកស្រង់

[2534] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657355 KH 00162489។ ជើងទំព័រ ១៤២៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2535] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៥" ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.8.4 EN 00657355 KH 00162489។

[2536] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុន ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/34 ឆ.១៥។

[2537] កថាខណ្ឌ ៥៦៤ នៃដីកាសន្និដ្ឋានស្តាពរ៖ "យើងអាចអះអាងដោយមានការជឿជាក់ថា អ្នកឃុំខ្លួននៅវត្តឥន្ទញ្ញាណ មានគួលេខខ្ពស់ច្រើនជាងសពចំនួនប្រមាណ ៥០០-១០០០ នាក់ ដែលបានរកឃើញនៅទីនោះភ្លាមៗ ក្រោយការបរាជ័យនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ... មិនមែនគ្រប់រណ្តៅទាំងអស់ នៅវត្តឥន្ទញ្ញាណសុទ្ធតែបានកាយធ្វើកោសល្យវិច័យនោះទេក្នុងឆ្នាំ ១៩៧៩ ដោយមានរបាយការណ៍ពីរណ្តៅសពថ្មីៗ បានឃើញនៅទីតាំងនោះក្នុងឆ្នាំ ១៩៩២ និង ឆ្នាំ ២០០៣។ មានរណ្តៅជាច្រើនទៀតមិនទាន់រកឃើញ។ ទីពីរ គួលេខទាំងនេះ ត្រូវតែរាប់ចូលបន្ថែមនូវបណ្តាលអ្នកទោសដែលបានដោះលែង នៅក្នុង និង ចុង របបកម្ពុជាប្រជាធិបតេយ្យ ឬ ក្រោយមកបានបញ្ជូនមកសម្លាប់នៅ ស-២១"។

[2538] ជើងទំព័រ ១៧៦៨, ១៧៧០-៧៤, ១៧៨៣-៨៤, ១៧៦៨, ១៧៧០-៧៨ នៃដីកាសន្និដ្ឋានស្តាពរ។

ការមើលឃើញពីចម្ងាយនូវអ្នកទោសនៅវត្តឥន្ទញ្ញាណក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និង របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតំណែងដែលមិនគាំទ្រការអះអាងរបស់គាត់[2539]។

i. សាក្សីដែលបានទៅមើលវត្តឥន្ទញ្ញាណ ក្រោយឆ្នាំ ១៩៧៩ មិនអាចជឿជាក់បាន និង បាននិយាយផ្ទុយគ្នា

៦៦៩. **ន្ឋន យឹម៖** ន្ឋន យឹម មិនអាចជឿជាក់បានឡើយ។ គាត់មានវ័យក្មេងក្នុងអំឡុងពេលដែលព្រឹត្តិការណ៍កើតឡើង ទាយស្មាន និង លើកឡើងផ្ទុយពី ប៉ូច កុយ ឱន ជុន និង សុីម នី។ ន្ឋន យឹម បានប៉ាន់ស្មានថា គាត់បានឃើញសាកសពយ៉ាងច្រើនបំផុតចំនួន ១000 នាក់ នៅជុំវិញវត្តឥន្ទញ្ញាណក្រោយពីឆ្នាំ ១៩៧៩[2540]។ ន្ឋន យឹម មានអាយុ ៩ ឆ្នាំ នៅពេលគាត់បានមកមើលវត្តឥន្ទញ្ញាណលើកដំបូងនៅឆ្នាំ ១៩៧៩ ជាមួយបងប្រុស និង ប្អូនស្រីរបស់គាត់ដែលទាំងពីរនាក់បានស្លាប់[2541]។ ក្រោយមកគាត់បានចូលរួមសម្អាតវត្តជាមួយម្តាយរបស់គាត់គឺ ឱន ជុន[2542] និង ប៉ូច កុយ[2543]។ គាត់បានអះអាងថា បានឃើញឆ្អឹងសាកសពដែលលើដីក្នុងបរិវេណវត្ត នៅក្នុងពាងទឹក និង ធុងសាំង នៅក្បែរព្រៃឫស្សី និង សាកសពចំនួន ១00 នាក់ ដែលជាប់ខ្នោះនៅក្នុងរោងបាយ[2544]។ ប៉ូច កុយ ដែលនៅជាមួយ ន្ឋន យឹម នៅពេលពួកគេចូលរោងបាយ មិនបាននិយាយអំពីសាកសពណាមួយដែលនៅលើដីនោះទេ[2545] មានតែសាកសពដែលត្រូវបានគេរកឃើញនៅក្នុងកន្លែងនីមួយៗ ហើយមិនមែននៅក្នុងផ្នូរធំៗទេ[2546]។ ឱន ជុន ក៏មិនបានឃើញសាកសពនៅក្នុង

[2539] ជើងចំព័រ ១៦៧៦-៧៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2540] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ន្ឋន យឹម ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/66 អ.១៣-១៤, អ.១៨, អ.២២-៣០។ កថាខណ្ឌ ៥៦២ ជើងចំព័រ ១៧៦៨, ១៧៧0-៧៤, ១៧៨៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2541] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ន្ឋន យឹម ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/66 EN 00986324 KH 00977142-00977143 អ.៦-៧។

[2542] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ន្ឋន យឹម ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/66 អ.១៥។

[2543] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ន្ឋន យឹម ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/66 អ.២៥, អ.២៧។

[2544] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ន្ឋន យឹម ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/66 អ.៥, អ.១៤, អ.២២-៣០។

[2545] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/30 EN 01049148-01049149 KH 01363895-01363897។

[2546] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១0 ឯកសារ D2/22 EN 00634154 KH 00662131។

អោងបាយដែរ[2547]។ ស៊ឹម នី ដែលបានសង្កេតមើលវត្តឥន្ទញ្ញាណពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មិនបានឃើញពាងទឹកនៅក្នុងបរិវេណវត្តទេ[2548]។

៦៧០. **ឱន ជុន៖** ឱន ជុន មិនអាចជឿជាក់បានឡើយ។ គាត់ទាយស្មាន និង និយាយផ្ទុយពី ប៉ូច កុយ។ ឱន ជុន បានប៉ាន់ស្មានថា បានឃើញឆ្អឹងលលាដ៍ក្បាលជិនួនពី ៤០០ ទៅ ៥០០ ក្បាលនៅលើដីក្នុងវត្តក្នុងឆ្នាំ១៩៧៩[2549]។ នៅពេលតទល់នឹងចម្លើយរបស់ ប៉ូច កុយ ដែលនិយាយថា សាកសពចំនួន ២០០ ត្រូវបានជីកកកាយពីរណ្តៅនៅដើមឆ្នាំ ១៩៨០ គាត់បានពន្យល់ថា ប៉ូច កុយ មិនបានចូលរួមក្នុងការសម្អាតរាល់ថ្ងៃដូចគាត់បានធ្វើទេ[2550]។ គាត់បានអះអាងថា ស្ត្រីម្នាក់ឈ្មោះ យាយ ប៉ូ អាចបញ្ជាក់បញ្ហានេះបាន ប៉ុន្តែគាត់បានស្លាប់ហើយ[2551]។ មិនដូចនឹង ប៉ូច កុយ ឱន ជុន មិនបានឃើញទាហានវៀតណាមនៅខាងក្នុងកុដិលោកនៅវត្តឥន្ទញ្ញាណទេ[2552]។

៦៧១. **ប៉ូច កុយ៖** ប៉ូច កុយ មិនគាំទ្រការអះអាងរបស់ ស.ព.អ. ទេ។ ក្រៅពីការលើកឡើងផ្ទុយ និង ការបង្ខូចភាពអាចជឿជាក់បាននៃការអះអាងរបស់ នួន ឃីម និង ឱន ជុន[2553] គាត់បានបញ្ជាក់ថា មិនមានកំណត់ត្រាជាផ្លូវការ រូបភាព ឬ ការជីកកកាយជាផ្លូវការនៃទីកន្លែងនោះទេ[2554]។ ឆ្អឹងទាំងអស់ត្រូវបានបូជា ឬ ត្រូវបានទុកនៅក្នុងចេតិយនៅក្នុងបរិវេណវត្ត[2555]។ ប៉ូច កុយ មិនបានដឹងទេថាតើ

[2547] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱន ជុន ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/65 អ.៣៧, អ.៣៩។

[2548] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D114/46 EN 01065179 KH 01307873។ *សូមមើល* កថាខណ្ឌ ៦៧៨ *ខាងក្រោម* ។

[2549] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱន ជុន ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/65 អ.១៩។ ជើងទំព័រ ១៧៦៨, ១៧៧០-៧៨, ១៧៨៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2550] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱន ជុន ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/65 អ.២៧។

[2551] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱន ជុន ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/65 អ.២៧។

[2552] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឱន ជុន ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D54/65 អ.៣៧, អ.៣៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ឯកសារ D2/4 អ.៣៣។

[2553] *សូមមើល* កថាខណ្ឌ ៦៦៩-៧០ *ខាងលើ*។

[2554] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D2/4 អ.៤១។ *សូមមើលផងដែរ* របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22 EN 00634155 KH 00662131។

[2555] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D2/4 អ.៤១។ *សូមមើលផងដែរ* របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22 EN 00634155 KH 00662131។

មានលលាដ៍ក្បាលចំនួនប៉ុណ្ណា ដែលនៅសេសសល់នៅវត្ត ប៉ុន្តែបើយោងតាមកូនប្រុសរបស់គាត់ មានតែចំនួន ៦ ប៉ុណ្ណោះ[2556]។ ចម្លើយរបស់ ប៉ូច កុយ ដែលថា វត្តឥន្ទញ្ញាណត្រូវបានគេប្រើជាមន្ទីរសន្តិសុខ និង វាលពិឃាត គឺពាក្យចចាមអារ៉ាម។ គាត់បានឮរឿងនេះពី ជុំ ពេជ្រ ដែលបានស្លាប់ហើយ[2557]។ ប៉ូច កុយ មិនដែលបានទៅវត្តឥន្ទញ្ញាណក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ មិនបានដឹងថា តើមនុស្សប្រភេទណាត្រូវបានឃុំនៅទីនោះ ហើយមិនបានដឹងថា អ្នកណាដែលត្រូវបានឃាត់ខ្លួននៅទីនោះដែលនៅរស់[2558]។ តម្លៃជាភស្តុតាងរបស់គាត់មានកម្រិត នៅត្រឹមអ្វីដែលគាត់បានឃើញនៅក្នុងឆ្នាំ ១៩៧៩។ ប៉ូច កុយ បានស្លាប់បាត់ទៅហើយ[2559] ដូច្នេះ មាស មុត មិនមានឱកាសពិនិត្យដេញដោលគាត់នៅក្នុងការជំនុំជម្រះក្នុងសវនាការ និង បញ្ជាក់បំភ្លឺអំពីការសង្កេតរបស់គាត់នៅឆ្នាំ ១៩៧៩ ក្រោយពិនិត្យឃើញការលើកឡើងរបស់ ឱន ជុន និង នួន ឃឹម នោះឡើយ។

៦៧២. **សុខ ឡាង៖** សុខ ឡាង មិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ សុខ ឡាង បានក្លាយជាសមាជិកបុគ្គលិកមន្ទីរធម្មការ និង សាសនានៅខេត្តព្រះសីហនុក្នុងឆ្នាំ ១៩៨០[2560]។ គាត់បាននិយាយថានៅឆ្នាំ ១៩៨១ ឬ ឆ្នាំ ១៩៨២ ព្រះសង្ឃបានរាយការណ៍ប្រាប់គាត់ថា បានរកឃើញផ្នឹងសាកសពចំនួនប្រាំពីរនៅវត្តឥន្ទញ្ញាណ[2561]។ គាត់បានសរសេររបាយការណ៍នៅក្នុងកំណត់ហេតុមួយ ប៉ុន្តែ បានបាត់ទៅហើយ[2562]។ នៅពេលគាត់ទៅវត្តឥន្ទញ្ញាណ ព្រះសង្ឃបានបូជាសាកសពនោះរួចទៅហើយ[2563]។ នៅពេលតទល់នឹងចម្លើយមុនរបស់គាត់ដែលថា ព្រះសង្ឃបានរកឃើញសាកសពចំនួន ១៧ នាក់ គាត់បានអះអាងថា សាកសពចំនួនប្រាំពីរនាក់នោះ គឺជាទាហានមានឯកសណ្ឋានដែលបានរកឃើញ រីឯសាកសពចំនួន ១០ ផ្សេងទៀត គឺជាប្រជាជនសាមញ្ញដែលបាន

[2556] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ឯកសារ D2/4 ឆ.៤៣។

[2557] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D2/4 ឆ.១៧-១៨។

[2558] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ D2/4 ឆ.១៦-១៧, ឆ.៤៦។

[2559] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D114/30 EN 01049149 KH 01363896។

[2560] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឡាង ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/111 ឆ.៦។

[2561] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឡាង ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/111 ឆ.៦។

[2562] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឡាង ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/111 ឆ.១៦។

[2563] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឡាង ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/111 ឆ.១៨។

ស្លាប់ដោយសារជំងឺ ឬ ភាពអត់ឃ្លាន[2564]។ គាត់មិនបាននិយាយអំពីឆ្នឹងដ៏ច្រើនដែលនៅសេសសល់ ហើយត្រូវបាន ន្ឋន យីម ឱន ជុន និង ប៉ូច កុយ បានអះអាងថាបានឃើញនោះទេ។

ii. សាក្សីដែលបានឃើញ ឬ បានជាប់ឃុំនៅវត្តឥន្ទញ្ញាណ នៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និង របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មិនគាំទ្រការអះអាងរបស់ ស.ព.អ.

៦៧៣. **ស៊ឹម នី៖** ស៊ឹម នី មិនគាំទ្រការអះអាងរបស់ ស.ព.អ. ទេ។ ស៊ឹម នី បានដាំបន្លែនៅក្បែរវត្តឥន្ទញ្ញាណ មុនពេលគាត់ត្រូវបានគេបញ្ជូនទៅភូមិភាគបូព៌ានៅចុងឆ្នាំ ១៩៧៨[2565]។ គាត់បានរៀបរាប់ថា វត្តឥន្ទញ្ញាណជា "កន្លែងលត់ដំ" មិនមែនជាគុកទេ ដែលអ្នកប្រព្រឹត្តបទល្មើសតូចតាចនឹងត្រូវបានឃុំជាបណ្តោះអាសន្នមុនពេលត្រូវបានស្តារនីតិសម្បទាឡើងវិញ និង ដោះលែង[2566]។ គាត់បានឃើញអ្នកទោសជាទៀងទាត់នៅពេលពួកគេទៅធ្វើការនៅស្រែ និង អាចនិយាយជាមួយពួកគេទៀតផង[2567]។ តាមគាត់ដឹង អ្នកទោសគឺជាកម្មាភិបាល៖ យោធា កម្មករ និងអ្នកនេសាទ មកពីកងនេសាទ[2568]។ គាត់មិនបានឃើញស្រីៗ កូនក្មេង ជនជាតិថៃ ជនជាតិវៀតណាម ឬក៏អ្នកទោសមកពីបស្ចិមប្រទេស ក្នុងអំឡុងពេលគាត់នៅទីនោះ នៅក្បែរវត្តឥន្ទញ្ញាណនោះទេ[2569]។ គាត់ក៏មិនបានឃើញផ្នូរនៅជិតវត្តដែរ[2570]។ នៅពេល ស៊ឹម នី បានទៅមើលវត្តឥន្ទញ្ញាណជាមួយ ក.ស.ច.ស. នៅ

[2564] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឡាង ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/111 ន.១៩-២១។

[2565] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/31 ន.៦-៧, ន.៩។ *សូមមើលផងដែរ* កថាខណ្ឌ ២៤៥ និង ៤០៦-០៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2566] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/30.1 EN 1070549 KH 00964127។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/32 ន.១៧, ន.២៨។

[2567] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/32 ន.៦, ន.១៨។

[2568] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/32 ន.២១។

[2569] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/32 ន.២២-២៣, ន.២៧។

[2570] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/32 ន.២៩។

ខែកញ្ញា ឆ្នាំ ២០១៤ បរិវេណវត្តពោរពេញទៅដោយអាគារថ្មីជាច្រើន ហើយរូបរាងរបស់វាបានផ្លាស់ប្តូរយ៉ាងខ្លាំងពីអ្វីដែលគាត់បានសង្កេតឃើញក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2571]។

៦៧៤. **មូល ឈិន៖** មូល ឈិន មិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ មូល ឈិន ត្រូវបានគេឃុំឃាំងនៅវត្តឥន្ទញ្ញាណ ក្នុងរយៈពេលបីថ្ងៃ នៅមុនពេលកងទ័ពវៀតណាមបានចូលមកដល់បន្តិច[2572]។ នៅពេលគាត់ត្រូវបានស្តាប់ចម្លើយដំបូងដោយ ក.ស.ច.ស. គាត់បាននិយាយថា គ្មាននរណាម្នាក់បានសួរចម្លើយ ធ្វើបាប ឬ ដាក់ខ្នោះគាត់នៅទីនោះទេ[2573]។ នៅពេលដែលគាត់ទៅមើលវត្តឥន្ទញ្ញាណ ជាមួយ ក.ស.ច.ស. គាត់បានផ្លាស់ប្តូររឿងរ៉ាវរបស់គាត់។ គាត់បានឃើញអំពីការជាប់ខ្នោះនៅទីនោះជាមួយអ្នកទោសចំនួន ២០ នាក់នៅក្នុងរោងបាយ និង មានបំណងចង់តែ "ចម្លើយមុនរបស់គាត់"[2574]។ បើទោះបីជាការរៀបរាប់របស់ មូល ឈិន អំពីការជាប់ខ្នោះជាមួយអ្នកទោសចំនួន ២០ នាក់ អាចជឿជាក់បានក៏ដោយ ក៏វាមិនមែនជាការរៀបរាប់អំពីផ្នូរ និង ផ្នឹងដែលនៅសេសសល់ ដូចបានសង្កេតដោយ ន្ឋន ឃីម ឱន ជុន និង ប៉ូច កុយ ក្រោយឆ្នាំ ១៩៧៩

[2571] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/88 ឯ.៩។ *សូមមើលផងដែរ* កថាខណ្ឌ ៦៧៨ *ខាងក្រោម*។

[2572] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៥ ឯកសារ D114/39 EN 01079212-01079213 KH 01065092។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឯ.១៥៩។

[2573] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ស-ឯ.១៦១, ស-ឯ.១៦៧៖ "ស៖ តើគេប្រព្រឹត្តចំពោះលោកយ៉ាងដូចម្តេចដែរ ពេលលោកជាប់នៅវត្តនោះ? ឯ.១៦១៖ នៅទីនោះ គេមិនសួរចម្លើយខ្ញុំទេ ហើយក៏មិនធ្វើអ្វីខ្ញុំដែរ។ ... ស៖ តើលោកត្រូវគេដាក់ខ្នោះដែរឬទេ? ឯ.១៦៧៖ នៅវត្តឥន្ទញ្ញាណ គេមិនដាក់ខ្នោះខ្ញុំទេ"។

[2574] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៥ ឯកសារ D114/40 ស-ឯ.៣៖ "ត្រង់ចម្លើយ ១៦៧ ក្នុងការស្តាប់សម្ភាសន៍លើកមុន លោកបាននិយាយថា ពេលជាប់ឃុំនៅវត្តឥន្ទញ្ញាណ គេមិនដាក់ខ្នោះលោកទេ ប៉ុន្តែនៅទីកសាបគេដាក់ច្រវាក់ជើងលោក។ ក្នុងពេលទស្សនាទីតាំងនៅវត្តឥន្ទញ្ញាណ លោកនៅចាំបន្ទប់ដែលគេឃុំឃាំងលោក និង បានប្រាប់យើងពេលស្ថិតក្នុងសាលាអាន់នោះថា គេដាក់ខ្នោះលោកជាមួយអ្នកទោសប្រហែល ២០ នាក់ ផ្សេងទៀត នៅក្នុងសាលាអាន់នោះ។ សូមលោកពន្យល់អំពីហេតុការណ៍នេះ? ឯ.៣៖ ត្រឹមត្រូវហើយ ខ្ញុំចង់កែតម្រូវចម្លើយដែលខ្ញុំបានផ្តល់កាលពីលើកមុន។ ពិតណាស់ ពេលខ្ញុំទៅសាលាអាន់ក្នុងវត្តឥន្ទញ្ញាណជាមួយលោក ភ្លាមៗនោះ ខ្ញុំចងចាំថា គេដាក់ខ្នោះជើងខ្ញុំ ដែលធ្វើឈើ និង សិករនុកដែកវែងជាមួយនឹងអ្នកទោសប្រហែល ២០ នាក់ផ្សេងទៀត"។

នោះដែរ។ មូល ឈិន គឺនៅវត្តឥន្ទញ្ជាណ មុនពេលវៀតណាមមកដល់[2575]។ គាត់មិនបាននិយាយអំពីផ្នូរ ឬ ការកាប់សម្លាប់នោះទេ។

៦៧៥. **ទូច សឿលី៖** ទូច សឿលី មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។ ទូច សឿលី បានធ្វើការនៅជិតវត្តឥន្ទញ្ជាណនៅឆ្នាំ ១៩៧៧ ហើយបានឃើញអ្នកទោសនៅទីនោះ ខណៈដែលគាត់កំពុងបេះផ្លែឈើ[2576]។ អ្នកយាមបានអនុញ្ញាតឱ្យគាត់ចូលក្នុងវត្ត៖ "ម៉ូចអត់មានអីតឹងរឹងផង"[2577]។ គាត់អាចដើរលេងជុំវិញធម្មតា ហើយបេះផ្លែឈើ និង អាចនិយាយជាមួយអ្នកយាមបាន[2578]។ គាត់បានប្រាប់ ក.ស.ច.ស. ថា៖ "បើមានអ្នកទោសច្រើន គេប្រហែលយាមមិនឱ្យយើងចូលទេ។ ប៉ុន្តែមិត្តខ្ញុំបីបួននាក់ដើរចូលធម្មតា មនុស្សទាំងនោះអត់ខ្លាចផង។ ហើយខ្ញុំក៏ឃើញតែម្នាក់ អត់ឃើញអ្នកទោសច្រើនផង"[2579]។ ទូច សឿលី មិនជឿថា អ្នកទោសត្រូវបានសម្លាប់នៅវត្តឥន្ទញ្ជាណទេ[2580]។ គាត់បានប៉ាន់ស្មានថា ក្រោយមក មនុស្សត្រូវបានគេបញ្ជូនទៅភ្នំពេញ ឬ កន្លែងផ្សេងទៀតដើម្បីសម្លាប់ចោល[2581]។

៦៧៦. **របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចុះខែធ្នូ ឆ្នាំ ២០១០៖** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស. ចុះខែធ្នូ ឆ្នាំ ២០១០ មិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ របាយការណ៍ស្តីពីការកំណត់ទីកន្លែងនេះ បង្ហាញពីភាពមិនគ្រប់ជ្រុងជ្រោយនៃការស៊ើបអង្កេតនៅវត្តឥន្ទញ្ជាណ។ ការផ្លាស់ប្តូរយ៉ាងច្រើនបានកើតឡើងនៅក្នុងបរិវេណ ដែលមិនអាចឱ្យយើងកំណត់ដោយជាក់លាក់នូវចំហំ និង ចំណុះទីតាំងនោះទេ[2582]។ អ្នកស៊ើបអង្កេត

[2575] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៥ ឯកសារ D114/39 EN 01079213-01079213 KH 01065092។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឆ.១៥៩។ ជើងទំព័រ ១៦៧៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2576] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/15 ឆ.២៧។ *សូមមើល* ជើងទំព័រ ១៦៧៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2577] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/187 ឆ.២៦។

[2578] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ឯកសារ D114/187 ឆ.២៧។

[2579] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/187 ឆ.៣១។

[2580] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/15 ឆ.២៨។

[2581] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D2/15 ឆ.២៨។

[2582] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22 EN 00634142 KH 00662109។

ក.ស.ច.ស. បានកត់សម្គាល់ថា "កន្លងមក នៅមិនទាន់មានការប៉ាន់ប្រមាណ ដោយផ្អែកលើការរៀបរាប់របស់សាក្សីពីចំណុះដែលទីតាំងនេះ អាចឃុំខ្លួនមនុស្សបាន ក្នុងអំឡុងពេលដែលទីតាំងនេះនៅមានប្រតិបត្តិការនោះនៅឡើយទេ"[2583] ។ "មិនមានព័ត៌មានថាតើ ប្រសិនបើមានមន្ទីរឃុំឃាំងមែន មានអ្នកជាប់ឃុំ ឬ 'អ្នកទោស្រាល' ចំនួនប៉ុន្មាននាក់ដែលអាចត្រូវបានឃុំឃាំងក្នុងបរិវេណនោះ។ តើចំនួនអ្នកទោសក្នុងអំឡុងពេលនោះ មានការប្រែប្រួលយ៉ាងដូចម្តេច? ឬ តើនៅពេលណាដែលចំនួនអ្នកទោសកើនឡើងដល់កម្រិតខ្ពស់បំផុត នៅពេលមានព្រឹត្តិការណ៍ជាក់លាក់អ្វីមួយនោះ?"[2584]។ អ្នកស៊ើបអង្កេតបានកត់សម្គាល់ផងដែរថា ការប្រែប្រួលទីតាំង និង ការដាំរុះបន្លែ "អាចនឹងធ្វើឱ្យលទ្ធផល/សកម្មភាពស៊ើបអង្កេតដោយប្រយោលណាមួយ មិនអាចយកជាការបាន។ នៅដំណាក់កាលនេះ សកម្មភាពទន្ទ្រានបន្ថែមនោះ នៅមិនទាន់អាចមានលទ្ធភាពប្រព្រឹត្តិទៅបានទេ"[2585]។

៦៧៧. **របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចុះខែកុម្ភៈ ឆ្នាំ ២០១៤៖** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចុះខែកុម្ភៈ ឆ្នាំ ២០១៤ មិនគាំទ្រការអះអាងរបស់ ក.ស.ព. នោះទេ។ របាយការណ៍នេះក៏គូសបញ្ជាក់ផងដែរ អំពីភាពមិនគ្រប់ជ្រុងជ្រោយ នៃការស៊ើបអង្កេតនៅវត្តឥន្ទញ្ញាណ។ នៅមុនពេលចុះពិនិត្យទីតាំងនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៤ ក.ស.ច.ស. បានព្យាយាមស្វែងរកភ័ស្តុតាងឯកសារ និង សាក្សី ពីអាជ្ញាធរដែលអាចរក្សាទុកកំណត់ត្រាទាក់ទងនឹងការស៊ើបអង្កេតរបស់ខ្លួននៅវត្តឥន្ទញ្ញាណ[2586]។ សាលាក្រុងកំពង់សោម និង ក្រសួងធម្មការ មិនមានកំណត់ត្រាបែបនេះទេ[2587]។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ក៏បង្ហាញពីភាពមិនស៊ីចង្វាក់គ្នារវាងការរៀបរាប់របស់ ប៉ូច កុយ ឱន ជុន និង ឆួន ឃីម ផងដែរ៖

[2583] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22 EN 00634142 KH 00662109។

[2584] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22 EN 00634142 KH 00662109។

[2585] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ D2/22 EN 00634155 KH 00662133។

[2586] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/30 EN 01049147-01049148 KH 01363894។

[2587] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/30 EN 01049147-01049148 KH 01363894។

> វាគឺជាការសំខាន់ក្នុងការបញ្ជាក់ថា នៅមានសំណួរដែលមិនទាន់បានដោះស្រាយ រវាងការរៀបរាប់របស់សាក្សីឈ្មោះ ប៉ូច កុយ (ស្លាប់) និង ការរៀបរាប់របស់លោកស្រី ឱន ជុន និង កូនប្រុសរបស់គាត់ គឺលោក ន្ឋន ឃីម។ ការរៀបរាប់របស់សាក្សី ប៉ូច កុយ ខ្វះការយោងណាមួយចំពោះសាកសព ដែលបានរកឃើញនៅលើផ្ទៃដី បើទោះជាលោក ន្ឋន ឃីម បានបញ្ជាក់ថា នៅក្នុងពេលដែលគាត់បានឃើញសាកសពទាំងនោះនៅក្នុងសាលាឆាន់ ឈ្មោះ ប៉ូច កុយ ក៏មានវត្តមានជាមួយគាត់ដែរ។
>
> ឈ្មោះ ប៉ូច កុយ យោងទៅលើវត្តមានរបស់កងទ័ពវៀតណាម នៅក្នុងឆ្នាំ ១៩៧៩ ដែលសាក្សីលោកស្រី ឱន ជុន និង លោក ន្ឋន ឃីម មិនបានបញ្ជាក់នោះទេ។ វាហាក់ដូចជាសាក្សីទាំងអស់បានស្ថិតនៅទីកន្លែងនោះ ប្រហែលជានៅក្នុង [រយៈពេល] ដូចគ្នា ឈ្មោះ ប៉ូច កុយ ប្រហែលជាបានស្ថិតនៅទីនោះមុនគេ[2588]។

ចំពោះផ្នូររួមពីរដែលកំណត់អត្តសញ្ញាណដោយ ឱន ជុន និង ន្ឋន ឃីម នៅជិតផ្ទះរបស់ពួកគេ អ្នកស៊ើបអង្កេតបានកត់សម្គាល់ថា៖ “ផ្ទៃដីនោះ មិនបង្ហាញនូវការបញ្ជាក់ណាមួយថា មានរណ្តៅសាកសពមនុស្សនៅពីក្រោមនោះទេ”[2589]។ ក.ស.ច.ស. មិនបានប៉ះពាល់ផ្ទៃដីនោះទេ ដូច្នេះ គ្មានការសន្និដ្ឋានណាមួយអាចធ្វើឡើង អំពីអ្វីដែលត្រូវបានគេអះអាងថាកប់នៅក្រោមដីនោះឡើយ[2590]។

៦៧៨. **របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចុះខែកញ្ញា ឆ្នាំ ២០១៤៖** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចុះខែកញ្ញា ឆ្នាំ ២០១៤ មិនគាំទ្រការអះអាងរបស់ ស.ព.អ. ឡើយ។ នៅខែឧសភា ឆ្នាំ ២០១៤ ក.ស.ច.ស. បានចុះទៅពិនិត្យវត្តឥន្ទញ្ញាណម្តងទៀត ជាមួយ ស៊ឹម នី[2591]។ តាមការចងចាំរបស់ ស៊ឹម នី អ្នកស៊ើបអង្កេត ក.ស.ច.ស. បានលើកឡើងបន្ថែមទៀតអំពីការ

[2588] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/30 EN 01049148-01049149 KH 01363896។

[2589] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/30 EN 01049155 KH 01363905។

[2590] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/30 EN 01049155 KH 01363905។

[2591] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/46 EN 01065172, 01065180 KH 01307862-01307863, 01307874-01307875។

សង្ស័យ ចំពោះភាពជឿជាក់បាននៃការរៀបរាប់របស់ ន្ឋន ឃីម ឱន ជុន និង ប៉ាក សុខ[2592]។ លោកបានកត់សម្គាល់ថា៖

> នៅមានបញ្ហាដែលមិនទាន់ដោះស្រាយមួយ នៅពេលធ្វើការប្រៀបធៀបចម្លើយរបស់សាក្សី ស៊ឹម នី ជាមួយនឹងចម្លើយរបស់សាក្សី ន្ឋន ឃីម អំពីវត្តមាន ពាងទឹក និង អាគារនានា។ សាក្សីទាំងពីរបានលើកឡើងពីតំបន់ដូចគ្នា ដែលស្ថិតនៅផ្នែកខាងលើនៃបរិវេណវត្ត ... ។ ខណៈពេលដែល ន្ឋន ឃីម បាននិយាយអំពីការឃើញសាកសពនៅលើដី និងសាកសពនៅក្នុងពាងទឹក និង ធុងទឹក នៅពាក់កណ្តាលឆ្នាំ ១៩៧៩ គាត់មិនបានលើកឡើងអំពីរោងឈើនោះឡើយ...។ សាក្សី ស៊ឹម នី ធ្លាប់បានឃើញរោងដាក់អ្នកទោស ប៉ុន្តែគាត់មិនបានឃើញពាងទឹកនោះឡើយ... ។ ភាពមិនស៊ីចង្វាក់គ្នាមួយទៀតអំពីវត្តមានអាគារនានា (សាលាឆាន់ និង ព្រះវិហារ)[2593]។

ខ. ទីកសាប

៦៧៩. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនបានគាំទ្រការអះអាងរបស់គាត់ដែលថា ចំនួនជនរងគ្រោះនៅទីសាប មានលើសពីចំនួនសាកសព ១000 នាក់ ដែលត្រូវបានគេរកឃើញនៅទីនោះបន្ទាប់ពីឆ្នាំ ១៩៧៩ ឡើយ[2594]។ ស.ព.អ. ដកស្រង់ជាចម្បងនូវការប៉ាន់ស្មានបំផ្លើសចំនួនអ្នកទោស និង ការសម្លាប់ ដោយសាក្សីដែលមិនអាចជឿជាក់បាន ដូចជា ជេត ប៊ុណ្ណា ប្រាក់ ប៊ុននីលិន សារិន ឯក នី និង ប៉ាក សុខ ជាដើម[2595]។ គាត់ដកស្រង់ការរៀបរាប់របស់សាក្សី ដែលបានឃើញឆ្អឹងសាកសពនៅសេសសល់នៅតំបន់ទីកសាបបន្ទាប់ពីឆ្នាំ ១៩៧៩ គឺជាទាយស្មាន មិនអាចជឿជាក់បាន ឬ មិនគាំទ្រការអះអាងរបស់គាត់[2596]។ ស.ព.អ. ក៏មិនអើពើផងដែរនឹងភ័ស្តុតាងបរិបទ ដែលបង្ហាញថា អ្នកដែលកប់នៅក្នុងរណ្តៅសាកសពអាចជាទាហាន លន់ នល់ ឬ ទាហាន

[2592] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/46 EN 01065179 KH 01307873-01307874។

[2593] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/46 EN 01065179 KH 01307873។

[2594] កថាខណ្ឌ ៥០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2595] ជើងទំព័រ ១៨៩៩, ១៩០២, ១៩០៤, ១៩៦៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2596] ជើងទំព័រ ១៨៩៩, ១៩០១,១៩៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

កម្ពុជាប្រជាធិបតេយ្យ ដែលបានស្លាប់នៅក្នុងការប៉ះទង្គិចគ្នា ក្នុងអំឡុងពេលនៃការកាន់កាប់ខេត្តកំពង់សោម ឬ អ្នកដែលស្លាប់ដោយជំងឺគ្រុនចាញ់ ឬ ជំងឺផ្សេងទៀត។

i. ការប៉ាន់ស្មានចំនួនជនរងគ្រោះនៅទឹកសាបដែល ស.ព.អ. ដកស្រង់ គឺជាការទាយស្មាន និង មិនអាចជឿជាក់បាន

៦៨០. **ជេត ប៊ុណ្ណា៖** ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[2597]។ គាត់បានប៉ាន់ស្មានថា ទឹកសាបគឺជាកន្លែងកាប់សម្លាប់មួយ ដោយសារតែគាត់អះអាងថា បានឃើញសាកសពអណ្តែតនៅតាមដងទន្លេសាបយូរៗម្តង[2598]។ តាមដែលមេធាវីការពារក្តីដឹងច្បាស់ គ្មានភ័ស្តុតាងផ្សេងទៀត ដែលស៊ីចង្វាក់នឹងរឿងរ៉ាវរបស់ ជេត ប៊ុណ្ណា ឡើយ។ ងួន ឡាយ បានហែលទឹកទន្លេនោះរៀងរាល់ថ្ងៃ ហើយមិនដែលឃើញសាកសពណាអណ្តែតទឹកនៅទីនោះទេ។ គាត់គ្រាន់តែបានឃើញមនុស្សជិះទូកលង់ទឹកដោយសាររលកវ៉ៃលិច[2599]។ ភ័ស្តុតាងរបស់ ជេត ប៊ុណ្ណា នៅទឹកសាប គឺជាពាក្យចចាមអារ៉ាម ដែលមិនមានអ្វីផ្ទៀងផ្ទាត់បាន។ គាត់បានឮពីទាហានម្នាក់នៅក្នុងអង្គភាពរបស់គាត់ថា អ្នកទោសចំនួន ១០០ នាក់ត្រូវបានឃុំខ្លួនជាមួយគាត់នៅទឹកសាប ហើយថា នៅសល់តែអ្នកទោសចំនួន ២០ នាក់ ប៉ុណ្ណោះ នៅពេលដែលកងទ័ពវៀតណាមបានមកដល់[2600]។

៦៨១. **ប្រាក់ ប៊ុននី៖** ប្រាក់ ប៊ុននី មិនអាចជឿជាក់បានឡើយ[2601]។ គាត់បានប៉ាន់ស្មានថា មានមនុស្សជាច្រើននាក់បានជាប់ឃុំនៅទឹកសាប ហើយប៉ាន់ប្រមាណថា ជារៀងរាល់ខែ មានមនុស្សប្រមាណ ១០ នាក់មកពីអង្គភាពរបស់គាត់ត្រូវបានគេនាំយកទៅទីនោះ[2602]។ គាត់មិនបានដឹងផ្តាល់អំពីទឹកសាបក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យឡើយ។ គាត់គ្រាន់តែធ្វើការនៅចម្ការដូង ហើយមិនដែលបានឃើញអ្នកទោសត្រូវបានដឹកជញ្ជូននៅទីនោះទេ[2603]។ គាត់មានអាយុ ១៥ ឬ ១៦ ឆ្នាំ នៅ

[2597] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2598] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ន.២៥។ ជើងទំព័រ ១៩០៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2599] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D114/139 ន.១៣២-១៣៥។

[2600] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១៥ ឯកសារ D114/66 ន.១៨។

[2601] *សូមមើល* កថាខណ្ឌ ៤២៥ *ខាងលើ* សម្រាប់ព័ត៌មានអំពីសាក្សីរូបនេះ។

[2602] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 ន.៩៩-១០០។ ជើងទំព័រ ១៩០២ នៃដីកាសន្និដ្ឋានស្តាពរ។

[2603] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 ន.១០៤។

ពេលគាត់បានឮជាលើកដំបូង អំពីទឹកសាប ពីសហសេវិករបស់គាត់ក្នុងឆ្នាំ ១៩៧៧[2604]។ ការប៉ាន់ស្មានរបស់គាត់អំពីចំនួនជនរងគ្រោះនៅទឹកសាប និង ការសន្មតថា វាជាមន្ទីរសន្តិសុខទំនងជាផ្អែកលើអ្វីដែលគាត់បានឃើញនៅទីនោះក្រោយខែមករា ឆ្នាំ ១៩៧៩[2605]។

៦៨២. **លិន សារិន៖** លិន សារិន មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មនុស្សដែលគាត់បានឃើញត្រូវបានដឹកទៅទឹកសាប ត្រូវបានសម្លាប់ចោល៖ "ខ្ញុំក៏បានឮពីប្រជាជនថា គេយកមនុស្សទៅសម្លាប់នៅទឹកសាប។ ដូច្នេះហើយបានជាខ្ញុំច្បាស់ថា មនុស្សត្រូវបានយកទៅសម្លាប់នៅទឹកសាប"[2606]។ លិន សារិន មានអាយុប្រហែលប្រាំបី ឬ ប្រាំបួនឆ្នាំ បន្ទាប់ពីការដួលរលំភ្នំពេញ និងមានការលំបាកក្នុងការនឹកឃើញឡើងវិញពីព្រឹត្តិការណ៍ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[2607]។ ការដឹងឮរបស់គាត់អំពីទឹកសាបមានកម្រិតត្រឹមអ្វីដែលគាត់ឮពីអ្នកដទៃ[2608]។

៦៨៣. **ឯក នី៖** ឯក នី មិនអាចជឿជាក់បានឡើយ[2609]។ គាត់បានប៉ាន់ស្មានថា គាត់បានឃើញអ្នកទោសចំនួនពី ២០ ទៅ ៣០ នាក់ ដឹកឈើនៅជុំវិញទឹកសាប[2610]។ គាត់មិនបានដឹងថាមានអ្នកទោសសរុបចំនួនប៉ុន្មាននាក់ត្រូវបានឃុំនៅទឹកសាបនោះទេ ព្រោះគាត់មិនត្រូវបានអនុញ្ញាតឱ្យទៅទីនោះ[2611]។ បើទោះបីជាការរៀបរាប់របស់គាត់អាចឱ្យជឿជាក់បានក៏ដោយ ក៏វានឹងមិនបន្ថែម ឬ ជាមូលដ្ឋាននៃការប៉ាន់ប្រមាណរបស់ ស.ព.អ. ដែលថា មានពេលមួយនោះ ជនជាប់ឃុំមានរហូតដល់ ១០០ នាក់ អាចត្រូវបានឃុំឃាំងនៅទឹកសាបនោះដែរ[2612]។

[2604] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 អ.៨៣-៨៦។

[2605] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/242 អ.៩៣-៩៤។

[2606] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/121 អ.៨, អ.២២។ ជើងទំព័រ ១៩៦៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2607] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/121 អ.២-៣, អ.៦។

[2608] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/121 អ.៦, អ.៨, អ.១០, អ.១២។

[2609] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 អ.២៦ (ការគូសបញ្ជាក់បន្ថែម)។ ជើងទំព័រ ១៨៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2610] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 អ.២៦។ ជើងទំព័រ ១៨៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2611] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/102 អ.២៦។

[2612] កថាខណ្ឌ ៥០៣ នៃដីកាសន្និដ្ឋានស្តាពរ។

៦៨៤. **ប៉ាក សុខ៖** ប៉ាក សុខ មិនអាចជឿជាក់បានឡើយ[2613]។ គាត់បានអះអាងថាបានឃើញមនុស្សជាប់ឃុំនៅទឹកសាបម្តងម្កាល ហើយបាននិយាយថា គាត់បានឃើញអ្នកទោសចំនួនពី ៥០ ទៅ ៦០ នាក់នៅទីនោះ[2614]។ ប៉ាក សុខ មិនដែលជាប់ឃុំឃាំងនៅទឹកសាប[2615] ហើយបានផ្តល់សក្ខីកម្មផ្ទុយគ្នាអំពីប្រភេទអ្នកទោសដែលចាប់ឃុំនៅទីនោះ[2616] ដែលបង្ហាញថា គាត់មិនបានដឹងអំពីអ្វីដែលបានកើតឡើងនៅទឹកសាបពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ បើទោះបីជាការរៀបរាប់របស់ ប៉ាក សុខ អាចឱ្យជឿជាក់បានក៏ដោយ ក៏ ស.ព.អ. និយាយបំផ្លើសភ័ស្តុតាងរបស់គាត់។

ii. ភ័ស្តុតាងរបស់សាក្សី ដែលបានរកឃើញឆ្ពឹងនៅសេសសល់ជិតទឹកសាបក្រោយឆ្នាំ ១៩៧៩ មិនគាំទ្រការអះអាងរបស់ ស.ព.អ.

៦៨៥. **ឡាក់ សាផាន៖** ឡាក់ សាផាន មិនអាចជឿជាក់បានឡើយ[2617]។ យោងតាម ឡាក់ សាផាន ទឹកសាបត្រូវបានប្រើជាបន្ទាយយោធារបស់ លន់ នល់។ គាត់បានឃើញកងទ័ព លន់ នល់ ដកថយពីទឹកសាប នៅពេលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានវាយប្រហារនៅក្នុងអំឡុងពេលកាន់កាប់កំពង់សោម[2618]។ គាត់មិនបានដឹងឮដោយផ្ទាល់អំពីអ្វីដែលបានកើតឡើងនៅទឹកសាបទេ បន្ទាប់ពីទីតាំងនេះត្រូវបានកាន់កាប់ដោយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យនោះ[2619]។ នៅខែឧសភា ឬខែមិថុនា ឆ្នាំ ១៩៧៩ គាត់បានដើរកាត់ចម្ការធូរេននៅជិតទឹកសាប ហើយបានអះអាងថា បាន

[2613] *សូមមើល* កថាខណ្ឌ ២៣៣-៣៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2614] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 13.58.05-14.07.12, 14.11.54-14.14.44។ ជើងចំពីរ ១៨៩៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2615] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ឯកសារ D114/297.1.20 នៅម៉ោង 13.58.05-14.07.12។

[2616] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/27 អ.៨-៩ ។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 14.07.12-14.11.54។ *សូមមើលផងដែរ* កថាខណ្ឌ ៤២២ *ខាងលើ*។

[2617] *សូមមើល* កថាខណ្ឌ ៦២៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2618] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/3 អ.២-៣។

[2619] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ឯកសារ D114/3 អ.៤។

ឃើញផ្នូររួមនៅក្រោមដើមធូរេន[2620]។ គាត់បានប៉ាន់ស្មានថា គាត់បានឃើញផ្នូររាប់រយនៅទីនោះ[2621]។ គាត់បានប្រាប់ ក.ស.ច.ស. ថា គាត់មិនអាចពិពណ៌នាអំពីសំលៀកបំពាក់ ដែលគាត់បានឃើញនៅក្នុងផ្នូររួមនៅទឹកសាបនោះទេ[2622] ដែលវាផ្ទុយនឹងការស្តាប់ចម្លើយរបស់គាត់កាលពីថ្ងៃមុន ដែលគាត់បានអះអាងថា គាត់អាចបែងចែកឆ្អឹងជនជាតិថៃ វៀតណាម និង ខ្មែរ នៅទឹកសាប ដោយផ្អែកលើសម្លៀកបំពាក់របស់ពួកគេ[2623]។ ការអះអាងរបស់គាត់ដែលថា មនុស្សត្រូវបានសម្លាប់នៅទឹកសាប គឺផ្អែកលើពាក្យចចាមអារ៉ាម[2624]។

៦៨៦. **កុយ ណែន**៖ កុយ ណែន មិនអាចជឿជាក់បានឡើយ[2625]។ គាត់បានប៉ាន់ស្មានថា ជនស៊ីវិលត្រូវបានគេយកចេញពីសហករណ៍របស់គាត់ ទៅសម្លាប់ចោលនៅទឹកសាបនៅដើមឆ្នាំ ១៩៧៦[2626]។ ការដឹងឮរបស់គាត់អំពីទឹកសាបពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៧៩ មានកម្រិតនៅត្រឹមអ្វីដែលគាត់បានឮពីអ្នកដទៃ[2627]។ គាត់មិនបានឃើញអ្នកទោសនៅទឹកសាបពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ ពីព្រោះគាត់ជាអ្នកនេសាទ ហើយមិនត្រូវបានអនុញ្ញាតឱ្យឡើងឆ្នេរក្បែរវានោះទេ[2628]។ នៅក្នុងឆ្នាំ១៩៨០ គាត់ត្រូវបានតែងតាំងជាមេភូមិដោយសារអាជ្ញាធរវៀតណាម ហើយទទួលការងារបោសសម្អាតតំបន់នេះ និង បានឃើញឆ្អឹងមនុស្ស និង ឯកសណ្ឋានយោធា លន់ នល់[2629]។ គាត់បានឮថា នៅក្នុងអំឡុងពេលនៃការកាន់កាប់ខេត្តកំពង់សោម កងទ័ពរាប់ពាន់នាក់របស់ លន់ នល់

[2620] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/3 អ.៩-១០។ ជើងទំព័រ ១៩៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2621] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/3 អ.១០។

[2622] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/3 អ.១៤។

[2623] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/2 អ.៧។

[2624] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/3 អ.៤។ ជើងទំព័រ ១៩៥៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2625] *សូមមើល* កថាខណ្ឌ ៤២៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2626] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 អ.៥។ ជើងទំព័រ ១៩០១ នៃដីកាសន្និដ្ឋានស្តាពរ។

[2627] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 អ.១៣-១៤, អ.១៩។

[2628] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 អ.១២, អ.២០, អ.២២។

[2629] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 អ.៥, អ.៣០។

ត្រូវបានសម្លាប់នៅទឹកសាប[2630]។ តម្លៃជាភ័ស្តុតាងរបស់ កុយ ណែន មានកម្រិតនៅត្រឹមអ្វីដែលគាត់ឃើញក្រោយឆ្នាំ ១៩៧៩។ ភ័ស្តុតាងរបស់គាត់គាំទ្រការសន្និដ្ឋានដែលថា ផ្នូររួមដែលបានរកឃើញនៅតំបន់ទឹកសាប អាចជាឆ្អឹងទាហាន លន់ នល់ ដែលបានស្លាប់នៅក្នុងការប៉ះទង្គិចគ្នាជាមួយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអំឡុងពេលកាន់កាប់កំពង់សោម[2631]។

៦៨៧. **ម៉ែង សឹក៖** ម៉ែង សឹក មិនអាចជឿជាក់បានឡើយ។ គាត់បានអះអាងថាបានឃើញឆ្អឹង និងខោអាវនៅក្នុងតំបន់ទឹកសាប ប៉ុន្តែមិនអាចចាំថានៅឆ្នាំណានោះទេ[2632]។ ការអះអាងរបស់គាត់ដែលថាអ្នកនេសាទថៃត្រូវបានសម្លាប់នៅទឹកសាបគឺជាពាក្យចចាមអារ៉ាមមិនអាចផ្ទៀងផ្ទាត់បាន។ គាត់មិនដែលបានឃើញការសម្លាប់នៅទឹកសាបទេ ហើយបានឮរឿងនេះពី "ប្រភពគ្មានអត្តសញ្ញាណ"[2633]។ ការអះអាងរបស់គាត់ក៏ផ្ទុយផងដែរ នឹងការពិពណ៌នារបស់គាត់អំពីសម្លៀកបំពាក់ដែលគាត់បានប្រាប់ ក.ស.ច.ស. ថាគាត់បានឃើញនៅទឹកសាប ជាសម្លៀកបំពាក់ទាហាន[2634]។ ម៉ែង សឹក ក៏បានប៉ាន់ស្មានផងដែរថា សាកសពត្រូវបានកប់នៅក្នុងរណ្តៅនៅក្រោមដើមធូរេននៅជិតទឹកសាប ព្រោះដើមធូរេនដែលគាត់បានឃើញងាប់អស់ហើយ[2635]។ គាត់មិនបានឃើញសាកសពជាក់ស្តែងកប់នៅក្នុងរណ្តៅទាំងនោះទេ[2636]។

៦៨៨. **សឹង ណុច៖** សឹង ណុច មិនគាំទ្រការអះអាងរបស់ ស.ព.អ. ទេ។ គាត់ធ្លាប់រស់នៅក្នុងចម្ការដូងចេងហោង ហើយកងរបស់គាត់ត្រូវបានគេចាត់ឱ្យទៅថែទាំចម្ការធូរេននៅក្នុងឆ្នាំ ១៩៧៦[2637]។ គាត់បានប្រាប់ ក.ស.ច.ស. ថា គាត់គ្រាន់តែបានឃើញទាហានប្រដាប់អាវុធនៅឯកន្លែងចម្ការ

[2630] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 ឯ.៥។

[2631] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/104 ឯ.៣៤៖ "ពេលគេវាយភ្នំពេញ កម្លាំងរបស់ខ្ញុំបានវាយនៅទឹកសាបកំពង់សោម រឿមជាមួយកងពលលេខ ១"។

[2632] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែង សឹក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/177 ឯ.១១។ ជើងទំព័រ ១៩០៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2633] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែង សឹក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/177 ឯ.១៥-១៦, ឯ.៤០។

[2634] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែង សឹក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/177 ឯ.២៥។

[2635] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែង សឹក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/177 ឯ.៤៩។

[2636] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែង សឹក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/177 ឯ.៤៨។

[2637] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឯ.២៦២-៧៣, ឯ.២៨១។

ធ្លុះធ្លុងម្តង ហើយមិនដឹងថាមានការសម្លាប់ណាមួយកើតឡើងនៅទីនោះទេ[2638]។ ចម្លើយរបស់គាត់ដែលថា ប្រជាជនត្រូវបានសម្លាប់នៅទីនោះ ហាក់បីដូចជាផ្អែកទៅលើអ្វីដែលគាត់បានឃើញនៅក្រោយឆ្នាំ ១៩៧៩[2639]។ នៅឆ្នាំ ១៩៨០ គាត់បានទទួលបញ្ជាពីផ្នែកឃោសនាការ ឱ្យគាស់ផ្នូរនៅទីកសាប និង ប្រមូលឆ្អឹង "ដើម្បីរក្សាទុកជាភស្តុតាងសម្រាប់តុលាការសព្វថ្ងៃ"[2640]។ គាត់បានគាស់ឆ្អឹងលលាដ៏ក្បាលតែចំនួនពីបួនទៅដប់ប៊ុណ្ណោះ រួមទាំងឆ្អឹងផ្សេងទៀត[2641]។ គាត់មិនបានរាប់ថាតើមានរណ្តៅផ្នូរចំនួនប៉ុន្មាននៅទីនោះ ហើយបានចំណាយពេលមួយព្រឹកគាស់រណ្តៅផ្នូរទាំងនោះ[2642]។

៦៨៩. **ចេង ឡុង៖** ចេង ឡុង មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់ គឺផ្អែកលើពាក្យចចាមអារ៉ាម ដែលមិនអាចផ្ទៀងផ្ទាត់បាន។ គាត់មិនបានឃើញមនុស្សត្រូវគេនាំយកទៅទីកសាបនោះទេ[2643]។ ចេង ឡុង បានឮពីអ្នកដទៃថា មនុស្សត្រូវបានគេយកទៅសម្លាប់នៅទីនោះ[2644]។ អ្នកដែលប្រាប់គាត់អំពីព័ត៌មាននេះបានស្លាប់អស់ហើយ[2645]។ ក្រោយឆ្នាំ ១៩៧៩ ចេង ឡុង បានទៅទីកសាបដាំដុះបន្លែ និង បានអះអាងថាបានឃើញឆ្អឹងនៅទីនោះ[2646]។ គាត់បានប្រាប់ ក.ស.ច.ស. ថា គាត់បានឃើញផ្នូរជាច្រើន ប៉ុន្តែមានតែឆ្អឹងមួយចំនួនតូចប៉ុណ្ណោះ[2647]។ ទោះបីជារកឃើញគ្រាប់រំសេវ នៅទីកសាបក៏ដោយ ក៏គាត់បានប៉ាន់ស្មានថា ទាហានមិនត្រូវបានសម្លាប់នៅទីនោះដែរ

2638 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឧ.២៧៩-៨០។

2639 *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឧ.១៤១។

2640 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឧ.១៤១-៤២។

2641 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឧ.១៤៣។

2642 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឧ.១៥៩, ឧ.១៦៥។

2643 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ឧ.៣១។

2644 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ឧ.២៨-២៩, ឧ.៤៣។

2645 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ឧ.៣២។

2646 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ឧ.៣៣, ឧ.៤១។ ជើងទំព័រ ១៩៦៩ នៃដីកាសន្និដ្ឋានស្តាពរ។

2647 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ឧ.៣៧-៣៨, ឧ.៤១។

ប៉ុន្តែអ្នកដែលលួចអាហារត្រូវបានសម្លាប់នៅទីនោះ[2648]។ នេះជាការជឿជាក់របស់គាត់ ពីព្រោះមនុស្សដែលមិនស្គាល់ឈ្មោះផ្សេងទៀតបានប្រាប់គាត់ដូច្នោះ[2649]។ ទីតាំងផ្ទះរួម ដែល ចេង ឡុង បានឃើញ ក៏ត្រូវបានឈូសឆាយ និង ជីកកាយ ដើម្បីសាងសង់ផ្លូវ[2650]។

៦៩០. **ឆេង ជាង៖** ឆេង ជាង មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់គឺមានមូលដ្ឋានលើពាក្យចចាមអារ៉ាម ដែលមិនអាចផ្ទៀងផ្ទាត់បាន។ គាត់ជាអ្នកបច្ចេកទេសនេសាទនៅក្នុងអង្គភាពនេសាទ[2651]។ គាត់មិនបានដឹងថាមានអ្វីកើតឡើងនៅទីកសាបទេពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ[2652]។ មានពាក្យចចាមអារ៉ាមនៅភូមិរបស់គាត់ថា សាកសពត្រូវបានកប់នៅជិតទីកសាប ហើយប្រជាជនបានទៅស្វែងរកមាសនៅទីនោះ[2653]។

iii. ស.ព.អ. មិនអើពើនឹងភស្តុតាងដែលថា អ្នកដែលកប់នៅក្នុងផ្ទះរួមអាចជាទាហានកម្ពុជាប្រជាធិបតេយ្យ ឬ ជាទាហាន លន់ នល់ ឬ អ្នកដែលស្លាប់ដោយសារជំងឺគ្រុនចាញ់ ឬ ជំងឺផ្សេងទៀត

៦៩១. ស.ព.អ. មិនអើពើនឹងភស្តុតាងដែលបង្ហាញថា រណ្តៅសាកសព និង ឆ្អឹងសាកសពដែលត្រូវបានគេរកឃើញនៅតំបន់ទីកសាបក្រោយឆ្នាំ ១៩៧៩ អាចជាឆ្អឹងរបស់ទាហាន លន់ នល់ ឬ ទាហានកម្ពុជាប្រជាធិបតេយ្យ ដែលបានស្លាប់នៅក្នុងការប៉ះទង្គិចគ្នា ក្នុងអំឡុងពេលនៃការកាន់កាប់ខេត្តកំពង់សាម ឬ អ្នកដែលស្លាប់ដោយសារជំងឺគ្រុនចាញ់ ឬ ជំងឺផ្សេងទៀត។ ទីកសាប គឺជាអតីតមូលដ្ឋានយោធា លន់ នល់ នៅមុនការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ[2654]។ មុនពេលកងពល

[2648] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ន.៤២-៤៣។

[2649] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ន.៤៣។

[2650] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/96 ន.៣០។

[2651] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ន.២១-២២, ន.១២១។

[2652] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ន.១១៧។

[2653] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/241 ន.១១៨, ន.១២០។

[2654] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ D114/99 EN 01125388 KH 01519475-01519476។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/227 EN 01301664 KH 01397151។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/3 ន.២-៣។

ធំលេខ ៣ ឈរជើងនៅកំពង់សោម មានការប៉ះទង្គិចគ្នារវាងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និង ទាហាន លន់ នល់ នៅទីកសាប[2655]។ សាក្សីដែលបានទៅមើលទីកសាបនៅក្រោយឆ្នាំ ១៩៧៩ បានមើលឃើញឯកសណ្ឋានទាហាន លន់ នល់ ក្នុងចំណោមគ្រោងឆ្អឹង[2656]។

៦៩២. សាក្សីជាច្រើនបានថ្លែងផងដែរថា មនុស្សជាច្រើននៅក្នុងតំបន់កំពង់សោម បានធ្លាក់ខ្លួនឈឺ និង បានស្លាប់ដោយសារជំងឺគ្រុនចាញ់[2657]។ អ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរពេទ្យកំពង់សោម[2658]។ មាស សារ៉ាន ជាគ្រូពេទ្យនៅមន្ទីរពេទ្យចម្ការចេកក្នុងខេត្តកំពង់សោម បានថ្លែងថា នៅក្នុង ឆ្នាំ ១៩៧៥ មានករណីជំងឺគ្រុនចាញ់ច្រើនណាស់ ដែលត្រូវបញ្ជូនគ្រូពេទ្យទាំងអស់ត្រូវបានដាក់ បញ្ជូនទៅអូរឈើទាល[2659]។ សឹង ណុច ដែលធ្វើការនៅក្នុងកងកុមារនៅចម្ការធ្លុងចេងហោង និង ចម្ការរមួង បានប្រាប់ ក.ស.ច.ស.-ថា កុមារស្ទើរតែទាំងអស់នៅក្នុងតំបន់របស់គាត់បានកើតជំងឺគ្រុន ចាញ់៖ “អ្នកខ្លះស្លាប់ដោយគ្មានម្ដាយដឹង។ អ្នកខ្លះដែលម្ដាយដឹង ក៏គេមិនឱ្យយកទៅបញ្ចុះឯណា ដែរ។ គេឱ្យកប់នៅចម្ការរមួងហ្នឹង កន្លែងគេនៅហ្នឹង”[2660]។

[2655] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម កង់ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/104 ឆ.៣៤។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 ស-ឆ.២១៖ “ស៖ តើលោកនៅឯណានៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥? ឆ.២១៖ ខ្ញុំនៅសមរភូមិទីកសាប”។

[2656] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 ឆ.២៨-៣២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/3 ឆ.២-៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង សឹក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/177 ឆ.២៥។

[2657] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.៣៨-៣៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន់ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D114/202 ឆ.៣៣។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.១២៩, ឆ.១៣៦-៣៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សារ៉ាន ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/117 ឆ.៤-៥, ឆ.២៤។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/99 ឆ.៣១។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 ឆ.៧៣។

[2658] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ចក់ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D114/186 ឆ.៣៨-៣៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.១២៩, ឆ.១៣៦-១៣៩។

[2659] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សារ៉ាន ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/117 ឆ.១, ឆ.៤។

[2660] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ឯកសារ D114/156 ឆ.១៧, ឆ.៧៣។

គ. ការដ្ឋានស្ទឹងហាវ

៦៩៣. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា កម្លាភិបាលកងពលធំលេខ ១៦៥ ដែលបានរំសាយ បានធ្វើការនៅស្ទឹងហាវ ក្នុងលក្ខខណ្ឌដែលចាត់ទុកជាឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ[2661]។ ស.ព.អ. ដកស្រង់ជាចម្បងនូវការប៉ាន់ស្មានបំផ្លើសចំនួនកម្មករនៅស្ទឹងហាវ ពី មាស អ៊ឹម ជេត ប៊ុណ្ណា អែម សុន ប៉ែន សារិន "សៀង" ព្រុំ សម្បត្តិ អ៊ុយ ញ៉ឹក សុខ នាង ប្រាក់ សុខា ប្រេស មាន និង អ៊ឹម សុខន[2662]។ គាត់ក៏ដកស្រង់ផងដែរចម្លើយពី ឡុង ផាន់ស៊ី នង នេត និង សន ជួន ដែលមិនមានមូលដ្ឋានគាំទ្រ[2663]។

i. ការប៉ាន់ស្មានចំនួនកម្មករនៅស្ទឹងហាវដែល ស.ព.អ. ដកស្រង់ គឺជាការទាយស្មាន និង មិនអាចជឿជាក់បាន

៦៩៤. **មាស អ៊ឹម៖** មាស អ៊ឹម មិនអាចជឿជាក់បានឡើយ[2664]។ គាត់បានប៉ាន់ស្មានថា មានកម្មករចំនួន ៨០០ នាក់នៅស្ទឹងហាវ[2665]។ ក្នុងនាមជាបងប្រុស មាស មុត គាត់មិនបានស្បថថានឹងប្រាប់ការពិតនោះទេ[2666]។ គាត់បានបង្ហាញឱ្យឃើញលក្ខណៈមិនស្មោះត្រង់ នៅពេលដែលគាត់បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា "ដូច្នេះ ខ្ញុំប្រាប់គាត់ខ្លះពិត ខ្លះមិនពិត" ពីព្រោះគាត់គ្រាន់តែ "សំណេះសំណាលលេង" ជាមួយអ្នកសម្ភាសន៍ប៉ុណ្ណោះ[2667]។

៦៩៥. **ជេត ប៊ុណ្ណា៖** ជេត ប៊ុណ្ណា មិនអាចជឿជាក់បានឡើយ[2668]។ គាត់បានប៉ាន់ស្មានថា កម្លាំងដែលត្រូវបានរំសាយត្រូវបានបញ្ជូនទៅស្ទឹងហាវពីឆ្នាំ ១៩៧៧ តទៅ[2669]។ គាត់ត្រូវបានបញ្ជូនទៅស្ទឹងហាវ

[2661] កថាខណ្ឌ ៦១៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2662] ជើងចំពីរ ២៤១២, ២៤១៤, ២៤១៦, ២៤៨២ នៃដីកាសន្និដ្ឋានស្តាពរ។

[2663] ជើងចំពីរ ២៤១៦, ២៥៨០-៨១ នៃដីកាសន្និដ្ឋានស្តាពរ។

[2664] *សូមមើល* កថាខណ្ឌ ២៥៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2665] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/214 អ.២៨-២៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 អ.៥៤។ ជើងចំពីរ ២៤១២ នៃដីកាសន្និដ្ឋានស្តាពរ។

[2666] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/215 EN 01333468 KH 01301430។ វិធាន ២៥(២) នៃវិធានផ្ទៃក្នុង។

[2667] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/214 អ.៦។

[2668] *សូមមើល* កថាខណ្ឌ ១៨៦-៨៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៧៨ មិនយូរប៉ុន្មានមុនពេលវៀតណាមមកដល់[2670]។ ការដឹងឮរបស់គាត់ពីស្នឹងហាវមានកម្រិតត្រឹមរយៈពេលខ្លីដែលគាត់បាននៅទីនោះ។ គាត់មិនដឹងថានៅពេលណា និង ទាហានកងពលធំលេខ ១៦៥ ចំនួនប៉ុន្មាននាក់ ត្រូវបានបញ្ជូនទៅស្នឹងហាវពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ។

៦៩៦. **អែម សុន៖** អែម សុន មិនអាចជឿជាក់បានឡើយ[2671]។ គាត់បានប៉ាន់ស្មានថា គាត់បានឃើញកម្មករចំនួនប្រមាណ ១០០ នាក់ រួមទាំងកម្មករចិនផងដែរ នៅទីតាំងកំពង់ផែស្នឹងហាវ[2672]។ ការដឹងឮរបស់គាត់ពីស្នឹងហាវមានកម្រិត៖ គាត់បានបើកឡានកម្មករចិននៅទីនោះ ហើយបានទៅដឹកពួកគេនៅពេលល្ងាច ដើម្បីយកទៅផែកំពង់សោម[2673]។ អែម សុន មិនដឹងថាមានការដ្ឋានចំនួនប៉ុន្មាននៅស្នឹងហាវនោះទេ ហើយមិនអាចពិពណ៌នាអំពីស្ថានភាពរស់នៅរបស់កម្មករឡើយ[2674]។

៦៩៧. **ប៉ែន សារិន៖** ប៉ែន សារិន មិនអាចជឿជាក់បានឡើយ[2675]។ គាត់បានប៉ាន់ស្មានថា មានកម្មករគ្មានជំនាញចំនួនប្រមាណ ៣០ នាក់ បានធ្វើការក្នុងគម្រោងផ្លូវមួយនៅស្នឹងហាវ[2676]។ បើទោះបីជាការប៉ាន់ស្មានរបស់ ប៉ែន សារិន មានភាពត្រឹមត្រូវក៏ដោយ ក៏ ស.ព.អ. និយាយបំផ្លើសភ័ស្តុតាងនេះដែរ។ ប៉ែន សារិន បានប្រាប់ ក.ស.ច.ស. ថា កម្លាំងស្ត្រីមិនបានធ្វើការនៅក្នុងគម្រោងផ្លូវជាទៀង

[2669] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/86 ឆ.១៩។ ជើងទំព័រ ២៤១០ នៃដីកាសន្និដ្ឋានស្តាពរ។

[2670] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/86 ឆ.១៦។

[2671] *សូមមើល* កថាខណ្ឌ ២៣៦, ២៤៤, ៣៤៩, ៤១៦ និង ៥១៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2672] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/49 ឆ.៤១។ ជើងទំព័រ ២៤១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2673] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/49 ឆ.៣២, ឆ.៣៦។

[2674] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/49 ឆ.៣៤, ឆ.៤០។

[2675] *សូមមើល* កថាខណ្ឌ ៤១៣ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2676] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7 ឆ.១១។ ជើងទំព័រ ២៤១៨ នៃដីកាសន្និដ្ឋានស្តាពរ។

ទាត់នោះទេ៖ "គេមកជួយម្តងម្កាលប៉ុណ្ណោះ" [2677]។ ប៉ែន សារិន បានទទួលមរណភាពហើយ ដូច្នេះ មាស មុត មិនអាចមានឱកាសតទល់ជាមួយនឹងចម្លើយរបស់គាត់បានឡើយ[2678]។

៦៩៨. **"សៀង"៖** "សៀង" មិនអាចជឿជាក់បានឡើយ[2679]។ គាត់បានប៉ាន់ស្មានថាមានមនុស្សចំនួនប្រមាណ ១០០ នាក់ កំពុងធ្វើការនៅកន្លែងវាយយកថ្មនៅស្ទឹងហាវ[2680]។ ដោយសារគាត់បានបដិសេធមិនផ្តល់ចម្លើយឱ្យ ក.ស.ច.ស.[2681] ចម្លើយរបស់គាត់មិនបានត្រូវបានដេញដោលដោយភាគីដែលគ្មានប្រយោជន៍នៅក្នុងរឿងក្តីឡើយ។

៦៩៩. **ព្រំ សម្បត្តិ៖** ព្រំ សម្បត្តិ មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មានកម្មករចំនួន ១០០ នាក់ នៅស្ទឹងហាវ នៅពេលគាត់នៅទីនោះមួយរយៈពេលខ្លី មុនពេលកងទ័ពវៀតណាមមកដល់[2682]។ គាត់បានប្រាប់ ក.ស.ច.ស. ថា អង្គភាពទាំងមូលរបស់គាត់ត្រូវបានបញ្ជូនទៅទីនោះដែលមានគ្នាតែបីនាក់ប៉ុណ្ណោះ[2683]។ ព្រំ សម្បត្តិ មិនអាចចងចាំថា គាត់នៅក្នុងកងពលធំណាមួយ[2684] ឬ កងវរសេនាតូចណាមួយ[2685] ឬ នរណាជាអ្នកចាត់តាំងគាត់ឱ្យធ្វើការនៅស្ទឹងហាវឡើយ[2686]។

[2677] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន សារិន ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/7 អ.១២។

[2678] ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ ទី ២ និងទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៩ ខែមករា ឆ្នាំ ២០១៦ ឯកសារ D223 កថាខណ្ឌ ១០១។

[2679] *សូមមើល* កថាខណ្ឌ ២១៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2680] កិច្ចសម្ភាសន៍របស់ ក.ស.ព. ជាមួយ "សៀង" ឯកសារ D1.3.13.11 EN 00217566។ ជើងទំព័រ ២៤១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2681] ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរទី ១ ទី ២ និងទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៩ ខែមករា ឆ្នាំ ២០១៦ឯកសារ D223 កថាខណ្ឌ ៩៩-១០០។

[2682] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 អ.២១០, អ.២២៦-២៨។ ជើងទំព័រ ២៤១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2683] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 អ.២១៨, អ.២២៧។

[2684] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 អ.១៧។

[2685] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 អ.១៩។

[2686] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 អ.២៣៣។

៧០០. **អ៊ុយ ញ៊ឹក៖** អ៊ុយ ញ៊ឹក មិនអាចជឿជាក់បានឡើយ[2687]។ គាត់បានប៉ាន់ស្មានថា មានមនុស្សចំនួនប្រមាណ ១០០ នាក់ មកពីកងវរសេនាតូចលេខ ៣៨៦ បានធ្វើការនៅកំពង់ផែស្ទឹងហាវ[2688]។ ការខ្វះភាពជឿជាក់លើ អ៊ុយ ញ៊ឹក ទាក់ទងនឹងស្ទឹងហាវ ត្រូវបានបង្ហាញឱ្យឃើញ តាមរយៈភ័ស្តុតាងផ្ទុយគ្នារបស់គាត់អំពីការណ៍ដែលគាត់បានឃើញ មាស មុត នៅស្ទឹងហាវ[2689]។

៧០១. **សុខ នាង៖** សុខ នាង មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មានមនុស្សចំនួនប្រមាណជាង ២០០ នាក់ ធ្វើការនៅកំពង់ផែនេសាទ[2690]។ គាត់ជាពេទ្យធ្វើការនៅស្ទឹងហាវ ហើយបានទទួលស្គាល់ចំពោះមុខ ក.ស.ច.ស. ថា គាត់មិនអាចប៉ាន់ស្មានថាតើមានមនុស្សចំនួនប៉ុន្មាននាក់ធ្វើការនៅកំពង់ផែស្ទឹងហាវឡើយ[2691]។

៧០២. **ប្រាក់ សុខា៖** ប្រាក់ សុខា មិនអាចជឿជាក់បានឡើយ[2692]។ គាត់បានប៉ាន់ស្មានថា មានកងវរសេនាតូច ចំនួនពីពីរ ទៅ បី ធ្វើការនៅស្ទឹងហាវ ហើយថា មានប្រជាជន ១៧ មេសា ចំនួនពី ៣០ ទៅ ៤០ នាក់ នៅក្នុងកងចល័តរបស់គាត់[2693]។ គាត់បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់មិនបានចាំព្រឹត្តិការណ៍ទាំងនោះទេ[2694]។ ស.ព.អ. ផ្អែកជាចម្បងលើកិច្ចសម្ភាសន៍របស់ ប្រាក់ សុខា

[2687] *សូមមើល* កថាខណ្ឌ ២៥២ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2688] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៊ឹក ចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/77 ន.៤៤-៤៧។ ជើងទំព័រ ២៤១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2689] *សូមមើល* កថាខណ្ឌ ២៥២ *ខាងលើ*។

[2690] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ន.៤០។ ជើងទំព័រ ២៤១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2691] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/83 ន.៨, ន.៤០។

[2692] *សូមមើល* កថាខណ្ឌ ៤៣៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2693] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់ សុខា ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/35.1 EN 00971214 KH 00964254។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ D54/36 ន.១១។ ជើងទំព័រ ២៨៤២ នៃដីកាសន្និដ្ឋានស្តាពរ។

[2694] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D54/35.1 EN 00971214 KH 00964254៖ “មានច្រើន កាលហ្នឹងខ្ញុំភ្លេច”។

ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា[2695] ដែលមិនទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បាន និងភាពពាក់ព័ន្ធនោះឡើយ[2696]។

៧០៣. **ប្រេស មាន៖** ស.ព.អ. និយាយបំផ្លើសភ័ស្តុតាងរបស់ ប្រេស មាន។ ប្រេស មាន ត្រូវបានបញ្ជូនទៅស្ទឹងហាវនៅពាក់កណ្តាលឆ្នាំ ១៩៧៦ ហើយគាត់នៅទីនោះរហូតដល់ឆ្នាំ ១៩៧៩[2697]។ នៅពេលស្តាប់ចម្លើយជាលើកដំបូងជាមួយ ក.ស.ច.ស. គាត់បាននិយាយថា មាន "មនុស្សជាច្រើន" ធ្វើការជាមួយគាត់នៅតំបន់វាយថ្ម[2698]។ នៅក្នុងពេលស្តាប់ចម្លើយលើកទីពីររបស់គាត់ជាមួយ ក.ស.ច.ស. គាត់បានបញ្ជាក់ថា មានមនុស្សចំនួនប្រមាណ ២០ នាក់ធ្វើការជាមួយគាត់នៅតំបន់វាយថ្ម នៅពាក់កណ្តាលឆ្នាំ ១៩៧៦[2699]។

៧០៤. **អ៊ឹម សុខន៖** អ៊ឹម សុខន មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មានមនុស្សចំនួនប្រមាណ ១១០ នាក់ រួមទាំងកម្មករចិនផងដែរ ធ្វើការជាមួយគាត់នៅស្ទឹងហាវ ហើយថា ទាហានទាំងអស់មកពីតាមកោះគ្រប់កន្លែង បានឈរជើងនៅស្ទឹងហាវក្នុងឆ្នាំ ១៩៧៧[2700]។ ក្នុងនាមជាទាហានថ្នាក់ទាបក្នុងអង្គភាពថ្មើរជើង[2701] អ៊ឹម សុខន មិនអាចបានដឹងថាមានមនុស្សចំនួនប៉ុន្មាននាក់ធ្វើការនៅស្ទឹងហាវ ឬ ទាហានប៉ុន្មាននាក់មកពីតាមកោះ ត្រូវបានបញ្ជូនទៅធ្វើការនៅទីនោះឡើយ។

[2695] ជើងទំព័រ ២៤១៣, ២៣៩៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2696] *សូមមើល* កថាខណ្ឌ ១៤០ *ខាងលើ* ទាក់ទងនឹងការប្រើប្រាស់ប្រភេទនៃភស្តុតាងនេះ។

[2697] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/12 ឆ.១១-១២។

[2698] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ D54/12 ឆ.២០។ ជើងទំព័រ ២៤១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2699] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៣ឯកសារ D54/13 ឆ.២០។

[2700] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ឯកសារ D114/178 ឆ.៤១, ឆ.៦៧។ ជើងទំព័រ ២៤១៤, ២៤១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2701] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/112 ឆ.៤១។

ii. ភ័ស្តុតាងរបស់សាក្សីដែលជាប់ឃុំនៅស្ទឹងហាវ គឺមិនអាចជឿជាក់បាន និង មិនគាំទ្រការអះអាងរបស់ សហព្រះរាជអាជ្ញា

៧០៥. **ឡុង ផាន់ស៊ី៖** ឡុង ផាន់ស៊ី មិនអាចជឿជាក់បានឡើយ[2702]។ គាត់បានប៉ាន់ស្មានថា កងវរសេនាតូចរបស់គាត់មានសមាជិកយោធាចំនួន ១០០ ទៅ ២០០ នាក់ ហើយថា គាត់បានឃើញអ្នកទោសចំនួនពី ២០ ទៅ ៣០ នាក់នៅគុកស្ទឹងហាវ នៅពេលគាត់ត្រូវបានឃុំខ្លួននៅទីនោះ[2703]។ គាត់មិនអាចចាំបានច្បាស់ថាគេឃុំគាត់នៅស្ទឹងហាវ ឬ ទឹកសាប នៅពេលណាទេ ហើយគាត់មិនត្រូវបានអនុញ្ញាតឱ្យនិយាយជាមួយអ្នកទោសផ្សេងទៀតនៅគុកស្ទឹងហាវឡើយ[2704]។ ឡុង ផាន់ស៊ី ក៏បានប៉ាន់ស្មានផងដែរថា ទឹកសាប គឺស្ថិតនៅក្រោមឃុត្តាធិការរបស់កងពលលេខធំលេខ ១៦៥៖ "នេះគ្រាន់តែជាការសន្និដ្ឋានរបស់ខ្ញុំទេ"[2705]។

៧០៦. **សន ជួន៖** សន ជួន មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មានមនុស្សចំនួនរាប់រយនាក់ ធ្វើការនៅស្ទឹងហាវ ហើយថា មានអ្នកទោសចំនួនប្រមាណ ១០ នាក់ នៅក្នុងគុកស្ទឹងហាវនៅពេលគាត់ជាប់គុកនៅទីនោះ[2706]។ គាត់មិនអាចចាំបានទេថា គាត់ធ្វើការនៅស្ទឹងហាវនៅពេលណា[2707] គេចាប់គាត់ដាក់គុកនៅពេលណា[2708] ឬ ទីតាំងដែលគេចាប់គាត់នោះនៅទីណាឡើយ[2709]។ គាត់បានស្មានថា គាត់ត្រូវបានគេចាប់ខ្លួននៅឆ្នាំ ១៩៧៨ និង ជាប់គុកនៅស្ទឹងហាវ ប៉ុន្តែគាត់បានភ្ជាប់ចំនួនអ្នកទោសដែលត្រូវបានចាប់ខ្លួនជាមួយគាត់[2710]។ គាត់ក៏បាននិយាយផងដែរថា គាត់មិន

[2702] *សូមមើល* កថាខណ្ឌ ៤២៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2703] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 អ.១៨, អ.៣៥។ ជើងទំព័រ ២៤១៦, ២៥៨២ នៃដីកាសន្និដ្ឋានស្តាពរ។

[2704] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D114/208 អ.៤៩-៥០។

[2705] *សូមមើលផងដែរ ខ.ថ.* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១៦ D114/208 អ.៤១។

[2706] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/219 EN 01395464 KH 01301516-01301517 អ.៥៥។ ជើងទំព័រ ២៤១៦, ២៥៨១ នៃដីកាសន្និដ្ឋានស្តាពរ។

[2707] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/219 អ.២៤។

[2708] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/219 អ.៣៤។

[2709] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/219 អ.២៩។

[2710] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/219 អ.៣៥, អ.៥៥។

យល់ពីគោលបំណងរបស់ ក.ស.ច.ស. ក្នុងការប្រមូលទាំងភស្តុតាងដាក់បន្ទុក ទាំងភស្តុតាងដោះបន្ទុកនោះទេ[2711]។

៧០៧. **នង នេត៖** នង នេត មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មានកម្មករចំនួនប្រមាណ ១០០ នាក់នៅស្ទឹងហារ ហើយមានអ្នកទោសចំនួនប្រមាណ ៥០ នាក់ ផ្សេងទៀត ជាប់គុកជាមួយគាត់[2712]។ គាត់ត្រូវបានបញ្ជូនទៅស្ទឹងហារនៅចុងឆ្នាំ ១៩៧៨ គឺមួយខែមុនការមកដល់នៃកងទ័ពវៀតណាម[2713]។ គាត់ និង អ្នកផ្សេងទៀត បានចាប់ខ្លួន ហឿន ដែលជាអ្នកគ្រប់គ្រងការដ្ឋានសាងសង់ ហើយបានបញ្ជូនគាត់ទៅយោធា[2714]។ យោងទៅតាម នង នេត ហឿនត្រូវបានដោះលែង ហើយទាហានម្នាក់បានឃុំខ្លួនគាត់ និង មនុស្សចំនួន ៥០ នាក់ផ្សេងទៀត[2715]។ នង នេត មិនបាននិយាយថា ការឃុំឃាំងគាត់ធ្វើឡើងជាបណ្តោះអាសន្ន ឬ រៀបរាប់អំពីស្ថានភាពជាប់ក្នុងពន្ធនាគារនោះទេ[2716]។ បើទោះបីជាការរៀបរាប់របស់ នង នេត អាចឱ្យជឿជាក់បានក៏ដោយ ក៏ ស.ព.អ. និយាយបំផ្លើសភស្តុតាងរបស់គាត់។

ឃ. ការដ្ឋានការងារនៅតំបន់រាម

៧០៨. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ មិនគាំទ្រការអះអាងរបស់គាត់ដែលថា កម្មកររាប់ពាន់នាក់ បានធ្វើការនៅការដ្ឋានរាម ក្នុងលក្ខខណ្ឌដែលជាឧក្រិដ្ឋកម្មនៃការដាក់ឱ្យទៅជាទាសករឡើយ[2717]។ ស.ព.អ. ដកស្រង់ការប៉ាន់ស្មានបំផ្លើសមួយចំនួនពីសាក្សីមិនអាចឱ្យជឿជាក់បាន អំពីចំនួនកម្មករនៅការដ្ឋានតំបន់រាម។ គាត់ក៏បានសំអាងផងដែរ លើការរៀបរាប់នីមួយៗរបស់សាក្សីដែលបានធ្វើការនៅសហករណ៍តំបន់រាម ដែលមិនបានផ្តល់ហេតុផល ឬ បង្កើតបានជាចំនួនជនរងគ្រោះដែលគាត់អះអាងនោះទេ។ បើទោះបីជាមនុស្សចំនួនរាប់ពាន់នាក់បានរស់នៅ និង ធ្វើការនៅរាមក៏ដោយ ក៏ករណីនេះនឹងមិនដំឡើងឱ្យ មាស មុត ស្ថិតនៅក្នុងកម្រិតនៃ “មេដឹកនាំជាន់ខ្ពស់”

[2711] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ D114/219 ឧ.២។

[2712] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង នេត ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/68 ឧ.២៩, ឧ.៣១, ឧ.៣៤។ ជើងចំពីរ ២៤១៦, ២៥៨០ នៃដីកាសន្និដ្ឋានស្តាពរ។

[2713] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង នេត ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/68 ឧ.១៣។

[2714] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង នេត ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/68 ឧ.២៩, ឧ.៣៤។

[2715] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង នេត ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/68 ឧ.៣៤។

[2716] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង នេត ចុះថ្ងៃទី ៥ ខែមីនា ឆ្នាំ ២០១៤ ឯកសារ D54/68 ឧ.៣៤។

[2717] កថាខណ្ឌ ៦៧៤ នៃដីកាសន្និដ្ឋានស្តាពរ។

ឬ បុគ្គលម្នាក់ "ដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។ សហការណ៍ និង ការដ្ឋានការងារស្រដៀងគ្នា មានវត្តមាននៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ[2718]។

៧០៩. **កង សុំ៖** កង សុំ មិនអាចជឿជាក់បានឡើយ[2719]។ គាត់បានប៉ាន់ស្មានថា មនុស្សចំនួន ៣០០០ នាក់ធ្វើការនៅវាលស្រែក្បែរព្រលានយន្តហោះកងកេង[2720]។ កង សុំ បានស្រវឹងនៅពេលគាត់ត្រូវបានសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមានការលំបាកក្នុងការរំលឹកព្រឹត្តិការណ៍នៅពេលគាត់ត្រូវបានស្តាប់ចម្លើយដោយ ក.ស.ច.ស.[2721]។ សូម្បីតែបន្ទាប់ពីអ្នកស៊ើបអង្កេត ក.ស.ច.ស. សង្កត់ឱ្យ កង សុំ ផ្តល់ចម្លើយឱ្យដូចនឹងចម្លើយរបស់គាត់ផ្តល់មជ្ឈមណ្ឌលឯកសារកម្ពុជា[2722] ក៏គាត់មិនអាចប្រាប់ពីកាលវេលាច្បាស់លាស់អំពីទីកន្លែងគាត់រស់នៅពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ[2723]។

៧១០. **កុយ ណែន៖** កុយ ណែន មិនអាចជឿជាក់បានឡើយ[2724]។ គាត់បានប៉ាន់ប្រមាណថា មនុស្សរាប់ពាន់នាក់ បានរស់នៅក្នុងសហការណ៍ ហើយថា មនុស្សចំនួនពី ៨០០ ទៅ ១០០០ នាក់ បានធ្វើការ

[2718] *សូមមើល* កថាខណ្ឌ ៥៤៦ *ខាងលើ* និង កថាខណ្ឌ ៧២៩ *ខាងក្រោម* ។

[2719] *សូមមើល* កថាខណ្ឌ ២២៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2720] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.១៦៨, ឆ.២៧៨។ ជើងទំព័រ ២៧២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2721] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ឆ.៩៩។

[2722] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ស-ឆ.៣, ស-ឆ.៩៩, ស-ឆ.១០១, ស-ឆ.១០៦៖ "ស៖ បើសិនជាខ្ញុំសួរលោកថ្ងៃនេះ ដូចសំណួរដែលខាងមជ្ឈមណ្ឌលឯកសារកម្ពុជាសួរលោក តើលោកឆ្លើយប្រាប់ខ្ញុំដូចដែល លោកឆ្លើយប្រាប់ខាងមជ្ឈមណ្ឌលឯកសារកម្ពុជាឬទេ? ឆ.៣៖ បាទ។ ... ស៖ អ្វីដែលលោកប្រាប់ខ្ញុំនៅពេលនេះ មិនឆ្ងុះបញ្ចាំងពីអ្វីដែលលោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីខែមីនា ឆ្នាំ ២០១៥ ឡើយ ។ ខ្ញុំមានបញ្ហានៅក្នុងការយល់ថា ហេតុអ្វីបានជាការចងចាំរបស់លោកកាលពីបីខែមុនច្បាស់ជាងអ្វីដែលលោកឆ្លើយនៅពេលនេះ? ឆ.៩៩៖ ពេលនោះខ្ញុំស្រវឹង។ ... ស៖ ខ្ញុំចង់បញ្ជាក់ម្តងទៀតជាមួយលោកថា បើសិនជាខ្ញុំសួរសំណួរដដែលដូចដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍លោកនោះ តើលោកនឹងឆ្លើយចម្លើយដែល ឬ ក៏ខុសពីមុន? ឆ.១០១៖ ខ្ញុំចងចាំមិនបាន។ ខ្ញុំឆ្លើយមិនបានដូចដដែលទេ។ ខ្ញុំចាំបានលុះណាតែខ្ញុំស្តាប់ខ្សែអាត់សំឡេងរបស់ខ្ញុំនៅពេលនោះ។ ... ស៖ ខ្ញុំចង់បញ្ជាក់លោកថា កាលដែលលោកឆ្លើយនេះគឺក្រោមពាក្យសម្បថ តែលោកឥឡូវនេះលោកដូចជាឆ្លើយក្នុងការបារម្ភ ។ ខ្ញុំសូមឱ្យលោកជួយសម្រួលក្នុងចម្លើយរបស់លោក។ ឆ.១០៦៖ ខ្ញុំឆ្លើយតែតាមការដែលខ្ញុំដឹង"។

[2723] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/79 ស-ឆ.២២៩។

[2724] *សូមមើល* កថាខណ្ឌ ៤២៤ និង ៦៨៦ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

នៅក្នុងគម្រោងទំនប់បិតត្រាំង[2725]។ កុយ ណែន បានឈរជើងនៅសហករណ៍បបុស ចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ពេលកងទ័ពវៀតណាមចូលមកដល់នៅឆ្នាំ ១៩៧៩[2726]។ ការដឹងឮ របស់គាត់អំពីអ្វីដែលបានកើតឡើងនៅក្នុងសហករណ៍ផ្សេងទៀត គឺជាពាក្យចចាមអារ៉ាម ដែល មិនអាចផ្ទៀងផ្ទាត់បាន។ គាត់បានឮពាក្យចចាមអារ៉ាមថា មនុស្សត្រូវបានសម្លាប់នៅចម្ការធូរេន ពីប្រពន្ធរបស់ទាហានដែលជាប្រធានសហករណ៍[2727]។ ការដឹងឮរបស់គាត់អំពីគម្រោងទំនប់បិត ត្រាំង គឺមានកម្រិត ពីព្រោះគាត់ធ្វើការនៅទីនោះត្រឹមតែក្នុងរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ[2728]។

៧១១. **មូល ឈិន៖ មូល ឈិន** មិនអាចជឿជាក់បានឡើយ[2729]។ គាត់បានប៉ាន់ស្មានថា កងទ័ពចំនួនរាប់ ពាន់នាក់ត្រូវបានរំសាយ ហើយត្រូវបានបញ្ជូនទៅកងផលិតផ្សេងៗគ្នា ហើយថា មានមនុស្សចំនួន ៣០០ នាក់ បានធ្វើការក្នុងគម្រោងទំនប់បិតត្រាំង[2730]។ មូល ឈិន គឺជាឃ្លួនជនធម្មតា ដែលបាន ប៉ាន់ស្មានថា មាស មុត បានចេញបញ្ជារំសាយជួរ ហើយចាត់តាំងកងទ័ពឱ្យទៅធ្វើការងារនៅក្នុង កងផលិតផ្សេងៗគ្នា។ ដោយសារគាត់មានទំនោរទៅរកការប៉ាន់ប្រមាណ និង សំអាងលើការដឹង ឮប្រយោល[2731] ការប៉ាន់ស្មានរបស់គាត់អំពីចំនួនកម្មករនៅគម្រោងទំនប់បិតត្រាំង គឺមិនអាចឱ្យជឿ

[2725] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/90 ឆ.២, ឆ.៤១។ ជើងទំព័រ ២៧២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2726] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/90 ឆ.២, ឆ.១២។

[2727] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/90 ស-ឆ.២, ឆ.៣, ឆ.៤៖ "តើប្រជាជនទាំងអស់គ្នាដឹងថា ខ្មែរក្រហមយកមនុស្សទៅសម្លាប់នៅកន្លែងហ្នឹង [ចម្ការធូរេន] តាមរបៀបណា? ឆ.២៖ ខ្ញុំដឹងថាខ្មែរក្រហមយកមនុស្សទៅសម្លាប់នៅទីនោះ តាមរយៈប្រពន្ធរបស់យោធាខ្មែរក្រហម។ អំឡុងពេលនោះ ប្រពន្ធរបស់ យោធាខ្មែរក្រហមគឺជាប្រធានសហករណ៍នៅតំបន់នេះ។ នៅកន្លែងនេះមានសហករណ៍បបុស និង សហករណ៍ពូធឿង ហើយ មនុស្សនៅក្នុងសហករណ៍ទាំងពីរនេះមានចំនួនរាប់ពាន់នាក់ រួមទាំងគ្រួសារយោធា យោធាផង។ ... ឆ.៣៖ ឧទាហរណ៍ ប្រធាន សហករណ៍ទាំងពីរនេះបានប្រាប់ប្រជាជនថា ២ ឬ ៣ គ្រួសារនេះត្រូវបានចាប់ខ្លួន គឺត្រូវបានយកទៅសម្លាប់នៅចម្ការធូរេន។ ... ឆ.៤៖ ពួកគេនិយាយរឿងទាំងនេះប្រាប់ទៅកាន់ប្រជាជន ដើម្បីបំភិតបំភ័យប្រជាជនកុំឱ្យធ្វើអីឱ្យមានកំហុស"។

[2728] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/90 ឆ.៤០។

[2729] *សូមមើល* កថាខណ្ឌ ៣៦១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2730] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឆ.៩២។ កំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៥ ឯកសារ D114/40 ឆ.២១។ ជើងទំព័រ ២៧២៤, ២៧៣១, ២៨០៣ នៃដីកាសន្និដ្ឋានស្តាពរ។

[2731] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D114/31 ឆ.១៩, ឆ.៩៣។

ជាក់បានឡើយ[2732]។ បើទោះបីជា ស.ច.ស. ផ្តល់តម្លៃដល់ភ័ស្តុតាងរបស់ មូល ឈិន ក៏ដោយ ក៏ការប៉ាន់ស្មានរបស់គាត់អំពីចំនួនកម្មករនៅគម្រោងទំនប់បិតត្រាំង គឺផ្ទុយពីការប៉ាន់ស្មានរបស់សាក្សីផ្សេងទៀតដែរ។

៧១២. **ព្រំ សម្បត្តិ៖** ព្រំ សម្បត្តិ មិនអាចជឿជាក់បានឡើយ[2733]។ គាត់បានប៉ាន់ស្មានថា មានកម្មករ "ជាច្រើននាក់" មកពីអង្គភាពរបស់គាត់ និង អង្គភាពផ្សេងទៀត នៅគម្រោងទំនប់បិតត្រាំង[2734]។ ព្រំ សម្បត្តិ មិនបានផ្តល់ចំនួន ឬ រង្វង់តួលេខឡើយ ហើយបានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. ថា គាត់មិនដឹងពីចំនួនកម្មកររនោះទេ[2735]។

៧១៣. **សៅ ម៉ែន៖** សៅ ម៉ែន មិនអាចជឿជាក់បានឡើយ។ ដំបូង គាត់បានប្រាប់ ក.ស.ច.ស. ថា មាន "មនុស្សរាប់រយនាក់" នៅក្នុងគម្រោងទំនប់បិតត្រាំង ពីព្រោះថា "យើងតម្រង់ជួរវែង ចាំយកបបរហូប" [2736]។ ក្រោយមក គាត់បានប្រាប់ ក.ស.ច.ស. ថា មានមនុស្សរាប់ពាន់នាក់នៅទីនោះ ពីព្រោះមានផ្ទះបាយពីរកន្លែងនៅទីនោះ ដែលមានកម្មកចំនួនយ៉ាងតិច ២០០ ទៅ ៣០០ នាក់ នៅផ្ទះបាយទាំងនោះ[2737]។ នៅពេលសួរម្តងទៀតឱ្យប៉ាន់ប្រមាណចំនួនកម្មករ នៅគម្រោងទំនប់បិតត្រាំង គាត់បាននិយាយថា មានកម្មកររាប់រយនាក់ ប៉ុន្តែ នាងមិនបានរាប់ចំនួនផ្ទះបាយនោះទេ[2738]។

៧១៤. **ធក សែន៖** ធក សែន មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មាន "កុមារប្រហែល ១៥០ នាក់" នៅក្នុងអង្គភាពរបស់គាត់ ដែលធ្វើការនៅចម្ការដូង ហើយថា មានមនុស្សចំនួនរាប់

[2732] *សូមមើល*កថាខណ្ឌ ៣៦១ និង ៦៤៩ *ខាងលើ* ដែលបរិយាយពីឧទាហរណ៍ដែល មូល ឈិន ចូលរួមក្នុងការនិយាយស្មានៗ។

[2733] *សូមមើល* កថាខណ្ឌ ៦៩៩ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2734] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 ឆ.១៩៤។ ជើងទំព័រ ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2735] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D114/109 ឆ.១៩៤។

[2736] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ម៉ែន ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/239 ឆ.១២។ ជើងទំព័រ ២៧២៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2737] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ម៉ែន ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/239 ស-ឆ.២៦-២៨៖ "ស៖ តាមលោកស្រីស្មាន តើគេយកមនុស្សពីការដ្ឋានបិតត្រាំងប្រហែលប៉ុន្មានដែរ? ឆ.២៦៖ ច្រើនណាស់ ផ្លាស់ក៏ផ្លាស់ បាត់ក៏បាត់។ មានមនុស្សរាប់ពាន់នាក់។ ចង្ក្រានបាយមួយៗមានមនុស្សពីរបីរយនាក់។ ស៖ តើលោកស្រីអាចនិយាយថា មួយពាន់ពីរនាក់ បីបួនពាន់ ឬ ក៏ប៉ុន្មានពាន់ដែរ? ឆ.២៧៖ ចង្ក្រានបាយមួយហ្នឹងមានពីរបីរយនាក់ហើយ ចុះប៉ុន្មានចង្ក្រានបាយ មានច្រើនចង្ក្រាន។ ស៖ តើមានចង្ក្រានប៉ុន្មានដែរនៅការដ្ឋានបិតត្រាំង? ឆ.២៨ ចង្ក្រានពីរ"។ ជើងទំព័រ ២៧២៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2738] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ម៉ែន ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/239 ឆ.៤៦។

រយនាក់ ធ្វើការនៅគម្រោងទំនប់បិតត្រាំង[2739]។ ធក សែន បានចាប់ផ្តើមផ្តល់ចម្លើយឱ្យ ក.ស.ច.ស. ដោយដំបូងសុំទោស ប្រសិនបើគាត់បាននិយាយអ្វីខុសថា៖ "កាលជំនាន់នោះ ខ្ញុំនៅក្មេងៗ... សភាពការណ៍នៅក្នុងប្រទេសហ្នឹង ខ្ញុំមិនបានដឹងដែរ"[2740]។ ក្រៅពីការបំផ្លើស ការប៉ាន់ស្មានរបស់គាត់អំពីចំនួនកុមារធ្វើការនៅចម្ការរួងនោះ គឺផ្ទុយពី ប្រាក់ ប៊ុននី ដែលបាននិយាយថា មានកុមារចំនួន ៥០ នាក់ នៅក្នុងអង្គភាពនីមួយៗ ដែលធ្វើការនៅចម្ការរួង[2741]។

៧១៥. **ងួន ឡាយ៖** ងួន ឡាយ មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា មានមនុស្សចំនួនរាប់រយ ឬ រាប់ពាន់នាក់ ធ្វើការក្នុងគម្រោងទំនប់បិតត្រាំង[2742]។ ងួន ឡាយ បានទៅទំនប់តែម្តងគត់ ដើម្បីដឹកសម្ភារ[2743]។

៧១៦. **ញូង ជ្រោង៖** ញូង ជ្រោង មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា កម្មករចំនួនពី ៥០០ ទៅ ៦០០ នាក់បានចូលរួមនៅក្នុងការសាងសង់ទំនប់[2744]។ គាត់មិនបានប្រាប់ឈ្មោះទំនប់ ដែលគាត់បានលើកឡើងប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស. មុនពេលផ្តល់ចម្លើយទេ[2745]។ គាត់មិនបានចូលរួមនៅក្នុងការសាងសង់ទំនប់ ហើយមិនបានបង្ហាញពីពេលវេលា និង ថាតើគាត់បានឃើញកម្មករចំនួនប៉ុន្មានដង នៅកន្លែងដែលគាត់បានលើកឡើងនោះទេ[2746]។

៧១៧. **ភិន វេញ៖** ភិន វេញ មិនអាចជឿជាក់បានឡើយ។ គាត់បានផ្តល់ចម្លើយដោយផ្អែកលើការទាយស្មាន និង បានផ្តល់ភ័ស្តុតាងផ្ទុយគ្នា។ ភិន វេញ បានប៉ាន់ស្មានថា មានមនុស្សជាច្រើនធ្វើការនៅគម្រោងទំនប់បិតត្រាំង ហើយថា មានកុមារចំនួន ២៥០ នាក់នៅក្នុងកងកុមារ ដែលធ្វើការនៅ

[2739] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធក សែន ចុះថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/243 ឧ.២៤, ឧ.៩៩។ ជើងទំព័រ ២៧២៤, ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2740] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធក សែន ចុះថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៦ឯកសារ D114/243 ឧ.៩។

[2741] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៦ឯកសារ D114/242 ឧ.៣១។

[2742] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D114/139 ឧ.១០៦។ ជើងទំព័រ ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2743] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ D114/139 ឧ.១០២-០៤។

[2744] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6 ឧ.២៦។ ជើងទំព័រ ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2745] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6 ឧ.២៤-២៦។

[2746] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១០ ឯកសារ D2/6 ឧ.២៨-២៩។

ទីនោះ[2747]។ ភិន វេញ មិនបានផ្តល់មូលដ្ឋានគាំទ្រការប៉ាន់ប្រមាណរបស់គាត់ទេ ហើយបានផ្តល់សក្ខីកម្មផ្ទុយគ្នា។ គាត់មានអាយុ ១៥ ឬ ១៦ ឆ្នាំ នៅពេលដែលគាត់ធ្វើការនៅគម្រោងទំនប់បិតត្រាំង ប៉ុន្តែបានប្រាប់ ក.ស.ច.ស. ថា ក្មេងអាយុច្រើនជាងគេនៅក្នុងកងកុមាររបស់គាត់មានអាយុ ១៤ ឆ្នាំ[2748]។

៧១៨. **សឹង ណុច**៖ សឹង ណុច មិនអាចជឿជាក់បានឡើយ[2749]។ គាត់បានធ្វើការនៅគម្រោងទំនប់បិតត្រាំង តែក្នុងពីរ ឬ បីថ្ងៃប៉ុណ្ណោះ[2750]។ ដំបូងគាត់បានប្រាប់ ក.ស.ច.ស. ថា គាត់មិនបានដឹងថាតើមានមនុស្សប៉ុន្មាននាក់ធ្វើការនៅគម្រោងទំនប់បិតត្រាំងនោះទេ[2751]។ បន្ទាប់ពីអ្នកស៊ើបអង្កេត ក.ស.ច.ស. សួរបញ្ជាក់ឱ្យផ្តល់ចំនួនប៉ាន់ប្រមាណ គាត់បានប៉ាន់ស្មានថា មានមនុស្សចំនួនប្រមាណជា ៤០០ ទៅ ៥០០ នាក់ ធ្វើការនៅទីនោះ[2752]។

៧១៩. **ស្ងួន ផ**៖ ស្ងួន ផ មិនអាចជឿជាក់បានឡើយ។ ចម្លើយរបស់គាត់គឺផ្អែកលើពាក្យចចាមអារ៉ាម និងការប៉ាន់ស្មាន។ ស្ងួន ផ បានប៉ាន់ស្មានថា ទាហានចំនួនពី ២០០ ទៅ ៣០០ នាក់មកពីកងគាត់ ត្រូវបានរំសាយ ហើយបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកងកេង[2753]។ គាត់បានប្រាប់ ក.ស.ច.ស. ថាគាត់មិនដឹងថាហេតុអ្វីបានជាអង្គភាពរបស់គាត់ត្រូវបានរំសាយនោះទេ ប៉ុន្តែ គាត់ “បានឮថាកម្មាភិបាលមកពីតំបន់ ៣៧ បានចូលដៃជាមួយខ្មាំង”[2754]។ គាត់បានទាយស្មានអំពីចំនួនទាហាន

[2747] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភិន វេញ ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/240 អ.១១, អ.១៥, អ.២៤, អ.២៧, អ.៤៦, អ.៤៧។ ជើងចំពរ ២៧២៤, ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2748] ភិន វេញ កើតនៅថ្ងៃទី ២២ ខែសីហា ឆ្នាំ ១៩៦០ និង ធ្វើការនៅចំនប់បិតត្រាំងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦។ *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភិន វេញ ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/240 EN 01479300 KH 01318507 អ.១៥, អ.២៥។

[2749] *សូមមើល* កថាខណ្ឌ ៤៤០ *ខាងលើ* សម្រាប់ពត៌មានបន្ថែមពីសាក្សីរូបនេះ។

[2750] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 អ.១៩៨។

[2751] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ D114/156 អ.១៨៩។

[2752] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ D114/156 អ.១៩១។ ជើងចំពរ ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2753] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្ងួន ផ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/121 អ.២០, អ.២២, អ.២៤។ ជើងចំពរ ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2754] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្ងួន ផ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/121 អ.២១។

មកពីកងរបស់គាត់ ដែលត្រូវបានបញ្ជូនទៅព្រលានយន្តហោះកែងកង ហើយមិនបាននិយាយថាតើមានមនុស្សចំនួនប៉ុន្មាននាក់ផ្សេងទៀតធ្វើការនៅក្នុងតំបន់នោះទេ[2755]។

៧២០. **ខឹម យ៉ាត៖** ខឹម យ៉ាត មិនអាចជឿជាក់បានឡើយ។ គាត់បានឆ្លើយដោយផ្អែកលើការប៉ាន់ស្មាន និងមានការចងចាំមិនល្អ។ លោកបានប៉ាន់ស្មានថា ទាហានចំនួនពី ២០០ ទៅ ៣០០ នាក់ បានទៅធ្វើការនៅព្រលានយន្តហោះកងកែង ហើយថា បុគ្គលិកយោធាផ្សេងទៀតត្រូវបានបញ្ជូនទៅកន្លែងផ្សេង[2756]។ ការស្តាប់ចម្លើយរបស់ ក.ស.ច.ស. បានបញ្ចប់ភ្លាមៗយ៉ាងសោះកក្រោះ ហើយ ខឹម យ៉ាត មិនត្រូវបានគេចោទសួរបន្ថែមទៀត អំពីអ្វីដែលគាត់បានឃើញ ឬ ថាតើហេតុអ្វីបានជាគាត់ស្មានថាបុគ្គលិកយោធាផ្សេងទៀតត្រូវបានបញ្ជូនទៅកន្លែងផ្សេងទៀតនោះទេ[2757]។ គាត់បានចង្អុលបង្ហាញនៅចុងបញ្ចប់នៃកិច្ចសម្ភាសន៍របស់គាត់ថា គាត់មានការពិបាកក្នុងការចងចាំព្រឹត្តិការណ៍ និង បានយល់ព្រមផ្តល់ចម្លើយបន្ថែមទៀត[2758]។ ខឹម យ៉ាត មិនដែលត្រូវស្តាប់ចម្លើយឡើងវិញទេ។

៧២១. **ណុប ផន៖** ណុប ផន មិនអាចជឿជាក់បានឡើយ។ គាត់បានប៉ាន់ស្មានថា "មានទាហានប្រហែលជា ៦០ ទៅ ១០០ នាក់ នៅក្នុងកងអនុសេនាធំរបស់ខ្ញុំ ដែលត្រូវបានគេរំសាយ" និង បញ្ជូនទៅកងកែងដើម្បីធ្វើស្រែ[2759]។ ណុប ផន មិនត្រូវបានគេសួរថាតើគាត់បានតួលេខនេះដោយរបៀបណាទេ។ បើទោះបីជាការប៉ាន់ស្មានរបស់គាត់ត្រឹមត្រូវក៏ដោយ ក៏វាមិនគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការ

[2755] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ផ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D114/121 ឆ.២៥។

[2756] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/97 ឆ.៥១។ ជើងទំព័រ ២៧២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2757] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/97 EN 01074516 KH 00988698៖ "យោបល់អ្នកស៊ើបអង្កេត៖ ជាអកុសល យើងត្រូវផ្អាកបទសម្ភាសន៍ត្រឹមនេះសិន ដោយសារពេលល្ងាចណាស់ ហើយក្រុមការងារត្រូវវិលត្រឡប់ទៅភ្នំពេញវិញ។ សាក្សីបានបង្ហាញពីទឹកចិត្តរបស់គាត់ ហើយព្រៀមព្រៀងផ្តល់បទសម្ភាសន៍បន្តទៀតនៅទីក្រុងភ្នំពេញ"។

[2758] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/97 ឆ.៤២។

[2759] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ផន ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/135 ឆ.១៩។ ជើងទំព័រ ២៧២៤ នៃដីកាសន្និដ្ឋានស្តាពរ។

អះអាងរបស់ ស.ព.អ. ដែលថា មានពេលមួយនោះ កម្មករវាប់ពាន់នាក់បានធ្វើការនៅការដ្ឋានតំបន់រាមនោះដែរ[2760]។

៧២២. **ប្រាក់ សុខា៖** ស.ព.អ. បកស្រាយភ័ស្តុតាងរបស់ ប្រាក់ សុខា ខុស។ ស.ព.អ. ដកស្រង់សម្តីប្រាក់ សុខា ដែលថា មានមនុស្សចំនួនប្រមាណ ៦៥០ នាក់ នៅក្នុងកងចល័តរបស់គាត់នៅព្រែកចាក[2761]។ ប្រាក់ សុខា មិនបាននិយាយបែបនេះទេ។ គាត់បាននិយាយថា កងទ័ពទាំងអស់ក្នុងកងវរសេនាតូចចំនួនពីរត្រូវបានគេបញ្ជូនទៅទីនោះ ហើយបានរៀបរាប់អំពីរចនាសម្ព័ន្ធទូទៅនៃកងវរសេនាតូច ប៉ុន្តែមិនបានផ្តល់ចំនួន ឬ ការប៉ាន់ស្មានជាក់លាក់នោះទេ[2762]។ គាត់ក៏បាននិយាយផងដែរថា ចំនួនមនុស្សនៅក្នុងកងរបស់គាត់មានការផ្លាស់ប្តូរ[2763]។

៧២៣. **ហ៊ឹង អ៊ុច៖** ហ៊ឹង អ៊ុច មិនអាចជឿជាក់បានឡើយ[2764]។ គាត់បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា កងទាំងមូលរបស់គាត់ត្រូវបានបញ្ជូនទៅវាលយន្តហោះកងកេង ដើម្បីធ្វើស្រែ[2765]។ ក្រោយមក គាត់បានប្រាប់ ក.ស.ច.ស. ថា គាត់មិនបានដឹងអំពីការបោសសំអាតកម្មាភិបាលណាម្នាក់ទេ៖ “ខ្ញុំគ្រាន់តែជាយុទ្ធជនម្នាក់ប៉ុណ្ណោះ។ ខ្ញុំមិនដឹងឡើយ នៅពេលដែលនរណាម្នាក់ត្រូវបានដកចេញ ឬបញ្ជូលទៅក្នុងមុខដំណែងណាមួយ...។ ខ្ញុំមិនបានយកចិត្តទុកដាក់ទៅលើមនុស្សដែលត្រូវបានផ្ទេរចេញទាំងអស់នោះទេ។ ខ្ញុំខំតែយកចិត្តទុកដាក់នឹងការងាររបស់ខ្ញុំទេ”[2766]។

៧២៤. **សយ ប៊ិន៖** សយ ប៊ិន មិនអាចជឿជាក់បានឡើយ[2767]។ ដោយទទួលស្គាល់ថា គាត់មិនអាចកំណត់ចំនួនពិតប្រាកដនៃកម្មករនៅឡតដ្ឋនៅជិតព្រលានយន្តហោះកេងកងនោះទេ គាត់បានប៉ាន់ស្មានថា

[2760] កថាខណ្ឌ ៦៧៥ នៃដីកាសន្និដ្ឋានស្តាពរ។

[2761] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/36 ឧ.៤។ ជើងចំពីរ ២៧២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2762] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/36 ឧ.៤។

[2763] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D54/36 ឧ.៤។

[2764] *សូមមើល* កថាខណ្ឌ ២៨១ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2765] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០០៧ ឯកសារ D54/81.2 EN 01001396 KH 00984339។

[2766] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹង អ៊ុច ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៤ ឯកសារ D54/83 ឧ.៧។

[2767] *សូមមើល* កថាខណ្ឌ ៣១៣ និង ៤៣៧ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

មានកម្មករចំនួនជាង ១០០ នាក់ នៅទីនោះ[2768]។ គាត់គ្រាន់តែបានទៅទីនោះនៅចុងឆ្នាំ ១៩៧៥ ប៉ុណ្ណោះ[2769]។ ការប៉ាន់ប្រមាណរបស់គាត់ ទំនងជាផ្អែកលើអ្វីដែលគាត់បានឮពីមិត្តរបស់គាត់ដែលធ្វើការនៅទីនោះ[2770]។

៧២៥. **នួ សារឿន៖** នួ សារឿន មិនអាចជឿជាក់បានឡើយ[2771]។ គាត់បានប៉ាន់ស្មានថា មានកម្មកររាប់រយនាក់នៅគម្រោងទំនប់បិតត្រាំង "ដែលមើលទៅឃើញខ្មៅពាសពេញការដ្ឋាននោះ"[2772] ។ គាត់មិនបានធ្វើការនៅគម្រោងទំនប់បិតត្រាំងទេ ពីព្រោះគាត់ស្ថិតនៅក្នុងកងកុមារ[2773]។ គាត់បានប្រាប់ ក.ស.ច.ស. ថា អង្គភាពរបស់គាត់ជួនកាល បានកាត់ស្មៅនៅក្បែរគម្រោងទំនប់បិតត្រាំង[2774] ប៉ុន្តែមិនបាននិយាយថាតើគាត់នៅជិតកន្លែងនោះប៉ុណ្ណា ឬ ថាតើគាត់ធ្វើការនៅក្បែរនោះញឹកញាប់ប៉ុណ្ណានោះទេ។

៧២៦. **លុន សេង៖** លុន សេង មិនអាចជឿជាក់បានឡើយ[2775]។ គាត់បានប៉ាន់ស្មានថា ទាហានចំនួន ១៥០០ នាក់ មកពីភូមិភាគបូព៌ា ត្រូវបានគេរំសាយ ហើយត្រូវបានបញ្ជូនទៅ "កងផលិតធំ"[2776] នៅពុតទេ។ លុន សេង បានប្រាប់ ក.ស.ច.ស. ថា គាត់បានដឹងថា ទាហានចំនួន ១៥០០ នាក់ មកពីភូមិភាគបូព៌ា ត្រូវបានដាក់នៅក្នុង "កងផលិតធំ" ពីព្រោះ មាស មុត បានប្រកាសថា កម្មាភិបាល

[2768] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 អ.១៤។ ជើងទំព័រ ២៧២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2769] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 អ.១៤។

[2770] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/17 អ.១៤។

[2771] *សូមមើល* កថាខណ្ឌ ៦៥៥ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2772] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 អ.១៦។ ជើងទំព័រ ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2773] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 អ.១៣។

[2774] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 អ.១៤៖ "ពេលខ្លះយើងទៅកាត់ស្មៅនៅជិតការដ្ឋានទំនប់នោះ"។

[2775] *សូមមើល* កថាខណ្ឌ ១៩៤ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2776] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/43 អ.១៩។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/44 អ.៦, អ.១៩, អ.២២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/45 អ.១៣-១៦។ ជើងទំព័រ ២៦៨៦, ២៧២៤, ២៨២៥ នៃដីកាសន្និដ្ឋានស្តាពរ។

ភូមិភាគឫព័ត្រូវតែរំសាយ ដោយហេតុថាពួកគេជាសមាធាតុមិនល្អ[2777]។ ចម្លើយរបស់ សេង ស៊ីន ដែលជាប្រភពតែមួយគត់ ស.ព.អ. ដកស្រង់ ដើម្បីគាំទ្រការអះអាងរបស់គាត់អំពី "កងផលិតធំ" មិនស៊ីចង្វាក់គ្នាជាមួយរឿងរបស់ លុន សេង ទេ[2778]។ សេង ស៊ីន បានប្រាប់ ក.ស.ច.ស. ថា គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅកងផលិតនៅភូមិប្របុក មិនមែន ពុតទេ ទេ[2779]។

៧២៧. **អ៊ុក សុក៖** អ៊ុក សុក មិនអាចជឿជាក់បានឡើយ[2780]។ គាត់បានប្រាប់ ក.ស.ច.ស. ថា មានកុមារចំនួន ២០ នាក់ នៅក្នុងកងដែលបានចាត់ឱ្យគាត់ទៅនោះ[2781]។ អ៊ុក សុក បានផ្តល់ចម្លើយផ្ទុយគ្នាឱ្យ ក.ស.ច.ស. និង មជ្ឈមណ្ឌលឯកសារកម្ពុជា អំពីអ្នកដែលមើលការខុសត្រូវលើមន្ទីរពេទ្យកងពលធំលេខ ១៦៥[2782] តើមានក្មេងប៉ុន្មាននាក់នៅក្នុងកងរបស់គាត់ និង ចំនួនអាហារប៉ុន្មានដែលពួកគេបានទទួល[2783] ហើយថាតើមានមនុស្សបាត់ខ្លួនទេ ឬ ត្រូវបានគេចាប់ខ្លួនពីសហការណ៍របស់គាត់ឬយ៉ាងណា[2784]។ នាងបានទទួលស្គាល់ថា ខ្លួនមានបញ្ហានៃការចងចាំ[2785]។ បើទោះបីជាការរៀបរាប់របស់ អ៊ុក សុក អាចឱ្យជឿជាក់បានក៏ដោយ ក៏ ស.ព.អ. និយាយបំផ្លើសពីភ័ស្តុតាងរបស់គាត់។ ស្ត្រីចំនួន ១០ នាក់ផ្សេងទៀតត្រូវបានចាត់ឱ្យមើលថែកងកុមាររបស់ អ៊ុក សុក[2786]។ គាត់

[2777] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D54/44 អ.១៩, អ.២២។ ជើងទំព័រ ២៦៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2778] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 អ.១៦៦។ ជើងទំព័រ ២៦៨៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2779] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D114/89 អ.១៤០។

[2780] *សូមមើល* កថាខណ្ឌ ៤៣៨ *ខាងលើ* សម្រាប់ព័ត៌មានបន្ថែមពីសាក្សីរូបនេះ។

[2781] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៥៦។ ជើងទំព័រ ២៧២៤ នៃដីកាសន្និដ្ឋានស្តាពរ។

[2782] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៨៣-៨៩។

[2783] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.១០២-០៣, អ.១១០-១៧។

[2784] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.១៤៧-៥២។

[2785] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.១៥០-៥១។

[2786] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ D114/53 អ.៥៥។

បានប្រាប់ ក.ស.ច.ស. ថា ការងាររបស់កុមារមិនលំបាកទេ ហើយថា ក្មេងៗមួយចំនួនបានទៅសាលារៀន[2787]។

៧២៨. បន្ថែមពីលើការប៉ាន់ស្មានបំផ្លើសទាំងនេះ ស.ព.អ. ក៏ដកស្រង់ផងដែរសម្តីរបស់ ប៉ាក សុខ សំ សោម ជេត ប៊ុណ្ណា និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ណុប សុម៉ាលី និង យិន តេង ដែលនិយាយថា ពួកគេបានចូលរួមក្នុងការងារបង្កបង្កើនផល ឬ ការសាងសង់ទំនប់នៅរាម[2788]។ សាក្សីទាំងនេះមិនបានផ្តល់នូវការប៉ាន់ស្មាន អំពីចំនួនកម្មករនៅក្នុងតំបន់ដែលពួកគេធ្វើការនោះទេ។ ការណ៍ដែលសាក្សីទាំងនេះបានធ្វើការនៅការដ្ឋានតំបន់រាម បន្ថែមលើអ្វីដែលបានលើកឡើងដោយសាក្សីខាងលើ មិនគាំទ្រការអះអាងរបស់ ស.ព.អ. នោះទេ។

៧២៩. បើទោះបីជាទាហាន និង ជនស៊ីវិលចំនួន ១៧០០០ នាក់ បានដាំដុះដំណាំ ដូចដែលបានរាយការណ៍ទៅ សុន សេន នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ មែនក៏ដោយ[2789] ក៏រឿងនេះមិនអាចដំឡើងឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឬ អ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។ ការដ្ឋានស្រដៀងគ្នា កើតមាននៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ កន្លែងខ្លះមានកម្មកររាប់ពាន់នាក់[2790]។ នៅក្នុងរឿងក្តី ០០១ បណ្ឌិត Etcheson បានផ្តល់សក្ខីកម្មថា នៅឆ្នាំ ១៩៧៥ "គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចថា ប្រជាជនចំនួនជាងកន្លះលាន គួរតែត្រូវបញ្ជូនទៅភូមិភាគ

[2787] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៥ឯកសារ D114/53 ឯ.៥៣, ឯ.៥៥។

[2788] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ឯកសារ D114/297.1.20 នៅម៉ោង 10.48.52-10.51.34។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ចុះថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៥ ឯកសារ D114/6 ឯ.៨៧-៨៩, ឯ.១៥៨។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៥ឯកសារ D114/58 ឯ.៤៨។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ណាប់ សុម៉ាលី ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៣ ឯកសារ D11/388 EN 01073730 KH 00991883-00991884។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៥ឯកសារ D114/65 ឯ.១៦។ ជើងទំព័រ ២៧២៩, ២៧៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2789] កំណត់ហេតុនៃការប្រជុំយោធា ចំណងជើងថា "កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភារបស់កងពល និង វរសេនាធំ" ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ ឯកសារ D1.3.27.18 EN 00195341 KH 00052391។ ជើងទំព័រ ២៧២៧, ២៧២៩ នៃដីកាសន្និដ្ឋានស្តាពរ។

[2790] *សូមមើល* កថាខណ្ឌ ៣៨០ នៃសាលក្រមក្នុងរឿងក្តី ០០២/០១។ កថាខណ្ឌ ២២៤ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

ពាយ័ព្យ ហើយឱ្យធ្វើការនៅក្នុងសហករណ៍កសិកម្ម...”[2791]។ ការណ៍ដែលការដ្ឋាន និង សហករណ៍អាចមាននៅក្នុងតំបន់នៅក្រោមការគ្រប់គ្រងរបស់ មាស មុត មិនដំឡើងឱ្យ មាស មុត ស្ថិតនៅក្នុងប្រភេទជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” នោះទេ។

ង. វាលពិឃាតដែលត្រូវបានចោទប្រកាន់

៧៣០. ប្រភពទាំងឡាយដែល ស.ព.អ. ដកស្រង់ គឺមិនគ្រប់គ្រាន់ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថាចម្ការធ្លូវនចំនួនពីរគឺ ចម្ការធ្លូវនចេងហោង (ចម្ការធ្លូវនទីមួយ) និង ចម្ការធ្លូវនអូរត្រាវ (ចម្ការធ្លូវនទីពីរ) និង អតីតមូលដ្ឋានឈរជើងរបស់ លន់ នល់ ដែលគេស្គាល់ថាជា *មណ្ឌលណាន់* ត្រូវបានប្រើជាវាលពិឃាតនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2792]។ ស.ព.អ. ដកស្រង់ជាចម្បងការរៀបរាប់តាមបែបទាយស្នានរបស់សាក្សី ដែលបានទៅពិនិត្យទីតាំងទាំងនោះក្រោយឆ្នាំ ១៩៧៩ និង បានឃើញឆ្អឹងនៅទីនោះ។ គ្មានសាក្សីណាមួយក្នុងចំណោមសាក្សីទាំងនេះ បានឃើញការកាប់សម្លាប់នៅកន្លែងទាំងនេះនៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ ម្នាក់ៗ បានប៉ាន់ស្មានថា ផ្នូរ រួមដែលពួកគេបានឃើញ គឺជាវាលពិឃាត ដោយសារឆ្អឹងដែលពួកគេបានឃើញនៅទីនោះក្រោយឆ្នាំ ១៩៧៩។

៧៣១. **ចម្ការធ្លូវនចេងហោង (ចម្ការធ្លូវនទី១)៖** ស.ព.អ. ដកស្រង់ជាចម្បងចម្លើយទាយស្នានរបស់ ទូ សារឿន និង ឡាក់ សាផាន ដែលបានឃើញឆ្អឹងនៅចម្ការធ្លូវនចេងហោងក្រោយឆ្នាំ ១៩៧៩[2793] និង ភ័ស្តុតាងពាក្យចចាមអារ៉ាមរបស់ ប៉ាក សុខ[2794] ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា

[2791] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៩ ឯកសារ E3/55 នៅម៉ោង 15.59.38-16.03.40។

[2792] កថាខណ្ឌ ៦៥៨-៦១ នៃដីកាសន្និដ្ឋានស្តាពរ។

[2793] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 ន.៤, ន.៤៦។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/123 ន.២-៣, ន.១២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ D54/90 ន.២០។ ជើងទំព័រ ២៩២៩-៣១, ២៩៣៣-៣៧ នៃដីកាសន្និដ្ឋានស្តាពរ។

[2794] *រឿងក្តី ន្ជន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.43.36-10.46.23៖ “ខ្ញុំបានសាកសួរដោយស្មោះត្រង់ ដែលយោធានោះឃើញថាគឺសម្លាប់ពិតប្រាកដមែន”។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/26 ន.១៦។ ជើងទំព័រ ២៩៣៨-៣៩ នៃដីកាសន្និដ្ឋានស្តាពរ។

ចម្ការធូរេនចេងហោងត្រូវបានប្រើជាវាលពិឃាត[2795]។ នូ សារឿន មិនបានឃើញការកាប់សម្លាប់ណាមួយនៅចម្ការធូរេនចេងហោងក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។ គាត់បានឮការសម្លាប់ដែលបានកើតឡើងនៅទីនោះពីប្រធានអង្គភាពរបស់គាត់[2796]។ ឡាក់ សាផាន បានទាយស្មានថា ចម្ការធូរេនចេងហោង គឺជាវាលពិឃាតដោយសារមានពាក្យចចាមអារ៉ាមនៅក្នុងភូមិរបស់គាត់ថា គេបានយកមនុស្សទៅសម្លាប់ចោលនៅទីនោះ[2797]។ គាត់បានប្រាប់ ក.ស.ច.ស. ថា គាត់បានគិតថា ឆ្អឹងទាំងអស់បានបាត់អស់ហើយ ដោយសារតែទីតាំងនេះត្រូវបានគេសំអាតសម្រាប់យកធ្វើកសិកម្ម ហើយថា វានឹងមានការលំបាកក្នុងការស្វែងរកឆ្អឹងទាំងនោះ[2798]។ ប៉ាក សុខ បានឮពីទាហានផ្សេងទៀតថា ការកាប់សម្លាប់ត្រូវបានធ្វើឡើងនៅចម្ការធូរេនចេងហោង[2799]។

៧៣២. **ចម្ការធូរេនអូរត្រាវ (ចម្ការធូរេនទីពីរ)៖** ស.ព.អ. ដកស្រង់ជាចម្បងនូវចម្លើយប៉ាន់ស្មានពី កុយ ណែន ឡាក់ សាផាន និង ប៉ាក សុខ ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា ចម្ការធូរេនអូរត្រាវត្រូវបានប្រើជាវាលពិឃាត[2800]។ កុយ ណែន បានមកមើលចម្ការធូរេនអូរត្រាវដំបូងនៅក្រោយឆ្នាំ ១៩៧៩ ហើយបានឃើញឆ្អឹងនៅទីនោះ[2801]។ គាត់មិនដែលបានឃើញការកាប់សម្លាប់នៅទីនោះទេ ប៉ុន្តែបានឮថា វាជាកន្លែងកាប់សម្លាប់ ពីភរិយារបស់ទាហានកម្ពុជាប្រជាធិបតេយ្យ[2802]។ ឡាក់ សាផាន បានទៅមើលចម្ការធូរេនអូរត្រាវដំបូងនៅឆ្នាំ ១៩៧៩[2803]។ គាត់បានប៉ាន់ស្មានថា វា

[2795] កថាខណ្ឌ ៧១៦ នៃដីកាសន្និដ្ឋានស្តាពរ។

[2796] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ សារឿន ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ ឯកសារ D54/18 ឧ.៣៩, ឧ.៤៣-៤៤។ ជើងចំពរ ២៩៣០-៣១ នៃដីកាសន្និដ្ឋានស្តាពរ។

[2797] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ឯកសារ D54/123 ឧ.៩៖ "រឿងបែបនេះមិនអាចលាក់បានទេ គឺមនុស្សនិយាយពីមាត់មួយទៅមាត់មួយ តៗគ្នា។ វាកាន់តែបញ្ចាក់ឱ្យកាន់តែច្បាស់ ក្រោយពេលខ្ញុំវិលត្រឡប់មកវិញ ថាមានការសម្លាប់នៅទីនោះមែន ដោយសារខ្ញុំបានទៅ និង ឃើញឆ្អឹង ព្រមទាំងលលាដ៍ក្បាលនៅទីនោះ"។

[2798] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ឯកសារ D54/123 ឧ.១៦។

[2799] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D114/297.1.20 នៅម៉ោង 10.43.36-10.46.23។

[2800] ជើងចំពរ ២៩៧៦, ២៩៤០-៥០, ២៩៥៥-៦២ នៃដីកាសន្និដ្ឋានស្តាពរ។

[2801] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/90 ឧ.២០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 ឧ.១។

[2802] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/90 ឧ.២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 ឧ.២, ឧ.៣។

[2803] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/2 ឧ.៤។

ជាវាលពិឃាត ដោយសារគាត់បានឮពីប្រជាជននៅក្នុងតំបន់របស់គាត់ ជឿជាក់ថា វាជាកន្លែងបែបនោះមែន[2804]។

៧៣៣. ***មជ្ឈមណ្ឌលណែនាំ៖*** ស.ព.អ. ដកស្រង់ជាចម្បងចម្លើយទាយស្មានរបស់ ប៉ាក សុខ សៅ មែន និង កុយ ណែន ដើម្បីគាំទ្រការអះអាងរបស់គាត់ដែលថា អតីតបន្ទាយ លន់ នល់ ដែលត្រូវបានគេស្គាល់ថាជា *មជ្ឈមណ្ឌលណែនាំ*[2805] ត្រូវបានប្រើជាវាលពិឃាតនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2806]។ សាក្សីទាំងនេះមិនបានដឹងផ្តាល់អំពីអ្វីដែលបានកើតឡើងនៅ *មជ្ឈមណ្ឌលណែនាំ* នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ[2807]។ បន្ថែមពីលើការរៀបរាប់បែបប៉ាន់ស្មាននេះ ស.ព.អ. ដកស្រង់ ស្ងួន ណុច កុយ ណែន និង មុំ ម៉េង ដែលបានឃើញឆ្អឹងដែលនៅសល់នៅទីនោះក្រោយឆ្នាំ ១៩៧៩[2808]។ ទីតាំងទាំងពីរនេះដែល មុំ ម៉េង កំណត់អត្តសញ្ញាណជូន ក.ស.ច.ស. បានផ្តាស់ប្តូរច្រើន។ ទីតាំងមួយត្រូវបានឈូសឆាយដើម្បីយកធ្វើជាចម្ការ ចំណែកទីតាំងមួយទៀត

[2804] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/2 ឆ.១០៖ "ពួកប្រជាជនមូលដ្ឋាននៅកន្លែងនេះ គេដឹងទាំងអស់គ្នាថា កន្លែងសម្លាប់មនុស្សមានពីរកន្លែង គឺមួយកន្លែងនៅចម្ការធូរេន អ៊ីង ក្រពុំផ្ការ និង មួយកន្លែងទៀតនៅចម្ការធូរេននៅទឹកសាប"។

[2805] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D114/2 ស-ឆ.១២៖ "ស៖ តើលោកធ្លាប់ឮកន្លែងសេអ៊ី [*មណ្ឌលកែប្រែ*] ដែរឬទេ? ឆ.១២៖បាទ ខ្ញុំស្គាល់កន្លែងសេអ៊ី គឺជាអតីតបន្ទាយទាហាន លន់ នល់"។

[2806] កថាខណ្ឌ ៦៦១ ជើងទំព័រ ២៩៦៥-៦៦, ២៩៦៨-៧២ នៃដីកាសន្និដ្ឋានស្តាពរ។

[2807] *រឿងក្តី ខ្លួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ឯកសារ D114/297.1.20 នៅម៉ោង 10.48.52 ("យោធានោះក៏បាននិយាយប្រាប់ខ្ញុំច្បាស់លាស់ហើយថា ប្រជាជន ១៧ មេសា នោះ ...យកទៅដាំចោលនៅលើចំណោតសេអ៊ីអស់ហើយ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០១៣ ឯកសារ D54/26 ឆ.២៩ ("យោងតាមយោធាដែលបានប្រាប់ខ្ញុំ គឺមានមនុស្សប្រហែលបីឡានទ្រុង ដែលត្រូវបានយកទៅសម្លាប់នៅទីនោះ")។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ម៉ែន ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០១៦ ឯកសារ D114/239 ឆ.២០ ("គេថាយកទៅសេអ៊ីហ្នឹង") ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/89 ឆ.៩ ("នៅពេលនោះ អ្នកភូមិទាំងអស់ដឹងតាមគ្នាថា នៅពេលដែលមនុស្សត្រូវបានចាប់ខ្លួនពីសហករណ៍ភូមិពូធ្មៀង គេនឹងយកទៅសម្លាប់នៅកន្លែងសេអ៊ី។ ប៉ុន្តែប្រសិនបើគេចាប់មនុស្សពីសហករណ៍ភូមិបបុស គឺនឹងយកទៅសម្លាប់នៅទឹកសាប")។

[2808] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្ងួន ឈុំ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D114/179 ឆ.៦០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០១៤ ឯកសារ D54/91 ឆ.១៧។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ម៉េង ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៤ឯកសារ D114/4 ឆ.១៦-១៩, ឆ.២១, ឆ.២៤។ ជើងទំព័រ ២៩៧៣-៧៨ នៃដីកាសន្និដ្ឋានស្តាពរ។

រងប៉ះពាល់ដោយសារការសាងសង់ផ្លូវ និង មានស្មៅខ្ពស់ៗដុះជុំជិត ធ្វើឱ្យយើង "ពិបាកមើលដីកំណត់ថាជាផ្នូររួម" ណាស់[2809]។

៣. សេចក្តីសន្និដ្ឋាន

៧៣៤. ស.ព.អ. ខកខានមិនបានបង្ហាញមូលដ្ឋានគាំទ្រការអះអាងរបស់គាត់ដែលថា មនុស្សជាងមួយពាន់នាក់ត្រូវបានចាប់ខ្លួន និង សម្លាប់ដោយកងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សរាប់ពាន់នាក់ត្រូវបានឃុំខ្លួន និង សម្លាប់ចោលនៅក្នុងមន្ទីរសន្តិសុខក្នុងតំបន់ស្វយ័តកំពង់សោម ហើយយ៉ាងហោចណាស់ កងទ័ព និង ជនស៊ីវិលចំនួន ១០០០០ នាក់ត្រូវបានគេធ្វើឱ្យទៅជាទាសកររនៅតាមការដ្ឋាន និង សហករណ៍នៅស្ទឹងហាវ និង រាម[2810]។ យ៉ាងច្រើនបំផុត ភ័ស្តុតាង គឺមិនគ្រប់ជ្រុងជ្រោយ។ នៅកន្លែងដែលសាក្សីបង្ហាញនូវលំដាប់តួលេខ ការគណនាតាមបែបសាមញ្ញត្រូវធ្វើឡើង ដោយប្រើប្រាស់ការប៉ាន់ស្មានទាបបំផុតដោយសាក្សី[2811]។ បើទោះបីជាចំនួនដែលត្រូវបានអះអាងដោយ ស.ព.អ. ត្រូវបានបង្ហាញដោយភស្តុតាងក៏ដោយ ក៏តួលេខទាំងនេះត្រូវបានគេពិចារណាប្រៀបធៀបនឹងការឈឺចាប់រួម ដែលបណ្តាលមកពីគោលនយោបាយ ប.ក.ក.។

៧៣៥. នៅពេលប្រៀបធៀបទៅនឹងចំនួនសរុបនៃការស្លាប់ពីការសម្លាប់ ការផ្តាស់ទីលំនៅ ការអត់ឃ្លាន ការបង្ខំឱ្យធ្វើការ ការដាក់ពន្ធនាគារ និង សេវាសុខភាពសាធារណៈមិនគ្រប់គ្រាន់ ចំនួនជនរងគ្រោះដែល ស.ព.អ. អះអាង គឺមានចំនួនតិចតួច។ សម្រាប់គោលបំណងប្រៀបធៀប នៅក្នុងរឿងក្តី ០០៤/១ ស.ច.ស. បានរកឃើញថា ការទទួលយកកម្រិតអប្បបរមាដោយប្រុងប្រយ័ត្នបំផុត ដែល អ៊ឹម ចែម ទទួលខុសត្រូវចំពោះជនរងគ្រោះនៃអំពើមនុស្សឃាតចំនួនពី ២០០០ ដល់ ១០៨០០ នាក់ ជនរងគ្រោះនៃអំពើដាក់ក្នុងមន្ទីរឃុំឃាំងចំនួនរាប់រយនាក់ និង អាចរាប់ពាន់នាក់ ព្រមទាំងជនរងគ្រោះនៃអំពើដាក់ឱ្យទៅជាទាសករចំនួនពីរាប់ពាន់នាក់ ទៅរាប់ម៉ឺននាក់[2812]។ ការរកឃើញនេះមិនបានដំឡើង អ៊ឹម ចែម ទៅដល់កម្រិត "ថ្នាក់ដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ "ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។ ចំនួនជនរងគ្រោះដែលអះអាងដោយ ស.ព.អ. នៅក្នុងរឿងក្តី ០០៣ ក៏មិនធ្វើ

[2809] របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៣ ឯកសារ D54/22 EN 00947624 KH 01002681។

[2810] កថាខណ្ឌ ១០៩១ នៃដីកាសន្និដ្ឋានស្តាពរ។

[2811] *សូមមើល* កថាខណ្ឌ ២១៨ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[2812] កថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

ឱ្យ មាស មុត ក្លាយជា "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះដែរ។

V. សេចក្តីសន្និដ្ឋាន

៧៣៦. ស.ច.ស. គួរផ្អាកកិច្ចដំណើរការនីតិវិធីទាំងស្រុងជាអចិន្ត្រៃយ៍ នៅពេលពិចារណាលើភាវនីយភាពខ្ពស់ដែលថា នឹងមិនមានថវិកាគ្រប់គ្រាន់ សម្រាប់ការពិនិត្យមើលបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ការជំនុំជម្រះក្តីក្នុងសវនាការ និង ការប្តឹងសាទុក្ខ ហើយ មាស មុត នឹងមិនមានយន្តការនីតិវិធីសម្រាប់តវ៉ាបទចោទប្រឆាំងនឹងគាត់ ប្រសិនបើកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក. នឹងបញ្ចប់ដោយគ្រាន់តែខ្វះថវិកានោះ។

៧៣៧. ជាជម្រើសម្យ៉ាងទៀត ស.ច.ស. គួរតែចេញដីកាលើកលែងការចោទប្រកាន់។

៧៣៨. មាស មុត មិនស្ថិតនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក. នោះទេ ព្រោះគាត់មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះដែរ។ គាត់មិនមានឋានៈខ្ពស់គ្រប់គ្រាន់នៅក្នុងឋានានុក្រម ប.ក.ក. រហូតដល់មានសិទ្ធិអំណាច ឬ ឆន្ទានុសិទ្ធិសម្រេចកំណត់គោលនយោបាយ ឬ ការអនុវត្តគោលនយោបាយនោះឡើយ។ គាត់បានប្រតិបត្តិការនៅក្នុងតំបន់ភូមិសាស្ត្រដែលមានកម្រិត។

៧៣៩.ស.ព.អ. សន្និដ្ឋានបំផ្លើសនៅក្នុងការអះអាងរបស់ខ្លួន ដោយសំអាងលើភ័ស្តុតាងដែលមានការសង្ស័យពោលគឺ៖ **ក.** សាក្សីដែលចម្លើយរបស់ពួកគេបានផ្អែកលើពាក្យចចាមអារ៉ាម ឬ ការប៉ាន់ស្មាន ឬ ដែលបានមកពីការធ្វើទារុណកម្ម **ខ.** សាក្សីដែលចម្លើយរបស់ពួកគេ មិនគាំទ្រការអះអាងរបស់គាត់ **គ.** ភ័ស្តុតាងឯកសារដែលមិនអាចជឿជាក់បាន មានតម្លៃជាភ័ស្តុតាងតិចតួច ឬ មិនគាំទ្រការអះអាងរបស់គាត់ និង **ឃ.** ភ័ស្តុតាងដែលទទួលបានតាមរយៈការប្រើប្រាស់ដែលមិនទទួលបានការអនុញ្ញាតនូវភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។ គាត់បកស្រាយភ័ស្តុតាងមិនត្រឹមត្រូវ និង មិនអើពើនឹងភ័ស្តុតាងបរិបទ និង រចនាសម្ព័ន្ធ ដែលធ្វើឱ្យការអះអាងរបស់គាត់មិនរឹងមាំ ឬ ដែលផ្ទុយពីការអះអាងរបស់គាត់ និង ពឹងផ្អែកយ៉ាងខ្លាំងលើសាក្សីដែលមិនអាចជឿជាក់បានដដែលៗ ក្នុងការបង្ហាញពីតួនាទី សិទ្ធិអំណាច និង ការពាក់ព័ន្ធរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មដែលចោទប្រកាន់។

៧៤០. អង្គជំនុំជម្រះសាលាដំបូង ដែលមានហេតុផលត្រឹមត្រូវ នឹងមិនអាចរកឃើញឱ្យហួសពីវិមតិសង្ស័យថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ឡើយ ផ្អែកតាមភស្តុតាងដែលមានក្នុងសំណុំរឿងនោះ សូម្បីតែនៅពេលដែលពិនិត្យមើលក្នុងក្របខ័ណ្ឌជាប្រយោជន៍ដល់ ស.ព.អ. ក៏ដោយ។ នៅពេលពិនិត្យមើលជាមួយនឹងស្ថានភាពនៃការឈឺចាប់ជារួមដែលបណ្តាលមកពីគោលនយោបាយ ប.ក.ក. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌណាមួយដែលអាចធ្លាក់លើ មាស មុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងដែនទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នៅកំពង់សោម ឬក្នុងតំបន់ ៥០៥ មិនបានធ្វើឱ្យគាត់ក្លាយជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះឡើយ។

សូមណែនាំសហចៅក្រមស៊ើបអង្កេតមេត្តាទទួលយកចម្លើយនេះដោយក្តីគោរពអំពីយើងខ្ញុំ។

ធ្វើរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨

សហមេធាវីការពារក្តី មាស មុត

អាង ឧត្តម	Michael G. KARNAVAS